ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារលេខ D359/24 និង D360/33

*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/កសចស (អបជ៦០)

**<u>អង្គបុរេជំនុំជម្រះ</u>**

| | |
|---|---|
| ចំពោះមុខ: | **ចៅក្រម ប្រាក់ គីមសាន** **ជាប្រធាន** |
| | **ចៅក្រម** Olivier BEAUVALLET |
| | **ចៅក្រម ន៉ីយ ថុល** |
| | **ចៅក្រម** Kang Jin BAIK |
| | **ចៅក្រម ហួត វុទ្ធី** |
| កាលបរិច្ឆេទ: | **ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩** |
| ភាសាដើម: | **ខ្មែរ/អង់គ្លេស/បារាំង** |
| ចំណាត់ថ្នាក់: | **សាធារណៈ** |

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 19 / 12 / 2019
ម៉ោង (Time/Heure): 12:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

# សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ

**<u>សហព្រះរាជអាជ្ញា:</u>**

ជា លាង
Brenda HOLLIS

**<u>សហមេធាវីការពារក្តី អោ អាន:</u>**

មុំ លុជ្ស
Richard ROGERS
Göran SLUITER

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី</u>**

ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉ែន ពៅ
Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Daniel MCLAUGHLIN
Lyma NGUYEN
Nushin SARKARATI

# មាតិកា

I. ប្រវត្តិនីតិវិធី ........ 2

II. ការបញ្ចូលគ្នា ........ 10

III. បទដ្ឋាននៃការពិនិត្យឡើងវិញ ........ 11

IV. បញ្ហាបឋម ........ 13

ក. អំណាចរបស់ អង្គបុរេជំនុំជម្រះ លើដំណាក់កាលនៃការស៊ើបអង្កេត ........ 13

១. តួនាទីរបស់អង្គបុរេជំនុំជម្រះជាស្ថាប័នស៊ើបសួរទីពីរ និង សិទ្ធិអំណាចចុងក្រោយនៅដំណាក់កាលស៊ើបសួរ ........ 18

២. សិទ្ធិអំណាចក្នុងការត្រួតពិនិត្យមើលរបស់អង្គបុរេជំនុំជម្រះជាស្ថាប័នស៊ើបសួរទីពីរ ........ 21

៣. វិសាលភាពនៃសិទ្ធិអំណាចក្នុងការត្រួតពិនិត្យរបស់អង្គបុរេជំនុំជម្រះនៅក្នុងរឿងក្តីបច្ចុប្បន្ននេះ ........ 24

ខ. ជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ........ 27

គ. ការពន្យាពេលហួសហេតុនៅក្នុងការចេញដីកាដំណោះស្រាយ ........ 30

ឃ. ការពិចារណាលើភស្តុតាង ........ 35

១. គោលការណ៍ស្តីពីសេរីភាពនៃភស្តុតាង ........ 36

២. បទដ្ឋាននៃភស្តុតាង ........ 41

ង. ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា ........ 43

១. ច្បាប់ជាធរមាន ........ 44

២. សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញដីកាដំណោះស្រាយដែលដាច់ពីគ្នា ........ 48

៣. ការពិភាក្សា ........ 52

ក. គោលការណ៍ជាសារវ័ន្តគ្រប់គ្រងលើការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ........ 53

ខ. ការដោះស្រាយការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ........ 56

គ. ការសន្និដ្ឋានទាក់ទងនឹងការចេញដីកាដំណោះស្រាយដែលដាច់ពីគ្នា ........ 61

V. ភាពអាចទទួលយកបាន ........ 65

ការទទួលយកជាផ្លូវការ ........ 65

01634755



**បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ**.....66

**បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ**.....66

**បណ្ដឹងឧទ្ធរណ៍របស់សហមេធាវីការពារក្ដី**.....67

១. សារណា.....67

២. ការពិភាក្សា.....69

ក. មូលដ្ឋានទទួលយកបណ្ដឹងឧទ្ធរណ៍.....78

មូលដ្ឋានទី១ ទទួលយកបាន.....79

មូលដ្ឋាន ២-៧ អាចទទួលយកបាន.....79

មូលដ្ឋានទី៨-៩, ១១, ១២(i) ១៥(i) គឺអាចទទួលយកបាន.....80

មូលដ្ឋានទី១៣ អាចទទួលយកបាន.....81

មូលដ្ឋានទី១៦(ii) និង (iii) អាចទទួលយកបាន.....81

ខ. មូលដ្ឋានបណ្ដឹងឧទ្ធរណ៍មិនអាចទទួលយកបាន.....82

មូលដ្ឋានទី១០ និង ១៧ មិនអាចទទួលយកបាន.....82

មូលដ្ឋាន១២(ii) ១៤ ១៥(ii) ១៦(i) មិនអាចទទួលយកបាន.....83

មូលដ្ឋានទី១៨ មិនអាចទទួលយកបាន.....85

VI. **ការពិចារណាលើអង្គសេចក្ដី**.....88

VII. **សេចក្ដីសម្រេច**.....89

VIII. **យោបល់លោកចៅក្រមប្រាក់ គឹមសាន លោកចៅក្រមន័យ ថុល និង លោកចៅក្រម ហួត វុទ្ធី**.....91

**ក. ប្រវត្តិនៃសំណុំរឿង០០៤**.....91

**ខ. បុព្វកថា**.....94

១. ក្នុងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ.....94

២. វិធានផ្ទៃក្នុង.....94

**គ. ប្រវត្តិនៃការនាំយកខ្មែរក្រហមមកកាត់ទោស**.....94

១. សង្គ្រាមត្រជាក់.....95

២. ការបង្កើតរដ្ឋាភិបាលចម្រុះ.....96

៣. នយោបាយអាមេរិកចំពោះខ្មែរក្រហម.....96

៤. ការចាប់ផ្តើមចរចារបង្កើតអ.វ.ត.ក និងការធ្វើសម្បទានទៅវិញទៅមក ....................96

៥. ឧបសគ្គរាំងរល់ការបង្កើតអ.វ.ត.ក ....................96

៦. ការដកខ្លួនរបស់អង្គការសហប្រជាជាតិ ....................97

៧. ការចូលរួមសារជាថ្មីរបស់អង្គកាសហប្រជាជាតិ ....................97

៨. ការធ្វើសម្បទានរបស់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ....................98

៩. ការជ្រើសរើសយកចំនួនជនត្រូវចោទមកកាត់ទោស ....................98

**ឃ. មេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត** ....................99

១. អំពីរចនាសម្ព័ន្ធរដ្ឋអំណាច នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ....................99

**ង. គោលបំណងនៃការបង្កើតអ.វ.ត.ក** ....................105

១. កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ ....................105

២. ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ....................106

៣. វិធានផ្ទៃក្នុង ....................106

៤. ការប្រជុំនៅរដ្ឋសភា ....................108

**ច. ដំណើរនៃសំណុំរឿង ០០៤** ....................111

១. ការស៊ើបអង្កេតបឋមដោយសហព្រះរាជអាជ្ញា ៖ ការចោទប្រកាន់ ....................111

២. ការអនុវត្តជាក់ស្តែងរបស់សហព្រះរាជអាជ្ញា ....................112

៤. ការខកខានពុំបានដាក់ក្រោមការពិនិត្យរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ....................122

៥. កំហុសប្រឆាំងនឹងមាត្រា១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ....................122

៦. ការអនុវត្តជាក់ស្តែងរបស់សហចៅក្រមស៊ើបអង្កេត ....................123

**ឆ. គោលការណ៍ច្បាប់** ....................130

១. ចន្លោះប្រហោងនៃច្បាប់ ....................130

២. គោលការណ៍នៃការបកស្រាយច្បាប់ ....................130

៣. គោលការណ៍នីត្យានុកូលភាព ....................131

៤. ភាពច្បាស់លាស់នៃច្បាប់ ....................131

៥. យុត្តិធម៌អូសបន្លាយ គឺអយុត្តិធម៌ ....................132

01634757



**សេចក្តីសន្និដ្ឋាន** ........ 132

IX. **យោបល់ចៅក្រមអន្តរជាតិ** ........ 135

**បណ្តឹងឧទ្ធរណ៍របស់អោ អាន ប្រឆាំងនឹងដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ)** ........ 135

**ក. មូលដ្ឋានទី១÷ ការចេញដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះ ជាមួយនឹងដីកាសម្រេចលើកលែងចោទប្រកាន់ដែលមានសុពលភាព** ........ 135

១. សារណា ........ 135

២. ការពិភាក្សា ........ 143

**ខ. មូលដ្ឋានទី ២÷ ការសន្និដ្ឋានពីឆន្ទានុសិទ្ធិដោយសេរី ដែលត្រូវបានចោទប្រកាន់** ........ 148

១. សារណា ........ 148

២. ការពិភាក្សា ........ 150

**គ. មូលដ្ឋានទី៣ ÷ កំហុសក្នុងការបកស្រាយពាក្យ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" នៅក្នុងលក្ខណៈទូលំទូលាយពេក** ........ 151

១. សារណា ........ 151

២. ការពិភាក្សា ........ 157

**ឃ. មូលដ្ឋានទី៤÷ ការអនុវត្តបទដ្ឋាននៃការបង្ហាញភស្តុតាងមិនត្រឹមត្រូវ** ........ 164

១. សារណា ........ 164

២. ការពិភាក្សា ........ 165

**ង. មូលដ្ឋានទី៥÷ ការពិចារណាលើភស្តុតាង - សេចក្តីផ្តើម** ........ 168

**មូលដ្ឋានទី ៥(i). ការចោទប្រកាន់ចំពោះការខកខានអនុវត្តសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/១** ........ 169

១. សារណា ........ 169

ខ. ការពិភាក្សា ........ 172

**មូលដ្ឋានទី ៥(ii). ការចោទប្រកាន់ថាមិនបានវាយតម្លៃទៅលើភាពអាចជឿជាក់បានរបស់សាក្សី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសំខាន់ៗ** ........ 174

បទដ្ឋាននៃការត្រួតពិនិត្យ ........ 175

**ក. ឃ្លាក់ យុត** ........ 177

01634758



១. សារណា ........ 177

២. ការពិភាក្សា ........ 181

**ខ. យូ ទ៉ាន់** ........ 187

១. សារណា ........ 187

២. ការពិភាក្សា ........ 189

**គ. ពៅ សារ៉ុម, ពុត គុល និង កែច ធឿន** ........ 191

១. សារណា ........ 191

២. ការពិភាក្សា ........ 192

**ឃ. ញ៉ែម ចេន** ........ 193

១. សារណា ........ 193

២. ការពិភាក្សា ........ 194

**ង. ជុំ ខៀវ (ខ៊ុំច)** ........ 197

១. សារណា ........ 197

២. ការពិភាក្សា ........ 198

**ច. ពេញ ទ៉ា និង ញ៉ឹម គុល** ........ 201

១. សារណា ........ 201

២. ការពិភាក្សា ........ 202

**មូលដ្ឋានទី ៥(iii). ការចោទប្រកាន់ថាសំអាងទៅលើភស្តុតាងដែលប្រឡូកប្រឡាក់** ........ 203

១. សារណា ........ 203

២. ការពិភាក្សា ........ 205

**មូលដ្ឋានទី៥(iv). ការចោទប្រកាន់ចំពោះកំហុសនៃការសំអាងទៅលើភស្តុតាងដែលពុំមានការបញ្ជាក់បន្ថែម** ........ 210

១. សារណា ........ 210

២. ការពិភាក្សា ........ 212

**មូលដ្ឋានទី៥(v). ការចោទប្រកាន់ចំពោះកំហុសនៃការសំអាងលើភស្តុតាងចចាមអារ៉ាម** ........ 215

01634759



១. សារណា ....215

២. ការពិភាក្សា....218

**មូលដ្ឋានទី៦÷ មុខដំណែងរបស់អោ អាន នៅក្នុង ប.ក.ក និងតួនាទីរបស់គាត់នៅក្នុងបទល្មើស-សេចក្តីផ្តើម** ....222

**មូលដ្ឋានទី៦**(i). **តួនាទីរបស់អោ អាន ក្នុងការកំណត់ ឬបកស្រាយគោលនយោបាយប.ក.ក**.224

១. សារណា និងការពិភាក្សា....224

**មូលដ្ឋានទី ៦**(ii). **តួនាទីរបស់ អោ អាន ក្នុងការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាធៀបទៅនឹងមន្ត្រីខ្មែរក្រហមផ្សេងទៀត** ....225

១. សារណា ....225

២. ការពិភាក្សា....226

**មូលដ្ឋានទី ៦**(iii). **តួនាទីរបស់ អោ អាន ក្នុងការរៀបចំផែនការ និងដឹកនាំការបោសសម្អាតកម្មាភិបាលភូមិភាគកណ្តាលដែលកំពុងកាន់តំណែង និងប្រជាជនស៊ីវិល**....228

១. សារណា ....228

២. ការពិភាក្សា....230

**មូលដ្ឋានទី៦**(iv). **តួនាទី និងសិទ្ធិអំណាចរបស់ អោ អាន នៅក្នុងភូមិភាគកណ្តាល**....233

១. សារណា ....233

២. ការពិភាក្សា....235

ក. អនុលេខាភូមិភាគកណ្តាល....235

ខ. លេខាភូមិភាគកណ្តាលស្តីទី ....241

**មូលដ្ឋានទី៦**(v). **មុខដំណែងរបស់ អោ អាន ជាលេខាតំបន់ ៤១** ....245

៦(v)(ក) មុខតំណែងរបស់ អោ អាន ក្នុងនាមជាលេខាតំបន់ ៤១ តាមផ្លូវច្បាប់....246

១. សារណា....246

២. ការពិភាក្សា ....247

៦(v)(ខ) សិទ្ធិអំណាចរបស់ អោ អាន នៅតំបន់ ៤១ ....249

៦(v)(ខ)(១) សិទ្ធិអំណាចក្នុងការទទួល អនុវត្ត ឬរាយការណ៍អំពីបញ្ហាទៅថ្នាក់ភូមិភាគ ....250

១. សារណា ....250

01634760



២. ការពិភាក្សា ........ 252

៦(v)(ខ)(២) សិទ្ធិអំណាចក្នុងការតែងតាំងកម្មាភិបាល ........ 254

១. សារណា ........ 254

២. ការពិភាក្សា ........ 255

៦(v)(ខ)(3) សិទ្ធិអំណាចក្នុងការដក ដាក់ជំនួស ឬដាក់ទណ្ឌកម្មកម្មាភិបាល ........ 257

១. សារណា ........ 257

២. ការពិភាក្សា ........ 258

៦(v)(ខ)(៤) សិទ្ធិអំណាចក្នុងការចេញបញ្ជា ឬអនុញ្ញាតឱ្យកម្មាភិបាលអនុវត្ត ........ 260

១. សារណា ........ 260

២. ការពិភាក្សា ........ 261

៦(v)(ខ)(៥) សិទ្ធិអំណាចក្នុងការទទួលរបាយការណ៍ពីកម្មាភិបាល ........ 265

១. សារណា ........ 265

២. ការពិភាក្សា ........ 267

៦(v)(ខ)(៦) សិទ្ធិអំណាចក្នុងការដឹកនាំកិច្ចប្រជុំថ្នាក់តំបន់ ........ 269

១. សារណា និងការពិភាក្សា ........ 269

៦(v)(គ) សិទ្ធិអំណាចលើបញ្ហាសន្តិសុខ និងមន្ទីរក្នុងតំបន់៤១ ........ 270

១.សារណា ........ 270

២. ការពិភាក្សា ........ 270

៦(v)(ឃ) សិទ្ធិអំណាចលើយោធាតំបន់៤១ ........ 273

១. សារណា ........ 273

២. ការពិភាក្សា ........ 274

៦(v)(ង) សិទ្ធិអំណាចលើភស្តុភារ និងចលនាប្រជាជនក្នុងតំបន់៤១ ........ 276

១. សារណា ........ 276

២. ការពិភាក្សា ........ 277

៦(v)(ច) ឥទ្ធិពលលើយុត្តាធិការបុគ្គល ........ 279

១.សារណា និងការពិភាក្សា ....................................................279

**មូលដ្ឋានទី៦(vi). តួនាទីរបស់អោ អាន ក្នុងអំពើប្រល័យពូជសាសន៍ជនជាតិចាម** ....................281

១. សារណា ....................................................281

២. ការពិភាក្សា ....................................................282

**មូលដ្ឋានទី៦(vii). តួនាទីរបស់ អោ អាន ក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ នៅស្រុកព្រៃឈរ និងស្រុកកំពង់សៀម** ....................288

១. សារណា ....................................................288

២. ការពិភាក្សា ....................................................289

**មូលដ្ឋានទី៦(viii)៖ តួនាទីរបស់ អោ អាន នៅក្នុងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅតាមទីតាំងឧក្រិដ្ឋកម្ម** ....................293

១. សារណា ....................................................293

២. ការពិភាក្សា ....................................................294

**ច. មូលដ្ឋានទី៧៖ សម្អាងហេតុដែលមានកំហុសឆ្គងដែលថាឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់មានស្ថានទម្ងន់ល្មមគ្រប់គ្រាន់** ....................294

១. សារណា ....................................................294

២. ការពិភាក្សា ....................................................297

**ឆ. មូលដ្ឋានទី៨៖ ការអនុវត្តច្បាប់ទំនៀមទំលាប់អន្តរជាតិ រំលោភទៅលើគោលការណ៍នីត្យានុកូលភាព** ....................303

១. សារណា ....................................................303

២. ការពិភាក្សា ....................................................306

**ជ. មូលដ្ឋានទី ៩៖ សហឧក្រិដ្ឋកម្មរួមពុំមែនជាទម្រង់នៃការទទួលខុសត្រូវមួយ ដែលអាចអនុវត្តបាននៅអ.វ.ត.ក នោះឡើយ** ....................311

១. សារណា ....................................................311

២. ការពិភាក្សា ....................................................312

**ឈ. មូលដ្ឋានទី១១៖ ការរៀបផែនការ មិនមែនជាទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តនៅអ.វ.ត.ក បានទេ** ....................317

១. សារណា ....................................................................................................................317

២. ការពិភាក្សា................................................................................................................318

**ញ. មូលដ្ឋានទី ១២(i)÷ ការទទួលខុសត្រូវរបស់ថ្នាក់លើពុំមែនជាទម្រង់នៃការទទួលខុសត្រូវជាឯកភាព នៅក្នុងសំណុំរឿង របស់ អោ អាន** ....................................................................................323

១. សារណា ....................................................................................................................323

២. ការពិភាក្សា................................................................................................................324

**ដ. មូលដ្ឋានទី១៣÷ ថាតើ អ.វ.ត.ក មានយុត្តាធិការក្នុងការជំនុំជម្រះបទល្មើសជាតិដែលបានប្រព្រឹត្តចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ឬទេ**....................................................................328

១.សារណា ....................................................................................................................328

២. ការពិភាក្សា................................................................................................................330

**ឋ. មូលដ្ឋានទី១៥(i)÷ អាពាហ៍ពិពាហ៍ដោយបង្ខំពុំស្ថិតនៅក្រោមយុត្តាធិការនៃ អ.វ.ត.ក**......332

១. សារណា ....................................................................................................................332

២. ការពិភាក្សា................................................................................................................333

**ឌ. មូលដ្ឋានទី១៦(ii) និង១៦(iii)÷ ការអនុវត្តដោយខុសឆ្គងនូវធាតុផ្សំ អំពើប្រល័យពូជសាសន៍** 338

១. សារណា ....................................................................................................................338

២. ការពិភាក្សា................................................................................................................341

**ឍ. សន្និដ្ឋានសម្រាប់បណ្តឹងឧទ្ធរណ៍របស់អោ អាន**..................................................................351

**បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជម្រះ)**
.....................................................................................................................................353

១. សារណា ....................................................................................................................353

២. ការពិភាក្សា................................................................................................................361

**បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (ឯកសារ** D359)....................................................................................................................364

១. សារណា ....................................................................................................................364

ក. មូលដ្ឋាន ក៖ កំហុសអង្គច្បាប់នៃការខកខានមិនបានធ្វើការសន្និដ្ឋាន..............................365

ខ. មូលដ្ឋាន ខ៖ កំហុសអង្គហេតុឬ កំហុសអង្គច្បាប់ ក្នុងការផ្តល់ទម្ងន់ហួសហេតុទៅលើការបង្ខិតបង្ខំ ការគាបសង្កត់ និងបញ្ជារបស់ថ្នាក់លើ ......367

គ. មូលដ្ឋាន គ៖ កំហុសអង្គច្បាប់នៃការសម្រេចថា ឌុច គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់ ......368

ឃ. មូលដ្ឋាន ឃ៖ កំហុសអង្គហេតុទាក់ទងទៅនឹងការវាយតម្លៃលើភាពអាចជឿជាក់បាននៃភស្តុតាង ......370

ង. មូលដ្ឋាន ង៖ ការសន្និដ្ឋានលើអង្គហេតុដោយខុសឆ្គង ដោយមានផលប៉ះពាល់ ដែលជាកត្តាសម្រេច ទៅលើបញ្ហាយុត្តាធិការបុគ្គល ......371

ច. មូលដ្ឋាន ច៖ កំហុសអង្គច្បាប់ដែលមិនបានពិចារណា អំពីផលប៉ះពាល់នៃតួនាទីជាអ្នកដឹកនាំរបស់ អោ អាន នៅក្នុងអំពើប្រល័យពូជសាសន៍ ......374

ឆ. សារណាពាក់ព័ន្ធនឹងដីកាដំណោះស្រាយដែលផ្ទុយគ្នា ......375

២. ការពិភាក្សា ......377

**សេចក្តីសន្និដ្ឋាន** ......378

**ការសម្រេចលើបណ្តឹងឧទ្ធរណ៍** ......378

**វិធាន ៧៧(១៣)(ខ)** ......379

**វិធានការសន្តិសុខ** ......380

**ផ្នែកសម្រេចសេចក្តី** ......382

**តារាងអក្សរកាត់**

| ពាក្យ | ពាក្យបំព្រួញ/អក្សរកាត់ |
|---|---|
| កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ | កិច្ចព្រមព្រៀង អ.វ.ត.ក |
| ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា | ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក |
| អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា | អ.វ.ត.ក |
| រាជរដ្ឋាភិបាលកម្ពុជា | RGC |
| តុលាការព្រហ្មទណ្ឌអន្តរជាតិ | តុលាការ ICC |
| តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេស យូហ្គោស្លាវី | តុលាការ ICTY |
| តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រវ៉ាន់ដា | តុលាការ ICTR |
| តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន | តុលាការ SCSL |
| តុលាការអន្តរជាតិ | តុលាការ ICJ |
| អង្គជំនុំជម្រះវិសាមញ្ញអាហ្វ្រិក | តុលាការ EAC |
| គណកម្មការច្បាប់អន្តរជាតិ | ILC |
| អនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា | អនុសញ្ញាទីក្រុងវីយែន |
| កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ | កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ |
| ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង, ការផ្តន្ទាទោសទៅលើបុគ្គលទាំងឡាយដែលមានពិរុទ្ធពីបទឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព និងប្រឆាំងនឹងមនុស្សជាតិ | ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង |
| ធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិ ឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងសម្រាប់ការកាត់សេចក្តី និងការផ្តន្ទាទោស | ធម្មនុញ្ញ នូរ៉ាំប៊ើក |

| | |
|---|---|
| ចំពោះឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗរបស់សម្ព័ន្ធមិត្តអឺរុប | |
| ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា | ធម្មនុញ្ញទីក្រុងតូក្យូ |
| តុលាការយោធាអន្តរជាតិ សាលក្រម ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៤៦ ការកាត់សេចក្ដីឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗនៅចំពោះមុខតុលាការយោធាអន្តរជាតិ | សាលក្រមនូរ៉ាំប៊ើក |
| អនុសញ្ញាស្ដីពីការទប់ស្កាត់ និងការផ្ដន្ទាទោសលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ | អនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍ |
| សហឧក្រិដ្ឋកម្មរួម | JCE |
| បក្សកុម្មុយនីស្តកម្ពុជា | ប.ក.ក |
| កងទ័ពបដិវត្តន៍កម្ពុជា | ក.ប.ក |
| មជ្ឈមណ្ឌលឯកសារកម្ពុជា | DC-Cam |

**អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** ("អ.វ.ត.ក") បានទទួលដោះស្រាយបណ្តឹងឧទ្ធរណ៍ចំនួនបីប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរដែលផ្ទុយគ្នា គឺ ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់)[1] របស់សហចៅក្រមស៊ើបអង្កេតជាតិ និងដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ)[2] របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ បណ្តឹងឧទ្ធរណ៍ទាំងបីនេះរួមមាន ៖

(១) បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ ("បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ")[3]។

(២) បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិលើដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (ឯកសារ D359) ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ("បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ")[4]។

(៣) បណ្តឹងឧទ្ធរណ៍របស់ អោ អាន លើដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ("បណ្តឹងឧទ្ធររបស់ អោ អាន")[5]។

---

[1] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៤/២") ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ដែលត្រូវបានជូនដំណឹងជាភាសាខ្មែរនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ និងជាភាសាអង់គ្លេសនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D359 ("ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D359)")។

[2] សំណុំរឿង ០០៤/២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ដែលត្រូវបានជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ និងជាភាសាខ្មែរនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ឯកសារ D360 ("ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ 360)")។

[3] សំណុំរឿង ០០៤/២ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ ដែលត្រូវបានជូនដំណឹងជាភាសាខ្មែរនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ និងជាភាសាអង់គ្លេសនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩ ឯកសារ D360/8/1 ("បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1)")។

[4] សំណុំរឿង ០០៤/២ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (ឯកសារ D359) ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ដែលត្រូវបានជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៩ និងជាភាសាខ្មែរនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ ឯកសារ D359/3/1 ("បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1)")។

[5] សំណុំរឿង ០០៤/២ បណ្តឹងឧទ្ធរណ៍របស់ អោ អាន លើដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ (ត្រូវបានដាក់កាលពីថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១៨) ដែលត្រូវបានជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨ និងជាភាសាខ្មែរនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩ ឯកសារ D360/5/1 ("បណ្តឹង

## I. ប្រវត្តិនីតិវិធី

១. កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ករណីខ្វែងយោបល់គ្នា នៅចំពោះមុខអង្គបុរេជំនុំជម្រះ ស្របតាមវិធាន ៧១(២) នៃវិធានផ្ទៃក្នុង ដោយរាយការណ៍ថា សហព្រះរាជអាជ្ញាជាតិមិនយល់ស្រប ទៅនឹងការចោទប្រកាន់អំពីឧក្រិដ្ឋកម្មថ្មីៗ ដែលបានចង្អុលបង្ហាញនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមឡើយ។[6] នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះ បានចេញសេចក្តីពិចារណាលើករណីខ្វែងយោបល់គ្នានេះ។[7]

២. នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ដោយស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត បើកកិច្ចស៊ើបសួរតាមផ្លូវតុលាការប្រឆាំងនឹង អោ អាន នៅក្នុងចំណោមជនសង្ស័យដទៃទៀត ទាក់ទងនឹងការចោទប្រកាន់មួយចំនួនអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រល័យពូជសាសន៍ និងការរំលោភបំពានលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ (ក្រមឆ្នាំ១៩៥៦)។[8] ការចោទប្រកាន់បន្ថែមត្រូវបានដាក់ជូននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមចំនួនប្រាំមួយ ដែលបានដាក់នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១[9] ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១[10] ថ្ងៃទី២៤ ខែមេសា

---

ឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1)")។

[6] ករណីខ្វែងយោបល់គ្នា ០០១/១៨-១១-២០០៨-អ.វ.ត.ក/អ.ប.ជ ឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីហេតុការណ៍ និងមូលហេតុនៃខ្វែងយោបល់គ្នា អនុលោមតាមវិធាន ៧១(២) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ (ឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីការខ្វែងយោបល់)។

[7] ករណីខ្វែងយោបល់គ្នា ០០១/១៨-១១-២០០៨-អ.វ.ត.ក/អ.ប.ជ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឯកសារ D1/1.3។

[8] សំណុំរឿង ០០៤/២០-១១-២០០៨-អ.វ.ត.ក/ក.ស.ច.ស ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D1 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី៣ (D1)")។

[9] សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០៤") ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D27។។ *សូមមើលផងដែរ* សំណុំរឿង ០០៤ សេចក្តីសម្រេចអំពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D27/3។

[10] សំណុំរឿង ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ ឯកសារ D65។

ឆ្នាំ២០១៤[11] ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៥[12] ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១១[13] និងថ្ងៃទី០៨ ខែមេសា ឆ្នាំ ២០១៦[14]។

៣. ករណីខ្វែងយោបល់គ្នាជាសម្ងាត់ រវាងសហចៅក្រមស៊ើបអង្កេតទាំងពីរ បានចុះបញ្ជីនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៣ ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ និងថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨។ ករណីខ្វែងយោបល់ទាំងនេះមិនត្រូវបានដាក់ជូននៅចំពោះមុខអង្គបុរេជំនុំជម្រះនោះទេ។

៤. នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចោទប្រកាន់ អោ អាន ចំពោះការរំលោភបំពានលើមាត្រា ៥០១ និងមាត្រា ៥០៦ (មនុស្សឃាត) នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។[15] អោ អាន បានផ្តល់ចម្លើយជាលើកដំបូង និងបានបញ្ជាក់ថា គាត់សុំអនុវត្តសិទ្ធិនៅស្ងៀមរបស់គាត់ និងមិនឆ្លើយទៅនឹងសំណួរណាមួយឡើយ។[16]

៥. នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចចោទប្រកាន់ អោ អាន អំពីឧក្រិដ្ឋកម្មមួយចំនួនបន្ថែមទៀត រួមមាន អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។[17] អោ អាន បានលះបង់សិទ្ធិរបស់គាត់មិនចូលរួមនៅក្នុងការបង្ហាញខ្លួនម្តងទៀតទេ ហើយមេធាវីរបស់

---

[11] សំណុំរឿង ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ឯកសារ D191។

[12] សំណុំរឿង ០០៤ ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យឯកសារ D237 ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ D237/1។

[13] សំណុំរឿង ០០៤ ចម្លើយតបទៅដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវត្តអង្គតាមាក់ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១១ ឯកសារ D254/1។

[14] សំណុំរឿង ០០៤ ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរទៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងតំបន់១ និងតំបន់៤ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ និងបានដាក់ជូននៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៦ ឯកសារ D272/1។

[15] សំណុំរឿង ០០៤ កំណត់ហេតុនៃការស្តាប់ចម្លើយនៃការបង្ហាញខ្លួនលើកដំបូងរបស់លោក អោ អាន ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ ("កំណត់ហេតុនៃការស្តាប់ចម្លើយនៃការបង្ហាញខ្លួនលើកដំបូងរបស់លោក អោ អាន (D242)")។

[16] កំណត់ហេតុនៃការស្តាប់ចម្លើយនៃការបង្ហាញខ្លួនលើកដំបូងរបស់លោក អោ អាន ((D242) ទំព័រ ៥-៦។

[17] សំណុំរឿង ០០៤ កំណត់ហេតុនៃការបង្ហាញខ្លួនម្តងទៀតរបស់ អោ អាន ចុះថ្ងៃទី២១៤ ខែមីនា ឆ្នាំ២០១៦ ឯកសារ D303 ("កំណត់ហេតុនៃការបង្ហាញខ្លួនម្តងទៀតរបស់ អោ អាន (D303)")។

គាត់បានជ្រើសរើសមិនធ្វើការកត់សម្គាល់ក្នុងនាមជាតំណាងរបស់គាត់នោះទេ។[18] បន្តបន្ទាប់មកទៀត អោ អាន មិនត្រូវបានផ្តល់ឱកាសម្តងទៀត ឱ្យផ្តល់ការពន្យល់នានាពាក់ព័ន្ធនឹងការចោទប្រកាន់មកលើរូបគាត់នោះឡើយ។

៦. នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ភាគីទាំងអស់ថា ពួកគាត់បានពិចារណាថា កិច្ចស៊ើបសួរប្រឆាំងនឹង អោ អាន បានបញ្ចប់ហើយ ។[19] នៅថ្ងៃដដែលនេះដែរ ពួកគាត់បានចេញដីកាសម្រេចបំបែកកិច្ចស៊ើបសួរចេញពីសំណុំរឿង ០០៤ ហើយបានបង្កើតសំណុំរឿងថ្មីមួយ គឺ សំណុំរឿង ០០៤/២។ [20] សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចបន្ថែមទៀត ដើម្បីកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ ដោយដកចេញអង្គហេតុដែលបានចោទប្រកាន់ ស្របតាមវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង។[21]

៧. ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីជូនដំណឹងលើកទីពីរ អំពីការបិទកិច្ចស៊ើបសួរ។[22]

៨. នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានបញ្ជូនសំណុំរឿងទៅឱ្យសហព្រះរាជអាជ្ញា ស្របតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ដោយស្នើឱ្យសហព្រះរាជអាជ្ញាដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួននៅក្នុងអំឡុងពេលបីខែ ("ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ")។[23]

---

[18] កំណត់ហេតុនៃការបង្ហាញខ្លួនម្តងទៀតរបស់ អោ អាន (D303) ទំព័រ ២។

[19] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ D334 ("សេចក្តីជូនដំណឹងលើកដំបូង អនុលោមតាមវិធាន ៦៦(១) (ឯកសារ D334)")។

[20] សំណុំរឿង ០០៤ ដីកាសម្រេចបំបែកសំណុំរឿង អោ អាន ចេញពីសំណុំរឿង ០០៤ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ D334/1។

[21] សំណុំរឿង ០០៤/២ ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន* ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ D337 (ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ) ។

[22] សំណុំរឿង ០០៤/២ សេចក្តីជូនដំណឹងលើកទី២ អំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ ឯកសារ D334/2។

[23] សំណុំរឿង ០០៤/២ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ អនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ ឯកសារ D351 ("ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ" (ឯកសារ D351)")។

៩. នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ សហព្រះរាជអាជ្ញាជាតិបានដាក់ដីកាសន្និដ្ឋានស្ថាពរ ដោយស្នើសុំឱ្យលើកលែងបទចោទប្រកាន់ទាំងអស់[24]។ ដោយឡែក នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ នេះវិញ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានស្ថាពរស្នើសុំឱ្យចោទប្រកាន់ និងបញ្ជូនខ្លួន អោ អាន ទៅជំនុំជម្រះ[25] ("ដីកាសន្និដ្ឋានស្ថាពរ")។ សហមេធាវីរបស់ អោ អាន ("សហមេធាវី") បានដាក់ចម្លើយតបទៅនឹងដីសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ("ចម្លើយតបរបស់ អោ អាន ទៅនឹងដីសន្និដ្ឋានស្ថាពរ") ។[26]

១០. នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេត បានជូនដំណឹងដល់ភាគីទាំងអស់ថា ពួកគាត់យល់ឃើញថា ដីកាដំណោះស្រាយដាច់ដោយឡែក និងផ្ទុយគ្នា ដែលត្រូវបានអនុញ្ញាតជាទូទៅនៅក្រោមច្បាប់ជាធរមាន ("ដីកាសម្រេចលើការដាក់បង្ហាញឯកសារពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នា")។[27] ពួកគាត់បានចុះបញ្ជីករណីខ្វែងយោបល់គ្នា ពាក់ព័ន្ធនឹងការចេញដីកាដំណោះស្រាយផ្ទុយគ្នានេះ នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨។

១១. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) សម្រេចបញ្ជូនខ្លួន អោ អាន ទៅជំនុំជម្រះ[28] ជាភាសាអង់គ្លេស។ ចំណែកឯសហចៅក្រមស៊ើបអង្កេតជាតិវិញ ដីកាដំណោះស្រាយ (លើកលែងចោទប្រកាន់)។[29] ដីកាដំណោះស្រាយទាំងពីរត្រូវបានដាក់ជូនដាច់ដោយឡែកពីគ្នាជាភាសាអង់គ្លេស និងភាសាខ្មែរតែប៉ុណ្ណោះ ឯសំណៅបកប្រែនឹងដាក់ជូនតាមក្រោយ។

---

[24] សំណុំរឿង ០០៤/២ ដីកាសន្និដ្ឋានស្ថាពរទាក់ទងករណី អោ អាន អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ ឯកសារ D351/4 ។

[25] សំណុំរឿង ០០៤/២ ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ ឯកសារ D351/5 ("ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D351/5)")។

[26] សំណុំរឿង ០០៤/២ ចម្លើយតបរបស់ អោ អាន ទៅនឹងដីសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ឯកសារ D351/6 ("ចម្លើយតបរបស់ អោ អាន ទៅនឹងដីសន្និដ្ឋានស្ថាពរ (D351/6)")។

[27] សំណុំរឿង ០០៤/២ ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D355/1 ("ដីកាសម្រេចលើការដាក់បង្ហាញឯកសារពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នា ("ឯកសារ D355/)") កថាខណ្ឌ ១៣-១៦។

[28] ដីកាបញ្ជូនទៅជំនុំជម្រះ (ឯកសារ D360)។

[29] ដីកាដំណោះស្រាយ (លើកលែងចោទប្រកាន់) (ឯកសារ D359)។

១២. នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ អង្គបុរេជំនុំជម្រះបានអនុញ្ញាតឲ្យភាគីទាំងអស់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍នៅក្នុងរយៈពេលដប់បួនថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីការបកប្រែដីកាដំណោះស្រាយទាំងពីរនេះរួចមក។[30]

១៣. នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ សហមេធាវីបានដាក់ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)។[31]

១៤. នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ និងនៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨ ការបកប្រែដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) និងដីកាដំណោះស្រាយ (លើកលែងចោទប្រកាន់) ត្រូវបានជូនដំណឹងដាច់ដោយឡែកៗពីគ្នា។

១៥. នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គបុរេជំនុំជម្រះបានអនុញ្ញាតឲ្យភាគីទាំងអស់ដាក់សេចក្តីសន្និដ្ឋានលើបណ្តឹងឧទ្ធរណ៍ក្នុងរយៈពេល ៤៥ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីការបកប្រែដីកាដំណោះស្រាយទាំងពីរ និងដាក់សេចក្តីសន្និដ្ឋានលើបណ្តឹងឧទ្ធរណ៍ចំនួន ១០០ ទំព័រ។[32]

---

[30] សំណុំរឿង ០០៤/២ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំបន្ថែមពេលវេលាកំណត់សម្រាប់សេចក្តី ជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ ឯកសារ D359/2។ *សូមមើលផងដែរ* សំណុំរឿង ០០៤/២ សំណើរបស់សហព្រះរាជអាជ្ញា សុំបន្ថែមពេលវេលាកំណត់សម្រាប់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/០២ ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០១៨ ឯកសារ D359/1 ។

[31] សំណុំរឿង ០០៤/២ ការជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ ឯកសារ D360/5។

[32] សំណុំរឿង ០០៤/២ សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់ សម្រាប់បណ្តឹងឧទ្ធរណ៍របស់ អោ អាន លើដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D360/7។ *សូមមើលផងដែរ* សំណុំរឿង ០០៤/២ សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ ឯកសារ D360/4។ សំណុំរឿង ០០៤/២ ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ អោ អាន ស្នើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍របស់គាត់ប្រឆាំងនឹងដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ ឯកសារ D360/6។

១៦. នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាអន្តរជាតិ និងសហព្រះរាជអាជ្ញាជាតិ បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (លើកលែងចោទប្រកាន់) [33] និងដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ)[34] រៀងៗខ្លួន។

១៧. នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាជាតិបានដាក់សារណាបណ្តឹងឧទ្ធរណ៍របស់គាត់ប្រឆាំងនឹងដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ជាភាសាខ្មែរ ("បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ")។[35] នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាអន្តរជាតិ និងសហមេធាវីបានដាក់សារណាបណ្តឹងឧទ្ធរណ៍របស់ពួកគាត់ជាភាសាអង់គ្លេសរៀងៗខ្លួន ប្រឆាំងនឹងដីកាដំណោះស្រាយ (លើកលែងចោទប្រកាន់) ("បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ")[36]និងដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ("បណ្តឹងឧទ្ធរណ៍របស់ អោ អាន")។[37]

១៨. នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានអនុញ្ញាតឱ្យភាគីដាក់ចម្លើយតបរបស់ខ្លួនកម្រាស់ ៥០ ទំព័រ ក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីការបកប្រែបណ្តឹងឧទ្ធរណ៍នីមួយៗរួច និងដាក់ការឆ្លើយតបកម្រាស់ ៣០ ទំព័រ ក្នុងរយៈពេល ១៥ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីការបកប្រែចម្លើយតបនីមួយៗរួច។[38]

---

[33] សំណុំរឿង ០០៤/២ សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចរបស់ ស.ច.ស.ជ លើកលែងការចោទប្រកាន់ប្រឆាំងនឹង អោ អាន (D359) ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D359/3។

[34] សំណុំរឿង ០០៤/២ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាជាតិ អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D360/8។

[35] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D360/8/1)។

[36] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D359/3/1)។

[37] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/5/1)។

[38] សំណុំរឿង ០០៤/២ សាលដីកាលើសំណើសុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រកំណត់ សម្រាប់ចម្លើយតប និងការឆ្លើយតបទាក់ទងនឹងបណ្តឹងឧទ្ធរណ៍នានាប្រឆាំងដីកាដំណោះស្រាយទាំងពីរក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ ឯកសារ D359/3/3 និង D360/5/3។ *សូមមើលផងដែរ* សំណុំរឿង ០០៤/២ សំណើរបស់ អោ អាន សុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់ សម្រាប់ចម្លើយតបរបស់គាត់ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន ឯកសារ (D359) និងការឆ្លើយតបណាមួយដែលពាក់ព័ន្ធ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ ឯកសារ D359/3/2។ សំណុំរឿង ០០៤/២ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំពន្យារពេល និងបន្ថែមចំនួនទំព័រកំណត់

១៩. ការបកប្រែបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ និងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ទៅជាភាសាខ្មែរ ត្រូវបានជូនដំណឹងនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ និងនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩ ដាច់ដោយឡែកពីគ្នា។ ចំណែកឯការបកប្រែបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិទៅជាភាសាអង់គ្លេស ត្រូវបានជូនដំណឹងនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩។

២០. នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ សហមេធាវីបានឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិជាភាសាអង់គ្លេស ("ចម្លើយតបរបស់ អោ អាន")[39] ចំណែកសហព្រះរាជអាជ្ញាអន្តរជាតិបានឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន")[40] និងបានឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ")[41] ជាភាសាអង់គ្លេស។ សហព្រះរាជអាជ្ញាជាតិមិនបានដាក់ចម្លើយតបទេ។

២១. ការបកប្រែជាភាសាខ្មែរ នៃចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន និងចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ បានជូនដំណឹងនៅថ្ងៃទី

---

សម្រាប់ចម្លើយតប និងការឆ្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩ ឯកសារ D360/5/2។

[39] សំណុំរឿង ០០៤/២ ចម្លើយតបរបស់ អោ អាន ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (D359) ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ បានដាក់ និងជូនដំណឹងភាសាអង់គ្លេសនៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ និងជាភាសាខ្មែរនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩ ឯកសារ D359/3/4 ("ចម្លើយតបរបស់ អោ អាន (D359/3/4)")។

[40] សំណុំរឿង ០០៤/២ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩ បានជូនដំណឹងភាសាអង់គ្លេសនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ និងជាភាសាខ្មែរនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ ឯកសារ D360/9 ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9)")។

[41] សំណុំរឿង ០០៤/២ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ បានជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ និងជាភាសាខ្មែរនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ ឯកសារ D360/10 ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D360/10)")។

១៥ ខែមីនា ឆ្នាំ២០១៩ ចំណែកការបកប្រែជាភាសាខ្មែរនៃចម្លើយតបរបស់ អោ អាន បានជូនដំណឹងនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩។

២២. នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ សហមេធាវីបានឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ជាភាសាអង់គ្លេស (“ការឆ្លើយតបរបស់ អោ អាន”)[42] ហើយនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាអន្តរជាតិបានឆ្លើយតបទៅនឹងចម្លើយតបរបស់ អោ អាន ជាភាសាអង់គ្លេស (“ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ”)[43] ។ ការបកប្រែជាភាសាខ្មែរនៃការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និង ការឆ្លើយតបរបស់ អោ អាន បានជូនដំណឹងនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ និងថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩។

២៣. នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ ក្រោយពេលស្តាប់ការលើកឡើងរបស់ភាគី[44] អង្គបុរេជំនុំជម្រះបានចេញដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើបណ្តឹងឧទ្ធរណ៍[45] ។ ការធ្វើសេចក្តីសន្និដ្ឋានដោយ

---

[42] សំណុំរឿង ០០៤/២ ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ បានជូនដំណឹងជាភាសាអង់គ្លេស នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ និងជាភាសាខ្មែរនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ ឯកសារ D360/11 (“ការឆ្លើយតបរបស់ អោ អាន (D360/11)”)។

[43] សំណុំរឿង ០០៤/២ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយតបរបស់ អោ អាន ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (D359) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ បានជូនដំណឹងជាភាសាខ្មែរនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ ឯកសារ D359/3/5 (“ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D359/3/5)”)។

[44] សំណុំរឿង ០០៤/២ សេចក្តីជូនដំណឹងរបស់អង្គបុរេជំនុំជម្រះដល់ភាគីតាមអ៊ីមែល ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៩ ឯកសារ D359/4.1.1 ។ សំណុំរឿង ០០៤/២ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះអំពីសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ ឯកសារ D359/4។ សំណុំរឿង ០០៤/២ អនុស្សរណៈរបស់ក្រុមមេធាវីការពារក្តី អោ អាន ធ្វើជូនអង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងសេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះដល់ភាគីនៅក្នុងសំណុំរឿងលេខ ០០៤/០២-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អង្គបុរេជំនុំជម្រះ៦០) ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៩ ឯកសារ D360/12 ។ សំណុំរឿង ០០៤/២ ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះ អំពីសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៩ ឯកសារ D360/13។

[45] សំណុំរឿង ០០៤/២ ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D360/14 និងឯកសារ D359/5។

ផ្ទាល់មាត់ទៅលើបណ្តឹងឧទ្ធរណ៍ ត្រូវបានធ្វើឡើងជាអសាធារណៈនៅថ្ងៃទី១៩ ២០ និង ២១ ខែមិថុនា ឆ្នាំ២០១៩[46] ។

## II. ការបញ្ចូលគ្នា

២៤. ដូចបានលើកឡើងរួចមកហើយ នៅក្នុងផ្នែកស្តីពីប្រវត្តិនីតិវិធី នាពេលនេះ អង្គបុរេជំនុំជម្រះបានទទួលបណ្តឹងឧទ្ធរណ៍ចំនួនបីជំទាស់ដីកាដំណោះស្រាយពីរ ក្រោយពីការបញ្ចប់កិច្ចស៊ើបសួរលើសំណុំរឿង ០០៤/២ រួចមក។

២៥. មាត្រា ២៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា *"កាលណាតុលាការបានទទួលនីតិវិធីច្រើនដែលមានអង្គហេតុច្រើនជាប់ទាក់ទងគ្នា តុលាការអាចបង្គាប់ឱ្យបញ្ចូលនីតិវិធីទាំងនោះជាមួយគ្នាបាន"*។

២៦. នៅក្នុងករណីចំពោះនេះ អង្គបុរេជំនុំជម្រះមិនបានទទួលករណីដែលជាប់ទាក់ទងគ្នាច្រើនទេ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបានទទួល*ករណីមួយ* ដែលជាប់ទាក់ទងនឹងដីកាដំណោះស្រាយផ្ទុយគ្នា ដែលបានបង្កើតឱ្យមានកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍មួយចំនួនខុសៗគ្នា ប៉ុន្តែ ជាប់ទាក់ទងគ្នាទាំងអស់។ ដោយពិចារណាទៅលើសិទ្ធិអំណាចរបស់អង្គជំនុំជម្រះ ក្នុងការចេញដីកាបង្គាប់ឱ្យបញ្ចូលជាមួយគ្នានូវ*នីតិវិធីច្រើន*ដែលជាប់ទាក់ទងគ្នា និងកាតព្វកិច្ចរបស់អង្គជំនុំជម្រះ ក្នុងការធានាឱ្យមានដំណើរការស្វែងរកយុត្តិធម៌ឱ្យបានត្រឹមត្រូវ និងឆាប់រហ័សនោះ អង្គជំនុំជម្រះយល់ឃើញថា ការបញ្ចូលនីតិវិធីជាមួយគ្នានៅក្នុងករណីនេះ គឺតម្រូវឱ្យមានដោយជៀសសមិនផុតឡើយ។

២៧. ជាលទ្ធផល អង្គបុរេជំនុំជម្រះសម្រេចបញ្ចូលគ្នាតែមួយ ហើយនឹងដោះស្រាយបណ្តឹងឧទ្ធរណ៍ទាំងឡាយជំទាស់ដីកាដំណោះស្រាយទាំងពីរ នៅក្នុងសេចក្តីពិចារណាទាំងនេះ។

---

[46] ប្រតិចារឹកថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/8.1, ERN 01626002-01626051 ទំព័រ ១៣-៦២។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1, ERN 01626055-01626124 ទំព័រ ១-៧០។ ប្រតិចារឹកថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/10.1, ERN 01626128-01626148 ទំព័រ ១-២១។

01634776



## III.បទដ្ឋាននៃការពិនិត្យឡើងវិញ

២៨. ការកំណត់ថាតើ អោ អាន ស្ថិតក្នុងចំណោម “ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត” ហើយថាតើ គាត់ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឬទេនោះ គឺជាសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិ[47]។ ទោះបីជាយ៉ាងណាក៏ដោយ ឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតក្នុងការកំណត់លើចំណុចនេះ គឺជាឆន្ទានុសិទ្ធិតុលាការ និងមិនអនុញ្ញាតឲ្យបំពេញកិច្ចតាមអំពើចិត្តទេ ប៉ុន្តែត្រូវអនុវត្តទៅតាមគោលការណ៍ច្បាប់ដែលមានច្បាស់លាស់[48]។ ទាក់ទិននឹងចំណុចនេះ ពាក្យថា “មេដឹកនាំជាន់ខ្ពស់” និង “ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត” គឺជាព្រំដែនយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[49]។ ទោះបីភាពបត់បែននៃពាក្យទាំងនេះតម្រូវឲ្យសហចៅក្រមស៊ើបអង្កេតមានសិទ្ធិអំណាចមួយចំនួនក៏ដោយ ក៏ឆន្ទានុសិទ្ធិនេះមិនមែនគ្មានព្រំដែន និងចៀសផុតពីការត្រួតពិនិត្យរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នោះទេ។ ហេតុនេះ អង្គបុរេជំនុំជម្រះនឹងពិនិត្យទៅលើការកំណត់របស់សហចៅក្រមស៊ើបអង្កេតដែលថា អោ អាន ស្ថិត ឬមិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់តុលាការ អនុលោមតាមបទដ្ឋាននៃការពិនិត្យឡើងវិញដែលអនុវត្តចំពោះសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិ។

---

[47] *សូមមើល* សំណុំរឿង ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (“សំណុំរឿង ០០៤/១”) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D308/3/1/20 (“សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20)”) កថាខណ្ឌ២០ ដែលយោងទៅសំណុំរឿង ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក (“សំណុំរឿង ០០១”) សាលដីកា (“សាលដីកា សំណុំរឿង ០០១ (ឯកសារ F28)”) កថាខណ្ឌ ៦២-៧៤, ៧៩។

[48] *សូមមើល* សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ២០ ដែលយោងទៅ តុលាការយោធាអន្តរជាតិ សាលក្រម ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៤៦ ការកាត់ទោសឧក្រិដ្ឋជនសង្គ្រាមធំៗនៅចំពោះមុខតុលាការយោធាអន្តរជាតិ វ៉ុល I (សាលក្រមនូរ៉ែមប៊ើក) ទំព័រ ១៧១-៣៦៧ នៅត្រង់ទំព័រ ២៥៦។

[49] *សូមមើល* សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ២០ ដែលយោងទៅ *កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ដែលបានចុះហត្ថលេខានៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ និងចូលជាធរមាននៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ (“កិច្ចព្រមព្រៀងបង្កើត អ.វ.ត.ក”)* មាត្រា ២(១)។ *ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុង រយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ* ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ នស/រកម/១០០៤/០០៦ ដោយបានធ្វើវិសោធនកម្ម ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (“ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក”) មាត្រា ២ថ្មី។

២៩. សេចក្តីសម្រេចតាមឆន្ទានុសិទ្ធិអាចត្រូវបានបដិសេធចោល ក្នុងករណីដែលសេចក្តីសម្រេចនោះ (១) ផ្អែកលើការបកស្រាយច្បាប់ជាមូលដ្ឋានមិនបានត្រឹមត្រូវ (គឺ កំហុសអង្គច្បាប់) ដែលនាំឱ្យសេចក្តីសម្រេចនោះគ្មានសុពលភាព (២) ផ្អែកលើការសន្និដ្ឋានលើអង្គហេតុមិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែត (គឺ កំហុសអង្គហេតុ) ដែលបណ្តាលឱ្យមានភាពមិនយុត្តិធម៌ និង/ឬ (៣) មានភាពអយុត្តិធម៌ ឬមិនសមហេតុសមផល ដែលជាការបំពានលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត និងបង្ខំឱ្យធ្វើការសន្និដ្ឋាន ដោយពួកគាត់មិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យបានប្រយ័ត្នប្រយែង។ អាចនិយាយម្យ៉ាងទៀតថា ត្រូវបង្ហាញឱ្យឃើញថា សហចៅក្រមស៊ើបអង្កេតមានកំហុស ឬមានការបំពារបំពាន ដែលមានអានុភាពទៅលើការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន[50]។

៣០. នៅក្នុងបរិបទនៃសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិ ជាធម្មតា អង្គបុរេជំនុំជម្រះនឹងបញ្ជូនសេចក្តីសម្រេចនេះឱ្យទៅសហចៅក្រមស៊ើបអង្កេតធ្វើការពិចារណាសាជាថ្មី [51] ហើយនឹងជំនួសសេចក្តីសម្រេចរបស់ខ្លួនតែក្នុងករណីពិសេសប៉ុណ្ណោះ [52] ។ នៅក្នុងករណីជាក់លាក់នៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ វិធាន ៧៩(១)នៃវិធានផ្ទៃក្នុង ស្នើឡើងថា អង្គបុរេជំនុំជម្រះមានអំណាចចេញដីកាដំណោះស្រាយថ្មីមួយ ឬចេញដីកាដំណោះស្រាយដែលបានកែប្រែរួច។ ដីកានេះនឹងយកមកធ្វើជាមូលដ្ឋាននៃការជំនុំ

---

[50] *សូមមើល* សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ២១ ដែលយោងទៅ *ក្នុងចំណោមករណីផ្សេងទៀត* សំណុំរឿង ០០៤ (អ.ប.ជ៥២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទងនឹងអំពើហិង្សាផ្លូវភេទ នៅគុកលេខ ៨ និងនៅក្នុងស្រុកបាកាន ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ ឯកសារ D365/3/1/5 កថាខណ្ឌ ១៥។

[51] *សូមមើល* ឧទា. សំណុំរឿង ០០២ (អ.ប.ជ៥២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំសម្គាល់បុគ្គលដូចមានរាយនាមនៅក្នុងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរស្តីពីការបាត់ខ្លួនដោយបង្ខំ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១០ ឯកសារ D310/1/3 កថាខណ្ឌ ១៦។ សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០២") (អ.ប.ជ៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីការណែនាំឱ្យពិចារណាឡើងវិញលើសំណើសុំ D153, D172, D173, D174, D178 និង D284 ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១០ ឯកសារ D300/1/7 (សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់នួន ជា (D300/1/7)) កថាខណ្ឌ ១៩, ២៦។

[52] សំណុំរឿង ០០២ (អ.ប.ជ៦៧) សាលដីកាស្តីពីការពិចារណាឡើងវិញ ទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D365/2/17 កថាខណ្ឌ ៦៧។

ជម្រះ[53]។ លើសពីនេះទៀត អង្គបុរេជំនុំជម្រះបានសម្រេចកាលពីលើកមុនថា ខ្លួនបានបំពេញតួនាទីជាសភាស៊ើបសួរ តាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុង អ.វ.ត.ក ដែលត្រូវធ្វើការស៊ើបសួររឿងក្តីនេះដោយខ្លួនឯង នៅពេលទទួលបានដីកាលើកលែងការចោទប្រកាន់ ដោយសារមានបណ្តឹងឧទ្ធរណ៍[54]។

## IV.បញ្ហាបឋម

### ក. អំណាចរបស់ អង្គបុរេជំនុំជម្រះ លើដំណាក់កាលនៃការស៊ើបអង្កេត

៣១. នៅក្នុងជំពូកនេះ អង្គបុរេជំនុំជម្រះសូមធ្វើការបំភ្លឺបញ្ជាក់អំពីលក្ខណៈ និងវិសាលភាពនៃអំណាចត្រួតពិនិត្យដែលភាគីបានស្នើសុំឱ្យអង្គជំនុំជម្រះយកមកអនុវត្តនៅក្នុងសំណុំរឿងនេះ។

៣២. តាំងពីដំបូងមក អង្គបុរេជំនុំជម្រះសូមរម្លឹកថា អង្គបុរេជំនុំជម្រះបានអនុវត្តអំណាចចម្រុះរួមមាន៖ ការពិនិត្យលើបណ្តឹងឧទ្ធរណ៍ទៅលើកំហុសអង្គច្បាប់ កំហុសអង្គហេតុ និងឆន្ទានុសិទ្ធិដែលត្រូវបានចោទប្រកាន់ [55] សម្រេចទៅលើបញ្ហាធំធេងនានាជាទូទៅសម្រាប់យុត្តិសាស្ត្រ និងកេរដំណែលរបស់អ.វ.ត.ក

---

[53] *សូមមើល* សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20)") កថាខណ្ឌ ២២ ដែលយោងទៅ សំណុំរឿង ០០១ (អ.ប.ជ០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D99/3/42 ("សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D99/3/42)") កថាខណ្ឌ ៤០។

[54] *សូមមើល* សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ២២ ដែលយោងទៅ សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D99/3/42) កថាខណ្ឌ ៤១-៤២។

[55] សំណុំរឿង ០០២ (អង្គបុរេជំនុំជម្រះ ១៤៥ & ១៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ D427/2/15 & D427/3/15 (សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ)(D427/2/15 និង D427/3/15)) កថាខណ្ឌ ៥៩-៦៣, ៨៦។ សំណុំរឿង ០០២ (អង្គបុរេជំនុំជម្រះ ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងដីកាដំណោះស្រាយ ឯកសារ D427/1/30 ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ (សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំនឹងដីកាដំណោះស្រាយ (អៀង សារី)(D427/1/30) កថាខណ្ឌ ៤៤-៤៧, ១១១-១១៣។ សំណុំរឿង ០០៤/១ (អង្គបុរេជំនុំជម្រះ ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D308/3/1/20 កថាខណ្ឌ ២០-២២, ២៥-២៧។ សំណុំរឿង ០០២ (អង្គបុរេជំនុំជម្រះ ៦១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួររបស់មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ សុំឱ្យស៊ើបអង្កេតទៅលើតួនាទីរបស់លោក អ៊ីសា ឧស្មាន នៅក្នុងការស៊ើបសួរ សុំ

[56] អំណាចដែលជាប់ជាមួយ ឬយុត្តិសាស្ត្រដែលជាប់ជាមួយ [57] និងអំណាចបន្ទាប់បន្សំនៃការស៊ើបអង្កេត ដែលកើតចេញពីតួនាទីរបស់សភាស៊ើបសួរនៅកម្ពុជា ក្នុងករណីដែលមានភាពចន្លោះប្រហោង នៅក្នុង

ឲ្យដកចេញកំណត់ហេតុស្តាប់ចម្លើយសាក្សីមួយចំនួន និងសុំឲ្យស្តាប់ចម្លើយសាក្សីមួយចំនួនជាថ្មីម្តងទៀត ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១០ ឯកសារ D361/2/4 កថាខណ្ឌ ១៥-១៦។ សំណុំរឿង ០០២ (អង្គបុរេជំនុំជម្រះ ៦៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូនៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០ ឯកសារ A371/2/12 កថាខណ្ឌ ២២។ សំណុំរឿង ០០២ (អង្គបុរេជំនុំជម្រះ ៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីការណែនាំឲ្យពិចារណាឡើងវិញលើសំណើសុំ D153, D172, D174, D178 និង D284 ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១០ ឯកសារ D300/1/7 កថាខណ្ឌ ១៤-១៥។

[56] សំណុំរឿង សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (D308/3/1) កថាខណ្ឌ ៧៣ *យោងទៅ* តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា (ICTR) រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Akayesu* សំណុំរឿងលេខ ICTR-96-4-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ១៩, ២៣-២៤។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Tadić* សំណុំរឿងលេខ IT-94-1-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ ដូចដែលបានធ្វើការកែតម្រូវក្នុងសាលដីកានៃបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ១៩៩៩ (សាលដីកាបណ្តឹងឧទ្ធរណ៍ *Tadić (ICTY)*) កថាខណ្ឌ ២៤៧, ២៨១, ៣១៦។ តុលាការ ICTY *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Mucić និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-96-21-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ២២១។

[57] សំណុំរឿង ០០២ (អង្គបុរេជំនុំជម្រះ ៧៣) សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D404/2/4 (សំណុំរឿង ០០២ សាលដីកាលើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី(D404/2/4))កថាខណ្ឌ ១០៦, ១១៥។ សំណុំរឿង ០០២ (អង្គបុរេជំនុំជម្រះ ០៣) សេចក្តីសម្រេចលើពាក្យសុំពិចារណាសាជាថ្មីអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ ឯកសារ C22/I/68 ឯកសារ ២៥-២៦។ សំណុំរឿង ០០៣ (អង្គបុរេជំនុំជម្រះ ០៣) ដីកាសម្រេចព្យួរការអនុវត្ត "ដីកាសម្រេចស្តីពីសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣" ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D14/1/2 (សំណុំរឿង ០០៣ ដីកាសម្រេចព្យួរការអនុវត្ត (D14/1/2)) កថាខណ្ឌ ៤-៥។ សំណុំរឿង ០០៤/២ សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំការកោសលុប និងការចាត់វិធានការបណ្តោះអាសន្ន ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ ឯកសារ D360/3 (សំណុំរឿង ០០៤/២សេចក្តីសម្រេចលើសំណើបន្ទាន់ របស់អោ អាន (D360/3)) កថាខណ្ឌ ៦-៧, ១២។ សំណុំរឿង ០០៣ (អង្គបុរេជំនុំជម្រះ ១១) សេចក្តីសម្រេចលើសំណើសុំឲ្យមានវិធានការបណ្តោះអាសន្ន ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ឯកសារ D56/19/8 កថាខណ្ឌ ១៥-១៦។

វិធានផ្ទៃក្នុង អ.វ.ត.ក [58] ។ អង្គបុរេជំនុំជម្រះអាចប្រើប្រាស់អំណាចមួយចំនួន ឬអំណាចទាំងអស់ក្នុងចំណោមអំណាចខុសៗគ្នាទាំងនេះនៅក្នុងកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន។

៣៣. ទាក់ទិននឹងចំណុចនេះ អង្គបុរេជំនុំជម្រះគូសបញ្ជាក់ថា អំណាចខាងដើមចំនួនបីដែលបានរៀបរាប់ខាងលើត្រូវបានបង្កើតឡើងយ៉ាងត្រឹមត្រូវនៅក្នុងយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ និងនៅក្នុងយុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ទោះបីអំណាចទីបួនគឺអំណាចបន្ទាប់បន្សំនៃការស៊ើបអង្កេត ដែលមកទល់នឹងពេលនេះត្រូវបានអង្គជំនុំជម្រះយកមកប្រើប្រាស់តិចតួច និងនៅក្នុងបរិបទផ្នែកនីតិវិធីមានកម្រិតក៏ដោយ តែកាលៈទេសៈពិសេសនៃសំណុំរឿងនេះ គាំទ្រឱ្យតុលាការនេះប្រើប្រាស់អំណាចនេះកាន់តែទូលំទូលាយជាងមុន[59]។

៣៤. ជាទូទៅ បទដ្ឋាននៃការពិនិត្យលើបណ្តឹងឧទ្ធរណ៍ដែលអនុវត្តចំពោះកិច្ចដំណើរការនីតិវិធីនេះត្រូវបានកំណត់ដោយឡែក [60] ។ ជំពូកនេះដើរតួនាទីជាចម្បងក្នុងការបង្ហាញអំពីអំណាចនានាដែលអង្គបុរេជំនុំជម្រះ

---

[58] សំណុំរឿង ០០១ (អង្គបុរេជំនុំជម្រះ ០១) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៧ ឯកសារ C5/45 (សំណុំរឿង០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន (D5/45)) កថាខណ្ឌ ៧។ សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D99/3/42) កថាខណ្ឌ ៤១។ សូមមើលផងដែរ សំណុំរឿង ០០២ (អង្គបុរេជំនុំជម្រះ ០៨) សេចក្តីសម្រេចលើកទីបីទៅលើសំណើសុំបំពេញកិច្ចស៊ើបសួរអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចំពោះសកម្មភាពរបស់បណ្ឌិត Craig ETCHESON នៅការិយាល័យសហព្រះរាជអាជ្ញាទាក់ទិននឹងការប្រាស្រ័យទាក់ទងតែភាគីម្ខាង ជាមួយបុគ្គលិកអន្តរជាតិនៅការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១០ (សំណុំរឿង ០០២ សេចក្តីសម្រេចលើកទីបី ទៅលើសំណើសុំរបស់អៀង សារី) ERN (EN) 0611365-0611371 កថាខណ្ឌ ៤។ សំណុំរឿង ០០១ (អង្គបុរេជំនុំជម្រះ ០១) សាលដីកាអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ នួន ជា ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ ឯកសារ C11/53 (សំណុំរឿង ០០១ សាលដីកាអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី(C11/53)) កថាខណ្ឌ ៣៨។

[59] នៅក្នុងជំពូកមួយទៀត អង្គបុរេជំនុំជម្រះបានផ្តល់សំអាងហេតុរបស់ខ្លួនអំពីមូលហេតុដែលអង្គជំនុំជម្រះពិចារណាឃើញថាសហចៅក្រមស៊ើបអង្កេតបានរំលោភបំពានទៅលើមូលដ្ឋានគ្រឹះនៃក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក នៅក្នុងសំណុំរឿងនេះ ដោយចេញដីកាដំណោះស្រាយពីរដាច់ពីគ្នា និងផ្ទុយគ្នា។ អង្គជំនុំជម្រះសន្និដ្ឋានថាត្រូវអនុវត្តអំណាចពិនិត្យយ៉ាងទូលំទូលាយដើម្បីស្តារនីត្យានុកូលភាព និងការដោះស្រាយចំពោះកំហុសផ្នែកនីតិវិធីដែលបង្កឡើងដោយសកម្មភាពមិនស្របច្បាប់របស់សហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿងនេះ។ សម្រាប់ព័ត៌មានលម្អិត *សូមមើល* កថាខណ្ឌ៨៨ ដល់១២៤។ *សូមមើល*ផងដែរ កថាខណ្ឌ ៣១ ដល់ ៥៤។

[60] *សូមមើលខាងក្រោម* កថាខណ្ឌ ២៨ ដល់ ៣០ ។

អាចចាត់ទុកជាការចាំបាច់ដែលត្រូវយកមកប្រើប្រាស់ ក្នុងនាមជាតុលាការស៊ើបអង្កេតថ្នាក់ទីពីរនៅក្នុងសំណុំរឿងនេះ។ ហេតុនេះការបញ្ជាក់បំភ្លឺធ្វើឡើងទាក់ទិននឹងប្រភព និងព្រំដែននៃមុខងារពិនិត្យលើបណ្តឹងឧទ្ធរណ៍ជាក់លាក់នេះ ដែលកើតចេញពីមុខងារនៃការពិនិត្យលើបណ្តឹងឧទ្ធរណ៍ដែលត្រូវបានអនុវត្តនៅក្នុងដំណាក់កាលនៃកិច្ចស៊ើបសួរ នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលថ្នាក់ជាតិ ដូចជាប្រព័ន្ធច្បាប់ដែលនៅជាធរមាននៅកម្ពុជា និងបារាំង នឹងផ្តល់នូវការឆ្លើយតបយ៉ាងចាំបាច់ ចំពោះការព្រួយបារម្ភនានាដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានលើកឡើង [61] ទាក់ទិនទៅនឹងការយល់ឃើញរបស់អង្គបុរេជំនុំជម្រះ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ក្នុងសំណុំរឿង ០០៤/១[62] ដោយលើកឡើងថា ក្នុងកាលៈទេសៈមួយចំនួន អង្គជំនុំជម្រះអាចដើរតួនាទីជា "ស្ថាប័នត្រួតពិនិត្យនៅដំណាក់កាលស៊ើបសួរ"។ ជាផ្នែកនៃការឆ្លើយតបរបស់ខ្លួនទៅនឹងសហចៅក្រមស៊ើបអង្កេតអន្តរជាតិនោះ អង្គបុរេជំនុំជម្រះគូសបញ្ជាក់បន្ថែមថា ជារឿយៗ អង្គជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៅតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀតក៏ដើរតួនាទីជំនួសស្ថាប័នថ្នាក់ក្រោមដែរ ដើម្បីបដិសេធ ឬបញ្ជាក់នូវសេចក្តីសន្និដ្ឋាននានារបស់ស្ថាប័នទាំងនេះ ឬសន្មតនូវសេចក្តីសន្និដ្ឋានរបស់ខ្លួនតាមវិធីដូចគ្នាទៅនឹងវិធីសាស្ត្រដែលអង្គជំនុំជម្រះថ្នាក់ទីពីរប្រកាន់យក[63]។

៣៥. អង្គបុរេជំនុំជម្រះ ទោះបីជាបញ្ជាក់សារជាថ្មីឡើងថា អង្គបុរេជំនុំជម្រះអាចដើរតួនាទីជាសភាស៊ើបសួររបស់កម្ពុជានៅក្នុងប្រព័ន្ធច្បាប់របស់ អ.វ.ត.ក នៅពេលកាលៈទេសៈតម្រូវដីដោយ[64] ក៏រម្លឹកផងដែរថា "ទំនាក់ទំនងសុខដុមរវាងចៅក្រមស៊ើបអង្កេត និងសភាស៊ើបសួរ តម្រូវជាចាំបាច់នូវការគោរពបុព្វសិទ្ធិរបស់ភាគីនីមួយៗ"[65]។ នៅក្នុងបរិបទនេះ អង្គជំនុំជម្រះមិនអាចទទួលយកការអនុវត្តជាប្រព័ន្ធ និងឥតឈប់

---

[61] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ២៦។

[62] សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង (D308/3/1/20)។

[63] តុលាការ ICTY *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Mladic* សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំប្តឹងជំទាស់ចៅក្រម Theodor Meron ចៅក្រម Carmel Agius និងចៅក្រម Liu Daqun សំណុំរឿងលេខ MICT-13-56-A ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ ២០១៨ កថាខណ្ឌ ៨២។

[64] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាឃុំខ្លួនបណ្តោះអាសន្ន (C5/45) កថាខណ្ឌ ៧។ សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D99/3/42) កថាខណ្ឌ ៤១។ *សូមមើល ផងដែរ* សំណុំរឿង ០០២ សេចក្តីសម្រេចលើកទីបី លើសំណើសុំរបស់ អៀង សារី ERN (EN) 0611365-0611371 កថាខណ្ឌ ៤។ សំណុំរឿង ០០១ សាលដីកាអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី (C11/53) កថាខណ្ឌ ៣៨។

[65] Christian GUÉRY, *"Les pouvoirs de la chambre de l'instruction et la liberté du magistrat instructeur"* ក្រមង Dalloz លេខ ៩ (២០០៧) ("GUÉRY, *Les pouvoirs de la chambre de l'instruction et la liberté du magistrat instructeur* (២០០៧)") ទំព័រ ៦០៣។

ឈររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងការបញ្ចៀសនូវការអន្តរាគមន៍របស់អង្គបុរេជំនុំជម្រះក្នុងការដោះស្រាយវិវាទរវាងសហចៅក្រមស៊ើបអង្កេត ដែលជាការប្រឆាំងនឹងប្រព័ន្ធច្បាប់របស់ អ.វ.ត.ក[66] ក៏ដូចជា ការចចេសរបស់ពួកគាត់ក្នុងការបដិសេធនូវរាល់ការគ្រប់គ្រងណាមួយពីតុលាការដែលមានសិទ្ធិអំណាចពិនិត្យមើលទៅលើបណ្តឹងឧទ្ធរណ៍[67] ដោយធ្វើឱ្យភាន់ច្រឡំ ជាអាទិ៍ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ និងមតិយោបល់រួមរបស់ចៅក្រម [68] ឬដីកាបញ្ជូនទៅជំនុំជម្រះ និងការរកឃើញអំពើពិរុទ្ធ [69] ។ ហេតុដូច្នេះ អង្គជំនុំជម្រះនេះយល់ឃើញថាជាការចាំបាច់ក្នុងការបញ្ជាក់ និងអះអាងពីមូលដ្ឋានគតិយុត្តិសម្រាប់តួនាទី និងមុខងាររបស់ខ្លួន ក្នុងនាមជាស្ថាប័នឧទ្ធរណ៍នៅដំណាក់កាលបុរេជំនុំជម្រះរបស់ អ.វ.ត.ក។ ប៉ុន្តែ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះពិចារណាឃើញថា ជាការមិនចាំបាច់ឡើយក្នុងការកត់ត្រាលម្អិតនូវគ្រប់ករណីទាំងអស់ ដែលការគោរពត្រឹមត្រូវលើសិទ្ធិអំណាចរបស់ខ្លួនត្រូវបានបំភ្លេចចោលដោយមិនត្រឹមត្រូវតាមច្បាប់ពីសំណាក់សហចៅក្រមស៊ើបអង្កេត។

៣៦. ហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ការទទូចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើការបន្តការអនុវត្តកិច្ចស៊ើបសួររបស់ខ្លួនក្នុងសំណុំរឿង ០០៤/២ ទោះបីជាមានកំហុសដែលបានលើកឡើងក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/១ ក្តី បង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិទទួលបានព័ត៌មានខុសទាំងស្រុង ពាក់ព័ន្ធនឹងអ្វីដែលជាលក្ខខណ្ឌតម្រូវសម្រាប់ការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងការអនុវត្តកិច្ចស៊ើបសួររបស់ខ្លួន។ ពាក់ព័ន្ធចំណុចនេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ការប្រើពាក្យ *ដោយខ្វះការយកចិត្តទុកដាក់* នៅក្នុងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ(ដីកាបញ្ជូនទៅជំនុំជម្រះ) បង្ហាញអំពីការយល់ខុសយ៉ាងខ្លាំងលើបុព្វសិទ្ធិ

---

[66] *សូមមើល* ខាងក្រោម កថាខណ្ឌ *៨៨ ដល់ ១២៤* ។

[67] *សូមមើល* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D360 កថាខណ្ឌ ១៧-៣៨។

[68] *សូមមើល* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ឯកសារ D360 កថាខណ្ឌ ៣៤ ("នៅក្នុងផ្នែកសេចក្តីសម្រេចនៃការយល់ឃើញជារួមរបស់ខ្លួន អ.ប.ជ បានបញ្ចូលមតិយោបល់របស់ខ្លួនថា តុលាការធម្មតារបស់កម្ពុជាមានយុត្តាធិការលើឧក្រិដ្ឋកម្មដែលមិនអាចធ្វើការជំនុំជម្រះបាននៅចំពោះមុខ អ.វ.ត.ក ជាអ្វីដែល អ.ប.ជ មិនអាចធ្វើបានឡើយ") (មានសេចក្តីបញ្ជាក់បន្ថែម)។

[69] *សូមមើល* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D360 កថាខណ្ឌ ៣៧(ខ)(iii) ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិយោងទន្ទឹករណ៍របស់គាត់ទៅលើសំអាងហេតុ ដែលបានអនុវត្តដើម្បីសម្រេចអំពីពិរុទ្ធភាព គឺមិនមែនដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ ("ចៅក្រម Eboe-Osuji បានធ្វើការសង្ខេបយ៉ាងល្អអំពីបញ្ហានេះថា: "ការរកឃើញអំពីពិរុទ្ធ [...] មិនមែនកើតចេញពីការឲ្យតម្លៃបំប៉ោងទៅលើភស្តុតាងដែលមានបានតាមរបៀបជំនាញឡើយ")។

របស់សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ[70]។ ការប្រើពាក្យនេះក៏បង្ហាញផងដែរពីការនាំយកនូវទស្សនាទានទាំងឡាយមិនត្រឹមត្រូវដែលមិនពាក់ព័ន្ធនឹងច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក ។ វាក៏បង្ហាញឱ្យឃើញបន្ថែមទៀតនូវការព្យាយាមយ៉ាងជាក់ស្តែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការរំដោះខ្លួនមិនត្រឹមតែចេញពីវិធាននៃច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពីការគ្រប់គ្រងការអនុវត្តត្រឹមត្រូវរបស់ខ្លួនដោយយុត្តាធិការបណ្តឹងឧទ្ធរណ៍ទៀតផង។

៣៧. នៅពេលនេះ អង្គជំនុំជម្រះនឹងបញ្ជាក់អំពីសិទ្ធិអំណាចដែលអង្គជំនុំជម្រះអាចយកមកប្រើនៅក្នុងករណីនេះ ក្នុងនាមជាតុលាការស៊ើបសួរទីពីរ ខណៈដែលកំពុងពិនិត្យមើលទៅលើសកម្មភាព និងការយល់ឃើញទាំងឡាយរបស់សហចៅក្រមស៊ើបអង្កេត។

### ១. តួនាទីរបស់អង្គបុរេជំនុំជម្រះជាស្ថាប័នស៊ើបសួរទីពីរ និង សិទ្ធិអំណាចចុងក្រោយនៅដំណាក់កាលស៊ើបសួរ

៣៨. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា អនុលោមតាមមាត្រា១២(១)នៃកិច្ចព្រមព្រៀង "នីតិវិធីរបស់ អ.វ.ត.ក ត្រូវសមស្របតាមច្បាប់កម្ពុជា"។ លើសពីនេះទៀត មាត្រា១២(២) នៃកិច្ចព្រមព្រៀង ចែងថា "អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលមានចែងក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលកម្ពុជាជាភាគីហត្ថលេខីដែរ"។[71] ទាក់ទិននឹងយន្តការ និងអាណត្តិពិសេសមានតែមួយរបស់ អ.វ.ត.ក អង្គបុរេជំនុំជម្រះយល់ឃើញថា ប្រព័ន្ធតុលាការ និងរចនាសម្ព័ន្ធរបស់ អ.វ.ត.ក ជាក់ស្តែង *ក្នុងចំណោមប្រការផ្សេងទៀត* យកគំរូតាមប្រព័ន្ធនីតិវិធីព្រហ្មទណ្ឌ ដូចមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលមានមូលដ្ឋានគ្រឹះចេញពីក្រមនីតិវិធីព្រហ្មទណ្ឌបារាំង។

៣៩. ពាក់ព័ន្ធនឹងចំណុចនេះ អង្គជំនុំជម្រះកត់សម្គាល់ថា មាត្រា ៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា "នៅក្នុងសាលាឧទ្ធរណ៍ មានសភាមួយដែលមានឈ្មោះថាសភាស៊ើបសួរ" និងកត់សម្គាល់ទៀតថា នៅក្នុង

---

[70] *សូមមើល* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D360 កថាខណ្ឌ ៣៧(ក), ៣៧(ខ)(ii), ៣៨។

[71] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១២(២)។

ប្រព័ន្ធចៅក្រមស៊ើបសួរជាច្រើនដទៃទៀត[72] សភាស៊ើបសួរគឺជាផ្នែកដ៏សំខាន់ និងចាំបាច់មួយនៃកិច្ចនីតិវិធីដំណាក់កាលបុរេជំនុំជម្រះ។

៤០. ក្នុងនាមជាស្ថាប័នមួយ ស្រដៀងគ្នាទៅនឹងសភាស៊ើបសួររបស់កម្ពុជាដែរនោះ សិទ្ធិអំណាចរបស់អង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក ក្នុងការពិនិត្យមើលឡើងវិញ អនុលោមតាមប្រព័ន្ធច្បាប់របស់ អ.វ.ត.ក អាចទាញចេញពីក្នុងមាត្រា ២៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលចែងថា៖

> *នៅរាល់ពេលដែលបានទទួលបណ្តឹង សភាស៊ើបសួរពិនិត្យមើលពីនិយ័តភាពនៃនីតិវិធី និងការប្រព្រឹត្តទៅដ៏ល្អនៃនីតិវិធី។* កាលណាពិនិត្យឃើញមូលហេតុនៃមោឃភាព សភាស៊ើបសួរអាចចាត់ទុកជាមោឃៈដោយឯកឯងនូវនីតិវិធីទាំងមូល ឬផ្នែកណាមួយ។ សភាស៊ើបសួរត្រូវធ្វើដូចដែលមានចែងនៅក្នុង មាត្រា២៨០ (អានុភាពនៃមោឃកម្ម)នៃក្រមនេះ (គូសបញ្ជាក់បន្ថែម)។

បទប្បញ្ញត្តិស្រដៀងគ្នានេះមាននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌក្នុងប្រព័ន្ធដឹកនាំដោយចៅក្រមជាច្រើនទៀត រួមទាំងបារាំង[73]។

៤១. ដោយមិនគិតពីឈ្មោះរបស់វា ជាសភាស៊ើបសួរទីពីរ សភាចោទប្រកាន់ ឬអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះបច្ចុប្បន្ននេះជាយុត្តាធិការចុងក្រោយបង្អស់លើដំណាក់កាលបុរេជំនុំជម្រះនៅ អ.វ.ត.ក។ ទោះបីជា

---

[72] *សូមមើល* ដូចជា ក្រមនីតិវិធីព្រហ្មទណ្ឌ (ក្រមប្រទេស[បារាំង]) មាត្រា ១៩១ (*"Chaque cour d'appel comprend au moins une chambre de l'instruction"*)។ ក្រមនីតិវិធីព្រហ្មទណ្ឌ (ក្រមប្រទេស[អាល់ហ្សេរី]) មាត្រា ១៧៦។ ក្រមនីតិវិធីព្រហ្មទណ្ឌ (ក្រមប្រទេស[អាយវ៉ូរីខូសត៍]) មាត្រា ១៩១។ ក្រមនីតិវិធីព្រហ្មទណ្ឌ (ក្រមប្រទេស[ហ្គីណេ]) មាត្រា ១៩១។ ក្រមនីតិវិធីព្រហ្មទណ្ឌ (ក្រមប្រទេស[ម៉ាដាហ្គាសស្កា]) មាត្រា ៣០ និង ៣០០។ ក្រមនីតិវិធីព្រហ្មទណ្ឌ (ក្រមប្រទេស[ម៉ាលី]) មាត្រា ១៩៦។ ក្រមនីតិវិធីព្រហ្មទណ្ឌ (ក្រមប្រទេស[សេណេហ្គាល់]) មាត្រា ១៨៥។ ក្រមនីតិវិធីព្រហ្មទណ្ឌ (ក្រមប្រទេស[សាធារណរដ្ឋអាហ្វ្រិកកណ្តាល]) មាត្រា ១៣០។

[73] *សូមមើល* ក្រមប្រទេស[បារាំង] មាត្រា ២០៦។ ក្រមប្រទេស[សេណេហ្គាល់] មាត្រា ១៩៩ (*"La chambre d'accusation examine la régularité des procédures qui lui sont soumises"*)។ ក្រមប្រទេស[អាល់ហ្សេរី] មាត្រា ១៩១។ ក្រមប្រទេស[អាយវ៉ូរីខូសត៍] មាត្រា ២០៦។ ក្រមប្រទេស[ហ្គីណេ] មាត្រា ២១១។ ក្រមប្រទេស[ម៉ាលី] មាត្រា ២០៦។ ក្រមស្តីពីកិច្ចស៊ើបសួរផ្នែកព្រហ្មទណ្ឌ (ប្រទេសបែលហ្ស៊ិក) មាត្រា ១៣៦ (*"La chambre des mises en accusation contrôle d'office le cours des instructions, peut demander des rapports sur l'état des affaires et peut prendre connaissance des dossiers"*)។ *សូមមើល ផងដែរ* ក្រមប្រទេស[បារាំង] មាត្រា ២០២ និង ២០៤។ ក្រមប្រទេស[សាធារណរដ្ឋអាហ្វ្រិកកណ្តាល] មាត្រា ១៣៨។ ។ ក្រមប្រទេស[អាល់ហ្សេរី] មាត្រា ១៨៦, ១៩១។ ក្រម[ប្រទេសអាយវ៉ូរីខូសត៍] មាត្រា ២០១ និង ២០២។ ក្រម[ប្រទេសហ្គីណេ] មាត្រា ២០៦ និង ២០៧។ ក្រម[ប្រទេសម៉ាលី] មាត្រា ២០៣។ ក្រម[ប្រទេសម៉ាដាហ្គាសស្កា] មាត្រា ៣១០។

យ៉ាងណាក្តី អង្គជំនុំជម្រះនេះខុសប្លែកមួយចំនួនពីស្ថាប័នពិនិត្យលើបណ្តឹងឧទ្ធរណ៍ដទៃទៀតនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ព្រោះថា ទោះជាអង្គជំនុំជម្រះនេះត្រូវពិនិត្យមើលលើ សេចក្តីសម្រេចនៅដំណាក់កាលជំនុំជម្រះ ដែលរួមមាន សាលក្រមសម្រេចលើពិរុទ្ធភាព ឬនិរទោស និងការផ្តន្ទាទោសក៏ដោយ ក៏អង្គជំនុំជម្រះនេះអាចដំណើរការជាតុលាការស៊ើបសួរទីពីរ[74]។

៤២. ពាក់ព័ន្ធនឹងចំណុចនេះ អង្គបុរេជំនុំជម្រះសូមយោងទៅអ្នកនិពន្ធសំខាន់មួយចំនួនដែលថ្លែងថា៖

> សភាស៊ើបសួរអាចត្រូវបានកំណត់ថាជាសភាសាលាឧទ្ធរណ៍ [...] ដែលមានបេសកកម្មមិនត្រឹមតែដឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់យុត្តាធិការសាលាដំបូងប៉ុណ្ណោះទេ ដែលជា សហចៅក្រមស៊ើបអង្កេត [...] ប៉ុន្តែ ថែមទាំងពិនិត្យមើលជាប្រចាំចំពោះភាពត្រឹមត្រូវនៃការស៊ើបអង្កេត និងកាន់តួនាទីត្រួតពិនិត្យជាមួយចៅក្រមស៊ើបសួរ ដោយសភាស៊ើបសួរអាចធ្វើឧបាស្រ័យដល់កំហុសទាំងឡាយរបស់ចៅក្រមស៊ើបសួរ។ ក្នុងន័យនេះ គេអាចចាត់ទុកថាសភានេះជាជាតុលាការស៊ើបសួរជាន់ខ្ពស់[75]។

៤៣. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា យន្តការត្រួតពិនិត្យដែលអាចប្រៀបធៀបគ្នាបានដទៃទៀត មានអត្ថិភាពនៅក្នុងតុលាការកូនកាត់ផ្សេងៗទៀត ដូចជា Chambre africaine extraordinaire d"accusation អមសាលាឧទ្ធរណ៍របស់ដាកា[76] និង "សភាចោទប្រកាន់ពិសេសរបស់សាធារណរដ្ឋអាហ្វ្រិ

[74] សូមមើល ឧ. ក្រមប្រទេស[ម៉ាដាហ្គាសស្កា] មាត្រា ៣០ La chambre d'accusation de la cour d'appel connat: [d]e l'appel des ordonnances du juge d'instruction [...] [et] est en outre juridiction d'instruction du second degré en matière criminelle"។ ក្រមប្រទេស[អាយវ៉រីខូសត៍] មាត្រា ២០("CCP (Ivory Coast) មាត្រា ២០៦ ("La Chambre d'Accusation examine dans tous les cas, y compris en matière de détention préventive, la régularité des procédures qui lui sont soumises") ស្ថិតក្នុងជំពូក ២ មានចំណងជើងថា "De la Chambre d'accusation : Juridiction d'instruction du second degré"។ សូមមើល ក្រមប្រទេស[បារាំង] មាត្រា ២០១ ("La chambre de l'instruction peut, dans tous les cas, à la demande du procureur général, d'une des parties ou même d'office, ordonner tout acte d'information complémentaire qu'elle juge utile") និងមាត្រា ២០៦ ("la chambre de l'instruction examine la régularité des procédures qui lui sont soumises") ស្ថិតក្នុងជំពូក ២ មានចំណងជើងថា "De la Chambre d" accusation : Juridiction d'instruction du second degré"។

[75] Henri ANGEVIN, Jean-Paul VALAT, "Chambre de l'instruction. – Composition. – Compétence. – Contrôle de l'activité des officiers et agents de police judiciaire", Jurisclasseur Procédure pénale, LexisNexis, ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ("ANGEVIN and VALAT, Chambre de l'instruction. – Composition (៨ វិច្ឆិកា ២០១៨)" កថាខណ្ឌ ១៣ (មានសេចក្តីបញ្ជាក់បន្ថែម)។ Jacques GUYÉNOT, "Le pouvoir de révision et le droit d'évocation de la chambre d'accusation", Revue de sciences criminelles et de Droit pénal comparé, Tome XIX (១៩៦៤) ទំព័រ ៥៥៩-៦០៣ ។

[76] លក្ខន្តិកៈនៃអង្គជំនុំជម្រះវិសាមញ្ញនៅអាហ្វ្រិក នៅក្នុងតុលាការ ប្រទេសសេណេហ្គាល់ បង្កើតឡើងដើម្បីកាត់ទោសបទ

កកណ្តាល [ដែល] ជាផ្នែកមួយនៃតុលាការព្រហ្មទណ្ឌពិសេស ដែលសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាចេញដោយការិយា ល័យស៊ើបសួរ"[77]។ អង្គបុរេជំនុំជម្រះក៏កត់សម្គាល់ផងដែរថា ទោះបីជាវាស្ថិតនៅក្នុងប្រព័ន្ធច្បាប់មួយខុសគ្នាស្រឡះក៏ដោយ ក៏ "អង្គបុរេជំនុំជម្រះរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវបានបង្កើតឡើងក្នុងចំណោមភារកិច្ចផ្សេងៗគឺដើម្បីធ្វើការ ត្រួតពិនិត្យផ្នែកតុលាការ [លើការទទួលខុសត្រូវរបស់រដ្ឋអាជ្ញា] ក្នុងដំណាក់កាលដំបូងនៃកិច្ចនីតិវិធី"[78] ដែលដំណាក់កាលនៃស៊ើបសួរមានដាក់បញ្ចូលនៅក្នុងប្រព័ន្ធនោះ។

៤៤. យោងទៅលើសំអាងហេតុខាងលើ អង្គបុរេជំនុំជម្រះបញ្ជាក់ថា តួនាទីដែលខ្លួនអាចអនុវត្តបាននៅក្នុងប្រព័ន្ធច្បាប់របស់ អ.វ.ត.ក រួមបញ្ចូលទាំងតួនាទីជាសភាស៊ើបសួរ ដែលរួមមានទាំងយុត្តាធិការឧទ្ធរណ៍លើកិច្ចរបស់សហចៅក្រមស៊ើបអង្កេត និងសេចក្តីសម្រេច ព្រមទាំងយុត្តាធិការស៊ើបសួរទីពីរផង[79]។

## ២. សិទ្ធិអំណាចក្នុងការត្រួតពិនិត្យមើលរបស់អង្គបុរេជំនុំជម្រះជាស្ថាប័នស៊ើបសួរទីពីរ

៤៥. អង្គបុរេជំនុំជម្រះបានសង្កត់ធ្ងន់អំពីតម្រូវការដែលខ្លួនត្រូវអនុវត្តជាពិសេសនូវសិទ្ធិអំណាចក្នុងការត្រួតពិនិត្យមើលយ៉ាងទូលំទូលាយនៅក្នុងរឿងក្តីនេះ[80]។ អង្គជំនុំជម្រះកត់សម្គាល់ថា មិនពាក់ព័ន្ធជាមួយនឹងកាលៈទេសៈពិសេសណាមួយឡើយ យុត្តិសាស្ត្ររបស់ខ្លួនពោរពេញទៅដោយឧទាហរណ៍នៃករណីនានា

---

ឧក្រិដ្ឋដែលបានប្រព្រឹត្តនៅ ឆាត ចន្លោះថ្ងៃទី៧ ខែមិថុនា ឆ្នាំ១៩៨២ និងថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៩០ មាត្រា ១១(២)។ *សូមមើល ផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌ (ប្រទេសសេណេហ្គាល់) មាត្រា ១៨៥។

[77] *ច្បាប់លេខ ១៥.០០៣ ស្តីពី* "Création, organisation et fonctionnement de la cour pénale spéciale" ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥, JORCA/ES លេខ ០៥ មាត្រា ១២(១) (បកប្រែក្រៅផ្លូវការ)។ *ច្បាប់លេខ ១៨.០១០ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៨ ស្តីពី* "Règlement de procédure et de preuve devant la cour pénale spéciale de la République centrafrica", (JORCA/ES №5), ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៨ មាត្រា ១០៧A ("*La Chambre d'accusation spéciale statue en Chambre du conseil sur les appels des ordonnances rendues par les Cabinets d'instruction*")។

[78] តុលាការព្រហ្មទណ្ឌអន្តរជាតិ *ស្ថានភាពស្តីពីនាវាដែលបានចុះបញ្ជីរបស់សហភាពកូម៉ូរ៉ូស សាធារណរដ្ឋ* Hellenic *និងព្រះរាជាណាចក្រកម្ពុជា* សំណុំរឿងលេខ ICC-01/13-68 សេចក្តីសម្រេចស្តីពី "ការអនុវត្តសម្រាប់ការត្រួតពិនិត្យឡើងវិញតាមផ្លូវតុលាការ ដោយរដ្ឋាភិបាលនៃសហភាពកូម៉ូរ៉ូស" អង្គបុរេជំនុំជម្រះទី ១ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ កថាខណ្ឌ ៩៣។

[79] Henri ANGEVIN, Jean-Paul VALAT, "*Chambre de l'instruction. – Pouvoirs de la chambre de l'instruction: révision, évocation, annulation. – supplément d'information. – décisions sur le fond*", Jurisclasseur Procédure pénale, LexisNexis ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ ("ANGEVIN និង VALAT *Chambre de l'instruction – pouvoirs de la chambre de l'instruction* (១៥ កុម្ភៈ ២០១៩)") កថាខណ្ឌ ១១២។

[80] សម្រាប់សេចក្តីលម្អិត សូមមើល កថាខណ្ឌ ខាងក្រោម កថាខណ្ឌ ៤៩ ដល់ ៥៤។

ដែលអង្គជំនុំជម្រះ ក៏ដូចស្ថាប័នតុលាការអន្តរជាតិដទៃទៀតដែរ ត្រូវតែអនុវត្តសិទ្ធិអំណាចដែលមិនចាំបាច់ត្រូវបញ្ជាក់ឱ្យបានច្បាស់នោះឡើយ ប៉ុន្តែនៅតែសមិតភាពជាមួយនឹងតួនាទីដែលប្រគល់ឱ្យខ្លួន តាមរយៈអត្ថបទច្បាប់នានារបស់ អ.វ.ត.ក។

៤៦. ហេតុនេះ នៅក្នុងករណីមួយចំនួន អង្គបុរេជំនុំជម្រះបានយល់ឃើញថា "វាមានលក្ខណៈសមស្របក្នុងការអនុវត្តយុត្តាធិការដែលខ្លួនទទួលបាន *ក្នុងនាមជាអង្គជំនុំជម្រះទទួលបណ្តឹងឧទ្ធរណ៍នៅដំណាក់កាលមុនអង្គសេចក្តី និងនៅពេលពុំមានសេចក្តីសម្រេចដាក់លាក់ណាមួយ [...] ដើម្បីជាផលប្រយោជន៍យុត្តិធម៌*"[81] ។ លើសពីនេះទៀត "អង្គបុរេជំនុំជម្រះអាចប្រើយុត្តាធិការដែលខ្លួនទទួលបានទៅតាមករណីនីមួយៗ ក្នុងលក្ខខណ្ឌថា បណ្តឹងឧទ្ធរណ៍មួយ ឬសំណើពាក់ព័ន្ធមួយ មិនត្រឹមតែពាក់ព័ន្ធនឹងបញ្ហាជាសារវ័ន្តប៉ុណ្ណោះទេ ប៉ុន្តែបណ្តឹងឧទ្ធរណ៍ ឬសំណើនោះក៏ត្រូវលើកឡើងបានត្រឹមត្រូវផងដែរ"[82]។ នៅក្នុងករណីដទៃទៀត អង្គបុរេជំនុំជម្រះត្រូវបានស្នើឱ្យបកស្រាយយុត្តាធិការលើបណ្តឹងឧទ្ធរណ៍ផ្អែកលើវិធាន២១ នៃវិធានផ្ទៃក្នុង ដើម្បី "ការពារផលប្រយោជន៍របស់ជនត្រូវចោទ និងធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីដោយយុត្តិធម៌ និងគោរពគោលការណ៍ចំពោះមុខ"[83]។

៤៧. ពាក់ព័ន្ធជាពិសេសទៅនឹងរឿងក្តីចំពោះមុខ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា អំណាចក្នុងការត្រួតពិនិត្យរបស់ខ្លួនជាសភាស៊ើបសួរទីពីរ អាចរួមមាន (i) អំណាចរបស់សភាស៊ើបសួរក្នុងការបោសសម្អាតភាព

---

[81] សំណុំរឿង ០០៤/២ សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អោ អាន (D360/3) កថាខណ្ឌ ៦ (មានសេចក្តីបញ្ជាក់បន្ថែម)។ *សូមមើល ផងដែរ* សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (D308/3/1/20) កថាខណ្ឌ ២៨ ("ក្នុងនាមជាស្ថាប័នដែលត្រួតពិនិត្យនៅដំណាក់កាលស៊ើបអង្កេត អង្គបុរេជំនុំជម្រះយល់ថា ជាការចាំបាច់ដែលត្រូវតែដោះស្រាយ")។

[82] សំណុំរឿង ០០៣ (អង្គបុរេជំនុំជម្រះ០១) សាលដីកាសម្រេចលើសំណើរបស់អង្គភាពគាំពារការពារក្តីសុំផ្អាកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ នៅចំពោះមុខអង្គបុរេជំនុំជម្រះ និងសុំឱ្យចាត់វិធានការទាក់ទងនឹងការធ្វើជាតំណាងប្រកបដោយប្រសិទ្ធិភាពជូនជនសង្ស័យក្នុងករណី ០០៣ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ERN (EN) 00751589-00751596 កថាខណ្ឌ ៩។

[83] សំណុំរឿង ០០៤/១ (អង្គបុរេជំនុំជម្រះ១៨) សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/១ លើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ ឯកសារ D239/1/8 ("សេចក្តីពិចារណាលើដីកាសម្រេចដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* (D239/1/8)") កថាខណ្ឌ ២៣។ សំណុំរឿង ០០៣ (អង្គបុរេជំនុំជម្រះ២១) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ឯកសារ D128/1/9 ("សេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ លើដីកាសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* (D128/1/9)") កថាខណ្ឌ ២៨។

មិនប្រក្រតីនៅក្នុងនីតិវិធីដែលខ្លួនបានទទួលវិនិច្ឆ័យ មុនពេលបញ្ជូនទៅជំនុំជម្រះ[84] (ii) សភាស៊ើបសួរ ឬ អំណាចរបស់អង្គបុរេជំនុំជម្រះរបស់ អ.វ.ត.ក ក្នុងករណីដែលខ្លួនបានទទួលវិនិច្ឆ័យ ដើម្បីពិនិត្យទាំងមូល និងកែសម្រួលរឿងក្តី រួមទាំងការកែតម្រូវកំហុស ក្នុងការកំណត់ប្រភេទនៃបទល្មើសរបស់ចៅក្រមស៊ើបអង្កេត និងកត់សម្គាល់គ្រប់កាលៈទេសៈច្បាប់ទាំងអស់ដែលពាក់ព័ន្ធនឹងអង្គហេតុ[85] និង *(iii) សិទ្ធិក្នុងការពិនិត្យ និងកែតម្រូវការងាររបស់ចៅក្រមស៊ើបអង្កេតនៅក្នុងនីតិវិធីនៃប្រតិបត្តិការចាំបាច់ណាមួយសម្រាប់បម្រើផលប្រយោជន៍នៃការបញ្ជាក់ការពិត*[86]។ អាចនិយាយម្យ៉ាងទៀតថា អំណាចក្នុងការពិនិត្យ អនុញ្ញាតឱ្យសភាស៊ើបសួរបែបនេះ ដោះស្រាយទាំងអស់ទៅលើកិច្ចទាំងឡាយទាក់ទិននឹងរឿងក្តីដែលអយ្យការ ឬចៅក្រមស៊ើបសួរមាន ឬគួរមាន ដើម្បីឱ្យការណែនាំនោះមានលក្ខណៈពេញលេញ និងស្របច្បាប់[87]។

៤៨. ចុងក្រោយ អង្គបុរេជំនុំជម្រះបញ្ជាក់ថា នៅពេលខ្លួនទទួលនីតិវិធីស៊ើបសួរចុងក្រោយ "យុត្តាធិការលើរឿងក្តីរបស់សភាស៊ើបសួរ មានលក្ខណៈទូទៅ មិនមែនមានលក្ខណៈជាក់លាក់ទេ។ រឿង ក្តីទាំងមូលត្រូវបានយោងដល់យុត្តាធិការនេះ មិនមែនត្រឹមតែផ្នែកនៃសេចក្តីសម្រេចនៃដីកានោះទេ"[88]។ ជាលទ្ធផល សភាស៊ើបសួរមានអំណាចពិនិត្យមួយ ដែលអនុញ្ញាតឱ្យខ្លួនបំពេញកិច្ចស៊ើបសួរតាមរយៈកិច្ចស៊ើបសួរបន្ថែម[89] និងដើម្បីវាយតម្លៃពីនិយ័តភាពនៃនីតិវិធី[90] នៅពេលកាលៈទេសៈតម្រូវ។ យោងតាមហេតុផល

---

[84] GUYÉNOT, *Le pouvoir de révision et le droit d'évocation de la chambre d'accusation* (ឆ្នាំ១៩៦៤) កថាខណ្ឌ ៣។

[85] GUYÉNOT, *Le pouvoir de révision et le droit d'évocation de la chambre d'accusation* (ឆ្នាំ១៩៦៤) កថាខណ្ឌ ៣។

[86] Frédéric DESPORTES, Laurence LAZERGES, *Traité de procédure pénale* ( Economica, Corpus, បោះពុម្ពលើកទី៣ ឆ្នាំ២០១៣) ("DESPORTES និង LAZERGES, Traité de procédure pénale (២០១៣)") កថាខណ្ឌ ២១៤៤ (មានសេចក្តីបញ្ជាក់បន្ថែម) ។

[87] GUYÉNOT, *Le pouvoir de révision et le droit d'évocation de la chambre d'accusation* (១៩៦៤) កថាខណ្ឌ ៣។ *សូមមើល ផងដែរ* Roger MERLE, André VITU, *Traité de droit criminel,* (Cujas, បោះពុម្ពលើកទី៥ ឆ្នាំ២០១៣) កថាខណ្ឌ ៥៦៩។

[88] Christian GUÉRY, *"Effet dévolutif de l'appel et manifestation de la vérité : du prétendu pouvoir de révision de la chambre de l'instruction"*, Droit pénal n° 5 (étude 8), LexisNexis ខែឧសភា ឆ្នាំ២០១៤ កថាខណ្ឌ ៣ (បកប្រែក្រៅផ្លូវការ)។

[89] ANGEVIN និង VALAT, *Chambre de l'instruction – pouvoirs de la chambre de l'instruction* (ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០១៩) កថាខណ្ឌ ១៣៩។

[90] ANGEVIN និង VALAT, *Chambre de l'instruction – pouvoirs de la chambre de l'instruction* (ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០១៩) កថាខណ្ឌ ៤ (មានសេចក្តីបញ្ជាក់បន្ថែម)។ DESPORTES and LAZERGES, Traité de procédure pénale (ឆ្នាំ ២០១៣) កថាខណ្ឌ ២១៤៥។ GUÉRY, *Les pouvoirs de la chambre de l'instruction et la liberté du magistrat*

ដែលបានផ្តល់ជូននៅក្នុងជំពូកដាច់ដោយឡែកមួយ[91] អង្គបុរេជំនុំជម្រះយល់ឃើញថា កាលៈទេសៈចាំបាច់មានអត្ថិភាពនៅក្នុងរឿងក្តីចំពោះមុខនេះ។

### ៣. វិសាលភាពនៃសិទ្ធិអំណាចក្នុងការត្រួតពិនិត្យរបស់អង្គបុរេជំនុំជម្រះនៅក្នុងរឿងក្តីបច្ចុប្បន្ននេះ

៤៩. អង្គបុរេជំនុំជម្រះរម្លឹកថា អង្គបុរេជំនុំជម្រះបានលើកឡើងពីមុនថា "ឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតក្នុងការកំណត់ [លើយុត្តាធិការបុគ្គល] នេះ គឺជាឆន្ទានុសិទ្ធិតុលាការ និងមិនអនុញ្ញាតឱ្យបំពេញកិច្ចតាមអំពើចិត្តទេ តែត្រូវអនុវត្តទៅតាមគោលការណ៍ច្បាប់ដែលមានច្បាស់លាស់"[92]។ នៅពេលដែលអង្គបុរេជំនុំជម្រះពិនិត្យលើនីត្យានុកូលភាពនៃនីតិវិធីពាក់ព័ន្ធដែលខ្លួនបានទទួល អង្គបុរេជំនុំជម្រះមានបំណងធ្វើឱ្យមានតុល្យភាពរវាងកម្រិតខ្ពស់នៃឆន្ទានុសិទ្ធិដែលច្បាប់បានផ្តល់ឱ្យសហចៅក្រមស៊ើបអង្កេត និងយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ[93]។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា នៅពេលខ្លួនដើរតួនាទីជាសភាស៊ើបសួររបស់ អ.វ.ត.ក និង ខ្លួនអនុវត្តអំណាចចុងក្រោយនៅដំណាក់កាលស៊ើបសួរ។ ដូច្នេះ អង្គជំនុំជម្រះសូមរម្លឹកថា គោលបំណងមួយក្នុងចំណោមគោលបំណងសំខាន់នានារបស់អង្គបុរេជំនុំជម្រះ គឺវាយតម្លៃទៅលើដំណាក់កាលស៊ើបសួរទាំងមូល និងចេញសេចក្តីសម្រេចចុងក្រោយពាក់ព័ន្ធនឹងបញ្ហានេះ[94]។ អង្គបុរេជំនុំជម្រះមានយុត្តាធិការសំខាន់ទូលំទូលាយទៅលើបញ្ហានានាដែលខ្លួនអាចទទួលយកមកពិនិត្យ និងមានសិទ្ធិអំណាចទូលំទូលាយក្នុងការវាយតម្លៃទៅលើសុចរិតភាពនៃកិច្ចស៊ើបសួរ និងអង្គសេចក្តីនៃរឿងក្តី ដើម្បីធានានូវគោលការណ៍អនាគតិ[95]។

---

*instructeur* (ឆ្នាំ២០០៧) ទំព័រ ៦០៣-៦០៧។

[91] សូមមើល កថាខណ្ឌខាងលើ កថាខណ្ឌ ៣១ ដល់ ៥៤។

[92] សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D308/3/1/20) កថាខណ្ឌ ២០។

[93] *សូមមើល ឧ.* សំណុំរឿង ០០៤ (អង្គបុរេជំនុំជម្រះ២៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹងការផ្តល់សក្ខីកម្មនៅពេលជំនុំជម្រះ នៅក្នុងសវនាការអសាធារណៈ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦ ឯកសារក D309/6 ថាខណ្ឌ ១៩-២០។ សំណុំរឿង ០០៤ សាលដីកាលើសំណើរបស់ យឹម ទិត្យ សុំធ្វើមោឃភាពឯកសារស៊ើបអង្កេតដែលធ្វើឡើងដោយ PAOLO STOCCHI ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ ឯកសារក D351/1/4 កថាខណ្ឌ ១៣។

[94] GUYÉNOT, *Le pouvoir de révision et le droit d'évocation de la chambre d'accusation* (ឆ្នាំ១៩៦៤) កថាខណ្ឌ ២, ៩, ៣៥។

[95] សាលាឧក្រិដ្ឋប្រទេសបារាំង ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥ សំណុំរឿងលេខ 15-84.671។

៥០. អង្គបុរេជំនុំជម្រះពិចារណាឃើញថា ការអនុវត្តអំណាចត្រួតពិនិត្យរបស់ខ្លួនជាសភាស៊ើបសួរ ពិតជាមានគោលបំណងសំខាន់ ក្នុងការធានាថា លក្ខខណ្ឌនៃការចេញដីកាដំណោះស្រាយ និងការស៊ើបអង្កេតជាបឋម អនុលោមតាមវិធាន២១ និងវិធាន ៧៦ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក និងមាត្រា ២៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ ហេតុដូច្នេះ នៅក្នុងបណ្តឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងដីកាដំណោះស្រាយ មានបញ្ហាបឋមជាច្រើនដែលអង្គបុរេជំនុំជម្រះអាចចាំបាច់ត្រូវពិចារណាមុនពេលដោះស្រាយលើអង្គសេចក្តីនៃសារណារបស់ភាគី ក្នុងនោះរួមទាំងអ្វីដែលអង្គបុរេជំនុំជម្រះបានកំណត់ប៉ុន្មានឆ្នាំមុនថាជាបញ្ហាដែលមានសារសំខាន់ជាទូទៅសម្រាប់យុត្តិសាស្ត្រនិងកេរដំណែលរបស់ អ.វ.ត.ក និង/ឬ អំណាចឥស្សរចិត្តរបស់ខ្លួននៅពេលពិចារណាលើដីកាដំណោះស្រាយ។

៥១. ពាក់ព័ន្ធនឹងបញ្ហានេះ ក្រៅពីការរួមចំណែកជាក់លាក់ដែលមានចែងនៅក្នុងវិធាន ៧១-៧៨ នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះក៏ត្រូវធានាថា “ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព”[96]គ្រប់ពេលក្នុងដំណាក់កាលនៅមុនពេលជំនុំជម្រះ។ ហេតុដូចនេះ អង្គជំនុំជម្រះមានយុត្តាធិការជាមូលដ្ឋានក្នុងការពិនិត្យទៅលើ “ការយកចិត្តទុកដាក់ត្រឹមត្រូវដែលត្រូវបានបង្ហាញឲ្យឃើញនៅក្នុងការប្រព្រឹត្តិរបស់សហចៅក្រមស៊ើបអង្កេត” ដែលបង្កើតបានជា “កត្តាពាក់ព័ន្ធនៅពេលដែលធ្វើការពិចារណានៅលើសិទ្ធិរបស់ជនរងគ្រោះនៅក្នុងដំណើរការនីតិវិធី”[97]។ អង្គជំនុំជម្រះក៏មានយុត្តាធិការជាមូលដ្ឋាន “ដើម្បីសម្រេចអំពីបញ្ហាបន្ទាប់បន្សំដែលកើតឡើងដោយសារតែផលវិបាកផ្ទាល់នៃនីតិវិធីដែលត្រូវបានប្តឹងមកខ្លួន” ក្នុងករណីដែលបញ្ញត្តិច្បាប់ពុំចែងច្បាស់ ឬយោងទៅលើសិទ្ធិអំណាចក្នុងការសម្រេច

---

[96] វិធាន ២១(១) នៃវិធានផ្ទៃក្នុង។

[97] សំណុំរឿង ០០៣ (អង្គបុរេជំនុំជម្រះ០១) សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សេង ចាន់ធារី ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ D11/1/4/2 (មតិយោបល់របស់លោកចៅក្រម DOWNING និងលោកស្រីចៅក្រម LAHUIS) កថាខណ្ឌ ៦។

លើបញ្ហាមួយ[98]។ យុត្តាធិការជាមូលដ្ឋានបែបនេះត្រូវចាត់ទុកថាចាំបាច់ដោយសារតែតម្រូវការចាំបាច់ក្នុងការធានាឱ្យបាននូវកិច្ចការរដ្ឋបាលតុលាការដែលល្អ និងមានយុត្តិធម៌[99]។

៥២. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា អំណាចរបស់អង្គជំនុំជម្រះក្នុងការត្រួតពិនិត្យអាចត្រូវយល់បាននៅក្នុងវិធាន៧៦(៧)នៃវិធានផ្ទៃក្នុង ដែលចែងថា "លើកលែងតែជាកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍ ដីកាដំណោះស្រាយត្រូវកែតម្រូវកំហុសនៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបសួរ"។ អំណាចត្រួតពិនិត្យនេះមានសារៈសំខាន់ណាស់ និងកំណត់ច្បាស់ថា "គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធីបែបនេះ អាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលឡើយ"។ ជាលទ្ធផល អង្គបុរេជំនុំជម្រះទទួលខុសត្រូវក្នុងការធានានៅក្នុងដំណាក់កាលស៊ើបសួរថា គោលការណ៍ជាសារវ័ន្តដែលជាមូលដ្ឋាននៃនីតិវិធីព្រហ្មទណ្ឌជាធរមាននៅចំពោះមុខ អ.វ.ត.ក ត្រូវបានគោរព។

៥៣. អង្គបុរេជំនុំជម្រះបញ្ជាក់ថា អង្គជំនុំជម្រះតែងតែមានការប្រុងប្រយ័ត្នខ្ពស់បំផុតនៅក្នុងដំណាក់កាលស៊ើបសួរចុងក្រោយ ដែលត្រូវមានអន្តរាគមន៍ពីយុត្តាធិការរបស់ខ្លួន។ ទោះជាយ៉ាងណាក្តី ដូចក្នុងសំណុំរឿង ០០៤/០១ ដែរ អង្គបុរេជំនុំជម្រះត្រូវតែដោះស្រាយបញ្ហាដែលមិនមានពីមុនមកជាច្រើននៅក្នុងសំណុំរឿង ០០៤/២ រួមទាំងបញ្ហាបច្ចុប្បន្ននេះ ពាក់ព័ន្ធនឹងសិទ្ធិអំណាចយុត្តាធិការរបស់អង្គបុរេជំនុំជម្រះដែលត្រូវបានបញ្ជាក់ជាថ្មីឡើងវិញ និងបញ្ជាក់បំភ្លឺនៅត្រង់ចំណុចនេះ។

៥៤. អង្គបុរេជំនុំជម្រះបញ្ជាក់ថា អង្គជំនុំជម្រះ តាមតួនាទីផ្លូវច្បាប់ដែលខ្លួនមាន បានព្យាយាមផ្តល់សច្ចភាពផ្លូវច្បាប់ និងយុត្តិធម៌នៅក្នុងករណីទាំងឡាយដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដាកទៅរកការបកស្រាយច្បាប់ជាធរមានទៅតាមការពេញចិត្តនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន[100] ដែលធ្វើឱ្យមានការបន្តព្យាយាមពង្រីកមិនសមហេតុផលនូវវិសាលភាពនៃអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន និងជំទាស់ទៅនឹងតួនាទី

---

[98] សំណុំរឿង ០០៣ (អង្គបុរេជំនុំជម្រះ២៧) សេចក្តីសម្រេចលើសំណើរបស់ មាស មុត សុំឱ្យអង្គបុរេជំនុំជម្រះបកស្រាយទូលាយអំពីវិសាលភាពដែលអាចអនុញ្ញាតបាននៃបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ និងបញ្ជាក់បំភ្លឺអំពីនីតិវិធីមោឃភាពដីកាដំណោះស្រាយ ឬ ផ្នែកនានានៃដីកាដំណោះស្រាយ ប្រសិនបើចាំបាច់ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ឯកសារ D158/1 កថាខណ្ឌ ១១។ *សូមមើល ផងដែរ* សំណុំរឿង ០០៣ (អង្គបុរេជំនុំជម្រះ១១) សេចក្តីសម្រេចលើសំណើសុំឱ្យផ្អាកការអនុវត្តដីកាសម្រេចឱ្យតែងតាំងមេធាវីបណ្តោះអាសន្នសំរាប់លោក មាស មុត ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤ ឯកសារ D56/19/14 កថាខណ្ឌ ១៦។ ដីកាសម្រេចព្យួរការអនុវត្ត (D14/1/2) កថាខណ្ឌ ៥។

[99] ដីកាសម្រេចព្យួរការអនុវត្ត (D14/1/2) កថាខណ្ឌ ៥។

[100] *សូមមើល ឧ.* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D360 កថាខណ្ឌ ២៩-៣០។

របស់អង្គបុរេជំនុំជម្រះជាស្ថាប័នត្រួតពិនិត្យនៅក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍ នៅដំណាក់កាលបុរេជំនុំជម្រះ។ អង្គជំនុំជម្រះពិចារណា *ក្នុងចំណោមប្រការផ្សេងទៀត* ថា ការធ្វើបែបនេះបង្ហាញអំពីការរំលោភជាក់ស្តែង លើមាត្រា ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ និងប្រយ័ត្នប្រយែងពីសំណាក់ចៅក្រមស៊ើបអង្កេតដែលមានហេតុផល។ ដូចបានពិភាក្សានៅក្នុងជំពូកមួយផ្សេងទៀត[101] ការជំទាស់របស់សហចៅក្រមស៊ើបអង្កេតទៅនឹងសិទ្ធិអំណាចរបស់អង្គបុរេជំនុំជម្រះ បានបណ្តាលឱ្យរឿងក្តីនេះមានលទ្ធផលដែលមិនធ្លាប់មានពីមុនមក គឺការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា និងដាច់ដោយឡែកពីគ្នា ដែលរំលោភទាំងស្រុងទៅលើមូលដ្ឋានតែមួយគត់នៃក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក[102]។

## ខ. ឋានៈរបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា

៥៥. នៅក្នុងដីកាដំណោះស្រាយនីមួយៗ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានគូសបញ្ជាក់អំពីការយល់ឃើញមុនៗរបស់អង្គបុរេជំនុំជម្រះថា តុលាការធម្មតារបស់កម្ពុជានៅតែមានយុត្តាធិការលើឧក្រិដ្ឋកម្មកើតឡើងក្នុងសម័យខ្មែរក្រហមដែលពុំអាចយកមកជំនុំជម្រះបាននៅចំពោះមុខ អ.វ.ត.ក[103] ចំណែកសហចៅក្រមស៊ើបអង្កេតជាតិបានអះអាងថា ច្បាប់ អ.វ.ត.ក មិនរាប់បញ្ចូលយុត្តាធិការបុគ្គល ឬ យុត្តាធិការលើរឿងក្តីរបស់តុលាការធម្មតារបស់កម្ពុជា ទៅលើឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តឡើងនៅក្រោមយុត្តាធិការ

---

[101] សូមមើល ខាងក្រោម កថាខណ្ឌ៨៨ ដល់ ១២៥។

[102] ក្រៅពីឧទាហរណ៍ដ៏សំខាន់នេះអំពីការអនុវត្តមិនត្រឹមត្រូវរបស់សហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះក៏កត់សម្គាល់ផងដែរ តាមរយៈការបង្ហាញឱ្យឃើញ អំពីសេចក្តីសម្រេចមួយក្នុងចំណោមសេចក្តីសម្រេចជាច្រើនរបស់សហចៅក្រមស៊ើបអង្កេតដែលចោទជាបញ្ហាផ្លូវច្បាប់យ៉ាងខ្លាំង ពោលគឺ ការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអំពីលទ្ធភាពនៃការចេញដីកាសម្រេចផ្អាកការស៊ើបអង្កេតជាអចិន្ត្រៃយ៍ និងការទប់ស្កាត់ការបើកកិច្ចស៊ើបសួរណាមួយឡើងវិញ ដោយសារតែបញ្ហាថវិកា គឺស្មើនឹងជូនដំណឹងអំពីការបដិសេធដែលអាចធ្វើទៅបាន ដោយសារតែមូលហេតុថវិកា ដែលជាការរំលោភលើវិធានផ្ទៃក្នុង ៦៧ (៣) (*សូមមើល* សំណុំរឿង ០០៣ ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ ឯកសារ D249/6 កថាខណ្ឌ ៦៩, ៨០)។

[103] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៣៤ *ដែលយោងទៅ* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/០១ (ឯកសារ D308/3/1/20) ទំព័រ ៣៨-៣៩។

ពេលវេលារបស់ អ.វ.ត.ក ឡើយ[104]។ ក្នុងនាមជាអង្គជំនុំជម្រះពិនិត្យលើបណ្ដឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះយល់ឃើញថាចាំបាច់ត្រូវដោះស្រាយចំពោះការយល់ឃើញផ្ទុយគ្នាទាំងនេះ។

៥៦. ចំពោះរឿងក្ដីទាំងឡាយ ដែល អ.វ.ត.ក បានទទួលរួចហើយនោះ អង្គបុរេជំនុំជម្រះសូមរំលឹកថា ពុំមានការចែងទុកជាមុនឡើយនៅក្នុងច្បាប់ជាធរមាន អំពីនីតិវិធីបញ្ជូនរឿងក្ដី។ រឿងក្ដីទាំងនោះ មិនអាចបញ្ជូនទៅតុលាការជាតិបានឡើយ[105]។ មានការបញ្ជាក់យ៉ាងច្បាស់តាំងពីឆ្នាំ២០០៩ មកម្ល៉េះថា ពុំមានការចោទប្រកាន់បន្ថែមទៀតឡើយ ក្រោយពីបញ្ចប់រឿងក្ដីទាំងបួនដែល អ.វ.ត.ក បានទទួលរួចហើយនោះ[106]។

៥៧. ពាក់ព័ន្ធនឹងរឿងក្ដីផ្សេងទៀត អង្គបុរេជំនុំជម្រះយល់ឃើញថា កម្ពុជាមានយុត្តាធិការឥស្សរចិត្តទៅលើរឿងក្ដីទាំងអស់ក្នុងសម័យខ្មែរក្រហម ដែល អ.វ.ត.ក មិនបានទទួល។ នៅមុនពេលបង្កើត អ.វ.ត.ក រាជរដ្ឋាភិបាលកម្ពុជាមិនត្រឹមតែមានជម្រើសដោយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានកាតព្វកិច្ចផងដែរតាមច្បាប់អន្តរជាតិ ក្នុងការចោទប្រកាន់មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ឬ អ្នកទាំងឡាយដែលត្រូវបានចោទប្រកាន់ថាទទួលខុសត្រូវខ្ពស់បំផុតចំពោះបទល្មើសអន្តរជាតិ ដែលនេះគឺជាការអនុវត្តយុត្តាធិការមូលដ្ឋានរបស់ខ្លួន។ តាមពិតទៅ នៅពេល អ.វ.ត.ក ចាប់បដិសន្ធិឡើងនោះ តុលាការកម្ពុជា កំពុងដំណើរការជំនុំជម្រះបុគ្គលមួយចំនួន ដែលបានបំពេញ (ឬ អាចបំពេញបាន) លក្ខខណ្ឌតម្រូវសម្រាប់យុត្តាធិការបុគ្គលនៅ អ.វ.ត.ក[107]។

៥៨. យោងតាមកិច្ចព្រមព្រៀងជាមួយអង្គការសហប្រជាជាតិ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើត អ.វ.ត.ក ជាតុលាការពិសេសនៅក្នុងប្រព័ន្ធតុលាការកម្ពុជាដែលមានស្រាប់[108] ហើយបានប្រគល់យុត្តាធិការជូន

---

[104] ដីកាដំណោះស្រាយ (ដីកាលើកលែងការចោទប្រកាន់) (D359) កថាខណ្ឌ ៤៣៤-៤៤៩ *ជាពិសេស* កថាខណ្ឌ ៤៤៧។

[105] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង 00៤/0១ (ឯកសារ D308/3/1/20) ទំព័រ ៧៤ *ដែលយោងទៅ* សំណុំរឿង ០០១ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងការឃុំខ្លួនបណ្ដោះអាសន្ន ឯកសារ C5/45 កថាខណ្ឌ ១៧។ សាលដីកាលើសំណុំរឿង ០០១ (ឯកសារ F28) កថាខណ្ឌ ៧១។

[106] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង 00៤/0១ (ឯកសារ D308/3/1/20) ទំព័រ ៧៤ *ដែលយោងទៅ* សេចក្ដីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្ដីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិស្ដីទី៖ សេចក្ដីសន្និដ្ឋានអំពីដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីចំនួនពីរ" ចុះថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ២០០៩។

[107] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង 00៤/0១ (ឯកសារ D308/3/1/20) ទំព័រ ៧៥។

[108] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង 00៤/0១ (ឯកសារ D308/3/1/20) កថាខណ្ឌ ៧៦ *ដែលយោងទៅ* ច្បាប់ អ.វ.ត.ក មាត្រា ២ថ្មី។ កិច្ចព្រមព្រៀង អ.វ.ត.ក បុព្វកថា កថាខណ្ឌ ៤។

ទៅ អ.វ.ត.ក ធ្វើការជំនុំជម្រះទៅលើមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត[109]។ មាត្រា ១ និងមាត្រា ២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ដែលដូចគ្នានឹងមាត្រា ១ និងមាត្រា ២*ថ្មី* នៃច្បាប់ អ.វ.ត.ក កម្រិតយ៉ាងច្បាស់នូវយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ត្រឹមតែមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មមួយចំនួនដែលបានប្រព្រឹត្តឡើងនៅក្នុងសម័យខ្មែរក្រហម។ នៅក្នុងច្បាប់ជាធរមាន មិនមានចែងថា អ.វ.ត.ក មានយុត្តាធិការផ្តាច់មុខទៅលើរឿងក្តីផ្សេងទៀតក្នុងសម័យខ្មែរក្រហមនោះឡើយ។ ការពិនិត្យយ៉ាងល្អិតល្អន់ទៅលើកំណត់ត្រាដែលមានស្រាប់អំពីប្រវត្តិនៃការចរចា គាំទ្រដល់ការសន្និដ្ឋានដែលថា អ.វ.ត.ក ពុំបានដកហូតចេញពីតុលាការជាតិ នូវយុត្តាធិការទៅលើរឿងក្តីក្នុងរបបខ្មែរក្រហមនោះឡើយ[110]។ ការកម្រិតយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក មិនអាចបកស្រាយ

---

[109] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/០១ (ឯកសារ D308/3/1/20) កថាខណ្ឌ ៧៥ *ដែលយោងទៅ* សាលដីកាក្នុងសំណុំរឿង ០០២ ស្តីពីបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) (ឯកសារ D427/2/15 និងឯកសារ D427/3/15) កថាខណ្ឌ ១០៣។

[110] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/០១ (ឯកសារ D308/3/1/20) កថាខណ្ឌ ៧៧។ រាជរដ្ឋាភិបាលកម្ពុជាបានពិចារណាឃើញថា វេទិកាសមស្របសម្រាប់ជំនុំជម្រះប្រភេទចារីកម្រិតខ្ពស់ដែលមានចំនួនកំណត់នោះ គឺតាមរយៈតុលាការពិសេសមួយក្រោមការជួយជ្រោមជ្រែងពីសហគមន៍អន្តរជាតិ ដែលមានសមាសភាពអន្តរជាតិចូលរួម និងអាណត្តិការងារមានកម្រិត ដោយសារពាក់ព័ន្ធនឹងសមត្ថភាព ធម្មានុរូប និងកេរ្តិ៍ដំណែល។ *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/០១ (ឯកសារ D308/3/1/20) កថាខណ្ឌ ៧៨ *ដែលយោងទៅ* "ការជជែកពិភាក្សា និងការឯកភាពលើវិសោធនកម្មរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំង ការជជែក និងការឯកភាពលើវិសោធនកម្មច្បាប់ស្តីពីការកាត់ទោសមេដឹកនាំខ្មែរក្រហម" សម័យប្រជុំលើកទី១ នៃរដ្ឋសភាអាណត្តិទី ៣ ថ្ងៃទី៤-៥ ខែតុលា ឆ្នាំ២០០៤ ប្រតិចារឹកមួយផ្នែកបានបោះពុម្ពផ្សាយនៅក្នុង*ការស្វែងរកការពិត (ទស្សនាវដ្តីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា)* លេខពិសេស សំណៅភាសាអង់គ្លេស (ត្រីមាសទី៤ ឆ្នាំ២០០៤) ("ការជជែកពិភាក្សានៅរដ្ឋសភាជាតិកម្ពុជា") ទំព័រ ២៨-៣០, ៣១-៣៤, ៤៥-៤៦, ៤៨។ រាជរដ្ឋាភិបាលកម្ពុជា *សេចក្តីថ្លែងការណ៍អំពីការជម្រុញទឹកចិត្តឱ្យបង្កើតសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជានៅក្នុងតុលាការជាតិដែលមានស្រាប់ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ* សេចក្តីថ្លែងការណ៍លេខ ០១ SCN.KBC ថ្ងៃទី១៨ ខែមករា ឆ្នាំ២០០១ [កម្រងច្បាប់ អ.វ.ត.ក] ទំព័រ ៣។ ក្រុមប្រឹក្សាធម្មនុញ្ញ *សេចក្តីសម្រេចលេខ ០៤០/០០២/២០០១* (ស្តីពីច្បាប់ អ.វ.ត.ក) ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១ [កម្រងច្បាប់ អ.វ.ត.ក] ទំព័រ ៣។ រាជរដ្ឋាភិបាលកម្ពុជា *សេចក្តីថ្លែងការណ៍អំពីការជម្រុញទឹកចិត្តលើសេចក្តីព្រាងច្បាប់ស្តីពីការព្រមព្រៀងបង្កើតកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹងការកាត់សេចក្តីក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ* សេចក្តីថ្លែងការណ៍លេខ ៣៨ SCN.KBT ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៣ [កម្រងច្បាប់ អ.វ.ត.ក] ទំព័រ ១។ សំណុំរឿង ០០៤/០១ សេចក្តីថ្លែងការណ៍របស់សាស្ត្រាចារ្យ SCHEFFER ឧបសម្ព័ន្ធ ក នៃសេចក្តីសន្និដ្ឋានរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីតួនាទីរបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ

ថាជាការផ្ទុះបញ្ចាំងអំពីចេតនារបស់អ្នកធ្វើសេចក្ដីព្រាងច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង អ.វ.ត.ក ដែលថា ចារីផ្សេងទៀតអាចរួចផុតពីសំណាញ់យុត្តិធម៌នោះឡើយ[111]។

៥៩. យោងតាមសំអាងហេតុខាងលើ អង្គបុរេជំនុំជម្រះសូមបញ្ជាក់ឡើងវិញអំពីការយល់ឃើញជា ឯកច្ឆ័ន្ទរបស់ខ្លួន នៅក្នុងសំណុំរឿង ០០៤/០១ ថា ច្បាប់ជាធរមានរបស់ អ.វ.ត.ក ពុំបានរាំងយុត្តាធិការជាតិ ហើយតុលាការធម្មតារបស់កម្ពុជា មានយុត្តាធិការពេញលេញជាមូលដ្ឋាន ទៅលើបញ្ហាយុត្តិធម៌ព្រហ្មទណ្ឌ។

## គ. ការពន្យាពេលហួសហេតុនៅក្នុងការចេញដីកាដំណោះស្រាយ

៦០. អង្គបុរេជំនុំជម្រះពិចារណាឃើញថា នៅក្នុងដីកាដំណោះស្រាយរបស់គាត់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានព្យាយាមគេចចេញពីការត្រួតពិនិត្យតាមផ្លូវតុលាការរបស់អង្គបុរេជំនុំជម្រះ ដោយបានលើកឡើងមិនត្រឹមត្រូវអំពីគោលការណ៍ជាមូលដ្ឋានដែលអង្គបុរេជំនុំជម្រះបានរម្លឹក[112]។

៦១. អង្គបុរេជំនុំជម្រះសូមរម្លឹកថា វិធាន ២១(៤) ចែងថា ការចោទប្រកាន់ត្រូវធ្វើឡើង "ក្នុងរយៈពេល

D30//3/1/9.2 កថាខណ្ឌ ៨-៩។ SCHEFFER "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" (ឆ្នាំ២០០៨) ទំព័រ ២៤០។

[111] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/០១ (ឯកសារ D308/3/1/20) ទំព័រ ៧៨ *ដែលយោងទៅលើ* ឯកអគ្គរដ្ឋទូត Thomas HAMMARBERG "តើសាលាក្ដីខ្មែរក្រហមបានព្រមព្រៀងគ្នាតាមនីតិវិធីណា៖ កិច្ចពិភាក្សារវាងរាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប" *ស្វែងរកការពិត* (ទស្សនាវដ្ដី *មជ្ឈមណ្ឌលឯកសារកម្ពុជា*) លេខ ២១ (ខែកញ្ញា ឆ្នាំ២០០១) ទំព័រ ៣៧។ ការជជែកគ្នានៅចំពោះមុខរដ្ឋសភាជាតិកម្ពុជាបានលើកឡើងថា ភាគីចរចាមានបំណងបញ្ចូលករណីពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនាសម័យខ្មែរក្រហម ដែលបានប្រព្រឹត្តឡើងដោយអ្នកដែលពុំមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ទៅក្នុងយុត្តាធិការនៃតុលាការជាតិ។ *សូមមើល ខ២. ការជជែកពិភាក្សារបស់សភាជាតិកម្ពុជា* ទំព័រ ៣៧។

[112] សូមមើល សំណុំរឿង ០០៤/១ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ឯកសារ D308/3/1/20 កថាខណ្ឌ ២៨-៣១។ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D360 កថាខណ្ឌ ១៨ (ជាពិសេស អង្គជំនុំជម្រះកត់សម្គាល់ទៅលើសេចក្ដីថ្លែងរបស់គាត់ថា "អ.ប.ជ ឯកសារ បានចោទថា ស.ច.ស បានរំលោភលើមាត្រា ៣៥ ថ្មី នៃច្បាប់ អ.វ.ត.ក និងវិធាន ២១(៤)")។ អង្គបុរេជំនុំជម្រះយល់ឃើញថា ការប្រើប្រាស់ពាក្យ "បានចោទប្រកាន់" របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពុំត្រឹមត្រូវទាំងខាងផ្នែកអង្គហេតុ ពីព្រោះអង្គជំនុំជម្រះ នៅក្នុងការសម្រេចរបស់ខ្លួន ពុំបានចោទប្រកាន់សហចៅក្រមស៊ើបអង្កេតនោះទេតែផ្ទុយទៅវិញបានវាយតម្លៃតាមផ្លូវតុលាការពីគុណភាពនៃនីតិវិធីដែល ស.ច.ស បានបំពេញ ហើយពុំសមស្របខាងផ្នែកអង្គច្បាប់ទេ ពីព្រោះសហចៅក្រមស៊ើបអង្កេតគួរតែប្រើពាក្យពេចន៍នេះឲ្យបានត្រឹមត្រូវសម្រាប់ការវាយតម្លៃរបស់គាត់អនុលោមតាមវិធាន ៦៧។

មួយសមស្រប"។ អង្គបុរេជំនុំជម្រះ ដែលជាតុលាការត្រួតពិនិត្យនៅដំណាក់កាលស៊ើបអង្កេត [113] យល់ឃើញថា ទោះបីជាវិធានផ្ទៃក្នុងពុំបានចែងឲ្យបានច្បាស់លាស់អំពីពេលវេលាកំណត់ សម្រាប់ការចេញដីកាដំណោះស្រាយក្តី ក៏សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចចេញដីកាដំណោះស្រាយក្នុងរយៈពេលមួយសមស្រប ដោយសារតែ គោលការណ៍នេះ រួមទាំងផ្នែកពាក់ព័ន្ធរបស់វានៅក្នុងមាត្រា ៣៥ ថ្មី នៃច្បាប់ អ.វ.ត.ក គឺជាគោលការណ៍មូលដ្ឋានដែលមានចែងក្នុងមាត្រា ១៤(៣)(គ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR")[114]។

៦២. ក្នុងករណីបច្ចុប្បន្ននេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតខកខានពុំបានចេញដីកាដំណោះស្រាយក្នុងរយៈពេលមួយសមស្របនោះទេ។

៦៣. ក្នុងករណីផ្សេងមួយទៀត [115] អង្គបុរេជំនុំជម្រះបានបញ្ជាក់ពីមុនរួចមកហើយអំពីសិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន ដោយរម្លឹកថា អនុលោមតាមវិធាន ៦៦(១) កាលបរិច្ឆេទកំណត់រយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃក្នុងការធ្វើសំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែម គិតរាប់ក្រោយពេលមាន "ការជូនដំណឹង អំពីការបញ្ចប់កិច្ចស៊ើបសួរ មិនថា សេចក្តីជូនដំណឹងនោះជាសេចក្តីជូនដំណឹង "លើកទីមួយ" ឬ "លើកទីពីរ" ដែលបានចេញក្រោយពេលបញ្ចប់កិច្ចស៊ើបសួរបន្ថែមនោះទេ[116]។

៦៤. អង្គបុរេជំនុំជម្រះ កត់សម្គាល់សេចក្តីប្រកាសរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅលេខជើងទំព័រយោងមួយនៃដីកាដំណោះស្រាយរបស់គាត់៖

> យើងមិនយល់ឃើញថា ចាំបាច់ត្រូវផ្តល់ជូនភាគីសំណុំរឿង ០០៤ ឬសំណុំរឿង ០០៤/២ នូវរយៈពេល ១៥ ថ្ងៃទៀតដើម្បីសុំឲ្យបំពេញកិច្ចស៊ើបសួរ យោងតាមមតិយោបល់របស់ អ.ប.ជ ទេ ពីព្រោះថា យើងយល់ឃើញថា គ្មានភាគីណាមួយទំនងជាទទួលរងផលប៉ះពាល់ដោយសារតែយើងមិនបានផ្តល់ជូនពេល ១៥ ថ្ងៃទៀតទេ ហើយច្បាស់ណាស់ ក៏មិនប៉ះពាល់ដល់ថ្នាក់ជា

[113] សូមមើល ខាងលើ កថាខណ្ឌ ៣៨ ដល់ ៤៤។

[114] អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ១៩៦៦, ៩៩៩ U.N.T.S ១៧១ និង ១០៥៧ U.N.T.S ៤០៧ ចូលជាធរមាននៅថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៧៦ (ICCPR) មាត្រា ១៤(៣)(គ)។

[115] សំណុំរឿង ០០៤ (អ.ប.ជ៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់ យឹម ទិត្យ សុំពេលវេលារៀបចំឲ្យបានគ្រប់គ្រាន់ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ឯកសារ D361/4/1/១០ កថាខណ្ឌ ២៣-២៧។

[116] សំណុំរឿង ០០៤ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ឯកសារ D361/4/1/10 កថាខណ្ឌ ២៤-២៥ (មានសេចក្តីបញ្ជាក់បន្ថែម)។

ករណីពិសេស ដែលតម្រូវឲ្យពិចារណាឡើងវិញលើសេចក្ដីសម្រេចរបស់យើងដែរ[117]។

៦៥. ក្នុងន័យនេះ អង្គបុរេជំនុំជម្រះពិចារណាឃើញថា អនុលោមតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង រយៈពេល ១៥ (ថ្ងៃ) គិតចាប់ពីថ្ងៃជូនដំណឹងលើកទីពីររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីការបញ្ចប់កិច្ចស៊ើបសួរ គួរត្រូវបានផ្ដល់ជូនភាគីដើម្បីពិនិត្យមើលភស្តុតាងដែលទើបតែប្រមូលបានថ្មី[118]។

៦៦. លើសពីនេះទៀត អង្គបុរេជំនុំជម្រះរម្លឹកថា អនុលោមតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង "*ភាគីទាំងអស់មាន* រយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ដើម្បីសុំឲ្យមានកិច្ចស៊ើបសួរបន្ថែម។ *ភាគីទាំងអស់* អាចលះបង់ថិរវេលានេះបាន[119]។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានសិទ្ធិពិចារណា ឬផ្ដល់ការពិចារណារបស់ខ្លួន ថាតើថិរវេលានេះចាំបាច់ត្រូវផ្ដល់ឲ្យ ឬមិនផ្ដល់ឲ្យនោះទេ ហើយជាលទ្ធផល និងកាន់តែសំខាន់ទៅទៀតនោះ ថិរវេលានេះមិនមែនសម្រាប់ឲ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិជា "អ្នកផ្ដល់ឲ្យ" នោះទេ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំអាចដកហូតសិទ្ធិពីភាគីនានានូវពេលវេលាដែលមានចែងយ៉ាងច្បាស់នៅក្នុងវិធាន ៦៦(១) តាមការបកស្រាយខុស និងតាមទំនើងចិត្តរបស់គាត់បានឡើយ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញទៀតថា កិច្ចដំណើរការនីតិវិធីមិនអាចពន្លឿនតាមរយៈកំហុសនីតិវិធីនេះបានទេ។

៦៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ទៀតថា សំណុំរឿងត្រូវបានបញ្ជូនទៅឲ្យសហព្រះរាជអាជ្ញាពិនិត្យក្នុងបំណងដើម្បីចេញដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧[120] គឺរយៈពេលពីរខែក្រោយពីការដាក់សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរចុងក្រោយ មិនមែន "ភ្លាមៗ" តាមវិធានផ្ទៃក្នុង ៦៦(៤) នោះទេ។

៦៨. នៅដំណាក់កាលនេះ អង្គបុរេជំនុំជម្រះរម្លឹកអំពីកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនចំពោះសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព[121] ហើយកិច្ចស៊ើបសួរតាមផ្លូវតុលាការពុំមានជាការអនុវត្តឆន្ទានុសិទ្ធិនោះឡើយ។ សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចបំពេញកិច្ចស៊ើបសួរតាមផ្លូវតុលាការនៅ

---

[117] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D360 កថាខណ្ឌ ៩ ជើងទំព័រយោងលេខ ២៥។

[118] សំណុំរឿង ០០៤ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ឯកសារ D361/4/1/10 ខណ្ឌ ២៧។

[119] វិធានផ្ទៃក្នុង ៦៦(១) (មានសេចក្ដីបញ្ជាក់បន្ថែម)។

[120] ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ឯកសារ D351។

[121] វិធាន ២១(១) នៃវិធានផ្ទៃក្នុង។

ក្នុងក្របខណ្ឌគតិយុត្តិ អ.វ.ត.ក ហើយអង្គបុរេជំនុំជម្រះ គឺជាតុលាការដែលពិនិត្យឡើងវិញ និងរួមចំណែកផ្តល់យុត្តិសាស្ត្ររបស់ខ្លួនឲ្យបានសមស្រប។ សហចៅក្រមស៊ើបអង្កេតត្រូវអនុវត្តការងារឲ្យស្របតាមច្បាប់ដែលមានជាធរមាន និងអនុវត្តសិទ្ធិអំណាចរបស់ខ្លួនដែលបានប្រគល់ដោយប្រុងប្រយ័ត្ន។ អង្គបុរេជំនុំជម្រះសង្កត់ធ្ងន់ថា មាត្រា ២៣ *ថ្មី* នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងយ៉ាងច្បាស់ថា ការបំពេញកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត "ត្រូវអនុវត្តតាមនីតិវិធីដែលមានជាធរមាន"[122] មិនមែនតាមការចូលចិត្ត របស់ខ្លួននោះទេ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា នីតិវិធីរបស់សហចៅក្រមស៊ើបអង្កេតត្រូវបានគ្រប ដណ្តប់ដោយច្បាប់អន្តរជាតិ[123]។ ត្រង់ចំណុចនេះ មាត្រា ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា "ក្រមនីតិវិធីព្រហ្មទណ្ឌ មានគោលបំណងកំណត់អំពី *វិធានទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់* ដើម្បីកំណត់ឲ្យបានច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ" (មានសេចក្តីបញ្ជាក់បន្ថែម)។ អាស្រ័យហេតុនេះ ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ជាធរមានសម្រាប់ អ.វ.ត.ក ត្រូវតែបកស្រាយឲ្យបានតឹងរ៉ឹងបំផុត។

៦៩. អង្គបុរេជំនុំជម្រះរម្លឹកថា ជាតុលាការអន្តរជាតិកូនកាត់អន្តរជាតិ អ.វ.ត.ក ត្រូវដំណើរការក្នុងក្របខណ្ឌតុលាការជាតិរបស់កម្ពុជា និងកត់សម្គាល់ថា វិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ផ្ទុះបញ្ច្រាំងមាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលចែងថា ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងឲ្យព្រះរាជអាជ្ញា "២ (ពីរ ថ្ងៃ) ក្រោយពីការជូនដំណឹងថា ការស៊ើបសួរត្រូវបានបញ្ចប់។ អង្គបុរេជំនុំជម្រះយល់ឃើញថា ការបង្កើតសំណុំឯកសារ និងការយកចិត្តទុកដាក់នៅក្នុងការផ្តល់ព័ត៌មានអំពីនីតិវិធី *ដែលជា* ការរៀបចំសំណុំរឿងឲ្យទាន់ពេលវេលារបស់សហចៅក្រមស៊ើបអង្កេតជាមួយនឹងនីតិវិធីដែលត្រូវគិតគូឲ្យបានសមស្រប គឺជាលក្ខខណ្ឌតម្រូវផ្លូវច្បាប់នៅក្នុងប្រព័ន្ធស៊ើបសួរដោយតុលាការ ដែលមានធម្មតាចំពោះយុត្តាធិការកូនកាត់ប្រភេទនេះ [124] ហើយមានលក្ខណៈវិសាមញ្ញបំផុត និងមានតែមួយគត់សម្រាប់ អ.វ.ត.ក បើប្រៀបធៀបនឹង

[122] ច្បាប់បង្កើត អ.វ.ត.ក មាត្រា ២៣ ថ្មី កថាខណ្ឌ ១។

[123] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១២(១)។

[124] *សូមមើល ឧ.* ច្បាប់ លេខ ១៨-០១០ ស្តីពីការបង្កើត វិធានស្តីពីនីតិវិធី និងភស្តុតាង នៃតុលាការព្រហ្មទណ្ឌពិសេស នៅសាធារណៈរដ្ឋអាហ្វ្រិកកណ្តាល មាត្រា ១០៣ ចែងពីការជូនដំណឹងទៅរដ្ឋអាជ្ញាឲ្យបានឆាប់រហ័សនៅពេលដឹងថាព័ត៌មាននេះត្រូវបានបញ្ចប់នៅសភាស៊ើបសួរ។ ក្រមប្រទេស[សេណេហ្កាល់] មាត្រា ១៦៩ ចែងអំពីថិរវេលាបីថ្ងៃមុនការជូនដំណឹងទៅកាន់ការិយាល័យរដ្ឋអាជ្ញាសាធារណៈ។ អង្គជំនុំជម្រះវិសាមញ្ញនៅទ្វីបអាហ្វ្រិក (EAC) *រវាង រដ្ឋអាជ្ញា ទល់នឹង HABRE et al* ដីកាសម្រេចបដិសេធចោលផ្នែកខ្លះ បញ្ជូនរឿងទៅជំនុំជម្រះ និងលើកលែងចោទ ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញអាហ្វ្រិក Assize ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារD2819 (ចៅក្រមស៊ើបអង្កេតដែលទទួលបន្ទុកលើរឿងក្តី Hissein HABRE បានបញ្ជូនសំណុំរឿងទៅការិយាល័យរដ្ឋអាជ្ញានៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៥ បានទទួលដីកាស្ពាតបញ្ជូនរឿងទៅជំនុំជម្រះនៅថ្ងៃទី០៦ ខែ

តុលាការអន្តរជាតិដទៃទៀត[125]។

៧០. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាដំណោះស្រាយរបស់គាត់ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ដែលបញ្ចប់កិច្ចស៊ើបសួរប្រឆាំងនឹង អោ អាន ក្នុងរយៈពេល ១៦ ខែ បន្ទាប់ពីការជូនដំណឹងលើកទីពីរអំពីការបញ្ចប់កិច្ចស៊ើបសួរតាមផ្លូវតុលាការទៅភាគីទាំងអស់ និងមេធាវីរបស់ពួកគេនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧[126]។

៧១. អង្គបុរេជំនុំជម្រះទទួលស្គាល់ថា ដំណើរការរៀបចំសេចក្តីព្រាងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (១៦ ខែ) មានរយៈពេលខ្លីជាងសំណុំរឿង ០០៤/១ (១៨ ខែ) ខណៈពេលដែលភាពស្មុគស្មាញ និងបរិមាណឯកសារនៃសំណុំរឿង ០០៤/២ មានច្រើនជាង។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះយល់ឃើញថា ថិរវេលានេះនៅតែច្រើនហួសហេតុ បើប្រៀបធៀបជាមួយដីកាដំណោះស្រាយដែលបានចេញក្នុងសំណុំរឿង ០០១ និង ០០២ ដែលមានថិរវេលាតែបីខែ សម្រាប់សំណុំរឿង ០០១ និងប្រាំបីខែ សម្រាប់សំណុំរឿង ០០២ ក្រោយពីការបញ្ចប់កិច្ចស៊ើបសួររួចមក។

៧២. សរុបសេចក្តីមក អង្គបុរេជំនុំជម្រះយល់ឃើញថា ការចេញដីកាដំណោះស្រាយមិនសមស្របដោយមានដីកាដាច់ដោយឡែកៗ និងខ្វែងយោបល់គ្នារបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត មានសរសេរតែមួយភាសា ក្នុងចំណោមភាសាផ្លូវការរបស់ អ.វ.ត.ក ដោយពុំមានការបង្ហាញពីកាលៈទេសៈពិសេស គឺជាការរំលោភទៅលើមាត្រា ៧ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ("សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ")[127] ដែលធ្វើឱ្យមានការពន្យារពេលហួសហេតុនៅក្នុងកិច្ចដំណើរការលើសំណុំរឿង ០០៤/២ ទាំងមូល។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះរម្លឹកដល់សហចៅក្រមស៊ើបអង្កេតថា ការចេញដីកាដំណោះស្រាយរបស់ពួកគាត់ដែលមានកម្រាស់ជាង ៤០០ ទំព័រ តែមួយភាសា ក្នុងចំណោមភាសាផ្លូវការរបស់ អ.វ.ត.ក ក៏បានធ្វើឱ្យមានការពន្យារពេលហួសហេតុ ដែលអាចជៀសបាន នៅក្នុងកិច្ច

---

កុម្ភៈ ឆ្នាំ២០១៥ ហើយមួយសប្តាហ៍ក្រោយមក បានចេញដីកាសម្រេចរបស់ខ្លួន)។

[125] Robert PETIT និង Anees AHMED "ការពិនិត្យឡើងវិញទៅលើយុត្តាធិការរបស់សាលាក្តីខ្មែរក្រហម" ព្រឹត្តិប័ត្រ Northwestern ស្តីពីសិទ្ធិមនុស្ស វ៉ុល ៨, II (Spring ឆ្នាំ២០១០) ទំព័រ ១៦៩។

[126] សំណុំរឿង ០០៤/២ការជូនដំណឹងលើកទីពីរអំពីការបញ្ចប់កិច្ចស៊ើបសួរតាមផ្លូវតុលាការប្រឆាំងនឹង អោ អាន ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ ឯកសារ D34/2។

[127] សេចក្តីណែនាំស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក អ.វ.ត.ក/០១/២០០៧/កំណែទី ៨ ដែលត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី ៧ ខែមីនា ឆ្នាំ ២០១២ មាត្រា ៧ ។

ដំណើរការសំណុំរឿង ០០៤/២ ទាំងមូល។

## ឃ. ការពិចារណាលើភស្តុតាង

៧៣. សហចៅក្រមទាំងពីររូបបានប្រើប្រាស់ជំពូកមួយចំនួននៅក្នុងដីកាដំណោះស្រាយរបស់ខ្លួនផ្តោតទៅលើ “ការពិចារណាលើភស្តុតាង” ដោយដោះស្រាយទៅលើភាពអាចជឿជាក់បាន និងតម្លៃជាភស្តុតាងនៃប្រភេទភស្តុតាងនានា[128]។ អង្គបុរេជំនុំជម្រះរម្លឹកថា បញ្ហានេះត្រូវបានយកមកដោះ ស្រាយយ៉ាងល្អិតល្អន់រួចមកហើយនៅក្នុងសំណុំរឿង ០០៤/១[129] ហើយថា ច្បាប់ អ.វ.ត.ក និង វិធានផ្ទៃក្នុង ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឬយុត្តិសាស្ត្រ[130] មិនបានប្រមើលមើលពីការពិចារណា លើភស្តុតាងនៅដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធីទេ[131]។ អនុលោមតាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង ភារកិច្ចផ្តាច់មុខរបស់សហចៅក្រមស៊ើបអង្កេតគឺការចេញដីកាដំណោះស្រាយថាត្រូវចោទ ប្រកាន់បញ្ជូនទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់ដោយផ្អែកទៅលើខ្លឹមសារនៃភស្តុតាងនៅក្នុងសំណុំរឿង។ ក្នុងការចេញដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតមានភារកិច្ចពិចារណាទៅលើភស្តុតាងទាំងអស់ និងមិនអាចបដិសេធចោលដោយមិនត្រឹមត្រូវ ឬមិនផ្តល់តម្លៃដល់ប្រភេទភស្តុតាងមួយចំនួន មុនពេលយកភស្តុតាងទាំងនោះទៅដេញដោលរវាងភាគីនានាបានឡើយ។

៧៤. ហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ការណ៍ដែលសហចៅក្រមស៊ើបអង្កេតព្យាយាមពន្យល់អំពីវិធីសាស្ត្ររបស់ខ្លួនក្នុងការកំណត់អំពីឋានានុក្រមនៃភស្តុតាងជារឿងឥតប្រយោជន៍ មិនចាំបាច់ និងមិនត្រឹមត្រូវតាមផ្លូវច្បាប់ឡើយ។ វិធីសាស្ត្រនេះផ្ទុយពីក្របខណ្ឌគតិយុត្តិជាធរមាន និងមិនស្របទៅនឹងយុត្តិសាស្ត្រដែលបានបង្កើតនៅតុលាការនេះទេ។

---

[128] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៣៥-៣៨, ១២៣-១៥៦។ ដីកាដំណោះស្រាយ (លើកលែងចោទប្រកាន់) (D359) កថាខណ្ឌ ៤៨៥-៤៩១។

[129] សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D308/3/1/20 កថាខណ្ឌ ៤១-៦៣។

[130] នៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០១ និង សំណុំរឿង ០០២ សហចៅក្រមស៊ើបអង្កេតមិនបានលើកឡើងពីបញ្ហាភស្តុតាងទាំងនេះទេ។ ក្នុងសំណុំរឿង ០០១ ដីកាដំណោះស្រាយចោទប្រកាន់ កាំង ហ្គេចអ៊ាវ ហៅឌុច ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ (D99)(សំណុំរឿង០០១ ដីកាដំណោះស្រាយ (D99)។សំណុំរឿង០០២ ដីកាដំណោះស្រាយក្នុងសំណុំរឿងចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ (សំណុំរឿង០០២ ដីកាដំណោះស្រាយ (D427)។

[131] សំណុំរឿង០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ឯកសារ D308/3/1/20 កថាខណ្ឌ ៤២។

៧៥. អង្គបុរេជំនុំជម្រះយល់ឃើញថាជាការចាំបាច់ដែលត្រូវពិនិត្យទៅលើថា (១) តើសហចៅក្រមស៊ើបអង្កេតមានកំហុសក្នុងការវាយតម្លៃពីភាពអាចជឿជាក់បាន និងតម្លៃជាភស្តុតាងនៃភស្តុតាងនានា ឬយ៉ាងណា និង (២) តើសហចៅក្រមស៊ើបអង្កេតបានយកបទដ្ឋាននៃភស្តុតាងដែលត្រឹមត្រូវមកអនុវត្ត ឬទេ។

## ១. គោលការណ៍ស្តីពីសេរីភាពនៃភស្តុតាង

៧៦. ក្នុងនាមជាតុលាការកូនកាត់ អ.វ.ត.ក អនុវត្តការងារតាមវិធានផ្ទៃក្នុងរបស់ខ្លួន និងច្បាប់កម្ពុជា។ វិធាន ៨៧ នៃវិធានផ្ទៃក្នុង ចែងច្បាស់ថា "លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះរាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក"។ ចំណុចនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលចែងច្បាស់អំពីគោលការណ៍ស្តីពីសេរីភាពនៃភស្តុតាង និងឥទ្ធិពលនៃជំនឿរបស់ចៅក្រម។ ហេតុនេះ ការប្រមូលភស្តុតាងនៅ អ.វ.ត.ក ពិតជាត្រូវបានគ្រប់គ្រងដោយគោលការណ៍ស្តីពីសេរីភាពនៃភស្តុតាងប្រាកដមែន[132] ដែលជាលក្ខណៈពិសេសនៃប្រព័ន្ធច្បាប់ស៊ីវិលភាគច្រើន[133]។ ហេតុនេះ ភស្តុតាងទាំងអស់ត្រូវតែទទួលយក ហើយជាទូទៅមានតម្លៃជាភស្តុតាងដូចគ្នា និងត្រូវស្ថិតក្នុងកិច្ចដំណើរការនីតិវិធីនៃការធ្វើមោឃភាពបាន[134]។ យើងអាច និយាយបានថា មានតែបទប្បញ្ញត្តិច្បាស់លាស់ដែលមាននៅក្នុងលិខិ

---

[132] សំណុំរឿង ០០៤ (អង្គបុរេជំនុំជម្រះ ៥១) សេចក្តីសម្រេចលើពាក្យសុំរបស់ យឹម ទិត្យ សុំធ្វើមោឃភាពលើសំណើសុំ និងការប្រើប្រាស់ព័ត៌មានបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសម្ភារៈស៊ើបអង្កេតពាក់ព័ន្ធ នៅក្នុងសំណុំរឿង ០០៤ ឯកសារ D370/1/1/6 ("សំណុំរឿង ០០៤ សេចក្តីសម្រេចពាក់ព័ន្ធនឹងប្រើប្រាស់ព័ត៌មានរបស់ដើមបណ្តឹងរដ្ឋប្បវេណី (D370/1/1/6)") កថាខណ្ឌ ១៧។

[133] ទាក់ទិននឹងវិធីសាស្ត្ររបស់កម្ពុជាចំពោះភស្តុតាងនៅក្នុងប្រព័ន្ធនីតិវិធីព្រហ្មទណ្ឌ *សូមមើល* Collectif, *Droit du Cambodge* (Bibliothèque de l'Association Henri Capitant, ការកែសម្រួលលើកទី១ ឆ្នាំ២០១៦) ទំព័រ ៤៤-៤៥។ ទាក់ទិននឹងវិធីសាស្ត្ររបស់បារាំងចំពោះភស្តុតាងនៅក្នុងប្រព័ន្ធនីតិវិធីព្រហ្មទណ្ឌ *សូមមើល* Jean PRADEL, *Procédure pénale* (Cujas, ការកែសម្រួលលើកទី១៤ ឆ្នាំ២០០៨-២០០៩) ទំព័រ ៣៦៤។ Bernard BOULOC, *Procédure pénale* (Dalloz ការកែសម្រួលលើកទី ២៤ ឆ្នាំ២០១៤) ទំព័រ ១២២។ គោលការណ៍ស្តីពីសេរីភាពនៃភស្តុតាងត្រូវបានលើកឡើងនៅក្នុងប្រព័ន្ធនីតិវិធីព្រហ្មទណ្ឌភាគច្រើនពីបណ្តាប្រទេសនានាដែលដោះស្រាយចំពោះបទល្មើសស្រដៀងគ្នា៖ *ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា* (ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧) ("ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧") មាត្រា ៣២១។ *ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង* មាត្រា ៤២៧ (បកប្រែក្រៅផ្លូវការ)។ *ក្រមនីតិវិធីព្រហ្មទណ្ឌសេណេហ្គាល់* មាត្រា ១៤១ (បកប្រែក្រៅផ្លូវការ)។ *ក្រមនីតិវិធីព្រហ្មទណ្ឌកូដឌីវ័រ* មាត្រា ៤១៨។ *ក្រមប្រទេស[ហ្គីណេ]* មាត្រា ៤២០ (បកប្រែក្រៅផ្លូវការ)។ *ក្រមប្រទេស[ម៉ាលី]* មាត្រា ៤១២ (បកប្រែក្រៅផ្លូវការ)។

[134] សំណុំរឿង០០៤ សេចក្តីសម្រេចពាក់ព័ន្ធនឹងប្រើប្រាស់ព័ត៌មានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ D370/1/1/6 កថាខណ្ឌ ១៧។

ឧបករណ៍គតិយុត្តិដែលបានលើកឡើងខាងលើប៉ុណ្ណោះដែលនឹងអនុញ្ញាតឱ្យងាកចេញពីគោលការណ៍នេះ។

៧៧. ក្រៅពីនេះ មាត្រា ២៣*ថ្មី* នៃច្បាប់ អ.វ.ត.ក ចែងថា "សហចៅក្រមស៊ើបអង្កេត អាចផ្អែកទៅលើមូលដ្ឋាននៃព័ត៌មាន ដែលទទួលបានពីស្ថាប័ននានា"។ បទប្បញ្ញត្តិនេះមិនរាប់បញ្ចូលការកំណត់ប្រភេទនៃភស្តុតាងនានាដែលមានលក្ខណៈអត្តនោម័ត ដោយផ្អែកលើប្រភពរបស់វាទេ ហើយគួសបញ្ជាក់ថា ភស្តុតាងទាំងអស់ទទួលបានការសន្មតតាមផ្លូវច្បាប់ថាមានតម្លៃជាភស្តុតាងដូចគ្នា ដរាបណាភស្តុតាងទាំងនេះត្រូវបានប្រមូលតាមផ្លូវច្បាប់ លើកលែងតែមានចែងជាក់លាក់ផ្សេងពីនេះនៅក្នុងច្បាប់។

៧៨. យុត្តាធិការកូនកាត់ផ្សេងទៀតបានប្រកាន់យកវិធីសាស្ត្រស្តីពីភស្តុតាងមួយស្រដៀងគ្នាដែរ។ ជាការពិត នៅអង្គជំនុំជម្រះវិសាមញ្ញអាហ្វ្រិក ("អ.វ.អ") អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា សេរីភាពនៃភស្តុតាងដូចមានចែងនៅក្នុងមាត្រា ៤១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌសេណេហ្គាល់ [135] អាចយកមកអនុវត្តបាននៅដំណាក់កាលមុនការជំនុំជម្រះលើអង្គសេចក្តី [136] ។ នាពេលថ្មីៗនេះ តុលាការព្រហ្មទណ្ឌពិសេសនៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល ក៏បានចែងយ៉ាងច្បាស់ដែរពីគោលការណ៍សេរីភាពនៃភស្តុតាង នៅក្នុងច្បាប់ស្តីពីការបង្កើតវិធាននីតិវិធី និងភស្តុតាង[137]។

៧៩. នៅក្នុងសេចក្តីពិចារណាទៅលើភស្តុតាងរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតពុំបានយកចិត្តទុកដាក់ទៅលើគោលការណ៍សេរីភាពនៃភស្តុតាងទេ ហើយបានពន្យល់ដោយមិនត្រឹមត្រូវពីការធ្វើចំណាត់ថ្នាក់ភស្តុតាងជាទម្រង់ពីរ៉ាមីត ដោយពុំមានបទប្បញ្ញត្តិផ្លូវច្បាប់ពាក់ព័ន្ធណាមួយអនុញ្ញាតឱ្យធ្វើបែបនេះទេ។ ភស្តុតាងដែលការិយាល័យសហចៅក្រមស៊ើបអង្កេតប្រមូលបានត្រូវបានចាត់ទុកថានៅលំដាប់កំពូលនៃពីរ៉ាមីត ហើយត្រូវបានយកមកសំអាងយ៉ាងលើសលប់នៅក្នុងចេញដីកាដំណោះស្រាយ [138] ។ ជាការពិត សហ

---

[135] *ក្រមនីតិវិធីព្រហ្មទណ្ឌសេណេហ្គាល់* មាត្រា ៤១៤ al.1 ("បទល្មើសព្រហ្មទណ្ឌអាចត្រូវបានបង្កើតឡើងដោយប្រភេទភស្តុតាងនានា ហើយចៅក្រមសម្រេចដោយផ្អែកលើជំនឿដោយស្មោះត្រង់ពិតប្រាកដ លុះត្រាតែច្បាប់មានចែងផ្សេងពីនេះ") (បកប្រែក្រៅផ្លូវការ)។

[136] EAC *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Habre និងអ្នកផ្សេងទៀត* Ordonnance de non-lieu partiel, de mise en accusation et de renvoi devant la Chambre Africaine Extraordinaire d'Assises, Chambre d'instruction, ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D2819 ("*Habre* Ordonnance de non-lieu partiel (EAC)") ទំព័រ ៦។

[137] ច្បាប់លេខ ១៨-០១០ ដែលបង្កើតវិធាននីតិវិធីនិងភស្តុតាងនៃតុលាការព្រហ្មទណ្ឌពិសេសនៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល មាត្រា ១៦១ ("តុលាការអនុវត្តវិធាននៃភស្តុតាងទូទៅដែលមាននៅក្នុងវិធាន និងជាពិសេសគឺ គោលការណ៍ស្តីពីសេរីភាពនៃភស្តុតាង") (បកប្រែក្រៅផ្លូវការ)។

[138] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ១២៣។ ដីកាដំណោះស្រាយ (លើកលែងចោទប្រកាន់)

ចៅក្រមស៊ើបអង្កេតបានពិចារណាថា ភស្តុតាងរបស់ខ្លួនតំណាងឲ្យការអនុវត្តតាមយ៉ាងខ្ជាប់ខ្ជួនទៅតាមនីតិវិធី ហេតុនេះទទួលបានការសន្មតពីភាពជាប់ពាក់ព័ន្ធ និងភាពអាចជឿជាក់បាន[139] ចំណែកឯភស្តុតាងដែលស្ថាប័នខាងក្រៅប្រមូលបាន ពុំទទួលបានការសន្មតបែបនេះឡើយ។ ទិនទាក់នឹងចំណុចនោះ ភស្តុតាងនានាដូចជាការសម្ភាសន៍នានាដែលបានធ្វើឡើងដោយការិយាល័យសហព្រះរាជអាជ្ញា របាយការណ៍ ឬឯកសារមួយចំនួនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បានទទួលតម្លៃជាភស្តុតាងទាបជាង ឬពុំមានតម្លៃជាភស្តុតាងទាល់តែសោះ[140]។

៨០. នៅក្នុងសំណុំរឿង ០០៤/១ អង្គបុរេជំនុំជម្រះបានរម្លឹកថា "សំណុំរឿងទាំងមូលត្រូវស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរបស់សហចៅក្រមស៊ើបអង្កេត មិនមែនត្រឹមតែភស្តុតាងដែលការិយាល័យសហចៅក្រមស៊ើបអង្កេតបានបង្កើតឡើងនោះឡើយ"[141]។ អង្គបុរេជំនុំជម្រះសូមបញ្ជាក់ថា ការធ្វើសេចក្តីអះអាងទូទៅពាក់ព័ន្ធនឹងតម្លៃជាភស្តុតាងនៃប្រភេទភស្តុតាងមួយចំនួនដែលត្រូវបានកំណត់ជាមុន ជារឿងមិនត្រឹមត្រូវឡើយ ជាពិសេសនៅពេលពឹងផ្អែកទៅលើប្រភព ជាងខ្លឹមសាររបស់វានោះ[142]។ នៅដំណាក់

(D359) កថាខណ្ឌ ៤៨៥។

[139] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ១២៣ *យោងទៅ* ភាពអាចជឿជាក់បាននៃប្រភេទភស្តុតាងដែលប្រមូលបាន ឬបានរៀបចំក្រោមការត្រួតពិនិត្យរបស់តុលាការ នៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដូចជា កំណត់ហេតុស្តាប់ចម្លើយសាក្សី និងបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១។ ដីកាដំណោះស្រាយ (លើកលែងចោទប្រកាន់) (D359) កថាខណ្ឌ ៤៨៥។

[140] ដីកាដំណោះស្រាយ (លើកលែងចោទប្រកាន់) (D359) កថាខណ្ឌ ៤៨៦-៤៨៨។ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ១២៤-១២៦ ("[ចម្លើយ ឬភស្តុតាងដទៃទៀត] របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានធ្វើឡើងដោយគ្មានការធានា និងបែបបទនីតិវិធីតុលាការ ដែលជាលក្ខខណ្ឌនៃកំណត់ហេតុស្តាប់ចម្លើយទេ ហេតុនេះមិនទទួលបានសច្ចធារណ៍បែបនេះឡើយ [...] ការស្តាប់ចម្លើយដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា ក្នុងអំឡុងពេលស៊ើបអង្កេតបឋមរបស់សហព្រះរាជអាជ្ញា បើទោះបីជាត្រូវបានរៀបចំឡើងជាពិសេសសម្រាប់កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌក៏ដោយ ក៏ការស្តាប់ចម្លើយទាំងនេះមិនត្រូវបានធ្វើឡើងដោយមានការស្បថដែរ ហើយត្រូវបានរៀបចំដោយភាគីមួយ ដែលមានផលប្រយោជន៍ជាក់ស្តែងនៅក្នុងលទ្ធផលនៃសំណុំរឿង។ ទោះជាយ៉ាងនេះក្តី ចម្លើយបែបនេះត្រូវបានប្រមូលឡើងក្នុងគោលបំណងសម្រាប់សវនាការព្រហ្មទណ្ឌ ដូច្នេះហើយជាគោលការណ៍ ត្រូវទទួលបានតម្លៃជាភស្តុតាងខ្ពស់ជាងភស្តុតាងដែលមិនបានរៀបចំក្នុងគោលបំណងបែបនេះ [...] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពុំអាចទទួលបានសច្ចធារណ៍នៃភាពអាចជឿជាក់បានទេ ហើយទទួលបានតម្លៃជាភស្តុតាងទាបប៉ុណ្ណោះ [...]")។

[141] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៥០ និងជើងទំព័រ ១០៣ *យោងទៅ* វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ មាត្រា ១២៧។

[142] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៥២។ ដូ

កាលនេះ "លក្ខណាវិនិច្ឆ័យពាក់ព័ន្ធតែមួយគត់ គួរតែជាឥទ្ធិពលដែលខ្លឹមសារនៃភស្តុតាងនោះអាចមាន ទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងបញ្ហាថាតើមានភស្តុតាងគ្រប់គ្រាន់ឬអត់ សម្រាប់ការចោទប្រកាន់នោះ"[143]។

៨១. ជាពិសេស អង្គបុរេជំនុំជម្រះយល់ឃើញថាមានបញ្ហាខ្លាំង នៅពេលមិនរាប់បញ្ចូលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងទៅក្នុងគោលការណ៍សច្ចធារណ៍នៃភាពអាចទុកចិត្តបាន និងឲ្យពាក្យសុំទាំងនោះ "ទទួលបានតម្លៃជាភស្តុតាងទាប" ដោយផ្អែកលើមូលដ្ឋាននៃកាលៈទេសៈជុំវិញការកត់ត្រាពាក្យសុំទាំងនោះ[144]។ ជាក់ស្តែង ទម្រង់បែបបទអំពីជនរងគ្រោះ និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មានព័ត៌មានដើមដំបូងអំពីអង្គហេតុពាក់ព័ន្ធ។ ភាពជឿជាក់នៃភស្តុតាងទាំងនោះគួរយកមកវាយតម្លៃទៅតាមករណីនីមួយៗ ហើយមិនអាចយល់ថា មិនអាចទុកចិត្តបានដោយស្វ័យប្រវត្តិនោះទេ[145]។ ករណីដែលថា ភស្តុតាងទាំងនោះមានប្រយោជន៍ផ្ទាល់ចំពោះលទ្ធផលនៃរឿងក្តីមិនគួរនាំឲ្យសន្មតដោយស្វ័យប្រវត្តិថា ភស្តុតាងទាំងនោះអាចជឿជាក់បានតិចតួចនោះទេ[146]។ អង្គបុរេជំនុំជម្រះរម្លឹកទៀតថា ការបកស្រាយបែបនេះកម្រិតប្រសិទ្ធភាពនៃសិទ្ធិរបស់ជនរងគ្រោះក្នុងការប្តឹងទៅតុលាការ[147] ហើយផ្ទុយនឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែល

---

ចដែលអ្នកធ្វើអត្ថាធិប្បាយមួយរូបបានលើកឡើងនៅក្នុងបរិបទមួយផ្សេងទៀតថា "aucune disposition légale ne permet au juge répressif d'écarter les moyens de preuve produits par les parties, au seul motif qu'ils auraient été obtenus de façon illicite ou déloyale; il leur appartient seulement d'en apprécier la valeur probante" (បកប្រែក្រៅផ្លូវការ៖ ពុំមានបទប្បញ្ញត្តិច្បាប់ណាមួយអនុញ្ញាតឲ្យចៅក្រមមិនរាប់បញ្ចូលនូវភស្តុតាងរបស់ភាគីណាមួយ ដោយត្រឹមតែថា ភស្តុតាងនោះអាចទទួលបានតាមវិធីដែលខុសច្បាប់ ឬមិនត្រឹមត្រូវនោះឡើយ។ មានការទទួលខុសត្រូវមួយក្នុងការវាយតម្លៃពីតម្លៃជាភស្តុតាង) *នៅក្នុង* Martine RACT-MADOUX, "La loyauté de la preuve en matière pénale : la liberté des preuves", *Procédures,* លេខ ១២ (ខែធ្នូ ឆ្នាំ២០១៥)។

[143] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៥២។

[144] ដីកាដំណោះស្រាយ (ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ១២៦។ ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងការចោទប្រកាន់) (ឯកសារ D359) កថាខណ្ឌ ៤៨៨។

[145] សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ៥៥។

[146] *សូមមើល* Göran SLUITER *និងអ្នកផ្សេងទៀត នីតិវិធីព្រហ្មទណ្ឌអន្តរជាតិ - គោលការណ៍ និងវិធាន* (Oxford University Press, 2013) ទំព័រ ១៣៥៣-១៣៥៤។

[147] សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ៥៦ *យោងលើ* ច្បាប់ អ.វ.ត.ក មាត្រា ៣៣ថ្មី។ វិធាន ២១ នៃវិធានផ្ទៃក្នុង។ សេចក្តីប្រកាសស្តីពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃបទឧក្រិដ្ឋ និងការបំពានអំណាច A/RES/40/34 *ជាពិសេស* ឧបសម្ព័ន្ធ កថាខណ្ឌ ៤-៥។ គោលការណ៍មូលដ្ឋាន និងគោលការណ៍ណែនាំស្តីពីសិទ្ធិទទួលបានឧបាស្រ័យ និងសំណងសម្រាប់ជនរងគ្រោះនៃការរំលោភធ្ងន់ធ្ងរនៃច្បាប់សិទ្ធិ

យោងតាមមាត្រា ១៣៧ ចែងយ៉ាងច្បាស់ថា ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវការទម្រង់ណាមួយ ដើម្បីចូលរួមនៅក្នុង ការស៊ើបអង្កេតឡើយ។ អាស្រ័យហេតុនេះ ការបកស្រាយរបស់សហ ចៅក្រមស៊ើបអង្កេតគ្មានមូលដ្ឋានផ្លូវច្បាប់ ហើយគ្មានប្រយោជន៍ ដោយហេតុថា ដើម្បីធានាតម្លៃនៃភស្តុតាង សហ ចៅក្រមស៊ើបអង្កេតត្រូវស្តាប់ចម្លើយគ្រប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី [148] ដែលជាហេតុនាំឱ្យមានការពន្យារកិច្ចដំណើរការនីតិវិធីកាន់តែយូរ។

៨២. អង្គបុរេជំនុំជម្រះយល់ឃើញថា ទោះបីជាតម្លៃនៃភស្តុតាង *តាមការពិនិត្យបឋម* អាចមានតិចតួចចំពោះផ្នែកនៃភស្តុតាងដាច់ដោយឡែកពីគ្នានីមួយៗក៏ដោយ ក៏ការដែលភស្តុតាងនេះមានភាព ពាក់ព័ន្ធខ្លះនោះ មានន័យថា ភស្តុតាងទាំងនោះត្រូវតែរកឱ្យបានសម្រាប់ទុកពិចារណា[149]។ ការ ស្តាប់ចម្លើយធ្វើឡើងដោយសហព្រះរាជអាជ្ញា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងឯកសារពីមជ្ឈមណ្ឌលឯកសារកម្ពុជា នៅតែមាននៅក្នុងសំណុំរឿង បើទោះជាសហចៅក្រម ស៊ើបអង្កេតកំណត់ថាតម្លៃភស្តុតាងរបស់វាមានកម្រិត ហើយអាចត្រូវយកមកពិចារណានៅក្នុងដំណាក់កាលជំនុំជម្រះបាន[150]។

៨៣. វិធីសាស្ត្រកំណត់ប្រភេទភស្តុតាងដែលយកមកប្រើប្រាស់ឡើងវិញដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងរឿងក្តីបច្ចុប្បន្ន មិនមែនត្រឹមតែងាកចាកចេញពីយុត្តិសាស្ត្រជាធរមានពីមុនរបស់ខ្លួន ប៉ុណ្ណោះទេ[151]

---

មនុស្សអន្តរជាតិ និងការរំលោភធ្ងន់ធ្ងរនៃច្បាប់មនុស្សធម៌អន្តរជាតិ A/RES/60/147 *ជាពិសេស* ឧបសម្ព័ន្ធ កថាខណ្ឌ ១២-១៤។

[148] សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ៥៥ (“ហេតុដូច្នេះ ប្រសិនបើសហចៅក្រមស៊ើបអង្កេត បដិសេធ *ជាបឋម* នូវសច្ចធារណ៍នៃភាពអាចជឿជាក់បានសម្រាប់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយផ្តល់នូវតម្លៃជាភស្តុតាងទាបជាងភស្តុតាងដទៃទៀត ដែលប្រមូលបានដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ពេលនោះសហចៅក្រមស៊ើបអង្កេត អាចខ្លួនឯងផ្ទាល់ ឬ តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស នឹងជាប់កាតព្វកិច្ចត្រូវស្តាប់ចម្លើយអ្នកដាក់ពាក្យសុំទាំងអស់ ក្នុងនាមជាសាក្សី ដោយពិចារណាថាពួកគាត់មាននូវព័ត៌មានដែលនាំទៅដល់ការស្វែងរកការពិត”)។

[149] សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ៥៣ និងលេខយោងជើងទំព័រ *យោងលើ* តុលាការពិសេសសម្រាប់សេរ៉ាឡេអូន (“តុលាការ SCSL”) រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Norman និងអ្នកផ្សេងទៀត* SCSL-04-14-AR65 បណ្តឹងសាទុក្ខ Fofana ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធសំណើសុំនៅក្រៅឃុំ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៥ កថាខណ្ឌ ២៣។ តុលាការ SCSL រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Sesay និងអ្នកផ្សេងទៀត* SCSL-04-15-T សេចក្តីសម្រេចលើពាក្យសុំរបស់ Gbao សុំដកភស្តុតាងរបស់សាក្សីដាក់បន្ទុក លោក Koker អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៥ កថាខណ្ឌ ៩។

[150] សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ៥៨។

[151] *សូមមើល* សំណុំរឿង ០០១ ដីកាដំណោះស្រាយ (ឯកសារ D99)។ សំណុំរឿង ០០២ ដីកាដំណោះស្រាយ (ឯកសារ D427)។

ប៉ុន្តែវាក៏ពុំត្រឹមត្រូវ ហើយពុំមានមូលដ្ឋាននៅក្នុងប្រព័ន្ធស៊ើបអង្កេតដឹកនាំដោយ ចៅក្រមដែរ។ អង្គបុរេជំនុំជម្រះយល់ឃើញថា ចំណុចនេះបង្ហាញឱ្យឃើញពីកំហុសធ្ងន់ធ្ងរនៅក្នុងការដឹកនាំកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៥៥ នៃវិធានផ្ទៃក្នុង ហើយប៉ះពាល់ដល់កេរ្តិ៍ដំណែល ច្បាប់របស់ អ.វ.ត.ក ទៀតផង។

## ២. បទដ្ឋាននៃភស្តុតាង

៨៤. អង្គបុរេជំនុំជម្រះរម្លឹកថា ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីមានផលប៉ះពាល់លើបទដ្ឋាននៃភស្តុតាង។ យោងតាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង លក្ខខណ្ឌសម្រាប់ចេញដីកាដំណោះស្រាយ គឺ អត្ថិភាពនៃ "ភស្តុតាងគ្រប់គ្រាន់" ដោយភ្ជាប់ជាមួយនឹងបទចោទ។ នៅក្នុដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានសំអាងលើយុត្តិសាស្ត្រនៃអង្គជំនុំជម្រះសាលាដំបូង ហើយនឹងអង្គជំនុំជម្រះតុលាការកំពូល ក្នុងការបង្កើតគោលការណ៍សម្រាប់ការវាយតម្លៃលើភស្តុតាង[152]។ ទោះបីជាយ៉ាងនេះក៏ដោយ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល មានកាតព្វកិច្ចគោរពតាមកាតព្វកិច្ច "ហួសពីវិមតិសង្ស័យ"[153] ដែលមានលក្ខណៈខ្ពស់ជាងបទដ្ឋាននៃ "ភស្តុតាងគ្រប់គ្រាន់"។ នៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ សហចៅក្រមស៊ើបអង្កេតបានកំណត់ថាតើអ្វីទៅដែលខ្លួនចាត់ទុកថាជា "បទចោទគ្រប់គ្រាន់"៖

> នៅក្នុងដំណាក់កាលស៊ើបសួរមុនអង្គសេចក្តីនេះ មិនមានការតម្រូវឱ្យបង្ហាញអំពីពិរុទ្ធភាពរបស់ជនត្រូវចោទនោះទេ (អង្គជំនុំជម្រះសាលាដំបូងគឺជាស្ថាប័នតែមួយគត់ ដែលមានសមត្ថកិច្ចក្នុងការធ្វើដូច្នេះ) ប៉ុន្តែ ចាំបាច់ត្រូវមានការបង្ហាញអំពី "ភវនីយភាព" នៃពិរុទ្ធភាព (មានន័យថា ស្ថានភាពដែលលើសពីលទ្ធភាពដែលអាចកើតមានធម្មតា)។ ហេតុដូច្នេះ ការវាយតម្លៃអំពីភស្តុតាងដាក់បន្ទុក នៅក្នុងដំណាក់កាលនេះ មានលក្ខណៈខុសពីសញ្ញាណនៃ "ជំនឿស៊ប់" របស់ចៅក្រមនៅក្នុងដំណាក់កាលជំនុំជម្រះ ប៉ុន្តែភស្តុតាងនៅក្នុងសំណុំរឿងត្រូវមានលក្ខណៈខ្លាំងក្លា និងស៊ីសង្វាក់គ្រប់គ្រាន់ ដើម្បីឱ្យមានតម្លៃជាភស្តុតាងបន្ទាល់[154]។

៨៥. អង្គបុរេជំនុំជម្រះពិចារណាឃើញថា "ទោះបីជាសញ្ញាណនៃ "បទចោទគ្រប់គ្រាន់" ដែលសហចៅក្រមស៊ើបអង្កេត ចាំបាច់ត្រូវតែពិចារណា ក្នុងការបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬ លើកលែងការចោទ

---

សំណុំរឿង ០០២ ដីកាសម្រេចលើកលែងការចោទប្រកាន់ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០ (ឯកសារ D420)។

[152] ដីកាដំណោះស្រាយ (ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ១២៣-១៣៦។ ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងការចោទប្រកាន់) (ឯកសារ D359) កថាខណ្ឌ ៤៨៥-៤៩១។

[153] វិធាន ៨៧ នៃវិធានផ្ទៃក្នុង។

[154] សំណុំរឿង ០០២ ដីកាដំណោះស្រាយ (ឯកសារ D427) កថាខណ្ឌ ១៣២៣ (លេខយោងជើងទំព័រត្រូវបានលុបចោល)។

ប្រកាន់ គមានភាពលំបាកក្នុងការធ្វើសទិទានកម្ម ប៉ុន្តែច្បាស់ណាស់ថា លក្ខខណ្ឌតម្រូវផ្លូវច្បាប់ សម្រាប់កិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការ វិវឌ្ឍន៍ជាបន្តបន្ទាប់ចាប់ពីត្រឹមលទ្ធភាព ឈានទៅដល់ "ភវនីយភាព" ឬ "ភាពអាចជឿជាក់បាន" នៃពិរុទ្ធភាពនៅក្នុងពេលស៊ើបអង្កេត ដើម្បីបង្ហាញភស្តុតាងនៃពិរុទ្ធភាពបែបនេះឱ្យហួសពីវិមតិសង្ស័យ នៅដំណាក់កាលជំនុំជម្រះ"[155]។ នៅក្នុងករណីស្រដៀងគ្នានោះ សហចៅក្រមស៊ើបអង្កេតនៃ EAC បានបញ្ជាក់ថា ទោះបីជានៅដំណាក់កាលមុនអង្គសេចក្តីមានភាពចាំបាច់ត្រូវមានលក្ខខណ្ឌលើសពីសូចនាករបញ្ជាក់ ឬ ភាពមន្ទិលសង្ស័យ ដើម្បីបញ្ជូនជនម្នាក់ទៅជំនុំជម្រះបានក៏ដោយ ភស្តុតាងដែលប្រមូលបានពុំទាន់ចាំបាច់ត្រូវបញ្ជាក់ពីពិរុទ្ធភាពឱ្យបានជាក់លាក់នៅឡើយនោះទេ [156]។ អង្គបុរេជំនុំជម្រះយល់ឃើញថា ការបកស្រាយនេះមានភាពត្រឹមត្រូវអាចយកមកអនុវត្តនៅក្នុងរឿងក្តីបច្ចុប្បន្ននេះបាន។ ជាការពិតណាស់ អង្គបុរេជំនុំជម្រះបានសម្រេចយ៉ាងស៊ីសង្វាក់គ្នាថា សញ្ញាណនៃ "បទចោទគ្រប់គ្រាន់" ឆ្លើយតបទៅនឹង*លក្ខខណ្ឌអប្បបរមា* នៃវិធាន ៥៥(៤) ស្តីពី "ភស្តុតាងស៊ីសង្វាក់ជាក់លាក់" ដែលបញ្ជាក់ថា ជនម្នាក់អាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋ នៅពេលដាក់បន្ទុក ឬ ចោទប្រកាន់ជនត្រូវចោទទៅជំនុំជម្រះ។

៨៦. ដោយមើលឃើញពីបទដ្ឋាននៃភស្តុតាងដែលអាចអនុវត្តបាន នៅក្នុងកិច្ចដំណើរការនីតិវិធីមុនអង្គសេចក្តី អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំចាំបាច់កំណត់ចំនួនជនរងគ្រោះឱ្យបានជាក់លាក់ និងត្រឹមត្រូវនោះទេ[157] ហើយពុំចាំបាច់ពិពណ៌នាលម្អិតអំពីវិធីសាស្ត្រដែលខ្លួនបានប្រើប្រាស់សម្រាប់ការកំណត់នោះដែរ[158]។ ទោះបីជាចំនួនជនរងគ្រោះគឺជាធាតុផ្សំមួយក្នុងចំណោមធាតុផ្សំដែលត្រូវយកមកពិចារណា សម្រាប់ការវាយតម្លៃលើស្ថានទម្ងន់នៃបទឧក្រិដ្ឋក៏ដោយ ក៏តុលាការពុំត្រូវការ[159] ចំនួន

---

[155] សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ៦២ *យោងលើ* Christian GUÉRY "Les paliers de la vraisemblance pendant l'instruction préparatoire", *La Semaine Juridique* (G. Ed. No. 24, ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៨)"។ ជាលទ្ធផល នេះពិតជាកំហុសអង្គច្បាប់ធ្ងន់ធ្ងរក្នុងការប្រកាសថា "ជនដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបឋមរបស់សហព្រះរាជអាជ្ញាត្រូវបានចាត់ទុកជាស្រេចរួចហើយថាជា "ជនត្រូវចោទ"" ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងការចោទប្រកាន់) (ឯកសារ D359) កថាខណ្ឌ ៥។

[156] *Habre* Ordonnance de non-lieu partiel (EAC) ទំព័រ ៥។

[157] សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ២១៤។

[158] ដីកាដំណោះស្រាយ (ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ១៣៧-១៥៤។

[159] *ឧទា. សូមមើល* តុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Stakić* IT-97-24-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៣ ("សាលក្រម *Stakić*") កថាខណ្ឌ ២០១ (អង្គជំនុំជម្រះសាលាដំបូងរកឃើញថា "ខ្លួនពុំអាច ហើយ

ជាក់លាក់សម្រាប់ការកំណត់ធាតុផ្សំនៃបទឧក្រិដ្ឋស្ទើរតែទាំងអស់នោះទេ។ ការប៉ាន់ស្មានចំនួនក្នុងកម្រិតសមហេតុផលមួយ ឬការយោងលើ "ការសម្លាប់ច្រើននាក់" ហាក់ដូចជាគ្រប់គ្រាន់ណាស់ទៅហើយ ហើយពុំរារាំងការសន្និដ្ឋានថា បទឧក្រិដ្ឋធ្ងន់ធ្ងរត្រូវបានប្រព្រឹត្តឡើងនៅកន្លែងជាក់លាក់មួយ និងក្នុងពេលជាក់លាក់ណាមួយនោះទេ[160]។

៨៧. ចៅក្រមនៃអង្គបុរេជំនុំជម្រះនឹងពិនិត្យទៅមូលដ្ឋាននីមួយៗនៃបណ្តឹងឧទ្ធរណ៍ ក្នុងករណីពាក់ព័ន្ធ ហើយនឹងទៅតាមករណីនីមួយៗ ដើម្បីកំណត់ថាតើសហចៅក្រមស៊ើបអង្កេតបានអនុវត្តបទដ្ឋាននៃភស្តុតាងសមស្របដែរឬទេ។

## ខ. ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា

៨៨. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ បានចេញដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) បញ្ជូន អោ អាន ទៅជំនុំជម្រះ[161]។ ក្នុងពេលជាមួយគ្នានោះ នៅក្នុងថ្ងៃតែមួយ សហចៅក្រមស៊ើបអង្កេតជាតិបានចេញដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) លើកលែងបទចោទទាំងអស់ប្រឆាំងនឹង អោ អាន[162]។ ជាផ្នែកមួយនៃយុត្តាធិការបណ្តឹងឧទ្ធរណ៍របស់ខ្លួន[163] អង្គបុរេជំនុំជម្រះនឹងសម្រេចថាតើ ការចេញដីកាដំណោះស្រាយពីរផ្សេងគ្នា ផ្ទុយគ្នាក្នុងពេល

---

នឹងនៅតែមិនអាចកំណត់អត្តសញ្ញាណថារីដែលស់ និងជនរងគ្រោះ ទៅតាមករណីនីមួយៗនោះទេ។ ក៏ប៉ុន្តែ ករណីនេះមិនរារាំងដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការសន្និដ្ឋានថា ការកាប់សម្លាប់ត្រូវបានប្រព្រឹត្តឡើងនៅកន្លែងជាក់លាក់មួយ និងក្នុងពេលជាក់លាក់មួយនោះទេ បើទោះជាពុំបានដឹងអំពីចំនួនជនរងគ្រោះជាក់លាក់ក៏ដោយ")។ *សូមមើលផងដែរ* តុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kamuhanda* ICTR-95-54A-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៤ កថាខណ្ឌ ៦៩៨។ តុលាការ ICTR រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Ntakirutimana* ICTR-96-10 & TCTR-96-17-T សាលក្រម និងការកំណត់ទោស អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៣ កថាខណ្ឌ ៦៣១, ៦៣៥។ *សូមមើល* តុលាការ ICTR រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Akayesu* សំណុំរឿងលេខ ICTR-96-40-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ ២៨២។

160 សាលក្រម *Stakić* (តុលាការ ICTY) កថាខណ្ឌ ២០១។

161 ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D360។

162 ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) ឯកសារ D359។

163 អង្គបុរេជំនុំជម្រះគាំទ្រដល់ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការ ICTY ដែលថា យុត្តាធិការតុលាការកំពូល បើតាមច្បាប់អន្តរជាតិ រួមមានសិទ្ធិអំណាចតាមផ្លូវច្បាប់ ""បញ្ជាក់អំពីច្បាប់ [...] នៅក្នុងលក្ខណៈស្ថាពរ និងសម្រេច" (តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង Tadic*, IT-94-1-AR72 សាលដីកាលើញត្តិរបស់មេធាវីការពារក្តី សុំប្តឹងឧទ្ធរណ៍បន្ទាន់

តែមួយ ដែលមិនធ្លាប់មានពីមុនមក នៅក្នុងសំណុំរឿងតែមួយ អនុលោមតាមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ដែរឬទេ។

៨៩. ផ្អែកលើសំអាងហេតុដែលបានលើកឡើង អង្គបុរេជំនុំជម្រះសម្រេចថា ដោយចេញដីកាដំណោះស្រាយដាច់ពីគ្នា សហចៅក្រមស៊ើបអង្កេតបានរំលោភបំពានទៅលើក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ប្រាសចាកពីតួនាទីខ្ពស់បំផុតរបស់ពួកគេ និងបង្កើតជាស្ថានភាពគតិយុត្តិដែលមិនធ្លាប់មាន ដែលធ្វើឱ្យប៉ះពាល់ដល់មូលដ្ឋានសំខាន់ៗនៃអង្គភាពតុលាការរបស់ពួកគេ។ អង្គជំនុំជម្រះពិភាក្សានៅក្នុងជំពូកផ្សេងៗគ្នាអំពីផលប៉ះពាល់នៃកំហុសជាសារវ័ន្តបែបនេះចំពោះស្ថានភាពផ្លូវច្បាប់ របស់ដីកាដំណោះស្រាយនីមួយៗ[164] និងសិទ្ធិអំណាចក្នុងការត្រួតពិនិត្យដែលអង្គជំនុំជម្រះត្រូវអនុវត្ត នៅក្នុងកាលៈទេសៈពិសេសបែបនេះ[165] ដើម្បីស្តារនីត្យានុកូលភាព និងផ្តល់ឧបាស្រ័យចំពោះការខូចខាតទៅលើនីតិវិធី ដែលកើតឡើងដោយសារតែកិច្ចមិនស្របច្បាប់របស់សហចៅក្រមស៊ើបអង្កេត នៅក្នុងសំណុំរឿងនេះ។

៩០. នៅក្នុងជំពូកនេះ អង្គបុរេជំនុំជម្រះនឹងពិនិត្យទៅលើ (១) ច្បាប់ដែលគ្រប់គ្រងទៅលើបញ្ហាចំពោះមុខ (២) យុត្តិកម្មដែលខុសឆ្គងរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញដីកាដំណោះស្រាយដាច់ពីគ្នា និង (៣) ថាតើនីតិវិធីដោះស្រាយការខ្វែងយោបល់គ្នា គួរត្រូវបានប្រើប្រាស់ដោយរបៀបណានៅក្នុងសំណុំរឿងនេះ។

## ១. ច្បាប់ជាធរមាន

៩១. ជាដំបូង អង្គបុរេជំនុំជម្រះកត់សម្គាល់ពីសារៈសំខាន់នៃការទទួលខុសត្រូវរួមរបស់សហចៅក្រមស៊ើបអង្កេតទាំងពីរ ក្នុងការបំពេញកិច្ចស៊ើបសួរនៅ អ.វ.ត.ក ដូចមានចែងក្នុងមាត្រា ១៤ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នៅក្នុងផ្នែកពាក់ព័ន្ធ ដែលថា “ចៅក្រមទាំងអស់ត្រូវព្យាយាមសម្រេចឱ្យបានភាពឯកច្ឆន្ទក្នុងសេចក្តីសម្រេចរបស់ខ្លួន”។ ជាពិសេស មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា៖

> រាល់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់ ម្នាក់ជាកម្ពុជា និងម្នាក់

---

ប្រឆាំងយុត្តាធិការ, អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ ១០។ សូមមើលផងដែរ កថាខណ្ឌ ១១)។ នៅក្នុងប្រព័ន្ធច្បាប់ អ.វ.ត.ក អង្គបុរេជំនុំជម្រះប្រើប្រាស់មុខងារនេះ ក្នុងនាមជាមជ្ឈត្តករចុងក្រោយ សម្រាប់ច្បាប់ដែលត្រូវអនុវត្ត ចំពោះដំណាក់កាលស៊ើបអង្កេតនៃកិច្ចដំណើរការនីតិវិធី។

[164] សូមមើល ខាងក្រោម កថាខណ្ឌ ១៧០ ដល់ ៣០០។

[165] សូមមើល ខាងលើ កថាខណ្ឌ ៣១ ដល់ ៥៤។

ទៀតជាបរទេស [...] ដោយអនុវត្តតាមនីតិវិធីដែលនៅជាធរមាន។ ប្រសិនបើនីតិវិធីដែលមានស្រាប់ ពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬ ប្រសិនបើមានបញ្ហាទាក់ទងទៅនឹង ភាពសមស្របនៃនីតិវិធីទាំងនេះ ជាមួយបទដ្ឋានអន្តរជាតិ សហចៅក្រមស៊ើបអង្កេត អាចស្វែងរក ការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ

៩២. ចំពោះការចេញដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះកត់សម្គាល់ថា វិធាន ៦៧ នៃវិធានផ្ទៃក្នុង បានចែងនៅត្រង់ផ្នែកពាក់ព័ន្ធថា៖

វិធាន ៦៧. ដីកាដំណោះស្រាយ ដោយសហចៅក្រមស៊ើបអង្កេត

១. សហចៅក្រមស៊ើបអង្កេត ត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយ ថាត្រូវចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់។ ដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា មិនចងសហចៅក្រមស៊ើបអង្កេតឡើយ ។

២. ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ ត្រូវបញ្ជាក់អំពីអត្តសញ្ញាណនៃជនជាប់ចោទ ការបង្ហាញអំពីអង្គហេតុ និងការកំណត់ប្រភេទបទល្មើស ដោយសហចៅក្រមស៊ើបអង្កេត ក្នុងនោះមានទាំងបទប្បញ្ញត្តិ នៃបទឧក្រិដ្ឋដែលពាក់ព័ន្ធ និងប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ បើពុំនោះសោត ដីកានេះត្រូវចាត់ទុកជាមោឃៈ ដោយមានកំហុសនីតិវិធី ។

៣. សហចៅក្រមស៊ើបអង្កេត ត្រូវចេញដីកាលើកលែងចោទប្រកាន់ ក្នុងករណីដូចខាងក្រោម:

ក-អំពើដែលចោទប្រកាន់ មិនរាប់ចូលជាបទឧក្រិដ្ឋ ដែលស្ថិតនៅក្រោមយុត្តាធិការ នៃអង្គជំនុំជម្រះវិសាមញ្ញ ។

ខ-ជនប្រព្រឹត្តបទឧក្រិដ្ឋនោះ មិនទាន់កំណត់អត្តសញ្ញាណនៅឡើយ ឬ

គ-ពុំមានភស្តុតាងគ្រប់គ្រាន់ ដើម្បីផ្តន្ទាទោសជនត្រូវចោទ

៤. ដីកាដំណោះស្រាយត្រូវតែមានសំអាងហេតុ។

៩៣. ចំពោះការខ្វែងយោបល់គ្នាណាមួយរវាងសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះកត់សម្គាល់ថា មាត្រា ៥(១), (៤) និង មាត្រា ៧ នៃកិច្ចព្រមព្រៀងស្តីពីការបង្កើតអ.វ.ត.ក បានចែងនៅក្នុងផ្នែកពាក់ព័ន្ធថា៖

មាត្រា ៥ ចៅក្រមស៊ើបអង្កេត

១-មានចៅក្រមស៊ើបអង្កេតខ្មែរមួយរូប និងចៅក្រមស៊ើបអង្កេតអន្តរជាតិមួយរូប ដែលបម្រើការជាសហចៅក្រម ស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេត ទទួលខុសត្រូវចំពោះការងារស៊ើបអង្កេត។

៤-សហចៅក្រមស៊ើបអង្កេតត្រូវសហការគ្នា ដើម្បីឈានទៅដល់ការឯកភាពគ្នាមួយក្នុងការស៊ើបអង្កេត។ នៅក្នុង ករណីដែលចៅក្រមស៊ើបអង្កេតមិនអាចឯកភាពគ្នាថា ត្រូវបន្តការស៊ើបអង្កេតណាមួយ ការស៊ើបអង្កេតនោះ ត្រូវដំណើរការទៅមុខទៀត លើកលែងតែចៅក្រមទាំងនេះ ឬចៅក្រមណាម្នាក់ក្នុងចំណោមចៅក្រមទាំងនេះ ធ្វើការស្នើសុំនៅក្នុងរយៈ ពេលសាមសិបថ្ងៃ ឱ្យដោះស្រាយការខ្វែងគំនិតគ្នានេះតាមមាត្រា ៧។

មាត្រា៧៖ ការដោះស្រាយនូវការខ្វែងយោបល់គ្នារវាង សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា

១-ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញាបានធ្វើសំណើស្របតាមមាត្រា៥ វាក្យខណ្ឌ៤ ឬមាត្រា៦ វាក្យខណ្ឌ៤ តាមករណីដែលកើតឡើង សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា ត្រូវធ្វើឯកសាររាយការណ៍ជាលាយលក្ខណ៍អក្សរពីអង្គហេតុ និងហេតុផលបញ្ជាក់ពីគោលជំហរខ្វែងគំនិតគ្នារបស់ខ្លួន ដាក់ជូនប្រធានការិយាល័យរដ្ឋបាល។

២-ការខ្វែងគំនិតគ្នានេះ នឹងត្រូវដោះស្រាយជាបន្ទាន់ដោយ "អង្គបុរេជំនុំជម្រះ" មួយមានចៅក្រមប្រាំរូប [...]

៣-ពេលដែលទទួលបានឯកសាររាយការណ៍ ដូចបានចែងក្នុងវាក្យខណ្ឌទី១ ប្រធានការិយាល័យរដ្ឋបាលត្រូវកោះប្រជុំអង្គបុរេជំនុំជម្រះភ្លាម និងបែងចែកឯកសាររាយការណ៍នេះ ជូនដល់សមាជិកអង្គបុរេជំនុំជម្រះ។

៤-ការសម្រេចសេចក្តីរបស់អង្គបុរេជំនុំជម្រះ ដែលមិនអាចប្តឹងឧទ្ធរណ៍បាន ត្រូវមានសំឡេងឆ្នោតគាំទ្រ ដោយ ចៅក្រមយ៉ាងតិចបួនរូប។ ការសម្រេចសេចក្តីនេះ ត្រូវជូនដល់ប្រធានរដ្ឋបាលដែលនឹងផ្សព្វផ្សាយ ហើយចែកជូនដល់សហ ចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា។ សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា នឹងត្រូវដំណើរការភ្លាមៗ ស្របទៅតាមការសម្រេចរបស់អង្គបុរេជំនុំជម្រះ។ ប្រសិនបើគ្មានមតិភាគច្រើន ដែលត្រូវការសម្រាប់ធ្វើការសម្រេច សេចក្តីទេការស៊ើបអង្កេត ឬការចោទប្រកាន់នឹងត្រូវបន្តដំណើរការទៅមុខទៀត។

៩៤. វិធាន ៧២ នៃវិធានផ្ទៃក្នុង ចែងលម្អិតអំពីនីតិវិធីដោះស្រាយការខ្វែងយោបល់គ្នាដូចតទៅ៖

វិធាន ៧២៖ ដំណោះស្រាយករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត

១. ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត សហចៅក្រមស៊ើប

អង្កេតណាម្នាក់ឬ ទាំងពីរអាចធ្វើកំណត់ហេតុអំពីមូលហេតុពិតប្រាកដនៃការខ្វែងយោបល់គ្នានេះដោយមានហត្ថលេខា និងចុះកាលបរិច្ឆេទដែលត្រូវយកទៅដាក់ចូលក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នាដោយឡែក ដែលរក្សាទុកដោយក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ។

២. ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ សហចៅក្រមស៊ើបអង្កេតណាម្នាក់អាចនាំយកករណីខ្វែងយោបល់គ្នានេះ ទៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយបញ្ជូនឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សរអំពីហេតុការណ៍ និង មូលហេតុនៃការខ្វែងយោបល់គ្នានេះទៅការិយាល័យរដ្ឋបាល ដែលត្រូវរៀបចំកោះប្រជុំអង្គបុរេជំនុំជម្រះជាបន្ទាន់ និងបញ្ជូនឯកសារទាំងនេះទៅចៅក្រមទាំងអស់ ដោយចម្លងជូនមួយច្បាប់ទៅសហចៅក្រមស៊ើបអង្កេតម្ខាងទៀត ។ ប្រសិនបើការខ្វែងយោបល់គ្នាពាក់ព័ន្ធទៅនឹងការឃុំខ្លួនបណ្ដោះអាសន្នរបស់ជនត្រូវចោទ រយៈពេលនេះត្រូវបន្ថយមកត្រឹម៥(ប្រាំ)ថ្ងៃវិញ។ ក្នុងករណីនេះ សហចៅក្រមស៊ើបអង្កេតម្ខាងទៀត អាចដាក់ជូនឯកសារឆ្លើយតបក្នុង រយៈពេល១០(ដប់)ថ្ងៃ ។ ឯកសារអំណះអំណាងដែលទាក់ទងនឹងអង្គហេតុ និងមូលហេតុនៃការខ្វែងយោបល់គ្នា មិនត្រូវដាក់ចូលក្នុងសំណុំរឿងទេ លើកលែងតែក្នុងករណីដែលមានចែងក្នុងអនុវិធាន ៤ (ខ) ខាងក្រោម។ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេតត្រូវបញ្ជូនសំណុំរឿងថតចម្លងមួយច្បាប់ទៅអង្គបុរេជំនុំជម្រះភ្លាម ។

៣. ក្នុងអំឡុងពេលនៃការដោះស្រាយការខ្វែងយោបល់គ្នានេះ សហចៅក្រមស៊ើបអង្កេតត្រូវប្រឹងប្រែងស្វែងរកការឯកភាពគ្នា ។ កិច្ច ឬ សេចក្ដីសម្រេចដែលជាកម្មវត្ថុនៃការខ្វែងយោបល់គ្នានេះ ត្រូវតែអនុវត្តលើកលែងតែបញ្ហាខ្វែងយោបល់គ្នាពាក់ព័ន្ធទៅនឹងចំណុចដូចខាងក្រោម ៖

ក-សេចក្ដីសម្រេចណាមួយដែលអាចនាំឲ្យជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណីធ្វើបណ្ដឹងឧទ្ធរណ៍ ដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ ។

ខ-ការជូនដំណឹងអំពីបទចោទប្រកាន់ ។ ឬ

គ-ដីកាបង្គាប់ឲ្យចាប់ខ្លួន ។

ក្នុងករណីទាំងនេះ គ្មានសកម្មភាពណាមួយដែលពាក់ព័ន្ធទៅការខ្វែងយោបល់គ្នា ត្រូវបានអនុវត្តទេ រហូតដល់មានការព្រមព្រៀងគ្នាណាមួយត្រូវបានបង្កើតឡើង ឬរយៈពេល៣០ (សាមសិប) ថ្ងៃ បានកន្លងហួស ឬ អង្គបុរេជំនុំជម្រះបានទទួលយករឿងខ្វែងយោបល់គ្នាមកជំនុំជម្រះ ហើយបានបញ្ចប់នីតិវិធីដោះស្រាយបញ្ហាខ្វែងយោបល់គ្នានេះ ។

៤. អង្គបុរេជំនុំជម្រះ ត្រូវដោះស្រាយបញ្ហាខ្វែងយោបល់នេះ ដូចខាងក្រោម ៖[...]

ឃ-សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឲ្យមានសម្លេងគាំទ្រពីចៅក្រម ៤(បួន)រូប

យ៉ាងតិច។ សេចក្តីសម្រេចនេះបិទផ្លូវប្តឹងឧទ្ធរណ៍។ ប្រសិនបើអង្គបុរេជំនុំជម្រះ មិនអាចរក បាននូវសម្លេងគាំទ្រភាគច្រើន តាមការតម្រូវស្របតាមមាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានោះ សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្រ មាន ន័យថាដីកាកិច្ចស៊ើបសួរដែលធ្វើឡើងដោយ សហចៅក្រមស៊ើបអង្កេតណាម្នាក់ ត្រូវមានសុពលភាព ឬមានន័យថា ដីកា ឬ កិច្ចស៊ើបសួរ ដែលបម្រុងនឹងធ្វើដោយសហចៅក្រមស៊ើប អង្កេតម្នាក់ ត្រូវតែយកមកអនុវត្ត។ [...]

៩៥. ជាចុងក្រោយ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា មាត្រា ១២(១) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក និងវិធាន ២ នៃវិធានផ្ទៃក្នុង កំណត់ថា នីតិវិធីនៅចំពោះមុខ អ.វ.ត.ក ចាំបាច់ត្រូវអនុលោមទៅតាមច្បាប់កម្ពុជា និងបទដ្ឋានអន្តរជាតិ។ ក្នុងន័យនេះ មាត្រា ១(១) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាបានចែងនៅក្នុងផ្នែកពាក់ព័ន្ធថា ក្រមនេះ "មានគោលបំណងកំណត់អំពីវិធានទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ ដើម្បីកំណត់ឲ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ"។ មាត្រា ២០ថ្មី ២៣ថ្មី ៣៣ថ្មី និង៣៧ថ្មី នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក ក៏បានចែងយ៉ាងច្បាស់ថា ស្ថាប័នរបស់ អ.វ.ត.ក ត្រូវតែគោរពតាមនីតិវិធីដែលនៅជាធរមានទាំងអស់។ អង្គជំនុំជម្រះសម្រេចថា បទប្បញ្ញត្តិទាំងអស់នេះមានគោលដៅធានានូវនីត្យានុកូលភាព ភាពយុត្តិធម៌ និងប្រសិទ្ធិភាពរបស់កិច្ចដំណើរការនីតិវិធី អ.វ.ត.ក។

## ២. សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញដីកាដំណោះស្រាយដែលដាច់ពីគ្នា

៩៦. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា នីតិវិធីសំណុំរឿង ០០៤/២ មានការខ្វែងយោបល់គ្នាជាសម្ងាត់មួយចំនួនរវាងសហចៅក្រមស៊ើបអង្កេត[166]។ ការខ្វែងយោបល់គ្នាទាំងនេះ មិនត្រូវបានលើកយកមកដាក់

---

[166] អង្គបុរេជំនុំជម្រះកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតមិនបានលើកឡើងអំពីការខ្វែងយោបល់ដូចគ្នាឡើយ នៅក្នុងដីកាដំណោះស្រាយរបស់ខ្លួននីមួយៗ។ សូមមើល ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D360 កថាខណ្ឌ ១ ("ការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ក្នុងសំណុំរឿងនេះ ត្រូវបានចុះកំណត់ហេតុនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ ២០១៣, ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៣, ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥, ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ និងថ្ងៃទី១២ ខែកក្កដា ឆ្នាំ ២០១៨")។ សូមមើលផងដែរ ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) ឯកសារ D359 កថាខណ្ឌ ២២ ("នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេត បានចុះកំណត់ហេតុការខ្វែងយោបល់អំពីរបៀបនិងវិធីសាស្ត្រនៃការស៊ើបអង្កេត") កថាខណ្ឌ ៤៥ ("នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១២ ស.ច.ស បានធ្វើការខ្វែងយោបល់ ទាក់ទិនដីកាចាត់ឲ្យស៊ើបសួរជំនួស និងការឆ្លើយតបទៅ ស.ព លើសំណើសុំការស៊ើបអង្កេត") កថាខណ្ឌ ៤៧ ("នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៣ ស.ច.ស បានខ្វែងយោបល់ទាក់ទង ការផ្តល់លេខក្នុងសំណុំរឿងនេះ") កថាខណ្ឌ ៤៩ ("នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៤ ស.ព.អ បានខ្វែង

នៅចំពោះមុខអង្គបុរេជំនុំជម្រះឡើយ។ ដូចដែលបានកត់សម្គាល់ខាងលើ នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយពីរដាច់ពីគ្នា និងផ្ទុយពីគ្នា ក្នុងពេលតែមួយ។ ការដាក់ដីកាដំណោះស្រាយដែលដាច់ពីគ្នា បានបង្ហាញពីការខ្វែងយោបល់គ្នា ដែលមិនអាចដោះស្រាយបានរវាងសហចៅក្រមស៊ើបអង្កេត ទៅលើបញ្ហាថាតើ អោ អាន ត្រូវស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត .ក ដែរឬយ៉ាងណា។

៩៧. សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការចេញដីកាដំណោះស្រាយដាច់ពីគ្នា និងផ្ទុយគ្នានេះ ត្រូវបានបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ពួកគាត់ចំនួនពីរ នាពេលកន្លងមកហើយ ដែលបានអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាដាក់ដីកាសន្និដ្ឋានស្ថាពរពីរដាច់ពីគ្នា ("ដីកាសម្រេចលើសំណើសុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធ នឹងការខ្វែងយោបល់គ្នា")[167] ហើយសម្រេចថា ច្បាប់ជាធរមានអនុញ្ញាតឱ្យដាក់ឯកសារបែបនេះបាន ("ដីកាសម្រេចលើសំណើសុំការបញ្ជាក់បំភ្លឺ")[168]។ អង្គបុរេជំនុំជម្រះចាត់ទុកថា ជារឿងសំខាន់ដែលត្រូវដកស្រង់មួយផ្នែកធំចេញពីដីកាសម្រេចនេះ ដោយចាប់ផ្តើមពី ដីកាសម្រេចលើសំណើសុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នា៖

> ១៤. ដើម្បីកុំឱ្យមានការតវ៉ា អំពីចំណុចនេះនាពេលអនាគត និងដើម្បីចំណេញពេលវេលាសម្រាប់ភាគីទាំងអស់ យើងសូមបញ្ជាក់ថា យើងពិចារណាចេញដីកាដំណោះស្រាយ ដាច់ដោយឡែកពីគ្នានិងផ្ទុយគ្នា ដែលដែលបានអនុញ្ញាតជាទូទៅ តាមច្បាប់ជាធរមាន ជាពិសេសតាមសំអាងហេតុ ដែលយើងបានរកឃើញពាក់ព័ន្ធនឹង ដីកាសន្និដ្ឋានស្ថាពរផ្ទុយគ្នា [...]
>
> ១៥. យើងដឹងអំពីបញ្ហាដែលអាចនឹងកើតឡើង នៅដំណាក់កាលបណ្តឹងឧទ្ធរណ៍។ វិធានផ្ទៃក្នុង ៧៧(១៣) គ្រាន់តែចែងអំពីសេណារីយ៉ូ ដែលមានដីកាលើកលែងការចោទប្រកាន់ ឬក៏មានដីកាចោទប្រកាន់ បញ្ជូនទៅជំនុំជម្រះរួមគ្នា ប៉ុន្តែមិនមានចែងអំពីដីកាដំណោះស្រាយ ដាច់ដោយឡែកពីគ្នាទេ។ យ៉ាងណាក៏ដោយមិនមានយុត្តិកម្មទេ ប្រសិនបើអះអាងថា មានការហាមឃាត់មិនឱ្យមាន ដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា។ ផ្ទុយមកវិញ ជាឧទាហរណ៍ នៅក្នុង

---

យោបល់លើការសួរតទល់គ្នារវាងសាក្សី") កថាខណ្ឌ ៥០ ("នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ ស.ច.ស បានខ្វែងយោបល់ពីការជូនដំណឹងពីបទចោទទៅ អោ អាន")។

[167] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ១៤ *យោងទៅរក* ដីកាសម្រេចលើសំណើសុំដាក់បង្ហាញ ឯកសារដែលពាក់ព័ន្ធ ការខ្វែងយោបល់គ្នា ឯកសារ D355/1កថាខណ្ឌ ១៣-១៦។

[168] សំណុំរឿង ០០៤/២ ដីកាសម្រេចលើសំណើរបស់ អោ អាន សុំការបញ្ជាក់បំភ្លឺ ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D353/1 ("ដីកាសម្រេចលើសំណើសុំការបញ្ជាក់បំភ្លឺ (ឯកសារ D353/1)")។

សាលដីការបស់ខ្លួននៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះតុលាការកំពូល បានទទួលស្គាល់យ៉ាងច្បាស់អំពីសេណារីយ៉ូដែល ស.ច.ស មានសំអាងហេតុខ្វែងយោបល់ អំពីយុត្តាធិការបុគ្គល ហើយក៏ទទួលស្គាល់យ៉ាងច្បាស់ថា នៅក្នុងបរិបទនៃនីតិវិធីខ្វែងយោបល់ កិច្ចស៊ើបសួរត្រូវបន្តទៅមុខ។

១៦. យើងយល់ឃើញថា ដំណាក់កាលស៊ើបសួរ ចប់នៅពេលចុងក្រោយបំផុត គឺនៅពេលដែលអង្គបុរេជំនុំជម្រះចេញសាលដីកាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ។ ប្រសិនបើអង្គបុរេជំនុំជម្រះ មិនមានសម្លេងភាគច្រើន គាំទ្រដីកាដំណោះស្រាយណាមួយ ក្នុងចំណោមដីកាដំណោះស្រាយទាំងពីរទេនោះ ដីកាដំណោះស្រាយទាំងពីរ ត្រូវតម្កល់ទុកជាបានការ តាមការអនុវត្តវិធានផ្ទៃក្នុង ៧៧(១៣)។[169]

នៅក្នុងដីកាសម្រេចលើសំណើសុំការបញ្ជាក់បំភ្លឺ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ពាក់ព័ន្ធនីតិវិធីការខ្វែងយោបល់គ្នា៖

២៣. ដោយសារថា ការដាក់ដីកាសន្និដ្ឋានស្ថាពរពីរ គឺជាភស្តុតាងបញ្ជាក់ពីការខ្វែងយោបល់រវាងសហព្រះរាជអាជ្ញា ទើបបញ្ហាចោទថាតើសហព្រះរាជអាជ្ញា មានកាតព្វកិច្ចត្រូវប្រើប្រាស់ទាំងស្រុង នូវវិធានការដោះស្រាយជម្លោះដែរឬអត់ និយាយម្យ៉ាងទៀតថាតើ យន្តការដោះស្រាយយោងតាម វិធានផ្ទៃក្នុង ៧១ គឺជាលក្ខខណ្ឌតម្រូវ ឬក៏ជាឆន្ទានុសិទ្ធិ [...] ដែលស្ថិតនៅក្នុងដែនអំណាចរបស់យើង [សហចៅក្រមស៊ើបអង្កេត] ពីព្រោះថាបញ្ហាចោទនេះ ពាក់ព័ន្ធនឹងការអាចទទួលយក ដីកាសន្និដ្ឋានស្ថាពរ [...]។

២៧. យើង [...] ឃើញច្បាស់ថាតាមច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង ការធ្វើកំណត់ហេតុករណីខ្វែងយោបល់ រវាងសហព្រះរាជអាជ្ញា គឺជាបញ្ហាឆន្ទានុសិទ្ធិ។ ហេតុនេះយើងមិនយល់ឃើញ សហព្រះរាជអាជ្ញាមានកាតព្វកិច្ច ប្រើប្រាស់ទាំងស្រុង នូវវិធានការដោះស្រាយជម្លោះទេ។ [...][170]

ចំពោះភាពស្របច្បាប់នៃការដាក់ដីកាសន្និដ្ឋានស្ថាពរជាច្រើននោះ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់នៅក្នុងដីកាសម្រេចដដែលថា៖

---

[169] ដីកាសម្រេចលើការបង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នា (ឯកសារ D353/1) កថាខណ្ឌ ១៤-១៦ (លុបចោលជើងទំព័រ)។

[170] ដីកាសម្រេចលើសំណើសុំការបញ្ជាក់បំភ្លឺ (ឯកសារ D353/1) កថាខណ្ឌ ២៣, ២៧។

៣២. យើងយល់ស្រប [...] ខ្លឹមសារមួយនៃវិធានផ្ទៃក្នុង ៦៦(៥) ចែងអំពីដីកាសន្និដ្ឋានស្ថាពរមួយ ប៉ុន្តែភាសានេះមិនតម្រូវឱ្យមាន ដីកាសន្និដ្ឋានស្ថាពរមួយរួមគ្នាទេ ហើយក៏មិនបានដកចេញនូវការដាក់ ដីកាសន្និដ្ឋានស្ថាពរដាច់ដោយឡែកពីគ្នាដែរ [...]។ សហព្រះរាជអាជ្ញាត្រូវធ្វើការរួមគ្នា ដើម្បីរៀបចំសេចក្តីសន្និដ្ឋានចោទប្រកាន់ ប៉ុន្តែការដែលសហព្រះរាជអាជ្ញា អាចខ្វែងយោបល់គ្នា ត្រូវបានទទួលស្គាល់នៅក្នុង កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ ជាមួយរាជរដ្ឋាភិបាលកម្ពុជា ដែលតម្រូវឱ្យសហព្រះរាជអាជ្ញា "សហការគ្នាដើម្បីឈានទៅដល់ការឯកភាពមួយ ក្នុងការចោទប្រកាន់" ហើយពិតណាស់មានបទប្បញ្ញត្តិ អំពីយន្តការដោះស្រាយជម្លោះ ដោយកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ ជាមួយរាជរដ្ឋាភិបាលកម្ពុជា ចែងយ៉ាងច្បាស់ថា អាចមានករណីខ្វែងយោបល់គ្នា "ថាតើត្រូវបន្តការចោទប្រកាន់ដែរឬអត់"។

៣៣. ការពិចារណាថែមទៀតគឺថា [...] យើង [សហចៅក្រមស៊ើបអង្កេត] មិនជាប់កាតព្វកិច្ចត្រូវទទួលយកខ្លឹមសារ នៃដីកាសន្និដ្ឋានស្ថាពរណាមួយឡើយ [...]

៣៤. ចំពោះការអះអាងដែលថា ការដាក់ដីកាសន្និដ្ឋានស្ថាពរពីរ គឺផណ្តើមយក "អំណាចផ្តាច់មុខ" របស់អង្គបុរេជំនុំជម្រះយ៉ាងស្រួល ដើម្បីដោះស្រាយជម្លោះ [...] យើងមិនយល់ឃើញថាការប្តឹងទៅអង្គបុរេជំនុំជម្រះ គឺជាលក្ខខណ្ឌតម្រូវចាំបាច់ទេ ហេតុនេះមិនមានអំណាចផ្តាច់មុខដែលត្រូវផណ្តើមទេ។[171]

៩៨. នៅពេលចាប់ផ្តើម អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ការដាក់ដីកាសន្និដ្ឋានស្ថាពរពីរផ្សេងគ្នារបស់សហព្រះរាជអាជ្ញា មិនបានរារាំងសហចៅក្រមស៊ើបអង្កេតមិនឱ្យចេញដីកាដំណោះស្រាយតែមួយ នៅក្នុងសំណុំរឿង០០៤/២ទេ[172]។ ក្នុងន័យនេះ អង្គជំនុំជម្រះសង្កត់ធ្ងន់ ក្នុងលក្ខណៈជាបញ្ហាបឋម ពីភាពខុសគ្នាជាសារវន្តដែលមានចំពោះមុខងារ និងសិទ្ធិអំណាចរវាងសារណារបស់ភាគី និងសេចក្តីសម្រេចតាមផ្លូវតុលាការ ដែលចេញដោយចៅក្រម ដូចជា ដីកាដំណោះស្រាយជាដើម។ឯករាជ្យភាពនៃបញ្ហាថាតើការដាក់ដីកាសន្និដ្ឋានស្ថាពរ ដែលដាច់ពីគ្នា និងផ្ទុយគ្នា ដោយសហព្រះរាជអាជ្ញា ត្រូវបានអនុញ្ញាតដែរឬអត់ នៅក្នុងប្រព័ន្ធច្បាប់របស់ អ.វ.ត.ក នោះ អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្តកំហុសអង្គច្បាប់ដ៏ធំធេងក្នុងករណីនេះ ដោយសារសហចៅក្រមស៊ើបអង្កេតសម្រេចថា ក្របខណ្ឌគតិយុត្តិ

---

[171] ដីកាសម្រេចលើសំណើសុំការបញ្ជាក់បំភ្លឺ (ឯកសារ D353/1) កថាខណ្ឌ ៣២-៣៤ (គូសបញ្ជាក់និង លុបចោលជើងទំព័រ)។

[172] ក្នុងន័យនេះ អង្គបុរេជំនុំជម្រះ យល់ថាការចេញដីកាដំណោះស្រាយពីរនេះ គឺជានីតិវិធីមិនប្រក្រតីដំបូងដែលមិនអាចប្រកែកបាន នៅក្នុងដំណាក់កាលបិទការស៊ើបសួរ។

អ.វ.ត.ក អនុញ្ញាតឱ្យចេញដីកាដំណោះស្រាយ ដែលដាច់ពីគ្នា និងផ្ទុយគ្នា។

៩៩. បន្ថែមលើនេះទៀត និងបើទោះបីជាអាចសន្មតថា សហចៅក្រមស៊ើបអង្កេតអាចប្រព្រឹត្តកំហុសអង្គច្បាប់នេះ ក្នុងគោលបំណងល្អក្តី ប៉ុន្តែ អង្គជំនុំជម្រះមិនអាចមិនគិតថា សហចៅក្រមស៊ើបអង្កេតប្រហែលមានចេតនាពិតប្រាកដក្នុងការគេចវេសពីការអនុវត្តច្បាប់ នៅក្នុងករណីនេះ ហើយបង្កើតភាពទាល់ច្រកផ្នែកនីតិវិធីនាពេលបច្ចុប្បន្ន។ តាមពិតទៅ តាមរយៈដីកាសម្រេចពីខាងលើរបស់ពួកគេ ច្បាស់ណាស់ថា សហចៅក្រមស៊ើបអង្កេតព្យាយាមធានាដោយមានចេតនាថា ដំណោះស្រាយណាមួយចំពោះបញ្ហាដែលពួកគេខ្វែងយោបល់គ្នា នឹងត្រូវបានដោះស្រាយតែក្នុងផ្នែកនៃកិច្ចដំណើរការបណ្តឹងឧទ្ធរណ៍ នៅចំពោះមុខអង្គបុរេជំនុំជម្រះតែប៉ុណ្ណោះ មិនមែនតាមរយៈនីតិវិធី ដែលបានកំណត់ជាក់លាក់ដោយក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក សម្រាប់ដោះស្រាយតែចំពោះការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតនោះទេ។ សហចៅក្រមស៊ើបអង្កេតបានដឹងអំពីការលំបាកដែលបណ្តាលមកពីសកម្មភាពរបស់ពួកគាត់[173]។ ប៉ុន្តែ ពួកគាត់ធ្វើឱ្យប្រាកដក្នុងការបិទបាំងការខ្វែងយោបល់ ពីយន្តការដោះស្រាយតាមផ្លូវច្បាប់ប្រកបដោយប្រសិទ្ធភាព ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង។

១០០. អង្គបុរេជំនុំជម្រះសូមប្រកាសថ្កោលទោសយ៉ាងច្បាស់លាស់ចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើប្រព័ន្ធច្បាប់របស់ អ.វ.ត.ក នេះ។ អង្គជំនុំជម្រះនឹងបញ្ជាក់អំពីច្បាប់ជាធរមានដែលត្រឹមត្រូវ មុនពេលធ្វើការពិចារណានៅក្នុងជំពូកមួយផ្សេងទៀត អំពីផលវិបាកជាក់ស្តែងដែលចាំបាច់ សម្រាប់ការរំលោភបំពានរបស់សហចៅក្របស៊ើបអង្កេតទៅលើក្របខណ្ឌច្បាប់របស់ អ.វ.ត.ក។

## ៣. ការពិភាក្សា

១០១. ដូចនឹងប្រព័ន្ធច្បាប់ដទៃទៀតដែរ ច្បាប់គ្រប់គ្រងលើកិច្ចដំណើរការនីតិវិធី អ.វ.ត.ក មិនដោះស្រាយរាល់ភាពមិនច្បាស់លាស់ផ្នែកគតិយុត្តិ ដែលអាចលេចឡើងទាក់ទងនឹងបញ្ហាអង្គសេចក្តី និងបញ្ហានីតិវិធីឡើយ។ ប៉ុន្តែ ច្បាប់នេះបានត្រៀមទុកសម្រាប់ការខ្វែងយោបល់គ្នាដែលអាចកើតឡើង នៅក្នុងបរិបទចម្រុះគ្នារបស់ អ.វ.ត.ក ហើយចែងអំពីនីតិវិធី ដើម្បីចាត់ចែង និង/ឬ ដោះស្រាយការខ្វែងយោបល់គ្នាបែបនេះ ដើម្បីជៀសវាងភាពទាល់ច្រកផ្នែកនីតិវិធីណាមួយ។ បើតាមកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក មុខ

---

[173] ដីកាសម្រេចលើសំណើសុំដាក់បង្ហាញ ឯកសារដែលពាក់ព័ន្ធការខ្វែងយោបល់គ្នា (ឯកសារ D355/1 ) កថាខណ្ឌ ១៥។ *សូមមើលផងដែរ* កថាខណ្ឌ ១៦។

01634818



ងារចម្បងដែលផ្តល់ជូនអង្គបុរេជំនុំជម្រះ គឺផ្តល់យ៉ាងច្បាស់នូវយន្តការដើម្បីដោះស្រាយជាស្ថាពរ ចំពោះការខ្វែងយោបល់គ្នា រវាងសហព្រះរាជអាជ្ញា និងរវាងសហចៅក្រមស៊ើបអង្កេត។ ក្នុងករណីនេះ សហចៅក្រមស៊ើបអង្កេតសម្រេចគេចវេសពីយន្តការនេះ ហើយជាជំនួស បានចេញដីកាដំណោះស្រាយដាច់ពីគ្នា និងផ្ទុយគ្នា ទាំងដែលដឹងច្បាស់ថាសកម្មភាពបែបនេះនឹងបណ្តាលឱ្យមានបញ្ហានៅក្នុងប្រព័ន្ធច្បាប់ អ.វ.ត.ក។

១០២. អង្គបុរេជំនុំជម្រះចាំបាច់ត្រូវសម្រេចថាតើ សកម្មភាពនេះគោរពតាមក្របខណ្ឌច្បាប់ អ.វ.ត.ក ដែរឬអត់។ សម្រាប់សំអាងហេតុដូចបានលើកឡើងនេះ អង្គជំនុំជម្រះសម្រេចថា ការចេញដីកាដំណោះស្រាយដាច់ពីគ្នារបស់សហចៅក្រមស៊ើបអង្កេត បានរំលោភបំពានទៅលើមូលដ្ឋានផ្ទាល់នៃប្រព័ន្ធច្បាប់ អ.វ.ត.ក។ អង្គជំនុំជម្រះនឹងពិភាក្សាអំពី (ក) គោលការណ៍ជាសារវ័ន្តគ្រប់គ្រងលើការខ្វែងយោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេត និង (ខ) នីតិវិធីដែលមានស្រាប់ ក្នុងការដោះស្រាយការខ្វែងយោបល់គ្នារវាងចៅក្រម និង (គ) ផ្តល់ការសន្និដ្ឋានចំពោះការចេញដីកាដំណោះស្រាយពីដែលផ្ទុយគ្នា ក្នុងពេលតែមួយរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងសំណុំរឿងនេះ។

### ក. គោលការណ៍ជាសារវ័ន្តគ្រប់គ្រងលើការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត

១០៣. ជាបឋម អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ការបំពេញកិច្ចស៊ើបសួររួមគ្នា ដោយសហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺជាគោលការណ៍គតិយុត្តិជាមូលដ្ឋានដ៏សំខាន់នៅ អ.វ.ត.ក ដូចមានចែងក្នុងមាត្រា ៥(១) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក "មានចៅក្រមស៊ើបអង្កេតខ្មែរមួយរូប និងចៅក្រមស៊ើបអង្កេតអន្តរជាតិមួយរូប ដែលបម្រើការជាសហចៅក្រមស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតទទួលខុសត្រូវចំពោះការងារស៊ើបអង្កេត"។

១០៤. ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ពង្រឹងគោលការណ៍ជាសារវ័ន្តនេះ ដោយចែងថា "ចៅក្រមទាំងអស់ត្រូវព្យាយាមសម្រេចឱ្យបានភាពឯកច្ឆ័ន្ទក្នុងសេចក្តីសម្រេចរបស់ខ្លួន"[174]។ សំខាន់ជាងនេះ មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មិនត្រឹមតែចែងឡើងវិញពីគោលការណ៍នេះប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងចែងពីការបញ្ជាក់បន្ថែមទៀតអំពីថាតើគោលការណ៍នេះត្រូវអនុវត្តតាមរបៀបណា ដោយតម្រូវយ៉ាងច្បាស់ថា "រាល់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់ ម្នាក់ជាកម្ពុជា និងម្នាក់ទៀត

[174] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ១៤(១)។

ជាបរទេស ដែលហៅថា "សហចៅក្រមស៊ើបអង្កេត" ដោយអនុវត្តតាមនីតិវិធីដែលនៅជាធរមាន"[175]។ អង្គជំនុំជម្រះសម្រេចថា បទប្បញ្ញត្តិនេះមានន័យថា សហចៅក្រមស៊ើបអង្កេតត្រូវបំពេញកិច្ចស៊ើបសួររួមគ្នា ហើយអនុលោមទៅតាមបទប្បញ្ញត្តិច្បាប់ជាធរមាននៅ អ.វ.ត.ក។ អង្គជំនុំជម្រះកត់សម្គាល់ទៀតថា បទប្បញ្ញត្តិនេះបានឆ្លុះបញ្ចាំងអំពីមាត្រា ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលចែងថា ក្រមនេះ "មានគោលបំណងកំណត់អំពីវិធានទាំងឡាយ ដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ ដើម្បីកំណត់ឱ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ"[176]។

១០៥. នាពេលកន្លងមក អង្គបុរេជំនុំជម្រះបានទទួលស្គាល់ជាគោលការណ៍នូវលទ្ធភាព និងសុពលភាព ដែលសហចៅក្រមស៊ើបអង្កេតមួយរូប បំពេញកិច្ចតែម្នាក់ឯង ជាពិសេសនៅក្នុងករណីដែល សហការីរបស់គាត់បានដកខ្លួនចេញពីការបន្តកិច្ចស៊ើបសួរ[177]។ អង្គជំនុំជម្រះបានបញ្ជាក់ដោយច្បាស់លាស់បំផុតថា "វិធានចែងថា សហចៅក្រមស៊ើបអង្កេតម្នាក់ អាចបំពេញកិច្ចមានសុពលភាពតែម្នាក់ឯងបាន ប្រសិនបើលក្ខខណ្ឌតម្រូវនៃនីតិវិធីនៃការខ្វែងយោបល់គ្នាត្រូវបានបំពេញ"[178]។ អង្គជំនុំជម្រះលើកឡើងទៀតថា "ក្របខណ្ឌច្បាប់បច្ចុប្បន្ន មានប្រព័ន្ធត្រួតពិនិត្យគ្រប់គ្រាន់ ដើម្បីធានាថា សកម្មភាពជាឯកតោភាគីត្រូវបាន

---

[175] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២៣ (ដោយគូសបញ្ជាក់បន្ថែម)។

[176] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ១។

[177] សំណុំរឿង ០០៤/១ (អង្គបុរេជំនុំជម្រះ ២០) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើញត្តិសុំពិចារណាឡើងវិញ និងសុំលុបចោលដីកាកោះ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៤ ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D236/1/1/8 ("សំណុំរឿង ០០៤/១ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ពាក់ព័ន្ធដីកាកោះ (ឯកសារ D236/1/1/8)") កថាខណ្ឌ ៣០ ("វិធានជាធរមានចែងច្បាស់ថា សហចៅក្រមស៊ើបអង្កេតម្នាក់ អាចបំពេញកិច្ចតែម្នាក់ឯងបាន ប្រសិនបើនីតិវិធីនៃការខ្វែងយោបល់គ្នា ត្រូវបានអនុវត្តតាម")។ សូមមើលផងដែរ សំណុំរឿង ០០៤ (អង្គបុរេជំនុំជម្រះ០៩) សេចក្តីសម្រេចលើសំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម សុំព្យួរការអនុវត្ត ដីកាកោះហៅអ្នកស្រី ឱ្យមកបង្ហាញខ្លួនជាលើកដំបូង ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤ ឯកសារ A122/6.1/3 ("សំណុំរឿង ០០៤ សេចក្តីសម្រេចលើសំណើសុំព្យួរការអនុវត្ត (ឯកសារ A122/6.1/3)") កថាខណ្ឌ ១៤។

[178] សំណុំរឿង ០០៤ (អង្គបុរេជំនុំជម្រះ១៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន ប្រឆាំងដីកាសម្រេច បដិសេធសំណើរបស់គាត់ ស្នើសុំព័ត៌មានទាក់ទងនឹង ករណីខ្វែងយោបល់គ្នា របស់សហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៣, ថ្ងៃ ទី២២ ខែមករា ឆ្នាំ២០១៥ ឯកសារ D208/1/1/2 ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងការបដិសេធមិនផ្តល់ព័ត៌មាន (ឯកសារ D208/1/1/2)") កថាខណ្ឌ ១១។ សូមមើល សំណុំរឿង០០៤ សេចក្តីសម្រេចលើសំណើសុំព្យួរការអនុវត្ត (ឯកសារ A122/6.1/3) កថាខណ្ឌ ១៤។ សំណុំរឿង ០០៤/១ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ពាក់ព័ន្ធដីកាកោះ (ឯកសារ D236/1/1/8) កថាខណ្ឌ ២៤។ សូមមើលផងដែរ សំណុំរឿង ០០៣ ការពិចារណាលើការសម្រេច ដាក់ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ឯកសារ D128/1/9 កថាខណ្ឌ ៣៤។

ធ្វើឡើងអនុលោមទៅតាមច្បាប់"[179]។

១០៦. នៅក្នុងការសម្រេចមួយផ្សេងទៀត អង្គជំនុំជម្រះបញ្ជាក់ច្បាស់ថា "សហចៅក្រមស៊ើបអង្កេត មិនមានកាតព្វកិច្ចក្នុងការជូនដំណឹងដល់អង្គបុរេជំនុំជម្រះទេ នៅពេលដែលខ្លួនមិនព្រមព្រៀងគ្នាលើ បញ្ហាណាមួយដែលនៅចំពោះមុខ" ប្រសិនបើចៅក្រមឯកភាពលើវិធីសាស្ត្រដែល "ស្រប" ទៅនឹង "គោលជំហរបច្ចុប្បន្ន" ដែលជាមុខងារសំខាន់នៃក្របខណ្ឌគតិយុត្ត អ.វ.ត.ក គឺថា "ការស៊ើបអង្កេតត្រូវតែបន្ត"[180]។

១០៧. ក្នុងន័យនេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា មាត្រា ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានគាំទ្រ និងកំណត់ច្បាស់អំពី មាត្រា ៥(៤) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ដោយចែងថា "ក្នុងករណីដែលមានភាពមិនយល់ស្របគ្នា រវាងសហចៅក្រម [...] ការស៊ើបអង្កេតត្រូវធ្វើបន្ត ដរាបណាសហចៅក្រមស៊ើបអង្កេតទាំងពីរ ឬមួយរូប ក្នុងចំណោមពួកគេ ពុំបានប្តឹងមិនសុខចិត្ត ក្នុងរយៈពេលសាមសិបថ្ងៃ ថាភាពខ្វែងយោបល់គ្នាត្រូវដោះស្រាយ"។ កថាខណ្ឌ ៤(ឃ) នៃ វិធាន ៧២ នៃវិធានផ្ទៃក្នុង ដែលគ្រប់គ្រងលើការដោះស្រាយ ការខ្វែងយោបល់គ្នារវាង សហចៅក្រមស៊ើបអង្កេត ដោយអង្គបុរេជំនុំជម្រះនោះ បានចែងគាំទ្របន្ថែមលើគោលជំហរជាមូលដ្ឋាននេះថា៖

> (៤) អង្គបុរេជំនុំជម្រះ ត្រូវដោះស្រាយបញ្ហាខ្វែងយោបល់នេះ ដូចខាងក្រោម ៖
> ឃ. សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះតម្រូវឱ្យមានសម្លេងគាំទ្រពីចៅក្រម ៤(បួន) រូប យ៉ាងតិច។ សេចក្តីសម្រេចនេះបិទផ្លូវប្តឹងឧទ្ធរណ៍។ ប្រសិនបើអង្គបុរេជំនុំជម្រះមិនអាចរកបាននូវសម្លេងគាំទ្រភាគច្រើន តាមការតម្រូវ ស្របតាមមាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានោះ សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្រ មានន័យថា ដីកា ឬ កិច្ចស៊ើបសួរដែលធ្វើឡើងដោយ សហចៅក្រមស៊ើបអង្កេតណាម្នាក់ ត្រូវមានសុពលភាព ឬមានន័យថា ដីកា ឬកិច្ចស៊ើបសួរ ដែលបម្រុងនឹងធ្វើដោយសហចៅក្រមស៊ើបអង្កេតម្នាក់ ត្រូវតែយកមកអនុវត្ត [...]។

[179] សំណុំរឿង ០០៤/១ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីកាសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើញត្តិសុំពិចារណាឡើងវិញ និងសុំលុបចោលដីកាកោះ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៤ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ពាក់ព័ន្ធដីកាកោះ (ឯកសារ D236/1/1/8) កថាខណ្ឌ ៣១។ សំណុំរឿង ០០៣ ការពិចារណាលើការសម្រេច ដាក់ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* (ឯកសារ D128/1/9) កថាខណ្ឌ ៣៤។

[180] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ (អៀង សារី) ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/1/30 កថាខណ្ឌ ២៧៤។

១០៨. នៅក្នុងករណីនេះ អង្គជំនុំជម្រះត្រូវតែបញ្ជាក់ច្បាស់ ថាតើគោលការណ៍គតិយុត្តិទាំងអស់នេះ បណ្ដាលឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយដាច់ពីគ្នាដែរឬទេ តាមមាត្រា ៦៧ នៃវិធានផ្ទៃក្នុង ជាជាងបញ្ជូនបញ្ហាដែលពួកគាត់ខ្វែងយោបល់គ្នា ទៅអង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង។

ខ. ការដោះស្រាយការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត

១០៩. ជាដំបូង អង្គជំនុំជម្រះយល់ថា បញ្ហាថាតើសហចៅក្រមស៊ើបអង្កេត មានកាតព្វកិច្ចត្រូវបញ្ជូនការខ្វែងយោបល់គ្នា ទៅអង្គបុរេជំនុំជម្រះដែលឬអត់ តាមវិធាន ៧២ នៃវិធានផ្ទៃក្នុង ស្ថិតក្រោមគោលការណ៍រួមដែលថា កិច្ចដំណើរការនីតិវិធី អ.វ.ត.ក ចាំបាច់ត្រូវគោរពតាមលក្ខខណ្ឌតម្រូវ ប្រសិទ្ធភាព នីត្យានុកូលភាព ភាពយុត្តិធម៌ តាមក្របខណ្ឌគតិយុត្តិ អ.វ.ត.ក។ ក្នុងករណីនេះ លក្ខខណ្ឌតម្រូវនៃយុត្តិធម្មព្រហ្មទណ្ឌប្រកបដោយប្រសិទ្ធភាព មានតម្លៃសម្រាប់ការយកចិត្តទុកដាក់ជាពិសេសរបស់អង្គជំនុំជម្រះនេះ។

១១០. អង្គបុរេជំនុំជម្រះបានទទួលស្គាល់ នាពេលកន្លងមកថា នៅពេលបង្កើត អ.វ.ត.ក រាជរដ្ឋាភិបាលកម្ពុជា យ៉ាងហោចណាស់ បានអនុវត្តកាតព្វកិច្ចច្បាប់អន្តរជាតិរបស់ខ្លួនមួយផ្នែក ក្នុងការស៊ើបអង្កេតនិងចោទប្រកាន់ឧក្រិដ្ឋកម្មនៅសម័យខ្មែរក្រហម[181]។ ទាំងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ដែលអនុវត្តនៅកម្ពុជា តម្រូវថា កិច្ចខិតខំប្រឹងប្រែងក្នុងការស៊ើបអង្កេត និងចោទប្រកាន់ ទៅលើឧក្រិដ្ឋកម្មទាំងអស់នេះ ត្រូវតែពិតប្រាកដ មិនក្លែងក្លាយ មានន័យថា ស្ថាប័នរបស់ អ.វ.ត.ក ត្រូវតែធានានូវការស៊ើបអង្កេត និងការចោទប្រកាន់ ប្រកបដោយប្រសិទ្ធភាព ចំពោះឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដោយគោរពទៅតាមនីតិវិធី ដែលនៅមានជាធរមានទាំងអស់។

១១១. មធ្យោបាយមួយដែលរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ធានានូវយុត្តិធម៌ប្រកបដោយប្រសិទ្ធភាពនៅក្នុងបរិបទរបស់ អ.វ.ត.ក គឺការធានាថា នីតិវិធីមិនមែនសម្រាប់ត្រឹមតែដោះស្រាយការខ្វែងយោបល់គ្នាដែលកើតឡើង នៅក្នុងអំឡុងពេលស៊ើបអង្កេត និងចោទប្រកាន់ប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងដោះស្រាយជាស្ថាពរចំពោះការខ្វែងយោបល់គ្នាបែបនេះ ដើម្បីជៀសវាងការជាប់គាំងផ្នែកនីតិវិធី ដែលអាចប៉ះពាល់ដល់ប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធី។ នីតិវិធីទាំងអស់នេះត្រូវបានបញ្ជាក់ និងគ្រប់គ្រងដោយគោលជំហរជាក់ស្ដែង ដូចមានចែងផងដែរនៅក្នុង មាត្រា ៥(៤) នៃកិច្ចព្រមព្រៀងស្ដីពីការបង្កើត អ.

[181] សំណុំរឿង ០០៤/១ ការពិចារណាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D308/3/1 កថាខណ្ឌ ៧៥ ។

វ.ត.ក ដែលចែងយ៉ាងច្បាស់ថា នៅពេលដែល "ចៅក្រមស៊ើបអង្កេតមិនអាចឯកភាពគ្នាថា ត្រូវបន្តការស៊ើបអង្កេតណាមួយ ការស៊ើបអង្កេតនោះ ត្រូវដំណើរការទៅមុខទៀត លើកលែងតែចៅក្រមទាំងនេះ ឬចៅក្រមណាម្នាក់ក្នុងចំណោមចៅក្រមទាំងនេះ ធ្វើការស្នើសុំ [...] ឱ្យដោះស្រាយការខ្វែងគំនិតគ្នានេះ"។

១១២. ក្នុងករណីនេះ អង្គជំនុំជម្រះយល់ថា បញ្ហាដែលថាសហចៅក្រមស៊ើបអង្កេតមានបុព្វសិទ្ធិដែរឬអត់ក្នុងការចេញដីកាដំណោះស្រាយដែលដាច់ពីគ្នា ជំនួសឱ្យការបញ្ជូនការខ្វែងយោបល់គ្នាទៅអង្គបុរេជំនុំជម្រះនោះ គឺអាស្រ័យទៅលើថាតើ ការដែលសហចៅក្រមស៊ើបអង្កេតមិនបានគោរពទៅតាម នីតិវិធីដោះស្រាយការខ្វែងយោបល់ ដូចមានចែងក្នុងមាត្រា ៧២ នៃវិធានផ្ទៃក្នុង បានគេចវេសដែរឬអត់ ពីឥទ្ធិពលពិតប្រាកដនៃគោលជំហរជាក់ស្តែង ដែលជាមូលដ្ឋាននៃប្រព័ន្ធគតិយុត្តិរបស់ អ.វ.ត.ក ទាំងមូល។ ក្នុងន័យនេះ អង្គជំនុំជម្រះសង្កត់ធ្ងន់ថា គោលការណ៍ដែលជាមូលដ្ឋាន និងជាកត្តាកំណត់ចំពោះគោលជំហរជាក់ស្តែង មិនអាចត្រូវបានទាត់ចោល ឬដកហូតឥទ្ធិពល និងទម្ងន់ពេញទាំងស្រុងរបស់វា ដោយការរៀបចំការបកស្រាយជាបណ្តាញ តាមរយៈការកេងចំណេញពីភាពមិនច្បាស់លាស់ដែលអាចមាននៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង ដើម្បីធ្វើឱ្យគោលការណ៍ស្នូលនេះ ក្លាយទៅជាគ្មានន័យនោះទេ។ ការសម្រេចផ្សេងពីនេះ នឹងនាំទៅដល់លទ្ធផលផ្លូវច្បាប់ ដែលមិនសមហេតុផលទាល់តែសោះ ដោយរំលោភបំពានទាំងទៅលើច្បាប់អន្តរជាតិនិងច្បាប់កម្ពុជា។

១១៣. ដោយផ្អែកលើការបកស្រាយខាងលើ អង្គបុរេជំនុំជម្រះនឹងបញ្ជាក់ពីបណ្តានីតិវិធីផ្សេងៗគ្នាជាច្រើនដែលសហចៅក្រមស៊ើបអង្កេតអាចប្រើប្រាស់ ដើម្បីចាត់ចែង និងដោះស្រាយការខ្វែងយោបល់គ្នារបស់ពួកគាត់ ស្របទៅតាមក្របខណ្ឌច្បាប់ អ.វ.ត.ក។ ក្នុងន័យនេះ លក្ខណៈ និងភាពធ្ងន់ធ្ងរនៃការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត គួរផ្តល់ព័ត៌មានទៅនីតិវិធីដែលសមស្របបំផុតដើម្បីអនុវត្តតាមដោយផ្អែកទៅលើកាលៈទេសៈពិសេសនៃករណីនីមួយៗ។ ហេតុដូច្នេះបណ្តុំសកម្មភាពដែលមានអាចចាប់ផ្តើមពីការអត់ធ្មត់ដោយលាក់លៀមចំពោះកិច្ច ឬសេចក្តីសម្រេច ដែលសហចៅក្រមស៊ើបអង្កេតម្នាក់ទៀតបានបំពេញ រហូតទៅដល់ការចុះកំណត់ហេតុការខ្វែងយោបល់គ្នា ឬបញ្ជូនការខ្វែងយោបល់គ្នា ដើម្បីស្នើសុំការធ្វើមោឃភាពជាផ្លូវការ ចំពោះកិច្ច ឬសេចក្តីសម្រេច ដែលរងការជំទាស់នោះ ដោយផ្អែកទៅតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង។

១១៤. នៅក្នុងស្ថានភាពណាមួយ ក្នុងចំណោមស្ថានភាពទាំងអស់នេះ អង្គជំនុំជម្រះសង្កត់ធ្ងន់ថា សកម្មភាពរបស់សហចៅក្រមស៊ើបអង្កេត នៅគ្រប់ពេលទាំងអស់ ត្រូវតែស្ថិតក្នុងសមត្ថកិច្ចផ្ទាល់របស់ពួកគាត់

ហើយត្រូវបំពេញអនុលោមទៅតាមគោលការណ៍សហប្រតិបត្តិការ ដូចមានចែងក្នុងមាត្រា ៥(៤) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ដែលបានឆ្លុះបញ្ចាំងផងដែរ អំពីឋានៈស្មើគ្នារបស់សហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅក្នុងប្រព័ន្ធចម្រុះរបស់ អ.វ.ត.ក[182]។ បន្ថែមលើនេះ អង្គជំនុំជម្រះគួសបញ្ជាក់ថា តាមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតត្រូវតែបន្តស្វែងរកគោលជំហររួមមួយ នៅក្នុងដំណើរការខ្វែងយោបល់គ្នា។ ប្រព័ន្ធច្បាប់ អ.វ.ត.ក ត្រូវបានរៀបចំយ៉ាងប្រុងប្រយ័ត្ន និងមានរចនាសម្ព័ន្ធ ដើម្បីធានានូវការបំពេញកិច្ច និងអនុវត្តកិច្ចរួមគ្នា ចំពោះការស៊ើបសួរតាមផ្លូវតុលាការ ដោយសហចៅក្រមស៊ើបអង្កេតពីររូប។ ហេតុដូច្នេះ ចៅក្រមទាំងពីរអាចឈានដល់ការឯកភាពគ្នា នៅដំណាក់កាលណាមួយនៃការស៊ើបអង្កេត នៅក្នុងសំណុំរឿង ដែលខ្លួនបានទទួល។ ការរំលេចឡើងនូវការខ្វែងយោបល់គ្នាណាមួយរវាងសហចៅក្រមស៊ើបអង្កេត អំពីករណីបែបនេះ ក៏បានទទួលការអនុញ្ញាតដែរ ប៉ុន្តែទាល់តែការខ្វែងយោបល់គ្នានេះគោរពទៅតាមនីតិវិធីដែលនៅជាធរមានស្រាប់ ហើយស្របទៅតាមគោលបំណងពិតប្រាកដ ដែលជាមុខងារសំខាន់របស់ប្រព័ន្ធច្បាប់ អ.វ.ត.ក ហើយផ្តល់ជាមធ្យោបាយប្រកបដោយប្រសិទ្ធភាពក្នុងការដោះស្រាយស្ថានភាពទាល់ច្រក ផ្នែកនីតិវិធីដែលអាចមានណាមួយ។

១១៥. ជាពិសេស អង្គជំនុំជម្រះសម្រេចថា តាមមាត្រា ២៣ថ្មី (៣) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលចែងថា "ការស៊ើបអង្កេតត្រូវធ្វើបន្ត ដរាបណាសហចៅក្រមស៊ើបអង្កេតទាំងពីរ ឬមួយរូប ក្នុងចំណោមពួកគេ ពុំបានប្តឹងមិនសុខចិត្ត ក្នុងរយៈពេលសាមសិបថ្ងៃ ថា ភាពខ្វែងយោបល់គ្នាត្រូវដោះស្រាយដោយអនុវត្តតាមបទប្បញ្ញត្តិដូចខាងក្រោម"[183] សហចៅក្រមស៊ើបអង្កេតមួយរូប អាចអនុញ្ញាតដោយត្រឹមត្រូវឱ្យសហការីរបស់គាត់ អាចអនុវត្តកិច្ចទៅបាន ដោយខ្លួនគាត់មិនចូលរួមពាក់ព័ន្ធនៅក្នុងកិច្ចបែបនេះ បើទោះបីជាមិនបានចុះកំណត់ហេតុអំពីការខ្វែងយោបល់គ្នាក្តី ដែលធ្វើដូច្នេះគឺអនុញ្ញាតឱ្យការស៊ើបអង្កេតអាចបន្តទៅមុខបាន។

១១៦. ក្នុងករណីការខ្វែងយោបល់គ្នា ពាក់ព័ន្ធបញ្ហាធ្ងន់ធ្ងរ ដូចជា បញ្ហាដែលជាចំណុចស្នូលនៃការស៊ើបអង្កេតជាដើម សហចៅក្រមស៊ើបអង្កេតមួយរូបអាចលើកការជំទាស់របស់គាត់ប្រឆាំងនឹងកិច្ច ឬសេចក្តីសម្រេចរបស់សហការីគាត់ ដោយការចុះកំណត់ហេតុជាផ្លូវការលើការខ្វែងយោបល់គ្នា[184]។ អង្គជំនុំជម្រះ

---

[182] កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៥(១) រួមជាមួយច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២៧ថ្មី។

[183] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២៣ថ្មី កថាខណ្ឌ ៣។

[184] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២៣ថ្មី កថាខណ្ឌ ៣។ វិធាន ៧២(១) នៃវិធានផ្ទៃក្នុង ("ក្នុងករណីមានការខ្វែង

សម្រេចថា ការបង្ហាញជាផ្លូវការពីការខ្វែងយោបល់គ្នា អនុលោមតាមមាត្រា ២៣ថ្មី(៣) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធាន ៧២(១) នៃវិធានផ្ទៃក្នុង ឬការឈានទៅដល់ការឯកភាពគ្នា ទៅលើបញ្ហាដែលកំពុងចោទ ត្រូវបានទទួលស្គាល់ និងត្រូវបានអនុញ្ញាតនៅក្នុង ប្រព័ន្ធច្បាប់ អ.វ.ត.ក។ ក្នុងករណីបែបនេះ "សហចៅក្រមស៊ើបអង្កេតណាម្នាក់ ឬទាំងពីរ អាចធ្វើកំណត់ហេតុអំពីមូលហេតុពិតប្រាកដនៃការខ្វែងយោបល់គ្នានេះ ដោយមានហត្ថលេខា និងចុះកាលបរិច្ឆេទ ដែលត្រូវយកទៅដាក់ចូលក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នាដោយឡែក ដែលរក្សាទុកដោយក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត" ដោយអនុលោមតាមវិធាន ៧២(១) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះយល់ថា បន្ទាប់មកការខ្វែងយោបល់គ្នា ត្រូវបានរក្សាទុករវាង សហចៅក្រមស៊ើបអង្កេត ហើយទៅជាការសម្ងាត់។ អង្គជំនុំជម្រះកត់សម្គាល់ទៀតថា មាត្រា ៥(៤) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធាន ៧២(៣) នៃវិធានផ្ទៃក្នុង បានចែងយ៉ាងច្បាស់ថា ក្នុងករណីបែបនេះ សហចៅក្រមស៊ើបអង្កេតមួយរូបអាចបំពេញកិច្ចដោយមិនមានការយល់ព្រមពីចៅក្រមមួយរូបទៀតបាន នៅក្នុងពេលវេលាកំណត់ជាក់ច្បាស់[185]។ បន្ទាប់មក សហចៅក្រមស៊ើបអង្កេតរូបនេះអាចបន្តនីតិវិធីជាមួយ សេចក្តីសម្រេចដែលរងការជំទាស់ ពេលដែលវេលាកំណត់ដែលបានតម្រូវបានកន្លងផុតទៅ[186]។

១១៧. អង្គជំនុំជម្រះកត់សម្គាល់ថា នៅពេលដែលការខ្វែងយោបល់គ្នា មានភាពធ្ងន់ធ្ងរខ្លាំងដែលសហចៅក្រមស៊ើបអង្កេតមួយរូបចង់បញ្ឈប់ការអនុវត្តសេចក្តីសម្រេចរបស់សហការីគាត់នោះ មធ្យោបាយតាមផ្លូវច្បាប់តែមួយគត់ដែលមានសម្រាប់ចៅក្រមរូបនោះគឺ ការបញ្ជូនការខ្វែងយោបល់គ្នា ទៅអង្គបុរេជំនុំជម្រះ ដែលជាអង្គជំនុំជម្រះទទួលបានសិទ្ធិអំណាចជាពិសេស និងជាក់លាក់ ដើម្បីដោះស្រាយភាពខុសគ្នារវាងសហចៅក្រមស៊ើបអង្កេត។ ដើម្បីចាប់ផ្តើមយន្តការដោះស្រាយការខ្វែងយោបល់គ្នាប្រកបដោយប្រសិទ្ធភាពនេះ សហចៅក្រមស៊ើបអង្កេតចាំបាច់ត្រូវដាក់របាយការណ៍ជាលាយលក្ខណ៍អក្សរអំពី

---

យោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតណាម្នាក់ឬ ទាំងពីរអាចធ្វើកំណត់ហេតុអំពីមូលហេតុពិតប្រាកដ នៃការខ្វែងយោបល់គ្នានេះ ដោយមានហត្ថលេខា និងចុះកាលបរិច្ឆេទ ដែលត្រូវយកទៅដាក់ចូលក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នាដោយឡែក ដែលរក្សាទុកដោយ ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត")។

[185] សំណុំរឿង ០០៤/១ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ពាក់ព័ន្ធដីកាកោះ (ឯកសារ D236/1/1/8) កថាខណ្ឌ ២៤, ២៩-៣០។

[186] សំណុំរឿង ០០៤/១ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ពាក់ព័ន្ធដីកាកោះ (ឯកសារ D236/1/1/8) កថាខណ្ឌ ២៤, ២៩-៣០។

អង្គហេតុ និងមូលហេតុនៃការខ្វែងយោបល់គ្នា[187]។ ច្បាប់ជាធរមានរបស់ អ.វ.ត.ក ផ្តល់ដល់អង្គបុរេជំនុំជម្រះនូវសិទ្ធិអំណាចដែលចាំបាច់សម្រាប់ដោះស្រាយជាស្ថាពរលើបញ្ហាដែលមានជម្លោះរវាងសហចៅក្រមស៊ើបអង្កេតពីររូប ដែលមានសិទ្ធិអំណាចស្មើគ្នា ហើយសម្រេចថាតើ គួរ ឬមិនគួរអនុវត្តសេចក្តីសម្រេចដែលរងការជំទាស់។ ក្នុងករណីដែលអង្គបុរេជំនុំជម្រះមិនអាចស្វែងរកសម្លេងភាគច្រើនលើសលប់ដើម្បីដោះស្រាយសម្រេចការខ្វែងយោបល់គ្នាទេនោះ ក្របខណ្ឌគតិយុត្តិ អ.វ.ត.ក បានចែងថា បញ្ហានេះនឹងត្រូវដោះស្រាយ ដោយស្ថានភាពកំណត់ ដែលជាការចែងថា ការស៊ើបអង្កេតចាំបាច់ត្រូវបន្ត[188]។

១១៨. អង្គជំនុំជម្រះបញ្ជាក់ឡើងវិញថា សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចត្រូវបន្តស្វែងរកសំអាងហេតុគតិយុត្តិរួមគ្នា ឬត្រូវឯកភាពគ្នាលើសកម្មភាពដែលត្រូវអនុវត្ត នៅក្នុងអំឡុងពេលដោះស្រាយ ការខ្វែងយោបល់គ្នានេះ[189]។ ការប្រើប្រាស់ទម្រង់បច្ចុប្បន្នកាល នៅក្នុងវិធាន ៧២(៣) នៃវិធានផ្ទៃក្នុង បង្ហាញដោយឥតមន្ទិលចំពោះបញ្ហានេះ ហើយបញ្ជាក់យ៉ាងច្បាស់ថា សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចបដិការក្នុងន័យនេះទៅតាមក្របខណ្ឌគតិយុត្តិ អ.វ.ត.ក[190]។

---

[187] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២៣ថ្មី កថាខណ្ឌ ៤។ វិធាន ៧២(២) នៃវិធានផ្ទៃក្នុង។

[188] នេះគឺប្រាកដជាអ្វីដែលបានធ្វើឡើង ក្នុងសំណុំរឿងដែលស្ថិតក្នុងដៃ នៅពេលដែលសហព្រះរាជអាជ្ញា បានលើកឡើងអំពីការខ្វែងយោបល់គ្នា (សូមមើល កំណត់ត្រាជាលាយលក្ខណ៍អក្សរ របស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីការខ្វែងយោបល់គ្នា (ឯកសារ D1)។ សូមមើលផងដែរ ការខ្វែងយោបល់គ្នា ០០១/១៨-១១-២០០៨-អវតក/អង្គបុរេជំនុំជម្រះ ការកែតម្រូវលើសេចក្តីដកស្រង់ការពិចារណា របស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធ និងករណីខ្វែងយោបល់គ្នា របស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធ II ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ ឯកសារ D1/1.2 ទំព័រ ២)។ ក្នុងន័យនេះ អង្គជំនុំជម្រះកត់សម្គាល់ពីកំហុសឆ្គងនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ ដែលបញ្ជាក់ដោយខុសឆ្គងថា សហព្រះរាជអាជ្ញាជាតិបានកត់កំណត់ហេតុនៃការខ្វែងយោបល់គ្នា ដែលត្រូវបញ្ជូនទៅអង្គបុរេជំនុំជម្រះ។ សូមមើល ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D359) កថាខណ្ឌ ១៥)។

[189] វិធាន ៧២(៣) នៃវិធានផ្ទៃក្នុង។

[190] វិធាន ៧២(៣) នៃវិធានផ្ទៃក្នុង ("") Internal Rule 72(3) ("៣. ក្នុងអំឡុងពេលនៃការដោះស្រាយ ការខ្វែងយោបល់គ្នានេះ សហចៅក្រមស៊ើបអង្កេត ត្រូវប្រឹងប្រែងស្វែងរកការឯកភាពគ្នា។ កិច្ច ឬ សេចក្តីសម្រេចដែលជាកម្មវត្ថុ នៃការខ្វែងយោបល់គ្នានេះ ត្រូវតែអនុវត្តលើកលែងតែបញ្ហាខ្វែងយោបល់គ្នា ពាក់ព័ន្ធទៅនឹងចំណុចដូចខាងក្រោម ៖ ក-សេចក្តីសម្រេចណាមួយ ដែលអាចនាំឲ្យជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណីធ្វើបណ្តឹងឧទ្ធរណ៍ ដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ។ ខ-ការជូនដំណឹងអំពីបទចោទប្រកាន់។ ឬ គ-ដីកាបង្គាប់ឲ្យចាប់ខ្លួន ។ ក្នុងករណីទាំងនេះ គ្មានសកម្មភាពណាមួយ ដែលពាក់ព័ន្ធទៅការខ្វែងយោបល់គ្នាត្រូវបានអនុវត្តទេ រហូតដល់មានការព្រមព្រៀងគ្នាណាមួយ ត្រូវបានបង្កើតឡើង ឬ រយៈពេល ៣០(សាមសិប)ថ្ងៃ បានកន្លងហួស ឬ អង្គបុរេជំនុំជម្រះបានទទួលយករឿងខ្វែងយោបល់គ្នាមកជំនុំជម្រះ ហើយបានបញ្ចប់នីតិវិធីដោះស្រាយបញ្ហាខ្វែងយោបល់គ្នា

១១៩. ផ្ទុយទៅវិញ ច្បាប់ដែលអនុវត្តនៅ អ.វ.ត.ក ចែងយ៉ាងច្បាស់ថា ទោះបីជាមានចេតនាពិតប្រាកដក្នុងការឈានទៅរកការសម្រុះសម្រួល ឬស្វែងរកការឯកភាពជាឯកច្ឆ័ន្ទក្តី ប៉ុន្តែសហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលមានសិទ្ធិអំណាចស្មើគ្នា អាចនៅតែមិនមានលទ្ធភាពក្នុងការយល់ស្របជាមួយគ្នា លើបញ្ហារួមគ្នា។ ក្នុងករណីបែបនេះ អង្គជំនុំជម្រះយល់ថា ក្នុងករណីដែលបញ្ហាដែលជាជម្លោះ ឬការខ្វែងយោបល់គ្នាដែលមានរយៈពេលវែង ទៅលើបញ្ហាមួយបានបង្កការខូចខាតដល់ប្រសិទ្ធភាពរបស់ការស៊ើបសួរតាមផ្លូវតុលាការ នោះក្របខណ្ឌគតិយុត្តិ អ.វ.ត.ក មិនអនុញ្ញាតឱ្យការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត អាចនៅបន្ត ឬអាចបិទបាំងពីយន្តការដោះស្រាយការខ្វែងយោបល់គ្នាបានទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចថា ក្នុងករណីដែលនីតិវិធីដោះស្រាយការខ្វែងយោបល់គ្នា ដែលនៅមានស្រាប់ជាធរមាន គឺជាយន្តការតែមួយគត់ដែលនៅអាចអនុវត្តបានសម្រាប់សហចៅក្រមស៊ើបអង្កេត ក្នុងការទប់ស្កាត់ការកើតមានភាពទាល់ច្រកផ្នែកនីតិវិធី និងធានាអំពីនីត្យានុកូលភាព ភាពយុត្តិធម៌ និងប្រសិទ្ធភាពនៃការស៊ើបសួរតាមផ្លូវតុលាការនោះ សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចដើម្បីចាប់ផ្តើមយន្តការនេះ តាមរយៈការបញ្ជូនការខ្វែងយោបល់គ្នារបស់ពួកគាត់ទៅអង្គបុរេជំនុំជម្រះ។

### គ. ការសន្និដ្ឋានទាក់ទងនឹងការចេញដីកាដំណោះស្រាយដែលដាច់ពីគ្នា

១២០. យោងតាមការពិភាក្សាខាងលើ អង្គបុរេជំនុំជម្រះយល់ឃើញថា ក្នុងករណីការខ្វែងយោបល់គ្នាទាក់ទងនឹងបញ្ហាដែលចាំបាច់ត្រូវតែសម្រេចដោយដីកាដំណោះស្រាយមួយ តាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង នោះ ក្របខណ្ឌគតិយុត្តិ អ.វ.ត.ក អនុញ្ញាតឱ្យមានសកម្មភាពតែពីរប៉ុណ្ណោះ អនុលោមទៅតាមមាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធាន ៧២(៣) នៃវិធានផ្ទៃក្នុង។ សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចត្រូវឈានទៅការឯកភាពគ្នាជាឯកច្ឆ័ន្ទ ជាប្រយោល ឬដោយផ្ទាល់ក្តី ទៅលើបញ្ហាទាំងនោះ ឬសហចៅក្រមស៊ើបអង្កេតត្រូវបញ្ជូនការខ្វែងយោបល់គ្នាលើបញ្ហាបែបនេះ ទៅអង្គបុរេជំនុំជម្រះ។ បន្ថែមលើនេះ បើទោះបីជាសហចៅក្រមស៊ើបអង្កេតមានឆន្ទានុសិទ្ធិក្នុងការឯកភាព ទោះបីជាដោយប្រយោលក្តី

---

នេះ។ Règlement intérieur 72(3) (« 3. Au cours de la période de règlement du désaccord, les co-juges d'instruction recherchent un consensus. Cependant, l'acte ou la décision qui a fait l'objet du différend est exécuté, sauf en cas de désaccord concernant : a) Une décision susceptible d'appel par la personne mise en examen ou la partie civile en application de ce Règlement ។ b) La notification des chefs d'inculpation ។ c) La délivrance d'un mandat d'arrêt, auquel cas, aucun acte relatif à la question litigieuse ne peut être accompli tant que la Chambre préliminaire n'a pas résolue le désaccord ou, si elle n'a pas été saisie, avant un délai de 30 (trente) jours, à moins que les co-juges d'instruction ne parviennent à un consensus »)។

ក្នុងការបំពេញកិច្ចដែលរងការជំទាស់ ប៉ុន្តែការបញ្ជូនជាផ្លូវការនូវការខ្វែងយោបល់គ្នា ទៅអង្គជំនុំជម្រះនោះ គឺជាការចាំបាច់ខានមិនបាន នៅពេលដែលពួកគេមិនអាចឈានទៅរកគោលជំហររួមគ្នាមួយបាន ក្នុងពេលវេលាសមស្រប ទៅលើបញ្ហាណាមួយដែលប៉ះពាល់ដល់ដីកាដំណោះស្រាយ ដោយសារតែក្នុងករណីបែបនេះ សហចៅក្រមស៊ើបអង្កេតមិនមានមធ្យោបាយផ្លូវច្បាប់ និងជាក់ស្តែងណាមួយផ្សេងទៀត ដើម្បីដោះស្រាយជម្លោះរបស់ពួកគេ និងដើម្បីជៀសវាងភាពទាល់ច្រកផ្នែកនីតិវិធី។

១២១. អង្គបុរេជំនុំជម្រះយល់ឃើញថា អត្ថបទច្បាប់ដែលគ្រប់គ្រងលើកិច្ចដំណើរការនីតិវិធី អ.វ.ត.ក នៅពេលពិនិត្យមើលក្នុងស្ថានភាពនេះ មិនមានភាពស្រពិចស្រពិលខ្លាំងទេ។ វិធាន ៦៧(១) នៃវិធានផ្ទៃក្នុង បានចែងយ៉ាងច្បាស់ថា "សហចៅក្រមស៊ើបអង្កេត*ត្រូវបញ្ចប់* កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយថាត្រូវចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ *ឬ* លើកលែងការចោទប្រកាន់"។ សទ្ទានុក្រមរបស់វិធានផ្ទៃក្នុងបានបន្ថែមថា "**ដីកាដំណោះស្រាយ**សំដៅទៅលើដីកាចុងក្រោយដែលធ្វើឡើង ដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ នៅពេលបញ្ចប់ដំណើរការស៊ើបសួរ ដែលអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងចោទប្រកាន់"[191]។ បទប្បញ្ញត្តិទាំងអស់នេះចែងយ៉ាងច្បាស់ថា ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត គឺជាដីកាសម្រេចតែមួយគត់ ហើយមិនបានផ្តល់មូលដ្ឋានគតិយុត្តិ ដើម្បីអះអាងថា ក្របខណ្ឌគតិយុត្តិ អ.វ.ត.ក អនុញ្ញាតឲ្យមានការចេញដីកាដំណោះស្រាយដែលដាច់ពីគ្នាទេ។ ក្នុងន័យនេះ ការបកស្រាយទៅលើវិធាន ១(២) នៃវិធានផ្ទៃក្នុង ដែលបង្ហាញថា នៅក្នុងវិធានផ្ទៃក្នុង ឯកវចនៈក៏អាចយល់ជាពហុវចនៈ និងការយោងទៅរកសហចៅក្រមស៊ើបអង្កេត "សំដៅទៅដល់សហចៅក្រមស៊ើបអង្កេតទាំងពីរ ដែលធ្វើការសម្រេចចិត្តរួមគ្នា និងចៅក្រមស៊ើបអង្កេតណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ" មិនបានផ្តល់មូលដ្ឋានគតិយុត្តិគ្រប់គ្រាន់ ដើម្បីទាត់ចោល ឬកាត់បន្ថយគោលការណ៍ស្នូលនៃការឯកភាពគ្នា ដូចជាថា គោលជំហរជាក់ស្តែង ឬទាមទាសិទ្ធិអំណាចក្នុងការបំពេញកិច្ច នៅពេលដែលផលប៉ះពាល់ដោយសារការអនុវត្តសិទ្ធិអំណាចបែបនេះ អាចមានទំនាស់ជាមួយគោលការណ៍ទាំងអស់នេះ។ វិធានស្តីពីការបកស្រាយក្នុងន័យចង្អៀត ទៅលើលក្ខន្តិកៈព្រហ្មទណ្ឌ បានទប់ស្កាត់បន្ថែមទៀតចំពោះការបកស្រាយតាមអំពើចិត្តណាមួយ នៅក្នុងអត្ថន័យនេះ។

[191] វិធានផ្ទៃក្នុង សទ្ទានុក្រម ទំព័រ ៨៣ (ដោយគូសបញ្ជាក់បន្ថែម) *contra* ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៦ -៨។ ការលើកទឡ្ហីករណ៍ទាក់ទងការបកប្រែ ឬលក្ខណៈពិសេសនៃភាសាខ្មែរ ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើង គឺមានលក្ខណៈមិនរឹងមាំសោះត្រង់ចំណុចនេះ បើតាមទស្សនៈរបស់អង្គជំនុំជម្រះ។

១២២. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះច្រានចោលសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតសម្រាប់ការអះអាងពីការអនុញ្ញាតតាមផ្លូវច្បាប់លើការចេញដីកាដំណោះស្រាយពីរ ដែលផ្ទុយគ្នា និងដាច់ពីគ្នា នៅ អ.វ.ត.ក[192]។ ក្រៅពីកំហុសអង្គច្បាប់យ៉ាងជាក់ច្បាស់ ដែលសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតបានពឹងផ្អែកទៅលើនោះ អង្គជំនុំជម្រះក៏យល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានបញ្ចូលលក្ខណៈពិសេសនៃសេចក្តីសម្រេចតាមផ្លូវតុលាការ ជាមួយនឹងការដាក់សារណារបស់ភាគី។ ភារកិច្ចតាមផ្លូវតុលាការក្នុងការប្រកាស ដោយផ្អែកទៅលើច្បាប់ សេចក្តីសម្រេចលើបញ្ហាដែលមានវិវាទ (*jurisdictio*) គឺជាចំណុចសំខាន់បំផុតនៃការទទួលខុសត្រូវ និងមុខងារដ៏ខ្ពង់ខ្ពស់បំផុតរបស់ចៅក្រម[193]។ ហេតុដូច្នេះ ការប្រកាសសម្រេចវិនិច្ឆ័យ និងការដោះស្រាយបញ្ហាដែលជាជម្លោះ ត្រូវមានឥទ្ធិពល និងជាកាតព្វកិច្ចផ្លូវច្បាប់ (*imperium*) ដែលខុសពីសារណារបស់ភាគី[194]។ ចៅក្រមអាចមានកំហុសលើសេចក្តីសម្រេច ដែលអាចត្រូវបានកែតម្រូវនៅដំណាក់កាលបណ្តឹងឧទ្ធរណ៍។ ប៉ុន្តែ ចៅក្រមមិនអាចគេចចេញពីការវិនិច្ឆ័យលើបញ្ហាដែលនៅចំពោះមុខខ្លួន ឬគេចចេញពីការឈានទៅសន្និដ្ឋាន ដែលសម្រេចដោយប្រសិទ្ធភាពទៅលើបញ្ហានេះនោះទេ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា នៅ អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតត្រូវទទួលបន្ទុករួមគ្នាលើអង្គភាពតុលាការនេះ។ នៅពេលដែលការខ្វែងយោបល់គ្នារបស់ពួកគេរារាំងពួកគាត់មិនឱ្យឈានទៅដល់ ការសម្រេចជាស្ថាពររួមគ្នាទៅលើសំណុំរឿងដែលពួកគាត់បានទទួលវិនិច្ឆ័យនោះ ចៅក្រមនៅតែ

---

[192] សូមមើល ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ១៤ *យោងទៅរក* ដីកាសម្រេចលើសំណើសុំដាក់បង្ហាញ ឯកសារដែលពាក់ព័ន្ធ ការខ្វែងយោបល់គ្នា (ឯកសារ D355/1 ) កថាខណ្ឌ ១៣-១៦។ សូមមើលផងដែរ ដីកាសម្រេចលើសំណើសុំការបញ្ជាក់បំភ្លឺ (ឯកសារ D353/1) កថាខណ្ឌ ៣២-៣៧, ៤២។

[193] អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ធាតុផ្សំយ៉ាងសំខាន់នៃនិយមន័យរបស់យុត្តាធិការតុលាការ គឺ (១) ទំនាស់ (២) លក្ខណៈជាកាតព្វកិច្ចនៃការប្រកាស និង (៣) មូលដ្ឋាននៃច្បាប់ ដែលបណ្តាលឱ្យមានការប្រកាសបែបនេះ។ អង្គជំនុំជម្រះកត់សម្គាល់ជាពិសេសថា លក្ខណៈជាកាតព្វកិច្ចនៃការប្រកាសនេះ គឺជាផលវិបាកនៃលក្ខណៈចងកាតព្វកិច្ចរបស់ទស្សនៈដែលមានជាយូរមកហើយ ដែលថា ចៅក្រមគឺជា "មាត់ដែលនិយាយពាក្យច្បាប់", Robert KOLB, «Le degré d'internationalisation des tribunaux pénaux internationalisés », in Hervé ASCENSIO, Elisabeth LAMBERT-ABDELGAWAD and Jean-Marc SOREL (eds), *Les juridictions pénales internationalisée (Cambodge, Kosovo, Sierra Leone, Timor Leste)*(Société de Législation Comparée, 2006)("KOLB, *Le degré d'internationalisation des tribunaux pénaux internationalisés*") , p. 48 (« On s'accorde pour dire qu'une juridiction est un organe qui tranche des différends par des décisions obligatoires fondées sur 1' application du droit. En somme, il y a trois éléments qui sont censés essentiels dans la définition d'une juridiction: (1) le différend។ (2) l'obligatoriété du prononcé។ (3) le fait de statuer sur la base du droit »)

[194] KOLB, *Le degré d'internationalisation des tribunaux pénaux internationalisés* ទំព័រ ៤៨។ មានការសរសេរបន្ថែមទៀតថា « le prononcé n'est obligatoire que parce qu'il dit le droit (qui est obligatoire) et il ne l'est que dans la mesure où il dit le droit » (ការប្រកាសគឺមិនត្រឹមតែមានលក្ខណៈជាកាតព្វកិច្ច ដោយសារតែវាចែងអំពីច្បាប់ (ដែលចងកាតព្វកិច្ច) ប៉ុណ្ណោះទេ ប៉ុន្តែវាស្ថិតនៅក្នុងកម្រិតដែលវាអាចចែងជាច្បាប់ទៀតផង) ។

01634829



ចាំបាច់ត្រូវបំពេញមុខងារ និងភារកិច្ចតុលាការរបស់ពួកគេ ដោយគោរពតាមនីតិវិធីដែលមាននៅក្នុងក្របខណ្ឌគតិយុត្តិ អ.វ.ត.ក ដើម្បីដោះស្រាយការខ្វែងយោបល់គ្នារបស់ពួកគាត់ និងធានាថាអាចទទួលបានការសម្រេចជាស្ថាពរទៅលើបញ្ហាដែលស្ថិតក្រោមយុត្តាធិការរបស់ខ្លួន។

១២៣. ជាការសន្និដ្ឋាន អង្គបុរេជំនុំជម្រះសង្កត់ធ្ងន់ថា កំហុសដែលសហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្តនៅក្នុងសំណុំរឿងនេះ ធ្វើឱ្យខូចខាតដល់មូលដ្ឋាននៃប្រព័ន្ធចម្រុះ និងមុខងារដ៏ត្រឹមត្រូវរបស់ អ.វ.ត.ក។ ទោះបីជាបញ្ហានៅចំពោះមុខមានភាពធ្ងន់ធ្ងរ និងផុយស្រួយក្តី ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតនៅតែអនុញ្ញាតឱ្យខ្លួនឯងចេញដីកាដំណោះស្រាយ ដែលមានសំអាងហេតុតិចតួចគួរឱ្យកត់សម្គាល់ ដើម្បីផ្តល់យុត្តិកម្មដល់សកម្មភាពរបស់ខ្លួន ដោយគ្រាន់តែរម្លឹកអំពីសេចក្តីសម្រេចរបស់ខ្លួនមួយនាពេលកន្លងមកប៉ុណ្ណោះ[195]។ ជាពិសេស អង្គជំនុំជម្រះយល់ឃើញថា ជារឿងគួរឱ្យរំខានខ្លាំងដែលដីកាសម្រេចដាច់ពីគ្នានេះ ត្រូវបានចេញនៅថ្ងៃតែមួយ មួយភាសា ដោយមានការប្រកាសយ៉ាងច្បាស់ដោយសហចៅក្រមស៊ើបអង្កេតទាំងពីរថា ពួកគាត់បានឯកភាពគ្នាលើការចេញដោយខុសច្បាប់នូវដីកាដំណោះស្រាយដាច់ពីគ្នាហើយផ្ទុយគ្នានេះ។ អង្គជំនុំជម្រះយល់ថា ការអនុវត្តដោយខុសឆ្គងរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងករណីនេះ បង្កគ្រោះថ្នាក់ដល់ប្រព័ន្ធគតិយុត្តិទាំងមូល ដែលគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។ គួរឱ្យភ្ញាក់ផ្អើល ចៅក្រមស៊ើបអង្កេតបាន "ដឹងអំពីបញ្ហា" ដែលអាចកើតឡើងដោយសារតែដីកាដំណោះស្រាយដែលដាច់ពីគ្នា ជាពិសេស នៅដំណាក់កាលបណ្តឹងឧទ្ធរណ៍នោះ[196]។ ប៉ុន្តែ ទោះជាបែបនេះក្តី សហចៅក្រមស៊ើបអង្កេតនៅតែសម្រេចលាក់ការខ្វែងយោលប់គ្នា មិនឱ្យទទួលបានយន្តការដែលមាន សម្រាប់ដោះស្រាយជម្លោះប្រកបដោយប្រសិទ្ធភាពបំផុត នៅក្រោមក្របខណ្ឌគតិយុត្តិ អ.វ.ត.ក ដើម្បីធានានូវការជៀសផុតពីភាពទាល់ច្រកផ្នែកនីតិវិធីនោះទេ។ ក្រៅពីកំហុសអង្គច្បាប់យ៉ាងជាក់ច្បាស់ដែលរំលោភបំពានទៅលើគោលការណ៍ជាសារវ័ន្តរបស់ក្របខណ្ឌគតិយុត្តិ អ.វ.ត.ក អង្គបុរេជំនុំជម្រះយល់ថា សកម្មភាពខុសច្បាប់របស់សហចៅក្រមស៊ើបអង្កេត អាចជាការបដិសេធនូវយុត្តិធម៌ ជាពិសេស ដោយសារតែអង្គជំនុំជម្រះនេះមិនអាចមិនយល់ថា សហចៅក្រមស៊ើបអង្កេតប្រហែលជាមានចេតនាច្បាស់លាស់ក្នុងការផ្តាញ់ផ្តាលគោលបំណងនៃស្ថានភាពកំណត់ក្នុងសំណុំរឿងនេះ ហើយព្យាយាមដោយចេតនាក្នុងការ

---

[195] សូមមើល ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ១៤*យោងទៅរក* ដីកាសម្រេចលើសំណើសុំដាក់បង្ហាញ ឯកសារដែលពាក់ព័ន្ធ ការខ្វែងយោបល់គ្នា (ឯកសារ D355/1 ) កថាខណ្ឌ ១៣-១៦។ សូមមើលផងដែរ ដីកាសម្រេចលើសំណើសុំការបញ្ជាក់បំភ្លឺ (ឯកសារ D353/1) កថាខណ្ឌ ៣២-៣៧, ៤២។

[196] ដីកាសម្រេចលើសំណើសុំដាក់បង្ហាញ ឯកសារដែលពាក់ព័ន្ធ ការខ្វែងយោបល់គ្នា (ឯកសារ D355/1 ) កថាខណ្ឌ ១៥។ សូមមើលផងដែរ កថាខណ្ឌ ១៦។

រារាំងសិទ្ធិអំណាចរបស់អង្គបុរេជំនុំជម្រះ។

១២៤. ក្រោយស៊ើបអង្កេតរយៈពេល ១០ ឆ្នាំ លើឧក្រិដ្ឋកម្ម ដែលស្ថិតក្នុងចំណោមឧក្រិដ្ឋកម្មព្រៃផ្សៃ និងសាហាវយង់ឃ្នងបំផុតនៅក្នុងសតវត្សរ៍ទី ២០ នេះ អង្គបុរេជំនុំជម្រះសម្តែងការសោកស្តាយ និងថ្កោលទោសយ៉ាងខ្លាំងចំពោះស្ថានភាពគតិយុត្តិដែលមិនធ្លាប់មានពីមុន ដោយសារតែសកម្មភាពរបស់សហចៅក្រមស៊ើបអង្កេត បានបង្កឡើងចំពោះកិច្ចដំណើរការនីតិវិធីបច្ចុប្បន្នរបស់ អ.វ.ត.ក។ អង្គជំនុំជម្រះកត់សម្គាល់ដោយក្តីសោកស្តាយថា តាមការដឹងរបស់ខ្លួនកន្លងមក មិនដែលមានទាល់តែសោះនៅក្នុងប្រវត្តិសាស្ត្រជាតិ ឬ ប្រព័ន្ធច្បាប់អន្តរជាតិ ដែលសំណុំរឿងព្រហ្មទណ្ឌមួយ មានលក្ខណៈប្រហាក់ប្រហែលនឹងការចេញសេចក្តីសម្រេចពីរដែលផ្ទុយគ្នា ក្នុងពេលតែមួយ ដោយអង្គភាពតុលាការតែមួយនោះ។ អង្គជំនុំជម្រះបានពិភាក្សាយ៉ាងលម្អិតនៅក្នុងជំពូកពិសេសមួយអំពីសិទ្ធិអំណាចត្រួតពិនិត្យជាពិសេស[197] ដែលអង្គជំនុំជម្រះត្រូវប្រើប្រាស់ ក្នុងករណីដែលមានការមិនគោរពយ៉ាងងងើល ដោយសហចៅក្រមស៊ើបអង្កេតបែបនេះ ទៅលើគោលការណ៍ស្នូលដែលជាមូលដ្ឋាននៃប្រព័ន្ធច្បាប់ អ.វ.ត.ក និងការមិនប្រកាន់ខ្ជាប់នូវភារកិច្ចដ៏ធំធេងដែលអង្គភាពរបស់ខ្លួនត្រូវបំពេញ តាមក្របខណ្ឌគតិយុត្ត អ.វ.ត.ក នោះ។ អង្គជំនុំជម្រះក៏ធ្វើការបញ្ជាក់ផ្សេងផងដែរអំពីផលប៉ះពាល់ដែលកំហុសជាសារវ័ន្តនេះមាន ចំពោះស្ថានភាពគតិយុត្តិរបស់ដីកាដំណោះស្រាយនីមួយៗ[198]។

## V. ភាពអាចទទួលយកបាន
## ការទទួលយកជាផ្លូវការ

១. ដោយស្របតាមវិធាន ៧៥ ដែលគ្រប់គ្រងវិធី និងពេលវេលាកំណត់សម្រាប់ការដាក់បណ្តឹងឧទ្ធរណ៍ នៅចំពោះមុខអង្គបុរេជំនុំជម្រះ បណ្តឹងឧទ្ធរណ៍ទាំងបី ប្រឆាំងនឹងដីកាដំណោះស្រាយផ្ទុយគ្នា ទាំង ២ ទទួលយកបានជាផ្លូវការ ពីព្រោះការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ និងសារណា ត្រូវបានដាក់ក្នុងពេលវេលាដែលបានកំណត់ និងស្របតាមការណែនាំ[199]។

---

[197] សូមមើល ខាងលើ កថាខណ្ឌ៣១ ដល់ ៥៤។

[198] សូមមើល ខាងក្រោម កថាខណ្ឌ១៧០ ដល់ ៣០០ កថាខណ្ឌ៣០២ ដល់ ៣២៧។

[199] វិធាន ៧៥ នៃវិធានផ្ទៃក្នុង។ សេចក្តីសម្រេចលើការបន្ថែមពេលវេលាសម្រាប់ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ (D359/2)។ សេចក្តីសម្រេចលើការបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់សារណាបណ្តឹងឧទ្ធរណ៍ (D360/7)។ សាលដីកាលើការបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រកំណត់សម្រាប់ចម្លើយតប និងការឆ្លើយតប (D359/3/3 & D360/5/3)។

01634831



## បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ

១២៦. សហព្រះរាជអាជ្ញាជាតិបានប្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អនុលោមតាមវិធាន ៦៧(៥) វិធាន ៧៣(ក) និងវិធាន ៧៤(២) នៃវិធានផ្ទៃក្នុង [200] ។ សហព្រះរាជអាជ្ញាអន្តរជាតិមិនបានជេញដោលទៅលើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍នេះឡើយ[201]។

១២៧. អង្គបុរេជំនុំជម្រះយល់ឃើញថា អនុលោមតាមវិធាន ៦៧(៥) និងវិធាន ៧៤(២) នៃវិធានផ្ទៃក្នុង ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) អាចត្រូវប្តឹងឧទ្ធរណ៍បាន ព្រោះសហព្រះរាជអាជ្ញាជាតិអាចប្តឹងឧទ្ធរណ៍លើដីកាទាំងអស់ដែលសហចៅក្រមស៊ើបអង្កេតចេញ [202] ។ ហេតុដូច្នេះ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ អាចទទួលយកបាន។

## បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ

១២៨. សហព្រះរាជអាជ្ញាអន្តរជាតិបានប្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) របស់សហចៅក្រមស៊ើបអង្កេតជាតិ អនុលោមតាមវិធាន ៦៧(៥) និងវិធាន ៧៤(២) [203] នៃវិធានផ្ទៃក្នុង។ សហមេធាវីមិនបានជេញដោលពីភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍នេះ ឡើយ[204]។

១២៩. អង្គបុរេជំនុំជម្រះយល់ថា អនុលោមតាមវិធាន ៦៧(៥) និងវិធាន ៧៤(២) នៃវិធានផ្ទៃក្នុង ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) អាចត្រូវប្តឹងឧទ្ធរណ៍បាន ព្រោះសហ ព្រះរាជអាជ្ញាអន្តរជាតិអាចប្តឹងឧទ្ធរណ៍លើដីកាទាំងអស់ដែលសហចៅក្រមស៊ើបអង្កេតចេញ[205]។ ហេតុដូច្នេះ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិអាចទទួលយកបាន។

---

[200] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ឯកសារ D360/8/1 កថាខណ្ឌ ៦។

[201] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ឯកសារ D360/10។

[202] វិធាន ៦៧(៥) និងវិធាន ៧៤(២) នៃវិធានផ្ទៃក្នុង។

[203] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារ D359/3/1 កថាខណ្ឌ ៤, ៦។

[204] ចម្លើយតបរបស់ អោ អាន ឯកសារ D359/3/4។

[205] វិធាន ៦៧(៥) និងវិធាន ៧៤(២) នៃវិធានផ្ទៃក្នុង។

# បណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី

## ១. សារណា

១៣០. សហមេធាវីបានដាក់បណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមអន្តរជាតិ អនុលោមតាមវិធាន ៦៧(៥) ៧៤(៣)(ក) និង ២១ នៃវិធានផ្ទៃក្នុង[206]។ សហមេធាវីលើកឡើងពីគោលការណ៍ចំនួនបីជាមូលដ្ឋានដែល អ.ប.ជ គួរតែយល់ឃើញថា មូលដ្ឋាននីមួយៗ អាចទទួលយកបានលើបណ្តឹងឧទ្ធរណ៍៖ (១) យុត្តាធិការបុគ្គល (២) យុត្តាធិការលើរឿងក្តី និង (៣) គោលការណ៍ជាសារវ័ន្តនៃការជំនុំជម្រះក្តីដោយយុត្តិធម៌ រួមទាំងការលើកទឡ្ហីករណ៍បន្ថែមលើយុត្តាធិការនៅក្នុងសវនាការបណ្តឹងឧទ្ធរណ៍[207]ផងដែរ។ សហព្រះរាជអាជ្ញាអន្តរជាតិមិនជំទាស់នឹងភាពទទួលយកបាននៃ បណ្តឹងឧទ្ធរណ៍របស់អោអាន ឡើយ[208]។

១៣១. ទីមួយ ពាក់ព័ន្ធនឹងយុត្តាធិការបុគ្គល សហមេធាវីលើកទឡ្ហីករណ៍ថា មូលដ្ឋានទី ១-៧ ទី១០ ទី១២ ទី១៤ និង ទី ១៦-១៧ អាចទទួលយកបាន អនុលោមតាមវិធាន ៧៤(៣)(ក) "ជាទឡ្ហីករណ៍មានសុពលភាពចំពោះការបញ្ជាក់ [របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ] លើយុត្តាធិការបុគ្គលរបស់តុលាការលើ អោអាន" ដោយគិតពី "វិធីសាស្ត្រទូលំទូលាយ" របស់ អ.ប.ជ ក្នុងការទទួលយកទឡ្ហីករណ៍អំពីយុត្តាធិការរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងសំណុំរឿង០០៤/១[209]។ មូលដ្ឋានទី១ ដោះស្រាយបញ្ហានៃការចេញដីកាដំណោះស្រាយចំនួនពីរដំណាលគ្នា។ មូលដ្ឋានទី ២-៧ ពាក់ព័ន្ធនឹងកំហុសអង្គច្បាប់ និងអង្គហេតុក្នុងការកំណត់ថា អោ អាន ស្ថិតក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់។ មូលដ្ឋានទី១០ ទី១២ ទី១៤ និង ទី ១៦-១៧ ត្រូវបានចោទថាជាការជំទាស់តវ៉ាអំពីទម្រង់អំពីប្រល័យពូជសាសន៍ អំពើអមនុស្សធម៌ដទៃទៀត និងសហឧក្រិដ្ឋកម្ម នៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)[210]។ សហមេធាវីលើកទឡ្ហីករណ៍បន្ថែមទៀតថា ប្រសិនបើសហចៅក្រមស៊ើប

---

[206] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១, ១១។

[207] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១, ១១។ ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/10.1 និង ឯកសារ D360/19.1 ERN 01626145-01626148 ទំព័រ ១៨ បន្ទាត់ ១៤ ដល់ ទំព័រ ២០ បន្ទាត់ ២១។

[208] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9) ។

[209] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២-១៣ *យោងទៅ* សំណុំរឿង០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D308/3/1/20 កថាខណ្ឌ ២០, ២៤-២៦។

[210] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៣។

អង្កេតបានកំណត់ឧក្រិដ្ឋកម្មទាំងនេះបានត្រឹមត្រូវ និងអនុវត្តច្បាប់នោះ អោ អាន មិនអាចស្ថិតក្នុងចំណោមជនដែលទទួលខុសត្រូវខ្ពស់បំផុតឡើយ[211]។

១៣២. ទីពីរ ក្រោមយុត្តាធិការលើរឿងក្តី សហមេធាវីតវ៉ាថា មូលដ្ឋានទី ៨-៩ ១១, ១៣ និង ១៥ អាចទទួលយកបាន អនុលោមតាមវិធាន ៧៤(៣)(ក) ថាជាការជំទាស់តវ៉ាទៅនឹងយុត្តាធិការបុគ្គលរបស់តុលាការ ដោយហេតុថា ការជំទាស់តវ៉ាទាំងនោះទាក់ទិននឹង "អត្ថិភាពនៃឧក្រិដ្ឋកម្មជាក់លាក់មួយចំនួន ព្រមទាំងទម្រង់នៃការទទួលខុសត្រូវ និងថាតើការអនុវត្តទម្រង់នៃការទទួលខុសត្រូវទាំងនេះនៅក្នុងសំណុំរឿង០០៤/០២ រំលោភគោលការណ៍នីត្យានុកូលភាពដែរឬយ៉ាងណា"[212]។ មេធាវីអះអាងថា "ការជំទាស់តវ៉ាទាំងនេះអាចត្រូវបានលើកឡើងប្រឆាំងនឹងអត្ថិភាពផ្លូវច្បាប់ចំពោះបទល្មើសឬទម្រង់នៃការទទួលខុសសម្រាប់ឧក្រិដ្ឋកម្មទាំងមូល ឬអត្ថិភាពនៃធាតុផ្សំទូទៅសម្រាប់ឧក្រិដ្ឋកម្មទាំងនេះ"[213]។

១៣៣. ទីបី នៅក្នុងបរិបទនៃការជំនុំជម្រះក្តីដោយយុត្តិធម៌ សហមេធាវីអះអាងបញ្ជាក់ថា មូលដ្ឋានទី១ (តវ៉ាទៅនឹងការចេញដីកាដំណោះស្រាយចំនួនពីរ) និង មូលដ្ឋានទី១៨ ("ឥទ្ធិពលរួម"នៃការរំលោភបំពានសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ដែលអះអាងម្តងទៀត) ទទួលយកបាន អនុលោមតាមការបកស្រាយក្នុងន័យទូលាយលើវិធាន៧៤(៣) ដោយពិចារណាលើវិធាន ២១ ពីព្រោះវារំលោភសិទ្ធិរបស់ អោ អាន ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ហើយចំណុចនេះត្រូវតែបានដោះស្រាយនៅដំណាក់កាលជំនុំជម្រះ[214]។ ចំពោះទឡ្ហីករណ៍នៅពេលសវនាការលើបណ្តឹងឧទ្ធរណ៍នៅក្នុងចំណោមបញ្ហាផ្សេងៗ

---

[211] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៣។

[212] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤។

[213] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤ *យោងទៅ សំណុំរឿង ០០២* សាលដីកាលើបណ្តឹងឧទ្ធរណ៍(អៀង សារី) ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/1/30 កថាខណ្ឌ ៤៥-៤៦។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ (នួន ជា និង អៀង ធីរិទ្ធ) ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/2/15 & D427/3/15 កថាខណ្ឌ ៦០-៦១។

[214] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៥-១៦ *យោងទៅ* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង សារី) (D427/1/30) កថាខណ្ឌ ៤៨-៤៩។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (D427/2/15 & D427/3/15) កថាខណ្ឌ ៧១-៧៣។ សំណុំរឿង ០០២ (អ.ប.ជ ១០៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ D427/4/15 ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (ខៀវ សំផន) (D427/4/15)") កថាខណ្ឌ ១៨។ សំណុំរឿង ០០២ (អ.ប.ជ ៣៨) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ

សហមេធាវីអះអាងបន្ថែមទៀតថា ភាពខុសគ្នាផ្នែកនីតិវិធីរវាងភាគី អនុលោមតាមវិធាន៧៤ ឧទាហរណ៍ថា សហព្រះរាជអាជ្ញាទទួលបានវិធីបណ្ដឹងឧទ្ធរណ៍ចំហរ ចំណែកឯសហមេធាវីត្រូវបានកម្រិតឱ្យត្រឹមមូលដ្ឋានតិចតួច គឺជាការរំលោភលើគោលការណ៍សមភាពនៃមធ្យោបាយក្នុងការតទល់ក្ដី[215]។ ដោយយោងដល់បណ្ដឹងឧទ្ធរណ៍ដែលមិនទាន់សម្រេច សហមេធាវីលើកទឡ្ហីករណ៍ថា "យុត្តាធិការបុគ្គលមានលក្ខណៈពាក់ព័ន្ធគ្នាខាងក្នុងជាមួយទិដ្ឋភាពទាំងអស់នៃការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល" ហេតុដូចនេះ ការជំទាស់តវ៉ាទាំងអស់ទាក់ទិននឹងការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល ទទួលយកបាន[216]។ សហមេធាវីលើកឡើងថា វិធីសាស្ត្រនេះស្របតាមសំអាងហេតុរបស់អង្គជំនុំជម្រះក្នុងសំណុំរឿង០០៤/០១[217]។

## ២. ការពិភាក្សា

១៣៤. មូលដ្ឋានច្បាប់ដែលគ្រប់គ្រងភាពទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍ត្រូវបានដោះស្រាយ ហើយការជំទាស់តវ៉ានឹង (១) យុត្តាធិការលើរឿងក្ដីអនុលោមតាមវិធាន៧៤ (២) យុត្តាធិការបុគ្គលអនុលោមតាមវិធាន៧៤ និង (៣) បញ្ហាពិសេសនៃការជំនុំជម្រះក្ដីដោយយុត្តិធម៌ ដែលត្រូវបានពិនិត្យទៅតាមករណីនីមួយៗ ដែលគួរតែពង្រីកវិធាន៧៤ ក្រោមវិធាន ២១។

១៣៥. ជំពូក II នៃច្បាប់បង្កើត អ.វ.ត.ក ផ្ដល់ចំណុចសំខាន់ៗលើយុត្តាធិការបុគ្គល យុត្តាធិការពេលវេលា និងយុត្តាធិការលើរឿងក្ដី របស់ អ.វ.ត.ក[218]។ សញ្ញាណនៃការជំទាស់យុត្តាធិការមួយគឺជាទូទៅត្រូវបានចាត់ទុកថាជាចម្លើយមិនទទួលសមត្ថកិច្ចរបស់តុលាការ ដោយមូលហេតុនៃបុគ្គលពាក់ព័ន្ធ ដោយមូលហេតុ

D97/15/9 ("សាលដីកាលើសហឧក្រិដ្ឋកម្មរួមក្នុងសំណុំរឿង ០០២ (D97/15/9)") កថាខណ្ឌ ៣១-៣៤។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំឲ្យរកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី (D264/1) ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ ឯកសារ D264/2/6 ("សាលដីកាលើការរំលោភនីតិវិធីក្នុងសំណុំរឿង ០០២ (D264/2)") កថាខណ្ឌ ១៣-១៤។ សំណុំរឿង ០០៤/១ សេចក្ដីពិចារណាលើការសម្រេចឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ ឯកសារ*D239/1/8 កថាខណ្ឌ ២៣។

[215] ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/10.1 និង ឯកសារ D360/19.1 ERN 01626145 ទំព័រ ១៨ បន្ទាត់ ១៤ - ២៥។

[216] ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/10.1 និង ឯកសារ D360/19.1 ERN 01626145-01626148 ទំព័រ ១៨ បន្ទាត់ ២៤ ដល់ ទំព័រ ២១ បន្ទាត់ ២។

[217] ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/10.1 និង ឯកសារ D360/19.1 ERN 01626146-01626147 ទំព័រ ១៩ បន្ទាត់ ១៥ ដល់ ទំព័រ ២០ បន្ទាត់ ២១។

[218] ច្បាប់ អ.វ.ត.ក ជំពូកទី ២ មាត្រា ២ថ្មី-៨។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (D427/2/15 & D427/3/15) កថាខណ្ឌ ៦៣។

នៃរឿងក្ដីពាក់ព័ន្ធ ដោយមូលហេតុនៃយុត្តាធិការពេលវេលា និងដោយមូលហេតុនៃទីកន្លែង[219]។ វិធាន៧៤ (៣) ផ្ដល់ឲ្យជនត្រូវចោទ ឬជនជាប់ចោទ នូវសិទ្ធិប្ដឹងឧទ្ធរណ៍មានកម្រិត តែចំពោះដីកា និងសេចក្ដីសម្រេច ដែលមានចែងជាពិសេសក្រោមបទប្បញ្ញត្តិ[220]។ ពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទគឺវិធាន ៧៤ (៣)(ក) ដែលចែងថា "ជនត្រូវចោទឬជនជាប់ចោទអាចធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា [...]ឬ សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត៖ ក) ការបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក[...]"[221]។ ផ្អែកលើ វិធាន៧៤(៣)(ក) ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) "ត្រូវតែអាចប្ដឹងឧទ្ធរណ៍ពាក់ព័ន្ធនឹង បញ្ហាយុត្តាធិការដែលសម្រេចដោយសហចៅក្រមស៊ើបអង្កេត"[222]។

១៣៦. វិសាលភាពនៃយុត្តាធិការលើរឿងក្ដីនៅអ.វ.ត.ក កម្រិតត្រឹមតែឧក្រិដ្ឋកម្មដែលចែងក្នុងមាត្រា៣ថ្មី ដល់មាត្រា ៨ នៃច្បាប់បង្កើត អ.វ.ត.ក តែប៉ុណ្ណោះ។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា "ដើម្បី ឲ្យបទល្មើសដែលត្រូវបានចោទប្រកាន់ និងទម្រង់នៃការចូលរួមស្ថិតនៅក្នុងយុត្តាធិការលើរឿងក្ដីរបស់ អ.វ.ត.ក ត្រូវតែ ១) "មានចែងនៅក្នុង [ច្បាប់ស្ដីពីការបង្កើតអ.វ.ត.ក] ដោយច្បាស់លាស់ ឬដោយ ប្រយោល" និង ២) មានអត្ថិភាពក្រោមច្បាប់កម្ពុជា ឬច្បាប់អន្តរជាតិ នៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩"[223]។

១៣៧. ដោយរៀបរាប់បន្ថែមអំពីយុត្តាធិការលើរឿងក្ដី អង្គបុរេជំនុំជម្រះរម្លឹកថា បណ្ដឹងឧទ្ធរណ៍ដែល៖

> ១) "បណ្ដឹងជំទាស់ [...] អត្ថិភាពនៃទម្រង់នៃការទទួលខុសត្រូវ ឬការទទួលស្គាល់ទម្រង់តាម ច្បាប់នោះ [...] នៅពេលដែលចោទប្រកាន់" ឬ ២) តវ៉ាថា ទម្រង់នៃការទទួលខុសត្រូវ "មិន

---

219 សេចក្ដីពិចារណាលើការសម្រេចឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*ក្នុងសំណុំរឿង ០០៤/១ (D239/1/8) កថាខណ្ឌ ២២។

220 វិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (ខៀវ សំផន) (D427/4/15) កថាខណ្ឌ ១៤។

221 វិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង។

222 សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (ខៀវ សំផន) (D427/4/15) កថាខណ្ឌ ១៤ (លុបជើងទំព័រ)។ *សូមមើលផងដែរ* សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង សារី) (D427/1/30) កថាខណ្ឌ ៤៤-៤៥។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (D427/2/15 & D427/3/15) កថាខណ្ឌ ៥៩-៦០។ សាលដីកាលើសហឧក្រិដ្ឋកម្មរួមក្នុងសំណុំរឿង ០០២ (D97/15/9) កថាខណ្ឌ ១៩, ២១។

223 សំណុំរឿង ០០១ សាលដីកាក្នុងសំណុំរឿង ០០១ (F28) កថាខណ្ឌ ៩៨ (លុបជើងទំព័រ)។

អាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មជាក់លាក់ណាមួយ” នៅពេលដែលចោទប្រកាន់នោះទេ និង ៣) បង្ហាញថា “ការអនុវត្តទម្រង់នៃការទទួលខុសត្រូវនឹងរំលោភលើគោលការណ៍នីត្យានុកូលភាព” លើកឡើងនូវបណ្តឹងជំទាស់យុត្តាធិការជាកម្មវត្ថុអាចទទួលយកបានដែលអាចធ្វើឡើងនៅក្នុងដំណាក់កាលបុរេជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធី[224]។

១៣៨. មូលដ្ឋានបណ្តឹងឧទ្ធរណ៍ដែលជំទាស់បទល្មើសសារធាតុត្រូវបានរកឃើញថាជាការលើកឡើងការជំទាស់យុត្តាធិការលើរឿងក្តី “ដែលមានការជំទាស់មួយទៅនឹងអត្ថិភាពនៃច្បាប់នៃបទល្មើស និងធាតុផ្សំនៅក្នុងពេលវេលាពាក់ព័ន្ធនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលប្រសិនបើបានអនុវត្ត គឺអាចផ្តល់លទ្ធផលជាការរំលោភគោលការណ៍នីត្យានុកូលភាព”[225]។

១៣៩. ផ្ទុយទៅវិញ ក្នុងការរៀបរាប់អំពីព្រំដែនកំណត់នៃយុត្តាធិការលើរឿងក្តី អង្គបុរេជំនុំជម្រះសម្រេចថា ការជំទាស់ពាក់ព័ន្ធនឹងទម្រង់ជាក់លាក់នៃទម្រង់នៃការទទួលខុសត្រូវ ឬបទល្មើសសារធាតុ “គឺជាបញ្ហាដែលត្រូវដោះស្រាយនៅពេលជំនុំជម្រះ” ហេតុដូចនេះ មិនអាចទទួលយកបាន[226]។ ហេតុដូច្នេះ ការជំទាស់ពាក់ព័ន្ធនឹងថាតើធាតុផ្សំនៃបទល្មើស ឬទម្រង់នៃការទទួលខុសត្រូវ ពិតជាមានអត្ថិភាពពិតជាក់ស្តែងឬទេ

---

[224] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង សារី) (D427/1/30) កថាខណ្ឌ ៤៥។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (D427/2/15 & D427/3/15) កថាខណ្ឌ ៦០។ សាលដីកាលើសហឧក្រិដ្ឋកម្មរួមក្នុងសំណុំរឿង ០០២ (D97/15/9) កថាខណ្ឌ ២៣-២៤។

[225] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង សារី) (D427/1/30) កថាខណ្ឌ ៤៦។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (D427/2/15 & D427/3/15) កថាខណ្ឌ ៦១។ សំណុំរឿង ០០៤/២ (អ.ប.ជ ៤២) សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងការជូនដំណឹងស្តីពីការបកស្រាយ “ការវាយប្រហារទៅលើប្រជាជនស៊ីវិល” នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធរបស់របប ឬរដ្ឋមួយ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ ឯកសារ D347.1/1/7 កថាខណ្ឌ ១១។ *សូមមើលផងដែរ* សាលដីកាលើសហឧក្រិដ្ឋកម្មរួមក្នុងសំណុំរឿង ០០២ (D97/15/9) កថាខណ្ឌ ២៣។ សំណុំរឿង ០០៣ (អ.ប.ជ ៣០) សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ទៅនឹងដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៧ ឯកសារ D87/2/1.7/1/1/7 (សំណុំរឿង ០០៣ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់មាស មុត ប្រឆាំងនឹងជម្លោះប្រដាប់អាវុធ (D87/2/1.7/1/1/7)) កថាខណ្ឌ ១២។

[226] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង សារី) (D427/1/30) កថាខណ្ឌ ៤៥-៤៦។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (D427/2/15 & D427/3/15) កថាខណ្ឌ ៦០, ៦២។

ដែលផ្ទុយទៅនឹងមានអត្ថិភាពតាមផ្លូវច្បាប់នៅពេលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដែលបានចោទប្រកាន់ គឺជាបញ្ហាដែលត្រូវដោះស្រាយនៅពេលជំនុំជម្រះ[227]។ ពាក់ព័ន្ធនឹងកំហុសដែលបានចោទប្រកាន់ជាទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ បញ្ហាបែបនេះ "ច្បាស់ណាស់ថា មិនមែនមានលក្ខណៈជាបញ្ហាយុត្តាធិការឡើយ ហេតុដូច្នេះ មិនអាចទទួលយកបាននៅក្នុងដំណាក់កាលមុនជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីឡើយ ដោយគិតដល់អត្ថន័យទាំងមូលនៃវិធាន៧៤(៣)(ក) និងជំពូក II នៃច្បាប់បង្កើត អ.វ.ត.ក[228]។ អង្គជំនុំ

[227] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង សារី) (D427/1/30) កថាខណ្ឌ ៤៥-៤៦។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (D427/2/15 & D427/3/15) កថាខណ្ឌ ៦០, ៦២។ សាលដីកាលើសហឧក្រិដ្ឋកម្មរួមក្នុងសំណុំរឿង ០០២ (D97/15/9) កថាខណ្ឌ ២៣។ *សូមមើលផងដែរ* តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blaškić* សំណុំរឿងលេខ IT-95-14-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ ("សាលដីកាក្នុងរឿងក្តី *Blaškić* (ICTY)") កថាខណ្ឌ ៣២-៤២ (ការបង្ហាញព្រំដែននឹងធាតុផ្សំផ្លូវចិត្តនៃពាក្យ "ការបញ្ជា" តាមមាត្រា ៧(១) នៃលក្ខន្តិកៈ)។ តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Milutinović និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-05-87-PT សេចក្តីសម្រេចលើពាក្យសុំរបស់ Ojdanić ជំទាស់ទៅនឹងយុត្តាធិការលើសហចារីមិនផ្ទាល់ អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ ២៣ (ពិភាក្សាអំពីយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងព្រំដែននៃការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម)។ តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-96 -21-AR72.5 សេចក្តីសម្រេចលើពាក្យសុំការអនុញ្ញាតរបស់ Hazim Delić (វិការៈក្នុងទម្រង់នៃដីកាបញ្ជូនទៅជំនុំជម្រះ) អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៩៦ កថាខណ្ឌ ២៧ (សម្រេចថា វិវាទនានាពាក់ព័ន្ធនឹងខ្លឹមសារនៃឧក្រិដ្ឋកម្មដែលបានរួមបញ្ចូលនៅក្នុងមាត្រា ២, ៣, ៤ និង ៥ នៃលក្ខន្តិកៈ គឺជាបញ្ហាសម្រាប់ជំទាស់ក្នុងការជំនុំជម្រះ ពុំមែនជាការជំទាស់មុនការជំនុំជម្រះនោះឡើយ)។ តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Furundžija* សំណុំរឿងលេខ IT-05-17/1-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៨ កថាខណ្ឌ ១៧២-១៨៦ (ពិភាក្សាអំពីធាតុផ្សំដែលចាំបាច់ដើម្បីធ្វើសេចក្តីសន្និដ្ឋានទៅលើបទល្មើសរំលោភផ្លូវភេទអនុលោមតាមមាត្រា ៧៥ នៃលក្ខន្តិកៈ)។ តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-96-23 សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០១ ("សាលក្រមក្នុងរឿងក្តី *Kunarac និងអ្នកផ្សេងទៀត* (ICTY)") កថាខណ្ឌ ៤៣៦-៤៦០ (សាលក្រមដែលបង្ហាញព្រំដែននៃបទល្មើសរំលោភផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអនុលោមតាមមាត្រា ៥ (ឆ) នៃលក្ខន្តិកៈ)។

[228] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង សារី) (D427/1/30) កថាខណ្ឌ ៤៧។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (D427/2/15 & D427/3/15) កថាខណ្ឌ ៦៣ *យោងទៅ* សេចក្តីសម្រេចលើយុត្តាធិការក្នុងរឿងក្តី *Gotovina និងអ្នកផ្សេងទៀត* (ICTY) កថាខណ្ឌ ២១, ២៤ (សន្និដ្ឋានថា ទឡ្ហីករណ៍នានាដែលចោទប្រកាន់ថា អយ្យការមិនបានលើកឡើងនូវធាតុផ្សំមួយនៃទម្រង់នៃការទទួលខុសត្រូវឲ្យបានត្រឹមត្រូវ បទប្បញ្ញត្តិនានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះរួមមិនស៊ីសង្វាក់គ្នា ហើយអយ្យការមិនបានបង្ហាញអង្គហេតុគាំទ្រដល់អត្ថិភាពនៃធាតុផ្សំមួយនៃឧក្រិដ្ឋកម្មមួយដែលបង្ហាញជាការចោទប្រកាន់ដែលមិនអាចទទួលយកបានដោយមានវិការៈនៅក្នុងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ)។ តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Prlić និងអ្នកផ្សេង*

01634838



ជម្រះរម្លឹកថា គ្មានបទប្បញ្ញត្តិណានៅក្នុងច្បាប់បង្កើត អ.វ.ត.ក "បញ្ជាក់ថា កំហុសដែលបានចោទប្រកាន់ក្នុងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើកឡើងបញ្ហាយុត្តាធិការឡើយ។ ហេតុដូច្នេះ ទឡ្ហីករណ៍ទាំងនេះ អាចយកមកអង្គជំនុំជម្រះសាលាដំបូង ដើម្បីពិចារណាលើអង្គសេចក្តីនៅពេលជំនុំជម្រះ [...]"[229]។

១៤០. យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក គឺកម្រិតត្រឹមតែ "មេដឹកនាំជាន់ខ្ពស់" និង "ជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត"ចំពោះឧក្រិដ្ឋកម្ម[230]។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ទោះបីជាពាក្យ "ទទួលខុសត្រូវខ្ពស់បំផុត" មិនមានចែងនៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក ឬច្បាប់បង្កើត អ.វ.ត.ក ក៏ដោយ ប៉ុន្តែអាចស្វែងយល់បានតាមរយៈការបកស្រាយដោយមើលទៅលើយុត្តិសាស្ត្រអន្តរជាតិ ដោយពិចារណាលើកម្មវត្ថុ និងគោលបំណងនៃលិខិតូបករណ៍បង្កើតតុលាការនេះ[231]។ ដូចដែលអង្គជំនុំជម្រះមួយចំនួននៃ អ.វ.ត.ក បានសម្រេចរួចហើយ យុត្តិសាស្ត្រអន្តរជាតិបញ្ជាក់ថា ការកំណត់អ្នកដែលស្ថិតក្នុងប្រភេទ "ជនទទួលខុសត្រូវខ្ពស់បំផុត" រួមមានការវាយតម្លៃលើគុណវិស័យ និងបរិមាណវិស័យលើភាពធ្ងន់ធ្ងររបស់ឧក្រិដ្ឋកម្ម (ដែលបានលើកឡើង ឬចោទប្រកាន់) និងកម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យ[232]។

---

*ទៀត* សំណុំរឿងលេខ IT-04-74-AR72.1 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ថែរបស់ Petković ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើយុត្តាធិការ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៥ កថាខណ្ឌ ១៣។

[229] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង សារី) (D427/1/30) កថាខណ្ឌ ៤៧។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (D427/2/15 & D427/3/15) កថាខណ្ឌ ៦៣។

[230] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ២(១)។ ច្បាប់ អ.វ.ត.ក មាត្រា ២ថ្មី។

[231] *សូមមើល អនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា* ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៦៩ ឯកសារ 1155 U.N.T.S. 331 *ចូលជាធរមាន*នៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៨០ ("អនុសញ្ញាទីក្រុងវីយែន") មាត្រា ៣១(១)(២) (ចែងថា ពាក្យពេចន៍នៅក្នុងលិខិតុបករណ៍មួយត្រូវបកស្រាយជាចម្បងផ្តោតលើបរិបទរបស់វា ដែលរួមមាន អត្ថបទនៃលិខិតុបករណ៍នោះទៅតាមកម្មវត្ថុ និងគោលបំណងរបស់វា)។ កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១២(១) (ចែងថា នៅពេលមានភាពមិនច្បាស់លាស់នៅក្នុងច្បាប់ជាធរមាន "គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបង្កើតឡើងក្នុងកម្រិតអន្តរជាតិ")។ ច្បាប់ អ.វ.ត.ក មាត្រា ២៣ថ្មី (ចែងថា សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំនៅក្នុងវិធាននៃនីតិវិធីនៅកម្រិតអន្តរជាតិបាន)។ *សូមមើលផងដែរ* សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់លើភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ (D404/2/4) កថាខណ្ឌ ៥៨-៦០។

[232] *សូមមើលឧទាហរណ៍* សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 ("សាលក្រមក្នុងសំណុំរឿង ០០១ (E188)") កថាខណ្ឌ ២២ ជើងទំព័រអមជាមួយ។ សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) យោបល់របស់ចៅក្រម BAIK និង BEAUVALLET កថាខណ្ឌ

១៤១. ការវាយតម្លៃលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានលើកឡើង ឬដែលបានចោទប្រកាន់ គឺផ្អែកលើកត្តាផ្សេងៗ ដូចជា ចំនួនជនរងគ្រោះ វិសាលភាពភូមិសាស្ត្រ និងពេលវេលា និងលក្ខណៈដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបានលើកឡើងថាបានប្រព្រឹត្ត ចំនួនហេតុការណ៍ដាច់ពីគ្នា លក្ខណៈ និងទំហំ និងឥទ្ធិពលលើជនរងគ្រោះ[233]។ ការវាយតម្លៃចុងក្រោយលើកម្រិតទទួលខុសត្រូវរបស់ជនសង្ស័យរួមមានការពិចារណានានា ដូចជា (ប៉ុន្តែមិនកម្រិតត្រឹមតែ) កម្រិតនៃការចូលរួមរបស់ជនសង្ស័យក្នុងបទល្មើស ឋានៈ ឬមុខតំណែងតាមឋានានុក្រម (ក្នុងនោះរួមមាន ចំនួននៃមន្ត្រីក្រោមបង្គាប់ និងថ្នាក់លើតាមឋានានុក្រម) ភាពអចិន្ត្រៃយ៍នៃមុខតំណែង និង តួនាទី និងការទទួលខុសត្រូវតាមព្រឹត្តន័យរបស់ជនសង្ស័យ[234]។

១៤២. លើសពីនេះទៀត ក្នុងសំណុំរឿង០០៤/០១ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា អ.វ.ត.ក ពុំមានយុត្តាធិការបុគ្គលលើជនត្រូវចោទឡើយ[235]។ អង្គបុរេជំនុំជម្រះសម្រេចថា នៅពេលដែលមានសំអាងហេតុពីមុនថាពុំមានយុត្តាធិការ ចំណុចនេះអាចពិនិត្យឡើងវិញបាន។ លើសពីនេះទៀត អង្គបុរេជំនុំជម្រះ "ដែលជាអង្គជំនុំជម្រះពិនិត្យមើលលើបណ្តឹងឧទ្ធរណ៍ ប្រាកដជាអាចពិនិត្យមើលលើសេចក្តីសន្និដ្ឋាននានាដែលនាំឱ្យមានការសម្រេចបែបនេះ រួមទាំងសេចក្តីសន្និដ្ឋានទាំងឡាយណាពាក់ព័ន្ធនឹងអត្ថិភាពនៃបទល្មើស ឬភាពនីយភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ"[236]។ ចំណុចនេះជាការផ្ទុយទៅនឹងសារណារបស់សហ

---

៣២១។ សំណុំរឿង ០០៣ សេចក្តីសម្រេចលើយុត្តាធិការបុគ្គល និងគោលនយោបាយនៃការស៊ើបអង្កេតពាក់ព័ន្ធនឹងជនសង្ស័យ មាស មុត ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១២ ឯកសារ D48 ("សេចក្តីសម្រេចលើយុត្តាធិការបុគ្គលក្នុងសំណុំរឿង ០០៣ (D48)") កថាខណ្ឌ ១៥ និងជើងទំព័រ ២៥។

[233] សាលក្រមក្នុងសំណុំរឿង ០០១ (E188) កថាខណ្ឌ ២២។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) យោបល់របស់ចៅក្រម BAIK និង BEAUVALLET កថាខណ្ឌ ៣២៧។ តុលាការ ICC *ស្ថានភាពស្តីពីនាវាដែលបានចុះបញ្ជីនៅសហភាពកូម៉ូរ៉ូស សាធារណរដ្ឋហេលែនិក និងព្រះរាជាណាចក្រកម្ពុជា* សំណុំរឿងលេខ ICC-01/13-34 សេចក្តីសម្រេចលើសំណើរបស់សហភាពកូម៉ូរ៉ូសសុំពិនិត្យឡើងវិញទៅលើសេចក្តីសម្រេចរបស់រដ្ឋអាជ្ញាមិនអាចដំណើរការកិច្ចដំណើរការស៊ើបអង្កេត អង្គបុរេជំនុំជម្រះ I ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ កថាខណ្ឌ ២១។

[234] សាលក្រមក្នុងសំណុំរឿង ០០១ (E188) កថាខណ្ឌ ២២។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) យោបល់របស់ចៅក្រម BAIK និង BEAUVALLET កថាខណ្ឌ ៣៣២។

[235] សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ (ផ្នែកសេចក្តីសម្រេច) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ D308 កថាខណ្ឌ ១០-១១, ១៤។ សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D308/3 ("ដីកាដំណោះស្រាយ (សំអាងហេតុ) ក្នុងសំណុំរឿង ០០៤/១ (D308/3)") កថាខណ្ឌ ៣១២-៣២៥។

[236] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ២៦។

មេធាវី[237] អង្គបុរេជំនុំជម្រះសង្កេតឃើញថា ក្នុងសំណុំរឿង០០៤/០១ ដែលខុសប្លែកពីករណីនេះ គឺថា សំអាងហេតុទាំងនោះត្រូវបានធ្វើឡើង ពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍ដែលដាក់ អនុលោមតាមវិធាន៧៤(២) ដោយសហព្រះរាជអាជ្ញាអន្តរជាតិដែលអាចប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា និងសេចក្ដីសម្រេចទាំងអស់[238]។ បញ្ហានេះមិនពាក់ព័ន្ធនឹងបទប្បញ្ញត្តិដែលមានចែងក្នុងវិធាន ៧៤(៣) សម្រាប់ជនជាប់ចោទដូចនៅទីនេះឡើយ[239]។

១៤៣. អង្គបុរេជំនុំជម្រះមិនយល់ថា វិធីសាស្ត្រស្រដៀងគ្នាអនុវត្តចំពោះបណ្ដឹងឧទ្ធរណ៍ដែលដាក់ អនុលោមតាមវិធាន៧៤(៣)(ក) ដែលជំទាស់នឹងយុត្តាធិការបុគ្គលលើជនជាប់ចោទឡើយ។ ភាពខុសគ្នាផ្នែកនីតិវិធីរវាងសិទ្ធិបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា និងជនជាប់ចោទ មិនរំលោភគោលការណ៍សមភាពនៃមធ្យោបាយក្នុងការតទល់ក្ដីឡើយ[240]។ អង្គជំនុំជម្រះកន្លងមកសម្រេចថា នៅ អ.វ.ត.ក វិធានអនុវត្តកំណត់សិទ្ធិនីតិវិធីប្ដឹងឧទ្ធរណ៍ខុសៗគ្នាក្នុងការប្ដឹងតវ៉ាដោយភាគី "ចំពោះភាពអាចទទួលយកបាន អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃ ក្នុងការពិនិត្យបណ្ដឹងឧទ្ធរណ៍ទៅតាមករណីនីមួយៗ មានគោលបំណងដើម្បីធានាសិទ្ធិរបស់ភាគីទាំងអស់"[241]។ អង្គបុរេជំនុំជម្រះយល់ឃើញថា វាជាចេតនាច្បាស់លាស់របស់អ្នកធ្វើសេចក្ដីព្រាងក្នុងការផ្ដល់សិទ្ធិនីតិវិធីប្ដឹងឧទ្ធរណ៍ដល់ភាគីអនុលោមតាមវិធាន៧៤។ បទប្បញ្ញត្តិនេះដែលបញ្ជាក់ពីសិទ្ធិដែលមានចែង អាចក្លាយជាឥតន័យ ប្រសិនបើជនជាប់ចោទអាចជំទាស់នឹងអ្វីៗដែលពាក់ព័ន្ធនឹង "ការទទួលខុសត្រូវព្រហ្មទណ្ឌ" រួមទាំងទម្រង់នៃបទល្មើស ឬទម្រង់នៃការទទួលខុសត្រូវតាមលក្ខណៈយុត្តាធិការបុគ្គល[242]។

---

[237] ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/10.1 និង ឯកសារ D360/19.1 ERN 01626146-01626147 ទំព័រ ១៩ បន្ទាត់ ១៥ ដល់ ទំព័រ ២០ បន្ទាត់ ២១។ បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២-១៣ *យោងទៅ* សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ២០, ២៤-២៦។

[238] វិធាន ៧៤(២) នៃវិធានផ្ទៃក្នុង។

[239] វិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (ខៀវ សំផន) (D427/4/15) កថាខណ្ឌ ១៤។

[240] *ផ្ទុយពី*ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/10.1 និង ឯកសារ D360/19.1 ERN 01626145 ទំព័រ ១៨ បន្ទាត់ ១៤-២៤។

[241] សំណុំរឿង ០០៤ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់យឹម ទិត្យ ឯកសារD361/4/1/10 កថាខណ្ឌ ១៩។

[242] *ផ្ទុយពី*ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/10.1 និង ឯកសារ D360/19.1 ERN 01626145-01626147 ទំព័រ ១៨ បន្ទាត់ ២៤ ដល់ ទំព័រ ២០ បន្ទាត់ ៨។

១៤៤. លើសពីនេះទៀត ការកំណត់យុត្តាធិការបុគ្គលតម្រូវឱ្យមានវិសាលភាពនៃការពិនិត្យពិច័យភស្តុតាង។ មិនដូចគ្នានឹងអង្គជំនុំជម្រះសាលាដំបូងដែលពិចារណាលើពិរុទ្ធភាព ឬការគ្មានពិរុទ្ធភាពនៃជនជាប់ចោទ ដោយថ្លឹងថ្លែងភស្តុតាងទាំងអស់នៅពេលជំនុំជម្រះ អង្គបុរេជំនុំជម្រះប្រឈមនឹងការជំទាស់តវ៉ាយុត្តាធិការបុគ្គលពាក់ព័ន្ធនឹង "ជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត" គួរតែពិចារណាលើវិសាលភាពភស្តុតាងដែលមានកម្រិត ដែលតម្រូវយ៉ាងខ្លាំងក្នុងការវាយតម្លៃបញ្ហាច្បាស់លាស់នៃយុត្តាធិការបុគ្គលនៅដំណាក់កាលមុនជំនុំជម្រះ។ ដូច្នេះ ក្នុងការពិចារណាលើបញ្ហានេះ អង្គបុរេជំនុំជម្រះត្រូវតែកម្រិតការវាយតម្លៃចុងក្រោយចំពោះបញ្ហាដែលមានលក្ខណៈសំខាន់ក្នុងការកំណត់យុត្តាធិការបុគ្គល គឺ ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និង/ឬកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ។

១៤៥. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា ការជំទាស់នឹងយុត្តាធិការបុគ្គលពាក់ព័ន្ធនឹង "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"គួរតែសំដៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និង/ឬកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ។ ការជំទាស់ពាក់ព័ន្ធនឹងការដាក់បន្ទុកពិរុទ្ធភាពរបស់ជនជាប់ចោទដែលហួសពីការកម្រិតនេះ ក្នុងនោះរួមមានវង្វង់នៃបទល្មើស ឬទម្រង់នៃការទទួលខុសត្រូវ មិនអាចបង្កើតបានជាការជំទាស់យុត្តាធិការបុគ្គល និងមិនអាចទទួលយកបាន។

១៤៦. ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ដែលដាក់អនុលោមតាមវិធាន២១ អង្គបុរេជំនុំជម្រះបានសម្រេចនៅក្នុងសំណុំរឿងមុនៗថា "ស្របជាមួយនឹងមាត្រា៣៣(ថ្មី)នៃច្បាប់ អ.វ.ត.ក ដែលចែងថា ការជំនុំជម្រះក្តីត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ និងដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទ និងស្របជាមួយនឹងមាត្រា១៤នៃកតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលអាចអនុវត្តបាននៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី នៅចំពោះមុខអ.វ.ត.ក [...] ការពិចារណាសំខាន់ជាងគេនៅក្នុងគ្រប់កិច្ចដំណើរការនីតិវិធីនៅចំពោះមុខអ.វ.ត.ក គឺភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធិ ដូចមានចែងនៅក្នុងវិធាន២១(១)(ក)នៃវិធានផ្ទៃក្នុង"[243]។ អង្គជំនុំជម្រះកត់សម្គាល់ថា "ហេតុដូច្នេះ នៅពេល

[243] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង សារី) (D427/1/30) កថាខណ្ឌ ៤៩ *ដកស្រង់ពី* សាលដីកាលើការរំលោភនីតិវិធីក្នុងសំណុំរឿង ០០២ (D264/2) កថាខណ្ឌ ១៣-១៤។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (D427/2/15 & D427/3/15) កថាខណ្ឌ ៧១ *យោងទៅ* សាលដីកាលើការរំលោភនីតិវិធីក្នុងសំណុំរឿង ០០២ (D264/1) កថាខណ្ឌ ១៣-១៤។ *សូមមើល* សំណុំរឿង ០០២ (អ.ប.ជ ៥៨) សាលដីកាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចលើសំណើលើកទី១៨របស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D273/3/5 កថាខណ្ឌ ១០។

ដែលអង្គហេតុ និងកាលៈទេសៈនានានៃបណ្តឹងឧទ្ធរណ៍តម្រូវឱ្យមានការពិចារណាសំខាន់ជាងគេ អង្គបុរេជំនុំជម្រះបានយល់ឃើញថា ខ្លួនមានសមត្ថកិច្ចធ្វើការពិចារណាអំពីមូលដ្ឋាននានាដែលបានលើកឡើងដោយម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលមិនត្រូវបានរៀបរាប់ច្បាស់លាស់ ស្របតាមវិធាន៧៤(៣) នៃវិធានផ្ទៃក្នុងតាមរយៈការបកស្រាយដែលមានគំនិតច្រើនអំពីសិទ្ធិរបស់ជនត្រូវចោទក្នុងការប្តឹងឧទ្ធរណ៍ស្របតាមវិធាន២១ នៃវិធានផ្ទៃក្នុង"[244]។ លើសពីនេះទៀត វាមានលក្ខណៈសមស្របតាមពេលវេលាក្នុងការធ្វើការបកស្រាយលើសញ្ញាណនៃយុត្តាធិការ ជាពិសេសស ក្នុងស្ថានភាពដែលបញ្ហាចំពោះមុខនេះ មិនអាចប្រមើលឃើញនៅក្នុងវិធានផ្ទៃក្នុង និងដែលតម្រូវឱ្យមានដំណោះស្រាយភ្លាមៗដើម្បីទប់ស្កាត់ការធ្វើឱ្យអន្តរាយដល់កិច្ចដំណើរការនីតិវិធី[245]។

១៤៧. យ៉ាងណាក៏ដោយ អង្គបុរេជំនុំជម្រះបានបញ្ជាក់ស្របៗគ្នាថា វិធាន ២១ មិនបើកផ្លូវដោយស្វ័យប្រវត្តិឱ្យមានបណ្តឹងឧទ្ធរណ៍ឡើយ បើទោះជានៅពេលបណ្តឹងឧទ្ធរណ៍លើកឡើងអំពីបញ្ហាការជំនុំជម្រះក្តីដោយយុត្តិធម៌ក៏ដោយ[246]។ ភាគីដែលកើតទុក្ខមិនសុខចិត្តត្រូវបង្ហាញថា កាលៈទេសៈពិសេស តម្រូវឱ្យអង្គ

---

[244] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង សារី) (D427/1/30) កថាខណ្ឌ ៤៩។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (D427/2/15 & D427/3/15) កថាខណ្ឌ ៧១។ *សូមមើល* សាលដីកាលើសហឧក្រិដ្ឋកម្មរួមក្នុងសំណុំរឿង ០០២ (D97/15/9) កថាខណ្ឌ ៣០។ សំណុំរឿង ០០៣ (អ.ប.ជ ២៩) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលដាក់ មាស មុត ឱ្យស្ថិតក្រោមការត្រួតពិនិត្យពីអំពើបំពារបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មថ្នាក់ជាតិ និងអនុវត្តសហឧក្រិដ្ឋកម្មរួម និងទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ឯកសារ D174/1/4 មតិយោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK ("សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចចោទប្រកាន់ក្នុងសំណុំរឿង ០០៣ (D174/1/4) (មតិយោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK)") កថាខណ្ឌ ១៩។ សំណុំរឿង ០០៤ (អ.ប.ជ ០៥) ការពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់តាអាន ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធលើសំណើសុំពិនិត្យមើលឯកសារសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤ ឯកសារ D121/4/1/4 មតិយោបល់របស់ចៅក្រម CHUNG និងចៅក្រម DOWING ("ការពិចារណាលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងការសុំចូលមើលឯកសារសំណុំរឿងក្នុងសំណុំរឿង ០០៤ (D121/4/1/4) កថាខណ្ឌ ៩។

[245] *សូមមើលឧទាហរណ៍* សេចក្តីពិចារណាលើការសម្រេចឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*ក្នុងសំណុំរឿង ០០៤/១ (D239/1/8) កថាខណ្ឌ ២២-២៣។

[246] *សូមមើលឧទាហរណ៍* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (D427/2/15 & D427/3/15) កថាខណ្ឌ ៧៣។ សេចក្តីពិចារណាលើការសម្រេចឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ក្នុងសំណុំរឿង ០០៤/១ (D239/1/8) កថាខណ្ឌ ១៧។ សេចក្តីពិចារណាលើការដាក់ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* (D128/1/9) កថាខណ្ឌ ២០។

ជំនុំជម្រះធ្វើអន្តរាគមន៍នៅដំណាក់កាលដែលបណ្តឹងឧទ្ធរណ៍ ត្រូវបានដាក់ ដើម្បីចៀសវាងព្យសនកម្មដែលមិនអាចកែបានដល់ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ឬដល់សិទ្ធិជាសារវ័ន្តនៃការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌[247]។ នៅក្នុងរឿងក្តីនេះ អង្គបុរេជំនុំជម្រះនឹងពិចារណាទៅតាមករណីនីមួយៗ ថាតើលក្ខខណ្ឌទាំងឡាយតម្រូវឲ្យមានការបកស្រាយទូលំទូលាយលើវិធាន ៧៤(៣) ដោយពិចារណាលើវិធាន ២១ ដែរឬយ៉ាងណា។ ជាពិសេស នៅពេលបណ្តឹងឧទ្ធរណ៍ដែលបានដាក់ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះអនុលោមតាមវិធាន៧៤ លើកឡើងពីបញ្ហាមួយដែលអង្គជំនុំជម្រះសាលាដំបូងមិនអាចកែតម្រូវបាន ហើយការបដិសេធបណ្តឹងឧទ្ធរណ៍មួយ អាច "បង្កព្យសនកម្មដែលមិនអាចជួសជុលបានទៅលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនជាប់ចោទ"។ វិធាន២១ អាចតម្រូវឲ្យមានការពង្រីកវិធាន៧៤ ទៅតាមករណីនីមួយៗ[248]។

## ក. មូលដ្ឋានទទួលយកបណ្តឹងឧទ្ធរណ៍

១៤៨. អង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋានទី១-១៩, ១១, ១២(i),១៣,១៥(i),១៦(ii) និង (iii) អាចទទួលយកបាន ដោយកំណត់ពីសំអាងហេតុខាងក្រោម។ ជាបឋម អង្គជំនុំជម្រះកត់សម្គាល់ថា សហមេធាវីផ្តល់ទឡ្ហីករណ៍ផ្សេងគ្នាចំនួនពីរក្នុងមូលដ្ឋានទី ១២ និងទី ១៥ ទោះបីជាមិនបានចែងដូច្នេះនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនក្តី។ ដើម្បីឲ្យមានភាពច្បាស់លាស់នៅផ្នែកខាងក្រោម អង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋានទី ១២ (i) ពាក់ព័ន្ធនឹងអត្ថិភាពនៃច្បាប់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ ជាទម្រង់នៃការទទួលខុសត្រូវមួយ ចំណែកមូលដ្ឋាន ១២(ii) ពាក់ព័ន្ធជុំវិញការអនុវត្ត និងទម្រង់[249]។ មូលដ្ឋានទី ១៥(i) ពាក់ព័ន្ធនឹងអត្ថិភាពនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំជាអំពើអមនុស្សធម៌ដទៃទៀត ក្នុងពេលវេលាពាក់ព័ន្ធនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចំណែកមូលដ្ឋានទី ១៥(ii) ដាក់បន្ទុកលើទម្រង់ ដែលរួមមានបញ្ហាលក្ខណៈ និងភាពធ្ងន់ធ្ងរនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការញែក

---

[247] *សូមមើលឧទាហរណ៍* សេចក្តីពិចារណាលើការសម្រេចឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*ក្នុងសំណុំរឿង ០០៤/១ (D239/1/8) កថាខណ្ឌ ១៧។ សេចក្តីពិចារណាលើការដាក់ឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* (D128/1/9) កថាខណ្ឌ ២០។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចចោទប្រកាន់ក្នុងសំណុំរឿង ០០៣ (D174/1/4) (មតិយោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK) កថាខណ្ឌ ១៩។

[248] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង សារី) (D427/1/30) កថាខណ្ឌ ៤៨។

[249] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៨០ (កថាខណ្ឌនេះគឺជាមូលដ្ឋានទី ១២(i) និងអាចទទួលយកបាន) កថាខណ្ឌ ១៨១ (កថាខណ្ឌគឺជាមូលដ្ឋានទី ១២ (ii) និងមិនអាចទទួលយកបានទេ)។

01634844



ដាច់ពីគ្នាជាមួយនឹងការរៀបអាពាហ៍ពិពាហ៍តាមរយៈការផ្សំផ្គុំ[250]។

មូលដ្ឋានទី១ ទទួលយកបាន

១៤៩. អង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋានទី១ អាចទទួលយកបាន អនុលោមតាមការបកស្រាយទូលំទូលាយនៃវិធាន៧៤(៣) ដោយពិចារណាវិធាន២១[251]។ ការចេញដីកាដំណោះស្រាយពីរគឺជាជាស្ថានភាពថ្មី ហើយប្លែកនៅចំពោះមុខ អ.វ.ត.ក។ អង្គជំនុំជម្រះយល់ឃើញថា ជាការចាំបាច់ក្នុងការទទួលយកការបក ស្រាយពង្រីកបន្ថែមលើវិធាន៧៤(៣) ដោយពិចារណាលើវិធាន២១ ដោយហេតុថា ការចេញដីកាដំណោះ ស្រាយចំនួនពីរពុំបានប្រមើលទុកនៅក្នុងវិធានផ្ទៃក្នុងឡើយ ហើយអាចតម្រូវឱ្យមានដំណោះស្រាយមួយ មុនពេលជំនុំជម្រះ ដើម្បីបង្ការផលប៉ះពាល់ដែលមិនអាចកែប្រែបានលើសិទ្ធិទទួលការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនជាប់ចោទ[252]។ ចំណុចនេះរួមមានការពិចារណាលើសមត្ថភាពរបស់ជនជាប់ចោទក្នុងការរៀបចំ និងកិច្ចនីតិវិធីជំនុំជម្រះក្តីដោយយុត្តិធម៌គ្រប់ជ្រុងជ្រោយ។

មូលដ្ឋាន ២-៧ អាចទទួលយកបាន

១៥០. ក្រោមវិធាន៧៤(៣)(ក) មូលដ្ឋានទី២ និង ទី៣ ជាការជំទាស់ទៅនឹងយុត្តាធិការបុគ្គលដែលអាចទទួលយកបាន។ អង្គបុរេជំនុំជម្រះយល់ឃើញថា វិសាលភាពនៃឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងការកំណត់យុត្តាធិការបុគ្គល (មូលដ្ឋានទី២) និងការបកស្រាយពាក្យ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" (មូលដ្ឋានទី៣) មានឥទ្ធិពលដោយផ្ទាល់លើសមត្ថភាពរបស់តុលាការក្នុងការអនុ

---

[250] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៩២ (កថាខណ្ឌនេះគឺជាមូលដ្ឋានទី ១៥(i) និងអាចទទួលយកបាន) កថាខណ្ឌ ១៩៣ (កថាខណ្ឌនេះគឺជាមូលដ្ឋានទី ១៥(ii) និងមិនអាចទទួលយកបានទេ)។

[251] *សូមមើលឧទាហរណ៍* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (D427/2/15 & D427/3/15) កថាខណ្ឌ ៧១។ សាលដីកាលើសហឧក្រិដ្ឋកម្មរួមក្នុងសំណុំរឿង ០០២ (D97/15/9) កថាខណ្ឌ ៣០។

[252] សំណុំរឿង ០០៤ សលដីកាលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ D361/4/1/10 កថាខណ្ឌ ១៩។ សេចក្តីពិចារណាលើការសម្រេចឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*ក្នុងសំណុំរឿង ០០៤/១ (D239/1/8) កថាខណ្ឌ ១៧, ២២-២៣។ សេចក្តីពិចារណាលើការដាក់ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* (D128/1/9) កថាខណ្ឌ ២០។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចចោទប្រកាន់ក្នុងសំណុំរឿង ០០៣ (D174/1/4) (មតិយោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK) កថាខណ្ឌ ១៩។ សំណុំរឿង ០០៤/២ (អ.ប.ជ ៤៤) សេចក្តីសម្រេចរបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យអនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D351/2/3 កថាខណ្ឌ ៨។

វត្តយុត្តាធិការ។ ហេតុដូចនេះ មូលដ្ឋានទី២ និង មូលដ្ឋានទី៣ គឺជាការជំទាស់យុត្តាធិការ[253]។

១៥១. អនុលោមតាមវិធាន៧៤(៣)(ក) អង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋានទី៤-៧ អាចទទួលយកបាន ជាការជំទាស់នឹងយុត្តាធិការបុគ្គល ដោយហេតុថា "ការអនុវត្តបទដ្ឋានភស្តុតាង" មិនសមស្រប ដែលបានចោទ (មូលដ្ឋានទី៤) "ឋានានុក្រមភស្តុតាង" (មូលដ្ឋានទី៥) តួនាទីរបស់ អោ អាន នៅក្នុង ប.ក.ក (មូលដ្ឋានទី ៦) និងភាពគ្រប់គ្រាន់នៃភាពធ្ងន់ធ្ងរពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់(មូលដ្ឋានទី៧) មានលក្ខណៈសំខាន់ក្នុងការកំណត់យុត្តាធិការបុគ្គល[254]។

មូលដ្ឋានទី៨-៩, ១១, ១២(i) ១៥(i) គឺអាចទទួលយកបាន

១៥២. អង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋានទី៨, ៩, ១១, ១២(i) និង១៥(i) អាចទទួលយកបាន អនុលោមតាមវិធាន៧៤(៣)(ក)។ អង្គបុរេជំនុំជម្រះកត់សម្គាល់ជាបឋមថា សហមេធាវីស្នើថា មូលដ្ឋានទី១២(i) (ការទទួលខុសត្រូវរបស់ថ្នាក់លើ មិនមែនជាទម្រង់នៃការទទួលខុសត្រូវដែលអនុវត្តនៅ អ.វ.ត.ក ឡើយ) គឺជាបញ្ហាមួយដែលដាក់បន្ទុកលើយុត្តាធិការបុគ្គល[255]។ ប៉ុន្តែ អង្គជំនុំជម្រះយល់ឃើញថា មូលដ្ឋានទី១២(១) មិនពាក់ព័ន្ធយុត្តាធិការបុគ្គលឡើយ ប៉ុន្តែពិនិត្យលើចំណុចនេះជាបញ្ហាដែលដាក់បន្ទុកលើយុត្តាធិការរឿងក្តី។

១៥៣. មូលដ្ឋានទី៨, ៩, ១១, ១២(i) និង ១៥(i) ជំទាស់នឹងអត្ថិភាពច្បាប់លើទម្រង់នៃការទទួលខុសត្រូវ និងបទល្មើសសារធាតុត្រង់ចំណុចពេលវេលាពាក់ព័ន្ធនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ អង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋានទី៨ ជំទាស់ជាទូទៅលើកំហុសរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលបានចោទ ក្នុងការសម្រេចថា អត្ថិភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលជាការរំលោភគោលការណ៍នីត្យានុកូលភាព[256]។ មូលដ្ឋានទី៩, ១១, និង ១២(i) ដាក់បន្ទុកលើយុត្តាធិការរបស់តុលាការលើសហឧក្រិដ្ឋកម្មរួមការរៀបចំផែនការ និងការទទួលខុសត្រូវរបស់ថ្នាក់លើជាទម្រង់នៃការទទួលខុសត្រូវ ហើយមូលដ្ឋាន១៥(i) ជំទាស់ទៅនឹងយុត្តាធិការរបស់តុលាការលើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំជាអំពើអមនុស្សធម៌

[253] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៣៩-៥៤។

[254] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៥៥-១៦៣។

[255] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៣។

[256] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៦៦-១៧០។

ផ្សេងទៀត[257]។ អង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋានទី៨ ៩ ១១ ១២(i) និង១៥(i) គឺជាការជំទាស់យុត្តាធិការដែលមានសុពលភាព ដោយហេតុថា មូលដ្ឋានទាំងនេះជំទាស់នឹងការអនុវត្តរបស់តុលាការជាមួយនឹងគោលការណ៍នីត្យានុកូលភាព ជាបុរេលក្ខខណ្ឌសម្រាប់បង្កើតយុត្តាធិការ អ.វ.ត.ក លើឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវនៅក្នុងច្បាប់បង្កើត អ.វ.ត.ក[258]។

មូលដ្ឋានទី១៣ អាចទទួលយកបាន

១៥៤. អង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋានទី១៣ ដែលផ្តល់ទឡ្ហីករណ៍បដិសេធបទចោទតាមច្បាប់ជាតិនៃមនុស្សឃាតគិតទុកជាមុន ដោយមូលហេតុផុតសុពលភាពនៃអាជ្ញាយុកាល[259]នោះ អាចទទួលយកបាន ដោយហេតុថា បញ្ហានេះស្ថិតក្រោមការជំទាស់លើយុត្តាធិការរឿងក្តីក្រោមវិធាន៧៤(៣)(ក)។ អង្គជំនុំជម្រះរម្លឹកថា "បញ្ហាលទ្ធភាពរបស់ អ.វ.ត.ក ក្នុងការកាត់សេចក្តីបទឧក្រិដ្ឋជាតិនានា ដែលមានអាជ្ញាយុកាល គឺជាបញ្ហាយុត្តាធិការ"[260]។ ហេតុដូចនេះ មូលដ្ឋានទី១៣ គឺជាមូលដ្ឋានបណ្តឹងឧទ្ធរណ៍ដែលទទួលយកបាននៅក្នុងដំណាក់កាលមុនជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធី។

មូលដ្ឋានទី១៦(ii) និង (iii) អាចទទួលយកបាន

១៥៥. អង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋានទី១៦(ii) និង (iii) អាចទទួលយកបានជាការជំទាស់យុត្តាធិការបុគ្គលអនុលោមតាមវិធាន៧៤(៣)(ក)។ មូលដ្ឋានទី១៦ (ii) ដែលចោទថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានបង្ហាញថា ជនជាតិចាមត្រូវបានកំណត់អត្តសញ្ញាណដោយវិជ្ជមាន និងកំណត់ជាគោលដៅ "ដូច្នេះ" គឺជាការដាក់បន្ទុកលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម[261]។ មូលដ្ឋានទី១៦ (iii) ដែលជំទាស់សហ

[257] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៧១-១៧៤, ១៧៨-១៨០, ១៩២។

[258] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង សារី) (D427/1/30) កថាខណ្ឌ ៦៩។

[259] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៨២-១៨៥។

[260] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង សារី) (D427/1/30) កថាខណ្ឌ ៧៤-៧៦ (សន្និដ្ឋានថា ការបញ្ជូនចុងចោទទៅជំនុំជម្រះចំពោះបទល្មើសថ្នាក់ជាតិបានបញ្ជាក់អំពីយុត្តាធិការរបស់ អ.វ.ត.ក ទៅលើបទល្មើសទាំងនោះ ហើយមូលដ្ឋានមួយនៃបណ្តឹងឧទ្ធរណ៍ដែលលើកឡើងពីបញ្ហាថាតើ អ.វ.ត.ក គួរចោទប្រកាន់បទល្មើសថ្នាក់ជាតិ ដែលស្ថិតក្រោមបញ្ញត្តិនៃអាជ្ញាយុកាល ឬយ៉ាងណា គឺជាបញ្ហាយុត្តាធិការដែលគួរយកមកដោះស្រាយនៅក្នុងដំណាក់កាលនេះ)។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (D427/2/15 & D427/3/15) កថាខណ្ឌ ៦៧។

[261] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៩៧-១៩៨។

ចៅក្រមស៊ើបអង្កេតលើការអនុវត្តធាតុផ្សំអត្តនោម័តចំពោះអំពើប្រល័យពូជសាសន៍លើជនជាប់ចោទ រួមទាំងចេតនាជាក់លាក់ក្នុងការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍ គឺជាការដាក់បន្ទុកលើការទទួលខុសត្រូវរបស់ អោ អាន ចំពោះឧក្រិដ្ឋកម្ម[262]។ ហេតុដូចនេះ អង្គជំនុំជម្រះយល់ឃើញថា មូលដ្ឋានទាំងនេះអាចទទួលយកបានជាការជំទាស់នឹងយុត្តាធិការបុគ្គលសមស្រប។

## ខ. មូលដ្ឋានបណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបាន

### មូលដ្ឋានទី១០ និង ១៧ មិនអាចទទួលយកបាន

១៥៦. អង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋានទី១០ និង ១៧ លើកឡើងអំពីវិការៈជាទម្រង់នៃដីកាសម្រេចចោទប្រកាន់។ ក្នុងមូលដ្ឋានទី១០ សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានស្នើសុំត្រឹមត្រូវ និងកំណត់ជាបញ្ហាអង្គហេតុ ពីវិសាលភាព និងទម្រង់នៃក្រុមសហឧក្រិដ្ឋកម្មរួមក្នុងនោះ រួមទាំងការពង្រីកវិសាលភាពភូមិសាស្ត្រសហឧក្រិដ្ឋកម្ម ឬដាក់បញ្ចូលគ្នាគោលបំណងរួមនានារបស់ក្រុមសហឧក្រិដ្ឋកម្មផ្សេងៗគ្នា[263]។ ក្នុងមូលដ្ឋាន១៧ សហមេធាវីលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានបញ្ចូលអំពើប្រល័យពូជសាសន៍នៅក្នុងគោលបំណងរួមរបស់ក្រុមសហឧក្រិដ្ឋកម្ម[264]។ អង្គបុរេជំនុំជម្រះយល់ឃើញថា កិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើតមូលដ្ឋានបណ្តឹងឧទ្ធរណ៍ទាំងនេះគឺជាការជំទាស់ដាក់បន្ទុកលើយុត្តាធិការបុគ្គលថាមិនអាចជឿបាន[265]។ អង្គបុរេជំនុំជម្រះយល់ឃើញថា វិការៈដែលរងការចោទប្រកាន់ មិនបានដាក់បន្ទុកដោយផ្ទាល់លើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទ ឬការទទួលខុសត្រូវរបស់ អោ អាន ឡើយ ហេតុដូចនេះ មិនអាចបង្កើតបានជាការជំទាស់យុត្តាធិការបុគ្គលបានឡើយ។ អង្គបុរេជំនុំជម្រះរម្លឹកថា ការជំទាស់ទៅនឹងវិការៈដែលបានចោទប្រកាន់ក្នុងទម្រង់នៃដីកាសម្រេចចោទប្រកាន់ គឺជាការច្បាស់ណាស់ថាមានលក្ខណៈមិនមែនយុត្តាធិការឡើយ[266]។ ចំណុច

---

[262] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៩៩-២០២។

[263] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៧៥-១៧៧។

[264] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ២០៣-២០៥។

[265] ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/10.1 និង ឯកសារ D360/19.1 ERN 01626145-01626148 ទំព័រ ១៨ បន្ទាត់ ២៤ ដល់ ទំព័រ ២១ បន្ទាត់ ១២។ បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៣។

[266] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង សារី) (D427/1/30) កថាខណ្ឌ ៤៧។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (D427/2/15 & D427/3/15) កថាខណ្ឌ ៦៣។

01634848



នេះមានលក្ខណៈជាក់ស្តែងនៅក្នុងការជំទាស់របស់សហមេធាវីទៅនឹងមូលដ្ឋានទី១០ (ភាពមិនច្បាស់លាស់នៃពាក្យ "កម្មាភិបាល ប.ក.ក ដទៃទៀត"[267] ឬ វិសាលភាពភូមិសាស្ត្រដែលចោទប្រកាន់មិនសមស្រប[268]) និង មូលដ្ឋានទី១៧ (ការខកខានមិនបានបញ្ចូលអំពើប្រល័យពូជសាសន៍នៅក្នុងការរៀបរាប់ពីគោលបំណងរួមរបស់សហឧក្រិដ្ឋកម្ម[269])។ ហេតុដូច្នេះ វិការៈបែបនេះក្នុងទម្រង់នៃដីកាសម្រេចចោទប្រកាន់ មិនអាចទទួលយកបាននៅក្នុងដំណាក់កាលមុនជំនុំជម្រះនៃកិច្ចនីតិវិធីឡើយ[270]។

### មូលដ្ឋាន១២(ii) ១៤ ១៥(ii) ១៦(i) មិនអាចទទួលយកបាន

១៥៧. អង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋានទី១២ (ii) ១៤ ១៥(ii) និង ១៦(i) មិនអាចទទួលយកបានទេ។ មូលដ្ឋានទាំងនេះជំទាស់នឹងទម្រង់បទល្មើស និងទម្រង់នៃការទទួលខុសត្រូវ និងការអនុវត្តជាក់ស្តែង មិនមែនអត្ថិភាពក្នុងច្បាប់នៅក្នុងចំណុចពេលវេលាពាក់ព័ន្ធទៅនឹងដីកាសម្រេចចោទប្រកាន់ឡើយ។

១៥៨. អង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋានទី១២ (ii) មិនអាចទទួលយកបាន ដោយហេតុថា មូលដ្ឋាននេះទាក់ទិននឹងទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ។ សហមេធាវីលើកឡើងថា សហចៅក្រមអន្តរជាតិ "អនុវត្តខុសធាតុផ្សំច្បាប់" នៃការទទួលខុសត្រូវរបស់ថ្នាក់លើ។ ចំណុចនេះគួរដោះស្រាយនៅពេលជំនុំជម្រះ[271]។ មូលដ្ឋានទី១៤ ១៥ (ii) និង ១៦ (i) ជំទាស់នឹងទម្រង់នៃធាតុផ្សំនៃបទល្មើសសារធាតុនៃអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមទាំងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ) និងអំពើប្រល័យពូជសាសន៍[272]។ អង្គបុរេជំនុំជម្រះយល់ឃើញថា ការប៉ុនប៉ងរបស់សហមេធាវីក្នុងការបង្កើតមូលដ្ឋានបណ្តឹងឧទ្ធរណ៍ទាំងនេះថាជាការជំទាស់យុត្តាធិការបុគ្គល មិនអាចជឿបានទេ[273]។

---

[267] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៧៥។

[268] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៧៦។

[269] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ២០៣។

[270] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង សារី) (D427/1/30) កថាខណ្ឌ ៤៧។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (D427/2/15 & D427/3/15) កថាខណ្ឌ ៦៣។

[271] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៨១។

[272] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង សារី) (D427/1/30) កថាខណ្ឌ ៤៦-៤៧។ បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៨៦-១៨៩, ១៩៣, ១៩៦។

[273] ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/10.1 និង ឯកសារ D360/19.1 ERN

១៥៩. ក្នុងមូលដ្ឋានទី១៤ សហមេធាវីជំទាស់នឹងការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតលើពិរុទ្ធភាពជាមូលដ្ឋានសម្រាប់អំពើអមនុស្សធម៌ផ្សេងៗទៀត និងការពឹងផ្អែករបស់ខ្លួនទៅលើច្បាប់សិទ្ធិមនុស្សក្នុងការកំណត់ថា ទង្វើនោះមានលក្ខណៈ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នា[274]។ លើសពីនេះទៀត សហមេធាវីចោទថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានបង្ហាញថា អោ អាន មានធាតុផ្សំអត្តនោម័តចាំបាច់សម្រាប់អំពើអមនុស្សធម៌ផ្សេងៗទៀត រួមទាំងការខកខានមិនបានបញ្ជាក់ច្បាស់លាស់អំពីធាតុផ្សំនៃទង្វើដែលស្មើនឹងអំពើអមនុស្សធម៌ផ្សេងៗទៀត និងការខកខានមិនបានរៀបរាប់ថាតើ អោ អាន មានបំណងធ្វើឱ្យឈឺចាប់ធ្ងន់ធ្ងរ ឬរបួសធ្ងន់ធ្ងរ តាមរយៈអំពើជាមូលដ្ឋាននៃការរំលោភផ្លូវភេទ[275]។ អង្គជំនុំជម្រះយល់ឃើញថា ទឡ្ហីករណ៍នេះតំណាងឱ្យបញ្ហាពិតប្រាកដ ដែលនឹងត្រូវបានផាត់ចេញពីយុត្តាធិការ គឺទម្រង់នៃធាតុផ្សំនៃបទល្មើស និងបញ្ហាអង្គហេតុដែលនឹងត្រូវដោះស្រាយនៅក្នុងដំណាក់កាលជំនុំជម្រះ។

១៦០. ក្នុងមូលដ្ឋានទី១៥ (ii) សហមេធាវីលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានបង្ហាញពីលក្ខណៈ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នានៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងដាក់បញ្ចូលគ្នារវាងអាពាហ៍ពិពាហ៍ដោយបង្ខំជាមួយនឹងការរំលោភផ្លូវភេទ ដើម្បីបង្កើនកម្រិតធ្ងន់ធ្ងរ[276]។ ចំណុចនេះបង្កើតបានជាការជំទាស់ទៅនឹងទម្រង់នៃធាតុផ្សំបទល្មើសនៃអំពើអមនុស្សធម៌ផ្សេងៗទៀត(លក្ខណៈ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នា) និងអត្ថិភាពរបស់វានៅក្នុងសភាពជាក់ស្តែងដែលជាការផ្ទុយទៅនឹងអត្ថិភាពតាមផ្លូវច្បាប់។

១៦១. ក្នុងមូលដ្ឋានទី១៦ (i) សហមេធាវីលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការបដិសេធធាតុផ្សំតាមបរិបទនៃអំពើប្រល័យពូជសាសន៍ រួមទាំងភាពចាំបាច់ក្នុងការបង្ហាញពីអត្ថិភាពនៃគោលនយោបាយឬផែនការរបស់រដ្ឋ[277] ឬទង្វើនោះបានកើតឡើងនៅក្នុងគំរូមួយជាក់ស្តែងនៃទង្វើ

01626146-01626147 ទំព័រ ១៩ បន្ទាត់ ១៥ ដល់ ទំព័រ ២០ បន្ទាត់ ២១។

[274] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៨៦-១៨៨។

[275] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៨៦-១៩១។

[276] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៩៣។

[277] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៩៦ *ដកស្រង់ពី* ដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៨៦ ("មិនមានលក្ខខណ្ឌតម្រូវថា អំពើដែលបានចោទប្រកាន់នោះត្រូវតែបានកើតឡើងនៅក្នុងបរិបទដែលបង្ហាញឱ្យឃើញច្បាស់អំពីលំនាំអំពើស្រដៀងគ្នាទេ។ ស្រដៀងគ្នានេះដែរ អត្ថិភាពនៃគោលនយោបាយ ឬផែនការរបស់រដ្ឋ (ឬគោលនយោបាយ ឬផែនការផ្សេងទៀត) ដើម្បីប្រព្រឹត្តអំពើប្រល័យពូជសាសន៍ គឺមិនមែនជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទេ")។

ប្រហាក់ប្រហែលគ្នា[278]។ អង្គបុរេជំនុំជម្រះយល់ឃើញថា ចំណុចទាំងនេះដាក់បន្ទុកលើទម្រង់នៃធាតុផ្សំបទល្មើស និងមិនបង្កើតបានជាការជំទាស់យុត្តាធិការដែលទទួលយកបានទេ។

## មូលដ្ឋានទី១៨ មិនអាចទទួលយកបាន

១៦២. សហមេធាវីស្នើថា ឥទ្ធិពលរួមគ្នានៃការរំលោភសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ធ្វើឱ្យប៉ះពាល់ដល់សុចរិតភាពនៃកិច្ចដំណើរការនីតិវិធីក្នុងរបៀបមួយដែលធ្ងន់ធ្ងរ និងមិនអាចជួសជុលបានក្នុងការមិនអាចធ្វើឱ្យមានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុស ឬរំលោភឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការខកខានមិនបានបដិសេធ ឬផ្អាកសំណុំរឿង ដើម្បីធានាភាពត្រឹមត្រូវ និងសុចរិតភាពនៃកិច្ចនីតិវិធី និងសិទ្ធិរបស់ អោ អាន[279]។ សហមេធាវីលើកទឡ្ហីករណ៍ថា វិធានបោះឆ្នោតរកសំឡេងភាគច្រើនលើសលប់ បានធ្វើឱ្យប៉ះពាល់ដល់សច្ចធានិរទោសរបស់ អោ អាន[280]។ លើសពីនេះទៀត កំហុស ការខកខានមិនបានអនុវត្ត និងការធ្វេសប្រហែស បានរំលោភសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ អោ អាន រួមទាំងសិទ្ធិមានមេធាវី[281] សិទ្ធិទទួលព័ត៌មានអំពីបទចោទ[282] សិទ្ធិរៀបចំខ្លួនការពារក្តីប្រកបដោយប្រសិទ្ធភាព[283] សិទ្ធិប្តឹងឧទ្ធរណ៍[284] និងរំលោភគោលការណ៍សមភាពនៃមធ្យោបាយតទល់ក្តី[285]។ លើសពីនេះទៀត សហមេធាវីលើកឡើងថា វិបត្តិថវិការបស់តុលាការធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ អោ អាន និងសុចរិតភាពរបស់តុលាការ[286]។ ដោយពិចារណាលើកំហុសបន្ថែមលើគ្នាទាំងនេះ សហមេធាវីស្នើថា មានឧបាស្រ័យសមស្របតែមួយគត់ គឺត្រូវផ្អាកកិច្ចដំណើរ

---

[278] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៩៦។

[279] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៣, ២០៧-២៣០។ សំណុំរឿង ០០៤/២ ឯកសារប្រតិចារិក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (ប្រតិចារិក) ឯកសារ D359/9.1 និង D360/18.1 ERN 01625313-01625315 ទំព័រ ៥៤ ជួរ ១៧ ដល់ ទំព័រ៥៦ ជួរ១៩។

[280] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៥, ២១០-២១២។សំណុំរឿង ០០៤/២ ឯកសារប្រតិចារិក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (ប្រតិចារិក) ឯកសារ D359/9.1 និង D360/18.1 ERN 01625313-01625315 ទំព័រ ៥៦ ជួរ ២០ ដល់ ទំព័រ៥៧ ជួរ១២។

[281] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៥, ២១៣-២១៤។

[282] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៥, ២១៣, ២១៥។

[283] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៥, ២១៣, ២១៦-២១៧។

[284] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៥, ២១៣, ២១៨។

[285] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៥, ២១៣, ២១៦-២១៧។

[286] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៥, ២១៩-២២២។

ការនីតិវិធិ ឬទម្លាក់ការចោទប្រកាន់ប្រឆាំងនឹង អោ អាន[287]។

១៦៣. ទីមួយ អង្គបុរេជំនុំជម្រះយល់ឃើញថា ការកំណត់ខុសរបស់សហមេធាវីទៅលើវិធានបោះឆ្នោតមតិភាគច្រើនលើសលប់របស់អង្គជំនុំជម្រះ ថាជា"ការបំពានសច្ចធានិរទោស"នោះ គឺជាការអនុវត្តគោលការណ៍នោះខុស និងយល់ខុសលើក្របខណ្ឌច្បាប់ អ.វ.ត.ក[288]។ អង្គជំនុំជម្រះរម្លឹកអំពីលក្ខណៈអនាគតិនៃអាណត្តិរបស់សហចៅក្រមស៊ើបអង្កេត និងគោលបំណងនៃកិច្ចស៊ើបសួរ។ អនុលោមតាមវិធាន ៥៥(៥) សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចដឹកនាំកិច្ចស៊ើបសួរដោយអនាគតិ"ទោះបីជាភស្តុតាងដែលនឹងរកបាននោះជាភស្តុតាងដាក់បន្ទុក ឬភស្តុតាងដោះបន្ទុកក៏ដោយ ដើម្បីបង្ហាញការពិត"[289]។ អង្គជំនុំជម្រះសង្កត់ធ្ងន់ថា កិច្ចនីតិវិធីនេះស្ថិតក្នុងដំណាក់កាលមុនជំនុំជម្រះ ដែលមិនពាក់ព័ន្ធនឹងការកំណត់ថា មានពិរុទ្ធភាព ឬគ្មានពិរិទ្ធភាពនោះទេ[290]។ អង្គបុរេជំនុំជម្រះយល់ឃើញថា សច្ចធានិរទោសត្រូវបានការពារគ្រប់គ្រាន់ ដោយហេតុថា អនុលោមតាមវិធាន ៩៨(៤) ការសម្រេចផ្តន្ទាទោសនៅក្នុងដំណាក់កាលជំនុំជម្រះក្តីទាមទារឱ្យមានសំឡេងគាំទ្រយ៉ាងហោចណាស់ពីចៅក្រមបួនសម្លេង និងនៅពេលរកសម្លេងភាគច្រើនតាមតម្រូវការមិនបានទេ "មានន័យថា ជនជាប់ចោទត្រូវរួចផុតពីបទចោទ"[291]។

១៦៤. ទីពីរ អង្គបុរេជំនុំជម្រះរម្លឹកថា នៅពេលដែលការរំលោភសិទ្ធិដែលបានលើកឡើងត្រូវបានជំទាស់ និងកន្លងមកត្រូវបានបដិសេធ បញ្ហានេះត្រូវចាត់ទុកជាអាសារឥតបានការ។ នៅទីនេះ សហមេធាវីលើកឡើងពីបញ្ហាការជំនុំជម្រះក្តីដោយយុត្តិធម៌ត្រូវបានជំទាស់រួចហើយ ហើយនៅក្នុងចំណុចរបត់នេះ ខកខានមិនបានផ្តល់មូលដ្ឋានគ្រប់គ្រាន់សម្រាប់ពិចារណាឡើងវិញឡើយ។ ជាពិសេស ការចោទអំពីការរំលោភទាំងឡាយត្រូវបានអះអាងជាថ្មី ក្នុងនោះរួមទាំង គោលការណ៍សមភាពនៃមធ្យោបាយតទល់ក្តី សិទ្ធិរបស់ អោ អាន ក្នុងការទទួលព័ត៌មានអំពីបទចោទ សិទ្ធិរៀបចំការការពារក្តីប្រកបដោយប្រសិទ្ធភាព និង សិទ្ធិ

[287] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ២២៨-២២៩។ សំណុំរឿង ០០៤/២ ឯកសារប្រតិចារិក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (ប្រតិចារិក) ឯកសារ D359/9.1 និង D360/18.1 ERN 01625316-01625318 ទំព័រ ៥៧ ជួរ ២០ ដល់ ទំព័រ៥៨ ជួរ១៤។

[288] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ២១២។

[289] វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង។

[290] សេចក្តីពិចារណាលើការសម្រេចឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*ក្នុងសំណុំរឿង ០០៤/១ (D239/1/8) មតិយោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BWANA កថាខណ្ឌ ១៣។

[291] វិធាន ៩៨(៤) នៃវិធានផ្ទៃក្នុង។

ប្តឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងសិទ្ធិចូលពិនិត្យសំណុំរឿង[292] និងបញ្ហាពាក់ព័ន្ធនឹងកំណត់ហេតុស្តាប់ចម្លើយមិនមែនសោតទស្សន៍[293] ការធ្វេសប្រហែសរបស់អ្នកស៊ើបអង្កេត[294] និងសេចក្តីសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតលើសំណើសុំបំពេញកិច្ចស៊ើបសួរ[295] គឺថា ចំណុចទាំងអស់នេះត្រូវបានតតាំងគ្នាពីមុនរួចមកហើយ ហើយត្រូវបានបដិសេធដោយអង្គបុរេជំនុំជម្រះ ដោយហេតុថា ពុំមានការបង្ហាញអំពីព្យសនកម្មឡើយ។ ហេតុដូចនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ឥឡូវនេះ ពុំចាំបាច់មានអន្តរាគមន៍ដើម្បីបញ្ចៀសព្យសនកម្មដែលមិនអាចកែបានចំពោះសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ឡើយ។

១៦៥. ទីបី អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ការចេញដីកាដំណោះស្រាយចំនួនពីររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត អាចបង្កើតជាភាពមិនច្បាស់លាស់ជុំវិញបទចោទទាំងនោះ។ អង្គជំនុំជម្រះយល់ឃើញថា បញ្ហាជាក់លាក់នេះ ដែលពាក់ព័ន្ធនឹងការចេញដីកាដំណោះស្រាយចំនួនពីរដំណាលគ្នា ត្រូវបានទទួលយក ក្នុងមូលដ្ឋានទី១ អនុលោមតាមវិធាន៧៤(៣) ដោយពិចារណាលើវិធាន ២១។ ពុំអនុញ្ញាតឲ្យមានការពិភាក្សាបន្ថែមនៅទីនេះទេ។

១៦៦. ទីបួន ទាក់ទិននឹងទឡ្ហីករណ៍របស់សហមេធាវីពាក់ព័ន្ធនឹង "ការពន្យារពេលចំនួនបួនខែកន្លះ" នៅក្នុងការចាត់តាំងលោក Richard ROGERS ជាសហមេធាវីអន្តរជាតិសម្រាប់ អោ អាន[296] អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ជនជាប់ចោទត្រូវបានតំណាងគ្រប់ពេលទាំងអស់ដោយមេធាវីកម្ពុជាតាមការជ្រើសរើសរបស់គាត់ គឺ លោក មុំ លុច្ឆ និងយល់ឃើញថា ជនជាប់ចោទខកខានមិនបានបង្ហាញព្យសនកម្មមិន

---

[292] ការពិចារណាលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងការសុំចូលមើលឯកសារសំណុំរឿងក្នុងសំណុំរឿង ០០៤ (D121/4/1/4)។

[293] សំណុំរឿង ០០៤/២ (អង្គបុរេជំនុំជម្រះ ៣១) សាលដីកាលើសំណើរបស់ អោ អាន សុំធ្វើមោឃភាពកំណត់ហេតុនៃការស្តាប់ចម្លើយដែលមិនមានខ្សែអាត់សំឡេង ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ D296/1/1/4។

[294] សំណុំរឿង ០០៤/២ (អង្គបុរេជំនុំជម្រះ ៣៧) សាលដីកាលើសំណើរបស់ អោ អាន សុំធ្វើមោឃភាពលើកំណត់ហេតុស្តាប់ចម្លើយដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតបីរូប ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ ឯកសារ D338/1/5 (សាលដីកាមោឃភាពកំណត់ហេតុស្តាប់ចម្លើយ D338/1/5 )។

[295] សំណុំរឿង ០០៤ (អង្គបុរេជំនុំជម្រះ អ.ប.ជ ២៤) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើកទីប្រាំរបស់ អោ អាន សុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ D260/1/1/3។ សំណុំរឿង ០០៤ (អង្គបុរេជំនុំជម្រះ ០៧) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ D190/1/2 (សាលដីកាលើបណ្តឹងឧទ្ធរណ៍អោ អាន ប្រឆាំងនឹងការបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ D190/1/2)។ ការពិចារណាលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងការសុំចូលមើលឯកសារសំណុំរឿងក្នុងសំណុំរឿង ០០៤ (D121/4/1/4)។

[296] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ២១៤។

អាចកែបានណាមួយចំពោះសិទ្ធិមានមេធាវីរបស់គាត់ឡើយ។

១៦៧. ពាក់ព័ន្ធនឹងការចោទប្រកាន់របស់សហមេធាវីពីភាពមិនច្បាស់លាស់ផ្នែកហិរញ្ញវត្ថុរបស់តុលាការ [297] អង្គបុរេជំនុំជម្រះសង្កេតឃើញថា សហមេធាវីខកខានមិនបានបង្ហាញគ្រប់គ្រាន់ថា ការជំនុំជម្រះក្តីដោយយុត្តិធម៌តាមច្បាប់មិនទំនងជាទទួលបានឡើយ ដោយហេតុថាពុំមានថវិកាគ្រប់គ្រាន់នៅក្នុងដំណាក់កាលកិច្ចដំណើរការនីតិវិធីនេះ។ ហេតុដូចនេះ អង្គជំនុំជម្រះយល់ឃើញថា សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានភាពត្រឹមត្រូវផ្នែកនីតិវិធិនៅក្នុងដំណាក់កាលបច្ចុប្បន្ននេះមិនមានហានិភ័យទទួលការបំពានដោយមិនអាចកែបាននោះឡើយ។

១៦៨. ចំណុចចុងក្រោយ ដោយគ្មានការបង្ហាញការរំលោភសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ អង្គបុរេជំនុំជម្រះយល់ឃើញថា ទឡ្ហីករណ៍របស់សហមេធាវីពាក់ព័ន្ធនឹងឥទ្ធិពលបន្ថែមលើគ្នាទៅលើការរំលោភសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងសំណើរបស់សហមេធាវីសុំផ្អាកកិច្ចនីតិវិធីអចិន្ត្រៃយ៍ ឬទម្លាក់ការចោទប្រកាន់ថាជាឧបាស្រ័យមួយ ពុំមានភាពត្រឹមត្រូវទេ។ អង្គបុរេជំនុំជម្រះបដិសេធមិនទទួលយកមូលដ្ឋានទី១៨ ឡើយ។

## VI. ការពិចារណាលើអង្គសេចក្តី

១៦៩. ទោះបីជាសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះស្តីពីភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ត្រូវបានលើកឡើងនៅក្នុងកថាខណ្ឌខាងលើក្តី បន្ទាប់ពីប្រជុំពិភាក្សារួចហើយ អង្គជំនុំជម្រះមិនអាចទទួលបានសម្លេងភាគច្រើនលើសលប់នៃសម្លេងគាំទ្រចំនួនបួនតាមការកំណត់ ដើម្បីឈានទៅសេចក្តីសម្រេចផ្អែកលើសំអាងហេតុរួមលើអង្គសេចក្តីឡើយ។ អនុលោមតាមវិធាន ៧៧(៤) នៃវិធានផ្ទៃក្នុង មតិរបស់សមាជិកផ្សេងៗគ្នានៃអង្គបុរេជំនុំជម្រះត្រូវបានភ្ជាប់មកជាមួយសាលដីកានេះ។

---

[297] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ២១៩-២២២។ សំណុំរឿង ០០៤/២ ឯកសារប្រតិចារិក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (ប្រតិចារិក) ឯកសារ D359/9.1 និង D360/18.1 ERN 01625315 ទំព័រ ៥៦ ជួរទី៥ ដល់ទំព័រ៥៦ ជួរទី១៦។

## VII. សេចក្តីសម្រេច

### អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទ៖

- **បង្គាប់** ឱ្យដាក់បញ្ចូលគ្នានៃបណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងដីកាដំណោះស្រាយទាំងពីរ។

- **សម្រេច** ថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិអាចទទួលយកបាន។

- **សម្រេច** ថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ អាចទទួលយកបាន។

- **សម្រេច** ចំពោះបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អោ អាន នៅមូលដ្ឋានទី១ ដល់ទី ៩ ទី១១ ទី១២(i) ទី១៣ ទី១៥(i) ទី១៦(ii) ទី១៦(iii) ថាអាចទទួលយកបាន។

- **សម្រេច** ថា មូលដ្ឋានផ្សេងទៀតនៃបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អោ អាន មិន អាចទទួលយកបាន។

- **ប្រកាស** ថា អង្គបុរេជំនុំជម្រះអាចប្រើប្រាស់សិទ្ធិអំណាចក្នុងការត្រួតពិនិត្យលើបញ្ហាស៊ើប អង្កេត។

- **ប្រកាស** ថា ដោយផ្អែកលើយុត្តាធិការរបស់ អ.វ.ត.ក តុលាការសាមញ្ញរបស់កម្ពុជាមាន យុត្តាធិការពេញលេញទៅលើបញ្ហានៃយុត្តិធម៌ផ្នែកព្រហ្មទណ្ឌ។

- **ប្រកាស** ថា ការពន្យារពេលក្នុងការចេញដីកាដំណោះស្រាយ បន្ទាប់ពីបញ្ចប់ការស៊ើបអង្កេត ទៅលើ អោ អាន គឺជាការមិនត្រឹមត្រូវ។

- **ប្រកាស** ថា សហចៅក្រមស៊ើបអង្កេតមានកំហុសក្នុងការវាយតម្លៃទៅលើតម្លៃជាភស្តុតាង និងភាពអាចជឿជាក់បាននៃភស្តុតាង។

- **ប្រកាស** ថា ការចេញដីកាដំណោះស្រាយពីរ ដែលផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺ ខុសច្បាប់ ហើយរំលោភបំពានទៅលើក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក។

- **ប្រកាស** ថា អង្គបុរេជំនុំជម្រះមិនអាចទទួលបានសម្លេងគាំទ្រ យ៉ាងតិចបួនសម្លេង សម្រាប់ ចេញសាលដីកា ផ្អែកលើសំអាងហេតុរួមគ្នា លើអង្គសេចក្តីបានឡើយ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវតវ៉ា។

អនុលោមតាមវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ ត្រូវជូនដំណឹងទៅសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងភាគីនានា អំពីសាលដីកានេះ។

**រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០១៩**

**អង្គបុរេជំនុំជម្រះ**

ប្រាក់ គឹមសាន | Olivier BEAUVALLET | ន័យ ថុល | Kang Jin BAIK | ហួត វុទ្ធី

ចៅក្រមប្រាក់ គឹមសាន ចៅក្រមន័យ ថុល និងចៅក្រមហួត វុទ្ធី សូមលើកឡើងនូវមតិយោបល់របស់ខ្លួន ទាក់ទិននឹងអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍។ ចៅក្រម Olivier BEAUVALLET និងចៅក្រម Kang Jin BAIK សូមលើកឡើងនូវមតិយោបល់របស់ខ្លួន ទាក់ទិននឹងអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍។

## VIII.យោបល់លោកចៅក្រមប្រធាន គីមសាន លោកចៅក្រមន័យ ថុល និង លោកចៅក្រម ហួត វុទ្ធី

១៧០. បន្ទាប់ពីសំណុំរឿង០០១ និង០០២ ការដោះស្រាយបណ្ដឹងនានាទាក់ទងនឹងសំណុំរឿង០០៣ និង ០០៤ សហព្រះរាជអាជ្ញា និងសហចៅក្រមត្រូវតែស្វែងយល់ឱ្យបានច្បាស់អំពីបញ្ហាប្រឈមនានា ដែលជាឧបសគ្គរារាំងក្នុងបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រកបទៅដោយភាពឥតខ្ចោះតាមផ្លូវច្បាប់។ ទាំងកិច្ចព្រមព្រៀង ទាំងច្បាប់ស្ដីពីការបង្កើតអ.វ.ត.ក ទាំងវិធានផ្ទៃក្នុង ជាពិសេសសេចក្ដីប្រកាសព័ត៌មានផ្សេងៗ បង្កើត បានជាភស្ដុតាងប្រត្យក្សដែលសហព្រះរាជអាជ្ញា និងសហចៅក្រមគប្បីទទួលយក ហើយអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការពិចារណា និងចេញសេចក្ដីសម្រេចប្រកបដោយតក្កភាព ។ ការបំភ្លេចចោលភស្ដុតាងទាំងនោះ ហើយចេញសេចក្ដីសម្រេច គឺពិតជាប្រាសចាកនូវសច្ចភាពដែល អ.វ.ត.ក ពុំអាចឈានដល់ការបិទសំណុំរឿងក្ដីតាមនិតិវិធីច្បាប់បានឡើយ ។

១៧១. តើមានបញ្ហាអ្វីខ្លះដែលមានកើតឡើងចំពោះសំណុំរឿង០០៣ និង ០០៤ ។ សំណុំរឿង០០៣ និង ០០៤ ចាប់ផ្ដើមចេញដំណើរ ខុសប្លែកពីសំណុំរឿង០០១ និង០០២ ពោលគឺសហព្រះរាជអាជ្ញាអន្តរជាតិជ្រើសរើសយកជនមួយចំនួនមកធ្វើការស៊ើបអង្កេតបឋមជាឯកតោភាគី បិទបាំងពុំជូនដំណឹងដល់សហព្រះរាជអាជ្ញាជាតិឡើយ ។ តើការអនុវត្តនីតិវិធីបែបនេះរបស់សហព្រះរាជអាជ្ញាអន្តរជាតិសមស្របតាមកិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក ដែលឬទេ? ហើយមកដល់ដំណាក់កាលចៅក្រមស៊ើបអង្កេត បន្ទាប់ពីបញ្ចប់កិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតទាំងពីរ បានសម្រេចចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា ដែលជាករណីមិនធ្លាប់មាន។ ដីកាដំណោះស្រាយទាំងពីរនេះក្លាយទៅជាកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍ចំនួនបី។

១៧២. ចៅក្រមជាតិនៃ អង្គបុរេជំនុំជម្រះ យល់ថាដើម្បីអាចឆ្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍ទាំងនោះបាន គឺយើងត្រូវស្វែងយល់អំពីប្រវត្តិនៃការនាំយកខ្មែរក្រហមមកកាត់ទោស តាមរយៈកិច្ចចរចាបង្កើតកិច្ចព្រមព្រៀងរវាងកម្ពុជា និងអង្គការសហប្រជាជាតិ ច្បាប់ស្ដីពីការបង្កើតអ.វ.ត.ក វិធានផ្ទៃក្នុង បុព្វកថា និងសេចក្ដីប្រកាសព័ត៌មានផ្សេងៗ។

### ក. ប្រវត្តិនៃសំណុំរឿង០០៤

១៧៣. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតជាតិ បានចេញដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន ជាភាសាខ្មែរ[298] ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ (សចសអ) បានចេញ

[298] ដីកាដំណោះស្រាយ (លើកលែងចោទ) ឯកសារលេខ D359។

ដីកាដំណោះស្រាយ សម្រេចចោទប្រកាន់ អោ អាន និងបញ្ជូនសំណុំរឿងនេះទៅជំនុំជម្រះ ជាភាសាអង់គ្លេស[299]។

១៧៤. នៅថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១៨ អង្គបុរេជំនុំជម្រះ (អង្គបុរេជំនុំជម្រះ) បានទទួលបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងដីកាដំណោះស្រាយរបស់ សចសអ ក្នុងសំណុំរឿង ០០៤/២ ជាភាសាខ្មែរ[300] និងជាភាសាអង់គ្លេស នៅថ្ងៃទី ២៨ ខែមករា ឆ្នាំ២០១៩។

១៧៥. នៅថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១៨ អង្គបុរេជំនុំជម្រះ បានទទួលបណ្តឹងឧទ្ធរណ៍របស់ អោ អាន លើដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ជាភាសាអង់គ្លេស[301] និងជាភាសាខ្មែរ នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩។

១៧៦. នៅថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១៨ អង្គបុរេជំនុំជម្រះ បានទទួលបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (D359) ជាភាសាអង់គ្លេស[302] និងជាភាសាខ្មែរ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩។

១៧៧. ក្រោយពីមានបណ្តឹងឧទ្ធរណ៍ផ្សេងៗ ប្រឆាំងនឹងដីកាដំណោះស្រាយគ្រប់រឿងក្តីទាំងអស់ពិសេសរឿងក្តីបច្ចុប្បន្ន ដែលមានដីកាដំណោះស្រាយដល់ទៅពីរហើយមានខ្លឹមសារផ្ទុយគ្នា អង្គបុរេជំនុំជម្រះ គប្បីធ្វើការវិភាគឲ្យបានស៊ីជម្រៅ និងស្រាវជ្រាវរាល់ឯកសារពាក់ព័ន្ធ ដើម្បីឈានទៅអនុវត្តនីតិវិធីជាបន្តទៅទៀត ថាតើគប្បីទទួលស្គាល់ ឬបដិសេធ ដីកាដំណោះស្រាយណាមួយ។

១៧៨. រឿងក្តីដែលទាក់ទងនឹងសំណុំរឿង០០៣ និង ០០៤ មានលក្ខណៈខុសប្លែកពីរឿងក្តីក្នុងសំណុំរឿង ០០១ និង ០០២ ។ ក្នុងរឿងក្តីសំណុំរឿង០០១ និង ០០២ សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ បានប្រជុំឯកភាពគ្នាសម្រេចនាំយកជនសង្ស័យដែលជាមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតផ្តើមធ្វើការស៊ើបអង្កេតបឋម និងបង្កើតជាដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទៅសហចៅក្រមស៊ើបអង្កេតដើម្បីធ្វើការស៊ើបអង្កេត ។

---

[299] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារលេខ D360។

[300] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ឯកសារលេខ D360/8/1។

[301] បណ្តឹងឧទ្ធរណ៍របស់អោ អាន ឯកសារលេខ D360/5/1។

[302] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ D359/3/1។

01634858



១៧៩. ដោយឡែក ដំណើរនៃសំណុំរឿង០០៣ និង ០០៤នេះ គឺចាប់ផ្តើមចេញពីការបិទបាំងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលបានធ្វើការស៊ើបអង្កេតបឋមជាឯកតោភាគី ដោយពុំបានជូនដំណឹងដល់សហព្រះរាជអាជ្ញាជាតិឡើយ។ សកម្មភាពរបស់សហព្រះរាជអាជ្ញាអន្តរជាតិនេះ ខុសនឹងគោលការណ៍ << សហ >> ។ នៅពេលឈានដល់ការសម្រេចចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី២០០៣/២០/-១១-២០០៨ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី៣០០៤/២០/-១១-២០០៨ ក៏កើតមានការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាទាំងពីរ ដែលត្រូវដោះស្រាយតាមវិធាន៧១ នៃវិធានផ្ទៃក្នុង ។

១៨០. ការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាទាំងពីរផ្តោតសំខាន់ទៅលើយុត្តាធិការបុគ្គល គឺជនសង្ស័យដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី២ និងទី៣ តើជាមេដឹកនាំជាន់ខ្ពស់ និងជាអ្នកទទួលខុសត្រូវខ្ពស់បំផុតដែលត្រូវនាំយកមកកាត់ទោសតាមកិច្ចព្រមព្រៀងរវាងកម្ពុជា និង អង្គការសហប្រជាជាតិ និងច្បាប់ស្តីពី អ.វ.ត.ក. ឬទេ។[303]

១៨១. ការខ្វែងយោបល់របស់សហព្រះរាជអាជ្ញាជាតិ ជាមួយនឹងសហព្រះរាជអាជ្ញាអន្តរជាតិ នេះឃើញថា មិនបានធ្វើឱ្យការស៊ើបអង្កេតត្រូវបានអាក់ខានទេ ដោយហេតុថាតាមវិធាន៧៧.១៣ នៃវិធានផ្ទៃក្នុង ប្រសិនបើរកមិនបានសម្លេងគាំទ្រភាគច្រើនដាច់ខាតទេ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះត្រូវតែបន្តអត្ថិភាព។ ហេតុដូច្នេះហើយ សំណុំរឿង០០៣ និង ០០៤ ត្រូវបានបន្តការស៊ើបអង្កេត ដោយពឹងផ្អែកទៅលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលមានតែសហព្រះរាជអាជ្ញាអន្តរជាតិម្នាក់គត់ ធ្វើការស៊ើបអង្កេតបឋមជាសម្ងាត់។

១៨២. បញ្ហាចម្រូងចម្រាស នៃសំណុំរឿងនេះបន្តមានជាហូរហែររហូតដល់ពេលដែលសហចៅក្រមស៊ើបអង្កេតទាំងជាតិ និងអន្តរជាតិបានសម្រេចបញ្ចប់កិច្ចស៊ើបសួរ និងចេញដីកាដំណោះស្រាយ។ អង្គស៊ើបអង្កេតបានសម្រេចចេញដីកាដំណោះស្រាយពីរដាច់ចេញពីគ្នា ហើយមិនតែប៉ុណ្ណោះដីកាទាំងពីរនោះមានអត្ថន័យផ្ទុយគ្នាទៅទៀត ដែលស្ថានការណ៍បែបនេះជាស្ថានការណ៍ថ្មីមិនដែលមានក្នុងប្រវត្តិសាស្ត្រតុលាការទេ។ នៅពេលនេះបណ្តឹងឧទ្ធរណ៍ចំនួន ៣ ត្រូវបានដាក់ប្រឆាំងនឹងដីកាដំណោះស្រាយទាំង២ បានមកដល់ អង្គបុរេជំនុំជម្រះ ដូច្នេះដើម្បីឱ្យ អង្គបុរេជំនុំជម្រះ ធ្វើការសម្រេចលើបណ្តឹងឧទ្ធរណ៍ទាំងនេះបាន

---

[303] ឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នាស្របតាមវិធាន៧១.២ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ និង ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៨។

ចៅក្រមជាតិនៃ អង្គបុរេជំនុំជម្រះ យល់ថាវាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការរម្លឹកឡើងវិញ តាំងពីជំហ៊ានដំបូង នៃការកកើត អ.វ.ត.ក និងអ្វីទៅដែលជាគោលបំណងពិតប្រាកដនៃការបង្កើត អ.វ.ត.ក។

## ខ. បុព្វកថា

### ១. ក្នុងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា

១៨៣. ដោយហេតុថា នៅក្នុងសេចក្តីសម្រេចចិត្តលេខ៥៧/២២៨ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ មហាសន្និបាតបានទទួលស្គាល់ការព្រួយបារម្ភពេញច្បាប់របស់រដ្ឋាភិបាលកម្ពុជានិងប្រជាជនកម្ពុជាក្នុងការស្វែងរយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថេរភាព សន្តិភាព និងសន្តិសុខ។[304]

១៨៤. ដូច្នេះឃើញថាគោលបំណងនៃការបង្កើតអ.វ.ត.ក មិនមែនមានត្រឹមតែស្វែងរកយុត្តិធម៌នោះទេ ប៉ុន្តែវាមានបញ្ចូលនូវការបង្រួបបង្រួមជាតិ ស្ថេរភាព សន្តិភាព និងសន្តិសុខផងដែរ។

### ២. វិធានផ្ទៃក្នុង

១៨៥. ដូចគ្នាដែរ បុព្វកថា នៃវិធានផ្ទៃក្នុង មានលក្ខណៈដូចគ្នាបេះបិតទៅនឹងបុព្វកថានៃកិច្ចព្រមព្រៀងខាងលើ។

## គ. ប្រវត្តិនៃការនាំយកខ្មែរក្រហមមកកាត់ទោស

១៨៦. ប្រវត្តិសាស្ត្រកម្ពុជាចាប់តាំងពីការដួលរលំ នៃរបបខ្មែរក្រហមមានសភាពស្មុគស្មាញណាស់។ ជាការលំបាកណាស់ក្នុងការស្វែងយល់ អំពីដំណើរការដ៏តឹងតែងក្នុងដំណើរឆ្ពោះទៅកាន់ការទទួលខុសត្រូវប្រសិនបើ គ្មានការស្វែងយល់ឲ្យបានច្បាស់លាស់អំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ដែលគ្របដណ្តប់ដំណើរការនេះ។ ក្រោយថ្ងៃដួលរលំនៃរបបកម្ពុជាប្រជាធិប្បតេយ្យនៅខែ មេសា ឆ្នាំ ១៩៧៩ ប្រទេសកម្ពុជាត្រូវប្រឈមមុខបញ្ហា សំខាន់ៗដែលត្រូវដោះស្រាយដោយខានពុំបាន។ បញ្ហាប្រឈមចម្បងៗគឺការផ្សះផ្សាជាតិ និងការស្វែងរកសន្តិភាពយូរអង្វែង និងការនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោស[305]។

១៨៧. ក្នុងនោះ ការនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោសដែលឈានដល់ការបង្កើតអង្គជំនុំជម្រះមួយប្រកបទៅដោយស្តង់ដារ អន្តរជាតិ ប៉ុន្តែ ត្រូវរក្សាបាននូវ យុត្តិធម៌ សន្តិភាព ការផ្សះផ្សាជាតិ របស់ជនរង

[304] *ការកាត់ទោសខ្មែរក្រហម* សេចក្តីសម្រេចចិត្តលេខ ៥៧/២២៨ ចុះថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០០៣,UN Doc.A/RES/57/228។

[305] ស្វែងរកការពិត-វេទិកាពិភាក្សាសាធារណៈ លេខ៨៣ ខែវិច្ឆិកា ឆ្នាំ២០០៦ ទំព័រ៤៧។

គ្រោះ ក្រោមអំពើទារុណកម្មនៃរបបខ្មែរក្រហម ដែលមានចែងក្នុង បុព្វកថា ក្នុងកិច្ចព្រមព្រៀង និង ក្នុង វិធានផ្ទៃក្នុង។

១៨៨. បញ្ហាទាំងពីរខាងលើ ទាមទារឲ្យមាន សកម្មភាពការទូត ដ៏មមាញឹក បើកការប្រជុំចរចាដ៏ច្រើន សន្ធឹកសន្ធាប់ ការធ្វើសម្បទានដោយប្រុងប្រយ័ត្ន របស់គណៈប្រតិភូគ្រប់ភាគី អន្តរាគមន៍ របស់អង្គការ សហប្រជាជាតិ របស់សហគមន៍អន្តរជាតិ និង មហាអំណាចដែលជាប់ពាក់ព័ន្ធនឹងជម្លោះនៅកម្ពុជា បង្កើត បានជា សេណារីយោ ដ៏ច្រើនសន្ធឹកសន្ធាប់ មិនគប្បីមើលរំលង ហើយដែលត្រូវលើកមកពិចារណា។

១៨៩. ប្រាំបីខែបន្ទាប់ពីការដួលរលំរបប ប៉ុល ពត ក្រសួងយុត្តិធម៌កម្ពុជាបានរៀបចំកាត់ទោស ប៉ុល ពត និង អៀង សារី ប៉ុន្តែត្រូវបានបដិសេធដោយសហគមន៍អន្តរជាតិ[306]។

### ១. សង្គ្រាមត្រជាក់

១. សង្គ្រាមត្រជាក់លើកទី១៖ ចិន សហរដ្ឋអាមេរិក រួមគ្នាប្រឆាំង សហភាពសូវៀត និងសម្ព័ន្ធមិត្តវៀតណាម និង ឡាវ (1979)។

២. សង្គ្រាមត្រជាក់លើកទី២៖ វៀតណាម គាំទ្រដោយសហភាពសូវៀត ប្រឆាំង ចិន និង អាមេរិក និងថៃ។

៣. នៅឆ្នាំ១៩៨២ អន្តរជាតិបានបោះឆ្នោតផ្តល់អាសនៈកម្ពុជាឲ្យរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិប្បតេយ្យ (ខ្មែរក្រហម និង សឺន សាន និង សីហនុ)។

១៩០. នៅឆ្នាំ ១៩៨៩ សង្គ្រាមត្រជាក់បានឈានមកដល់ទីបញ្ចប់ នៅពេលជំនួយសេដ្ឋកិច្ច សូវៀតបានធ្លាក់ចុះយ៉ាងខ្លាំង។ អង្គការសហប្រជាជាតិ និងប្រទេសមហាអំណាចសំខាន់ៗ មួយចំនួននៅមានកិច្ចការសំខាន់ដែលត្រូវធ្វើជាជាងការកាត់ទោសខ្មែរក្រហម។ សហគមន៍អន្តរជាតិ ជាថ្មីម្តងទៀតយល់ឃើញថាការជួយជ្រោមជ្រែងរបស់ខ្លួន គឺមានសារៈសំខាន់ណាស់ សម្រាប់សន្តិភាពយូរអង្វែង នៅកម្ពុជា ហើយការពិភាក្សាពីបញ្ហាកាត់ទោស ខ្មែរក្រហមអាចនឹងបំផ្លាញដល់ដំណើរការសន្តិភាព។ ដូច្នេះការខិតខំប្រឹងប្រែង ក្នុងការស្វែងរកយុត្តិធម៌ពីឧក្រិដ្ឋកម្ម ក្នុងរបបខ្មែរក្រហម ត្រូវបានទុកឲ្យនៅម្ខាង ដើម្បីជាប្រយោជន៍ដល់ការថែរក្សា ដំណោះស្រាយសន្តិភាពនៅកម្ពុជា[307]។ ដោយសារមានការអំពាវនាវយ៉ាងខ្លាំងក្លាពី ក្រុមប្រឹក្សាសន្តិ

[306] ស្វែងរកការពិត-វេទិកាពិភាក្សាសាធារណៈ: លេខ៨៣ ខែវិច្ឆិកា ឆ្នាំ២០០៦ ទំព័រ៤៨។

[307] ស្វែងរកការពិត-វេទិកាពិភាក្សាសាធារណៈ: លេខ៨៣ ខែវិច្ឆិកា ឆ្នាំ២០០៦ ទំព័រ៥១។

សុខភាគីជម្លោះទាំងបួនបានចុះហត្ថលេខា លើផែនការសន្តិភាពនៅថ្ងៃទី ២៣ តុលា ឆ្នាំ១៩៩១។

១៩១. ដូច្នេះទោះមានរបាយការណ៍ជាច្រើនស្តីពីអំពើឃោរឃៅរបស់ខ្មែរក្រហមក៏ដោយ ក៏អង្គការសហប្រជាជាតិនៅតែបន្តគាំទ្រចលនាតស៊ូរបស់ខ្មែរក្រហម ព្រមទាំងផ្តល់ធម្មានុភាពនយោបាយទៅឱ្យរបបកម្ពុជាប្រជាធិប្បតេយ្យ ដែលដួលរលំនេះទៀតផង។ រដ្ឋាភិបាលកម្ពុជា ប្រជាធិប្បតេយ្យ បានកាន់កាប់អាសនៈ នៅអង្គការសហប្រជាជាតិ រហូតដល់កិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ ១៩៩១។

## ២. ការបង្កើតរដ្ឋាភិបាលចម្រុះ

១៩២. បន្ទាប់ពីការបោះឆ្នោតជាសកល រដ្ឋាភិបាលចម្រុះមួយត្រូវបានបង្កើតឡើង ហើយប្រាំខែក្រោយមករដ្ឋធម្មនុញ្ញថ្មីមួយត្រូវបានអនុម័តឡើងនៅខែវិច្ឆិកា ឆ្នាំ ១៩៩៣។

## ៣. នយោបាយអាមេរិកចំពោះខ្មែរក្រហម

១៩៣. នៅឆ្នាំ ១៩៩៤ នយោបាយអាមេរិកកាំងចំពោះខ្មែរក្រហមក៏ចាប់ផ្តើមឡើង។ សភាអាមេរិកបានអនុម័តច្បាប់យុត្តិធម៌ស្តីពីអំពើប្រល័យពូជសាសន៍ នៅកម្ពុជា ដោយអំពាវនាវឱ្យរដ្ឋាភិបាលអាមេរិកគាំទ្រដល់កិច្ចខំប្រឹងប្រែងទាំងឡាយក្នុងការនាំយកសមាជិកខ្មែរក្រហម មកទទួលខុសត្រូវចំពោះ បទឧក្រិដ្ឋដែលប្រព្រឹត្តចន្លោះពីឆ្នាំ ១៩៧៥១៩៧៩។ កន្លងមក ពួកគេពុំបានចាប់អារម្មណ៍នឹងបញ្ហានេះទេ ព្រមទាំងបានបោះឆ្នោត ផ្តល់អាសនៈកម្ពុជា ឱ្យរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិប្បតេយ្យថែមទៀតផង[308]។

## ៤. ការចាប់ផ្តើមចរចារបង្កើតអ.វ.ត.ក និងការធ្វើសម្បទានទៅវិញទៅមក

១៩៤. តាំងពីដើមមកភាគីទាំងពីរមានគំនិតផ្សេងគ្នាអំពីថាតើសាលាក្តីនេះនិងត្រូវបង្កើតឡើងដោយរបៀបណា។ ភាពខុសគ្នានេះមានស្ទើរតែគ្រប់តំណាក់កាលទាំងអស់នៃ ការបង្កើតសាលាក្តី។ ភាពខុសគ្នាទាំងនោះវាស្តែងឡើតតាមរយៈការពិភាក្សាដ៏តឹងតែងជាច្រើនទាក់ទងនឹងប្រភេទ និងយុត្តាធិការរបស់សាលាក្តីនេះ។

## ៥. ឧបសគ្គរាំងរដល់ការបង្កើតអ.វ.ត.ក

១៩៥. ទោះជាយ៉ាងនេះក្តី ការខិតខំប្រឹងប្រែង ឱ្យមានការទទួលខុសត្រូវនៅកម្ពុជាត្រូវបានអាក់ខានទៅវិញដោយ៖ នៅខែកញ្ញា ឆ្នាំ១៩៩៦ ការលើកលែងទោស អៀង សារី **ក្នុងន័យបង្រួមបង្រួមផ្សះផ្សារជាតិ**។ព្រះ

---

[308] ស្វែងរកការពិត-វេទិកាពិភាក្សាសាធារណៈ លេខ៨៣ ខែវិច្ឆិកា ឆ្នាំ២០០៦ ទំព័រ៥២។

01634862



មហាក្សត្រ ព្រះរាជទានទោសជាផ្លូវការដល់អតីត ឧបនាយករដ្ឋមន្ត្រី អៀង សារី ដែលត្រូវបានកាត់ទោសប្រហារជីវិតដោយសាលាក្តីឆ្នាំ ១៩៧៩។ ការលើកលែងទោសត្រូវបានធ្វើឡើងដោយសារ អៀង សារី បានដកខ្លួនចេញពីក្រុមហើយចុះចូលជាមួយរាជរដ្ឋាភិបាល(សីហា ១៩៩៦) ដែលទើបបង្កើតថ្មី ។

១៩៦. នៅឆ្នាំ១៩៩៦ កងកម្លាំងខ្មែរក្រហមបានឈានដល់ចំណុចបំបែក (ខែមិថុនា ១៩៩៧ ប៉ុល ពតត្រូវបាន កាត់ទោសដោយតុលាការប្រជាជន នៅតំបន់អន្លង់វែង ពីបទចោទប្រកាន់សម្លាប់អតីតរដ្ឋមន្ត្រីក្រសួងការពារជាតិ របស់ខ្មែរក្រហម សុន សេន)។ សភាពការណ៍ ខែធ្នូ ឆ្នាំ ១៩៩៨ មេដឹកនាំខ្មែរក្រហមពីររូប ខៀវ សំផន និង នួន ជា បានប្រកាសផ្តាច់ខ្លួនចេញពីបក្សកម្មុយនីស្តកម្ពុជា ក្នុងខែមេសា ឆ្នាំ១៩៩៨ ប៉ុល ពត ស្លាប់ ។ ខែ មិនា ឆ្នាំ១៩៩៩ មេដឹកនាំខ្មែរក្រហមមួយរូបទៀត តា ម៉ុក ត្រូវបានចាប់ខ្លួន។ នៅខែមករា ឆ្នាំ២០០១ រដ្ឋសភាជាតិបានអនុម័ត លើសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតសាលាក្តី ដែលមានទម្រង់ជាអង្គជំនុំជម្រះវិសាមញ្ញ ដែលជាប្រព័ន្ធតុលាការជំនុំជម្រះ និងមានការចូលរួមពី មន្ត្រីជាតិ និង អន្តរជាតិ។

## ៦. ការដកខ្លួនរបស់អង្គការសហប្រជាជាតិ

១៩៧. នៅខែកុម្ភៈ ឆ្នាំ ២០០២ អង្គការសហប្រជាជាតិបានប្រកាសដកខ្លួនចេញពីការចរចា។ ការបញ្ឈប់ការចរចាត្រូវបានក្រុមអ្នករិះគន់ និយាយថា មានន័យស្មើនឹងការជំរុញឲ្យមាននិទណ្ឌភាព[309]។

## ៧. ការចូលរួមសារជាថ្មីរបស់អង្គកាសហប្រជាជាតិ

១៩៨. នៅក្នុងសេចក្តីសម្រេច ដែលគាំទ្រដោយជប៉ុន និង បារាំង នៅខែ ធ្នូ ឆ្នាំ ២០០២ មហាសន្និបាតអង្គការសហប្រជាជាតិ បានផ្តល់សិទ្ធិ ឲ្យអគ្គលេខាធិការ អង្គការសហប្រជាជាតិ ផ្តើមការចរចាក្នុងការបង្កើតសាលាក្តីជាថ្មីម្តងទៀត។ រដ្ឋជាសមាជិកអង្គការសហប្រជាជាតិបានស្វាគមន៍ច្បាប់ឆ្នាំ ២០០១ ហើយជំរុញឲ្យការិយាល័យកិច្ចការច្បាប់របស់អង្គការសហប្រជាជាតិ ដោះស្រាយឲ្យបានឆាប់រហ័សនូវបញ្ហាសំខាន់ៗទាំងឡាយ ហើយនៅថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០០៣ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង បង្កើតតុលាការដែលនិងដំណើរការនៅក្នុងរង្វង់ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឆ្នាំ ២០០១ ដែលមានឈ្មោះថា "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា"។

[309] ស្វែងរកការពិត-វេទិកាសាធារណៈ លេខ៨៤ ខែធ្នូ ឆ្នាំ២០០៦ ទំព័រ៥៤។

01634863



## ៨. ការធ្វើសម្បទានរបស់រដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ

១៩៩. ការចរចាអស់រយៈពេលជាច្រើនឆ្នាំជម្រុញឲ្យ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាផ្តល់សម្បទានឲ្យគ្នាទៅវិញទៅមកលើបញ្ហាសំខាន់ៗជាច្រើនទាក់ទងទៅនឹងការបង្កើតសាលាក្តីកាត់ទោសខ្មែរក្រហម។ ទោះបីជាភាគីទាំងពីរបានធ្វើសម្បទានយ៉ាងណាក៏ដោយ លទ្ធផលនៃការចរចាទាក់ទងនឹងដែនយុត្តាធិការរបស់តុលាការភាគីទាំងពីរបានយល់ស្របថា វាមិនប្រាកដប្រជាទេ៖[310]

២០០. ចំនួនជនដែលត្រូវយកមកកាត់ទោស ស្នើរឡើងក្នុងរបាយការណ៍របស់អ្នកជំនាញអង្គការសហប្រជាជាតិ ក្នុងឆ្នាំ ១៩៩៩ គឺមាន ២០ទៅ៣០នាក់ ជាចំនួន ដែលភាគីកម្ពុជាប្រឆាំងដាច់ខាត។

២០១. ចំនួនដែលស្នើដោយកម្ពុជា មានចំនួន ៤ ទៅ ៥ នាក់ប៉ុណ្ណោះ (អៀងសារីត្រូវបានព្រះមហាក្សត្រលើកលែងទោស)។

២០២. ដូច្នេះពុំមានការឯកភាពគ្នាលើចំនួនជន ដែលត្រូវនាំយកមកកាត់ទោស ហើយការ ចចារក្រោយៗមកទៀតលើបញ្ហានេះត្រូវបានរក្សាទុកជាការសម្ងាត់សូម្បីតែសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានស្នើសុំពីផ្នែកបណ្ណសាររបស់អង្គការសហប្រជាជាតិ នូវកំណត់ហេតុនៃចចាររវាងអង្គការសហប្រជាជាតិជាមួយរដ្ឋាភិបាលកម្ពុជា សំណើនេះពុំទទួលបានចម្លើយជាវិជ្ជមានឡើយ។[311]

## ៩. ការជ្រើសរើសយកចំនួនជនត្រូវចោទមកកាត់ទោស

២០៣. ដោយជ្រើសរើសយកចំនួន ជនត្រូវចោទតិចបែបនេះ ទើបបើកផ្លូវឲ្យតុលាកាអាចដំណើរការបាន។ ភាពមិនប្រាកដប្រជានេះបានត្រឹមឈានដល់ការប្រើពាក្យ " អ្នកដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត" ក្នុងកិច្ចព្រមព្រៀងក៏ដូចច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ ការមិនចុះសម្រុងរវាងភាគី អង្គការសហប្រជាជាតិ និងភាគីកម្ពុជាលើចំនួនជនដែលត្រូវនាំយកមកកាត់ទោស នៅអ.វ.ត.ក បង្កើតបានជាការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាជាតិ និងព្រះរាជអាជ្ញាអន្តរជាតិ ការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតជាតិនិង អន្តរជាតិ ក្នុងសំណុំរឿង ០០៣ និង សំណុំរឿង ០០៤។ ដូច្នេះ កិច្ចព្រមព្រៀងក៏ដូចជាច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង បានសម្រេចយកនីតិវិធី សម្រាប់ដោះស្រាយការខ្វែងគំនិតគ្នារវាងសហព្រះអាជ្ញាជាតិនិងអន្តរជាតិ និងរវាងសហចៅក្រមស៊ើបអង្កេតជាតិនិងអន្តរជាតិ ដូចមានចែងក្នុង

[310] ស្វែងរកការពិត-វេទិកាពិភាក្សាសាធារណៈ លេខ៨៤ ខែធ្នូ ឆ្នាំ២០០៦ ទំព័រ៥៤។

[311] ស្វែងរកការពិត-វេទិកាពិភាក្សាសាធារណៈ លេខ ៨៤ ខែធ្នូ ឆ្នាំ២០០៦ ទំព័រ ៥៥។

វិធាន ៧១ និង វិធាន ៧២ នៃវិធានផ្ទៃក្នុង។

## ឃ. មេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត

២០៤. ទាំងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាទាំងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ពុំមានមាត្រាណាមួយបកស្រាយអត្ថន័យជាក់លាក់នៃពាក្យ "មេដឹកនាំជាន់ខ្ពស់ និងជនទាំង ឡាយ ដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌ កម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទំលាប់អន្តរជាតិព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែល ប្រទេសកម្ពុជាទទួលស្គាល់ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ០៦ មករា ១៩៧៩ នោះទេ។

២០៥. ដូច្នេះគប្បីលើកយកពាក្យ "មេដឹកនាំជាន់ខ្ពស់និងជនទាំងឡាយដែលទទួលខុសត្រូវ ខ្ពស់បំផុត" មក ធ្វើ ការពិនិត្យពិចារណា។

២០៦. ជាបឋម យើងលើកយកពាក្យ "មេដឹកនាំជាន់ខ្ពស់" មកពិនិត្យ។

២០៧. ដើម្បីអោយបានយល់ច្បាស់អំពីពាក្យថា"មេដឹកនាំជាន់ខ្ពស់" គប្បីលើកយករចនាសម្ព័ន្ធរដ្ឋអំណាច របបកម្ពុជាប្រជាធិបតេយ្យដែលមានចែងក្នុងដីកាសន្និដ្ឋានស៊ើបសួរចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧[312]។

### ១. អំពីរចនាសម្ព័ន្ធរដ្ឋអំណាច នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

២០៨. សហព្រះរាជអាជ្ញាបានលើកឡើងថា៖

២០៩. បក្សកុម្មុយនីស្តកម្ពុជា បានត្រួតត្រាលើរបបកម្ពុជាប្រជាធិបតេយ្យដែលស្ថិតក្នុងយុត្តាធិការរបស់ អ .វ.ត.ក។ បក្សបានអនុវត្តសិទ្ធិអំណាចរបស់ខ្លួន និងត្រួតត្រាប្រទេសតាមរយៈបណ្តាញ ចំនួន បី៖អង្គការរដ្ឋ បាល របស់បក្សកុម្មុនីស្តកម្ពុជា និង កងទ័ពបដិវត្តន៍កម្ពុជា"។[313]

២១០. សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុនីស្តកម្ពុជា និងកម្មាភិបាលជាន់ខ្ពស់ របស់បក្ស កុម្មុនី

[312] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ក្នុងសំណុំរឿង ០០២ (ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារលេខ D3)ឯកសារ D3 កថាខណ្ឌ១៧។

[313] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារលេខ D3 ចាខណ្ឌទី១៧។

ស្តកម្ពុជាបានអនុវត្តសិទ្ធិអំណាចជាក់ស្តែង និង ស្របច្បាប់នៅទូទាំងកម្ពុជាប្រជាធិបតេយ្យ ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ទាំងនៅពេលដែលបក្សកុម្មុនីស្តកម្ពុជាបានអះអាងថា រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា ជារដ្ឋាភិបាល និងនៅក្នុងពេលបន្តនៃរបបនោះ។[314]

២១១. ចាប់តាំងពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី១៣ មេសា ឆ្នាំ១៩៧៦ បក្សកុម្មុនីស្តកម្ពុជា បានរក្សានូវការបំភាន់ភ្នែកដែលថារាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជាគឺជារដ្ឋាភិបាលជាផ្លូវការ។ រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជាបានចូលរួម ក្នុងការរៀបចំរដ្ឋធម្មនុញ្ញនៃកម្ពុជា ប្រជាធិបតេយ្យ ដែលបានប្រកាសអោយប្រើនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ ដែលបានបង្កើតអង្គការ រដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ។ បន្ទាប់មកនៅថ្ងៃទី២០ ខែមិនា ឆ្នាំ១៩៧៦ រាជរដ្ឋាភិបាលបង្រួប បង្រួមជាតិកម្ពុជាបានអះអាងថា បានធ្វើការបោះឆ្នោតជ្រើសរើស និងតែងតាំងសភាតំណាង ប្រជាជនកម្ពុជា ដែលរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជាបានដាក់ជូនការលាលែងពីតំណែង របស់សមាជិកទាំងនោះនៅថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៧៦ ។ [315]

២១២. នៅថ្ងៃទី ១៣ ខែមេសា ឆ្នាំ១៩៧៦ សភាតំណាងប្រជា ជនបាន អះអាងថាបានជ្រើសរើស និងតែងតាំងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុនីស្ត កម្ពុជា និងកម្មាភិបាលជាន់ខ្ពស់ បក្សកុម្មុនីស្តកម្ពុជាដទៃទៀតត្រូវបានតែងតាំងនូវតួនាទីខ្ពស់បំផុត នៅក្នុងអង្គការរដ្ឋទាំងអស់។ នៅខណៈដែលមានការអះអាងថារាជរដ្ឋាភិបាលបង្រួបបង្រួមជាតិ កម្ពុជាបានតែងតាំងមេដឹកនាំបក្សកុម្មុនីស្តកម្ពុជា ក្នុងខែមេសា ឆ្នាំ១៩៧៦ ជាការពិត គឺគណៈ កម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុនីស្តកម្ពុជាបាន ធ្វើការតែងតាំងពួកគេនូវតួនាទីអស់ទាំងអស់រួចទៅ ហើយ យ៉ាងហោចណាស់នៅក្នុងខែតុលា ឆ្នាំ១៩៧៥។[316]

២១៣. តាមសេចក្តីសម្រេចចិត្តរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ បក្សកុម្មុនីស្តកម្ពុជាគឺបក្សកុម្មុនីស្ត កម្ពុជាដែលមានភារកិច្ចទទួលខុសត្រូវក្នុងការរៀបចំរដ្ឋធម្មនុញ្ញ និងអនុវត្តការបោះឆ្នោតព្រមទាំង ការបង្កើតនូវសភាតំណាងប្រជាជនកម្ពុជា គណៈប្រធានរដ្ឋនិងរដ្ឋាភិបាលដែលជា អង្គការរដ្ឋទាំង ស្រុងរបស់បក្ស។ គណៈកម្មាធិការអចិន្ត្រៃយ៍មជ្ឈឹមបក្សកុម្មុនីស្តកម្ពុជា បានចាត់ទុកថាសភាគឺគ្មាន តំលៃអ្វីទាំងអស់ហើយមិន

[314] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារលេខ D3 កថាខណ្ឌទី១៨។

[315] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារលេខ D3 កថាខណ្ឌទី១៩។

[316] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារលេខ D3 កថាខណ្ឌទី២០។

មានភស្តុតាងណាមួយបង្ហាញថា សភាបានអនុម័ត ឬ ប្រកាសអោយ ប្រើនូវ ច្បាប់ណាមួយទេ។[317]

២១៤. បក្សកុម្មុនីស្តកម្ពុជាមានរចនាសម្ព័ន្ធជាឋានានុក្រម ដែលជាអង្គការរដ្ឋបាលខ្ពស់បំផុតរបស់ បក្សកុម្មុនីស្តកម្ពុជាគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការអចិន្ត្រៃយ៍មជ្ឈឹម បក្សកុម្មុនីស្ត កម្ពុជាមានសមត្ថភាពក្នុងការបង្កើត រៀបចំ ណែនាំបញ្ជានិងតាមដានគោលនយោបាយ របស់ បក្សកុម្មុនីស្តកម្ពុជា។ អង្គការរដ្ឋបាលថ្នាក់ក្រោមរបស់បក្សកុម្មុនីស្តកម្ពុជាភូមិភាគតំបន់ស្រុក និងសាខានឹងអនុវត្តព្រមទាំងរាយការណ៍ពីគោលនយោបាយទាំងនេះនៅទូទាំងផ្ទៃប្រទេស នៃរបប កម្ពុជាប្រជាធិបតេយ្យ។[318]

២១៥. បក្សកុម្មុនីស្តកម្ពុជាបានអនុវត្តនូវវិធីសាស្ត្រដូចខាងក្រោមដើម្បីធានានូវភាពសំងាត់របស់ខ្លួន។ មេដឹកនាំរបស់បក្សកុម្មុនីស្តកម្ពុជាបានជ្រើសរើសយកការប្រើប្រាស់ *ឈ្មោះសម្ងាត់* ហើយបន្ទាប់ មក នឹងប្រើប្រាស់ឈ្មោះហៅក្រៅទាំងនោះ ដោយប្រើឈ្មោះជាលេខកូដហើយជាញឹកញាប់បាន ផ្លាស់ប្តូរទាំងឈ្មោះហៅក្រៅ និងឈ្មោះជាលេខកូដទាំងនោះ។ មេដឹកនាំកំពូលទាំងពីររូបនៃបក្ស កុម្មុនីស្តកម្ពុជា ត្រូវបានគេស្គាល់រួម គ្នាថាជា*អង្គការ* ទោះបីជាពាក្យនេះត្រូវបានប្រើក្នុងចំណោម ប្រជាជនទូទៅដើម្បីនិយាយ ពីកម្មាភិបាលណាម្នាក់ដែលតំណាងអោយរដ្ឋអំណាចនៃបក្សកុម្មុនីស្ត កម្ពុជា។ ពួកគេបានសំគាល់ទីតាំង ភូមិសាស្ត្រ និងស្ថាប័ន នានាដោយប្រើឈ្មោះជាលេខកូដ និងអក្សរ ដូចជា ៥៦០ (ភូមិភាគពាយ័ព្យ), ប-១ (ក្រសួងការបរទេស), ស-២១ (មណ្ឌលសន្តិសុខសំខាន់ជាងគេបង្អស់), ក-៣(មន្ទីរមជ្ឈឹមបក្ស), និងព-១ (មន្ទីរពេទ្យ កាល់ម៉ែត)។ នៅក្នុងករណីជាច្រើនបក្សកុម្មុនីស្តកម្ពុជាបាននិយាយពីអ្នកដែលទទួលខុសត្រូវនៅក្នុងទីតាំងណា មួយឬស្ថាប័នណាមួយ ដោយប្រើលេខកូដ ដែលគេបានកំណត់ សម្គាល់សម្រាប់ទីតាំង ឬស្ថាប័ននោះ។[319]

២១៦. នៅខណៈដែលលក្ខន្តិកៈ របស់បក្សកុម្មុនីស្តកម្ពុជាបានផ្តល់សិទ្ធិអំណាចខ្ពស់បំផុតនៅទូទាំង ប្រទេសទៅក្នុងដៃរបស់ មហាសន្និបាតបក្សកុម្មុនីស្តកម្ពុជា ដែលត្រូវជួបប្រជុំរៀងរាល់បួនឆ្នាំម្តង លក្ខន្តិកៈ នោះកំណត់អត្តសញ្ញាណថា គណៈកម្មាធិការមជ្ឈឹមបក្សកុម្មុនីស្តកម្ពុជាជា "អង្គភាពប្រតិបត្តិខ្ពស់បំផុត នៅទូទាំងប្រទេស" សម្រាប់ចន្លោះពេលបួនឆ្នាំនោះ។ ក្នុងការអនុវត្តន៍ អនុគណៈកម្មាធិការរបស់គណៈកម្មាធិការមជ្ឈឹមបក្សកុម្មុនីស្តកម្ពុជា ដែលគេស្គាល់ថាជា គណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុនីស្តកម្ពុជា ដើរតួនាទីជា

[317] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារលេខ D3 កថាខណ្ឌទី២១។

[318] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារលេខ D3 កថាខណ្ឌទី២២។

[319] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារលេខ D3 កថាខណ្ឌទី២៣។

*អង្គភាពខ្ពស់បំផុត ហើយ ដែលមានសិទ្ធិអំណាចបំផុត នៅក្នុងបក្សកុម្មុនីស្តកម្ពុជា និងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ* ។[320]

២១៧. គណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុនីស្តកម្ពុជាបានអនុវត្តនូវសិទ្ធិអំណាច ដើម្បីបង្កើតណែនាំ អនុវត្ត និងតាមដានការប្រព្រឹត្តិទៅនូវគោលនយោបាយទាំងអស់ទាក់ទងនឹងបញ្ហារដ្ឋ និងបញ្ហា របស់បក្សកុម្មុនីស្តកម្ពុជា។ ជាពិសេស គណៈកម្មាធិការអចិន្ត្រៃយ៍ត្រួតពិនិត្យគោល នយោបាយទាក់ទង ទៅនឹងសន្តិសុខក្នុង និងក្រៅប្រទេស កិច្ចការបរទេស កិច្ចការក្នុងប្រទេស រួមទាំងផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម ឧស្សាហ៍កម្ម កសិកម្ម សុខាភិបាល និងសង្គមកិច្ច ឃោសនាការ និងអប់រំ ព្រមទាំងបញ្ហារដ្ឋបាល បុគ្គលិករដ្ឋ និងបុគ្គលិកបក្សកុម្មុនីស្តកម្ពុជា។ គណៈកម្មាធិការអចិន្ត្រៃយ៍ បានពិភាក្សា និងបញ្ជានូវការផ្លាស់ប្តូរទីកន្លែងដោយបង្ខំក្នុងទ្រង់ទ្រាយធំ បានពិភាក្សានិងបញ្ជាការប្រើការ ធ្វើ ពលកម្មដោយបង្ខំ បានបញ្ជាការចាប់ខ្លួន និងការសួរចម្លើយ "ខ្មាំង" បានដឹងពីស្ថានភាពរស់នៅ អមនុស្សធម៌ នៅទូទាំងប្រទេស និងមានសិទ្ធិអំណាច បញ្ជាការប្រហារជីវិត ប្រជាជនតាមទំនើងចិត្ត។[321]

២១៨. សមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុនីសកម្ពុជាដូចតទៅនេះ គឺជាសមាជិកនៃ គណៈកម្មាធិការអចិន្ត្រៃយ៍ ៖ ប៉ុល ពត (លេខាបក្សកុម្មុនីស្តកម្ពុជា "ស្លាប់"), នួន ជា (អនុលេខាបក្ស កុម្មុនីស្តកម្ពុជា) អៀង សារី, វន វ៉េត (ស្លាប់), សោ ភឹម (ស្លាប់), តាម៉ុក (ស្លាប់), និង សុន សេន (ស្លាប់) ។

២១៩. គណៈកម្មាធិការអចិន្ត្រៃយ៍បានជួបប្រជុំជាញឹកញាប់ និងទៀងទាត់ដោយមានការចូលរួមពីសមាជិកទាំងអស់ ឬ សមាជិកខ្លះ។ សមាជិកគណៈកម្មាធិការមជ្ឈិមបក្សកុម្មុនីស្តកម្ពុជា ដែលមិនមែន ជាគណៈកម្មាធិការអចិន្ត្រៃយ៍ រួមទាំង ខៀវ សំផន និងកម្មាភិបាលបក្សកុម្មុនីស្តកម្ពុជា ថ្នាក់ខ្ពស់ដទៃទៀតបានចូលរួម ក្នុងអង្គប្រជុំជាញឹកញាប់។[322]

២២០. មន្ទីរ៨៧០ តាមដានការអនុវត្តន៍គោលនយោបាយ របស់គណៈកម្មាធិការអចិន្ត្រៃយ៍។ ដោយមានទីតាំងនៅភ្នំពេញ មន្ទីរ៨៧០ មានតួនាទីជាលេខាធិការដ្ឋាន សម្រាប់គណៈកម្មាធិការ អចិន្ត្រៃយ៍បក្សកុម្មុនីស្តកម្ពុជា។ មន្ទីរ៨៧០ មិនត្រឹមតែបញ្ជូនសេចក្តីណែនាំគោលនយោបាយរបស់ គណៈកម្មាធិការអចិន្ត្រៃយ៍ទៅកាន់អង្គការរដ្ឋបាលថ្នាក់ក្រោមរបស់បក្សកុម្មុនីស្តកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែ បានរៀបចំ និងចែកចាយរបាយ

---

[320] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារលេខ D3 កថាខណ្ឌទី២៤។

[321] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារលេខ D3 កថាខណ្ឌទី២៥។

[322] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារលេខ D3 កថាខណ្ឌទី២៦។

ការណ៍ ដែលទទួលបានពីភូមិភាគ និងអង្គការរដ្ឋបាល របស់បក្ស កុម្មុនីស្តកម្ពុជា ដទៃទៀត ព្រមទាំងពីអង្គការកងទ័ពបដិវត្តន៍កម្ពុជា អំពីស្ថានភាពទូទៅ និងការអនុវត្តន៍គោលនយោបាយរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៅ ទូទាំងកម្ពុជាប្រជាធិបតេយ្យ។[323]

២២១. គណៈកម្មាធិការអចិន្ត្រៃយ៍ និងមន្ទីរ៨៧០ ធ្វើការជិត ស្និត ឮជាមួយក្រសួងរដ្ឋាភិបាលនានា ក្នុងការអនុវត្តន៍គោលនយោបាយរបស់បក្ស។ ស្ថិត នៅក្រោមការដឹកនាំរបស់សមាជិកគណៈ កម្មាធិការអចិន្ត្រៃយ៍ គណៈកម្មាធិការមជ្ឈិម ក្រសួងនានាមានមុខងារជាផ្នែកប្រតិបត្តិរបស់បក្ស កុម្មុនីស្តកម្ពុជា។ ជាឧទាហរណ៍ អៀង ធីរិទ្ធ ដែលជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច មានទំនាក់ ទំនងផ្ទាល់ជាមួយ ប៉ុល ពត, នួន ជា, ខៀវ សំផន និងសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ដទៃទៀត។[324]

២២២. យើងអាចសន្និដ្ឋានបានថា បក្សកុម្មុនីស្តកម្ពុជាបានគ្រប់ គ្រងកម្ពុជាប្រជាធិបតេយ្យតាមរយៈអង្គការរដ្ឋកម្ពុជា ប្រជាធិបតេយ្យ អង្គការរដ្ឋបាលរបស់បក្ស និងកងទ័ពបដិវត្តន៍កម្ពុជា។ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៦ និងលក្ខន្តិកៈបក្សបានផ្តល់អំណាចយ៉ាងធំធេងទៅអោយគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ។ ប៉ុន្តែក្នុងការអនុវត្តន៍ជាក់ស្តែង គឺអនុគណៈកម្មាធិការនៃគណៈកម្មាធិការកណ្តាល ដែលហៅថា “គណៈកម្មាធិការ អចិន្ត្រៃយ៍” ជាអ្នកដើរតួនាទី ជាអង្គភាពប្រកបដោយសិទ្ធិអំណាចធំបំផុត និងខ្ពស់បំផុតរបស់រដ្ឋ ដែលមាន សមាសភាពចំនួនប្រាំពីររូបគឺ[325] ៖

| | |
|---|---|
| ប៉ុល ពត | លេខាបក្ស (ស្លាប់) |
| នួន ជា | អនុលេខាបក្ស |
| អៀង សារី | សមាជិក |
| សោ ភឹម | សមាជិក (ស្លាប់) |
| តា ម៉ុក | សមាជិក (ស្លាប់) |
| វន វេត | សមាជិក (ស្លាប់) |
| ស៊ុន សេន | សមាជិក (ស្លាប់) |

២២៣. ជនទាំងប្រាំពីរនាក់នេះ ចាត់ទុកជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យប៉ុន្តែបច្ចុប្បន្ននៅ

[323] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារលេខ D3 កថាខណ្ឌទី២៧។

[324] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារលេខ D3 កថាខណ្ឌទី២៨។

[325] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារលេខ D3 កថាខណ្ឌទី៤ ដល់ ១៥។

រស់ តែមួយរូបគឺ នួន ជា ដែលកំពុងស្ថិតក្នុងសមត្ថកិច្ចនៃការវិនិច្ឆ័យទោស របស់ អ.វ.ត.ក។ កាំង ហ្កេច អ៊ាវ ហ ឌុច ពុំមែនជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ឡើយ។ ដូច្នេះ កាំង ហ្កេច អ៊ាវ ប្រាកដជាប្រភេទ "**ជនដែលទទួលខុសត្រូវខ្ពស់បំផុត**" ចំពោះឧក្រិដ្ឋកម្ម។

២២៤. ផ្អែកតាមរចនាសម្ព័ន្ធរដ្ឋអំណាចនៃរបបកម្ពុជាប្រជាធិបតេយ្យ មេដឹកនាំជាន់ខ្ពស់នៃរបប កម្ពុជាប្រជាធិបតេយ្យ គឺគណៈកម្មាធិការ អចិន្ត្រៃយ៍នៃគណៈកម្មាធិការ មជ្ឈិមបក្សកុម្មុយនីស្ត កម្ពុជា ដែលមានឈ្មោះ [326]

| | |
|---|---|
| ប៉ុល ពត | លេខាបក្ស (ស្លាប់) |
| នួន ជា | អនុលេខាបក្ស |
| អៀង សារី | សមាជិក (ស្លាប់) |
| សោ ភឹម | សមាជិក (ស្លាប់) |
| តា ម៉ុក | សមាជិក (ស្លាប់) |
| វន វ៉េត | សមាជិក (ស្លាប់) |
| សុន សេន | សមាជិក (ស្លាប់) |

២២៥. គួរកត់សំគាល់ថា មេដឹកនាំជាន់ខ្ពស់ដែលរស់រានមានជីវិតរហូតមកដល់សព្វថ្ងៃគឺមានតែ នួន ជា។ ចំពោះជនដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរទី២ និងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរទី៣ ក្នុងនោះមាន អោ អាន ផងដែរ ពុំមែនជាមេដឹកនាំជាន់ខ្ពស់និងពុំមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ។

២២៦. ព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងនាសវនាការថ្ងៃ១៩ ខែមិថុនា ឆ្នាំ២០១៩ ថា ដូចសម្តេច សុខ អាន បានកត់សម្គាល់ថាមានចំនួនតិចតួចអាចជា ៣០ នាក់ ឬ ក៏អាចថាធ្វើម៉េចកាត់សេចក្តីឱ្យបានមុនពេលពួកគាត់ស្លាប់បាត់បង់ជីវិត ។ សហព្រះរាជអាជ្ញាអន្តរជាតិបន្ថែមទៀតថា វាកំណត់ត្រឹមប្រហែល បួន ដប់នាក់ ហើយឥឡូវនេះយើងមានប្រាំពីរ ប្រាំបីនាក់ ហើយយើងលើកលែងចោទប្រកាន់ម្នាក់រួចទៅហើយ ។ល។

២២៧. ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះយល់ឃើញថា ការលើកឡើងរបស់សហព្រះរាជអាជ្ញាអន្តរជាតិផ្ទុយទៅនឹងភស្តុតាងដែលលោកបានលើកឡើងនៅក្នុងឯកសារ D360/10 ទាក់ទងនឹងប្រសាសន៍របស់ឯក

[326] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឯកសារលេខ D3 កថាខណ្ឌទី៧ ដល់ ២១។

ឧត្តម កែវ រេមី និងពុំមានមូលដ្ឋានច្បាស់លាស់ឡើយ។

## ខ. គោលបំណងនៃការបង្កើតអ.វ.ត.ក

២២៨. ដើម្បីបង្ហាញអំពីគោលបំណងសំខាន់ៗ ក្នុងការបង្កើត អ.វ.ត.ក ចៅក្រមជាតិនៃ អង្គបុរេជំនុំជម្រះ សូមលើកយកកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក វិធានផ្ទៃក្នុង និង បុព្វកថា មកបញ្ជាក់ជូនដូចខាងក្រោម៖

### ១. កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ

២២៩. តាមសំណើសុំជំនួយជាផ្លូវការ នាថ្ងៃទី២១ ខែមិថុនា ឆ្នាំ ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ បានចុះកិច្ចព្រមព្រៀងមួយ នៅថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០០៣ ក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម និង ការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ ដែលប្រព្រឹត្តឡើងអំឡុងក្នុងរបបកម្ពុជាប្រជាធិប្បតេយ្យ ចាប់ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ៦ ខែមករា ឆ្នាំ ១៩៧៩។

២៣០. មាត្រា ១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ចែងថា៖ គោលបំណងរបស់កិច្ចព្រមព្រៀងនេះ គឺកំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និង រដ្ឋាភិបាលកម្ពុជា ដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិប្បតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរ ទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទំលាប់អន្តរជាតិ ព្រមទាំងការរំលោភអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តិ ក្នុងអំឡុងថ្ងៃទី ១៧ មេសា ១៩៧៥ ដល់ ថ្ងៃ ៦ មករា ១៩៧៩។ ក្នុងចំណោមប្រការផ្សេងៗទៀត កិច្ចព្រមព្រៀងនេះផ្តល់នូវមូលដ្ឋានគតិយុត្តិ គោលការណ៍នឹងបែបបទសម្រាប់កិច្ចសហប្រតិបត្តិការនេះ។

២៣១. មាត្រា ២ នៃកិច្ចព្រមព្រៀងចែងថា៖ កិច្ចព្រមព្រៀងនេះទទួលស្គាល់ថា អង្គជំនុំជម្រះវិសាមញ្ញមានយុត្តាធិការលើរឿងក្តី ដូចដែលបានចែងក្នុង “ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តី ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ក្នុងរយៈកាលកម្ពុជាប្រជាធិប្បតេយ្យ” (បន្ទាប់ពីនេះហៅថា “ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ”) ដូចដែលបានអនុម័តនិងធ្វើវិសោធនកម្ម ដោយអង្គនីតិបញ្ញត្តិកម្ពុជា នៅក្រោមរដ្ឋធម្មនុញ្ញកម្ពុជា។ កិច្ចព្រមព្រៀងនេះ ទទួលស្គាល់ផងដែរថា អង្គជំនុំ

ជម្រះវិសាមញ្ញ មានយុត្តាធិការលើរូបបុគ្គលជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិប្បតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលបានចែងក្នុងមាត្រា ១ នៃកិច្ចព្រមព្រៀង។

២៣២. កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តក្នុងប្រទេសកម្ពុជា តាមរយៈច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅពេលអនុម័ត និងធ្វើវិសោធនកម្មរួច។ កិច្ចព្រមព្រៀងនេះត្រូវអនុវត្តតាមអនុសញ្ញាទីក្រុង វីយែន ស្តីពីច្បាប់នៃសន្ធិសញ្ញា ជាពិសេសមាត្រា ២៦ និង ២៧។

២៣៣. នៅក្នុងករណីចាំបាច់មានវិសោធនកម្មលើច្បាប់ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិសោធនកម្មបែបនេះត្រូវតែមានការពិគ្រោះយោបល់គ្នា ជាមុនរវាងភាគីទាំងពីរ។

## ២. ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក

២៣៤. មាត្រា១ ចែងថា៖ ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោស មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិប្បតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទំលាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩។

២៣៥. មាត្រា ២ ថ្មី ចែងថា៖ ត្រូវបានបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់ ពោលគឺសាលាដំបូងនិងតុលាការកំពូល ដើម្បីជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិប្បតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរ ទៅលើច្បាប់កម្ពុជា ដែលពាក់ព័ន្ធនិងអំពើឧក្រិដ្ឋ ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ និងការរំលោភទៅលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩។

២៣៦. មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិប្បតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មខាងលើនេះ ហៅថា “ជនសង្ស័យ”។

## ៣. វិធានផ្ទៃក្នុង

២៣៧. វិធាន ១៖ ការចូលជាធរមាននិងការបកស្រាយ

១. វិធានផ្ទៃក្នុងនេះត្រូវចូលជាធរមានតាមរយៈការបោះពុម្ពផ្សាយជាផ្លូវការដោយ ការិយា ល័យរដ្ឋបាល និងក្នុងរយៈពេលមិនលើសពី១០ថ្ងៃ ក្រោយពីឯកសារដូចគ្នាដែលមានជាភាសាខ្មែរ ដូចគ្នា អង់គ្លេស បារាំង ត្រូវបានអនុម័តដោយកិច្ចប្រជុំពេញអង្គ។

២ នៅក្នុងឯកសារនេះ ពាក្យសំគាល់ភេទប្រុស .ក៏ត្រូវរាប់បញ្ចូលភេទស្រីដែរ ហើយឯកវចនៈ ក៏អាចយល់ជាពហុវចនៈដែរ ហើយក៏អនុវត្តដូចគ្នាផងដែរ ចំពោះករណីបញ្ច្រាសមកវិញ។ ជាពិសេសលើកលែងតែមានចែងផ្សេងពីនេះ ការយោងនៅក្នុងវិធានផ្ទៃក្នុងនេះ ចំពោះពាក្យសហចៅក្រមស៊ើបអង្កេត សំដៅទៅដល់សហចៅក្រមស៊ើបអង្កេតទាំងពីរដែលធ្វើការសម្រេចចិត្តរួមគ្នា និងចៅក្រមស៊ើបអង្កេតណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ ទោះបីដោយផ្ទាល់ឬតាមរយៈតំណាង។ ករណីដូចគ្នានេះដែរ ត្រូវយកមកអនុវត្ត ចំពោះសហព្រះរាជអាជ្ញា។ បទប្បញ្ញត្តិនេះមិនមានផលប៉ះពាល់ផ្នែកវេយ្យាករណ៍ ដល់ឯកសារជាភាសាខ្មែរឡើយ។

២៣៨. វិធាន ២៖ នីតិវិធីអនុវត្តសម្រាប់បញ្ហាចន្លោះប្រហោងនៅក្នុងវិធានផ្ទៃក្នុង

នៅក្នុងអំឡុងពេលដំណើរការ របស់អង្គជំនុំជម្រះវិសាមញ្ញ ប្រសិនបើមានបញ្ហាណាមួយកើតមានឡើង ដែលមិនមានចែងក្នុងវិធានផ្ទៃក្នុងនេះ សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ត្រូវធ្វើការសម្រេចចិត្ត ដោយស្របទៅលើមាត្រា ១២ នៃកិច្ចព្រមព (១)ព្រៀង និងមាត្រា ២០ថ្មី ២៣ ថ្មី ៣៣ ថ្មី ឬមាត្រា ៣៧ ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងដោយផ្តោតការយកចិត្តទុកដាក់ជាពិសេស ទៅលើគោលការណ៍ជាមូលដ្ឋាន ដែលមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុងនេះ និងច្បាប់នីតិវិធីព្រហ្មទណ្ឌជាធរមាន។ ក្នុងករណីនេះ សំណើសុំធ្វើ**វិសោធនកម្ម** វិធានផ្ទៃក្នុង ត្រូវដាក់ជូនទៅគណកម្មាធិការនីតិវិធីនិងវិធានផ្ទៃក្នុងអោយបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។

២៣៩. វិធាន ៣៖ ការធ្វើវិសោធនកម្ម

១.សំណើសុំធ្វើវិសោធនកម្មលើវិធានផ្ទៃក្នុងនេះ អាចត្រូវដាក់ជូនគណកម្មាធិការនីតិវិធី និង វិធានផ្ទៃក្នុង ដោយសហព្រះរាជអាជ្ញាណាម្នាក់ សហចៅក្រមស៊ើបអង្កេតណាម្នាក់ ចៅក្រមណាម្នាក់ ប្រធានអង្គភាពគាំពារការពារក្តី អង្គភាពគាំពារជនរងគ្រោះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រធាន ឬអនុប្រធានការិយាល័យរដ្ឋបាល។

២. សំណើសុំធ្វើវិសោធនកម្ម ដែលបញ្ជូនពីគណកម្មាធិការនីតិវិធីផ្ទៃក្នុង ត្រូវដាក់ជូនកិច្ចប្រជុំពេញអង្គ ដើម្បីអនុម័ត ដោយស្របទៅនឹងនីតិវិធីសម្រាប់ការអនុម័តវិធានផ្ទៃក្នុងនេះ។

៣. លើកលែងតែមានការចែងផ្សេងពីនេះ វិសោធនកម្មត្រូវចូលជាធរមានភ្លាម បន្ទាប់ពីការបោះពុម្ពផ្សាយ ជាផ្លូវការដោយការិយាល័យរដ្ឋបាលនឹងមិនត្រូវលើសពីរយៈពេល១០ថ្ងៃ ក្រោយពេលទទួលបានការអនុម័តពីកិច្ចប្រជុំពេញអង្គ ជាភាសាខ្មែរ អង់គ្លេស និងបារាំង។

## ៤. ការប្រជុំនៅរដ្ឋសភា

២៤០. នៅក្នុងកំណត់ហេតុអំពីអង្គប្រជុំរបស់សភាជាតិ នៃព្រះរាជាណាចក្រកម្ពុជា លើសេចក្តីព្រាងច្បាប់ស្តីពី ការបង្កើតឲ្យមាន អ.វ.ត.ក (ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០) **ឯកឧត្តម សុខ អាន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ជាប្រធានក្រុមការងារបានគូសបញ្ជាក់ជូនសភាពេញអង្គថា " វង្វង់សមត្ថកិច្ច ហៅថាទិដ្ឋភាពនៃសមត្ថកិច្ចបុគ្គល គឺកំណត់ទៅលើមុខសញ្ញា ដែលត្រូវជាកម្មវត្ថុនៃការវិនិច្ឆ័យទោស របស់អង្គជំនុំជម្រះវិសាមញ្ញ គឺមានតែមេដឹកនាំជាន់ខ្ពស់ និង អ្នកដែលទទួលខុសត្រូវខ្ពស់បំផុត គឺសំដៅលើមុខសញ្ញាមួយចំនួនតូចចង្អៀតទេ...អ្នកដែលធ្វើខុសច្រើនជាងគេបំផុត ហើយនៅក្នុងស្មារតីនៃមាត្រា មួយយើងឃើញហើយគឺថា មុខសញ្ញានេះមិនច្រើន មិនទូលាយ មិនរាលដាលនោះទេ គឺស្មារតីចង់បានបង្រួញមុខសញ្ញានេះ ឲ្យច្បាស់លាស់ ឲ្យជាក់ស្តែង ឲ្យតិចបំផុត។[327]

២៤១. សមាជិកសភាផ្សេងទៀង មានជាអាទិ **ឯកឧត្តម ជាម យៀប** ឯកឧត្តមក៏បាន ចូលរួមមានមតិ ទាក់ទងនឹងជំពូក សមត្ថកិច្ចបុគ្គល ដោយបានបញ្ជាក់យ៉ាងច្បាស់ថា "ខ្ញុំសូមអំពាវនាវដល់បងប្អូនដែលធ្លាប់បានស្ថិតក្នុងរបប កម្ពុជាប្រជាធិប្បតេយ្យ សុំកុំយល់ច្រឡំ .... គោលបំណងនៃច្បាប់នេះវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិប្បតេយ្យ អីចឹងទេ សូមអំពាវនាវមន្ត្រីស៊ីវិល មន្ត្រីយោធានិងយុទ្ធជន ដែលធ្លាប់ចូលរួមក្នុងរបបខ្មែរក្រហមក្រោយធ្វើសមាហរនកម្ម ឬចុះចូលរាជរដ្ឋាភិបាលកម្ពុជា ដែលដឹកនាំដោយសម្តេច ហ៊ុន សែន រួចហើយ មេត្តាកុំមានការព្រួយបារម្ភអ្វី ....មាត្រាមួយនេះបានចែងច្បាស់លាស់អំពីគោលបំណងទិសដៅគឺវិនិច្ឆ័យទោសចំពោះតែមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិប្បតេយ្យតែប៉ុណ្ណោះទេ។[328]

២៤២. **ឯកឧត្តម ម៉ែន បញ្ញា** បានបញ្ជាក់ថា ខ្ញុំបាទសុំឯកភាព លើបញ្ញត្តិជាទូទៅ ជំពូកមួយនេះដែលមានតែមួយមាត្រា ប៉ុន្តែបានកំណត់ច្បាស់លាស់អំពីគោលបំណងអំពីមុខសញ្ញាដែលត្រូវវិនិច្ឆ័យទោស ខ្ញុំរីករាយដោយយើង....កំពុងតែខិតខំបិទនូវទំព័រប្រវត្តិសាស្ត្រដ៏ខ្មៅងងឹត របស់ប្រជាជាតិកម្ពុជាយើង។[329]

---

[327] ទស្សនាវដ្តី ស្វែងរកការពិត លេខ ១៣ ខែមករា ឆ្នាំ២០០១ ទំព័រ ៦៣, លេខ ១៤ ខែកុម្ភៈ ឆ្នាំ២០០១ ទំព័រ ៤៨ និងទំព័រ ៤៩។

[328] ទស្សនាវដ្តី ស្វែងរកការពិត លេខ ១៤ ខែកុម្ភៈ ២០០១ ទំព័រ ៥៥។

[329] ទស្សនាវដ្តី ស្វែងរកការពិត លេខ ១៤ ខែកុម្ភៈ ២០០១ ទំព័រ ៥៦។

២៤៣. **ឯកឧត្តម សុខ អាន** សន្និដ្ឋានថា៖ ទាល់តែយើងគិតអំពីទិដ្ឋភាពទាំងអស់ឱ្យគ្រប់ជ្រុងជ្រោយ បានន័យថា ទាំងទិដ្ឋភាពច្បាប់ ទាំងទិដ្ឋភាពនយោបាយ ទាំងទិដ្ឋភាពប្រវត្តិសាស្ត្រ វាពាក់ព័ន្ធគ្នា វាប្រហាក់ប្រហែលគ្នាទាំងអស់ បើយើងគិតតែអំពីច្បាប់ ហើយផ្អែកទៅលើច្បាប់ដែលយើងមាន ដែលយើងអត់យើងថាខុសច្បាប់ អាហ្នឹងគឺអត់ទៅរួចទេ បើយើងគិតថា យើងយកតែច្បាប់ដែលមានយកមកមើលតម្រូវកន្លែងណា ដែលច្បាប់នេះមាន យើងគិតថាវា ខុសច្បាប់នេះទៅមិនរួចទេ ហើយច្បាប់នេះលើកឡើងនូវរូបមន្តថ្មីនៃទស្សនទានថ្មី ហើយក៏គោលការណ៍ថ្មីធំៗ ដូចខ្ញុំបានជម្រាប់ហើយដែល ឆ្លុះបញ្ចាំងនូវជំហានសម្រុះសម្រួលទាំង៤ធំៗ៖

២៤៤. តុលាការអន្តរជាតិ យើងទាមទារតុលាការជាតិឈប់និយាយអំពី តុលាការអន្តរជាតិ គឺនិយាយអំពីតុលាការដែលមានលក្ខណៈអន្តរជាតិ គឺតុលាការជាតិ ប៉ុន្តែមានអង្គជំនុំជម្រះវិសាមញ្ញ ដែលមានចៅក្រមបរទេសចូលរួម នេះជាគោលការណ៍ថ្មីក្នុងច្បាប់អន្តរជាតិ លើកទី១នៅលើសាកលលោក ដូច្នេះគោលការណ៍នេះក៏ត្រូវថ្មីដែរ។

២៤៥. គោលការណ៍ទី២: ចំនួនចៅក្រម គេសុខចិត្តឱ្យខ្មែរមានភាគច្រើន ប៉ុន្តែ ភាគច្រើនរាំងស្ទះបាន រូបមន្តថ្មី ទាល់តែមានចៅក្រម១នាក់ចូលរួមទើបយកការសំរេចបាន។ ឥតដែលមានទេ។

២៤៦. គោលការណ៍ទី៣ បង្កើតឱ្យមានសហចៅក្រម ស៊ើបអង្កេត។

២៤៧. គោលការណ៍ទី៤ ព្រះរាជអាជ្ញា២នាក់ ត្រូវឱ្យមាន Consensus ឱ្យមានភាពឯកច្ឆ័នជាមួយគ្នាជារលូន ប៉ុន្តែថ្ងៃណាមួយភាគីទាស់គ្នា ត្រូវបង្កើតរូបមន្តថ្មី អង្គបុរេជំនុំជម្រះ ដូច្នេះត្រូវគិតគ្រប់ទិដ្ឋភាពទាំងអស់គឺ ច្បាប់ នយោបាយ ប្រវត្តិសាស្ត្រ វាពាក់ព័ន្ធគ្នា វាប្រទាក់ប្រទិនគ្នាទាំងអស់ ចំណុចមួយទៀតសំខាន់គួរឱ្យកត់សំគាល់ គឺចៅក្រមបរទេសទាំងអស់ត្រូវទទួលការតែងតាំងពី ស្ថាប័នជាន់ខ្ពស់របស់កម្ពុជាដែលមានសមត្ថកិច្ច គឺ ឧត្តមក្រុមប្រឹក្សាចៅក្រមជាអ្នកតែងតាំង។

២៤៨. គួរកត់សម្គាល់ថា អ្នកតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតអ.វ.ត.ក បានដឹងថា មានប្រភេទនៃចារី ចំនួនដ៏ច្រើន សន្លឹកសន្ធាប់ហើយពួកគេ នឹងមិនត្រូវជំនុំជម្រះក្តីនៅចំពោះមុខអ.វ.ត.កទេ។ ត្រង់ចំណុចនេះដើម្បី ឱ្យដឹងកាន់តែច្រើនតាមដែលអាចធ្វើទៅបាន អំពីគោលបំណងរបស់ភាគីនៅក្នុង កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានស្នើរសុំពីផ្នែកបណ្ណសាររបស់អង្គការសហប្រជាជាតិ នូវកំណត់ហេតុនៃការចរចាគ្នារវាងអង្គការសហប្រជាជាតិ ជាមួយរដ្ឋាភិបាលកម្ពុជា

ក៏ប៉ុន្តែអង្គការសហប្រជាជាតិបានបដិសេធមិនបង្ហាញឯកសារភាគច្រើនក្នុងចំណោមឯកសារដែលបានស្នើសុំទេ ដោយផ្អែកលើមូលហេតុរក្សានូវការសម្ងាត់។

២៤៩. ក្នុងការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០៤/២ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា**ឯកឧត្តមកែវ រមី** ក្នុងឃ្លាចុងក្រោយបានលើកឡើងថា, វាមិនមានយុត្តិធម៌ទេ បើយើងកាត់ទោសតែ ៣ ឬ ៤ នាក់នោះ(ឆ្លើយតបទៅនឹង**ឯកឧត្តម សុខ អាន**)។ នេះជាភស្តុតាងច្បាស់ក្រឡែតនាពេលប្រជុំឆ្លងសេចក្តីព្រៀងច្បាប់អ.វ.ត.ក នៅរដ្ឋសភាកម្ពុជា គឺ**ឯកឧត្តម សុខ អាន** បានបញ្ជាក់ថា ជនដែលត្រូវនាំយកមកកាត់ទោសនៅអ.វ.ត.ក មានចំនួនតែ៣ ឬ ៤ នាក់ប៉ុណ្ណោះ ដូចអ្វីដែល **ឯកឧត្តម កែវ រមី** បានលើកឡើងគឺជាគោលបំណងនៃការតាក់តែងកិច្ចព្រមព្រៀង និងច្បាប់ស្តីពីអ.វ.ត.ក ។[330]

២៥០. ភស្តុតាងដូចបានរៀបរាប់ក្នុងប្រវត្តិនៃការនាំយកខ្មែរក្រហមមកកាត់ទោសរហូតដល់ការប្រជុំឆ្លងសេចក្តីព្រៀងច្បាប់នៅរដ្ឋសភាជាតិ និងរចនាសម្ពន្ធគ្រប់គ្រងរដ្ឋអំណាចក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលលើកឡើងដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៧ ក្នុងសំណុំរឿង០០២ ឯកសារD3 បានបញ្ជាក់យ៉ាងច្បាស់ថា គោលបំណងនៃការប្រើពាក្យ មេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ក្នុងកិច្ចព្រមព្រៀង ក៏ដូចជាក្នុងច្បាប់អ.វ.ត.ក គឺសំដៅទៅលើតែជនមួយចំនួន ៤ ទៅ ៥ នាក់ ដែលមានក្នុងសំណុំរឿង០០១ និង ០០២ តែប៉ុណ្ណោះ ។

២៥១. ការនាំយកជនផ្សេងទៀតមកចោទប្រកាន់ ហើយបង្កើតជាសំណុំរឿង០០៣ និង០០៤ គឺពិតជារំលោភកិច្ចព្រមព្រៀង និងច្បាប់អ.វ.ត.ក ព្រមទាំងពុំអាចបិទសំណុំរឿងក្តីនេះតាមគតិច្បាប់ឡើយ។ ដូច្នេះការអនុវត្តការស៊ើបអង្កេតបឋមជាឯកតោភាគីដោយសហព្រះរាជអាជ្ញាអន្តរជាតិ គឺពិតជាផ្ទុយនឹងគោលការណ៍កុងសង់ស៊ុស ហើយដីកាដំណោះស្រាយដែលចោទប្រកាន់ អោ អាន បញ្ជូនទៅជំនុំជម្រះដែលកើតពីលទ្ធផលនៃការស៊ើបអង្កេតបឋមដោយខុសច្បាប់គប្បីទុកជាមោឃៈ ។

---

[330] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ឯកសារ D360/10 កថាខណ្ឌ ១១-១២ *យោងទៅរក* "ការចរចារ និងការអនុម័ត កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា និងការចរចារ និងការអនុម័ត វិសោធនកម្មលើច្បាប់ស្តីពីការកាត់ទោសមេដឹកនាំខ្មែរក្រហម" សម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភាកម្ពុជា ថ្ងៃទី ៤-៥ ខែតុលា ឆ្នាំ២០០៤ ឯកសារលេខ D359/3/1.1.45។

## ច. ដំណើរនៃសំណុំរឿង ០០៤

### ១. ការស៊ើបអង្កេតបឋមដោយសហព្រះរាជអាជ្ញា ៖ ការចោទប្រកាន់

២៥២. **វិធាន៤៩៖ ការអនុវត្តបណ្តឹងអាជ្ញា**

> ១- ការចោទប្រកាន់ចំពោះបទឧក្រិដ្ឋទាំងឡាយណាដែលស្ថិតនៅក្នុង យុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ អាចធ្វើឡើងបានតាមការផ្តួចផ្តើម គំនិតរបស់សហព្រះរាជអាជ្ញាតែប៉ុណ្ណោះ ទោះបីជាការសម្រេចចិត្ត ដោយឯកឯង ឬដោយផ្អែកតាមពាក្យបណ្តឹងក៏ដោយ។
> ២- សហព្រះរាជអាជ្ញាត្រូវទទួល និងពិចារណាលើពាក្យបណ្តឹងជាលាយល័ក្ខអក្សរ ឬ ព័ត៌មានទាំងឡាយណាដែលចោទប្រកាន់ អំពីការប្រព្រឹត្តឧក្រិដ្ឋកម្ម នៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។

២៥៣. មាត្រា ១៦ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា៖ រាល់ការសន្និដ្ឋានចោទប្រកាន់ជូនទៅអង្គជំនុំជម្រះវិសាមញ្ញ គឺជាការទទួលខុសត្រូវ របស់ព្រះរាជអាជ្ញាទាំងពីរនាក់ ម្នាក់ជាកម្ពុជា និង ម្នាក់ទៀតជាបរទេស ដែលហៅថា "សហព្រះរាជអាជ្ញា" ដែលធ្វើការរួមគ្នា ដើម្បីរៀបចំឯកសារ និងធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ជនសង្ស័យ សម្រាប់អង្គជំនុំជម្រះវិសាមញ្ញ។

២៥៤. យល់ឃើញថា បណ្តឹងអាជ្ញា- ការចោទប្រកាន់ចំពោះបទឧក្រិដ្ឋទាំងឡាយណា ធ្វើឡើងបានតែក្នុងយុត្តាធិការរបស់ អ.វ.ត.ក តែប៉ុណ្ណោះ ដូច្នេះការអនុវត្តរបស់សហព្រះរាជអាជ្ញាត្រូវឆ្លងកាត់ គោលការណ៍ Consensus រវាងសហព្រះរាជអាជ្ញាទាំងពីរនាក់ បានន័យថា ត្រូវមានការយល់ព្រមពីសហព្រះរាជអាជ្ញាកម្ពុជា និងអន្តរជាតិដាច់ខាត គឺមិនអាចធ្វើការលាក់លៀម ឬលួចធ្វើតែម្នាក់ឯងបានទេ។ ហើយការចោទប្រកាន់ចំពោះបទឧក្រិដ្ឋទៀតសោត ក៏ពុំអាចធ្វើឡើងចំពោះជនផ្សេងដទៃទៀត នៅក្រៅយុត្តាធិការរបស់អ.វ.ត.ក ឡើយ។

២៥៥. **វិធាន៥០៖ ការស៊ើបអង្កេតបឋម**

> សហព្រះរាជអាជ្ញា អាចដឹកនាំការស៊ើបអង្កេតបឋម ដើម្បីកំណត់ភស្តុតាង ដែលបង្ហាញអំពីការប្រព្រឹត្តឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក និងកំណត់អត្តសញ្ញាណជនសង្ស័យ និងសាក្សីសំខាន់ៗ។

២៥៦. ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ យល់ឃើញថា ការស៊ើបអង្កេតបឋមត្រូវឆ្លងកាត់ នីតិវិធីជាបន្ត

បន្ទាប់ទើបសម្រេចចេញជាដីកាសន្និដ្ឋាន បញ្ជូនរឿងទៅស៊ើបសួរ។

២៥៧. ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ យល់ឃើញថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវបញ្ជាក់អំពីពត៌មានផ្សេងៗ ភ្ជាប់ដោយសម្ភារៈដែលចាត់ទុកជាភស្តុតាង ដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ដែលត្រូវតែទទួលការឯកភាពពី សហព្រះរាជអាជ្ញាជាតិ តាមគោលការណ៍ Consensus។

## ២. ការអនុវត្តជាក់ស្តែងរបស់សហព្រះរាជអាជ្ញា

២៥៨. សហព្រះរាជអាជ្ញាពុំមានគោលការណ៍ច្បាស់លាស់ដើម្បីកំណត់មុខសញ្ញាជនដែលត្រូវធ្វើការចោទប្រកាន់។ អង្គបុរេជំនុំជម្រះ ត្រូវពិនិត្យលើការអនុវត្ត ឆន្ទានុសិទ្ធិរបស់សហព្រះរាជអាជ្ញា ដើម្បីកំណត់ថា ចំណាត់ការរបស់សហព្រះរាជអាជ្ញា អនុវត្តបានត្រឹមត្រូវតាមអង្គហេតុ និង អង្គច្បាប់ ដែរឬទេ។

២៥៩. នៅថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិ បានបញ្ជាក់ថានៅ អ.វ.ត.ក នេះ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី ពុំមានផែនការណាមួយដើម្បីចាត់វិធានការធ្វើការស៊ើបអង្កេតបឋមក្រោយៗទៀតបន្ថែមទៅលើជនសង្ស័យផ្សេងទៀតនោះឡើយ។ តាមរយៈការបញ្ជូនជនសង្ស័យចំនួនប្រាំ(៥)រូបនេះ ឱ្យទៅសហចៅក្រមស៊ើបអង្កេត ដើម្បីបំពេញកិច្ចស៊ើបសួរ សហព្រះរាជអាជ្ញាអន្តជាតិស្តីទី មានការយល់ស្របតាមសេចក្តីថ្លែងការណ៍របស់អតីតសហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៩ ដែលថាសំណុំរឿងចុងក្រោយដែលត្រូវធ្វើការ ចោទប្រកាន់ទាំងនេះនឹងនាំមកនូវការទទួលខុសត្រូវកាន់តែទូលំទូលាយ ថែមទៀតចំពោះឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្តនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិប្បតេយ្យ ពី ឆ្នាំ ១៩៧៥-១៩៧៩។

២៦០. ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ ធ្លាប់បានពិចារណាម្តងរួចហើយអំពី អនីត្យានុកូលភាពនៃកិច្ចស៊ើបសួរបឋមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ហើយដែលមានសេចក្តីដូចតទៅ៖

> *១. សហព្រះរាជអាជ្ញាជាតិ តាមចម្លើយរបស់ខ្លួន ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ បានអះអាងថា តាមវិធានផ្ទៃក្នុងរាល់ការដឹកនាំការស៊ើបអង្កេតបឋម និងការចោទប្រកាន់ទាំងអស់សុទ្ធតែ ប្រើពាក្យ "សហព្រះរាជអាជ្ញា"។ បើព្រះរាជអាជ្ញាណាមួយបំពេញកិច្ចតែឯង ដោយគ្មានការ ផ្ទេរសិទ្ធិនោះ វាផ្ទុយទៅនឹងបញ្ញត្តិនៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដែលបាន លើកឡើងថាវៀរលែងតែសកម្មភាពទាំងឡាយ ដែលត្រូវធ្វើរួមគ្នាក្រោមច្បាប់*

ស្តីពីការបង្កើត អ.វ.ត.ក និង វិធានផ្ទៃក្នុងនេះ សហព្រះរាជអាជ្ញាអាចផ្ទេរអំណាចទៅឱ្យព្រះរាជអាជ្ញាណាមួយ ក្នុងចំណោម សហព្រះរាជអាជ្ញាទាំងពីររូប តាមរយៈសេចក្តីសម្រេចរួមគ្នាជាលាយ លក្ខណ៍អក្សរឱ្យបំពេញកិច្ចតែម្នាក់ឯងបាន។ ដូច្នេះឃើញថាការបំពេញកិច្ចដែលធ្វើឡើងកន្លងមក ទាក់ទងនឹងដីកាសន្និដ្ឋាន បញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ នោះគឺ សហព្រះរាជអាជ្ញាអន្តរជាតិ និងមន្ត្រីរបស់ខ្លួនធ្វើដោយឯកឯងមិនបានស្នើសុំ ឬពិភាក្សាពីសហ ព្រះរាជអាជ្ញាជាតិទេ។

២. យោងតាមច្បាប់ អ.វ.ត.ក ការចោទប្រកាន់មានតម្លៃអាចទទួលយកបាន តាមផ្លូវច្បាប់នោះ លុះត្រាតែសហព្រះរាជអាជ្ញាទាំងពីរ ពោលគឺសហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញា អន្តរជាតិមានការឯកភាពគ្នា ដោយយោងលើពាក្យបណ្តឹង ឬដោយឆន្ទា នុសិទ្ធិរបស់ខ្លួន។ កិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក បានបញ្ជាក់ច្បាស់ថា នៅ អ.វ.ត.ក ត្រូវមានព្រះរាជអាជ្ញាពីរ រូបដែលហៅថា "សហព្រះរាជអាជ្ញា" ហើយត្រូវធ្វើការសហការគ្នា ក្នុងការបំពេញការងារ។ ដូច្នេះឃើញថា ភស្តុតាងនានា ដែលទទួលបានពីការស៊ើបអង្កេត បឋមរបស់សហព្រះរាជអាជ្ញា អន្តរជាតិទាក់ទងទៅនឹងជនសង្ស័យថ្មីទាំងនោះ សហព្រះរាជអាជ្ញាជាតិពុំ ដែលបានចូលរួម ឬ ផ្តល់សិទ្ធិអំណាចដល់មន្ត្រីរបស់ខ្លួនក្នុងការចូលរួមស៊ើប អង្កេតនោះទេ។

៣. សហព្រះរាជអាជ្ញាជាតិ និងមន្ត្រីរបស់ខ្លួនមិនដែលបានចូលរួម និង/ឬ គាំទ្រ ដល់ការស៊ើប-អង្កេតបឋមក្នុងការកំណត់មុខសញ្ញាជនសង្ស័យដើម្បីយកមកធ្វើការប្តឹង ចោទប្រកាន់ដូចដែលមាន នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ និងទី៣ ដែលធ្វើឡើងដោយសហព្រះរាជ អាជ្ញាអន្តរជាតិនោះទេ។ រហូតដល់ការស៊ើបអង្កេតបឋមដែលធ្វើឡើងដោយ សហព្រះ រាជអាជ្ញាអន្តរជាតិ និងមន្ត្រីរបស់ខ្លួនបានចប់សព្វគ្រប់ ទើបសហព្រះរាជអាជ្ញាជាតិ បានទទួល ព័ត៌មានក្រៅផ្លូវការថា ខាងផ្នែកអន្តរជាតិបានធ្វើការអង្កេតបឋមទាក់ទងនឹងកិច្ចការ មួយចំនួន ហើយការអង្កេតបឋមនេះក៏បានចប់សព្វ គ្រប់រួចរាល់ហើយដែរ។ ពេលទទួលព័ត៌-មានដូចនេះ សហព្រះរាជអាជ្ញាជាតិបានទៅសួរនាំសហព្រះរាជអាជ្ញាអន្តរជាតិ ប៉ុន្តែពេលនោះសហព្រះរាជ អាជ្ញាអន្តរជាតិអវត្តមានទើបសហព្រះរាជអាជ្ញាជាតិទៅជួបជាមួយសហ-ព្រះរាជអាជ្ញារងអន្តរ ជាតិ គឺ លោក វី

លៀម ស្មឹត។ ពេលសួរនាំករណីអង្កេតបឋមនេះ លោក វីលៀមស្មឹត បានប្រាប់ថា ពិតជាមានការស៊ើបអង្កេតបឋមដូចដែលសហព្រះរាជអាជ្ញាជាតិ ទទួលបានព័ត៌មាននោះមែន ហើយ លោក វីលៀម ស្មឹត ក៏បានពោលពាក្យថា "សុំទោស" ចំពោះ ការធ្វើអង្កេតបឋមដោយ ឯកឯងនេះ ហើយសន្យាថា បើពេលក្រោយមានធ្វើអ្វីទៀត ខ្លួននឹងជូនដំណឹងដល់សហព្រះ រាជជាតិ។

៤. សហព្រះរាជអាជ្ញាអន្តរជាតិ បានធ្វើការសម្រេចចិត្តក្នុងការផ្តួចផ្តើម ស៊ើប អង្កេតនេះដោយ ឯកឯង ដូច្នេះព្រះរាជអាជ្ញាជាតិមិនបានដឹងអំពីបញ្ហានេះទេ។ ព្រះរាជអាជ្ញាអន្តរជាតិ តាមចម្លើយ របស់ខ្លួនចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ បានអះអាងថា៖ កិច្ចស៊ើបសួរបឋមទាក់ទង នឹងដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរលើកទីមួយ លើកទីពីរ និង លើកទីបី ជាគោលការណ៍ត្រូវបានឈរលើមូលដ្ឋាននៃការវិភាគឯកសារធ្វើឡើងនៅក្នុងតុលាការដែលប្រមូលបានពីមជ្ឈ មណ្ឌលឯកសារកម្ពុជា (DC-Cam) ដែលបានទទួលមុនថ្ងៃ ទី១៨ ខែកក្កដា ឆ្នាំ២០០៧, មានន័យថា មុនការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីមួយ។ ភាគច្រើនបំផុតនៃការអនុញ្ញាត សម្រាប់កិច្ចស៊ើបសួរបឋមនៅពេលណាត្រូវបានផ្តល់ ដោយព្រះរាជអាជ្ញាណាម្នាក់ ឬសហព្រះ រាជអាជ្ញាក៏ដោយ គឺត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ ដែលអនុញ្ញាតដោយច្បាប់។

៥. ការិយាល័យសហព្រះរាជអាជ្ញា បានចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួន នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០០៦។ តាមព័ត៌មានដែលរកបានចំពោះការិយាល័យនាពេលនោះ អ្នកស៊ើបអង្កេតរបស់ខ្លួន បានកំណត់អត្តសញ្ញាណជនសង្ស័យសក្តានុពលចំនួនដប់ប្រាំមួយ នាក់ក្នុងបញ្ជីមួយ នៅថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០០៦ ដែលជនសង្ស័យទាំងនេះ បានជាប់ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋ ដែលស្ថិតក្នុងយុត្តាធិការរបស់តុលាការនេះ និងជនដែលស្ថិតក្នុងយុត្តាធិការបុគ្គលយ៉ាងសំខាន់ របស់តុលាការនេះដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលអាចរកបានជាសាធារណៈ។ ប៉ុន្តែនៅ ថ្ងៃនោះ ជនសង្ស័យសក្តានុពលម្នាក់បានស្លាប់។ អាស្រ័យហេតុនេះ បញ្ជីឈ្មោះជនសង្ស័យសក្តានុពលទាំងអស់ត្រូវបានកាត់បន្ថយមកត្រឹម ដប់ប្រាំនាក់ ហើយការិយាល័យ បានបើកកិច្ចស៊ើបសួរបឋមលើជនសង្ស័យទាំងអស់ដប់ប្រាំនាក់នោះ ទៅតាមឆន្ទានុសិទ្ធិ របស់សហ ព្រះរាជអាជ្ញា។

៦. មកដល់ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៦ ការិយាល័យបានធ្វើសេចក្តីព្រាងដីកា សន្និ ដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរសម្រាប់ជនសង្ស័យទាំង១៥នាក់។ សេចក្តីព្រាងនៃដីកា សន្និដ្ឋានទាំងនេះ ត្រូវបាន ចែកជូន និងពិនិត្យឡើងវិញដោយសហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញា បានកំណត់ថា កិច្ចស៊ើបសួរបឋមបន្ថែមនឹងតម្រូវឱ្យមានសម្រាប់ជនសង្ស័យទាំង ១៥នាក់ នេះ។ បន្ទាប់មក សហព្រះរាជអាជ្ញាបានធ្វើការសម្រេចចិត្ត ដើម្បីផ្តល់អាទិភាពសម្រាប់ ជន សង្ស័យដោយបាន ផ្អែកលើលក្ខណៈវិនិច្ឆ័យឯករាជ្យចំនួនពីរ៖ (១) ថាតើការិយាល័យមានភស្តុ តាងគ្រប់គ្រាន់នៅ ក្នុងដៃហើយឬនៅ ដើម្បីបំពេញទៅលើលក្ខណៈវិនិច្ឆ័យនៃ "ហេតុផលជឿ បាន" សម្រាប់ជន-សង្ស័យជាក់លាក់ណាម្នាក់ ស្ថិតក្នុងក្របខណ្ឌពេល វេលាខ្លីប្រហាក់ប្រហែលគ្នា និង (២) ឋានៈរបស់ជនសង្ស័យនៅក្នុងឋានានុក្រមនៃបក្សកុម្មុនីស្តកម្ពុជា។ ការវាយតម្លៃនេះ ជាលទ្ធផល បង្កើតបានទូវបញ្ជីមួយមានជនសង្ស័យចំនួនប្រាំមួយនាក់ ដែលជា ប្រធានបទនៃ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងបញ្ជីមួយទៀតមានជនសង្ស័យ ប្រាំបួននាក់បន្ថែមទាក់ទងនឹងជនសង្ស័យដែលត្រូវបន្តនៅក្នុងកិច្ចស៊ើបសួរបឋមតាម ពេលវេលា និងធនធានដែលអនុញ្ញាត។

៧. មកដល់ដើមខែកក្កដា ឆ្នាំ២០០៧ ការិយាល័យបានបង្កើតសេចក្តីព្រាងដីកា សន្និដ្ឋានបញ្ជូនរឿង ឱ្យស៊ើបសួរមួយដែលមានលក្ខណៈជឿនលឿន ដោយចង្អុល ឈ្មោះជនសង្ស័យប្រាំមួយនាក់៖ នួន ជា, អៀង សារី, អៀង ធីរិទ្ធ, ខៀវ សំផន, ឌុច និង វ៉ាន់ រិទ្ធ។ ប៉ុន្តែ ក្នុងថ្ងៃស្នើដាក់ដីកា សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីមួយនោះ ដូចបានជម្រាបជូន ខាងលើសហព្រះរាជ-អាជ្ញាជាតិបានកំណត់ថា តាមទស្សនៈរបស់គាត់ ភស្តុតាងដែលបាន បង្កើតឡើងសម្រាប់ជន សង្ស័យ វ៉ាន់ រិទ្ធ មិនបំពេញបានទូវលក្ខណៈវិនិច្ឆ័យនៃ "ហេតុផលឱ្យជឿបាន" ទេ។

៨. ក្រោយថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ការិយាល័យបានបន្តកិច្ចស៊ើបសួរ បឋមលើ ជនសង្ស័យ នៅសល់ដប់នាក់ទៀត។ ទោះជាយ៉ាងនេះក្តីដើមឆ្នាំ២០០៨ ការិយាល័យសហព្រះ រាជអាជ្ញា ("ក.ស.ព") បាន ដឹងថាជនសង្ស័យម្នាក់ក្នុងចំណោមជនសង្ស័យទាំងដប់បាន ស្លាប់ហើយនៅ ពេលថ្មីៗនេះ ដោយបុព្វហេតុ ធម្មជាតិ ដោយបន្សល់ទុកជនសង្ស័យប្រាំបួន នាក់ ដល់ ក.ស.ព។ ក្នុងចន្លោះពេលនៃកិច្ចស៊ើបសួរបឋមបន្ថែមក្នុងឆ្នាំ២០០៨ សហព្រះរាជ អាជ្ញាបានកំណត់ថា បទឧក្រិដ្ឋទាំងឡាយណា ដែលអាចត្រូវបានប្រព្រឹត្ត

ឡើងដោយជនសង្ស័យបីនាក់ក្នុងចំណោម ជនសង្ស័យបន្ថែមទោះបីជាមិនមានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ស្ថិត ក្នុងយុត្តាធិការរបស់តុលាការ ឬ ភស្តុតាងភ្ជាប់ជនសង្ស័យទាំងនេះទៅក្នុងបទ ឧក្រិដ្ឋទាំងនោះ មិនអាចបង្កើតបានទៅតាម ក្របខណ្ឌពេលវេលាសមស្រប ដោយសារធនធានសម្រាប់ កិច្ចស៊ើបសួរក៏ដោយ។ កិច្ចស៊ើប-សួរបឋមនៅតែ បានបន្តធ្វើទៅលើជនសង្ស័យប្រាំមួយ នាក់ដែលនៅសល់។

៩. នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរបឋម ដែលបានធ្វើឡើងចាប់ពីខែកក្កដា ឆ្នាំ ២០០៧ ដល់ ខែវិច្ឆិកា ឆ្នាំ២០០៨ ទោះបីជាដឹងក៏ដោយ សហព្រះរាជអាជ្ញាជាតិបានបង្ហាញ ពីការមិនចង់ឱ្យមានកិច្ចស៊ើបសួរ ហើយស្របគ្នានេះដែរ ក៏ហាក់ដូចជាមិនលើកទឹកចិត្តដល់បុគ្គលិករបស់គាត់ឱ្យចូលរួមឱ្យបានសកម្មនៅក្នុងការងារនេះដែរ។ នៅខែតុលា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញា អន្តរជាតិ បានត្រៀមរៀបចំនូវសេចក្តីព្រាងនៃដីកា សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដោយចង្អុលឈ្មោះ ជនសង្ស័យថ្មីប្រាំមួយនាក់។ ច្បាប់ចម្លងជឿនលឿន នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ ជាភាសាខ្មែរត្រូវបានផ្តល់ជូនទៅឱ្យសហព្រះរាជអាជ្ញាជាតិ និងទើបគាត់បាននិយាយអំពី អលទ្ធភាពរបស់គាត់ ក្នុងការបញ្ជូនដីកាសន្និដ្ឋានទាំងនោះទៅសហចៅក្រមស៊ើបអង្កេត ដែលនេះ ជាការស្តែងចេញឱ្យឃើញច្បាស់អំពីការខ្វែង យោបល់គ្នានេះ។

១០. លើសពីនេះទៀត នៅក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងចម្លើយតប របស់សហព្រះរាជអាជ្ញាជាតិ ទៅនឹងសេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះឱ្យដាក់ ឯកសារ បន្ថែម សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា៖ "និយ័តភាពនៃកិច្ចស៊ើបសួរបឋម ដូចបាន លើកឡើងនៅកថាខណ្ឌ ១.គ ខាងលើមិនជាប់ពាក់ព័ន្ធទៅនឹងការកំណត់លើការខ្វែង យោបល់នេះទេ។ សហព្រះរាជអាជ្ញាអន្តរជាតិ សូមប្រកាន់ជំហរថា បញ្ហាតែមួយគត់នៅក្នុងកិច្ច ដំណើរការនីតិវិធីទាំងអស់នេះ គឺអំពីថាតើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មីទាំងពីរ និងដីកា សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមមួយគួរតែ ត្រូវបានបញ្ជូនទៅសហចៅក្រមស៊ើបអង្កេត សម្រាប់កិច្ចស៊ើបសួរដែរឬទេ។ បញ្ហាអំពីភាពទៀងទាត់ នៃកិច្ចស៊ើបសួរបឋម ប្រសិនបើមាន សុពលភាពទាំងអស់នោះវាត្រូវធ្លាក់ទៅលើតែយុត្តាធិការរបស់សហចៅក្រមស៊ើបអង្កេតតែ ប៉ុណ្ណោះដែលជាអ្នកអាចអនុញ្ញាតឱ្យ

ភាគីដែលស្នើសុំនូវដំណោះស្រាយសមស្របចំពោះការទុក ជាមោឃៈក្រោមវិធាន៧៦។ អាស្រ័យហេតុនេះអង្គបុរេជំនុំជម្រះ មិនមានយុត្តាធិការដើម្បីធ្វើការ ពិចារណាទៅលើអញ្ញត្រកម្មនេះទេនៅ ក្នុងដំណាក់កាល់នេះ និងនៅក្នុងកិច្ចដំណើរការទាំងនេះ។ នៅក្នុងព្រឹត្តិការណ៍ណាក៏ដោយ កិច្ចស៊ើបសួរបឋមដែលនាំឱ្យមានការស៊ើបសួរថ្មីៗ គឺត្រូវ បានធ្វើឡើងដោយត្រឹមត្រូវ។

១១. ក្នុងខណៈដែលសហព្រះរាជអាជ្ញាជាតិ មិនបានលើកឡើងនូវសំអាងហេតុអំពី ផលវិបាកនោះ សហព្រះរាជអាជ្ញាអន្តរជាតិសន្មតថា លោកស្រីមានបំណងចង់លើកឡើងថា ការស៊ើបសួរជា ឯកតោភាគីនេះ គឺធ្វើឱ្យបាត់ប្រសិទ្ធិភាពនៃសេចក្តីសន្និដ្ឋានថ្មីនេះ ដែលហេតុដូចនេះគួរតែត្រូវ បានបដិសេធចោល។

១២. សហព្រះរាជអាជ្ញាអន្តរជាតិបញ្ជាក់ឡើងវិញជាថ្មីថា អញ្ញត្រកម្មជាបឋមដែលសហព្រះរាជ អាជ្ញាជាតិបានលើកឡើងអំពីបញ្ហានេះ គឺយឺតពេលជាទីបំផុត និងជាគំនិតដែលគិតឃើញតាម ក្រោយ។ នៅក្នុងករណីណាក៏ដោយសហព្រះរាជអាជ្ញាអន្តរជាតិលើក ឡើងថានិយ័តភាពនៃ ការស៊ើបសួរបឋម គឺមិនមានការជាប់ទាក់ទងគ្នាទៅនឹងការកំណត់សម្រេចអំពីដំណើរការ នៃនីតិវិធីទាំងនេះទេ។ បញ្ហាតែមួយគត់ដើម្បីកំណត់សម្រេចនៅទីនេះ គឺអំពី ថាតើសេចក្តីសន្និដ្ឋាន ដាក់ជូនថ្មីគួរត្រូវបញ្ជូនទៅឱ្យសហចៅក្រមស៊ើបអង្កេតដែរឬទេ? បញ្ហាអំពីនិយ័តភាពនៃការ ស៊ើបសួរបឋម ទោះបីជាមានការជំទាស់ ដែលមានសុពលភាពក្តី ក៏វាស្ថិតនៅក្នុងយុត្តាធិការរបស់សហចៅក្រមស៊ើបអង្កេតដែ លអាចអនុញ្ញាតឱ្យភាគីដែលជាអ្នកដាក់សំណើនូវការដោះស្រាយតាមផ្លូវច្បាប់ដោយការធ្វើមោឃភាពស្របតាមវិធាន៧៦ នៃវិធានផ្ទៃក្នុងដែរ។ អាស្រ័យហេតុនេះ ក្នុងដំណាក់កាលនេះ និងនៅក្នុងដំណើរការនៃនីតិវិធីនេះ អង្គបុរេជំនុំជម្រះ មិនមានយុត្តាធិការនឹងធ្វើការពិនិត្យពិចារណាទៅលើអញ្ញត្រកម្មនេះ ទេ។

១៣. វិសាលភាពនៃដំណើរការនីតិវិធីត្រូវបានកម្រិតត្រឹមតែបញ្ហា ដែលបានលើក ឡើងនៅក្នុង សេចក្តីថ្លែងការណ៍របស់អ្នកដែលស្នើសុំ (ដែលនៅទីនេះ គឺសហព្រះរាជអាជ្ញាអន្តរជាតិ) និង សេចក្តី ថ្លែងការណ៍ឆ្លើយតបដោយអ្នកឆ្លើយតប (ដែលនៅទីនេះ គឺសហ

ព្រះ រាជអាជ្ញាជាតិ)។ សហព្រះរាជអាជ្ញា អន្តរជាតិលើកឡើងថាតុលាការអាជ្ញាកណ្ដាលកំណត់ សម្រេចលើបញ្ហា ផ្សេងៗ ដែលបានលើកឡើងនៅក្នុងសេចក្ដីថ្លែងការណ៍ និងក្លាយទៅជាតុលាការដែលលែង មានសិទ្ធិអំណាចតទៅទៀត (functus officio) ក្រោយពេលបានបំពេញភារកិច្ចរបស់ខ្លួន ក្នុងការកំណត់សម្រេចរួចរាល់ហើយ។ ភាគីទាំងឡាយដែលលើកឡើងអំពី បញ្ហាថ្មីៗនៅមុន ដំណាក់កាលដែលហួសពីវិសាលភាពនៃការខ្វែងយោបល់គ្នាពីដំបូង គឺត្រូវតែឆ្លងកាត់ការចាប់ ផ្ដើមក្នុងកម្រិតខ្ពស់បំផុតមួយ ដើម្បីបានការទទួលយល់ព្រមទៅលើការលើកសំអាងទាំងនេះ ឬលើកឡើងនូវបញ្ហាទាំងនោះថាជាការខ្វែងយោបល់គ្នា ដែលទើបតែមានថ្មីៗ។ សហព្រះរាជ អាជ្ញាអន្តរជាតិសង្កេតឃើញថានៅទីនេះ សហព្រះរាជអាជ្ញាជាតិ បានលើកឡើងនូវបញ្ហាផ្សេងៗ ដែលទើបតែ មានថ្មីៗនៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹង ការចោទសួរដោយអង្គបុរេជំនុំជម្រះ ហើយមិនបានបង្ហាញអំពីមូលហេតុត្រឹមត្រូវ ថាតើហេតុអ្វីបានជាការលើកសំអាងថ្មីៗរបស់ លោកស្រីត្រូវយកមកដាក់ជំនួសឱ្យសេចក្ដីថ្លែងការណ៍ ឆ្លើយតបរបស់លោកស្រី ដែលក្នុងនោះ មិនបានលើកអំពីបញ្ហាទាំងនោះណាមួយ ទាល់តែសោះទៅវិញ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា ការលើកសំអាងថ្មីៗរបស់ សហព្រះរាជអាជ្ញាជាតិ គួរតែត្រូវបានបដិសេធចោល ឬក៏ធ្វើមិនដឹងមិនឮ។

១៤. ដោយមិនធ្វើឱ្យខូចដល់អ្វីដែលមានពីមុនមកនេះ សហព្រះរាជអាជ្ញាអន្តរជាតិសូមជូនជាសេចក្ដី សន្និដ្ឋានដើម្បីពិនិត្យពិចារណាថា និយ័តភាពនៃកិច្ចស៊ើបសួរបឋម ដែល នាំឱ្យមានការដាក់ សេចក្ដីសន្និដ្ឋានថ្មីៗទៀត គឺវាហួសពីវិសាលភាពនៃដំណើរការ នៃនីតិវិធីនៃការខ្វែងយោបល់គ្នា ទាំងនេះហើយ។

១៥. ជាងនេះទៅទៀត គាត់លើកឡើងថា បញ្ហាអំពីនិយ័តភាពនៃសេចក្ដីសន្និដ្ឋាន ជាបឋម គឺមិនមែន ជាការតភ្ជាប់គ្នាទាំងស្រុង ដែលមិនអាចកាត់ផ្ដាច់បាន ទៅនឹងបញ្ហាស្ដី ពីសេចក្ដីសន្និដ្ឋានថ្មីៗ ដែលធ្វើឱ្យការ កំណត់សម្រេចលើសេចក្ដីសន្និដ្ឋានលើកទី២ អាចនឹងពឹងផ្អែកទៅលើការកំណត់ សម្រេចទៅលើសេចក្ដី សន្និដ្ឋាន លើកទី១ នោះទេ។ បញ្ហាទាំងនេះ គឺជាបញ្ហាផ្សេងដាច់ពីគ្នា ដែលអាចដាក់ឱ្យស្ថិតនៅក្រោមការកំណត់សម្រេចដោយឯករាជ្យ។ ក្នុងករណីណាក៏ដោយនិយ័តភាពនៃបណ្ដឹងណាមួយ នៅក្នុងអម្លុងពេលនៃការ

ស៊ើប សួរអាច ត្រូវបានតវ៉ាជំទាស់ដោយភាគីណាមួយផ្អែកតាមវិធាន៧៦។អាស្រ័យ ហេតុនេះ បើសិនជាភាគី ណាមួយអាចលើកឡើងនូវករណីដែលមានសុពលភាពថា ការស៊ើបសួរបឋមជា "ឯកតោ ភាគី" មួយដែលបានធ្វើឱ្យ ដំណើរការនៃនីតិវិធីបាត់បង់ប្រសិទ្ធិភាព ភាគីនោះអាចស្វែង រកសុំឱ្យធ្វើមោឃភាពនូវបណ្តឹងដែលលទ្ធផលណា មួយ ឬ ទាំង អស់។

១៦. សហព្រះរាជអាជ្ញាអន្តរជាតិកត់សម្គាល់ថា ការអនុញ្ញាតដើម្បីឱ្យធ្វើការស៊ើប អង្កេតបឋម ភាគ ច្រើននៅពេលដែលផ្តល់ដោយសហព្រះរាជអាជ្ញាតែមួយរូប ឬទាំងពីររូប គឺធ្វើឡើងដោយផ្ទាល់មាត់ ដែលធ្លាប់ បានអនុញ្ញាតធ្វើបែបនេះបាន។ ក្នុងករណីណាក៏ដោយ ឯកសារជាមូលដ្ឋាន នៃការបង្កើតតុលាការ នេះបានគ្រោងទុក អំពីការធ្វើសកម្មភាពរួមគ្នា ដោយសហព្រះរាជអាជ្ញាទាំងពីរ ដើម្បីបំពេញឱ្យសម្រេចនូវ អាណត្តិរបស់ខ្លួន សហព្រះរាជអាជ្ញា អន្តរជាតិលើកអំណះអំណាងថាឯកសារទាំងនោះក៏បានគ្រោងទុកផងដែរ ថាសហព្រះរាជ អាជ្ញា ត្រូវអនុវត្តមុខងារប្រចាំថ្ងៃរបស់ខ្លួនដោយរួមគ្នា ឬដាច់ដោយឡែកពីគ្នា។ អាស្រ័យហេតុ នេះ ដោយសន្មតថា ការស៊ើបសួរបឋមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ គឺជាការស៊ើបអង្កេត ដែលជាក់ស្តែងធ្វើឡើងដោយ "ឯកតោភាគី" នោះក្តី ក៏ផ្អែកតាមវិធានផ្ទៃក្នុង គាត់លើក ឡើង ទៀតថា គឺអាចអនុញ្ញាតឱ្យធ្វើបានដែរ ឱ្យតែការខ្វែងយោបល់គ្នានោះ ត្រូវបានធ្វើឱ្យបាន ឃើញច្បាស់លាស់ និងដាក់លាក់នៅក្នុង ដំណាក់កាល នៃការចុះហត្ថលេខា លើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

១៧. យើងយល់ឃើញថា តាមរយៈការអះអាងរបស់សហព្រះរាជអាជ្ញាទាំងពីរ ពិតជាមិនឃើញមានការពិភាក្សា ឬការផ្តល់ព័ត៌មានណាមួយ ទាក់ទងទៅនឹងការស៊ើបអង្កេតបឋមរវាងសហព្រះរាជអាជ្ញា ទាំងពីរ ដើម្បីឈានទៅដល់ការរៀបចំឱ្យមានដីកា សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី២ និងដីកាសន្និដ្ឋានញ្ជូនរឿងឱ្យស៊ើបសួរទី៣នោះទេ។ ដូច្នេះ យើងយល់ ឃើញថាការស៊ើបអង្កេតបឋមគឺត្រូវបានធ្វើឡើង ដោយសហ ព្រះរាជអាជ្ញាអន្តរជាតិ ដោយ ឯកឯង។ ទន្ទឹមនឹងនោះការសុំទោសរបស់លោក វីលៀម ស្មីត ព្រះរាជអាជ្ញា រងអន្តរជាតិ ដែលពុំត្រូវបានសហព្រះរាជអាជ្ញាអន្តរជាតិបដិសេធនោះ ជាសក្ខីកម្ម

*បញ្ជាក់កាន់តែ ច្បាស់ថែមទៀតថា ពិតជាមានការខកខានពុំបានជូនដំណឹងដល់សហព្រះរាជអាជ្ញាជាតិ អំពីការស៊ើបអង្កេតបឋមប្រាកដ មែន។*

*១៨. យោងតាមមាត្រា១៦ នៃច្បាប់ អ.វ.ត.ក និង មាត្រា ៦(១) នៃកិច្ចព្រមព្រៀង យើងយល់ឃើញ ថា ក្នុងករណីនៃការខ្វែងយោបល់គ្នានេះ ការស៊ើបអង្កេតបឋម ជាចំណុច ផ្តើមមួយយ៉ាងសំខាន់ ដែលធ្វើឱ្យដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យសួរមានសុពលភាព។ ការដែលសហព្រះរាជអាជ្ញាអន្តរជាតិ បើកការស៊ើបអង្កេត បឋមដោយគ្មានការជូនដំណឹងជាមុន ឬ ការពិភាក្សាក្នុង ការសហការគ្នាជាមួយ សហព្រះរាជអាជ្ញាជាតិ គឺជាការរំលោភទៅលើច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង និងវិធានផ្ទៃក្នុង។ ផលវិបាក នៃការរំលោភខាងលើអាចមាន ក្នុងដំណើរការនីតិវិធីនៅដំណាក់កាលក្រោយមកទៀត នឹងមិនត្រូវយកមកពិចារណា ពាក់ព័ន្ធនឹង ករណីខ្វែងយោបល់ចំពោះមុខយើងឡើយ។*

**វិធាន ៦៧៖ ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត**

២៦១. សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយថាត្រូវចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់។ ដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាមិនចងសហចៅក្រមស៊ើបអង្កេតឡើយ។

២៦២. ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ យល់ឃើញថា សហចៅក្រមស៊ើបអង្កេត ទាំងពីរនាក់ ពុំមានជម្រើសអ្វីក្រៅពី ចេញដីកាដំណោះស្រាយរួមគ្នាមួយ ក្រោយបញ្ចប់ការស៊ើបសួរ។

២៦៣. ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ យល់ឃើញថា ប្រសិនបើកើតមានការខ្វែងគំនិតគ្នា សហចៅក្រមស៊ើបអង្កេតត្រូវអនុវត្ត ឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យបានត្រឹមត្រូវតាម នីតិវិធី គឺត្រូវតែឆ្លងកាត់នីតិវិធីតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង។ ការគេចវេសមិនឆ្លងកាត់វិធាន ៧២ គឺជាការបំពានឆន្ទានុសិទ្ធិឬការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនពុំបានត្រឹមត្រូវ។

២៦៤. វិធាន៦៧.១ ចែងយ៉ាងច្បាស់ថា នៅពេលបញ្ចប់កិច្ចស៊ើបសួរសហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាដំណោះស្រាយ តែមួយឬបញ្ជូនជនចោទទៅជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់។ ថ្វីត្បិតតែវិធានពុំបានហាម ការចេញដីកាដំណោះស្រាយពីរផ្ទុយក៏ដោយ ក៏តាមគោលការណ៍ច្បាប់ រឿងក្តីតែមួយមិនអាចមានដីកាដំណោះស្រាយពីរផ្ទុយគ្នាដូចករណី អោ អាន ឡើយ ទោះបីកិច្ចព្រមព្រៀង ច្បាប់អ.វ.ត.ក និង

វិធានផ្ទៃក្នុងបានបង្កើតអោយមានសហមន្ត្រី (សហព្រះរាជអាជ្ញា និង សហចៅក្រមស៊ើបអង្កេត) ក៏ដោយ ពីព្រោះថា វិធានផ្ទៃក្នុងបានកំណត់ វិធាន ៧២ សម្រាប់ដោះស្រាយករណីខ្វែងយោបល់គ្នា។

២៦៥. គួរកត់សម្គាល់ថា ប៉ុន្តែសហចៅក្រមស៊ើបអង្កេតពុំបានអនុវត្ត វិធាន ៧២ស្តីពីការខ្វែងយោបល់គ្នា ឲ្យបានត្រឹមត្រូវ តាមច្បាប់ទេ បែរជារំលងវិធាន ៧២ ហើយចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា គឺដីកាដំណោះស្រាយ លើកលែងចោទប្រកាន់ និងដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ។

២៦៦. ប្រសិនបើ សហព្រះរាជអាជ្ញាខ្វែងគំនិតគ្នា មុនសម្រេចចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ គំនិតខ្វែងនោះ ត្រូវដោះស្រាយតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង។

២៦៧. ដោយឡែកប្រសិនបើ សហចៅក្រមស៊ើបអង្កេត មានការខ្វែងគំនិតគ្នាមុននឹងសម្រេចចេញដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់) នោះ ត្រូវដោះស្រាយតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង ដល់វិធាន ៧៧.១៣។

២៦៨. ប្រសិនបើគេចចេញពីវិធាន ៧២ ដល់វិធាន ៧៧.១៣ នៃវិធានផ្ទៃក្នុង កិច្ចព្រមព្រៀង ច្បាប់ស្តីពី អ.វ.ត.ក និង វិធានផ្ទៃក្នុង ពុំបានចែងនិងពុំបានគ្រោងទុកនូវដំណោះស្រាយសមស្របដែលអាចអនុវត្តបានចំពោះផលវិបាកដែលកើតពីការគេចវេសនោះទេ។ ដូច្នេះ ករណីនេះជាចន្លោះប្រហោងនៃច្បាប់ ឬ ច្បាប់ពុំបានចែង ដែលគប្បីស្វែងរកដំណោះស្រាយ ដែលសមស្រប ដូចមានចែងក្នុងវិធាន២ នៃវិធានផ្ទៃក្នុងស្តីពីនីតិវិធីអនុវត្តសម្រាប់បញ្ហាចន្លោះប្រហោងនៅក្នុងវិធានផ្ទៃក្នុង។

២៦៩. ទន្ទឹមនឹងនេះ សហចៅក្រមស៊ើបអង្កេតជាតិបានលើកឡើង ក្នុងដីកាដំណោះស្រាយ កថាខណ្ឌ ៤៨៤ ដែលមានខ្លឹមសារថា៖ ជាសរុប ក្រោយពីបានពិនិត្យមើលសាវតានៃការស្វែងរកយុត្តិធម៌មុនការបង្កើត អ.វ.ត.ក ជំហររបស់ភាគីក្នុងកំឡុងពេលធ្វើច្បាប់ និងកិច្ចព្រមព្រៀង អ.វ.ត.ក ការបកស្រាយច្បាប់ព្រហ្មទណ្ឌតាមអត្ថន័យចង្អៀត យុត្តាធិការបែបជ្រើសរើស ខ្លឹមសារជាក់ស្តែងនៃច្បាប់ អ.វ.ត.ក ព្រមទាំងជំហររបស់ភាគី ជាពិសេសភាគីជាតិ តាំងពីមុនបង្កើត អ.វ.ត.ក ផ្តោតលើការផ្សះផ្សារជាតិ និងការស្វែងរកយុត្តិធម៌ វាទាមទារឲ្យមានការថ្លឹងថ្លែងដោយផ្តោតលើមេដឹកនាំជាន់ខ្ពស់ជាមុខសញ្ញា តិចតួច តូចចង្អៀត។ តំណាងរាជរដ្ឋាភិបាល ក្នុងអំឡុងពេលពិភាក្សាច្បាប់ នៅរដ្ឋសភាជាតិ បានបង្ហាញនូវជំហរនេះ។ សហចៅក្រមស៊ើបអង្កេត ទាំងជាតិនិងអន្តរជាតិ ធ្លាប់បានអះអាងនូវការគោរពស្មារតី នៃភាគីចចារបង្កើត អ.វ.ត.ក។

២៧០. ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ រម្លឹកថា៖ ក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០១៧ កថាខណ្ឌ ៣៥ ក្នុងសំណុំរឿង អ៊ឹម ចែម សហចៅក្រមស៊ើបអង្កេតបានលើកឡើងថា ដើម្បីបញ្ជាក់ឡើងវិញនូវសម្ដីដែលបានលើកឡើងខាងលើ គេបានដឹងអំពីចន្លោះប្រហោង នេះនៅក្នុងអំឡុងពេលចរចាររវាងភាគីជាតិ និងភាគីអន្តរជាតិ។ វាក៏ជាលក្ខណៈទូទៅនៃប្រព័ន្ធយុត្តាធិការ (ដែលមានលក្ខណៈ) អន្តរជាតិ ដែលបានបង្កើតឡើងដើម្បីបញ្ចប់ស៊ីណារីយ៉ូ ក្រោយជម្លោះតាមផ្លូវតុលាការអតីតពួកខ្មែរក្រហមទាំងមូល និងទំនងជាពុំពេញចិត្ត និងអយុត្តិធម៌សម្រាប់មនុស្សភាគច្រើន។ ទោះបីជាយ៉ាងនេះក្ដីចៅក្រមនៃ អ.វ.ត.ក ត្រូវគោរពតាមសេចក្ដីសម្រេចតាមផ្លូវនយោបាយរបស់អ្នកតាក់តែងច្បាប់ ក្រោយទទួលបានពត៌មានគ្រប់ជ្រុងជ្រោយ ហើយម្យ៉ាងទៀត ការងារនេះមិនត្រូវ និងមិនអាចប្រដូចនឹងសច្ចធារណ៍មានទោស ឬសច្ចធារណ៍ដោយស្វ័យប្រវត្តិនៃការទទួលខុសត្រូវខ្ពស់ចំពោះបុគ្គលដែល ត្រូវបាននាំមកចំពោះមុខតុលាការដោយសារការចោទប្រកាន់របស់ ក.ស.ព នោះឡើយ។

### ៤. ការខកខានពុំបានដាក់ក្រោមការពិនិត្យរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

២៧១. នៅក្នុងនីតិវិធីនៃសំណុំរឿង០០៤/២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសនីតិវិធីតាំងពីដំបូង ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដំណើរនីតិវិធី ដោយមិនគោរពតាមគោលការណ៍ពោលគឺមិនបានដាក់ អោ អាន ឱ្យស្ថិតនៅក្រោមការពិនិត្យនោះទេ។ ការណ៍នេះគឺខុសនឹងមាត្រា១២៦ នៃក្រមព្រហ្មទណ្ឌកម្ពុជា ព្រោះមាត្រានេះតម្រូវឱ្យចៅក្រមស៊ើបសួរត្រូវតែដាក់ឱ្យស្ថិតក្រោមការពិនិត្យនូវបុគ្គលដែលមានចង្អុលបង្ហាញប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ នេះចាត់ទុកជាកំហុសនីតិវិធីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

### ៥. កំហុសនីតិវិធីប្រឆាំងនឹងមាត្រា១២៧ នៃក្រមព្រហ្មទណ្ឌ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

២៧២. សំណុំរឿង ០០៤/២ នេះ សហចៅក្រមស៊ើបសួរអន្តរជាតិពិតជាបានដឹងអំពីការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាអន្តរជាតិ និងសហព្រះរាជអាជ្ញាជាតិ ហើយតាមមាត្រា១២៧ នៃក្រមព្រហ្មទណ្ឌសហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវធ្វើការស៊ើបអង្កេតទាំងដាក់បន្ទុក និងដោះបន្ទុក។ ប៉ុន្តែជាក់ស្ដែង ពុំមានភស្តុតាងណាមួយបញ្ជាក់ថាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានធ្វើការស៊ើបអង្កេតដោះបន្ទុកឡើយពោលគឺសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានស៊ើបអង្កេតតែទៅលើអង្គហេតុ ហើយមិនអើពើនឹងការយល់ឃើញរបស់សហព្រះរាជអាជ្ញាជាតិស្ដីអំពីយុត្តាធិការបុគ្គលនោះឡើយ។ ដូច្នេះហើយការបំពេញកិច្ច

ស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពុំបានបំពេញតួនាទីរបស់ខ្លួនបានគ្រប់ជ្រុងជ្រោយនោះទេ។

## ៦. ការអនុវត្តជាក់ស្តែងរបស់សហចៅក្រមស៊ើបអង្កេត

### ក. ដីកាដំណោះស្រាយលើកលែងចោទរបស់សហចៅក្រមស៊ើបអង្កេតជាតិ

២៧៣. សហចៅក្រមស៊ើបអង្កេតជាតិ មិនបានឯកភាពដាក់អោ អានឱ្យស្ថិតក្រោមការពិនិត្យទេ[331]។ សហចៅក្រមស៊ើបអង្កេតជាតិបានពិចារណាផ្តោតទៅលើថាតើ អោ អាន ស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែរ ឬទេ? លក្ខណៈពិសេសនៃកិច្ចព្រមព្រៀង និងច្បាប់ស្តីពី អ.វ.ត.ក ផ្ទុះបញ្ចាំងពីយុត្តាធិការជ្រើសរើស។ អង្គហេតុដែលត្រូវបានប្តឹងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ជាសត្យានុម័តពិតជាមាន ទោះបីជាយ៉ាងនេះក្តី ដីកាដំណោះស្រាយនេះត្រូវបានចេញដោយផ្អែកលើភស្តុតាង ដែលបានមកពីលទ្ធផលនៃការស៊ើបអង្កេតស្របច្បាប់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតលើអង្គហេតុទាំងអស់[332]។

២៧៤. សហព្រះរាជអាជ្ញាអន្តរជាតិ បានបើកការស៊ើបអង្កេតបឋមដោយឯកឯង ខណៈបរិបទច្បាប់នៅ អ.វ.ត.ក គោលការណ៍ "សហ" ត្រូវបានក្លាយជាចំណងតាមផ្លូវច្បាប់ជាលក្ខខណ្ឌកំណត់ ទោះបីជាស្ថិតក្នុងដំណាក់កាល ស.ព ក៏ដោយ ស.ព ត្រូវតែធ្វើរួមគ្នា[333]។ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ស.ព.អ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរជាអត្តនោម័តតែម្នាក់ឯង ក្នុងក្របខ័ណ្ឌនៃសំណុំរឿងនេះដោយបានចោទ អោ អាន ឱ្យទទួលខុសត្រូវ ចំពោះឧក្រិដ្ឋកម្មដែលស្ថិតក្រោមយុត្តាធិការ អ.វ.ត.ក។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ មិនត្រូវបានចាត់ការដោយ ស.ច.ស ភ្លាមទេ ដោយហេតុថាទន្ទឹមគ្នានោះ ស.ព.ជ បានប្តឹងជំទាស់ឱ្យពិចារណាលើបញ្ហានៃការខ្វែងយោបល់ ដែលជាកម្មវត្ថុនឹងត្រូវបានបញ្ជូនទៅ អ.ប.ជ។ ជាលទ្ធផល អ.ប.ជ រកសម្លេងមិនបាន ដែលការណ៍នេះជាផលវិបាកផ្អែកគតិយុត្តក្នុងបរិបទ អ.វ.ត.ក ដែលនាំឱ្យដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមានអនុភាពគតិយុត្តកើតឡើង។ បន្ទាប់មក ស.ព.អ ស្តីទីបានបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមក ស.ច.ស សុំឱ្យបំពេញកិច្ចស៊ើបសួរទៅលើអង្គហេតុក្នុងសំណុំរឿងលេខ០០៤ ហើយក្រោយមកត្រូវបានបំបែកជាសំណុំរឿងលេខ ០០៤/២។[334]

[331] ដីកាដំណោះស្រាយ (លើកលែងចោទ) ឯកសារលេខ D359 កថាខណ្ឌ១។

[332] ដីកាដំណោះស្រាយ (លើកលែងចោទ) ឯកសារលេខ D359 កថាខណ្ឌ២។

[333] ដីកាដំណោះស្រាយ (លើកលែងចោទ) ឯកសារលេខ D359 កថាខណ្ឌ១៤។

[334] ដីកាដំណោះស្រាយ (លើកលែងចោទ) ឯកសារលេខ D359 កថាខណ្ឌ១៥។

២៧៥. នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ ស.ច.ស.អ បានធ្វើនីតិវិធីនៃការបង្ហាញខ្លួនលើកដំបូង ដោយដាក់ អោ អាន ឱ្យស្ថិតនៅក្រោមការពិនិត្យ ប៉ុន្តែ ចំណាត់ការនៃកិច្ចនីតិវិធីនេះត្រូវបានរងនូវការខ្វែងយោបល់ពីសំណាក់ ស.ច.ស.ជ ដោយផ្អែកលើវិធាន ៧២ ចំនុចទី១ នៃវិធានផ្ទៃក្នុង។[335] ស.ច.ស.ជ មិនបានឯកភាពនូវការសម្រេចដាក់ អោ អាន ឱ្យស្ថិតនៅក្រោមការពិនិត្យទេ ពីព្រោះថា ស.ច.ស.ជ នៅតែយល់ឃើញថា បើតាមលទ្ធផលដែលទទួលបានពីការស៊ើបសួរ នៅតែមានវិមតិសង្ស័យលើឈ្មោះ អោ អាន ពាក់ព័ន្ធនឹងបញ្ហាយុត្តាធិការបុគ្គល ដើម្បីដាក់ឈ្មោះនេះឱ្យស្ថិតនៅក្រោមការពិនិត្យ។ បញ្ហាយុត្តាធិការបុគ្គលលើ អោ អាន ជាបញ្ហាអាទិភាពបំផុតមួយ ដែលជាកម្មវត្ថុនៃការពិចារណាមុននឹងចំណាត់ការលើកិច្ចផ្សេងទៀតសម្រាប់បរិបទច្បាប់នៅ អ.វ.ត.ក ជាយុត្តាធិការជ្រើសរើស។[336]

២៧៦. ការសម្រេចបើកការស៊ើបអង្កេតលើបុគ្គលណាមួយជាឆន្ទានុសិទ្ធិរបស់ ស.ច.ស។[337] ក្រោយពីទទួលបាន ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ សហចៅក្រមស៊ើបអង្កេត អាចធ្វើការអង្កេត និងមិនទាន់ដាក់ជនណាមួយក្រោមការពិនិត្យភ្លាមទេ។ ជនត្រូវចោទអាចត្រូវបានហៅមកឆ្លើយ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត។ ក្នុងដំណាក់កាលនេះសហចៅក្រមស៊ើបអង្កេត អាចចម្រេចលើកលែងចោទប្រកាន់។ ជាគោលការណ៍ចៅក្រមស៊ើបអង្កេតនឹងមិនបញ្ជូនទៅជំនុំជម្រះទេ ប្រសិនបើមិនបានដាក់ឱ្យស្ថិតក្រោមការពិនិត្យជាមុន ដោយសារ ជនត្រូវចោទមិនទាន់ត្រូវបានជូនដំណឹងជាមុន អំពីបទចោទប្រកាន់ ដែលនាំឱ្យសាមីជនត្រូវចោទ មានពេលវេលា និងពិចារណានូវមធ្យោបាយការពារខ្លួន ដើម្បីឆ្លើយតបចំពោះបទចោទ។ ការបញ្ជូនទៅជម្រះក្នុងករណីនេះ នឹងនាំឱ្យមានការរំលោភសិទ្ធិទទួលការកាត់សេចក្តីដោយយុត្តិធម៌។[338]

២៧៧. អ.វ.ត.ក ត្រូវបានបង្កើតឡើងតាមរយៈកិច្ចព្រមព្រៀងរវាង រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។ អ.វ.ត.ក ជាតុលាការពិសេសហើយអនុលោមតាមគោលបំណងរបស់អ.វ.ត.ក មានតែបុគ្គលពីរប្រភេទដែលស្ថិតក្នុងយុត្តាធិការ។ អាស្រ័យហេតុនេះ ខុសពីតុលាការជាតិ ស.ច.ស ត្រូវគិតជាបឋមសិនថាតើបុគ្គលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរជាជនស្ថិតក្នុងសមត្ថកិច្ចរបស់ អ.វ.ត.ក ដែរឬទេ? មុននឹងសម្រេចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ។ ស.ច.ស ត្រូវពិចារណា ឱ្យបានហ្មត់ចត់ និង ពេញលេញ មុនសម្រេចដាក់បុគ្គលណាមួយស្ថិតនៅក្រោមការពិនិត្យ។ ក្នុងន័យនេះ ស.ច.ស ដូចដែលបាន

---

335 ដីកាដំណោះស្រាយ (លើកលែងចោទ) ឯកសារលេខ D359 កថាខណ្ឌ១៦។

336 ដីកាដំណោះស្រាយ (លើកលែងចោទ) ឯកសារលេខ D359 កថាខណ្ឌ១៧។

337 ដីកាដំណោះស្រាយ (លើកលែងចោទ) ឯកសារលេខ D359 កថាខណ្ឌ៧០។

338 ដីកាដំណោះស្រាយ (លើកលែងចោទ) ឯកសារលេខ D359 កថាខណ្ឌ៧១។

និយាយពីខាងដើមមានឆន្ទានុសិទ្ធិ ក្នុងការសម្រេច ដោយអនុលោមតាមគោលការណ៍ឯករាជ្យភាព និងមិនតម្រូវឱ្យសម្រេចភ្លាមៗនោះទេ នូវការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ។[339] ចៅក្រមស៊ើបសួរមិនអាចបញ្ជូនជនណាម្នាក់ទៅជំនុំជម្រះ ដោយមិនបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យជាមុនឡើយ។ យុត្តិសាស្ត្ររបស់តុលាការកំពូលបារាំងធ្លាប់បានបញ្ជាក់ដែរថា "ចៅក្រមស៊ើបសួរ មុននឹងចេញដីកាដំណោះស្រាយ ជាការលើកលែងចោទ ចៅក្រមស៊ើបសួរពុំចាំបាច់ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ឬការស្តាប់ចម្លើយជននោះឡើយ ប្រសិនបើចៅក្រមស៊ើបសួរយល់ថាពិរុទ្ធភាពនៃជននោះនឹងមិនត្រូវបានរកឃើញ"។[340]

២៧៨. ការមិនដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យលើបុគ្គលណាមួយ ហើយចុងបញ្ចប់បញ្ជូនគាត់ទៅទទួលការជំនុំជម្រះក្តី អាចបំពារបំពានដល់សិទ្ធិទាំងនេះ ដោយសារជនត្រូវចោទមិនមានឱកាសអនុវត្តសិទ្ធិ ជាលទ្ធផលនាំឱ្យសវនាការមិនមានភាពយុត្តិធម៌ទេ។ ការសម្រេចដាក់ជនត្រូវចោទណាមួយ ឱ្យស្ថិតនៅក្រោមការពិនិត្យ នឹងរុញកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌឱ្យដើរទៅមុខ ហើយតុលាការនឹងចំណាយពេលវេលាព្រមទាំងធនធាន ដើម្បីបំពេញតាមកិច្ចនីតិវិធីតម្រូវដោយច្បាប់។[341]

២៧៩. សហចៅក្រមស៊ើបអង្កេតជាតិបានសន្និដ្ឋានរួមថា៖ ក្រោយពីបានបង្ហាញពីតួនាទី អំណាច និងការចូលរួមរបស់ អោ អាន ទំនាក់ទំនងរវាង អោ អាន និង កែ ពក ព្រមទាំងអំណាច កែ ពក ជាលេខាភូមិភាគ ការប្រៀបធៀបអំណាចតួនាទី និងការចូលរួមរបស់ ឌុច និង អោ អាន គោលនយោបាយ និងរចនាសម្ព័ន្ធនៃអំណាចរបស់របបកម្ពុជាប្រជាធិបតេយ្យ និងប្រវត្តិ ព្រមទាំងចេតនានៃភាគីធ្វើកិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក យើងសន្និដ្ឋានថា៖ ក.តួនាទីរបស់ អោ អាន មិនមានការតែងតាំងជាផ្លូវការទេ។ ការចូលរួមសកម្មភាពការងារធ្វើឡើង តាមតួនាទី និងការទទួលខុសត្រូវ មិនមានអំណាចជាក់ស្តែង (De facto)ទេ។ គាត់ត្រូវបានធ្វើឡើង តាមបញ្ជា និងការណែនាំរបស់ កែ ពក ដែលស្ថិតនៅគ្រប់គ្រងដឹកនាំភូមិភាគកណ្តាលជាប្រចាំ ផ្ទាល់ ឬប្រយោល ទោះបីជាគាត់មានបេសកកម្ម នៅភូមិភាគបូព៌ាម្តងម្កាល ក្នុងរយៈពេលខ្លីក៏ដោយ។ កែ ពក មានអំណាច និងឥទ្ធិពល ហើយក៏ជាបុគ្គលតែម្នាក់គត់ ក្នុងកម្រិតភូមិភាគដែលរស់រានមានជីវិតក្នុងបរិបទវិសុទ្ធកម្មនៅភូមិភាគកណ្តាល។[342]

២៨០. ការចូលរួមសកម្មភាពរបស់អោ អាន ក្នុងឋានៈ ជាលេខាតំបន់ ៤១ នៃភូមិភាគកណ្តាលក្នុងរយៈ

---

[339] ដីកាដំណោះស្រាយ (លើកលែងចោទ) ឯកសារលេខ D359 កថាខណ្ឌ៧៣។

[340] ដីកាដំណោះស្រាយ (លើកលែងចោទ) ឯកសារលេខ D359 កថាខណ្ឌ៧៤។

[341] ដីកាដំណោះស្រាយ (លើកលែងចោទ) ឯកសារលេខ D359 កថាខណ្ឌ៧៦។

[342] ដីកាដំណោះស្រាយ (លើកលែងចោទ) ឯកសារលេខ D359 កថាខណ្ឌ៥៥២។

ពេលខ្លី ក្នុងបរិបទវិសុទ្ធកម្មរបស់បក្ស ដែលកម្មាភិបាលគ្រប់ជាន់ថ្នាក់បានចូលរួម។ ប្រសិនបើមានការប្រឆាំងជំទាស់ នឹងមិនរួចផុតពីសេចក្ដីស្លាប់ឡើយ។ ការចូលរួមរបស់ អោ អាន មិនមានស្វ័យភាព មិនសកម្ម គ្មានគំនិតផ្ដួចផ្ដើម និងមិនកៀកកិតនឹងការប្រព្រឹត្តបទល្មើស ដែលនេះមានភាពខុសស្រឡះយ៉ាងខ្លាំងជាមួយនឹងការចូលរួមយ៉ាងសកម្មកៀកកិត និងផ្ដួចផ្ដើមរបស់ឌុច។ បន្ថែមលើនេះ អោ អាន មិនបានចូលរួមធ្វើគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាឡើយ។[343]

## ខ. ការយល់ឃើញរបស់ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះលើដីកាលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ

២៨១. ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ ធ្លាប់បានពិចារណាលើសេចក្ដីសម្រេចក្នុងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង អ៊ឹម ចែម (អង្គបុរេជំនុំជម្រះ ៥០) ថាអ.វ.ត.ក ជាតុលាការពិសេសមួយដែលអនុវត្តនីតិវិធីនៃការចោទប្រកាន់ និងការស៊ើបសួរខុសពីតុលាការថ្នាក់ជាតិ។ ការចោទប្រកាន់ និងការស៊ើបសួររបស់តុលាការថ្នាក់ជាតិ គឺធ្វើឡើងតែអង្គហេតុ មានន័យថាចៅក្រមស៊ើបសួរ ទទួលបណ្ដឹងអំពីអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា[344]។ ផ្ទុយមកវិញ នៅអ.វ.ត.ក ការចោទប្រកាន់អាចធ្វើទៅបានលុះត្រាតែបំពេញបានលក្ខខណ្ឌ២ គឺ១. អង្គហេតុ-ឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរអន្តរជាតិ និងទំលាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងពីថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ និង ទី២.បុគ្គល ដែលជាមេដឹកនាំជាន់ខ្ពស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងជាជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម[345]។

២៨២. ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ យល់ឃើញថាចៅក្រមស៊ើបអង្កេតជាតិ បានអនុវត្តនីតិវិធីស៊ើបអង្កេតបានគ្រប់ជ្រុងជ្រោយដោយឈរលើមូលដ្ឋាននៃការខ្វែងគំនិតគ្នារវាងសហព្រះរាជអាជ្ញា ហើយតាមលទ្ធផលនៃការស៊ើបអង្កេត អោ អាន ស្ថិតនៅជាជនសង្ស័យ។ ដូច្នេះដីកាលើកលែងចោទប្រកាន់ អោ អាន របស់សហចៅក្រមស៊ើបអង្កេតជាតិ ដែលបានសម្រេចសេចក្ដីមកនេះមានលក្ខណៈត្រឹមត្រូវតាម អង្គច្បាប់

---

[343] ដីកាដំណោះស្រាយ (លើកលែងចោទ) ឯកសារលេខ D359 កថាខណ្ឌ៥៥៣។

[344] មាត្រា៤៤ និងមាត្រា១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[345] មាត្រា ១ នៃច្បាប់ស្ដីពីអ.វ.ត.ក មាត្រា១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងប្រទេសកម្ពុជា និងវិធាន៥៣ នៃវិធានផ្ទៃក្នុង។

01634892



ដែលគប្បីតម្កល់ទុកជាបានការ។

## គ. ដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

២៨៣. ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានលើកអំពីខ្លឹមសារនៃកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើតអ.វ.ត.ក និងការពិចារណាពាក្យថា មេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតរបស់អង្គជំនុំជម្រះតុលាការកំពូល (អ.ជ.ត.ក)។ ក្នុងកថាខណ្ឌ ៤៩ ដល់៥២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកត់សម្គាល់ឃើញថា ដោយប្រើប្រាស់និយមន័យដែលបានកំណត់នៅក្នុងសាលដីការបស់ខ្លួនក្នុងសំណុំរឿង ០០១ អ.ជ.ត.ក ក៏បានសម្រេចដោយប្រយោលថា ពុំមានមូលដ្ឋានទេ ចំពោះការអះអាងក្នុងន័យប្រវត្តិសាស្ត្រ និងនយោបាយដែលថា ការចរចាអំពីការបង្កើត អ.វ.ត.ក នាំឱ្យមានការយល់ឃើញជារួម និងត្រូវជាប់កាតព្វកិច្ចថា មានតែបុគ្គល (មានឈ្មោះ) មួយចំនួនប៉ុណ្ណោះ ដែលត្រូវស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ។ ពោលគឺ ការជ្រើសរើសយកបុគ្គលមួយចំនួនមកធ្វើការស៊ើបអង្កេត និងចោទប្រកាន់បញ្ជូនទៅជំនុំជម្រះកាលពីពេលមុន និងឥឡូវនេះ គឺជាបញ្ហាសិទ្ធិសុទ្ធសាធរបស់ ក.ស.ព និង ក.ស.ច.ស ហើយផ្អែកទាំងស្រុងទៅលើអង្គសេចក្តីនៃរឿងក្តីនីមួយៗ។[346] ទាំងក.ស.ព ទាំង ស.ច.ស មានសេរីភាពបដិសេធកិច្ចសន្យានយោបាយបែបនេះក្នុងរបៀបណាដែលរឹតត្បិតឆន្ទានុសិទ្ធិរបស់ ក.ស.ព និង ស.ច.ស ដែលមានចែងក្នុងច្បាប់ជាធរមាន។[347]

២៨៤. អ.វ.ត.ក មានយុត្តាធិការបុគ្គលលើអោ អាន។ អោ អានគឺជាមន្ត្រីខ្មែរក្រហមម្នាក់នៅក្នុងរយៈពេលនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក និងនៅក្នុងអំឡុងពេលដែលបទល្មើសបានកើតឡើង ដោយអោ អាន ត្រូវបានចោទថាជាអ្នកបង្កឡើង។ អោ អាន ប្រហែលជាមិនទាន់ដល់ឋានៈជាមេដឹកនាំជាន់ខ្ពស់ ប៉ុន្តែ អោ អាន ពិតជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវបំផុត។ ហេតុនេះ នៅដំណាក់កាលនេះ មិនចាំបាច់ត្រូវដោះស្រាយទាំងស្រុងលើបញ្ហាឋានៈជាមេដឹកនាំខ្ពស់ ដើម្បីកំណត់យុត្តាធិការបុគ្គលទេ។[348]

២៨៥. ដីកាដំណោះស្រាយដដែលខាងលើក្នុងកថាខណ្ឌ ៨៥៤ បានលើកឡើងថា "ហេតុផលបន្ថែមមួយទៀតក្នុងការមិនចេញដីកាឃុំខ្លួននាពេលនេះ គឺភាពមិនប្រាកដប្រជានៃនីតិវិធី ដែលបណ្តាលមកពីមានដីកា

[346] ដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារលេខ D360 កថាខណ្ឌ ៥៦។

[347] ដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៦៩៩។

[348] ដីកាដំណោះស្រាយ (បញ្ជូនទៅជំនុំជម្រះ) ឯកសារ D360 កថាខណ្ឌ ៦៩៧។

ដំណោះស្រាយពីរផ្ទុយគ្នា ដែលជាមូលហេតុធ្វើឲ្យមិនមានភាពច្បាស់លាស់យោងវិធានផ្ទៃក្នុង ៧៧(១៣) ថាតើការចោទប្រកាន់នឹងត្រូវដំណើការទៅមុខក្នុងករណីមិនមានមតិភាគច្រើនលើសលុប នៅក្នុងពេលមានឧទ្ធរណ៍ ទៅដល់អង្គបុរេជំនុំជម្រះ ឬយ៉ាងណា ... ដោយផ្អែកទៅលើអង្គហេតុទាំងឡាយដែលបានលើកឡើងនៅក្នុងកថាខណ្ឌ ១៥៧ ដល់៥៨៩ ត្រូវដាក់ទណ្ឌកម្មយោងមាត្រា ៣(ថ្មី) ២៩ និង៣៩ នៃច្បាប់ អ.វ.ត.ក និងមាត្រា ៥០១ និង៥០៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦"។[349]

## ឃ. ការយល់ឃើញរបស់អង្គបុរេជំនុំជម្រះ ចំពោះដីការដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

២៨៦. ការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមាននិយមន័យច្បាស់លាស់លើពាក្យថា មេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតទេ។ ជាមួយគ្នានេះដែរ នៅក្នុងឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ និង ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨ អំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នាពាក់ព័ន្ធជាពិសេសទៅលើយុត្តាធិការបុគ្គល ពុំមានការផ្តល់និយមន័យច្បាស់លាស់ឡើយ។

២៨៧. នៅក្នុងឯកសារដដែលនោះ ចំនុច ឃ ដែលស្តីអំពីមេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត កថាខណ្ឌ ២៩ និយាយថា៖ ប៉ុន្តែនៅក្នុងខណៈដែលវាច្បាស់ណាស់ថា អ.វ.ត.ក មានយុត្តាធិការទៅលើមេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត គេមិនច្បាស់ទាល់តែសោះ ថាតើពាក្យទាំងនោះមានអត្ថន័យយ៉ាងដូចម្តេច។ ពាក្យទាំងនេះមិនបានផ្តល់និយមន័យច្បាស់លាស់នៅក្នុងច្បាប់អ.វ.ត.ក ទេ ហើយមិនបានកំណត់និយមន័យនៅក្នុងមាត្រា១ នៃកិច្ចព្រមព្រៀងអ.វ.ត.ក នោះដែរ ដែលភាសាស្រដៀងគ្នាយ៉ាងខ្លាំងនេះត្រូវបានប្រើប្រាស់។ វិធានផ្ទៃក្នុងក៏មិនបានផ្តល់និយមន័យណាមួយ ហើយក៏គ្មានអង្គតុលាការណាមួយនៅអ.វ.ត.ក បានសម្រេចថាអត្ថន័យ "មេដឹកនាំជាន់ខ្ពស់" និង "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" មានន័យយ៉ាងណានោះដែរ។ ប៉ុន្តែអត្ថន័យនៃពាក្យមេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតអាចទាញចេញពី ទី១. ប្រវត្តិនៃការចារចាច្បាប់អ.វ.ត.ក និង ២. សេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌដទៃទៀតដែលបានបកស្រាយពាក្យស្រដៀងគ្នានេះ។

២៨៨. ក្នុងដីកាដំណោះស្រាយ កថាខណ្ឌ៦៩៩ ត្រង់សំអាងហេតុ អង្គច្បាប់អំពីយុត្តាធិកាបុគ្គល ឃ្លាចុង

[349] ដីកាដំណោះស្រាយ (បញ្ជូនទៅជំនុំជម្រះ) ឯកសារ D360 កថាខណ្ឌ ៨៥៤។

ក្រោយលើកឡើងថា៖ ត្រង់ន័យនោះ ច្បាស់ជាត្រឹមត្រូវដែលទទួលយកឥទ្ធិពលពីតួអង្គនយោបាយ អំពីបញ្ជីឈ្មោះជនដំបូង ដែលត្រូវស៊ើបអង្កេត នៅពេលចាប់ផ្តើមមានវត្តមាន អ.វ.ត.ក ប៉ុន្តែទាំង ក.ស.ព និងស.ច.ស មានសេរីភាពបដិសេធកិច្ចសន្យានយោបាយបែបនេះក្នុងរបៀបណាដែលរឹតត្បិតឆន្ទានុសិទ្ធិរបស់ ក.ស.ព និងស.ច.ស ដែលមានចែងនៅក្នុងច្បាប់ជាធរមាន។

២៨៩. ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ យល់ឃើញថា ការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថាកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ជាកិច្ចសន្យានយោបាយ គឺជាការភាន់ច្រលំ ពីព្រោះថា៖ យោងតាមស្មារតីនៃដំណើការនៃការតាក់តែង ពិភាក្សារហូតដល់មានកិច្ចព្រមព្រៀង គឺអ្នកច្បាប់តំណាងរាជរដ្ឋាភិបាលកម្ពុជា និង អ្នកច្បាប់តំណាងអង្គការសហប្រជាជាតិ បានបង្កើតបទដ្ឋានហិតូបករណ៍ច្បាប់ តាមរយៈកិច្ចព្រមព្រៀងនេះ ដែលបានកំណត់ពីវិសាលភាពនៃសមត្ថកិច្ចរបស់ អ.វ.ត.ក ក្នុងការបង្កើតច្បាប់ផ្សេងៗទៀត។ ក្នុងន័យនេះ កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិ មិនមែនជាទម្រង់កិច្ចសន្យានយោបាយដូចការលើកឡើងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិនោះទេ[350] ព្រោះពាក្យដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ប្រើគឺផ្ទុយទៅនឹងខ្លឹមសារដើមនៃកិច្ចព្រមព្រៀង ដោយហេតុថា កិច្ចសន្យាគឺជាពាក្យប្រើក្នុងន័យទំនាក់ទំនងរដ្ឋប្បវេណីដែលខុសពីកិច្ចព្រមព្រៀងដែលលើកឡើងខាងលើ។

២៩០. ដូច្នេះ ទាំងសហព្រះរាជអាជ្ញាអន្តរជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវតែគោរពតាមខ្លឹមសារ នៃកិច្ចព្រមព្រៀងដែលបានលើកឡើងខាងលើជាដាច់ខាត។ ម្យ៉ាងវិញទៀត ការប្រើឆន្ទានុសិទ្ធិរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការបកស្រាយឬពន្លាត និងប្រើប្រាស់ពាក្យពេចន៍ ត្រូវតែបកស្រាយក្នុងន័យចង្អៀត និងប្រើពាក្យពេចន៍ឱ្យត្រូវតាមពាក្យបច្ចេកទេសច្បាប់ ជាដាច់ខាត (ឃ្លាចុងក្រោយនៃកថាខណ្ឌ ៦៩) ។

២៩១. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានប្រើប្រាស់ខ្លឹមសារនៃការចរចាមួយភាគតូចដែលពុំបានឆ្លុះបញ្ចាំងពីការពិតនៃគោលគំនិតរបស់អ្នកតាក់តែងកិច្ចព្រមព្រៀង និងច្បាប់អ.វ.ត.កទាំងស្រុងទេ ហើយផ្អែកតែទៅលើអង្គហេតុទាំងស្រុង ដោយពុំបានអើពើទៅលើគោលការណ៍នៃការចោទប្រកាន់ និងការស៊ើបសួរដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង ច្បាប់ស្តីពីអ.វ.ត.ក វិធានផ្ទៃក្នុង និងបុព្វកថា ហើយទីបំផុតសម្រេចចោទប្រកាន់ អោ អាន និងបញ្ជូនទៅជំនុំជម្រះដោយខុសច្បាប់ ។

---

[350] ដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D360 កថាខណ្ឌ ៦៩៩។

២៩២. ម្យ៉ាងទៀតក្នុងដីកាដំណោះស្រាយ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំបានលើកឡើងអំពីលទ្ធផលនៃការស៊ើបអង្កេតលើយុត្តាធិការបុគ្គលទេ ហើយផ្តោតតែទៅលើអង្គហេតុ។ ហើយបើធ្វើការស៊ើបអង្កេតតាមរបៀបនេះ រាល់មន្ត្រីខ្មែរក្រហមទាំងអស់នឹងក្លាយជាកម្មវត្ថុនៃការយកមកកាត់ទោសនៅអ.វ.ត.ក។ ប៉ុន្តែហេតុអ្វីបានជាមានតែអោ អាន និង ជនត្រូវចោទក្នុងសំណុំរឿង ០០៣/០០៤ ដែលត្រូវបាននាំយកមកកាត់ទោស។ តើទង្វើបែបនេះ សមស្របតាមកស្មារតីនៃកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើតអ.វ.ត.ក ដែរឬទេ? សកម្មភាពរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្ទុយទៅនឹងកម្មវត្ថុនៃការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាទាំងពីរ ត្រង់ថាកម្មវត្ថុនៃការខ្វែងនោះ គឺយុត្តាធិការបុគ្គល មិនមែនអង្គហេតុនោះឡើយ។

២៩៣. ចំណាត់ការរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏បានផ្ទុយផងដែរទៅនឹង គំនិតនៃអ្នកតាក់តែងច្បាប់ រចនាសម្ព័ន្ធដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យ យុត្តិសាស្ត្រអន្តរជាតិ និងការអះអាងរបស់ខ្លួនកន្លងមក។[351]

២៩៤. ជាសរុប ដីកាសម្រេចបញ្ជូន អោ អាន ទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលបានសម្រេចសេចក្តីមកនេះ មានកំហុសអង្គច្បាប់ ដែលគប្បីបដិសេធចោល។

## ង. គោលការណ៍ច្បាប់

### ១. ចន្លោះប្រហោងនៃច្បាប់

២៩៥. ក្នុងសំណុំរឿងនេះ ឃើញថាសហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយពីរដែលមានអត្ថន័យផ្ទុយគ្នា ហើយដែលមិនមានច្បាប់កំណត់សម្រាប់ដោះស្រាយក្នុងករណីបែបនេះឡើយ។ ដូច្នេះបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទាំងពីរនេះ គឺជាបណ្តឹងដែលស្ថិតក្នុងករណីចន្លោះប្រហោងនៃច្បាប់ ឬពុំមានច្បាប់ចែង។

### ២. គោលការណ៍នៃការបកស្រាយច្បាប់

២៩៦. ដើម្បីធានាបាននូវគោលការណ៍នីត្យានុកូលភាព ការបកស្រាយច្បាប់គប្បីត្រូវធ្វើឡើងដោយតឹងរ៉ឹងមិនបកស្រាយតាមបែបសទិសភាពនោះឡើយ។ មាត្រា៥ នៃក្រមព្រហ្មទណ្ឌ ការបកស្រាយច្បាប់ ពិសេសច្បាប់ព្រហ្មទណ្ឌ ត្រូវមានគោលការណ៍នៃការបកស្រាយយ៉ាងច្បាស់លាស់ ហើយចៅក្រមមិនអាចបក

[351] ដីកាដំណោះស្រាយ (លើកលែងលចោទ) ឯកសារ D359 កថាខណ្ឌ៤៨៤។

ស្រាយតាមបែបពង្រីកវិសាលភាពនោះទេ និងមិនអាចបកស្រាយតាមបែបសទិសភាព។

២៩៧. ក្នុងករណីដែលពុំមានច្បាប់ចែងដូច្នេះ ចៅក្រមគប្បីពិនិត្យមើលទៅលើស្មារតីរបស់អ្នកតាក់តែងវិធានផ្ទៃក្នុង ថាតើពួកគេបានប្រមើលមើលឃើញដល់ករណីដែលអាចនឹងមានដីកាដំណោះស្រាយពីរបែបនេះ ហើយជាចេតនារបស់អ្នកតាក់តែងច្បាប់ ទុកឱ្យវាចន្លោះបែបនេះ ឬពួកគេពុំបានទឹកដល់នោះទេ។ ក្រៅអំពីចេតនារបស់អ្នកតាក់តែងវិធានផ្ទៃក្នុង យើងត្រូវពិនិត្យទៅលើគោលបំណងនៃការបង្កើតអ.វ.ត.ក នេះផងដែរ ដូចមានចែងនៅក្នុង គោលដៅរបស់ អ.វ.ត.ក.។

## ៣. គោលការណ៍នីត្យានុកូលភាព

២៩៨. លោកចៅក្រម Scalia[352] ជាអតីតចៅក្រមតុលាការកំពូលសហរដ្ឋអាមេរិក បានបញ្ជាក់ថាការបកស្រាយច្បាប់ គប្បីបកស្រាយទៅតាមគោលគំនិតរបស់អ្នកតាក់តែងច្បាប់ នាពេលច្បាប់នោះបង្កើត ពុំមែនបកស្រាយដោយពឹងផ្អែកលើវចនានុក្រម បកស្រាយតាមពាក្យពេជន៍ ឬគោលនយោបាយនាពេលបច្ចុប្បន្ននោះឡើយ។ ប្រសិនបើមិនធ្វើការបកស្រាយតាមចេតនារបស់អ្នកតាក់តែងច្បាប់ទេ នោះគោលការណ៍នីត្យានុកូលភាពនឹងមិនត្រូវបានបំពេញនោះឡើយ។ ហើយទន្ទឹមនឹងនេះ គោលការណ៍ចម្បងដែលត្រូវលើកយកមកពិចារណានោះ គឺគោលការណ៍វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ។

## ៤. ភាពច្បាស់លាស់នៃច្បាប់

២៩៩. លោកGustav Radbruch ជាទស្សនវិទូច្បាប់ បានចាត់ទុក Legal certainty (ភាពច្បាស់លាស់នៃច្បាប់), យុត្តិធម៌ និង Purposiveness (គោលដៅ) ជាសរសរស្តម្ភ នៃច្បាប់។ នៅក្នុងប្រពន្ធ័ច្បាប់អឺរ៉ុប (European Union Law) ភាពច្បាស់លាស់នៃច្បាប់ ជាតម្រូវការមួយដ៏សំខាន់ដែលមិនអាចខ្វះបាន។ ច្បាប់ ដាច់ខាតត្រូវតែច្បាស់លាស់ ក្នុងកម្រិតមួយអនុញ្ញាតឱ្យមនុស្ស ប្រសិនបើចាំបាច់ និង ក្រោមការណែនាំដ៏ត្រឹមត្រូវ អាចប្រមើលមើលដឹងអំពីលទ្ធផលនៃអំពើរបស់ខ្លួន។ ប៉ុន្តែក្នុងករណីយើងនេះ មិនមានភាពច្បាស់លាស់ណាមួយដែលអនុញ្ញាតឱ្យជនត្រូវចោទអាចប្រមើលមើលដឹងអំពីជោគវាសនារបស់ខ្លួននោះឡើយ។ ប្រសិនបើយើងអនុញ្ញាតឱ្យមានការបន្តសំណុំរឿងនេះទៅមុខ ដោយមិនអើពើនឹងដីកាលើកលែងចោទនោះ មានន័យថាយើងកំពុងតែមើលរំលងគោលការណ៍មួយនេះយ៉ាងប្រាកដណាស់។

[352] Justice Scalia និងការបកស្រាយអំពី Theory of Originalism

01634897



## ៥. យុត្តិធម៌អូសបន្លាយ គឺអយុត្តិធម៌

៣០០. ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរទាក់ទងនឹង អោ អាន (សំណុំរឿង 004) បានបញ្ជូនអោយសហចៅក្រមស៊ើបសួរ ដើម្បីបើកកិច្ចស៊ើបអង្កេត ក្រោយថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩។ ការស៊ើបអង្កេត ដំណើរការរហូតដល់ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៨ ទើបសម្រេចចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នាក្នុងពេលតែមួយ គឺ:

- ដីកាដំណោះស្រាយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបញ្ជូនរឿងទៅជំនុំជម្រះ។
- ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ សម្រេចលើកលែងចោទប្រកាន់។

៣០១. ការស៊ើបអង្កេតប្រើរយៈពេលជិត ១០ ឆ្នាំ ប៉ុន្តែពុំបានផ្តល់លទ្ធផលជាក់លាក់ឡើយ ដែលបណ្តាលអោយប៉ះពាល់ធ្ងន់ធ្ងរបំផុតដល់សិទ្ធិរបស់ អោ អាន។

## សេចក្តីសន្និដ្ឋាន
## សេចក្តីពិចារណារបស់ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ

៣០២. សេចក្តីពិចារណារបស់ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ

- ក្រោយពីបានពិចារណាលើសារណារបស់ភាគី
- ក្រោយពីបានពិចារណាលើភស្តុតាងទាំងអស់ រួមទាំងភស្តុតាងស្តីពីការឆ្លងសេចក្តីព្រាងច្បាប់ អ.វ.ត.ក នៅរដ្ឋសភាជាតិ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ យល់ឃើញថា**

i. ការប្រជុំឆ្លងសេចក្តីព្រាងច្បាប់នៅរដ្ឋសភាជាតិ បានផ្តល់សក្ខីកម្មបន្ថែមទៀត បញ្ជាក់អំពីគោលបំណងនៃអ្នកតាក់តែងកិច្ចព្រមព្រៀង និងច្បាប់អ.វ.ត.ក។

ii. ការស៊ើបអង្កេតបឋមដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិពុំបានអនុវត្តត្រឹមត្រូវតាមកិច្ចព្រមព្រៀង និងច្បាប់អ.វ.ត.ក ឡើយ។

iii. ការខ្វែងយោបល់រវាងសហព្រះរាជអាជ្ញាទាំងពីរក្នុងការសម្រេចចោទប្រកាន់ អោ អាន និងបញ្ជូនរឿងឲ្យស៊ើបសួរ មានកម្មវត្ថុទាក់ទងតែទៅលើយុត្តាធិកាបុគ្គលតែប៉ុណ្ណោះ គឺសំដៅទៅលើមេដឹកនាំ និងអ្នក

ទទួលខុសត្រូវខ្ពស់បំផុត។

iv. ក្នុងសេចក្តីថ្លែងការណ៍នាថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានបញ្ជាក់ថាពុំមានផែនការណាមួយដើម្បីចាត់ការលើការស៊ើបអង្កេតបឋមក្រោយៗទៀត បន្ថែមទៅលើជនសង្ស័យផ្សេងទៀតនោះឡើយ។ ដូច្នេះការស៊ើបអង្កេតបឋមក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិពុំមានហេតុផលត្រឹមត្រូវតាមច្បាប់អ.វ.ត.កឡើយ។

v. ការដែលសហចៅក្រមស៊ើបអង្កេតទាំង២ សម្រេចចេញដីកាដំណោះស្រាយពីរដែលមានខ្លឹមសារផ្ទុយគ្នាជាការរំលោភទាំងស្រុងទៅលើក្របខណ្ឌគតិយុត្តរបស់អ.វ.ត.ក។

vi. ការដែលសហចៅក្រមស៊ើបអង្កេតទាំង២ បានគេចចេញពីការខ្វែងយោបល់គ្នា ដែលត្រូវដោះស្រាយតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង បង្កើតបានជាឧបសគ្គដ៏ស្រួចស្រាវមួយ ពុំមានលទ្ធភាពដោះស្រាយសមស្របតាមគតិច្បាប់ឡើយ។

vii. វិធាន ៧៧.១៣ នៃវិធានផ្ទៃក្នុង ពុំបានគ្រោងទុក ឬក៏ ពុំអាចលើកជាវិធានសម្រាប់ដោះស្រាយការជាប់គាំងដោយមូលហេតុមានដីកាដំណោះស្រាយ២ មានខ្លឹមសារផ្ទុយគ្នាដូចករណីសំណុំរឿង ០០៤/២ នេះឡើយ ហើយនេះជាចន្លោះប្រហោងនៃច្បាប់ ឬច្បាប់ពុំមានចែង។

viii. ក្នុងករណីដែលច្បាប់ពុំមានចែងដូច្នេះ ហើយដើម្បីបិទសំណុំរឿង ០០៤/២ នេះស្របតាមច្បាប់ជាធរមាន ចៅក្រមជាតិនៃអបជ យល់ឃើញថាដំណោះស្រាយដែលសមស្របបំផុត សម្រាប់ករណីដែលដីកាដំណោះស្រាយទាំងពីរ ពុំអាចទទួលបានសំឡេងគាំទ្រភាគច្រើនបាន ដែលមានន័យថាដីកាដំណោះស្រាយលើកលែងចោទ ត្រូវបានតម្កល់ទុកជាបានការតាម វិធាន ៧៧.១៣ ហើយតាមវិធានដដែលនេះ ដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះ ពុំមានអានុភាពអនុវត្តឡើយ។

ix. ដីកាដំណោះស្រាយលើកលែងចោទប្រកាន់អោ អាន ដែលសម្រេចសេចក្តីមកនេះ ធ្វើឡើងតាមកិច្ចព្រមព្រៀង និងច្បាប់អ.វ.ត.ក ត្រូវតម្កល់ទុកជាបានការ។

x. ដីកាដំណោះស្រាយចោទប្រកាន់អោ អាន បញ្ជូនទៅជំនុំជម្រះ ដែលសម្រេចសេចក្តីមកនេះ ធ្វើឡើងពុំត្រឹមត្រូវតាមកិច្ចព្រមព្រៀង និងច្បាប់អ.វ.ត.ក ឡើយ ត្រូវទុកជាមោឃៈ។

## ហេតុដូច្នេះសម្រេច

- តម្កល់ដីកាដំណោះស្រាយលើកលែងចោទប្រកាន់ អោ អាន ទុកជាបានការ។
- ទុកជាមោឃៈ ដីកាដំណោះស្រាយចោទប្រកាន់ អោ អាន បញ្ជូនទៅជំនុំជម្រះ។

សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ៦០)

D359/24 និង D360/33

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០១៩

ប្រាក់ គឹមសាន

នំយ ធុល

ហួត វុទ្ធី

# IX. យោបល់ចៅក្រមអន្តរជាតិ

៣០៣. ចៅក្រមដែលលបានចុះហត្ថលេខា នឹងបង្ហាញខាងក្រោមនូវមតិយោបល់របស់ខ្លួនទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ទាំង៣។

## បណ្តឹងឧទ្ធរណ៍របស់អោ អាន ប្រឆាំងនឹងដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ)

### ក. មូលដ្ឋានទី១÷ ការចេញដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះ ជាមួយនឹងដីកាសម្រេចលើកលែងចោទប្រកាន់ដែលមានសុពលភាព

១. សារណា

៣០៤. នៅក្នុងបណ្តឹងឧទ្ធរណ៍ សហមេធាវីការពារក្តី អោ អាន បានអះអាងថា "ការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ស្របពេលជាមួយគ្នានឹង ការចេញដីកាលើកលែងចោទប្រកាន់ ត្រូវបានសំអាងទៅលើកំហុសអង្គច្បាប់" ហើយបានស្នើដល់អង្គបុរេជំនុំជម្រះឱ្យ (ក) ប្រកាសថា ការចេញដីកាដំណោះស្រាយទាំងពីរមិនស្របច្បាប់នោះឡើយ និង (ខ) "ធ្វើមោឃភាព" ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) និង "លើកលែងការចោទប្រកាន់" នៅក្នុងសំណុំរឿង[353]។ ដោយយោងទៅលើវិធាននៃការបកស្រាយ ដែលមានចែងក្នុងអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា ("អនុសញ្ញាទីក្រុងវីយែន") សហមេធាវីការពារក្តីបានលើកឡើងថា ពាក្យពេចន៍នៃវិធាន ៦៧ នៃវិធានផ្ទៃក្នុង បានប្រមើលមើលដោយច្បាស់លាស់អំពីដីកាដំណោះស្រាយតែមួយគត់ ហើយដោយគោលដៅ និងគោលបំណងនៃវិធានគឺដើម្បីគ្រប់គ្រងដើម្បីឱ្យកិច្ចស៊ើបសួរមានលទ្ធផលជាក់លាក់ពិតប្រាកដ និងស្របច្បាប់ អ្នកតាក់តែងច្បាប់មិនមានចេតនាក្នុងការអនុញ្ញាតឱ្យមានស្ថានភាពដែលសំណុំរឿងអាចត្រូវបានលើកលែងចោទប្រកាន់ផង និងបញ្ជូនទៅជំនុំជម្រះផង ដោយសហចៅក្រមស៊ើបអង្កេតពីររូប ដែលមានឋានៈ និងសិទ្ធិអំណាចស្មើគ្នានោះទេ[354]។ បទប្បញ្ញត្តិដទៃនៃក្របខណ្ឌគតិយុត្តិ អ.វ.ត.ក រួមទាំងមាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធាន ១៤ (៤) នៃវិធានផ្ទៃក្នុង បានគាំទ្រថា ដីកាដំណោះស្រាយមួយចាំបាច់ត្រូវតែជាលទ្ធផលការងាររួមរបស់សហ

[353] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ២០, ៣៦។

[354] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ២១-២៣។។ សំណុំរឿង ០០៤/០២ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ (ដីកាដំណោះស្រាយ) ឯកសារ D359/9.1 និង D360/18.1 ERN 01626058-01626509 ទំព័រ 4:10 ដល់ 5:13។

ចៅក្រមស៊ើបអង្កេតទាំងពីររូប[355]។ ការចេញដីកាដំណោះស្រាយពីរ នៅពេលបញ្ចប់កិច្ចស៊ើបសួរតែមួយ មិនស្របជាមួយក្របខណ្ឌគតិយុត្តិអន្តរជាតិ និងកម្ពុជា ព្រមទាំង អ.វ.ត.ក ទេ[356]។

៣០៥. លើសពីនេះទៀត សហមេធាវីការពារក្តីបានលើកឡើងថា ការចេញដីកាដំណោះស្រាយពីរ មិនធ្លាប់មានពីមុនមកទេ។ ការអនុវត្តបែបនេះជាការរំលោភទៅលើសិទ្ធិស្មើភាពចំពោះមុខច្បាប់ និងតុលាការរបស់ អោ អាន[357] និងការធានាពីសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ រួមទាំងសច្ចធារណ៍នៃនិរទោស សិទ្ធិទទួលបានការជំនុំជម្រះ ដោយអង្គជំនុំជម្រះមានសមត្ថកិច្ច និងយុត្តិធម៌ និងសិទ្ធិទទួលបានព័ត៌មានភ្លាមៗ និងដោយលម្អិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន និងសិទ្ធិត្រូវបានជំនុំជម្រះដោយឥតពន្យាពេលយូរហួសហេតុ[358]។ លើសពីនេះទៀត អត្ថិភាពនៃដីកាដំណោះស្រាយដែលផ្ទុយគ្នា បង្កើតបានជាការមាក់ងាយដល់គោលការណ៍សច្ចភាពគតិយុត្តិជាមូលដ្ឋាន និងជា "ការចំអកដល់យុត្តិធម៌"។ ការពិនិត្យឡើងវិញដោយតុលាការជាន់ខ្ពស់ ដែលផ្តល់លទ្ធផលគាំទ្រចំពោះដីកាដំណោះស្រាយទាំងពីរ នឹងកាន់តែបណ្តាលឲ្យមានការម៉ាក់ងាយដល់សច្ចភាពគតិយុត្តិ[359]។

៣០៦. សហមេធាវីការពារក្តីអះអាងទៀតថា ការចេញដីកាដំណោះស្រាយពីរបណ្តាលមកពីការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ដែលចាំបាច់ត្រូវដោះស្រាយ ដោយប្រើប្រាស់វិធាន ៧២ នៃវិធានផ្ទៃក្នុង ដែលកំណត់ថា ក្នុងករណីមិនមានដំណោះស្រាយរបស់អង្គបុរេជំនុំជម្រះ "ដីកា ឬកិច្ចស៊ើបសួរដែលធ្វើឡើងដោយ ស.ច.ស ណាម្នាក់ត្រូវមានសុពលភាព"[360]។ ដោយសារតែសហចៅក្រមស៊ើបអង្កេត

---

[355] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ២៤។ សំណុំរឿង ០០៤/០២ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (ដីកាដំណោះស្រាយ) ឯកសារ D359/9.1 និង D360/18.1 ERN 01626058-01626509 ទំព័រ 4:24 ដល់ 5:2។

[356] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ២៥។

[357] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ២៦-២៧ យោងទៅរក រដ្ឋធម្មនុញ្ញកម្ពុជា (ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣) មាត្រា ៣១។ កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤។ សំណុំរឿង ០០៤/០២ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (ដីកាដំណោះស្រាយ) ឯកសារ D359/9.1 និង D360/18.1 ERN 01626058-01626509 ទំព័រ 3:25 ដល់ 4:4។

[358] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ២៨-៣១។ ១៤។ សំណុំរឿង ០០៤/០២ ប្រតិចារឹកថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ (ដីកាដំណោះស្រាយ) ឯកសារ D359/10.1 និង D360/19.1 ERN 01625508, ទំព័រ 16:3 ដល់ 16:20។ សំណុំរឿង ០០៤/០២ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (ដីកាដំណោះស្រាយ) ឯកសារ D359/9.1 និង D360/18.1 ERN 01626060-01626561 ទំព័រ 5:24 ដល់ 6:25។

[359] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៣២។

[360] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៣៤ យោងទៅរក វិធាន ៧២(៤)(ឃ) នៃវិធានផ្ទៃក្នុង។

មិនបានបញ្ជូនការខ្វែងយោបល់គ្នាទៅអង្គបុរេជំនុំជម្រះ ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) ដែលមានលេខឯកសារទាបជាង ដែលបញ្ជាក់ថា ឯកសារនេះត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងមុនដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ត្រូវមានសុពលភាព[361]។ លើសពីនេះទៀត ដោយសារតែកិច្ចស៊ើបសួរបានបញ្ចប់ "ការសន្មតស្តីពីការបន្តស៊ើបសួរ ដែលអាចអនុវត្តបាននៅក្នុងអំឡុងពេលបើកកិច្ចស៊ើបអង្កេត មិនអាចប្រើប្រាស់តទៅទៀតបានទេ" ដូច្នេះ ដំណោះស្រាយដែលអាចអនុវត្តបានតែមួយគត់ តាមវិធាន ៧២ នៃវិធានផ្ទៃក្នុង គឺត្រូវសម្រេចឲ្យដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) មានសុពលភាព[362]។

៣០៧. ជាចុងក្រោយ និងជាជម្រើសមួយទៀត សហមេធាវីការពារក្តីបានលើកឡើងថា ដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា បង្កើតបានជាស្ថានភាពទាល់ច្រក ដែលមិនត្រូវបានប្រមើលទុកដោយវិធាននីតិវិធីអន្តរជាតិ ឬកម្ពុជា និង អ.វ.ត.ក[363]។ មាត្រា ៥ និងមាត្រា ៧ នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ត្រូវបានរៀបចំឡើងដើម្បីតែគ្រប់គ្រងទៅលើការខ្វែងយោបល់គ្នា នៅក្នុងដំណាក់កាលនៃកិច្ចស៊ើបសួរដែលកំពុងបន្ត មិនមែនស្ថានភាពបច្ចុប្បន្ន ដែលមានដីកាដំណោះស្រាយពីរផ្ទុយគ្នា បន្ទាប់ពីកិច្ចស៊ើបសួរនោះឡើយ[364]។ ភាពសមហេតុផលនៃនីតិវិធីនៅ អ.វ.ត.ក តម្រូវឲ្យមានការសន្និដ្ឋានច្បាស់លាស់នៅដំណាក់កាលស៊ើបអង្កេត មុនពេលដែលសំណុំរឿងអាចបន្តទៅមុខ ហើយចាំបាច់ត្រូវមានភាពច្បាស់លាស់អំពីបទចោទ[365]។ ជាលទ្ធផល រាល់វិមតិសង្ស័យនានាត្រូវតែ

---

សំណុំរឿង ០០៤/០២ ប្រតិចារិកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (ដីកាដំណោះស្រាយ) ឯកសារ D359/9.1 និង D360/18.1 ERN 01626058-01626509 ទំព័រ 4:23 ដល់ 5:7។

[361] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៣៥។

[362] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៣៤, ។ សំណុំរឿង ០០៤/០២ ប្រតិចារិកថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ (ដីកាដំណោះស្រាយ) ឯកសារ D359/10.1 និង D360/19.1 ERN 016260135 ទំព័រ 8:20 ដល់ 8:25។

[363] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៣៣, ៣៥-៣៦។ សំណុំរឿង ០០៤/០២ ប្រតិចារិកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (ដីកាដំណោះស្រាយ) ឯកសារ D359/9.1 និង D360/18.1 ERN 01626058 ទំព័រ 4:5 ដល់ 4:9, 01626061 ទំព័រ 7:1 ដល់ 7:19។

[364] សំណុំរឿង ០០៤/០២ ប្រតិចារិកថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ (ដីកាដំណោះស្រាយ) ឯកសារ D359/10.1 និង D360/19.1 ERN 016260135- 016260136 ទំព័រ 8:24 ដល់ 9:22។

[365] សំណុំរឿង ០០៤/០២ ប្រតិចារិកថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ (ដីកាដំណោះស្រាយ) ឯកសារ D359/10.1 និង D360/19.1 ERN 016260135- 016260136 ទំព័រ 8:20 ដល់ 9:12។

ដោះស្រាយជាប្រយោជន៍ដល់ អោ អាន ដែលតម្រូវឱ្យលើកលែងចោទប្រកាន់ទៅលើសំណុំរឿង[366]។

៣០៨. ជាចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ច្បាប់ពាក់ព័ន្ធអនុញ្ញាតឱ្យមានការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាលើកលែងចោទប្រកាន់ ដែលផ្ទុយគ្នា នៅក្នុងសំណុំរឿងតែមួយ ហើយតម្រូវថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានអនុភាព[367]។ ជាដំបូង ទោះបីជាអត្ថបទជាភាសាអង់គ្លេស នៃវិធាន ៦៧(១) នៃវិធានផ្ទៃក្នុង យោងទៅរក "សហចៅក្រមស៊ើបអង្កេត" ជាពហុវចនៈក្តី វិធានផ្ទៃក្នុងជាភាសាខ្មែរ "អាចសំដៅទៅសហចៅក្រមស៊ើបអង្កេតតែម្នាក់ ឬទាំងពីរ"[368]។ ដោយផ្អែកលើចំណុចនេះ និង វិធាន ១(២) ទើបវិធាន ៦៧(១) នៃវិធានផ្ទៃក្នុង ចាំបាច់ត្រូវបកស្រាយថា ផ្តល់សិទ្ធិដល់លទ្ធភាពដែលចៅក្រមតែមួយរូប អាចចេញដីកាដំណោះស្រាយមួយ[369]។ លើសពីនេះទៀត ពាក្យ "អាចជា" និង "ឬ" នៅក្នុងវិធាន ៦៧(១) គ្រាន់តែបង្ហាញពីលក្ខខណ្ឌតម្រូវ ដែលដីកាដំណោះស្រាយណាមួយដែលបានចេញ គឺជាការសម្រេចសេចក្តីអង្គហេតុ និងបទចោទទាំងអស់ និង "ការសន្និដ្ឋានទៅលើរឿងក្តីមួយយ៉ាងច្បាស់លាស់ ដែលអាចជា ដីកាសម្រេចចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាសម្រេចលើកលែងចោទប្រកាន់ (ឬដោយមានការចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ ចំពោះបទចោទខ្លះ និងលើកលែងការចោទប្រកាន់ខ្លះ)"[370]។ វិធាននេះមិនរារាំងការចេញដីកាដំណោះស្រាយពីរ ដែលទំនាស់គ្នា នៅក្នុងសំណុំរឿងតែមួយនោះឡើយ ដូចដែលយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលបានកំណត់[371]។ លើសពីនេះ

---

[366] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៣៣, ៣៥-៣៦។ សំណុំរឿង ០០៤/០២ ប្រតិចារិកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (ដីកាដំណោះស្រាយ) ឯកសារ D359/9.1 និង D360/18.1 ERN 01626058 4:5 ដល់ 4:9 01626061 7:4 ដល់ 7:18។

[367] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៥-១៥។ សំណុំរឿង ០០៤/០២ ប្រតិចារិកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS), D359/9.1 & D360/18.1, ERN (EN) 01625320-01625329, pp. 61:18 to 70:5។

[368] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះបណ្តឹងឧទ្ធរណ៍របស់ អោ អាន ឯកសារ (D360/9) កថាខណ្ឌ ១៣។ សំណុំរឿង ០០៤ ០២/ប្រតិចារិកថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០ ឯកសារ D359/10.1 និង D360/19.1 016260135- 016260136 ទំព័រ 7:27 ដល់ 8:21។ សំណុំរឿង ០០៤/ ០២ប្រតិចារិកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០ ឯកសារ D359/9.1 និង D360/18.1 ERN (EN) 01625327- 01625327 ទំព័រ 68:18 ដល់ 70:5។

[369] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៨។ សំណុំរឿង ០០៤/០២ ប្រតិចារិកថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ (ដីកាដំណោះស្រាយ) ឯកសារ D359/10.1 និង D360/19.1 ERN 016260135 ទំព័រ 4:20 ដល់ 4:25។

[370] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៩។

[371] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៩-១០

01634904



ទៀត សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដោយមិនបញ្ជូនការខ្វែងយោបល់គ្នាទៅអង្គបុរេជំនុំជម្រះ ដែលតាមរយៈនេះ ទើបភាគីទាំងអស់បានទទួល ផលប្រយោជន៍ពីដីកាដំណោះស្រាយពីរដែលលម្អិត រៀបរាប់អំពីសំអាងហេតុ និងការសម្រេចលើអង្គហេតុ របស់សហចៅក្រមស៊ើបអង្កេត[372]។

៣០៩. សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងទៀតថា សហមេធាវីការពារក្ដីមិនបានបង្ហាញថា ការចេញដីកាដំណោះស្រាយពីរ បានរំលោភបំពានទៅលើសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ របស់ អោ អាន[373]។ ការអះអាងរបស់សហមេធាវីការពារក្ដី (ដែលថា ការដែលមិនធ្លាប់មានដីកាដំណោះស្រាយចំនួនពីរ មិនមានភាពយុត្តិធម៌) មិនបានពិចារណាទៅលើអង្គហេតុដែលថា រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ សម្រេចគាំទ្របទដ្ឋានអន្តរជាតិសម្រាប់យុត្តិធម៌ និងភាពត្រឹមត្រូវ ដោយបង្កើតឡើងដោយចេតនានូវរចនាសម្ព័ន្ធរបស់ អ.វ.ត.ក ដែលមិនធ្លាប់មានពីមុន និងមានលក្ខណៈពិសេស ដោយមានចៅក្រមស៊ើបអង្កេតពីររូប។ ហេតុដូច្នេះហើយ ស្ថានភាពនេះមិនអាចកើតមានឡើងនៅទីកន្លែងផ្សេងឡើយ[374]។ ការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយសហចៅក្រមស៊ើបអង្កេតមួយរូប ក៏មិនបានលុបបំបាត់សច្ចធារណ៍នៃនិរទោស ដែលធានាអំពីកាតព្វកិច្ចក្នុងការបង្ហាញភស្តុតាងរបស់ព្រះរាជអាជ្ញា ដើម្បីបង្ហាញអំពីពិរុទ្ធភាពរបស់ជនជាប់ចោទឱ្យហួសពីវិមតិសង្ស័យនៅក្នុងការជំនុំជម្រះ។ នេះមិនមែនជាកាតព្វកិច្ចក្នុងការបង្ហាញភស្តុតាង ដែលបានតម្រូវសម្រាប់ដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ[375]។ លើសពីនេះទៀត ការចេញដីកាដំណោះស្រាយដែលផ្ទុយគ្នា មិនបានបង្កើនលទ្ធភាពដែលថា សំណុំរឿង ០០៤/០២ ត្រូវបានទុកចោល "ដោយមិនបានបញ្ញត្តិច្បាស់លាស់" នោះទេ ដោយ សារអនាគតនៃកិច្ចដំណើរការនីតិវិធីមានភាពច្បាស់លាស់ គឺថា ប្រសិនបើមិនមានបណ្ដឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយណា ទទួលបានជោគជ័យនៅអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង នឹងទទួលយកដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) អនុលោមតាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង[376]។ លើសពីនេះទៀត សហព្រះរាជអាជ្ញា

---

យោងទៅរក សាលដីកាសំណុំរឿង ០០១ (ឯកសារ F28) កថាខណ្ឌ ៦៥។

[372] សំណុំរឿង ០០៤/០២ ប្រតិចារឹកថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ (ដីកាដំណោះស្រាយ) ឯកសារ D359/10.1 និង D360/19.1 ERN ( 016260135, 016260139 ទំព័រ 3:20 ដល់ 3:25 ទំព័រ 7:2 ដល់ 7:25។

[373] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ១១-១៣។

[374] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ១១។

[375] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ១២។

[376] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ១៣។

01634905



អន្តរជាតិបានលើកឡើងថា គោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ* ត្រូវបានគេយល់ថា ជាគោលការណ៍ដែលពាក់ព័ន្ធ ចំពោះការសម្រេចលើអង្គហេតុ ដូច្នេះហើយ មិនតម្រូវឱ្យអង្គជំនុំជម្រះយកតាមគោលជំហររបស់សហមេធាវីការពារក្តី ទាក់ទងនឹងការបកស្រាយលើច្បាប់នោះទេ[377]។

៣១០. ជាចុងក្រោយទាក់ទងទៅនឹងការអះអាងរបស់សហមេធាវីការពារក្តីដែលថា ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) ចាំបាច់ត្រូវតែចាត់ទុកថាជា ដីកាដំណោះស្រាយដែលមានប្រសិទ្ធភាពតែមួយគត់ ដោយសារតែមានលេខឯកសារទាបជាង ដែលបង្ហាញថា ឯកសារនេះត្រូវបានដាក់មុន ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) នោះ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកទឡ្ហីករណ៍ថា វិធីសាស្ត្រនេះធ្វើតាមទំនើងចិត្ត មិនមានគោលការណ៍កំណត់ និងមិនមានមូលដ្ឋាននៃអង្គសេចក្តីសម្រាប់គោលជំហរ ឬនីត្យានុកូលភាព នៃសកម្មភាពដែលបានលើកឡើង ហើយសិទ្ធិរបស់ជនត្រូវចោទ និងផលប្រយោជន៍សង្គម ក្នុងការសម្រេចបានយុត្តិធម៌ បែរជាត្រូវសម្រេចបានតាមរយៈប្រកួតប្រជែងក្នុងការដាក់ឯកសារ[378]។

៣១១. នៅក្នុងការឆ្លើយតប សហមេធាវីការពារក្តីបានលើកឡើងថា ការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា វិធាន ៦៧ និងវិធាន ១(២) នៃវិធានផ្ទៃក្នុង អនុញ្ញាតឱ្យមានការចុះហត្ថលេខាទៅលើដីកាដំណោះស្រាយមួយ ដោយសហចៅក្រមស៊ើបអង្កេតតែមួយរូប ឃ្លាតចាកពីចំណុចស្នូលនៃទឡ្ហីករណ៍របស់សហមេធាវីការពារក្តីដែលថា វិធាន ៦៧ នៃវិធានផ្ទៃក្នុង ចែងអំពីដីកាដំណោះស្រាយតែមួយ[379]។ សហមេធាវីការពារក្តីបានលើកឡើងថា ទោះបីជាដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតតែមួយរូបអាចធ្វើទៅបាននៅពេលដែលការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ត្រូវបានដោះស្រាយដោយអង្គបុរេជំនុំជម្រះ តាមវិធាន ៧២ នៃវិធានផ្ទៃក្នុងក្តី ប៉ុន្តែ មិនមានការអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតនីមួយៗ ចេញដីកាដំណោះស្រាយរៀងៗខ្លួនឡើយ[380]។ តាមពិតទៅ ការបកស្រាយរបស់សហព្រះរាជ

---

សំណុំរឿង ០០៤/០២ ប្រតិចារឹកថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ (ដីកាដំណោះស្រាយ) ឯកសារ D359/10.1 និង D360/19.1 016260135- 016260136 ទំព័រ 7:27 ដល់ 8:21។

[377] សំណុំរឿង ០០៤/០២ ប្រតិចារឹកថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ (ដីកាដំណោះស្រាយ) ឯកសារ D359/10.1 និង D360/19.1 ERN 016260131ទំព័រ 4:4 ដល់ 4:15។

[378] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ១៤-១៥។

[379] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៨។

[380] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៧-៨។ សំណុំរឿង ០០៤/០២ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (ដីកាដំណោះស្រាយ) ឯកសារ D359/9.1 និង D360/18.1 ERN 01626058-01626509, ទំព័រ 4:15 ដល់ 5:12។

អាជ្ញាអន្តរជាតិ ទៅលើវិធាន ៦៧ នៃវិធានផ្ទៃក្នុង ដែលចាចែងអំពីលក្ខខណ្ឌតម្រូវនៃដីកាដំណោះស្រាយ ដែលបង្ហាញយ៉ាងសមស្របអំពីអង្គហេតុ និងបទចោទ និង "សន្និដ្ឋានទៅលើរឿងក្ដីមួយច្បាស់លាស់" គឺជាការផ្ទាញ់ខ្លួនឯង ដោយសារតែដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាសម្រេចលើកលែងចោទប្រកាន់ ដែលមានសុពលភាពនៅក្នុងសំណុំរឿងតែមួយ គឺជាការផ្ទុយគ្នាទាំងស្រុង ធៀបនឹងការសម្រេចសេចក្ដីយ៉ាងច្បាស់លាស់[381]។ លើសពីនេះទៀត ទស្សនៈរបស់ចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសំណុំរឿង ០០១ មិនបានអនុវត្តឡើយ ដោយសារតែទស្សនៈនោះត្រូវបានធ្វើឡើង នៅពេលពិនិត្យមើលលើការអនុវត្តនីតិវិធីខ្វែងយោបល់គ្នារបស់ អ.វ.ត.ក តាមវិធាន ៧២ នៃវិធានផ្ទៃក្នុង ដូច្នេះហើយ មិនអាចបកស្រាយថាជាការគាំទ្រដល់សុពលភាពនៃដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា តាមវិធាន ៦៧ នៃវិធានផ្ទៃក្នុងឡើយ[382]។

៣១២. លើសពីនេះទៀត សហមេធាវីការពារក្ដីបានអះអាងថា ទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា ដីកាដំណោះស្រាយដែលផ្សេងគ្នា ហើយផ្ទុយគ្នា មិនបានរំលោភបំពានទៅលើសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ អោ អាន នោះ មិនគួរឲ្យជឿជាក់បានទេ[383]។ ជាពិសេស ការអះអាងដែលថា "រចនាសម្ព័ន្ធពិសេសប្លែកពីគេ" ដែលមានចេតនាលើកស្ទួយបទដ្ឋានយុត្តិធម៌អន្តរជាតិ មិនបានការពារតុលាការមួយនេះពីការចោទប្រកាន់អំពីភាពអយុត្តិធម៌ ដែលបណ្ដាលមកពីរចនាសម្ព័ន្ធនេះឡើយ។ អ្វីដែលសំខាន់នោះគឺព្យសនកម្មដែលបានបង្កឡើងជាក់ស្ដែងចំពោះសិទ្ធិរបស់ អោ អាន តាមរយៈដីកាដំណោះស្រាយដែលផ្ទុយគ្នា[384]។ លើសពីនេះទៀត ការតែងតាំងចៅក្រមស៊ើបអង្កេតពីររូបទៅក្នុងសំណុំរឿងតែមួយ តាមពិតទៅមិនមែនជាលក្ខណៈពិសេសរបស់ អ.វ.ត.ក ទេ។ អ្វីដែលពិសេសគឺការចេញដីកាដំណោះស្រាយពីរផ្សេងគ្នា ហើយផ្ទុយគ្នា[385]។

---

[381] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៨។

[382] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៩ យោងទៅរក សាលដីកាសំណុំរឿង ០០១ (ឯកសារ F28) កថាខណ្ឌ ៦៥។ សំណុំរឿង ០០៤/០២ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (ដីកាដំណោះស្រាយ) ឯកសារ D359/9.1 និង D360/18.1 ERN 01626058-01626509 ទំព័រ 4:10 ដល់ 5:13។

[383] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ១០។ សំណុំរឿង ០០៤/០២ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D359/9.1 និង D360/18.1 ERN (EN) 01625367-01625368, pp. 108:12 to 109:1។

[384] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ១១-១២។

[385] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ១១ យោងទៅរក *ផងដែរ ក្រមនីតិវិធីព្រហ្មទណ្ឌ* មាត្រា ៨៣-១, ៨៣-២ (ភាសាបារាំង)។ សហមេធាវីការពារក្ដី បានកត់សម្គាល់ថា នៅប្រព័ន្ធបារាំង ចៅក្រមមួយរូបអាចខ្វែងយោបល់ និងបដិសេធមិនចុះហត្ថលេខា ទៅលើដីកាដំណោះស្រាយ ប៉ុន្តែមិនអាចចេញដីកាដែលផ្ទុយគ្នាបានទេ។ សំណុំរឿង ០០៤/០២ ប្រតិ

៣១៣.សហមេធាវីការពារក្តីបានលើកទឡ្ហីករណ៍ថា អត្ថិភាពនៃនីតិវិធីពិសេសនៃការខ្វែងយោបល់គ្នានៅក្នុងមាត្រា ៧ នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក និងវិធាន ៧២ នៃវិធានផ្ទៃក្នុង បានបញ្ជាក់អំពីកាអង្គហេតុដែលថា ភាគីនានាមិនធ្លាប់ប្រមើលអំពីលទ្ធភាពនេះឡើយ[386]។ លើសពីនេះ ដោយផ្ទុយពីការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិសម្រាប់ អ.វ.ត.ក ព្រះរាជអាជ្ញាមានកាតព្វកិច្ចក្នុងការបង្ហាញភស្តុតាងនៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី ចាប់ពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររហូតដល់បណ្តឹងសាទុក្ខចុងក្រោយ ដោយគ្រាន់តែផ្លាស់ប្តូរបទដ្ឋាននៃការបង្ហាញភស្តុតាងប៉ុណ្ណោះ[387]។ ហេតុដូច្នេះ សហមេធាវីការពារក្តីបានលើកឡើងថា ដើម្បីឱ្យសហចៅក្រមស៊ើបអង្កេត អាចចោទប្រកាន់បញ្ជូន អោ អាន ទៅជំនុំជម្រះបាន ព្រះរាជអាជ្ញាត្រូវតែបង្ហាញនៅក្នុងដីកាសន្និដ្ឋានស្ថាពរថា ភស្តុតាងមានការគាំទ្រ និងមានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ ដើម្បីផ្តល់ជាភស្តុតាងដល់កម្រិតជាក់លាក់មួយ។ ការបញ្ជូន អោ អាន ទៅជំនុំជម្រះ បើទោះបីជាមានអត្ថិភាពនៃដីកាសម្រេចលើកលែងចោទប្រកាន់ ដែលមានសុពលភាពមួយនោះ គឺជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរមួយទៅលើសច្ចធារណ៍នៃនិរទោសរបស់គាត់[388]។

៣១៤. ជាចុងក្រោយ ជំនួសឱ្យការស្វែងរកដំណោះស្រាយតាមទំនើងចិត្ត និងមិនមានគោលការណ៍អ្វីសម្រាប់ស្ថានភាពអយុត្តិធម៌មួយនេះ សហមេធាវីការពារក្តីស្នើថា ខ្លួនគ្រាន់តែសុំឱ្យអង្គបុរេជំនុំជម្រះដោះស្រាយស្ថានភាពអយុត្តិធម៌នេះ ដោយ "អនុវត្តវិធានជាធរមាន"[389]។ សហមេធាវីការពារក្តីស្នើដល់អង្គជំនុំជម្រះឱ្យសម្រេចថា ក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក និងកតិការសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ មិនបាន "អនុញ្ញាតឱ្យចេញដីកាដំណោះស្រាយ ដែលផ្ទុយគ្នានៅក្នុងរឿងក្តីតែមួយនោះទេ"។ សហមេធាវីការពារក្តីបានលើកឡើងថា ករណីនៃវិមតិសង្ស័យត្រូវដោះស្រាយជាប្រយោជន៍ដល់ អោ អាន ដោយអនុលោមតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា[390]។ សហមេធាវីការពារក្តីអះអាង

---

ចារីកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ (ដីកាដំណោះស្រាយ) ឯកសារ D359/9.1 និង D360/18.1 ERN 01626059 ទំព័រ 5:16 ដល់ 5:22។

[386] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ១១។

[387] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ១៣។

[388] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ១៣។

[389] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ១៥។

[390] ការឆ្លើយតបរបស់ អោ អាន ឯកសារ D360/11 កថាខណ្ឌ ៦, ១៥។ សំណុំរឿង ០០៤/០២ ប្រតិចារឹកថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ (ដីកាដំណោះស្រាយ) ឯកសារ D359/10.1 និង D360/19.1 ERN 016260134-016260136, 016260137-016260138 ទំព័រ 7:1 ដល់ 8:5, ទំព័រ 10:22 ដល់ 11:4។ សំណុំរឿង ០០៤/០២ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ (ដីកាដំណោះស្រាយ) ឯកសារ D359/9.1 និង D360/18.1 ERN 01626058-01626509 01626059 ទំព័រ 4:10 ដល់

ថា សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ត្រូវតែទទួលបានអានុភាពលើដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) គឺជាការរំលោភបំពាន់ទៅលើសមភាពរវាងចៅក្រម ដោយផ្អែកលើការបកស្រាយដោយមិនត្រឹមត្រូវ ទៅលើវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង និងយុត្តិសាស្ត្រដែលពុំអាចអនុវត្តបាន[391]។ ហេតុដូច្នេះ ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) ត្រូវតែមានអានុភាព[392]។

## ២. ការពិភាក្សា

៣១៥. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ដោយបញ្ជូន អោ អាន ទៅជំនុំជម្រះ[393]។ ចំណែកសហចៅក្រមស៊ើបអង្កេតជាតិបានចេញដីកាដំណោះស្រាយ លើកលែងការចោទប្រកាន់ចំពោះ អោ អាន[394]។ អង្គបុរេជំនុំជម្រះសូមរម្លឹកថា ការឯកភាពគ្នារបស់ចៅក្រមទាំងពីររូបក្នុងការចេញដីកាដំណោះស្រាយក្នុងពេលតែមួយ ដែលមានភាពផ្ទុយគ្នានេះ បង្កើតបានជាកំហុសអង្គច្បាប់[395]។

៣១៦. ចៅក្រមអន្តរជាតិកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតបានប្រើប្រាស់សិទ្ធិអំណាចដោយខុសឆ្គងក្នុងការចេញដីកាដំណោះស្រាយផ្សេងគ្នា ដែលផ្ទុយពីគ្នា នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧[396] ហើយពួកគាត់បានកត់ត្រាការខ្វែងយោបល់គ្នា ទាក់ទងនឹងការដាក់ដីកាដំណោះស្រាយផ្សេងគ្នា ហើយផ្ទុយគ្នា នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨ ដែលជារយៈពេលជិតមួយឆ្នាំក្រោយមក។

៣១៧. នាពេលនេះ ចៅក្រមអន្តរជាតិនឹងពិភាក្សាអំពីសុពលភាពនៃដីកាដំណោះស្រាយនីមួយៗ។ ចៅក្រមអន្តរជាតិពិចារណាថា ការបែកចេញពីគ្នារវាងសហព្រះរាជអាជ្ញាអន្តរជាតិ និងសហមេធាវីការពារក្តី អោ អាន នៅក្នុងទឡ្ហីករណ៍របស់ពួកគាត់ទាក់ទងនឹងនីត្យានុកូលភាពនៃការចេញដីកាដំណោះស្រាយពីរ ដែល

---

5:13 ទំព័រ 5:16 ដល់ 5:22 ទំព័រ 5:4 ដល់ 5:11, ទំព័រ 10:1 ដល់11:8។

[391] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ១៤, ១៦។

[392] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ១៥-១៦។

[393] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360)។

[394] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D359)។

[395] *សូមមើល* កថាខណ្ឌ ៨៨ ដល់ ១២៤ ។

[396] ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារ ដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ (ឯកសារ D355/1) កថាខណ្ឌ ១៣ ដល់ ១៥។

ផ្ទុយគ្នា ក្នុងពេលតែមួយ របស់សហចៅក្រមស៊ើបអង្កេត បាននាំទៅលើការសន្និដ្ឋានខុសគ្នាស្រឡះអំពីដីកាដំណោះស្រាយណាមួយ ដែលមានអានុភាពលើដីកាដំណោះស្រាយមួយទៀត ដែលបណ្តាលមកពី ការពឹងផ្អែកដោយមិនត្រឹមត្រូវរបស់ពួកគេទៅលើការសន្មតមួយចំនួន។ ចៅក្រមអន្តរជាតិមិនជឿជាក់ថា ដីកាសម្រេចលើកលែងចោទប្រកាន់មានអានុភាព ដោយសារតែទឡ្ហីករណ៍នានាដែលសហមេធាវីការពារក្តីបានលើកឡើងនោះទេ។ ចៅក្រមអន្តរជាតិក៏មិនជឿចំពោះទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងការឈានទៅដល់ការសន្និដ្ឋានរបស់គាត់នោះដែរ។

៣១៨. ដោយសារសំអាងហេតុដែលនឹងរៀបរាប់នៅផ្នែកខាងក្រោម ចៅក្រមអន្តរជាតិសម្រេចថា ដីកាដំណោះស្រាយដែលកំពុងចោទជាបញ្ហាទាំងពីរ មិនដូចគ្នាទាំងស្រុងនោះឡើយ សម្រាប់អនុលោមភាពជាមួយច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក និងសម្រេចថា មានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះដែលមានសុពលភាព។

៣១៩. ជាដំបូង ចៅក្រមអន្តរជាតិរម្លឹកថា សហចៅក្រមស៊ើបអង្កេតមួយរូប អាចចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយមានសុពលភាព តាមរយៈការបំពេញកិច្ចតែម្នាក់ឯង[397]។ លើសពីនេះទៀត ចៅក្រមអន្តរជាតិ កត់សម្គាល់ថា មាត្រា ៥(៤) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលចែងថា ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត “ការស៊ើបអង្កេតនោះត្រូវដំណើរការទៅមុខទៀត” លើកលែងតែចៅក្រមទាំងនោះ ឬចៅក្រមណាម្នាក់ ក្នុងចំណោមចៅក្រមទាំងនេះ បញ្ជូនការខ្វែងយោបល់របស់ពួកគេ ទៅអង្គបុរេជំនុំជម្រះ[398]។

---

[397] *សូមមើល* ខាងលើកថាខណ្ឌ ១០៥។ វិធាន ១(២) នៃវិធានផ្ទៃក្នុង (“ជាពិសេស លើកលែងតែមានចែងផ្សេងពីនេះ ការយោងនៅក្នុងវិធានផ្ទៃក្នុងនេះ ចំពោះពាក្យសហចៅក្រមស៊ើបអង្កេត សំដៅទៅដល់សហចៅក្រមស៊ើបអង្កេតទាំងពីរ ដែលធ្វើការសម្រេចចិត្តរួមគ្នា និងចៅក្រមស៊ើបអង្កេតណាម្នាក់ ក្នុងចំណោមអ្នកទាំងពីរ ទោះបីដោយផ្ទាល់ ឬតាមរយៈតំណាង ។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន ប្រឆាំងដីកាសម្រេចបដិសេធ សំណើរបស់គាត់ស្នើសុំព័ត៌មាន កថាខណ្ឌ ១១។ សំណុំរឿង ០០៤ សេចក្តីសម្រេចលើសំណើបន្ទាន់របសឯកសារ *A122/6.1/3,* កថាខណ្ឌ ១៩។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីកាសម្រេច ឯកសារ *D236/1/1/8* កថាខណ្ឌ ៣០។

[398] កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៥ (៤) (“សហចៅក្រមស៊ើបអង្កេតត្រូវសហការគ្នា ដើម្បីឈានទៅដល់ការឯកភាពគ្នាមួយ ក្នុងការស៊ើបអង្កេត។ នៅក្នុងករណីដែលចៅក្រមស៊ើបអង្កេត មិនអាចឯកភាពគ្នាថា ត្រូវបន្តការស៊ើបអង្កេតណាមួយ ការស៊ើបអង្កេតនោះត្រូវដំណើរការទៅមុខទៀត លើកលែងតែចៅក្រមទាំងនេះ ឬចៅក្រមណាម្នាក់ក្នុងចំណោមចៅក្រមទាំងនេះ ធ្វើការស្នើសុំនៅក្នុងរយៈ ពេលសាមសិបថ្ងៃ ឱ្យដោះស្រាយការខ្វែងគំនិតគ្នានេះតាមមាត្រា ៧”) (ដោយគូសបញ្ជាក់បន្ថែម)។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២៣ថ្មី កថាខណ្ឌទី៣ (“ការស៊ើបអង្កេតត្រូវធ្វើបន្ត ដរាបណាសហចៅក្រមស៊ើប

៣២០. ចៅក្រមអន្តរជាតិកត់សម្គាល់ថា គោលការណ៍នៃការបន្តកិច្ចស៊ើបសួរតាមផ្លូវតុលាការនេះ គ្រប់គ្រងទៅលើបញ្ហានៅចំពោះមុខនេះ។ ចៅក្រមអន្តរជាតិមិនជឿតាមការអះអាងរបស់សហមេធាវីការពារក្ដីដែលថា ការស៊ើបអង្កេតបានបញ្ចប់ ហើយសច្ចាធារណ៍នៃការបន្ត ដែលអាចអនុវត្តទៅបាន ក្នុងអំឡុងពេលស៊ើបអង្កេតដែលកំពុងដំណើរការ លែងអាចអនុវត្តបាននោះទេ[399]។

៣២១. ទោះបីជានីតិវិធីដោះស្រាយការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ដែលមានចែងក្នុងវិធាន ៧២ នៃវិធានផ្ទៃក្នុង អាចមិនត្រូវបានអនុវត្ត ចំពោះកិច្ចដំណើរការនីតិវិធី បន្ទាប់ពីការចេញដីកាដំណោះស្រាយក្ដី ប៉ុន្តែមិនបានរារាំងការអនុវត្តនីតិវិធីនៃការចេញដីកាដំណោះស្រាយ នៅមុនពេលពេលបញ្ចប់ការស៊ើបអង្កេតទេ[400]។ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ដោយត្រឹមត្រូវ[401] ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតមួយរូបស្នើចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយសហចៅក្រមស៊ើបអង្កេតមួយរូបទៀតមិនយល់ស្រប ពួកគាត់តែម្នាក់ ឬទាំងពីរនាក់ អាចលើកយកការខ្វែងយោបល់គ្នានេះ ទៅអង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង។

៣២២. ក្នុងសំណុំរឿងបច្ចុប្បន្ន មិនមានសហចៅក្រមស៊ើបអង្កេតរូបណា បានបញ្ជូនការខ្វែងយោបល់គ្នាទៅអង្គបុរេជំនុំជម្រះឡើយ នៅក្នុងរយៈពេល ៣០ ថ្ងៃ[402] បន្ទាប់ពីបានកត់ត្រាការខ្វែងយោបល់គ្នា នៅថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១៨។ ជាលទ្ធផល ការស៊ើបអង្កេត ឬការចោទប្រកាន់ ត្រូវបន្ត[403]។ ក្នុងស្ថានភាពពិសេសនេះ នៅពេលដែលសហចៅក្រមស៊ើបអង្កេតមួយរូបស្នើសុំចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ

---

អង្កេតទាំងពីរ ឬមួយរូប ក្នុងចំណោមពួកគេពុំបានប្ដឹងមិនសុខចិត្ត ក្នុងរយៈពេលសាមសិបថ្ងៃ ថាភាពខ្វែងយោបល់គ្នាត្រូវដោះស្រាយ ដោយអនុវត្តតាមបទប្បញ្ញត្តិដូចខាងក្រោម") (ដោយគូសបញ្ជាក់បន្ថែម)។

[399] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៣៥។

[400] វិធាន ៦៧(១) នៃវិធានផ្ទៃក្នុង ("សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយ")។

[401] សាលដីកាសំណុំរឿង 001 (ឯកសារ F28) កថាខណ្ឌ ៦៥ ("ប្រសិនបើអង្គបុរេជំនុំជម្រះសម្រេចថា សហចៅក្រមស៊ើបអង្កេតណាមួយ មានកំហុសក្នុងការសម្រេចចេញ ឬក្នុងការស្នើឱ្យចេញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ដោយមូលហេតុថា ជនត្រូវចោទគឺជា ឬមិនមែនជា ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ហើយប្រសិនបើអង្គបុរេជំនុំជម្រះ មិនអាចទទួលបានសម្លេងគាំទ្រភាគច្រើនលើសលប់ ទៅលើផលវិបាកនៃសេណារីយ៉ូនេះទេ "ដំណើរការស៊ើបអង្កេតត្រូវបន្តទៅមុខ") (ដោយគូសបញ្ជាក់បន្ថែម)។

[402] កិច្ចព្រមព្រៀងស្ដីពីការបង្កើត អ វ.ត.ក.មាត្រា ៥ (៤) , ច្បាប់ស្ដីពីការបង្កើត អ វ.ត.ក.មាត្រា ២៣ថ្មី និង វិធាន ៧២ (២) នៃវិធានផ្ទៃក្នុង។

[403] មាត្រា ៥(៤) និងមាត្រា ៧(៤) នៃកិច្ចព្រមព្រៀងស្ដីពីការបង្កើត អ.វ.ត.ក។ មាត្រា ២៣ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក។

ហើយសហចៅក្រមស៊ើបអង្កេតម្នាក់ទៀតមិនយល់ស្រប "ការស៊ើបអង្កេតនោះត្រូវដំណើរការទៅមុខទៀត" ដែលមានន័យថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចាំបាច់ត្រូវតែចេញតាមសំណើ[404]។

៣២៣. លើសពីនេះទៀត នៅពេលពិនិត្យមើលលើអត្ថន័យនៃពាក្យ "ការស៊ើបអង្កេតនោះត្រូវដំណើរការទៅមុខទៀត" អង្គជំនុំជម្រះយល់ថា មិនមាននរណាម្នាក់អាចបកស្រាយពាក្យពេចន៍នេះឱ្យបានសមហេតុផលតាមន័យធម្មតា និងផ្អែកទៅតាមគោលដៅ និងគោលបំណងរបស់ពាក្យពេចន៍នេះ ថាត្រូវរួមបញ្ចូលការចេញដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) ឡើយ[405]។ ជាដំបូង នៅក្នុងអត្ថន័យធម្មតា សំណើសុំចេញដីកាសម្រេចលើកលែងចោទប្រកាន់ ដែលផ្ទុយទាំងស្រុងពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលធ្វើឱ្យសំណុំរឿងត្រូវបន្តទៅជំនុំជម្រះ មិនអាចត្រូវបានទទួលស្គាល់ថាជា កិច្ចស៊ើបសួរផ្សេងឡើយ។ នេះមិនខុសអ្វីពីការកំណត់លក្ខណៈតាមបែបផ្សេងនៃការខ្វែងយោបល់របស់ សហចៅក្រមស៊ើបអង្កេតជាតិទៅលើការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ ដែលការខ្វែងយោបល់នេះចាំបាច់ត្រូវដោះស្រាយដោយនីតិវិធីដោះស្រាយការខ្វែងយោបល់គ្នា តាមវិធាន ៧២ នៃវិធានផ្ទៃក្នុង។ ទីពីរ គោលបំណងរបស់កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក គដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម[406]។ ជាការសមហេតុផលក្នុងការទាញចេញពីពាក្យពេចន៍នៃមាត្រា ៥(៤), ៦(៤) និង ៧ នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ២០ថ្មី ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធាន ១៣(៥), ១៤(៧), ៧១ និង ៧២ នៃវិធានផ្ទៃក្នុង ថា គោលដៅគន្លឹះនៃយន្តការដោះស្រាយការខ្វែងយោបល់គ្នា គឺដើម្បីរារាំងការជាប់គាំងដែលធ្វើឱ្យប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីជំនុំជម្រះ[407]។

---

[404] ចៅក្រមអន្តរជាតិមិនជឿថា វិធាន ៧២(៤)(ឃ) នៃវិធានផ្ទៃក្នុងដែលចែងថា "សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្រ មានន័យថាដីកា ឬ កិច្ចស៊ើបសួរដែលធ្វើឡើងដោយ សហចៅក្រមស៊ើបអង្កេតណាម្នាក់ ត្រូវមានសុពលភាព" ត្រូវអនុវត្តក្នុងករណីនេះ ដូចដែលសហមេធាវីការពារក្តីបានលើកឡើងនោះទេ (បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៣៥)។ វិធាន ៧២(៤)(ឃ) នៃវិធានផ្ទៃក្នុង អនុវត្តនៅពេលដែលអង្គបុរេជំនុំជម្រះ មិនអាចស្វែងរកសម្លេងភាគច្រើនលើសលប់ នៅក្នុងនីតិវិធីដោះស្រាយការខ្វែងយោបល់។ ករណីការខ្វែងយោបល់នាពេលនេះ មិនត្រូវបានបញ្ជូនមកអង្គបុរេជំនុំជម្រះឡើយ។

[405] អនុសញ្ញាទីក្រុងវីយែន មាត្រា ៣១(១) ("សន្ធិសញ្ញាត្រូវបកស្រាយដោយសុឆន្ទៈ ស្របទៅតាមអត្ថន័យធម្មតារបស់ពាក្យពេចន៍នៃសន្ធិសញ្ញានោះ នៅក្នុងបរិបទរបស់វា ហើយត្រូវផ្អែកទៅលើគោលដៅ និងគោលបំណងរបស់សន្ធិសញ្ញានោះដែរ")។

[406] មាត្រា ១ នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក , មាត្រា ១ នៃច្បាប់ ស្តីពីការបង្កើត អ.វ.ត.ក (ដោយគូសបញ្ជាក់បន្ថែម)។

[407] ប្រវត្តិនៃការចរចាររបស់ អ.វ.ត ក គាំទ្រដល់ការបកស្រាយនេះ ឧទាហរណ៍.D. SCHEFFERក្នុងករណីមិនមានសម្លេងភាគ" ច្រើនលើសលប់ ការស៊ើបអង្កេត ឬការស្នើឱ្យបញ្ជូនរឿងទៅជំនុំជម្រះត្រូវបន្តដំណើរការ") ។ D. CIORCIARY & A.

៣២៤. ហេតុដូច្នេះ ចៅក្រមអន្តរជាតិសម្រេចថា ការចេញដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បើទោះបីជាមានការយល់ព្រមដោយខុសឆ្គងរបស់គាត់ក្នុងការចេញដីកាសម្រេចលើកលែងចោទប្រកាន់ ក្នុងពេលជាមួយគ្នានឹងសហការីរបស់គាត់ក្តី ប៉ុន្តែ ជានីតិវិធី ដីកានេះមានអនុលោមភាព ទៅតាមច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក។ ចំណែកការចេញដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ មិនមានមូលដ្ឋានគតិយុត្តិឡើយ។

៣២៥. ចៅក្រមអន្តរជាតិបញ្ជាក់ថា ដីកាដំណោះស្រាយរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតចាំបាច់ត្រូវតែជាសេចក្តីសម្រេចតែមួយគត់[408] ហើយបញ្ជាក់ថា ការបញ្ជូនការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ទៅអង្គបុរេជំនុំជម្រះ គឺជាកាតព្វកិច្ចដែលត្រូវបំពេញ នៅពេលដែលពួកគាត់បរាជ័យក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការមានគោលជំហររួមគ្នាមួយទាក់ទងនឹងដីកាដំណោះស្រាយ ហើយសហចៅក្រមស៊ើបអង្កេតមិនមានមធ្យោបាយផ្សេងៗក្នុងការដោះស្រាយការខ្វែងយោបល់របស់ពួកគាត់ទេនោះ[409]។ ការចេញដីកាសម្រេចលើកលែងចោទប្រកាន់ដែលផ្ទុយគ្នាដោយសហចៅក្រមស៊ើបអង្កេតជាតិ ដោយមិនបានបញ្ជូនទៅអង្គបុរេជំនុំជម្រះ គឺជាការព្យាយាមយ៉ាងច្បាស់ក្នុងការគេចទាំងស្រុងចេញពីលក្ខខណ្ឌតម្រូវជាកាតព្វកិច្ច និងមានសារសំខាន់នេះ។ ទោះជាក្នុងមធ្យោបាយណាក៏ដោយ ក៏ការធ្វើនេះមិនមានយុត្តិកម្មបានឡើយ ដូច្នេះហើយ មិនមានអានុភាពផ្លូវច្បាប់ទេ។

៣២៦. ហេតុដូច្នេះ ចៅក្រមអន្តរជាតិសម្រេចថា ការចេញដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ គឺជាការអនុវត្តហួសសិទ្ធិអំណាចគតិយុត្តិ ដូច្នេះហើយត្រូវតែធ្វើមោឃភាព

---

HEINDEL, Hybrid Justice (បោះពុម្ពលើកទី១ សហរដ្ឋអាមេរិក The University of Michigan Press ឆ្នាំ (២០១៤) ឯកសារ D297.1 ទំព័រ ៣១ "ដើម្បីគ្រប់គ្រងលើហានិភ័យនៃការខ្វែងយោបល់គ្នា និងភាពទាល់ច្រក រវាងសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត មន្ត្រីអាមេរិកបានជំរុញឲ្យមានការបង្កើតក្រុមប្រឹក្សាជំនុំជម្រះពិសេសសម្រាប់គោលបំណងនេះ។ នៅពេលក្រោយបន្តិច មន្ត្រីអង្គការសហប្រជាជាតិ និងកម្ពុជា បានឯកភាពគ្នាក្នុងការបង្កើតអង្គបុរេជំនុំជម្រះ ដែលមានចៅក្រមកម្ពុជាបីរូប និងចៅក្រមអន្តរជាតិពីររូប ដែលមានសិទ្ធិអំណាចក្នុងការរារាំងការស៊ើបអង្កេត ឬការបញ្ជូនរឿងទៅជំនុំជម្រះ តាមរយៈការបោះឆ្នោតដោយសម្លេងភាគច្រើនលើសលប់")។ ចៅក្រមអន្តរជាតិកត់សម្គាល់ពីមតិរបស់សហមេធាវីការពារក្តីដែលថា "នៅពេលដែលអង្គបុរេជំនុំជម្រះមិនអាចស្វែងរកសម្លេងភាគច្រើនលើសលប់បាន សេចក្តីសម្រេចសម្រាប់សំណុំរឿង អោ អាន គឺថាការជំនុំជម្រះត្រូវបន្ត" (បណ្តឹងឧទ្ធរណ៍របស់ អោ អាន ឯកសារ D360/5/1 កថាខណ្ឌ ២១០ ជើងទំព័រ ៥៣៦) ។

[408] *សូមមើល* កថាខណ្ឌ ១២០ ដល់ ១២២។

[409] *សូមមើល* កថាខណ្ឌ ១០១ ដល់ ១១៩។

ហើយដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវមានសុពលភាព។

៣២៧. ចំពោះការចោទប្រកាន់ពីការរំលោភបំពានទៅលើសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ និងតុលាការរបស់ អោ អាន និងការធានាពីការជំនុំជម្រះប្រកបដោយយុត្តិធម៌ជាក់ច្បាស់ រួមទាំងសិទ្ធិទទួលបានសច្ចធារណ៍នៃនិរទោស សិទ្ធិទទួលបានការជំនុំជម្រះ ដោយតុលាការមានសមត្ថកិច្ច និងយុត្តិធម៌ សិទ្ធិទទួលបានព័ត៌មានភ្លាមៗ និងដោយលម្អិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន និងសិទ្ធិត្រូវបានជំនុំជម្រះដោយឥតពន្យាពេលយូរហួសហេតុ ព្រមទាំងគោលការណ៍សច្ចភាពយុត្តិធម៌[410] ចៅក្រមអន្តរជាតិពិចារណាឃើញថា ទឡ្ហីករណ៍ទាំងនេះសន្មតជាមុនពីការគាំទ្ររបស់ដីកាដំណោះស្រាយទាំងពីរ[411]។ ដោយសារបានសម្រេចថា មានតែដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) តែមួយដែលមានសុពលភាព ចៅក្រមអន្តរជាតិសម្រេចថា ទឡ្ហីករណ៍ទាំងអស់នេះមិនមានមូលដ្ឋានទេ។

៣២៨. ដូចគ្នាដែរ ចៅក្រមអន្តរជាតិកត់សម្គាល់ឃើញថា មិនមានភាពស្រពិចស្រពិលអ្វីទេនៅក្នុងបញ្ហានេះ ហើយយល់ថា មិនមានភាពចាំបាច់ក្នុងការត្រួតពិនិត្យបន្ថែមទៀតទៅលើទឡ្ហីករណ៍របស់សហមេធាវីការពារក្តី ទាក់ទងនឹងគោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ*[412] ដែលជាវិធាននៃការបង្ហាញភស្តុតាង និងមិនមែនជាការបកស្រាយច្បាប់ឡើយ[413]។

៣២៩. ជាការសន្និដ្ឋាន ចៅក្រមអន្តរជាតិសម្រេចបដិសេធមូលដ្ឋានទីមួយ។

## ខ. មូលដ្ឋានទី ២៖ ការសន្និដ្ឋានពីឆន្ទានុសិទ្ធិដោយសេរី ដែលត្រូវបានចោទប្រកាន់

### ១. សារណា

៣៣០. សហមេធាវីជំទាស់ថា សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានដោយយល់ខុសថា គាត់មានឆន្ទានុសិទ្ធិដោយសេរី ដើម្បីសម្រេចថាតើ អោ អាន ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឬយ៉ាងណា[414]

[410] សូមមើលផងដែរ បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ២៦-៣២។

[411] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៣២។

[412] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៣៣, ៣៥-៣៦។

[413] សំណុំរឿង ០០៣ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (D87/2/1.7/1/1/7) កថាខណ្ឌ ៦៥។

[414] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៣៩ *យោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំ

ដោយអនុវត្តតាម "យុត្តិសាស្ត្រខុសឆ្គង និងទស្សនៈហួសសម័យ" របស់អង្គជំនុំជម្រះតុលាការកំពូល ដោយផ្តល់ឱ្យសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត នូវព្រំដែនយុត្តាធិការដ៏ទូលំទូលាយដែលមិនសមស្រប ដែលទាមទារយ៉ាងខ្លាំងឱ្យផ្តន្ទាទោសចំពោះកម្មាភិបាលខ្មែរក្រហម ដែលនៅរស់រានមានជីវិតស្ទើរតែទាំងអស់[415]។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតគួរតែអនុវត្តតាមយុត្តាធិការរបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/១ ដែលសម្រេចថា ទោះបីសេចក្តីសម្រេចអំពីយុត្តាធិការបុគ្គល គឺជាសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិក្តី តែឆន្ទានុសិទ្ធិនេះមិនមែនគ្មានព្រំដែន ហើយចៀសមិនផុតពីការត្រួតពិនិត្យលើបណ្តឹងឧទ្ធរណ៍នោះទេ[416]។ វិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលច្រានចោលការពិនិត្យពិច័យផ្នែកតុលាការទៅលើបញ្ហាសំខាន់នៃយុត្តាធិការបុគ្គល ក៏មិនស្របទៅនឹងចេតនា និងការអនុវត្តន៍ជាបន្តបន្ទាប់របស់ភាគីនៃកិច្ចព្រមព្រៀង អ.វ.ត.ក ដែលជាឧបករណ៍សំខាន់ៗសម្រាប់យកមកបកស្រាយនោះដែរ[417]។

៣៣១.សហព្រះរាជអាជ្ញាអន្តរជាតិឆ្លើយតបថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានចាត់ទុកខ្លួនឯងថាមាន "ឆន្ទានុសិទ្ធិដោយសេរី"[418] នោះទេ។ សហមេធាវីផ្នែកទឡ្ហីករណ៍ផ្ទុយរបស់ខ្លួនទៅលើការកំណត់មិនត្រឹមត្រូវនៃការសរសេរឡើងវិញរបស់ចៅក្រមអំពីសេចក្តីសម្រេចមួយរបស់អង្គជំនុំជម្រះតុលាការកំពូលដែលការពិត បានពិភាក្សាអំពីអំណាចត្រួតពិនិត្យរបស់អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល ទាក់ទងនឹងបញ្ហាយុត្តាធិការ ហើយក្នុងកាលៈទេសៈណាក៏ដោយ គាត់បានទទួលស្គាល់ថាសូម្បីតែនៅចំពោះមុខអង្គជំនុំជម្រះទាំងនោះក៏ដោយ ក៏ការវាយតម្លៃនៅតែជាកម្មវត្ថុនៃការតវ៉ាដែល ឱ្យតែវាជាការរំលោភបំពានឆន្ទានុសិទ្ធិ[419]។ ជាងនេះទៀត តាមទស្សនៈផ្ទាល់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបញ្ចូលសេចក្តីពិភាក្សារបស់សហចៅក្រមស៊ើបអង្កេតទាំងពីររូបនៅក្នុងដីកាដំណោះស្រាយសំណុំរឿង ០០៤/១ (សំអាងហេតុ) ជាឯកសារយោងគឺថា ឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតមាន

ជម្រះ) (ឯកសារ D360) កថាខណ្ឌ ៥៥, ៦៩៩។

[415] បណ្តឹងឧទ្ធរណ៍របស់ អោ អាន ឯកសារ D360/5/1 កថាខណ្ឌ ៣៩,៤១ យោងទៅ ("សាលដីកាសំណុំរឿង ០០១ (ឯកសារ F28)") កថាខណ្ឌ ៦១, ៧៩។ ចម្លើយតបរបស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានស្ថាពរ (ឯកសារ D351/6) កថាខណ្ឌ ៧៧-៧៩។

[416] បណ្តឹងឧទ្ធរណ៍របស់ អោ អាន ឯកសារ D360/5/1 កថាខណ្ឌ ៤០ យោងទៅ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ឯកសារ (D308/3/1/20) កថាខណ្ឌ ២០។

[417] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៤១-៤២ *យោងទៅ* ចម្លើយតបរបស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានស្ថាពរ (ឯកសារ D351/6) កថាខណ្ឌ ៦២-៧៦។

[418] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ១៦-១៩។

[419] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ១៧។

កម្រិតតិចជាងយុត្តិសាស្ត្រដែលសរសេរឡើងវិញរបស់អង្គជំនុំជម្រះតុលាការកំពូល ហើយជាការពិត អាច ត្រូវបានត្រួតពិនិត្យឡើងវិញដោយអង្គជំនុំជម្រះផ្សេងទៀត[420]។

៣៣២.សហមេធាវីមិនឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះមូលដ្ឋាននេះ ទេ តែសូមលើកឡើងថា ចំណុចនេះមិនគួរបកស្រាយថា ត្រូវបានទទួលយកដោយតណ្ហីភាពនោះឡើយ[421]។

## ២. ការពិភាក្សា

៣៣៣.តាំងពីដំបូងមក ចៅក្រមអន្តរជាតិសូមអះអាងជាថ្មីថា ទោះបីសេចក្តីសម្រេចអំពីយុត្តាធិការបុគ្គល គឺជាសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិក្តី តែឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតក្នុងការសម្រេចនេះមិន អនុញ្ញាតឱ្យបំពេញកិច្ចតាមអំពើចិត្តទេ ជាពិសេស ដោយសារពាក្យ "មេដឹកនាំជាន់ខ្ពស់" និង "ជនទាំង ឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" គឺជាព្រំដែនយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[422]។

៣៣៤. នៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) សហចៅក្រមស៊ើបអង្កេតអន្តរជាតិបាន អនុម័តយកមតិយោបល់រួមរបស់សហចៅក្រមស៊ើបអង្កេតទាំងពីរ នៅក្នុងដីកាដំណោះស្រាយក្នុងសំណុំ រឿង ០០៤/១ (សំអាងហេតុ) ពាក់ព័ន្ធនឹងលក្ខណៈនៃការសម្រេចនេះ[423] ពោលគឺថា ការអនុវត្តឆន្ទានុសិទ្ធិ នេះ "តម្រូវឱ្យមានការវិនិច្ឆ័យបានខ្លះផងដែរ លើសេចក្តីសម្រេចរបស់ [សហព្រះរាជអាជ្ញា] និង [សហ ចៅក្រមស៊ើបអង្កេត]"[424]។ ហេតុនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំបានអះអាងថាមានឆន្ទានុសិទ្ធិ ដោយសេរី ដើម្បីសម្រេចថាតើ អោ អាន ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ទេ ដែលផ្ទុយទៅនឹង ការអះអាងរបស់សហមេធាវី ចំពោះមូលដ្ឋាននេះ[425]។ សេចក្តីសម្រេចលើសំណុំរឿង ០០៤/១ របស់អង្គ

---

[420] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ១៨-១៩ យោងទៅ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៥៤ សំណុំរឿង ០០៤/១ (ដីកា ដំណោះស្រាយ)(សំអាងហេតុ) ឯកសារ D308/3 កថាខណ្ឌ ៨-9។

[421] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៥។

[422] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) កថា ខណ្ឌ ២០។ *សូមមើលផងដែរ* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ២(១), ច្បាប់ អ.វ.ត.ក មាត្រា ២ថ្មី។

[423] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ *៥៤ យោងទៅ* ដីកាដំណោះស្រាយសំណុំ រឿង ០០៤/១ (សំអាងហេតុ) (ឯកសារ D308/3) កថាខណ្ឌ ៩-១០។

[424] ដីកាដំណោះស្រាយសំណុំរឿង ០០៤/១ (សំអាងហេតុ) (ឯកសារ D308/3) កថាខណ្ឌ ៩។

[425] សហមេធាវីក៏បានអះអាងផងដែរថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា គាត់មានឆន្ទានុសិទ្ធិដោយសេរី ទាក់

បុរេជំនុំជម្រះពាក់ព័ន្ធនឹងដែនកំណត់នៃឆន្ទានុសិទ្ធិនេះ[426] ដែលត្រូវបានសង្ខេបនៅក្នុងកថាខណ្ឌខាងលើ នៅតែតម្កល់ទុកជាបានការដដែល ហើយតាមពិតត្រូវបានបញ្ជាក់ជាថ្មី នៅក្នុងផ្នែកស្តីពីបទដ្ឋាននៃការពិនិត្យលើបណ្តឹងឧទ្ធរណ៍ នៃសាលដីកានេះ[427]។ ហេតុនេះ ចៅក្រមអន្តរជាតិសម្រេចបដិសេធមូលដ្ឋានទី ២។

## គ. មូលដ្ឋានទី៣ ៖ កំហុសក្នុងការបកស្រាយពាក្យ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" នៅក្នុងលក្ខណៈទូលំទូលាយពេក

### ១. សារណា

៣៣៥. សហមេធាវីលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ខុសលើកំហិតនៃយុត្តាធិការបុគ្គលដោយបកស្រាយអត្ថន័យពាក្យ ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតក្នុងលក្ខណៈទូលំទូលាយពេក[428]។ កំហុសនេះបានបង្ហាញឲ្យឃើញតាមវិធីបួនយ៉ាង។

៣៣៦. ទីមួយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានបកស្រាយដោយចង្អៀតលើអត្ថន័យពាក្យទទួលខុសត្រូវខ្ពស់បំផុត និងមានកំហុសដែលមិនអើពើដល់ប្រវត្តិនៃការចរចាបង្កើតតុលាការការអនុវត្តជាបន្តបន្ទាប់របស់ភាគី និង ទស្សនៈរបស់សហព្រះរាជអាជ្ញាជាតិ និង ចៅក្រមជាតិនៅពេលធ្វើការកំណត់ទៅ

---

ទិននឹងសេចក្តីថ្លែងការណ៍របស់គាត់ដែលថា សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០១ "មានសេរីភាពបដិសេធកិច្ចសន្យានយោបាយបែបនេះនៅក្នុងរបៀបណាដែលរឹតត្បិតឆន្ទានុសិទ្ធិរបស់ខ្លួន ដែលមានចែងនៅក្នុងច្បាប់ជាធរមាន"។ បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៣៩ ជើងទំព័រ ៥៩ *យោងទៅ*ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៦៩៩។ ទោះជាយ៉ាងណាក្តី នៅពេលអាចអត្ថបទដកស្រង់នេះនៅក្នុងបរិបទ វាបង្ហាញច្បាស់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបែរលើកឡើងថា កិច្ចសន្យានយោបាយពាក់ព័ន្ធបញ្ជីដើមនៃឈ្មោះមនុស្សដែលត្រូវធ្វើការស៊ើបអង្កេត នៅពេលចាប់ផ្តើមសកម្មភាពរបស់ អ.វ.ត.ក មិនអាចរឹតត្បិតឆន្ទានុសិទ្ធិតាមផ្លូវច្បាប់ដែលផ្តល់ដល់សហព្រះរាជអាជ្ញា និងសហចៅក្រមអង្កេតបានទេ។ ចំណុចនេះពុំមានន័យថា ឆន្ទានុសិទ្ធិរបស់សហព្រះរាជអាជ្ញា និងសហចៅក្រមអង្កេតគ្មានព្រំដែនកំណត់ឡើយ។

[426] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) កថាខណ្ឌ ២០។

[427] *សូមមើលខាងលើ* កថាខណ្ឌ ២៨ ដល់ ៣០។

[428] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៤៣-៤៤, ៥៤។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626056 ទំព័រ ២ បន្ទាត់ ១០-១៣, 01626062-01626063 ទំព័រ ៨ បន្ទាត់ ២១ ដល់ ទំព័រ ៩ បន្ទាត់ ៦។

លើជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត[429]។ ទោះបីជាចាប់តាំងពីដើមដំបូងមានការកម្រិតត្រឹមតែថ្នាក់ដឹកនាំ ប.ក.ក នៅមជ្ឈិមបក្ស ក៏ដោយ[430] ក៏ប៉ុន្តែ យុត្តាធិការបុគ្គល អ.វ.ត.ក ត្រូវបានពង្រីកដើម្បីបញ្ចូល ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតដើម្បីអនុញ្ញាតឱ្យមានការកាត់សេចក្តីលើ ឌុច[431]។ នៅក្នុងបរិបទ នេះ ការយល់ឃើញចង្អៀតនិងត្រឹមត្រូវនៃយុត្តាធិការបុគ្គលគឺក្តោបលើមន្ត្រីខ្មែរក្រហមដែលមានលក្ខណៈសំខាន់ ក្នុងការគាក់តែងនិងអនុវត្តគោលនយោបាយ ប.ក.ក និង អ្នកដែលមានតំណែងកាន់តែខ្ពស់នៅក្នុង ប.ក.ក និង តួនាទីនៅក្នុងឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត[432]។ ចំណុចនេះមិនរួមបញ្ចូលបុគ្គលទាំងឡាយដូចជា អោ អាន ឡើយ[433]។

៣៣៧. ទីពីរ ជាការរំលោភលើគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ និង ការបកស្រាយក្នុងន័យចង្អៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានអនុវត្តនិយមន័យចង្អៀតបំផុតនៃពាក្យ ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ដែលបានជាប្រយោជន៍ដល់ អោ អាន[434]។

៣៣៨. ទីបី សហមេធាវី តវ៉ាថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអនុវត្តវិធីសាស្ត្រ "ថយក្រោយ និងសិប្បនិមិត្ត"[435] នៅក្នុងដីកាដំណោះស្រាយ (ដីការបញ្ជូនរឿងទៅជំនុំជម្រះ) ដែលបំផ្លើសតួនាទីរបស់ អោ

---

[429] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៤៦។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626062-01626063 ទំព័រ ៨ បន្ទាត់ ២២ ដល់ ទំព័រ ៩ បន្ទាត់ ៣។

[430] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៤៦ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626063 ទំព័រ ៩ បន្ទាត់ ៣-៤។

[431] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៤៦ *យោងទៅ* ចម្លើយតបរបស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានស្ថាពរ (ឯកសារ D351/6) កថាខណ្ឌ ៨២-៩២, ៩៨។

[432] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៤៥, ៤៧, ៥៤។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626063 ទំព័រ ៩ បន្ទាត់ ៦-១៣។

[433] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៤៧។ *សូមមើលផងដែរ* ផ្នែកទី II ង (មានទឡ្ហីករណ៍របស់ អោ អាន ស្តីពីមូលដ្ឋានទី ៦)។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626063 ទំព័រ ៩ បន្ទាត់ ១៦-១៩, 01626121 ទំព័រ ៦៧ បន្ទាត់ ១-៣។

[434] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៤៨។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626063-01626064 ទំព័រ ៩ បន្ទាត់ ១៩ ដល់ ទំព័រ ១០ បន្ទាត់ ៤។

[435] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៥០។

អាន នៅក្នុងឧក្រិដ្ឋកម្ម និងបង្កើតនូវការភាន់ច្រឡំថាគាត់ស្ថិតក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត[436]។ ចំណុចជាក់ស្តែងគឺថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដាក់បញ្ចូលគ្នារវាង ទស្សនទានយុត្តាធិការបុគ្គលជាមួយនឹងទម្រង់នៃការទទួលខុសត្រូវដោយយល់ឃើញមិនត្រឹមត្រូវលើពាក្យ ទទួលខុសត្រូវខ្ពស់បំផុតដោយឆ្លងកាត់កញ្ចក់សហឧក្រិដ្ឋកម្មរួម ទម្រង់ទីមួយ ("JCE I")។ ការបកស្រាយនេះអាចនឹងក្តោបខ្សែសង្វាក់បញ្ជាទាំងមូលរបស់ ប.ក.ក ដែលជាការធ្វើឱ្យខូចដល់កម្មវត្ថុនៃការកម្រិតយុត្តាធិការបុគ្គលរបស់តុលាការ[437]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិរំលងដោយមិនត្រឹមត្រូវលើលក្ខខណ្ឌតម្រូវសម្រាប់ការវាយតម្លៃត្រឹមត្រូវមួយទៅលើយុត្តាធិការបុគ្គល ដោយទីមួយ វាយតម្លៃតួនាទី និងការទទួលខុសត្រូវរបស់ អោ អាន ចំពោះអំពើប្រល័យពូជសាសន៍នៅភូមិភាគកណ្តាល តាមរយៈសំណាញ់ដ៏ធំនៃសហឧក្រិដ្ឋកម្ម ទម្រង់ទីមួយ រួចហើយ កំណត់ថាការទទួលខុសត្រូវនេះគឺស្មើនឹងអ្វីដែលតម្រូវសម្រាប់យុត្តាធិការបុគ្គល[438]។ ផ្ទុយទៅវិញ សហមេធាវីអះអាងថា លក្ខខណ្ឌវិនិច្ឆ័យសម្រាប់កំណត់ថាតើ អោ អាន ស្ថិតនៅក្នុងចំណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"គួរតែត្រូវបានអនុវត្តជាមុន និង ពិនិត្យលើការទទួលខុសត្រូវព្រហ្មទណ្ឌតែក្នុងករណីដែលមានសំអាងហេតុគាំទ្រវិជ្ជមានប៉ុណ្ណោះ[439]។

៣៣៩. ទីបួន សហមេធាវីតវ៉ាថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយធ្វើការប្រៀបធៀប អោ អាន តែទៅនឹង អ៊ឹម ចែម និង ឌុច ដោយមិនបានរួមបញ្ចូលសមាជិកដទៃទៀត ដូចជា កែ ពក, តាម៉ុក, និង សៅ សារុន ជាអាទិ៍[440]។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឬយុត្តិសាស្ត្រ ពុំបានរឹតត្បិតចំពោះការវិភាគបែបប្រៀបធៀបដែលតម្រូវសម្រាប់ការវាយតម្លៃយុត្តាធិការបុគ្គលត្រឹមតែចំពោះមន្ត្រីខ្មែរក្រហមដែលត្រូវបានស៊ើបអង្កេត ចោទប្រកាន់ ឬផ្តន្ទាទោសដោយតុលាការឡើយ[441]។ ប្រសិនបើ

---

[436] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៥០-៥២។

[437] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៤៩ *យោងទៅ* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ២(១)។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1 ERN 01626064 ទំព័រ ១០ បន្ទាត់ ៤-១៥។ ប្រតិចារឹកថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/10.1 ERN 01626147 ទំព័រ ២០ បន្ទាត់ ១៣-១៧។

[438] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៥០-៥២។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626064 ទំព័រ ១០ បន្ទាត់ ៤-៦។

[439] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៥០។

[440] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៥៣។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626064 ទំព័រ ១០ បន្ទាត់ ១៦-២០។

[441] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៥៣។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំ

មាន ការវិភាគពិតប្រាកដមួយទាក់ទិននឹងកម្រិតនៃការទទួលខុសត្រូវ និងភាពធ្ងន់ធ្ងរនៃបទល្មើសដែលបាន ចោទប្រកាន់នោះ ម្ល៉េះសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនអាចរកឃើញថា អោ អាន ស្ថិតក្នុងយុត្តាធិ ការរបស់តុលាការឡើយ ដោយហេតុថាគាត់ពុំមានតំណែង ឬតួនាទីអ្វីសំខាន់ខ្លាំងឡើយ បើប្រៀបធៀប ជាមួយមន្ត្រីខ្មែរក្រហមដទៃទៀត[442]។

៣៤០. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិលើកទឡ្ហីករណ៍ថា សហមេធាវីខកខានមិនបាន បង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបកស្រាយពាក្យ ទទួលខុសត្រូវខ្ពស់បំផុត ក្នុងលក្ខណៈ ទូលំទូលាយពេកឡើយ[443]។ ទឡ្ហីករណ៍របស់សហមេធាវី ដែលថាតុលាការនេះត្រូវបានបង្កើតឡើង ដើម្បី កាត់សេចក្តី "តែមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម"[444] គឺពិតជាមិនត្រឹមត្រូវឡើយ ដោយហេតុថា កិច្ចព្រម ព្រៀងនិងច្បាប់បង្កើត អ.វ.ត.ក បានចែងច្បាស់ហើយថា អ.វ.ត.ក ត្រូវបានបង្កើតឡើងដើម្បីកាត់សេចក្តី មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋ កម្ម និង ការរំលោភបំពានធ្ងន់ធ្ងរដែលប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនោះ[445]។ លើសពីនេះទៀត ការ អះអាងដែលថាប្រភេទនៃអ្នកទទួលខុសត្រូវខ្ពស់បំផុត ត្រូវបានបន្ថែមដើម្បីអនុញ្ញាតឱ្យមានការកាត់សេចក្តី ចំពោះឌុច គឺជាការផ្ទុយទៅនឹងសេចក្តីថ្លែងរបស់ឧបនាយករដ្ឋមន្ត្រី សុខ អាន ដែលជាឥស្សរជនចរចារបស់ ភាគីកម្ពុជា នៅក្នុងរដ្ឋសភាជាតិនៅពេលអនុម័តច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[446]។ យោងតាមការ លើក

រឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626064 ទំព័រ ១០ បន្ទាត់ ២២-២៤។

[442] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៥៣-៥៤។ ផ្នែកទី II ង (មានទឡ្ហីករណ៍របស់ អោ អាន ស្តីពីមូលដ្ឋានទី ៦)។ ប្រតិចារិកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626064-01626065 ទំព័រ ១០ បន្ទាត់ ២៣ ដល់ ទំព័រ ១១ បន្ទាត់ ៥។

[443] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ២០។

[444] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ២១ *យោងទៅ*បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៤៦។

[445] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ២១។ ប្រតិចារិកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626101 ទំព័រ ៤៧ បន្ទាត់ ២-១៩។ ប្រតិចារិកថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/8.1, ERN 01626012-01626013 ទំព័រ ២៣ បន្ទាត់ ២៤ ដល់ ទំព័រ ២៤ បន្ទាត់ ៧។

[446] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ២២-២៣។ ប្រតិចារិកថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/8.1, ERN 01626014 ទំព័រ ២៥ បន្ទាត់ ៣-១២, 01626014-01626015 ទំព័រ ២៥ បន្ទាត់ ១៧ ដល់ ទំព័រ ២៦ បន្ទាត់ ២, 01626021-01626022 ទំព័រ ៣២ បន្ទាត់ ១៧ ដល់ ទំព័រ ៣៣ បន្ទាត់ ២។

ឡើងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំណះអំណាងដែលនៅសេសសល់ទាំងប៉ុន្មានរបស់សហមេធាវី លើមូលដ្ឋានរងនេះ គឺជាសេចក្ដីសន្និដ្ឋានសុំដែលគួរតែច្រានចោលដោយពុំចាំបាច់ពិចារណាវែងឆ្ងាយ[447]។

៣៤១. ពាក់ព័ន្ធនឹងគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ សហព្រះរាជអាជ្ញា លើកទឡ្ហីករណ៍ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានទទួលស្គាល់ដោយត្រឹមត្រូវថា ការអនុវត្តគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ និង ការយល់ឃើញក្នុងន័យចង្អៀត គឺកម្រិតតែចំពោះវិមតិសង្ស័យដែលនៅតែបន្តមានក្រោយពីការអនុវត្តវិធានបទដ្ឋាននៃការបកស្រាយប៉ុណ្ណោះ[448]។ ផ្អែកលើសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹង "មុខតំណែង និង លក្ខណៈវិសាលភាពភូមិសាស្ត្រ និង ផលប៉ះពាល់នៃសកម្មភាពរបស់គាត់" គឺគ្មានចំណុចដែលត្រូវមានមន្ទិលថា អោ អាន ស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក នោះទេ ទោះបីជាក្នុងន័យចង្អៀតបំផុតក្ដី[449]។

៣៤២. ពាក់ព័ន្ធនឹងការអះអាងអំពីវិធីសាស្ត្រ "ថយក្រោយ និងសិប្បនិមិត្ត"[450] ដែលវាយតម្លៃមិនត្រឹមត្រូវទៅលើការទទួលខុសត្រូវរបស់ អោ អាន តាមរយៈសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយនោះ ជាដំបូង សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា វាមិនត្រឹមតែសមស្របប៉ុណ្ណោះទេ គឺថែមទាំងចាំបាច់ផងដែរសម្រាប់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងការវាយតម្លៃអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ អោ អាន រួមទាំងតាមរយៈសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ ក្នុងការវាយតម្លៃថាតើ គាត់ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឬយ៉ាងណានោះ។ អង្គបុរេជំនុំបានចង្អុលបញ្ជាក់ថាវាមានភាពពាក់ព័ន្ធយ៉ាងសំខាន់ក្នុងការកំណត់[451]។ លើសពីនេះទៀត ផ្ទុយទៅនឹងទឡ្ហីករណ៍របស់សហមេធាវី ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) មិនបានសន្និដ្ឋានថា អោ អាន ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ដោយមូលហេតុតែ

---

447 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ២៤។

448 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ២៥ *យោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៥៥។ ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (សំអាងហេតុ) (ឯកសារ D308/3) កថាខណ្ឌ ២៦-៣៦។

449 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ២៦ *យោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៦៩៧-៧១២។

450 បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៥០។

451 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ២៧-២៨ *យោងទៅ* សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) កថាខណ្ឌ ២៦។

មួយថាគាត់ជាសមាជិកក្នុងសហឧក្រិដ្ឋកម្មទម្រង់ទីមួយតាមការចោទប្រកាន់នោះឡើយ។ ផ្ទុយទៅវិញ ការកំណត់ដែលមានសំអាងហេតុត្រឹមត្រូវ និងមូលដ្ឋានច្បាស់លាស់ សន្និដ្ឋានថា អោ អាន "គឺជាអ្នកចូលរួមប្រព្រឹត្តម្នាក់ដោយចេតនា និងមានទឹកចិត្តក្នុងការអនុវត្តគោលនយោបាយឧក្រិដ្ឋនិងអមនុស្សធម៌សាហាវយង់ឃ្នង" របស់កម្ពុជាប្រជាធិបតេយ្យ[452]។

៣៤៣. ចំណុចចុងក្រោយ ពាក់ព័ន្ធនឹងការលើកឡើងរបស់សហាមេធាវីដែលថា សហចៅក្រមស៊ើបអង្កេតមានកំហុសក្នុងការខកខានមិនបានប្រៀបធៀប អោ អាន ជាមួយនឹងមន្ត្រីខ្មែរក្រហមដទៃទៀត សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សហាមេធាវីមិនបានពន្យល់មូលហេតុឡើយថាហេតុអ្វីបានជាការវិភាគថាតើ កែ ពក តា ម៉ុក និង សៅ សារុន ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ឬយ៉ាងណានោះ ជាការចាំបាច់ក្នុងការកំណត់បែបនេះ ពាក់ព័ន្ធនឹង អោ អាន[453]។

៣៤៤. ជាការឆ្លើយតប សហាមេធាវីលើកទឡ្ហីករណ៍ថា សហព្រះរាជអាជ្ញាអន្តរជាតិខកខានមិនបានផ្តល់ភស្តុតាងគាំទ្រទឡ្ហីករណ៍របស់គាត់ និង ផ្ទុយមកវិញ រើសយកអ្វីដែលមានទាក់ទិននឹងប្រវត្តិចរចា ក្នុងគោលបំណងពង្រីកយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[454]។ ជាការផ្ទុយទៅនឹងការអះអាងរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ សហាមេធាវីមិនបានមិនយកចិត្តទុកដាក់ប្រភេទ "ទទួលខុសត្រូវខ្ពស់ បំផុត" ប៉ុន្តែបានបង្ហាញតាមរយៈការពិនិត្យហ្មត់ចត់នូវប្រវត្តិចរចា ថាមិនមានបំណងសំដៅប្រភេទច្រើនផ្សេងៗគ្នាឡើយ។ ផ្ទុយទៅវិញ សហព្រះរាជអាជ្ញាអន្តរជាតិ បានត្រឹមតែលើកមកសំអាងនូវសុន្ទរកថានយោបាយមួយ និងមិនអើពើដល់សេចក្តីថ្លែងរបស់ភាគីចរចានៅក្នុងចម្លើយតបរបស់ខ្លួនទេ។ ហេតុដូចនេះ សហព្រះរាជអាជ្ញាអន្តរជាតិពុំបានផ្តល់មូលដ្ឋានក្នុងការស្នើសុំបដិសេធ ទឡ្ហីករណ៍របស់សហាមេធាវីភ្លាមៗនោះឡើយ[455]។

---

[452] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ២៩ *យោងទៅ*ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៧១២។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626100-01626101 ទំព័រ ៤៦ បន្ទាត់ ២០ ដល់ ទំព័រ ៤៧ បន្ទាត់ ១៩, 01626102 ទំព័រ ៨-១២។

[453] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៣០។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626101-01626102 ទំព័រ ៤៧ បន្ទាត់ ២០ ដល់ ទំព័រ ៤៨ បន្ទាត់ ១២។

[454] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ១៧, ២២។

[455] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ១៨។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1 ERN 01626116 ទំព័រ ៦២ បន្ទាត់ ១៤-១៩។

៣៨៥. ជាងនេះទៀត ពាក់ព័ន្ធនឹងការវិភាគ "ថយក្រោយ និងសិប្បនិមិត្ត"[456] លើយុត្តាធិការបុគ្គលតាមរយៈ សហឧក្រិដ្ឋកម្ម ទម្រង់ទីមួយ ទីមួយសហមេធាវីតវ៉ាថា សហព្រះរាជអាជ្ញាយល់ខុសលើទឡ្ហីករណ៍អំពីការដាក់បញ្ចូលគ្នា នូវយុត្តាធិការបុគ្គលជាមួយនឹង សហឧក្រិដ្ឋកម្ម ទម្រង់ទីមួយ។ ខណៈដែលការទទួលខុសត្រូវព្រហ្មទណ្ឌអាចជាកត្តាមួយ ក្នុងការវាយតម្លៃយុត្តាធិការបុគ្គល វាមិនអាចត្រឹមតែជាកត្តាតែមួយឡើយ ពោលគឺយុត្តាធិការបុគ្គល មិនអាចផ្អែកតែលើសមាជិកភាពនៅក្នុងសហឧក្រិដ្ឋកម្ម ទម្រង់ទីមួយនោះទេ[457]។ សហព្រះរាជអាជ្ញាអន្តរជាតិថែមទាំងខកខានមិនបានបង្ហាញថា សហមេធាវីមិនបង្ហាញកំហុសអង្គច្បាប់ នៅក្នុងការវិភាគប្រៀបធៀបតឹងរ៉ឹង របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទៀតផង។ ជាការពិតណាស់ ពាក្យ "ទទួលខុសត្រូវខ្ពស់បំផុត"កំណត់ភាពចាំបាច់ក្នុងការវិភាគប្រៀបធៀបរវាងចារីដែលបានចោទប្រកាន់ ថាតើពួកគេនៅ រស់ ឬក៏ទទួលមរណភាព[458]។

៣៨៦. ចំណុចចុងក្រោយ ពាក់ព័ន្ធនឹង គោលការណ៍វិមតិសង្ស័យ សហមេធាវីលើកទឡ្ហីករណ៍ថា សហព្រះរាជអាជ្ញាផ្តល់ការពន្យល់ដ៏តិចតួច ស្ទើតែគ្មានតែម្តងអំពីវិធីដែលសហចៅក្រមស៊ើបអង្កេត អន្តរជាតិបានបកស្រាយក្នុងន័យចង្អៀតបំផុតតាមហេតុផលលើប្រភេទ ទទួលខុសត្រូវខ្ពស់បំផុត ក្រោមគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ និងការបកស្រាយដ៏តឹងរ៉ឹង[459]។

## ២. ការពិភាក្សា

៣៨៧. ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមអន្តរជាតិមិនមានកំហុសឡើយនៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) តាមរយៈការអះអាងថាបកស្រាយខុស ឬអនុវត្តខុសនូវពាក្យទទួលខុសត្រូវខ្ពស់បំផុតនោះ។ ចៅក្រមអន្តរជាតិសូមរម្លឹកថា ការកំណត់ថាតើ បុគ្គលម្នាក់ស្ថិតក្នុងចំណោមជនដែលទទួលខុសត្រូវខ្ពស់បំផុត គឺជាការសម្រេចដោយឆន្ទានុសិទ្ធិតុលាការ។ ដោយស្ថិតក្នុងសមត្ថកិច្ចរបស់សហចៅក្រមស៊ើបអង្កេត ឆន្ទានុសិទ្ធិនេះគឺត្រូវបានអនុវត្តដោយត្រឹមត្រូវនៅពេលអនុវត្តស្របតាមគោល

---

[456] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៥០។

[457] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ២០។

[458] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ២១។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626123 ទំព័រ ៦៩ បន្ទាត់ ១១-១៧។

[459] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ១៩។

ការណ៍ច្បាប់ដែលមានចែងច្បាស់លាស់[460]។

៣៤៨. ផ្ទុយទៅនឹងទឡ្ហីករណ៍របស់សហមេធាវី ចៅក្រមអន្តរជាតិសម្រេចថា៖ (១) សហចៅក្រមស៊ើបអង្កេត អន្តរជាតិមិនមានកំហុស ដោយអនុវត្ត "ការបកស្រាយទូលំទូលាយពេក"នៃពាក្យជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ឬដោយ "មិនអើពើ"កត្តាជាក់លាក់មួយចំនួន[461] ពីព្រោះសហមេធាវី ខកខានមិនបានផ្តល់ភស្តុតាងគាំទ្រដល់ "ការបកស្រាយក្នុងន័យចង្អៀត"នៃពាក្យជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ។ (២) សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសពាក់ព័ន្ធនឹងគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ពីព្រោះថា ការណ៍នេះគឺជាវិធាននៃបន្ទុកភស្តុតាង(មិនមែនជាការបកស្រាយច្បាប់ឡើយ) និង ពាក្យ ទទួលខុសត្រូវខ្ពស់បំផុតគឺត្រូវបានកំណត់ច្បាស់លាស់[462]។ មិនតែប៉ុណ្ណោះ ចៅក្រមអន្តរជាតិមិនយល់ស្របទេថា (៣) សហចៅក្រមស៊ើបអង្កេតអន្តរជាតិអនុវត្ត "វិធីសាស្ត្រថយក្រោយ និងសិប្បនិមិត្ត"[463] ដែលបំផ្លើសតួនាទីរបស់ អោ អាន ដោយឆ្លងកាត់កញ្ចក់សហឧក្រិដ្ឋកម្មទម្រង់ទីមួយ។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិវាយតម្លៃអំពីការរួមចំណែកជាក់ស្តែងរបស់ អោ អាន នៅក្នុងគោលការណ៍ច្បាប់ដែលមានចែងច្បាស់លាស់។ ចៅក្រមអន្តរជាតិសន្និដ្ឋាន ថា (៤) សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសក្នុងការប្រៀបធៀប អោ អាន ជាមួយ សមាជិកខ្មែរក្រហមមួយចំនួន(ប៉ុន្តែមិនមែន ដទៃទៀត) ហើយសហមេធាវីខកខានមិនបានបង្ហាញ ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការវាយតម្លៃលើកម្រិតទទួលខុសត្រូវនិង/ឬភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មរបស់ អោ អាន តាមការវិភាគលើករណីនីមួយៗ។

៣៤៩. ទីមួយ ចៅក្រមអន្តរជាតិមិនយល់ស្របឡើយថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានធ្វើការបកស្រាយទូលំទូលាយពេកលើពាក្យ ទទួលខុសត្រូវខ្ពស់បំផុត ឬមានកំហុសក្នុងការវាយតម្លៃជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ដោយ "មិនអើពើ" កត្តាជាក់លាក់មួយចំនួន ពោលគឺប្រវត្តិចរិតា ការអនុវត្តរបស់ភាគី និង ទស្សនៈរបស់សហព្រះរាជអាជ្ញាជាតិ ឬចៅក្រមជាតិ[464]។ សហមេធាវីខកខានមិន បាន

[460] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) កថាខណ្ឌ ២០។

[461] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៤៣-៤៤, ៤៦-៤៧។

[462] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងចំណោទទាក់ទងក្នុងសំណុំរឿង ០០៣ (ឯកសារ D87/2/1.7/1/1/7) កថាខណ្ឌ ៦៥។

[463] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៥០។

[464] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៤៤, ៤៦-៤៧។

បង្ហាញថា ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតរួមមាន "ការយល់ឃើញក្នុងន័យចង្អៀត" ដោយផ្អែកលើប្រវត្តិចរចា ការអនុវត្តជាបន្តបន្ទាប់របស់ភាគី ឬទស្សនៈរបស់ភាគីមួយចំនួន។

៣៥០. ចៅក្រមអន្តរជាតិសង្កេតឃើញថា ទោះបីជាពាក្យ ជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតមិនត្រូវបានកំណត់នៅក្នុងកិច្ចព្រមព្រៀង ឬច្បាប់បង្កើត អ.វ.ត.ក ក៏ដោយ ក៏ការបកស្រាយត្រឹមត្រូវ ផ្អែកលើកម្មវត្ថុនិងគោលបំណងរបស់លិខិតូបករណ៍បង្កើតតុលាការ អាចយល់បានតាមរយៈការពិនិត្យមើលលើយុត្តិសាស្ត្រអន្តរជាតិដែលពាក់ព័ន្ធ[465]។

៣៥១. ចៅក្រមអន្តរជាតិកត់សម្គាល់ថា សហមេធាវី បានផ្តល់នូវការបកស្រាយ "ចង្អៀត" គឺផ្អែកលើប្រវត្តិចរចាបង្កើត អ.វ.ត.ក និង/ឬ សេចក្តីថ្លែងរបស់ភាគីចរចា ទាំងនេះគឺគ្រាន់តែជាមធ្យោបាយបន្ថែមនៃការបកស្រាយតាមមាត្រា៣២នៃអនុសញ្ញាទីក្រុងវីយែនដែលនឹងត្រូវយកមកប្រើនៅពេលការបកស្រាយតាមមាត្រា៣១ មានន័យមិនច្បាស់លាស់ ឬនាំដល់លទ្ធផលមិនទំនងឬមិនសមហេតុផល[466]។ ក្នុងករណីនេះ មិនមែនអីចឹងឡើយ។ ផ្ទុយទៅវិញ សហមេធាវីមិនផ្តល់ភស្តុតាងជាក់ស្តែង ឬឧទាហរណ៍ប្រកបដោយខ្លឹមសារដើម្បីគាំទ្រ "ការអនុវត្តជាបន្តបន្ទាប់" ដែលបង្ហាញការព្រមព្រៀងរបស់ភាគីទៅលើការបកស្រាយ "ចង្អៀត"ឡើយ។

៣៥២. ចៅក្រមអន្តរជាតិបញ្ជាក់ដូចគ្នាទៅនឹងបណ្តាអង្គជំនុំជម្រះនៅ អ.វ.ត.ក មួយចំនួនទៀតថា យុត្តិសាស្ត្រ អន្តរជាតិកំណត់ថា ការកំណត់អត្តសញ្ញាណបុគ្គលដែលស្ថិតនៅក្នុងប្រភេទ ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត គឺពាក់ព័ន្ធនឹងការវាយតម្លៃបែបបរិមាណវិស័យនិងគុណវិស័យ នៃ (i) ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទ ឬដែលត្រូវចោទ និង (ii)កម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យ[467]។ អង្គ

---

[465] *សូមមើល* អនុសញ្ញាទីក្រុងវីយែន មាត្រា ៣១(១)-(២) (ចែងថា ពាក្យពេចន៍នៅក្នុងលិខិតុបករណ៍ត្រូវយកមកបកស្រាយជាបឋមទៅតាមបរិបទរបស់វា ដែលក្នុងនោះរួមមាន អត្ថបទនៃលិខិតុបករណ៍ ទៅតាមកម្មវត្ថុ និងគោលបំណងរបស់វា)។ កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១២(១) (ចែងថា នៅពេលមានភាពខ្វះចន្លោះនៅក្នុងច្បាប់ជាធរមាន "គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ")។ ច្បាប់ អ.វ.ត.ក មាត្រា ២៣ថ្មី (ដូចគ្នា)។ *សូមមើលផងដែរ* សាលដីកាលើបណ្តឹងឧទ្ធរណ៍ ស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០២ (D404/2/4) កថាខណ្ឌ ៥៨-៦០។ សាលដីកាក្នុងសំណុំរឿង ០០១ (ឯកសារ F28) កថាខណ្ឌ ៦៦។

[466] *សូមមើល* អនុសញ្ញាទីក្រុងវីយែន មាត្រា ៣១-៣២។

[467] *សូមមើល*ឧទាហរណ៍ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) មតិយោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣២១។ សាលក្រមក្នុងសំណុំរឿង ០០១ (ឯកសារ E188) កថាខណ្ឌ ២២ និងជើងទំព័រក្នុងកថាខណ្ឌនេះ។ ("សេចក្តីសម្រេចលើយុត្តាធិការបុគ្គលក្នុងសំណុំរឿង

ជំនុំជម្រះសូមរម្លឹកថា ពុំមានបញ្ជីកត់ត្រាកត្តាទាំងអស់ដែលត្រូវពិចារណានៅក្នុងការពិនិត្យឡើងវិញនេះទេ ហើយក៏ពុំមានបទដ្ឋានចម្រាញ់ពាក់ព័ន្ធនឹងតំណែងនៅក្នុងឋានានុក្រម[468] ឬ កម្រិតគណិតវិទ្យាសម្រាប់ចំនួនមនុស្សស្លាប់ដែរ។ ក៏ប៉ុន្តែ ការវាយតម្លៃយុត្តាធិការបុគ្គលតម្រូវឱ្យមានការវាយតម្លៃលើករណីនីមួយៗ ដោយពិចារណាលើបរិបទទូទៅ និង កាលៈទេសៈបុគ្គលរបស់ជនសង្ស័យ[469]។

៣៥៣. ចៅក្រមអន្តរជាតិបញ្ជាក់ថា ការវាយតម្លៃទៅលើកម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យ រួមមានការពិចារណាបែបនេះ ប៉ុន្តែមិនកំណត់ត្រឹមតែ កម្រិតនៃការចូលរួមរបស់ជនសង្ស័យនៅក្នុងឧក្រិដ្ឋកម្ម ឋានៈឬតួនាទីតាមឋានានុក្រម នោះទេ ដែលក្នុងនោះរួមមានចំនួនអ្នកនៅក្រោមបង្គាប់ និង ថ្នាក់លើតាមឋានានុក្រម អចិន្ត្រៃយ៍ភាពនៃតំណែង ឬតួនាទីនិងការទទួលខុសត្រូវតាមព្រឹត្តិន័យ[470]។ "ការយល់ឃើញជាលក្ខណៈចង្អៀត"របស់សហមេធាវីលើយុត្តាធិការបុគ្គលដែលថាក្តោបតែមន្ត្រី ខ្មែរក្រហមដែលសំខាន់ក្នុងការបង្កើតនិងអនុវត្តគោលនយោបាយ ប.ក.ក និងដែលមានតំណែងកាន់តែខ្ពស់នៅក្នុង ប.ក.ក និង តួនាទីនៅក្នុងឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត គឺមានកម្រិតខ្លាំងពេក និង ប្រាសចាកពីវិធីសាស្ត្រដែលបានចែងច្បាស់លាស់[471]។

៣៥៤. ទីពីរ ចំពោះគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនសង្ស័យវិញ ចៅក្រមអន្តរជាតិបញ្ជាក់ថា គោលការណ៍នេះមិនមែនជាវិធាននៃការបកស្រាយច្បាប់ទេ ប៉ុន្តែជាការបង្ហាញភស្តុតាង មួយ[472] និង ពិចារណាថា ការបកស្រាយពាក្យ ទទួលខុសត្រូវខ្ពស់បំផុតគឺមានការកំណត់ត្រឹមត្រូវ និង

---

០០៣ (ឯកសារ D48)") កថាខណ្ឌ ១៥ និង ជើងទំព័រ ២៥។

[468] *ផ្ទុយពី* ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (សំអាងហេតុ) (ឯកសារ D308/3) កថាខណ្ឌ ៣៩ ត្រូវបានគាំទ្រនៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៥៦ ជើងទំព័រ ១០១។

[469] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) មតិយោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣២១ *សូមមើលផងដែរ* កថាខណ្ឌ ៣២៧-៣៣៨។

[470] *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) មតិយោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣៣២-៣៣៨។ សាលក្រមក្នុងសំណុំរឿង ០០១ (E188) កថាខណ្ឌ ២២។ សេចក្តីសម្រេចលើយុត្តាធិការបុគ្គលក្នុងសំណុំរឿង ០០៣ (ឯកសារ D48) កថាខណ្ឌ ២៤។

[471] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៤៥-៤៧, ៥៤។ *សូមមើលផងដែរ* ចម្លើយតបរបស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានស្ថាពរ (ឯកសារ D351/6) កថាខណ្ឌ ៨១-៨៤។

[472] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងចំណាងទាក់ទងក្នុងសំណុំរឿង ០០៣ (ឯកសារ D87/2/1.7/1/1/7) កថាខណ្ឌ ៦៥។

ច្បាស់លាស់[473]។ ហេតុដូចនេះ ចៅក្រមអន្តរជាតិយល់ឃើញថា ទឡ្ហីករណ៍របស់សហមេធាវីមិន មានលក្ខណៈត្រឹមត្រូវ ដែលបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិគួរតែបានអនុវត្ត និយមន័យច្បាប់ក្នុងន័យចង្អៀតបំផុតទៅលើពាក្យ ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ក្រោមគោលការណ៍ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ[474]។

៣៥៥. ទីបី ពាក់ព័ន្ធនឹងកំហុសនៃការពិចារណាលើពាក្យ ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតតាមរយៈ សហឧក្រិដ្ឋកម្មទម្រង់ទីមួយ ចៅក្រមអន្តរជាតិពុំជឿជាក់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសដោយ អនុវត្តវិធីសាស្ត្រ "ថយក្រោយ និងសិប្បនិមិត្ត"ឡើយ[475]ដែលជាការបំផ្លើសតួនាទីរបស់ អោ អាន តាមរយៈ សហឧក្រិដ្ឋកម្ម ទម្រង់ទីមួយ។ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានកំណត់យុត្តាធិការបុគ្គលដោយផ្អែកតែទៅលើសមាជិកភាពនៅក្នុងសហឧក្រិដ្ឋកម្ម ទម្រង់ទីមួយ នោះទេ។ សហចៅក្រមស៊ើប អង្កេតអន្តរជាតិបានអនុវត្តឆន្ទានុសិទ្ធិទូលំទូលាយរបស់គាត់ ក្នុងការកំណត់យុត្តាធិការបុគ្គលទៅលើ អោ អាន និង បានពិនិត្យដោយយកចិត្តទុកដាក់លើកត្តាពាក់ព័ន្ធជាច្រើននៅក្នុងទម្រង់ភស្តុតាង ដែលរួមមាន ក្នុងចំណោមបញ្ហាផ្សេងៗ អំពើព្រហ្មទណ្ឌរបស់ អោ អាន ក្នុងនោះរួមមាននៅទីតាំងឧក្រិដ្ឋកម្មផ្សេងៗគ្នា និង តាមរយៈទម្រង់នៃការទទួលខុសត្រូវមួយចំនួនទៀត (ហួសពី សហឧក្រិដ្ឋកម្ម ទម្រង់ទីមួយ)។

៣៥៦. នៅក្នុងដីកាដំណោះស្រាយ(ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានធ្វើការពិចារណាក្នុងការកំណត់ថាតើបុគ្គលណាម្នាក់ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់តុលាការ[476]។ ក្រោយពី

---

[473] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងចំណាងទាក់ទងក្នុងសំណុំរឿង ០០៣ (ឯកសារ D87/2/1.7/1/1/7) កថាខណ្ឌ ៦៥។

[474] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៤៨។ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងចំណាងទាក់ទងក្នុងសំណុំរឿង ០០៣ (ឯកសារ D87/2/1.7/1/1/7) កថាខណ្ឌ ៦៥។

[475] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៥០។

[476] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៥៦ *យោងទៅ*ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (សំអាងហេតុ) (ឯកសារ D308/3) កថាខណ្ឌ ៣៧-៤១ (ក្នុងចំណោមនោះរួមមានកត្តានានាដូចជា៖ "ភាពធ្ងន់ធ្ងរនៃសកម្មភាពផ្ទាល់របស់បុគ្គលម្នាក់ និងផលវិបាកនៃអំពើទាំងនោះ" "កម្រិតដែលជនល្មើសអាចចូលរួមក្នុងការសម្រេចលើគោលនយោបាយ និង/ឬ ការអនុវត្តគោលនយោបាយ" "ការកំណត់ន័យលើខ្លឹមសារនៃគោលនយោបាយ និងមធ្យោបាយអនុវត្តគោលនយោបាយស្ថិតនៅលើថ្នាក់កំពូល" ថាតើ "កម្មាភិបាលថ្នាក់ក្រោមៗត្រូវបានផ្តល់លទ្ធភាពស្វែងយល់លម្អិតនៅក្នុងពេលអនុវត្ត

បានរកឃើញថា អោ អាន ស្ថិតក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ដោយមូលហេតុនៃការរួមបញ្ចូលគ្នានូវឋានៈ និង វិសាលភាពនៃសិទ្ធិអំណាចរបស់គាត់នៅក្នុងឋានានុក្រមកម្ពុជាប្រជាធិបតេយ្យ និង ដោយផ្អែកលើលក្ខណៈ និង ទំហំនៃឧក្រិដ្ឋកម្មរបស់គាត់[477] សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសន្និដ្ឋានថា ទាំងតួនាទីនិងការប្រព្រឹត្តរបស់ អោ អាន បានកំណត់ច្បាស់ថាគាត់គឺជាអ្នកដើរតួនាទីដ៏សំខាន់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង ជាអ្នកចូលរួមប្រព្រឹត្តម្នាក់ដោយចេតនា និងមានទឹកចិត្តក្នុងការអនុវត្តគោលនយោបាយឧក្រិដ្ឋនិងអមនុស្សធម៌[478]។

៣៥៧. ទោះបីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិវាយតម្លៃអំពើប្រល័យពូជសាសន៍ និង ផ្តល់តួលេខ ១៧.១១៥ នាក់ ដែលមានកម្រិតអប្បបរមា "បំផុត" នៃចំនួនជនជាតិចាមនៅភូមិភាគកណ្តាលតាមរយៈសហឧក្រិដ្ឋកម្ម ទម្រង់ទីមួយ ក៏ពិតមែន ប៉ុន្តែគាត់ក៏ពិចារណាលើទម្រង់នៃការទទួលខុសត្រូវត្រង់ចំណុចនេះដែរ[479] ។ ឥទ្ធិពលដ៏សំខាន់លើសហគមន៍ចាមគឺជាការពិចារណាដ៏សំខាន់មួយក្នុងការវាយតម្លៃអំពីលក្ខណៈ និង ភាពធ្ងន់ធ្ងរនៃឧក្រិដកម្មរបស់ អោ អាន[480]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏បានពិចារណាលើទីតាំងឧក្រិដ្ឋកម្មដទៃទៀតក្រោមការគ្រប់គ្រងរបស់ អោ អាន ផងដែរ។ ការណ៍នេះរួមមានមន្ទីរសន្តិសុខ និង កន្លែងសម្លាប់មនុស្ស ដែលតាមការប៉ាន់ប្រមាណតាមរបៀបអភិរក្សរបស់គាត់ គឺមានចំនួនមនុស្ស ១២.៩៤៤ នាក់ ត្រូវបានសម្លាប់ និង ការដ្ឋានដែលមានប្រជាជនរាប់ពាន់នាក់ត្រូវបានបង្ខំ ឲ្យធ្វើការក្រោមលក្ខខណ្ឌដ៏ពិបាក និង ការគំរាមសម្លាប់[481]។ ហេតុដូចនេះ ចៅក្រមអន្តរជាតិសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសតាមរយៈការអនុវត្តវិធីសាស្ត្រ "ថយក្រោយ និង សិប្បនិមិត្ត" ឬតាមរយៈការដាក់បញ្ចូលគ្នានូវយុត្តាធិការបុគ្គលជាមួយនឹងទម្រង់នៃការទទួលខុសត្រូវសហឧក្រិដ្ឋកម្ម

គោលនយោបាយទាំងនោះ" ឬយ៉ាងណា ហើយថា ពុំមានចំនួនជាក់លាក់នូវបុគ្គលដែលស្ថិតក្រោមយុត្តាធិការរបស់តុលាការទេ ហើយការជ្រើសរើសពឹងផ្អែកទាំងស្រុងទៅលើអង្គសេចក្តីនៃសំណុំរឿងនីមួយៗ)។

[477] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៦៩៩។

[478] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៧១២។

[479] ចៅក្រមអន្តរជាតិសន្និដ្ឋានថា ក្រៅពីសហឧក្រិដ្ឋកម្មរួម សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទប្រកាន់ អោ អាន ចំពោះការរៀបចំផែនការ ការបញ្ជា និងការញុះញង់ឲ្យមានអំពើប្រល័យពូជសាសន៍ទៅលើជនជាតិចាមនៅខេត្តកំពង់ចាម និងក្រោមការទទួលខុសត្រូវរបស់ថ្នាក់លើចំពោះអំពើប្រល័យពូជសាសន៍ទៅលើជនជាតិចាមនៅតំបន់ ៤១។ (សូមមើលឧទាហរណ៍ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៨៣៥, ៨៣៩, ៨៤៣, ៨៤៨-៨៤៩។

[480] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៧០៦-៧០៧

[481] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៧១១។

ទម្រង់ទីមួយនោះឡើយ។

៣៩៨. ទីបួន ចំពោះការលើកឡើងថាជាកំហុសរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងការប្រៀបធៀប អោ អាន ទៅនឹង អ៊ឹម ចែម និង ឌុច អង្គជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេត អន្តរជាតិមិនមានកំហុសក្នុងការវាយតម្លៃលើកម្រិតនៃការទទួលខុសត្រូវ និង/ឬភាពធ្ងន់ធ្ងរនៃ ឧក្រិដ្ឋកម្មរបស់ អោ អាន ឡើយ ក្នុងនោះរួមមានការប្រៀបធៀបជាមួយមន្ត្រីខ្មែរក្រហមមួយចំនួន (មិនបញ្ជាក់ថា ដទៃទៀតឡើយ)។ ចៅក្រមអន្តរជាតិកត់សម្គាល់ថា ខណៈដែលការវាយតម្លៃថាតើ ជនសង្ស័យណាម្នាក់ស្ថិតក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត អាចរួមបញ្ចូលការ ប្រៀបធៀបទៅនឹងមន្ត្រីខ្មែរក្រហមដទៃទៀត[482] ការប្រៀបធៀបទៅនឹងមន្ត្រីខ្មែរក្រហមគ្រប់រូបដែលគេស្គាល់គឺមិនមែនជាលក្ខខណ្ឌតម្រូវ ឬចាំបាច់ឡើយ[483]។ ជាងនេះទៀត អ៊ឹម ចែម និង ឌុច គឺជាមន្ត្រីខ្មែរក្រហមដែលបញ្ជាយុត្តាធិការបុគ្គលរបស់ខ្លួនជា "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ត្រូវបានតទល់ក្ដីនៅចំពោះមុខអង្គជំនុំជម្រះរបស់ អ.វ.ត.ក[484]។ ហេតុដូចនេះ ប្រការនេះមានលទ្ធភាពអាចធ្វើជាការវិភាគដោយសត្យានុម័តទៅលើអត្ថិភាពនៃឧក្រិដ្ឋកម្ម និង ភវនីយភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពុំមានកំហុសនៅក្នុងវិធីសាស្ត្រប្រៀបធៀបជាមួយនឹងមន្ត្រីខ្មែរក្រហមចំនួន២នាក់ទៀត ឡើយ។

៣៩៩. ចៅក្រមអន្តរជាតិកត់សម្គាល់ទៀតថា ការប្រៀបធៀបទៅនឹងមន្ត្រីខ្មែរក្រហមដទៃទៀតគឺគ្រាន់តែ

---

[482] *សូមមើលឧទាហរណ៍* សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) មតិយោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣៣៦ (កត់សម្គាល់ពីតួនាទី និងការទទួលខុសត្រូវជាក់ស្ដែងរបស់ អ៊ឹម ចែម ដែលហួសពីតួនាទី និងការទទួលខុសត្រូវរបស់លេខាស្រុកកម្ពុជា)។

[483] *សូមមើល* សាលក្រមក្នុងសំណុំរឿង ០០១ (ឯកសារ E188) កថាខណ្ឌ ២៤ ("ដោយសារទំហំនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ កិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក មិនបានដាក់កាតព្វកិច្ចឱ្យវិនិច្ឆ័យជនទាំងឡាយដែលអាចជាចារីដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងយុត្តាធិការរបស់ អ.វ.ត.ក ទេ។ [...] អង្គហេតុដែលថា បុគ្គលផ្សេងទៀតនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ដែលក្នុងអំឡុងពេលកាត់សេចក្ដី អាចនឹងចូលរួមប្រព្រឹត្តបទល្មើសដូចគ្នាក៏ដោយ ក៏វាមិនបានធ្វើឱ្យជនជាប់ចោទរួចផុតពីការចោទប្រកាន់ថា គាត់គឺជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតដែរ") (លុបចោលជើងទំព័រ)។

[484] *សូមមើលឧទាហរណ៍* សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) មតិយោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣២១-៣៤០។ *សូមមើលផងដែរ* សាលក្រមក្នុងសំណុំរឿង ០០១ (ឯកសារ E188) កថាខណ្ឌ ១៣-២៥។ សាលដីកាក្នុងសំណុំរឿង ០០១ (ឯកសារ F28) កថាខណ្ឌ ៥៨-៨១។

ជា កត្តាមួយក្នុងចំណោមកត្តាមួយចំនួនទៀតដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិធ្វើការពិចារណាដោយត្រឹមត្រូវ។ នៅក្នុងដីកាដំណោះស្រាយ(ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) សហចៅក្រមស៊ើបអង្កេតអន្តរជាតិសន្និដ្ឋានថា អោ អាន "ស្ថិតក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ពីព្រោះ ក្នុងចំណោមបញ្ហាផ្សេងៗ ការបញ្ចូលគ្នានូវឋានៈ និង វិសាលភាពសិទ្ធិអំណាចរបស់គាត់នៅក្នុងឋានានុក្រមនៃកម្ពុជាប្រជាធិបតេយ្យ" ការប្រព្រឹត្តិរបស់គាត់ "ជាអ្នកចូលរួមប្រព្រឹត្តម្នាក់ដោយចេតនា និងមានទឹកចិត្តក្នុងការអនុវត្តគោលនយោបាយឧក្រិដ្ឋ និងអមនុស្សធម៌សាហាវយង់ឃ្នង" និង "លក្ខណៈ និង ទំហំនៃឧក្រិដ្ឋកម្មរបស់គាត់"។ ជាងនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្លែងថាជាការច្បាស់ណាស់ថា មុខតំណែង លក្ខណៈ វិសាលភាពភូមិសាស្ត្រ និង ផលប៉ះពាល់នៃសកម្មភាព របស់ អោ អាន គឺ ច្បាស់ជាលើសជាងអ្វីដែល អ៊ឹម ចែម និង ឌុច មាន[485]។ ជាការប្រសើរបំផុតគឺថា ការប្រៀបធៀបទៅនឹងមន្ត្រីខ្មែរក្រហមដទៃទៀតគឺជាកត្តាមួយក្នុងចំណោមកត្តាជាច្រើនផ្សេងទៀត នៅក្នុងការវាយតម្លៃ ប៉ុន្តែមិនមែនជាកត្តាដែលមិនអាចប្រកែកបាននៅក្នុងការពិចារណារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិឡើយ។

៣៦០. ហេតុដូច្នេះ ចៅក្រមអន្តរជាតិយល់ឃើញថាពុំមានកំហុសឡើយ និងច្រានចោលមូលដ្ឋានទី៣។

## ឃ. មូលដ្ឋានទី៤÷ ការអនុវត្តបទដ្ឋាននៃការបង្ហាញភស្តុតាងមិនត្រឹមត្រូវ

### ១. សារណា

៣៦១. សហមេធាវីការពារក្តីជំទាស់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានអនុវត្តបទដ្ឋាននៃការបង្ហាញភស្តុតាងដែលត្រឹមត្រូវក្នុងការកំណត់ថា តើ អោ អាន ស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឬយ៉ាងណា[486]។ ដោយហេតុថា ការកំណត់យុត្តាធិការបុគ្គលមានសារៈសំខាន់ កំហុសនេះបង្កើតបានជាបន្ទុកមួយលើមេធាវីការពារក្តី និងនាំឱ្យមានការខ្វះខ្នាយធនធានតុលាការ[487]។ សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនដែលកំណត់អត្ថន័យអំពីបទដ្ឋាននៅក្នុង ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឡើយ និងថា "បទដ្ឋានដែលត្រូវបានយកមកអនុវត្តនៅត្រង់ចំណុចណារវាងមូលដ្ឋាន *បឋម* និងមូលដ្ឋានសមហេតុផលដើម្បីធ្វើឱ្យជឿជាក់

[485] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៦៩៩-៧១២។

[486] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/5/1) កថាខណ្ឌ ៥៥។

[487] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/5/1) កថាខណ្ឌ ៥៦។

ដែលមូលដ្ឋានទាំងពីរនេះមិនត្រឹមត្រូវនោះទេ”[488]។ សហមេធាវីអះអាងថា បទដ្ឋានត្រឹមត្រូវតម្រូវថា សហចៅក្រមស៊ើបអង្កេត ប្រមូល “ភស្តុតាងដែលមានលក្ខណៈខ្លាំងក្លា និងស៊ីសង្វាក់គ្រប់គ្រាន់ ដើម្បីឱ្យមានតម្លៃជាភស្តុតាងបន្ទាល់ ដល់ការបង្ហាញឱ្យលើសពីគ្រាន់តែជាភវនីយភាពថា អោ អាន គឺជាបុគ្គលម្នាក់ដែលស្ថិតនៅក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលត្រូវបានយកមកចោទប្រកាន់”[489]។ សហមេធាវីសន្និដ្ឋានថា ប្រសិនបើសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអនុវត្តបទដ្ឋាននៃការបង្ហាញភស្តុតាងត្រឹមត្រូវ ម្ល៉េះសម អ.វ.ត.ក មិនអាចអនុវត្តយុត្តាធិការបុគ្គលលើ អោ អាន ឡើយ[490]។

៣៦២. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា អំណះអំណាងរបស់សហមេធាវីមួយផ្នែក គឺជាការចោទប្រកាន់គ្មានហេតុផលលើកំហុសអង្គហេតុ[491] និង មួយផ្នែកទៀតជាការលើកឡើងជារួមនិងគ្មានមូលដ្ឋានដែលមិនបានបញ្ជាក់ឱ្យបានច្បាស់អំពីកំហុសច្បាស់លាស់ និងគួរបានច្រានចោល[492]។ សហមេធាវីមិនបានលើកឡើងអំពីអំណះអំណាងទាំងនេះនៅក្នុងការឆ្លើយតបឡើយ។

## ២. ការពិភាក្សា

៣៦៣. ចៅក្រមអន្តរជាតិសម្រេចថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសឡើយ ចំពោះការអះអាងថាមានការខកខានមិនបានកំណត់អត្ថន័យ ឬអនុវត្តបទដ្ឋាននៃការបង្ហាញភស្តុតាងត្រឹមត្រូវ។ អង្គបុរេជំនុំជម្រះយល់ឃើញថា (១) ការិយាល័យសហចៅក្រមស៊ើបអង្កេតបានបញ្ជាក់យ៉ាងច្បាស់ម្តងហើយម្តងទៀត និងតម្កល់បទដ្ឋានត្រឹមត្រូវក្នុងការចេញដីកាដំណោះស្រាយនានា និង (២) ការយល់ឃើញនេះ ត្រូវបានឆ្លុះបញ្ចាំងសមហេតុផលនៅក្នុងដីកាដំណោះស្រាយនេះ(ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ដែលបង្ហាញការអនុវត្តបទដ្ឋានត្រឹមត្រូវទាំងស្រុង។

៣៦៤. ទីមួយ អង្គបុរេជំនុំជម្រះរម្លឹកថា “អនុលោមតាមវិធាន៦៧ នៃវិធានផ្ទៃក្នុង លក្ខខណ្ឌវិនិច្ឆ័យសម្រាប់

---

488 បណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/5/1) កថាខណ្ឌ ៥៧។

489 បណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/5/1) កថាខណ្ឌ ៥៥។

490 បណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/5/1) កថាខណ្ឌ ៥៧។

491 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៣១។

492 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៣១។

ការចេញដីកាដំណោះស្រាយគឺអត្ថិភាពនៃ "ភស្តុតាងគ្រប់គ្រាន់ [...] ដើម្បីផ្តន្ទាទោសជនត្រូវចោទ"[493]។ នៅក្នុងដំណាក់កាលមុនជំនុំជម្រះក្តីនេះ វាគ្រប់គ្រាន់ហើយសម្រាប់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងការបង្ហាញភស្តុតាងដែលមានលក្ខណៈខ្លាំងក្លា និងស៊ីសង្វាក់"[494]។

៣៦៥. ចៅក្រមអន្តរជាតិសង្កេតឃើញថា នៅក្នុងដីកាដំណោះស្រាយលើកមុនក្នុងសំណុំរឿង០០១ សំណុំរឿង០០២ និង សំណុំរឿង០០៤/០១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនដែលខកខានក្នុងការដោះស្រាយបទដ្ឋាននៃការបង្ហាញភស្តុតាងដែលអាចអនុវត្តបាននេះនៅក្នុងដំណាក់កាលមុនការជំនុំជម្រះក្តីឡើយ[495]។ ក៏ប៉ុន្តែ នៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) នេះ ទោះបីជាសហ

---

[493] *សូមមើល* កថាខណ្ឌ ៨៤ ដល់ ៨៧។ សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ (D308/3/1/20) កថាខណ្ឌ ៦១-៦២ ("អនុលោមតាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង លក្ខខណ្ឌវិនិច្ឆ័យសម្រាប់ការចេញដីកាដំណោះស្រាយ គឺអត្ថិភាពនៃ "ភស្តុតាងគ្រប់គ្រាន់ [...] នៃបទចោទ"។ [...])។

[494] *សូមមើល* កថាខណ្ឌ ៨៤។ សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ (D308/3/1/20) កថាខណ្ឌ ៦១, ៣០៥, ៣១៣។

[495] *សូមមើល ឧ.* សំណុំរឿង ០០១ (D99) កថាខណ្ឌ ១៣០ (សហចៅក្រមស៊ើបអង្កេតបានសម្រេចថា ដោយផ្អែកលើអង្គហេតុដូចបានរៀបរាប់ខាងលើ "មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ (*charges suffisantes*) ក្នុងការបញ្ជូន កាំង ហ្កេកអ៊ាវ ហៅ ឌុច ទៅជំនុំជម្រះ" សម្រាប់បទល្មើសជាក់លាក់មួយចំនួន និងផ្នែកទី៤៖ សេចក្តីសម្រេច ទំព័រ ៧២ "ជាលទ្ធផល ការស៊ើបសួរបានបង្ហាញថា មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ប្រឆាំងនឹង កាំង ហ្កេកអ៊ាវ ហៅ ឌុច តាមរយៈអំពើសកម្ម និងអកម្មរបស់ខ្លួននៅទីក្រុងភ្នំពេញ និងលើទឹកដីកម្ពុជា [...] ត្រូវតែទទួលខុសត្រូវ [...]" ចំពោះឧក្រិដ្ឋកម្មជាក់លាក់មួយចំនួនដែលបានចោទប្រកាន់)។ *សូមមើលផងដែរ* ដីកាដំណោះស្រាយលើសំណុំរឿង ០០២ (D427) កថាខណ្ឌ ១៣២៣ (ដែលការិយាល័យសហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា "នៅក្នុងដំណាក់កាលស៊ើបសួរមុនអង្គសេចក្តីនេះ មិនមានការតម្រូវឱ្យបង្ហាញអំពីពិរុទ្ធភាពរបស់ជនត្រូវចោទទេ (ព្រោះថាអង្គជំនុំជម្រះសាលាដំបូង គឺជាស្ថាប័នតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការធ្វើដូច្នេះ) ប៉ុន្តែ ចាំបាច់ត្រូវមានការបង្ហាញអំពី"ភវនីយភាព"នៃពិរុទ្ធភាព (មានន័យថា ស្ថានភាពដែលលើសពីលទ្ធភាពដែលអាចកើតមានធម្មតា)។ ហេតុដូច្នេះ ការវាយតម្លៃអំពីភស្តុតាងដាក់បន្ទុកនៅក្នុងដំណាក់កាលនេះ មានលក្ខណៈខុសពីសញ្ញាណនៃ 'ជំនឿស៊ប់របស់ចៅក្រម' នៅក្នុងដំណាក់កាលជំនុំជម្រះ ប៉ុន្តែ ភស្តុតាងនៅក្នុងសំណុំរឿង ត្រូវមានលក្ខណៈខ្លាំងក្លា និងស៊ីសង្វាក់គ្រប់គ្រាន់ដើម្បីឱ្យមានការវាយតម្លៃជាភស្តុតាបន្ទាល់") (ជើងទំព័រយោងត្រូវបានលុបចោល)។ *សូមមើលផងដែរ* ដីកាដំណោះស្រាយ (សំអាងហេតុ) លើសំណុំរឿង ០០៤/១ (D308/3) កថាខណ្ឌ ២ (ដែលការិយាល័យសហចៅក្រមស៊ើបអង្កេត (រួមទាំងសហចៅក្រមស៊ើបអង្កេតអន្តរជាតិផងដែរ ចំពោះបញ្ហានេះ) បានសម្រេចថា "នៅក្នុងដីកាដំណោះស្រាយនេះ (សំអាងហេតុ) ការកត់សម្គាល់អង្គហេតុអំពីការចូលរួម [កោសលុប] គឺផ្អែកលើបទដ្ឋានលក្ខខណ្ឌភវនីយភាព សម្រាប់ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ មិនមែនលើលក្ខខណ្ឌបទដ្ឋាន 'ដោយគ្មានវិមតិសង្ស័យ' សម្រាប់សេចក្តីសម្រេចផ្តន្ទាទោស បន្ទាប់ពីការជំនុំជម្រះក្តី" ដែលយោង និងសម្រេចតាមយុត្តិសាស្ត្រ ពាក់ព័ន្ធនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ក្នុងកថាខណ្ឌ ២ ជើងទំព័រយោងលេខ ២ ដែលយោងទៅដីកាដំណោះស្រាយលើសំណុំរឿង ០០២ ((D427) កថាខណ្ឌ ១៣២៣-១៣២៦ *ដែលនៅក្នុងនោះ*បានសម្រេចថា បទដ្ឋានសម្រាប់

ចៅក្រមស៊ើបអង្កេតអន្តរជាតិព្យាយាមអនុវត្តឡើងវិញនូវឋានានុក្រមនៃភស្តុតាង ដែលត្រូវបានអង្គបុរេជំនុំជម្រះនេះប្រកាសមិនយល់ស្របក្នុងសំណុំរឿង០០៤/០១ យ៉ាងណាក៏ដោយ[496] ក៏សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានបញ្ជាក់អំពីបទដ្ឋានឲ្យបានច្បាស់លាស់ និងមិនបានលើកយកមកសម្អាងនូវផ្នែកពាក់ព័ន្ធនៃដីកាដំណោះស្រាយមុនៗឡើយ។ កំហុសដោយការធ្វេសប្រហែសនេះគឺគួរឲ្យសោកស្ដាយដោយហេតុថា វាធ្វើឲ្យប៉ះពាល់ដល់ភាពច្បាស់លាស់នៃសម្អាងហេតុតាមផ្លូវតុលាការ។

៣៦៦. ទីពីរ ទោះជាយ៉ាងណាក៏ដោយ ចៅក្រមអន្តរជាតិជឿជាក់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានកំហុសឡើយក្នុងការអនុវត្តរបស់គាត់នូវបទដ្ឋាននៃការបង្ហាញភស្តុតាងត្រឹមត្រូវជារួម។ ទោះបីជាកត់សម្គាល់ឃើញអំពីការនិយាយយោងខុសប្រក្រតីទៅលើភស្តុតាងក៏ដោយ[497] ក៏ចៅក្រមអន្តរជាតិបានពិនិត្យពិច័យលើការចោទប្រកាន់នីមួយៗរបស់សហមេធាវី និងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ទាំងមូល។ ការពិនិត្យយ៉ាងល្អិតល្អន់បង្ហាញថា ជារួម សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំបានអនុវត្តផ្ទុយពីបទដ្ឋានដែលបានបង្កើតឡើងឡើយ ហើយជាការពិត បានអនុវត្តបទដ្ឋាននៃការបង្ហាញភស្តុតាងត្រឹមត្រូវ ពោលគឺ អត្ថិភាពនៃ "ភស្តុតាងគ្រប់គ្រាន់[...]ដើម្បីផ្ដន្ទាទោសជនត្រូវចោទ"[498] នៅក្នុងដីកាដំណោះស្រាយ(ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)។

៣៦៧. ឧទាហរណ៍ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) បង្ហាញអំពីការអនុវត្តបទដ្ឋាននៃការបង្ហាញភស្តុតាងយ៉ាងត្រឹមត្រូវ ក្នុងការសម្រេច *ក្នុងចំណោមបញ្ហាផ្សេងៗ*ថា៖ "សក្ខីកម្ម[...]អាចមានលក្ខណៈគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីអង្គហេតុណាមួយក្នុងករណីដែលអាចជឿជាក់បាននិងមានតម្លៃជាភស្តុតាងគ្រប់គ្រាន់"[499]។ "មានភស្តុតាងរបស់សាក្សីគ្រប់គ្រាន់ [..] ដើម្បីសន្និដ្ឋានថា"[500]។ "ក៏មានភស្តុតាងគ្រប់គ្រាន់អាចសន្និដ្ឋានបានផងដែរថា[...]"[501]។ ការរៀបរាប់របស់សាក្សីមួយ ចំនួន"មានលក្ខណៈគ្រប់

ភស្តុតាងត្រូវមានលក្ខណៈខ្លាំងក្លា និងស៊ីសង្វាក់គ្រប់គ្រាន់ ដើម្បីឲ្យមានការវាយតម្លៃក្នុងកម្រិតជាក់លាក់មួយជាភស្តុតាបន្ទាល់)។

[496] *សូមមើលក្នុងចំណោម* កថាខណ្ឌ ៧៣ ដល់ ៨០។ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៣៥-៣៧, ១២៣-១៥៤។

[497] *សូមមើល ឧ.* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៥៧២, ៥៨៧ ឬ ៧០៥ (ដែលយោងទៅលើឧត្តមានុភាពនៃភស្តុតាងដូចបានអះអាងនៅក្នុងការពិភាក្សាទាំងនេះ)។

[498] សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ (D308/3/1/20) កថាខណ្ឌ ៦១-៦២។

[499] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D360) កថាខណ្ឌ ១៣០។

[500] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៤២២។

[501] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៧០៥។

គ្រាន់បំពេញលក្ខខណ្ឌ"[502] និង "កាលៈទេសៈទាំងនេះគឺជាភស្តុតាងគ្រប់ គ្រាន់ដែលបង្ហាញថា [...]"[503]។ ជាចុងក្រោយ សហចៅក្រមស៊ើបអង្កេត អន្តរជាតិបញ្ជាក់ថា "ខ្ញុំបានរកឃើញថាមានបទចោទគ្រប់គ្រាន់ក្នុងការបញ្ជូន អោ អាន ទៅជំនុំជម្រះ [...]"[504]។

៣៦៨. ដោយបានរកឃើញថា បទដ្ឋាននៃការបង្ហាញភស្តុតាងត្រឹមត្រូវ ត្រូវបានយកមកអនុវត្តនៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ជារួមនោះ[505] ចៅក្រមអន្តរជាតិមិនជឿជាក់ទៅលើអំណះអំណាងរបស់សហមេធាវីឡើយដែលថា សហចៅក្រមអន្តរជាតិ "បត់បែន និងពន្លាតបទដ្ឋាននៃការបង្ហាញភស្តុតាង ហេតុដូច្នេះបទដ្ឋាននេះមិនអាចទទួលស្គាល់តទៅទៀតបានទេ"[506]។ អាស្រ័យហេតុនេះ ចៅក្រមអន្តរជាតិសម្រេចបដិសេធមូលដ្ឋានទី៤។

### ខ. មូលដ្ឋានទី៥÷ ការពិចារណាលើភស្តុតាង - សេចក្តីផ្តើម

៣៦៩. មូលដ្ឋានទី៥ តវ៉ាចំពោះកំហុសរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការពិចារណាលើភស្តុតាង។ សហមេធាវីការពារក្តីអះអាងថា ប្រសិនបើសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានវាយតម្លៃត្រឹមត្រូវ និងពេញលេញលើខ្លឹមសារនៃភស្តុតាងមែននោះ គាត់ពុំអាចសម្រេចថា បទដ្ឋាននៃការបង្ហាញភស្តុតាងជាធរមានត្រូវបានបំពេញ ឬ អោ អាន ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក នោះទេ[507]។ អនុលោមតាមមូលដ្ឋានទី៥ សហមេធាវីការពារក្តីលើកឡើងនូវមូលដ្ឋានពាក់ព័ន្ធគ្នាចំនួន ០៥ ពោលគឺ សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខាន៖ (i) អនុវត្តសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/១ (ពោលគឺ ភស្តុតាងត្រូវយកមកវាយតម្លៃដោយសេរី)[508] (ii) វាយតម្លៃលើភាពគួរឱ្យជឿទុកចិត្ត

---

[502] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៨១៥។

[503] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៧៥២។

[504] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៨៥៣។

[505] សូមមើល *បន្ថែម ដែលក្នុងនោះរួមមាន* មូលដ្ឋានទី ៦, ៧។

[506] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/5/1) កថាខណ្ឌ ៥៧។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ពួកគេ (ឯកសារ D360/5/1) កថាខណ្ឌ ៥៧ ជើងទំព័រយោងលេខ ១០២ សហមេធាវីការពារក្តីបង្ហាញ "ឧទាហរណ៍ច្បាស់ក្រឡែតបំផុត" ចំនួនពីរនៃការអនុវត្តខុសទៅលើបទដ្ឋានដូចបានអះអាង ពាក់ព័ន្ធនឹងការយល់ឃើញថា អោ អាន ជាអនុលេខាភូមិភាគកណ្តាល និងជាលេខាភូមិភាគកណ្តាលស្តីទី *នៅក្នុងស្ថានភាពជាក់ស្តែង*។ មានកំហុសអង្គហេតុដូចបានលើកឡើង ដែលនឹងត្រូវពិនិត្យពិច័យយ៉ាងល្អិតល្អន់នៅក្នុងមូលដ្ឋានទី ៦ នៃសាលដីកានេះ (*សូមមើលខាងក្រោម* មូលដ្ឋានទី ៦ (iv))។

[507] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៥៩។

[508] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៦០-៦១ *យោង*សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/១

បានរបស់សាក្សី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីសំខាន់ៗ[509] (iii) ពិចារណា "វិធីសាស្ត្រគួរឱ្យសង្ស័យ" ដែលត្រូវបានប្រើប្រាស់ដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងការ "យក" ភស្តុតាង[510] (iv) ផ្ដល់ភស្តុតាងស៊ីសង្វាក់[511] និង (v) ប្រុងប្រយ័ត្នក្នុងការផ្អែកលើភស្តុតាងចចាមអារ៉ាម[512]។ ចៅក្រមអន្តរជាតិនឹងវាយតម្លៃលើអង្គសេចក្ដីនៃមូលដ្ឋាននីមួយៗ ក្នុងចំណោមមូលដ្ឋានទាំងនេះ។

## មូលដ្ឋានទី ៥(i). ការចោទប្រកាន់ចំពោះការខកខានអនុវត្តសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/១

### ១. សារណា

៣៧០. នៅក្នុងមូលដ្ឋានទី៥(i) សហមេធាវីការពារក្ដីតវ៉ាថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនពិចារណា ឬ បកស្រាយខុសលើការសម្រេចរបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/១ ហើយមានកំហុសចំពោះការអនុវត្តឋានានុក្រមនៃភស្តុតាងដោយផ្អែកលើប្រភព និងទម្រង់[513]។ សហ មេធាវីការពារ

---

លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ៥២-៥៩។ ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ២៤-២៧។ ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 01626065 ទំព័រ ១១:១៣-១១:២៣។

[509] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៦២-៧៥។ ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ២៨-៣០។ ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 01626065-01626068 ទំព័រ ១១:២២-១១:២៣, ១២:១២-១៤:៥។

[510] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧៦។ ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ២៩,៣២។ ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 01626068-01626069 ទំព័រ ១៤:៤-១៥:៣។

[511] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧៧។ ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ២៩។ ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 01626069-01626070 ទំព័រ ១៥:៣-១៦:៣។

[512] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧៨។ ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៣៥។ ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1ERN 01626070 ទំព័រ ១៦:៣-១៦:១៣។

[513] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៥៨-៦១ *យោង*សេចក្ដីពិចារណាក្នុងសំណុំរឿង ០០៤/១ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ៥២-៥៩ *និង* ដីកាដំណោះស្រាយ (ដីកា

ក្តីអះអាងថា "វាជាតួនាទីរបស់សហចៅក្រមស៊ើបអង្កេតដែលត្រូវវាយតម្លៃឱ្យបាន ពេញលេញ លើខ្លឹមសារនៃភស្តុតាង រួមទាំងភាពគួរឱ្យជឿជាក់បានផង នៅដំណាក់កាលចេញដីកាដំណោះស្រាយ"[514]។ សហមេធាវីការពារក្តីអះអាងថា ការវាយតម្លៃលើភាពអាចទុកចិត្តបាន ចាំបាច់ត្រូវពិនិត្យលើ (១) ភាពគួរឱ្យជឿទុកចិត្តរបស់សាក្សី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និង (២) កាលៈទេសៈនៃការទទួលបានភស្តុតាង ពោលគឺ យោងតាមការយល់ ឃើញរបស់សហមេធាវីការពារក្តី សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានធ្វើដូច្នេះ ដោយបាន "ជ្រើសរើសវិធីសាស្ត្រសម្រេចតាមទម្រង់ជាជាងខ្លឹមសារ រួមជាមួយនឹងឋានានុក្រមរបស់គាត់"[515]។

៣៧១. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា ទោះបីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ "មិនយល់ស្របជាមួយនឹងការផ្តល់សំអាងហេតុខ្លះៗរបស់ អ.ប.ជ នៅក្នុងសំណុំរឿង ០០៤/១" ក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំបានអនុវត្តឋានានុក្រមតឹងរ៉ឹង នៅពេលវាយតម្លៃលើភស្តុតាងនោះដែរ ហើយ តាមការអនុវត្តជាក់ស្តែង សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិនិត្យតម្លៃភស្តុតាងដែលជាប់ទាក់ទងនឹងគ្នា រួមទាំង បញ្ហានៃភាពអាចជឿជាក់បាន និងភាពអាចទុកចិត្តបានផ្សេងទៀត[516]។ សហព្រះរាអាជ្ញាអន្តរជាតិអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិនិត្យទៅលើការលើកឡើងរបស់ភាគី ឬ ក្រោមកាលៈទេសៈដែលគេមិនដឹង ដោយប្រុងប្រយ័ត្ន ដោយបានសំអាងលើការលើកឡើងទាំងនេះ នៅពេលណាដែលព័ត៌មាននោះ មានលក្ខណៈស៊ីសង្វាក់ជាមួយនឹងប្រភពផ្សេងទៀត[517]។ លើសពីនេះទៀត ក្រៅពីការសំអាងលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី "ដែលអាចធ្វើ

---

បញ្ជូនរឿងទៅជំនុំជម្រះ)(ឯកសារ D360) កថាខណ្ឌ ៣៥, ៣៧(ក)។ ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ២៣-២៧។ ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 01626062 & 01626065 ទំព័រ ១១:១៣-១១:២៣។

[514] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៦១ និង យោងជើងទំព័រលេខ ១១០។

[515] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៦១។ ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 01626065, 01626066 & 01626070 ទំព័រ ១១:២២-១១:២៣, ១២:៨-១២:១១, ១៦:១១-១៦:១៣។

[516] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៣៣ *យោង*ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៣៧(ក)(i), ២២៣, ២២៩, ២៤១, ២៦១, ៣៤២, ៣៦៨, ៣៧៥, ៣៧៨, ៣៩០, ៤០៤, ៤១១, ៥២៩-៥៣០, ៥៨៧, ៦២១-៦២២, ៦២៤។ ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/8.1 និង D360/18.1 ERN 01626038 ទំព័រ ៤៩:១៦-៤៩:១៩។

[517] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៣៣

ឱ្យមានមន្ទិល” ដែលមិនធ្លាប់បានពិនិត្យពិច័យឱ្យបានត្រឹមត្រូវមុនពេលដាក់មក សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដឹកនាំការស្តាប់ចម្លើយជាផ្លូវការជាមួយអ្នកដាក់ពាក្យសុំទាំងនោះ ដែលតាមការយល់ឃើញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ “បានបង្ហាញវិធីសាស្ត្រដ៏ប្រុងប្រយ័ត្ន និងសមស្របមួយសម្រាប់ការវាយតម្លៃលើភស្តុតាង”[518]។

៣៧២. នៅក្នុងការឆ្លើយតប សហមេធាវីការពារក្តីអះអាងថា សហព្រះរាជអាជ្ញាអន្តរជាតិ (១) បន្ធូរបន្ថយចំពោះការច្រានចោលរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិចំពោះការសម្រេចរបស់អង្គបុរេជំនុំជម្រះលើការវាយតម្លៃភស្តុតាងក្នុងសំណុំរឿង ០០៤/១ និង (២) មើលរំលងការអនុវត្តឡើងវិញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើឋានានុក្រមនៃភស្តុតាង ដែលខុសឆ្គងដដែលនេះ ដោយដាក់កំណត់ហេតុស្តាប់ចម្លើយរបស់ខ្លួននៅខ្ពស់ជាងគេ និងបានបដិសេធមិនធ្វើការពិនិត្យទៅលើខ្លឹមសារនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ[519]។ នៅពេលជំទាស់ទៅនឹងឧទាហរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិចំពោះការពិចារណាលើភស្តុតាងឱ្យបានសមស្របនោះ សហមេធាវីការពារក្តីអះអាងថា ឧទាហរណ៍ដែលបានយោងមានតិចតួច ហើយខកខានបង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិនិត្យតម្លៃនៃភស្តុតាងយ៉ាងប្រទាក់ក្រឡាគ្នា។ តាមការយល់ឃើញរបស់សហមេធាវីការពារក្តី ឧទាហរណ៍ទាំងនេះបង្ហាញអំពីរបៀបដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ “បានច្រានចោលជារហូត” លើភស្តុតាងដោះបន្ទុក និងមិនបានពិនិត្យទៅលើបញ្ហាខ្លឹមសារនៃភាពគួរឱ្យជឿទុកចិត្តបាន[520]។ ចំណុចចុងក្រោយ សហមេធាវីការពារក្តីអះអាងថា ការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីការពិចារណារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើភស្តុតាងផ្តល់ជូនដោយភាគី ឬ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពុំពាក់ព័ន្ធ ហើយ ទោះក្នុងករណីណាក៏ដោយ វានឹងមិនអាចបង្ហាញថា គាត់បានពិចារណាលើខ្លឹមសារនៃ

---

*យោង*ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) លេខយោងជើងទំព័រ ១០០៩, ១០១១, ១០៧៩, ១១០៨, ១៦០២, ១៧៣៤, ២១០៨។

[518] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៣៣ *យោង*ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៣៧(ក)(v)។

[519] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ២៣-២៤, ២៧ *យោង*ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ១២៣, ១២៧, ១៣០។ ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 01626066 ទំព័រ ១២:៣-១២:៧។

[520] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ២៥ *យោង*ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៣៣, លេខយោងជើងទំព័រ ៥៦។ ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 01626066 ទំព័រ ១២:៣-១២:៧។

01634937



កំណត់ហេតុស្តាប់ចម្លើយនោះទេ[521]។

## ខ. ការពិភាក្សា

៣៧៣.ចៅក្រមអន្តរជាតិយល់ឃើញថា (១) សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសចំពោះការព្យាយាមកែតម្រូវឋានានុក្រមនៃភស្តុតាង ដែលបានរិះគន់រួចហើយនៅក្នុងសំណុំរឿង ០០៤/១ ដោយ អង្គជំនុំជម្រះនេះ[522]។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះសន្និដ្ឋានថា (២) សហចៅក្រមស៊ើបអង្កេត អន្តរជាតិគ្រាន់តែអះអាងឡើងវិញអំពីឋានានុក្រមដែលខុសឆ្គងប៉ុណ្ណោះ ដោយពុំបានអនុវត្តវាជាក់ស្តែងនោះឡើយ ហើយនៅក្នុងការវិភាគនោះទៀតសោត គាត់បានធ្វើការវាយតម្លៃលើខ្លឹមសារ។

៣៧៤. ចំណុចទី១ ចៅក្រមអន្តរជាតិពិចារណាឃើញថា ការព្យាយាមការពារឋានានុក្រមនៃភស្តុតាង ក្នុងលក្ខណៈអរូបិយ និងដែលគ្មានប្រយោជន៍ទាល់តែសោះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពុំមានផលប៉ះពាល់ជាក់ស្តែងទៅលើការសម្រេចលើដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)។ ចៅក្រមអន្តរជាតិសូមរម្លឹកថា ការប្រឹងប្រែងរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៤/១ ដើម្បីធ្វើការពន្យល់អំពីវិធីសាស្ត្រនៃការកំណត់ឋានុក្រមកម្មនៃភស្តុតាង នៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) គឺគ្មានប្រយោជន៍ ពុំចាំបាច់ និងពុំត្រឹមត្រូវតាមផ្លូវច្បាប់[523]។ បើទោះជាយ៉ាងនេះក្តី សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចបង្កើតកំហុសនេះសាជាថ្មីនៅក្នុងរឿងក្តីនេះ[524]។

៣៧៥. ទោះបីជាទាមទារអនុវត្តឋានានុក្រមនៃភស្តុតាងរបស់ខ្លួន (ដែលត្រូវបានវាយតម្លៃនៅក្នុងផ្នែកស្តីពីបញ្ហាអញ្ញត្រកម្មនៅក្នុងសាលដីកានេះ) ក៏ដោយ[525] ក៏សហចៅក្រមស៊ើបអង្កេតអន្តរជាតិទទួលស្គាល់ក្នុងពេលតំណាលគ្នាថា វិធីសាស្ត្ររបស់ខ្លួនចំពោះការវាយតម្លៃលើភស្តុតាង ពុំមែនជាការដកហូតការវាយតម្លៃត្រឹមត្រូវនោះទេ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិអះអាងថា មិនមានបំណង "បង្កើតទ្រឹស្តីឋានានុក្រម

---

[521] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ២៦ *យោង*ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៣៣។

[522] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/១ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ៤២-៥២។

[523] *សូមមើល* ក្នុងចំណោម កថាខណ្ឌ ៧៣ ដល់ ៨០។ *សូមមើលផងដែរ* សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/១ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ៤២, ៥២។

[524] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D60) កថាខណ្ឌ ១២៣-១៣៦។

[525] *សូមមើល* ក្នុងចំណោម កថាខណ្ឌ ៧៣ ដល់ ៨០។

ភស្តុតាងនៅក្នុងបរិបទដែលភាគច្រើនលើសលុបមានវិធានផ្លូវការស្តីពីភស្តុតាង ហើយឋានានុក្រមតឹងរ៉ឹងបែបនេះក៏មិនបានអនុវត្តដែរនៅពេលដែលវាយតម្លៃភស្តុតាងនាពេលកន្លងមក”[526]។ ហេតុដូច្នេះ ចៅក្រមអន្តរជាតិត្រូវសន្និដ្ឋានថា ប្រសិនបើការអះអាងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីអ្វីដែលចាត់ទុកជា “គោលការណ៍” ដែលអនុវត្តចំពោះការវាយតម្លៃលើភស្តុតាង ពុំត្រូវបានយកមកអនុវត្តចំពោះការវាយតម្លៃលើភស្តុតាង នោះវាគ្មានមុខងារ ឬ សារៈសំខាន់ជាក់ស្តែងអ្វីទាំងអស់[527]។ គោលបំណងដូចបានអះអាងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិចំពោះការ “ទាញយក” កត្តារួមចេញ តាមបែបគណិតវិទ្យា[528] គឺជាវិធីសាស្ត្រមួយ ដែលងាកចេញពីតថភាពនៃការតម្លៃលើភស្តុតាងទៅតាមករណីនីមួយៗ ដោយពុំមានផលប៉ះពាល់លើរឿងក្តីនេះឡើយ។

៣៧៦. ចំណុចទី២ ចៅក្រមអន្តរជាតិជឿជាក់ថា នៅក្នុងការអនុវត្តជាក់ស្តែង សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពុំមានកំហុស ដោយសារការអនុវត្តឋានានុក្រមនៃភស្តុតាង នៅពេលវាយតម្លៃលើភស្តុតាងនោះទេ។ អង្គជំនុំជម្រះ រកឃើញឧទាហរណ៍ជាច្រើននៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) បង្ហាញអំពីការវាយតម្លៃលើភស្តុតាងដ៏ត្រឹមត្រូវ រួមទាំងឧទាហរណ៍ទាំងឡាយ ដែលនឹងពិភាក្សានៅក្នុងមូលដ្ឋានទី៥ (២)(៣)(៤) និង (៥) បន្ទាប់ពីនេះ។ ផ្ទុយពីការអះអាងរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានធ្វើការវាយតម្លៃពេញលេញ និងដោយសេរីលើភស្តុតាង រួមទាំង បានពិនិត្យខ្លឹមសារនៃភស្តុតាង មិនថាមានទម្រង់ ឬ ប្រភពមកពីណា[529] និងដោយពុំចាំបាច់យោងលើឋានានុក្រមនៃភស្តុតាងរបស់ខ្លួន

---

[526] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៣៧(ក)(i)។

[527] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៣៧(ក), ១២៨។

[528] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៣៧(ក)(i)។

[529] *ឧទា. សូមមើល* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ២២៩ (វាយតម្លៃខ្លឹមសារការពិតនៃកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួនពីរនាក់ និងសក្ខីកម្មពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំនៅស្រុកកំពង់សៀម ដោយពិចារណាទៅលើភស្តុតាងផ្ទុយនៃការបង្ខិតបង្ខំ រួមទាំង ហិង្សាលើរាងកាយ ការរំលោភសេពសន្ថវៈ និងការធ្វើមនុស្សឃាត) ៣៧៥ (រកឃើញថា ទោះបីជាកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីបានលើកឡើងថា គាត់បានទទួលបញ្ជាឲ្យចាប់ខ្លួនសម្លាប់អតីតទាហាន លន់ នល់ ក៏ដោយ ប៉ុន្តែដោយហេតុថា គាត់ពុំមាន “ការពាក់ព័ន្ធដោយផ្ទាល់” នៅក្នុងការកាប់សម្លាប់នៅគោកព្រីង គេ “ពុំអាចសន្និដ្ឋាន” បានទេថា ទាហាន លន់ នល់ ត្រូវបានសម្លាប់នៅទីនោះ) ៤១១ (ការវាយតម្លៃលើភាពអាចទុកចិត្តបានរបស់សាក្សី និងចេតនា ហើយបានពិភាក្សាអំពីមូលហេតុដែលភស្តុតាងលម្អិត និងស៊ីសង្វាក់របស់អតីតកងការពាររបស់ អោ អាន គួរយកជាមូលដ្ឋាន) ៦២១ (ការវាយតម្លៃលើភាពគួរឲ្យជឿទុកចិត្តបាននៃខ្លឹមសារភស្តុតាងរបស់សាក្សី ដែលបដិសេធថា ពុំបានដឹងអំពីការសម្លាប់ជនជាតិចាមនៅក្នុងខេត្តកំពង់ឆ្នាំ ក្រោយពីពិចារណាលើសាក្សីជាច្រើនដែលបានផ្តល់ចម្លើយថា អោ អាន មានការចូលរួមពាក់ព័ន្ធ)។ *សូមមើលផងដែរ* មូលដ្ឋាន ៥(ii), (iii), (iv) និង (v) ជាបន្តបន្ទាប់ ដែលឆ្លើយតបទៅនឹងបញ្ហានៃការពិចារណាលើភស្តុតាងនេះ

01634939



ដែលពុំអាចអនុវត្តបាននោះឡើយ។

៣៧៧. អាស្រ័យហេតុនេះ មូលដ្ឋានទី៥(១) ត្រូវបានច្រានចោល។

## មូលដ្ឋានទី ៥(ii). ការចោទប្រកាន់ថាមិនបានវាយតម្លៃទៅលើភាពអាចជឿជាក់បានរបស់សាក្សី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសំខាន់ៗ

៣៧៨. តាមមូលដ្ឋាន ៥ (ii) សហមេធាវីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសដោយមិនបានមើលទៅលើបញ្ហាភាពអាចជឿជាក់បាន ដែលប៉ះពាល់ដល់សាក្សី និងអ្នកដាក់ពាក្យសុំតាំងខ្លួនបណ្តឹងរដ្ឋប្បវេណីមួយចំនួន ដោយកំណត់ហេតុស្តាប់ចម្លើយរបស់ពួកគាត់ បានផ្តល់ជាភស្តុតាងសំខាន់ៗគាំទ្រដល់ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីយុត្តាធិការបុគ្គល។ ជាសំខាន់ សហមេធាវីបានអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានផ្តល់សំអាងហេតុ ឬបានផ្តល់សំអាងហេតុមិនគ្រប់គ្រាន់ ដែលដោះស្រាយពីភាពអាចជឿជាក់បានរបស់សាក្សី និងអ្នកដាក់ពាក្យសុំតាំងខ្លួនបណ្តឹងរដ្ឋប្បវេណីសំខាន់ៗចំនួនប្រាំបួនរូប[530] ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឆ្គងក្នុងការពឹងផ្អែកទៅលើភស្តុតាងរបស់បុគ្គលទាំងអស់នេះ ក្នុងការសម្រេចលើអង្គហេតុទាក់ទងនឹងតួនាទី និងការទទួលខុសត្រូវរបស់ អោ អាន[531]។ បញ្ហានៃភាពអាចជឿជាក់បានដែលរងការចោទប្រកាន់ រួមមាន "ចេតនាក្នុងការបិទបាំង សកម្មភាពបទល្មើសរបស់ខ្លួន អសង្គតិភាពធ្ងន់ធ្ងរនៅក្នុងចម្លើយរបស់ខ្លួន ដោយបង្ហាញពីភាពលម្អៀង និងកង្វះភស្តុតាងស៊ីសង្វាក់"[532]។ សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់ទៅនឹងបញ្ហានេះ ដោយអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានវាយតម្លៃដោយត្រឹមត្រូវលើបញ្ហាភាពអាចជឿជាក់បាន ហើយថា ការប្រឹងប្រែងរបស់សហមេធាវីក្នុងការបន្ទាបតម្លៃសាក្សី ពឹងផ្អែកលើ "ការវិភាគដែលមិនត្រឹមត្រូវ"[533]។

---

និងពង្រីកលើការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើខ្លឹមសារនៃភស្តុតាង មិនថាមានប្រភពមកពីណា។

[530] សាក្សី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានជំទាស់ រួមមាន ប្រាក់ យុត (មូលដ្ឋាន ៥(ii)(ក)), យូ វ៉ាន់ (មូលដ្ឋាន ៥(ii)(ខ)), ពៅ សារុំម, ពុត កុល និង កែវ វឿន (មូលដ្ឋាន ៥(ii)(គ)), ញ៉ែម ចេន (មូលដ្ឋាន ៥(ii)(ឃ)), ជុំ វង្ស (ង៉ូវ) (មូលដ្ឋាន ៥(ii)(ង)) និង ពេញ វ៉ា និង ញឹម កុល (មូលដ្ឋាន ៥(ii)(ច))។ ចៅក្រមអន្តរជាតិនឹងវាយតម្លៃអំពីការជំទាស់ជាក់លាក់ប្រឆាំងនឹងបុគ្គលទាំងនេះ នៅក្នុងផ្នែកជាបន្តបន្ទាប់ដូចខាងក្រោម។

[531] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៦២។ សូមមើលផងដែរ កថាខណ្ឌ ៦៣-៧៥។

[532] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៦២។

[533] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៣២,

៣៧៩. នៅក្នុងមូលដ្ឋាន ៥(ii) ជាដំបូង អង្គជំនុំជម្រះបានកំណត់អំពីបទដ្ឋាននៃការត្រួតពិនិត្យជាធរមាន។ បន្ទាប់មក ចំពោះសាក្សី ឬ អ្នកដាក់ពាក្យសុំតាំងខ្លួនបណ្ដឹងរដ្ឋប្បវេណី ដែលរងការជំទាស់នីមួយៗ អង្គជំនុំជម្រះលើកយកសារណារបស់សហមេធាវី និងគោលជំហររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ហើយឆ្លើយតបចំពោះទឡ្ហីករណ៍សំខាន់ៗ។

## បទដ្ឋាននៃការត្រួតពិនិត្យ

៣៨០. មុននឹងបន្តទៅមុខទៀត អង្គបុរេជំនុំជម្រះយល់ថាជាការចាំបាច់ត្រូវដោះស្រាយទៅលើបទដ្ឋាននៃការត្រួតពិនិត្យដែលនៅជាធរមាន។ ទោះបីជាសហមេធាវីបង្ហាញមូលដ្ឋាន ៥ (ii) ថាជាផ្នែកនៃការជំទាស់ផ្នែកច្បាប់ជាទូទៅរបស់ខ្លួនប្រឆាំងនឹងការវាយតម្លៃទៅលើភស្តុតាងតាមឋានានុក្រមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្ដី[534] តែអង្គបុរេជំនុំជម្រះយល់ថា ចំណុចមួយចំនួននៃបញ្ហានេះ និងមូលដ្ឋានរងបន្តបន្ទាប់មកទៀត នឹងបង្កើតជាបញ្ហាអង្គហេតុ[535]។

៣៨១. អង្គបុរេជំនុំជម្រះរម្លឹកថា ទោះបីជាកំហុសអង្គច្បាប់ដែលរងការចោទប្រកាន់ ត្រូវបានត្រួតពិនិត្យជាថ្មី ដើម្បីវាយតម្លៃថាតើ ការសម្រេចផ្នែកអង្គច្បាប់ត្រឹមត្រូវដែរឬយ៉ាងណាក្ដី កំហុសអង្គហេតុដែលរងការចោទប្រកាន់ ត្រូវបានពិនិត្យមើល ផ្អែកតាមបទដ្ឋាននៃភាពសមហេតុសមផល ដើម្បីសម្រេចថាតើមានអ្នកវិនិច្ឆ័យលើអង្គហេតុ ដែលមានហេតុផលណាម្នាក់ អាចឈានដល់ការសម្រេចលើអង្គហេតុដែលចោទជាបញ្ហានេះដែរឬយ៉ាងណា[536]។ នៅក្នុងករណីនេះ បន្ទុកគឺស្ថិតលើម្ចាស់បណ្ដឹងឧទ្ធរណ៍ ក្នុងការ

---

៣៤។ សូមមើលផងដែរ កថាខណ្ឌ ៣៥-៤៦។

[534] ចៅក្រមអន្តរជាតិកត់សម្គាល់ថា ការខកខានមិនបានផ្ដល់សំអាងហេតុ (គ្រប់គ្រាន់) គឺជាកំហុសអង្គច្បាប់។ សូមមើលសាលដីកា រវាង រដ្ឋអាជ្ញា ទល់នឹង *Kupreškić* (តុលាការ ICTY) របស់សាលាឧទ្ធរណ៍ ចុះថ្ងៃទី ២៣ ខែតុលា ឆ្នាំ២០០១ កថាខណ្ឌ ៣២, សាលដីកា រវាង រដ្ឋអាជ្ញា ទល់នឹង *Popović និងអ្នកឯទៀត* (តុលាការ ICTY) របស់សាលាឧទ្ធរណ៍ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ កថាខណ្ឌ ១៧, ១៣៣, សាលដីកា *Taylor* (តុលាការ SCSL) របស់សាលាឧទ្ធរណ៍ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ២៥, ២៩, ១២៥។ សូមមើលជាទូទៅ សាលដីកាសំណុំរឿង ០០២/០១ (ឯកសារ F36) កថាខណ្ឌ ២០២-២០៧)។

[535] ចៅក្រមអន្តរជាតិសង្កេតឃើញថា នៅក្នុងការឆ្លើយតប សហមេធាវីអះអាងថា ខ្លួនបានបង្ហាញអំពីកំហុសអង្គហេតុ និងអង្គច្បាប់ នៅក្នុងការវាយតម្លៃភស្តុតាងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ សូមមើល ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៣៣។ សូមមើលផងដែរ កថាខណ្ឌ ២៨។

[536] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៃសំណុំរឿង ០០២ (អៀង សារី) (ឯកសារ D427/1/30) កថាខណ្ឌ ១១៣, សាលដីកាសំណុំរឿង ០០២/០១ (ឯកសារ F36) កថាខណ្ឌ ៨៩-៩០។ សូមមើលផងដែរ សាលដីកា រវាង រដ្ឋអាជ្ញា ទល់នឹង *Rutaganda* (តុលាការ ICTR) របស់សាលាឧទ្ធរណ៍ ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ ៣៥៣ ("ពិតណាស់

បញ្ជាក់ថាមិនមានអ្នកវិនិច្ឆ័យអង្គហេតុដែលមានហេតុផលណាម្នាក់ អាចធ្វើការសម្រេច និងពឹងផ្អែកទៅលើភស្តុតាងដែលត្រូវបានជំទាស់ នៅក្នុងការសម្រេចលើអង្គហេតុនោះទេ[537]។ ជាពិសេស ចំពោះភស្តុតាងរបស់សាក្សី វត្តមាននៃភាពមិនស៊ីសង្វាក់គ្នា មិនបានតម្រូវដោយផ្ទាល់ ឱ្យអ្នកវិនិច្ឆ័យអង្គហេតុ ដែលមានហេតុផល ធ្វើការច្រានចោលសក្ខីកម្ម ដោយថាមិនអាចជឿជាក់បានឡើយ[538] ព្រោះអ្នកវិនិច្ឆ័យទៅលើអង្គហេតុ អាច "ទទួលយកសក្ខីកម្មរបស់សាក្សីមួយផ្នែក ហើយបដិសេធផ្នែកដទៃទៀត"[539] បន្ទាប់ពីបានពិចារណាទៅលើសក្ខីកម្មទាំងមូលហើយ។

៣៨២. សហមេធាវីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ តាមកម្រិតផ្សេងៗគ្នាផ្អែកទៅ

---

ដោយសារតែអង្គជំនុំជម្រះសាលាដំបូង មានភាពស័ក្តិសមបំផុតក្នុងការពិនិត្យមើលសាក្សីមុនដំបូងគេ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នឹងធ្វើអន្តរាគមន៍តែក្នុងករណីណាដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានបង្ហាញថា ភស្តុតាងដែលយកមកសំអាងមិនអាចត្រូវបានទទួលយក ដោយតុលាការប្រកបដោយវិចារណញ្ញាណ ឬក្នុងករណីណាដែលការវាយតម្លៃភស្តុតាងមានកំហុសឆ្គងទាំងស្រុង"), តុលាការ ICTR រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kayishema និង Ruzindana* សំណុំរឿងលេខ ICTR-95-1-A សាលក្រម (សំអាងហេតុ) អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ១២៩, តុលាការ SCSL រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Brima និងអ្នកឯទៀត* សំណុំរឿងលេខ SCSL-2004-16-A សាលក្រម អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ ២០០៨ ("សាលដីកា *Brima និងអ្នកឯទៀត* (តុលាការ SCSL")) កថាខណ្ឌ ១២០ ("ជាធម្មតា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នឹងតម្កល់ការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងលើបញ្ហានៃភាពអាចជឿជាក់បាន រួមទាំងការចាត់ការលើភស្តុតាងមិនស៊ីសង្វាក់គ្នា ហើយសន្និដ្ឋានថាជា កំហុសអង្គហេតុបានកើតឡើង នៅពេលសម្រេចថា គ្មានតុលាការប្រកបដោយវិចារណញ្ញាណណាមួយអាចធ្វើការសម្រេចដែលត្រូវបានជំទាស់បែបនេះឡើយ")។ សូមមើលផងដែរ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៃសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) យោបល់របស់ចៅក្រម BAIK និង ចៅក្រម BEAUVALLET កថាខណ្ឌ ២៥៩, ២៦៣, ២៨២ (ការអនុវត្តបទដ្ឋានវាយតម្លៃកំហុសអង្គច្បាប់ និងអង្គហេតុរួមគ្នា)។

[537] សាលដីកា *Rutaganda* (តុលាការ ICTR) កថាខណ្ឌ ៤៤២, តុលាការ ICTR រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Setako* សំណុំរឿងលេខ ICTR-04-81-A សាលក្រម អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ ៣១, សាលដីកា *Popović និងអ្នកឯទៀត* (តុលាការ ICTY) កថាខណ្ឌ ១២២៨។ សូមមើលផងដែរ កថាខណ្ឌ ១៩៨, ២០១។

[538] សាលដីកា *Kupreškić* (តុលាការ ICTY) កថាខណ្ឌ ៣១។ សូមមើលផងដែរ សាលដីកា *Rutaganda* តុលាការ ICTY) កថាខណ្ឌ ៣៥៣ ("គួរបញ្ជាក់ផងដែរថា ពាក់ព័ន្ធនឹងការវាយតម្លៃលើភាពអាចជឿជាក់បានរបស់សាក្សី និងភាពអាចទុកចិត្តបាននៃសក្ខីកម្ម អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកសក្ខីកម្មរបស់សាក្សី ទោះបីជាមានចម្លើយផ្ទុយគ្នាក៏ដោយ")។

[539] សាលដីកា *Popović និងអ្នកឯទៀត* (តុលាការ ICTY) កថាខណ្ឌ ១៣២។ សូមមើលផងដែរ សាលដីកាសំណុំរឿង ០០២/០១ (ឯកសារ F36) កថាខណ្ឌ ៣៥៧ ("អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ផ្អែកលើកាលៈទេសៈនៃរឿងក្តីនេះ ជាទូទៅ វាពុំមែនជាការមិនសមហេតុផលទេដែលអង្គជំនុំជម្រះសាលាដំបូងទទួលយកសក្ខីកម្មរបស់សាក្សីមួយផ្នែក ហើយបដិសេធផ្នែកដទៃទៀត"), ICTR សាលដីកាក្នុងរឿងក្តីរវាង រដ្ឋអាជ្ញាទល់នឹង *Muvunyi I*) ICTR -2000-55A-A របស់សាលាឧទ្ធរណ៍ ថ្ងៃទី១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ ២៦។

តាមសាក្សីពាក់ព័ន្ធ មិនបានផ្តល់ការពន្យល់អំពីបញ្ហាភាពអាចជឿជាក់បាន ហើយក៏មានកំហុសឆ្គងក្នុងការពឹងផ្អែកទៅលើភស្តុតាងសាក្សីដែលរងការជំទាស់ ទាក់ទងទៅនឹងបញ្ហាយុត្តាធិការបុគ្គលជាគន្លឹះ[540]។ អង្គជំនុំជម្រះនឹងប្រើប្រាស់បទដ្ឋានត្រួតពិនិត្យសមស្រប ដូចដែលបានរៀបរាប់ពីខាងលើ ក្នុងករណីពាក់ព័ន្ធដើម្បីធ្វើការវាយតម្លៃដូចខាងក្រោមលើការជំទាស់របស់សហមេធាវី។

## ក. ប្រាក់ យុត

### ១. សារណា

៣៨៣. សហមេធាវីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឆ្គងក្នុងការផ្តល់សំអាងហេតុគ្រប់គ្រាន់ ដើម្បីវាយតម្លៃទៅលើភាពអាចជឿជាក់បានរបស់ ប្រាក់ យុត ដែលជាអតីតលេខាស្រុកកំពង់សៀម។ បើតាមសហមេធាវី ប្រាក់ យុត មិនអាចជឿជាក់បាន ចំពោះបញ្ហាទាក់ទងនឹងយុត្តាធិការបុគ្គល ដោយសារតែចម្លើយរបស់គាត់ (១) មិនមានសង្គតភាព និងមិនមានភស្តុតាងសំអាង[541] (២) គាត់មានហេតុផលជំរុញឱ្យឆ្លើយកុហក[542] និង (៣) អ្នកស៊ើបអង្កេត "ផ្តល់" ព័ត៌មានដាក់បន្ទុក ដើម្បីបង្កើតជាភស្តុតាងដាក់បន្ទុក ប្រឆាំងនឹង អោ អាន[543]។ សហមេធាវីបានដាក់ជូនឧបសម្ព័ន្ធដែលរៀបរាប់

[540] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៦២, ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ២៩-៣០, ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D359/9.1 និង D360/18.1, ERN 01626066 ទំព័រ ១២។

[541] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៦៣ និងកំណត់សម្គាល់ជើងទំព័រ ១១៨-១១៩, ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D359/9.1 និង D360/18.1, ERN 01626067 ទំព័រ ១៣, 01626075 ទំព័រ ២១ 01626076 ទំព័រ ២២។ ជារួម សហមេធាវីអះអាងថា ចម្លើយមិនស៊ីសង្វាក់គ្នារបស់ ប្រាក់ យុត នៅក្នុងកំណត់ហេតុ ១៩ ផ្សេងគ្នា "មានច្រើនរាប់មិនអស់" និងអះអាងទៀតថា ចម្លើយរបស់អ្នកដែលធ្វើការជិត ឬជាមួយ ប្រាក់ យុត ពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៩ ពុំស៊ីសង្វាក់គ្នាជាមួយនឹងចម្លើយរបស់គាត់អំពីតួនាទី និងការទទួលខុសត្រូវរបស់ អោ អាន ដូចបានចោទប្រកាន់។

[542] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៦៣ និងកំណត់សម្គាល់ជើងទំព័រ ១២០, ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D359/9.1 និង D360/18.1, ERN 01626067 ទំព័រ ១៣, 01626116-17 ទំព័រ ៦២-៦៣។ ជារួម សហមេធាវីមានជំហរថា ប្រាក់ យុត បានព្យាយាមការពារខ្លួន និងសម្រាលតួនាទីរបស់គាត់ ព្រមទាំងគ្រួសារ នៅក្នុងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ដោយយក អោ អាន មកធ្វើជាអ្នកទទួលរងជំនួស។ ប្រាក់ យុត ទទួលបានការលើកទឹកចិត្តពីអ្នកស៊ើបអង្កេត "ដោយបានប្រាប់ទៅគាត់សុទ្ធតែព័ត៌មានដាក់បន្ទុក" ហើយគាត់បានយកព័ត៌មានទាំងនេះមកធ្វើជា "មូលដ្ឋានសម្រាប់ការភូតកុហកបន្ថែម" ដើម្បីកាត់បន្ថយហានិភ័យនៃការចោទប្រកាន់។

[543] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៦៣ និងកំណត់សម្គាល់ជើងទំព័រ ១២១, ប្រតិចារឹកសំណុំ

អំពីចម្លើយមិនស៊ីសង្វាក់គ្នារបស់ ប្រាក់ យុត ទៅលើបញ្ហាចម្បងនានា ដូចជា ថាតើ អោ អាន គឺជាថ្នាក់លើរបស់ ប្រាក់ យុត ដែរឬទេ នៅក្នុងតំបន់៤១ ថាតើគាត់មានសិទ្ធិអំណាច ក្នុងការរៀបចំពិធីអាពាហ៍ពិពាហ៍ដែរឬទេ និងថាតើគាត់បានចេញបញ្ជា ឲ្យប្រមូលប្រជាជនចាមដែរឬទេ[544]។ នៅក្នុងឧបសម្ព័ន្ធមួយទៀត សហមេធាវីបានផ្តល់ការបង្ហាញអំពីរឿងរ៉ាវរបស់ ប្រាក់ យុត ដែលប្រែប្រួលពីមួយពេលទៅមួយពេល ដែលថា ដោយសារតែឥទ្ធិពលរបស់អ្នកស៊ើបអង្កេត និងចេតនារបស់គាត់ "ចង់បិទបាំងការភូតកុហករបស់គាត់" និងបន្ទោសទៅលើ អោ អាន[545]។

៣៨៤. សហមេធាវីអះអាងបន្ថែមទៀតថា ប្រាក់ យុត គឺជា "ខ្មែរក្រហមដាច់ខាតម្នាក់"[546] ហើយមានទំនាក់ទំនងជិតស្និទ្ធជាមួយ តាម៉ុក[547]។ គាត់បានចូលរួមពាក់ព័ន្ធយ៉ាងសកម្មជាមួយនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ នៅក្នុងភូមិភាគកណ្តាល[548] ហើយត្រូវបានគេជឿថា គាត់បានសម្លាប់ប្តីរបស់គាត់ថែមទៀតផង នៅពេលដែលប្តីគាត់បាត់បង់ជំនឿទៅលើបដិវត្ត[549]។ ទោះបីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានទទួលស្គាល់ត្រួសៗអំពីបញ្ហានៃភាពអាចជឿជាក់បានរបស់ ប្រាក់ យុត ក្តី[550] ប៉ុន្តែ សហមេធាវីនៅតែរក្សាជំហរថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងដោយមិនបានវាយតម្លៃដោយប្រុងប្រយ័ត្នទៅលើភាពអាចជឿជាក់បានរបស់ ប្រាក់ យុត និងនៅតែបន្តពឹងផ្អែកទៅលើ ប្រាក់ យុត សម្រាប់ការសម្រេចរបស់គាត់ទៅលើយុត្តាធិការបុគ្គល[551]។

---

រឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D359/9.1 និង D360/18.1, ERN 01626067 ទំព័រ ១៣។

[544] សំណុំរឿង ០០៤/២ ឧបសម្ព័ន្ធ ឃ (អសង្គតិភាពរបស់ ប្រាក់ យុត ទាក់ទងទៅនឹងយុត្តាធិការបុគ្គល) នៃបណ្តឹងឧទ្ធរណ៍របស់ អោ អាន ឯកសារ D360/5/1.5 ("ឧសម្ព័ន្ធ ឃ នៃបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1.5)"), ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D359/9.1 និង D360/18.1, ERN 01626077-78 ទំព័រ ២៣-២៤។

[545] សំណុំរឿង ០០៤/២ ឧបសម្ព័ន្ធ គ (ការផ្លាស់ប្តូរសាច់រឿងរបស់ ប្រាក់ យុត) នៃបណ្តឹងឧទ្ធរណ៍របស់ អោ អាន ឯកសារ D360/5/1.4។

[546] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៦៤ និងកំណត់សម្គាល់ជើងទំព័រ ១២៣, ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D359/9.1 និង D360/18.1, ERN 01626067 ទំព័រ ១៣។

[547] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៦៤ និងកំណត់សម្គាល់ជើងទំព័រ ១២៤។

[548] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៦៤ និងកំណត់សម្គាល់ជើងទំព័រ ១២៥។

[549] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៦៤ និងកំណត់សម្គាល់ជើងទំព័រ ១២៦។

[550] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៦៣ និងកំណត់សម្គាល់ជើងទំព័រ ១២២ ដែលយោងទៅដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២២៩, ៣៦៨, ៤៥៤។

[551] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៦៣ និងកំណត់សម្គាល់ជើងទំព័រ ១១៧, ប្រតិចារឹកសំណុំ

៣៨៥. សហព្រះរាជអាជ្ញាអន្តរជាតិយល់ថា ការព្យាយាមរបស់សហមេធាវីដើម្បីបន្ទាបតម្លៃ ប្រាក់ យុត មិនបានជោគជ័យទេ។ សហព្រះរាជអាជ្ញាអន្តរជាតិបានកត់សម្គាល់ថា ប្រាក់ យុត ក្នុងនាមជាអតីតអ្នកនៅក្រោមបង្គាប់ផ្ទាល់របស់ អោ អាន មានព័ត៌មានផ្ទាល់អំពីការចេញបញ្ជារបស់ អោ អាន និងរបៀបនៃការអនុវត្តបញ្ជានោះ[552]។ ទោះបីជា ប្រាក់ យុត "ជាសាក្សីម្នាក់ស្មើរម្នាក់ដែលតែងតែបង្ហាញនូវការព្រួយបារម្ភយ៉ាងច្បាស់អំពីការសារភាពចំពោះឧក្រិដ្ឋកម្មដ៏រង្គាល" សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា អោ អាន មិនបានបង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានរំលោភបំពានទៅលើឆន្ទានុសិទ្ធិរបស់គាត់ ឬមានកំហុសក្នុងការពឹងផ្អែកទៅលើភស្តុតាងរបស់គាត់មួយផ្នែកឡើយ ពេលដែលបានពិចារណាដោយប្រុងប្រយ័ត្នទៅលើភស្តុតាងនោះជារួម[553]។ តាមពិតទៅ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានទទួលស្គាល់អំពីបញ្ហាភាពអាចជឿជាក់បានរបស់ ប្រាក់ យុត ហើយបានច្រានចោលភស្តុតាងមួយចំនួនរបស់គាត់ដោយសារតែមិនអាចជឿជាក់បាន[554]។

៣៨៦. សហព្រះរាជអាជ្ញាអន្តរជាតិ បានរិះគន់ការអះអាងរបស់សហមេធាវីអំពីភាពមិនស៊ីសង្វាក់គ្នា ដោយបញ្ជាក់ថា ចំណុចទាំងនេះ "ផ្អែកលើសម្រង់ខ្លីៗនៃភស្តុតាង ដែលមិនបង្ហាញបរិបទ"[555]។ ឧទាហរណ៍ ចំពោះការចោទប្រកាន់ពីភាពមិនស្របគ្នារបស់ ប្រាក់ យុត អំពីអ្នកដែលតែងតាំងគាត់ ជាលេខាស្រុកកំពង់សៀម សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា មិនមានភាពមិនស្របគ្នាសំខាន់ៗ

---

រឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D359/9.1 និង D360/18.1, ERN 01626067 ទំព័រ ១៣។

[552] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៣៥។ សូមមើលផងដែរ ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D359/8.1 និង D360/17.1, ERN 01626019 ទំព័រ ៣០, 01626029 ទំព័រ ៤០, 01626029 ទំព័រ ៤០, 01626031 ទំព័រ ៤២, 01626033 ទំព័រ ៤៤, 01626038-39 ទំព័រ ៤៨-៤៩, 01626046 ទំព័រ ៥៧, ប្រតិចារឹកសំណុំរឿង ០០៤២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ/ D359/9.1 និង D360/18.1, ERN 01626103-04 ទំព័រ ៤៩-៥០, 01626104-05 ទំព័រ ៥០-៥១។

[553] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៣៥ និងកំណត់សម្គាល់ជើងទំព័រ ៦៤។ សូមមើលផងដែរ ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D359/8.1 និង D360/17.1, ERN 01626039-40 ទំព័រ ៥០-៥១, ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D359/9.1 និង D360/18.1, ERN 01626105-06 ទំព័រ ៥១-៥២។

[554] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៣៨ និងកំណត់សម្គាល់ជើងទំព័រ ៧៤ ដែលយោងទៅដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២២៩, ២៤១, ៣៦៨, ៤៥៤។

[555] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៣៦។

01634945



ដែលតម្រូវឱ្យមានការពន្យល់ពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិទេ[556]។ ចំពោះការអះអាងដទៃទៀតអំពីភាពមិនស៊ីសង្វាក់គ្នា សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ពួកគេមិនបានបង្ហាញដូចគ្នាថា គ្មានអ្នកវិនិច្ឆ័យអង្គហេតុ ដែលមានហេតុផលណាម្នាក់ ពឹងផ្អែកទៅលើភស្តុតាងរបស់ ប្រាក់ យុត ទេ[557]។

៣៨៧. នៅក្នុងចម្លើយតបចំពោះការចោទប្រកាន់ថា ប្រាក់ យុត ត្រូវបាន "ផ្តល់" ព័ត៌មាន ដើម្បីឱ្យអ្នកស៊ើបអង្កេតអាចបង្កើតភស្តុតាងដាក់បន្ទុកចំពោះ អោ អាន សហព្រះរាជអាជ្ញាអន្តរជាតិបានរម្លឹកថា ការអះអាងនេះត្រូវបានអង្គបុរេជំនុំជម្រះច្រានចោលជាឯកច្ឆ័ន្ទ[558]។ លើសពីនេះទៀត ការរៀបរាប់របស់ អោ អាន ដែលថា ការិយាល័យសហចៅក្រមស៊ើបអង្កេត ការិយាល័យសហព្រះរាជអាជ្ញា និងប្រាក់ យុត បានរួមគ្នាបង្កើត "សំណាញ់កុហក" នោះ មិនត្រឹមតែគ្មានមូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវបានច្រានចោលភ្លាមៗទៀតផង[559]។

៣៨៨. លើសពីនេះទៀត សហព្រះរាជអាជ្ញាអន្តរជាតិបានឆ្លើយតបចំពោះការអះអាងរបស់សហមេធាវីដែលថា ភស្តុតាងរបស់ប្រាក់ យុត មិនមានភស្តុតាងសំអាង (ឬមានការគាំទ្រត្រឹមតែអ្នកនៅក្រោមបង្គាប់របស់គាត់) ដោយបញ្ជាក់ថា (១) ភស្តុតាងរបស់ប្រាក់ យុត ត្រូវបានគាំទ្រដោយសាក្សីដទៃផ្សេងទៀតជាច្រើន (២) នៅក្នុងសក្ខីកម្មរបស់សាក្សីដែលជិតស្និទ្ធជាមួយ ប្រាក់ យុត ពួកគេមិនបានលាក់បាំងឱ្យគាត់ឡើយ ប៉ុន្តែបែរជាឆ្លើយដាក់គាត់ទៅវិញ[560]។

---

[556] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៣៦ និងកំណត់សម្គាល់ជើងទំព័រ ៦៦-៦៧។ ផ្ទុយពីការអះអាងរបស់សហមេធាវីថា គាត់ប្រែប្រួលមិនទៀងម្តងថា អោ អាន ម្តងថា កែ ពក ម្តងថា កង ចាប ចៅក្រមអន្តរជាតិសង្កេតឃើញថា ប្រាក់ យុត ធ្លាប់បាននិយាយតែម្តង គាត់ថា អោ អាន ជាអ្នកចាត់តាំងគាត់ឱ្យធ្វើជាលេខាស្រុក។

[557] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៣៦ និងកំណត់សម្គាល់ជើងទំព័រ ៦៨។

[558] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៣៧ និងកំណត់សម្គាល់ជើងទំព័រ ៧០ ដែលយោងទៅសេចក្តីសម្រេចលើសំណើសុំមោឃភាពលើកំណត់ហេតុស្តាប់ចម្លើយ (ឯកសារ D338/1/5) កថាខណ្ឌ ២១-២២។

[559] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៣៧ និងកំណត់សម្គាល់ជើងទំព័រ ៧២, ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D359/8.1 និង D360/17.1, ERN 01626029-30 ទំព័រ ៤០-៤១។

[560] ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D359/9.1 និង D360/18.1, ERN 01626104-05 ទំព័រ

៣៨៩. នៅក្នុងការឆ្លើយតបរបស់ខ្លួន សហមេធាវីបានអះអាងថា ការព្យាយាមរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងការបដិសេធភាពមិនស្របគ្នាសំខាន់ៗជាច្រើនរបស់ ប្រាក់ យុត មិនគួរឱ្យជឿជាក់ឡើយ[561]។ បើយោងតាមសហមេធាវី សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គួរ “ពន្យល់ឱ្យបានពេញលេញពីមូលហេតុដែលគាត់ពឹងផ្អែកជាចម្បងទៅលើ” ប្រាក់ យុត បើទោះបីជាមានភាពមិនស្របគ្នាសំខាន់ៗ និងមានការព្រួយបារម្ភពីភាពជឿជាក់បានក្តី ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងបានធ្វើដូច្នេះឡើយ[562]។

## ២. ការពិភាក្សា

៣៩០. ចៅក្រមអន្តរជាតិកត់សម្គាល់ថា នៅពេលដើមដំបូង ចម្លើយ និងសក្ខីកម្មរបស់ ប្រាក់ យុត ត្រូវបានពឹងផ្អែកយ៉ាងច្រើននៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ហើយភាគីទាំងពីរបានពិភាក្សាយ៉ាងលម្អិតអំពីទឡ្ហីករណ៍លើភាពអាចជឿជាក់បាន និងភាពអាចទុកចិត្តបាននៃភស្តុតាងរបស់ ប្រាក់ យុត[563]។ ជាដំបូង ចៅក្រមអន្តរជាតិនឹងពិភាក្សាអំពីការចោទប្រកាន់ថា ប្រាក់ យុត មានមូលហេតុក្នុងការផ្តល់សក្ខីកម្មមិនពិត ហើយនឹងការចោទប្រកាន់ថា អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បាន “ផ្តល់” ព័ត៌មានដាក់បន្ទុកទៅឱ្យ ប្រាក់ យុត ដើម្បីទទួលបានភស្តុតាងដាក់បន្ទុកទៅលើ អោ អាន។ បន្ទាប់មក ចៅក្រមអន្តរជាតិនឹងពិភាក្សាអំពីការអះអាងរបស់សហមេធាវីដែលថា ភាពមិនស្របគ្នាសំខាន់ៗនៅក្នុងភស្តុតាងរបស់ ប្រាក់ យុត និងថាតើសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានផ្តល់សំអាងហេតុគ្រប់គ្រាន់ដែរឬទេ ចំពោះបញ្ហានេះ ដែលជាផ្នែកមួយនៃការវាយតម្លៃរបស់គាត់ទៅលើភាពអាចជឿជាក់បាន។

---

៥០៥-១។ លើសពីនេះទៀត សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ចម្លើយរបស់ ប្រាក់ យុត ស៊ីសង្វាក់គ្នាជាមួយចម្លើយរបស់សាក្សីផ្សេងទៀត ដែលបញ្ជាក់ថា ការសម្លាប់ជនជាតិចាម នៅស្រុកផ្សេងទៀតក្នុងតំបន់ ៤១ ត្រូវបានធ្វើឡើង តាមបញ្ជារបស់ អោ អាន។ សូមមើលផងដែរ ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D359/9.1 និង D360/18.1, ERN 01626106 ទំព័រ ៥២។

[561] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៣០ និងកំណត់សម្គាល់ជើងទំព័រ ៥៩, ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D359/9.1 និង D360/18.1, ERN 01626067 ទំព័រ ១៣, 01626116 ទំព័រ ៦២។

[562] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៣០ និងកំណត់សម្គាល់ជើងទំព័រ ៦០, ប្រតិចារឹកសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D359/9.1 និង D360/18.1, ERN 01626067 ទំព័រ ១៣។

[563] ទោះបីជាចៅក្រមអន្តរជាតិនឹងមិនលើកលម្អិតអំពីទឡ្ហីករណ៍នីមួយៗដែលបានលើកឡើងពាក់ព័ន្ធនឹងភាពអាចជឿជាក់បាន និងភាពអាចទុកចិត្តបាននៃភស្តុតាងរបស់ ប្រាក់ យុត ក៏ដោយ ក៏ចៅក្រមអន្តរជាតិបញ្ជាក់ថា ចៅក្រមអន្តរជាតិបានពិនិត្យ និងពិចារណាយ៉ាងចិត្តទុកដាក់លើសារណារបស់ភាគីទាក់ទងនឹងភស្តុតាងរបស់ ប្រាក់ យុត។

៣៩១. ចៅក្រមអន្តរជាតិយល់ថា មានភស្តុតាងដែលថា ប្រាក់ យុត មានមូលហេតុក្នុងការបន្ថយជាអតិបរមានូវតួនាទីរបស់គាត់នៅក្នុងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ជាពិសេស ដោយសារតែគាត់ ធ្លាប់ត្រូវបានពិចារណាសម្រាប់ការចោទប្រកាន់ នៅក្នុងរបាយការណ៍សកម្មភាពស៊ើបអង្កេតមួយ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត[564]។ ប៉ុន្តែ មូលហេតុក្នុងការបន្ថយការទទួលខុសត្រូវរបស់គាត់ និងបង្កើនការពន្លើសភារកិច្ចរបស់ អោ អាន បែបនេះ មិនមែនមានន័យថា គាត់ប្រឌិតទាំងស្រុងនូវភស្តុតាងទាក់ទងនឹងតួនាទីរបស់ អោ អាន ឡើយ ដោយសារតែគាត់ជាអតីតអ្នកនៅក្រោមបង្គាប់របស់ អោ អាន ហើយក៏មានភស្តុតាងសាក្សី និងភស្តុតាងកាលៈទេសៈដែលគាំទ្រ ទាក់ទងទាំងតួនាទីរបស់ អោ អាន និងបញ្ជាដែល ប្រាក់ យុត បានទទួលពី អោ អាន[565]។ ដោយយោងទៅតាមមូលហេតុរបស់ ប្រាក់ យុត ក្នុងការបន្ថយការទទួលខុសត្រូវរបស់គាត់ ការផ្លាស់ប្តូរជាទូទៅនៅក្នុងភស្តុតាងរបស់គាត់ បន្ទាប់ពីបានទទួលលិខិតធានាពីការិយាល័យសហចៅក្រមស៊ើបអង្កេតមក[566] ចៅក្រមអន្តរជាតិយល់ថា ភស្តុតាងរបស់គាត់គួរត្រូវបានត្រួតពិនិត្យដោយម៉ត់ចត់បំផុត ហើយអង្គបុរេជំនុំជម្រះកត់សម្គាល់ទៀតថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាយ៉ាងច្បាស់លាស់ទៅលើផលប៉ះពាល់នៃមូលហេតុនេះ សម្រាប់ភាពអាចជឿជាក់បាន នៃភស្តុតាងរបស់ ប្រាក់ យុត[567]។ ម្យ៉ាងវិញទៀត ចំពោះការចោទប្រកាន់ថា អ្នកស៊ើបអង្កេតតែងតែ "ផ្តល់" ព័ត៌មានទៅឱ្យ ប្រាក់ យុត ដើម្បីបង្កើតភស្តុតាងដាក់បន្ទុកប្រឆាំងទៅនឹង អោ អាន នោះ អង្គជំនុំជម្រះសូមច្រានចោលការអះអាងនេះ[568]។ លើសពីនេះទៀត ចំពោះការដែលសហមេធាវីលើកទឡ្ហីករណ៍ថា ភាពអាចជឿជាក់បាន និងភាពអាចទុកចិត្តបានរបស់ ប្រាក់ យុត ទទួលរងផលប៉ះពាល់ ដោយ

---

[564] សំណុំរឿង ០០៤ កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២ ឯកសារ D107/19, ERN 01347825។

[565] ដូចបានពិភាក្សានៅក្នុងមូលដ្ឋានទី ៦ ខាងក្រោម ចៅក្រមអន្តរជាតិយល់ឃើញថា ជាការសមស្របក្នុងការសន្និដ្ឋានថា អោ អាន ជាអតីតលេខាស្រុក ៤១ ហើយ ប្រាក់ យុត ក្នុងឋានៈជាអតីតលេខាស្រុកកំពង់សៀម គឺជាអ្នកក្រោមបង្គាប់ផ្ទាល់របស់ អោ អាន។

[566] លិខិតធានាជូន ប្រាក់ យុត ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ D117/71/1។

[567] ឧទាហរណ៍ សូមមើល ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៣៦៨, ៤៥៤ (បញ្ជាក់អំពី "មូលហេតុដែល ប្រាក់ យុត និយាយសម្រាលអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងស្រុករបស់គាត់" និងសន្និដ្ឋានថា ភស្តុតាងរបស់គាត់ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ ទួលបេង មិនអាចជឿជាក់បាន)។

[568] ដូចបានពិភាក្សានៅក្នុងមូលដ្ឋានទី ៥ (iii) ខាងក្រោម ចៅក្រមអន្តរជាតិបដិសេធជារួមចំពោះសារណារបស់សហមេធាវី ពាក់ព័ន្ធនឹងការចោទអំពីការស៊ើបអង្កេតមិនត្រឹមត្រូវ ឬភាពលម្អៀង។ ចៅក្រមអន្តរជាតិរម្លឹកថា សហមេធាវីធ្លាប់បានលើកឡើងពីការជំទាស់ដូចគ្នាប្រឆាំងនឹងបទសម្ភាសន៍របស់ ប្រាក់ យុត។ សូមមើល ឧបសម្ព័ន្ធ ខ នៃសំណើសុំធ្វើមោឃភាពកំណត់ហេតុស្តាប់ចម្លើយនានារបស់អ្នកស៊ើបអង្កេតចំនួនបីរូប (អ្នកស៊ើបអង្កេត Christian Baudesson) ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ D338/1/2.3 លេខរៀង ១០, ៥៦។

សារលក្ខណៈនៃសំណួរដែលបានចោទសួរនោះ ចៅក្រមអន្តរជាតិសម្រេចថាមិនមានភស្តុតាងសំអាងឡើយ[569]។

៣៩២. បន្ទាប់ទៅនេះ ចៅក្រមអន្តរជាតិនឹងពិនិត្យមើលទៅលើភាពមិនស្របគ្នាជាច្រើនទាក់ទងជាមួយនឹងបញ្ហាយុត្តាធិការបុគ្គល នៅក្នុងចម្លើយរបស់ ប្រាក់ យុត ដែលសហមេធាវីបានកំណត់[570]។ ចំពោះបញ្ហានេះ អង្គបុរេជំនុំជម្រះសម្រេចថា ភស្តុតាងរបស់ ប្រាក់ យុត ពិតជាមានភាពមិនស្របគ្នាខ្លះ ប៉ុន្តែ ក៏បានយល់ថា ក្នុងករណីចាំបាច់ សហចៅក្រមស៊ើបសួរបានផ្តល់មូលហេតុគ្រប់គ្រាន់ចំពោះការវាយតម្លៃរបស់គាត់ទៅលើភាពជឿជាក់បាន។ នៅក្នុងករណីខ្លះ ចៅក្រមអន្តរជាតិក៏យល់ឃើញថា សហមេធាវីវាយតម្លៃដោយមិនត្រឹមត្រូវលើចំណុចមួយចំនួននៃភស្តុតាងរបស់ ប្រាក់ យុត ឬលើកឡើងដោយមិនត្រឹមត្រូវថា ភាពមិនស្របគ្នាទាំងអស់នេះមានភាពពាក់ព័ន្ធ និងមានសារៈសំខាន់ចំពោះការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើយុត្តាធិការបុគ្គល។

៣៩៣. ចំពោះការចោទប្រកាន់អំពីចម្លើយមិនស្របគ្នារបស់ ប្រាក់ យុត អំពីបញ្ហាថាតើ អោ អាន ធ្វើដំណើរទៅភូមិភាគកណ្តាលជាមួយ ប្រាក់ យុត ឬក៏អត់នោះ[571] ចៅក្រមអន្តរជាតិយល់ឃើញថា មិនមានភាពមិនស្របគ្នាសំខាន់ឡើយនៅក្នុងភស្តុតាងរបស់គាត់។ ប្រាក់ យុត បានបញ្ជាក់ស្របគ្នាថា សាច់ញាតិរបស់គាត់បានរួមដំណើរជាមួយគាត់ ក្នុងពេលដែលគាត់ផ្ទេរទៅភូមិភាគកណ្តាល[572]។ បើពិនិត្យទៅលើភស្តុតាងរបស់

---

[569] ដូចអង្គបុរេជំនុំជម្រះធ្លាប់បានកត់សម្គាល់ពីមុន ត្រូវប្រុងប្រយ័ត្ន នៅពេលពិនិត្យសម្រង់បទសម្ភាសន៍ ដោយមិនពិចារណាលើបរិបទនៃភស្តុតាងជាទូទៅ។ សាលដីកាលើសំណើសុំធ្វើមោឃភាពលើកំណត់ហេតុស្តាប់ចម្លើយ (ឯកសារ D338/1/5) កថាខណ្ឌ ២២។ ចៅក្រមអន្តរជាតិយល់ឃើញថា សហមេធាវីមិនបានបង្ហាញថា តម្លៃជាភស្តុតាងនៃសក្ខីកម្មរបស់ ប្រាក់ យុត ត្រូវបានប៉ះពាល់ ដោយសារតែប្រភេទនៃសំណួរដែលបានចោទសួរនោះឡើយ។

[570] ចៅក្រមអន្តរជាតិពិភាក្សាអំពីភាពមិនស៊ីសង្វាក់គ្នាខ្លះនៃភស្តុតាងរបស់ ប្រាក់ យុត នៅក្នុងមូលដ្ឋានទី ៦ ប្រសិនបើពាក់ព័ន្ធ។

[571] ឧបសម្ព័ន្ធ ឃ នៃបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) ERN 01599794-98។

[572] កំណត់ហេតុនៃការស្តាប់ចម្លើយ ប្រាក់ យុត ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ ឯកសារ D117/70, ERN 01046793-94 (ឆ.៨-ឆ.១០) ("នៅពេលគេបញ្ជូនខ្ញុំទៅភូមិភាគកណ្តាល មានខ្ញុំ ប្តីខ្ញុំ ម្តាយខ្ញុំ និងនារីដប់នាក់ និងបុរសបួននាក់។ អ្នកទាំងអស់នោះជាបងប្អូនសាច់ញាតិខ្ញុំ"។ កំណត់ហេតុនៃការស្តាប់ចម្លើយ ប្រាក់ យុត ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ D6.1.730, ERN 00357510 ("អ្នកមកជាមួយខ្ញុំ មាននីរសាររបស់ខ្ញុំ ១០ នាក់ ហើយនិងអ្នកផ្សេងទៀតប្រហែល ៣០ នាក់")។ កំណត់ហេតុនៃការស្តាប់ចម្លើយ ប្រាក់ យុត ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D6.1.721, ERN 00407797 (ឆ.៥) ("កាលនោះ ខ្ញុំបានយកបងប្អូនខ្ញុំបួនប្រាំនាក់ និងម្តាយខ្ញុំទៅជាមួយ ព្រោះបើខ្ញុំទុកគាត់នៅទីនោះ ខ្ញុំខ្លាចគេធ្វើបាបគាត់")។ កំណត់ហេតុនៃការស្តាប់ចម្លើយ ប្រាក់ យុត ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ D117/71, ERN 01056224 (ឆ.១៥) ("ខ្ញុំបានធ្វើដំណើរជាមួយឪពុកម្តាយខ្ញុំ និងសាច់ញាត់របស់ខ្ញុំ មានប្រុសដប់នាក់ និងស្រីបួននាក់")។ ប្រតិចារឹកសំណុំរឿង ០០២ ថ្ងៃទី២៦ ខែមករា ឆ្នាំ

ប្រាក់ យុត ជារួម ព័ត៌មានរបស់គាត់ហាក់ដូចជាបញ្ជាក់ថា អោ អាន រួមដំណើរជាមួយ ប្រាក់ យុត តែនៅក្រោយពេលដែលពួកគេទាំងពីរ បានមកដល់ភូមិភាគកណ្ដាលប៉ុណ្ណោះ ហើយជាពិសេសគឺនៅពេលដែលពួកគេធ្វើដំណើរនៅក្នុងភូមិភាគកណ្ដាល ពីមន្ទីរភូមិភាគតាមមន្ទីរតំបន់នៅព្រៃទទឹង[573]។ ក្នុងករណីណាក៏ដោយ ថាតើ អោ អាន ធ្វើដំណើររួមគ្នាជាមួយ ប្រាក់ យុត ឬក៏អត់នោះ មិនមានភាពពាក់ព័ន្ធសំខាន់អ្វីជាមួយយុត្តាធិការបុគ្គលឡើយ។

៣៩៤. ចំពោះការចោទប្រកាន់ពីភាពមិនស្របគ្នាអំពីបញ្ហាថាតើ អោ អាន ជាថ្នាក់លើរបស់ ប្រាក់ យុត ឬអត់ នៅក្នុតំបន់ ៤១ នោះ[574] ចៅក្រមអន្តរជាតិរកឃើញមានភាពមិនស្របគ្នាឡើយ ហើយចៅក្រមអន្តរជាតិមិនចាត់ទុកថា ការដែលប្រាក់ យុត មិនបានលើកឡើងពីឈ្មោះរបស់ អោ អាន នៅក្នុងការស្ដាប់ចម្លើយមួយចំនួនរបស់គាត់នោះ គឺជាការប្រឆាំងជាមួយភស្តុតាងលម្អិតរបស់គាត់ ទាក់ទងនឹងតួនាទី និងសិទ្ធិអំណាចរបស់ អោ អាន ឡើយ។ បើទោះបីជា ប្រាក់ យុត មិនបានរម្លឹកអំពីឈ្មោះ អោ អាន នៅក្នុងការស្ដាប់ចម្លើយលើកទីមួយរបស់គាត់ ជាមួយអ្នកស៊ើបអង្កេតក្ដី[575] តែភាពស្ទាក់ស្ទើរពីដំបូងរបស់គាត់ក្នុងការបង្ហាញខ្លួន ប្រហែលជាដោយសារការភ័យខ្លាចពីការបង្ហាញពីការចូលរួមពេញលេញរបស់គាត់នៅក្នុងឧក្រិដ្ឋកម្ម និងធ្វើឱ្យគាត់ត្រូវទទួលរងការចោទប្រកាន់ ដូចដែលបានពិភាក្សាពីខាងលើនោះ អាចត្រូវបានចាត់ទុកថាជា ភាពមិនស្របគ្នាតូចតាច ដែលមិនបណ្ដាលឱ្យមានបញ្ហាធ្ងន់ធ្ងរចំពោះភាពអាចជឿជាក់បាននៃភស្តុតាងលម្អិតរបស់គាត់ផ្សេងទៀត អំពីតួនាទីរបស់ អោ អាន ក្នុងនាមជាលេខាតំបន់ ៤១ ឡើយ។ អង្គបុរេជំនុំជម្រះយល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសនៅក្នុងការវាយតម្លៃ និងការពឹង

---

២០១២ (ប្រាក់ យុត) ឯកសារ D179/1.2.5, ERN 00773595 ទំព័រ ៧៧ (“កាលនុំង ខ្ញុំទៅ មានម៉ែខ្ញុំ បងប្អូនខ្ញុំមួយក្រុមខ្ញុំ អត់មានអ្នកក្រៅទៅជាមួយផង។ ខ្ញុំអត់យកទៅ វាឆ្ងាយពេក។ ហើយម្យ៉ាងគេ ចិត្តគេក៏មិនចង់ទៅ ខ្ញុំយកបងប្អូនខ្ញុំទៅ សាច់ញាតិសន្ដានខ្ញុំហ្នឹងទៅជាមួយខ្ញុំ”។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ប្រាក់យុត ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៣ ឯកសារ D219/234.1.2, ERN 00963134 (ដានី៖ កាលជំនាន់ហ្នឹង អ៊ំទៅតែឯងអ៊ីចឹងទៅ? យុត៖ ទៅជាមួយកូនចៅខ្ញុំ បងប្អូនខ្ញុំ”)។

573 កំណត់ហេតុនៃការស្ដាប់ចម្លើយ ប្រាក់ យុត ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ D117/71, ERN 01046804 (ឆ.២៣)។

574 ឧបសម្ព័ន្ធ ឃ នៃបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) ERN 01599798-9801។

575 សូមមើល កំណត់ហេតុនៃការស្ដាប់ចម្លើយ ប្រាក់ យុត ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ D6.1.730, ERN 00357510។ ទោះក្នុងករណីណាក៏ដោយ ចៅក្រមអន្តរជាតិកត់សម្គាល់ឃើញថា ក្នុងចម្លើយជាបន្តបន្ទាប់របស់គាត់ ដែលផ្ទុយនឹងការអះអាងរបស់សហមេធាវី ប្រាក់ យុត ពិតជាបាននិយាយអំពី អោ អាន ដោយបញ្ជាក់ថា អោ អាន ជាសមាជិកគណៈតំបន់ ៣៥ ហើយក្រោយមក ត្រូវគេផ្លាស់ទៅភូមិភាគកណ្ដាល។ សូមមើល កំណត់ហេតុនៃការស្ដាប់ចម្លើយ ប្រាក់ យុត ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០០៩ ឯកសារ D6.1.733, ERN 00357518-19។ ចម្លើយនាពេលក្រោយៗមកទៀត ដែលសហមេធាវីបានយកមកសំអាង បានប្រាប់លម្អិតថា អោ អាន ជាថ្នាក់លើរបស់ ប្រាក់ យុត បន្ទាប់ពីការសួរសំណួរពាក់ព័ន្ធពីអ្នកស៊ើបអង្កេត។

ផ្អែកទៅលើភស្តុតាងរបស់ ប្រាក់ យុត ឡើយនៅត្រង់ចំណុចនេះ។

៣៩៥. ចំពោះចម្លើយរបស់ ប្រាក់ យុត អំពីបញ្ហាថាតើ អោ អាន បានចូលរួមដែរឬអត់ នៅក្នុងការប្រជុំរៀបចំផែនការនៅភ្នំពេញ អំពីការបោសសម្អាតកម្មាភិបាល ដែលកំពុងកាន់តំណែងនៅភូមិភាគកណ្ដាលនោះ[576] ចៅក្រមអន្តរជាតិយល់ឃើញថា មិនមានភាពមិនស្របគ្នាសំខាន់ៗទេត្រង់ចំណុចនេះ ដែលតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិធ្វើការពន្យល់ឡើយ។ ការអះអាងរបស់សហមេធាវីមិនបានផ្ទុះបញ្ជាំងឱ្យបានត្រឹមត្រូវអំពីភស្តុតាងរបស់ ប្រាក់ យុត ឡើយ[577]។ ប្រាក់ យុត មិនបានបដិសេធអំពីអត្ថិភាពនៃការប្រជុំរវាងកម្មាភិបាលជាន់ខ្ពស់នៅភ្នំពេញទេ ហើយគាត់បានបញ្ជាក់ស្របគ្នាថា គាត់បានចូលរួមការប្រជុំមួយផ្សេងទៀតនៅកំពង់ចាម[578]។ ទោះបីជាចៅក្រមអន្តរជាតិយល់ឃើញថា ប្រាក់ យុត មិនបានបង្ហាញពិតប្រាកដនៅក្នុងភស្តុតាងរបស់គាត់ ទាក់ទងនឹងការប្រជុំរវាងកម្មាភិបាលជាន់ខ្ពស់នៅទីក្រុងភ្នំពេញក្តី[579] តែអចៅក្រមអន្តរជាតិយល់ថា ភស្តុតាងរបស់ ប្រាក់ យុត នៅត្រង់បញ្ហានេះ នៅតែអាចជឿជាក់បាន។ ចៅក្រមអន្តរជាតិមិនឃើញមានកំហុសឆ្គងឡើយ[580]។

---

[576] ឧបសម្ព័ន្ធ ឃ នៃបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) ERN 01599796-97។

[577] ផ្ទុយពីការអះអាងរបស់សហមេធាវីថា ពីដំបូង ប្រាក់ យុត បញ្ជាក់ថា គាត់ (មិនមែន អោ អាន ទេ) បានចូលរួមប្រជុំនៅភ្នំពេញ ក្នុងកំណត់ហេតុ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ដែលសហមេធាវីយកមកសំអាង (ឯកសារ D6.1.730) នីរសាររបស់ កង ចាប បានប្រាប់ ប្រាក់ យុត ឲ្យរៀបចំខ្លួនទៅភ្នំពេញ ហើយពេលទៅដល់ គ្មានការប្រជុំទេ ប៉ុន្តែ គាត់បានរង់ចាំអស់ពីរយប់។ គាត់បានឆ្លើយថា ក្រោយមក គាត់បានចូលរួមប្រជុំជាមួយ កែ ពក នៅកំពង់ចាម។ សូមមើល កំណត់ហេតុនៃការស្តាប់ចម្លើយ ប្រាក់ យុត ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ D6.1.730, ERN 00357510-11។

[578] តាមរយៈចម្លើយរបស់គាត់ ចៅក្រមអន្តរជាតិសង្កេតឃើញថា ប្រាក់ យុត មានភាពស៊ីសង្វាក់គ្នា ដែលថា គាត់មិនបានចូលរួមប្រជុំនៅភ្នំពេញទេ ហើយផ្ទុយទៅវិញ គាត់បានសម្រាកនៅទីនោះបានពីរថ្ងៃ។ គាត់ក៏មានភាពស៊ីសង្វាក់គ្នាផងដែរអំពីការចូលរួមប្រជុំដាច់ដោយឡែកនៅកំពង់ចាម។ សូមមើល កំណត់ហេតុនៃការស្តាប់ចម្លើយ ប្រាក់ យុត ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ D6.1.730, ERN 00357509, កំណត់ហេតុនៃការស្តាប់ចម្លើយ ប្រាក់ យុត ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ ឯកសារ D117/70, ERN 01046793 (ឆ.១៤), បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ប្រាក់យុត ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៣ ឯកសារ D219/234.1.2, ERN 00963134, កំណត់ហេតុនៃការស្តាប់ចម្លើយ ប្រាក់ យុត ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ D219/120, ERN 01063619 (ឆ.៦២), ប្រតិចារឹកសំណុំរឿង ០០២ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ (ប្រាក់ យុត) ឯកសារ D219/702.1.95, ERN 01253317-18 ទំព័រ ៤៤-៤៥។

[579] សូមមើល ប្រតិចារឹកសវនាការសំណុំរឿង ០០២ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ (ប្រាក់ យុត) ឯកសារ D219/702.1.95, ERN 01253315-01253321។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ D219/120, ERN 01046840 (ឆ.៦២)។

[580] ទោះបីជាចៅក្រមអន្តរជាតិ ធ្វើសេចក្តីសន្និដ្ឋាននេះដោយផ្អែកលើការវិភាគឯករាជ្យរបស់ខ្លួនក៏ដោយ ក៏ចៅក្រមអន្តរជាតិកត់

01634951



៣៩៦. ចំពោះការចោទប្រកាន់ពីភាពមិនស្របគ្នាលើបញ្ហាថាតើ អោ អាន មានសិទ្ធិអំណាចក្នុងការរៀបចំពិធីអាពាហ៍ពិពាហ៍ដែរឬអត់នោះ[581] ចៅក្រមអន្តរជាតិយល់ថា មានភាពមិនស្របគ្នាសំខាន់ៗនៅក្នុងសក្ខីកម្មរបស់ ប្រាក់ យុត ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានផ្តល់សំអាងហេតុគ្រប់គ្រាន់ នៅពេលពិភាក្សាអំពីភាពអាចជឿជាក់បានរបស់ ប្រាក់ យុត ហើយបានពន្យល់ពីការពឹងផ្អែករបស់គាត់ទៅលើផ្នែកមួយចំនួននៃភស្តុតាងរបស់ ប្រាក់ យុត លើបញ្ហាមួយនេះ។ ជាឧទាហរណ៍ ប្រាក់ យុត បានផ្តល់សក្ខីកម្មថា មិនមានការរៀបអាពាហ៍ពិពាហ៍ទ្រង់ទ្រាយធំទេ នៅក្នុងស្រុករបស់គាត់[582]។ ប៉ុន្តែ ដូចដែលសហមេធាវីបានបញ្ជាក់ បន្ទាប់មកគាត់ក៏បានបញ្ជាក់ថា អោ អាន និងរូបគាត់បានចូលរួមក្នុងពិធីរៀបអាពាហ៍ពិពាហ៍ដែលមាន ១០គូ[583]។ ទោះបីជាចំណុចនេះមិនស្របគ្នាក្តី តែសហចៅក្រមស៊ើបអង្កេតអន្តរជាតិពឹងផ្អែកទៅលើភស្តុតាងរបស់ ប្រាក់ យុត ក្នុងការកំណត់ថា អោ អាន ធ្វើជាអធិបតីនៅក្នុងការរៀបអាពាហ៍ពិពាហ៍ចំនួន១០គូ នៅស្រុកកំពង់សៀម ដោយភ្ជាប់ជាមួយនឹងភស្តុតាងគាំទ្ររបស់ យូ វ៉ាន់[584]។ លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពន្យល់យ៉ាងច្បាស់លាស់ នៅពេលច្រានចោលសក្ខីកម្មរបស់ ប្រាក់ យុត ដែលថា ការរៀបអាពាហ៍ពិពាហ៍ធ្វើឡើងដោយស្ម័គ្រចិត្ត ហើយគូស្រករមិនត្រូវបានបង្ខំឱ្យផ្សំដំណេក

---

សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ យល់ឃើញស្រដៀងគ្នាថា ភស្តុតាងរបស់ ប្រាក់ យុត អាចជឿជាក់បានគ្រប់គ្រាន់ ដើម្បីគាំទ្រដល់ការសន្និដ្ឋានរបស់ខ្លួនថា មានការប្រជុំមួយនៅភ្នំពេញរវាង ប៉ុល ពត, នួន ជា និងកម្មាភិបាលភូមិភាគនិរតី ១០ នាក់។ សូមមើលប្រៀបធៀបជាមួយ សាលក្រមសំណុំរឿង ០០២/០២ (ឯកសារ E465) ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩ កថាខណ្ឌ ១៤៦៤ (យល់ឃើញបន្ថែមទៀតថា ការចងចាំតិចតួចរបស់ ប្រាក់ យុត អំពីព័ត៌មានលម្អិតទាំងនេះ "អាចដោយសារការគេចវេសដើម្បីបន្ថយការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់គាត់ ឬដោយសារពេលវេលាកន្លងទៅយូរពេក")។

[581] ឧបសម្ព័ន្ធ ឃ នៃបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1.5) ERN 01599803-01599804។

[582] ប្រតិចារឹកសវនាការសំណុំរឿង ០០២ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ (ប្រាក់ យុត) ឯកសារ D219/702.1.95, ERN 01253311 ទំព័រ ៣៨:៩ ដល់ ៣៨:១១។

[583] ប្រតិចារឹកសវនាការសំណុំរឿង ០០២ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ (ប្រាក់ យុត) ឯកសារ D219/702.1.95, ERN 01253311 ទំព័រ ៣៨:២២ ដល់ ៣៨:២៥។។ សូមមើលផងដែរ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ ២០០៩ ឯកសារ D6.1.730, ERN 00357516 (បញ្ជាក់ថា គាត់បានរៀបការចំនួនប្រាំគូ ទៅតាមសំណើរបស់ពួកគេ)។

[584] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៦៨៥(ក)។ លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានផ្អែកលើភស្តុតាងរបស់ ប្រាក់ យុត ពាក់ព័ន្ធនឹងដំណើរការរៀបចំអាពាហ៍ពិពាហ៍ ដោយ មានសំណើផ្លូវការមួយផ្ញើទៅថ្នាក់តំបន់ ដែលជាទូទៅឯកភាពទៅលើការរៀបអាពាហ៍ពិពាហ៍ បន្ទាប់មក ពិធីរៀបអាពាហ៍ពិពាហ៍ត្រូវបានរៀបចំឡើងនៅថ្នាក់ក្រោម។ សូមមើល ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៣១៨។ ចៅក្រមអន្តរជាតិជឿជាក់ថា កម្រិតនៃភាពស៊ីសង្វាក់គ្នា និងព័ត៌មានលម្អិតអំពីដំណើរការរៀបចំអាពាហ៍ពិពាហ៍នៅក្នុងចម្លើយរបស់ យូ វ៉ាន់ បញ្ជាក់ថា ភស្តុតាងជាអង្គហេតុទៅលើបញ្ហានេះអាចជឿជាក់បាន។

នោះ ក៏ដោយ "ក៏ភស្តុតាងលើសលប់អំពីការបង្ខិតបង្ខំធ្វើឱ្យសក្ខីកម្មរបស់ពួកគេមិនអាចជឿជាក់បាន"[585]។ ជាចុងក្រោយ ចៅក្រមអន្តរជាតិកត់សម្គាល់ថា ដោយមិនគិតអំពីបញ្ហានៃភាពអាចជឿជាក់បានខាងលើ ប្រាក់ យុត នៅតែផ្តល់ចម្លើយស្របគ្នា ទៅលើចំណុចជាក់លាក់ថា អោ អាន មានសិទ្ធិអំណាចលើការរៀបអាពាហ៍ពិពាហ៍។ ហេតុដូច្នេះ ចៅក្រមអន្តរជាតិជឿជាក់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសឆ្គងឡើយ ក្នុងការវាយតម្លៃទៅលើភាពអាចជឿជាក់បាន ហើយថា ការពឹងផ្អែករបស់គាត់ទៅលើភស្តុតាងរបស់ ប្រាក់ យុត មិនមែនថាមិនសមហេតុផលឡើយ[586]។

## ខ. យូ វ៉ាន់

### ១. សារណា

៣៩៧. សហមេធាវីបានអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឆ្គងដោយមិនបាន ត្រួតពិនិត្យឱ្យបានពេញលេញទៅលើខ្លឹមសារ និងភាពអាចជឿជាក់បាន នៃភស្តុតាងរបស់ យូ វ៉ាន់ ហើយមិនបានពន្យល់អំពីការពឹងផ្អែករបស់គាត់ទៅលើភស្តុតាងរបស់ យូ វ៉ាន់ សម្រាប់អង្គហេតុសំខាន់ៗទាក់ទងនឹងយុត្តាធិការបុគ្គល[587]។ ចំពោះសហមេធាវី ការពឹងផ្អែកយ៉ាងខ្លាំងរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅលើ យូ វ៉ាន់ ដែលជាអតីតនិរសាររបស់ ប្រាក់ យុត គឺជាឧទាហរណ៍មួយនៃការដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានដេញដោលឱ្យបានពេញលេញ និងដោយសត្យានុម័តទៅលើ ភាពអាចជឿជាក់បានរបស់ ប្រាក់ យុត[588]។ ជាពិសេស សហមេធាវីបានជំទាស់ចំពោះការប្រើប្រាស់ចម្លើយរបស់ យូ វ៉ាន់ ដើម្បី

---

[585] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២២៩។

[586] សូមមើលប្រៀបធៀបជាមួយ សាលក្រមសំណុំរឿង ០០២/០២ (ឯកសារ E465) កថាខណ្ឌ ៣១៩១ ("នេះមិនមែនជាលើកដំបូងទេ ដែលសាក្សីរូបនេះបានផ្តល់ព័ត៌មានបន្ថែម នៅពេលក្រោយមកនោះ ព្រោះថា សូម្បីតែក្នុងករណីហេតុស្តាប់ចម្លើយលើកទី ៥ របស់គាត់ក៏គាត់បានពន្យល់ថា គាត់បានលាក់ព័ត៌មានមួយចំនួននៅក្នុងការស្តាប់ចម្លើយគាត់ពីមុននោះ ដោយសារតែគាត់បារម្ភអំពីសុវត្ថិភាពរបស់គាត់។ ប្រាក់ យុត ហាក់ដូចជាមានទំនោរទូទៅមួយក្នុងការកាត់បន្ថយភស្តុតាងដាក់បន្ទុកមកលើខ្លួនគាត់ដែលពាក់ព័ន្ធនឹងគោលនយោបាយរបស់ ប.ក.ក។ ប្រាក់ យុត ក៏បានព្យាយាមនិយាយកាត់បន្ថយការប្រព្រឹត្តផ្ទាល់ខ្លួនរបស់គាត់ និងជាពិសេសតួនាទីរបស់គាត់ពាក់ព័ន្ធនឹងបញ្ហាដែលគាត់បានទទួលអំពីការកំណត់គោលដៅទៅលើជនជាតិចាមផងដែរ។ ទោះជាយ៉ាងនេះក្តី ក្រៅពីអ្វីដែលបានលើកឡើងខាងលើ អង្គជំនុំជម្រះយល់ឃើញថា សក្ខីកម្មរបស់គាត់មានលក្ខណៈលម្អិត ស៊ីសង្វាក់គ្នា និងអាចជឿជាក់បានជាទូទៅ ហើយអង្គជំនុំជម្រះកត់សម្គាល់ថា សក្ខីកម្មនេះត្រូវបានគាំទ្រដោយភស្តុតាងរបស់សាក្សីផ្សេងៗទៀត ដូចជា យូ វ៉ាន់ ជាដើម")។

[587] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៦៥-៦៦។

[588] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៦៥។

គាំទ្រចម្លើយរបស់ ប្រាក់ យុត ហើយចាត់ទុកថា យូ វ៉ាន់ មិនមានភាពគួរឱ្យជឿជាក់បាន ដោយសារតែ យូ វ៉ាន់ អាចត្រូវបានទទួលឥទ្ធិពលពី ប្រាក់ យុត[589]។ លើសពីនេះទៀត ភស្តុតាងរបស់ យូ វ៉ាន់ មិនអាចទុកចិត្តបានដោយសារតែគាត់ (១) បាន "ទទួល" ព័ត៌មានដាក់បន្ទុកពីអ្នកស៊ើបអង្កេត[590] (២) មិនស៊ីសង្វាក់គ្នាលើបញ្ហាគន្លឹះៗ[591] និង (៣) ជារឿយៗ "ផ្តល់" ព័ត៌មានដែល ប្រាក់ យុត បានប្រាប់គាត់[592]។

៣៩៨. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា សហមេធាវីមិនបានបំពេញកាតព្វកិច្ចនៃការបង្ហាញរបស់ពួកគេដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឆ្គងក្នុងការផ្តល់ទម្ងន់ទៅដល់ចម្លើយរបស់ យូ វ៉ាន់[593]។ ទីមួយ មិនមានសំអាងហេតុអ្វីក្នុងការផ្តល់យុត្តិកម្មចំពោះការច្រានចោល ការសម្រេចជាឯកច្ឆ័ន្ទរបស់អង្គបុរេជំនុំជម្រះ ដែលសម្រេចថា មិនមានការអនុវត្តកិច្ចស៊ើបសួរដោយមិនត្រឹមត្រូវនោះទេ[594]។ ទីពីរ ការចោទប្រកាន់ពីភាពមិនស្របគ្នា គ្មានមូលដ្ឋានគាំទ្រទេ[595]។ ទីបី ការកំណត់ប្រភេទនៃភស្តុតាងរបស់ យូ វ៉ាន់ ថាជាការផ្តល់ព័ត៌មានរបស់ ប្រាក់ យុត គឺជាការបញ្ជាក់ថា ព័ត៌មានរបស់ពួកគេ គាំទ្រគ្នាទៅវិញទៅមក ដែលនេះជាអង្គហេតុបង្ហាញថា ការចងចាំរបស់ យូ វ៉ាន់ គាំទ្រដល់ភស្តុតាងរបស់ ប្រាក់ យុត ហើយបង្ហាញពីភាពអាចជឿជាក់បានរបស់ភស្តុតាងនេះ[596]។ ជាចុងក្រោយ សហព្រះរាជអាជ្ញាអន្តរជាតិយល់ថា ការអះអាងថា ភស្តុតាងរបស់ យូ វ៉ាន់ "អាចត្រូវបានទទួលឥទ្ធិពល" ពី ប្រាក់ យុត នោះ ជាការស្មានប៉ុណ្ណោះ[597]។ ជាលទ្ធផល សហមេធាវីមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការបង្ហាញថា មិនមានអ្នកវិនិច្ឆ័យអង្គហេតុដែលមានហេតុផលណាម្នាក់ អាចពឹងផ្អែកទៅលើភស្តុតាងរបស់ យូ វ៉ាន់ ឡើយ។

[589] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៦៦ និងកំណត់សម្គាល់ជើងទំព័រ ១២៩។

[590] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៦៦ និងកំណត់សម្គាល់ជើងទំព័រ ១៣០។

[591] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៦៦ និងកំណត់សម្គាល់ជើងទំព័រ ១៣១។

[592] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៦៦ និងកំណត់សម្គាល់ជើងទំព័រ ១៣២។

[593] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៣៩។

[594] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៣៩ និងកំណត់សម្គាល់ជើងទំព័រ ៧៦។

[595] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៣៩ និងកំណត់សម្គាល់ជើងទំព័រ ៧៧។

[596] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៣៩ និងកំណត់សម្គាល់ជើងទំព័រ ៧៨។

[597] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៣៩ និងកំណត់សម្គាល់ជើងទំព័រ ៨០។

## ២. ការពិភាក្សា

៣៩៩. ចៅក្រមអន្តរជាតិយល់ថា មិនមានកំហុសឆ្គងក្នុងការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើភាពអាចជឿជាក់បានរបស់ យូ វ៉ាន់ ឬនៅក្នុងការពឹងផ្អែកទៅលើភស្តុតាងរបស់ យូ វ៉ាន់ ឡើយ។ ចំពោះការចោទប្រកាន់ពី វិការៈផ្នែកនីតិវិធី នៅក្នុងការប្រមូលភស្តុតាងវិញ ចៅក្រមអន្តរជាតិច្រានចោលទឡ្ហីករណ៍ទាំងអស់នេះទាំងស្រុង[598]។ ចៅក្រមអន្តរជាតិក៏មិនយល់ថា សហមេធាវីបានបង្ហាញភាពមិនស្របគ្នាជាសំខាន់នៅក្នុងភស្តុតាងរបស់ យូ វ៉ាន់ ដែលតម្រូវឱ្យមានការពន្យល់នោះដែរ[599]។ ចំពោះទឡ្ហីករណ៍ដែលថា យូ វ៉ាន់ "ផ្តល់" ព័ត៌មានដែលទទួលបានពី ប្រាក់ យុត នោះ ចៅក្រមអន្តរជាតិចាត់ទុកថា កាលៈទេសៈនេះមិនចោទជាបញ្ហាឡើយ សម្រាប់ភាពអាចជឿជាក់បានរបស់ យូ វ៉ាន់ ប៉ុន្តែ បែរជាជួយគាំទ្រ

---

[598] សូមមើល ខាងក្រោម មូលដ្ឋានទី ៥(iii)។ ចម្លើយដែលរងការជំទាស់ ត្រូវបានសហមេធាវីធ្វើការតវ៉ាជំទាស់កាលពីពេលមុន។ សូមមើល ឧបសម្ព័ន្ធ ខ នៃសំណើសុំធ្វើមោឃភាពកំណត់ហេតុស្តាប់ចម្លើយ ឯកសារ D338/1/2.3 លេខរៀងទី ៤។ សំណុំរឿង ០០៤/២ ឧបសម្ព័ន្ធ ឃ នៃសំណើសុំធ្វើមោឃភាពកំណត់ហេតុស្តាប់ចម្លើយនានារបស់អ្នកស៊ើបអង្កេតចំនួនបីរូប (អ្នកស៊ើបអង្កេត Andrea Ewing) ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ D338/1/2.5 លេខរៀងទី ១។ លើសពីនេះទៀត ចៅក្រមអន្តរជាតិយល់ឃើញថា សហមេធាវីមិនបានបង្ហាញឱ្យឃើញថា តម្លៃជាភស្តុតាងនៃសក្ខីកម្មរបស់ យូ វ៉ាន់ ត្រូវបានប៉ះពាល់ ឬថា វាមិនសមហេតុផលសម្រាប់វិនិច្ឆ័យទៅលើអង្គហេតុ ក្នុងការផ្អែកលើភស្តុតាងដែលរងការជំទាស់នេះទេ។

[599] សហមេធាវីបញ្ជាក់ពីភាពមិនស៊ីសង្វាក់គ្នាចំពោះពីរទៅលើ "បញ្ហាគន្លឹះៗ"។ ទាក់ទាងនឹងភាពមិនស៊ីសង្វាក់គ្នាទីមួយ ទោះបីជាសក្ខីកម្មរបស់ យូ វ៉ាន់ ថាតើគាត់បានប្រគល់សំបុត្ររវាង ប្រាក់ យុត និង អោ អាន ឬទេ មើលទៅហាក់ដូចជាមិនស៊ីសង្វាក់គ្នាក៏ដោយ ក៏ចៅក្រមអន្តរជាតិមិនជឿថា ភាពមិនស៊ីសង្វាក់គ្នានេះពាក់ព័ន្ធនឹង "បញ្ហាគន្លឹះ" មួយ ឬអង្គហេតុជាក់ស្តែងពាក់ព័ន្ធនឹងយុត្តាធិការបុគ្គលដែលតម្រូវឱ្យមានការពន្យល់។ *សូមប្រៀបធៀប* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ឯកសារ D219/138, ERN 01056044-01056045 (ឆ.២៣, ឆ.២៥-២៦) ជាមួយ ប្រតិចារឹកសវនាការសំណុំរឿង ០០២ ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ (យូ វ៉ាន់) ឯកសារ D219/702.1.87, ERN 01451945-01451946 ទំព័រ ៤២-៤៣។ ពាក់ព័ន្ធនឹងភាពមិនស៊ីសង្វាក់គ្នាទីពីរ អង្គជំនុំជម្រះយល់ឃើញថា ភស្តុតាងនេះមិនមែនមិនមានភាពស៊ីសង្វាក់គ្នាជាក់ស្តែងទេ ប៉ុន្តែ វាឆ្លុះបញ្ចាំងពីខ្សែសង្វាក់នៃការប្រាស្រ័យទាក់ទងតាមខ្សែទទឹងរវាងថ្នាក់តំបន់ ថ្នាក់ស្រុក និងថ្នាក់ឃុំ ក្នុងការអនុវត្តច្បាប់គ្រប់គ្រងលើកការរៀបអាពាហ៍ពិពាហ៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ប្រៀបធៀប កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ឯកសារ D219/138, ERN 01056057 (ឆ.៨០, ឆ.៨១) (អោ អាន ចេញច្បាប់ស្តីការរៀបអាពាហ៍ពិពាហ៍) ជាមួយ ប្រតិចារឹកសវនាការសំណុំរឿង ០០២ ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ (យូ វ៉ាន់) ឯកសារ D219/702.1.87, ERN (EN) 01438519-01438521, pp. 78-80 (ប្រាក់ យុត និង អោ អាន បានប្រកាសពីច្បាប់ស្តីពីការរៀបអាពាហ៍ពិពាហ៍)។ សូមមើលជាទូទៅ ប្រតិចារឹកសវនាការសំណុំរឿង ០០២ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ (យូ វ៉ាន់) ឯកសារ D219/702.1.94, ERN 01253374-01253376 ទំព័រ ២៧-២៩ (ក្រោយពីបញ្ជាក់ថា ប្រាក់ យុត ប្រកាសពីច្បាប់ស្តីពីការរៀបអាពាហ៍ពិពាហ៍ យូ វ៉ាន់ ពន្យល់ថា ហេតុអ្វីបានជាប្រាក់ យុត ធ្វើដូច្នេះ៖ "អាហ្នឹងមកពីគេបញ្ជាពីលើគាត់ទៀត បានគាត់ធ្វើអ៊ីចឹង")។

ដល់ភាពអាចជឿជាក់បាននៃភស្តុតាងរបស់គាត់ទៅវិញ គឺអង្គហេតុដែលថា យូ វ៉ាន់ បានរម្លឹកអំពីព័ត៌មានសម័យនោះ ដែលទទួលបានពី ប្រាក់ យុត ហើយថាការចងចាំទាំងនេះ ស្របគ្នាជាមួយខ្លឹមសារនៃសក្ខីកម្មរបស់ ប្រាក់ យុត ជាការគាំទ្រ និងពង្រឹងបន្ថែមទៅលើព័ត៌មាន[600]។ ប្រហែលគ្នានេះ ចៅក្រមអន្តរជាតិមិនយល់ថា ជាការមិនសមហេតុផលដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកទៅលើចម្លើយរបស់ យូ វ៉ាន់ ធ្វើជាភស្តុតាងគាំទ្រចំពោះអង្គហេតុសំខាន់ៗដែល ប្រាក់ យុត បានផ្តល់សក្ខីកម្មនោះទេ[601]។ ជាចុងក្រោយ ការព្យាយាមរបស់សហមេធាវីក្នុងការបន្ទាបតម្លៃភស្តុតាងរបស់ យូ វ៉ាន់ ដោយផ្អែកលើមូលដ្ឋានដែលថា គាត់ "អាចត្រូវបានទទួលឥទ្ធិពល" ពី ប្រាក់ យុត នោះ មិនមានមូលដ្ឋានឡើយ[602]។ ហេតុដូច្នេះ ចៅក្រមអន្តរជាតិយល់ថា ភស្តុតាងរបស់ យូ វ៉ាន់ ពាក់ព័ន្ធនឹងបញ្ហាយុត្តាធិការបុគ្គល អាចជឿជាក់បានជាទូទៅ[603]។

---

[600] ទោះបីជាចៅក្រមអន្តរជាតិឈានដល់ការធ្វើសេចក្តីសន្និដ្ឋាននេះ ដោយផ្អែកលើការវាយតម្លៃផ្ទាល់ខ្លួនទៅលើភស្តុតាងក៏ដោយ ក៏ចៅក្រមអន្តរជាតិកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០២ ប្រកាន់ជំហរស្រដៀងគ្នា។ នៅក្នុងការវាយតម្លៃលើភាពអាចជឿជាក់បាននៃសក្ខីកម្មរបស់ ប្រាក់ យុត និងការសន្និដ្ឋានថា សក្ខីកម្មរបស់គាត់អំពីការកំណត់គោលដៅជនជាតិចាម អាចជឿជាក់បានជាទូទៅ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ស្រដៀងគ្នាថា សក្ខីកម្មរបស់ ប្រាក់ យុត "ត្រូវបានគាំទ្រដោយភស្តុតាងរបស់សាក្សីដទៃៗទៀត ដូចជា យូ វ៉ាន់ ជាដើម") សាលក្រមសំណុំរឿង ០០២/០២ (ឯកសារ E465) កថាខណ្ឌ ៣១៩១។

[601] សូមមើលប្រៀបធៀបជាមួយ សាលក្រមសំណុំរឿង ០០២/០២ (ឯកសារ E465) កថាខណ្ឌ ៣២៨៨, ៣៦៥៦ (ផ្ទៀកលើសក្ខីកម្មរបស់ ប្រាក់ យុត និង យូ វ៉ាន់ ដែលមានភាពស៊ីសង្វាក់គ្នា)។

[602] សហមេធាវីមិនបានបញ្ជាក់ពីការអះអាងរបស់ខ្លួនថា យូ វ៉ាន់ "ទទួលឥទ្ធិពល" ដោយ ប្រាក់ យុត ហើយចៅក្រមអន្តរជាតិមិនបានរកឃើញការបញ្ជាក់ណាមួយថា ប្រាក់ យុត ព្យាយាមទាក់ទង យូ វ៉ាន់ និងកែប្រែសក្ខីកម្មរបស់គាត់ ដើម្បី "គាំទ្រការភូតកុហករបស់គាត់ [ប្រាក់ យុត]" ដូចដែលបានចោទប្រកាន់។ សូមមើលប្រៀបធៀបជាមួយ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ឯកសារ D219/138, ERN 01056066 (ឆ.១១៤)។

[603] ចៅក្រមអន្តរជាតិឈានដល់ការធ្វើសេចក្តីសន្និដ្ឋាននេះ ដោយផ្អែកលើការវាយតម្លៃផ្ទាល់ខ្លួនទៅលើសក្ខីកម្មរបស់ យូ វ៉ាន់ ប៉ុន្តែក៏បានសង្កេតឃើញផងដែរថា អង្គជំនុំជម្រះសាលាដំបូងបានប្រកាន់យកជំហរស្រដៀងគ្នា។ សូមមើលប្រៀបធៀបជាមួយ សាលក្រមសំណុំរឿង ០០២/០២ (ឯកសារ E465) កថាខណ្ឌ ៣៥៧៩ (ទទួលយកសក្ខីកម្មរបស់ យូ វ៉ាន់ ដែលបញ្ជាក់ថា ប្រាក់ យុត បានប្រកាសថា ការរៀបការចម្រុះជាតិសាសន៍ ត្រូវបានហាមឃាត់ និងសន្និដ្ឋានថា "សក្ខីកម្មរបស់ យូ វ៉ាន់ មានភាពស៊ីសង្វាក់គ្រប់គ្រាន់ជាមួយនឹងភស្តុតាងផ្សេងទៀត ដូច្នេះសក្ខីកម្មនេះអាចជឿជាក់បាន")។

01634956



## គ. ពៅ សារ៉ុម, ពុត កុល និង កែវ វឿន

### ១. សារណា

៤០០. សហមេធាវីបានអះអាងថា ការដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិពឹងផ្អែកទៅលើភស្តុតាងរបស់ ពៅ សារ៉ុម, ពុត កុល និង កែវ វឿន ដោយមិនមានការពន្យល់ គឺជាកំហុសឆ្គង ហើយថានេះជា "ភស្តុតាង [អំពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ] បង្កើតករណីជុំវិញការកុហករបស់ ប្រាក់ យុត"[604]។ សហមេធាវីកត់សម្គាល់ថា សាក្សីទាំងបីនាក់នេះ គឺជាសាច់ញាតិរបស់ ប្រាក់ យុត ហើយអះអាងថា ពួកគេគឺជា "សមាជិកក្រុមរបស់ ប្រាក់ យុត" ហើយមានមូលហេតុដើម្បីកុហក "ជាអាទិ៍បន្ទោស អោ អាន ដើម្បីការពារ ប្រាក់ យុត និងនាមត្រកូលរបស់ពួកគេ"[605]។ លើសពីនេះទៀត សហមេធាវីយល់ថា ប្រហែលជាអាចដែលថា សាក្សីទាំងអស់នេះបាននិយាយជាមួយ ប្រាក់ យុត អំពីការស៊ើបអង្កេត ហើយជាលទ្ធផល ភស្តុតាងរបស់ពួកគេខ្វះភាពអាចជឿជាក់បានឡើយ[606]។

៤០១. សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ការជំទាស់របស់សហមេធាវីទៅលើសាច់ញាតិរបស់ ប្រាក់ យុត ដោយមិនបានបង្ហាញថា សាក្សីទាំងអស់នេះបានបន្ទោសទៅលើ អោ អាន ដើម្បីការពារ "នាមត្រកូលរបស់ពួកគេ" ឬថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានរំលោភបំពានទៅលើឆន្ទានុសិទ្ធរបស់គាត់ឡើយ[607]។ សហព្រះរាជអាជ្ញាអន្តរជាតិកត់សម្គាល់ថា ភស្តុតាងដែលរងការជំទាស់របស់សាក្សីទាំងអស់នេះ គ្រាន់តែលើកឡើងអំពីតួនាទីរបស់ អោ អាន នៅក្នុងឧក្រិដ្ឋកម្មប៉ុណ្ណោះ[608]។លើសពីនេះទៀត ចំពោះភស្តុតាងរបស់ ពៅ សារ៉ុម ដែលឆ្លើយដាក់ទៅលើ អោ អាន ភស្តុតាងនេះក៏ឆ្លើយដាក់ផងដែរទៅលើ ប្រាក់ យុត និង ពៅ សារ៉ុម ខ្លួនគាត់ផងដែរ ដូច្នេះហើយមិនបានគាំទ្រដល់ការចោទប្រកាន់របស់សហមេធាវីដែលថា សាក្សីនេះឆ្លើយដាក់ អោ អាន ដោយខុសឆ្គង ដើម្បីការពារត្រកូលរបស់ពួកគេនោះឡើយ[609]។ ជា

[604] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៦៧ និងកំណត់សម្គាល់ជើងទំព័រ ១៣៣។

[605] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៦៨ និងកំណត់សម្គាល់ជើងទំព័រ ១៣៤-១៣៦។

[606] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៦៨ និងកំណត់សម្គាល់ជើងទំព័រ ១៣៧។។

[607] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៤០-៤១។

[608] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៤០ និងកំណត់សម្គាល់ជើងទំព័រ ៨២-៨៣។

[609] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៤០ និងកំណត់សម្គាល់ជើងទំព័រ ៨៤។

ចុងក្រោយ សហព្រះរាជអាជ្ញាអន្តរជាតិនៅតែរក្សាជំហរថា ការចោទប្រកាន់របស់សហមេធាវី អំពីភាពមិនត្រឹមត្រូវនោះ គឺជាការស្មានដោយគ្មានមូលដ្ឋាន[610]។

## ២. ការពិភាក្សា

៤០២. ចៅក្រមអន្តរជាតិយល់ថា ការព្យាយាមរបស់សហមេធាវីក្នុងការបន្ទាបតម្លៃ ពៅ សារ៉ុម, ពុត កុល និង កែវ វឿន មិនបានបង្ហាញពីកំហុសឆ្គងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិឡើយ។ ត្រឹមតែការចោទប្រកាន់ថា សាក្សីមួយចំនួនមានទំនាក់ទំនងជិតស្និទ្ធនោះ មិនបានធ្វើឱ្យប៉ះពាល់ដល់ភាពអាចជឿជាក់បានរបស់ភស្តុតាងសាក្សីទាំងនោះទេ។ លើសពីនេះទៀត នៅពេលត្រួតពិនិត្យទៅលើអង្គសេចក្តីនៃចម្លើយដែលរងការជំទាស់នោះ ចៅក្រមអន្តរជាតិមិនជឿថា ការជំទាស់របស់សហមេធាវីអំពីភាពអាចជឿជាក់បាននោះ មានភស្តុតាងគាំទ្រឡើយ។ កែវ វឿន មិនបានលើកឡើងអំពី អោ អាន នៅក្នុងភស្តុតាងដែលរងការជំទាស់ទេ[611]។ ភស្តុតាងរបស់ ពុត កុល មិនបានបង្ហាញពីមូលហេតុក្នុងការការពារ ប្រាក់ យុត ឬបន្ទោសទៅលើ អោ អានឡើយ[612] ហើយក្នុងករណីណាក៏ដោយ ចម្លើយរបស់គាត់មួយចំនួនអំពី អោ អាន ក៏មានការពាក់ព័ន្ធជាមួយ ប្រាក់ យុត ដែរ[613]។ ភស្តុតាងរបស់ ពៅ សារ៉ុម[614] ទោះបីជាបានឆ្លើយដាក់ អោ អាន ក្តី តែក៏បានឆ្លើយដាក់ ប្រាក់ យុត និងរូបគាត់ផ្ទាល់ផងដែរ នៅពេលរៀបចំបញ្ជីចាប់ខ្លួនមនុស្ស[615]។

---

[610] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៤១ និងកំណត់សម្គាល់ជើងទំព័រ ៨៥។

[611] សូមមើល កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ វឿន ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ D219/191, ERN 01068078 (ឆ.៤៧)។

[612] សូមមើល កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុត កុល ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣ ឯកសារ D117/26, ERN 00951885 (ឆ.៤) (បញ្ជាក់ថា ប្តីរបស់ ប្រាក់ យុត ត្រូវបានចាប់ខ្លួន ដោយគ្មានការចោទប្រកាន់) (ឆ.៥) (គ្រាន់តែរៀបរាប់ពីការធ្វើដំណើររបស់គាត់ពីភូមិភាគនិរតីទៅភូមិភាគកណ្តាល)។

[613] សូមមើល កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុត កុល ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣ ឯកសារ D117/26, ERN 00951886 (ឆ.១៣) (បញ្ជាក់ថា អោ អាន ដែលជាប្រធានតំបន់ ៤១ បានជួបជាមួយ ប្រាក់ យុត នៅស្រុកកំពង់សៀម ប៉ុន្តែសាក្សី "មិនហ៊ានទៅជិតគាត់ដើម្បីស្តាប់ការពិភាក្សារបស់គាត់ទាំងពីរឡើង")។

[614] ចៅក្រមអន្តរជាតិមិនជឿថា ពៅ សារ៉ុម ព្យាយាមទម្លាក់ទំនួលខុសត្រូវទៅលើ អោ អាន ទាំងខុស ដូចដែលបានប្រកាន់។ សូមមើល កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពៅ សារ៉ុម ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៥ ឯកសារ D219/284, ERN 01091376 (ឆ.៣៣) (ពៅ សារ៉ុម បញ្ជាក់ថា ប្តីរបស់ ប្រាក់ យុត ត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៧៧ ប៉ុន្តែ មិនបានបញ្ជាក់ ឬលើកឡើងថា អោ អាន ជាអ្នកបញ្ជាឱ្យចាប់ខ្លួនទេ)។

[615] នៅក្នុងភស្តុតាងដែលបានយោង ពៅ សារ៉ុម បានពន្យល់ពីរបៀបដែលគាត់ត្រូវបាន ណន ប្រធានមន្ទីរស្រុកកំពង់សៀម សុំឱ្យ

លើសពីនេះទៀត ការលើកឡើងរបស់សហមេធាវីដែលថា សាក្សីទាំងអស់នេះសមគំនិតជាមួយ ប្រាក់ យុត ដើម្បីទម្លាក់កំហុសទៅលើ អោ អាន ដោយមិនត្រឹមត្រូវនោះ ភាគច្រើនផ្អែកលើការស្មាន[616]។ ហេតុដូច្នេះ ចៅក្រមអន្តរជាតិយល់ថា ដោយមិនគិតអំពីទំនាក់ទំនងគ្រួសាររបស់ពួកគេជាមួយ ប្រាក់ យុត ភស្តុតាងរបស់ ពៅ សារ៉ុម, ពុត កុល និង កែវ វឿន អាចជឿជាក់បានជាទូទៅ ហើយអាចពឹងផ្អែកទៅលើដោយសមហេតុផលក្នុងការកំណត់អំពីយុត្តាធិការបុគ្គល។

## ឃ. ញៀម ចេន

### ១. សារណា

៤០៣. សហមេធាវីអះអាងថា ញ៉ែម ចេន មិនមែនជាសាក្សីគួរឱ្យជឿជាក់ឡើយ សម្រាប់បញ្ហាស្តីពីតួនាទី និងការទទួលខុសត្រូវរបស់ អោ អាន ហើយការពឹងផ្អែករបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ "ដោយគ្មានសំអាង" ទៅលើភស្តុតាងរបស់ ញ៉ែម ចេន គឺជាកំហុសអង្គច្បាប់[617]។ ជាពិសេស សហមេធាវីបានជំទាស់អំពីភាពអាចជឿជាក់បានរបស់ភស្តុតាង ញ៉ែម ចេន ដោយសារតែ (១) គាត់ជា "កុមារ" នៅក្នុងឆ្នាំ ១៩៧៧ ដល់ឆ្នាំ១៩៧៩ ដែលប៉ះពាល់មិនល្អដល់ភាពសុក្រិតនៃសក្ខីកម្មរបស់គាត់ ជាពិសេសដោយ "សំណួរណែនាំ" របស់អ្នកស៊ើបអង្កេត[618] (២) ភស្តុតាងរបស់គាត់គឺផ្អែកលើការស្មាន និងពាក្យចចាមអារាម

---

រៀបចំបញ្ជីឈ្មោះអ្នកដែលត្រូវចាប់ខ្លួន។ សូមមើល កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពៅ សារ៉ុម ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D219/284, ERN 01091382-01091383 (ឆ.៧៣, ឆ.៧៦-ឆ.៧៨)។ ពៅ សារ៉ុម ពន្យល់ថា អោ អាន បានចាត់តាំង ប្រាក់ យុត ឱ្យកាន់ស្រុកកំពង់សៀម។ បន្ទាប់មក ប្រាក់ យុត បានចាត់ ពៅ សារ៉ុម ជាប្រធានឃុំក្រឡា។ សូមមើល កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពៅ សារ៉ុម ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ឯកសារ D117/24, ERN 00947235 (ឆ.១១)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពៅ សារ៉ុម ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៣ ឯកសារ D117/33, ERN 00964468 (ឆ.៣)។

[616] ទោះបីជា ការដែលថា ពុត កុល បានទាក់ទងជាមួយ ប្រាក់ យុត មុនសម្ភាសន៍ជាមួយគាត់ នាំឱ្យមានការពិចារណាពាក់ព័ន្ធមួយ នៅក្នុងការវិភាគលើភាពអាចជឿជាក់បានរបស់សាក្សីក៏ដោយ សូមមើល កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុត កុល ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣ ឯកសារ D117/26, ERN 00951888-00951889 (ឆ.២៩) ក៏សហមេធាវីមិនបានផ្តល់សំអាងហេតុជាក់លាក់ណាមួយនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ពួកគេ ដើម្បីជឿថា សាក្សីបានសម្របសម្រួលដោយមិនត្រឹមត្រូវនូវសក្ខីកម្មរបស់ពួកគេ ឬកង្វល់ផ្សេងទៀតណាមួយដែលមានភស្តុតាងបង្ហាញច្បាស់លាស់ ដែលតម្រូវឱ្យមានការពន្យល់ខ្លះនៅក្នុងការវាយតម្លៃលើភាពអាចជឿជាក់បាន។ លើសពីនេះទៀត នៅក្នុងការវាយតម្លៃលើខ្លឹមសារនៃសក្ខីកម្មរបស់សាក្សីចំនួនបី ចៅក្រមអន្តរជាតិមិនជឿថា សាក្សីព្យាយាមធ្វើឱ្យការរៀបរាប់របស់ពួកគេមានភាពស៊ីសង្វាក់គ្នានោះទេ។

[617] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧០។

[618] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧០ និងកំណត់សម្គាល់ជើងទំព័រ ១៤០-១៤៣។

ដោយសារតែគាត់មិនមានការយល់ដឹងអំពីរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា និងបញ្ហាសំខាន់ៗដទៃទៀត[619] និង (៣) ភស្តុតាងរបស់គាត់មិនមានសំអាង និងមិនស្របជាមួយអ្នកដទៃ ដែលធ្វើការជាមួយ អោ អាន នៅពេលនោះ ហើយមិនមាននរណាម្នាក់អាចបញ្ជាក់ចម្លើយរបស់ ញ៉ែម ចេន ឡើយ[620]។

៤០៤. សហព្រះរាជអាជ្ញាអន្តរជាតិបានជំទាស់ទៅលើការវាយតម្លៃថា ញ៉ែម ចេន គឺជាសាក្សីដែលមិនអាចទុកចិត្តបាន។ ទីមួយ ញ៉ែម ចេន មិនមែនជា "កុមារ" ទេ គឺគាត់មានអាយុ ១៧ ឆ្នាំហើយ នៅពេលដែលគាត់ចាប់ផ្តើមធ្វើការជាមួយ អោ អាន នៅដើមឆ្នាំ១៩៧៧[621]។ ទីពីរ សហមេធាវីវាយតម្លៃដោយមិនត្រឹមត្រូវពីការសួរសំណួររបស់អ្នកស៊ើបអង្កេត ហើយទោះជាក្នុងករណីណាក្តី អង្គបុរេជំនុំជម្រះបានយល់រួចហើយថា មិនមានការកើតឡើងនូវភាពមិនត្រឹមត្រូវក្នុងការស៊ើបអង្កេតឡើយ[622]។ ទីបី ការចោទប្រកាន់អំពីភស្តុតាងចចាមអារាមដែលមិនមានការគាំទ្ររបស់ ញ៉ែម ចេន នោះ តាមពិតទៅត្រូវបានគាំទ្រមួយផ្នែកដោយ អោ អាន ខ្លួនគាត់ផ្ទាល់[623]។ សម្រាប់សហព្រះរាជអាជ្ញាអន្តរជាតិ ការជំទាស់ផ្សេងទៀតរបស់សហមេធាវី មិនគួរឱ្យជឿជាក់បាន ហើយមិនបានបន្ទាប់តម្លៃនៃភស្តុតាងរបស់ ញ៉ែម ចេន ឬបង្ហាញអំពីកំហុសឆ្គងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិឡើយ[624]។

## ២. ការពិភាក្សា

៤០៥. ចៅក្រមអន្តរជាតិមិនជឿថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឆ្គងក្នុងការវាយតម្លៃភាពអាចជឿជាក់បានរបស់ ញ៉ែម ចេន ឡើយ ហើយអង្គជំនុំជម្រះយល់ឃើញថា ញ៉ែម ចេន ជាទូទៅគឺជាសាក្សីគួរឱ្យជឿជាក់បាន។ ចៅក្រមអន្តរជាតិកត់សម្គាល់ថា ញ៉ែម ចេន មានអាយុ ១៧ ឆ្នាំ នៅពេលដែលគាត់ត្រូវបានចាត់តាំងឱ្យទៅធ្វើការងារជាមួយ អោ អាន ក្នុងនាមជាកងការពារផ្ទាល់ខ្លួន នៅដើមឆ្នាំ

[619] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧០ និងកំណត់សម្គាល់ជើងទំព័រ ១៤៤-១៤៧។

[620] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧០ និងកំណត់សម្គាល់ជើងទំព័រ ១៤៨-១៤៩។

[621] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៤២ និងកំណត់សម្គាល់ជើងទំព័រ ៨៧។

[622] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៤២ និងកំណត់សម្គាល់ជើងទំព័រ ៨៨-៨៩។

[623] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៤២ និងកំណត់សម្គាល់ជើងទំព័រ ៩០-៩១។

[624] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៤២ និងកំណត់សម្គាល់ជើងទំព័រ ៩២។

១៩៧៧[625]។ លើសពីនេះទៀត ចៅក្រមអន្តរជាតិមិនជឿថា ការចងចាំរបស់គាត់ ទទួលរងផលប៉ះពាល់ដោយសំណួរណែនាំនោះដែរ[626]។ ភស្តុតាងបង្ហាញថា ញ៉ែម ចេន គឺជាកងការពារផ្ទាល់របស់ អោ អាន ដែលតាមគាត់គ្រប់ពេលវេលា នៅពេលដែលសហការីដទៃទៀត នៅក្នុងកងការពារ មានភារកិច្ចផ្សេងនៅតាមទីតាំងដទៃ ហើយមានតែ ញ៉ែម ចេន និងអ្នកបើកឡានម្នាក់ប៉ុណ្ណោះ ដែលត្រូវបានចាត់តាំងឱ្យអមដំណើរ អោ អាន[627]។ ផ្ទុយពីការលើកឡើងរបស់សហមេធាវីដែលថា ញ៉ែម ចេន មិនមានការយល់ដឹងបក្ស

---

[625] ញ៉ែម ចេន កើតនៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៥៩។ សូមមើល កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/855, ERN 01344682។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ឯកសារ D219/731, ERN 01218070-01218071 (ឆ.៦, ឆ.១២)។

[626] ទោះបីជាសហមេធាវីអះអាងថា អ្នកស៊ើបអង្កេតលើកឡើងដោយមិនត្រឹមត្រូវនៅក្នុងអំឡុងពេលនៃកិច្ចសម្ភាសន៍ជាមួយ ញ៉ែម ចេន នៅខែតុលា ឆ្នាំ២០១៦ ថា អោ អាន មានជាប់ពាក់ព័ន្ធជាមួយការប្រជុំមួយនៅវត្តអង្គតាមាក់ ក៏ដោយ ក៏ចៅក្រមអន្តរជាតិកត់សម្គាល់ថា ញ៉ែម ចេន បានពិភាក្សាកាលពីពេលមុនអំពីវត្តមានរបស់ អោ អាន នៅក្នុងការប្រជុំ នៅក្នុងកិច្ចសម្ភាសន៍លើកមុនរបស់គាត់ នៅខែមីនា ឆ្នាំ២០១៦។ សូមមើល កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ឯកសារ D219/731, ERN 01218078 (ឆ.៨៧, ឆ. ៨៨)។

[627] សូមមើល កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ឯកសារ D219/731, ERN 01218070 (ឆ.៤, ឆ.៥) 01218071 (ឆ.១៧) 01218072 (ឆ.២៨, ឆ.២៩)។ សូមមើលផងដែរ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផៃ សល់ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦ ឯកសារ D219/759, ERN 01242599 (ឆ.២១)។ ទោះក្នុងករណីណាក៏ដោយ ចៅក្រមអន្តរជាតិ រកពុំឃើញភាពមិនស៊ីសង្វាក់គ្នាជាក់ស្តែងណាមួយនៅទីនេះ ដែលតម្រូវឱ្យមានការពន្យល់ពីអ្នកវិនិច្ឆ័យអង្គហេតុឡើយ។

មុយនីស្ដកម្ពុជា[628] ភស្តុតាងជាច្រើនរបស់ ញ៉ែម ចេន ផ្អែកលើពាក្យចចាមអារាមបែបស្មាន[629] ឬថាចម្លើយរបស់ ញ៉ែម ចេន មិនមានការគាំទ្រ ឬមិនស្របគ្នាជាមួយចម្លើយរបស់អ្នកដទៃនោះ[630] ចៅក្រមអន្តរ

---

[628] ចៅក្រមអន្តរជាតិសង្កេតឃើញថា ញ៉ែម ចេន បានបង្ហាញថា គាត់មានការចងចាំគួរឱ្យអស្ចារ្យពីបុគ្គល និងតួនាទីរបស់ពួកគេនៅក្នុងឋានានុក្រមកម្ពុជាប្រជាធិបតេយ្យ ថាតើពួកគេបច្ចុប្បន្ននៅរស់រានមានជីវិតឬទេ ហើយបើពួកគេនៅរស់រាន់មានជីវិត ថាតើពួកគេរស់នៅកន្លែងណា។ សូមមើល កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ឯកសារ D219/731, ERN 01218072 (ឆ.២១-ឆ.២៥) 01218074-01218076 (ឆ.៥០-ឆ.៦២) (រម្លឹកពីឈ្មោះ និងសារតាររបស់អ្នកស្ថិតនៅក្នុងសង្វាក់នៃការបញ្ជា ដែលទទួលខុសត្រូវលើការអនុញ្ញាតឱ្យសម្លាប់មនុស្សនៅមន្ទីរសន្តិសុខមិត្តសុប (គរ) ក៏ដូចជាខ្លឹមសារនៃការប្រជុំពាក់ព័ន្ធនឹងមន្ទីរសន្តិសុខនេះផងដែរ) 01218078-01218079 (ឆ.៩៣-ឆ.៩៦) 01218080 (ឆ.១០៧-ឆ.១១០) 01218081 (ឆ.១១៤-ឆ.១១៧)។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ឯកសារ D219/732, ERN 01218088 (ឆ.៥៤-ឆ.៥៨)។

លើសពីនេះទៀត សក្ខីកម្មរបស់ ញ៉ែម ចេន ពន្យល់ថា គាត់បានទៅប្រជុំគណៈភូមិភាគនៅកំពង់ចាមជាមួយ អោ អាន ចំនួន ៤ ដង និងបានស្ដាប់ឮ អោ អាន, កែ ពក និងអ្នកផ្សេងទៀត ពិភាក្សាគ្នាអំពីការចាប់ខ្លួនខ្មាំង ក្នុងចំណោមផែនការផ្សេងទៀត (កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/855, ERN 01344684-01344685 (ឆ.៥-ឆ.៨) និង 01344686 (ឆ.១៥-ឆ.១៨)) ដែលបញ្ជាក់ពីការដឹងឮរបស់គាត់អំពីបញ្ហាទាំងនេះ។ ជួនកាល ញ៉ែម ចេន ឈរនៅជិត អោ អាន នៅក្នុងការប្រជុំ និងអាចស្ដាប់ឮការពិភាក្សា (កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ឯកសារ D219/731, ERN 01218073 (ឆ.៣៤)) ទោះបី ញ៉ែម ចេន ទទួលស្គាល់ថា បើជាការប្រជុំ “សម្លាត់ខ្មាំង” អោ អាន មិនយកគាត់ទៅជាមួយទេ (កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/855, ERN 01344684 (ឆ.៦))។ ញ៉ែម ចេន ក៏បានអមដំណើរ អោ អាន ទៅប្រជុំនៅមន្ទីរ គរ និងវត្តបាធាយផងដែរ (កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ឯកសារ D219/731, ERN 01218073 (ឆ.៣៣)) និងបានឃើញដោយផ្ទាល់ភ្នែកនូវការសម្លាប់អ្នកទោសនៅវត្តបាធាយ (កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/731, ERN 01218076 (ឆ.៦៧, ឆ.៦៨))។

[629] ទោះបីជាសហមេធាវីតវ៉ាជំទាស់ទៅនឹងភស្តុតាងជាពាក្យចចាមអារ៉ាមរបស់ ញ៉ែម ចេន ទាក់ទិននឹងការដែល អោ អាន ទទួលបញ្ជាឱ្យសម្លាប់ពីថ្នាក់ភូមិភាគ ក៏ដោយ ក៏សហមេធាវីមិនបានបង្ហាញថា វាមិនសមហេតុផលដែលត្រូវផ្អែកលើភស្តុតាងរបស់ ញ៉ែម ចេន ពាក់ព័ន្ធនឹងបញ្ហានេះទេ ជាពិសេសស ដោយពិចារណាទៅលើការពន្យល់របស់ ញ៉ែម ចេន ថា គាត់បានដឹងពីខ្លឹមសារសំបុត្រពីនីរសាររបស់ កែ ពក។ សូមមើល កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/855, ERN 01344694 (ឆ.៧៩-ឆ.៨៦)។

[630] ចៅក្រមអន្តរជាតិយល់ឃើញថា ចម្លើយជាច្រើនរបស់ ញ៉ែម ចេន ដែលរងការជំទាស់ មានភាពស៊ីសង្វាក់គ្នាល្អជាមួយភស្តុតាងផ្សេងទៀត។ សូមមើល ឧទាហរណ៍ ដីកាដំណោះស្រាយ (ដីការបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៧៣ កំណត់សម្គាល់ជើងទំព័រ ៧១២ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិផ្អែកលើកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/855, ERN 01344686 (ឆ.១៥-ឆ.១៩)) ដែលពណ៌នាពីការចូលរួមប្រជុំជាមួយ អោ អាន ដែលនៅពេលនោះ កែ ពក បានប្រកាសពីផែនការ “ចាប់បង្អត់បាយ” ដោយការកាត់បន្ថយរបបអាហារ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានយោងទៅចម្លើយរបស់សាក្សីផ្សេងទៀតដែលមានភាពស៊ីសង្វាក់គ្នា ដែលរៀបរាប់ពីការកាត់បន្ថយរបប

ជាតិយល់ថា មិនមែនជារឿងមិនសមហេតុផលទេ ដែលអ្នកវិនិច្ឆ័យអង្គហេតុ ដែលមានហេតុផលណាម្នាក់ ទទួលយកភស្តុតាងដ៏លម្អិតរបស់ ញ៉ែម ចេន ទាក់ទងនឹងបញ្ហាយុត្តាធិការបុគ្គល ថាមានតម្លៃផ្នែកភស្តុតាង និងអាចជឿជាក់បាន។

## ខ. ជុំ វង្ស (ខ៉ូវ)

### *១. សារណា*

៤០៦. សហមេធាវីលើកឡើងថា ជុំ វង្ស មិនមានភាពអាចជឿជាក់បាន ចំពោះបញ្ហាទាក់ទងនឹងតួនាទី និងការទទួលខុសត្រូវរបស់ អោ អាន ហើយថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឆ្គងដែលពឹងផ្អែកទៅលើភស្តុតាងរបស់ ជុំ វង្ស "ដោយពុំមានការពន្យល់" សម្រាប់អង្គហេតុសំខាន់ៗ គាំទ្រការសម្រេចរបស់គាត់លើយុត្តាធិការបុគ្គល[631]។ ជាពិសេស សហមេធាវីបានអះអាងថាភស្តុតាងរបស់ ជុំ វង្ស មិនអាចជឿជាក់បានទេ ព្រោះ (១) ក្នុងនាមជាប្រធានមន្ទីរសន្តិសុខមិត្តសុប គាត់មានមូលហេតុក្នុងការកុហកដើម្បីគេចចេញពីការទទួលខុសត្រូវជាបុគ្គល[632] (២) អ្នកស៊ើបអង្កេត "ផ្តល់" ព័ត៌មានដោះបន្ទុកដល់ ជុំ វង្ស ដោយសួរគាត់សំណួរបិទ និងអនុវត្ត "វិធីគួរឲ្យសង្ស័យដទៃទៀត"[633]។ បើតាមសហមេធាវី សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអនុវត្ត "វិធីមិនសមហេតុផល" ចំពោះសាក្សីរូបនេះ ដោយសារតែ ជុំ វង្ស ត្រូវបានរកឃើញថា មិនអាចជឿជាក់បាន ចំពោះបញ្ហាមួយចំនួន ប៉ុន្តែ ចម្លើយរបស់គាត់ដែលឆ្លើយដាក់ អោ អាន (ប៉ុន្តែមិនមែនចម្លើយដោះបន្ទុក) នៅតែត្រូវបានពឹងផ្អែកទៅលើ[634]។

---

អាហារ ដើម្បីគាំទ្រដល់ការសន្និដ្ឋានថា លក្ខខណ្ឌធ្វើការនៅការដ្ឋានការងារកាន់តែលំបាកខ្លាំងឡើងៗ ក្រោយការមកដល់របស់ អោ អាន និងកម្មាភិបាលភូមិភាគនិរតីនៅភូមិភាគកណ្តាល ឧទាហរណ៍ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជាម ៣៧ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D219/293, ERN 01095221 (ឆ.៧) ("ពួកនិរតីគ្រប់គ្រង មានសភាពខ្លាំង។ ខ្ញុំចង់មានន័យថា ពួកគេប្រើមនុស្សមិនឲ្យឈប់សម្រាក មិនឲ្យហូបឆ្អែត និងប្រើវិន័យតឹងរ៉ឹងណាស់")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D219/504, ERN 01146391 (ឆ.១២៣) ("តាអួន ជាអ្នកប្រាប់ខ្ញុំ ឲ្យផ្តល់អាហារពីរពេលបែបនេះ ដោយសារតែយើងនៅក្រ ហើយត្រូវសន្សំសំចៃស្បៀង")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុំ សែ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D117/52, ERN 00990832 (ឆ.៦) ("មានការកែប្រែមួយចំនួន ដូចជា គេកាន់តែបន្ថយតិចទៅៗ ហើយជីវភាពរស់នៅកាន់តែលំបាកឡើងៗ។ ប្រជាជនមួយចំនួនធ្លាក់ខ្លួនឈឺដោយសារខ្វះរបបអាហារ")។

[631] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧១, ៧៣។

[632] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧២ និងកំណត់សម្គាល់ជើងទំព័រ ១៥១។

[633] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧២ និងកំណត់សម្គាល់ជើងទំព័រ ១៥២។

[634] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧៣ និងកំណត់សម្គាល់ជើងទំព័រ ១៥៣-១៥៥។

៤០៧. សហព្រះរាជអាជ្ញាអន្តរជាតិបានឆ្លើយតបថា ផ្ទុយពីការអះអាងរបស់សហមេធាវី សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពន្យល់យ៉ាងច្បាស់អំពីចំណុចណាមួយនៃភស្តុតាងរបស់ ជុំ វង្ស ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចថា មិនអាចជឿជាក់បាន និងអំពីមូលហេតុដែលគាត់ទទួលយកភស្តុតាងដទៃផ្សេងទៀត[635]។ នេះមិនមែនជាកំហុសឆ្គងនោះទេ បើទោះបីជាការពន្យល់នេះមិនត្រូវបានបញ្ជាក់នៅគ្រប់ពេលដែលដកស្រង់យកភស្តុតាងរបស់ ជុំ វង្ស មកនោះក្តី សហចៅក្រមស៊ើបអង្កេតអន្តរជាតិប្រកាន់ខ្ជាប់ទៅតាមទស្សនៈដែលបានបញ្ជាក់ទាំងអស់នេះ[636]។ សម្រាប់សហព្រះរាជអាជ្ញាអន្តរជាតិ ការសម្រេចដែលរងការជំទាស់ដទៃទៀត មានការគាំទ្រទាំងស្រុង ឬដោយផ្នែក[637]។ ហេតុដូច្នេះ សហមេធាវីមិនបានបង្ហាញថា "ការវាយតម្លៃដោយប្រុងប្រយ័ត្ន" របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើភស្តុតាងរបស់ ជុំ វង្ស មិនសមហេតុផលនោះទេ[638]។

## ២. ការពិភាក្សា

៤០៨. ចៅក្រមអន្តរជាតិមិនជឿថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឆ្គងក្នុងការផ្តល់ សំអាងហេតុដែលមិនគ្រប់គ្រាន់ ឬមិនសមហេតុផលឡើយ នៅក្នុងការវាយតម្លៃរបស់គាត់ទៅលើភាពអាចជឿជាក់បានរបស់ ជុំ វង្ស។ ចៅក្រមអន្តរជាតិកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពន្យល់ថា ចម្លើយរបស់ ជុំ វង្ស ពាក់ព័ន្ធនឹងតួនាទីរបស់គាត់នៅមន្ទីរសន្តិសុខមិត្តសុប មិនអាចជឿជាក់បាន ដោយសារតែមូលហេតុរបស់គាត់ក្នុងការបន្ថយការទទួលខុសត្រូវ[639]។ លើសពីនេះទៀត ចំពោះចម្លើយរបស់ ជុំ

[635] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៤៣ និង កំណត់សម្គាល់ជើងទំព័រ ៩៤។

[636] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៤៣ និង កំណត់សម្គាល់ជើងទំព័រ ៩៥។

[637] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៤៣ និង កំណត់សម្គាល់ជើងទំព័រ ៩៦។

[638] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៤៣។

[639] ចៅក្រមអន្តរជាតិ កត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានផ្តល់សំអាងហេតុច្បាស់លាស់អំពីថាតើហេតុអ្វីបានជាចម្លើយរបស់ ជុំ វង្ស អំពីនឹងតំណែង និងភារកិច្ចរបស់គាត់នៅមន្ទីរសន្តិសុខមិត្តសុប មិនអាចជឿជាក់បាន។ សូមមើល ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៣៩០ ("ការអះអាងរបស់ ង៉ូវ ថាមិនមែនជាប្រធានមន្ទីរសន្តិសុខមិត្តសុប មិនអាចជឿជាក់បានទេ យោងតាមទំហំ និងភាពស៊ីសង្វាក់គ្នានៃសក្ខីកម្មជំទាស់ ការរៀបរាប់ផ្ទាល់របស់គាត់ពីភារកិច្ចពិតប្រាកដរបស់គាត់ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ និងចេតនារបស់គាត់ ដែលទំនងជាចង់សម្រាលទំនួលខុសត្រូវរបស់គាត់ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅទីនោះ")។ សូមមើលផងដែរ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ

វង្ស ទាក់ទងនឹងបញ្ហាដទៃផ្សេងទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកទៅលើ ជុំ វង្ស ទាក់ទងជាមួយនឹងភស្តុតាងគាំទ្រ សម្រាប់សាក្សីដទៃផ្សេងទៀត[640]។

---

D360) កថាខណ្ឌ ៩០៩ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា ចម្លើយរបស់ ជុំ វង្ស ថាគាត់មិនដឹងថាគេប្រើវិធី ឬទារុណកម្មអ្វីខ្លះពេលសួរចម្លើយនោះ មិនអាចជឿជាក់បានទេ៖ "នេះមិនអាចជឿជាក់បានឡើយ ពីព្រោះក្នុងនាមជាប្រធានមន្ទីរសន្តិសុខ គាត់ចាំបាច់ត្រូវតែដឹងព័ត៌មាននេះ")។ សូមមើលផងដែរ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៩១១ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិពន្យល់ពីមូលហេតុដែលខ្លួនយល់ឃើញថាភស្តុតាងរបស់ ជុំ វង្ស ពាក់ព័ន្ធនឹងទស្សនកិច្ចរបស់ អោ អាន នៅមន្ទីរសន្តិសុខមិត្តសុប មិនអាចជឿជាក់បាន៖ "[...] សម្តីរបស់ ង៉ូវ អំពីការប្រជុំជាមួយ អោ អាន មានភាពមិនអាចជឿជាក់បាន ពីព្រោះគាត់អាចកំពុងប៉ុនប៉ងផ្តាច់ខ្លួនពីការជាប់ពាក់ព័ន្ធរបស់លេខាតំបន់ ក្នុងប្រតិបត្តិការសម្លាប់នៅទីតាំងនេះ ដើម្បីបន្ថយការទទួលខុសត្រូវរបស់ខ្លួនជាអតិបរមា")។

[640] សូមមើល ឧទាហរណ៍ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៧២ កំណត់សម្គាល់ជើងទំព័រ ៧០៦ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិយោងនៅក្នុងកំណត់សម្គាល់ជើងទំព័រមុន ទៅចម្លើយរបស់សាក្សីបីនាក់ដែលមានភាពស៊ីសង្វាក់គ្នា ដែលរៀបរាប់ថា ចាំបាច់ត្រូវមានលិខិតអនុញ្ញាតឱ្យធ្វើដំណើរនៅក្នុងតំបន់។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏បានដកស្រង់ផងដែរនៅក្នុងកំណត់សម្គាល់ជើងទំព័របន្ទាប់ នូវភស្តុតាងផ្សេងទៀតដែលមានផ្នែកខ្លះគាំទ្រដល់ចម្លើយរបស់ ជុំ វង្ស អំពីការតម្រូវឱ្យមានការអនុញ្ញាតពី អោ អាន ដើម្បីដឹកអ្នកទោសពីតំបន់មួយទៅតំបន់មួយ។ សូមមើល ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ១០៧៨ ឯកសារ D6.1.764, ERN 00001092 (ពណ៌នាអំពីហេតុការណ៍មួយដែលកើតឡើងនៅខែមីនា ឆ្នាំ១៩៧៨ នៅពេលទាហានតំបន់ ៤១ ឃាត់ខ្លួនយុទ្ធជនពីរនាក់ដែលធ្វើដំណើរឆ្លងកាត់តំបន់ ៤១ ដោយគ្មានលិខិតអនុញ្ញាតឱ្យធ្វើដំណើរ និងស្នើសុំឱ្យគណៈ ៨៧០ "ឱ្យដំណឹង មកទាក់ទងសមមិត្តអាន" ដើម្បីទទួលយុទ្ធជនទាំងនេះវិញ)។ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុស ឬមិនបានរំលោភលើឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការពិចារណាលើភស្តុតាងរបស់ ជុំ វង្ស ទាក់ទងនឹងការធ្វើដំណើរពីតំបន់មួយទៅតំបន់មួយថាអាចជឿជាក់បាន)។ *សូមមើលផងដែរ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៣៩៥ កំណត់សម្គាល់ជើងទំព័រ ១១៧១-១១៧៧ (ចៅក្រមអន្តរជាតិ កត់សម្គាល់ថា ភស្តុតាងរបស់ ជុំ វង្ស ទាក់ទងនឹងប្រព័ន្ធនៃការរាយការណ៍រវាងមិត្តសុប និង អោ អាន មានភាពស៊ីសង្វាក់គ្នាខ្លះជាមួយភស្តុតាងរបស់ ញ៉ែន ចេន និង សូ សារ៉េន។ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/855, ERN 01344693 (ឆ.៧៥-ឆ.៧៦) ("ជួនកាល គេឱ្យខាងសន្តិសុខ កាលណា គេមិនទុកចិត្តសន្តិសុខ គេឱ្យខ្ញុំទៅ ជូនណាឯកសារវាងល្មមៗ គេឱ្យនីរសារគេយកយក [...] ចេញពី ង៉ូវ មកប្រធានសន្តិសុខ")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សូ សារ៉េន ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ឯកសារ D219/800, ERN 01308053-01308054 (ឆ.១៨២, ឆ. ១៨៤-ឆ.១៨៦) ("អ្នកប្រើគឺ បងអូន ទេ ដែលប្រើឱ្យយកសំបុត្រទៅស្រុកផ្សេងៗ ហើយនិងយកទៅឱ្យ ង៉ូវ នៅមន្ទីរសន្តិសុខនោះ [...] យូរៗ បងអូនទៅម្តងដែរ [...] គាត់ទៅដល់ គាត់អង្គុយសំណេះសំណាលជាមួយ ង៉ូវ ទៅ")។ ចៅក្រមអន្តរជាតិយល់ឃើញថា ការផ្អែកទៅលើចម្លើយរបស់ ជុំ វង្ស ដែលទទួលស្គាល់ការប្រព្រឹត្តិប្រឆាំងនឹងផលប្រយោជន៍ផ្ទាល់ខ្លួនរបស់គាត់ដើម្បីសម្រាលការទទួលខុសត្រូវ ពុំមានភាពផ្ទុយគ្នាជាមួយនឹងសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពាក់ព័ន្ធនឹងភាពមិនអាចជឿជាក់បាននៃចម្លើយរបស់ ជុំ វង្ស ដែលបន្ថយភារកិច្ចរបស់គាត់នៅមន្ទីរសន្តិសុខមិត្តសុបទេ)។

៤០៩. ចៅក្រមអន្តរជាតិមិនយល់ថាជាកំហុស[641] ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិពឹងផ្អែកលើភស្តុតាងរបស់ ជុំ វង្ស ពាក់ព័ន្ធនឹង តួនាទីរបស់ អោ អាន នៅក្នុងការបោសសម្អាតខ្មាំង និងអតីតកម្មាភិបាល សិទ្ធិអំណាចរបស់គាត់លើការធ្វើដំណើរ សេដ្ឋកិច្ច និងកងទ័ពនៅក្នុងតំបន់៤១ ការគ្រប់គ្រងរបស់ អោ អាន ទៅលើបញ្ហាសន្តិសុខតំបន់ និងមន្ទីរ ប្រព័ន្ធរាយការណ៍នៅក្នុងតំបន់ ៤១ និងទៅកម្រិតភូមិភាគ និងការចេញបញ្ជាឱ្យចាប់ខ្លួន[642]។ នៅពេលវាយតម្លៃទៅលើភស្តុតាងជារួម ចៅក្រមអន្តរជាតិយល់ឃើញប្រហែលគ្នាថា ភស្តុតាងរបស់ ជុំ វង្ស ពាក់ព័ន្ធនឹងបញ្ហាអស់ទាំងនេះ ជាទូទៅ អាចជឿជាក់បាន។

៤១០. ជាចុងក្រោយ ចំពោះការអះអាងដែលថា អ្នកស៊ើបអង្កេត "ផ្តល់" ព័ត៌មានដាក់បន្ទុកទៅឱ្យ ជុំ វង្ស នោះ[643] អង្គជំនុំជម្រះច្រានចោលទាំងស្រុងលើការអះអាងនេះ។ ដោយផ្អែកទៅលើការដែលសហមេធាវីមិនបានបង្ហាញថា មិនមានអ្នកវិនិច្ឆ័យអង្គហេតុ ដែលមានហេតុផលណាម្នាក់ អាចទទួលយកភស្តុតាងរបស់ ជុំ វង្ស បាន ជាពិសេស នៅពេលមានការគាំទ្រនោះ ចៅក្រមអន្តរជាតិសម្រេចថា មិនមានកំហុស

---

[641] ដូចដែលកត់សម្គាល់នៅខាងដើម អ្នកវិនិច្ឆ័យទៅលើអង្គហេតុ អាច "ទទួលយកសក្ខីកម្មរបស់សាក្សីមួយផ្នែក ហើយបដិសេធផ្នែកដទៃទៀត"។ រឿងក្តី *Popović និងអ្នកផ្សេងទៀត* សាលដីកា (តុលាការ ICTY) កថាខណ្ឌ ១៣២។ សូមមើលផងដែរ សាលដីកាសំណុំរឿង ០០២/០១ (ឯកសារ F36) កថាខណ្ឌ ៣៥៧ ("នេះជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការវាយតម្លៃលើភាពអាចជឿទុកចិត្តបានចំពោះផ្នែកដាច់ដោយឡែកផ្សេងទៀតនៃសក្ខីកម្មរបស់បុគ្គលណាម្នាក់ ដោយពុំចាំបាច់បង្ហាញលម្អិតពីមូលហេតុដែលខ្លួនទទួលយកផ្នែកខ្លះ ហើយបដិសេធចោលផ្នែកដទៃទៀតនោះឡើយ")។

[642] សូមមើលឧទាហរណ៍ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២១៤ កំណត់សម្គាល់ជើងទំព័រ ៤៨៩ (បន្ថែមលើភស្តុតាងរបស់ ជុំ វង្ស សហចៅក្រមស៊ើបអង្កេតអន្តរជាតិយោងទៅកំណត់ហេតុស្តាប់ចម្លើយជាច្រើនដើម្បីគាំទ្រដល់ការសន្និដ្ឋានថា ពេលកម្មាភិបាលភូមិភាគនិរតីមកដល់ ការបោសសម្អាតកម្មាភិបាលកំពុងកាន់តំណែងត្រូវបានធ្វើឡើងនៅគ្រប់លំដាប់ថ្នាក់ទាំងអស់។ សូមមើល កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច ចំរើន ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ D219/435, ERN 01124169 (ឆ.៦៥-ឆ.៦៧) ("ចំពោះកម្មាភិបាលមូលដ្ឋានដែលជាប្រធានមុនៗត្រូវបានគេដកអស់បាត់ [...] ប្រធានមុនៗខ្លះត្រូវបាត់ខ្លួនអស់") និង 01124175 (ឆ.១៤០)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេញ វ៉ា ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ឯកសារ D219/226, ERN 01075658 (ឆ.១៣) ("បន្ទាប់ពីពួកកម្មាភិបាលនិរតីមកដល់ អតីតកម្មាភិបាលចាស់ៗច្រើននាក់ដែលខ្ញុំរាប់មិនអស់ ត្រូវបានគេបោសសម្អាត។ អ្នកទាំងនោះសុទ្ធតែជាកម្មាភិបាលប្រធានអង្គភាព")។

[643] សូមមើល ខាងក្រោម មូលដ្ឋានទី ៥(iii)។ ចម្លើយដែលរងការជំទាស់ត្រូវបានសហមេធាវីតវ៉ាជំទាស់កាលពីពេលមុន។ សូមមើល ឧបសម្ព័ន្ធ ខ នៃសំណើសុំធ្វើមោឃភាពកំណត់ហេតុស្តាប់ចម្លើយ ឯកសារ D338/1/2.3, ERN (EN) 01388934 លេខរឿងទី ៩។ ឧបសម្ព័ន្ធ ឃ នៃសំណើសុំធ្វើមោឃភាពកំណត់ហេតុស្តាប់ចម្លើយ ឯកសារ D338/1/2.5, ERN (EN) 01364471 លេខរឿងទី៤។ ពេលពិនិត្យមើលខ្លឹមសារនៃកិច្ចសម្ភាសន៍ ចៅក្រមអន្តរជាតិយល់ឃើញថា សហមេធាវីបានយោងទៅសម្រង់នៃកំណត់ហេតុស្តាប់ចម្លើយដែលផ្តាច់ចេញពីបរិបទ ហើយដូច្នេះ យល់ឃើញថា តម្លៃជាភស្តុតាងនៃភស្តុតាងនោះពុំត្រូវបានប៉ះពាល់ទេ។

01634966



ឆ្គងឡើយ ក្នុងការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ព្រមទាំងការពឹងផ្អែកទៅលើភស្តុតាងរបស់ ជុំ វង្ស។

## ច. ពេញ វ៉ា និង ញ៉ឹម កុល

### ១. សារណា

៤១១. សហមេធាវីបានអះអាងថា ភស្តុតាងរបស់ ពេញ វ៉ា និងញ៉ឹម កុល ជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនអាចជឿជាក់បានទេ ហើយថា ការពឹងផ្អែករបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើពួកគេ "ដោយគ្មានការពន្យល់" គឺជាកំហុសឆ្គង[644]។ ជាពិសេស សហមេធាវីជំទាស់ថា (១) ក្នុងនាមជាអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ពេញ វ៉ា និង ញ៉ឹម កុល ការស្តាប់ចម្លើយរបស់ពួកគេ មិនមានការធានាផ្នែកនីតិវិធីដូចគ្នា នឹងការស្តាប់ចម្លើយសាក្សីឡើយ[645] ហើយ (២) ពួកគេផ្តល់ចម្លើយមិនស្របគ្នា[646]។ បើតាមសហមេធាវី ដោយពិចារណាថា ដើមបណ្តឹងរដ្ឋប្បវេណីមានផលប្រយោជន៍នៅក្នុងសំណុំរឿង ហេតុដូច្នេះ ភស្តុតាងរបស់ពួកគេពាក់ព័ន្ធនឹងបញ្ហាយុត្តាធិការបុគ្គល មិនអាចជឿជាក់បានឡើយ[647]។

៤១២. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា សហមេធាវីមិនបានអនុវត្តកាតព្វកិច្ចក្នុងការបង្ហាញថា ការពឹងផ្អែកទៅលើភស្តុតាងរបស់ ពេញ វ៉ា និង ញ៉ឹម កុល មិនសមហេតុផលនោះ[648]។ ជាដំបូង ការជំទាស់របស់សហមេធាវី ទាក់ទងនឹងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគេ ផ្ទុយជាមួយនឹងយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង[649]។ ទីពីរ សហមេធាវីមានកាតព្វកិច្ចក្នុងការបង្ហាញពីភាពមិនស៊ីសង្វាក់គ្នាដែលបានលើកឡើង ហើយប្រសិនបើត្រូវបង្ហាញ មិនមានអ្នកវិនិច្ឆ័យអង្គហេតុ ដែលមានហេតុផលណា

---

[644] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧៤-៧៥។

[645] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧៥ និងកំណត់សម្គាល់ជើងទំព័រ ១៥៧-១៦១។

[646] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧៥ និងកំណត់សម្គាល់ជើងទំព័រ ១៦២-១៦៣។

[647] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧៥។

[648] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៤៥-៤៦។

[649] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៤៤ និងកំណត់សម្គាល់ជើងទំព័រ ៩៨ យោងទៅ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) កថាខណ្ឌ ៥១-៥៦។

ម្នាក់ អាចចាត់ទុកថាភស្តុតាងរបស់ពួកគេអាចជឿជាក់បាន អាស្រ័យដោយសារភាពមិនស៊ីសង្វាក់គ្នាបែបនេះទេ[650]។ សម្រាប់សហព្រះរាជអាជ្ញាអន្តរជាតិ ការជំទាស់របស់សហមេធាវី ទាក់ទងនឹងភាពមិនស៊ីចង្វាក់គ្នានៅក្នុងចម្លើយរបស់ ពេញ វ៉ា និង ញឹម កុល មិនមានមូលដ្ឋានឡើយ ហើយសហមេធាវីមិនបានបង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឆ្គងក្នុងការពឹងផ្អែកទៅលើភស្តុតាងបែបនេះ[651]។

## ២. ការពិភាក្សា

៤១៣. ចៅក្រមអន្តរជាតិយល់ថា មិនមានកំហុសឆ្គងឡើយដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិពឹងផ្អែកទៅលើភស្តុតាងរបស់ ពេញ វ៉ា និង ញឹម កុល។ ចៅក្រមអន្តរជាតិរម្លឹកថា "ភស្តុតាងទាំងអស់សុទ្ធតែអាចទទួលយកបាន ហើយជាទូទៅ ទទួលបាននូវសច្ចធារណ៍នៃភាពអាចជឿជាក់បាន តាមផ្លូវច្បាប់ដូចៗគ្នា" និងថា "ភាពអាចជឿជាក់បាននៃភស្តុតាងរបស់ [ដើមបណ្តឹងរដ្ឋប្បវេណី] ត្រូវបានវាយតម្លៃទៅតាមករណីនីមួយៗ"[652]។ ចៅក្រមអន្តរជាតិយល់ថា ឋានៈរបស់ ពេញ វ៉ា និង ញឹម កុល ជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនបានធ្វើឱ្យភស្តុតាងរបស់ពួកគាត់ មានភាពអាចជឿជាក់បានតិចជាងឡើយ ហើយចៅក្រមអន្តរជាតិយល់ទៀតថា ការចោទប្រកាន់របស់សហមេធាវី អំពីភាពមិនស៊ីសង្វាក់គ្នាមិនមានមូលដ្ឋាននោះឡើយ។ អង្គជំនុំជម្រះកត់សម្គាល់ថា ពេញ វ៉ា បានពិភាក្សាដោយស៊ីសង្វាក់គ្នាអំពីការរៀបចំពិធីរៀបអាពាហ៍ពិពាហ៍ពីរ នៅក្នុងតំបន់៤១[653]។ លើសពីនេះទៀត ចៅក្រមអន្តរជាតិមិនជឿថា ញឹម កុល និយាយប្រឆាំងខ្លួនឯងឡើយ ពាក់ព័ន្ធនឹងការជួបប្រជុំជាមួយ អោ អាន ដូចដែលបានចោទប្រកាន់

[650] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៤៤។

[651] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៤៥-៤៦។

[652] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) កថាខណ្ឌ ៥១, ៥៥។

[653] ចៅក្រមអន្តរជាតិកត់សម្គាល់ថា នៅក្នុងចម្លើយដែលបានយោង "ឈ្មោះមិត្តម៉េង មិនមែន អោ អាន ទេ ដែលជាអ្នករៀបការឱ្យ" ពេញ វ៉ា បានបំភ្លឺអំពីព័ត៌មានលម្អិតទាក់ទិននឹងការរៀបការរបស់គាត់ នៅដើមឆ្នាំ១៩៧៦ ដូចបានបង្ហាញនៅក្នុងសំណួរមុនៗ។ សូមមើល កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេញ វ៉ា ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ឯកសារ D219/226, ERN 01075663-01075664 (ឆ.២៩-ឆ.៣២, ឆ.៣៤)។ ការសង្កេតរបស់ ពេញ វ៉ា នាពេលក្រោយមក ថា "មិត្តអួន ឬមិត្តអាន បានរៀបការ សុត និង ត័ន" សំដៅដល់ការរៀបការមួយផ្សេងទៀតក្រោយការមកដល់របស់កម្មាភិបាលភូមិភាគនិរតី។ សូមមើល កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេញ វ៉ា ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៥ ឯកសារ D219/289, ERN 01091442 (ឆ.៨, ឆ.១០)។ នៅត្រង់នេះ ចៅក្រមអន្តរជាតិរកពុំឃើញមានភាពមិនស៊ីសង្វាក់គ្នាជាក់ស្តែងនៅក្នុងភស្តុតាងរបស់ ពេញ វ៉ា ពាក់ព័ន្ធនឹងការរៀបចំការរៀបការដែលតម្រូវឱ្យមានការពន្យល់ពីអ្នកវិនិច្ឆ័យទៅលើអង្គហេតុទេ។

ឡើងនោះទេ[654]។ ផ្ទុយពីការអះអាងរបស់សហមេធាវី ចៅក្រមអន្តរជាតិយល់ថា ភស្តុតាងរបស់ ពេញ វ៉ា និង ញឹម កុល ទាក់ទងនឹងយុត្តាធិការបុគ្គល អាចជឿជាក់បានជាទូទៅ។

## មូលដ្ឋានទី ៥(iii). ការចោទប្រកាន់ថាសំអាងទៅលើភស្តុតាងដែលប្រឡូកប្រឡាក់

### ១. សារណា

៤១៤. នៅក្រោមមូលដ្ឋានទី ៥ (iii) សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបាន សំអាងទៅលើភស្តុតាង "ដែលប្រឡូកប្រឡាក់" ដោយមិនគិតពីវិធីសាស្ត្រគួរឱ្យសង្ស័យ និងកាលៈទេសៈ ផ្សេងៗក្នុងការយកចម្លើយរបស់អ្នកស៊ើបអង្កេត[655] ដែលរួមមាន (១) ផ្តល់ព័ត៌មានដាក់បន្ទុកដល់សាក្សី និង អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[656] (២) ធ្វើការសន្ទនាក្រៅផ្លូវការមុនពេលសួរ ចម្លើយយកកំណត់ហេតុស្តាប់ចម្លើយ[657] និង (៣) ខកខានមិនបានសួរសាក្សី ឬអ្នកដាក់ពាក្យសុំតាំងខ្លួនជា

---

[654] ភាពផ្ទុយគ្នាដែលត្រូវបានចោទប្រកាន់នៅក្នុងចម្លើយរបស់ ញឹម កុល ថា គាត់ "មិនដឹងថា តាអានហ្នឹង មុខអាម៉េចផងដែរទេ" និង "ឃើញម្តង ពេលគាត់ជិះអាហ្សីបម៉ូស័រមក" ពុំមានមូលដ្ឋានត្រឹមត្រូវទេ ពីព្រោះនៅក្នុងចម្លើយបន្តបន្ទាប់ទៀតរបស់គាត់ ញឹម កុល បញ្ជាក់ថា ទោះបីជាគាត់បានឃើញ អោ អាន ចេញពីឡាន តែគាត់មិនបានមើលមុខរបស់ អោ អាន ទេ។ សូមមើល កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញឹម កុល ឯកសារ D219/422.4 ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២ ERN 01121137 (ពន្យល់ថា "ពេលនោះ យើងអត់ប៉ានមើលមុខផង [...] សម្រាប់ខ្ញុំ ខ្ញុំមិនបានជួបគាត់ដោយផ្ទាល់ទេ។ ប៉ុន្តែ ខ្ញុំបានឃើញគាត់")។ ទោះក្នុងករណីណាក៏ដោយ ចៅក្រមអន្តរជាតិយល់ឃើញថា ភាពមិនស៊ីសង្វាក់គ្នានៅក្នុងចម្លើយរបស់ ញឹម កុល មិនរារាំងដល់ អ្នកវិនិច្ឆ័យអង្គហេតុដែលមានហេតុផល ក្នុងការផ្អែកលើភស្តុតាងរបស់គាត់នោះទេ។

[655] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧៦។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 01626065-01626066 ទំព័រ ១១ បន្ទាត់ ២៥ - ទំព័រ ១២ បន្ទាត់ ១, ERN 01626068 ទំព័រ ១៤ បន្ទាត់ ៦-១១, ERN 01626118 ទំព័រ ៦៤ បន្ទាត់ ២-៥។ *សូមមើលផងដែរ* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៥៨ *យោងទៅ* ចម្លើយតបរបស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានស្ថាពរ (D351/6) កថាខណ្ឌ ១៣០-១៨២, ១៨៨-២០០, ២១២។

[656] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧៦ *យោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៦៣៣ ជើងទំព័រ ២១៥២-២១៥៣។ ចៅក្រមអន្តរជាតិសង្កេតឃើញថា សហមេធាវីគ្រាន់តែដកស្រង់ជើងទំព័រ ២១៥២ នៅក្នុងបណ្តឹងឧទ្ធរណ៍ តែក៏បានយោងទៅឧទាហរណ៍នានាដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដកស្រង់ នៅក្នុងជើងទំព័រ ២១៥៣ ផងដែរ។ ចៅក្រមអន្តរជាតិយកឧទាហរណ៍ទាំងអស់ដែលសហមេធាវីបានលើកយោងមកពិចារណា នៅក្នុងពេលសមស្រប។

[657] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧៦ *យោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៥២៣ ជើងទំព័រ ១៧២៧។

ដើមបណ្ដឹងរដ្ឋប្បវេណី អំពីប្រភពនៃភស្តុតាង[658]។

៤១៥. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា ក្នុងការអះអាងថា សហចៅក្រមស៊ើបអង្កេតមិនគិតពីភាពមិនត្រឹមត្រូវ ពីរបៀបនៃការយកចម្លើយនោះ សហមេធាវីកំពុងប៉ុនប៉ងប្ដឹងឡើងវិញទៅលើបញ្ហានានាដែលបានសម្រេចរួចហើយ[659]។ បើតាមការលើកឡើងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សហមេធាវីពុំបានផ្ដល់សំអាងហេតុសម្រាប់បដិសេធសេចក្ដីសម្រេចជាឯកច្ឆ័ន្ទរបស់អង្គបុរេជំនុំជម្រះដែលថា ពុំមានភាពមិនត្រឹមត្រូវបានកើតឡើងក្នុងការប្រមូលភស្តុតាងនោះទេ ហេតុនេះ សហមេធាវីមិនបានបង្ហាញពីកំហុសឆ្គងណាមួយដែលចាំបាច់ឱ្យមានអន្តរាគមន៍ដោយបណ្ដឹងឧទ្ធរណ៍នោះឡើយ។ ហេតុនេះ មូលដ្ឋាននេះគួរតែត្រូវបានបដិសេធចោលភ្លាមៗ[660]។ បើតាមទស្សនៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ការយកចម្លើយត្រូវបានធ្វើឡើងដោយប្រើប្រាស់វិធីសាស្ត្រស៊ើបអង្កេតត្រឹមត្រូវ ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិមានភាពត្រឹម ត្រូវក្នុងការសំអាងលើចម្លើយទាំងនេះ[661]។

៤១៦. នៅក្នុងការឆ្លើយតប សហមេធាវីបដិសេធថា ពួកគេពុំមែនកំពុងប្ដឹងឡើងវិញទៅលើបញ្ហាទាំងនោះទេ ដោយអះអាងថា សហព្រះរាជអាជ្ញាអន្តរជាតិបកស្រាយមិនត្រឹមត្រូវចំពោះសេចក្ដីសម្រេចពីមុនរបស់អង្គបុរេជំនុំជម្រះ[662]។ សហមេធាវីបញ្ជាក់ថា ក្រៅពីសម្រេចថា ភាពលម្អៀងរបស់អ្នកស៊ើបអង្កេតមិនត្រូវបានបង្ហាញ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា "កាលៈទេសៈនៃការប្រមូលភស្តុតាង រួមទាំង ភាពអាចទុកចិត្តបាននៃកិច្ចស្ដាប់ចម្លើយពាក់ព័ន្ធនឹងលក្ខណៈនៃសំណួរដែលបានសួរទៅកាន់សាក្សី និង ដើមបណ្ដឹងរដ្ឋប្បវេណី នឹងត្រូវយកមកវាយតម្លៃពេញលេញនៅដំណាក់កាលចេញដីកាដំណោះស្រាយដោយអង្គបុរេជំនុំជម្រះ"[663]។ ហេតុនេះ បញ្ហាលម្អៀងដែលបានលើកឡើងនៅក្នុងសេចក្ដីសម្រេចនោះខុសពីបញ្ហានៃការ

---

[658] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧៦ *យោងទៅ*ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ២៥៥ ជើងទំព័រ ៦៣២ *និង* កថាខណ្ឌ ២៥២ ជើងទំព័រ ៦២០។

[659] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៤៧។

[660] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៤៧ *យោងទៅ* សាលដីកាលើការសុំធ្វើមោឃភាពកំណត់ហេតុស្ដាប់ចម្លើយ (D338/1/5) កថាខណ្ឌ ២១-២៥។

[661] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៤៧។

[662] ការឆ្លើយតបរបស់ អោ អាន (D360/11) កថាខណ្ឌ ៣១។

[663] ការឆ្លើយតបរបស់ អោ អាន (D360/11) កថាខណ្ឌ ៣១-៣២ *យោងទៅ* សាលដីកាលើការសុំធ្វើមោឃភាពកំណត់ហេតុស្ដាប់ចម្លើយ (D338/1/5) កថាខណ្ឌ ២៥។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 និងD360/18.1 ERN 01626068 ទំព័រ ១៤ បន្ទាត់ ១២-១៥។ *ផ្ទុយពី* ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ

វាយតម្លៃភស្តុតាង ហើយពួកគេកំពុងលើកឡើងយ៉ាងត្រឹមត្រូវ និងទាន់ពេលវេលាអំពី បញ្ហានៃភាពអាចទុកចិត្តបាន និងភាពជឿជាក់បាន[664]។

## ២. ការពិភាក្សា

៤១៧. ចៅក្រមអន្តរជាតិសន្និដ្ឋានថា ការប្ដឹងឡើងវិញទៅលើការជំទាស់ដូចគ្នាទៅនឹងកំហុសនីតិវិធីនៅ ក្នុងការស៊ើបអង្កេតដែលត្រូវបានចោទប្រកាន់ គឺជារឿងមិនត្រឹមត្រូវទេ ហើយត្រូវតែបដិសេធចោលភ្លាមៗ។ ក្រៅពីនេះ ទីមួយ សហមេធាវីអាចជំទាស់ទៅនឹងតម្លៃជាភស្តុតាងដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានផ្ដល់ចំពោះភស្តុតាងនៅដំណាក់កាលនេះបាន។ ទោះជាមានការលើកឡើងយ៉ាងនោះក្ដី ចៅក្រមអន្តរជាតិសន្និដ្ឋានថា ទីពីរ សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានកំហុសក្នុងការសំអាងទៅលើភស្តុតាងដែលបានពីការស្ដាប់ចម្លើយនោះទេ។

៤១៨. ជាបឋម ចំពោះចំណុចដែលសហមេធាវីលើកឡើងពីទឡ្ហីករណ៍ពាក់ព័ន្ធនឹង "វិធីសាស្ត្រគួរឱ្យសង្ស័យ" ដែលត្រូវបានចោទប្រកាន់ ឬកំហុសនីតិវិធីក្នុងការប្រមូលភស្តុតាងនោះ ចៅក្រមអន្តរជាតិសម្រេចបដិសេធចោលការជំទាស់ទាំងនេះភ្លាមៗ ដោយសារទឡ្ហីករណ៍ទាំងនេះត្រូវបានប្ដឹង និងបដិសេធរួចរាល់ហើយ[665]។ ចៅក្រមអន្តរជាតិធ្លាប់បានច្រានចោលទឡ្ហីករណ៍របស់សហមេធាវីពាក់ព័ន្ធនឹងកំហុស

ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៣៧ ជើងទំព័រ ៧០, កថាខណ្ឌ ៣៩ ជើងទំព័រ ៧៦, កថាខណ្ឌ ៤២ ជើងទំព័រ ៨៩។

[664] ការឆ្លើយតបរបស់ អោ អាន (D360/11) កថាខណ្ឌ ២៣, ២៩, ៣២។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 និងD360/18.1 ERN 01626068-01626069 ទំព័រ ១៤ បន្ទាត់ ១៥ - ទំព័រ ១៥ បន្ទាត់ ២។

[665] *សូមមើល* សាលដីកាលើសំណើសុំធ្វើមោឃភាពលើកំណត់ហេតុស្ដាប់ចម្លើយ (D338/1/5)") កថាខណ្ឌ ១០, ២៣ ជើងទំព័រយោងលេខ ៦៤។ *សូមមើលផងដែរ* សំណុំរឿង ០០៤/២ សំណើសុំធ្វើមោឃភាពកំណត់ហេតុស្ដាប់ចម្លើយនានាដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតចំនួនបីរូប ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ D338/1/2 កថាខណ្ឌ ២២។ ចៅក្រមអន្តរជាតិកត់សម្គាល់ថា នៅក្នុងបណ្ដឹងឧទ្ធរណ៍នេះ សហមេធាវីការពារក្ដីលើកឡើងនូវកំហុសស៊ើបអង្កេត ដូចបានអះអាងនៅក្នុងសំណើសុំធ្វើមោឃភាពកំណត់ហេតុស្ដាប់ចម្លើយដដែល *ក្នុងនោះ*មានដូចជា: (i) "ការផ្ដល់" ព័ត៌មានដាក់បន្ទុក (ii) ការសន្ទនាដែលមិនបានថតសំឡេងឱ្យបានត្រឹមត្រូវ និង ((iii) ការខកខានពុំបានសួរមូលដ្ឋាន ឬប្រភពនៃភស្តុតាង។ *សូមមើលជាទូទៅ* សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ តា អាន ស្ដីពីការបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ (D190/1/2) កថាខណ្ឌ ១៩-២០ (ដែលលើកឡើងថា ម្ចាស់បណ្ដឹងឧទ្ធរណ៍គ្រាន់តែ "អះអាងឡើងវិញនូវទឡ្ហីករណ៍ដែលបានលើកឡើងរួចមកហើយ" និងលើកឡើងថា អង្គបុរេជំនុំជម្រះអាចបដិសេធបណ្ដឹងឧទ្ធរណ៍ ឬសំណើនេះចោល "នៅពេលដែលអង្គបុរេជំនុំជម្រះមិនអាចសម្រេចលើបញ្ហា ដែលបានលើកឡើងនៅចំពោះមុខខ្លួន ការពិនិត្យឡើងវិញលើបញ្ហាដែលដូចគ្នាជាសំខាន់ (ទាំងក្នុងអង្គហេតុ និងអង្គច្បាប់) តាមរយៈសំណើ

នីតិវិធី ហើយបានសន្និដ្ឋានថា អ្នកស៊ើបអង្កេតពុំមានកំហុសក្នុងការអនុវត្តការងាររបស់ខ្លួនទេ[666]។ ទោះជាយ៉ាងនេះក្តី ដូចដែលសហមេធាវីលើកឡើង ចៅក្រមអន្តរជាតិបានបញ្ជាក់រួចហើយថា ភាពអាចទុកចិត្តបាននៃការស្តាប់ចម្លើយនឹង "ត្រូវយកមកវាយតម្លៃពេញលេញនៅដំណាក់កាលចេញដីកាដំណោះស្រាយ រួមទាំងការវាយតម្លៃនាពេលក្រោយមកដោយអង្គបុរេជំនុំជម្រះ"[667]។ ហេតុនេះ ក្នុងការបដិសេធពាក្យសុំធ្វើមោឃភាពរបស់សហមេធាវី អង្គបុរេជំនុំជម្រះបើកឱ្យមានសំណួរអំពីតម្លៃជាភស្តុតាងដែលផ្តល់ទៅលើភ

---

សុំ ឬបណ្តឹងឧទ្ធរណ៍ដែលដាក់ដោយភាគីដដែល")។

[666] ជាពិសេស អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា (i) កំណត់ហេតុស្តាប់ចម្លើយដែលត្រូវបានជំទាស់ តាមការអះអាងថា "មានការផ្តល់" ព័ត៌មានដាក់បន្ទុកតាមរយៈសំណួរនាំមុខ និងសំណួរបើក ឬដោយការផ្តល់រឿងរ៉ាវជាមុននោះ ពុំបង្ហាញថាមានការអនុវត្តមិនត្រឹមត្រូវចំពោះឆន្ទានុសិទ្ធិរបស់អ្នកស៊ើបអង្កេត នៅក្នុងពេលស្តាប់ចម្លើយនោះទេ *សូមមើល* ("សាលដីកាលើសំណើសុំធ្វើមោឃភាពលើកំណត់ហេតុស្តាប់ចម្លើយ (D338/1/5)") កថាខណ្ឌ ២១, ២២, (ii) ការសន្ទនាដែលមិនបានថតសំឡេង (ដែលត្រូវបានកំណត់ថាជាកិច្ចសន្ទនា "វាយតម្លៃ") ពុំបង្ហាញនូវភាពលម្អៀង ឬភស្តុតាងពុំត្រឹមត្រូវ *សូមមើល* កថាខណ្ឌ ២៤ និង (iii) នត្ថិភាពដែលបានចោទប្រកាន់មកលើអ្នកស៊ើបអង្កេត ចំពោះការបន្តសួរដេញដោល ឬការជជីកសួរលើមូលដ្ឋាននៃការអះអាងដាក់បន្ទុក ពុំត្រូវបានបង្ហាញឱ្យឃើញថាមានភាពលម្អៀង ឬលេចឡើងនូវភាពលម្អៀងណាមួយនៅក្នុងករណីទាំងនោះទេ *សូមមើល* កថាខណ្ឌ ២៣។ ចៅក្រមអន្តរជាតិ កត់សម្គាល់ឃើញថា ឧទាហរណ៍ជាក់លាក់ទាំងអស់នៃភាពមិនប្រក្រតីក្នុងការស៊ើបអង្កេតដូចបានអះអាងនៅក្នុងសំអាងហេតុទី ៥(iii) នៃបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានសហមេធាវីការពារក្តីអះអាងកាលពីមុនរួចមកហើយ នៅក្នុងសំណើរបស់ពួកគេសុំឱ្យធ្វើមោឃភាពលើកំណត់ហេតុស្តាប់ចម្លើយ *សូមមើល ខ.* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៥ ឯកសារ D219/484 (ដែលត្រូវបានយោងរួចមកហើយនៅក្នុងឧបសម្ព័ន្ធ ខ នៃសំណើសុំធ្វើមោឃភាពលើកំណត់ហេតុស្តាប់ចម្លើយ ឯកសារ D338/1/2.3 លេខរៀង ៥៦)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ឯកសារ D219/138 (ដែលត្រូវបានយោងរួចមកហើយនៅក្នុងឧបសម្ព័ន្ធ ឃ នៃសំណើសុំធ្វើមោឃភាពលើកំណត់ហេតុស្តាប់ចម្លើយ ឯកសារ D338/1/2.5 លេខរៀង ១)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពិន ពៅ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D219/116 (ដែលត្រូវបានយោងរួចមកហើយនៅក្នុងឧបសម្ព័ន្ធ ក នៃសំណើសុំធ្វើមោឃភាពលើកំណត់ហេតុស្តាប់ចម្លើយ ឯកសារ D338/1/2.2 ត្រង់ ERN (EN) 01388910។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន គីមអេង ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ D107/5 (ដែលត្រូវបានយោងរួចមកហើយនៅក្នុងឧបសម្ព័ន្ធ ក នៃសំណើសុំធ្វើមោឃភាពលើកំណត់ហេតុស្តាប់ចម្លើយ ឯកសារ D338/1/2.2 ត្រង់ ERN (EN) 01388902)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១២ ឯកសារ D107/15 (ដែលត្រូវបានយោងរួចមកហើយនៅក្នុងឧបសម្ព័ន្ធ ក នៃសំណើសុំធ្វើមោឃភាពលើកំណត់ហេតុស្តាប់ចម្លើយ ឯកសារ D338/1/2.2 ត្រង់ ERN (EN) 01388901)។ ចៅក្រមអន្តរជាតិនឹងមិនពិនិត្យឡើងវិញទៅលើការសម្រេចរបស់ខ្លួនស្តីពីការចោទប្រកាន់ចំពោះការអនុវត្តកិច្ចស៊ើបសួរមិនត្រឹមត្រូវ ទាក់ទងនឹងការជំទាស់តវ៉ាដូចបានអះអាងជាថ្មីទៀតទាំងនេះទេ។ ចៅក្រមអន្តរជាតិនឹងគ្រាន់តែវាយតម្លៃ ថាតើសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបំពេញកិច្ចដោយមិនសមហេតុផលឬយ៉ាងណា ក្នុងការឈានដល់ការសន្និដ្ឋានលើអង្គហេតុ ដែលបានសំអាងលើភស្តុតាងចម្រូងចម្រាស់នេះ។

[667] សាលដីកាលើសំណើសុំធ្វើមោឃភាពលើកំណត់ហេតុស្តាប់ចម្លើយ (ឯកសារ D338/1/5) កថាខណ្ឌ ២៥។

ស្តុតាង សម្រាប់ធ្វើការវាយតម្លៃ នៅពេលនេះ។

៤១៩. ទីមួយ សហមេធាវីបានជំទាស់ទាន់ពេលវេលាចំពោះភាពអាចទុកចិត្តបាន និងភាពជឿជាក់បាននៃភស្តុតាងដែលអ្នកស៊ើបអង្កេតប្រមូលបាន។ ចៅក្រមអន្តរជាតិយល់ឃើញថា បញ្ហាថាតើសហចៅក្រមស៊ើបអង្កេតអន្តរជាតិមាន ឬគ្មានកំហុស ក្នុងការវាយតម្លៃទៅលើតម្លៃជាភស្តុតាង ចំពោះភស្តុតាងដែលបានពីការស្តាប់ចម្លើយ មានភាពខុសគ្នាស្រឡះពីបញ្ហាដែលសហមេធាវីបានលើកឡើងពីមុន គឺថាតើ ផ្នែកដែលត្រូវបានជំទាស់នៅក្នុងកំណត់ហេតុស្តាប់ចម្លើយមួយចំនួន ត្រូវធ្វើមោឃភាពដោយសារកំហុសនីតិវិធីដែលត្រូវបានចោទប្រកាន់ ឬយ៉ាងណា[668]។ ដោយបានសម្រេចថា ការចោទប្រកាន់ទាំងនេះពុំគ្រប់គ្រាន់ធ្វើឲ្យមានមោឃភាពចំពោះការស្តាប់ចម្លើយដែលត្រូវបានជំទាស់នោះ ចៅក្រមអន្តរជាតិបញ្ជាក់ថា ពុំមានសំអាងហេតុដែលធ្វើឲ្យប៉ះពាល់ដល់ភាពអាចទុកចិត្ត និងភាពជឿជាក់បាននៃភស្តុតាងឡើយ ដោយសារតែភាពមិនត្រឹមត្រូវនៃការស៊ើបអង្កេតនៅក្នុងរឿងក្តីនេះឡើយ។

៤២០. ទីពីរ ពាក់ព័ន្ធនឹងបញ្ហាថាតើ មាន ឬគ្មាន "ភស្តុតាងគ្រប់គ្រាន់"[669] នោះ ចៅក្រមអន្តរជាតិសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានកំហុសទេ ក្នុងការសំអាងទាំងស្រុងទៅលើចម្លើយពីការស្តាប់ចម្លើយ។ សហមេធាវីពុំមានបង្ហាញថា ការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅលើភាពអាចទុកចិត្តបាន និងតម្លៃជាភស្តុតាងនៃភស្តុតាងដែលបានពីការស្តាប់ចម្លើយ ពុំមានហេតុផលនោះឡើយ។

៤២១. ចៅក្រមអន្តរជាតិសង្កេតឃើញថា នៅក្នុងឧទាហរណ៍ជាក់លាក់ដែលសហមេធាវីលើកឡើង សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនគ្រាន់តែសំអាងទៅលើការស្តាប់ចម្លើយ ដែលអាច "ប្រឡូកប្រឡាក់" ដើម្បីស្នើឡើងមកធ្វើជាភស្តុតាង ប៉ុណ្ណោះទេ។ ផ្ទុយទៅវិញ គាត់បង្ហាញពីការវាយតម្លៃច្បាស់លាស់លើតម្លៃជាភស្តុតាង និងភាពអាចទុកចិត្តបាននៃភស្តុតាងទាំងនោះទៀតផង[670]។ នៅក្នុងករណីផ្សេងទៀត

[668] សាលដីកាលើសំណើសុំធ្វើមោឃភាពលើកំណត់ហេតុស្តាប់ចម្លើយ (ឯកសារ D338/1/5) កថាខណ្ឌ ១០, ១៥។

[669] សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ៦០-៦២។

[670] *សូមមើល ឧ.* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៥២៣ ជើងទំព័រយោងលេខ ១៧២៧ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សំអាងលើកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពិន ពៅ (ឯកសារ D219/116) ជាភស្តុតាងគាំទ្រដល់ផ្នែកសេចក្តីសម្រេចថា បន្ទាប់ពីកម្មាភិបាលភូមិភាគនិរតីបានមកដល់ ការសម្លាប់មនុស្សនៅមន្ទីរសន្តិសុខវត្តបាធាយបានកើនឡើង។ ដូចដែលបានលើកឡើងដោយសហមេធាវីការពារក្តី គ្រាន់តែជាការសន្មតថា អ្នកស៊ើបអង្កេតខកខានពុំបានកត់ត្រាការសន្ទនាដែលមិនបានថតសំឡេង ដែលតាមរយៈនោះ អ្នកស៊ើបអង្កេត "បានផ្តល់" ព័ត៌មានទាំងមិនត្រឹមត្រូវទាល់តែ

សហចៅក្រមស៊ើបអង្កេតអន្តរជាតិយោងទៅចម្លើយទាំងនោះ រួមជាមួយសម្ភារគាំទ្រផ្សេងទៀត[671]។

---

សោះដល់សាក្សីថា "អ្នកទោសរាប់ពាន់នាក់ត្រូវបានសម្លាប់" នៅមន្ទីរសន្តិសុខវត្តបាធាយនោះ គឺសហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំបានសំអាងទៅលើកំណត់ហេតុស្តាប់ចម្លើយនោះ ថាជាចំនួនភស្តុតាងពិតប្រាកដសម្រាប់ការសម្លាប់មនុស្សនៅវត្តបាធាយនោះទេ។ តាមពិតទៅ សហចៅក្រមស៊ើបអង្កេតអន្តរជាតិពិភាក្សាយ៉ាងច្បាស់លាស់ចំពោះភាពគួរឱ្យជឿជាក់បាននៃភស្តុតាងរបស់ ពិន ពៅ (*សូមមើល* កថាខណ្ឌ ៥២៩) និងពន្យល់យ៉ាងច្បាស់ក្រឡែតថា សាក្សីរូបនេះ "មិនអាចចាត់ថាជឿជាក់បានពាក់ព័ន្ធនឹងប្រភេទជនរងគ្រោះ និង*ចំនួននៃការសម្លាប់មនុស្សនៅវត្តបាធាយ*ខណៈដែលគាត់បានគ្រប់គ្រងនៅមន្ទីរសន្តិសុខនោះ" *សូមមើល* កថាខណ្ឌ ៥៣០ (មានសេចក្តីបញ្ជាក់បន្ថែម)។ ទោះបីជាចៅក្រមអន្តរជាតិកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្រោយមក បានសំអាងយ៉ាងចម្លែកទៅលើសាក្សី ពិន ពៅ នៅក្នុងជើងទំព័រយោងលេខ ១៧៧១ ដើម្បីជាការគាំទ្រដល់ចម្លើយថា "សាក្សីទាំងឡាយសង្កេតឃើញនូវការស៊ីសង្វាក់គ្នាថា ជនរងគ្រោះ [ដែលគេបានសម្លាប់នៅវត្តបាធាយ] មានចំនួនរាប់ពាន់នាក់" ក៏ដោយ ក៏ភាពមិនស៊ីសង្វាក់គ្នានេះមិនធ្វើឱ្យប៉ះពាល់ដល់ភាពសមហេតុផលនៃការយល់ឃើញពាក់ព័ន្ធនឹងចំនួនអ្នកសម្លាប់នៅវត្តបាធាយ ដោយសារមានកំណត់ហេតុស្តាប់ចម្លើយគាំទ្រជាច្រើនទៀតដែលបានយោងនៅក្នុងលេខជើងទំព័រយោងដដែល និងកថាខណ្ឌបន្តបន្ទាប់ទៀត)។ *សូមមើលផងដែរ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៦៣៣ ជើងទំព័រយោងលេខ ២១៥៣ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិផ្អែកលើកំណត់ហេតុស្តាប់ចម្លើយសាក្សី ប្រាក់ យុត (ឯកសារ D219/484) ជាភស្តុតាងដែលគាំទ្រថា អោ អាន បានបញ្ជាឱ្យ ប្រាក់ យុត លេខាស្រុកកំពង់សៀម រៀបចំបញ្ជីឈ្មោះជនជាតិចាមនៅស្រុកកំពង់សៀម។ ទោះបីជា "ការផ្តល់" ព័ត៌មានពីសំណាក់អ្នកស៊ើបអង្កេតទាក់ទងនឹងចំនួនជនជាតិចាមរបស់នៅក្នុងភូមិនានាចំណុះឱ្យស្រុកមិនត្រឹមត្រូវក្តី ក៏សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំបានសំអាងទៅលើផ្នែកនៃកិច្ចសម្ភាសន៍ដែលត្រូវបានជំទាស់នេះ ថាជាភស្តុតាងសម្រាប់ជនជាតិចាមដែលគេបានសម្លាប់នៅក្នុងស្រុកកំពង់សៀមនោះដែរ ប៉ុន្តែដើម្បីគាំទ្រដល់ការយល់ឃើញរបស់គាត់ថា អោ អាន បានបញ្ជាឱ្យចងក្រងបញ្ជីឈ្មោះជនជាតិចាមទៅវិញទេ។ ដូចបានលើកឡើងរួចមកហើយនៅក្នុងសំអាងហេតុទី ៥(ii) *ខាងលើ* សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានវាយតម្លៃពីភាពអាចឱ្យជឿជាក់បាននៃភស្តុតាងរបស់ ប្រាក់ យុត។ លើសពីនេះទៀត ចៅក្រមអន្តរជាតិកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានលើកឡើងនៅក្នុងឧបសម្ព័ន្ធ IV នៃដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ពីភស្តុតាងដែលគាំទ្រដល់ការគណនារបស់គាត់អំពីចំនួនជនជាតិចាមដែលត្រូវបានសម្លាប់នៅក្នុងស្រុកកំពង់សៀម ដែលបានផ្អែកទៅលើកំណត់ហេតុសម្លាប់ចម្លើយរបស់សាក្សីដទៃទៀត)។

[671] *សូមមើល ឧ.* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៥២ ជើងទំព័រយោងលេខ ៦២០ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សំអាងទៅលើកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក (D107/15) ដែលជាការគាំទ្រដល់ភស្តុតាងថា អោ អាន បានក្លាយជាអនុលេខាភូមិភាគកណ្តាលនៅចុងឆ្នាំ ១៩៧៧។ ដូចបានលើកឡើងដោយសហមេធាវីការពារក្តី ទោះបីជាអ្នកស៊ើបអង្កេតខកខានពុំបានសាកសួរអំពីមូលដ្ឋាននៃការដឹងឮនេះពុំត្រឹមត្រូវក៏ដោយ ក៏កំណត់ហេតុស្តាប់នៃការចម្លើយនេះគ្រាន់តែជាកំណត់ហេតុមួយ ក្នុងចំណោមកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក ជាច្រើនដែលត្រូវបានយកមកសំអាងដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ រួមទាំងសក្ខីកម្មរបស់ បាន សៀក ដែលឆ្លើយនៅក្នុងតុលាការនេះក្នុងសំណុំរឿង ០០២/២ ផងដែរ។ បាន សៀក ពន្យល់ថា នៅក្នុងចំណោមមុខតំណែងជាច្រើនទៀត គាត់បានកាន់មុខតំណែងមួយចំនួន ដូចជា ប្រធានពាណិជ្ជកម្មតំបន់៤២ និងអនុលេខាស្រុកចម្ការលើ ដែលគាំទ្រដល់ការដឹងរបស់គាត់អំពីរចនាសម្ព័ន្ធដឹកនាំរបស់ភូមិភាគកណ្តាល។ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ

ហេតុនេះ ចៅក្រមអន្តរជាតិសន្និដ្ឋានថា វិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមែនជាការខុសឆ្គងទេ ហើយសម្រេចថា ការសំអាងទាំងស្រុងរបស់គាត់ទៅលើភស្តុតាងដែលបានពីការស្តាប់ចម្លើយ

---

២០១៤ ឯកសារ D117/35 ត្រង់ ERN (KH) 00980365 (ឆ.១០)។ ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/០២ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៥ (បាន សៀក) ឯកសារ D219/702.1.75 ត្រង់ ERN (KH) 01424036-01424038។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏យោងទៅលើកំណត់ហេតុនៃការស្តាប់ចម្លើយជាច្រើនពីសាក្សីដទៃទៀត ថាជាភស្តុតាងគាំទ្រចំពោះតួនាទីរបស់ អោ អាន ជាអនុលេខាភូមិភាគកណ្តាល *ខ.* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុច វ៉ា ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ D219/178 ត្រង់ ERN (KH) 01066300 (ឆ.៦) ("*តា*អាន គឺជាអនុ កែ ពក និងជាសមាជិកគណៈភូមភាគ")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុម ប៊ុន ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D117/50 ត្រង់ ERN (KH) 00990812 (ឆ.២៩) ("បាទៗ *តា*អានហ្នឹងជាអនុ។ បើនិយាយពីខាងភូមិភាគ គាត់អនុ *តា*ពក") & 00990819 (ឆ.៧៥) ("*តា*អាន ហ្នឹងគាត់អនុភូមិភាគដែរ គាត់ដើររហូតមក ពេល *តា* ពក បញ្ជា ឬអត់នៅអី គាត់ដើរធ្វើការដែរ")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ D117/18 ត្រង់ ERN (KH) 00893171 (ឆ.២) ("ក្រោយពីការចាប់ខ្លួន សែ ខ្ញុំដឹងថា *តា*អាន គឺជាអនុរបស់ *តា*ពក តែម្នាក់ដែលនៅសល់")។ *សូមមើល* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៦៣៣ ជើងទំព័រយោងលេខ ២១៥១ (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ដែលបានយកមកសំអាង (ឯកសារ D219/138) គឺស៊ីសង្វាក់គ្នានឹងឯកសារផ្សេងទៀត រួមទាំងសក្ខីកម្មរបស់គាត់នៅក្នុងនៅក្នុងសណុំរឿង ០០២/២ ផង ដែលគាត់បានផ្តល់សក្ខីកម្មលម្អិតទាក់ទងនឹងបញ្ជីឈ្មោះជនជាតិចាម ដែលគេបានស្នើឲ្យគាត់រៀបចំ និងតួនាទីរបស់ អោ អាន នៅក្នុងការណែនាំឲ្យរៀបចំបញ្ជីឈ្មោះទាំងនេះ។ *សូមមើល* ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/០២ ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ (យូ វ៉ាន់) ត្រង់ ERN (KH) 01451953- 01451954, 01451956- 01451960។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏យោងទៅលើភស្តុតាងរបស់ ប្រាក់ យុត និង ញឹម កុល ដែលអាចត្រូវបានយកមកសំអាងប្រកបដោយហេតុផលថាជាប្រភពនៃភស្តុតាងគួរឲ្យជឿជាក់បាន ដូចដែលបានលើកឡើងនៅក្នុងសំដាងហេតុទី ៥(ii)។ *សូមមើល* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៥៥ ជើងទំព័រយោងលេខ ៦៣២ (បន្ថែមលើកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន គឹមអេង ដែលបានយកមកសំអាង (D107/5) សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏ផ្អែកលើកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែ ពេជ្រវណ្ណៈ និងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុម ប៊ុន (D117/50) ផងដែរ។ ចៅក្រមអន្តរជាតិទទួលស្គាល់ថា សហមេធាវីការពារក្តីលើកឡើងនូវការជំទាស់តវ៉ាជាក់លាក់មួយប្រឆាំងនឹងការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិថា អោ អាន បានបំពេញតួនាទីជាលេខាស្តីទីភូមិភាគកណ្តាល នៅក្នុងអំឡុងពេលដែល កែ ពក អវត្តមានពីភូមិភាគនេះ ហើយលើកបញ្ហាជាក់លាក់នេះឡើងនៅក្នុងសំអាងហេតុទី ៦(iv)។ សម្រាប់គោលបំណងនានានាពេលនេះ ចៅក្រមអន្តរជាតិសម្រេចថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំបានប្រព្រឹត្តកំហុសនៅក្នុងការសំអាងលើកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន គឹមអេង (ឯកសារ D107/5) និងបានពិចារណាយ៉ាងត្រឹមត្រូវចំពោះតម្លៃភវនីយភាពកម្រិតទាបនៃភស្តុតាងនេះ។ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ប្រៀបធៀបយ៉ាងច្បាស់លាស់លើចម្លើយរបស់ អ៊ិន គឹមអេង (D107/5) ត្រង់ ERN (KH) 00784994 (ឆ.២៧) ("នៅពេល កែ ពក អវត្តមាន អនុរបស់គាត់ដែលជាប្រធានតំបន់ឈ្មោះ *តា*អាន ជាអ្នកទទួលខុសត្រូវ") ទល់នឹងចម្លើយផ្ទុយគ្នារបស់ អ៊ិន គឹមអេង ដែលបានឆ្លើយនៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយផ្សេងទៀតរបស់គាត់ (ឯកសារ D117/66 ត្រង់ ERN (KH) 01023133 (ឆ.១៣) ("ខ្ញុំដឹងថា *តា*មឿន ឬ ហែន ធ្វើការជំនួសឲ្យ កែ ពក ពេលគាត់អវត្តមាន")។

មានហេតុផល។ ហេតុនេះ ចៅក្រមអន្តរជាតិសម្រេច បដិសេធមូលដ្ឋានទី ៥ (៣)។

## មូលដ្ឋានទី៥(iv). ការចោទប្រកាន់ចំពោះកំហុសនៃការសំអាងនៅលើភស្តុតាងដែលពុំមានការបញ្ជាក់បន្ថែម

### ១. សារណា

៤២២. សសហមេធាវីលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសដែលផ្អែកជាប្រព័ន្ធទៅលើដំណើររឿងមិនមានសំអាង ដើម្បីគាំទ្រអង្គហេតុជាក់ស្តែងដែលរំលេចសំអាងហេតុយុត្តាធិការបុគ្គលដែលវិធីនេះមានលក្ខណៈប្រាសចាកឆ្ងាយពីលក្ខខណ្ឌបទដ្ឋានភស្តុតាង[672]។ ទោះបីពុំមានវិធានទូទៅដែលថា សំអាងហេតុត្រូវតែគាំទ្រដោយភស្តុតាងមួយឬច្រើនក៏ដោយ ក៏សហមេធាវីអះអាងថា ការបញ្ជាក់បន្ថែមគឺមានសារៈសំខាន់នៅពេលសម្រេចអំពីភាពជាប់ពាក់ព័ន្ធ និងភាពអាចជឿជាក់បាននៃភស្តុតាងអនុលោមទៅតាមយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល តុលាការអន្តរជាតិ និងយុត្តាធិការច្បាប់ស៊ីវិលជាតិនានា[673]។ សហមេធាវីអះអាងបន្ថែមថា ត្រូវតែ “មានការប្រុងប្រយ័ត្ន” ចំពោះចម្លើយរបស់សាក្សីដែលពុំមានការបញ្ជាក់បន្ថែម ហើយថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការមិនប្រកាន់យកវិធីសាស្ត្រនេះ[674]។

៤២៣. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិឆ្លើយតបថា ការសំអាងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅលើដំណើររឿង “តែមួយ មិនមានការបញ្ជាក់បន្ថែម” ដែលបានអះអាង គឺត្រឹមត្រូវតាមផ្លូវច្បាប់[675]។ អ.វ.ត.ក និងតុលាការផ្សេងទៀតបានទទួលស្គាល់ថា ការបញ្ជាក់បន្ថែមរបស់សាក្សី និងភស្តុតាងមិនមែនជាលក្ខខណ្ឌតម្រូវផ្នែកច្បាប់ព្រហ្មទណ្ឌអន្តរជាតិនោះទេ[676] សូម្បីតែការសម្រេចដាក់ពិរុទ្ធភាព

[672] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧៧ និងជើងទំព័រ ១៦៧។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626069 ទំព័រ ១៥ បន្ទាត់ ២-៨។

[673] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧៧ និងជើងទំព័រ ១៦៨-១៧០។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626069 ទំព័រ ១៥ បន្ទាត់ ៨-១៥។

[674] ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626069 ទំព័រ ១៥ បន្ទាត់ ១៥-២២។

[675] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៤៨។

[676] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៤៨ និងជើងទំព័រ ១១១។

ក៏ដោយ[677] ហើយគ្រាន់តែជាកត្តាមួយក្នុងចំណោមកត្តាសក្តានុពលជាច្រើនទៀតដើម្បីពិចារណា ក្នុងការវាយតម្លៃភស្តុតាងប៉ុណ្ណោះ[678]។ នៅក្នុងកាលៈទេសៈណាក៏ដោយ សហព្រះរាជអាជ្ញាអន្តរជាតិយល់ឃើញថា ដំណើររឿងជាច្រើនដែលសហមេធាវីជំទាស់ "ត្រូវបានបញ្ជាក់បន្ថែមដោយ និងបានបញ្ជាក់បន្ថែមឱ្យច្បាស់ពី" ភស្តុតាងផ្សេងៗទៀត[679]។ សហព្រះរាជអាជ្ញាអន្តរជាតិកត់សម្គាល់បន្ថែមថា ការបញ្ជាក់បន្ថែមពុំតម្រូវឱ្យដំណើររឿងរបស់សាក្សីត្រូវតែដូចគ្នាបេះបិទគ្រប់ទិដ្ឋភាពនោះទេ តែ "បញ្ហាសំខាន់" គឺថា តើដំណើររឿងពីរ ឬច្រើនដែលអាចទុកចិត្តបាន មានភាពមិនស្របគ្នា ឬយ៉ាងណា[680]។

៤២៤. នៅក្នុងការឆ្លើយតប សហមេធាវីនៅតែរក្សាជំហរថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមើលរំលងចំពោះភាពខ្វះខាតការបញ្ជាក់បន្ថែម[681] ហើយបានរិះគន់ចំពោះ "ការយល់ច្រឡំជាមូលដ្ឋាន" របស់សហព្រះរាជអាជ្ញាអន្តរជាតិចំពោះទស្សនៈនៃភស្តុតាងបញ្ជាក់បន្ថែម[682]។ បើតាមសហមេធាវីគឺថា ការបញ្ជាក់បន្ថែម "ហាក់ដូចជាលក្ខខណ្ឌកំណត់" នៅពេលសាក្សី ឬអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពុំមានភាពអាចជឿជាក់បាន[683] ហេតុនេះហើយ គួរតម្រូវឱ្យមានភស្តុតាងបញ្ជាក់បន្ថែម ដើម្បីគាំទ្រដល់ភស្តុតាងរបស់សាក្សីដែលមិនអាចទុកចិត្តបាន[684]។ ចុងក្រោយ ដោយសារបទដ្ឋាននៃការបង្ហាញភស្តុតាងដែលជា "ភស្តុតាងពិតប្រាកដ និងភស្តុតាងមានការបញ្ជាក់គ្រប់គ្រាន់" នៅដំណាក់កាលចេញដីកាដំណោះស្រាយធ្វើឱ្យការបញ្ជាក់បន្ថែមក្លាយជា "ចំណុចសំខាន់នៃការវិភាគភស្តុតាង"[685] សហមេធាវីអះអាងថា ត្រូវតែបំពេញទៅតាមលក្ខខណ្ឌតម្រូវឱ្យមានភស្តុតាងបញ្ជាក់បន្ថែម មុននឹងទទួលយកអង្គហេតុនីមួយៗ ថាមានការបញ្ជាក់ត្រឹមត្រូវ[686]។

---

[677] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៤៨ និងជើងទំព័រ ១១២។

[678] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៤៨ និងជើងទំព័រ ១១៣។

[679] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៤៨ (លុបជើងទំព័រ)។

[680] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៤៨ ជើងទំព័រ ១១៤។

[681] ការឆ្លើយតបរបស់ អោ អាន (D360/11) កថាខណ្ឌ ២៩។

[682] ការឆ្លើយតបរបស់ អោ អាន (D360/11) កថាខណ្ឌ ៣៨ និង ជើងទំព័រ ៧៦។ ទោះបី សហមេធាវីលើកឡើងនូវទឡ្ហីករណ៍ទាំងនេះជាផ្នែកនៃការឆ្លើយតបរបស់ខ្លួននៅក្នុងមូលដ្ឋានទី ៦ ក្តី តែចៅក្រមអន្តរជាតិយល់ឃើញថា ជាការសមរម្យដែលលើកឡើងនូវទឡ្ហីករណ៍ទាំងនេះនៅទីនេះ។

[683] ការឆ្លើយតបរបស់ អោ អាន (D360/11) កថាខណ្ឌ ៣៩។

[684] ការឆ្លើយតបរបស់ អោ អាន (D360/11) កថាខណ្ឌ ៣៩ និងជើងទំព័រ ៧៩។

[685] ការឆ្លើយតបរបស់ អោ អាន (D360/11) កថាខណ្ឌ ៣៩។

[686] ការឆ្លើយតបរបស់ អោ អាន (D360/11) កថាខណ្ឌ ៤០។

## ២. ការពិភាក្សា

៤២៥. ចៅក្រមអន្តរជាតិសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានកំហុសទេ ដែលសំអាងទៅលើភស្តុតាងដែលត្រូវបានចោទប្រកាន់ថាពុំមានការបញ្ជាក់បន្ថែមនោះ[687]។ ជាបឋម ជាបញ្ហាអង្គច្បាប់ ចៅក្រមអន្តរជាតិសម្រេចថា ការបញ្ជាក់បន្ថែមទៅលើភស្តុតាងពុំមែនជាលក្ខខណ្ឌតម្រូវទេ ទោះបីវាជាកត្តាមួយក្នុងចំណោមកត្តាសំខាន់ជាច្រើន ក្នុងការវាយតម្លៃពីភាពជឿជាក់នៃភស្តុតាងក៏ដោយ។ ទីពីរ សហមេធាវីពុំបានបង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបំពេញកិច្ចមិនត្រឹមត្រូវ ក្នុងការសំអាងទៅលើភស្តុតាងពីសាក្សីដែលពុំមានការបញ្ជាក់បន្ថែម ដូចបានអះអាងនោះ។

៤២៦. ទីមួយ ចៅក្រមអន្តរជាតិរម្លឹកថា "ភស្តុតាងទាំងអស់សុទ្ធតែអាចទទួលយកបាន ហើយជាទូទៅទទួលបាននូវសច្ចធារណ៍នៃភាពជឿជាក់បាន" ហើយថា "លក្ខណៈវិនិច្ឆ័យតែមួយគត់ គួរតែជាឥទ្ធិពលដែលខ្លឹមសារនៃភស្តុតាងនោះអាចមានទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងបញ្ហាថា តើមានភស្តុតាងគ្រប់គ្រាន់ឬអត់ សម្រាប់ការចោទប្រកាន់នោះ"[688]។ ចៅក្រមអន្តរជាតិបញ្ជាក់ថា ពុំមានលក្ខខណ្ឌតាមផ្លូវច្បាប់ដែលថា ភស្តុតាងរបស់សាក្សីស្តីពីអង្គហេតុជាក់ស្តែងចាំបាច់ត្រូវតែមានការបញ្ជាក់បន្ថែមដោយភស្តុតាងពីប្រភពផ្សេងទៀត[689] នោះឡើយ ហើយថា ភស្តុតាងដែលពុំមានការបញ្ជាក់បន្ថែមពីសាក្សីតែម្នាក់អាចគាំទ្រដល់ការសម្រេចពីពិរុទ្ធភាពបាន ទោះបីនៅក្នុងដំណាក់កាលជំនុំជម្រះក៏ដោយ[690]។ ទោះបីសហមេធាវីលើកឡើងថា បទដ្ឋាននៃ "ភស្តុតាងមានលក្ខណៈខ្លាំងក្លា និងស៊ី

---

[687] ទោះជាយ៉ាងណាក្តី ចៅក្រមអន្តរជាតិកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការកំណត់ឋានានុក្រមនៃការវាយតម្លៃភស្តុតាង និងអាចស្វែងរកការបញ្ជាក់បន្ថែមចំពោះភស្តុតាងក្រៅពីកំណត់ស្តាប់ចម្លើយដែលរៀបចំដោយ ក.ស.ច.ស និងប្រតិចារឹកជំនុំជម្រះនៅ អ.វ.ត.ក។ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ១៣០។

[688] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៥១ ដល់ ៥២។

[689] ចៅក្រមអន្តរជាតិសង្កេតឃើញថា វិធាន ៦៧ នៃវិធានផ្ទៃក្នុងមិនតម្រូវឲ្យមានការបញ្ជាក់បន្ថែមទៅលើភស្តុតាង ក្នុងការចេញដីកាបញ្ជូនទៅជំនុំជម្រះទេ។ *សូមមើលផងដែរ* សាលដីកាសំណុំរឿង ០០២/១ (F36) កថាខណ្ឌ ៤២៤ ("ពុំមានវិធានទូទៅណាមួយចែងថា ប្រសិនបើពុំមានភស្តុតាងច្រើនគាំទ្រការយល់ឃើញទេនោះ ការយល់ឃើញឲ្យហួសពីវិមតិសង្ស័យមួយ ពុំអាចត្រូវបានធ្វើឡើងដោយសមហេតុផលបានឡើយ")។ សាលដីកាក្នុង *រឿងក្តី* Taylor (SCSL) កថាខណ្ឌ ៧៥។ តុលាការ ICTR *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Nahimana និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ICTR-99-52-A សាលដីការបស់សាលាឧទ្ធរណ៍ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧ ("សាលដីកាក្នុង *រឿងក្តី Nahimana* (ICTR) ជើងទំព័រ ១៣១២ (ប្រមូលសំណុំរឿងនៅតុលាការ ICTR និងសំណុំរឿងនៅតុលាការ ICTY ដែលសម្រេចដូចគ្នា)។

[690] សាលដីកាក្នុង *រឿងក្តី* Tadić (ICTY) កថាខណ្ឌ ៦៥-៦៦ (បញ្ជាក់អំពីការផ្តន្ទាទោសចំពោះអំពើឃាតកម្មទៅលើមន្ត្រីនគរបាលពីររូប ដែលផ្អែកផ្តាច់មុខទៅលើសក្ខីកម្មដែលគ្មានការបញ្ជាក់បន្ថែមរបស់សាក្សីតែម្នាក់)។ តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា ទល់*

សង្ខាក់គ្រប់គ្រាន់” យោងទៅការបញ្ជាក់បន្ថែមក៏ដោយ ក៏ចៅក្រមអន្តរជាតិយល់ឃើញថា ការយោងទៅ “ភស្តុតាងដែលមានការបញ្ជាក់បន្ថែម” នៅទីនេះ លើកឡើងនូវទស្សនៈថាតើ *មាន ឬមិនមានមូលដ្ឋានរួមនៃភស្តុតាងដើម្បីគាំទ្រដល់បទចោទជាមូលដ្ឋាន* ពុំមែនថាតើសេចក្តីសន្និដ្ឋានជាក់ស្តែងត្រូវបានគាំទ្រដោយភស្តុតាងពីរ ឬច្រើននោះឡើយ។ ទោះជាមានការលើកឡើងយ៉ាងនោះក្តី ទោះបីពុំតម្រូវឱ្យមានការបញ្ជាក់បន្ថែមក៏ដោយ តែអង្គហេតុដែលថា សក្ខីកម្មរបស់សាក្សីត្រូវបានបញ្ជាក់បន្ថែមដោយភស្តុតាងផ្សេងទៀត អាចជាកត្តាសំខាន់ក្នុងការវាយតម្លៃអំពីភាពជឿជាក់បាននៃសក្ខីកម្មនោះ[691]។

៤២៧. ដោយហេតុថា តម្លៃជាភស្តុតាងពឹងផ្អែកលើកត្តាជាច្រើននោះ ចៅក្រមអន្តរជាតិមិនបានកំណត់លក្ខខណ្ឌដាច់ណាត់ដែលថា ភស្តុតាងពីសាក្សីនានាដែលត្រូវបានជំទាស់ថា “មិនអាចទុកចិត្តបាន” ត្រូវមានការបញ្ជាក់បន្ថែម ដូចដែលសហមេធាវីបានលើកឡើងនោះទេ[692]។ ក្នុងការវាយតម្លៃទៅលើភស្តុតាង សហចៅក្រមស៊ើបអង្កេតអាចអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនបានផ្អែកលើករណីជាក់ស្តែងនីមួយៗ និងសន្និដ្ឋានថាចាំបាច់ត្រូវមានភស្តុតាងដែលមានការបញ្ជាក់បន្ថែម មុននឹងទទួលយកថា អង្គហេតុនីមួយៗមានការគាំទ្រគ្រប់គ្រាន់[693]។ នាពេលនេះ ចៅក្រមអន្តរជាតិសូមផ្តោតទៅលើការជំទាស់ជាក់លាក់របស់សហមេធាវី ដូច

---

*នឹង Haradinaj និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-04-84-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ (“សាលដីកាក្នុង*រឿងក្តី* Haradinaj (ICTY)”) កថាខណ្ឌ ២១៩ (សន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសទេក្នុងការសំអាងទៅលើភស្តុតាងរបស់សាក្សីដោយមិនតម្រូវឱ្យមានការបញ្ជាក់បន្ថែម ទោះបីសក្ខីកម្មនោះផ្ទុយពីភស្តុតាងរបស់សាក្សីម្នាក់ទៀតក៏ដោយ)។

[691] *សូមមើលឧទាហរណ៍* សាលដីកាក្នុង*រឿងក្តី* Kupreškić (ICTY) កថាខណ្ឌ ២២០។ តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Limaj និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-03-66-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧ (“សាលដីកាក្នុង*រឿងក្តី* Limaj (ICTY)”) កថាខណ្ឌ ២០៣។ តុលាការ ICTR *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង* Ntawukulilyayo សំណុំរឿងលេខ ICTR-05-82-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ កថាខណ្ឌ ២១។ តុលាការ ICTR *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Kayishema នឹង Ruzindana* សំណុំរឿងលេខ ICTR-95-1-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ (“សាលក្រមក្នុង*រឿងក្តី Kayishema នឹង Ruzindana* (ICTR)”) កថាខណ្ឌ ៨០។ តុលាការ ICC *ស្ថានភាពនៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោនៅក្នុង រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo* សំណុំរឿងលេខ ICC-01/04-01/06-803-tEN សេចក្តីសម្រេចលើការបញ្ជាក់ពីបទចោទ អង្គបុរេជំនុំជម្រះ I ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៧ (“សេចក្តីសម្រេចលើការបញ្ជាក់ពីបទចោទក្នុង*រឿងក្តី* Lubanga (ICC)”) កថាខណ្ឌ ១២១-១២២។

[692] ជាងនេះទៀត ដូចពន្យល់លម្អិតខាងក្រោម ចៅក្រមអន្តរជាតិមិនជឿថា រឿងរ៉ាវទាំងនោះ “ពុំមានការបញ្ជាក់បន្ថែម” នោះទេ។

[693] *សូមមើល* តុលាការ ICTR *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង* Gacumbitsi សំណុំរឿងលេខ ICTR-2001-64-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៦ (“សាលដីកាក្នុង*រឿងក្តី* Gacumbitsi (ICTR)”) កថាខណ្ឌ ១១៥។ សាលដីកាក្នុង*រឿងក្តី* Limaj (ICTY) កថាខណ្ឌ ២០៣។

បានលើកឡើងនៅក្នុងមូលដ្ឋានទី ៥(៤)។

៤២៨. ទីពីរ ចៅក្រមអន្តរជាតិពុំជឿថា សហមេធាវីបានបង្ហាញអំពីកំហុសរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលសំអាងខ្លាំងពេកទៅលើភស្តុតាងដែលពុំមានការបញ្ជាក់បន្ថែមនោះទេ។ ទោះបីការអះអាងរបស់សហមេធាវីដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសំអាងជាប្រព័ន្ធទៅលើសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី "តែមួយ មិនមានការបញ្ជាក់បន្ថែម"[694] ក៏ដោយ តែចៅក្រមអន្តរជាតិសន្និដ្ឋានថាចម្លើយជាច្រើនដែលត្រូវបានជំទាស់ ត្រូវបានបញ្ជាក់បន្ថែមដោយភស្តុតាងផ្សេងទៀត ទោះទាំងមូលក្តី ឬមួយផ្នែកក្តី[695]។ ជាងនេះទៀត ចៅក្រមអន្តរជាតិសង្កេតឃើញថា ដំណើររឿងមួយចំនួនក្នុងចំណោមដំណើររឿងផ្សេងទៀតដែលសាក្សីបានរៀបរាប់នោះ គឺបង្ហាញអំពីព្រឹត្តិការណ៍ពិសេស[696] ឬបង្ហាញពី

---

[694] ចៅក្រមអន្តរជាតិកត់សម្គាល់ថា រឿងរ៉ាវមួយចំនួនរបស់សាក្សី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានជំទាស់ គឺថា រឿងរ៉ាវរបស់ ញ៉ែម ចេន, ប្រាក់ យុត, ពេញ វ៉ា, យូ វ៉ាន់ និង ជុំ វង្ស ត្រូវបានសម្រេចថាអាចទុកចិត្តបានជាទូទៅនៅក្នុងមូលដ្ឋានទី ៥(ii)។

[695] ចៅក្រមអន្តរជាតិបានពិនិត្យយ៉ាងល្អិតល្អន់ទៅលើឧទាហរណ៍នីមួយៗដែលសហមេធាវីបានលើកឡើងនៅក្នុងមូលដ្ឋានទី ៥(iv) និងសន្និដ្ឋានថាឧទាហរណ៍ទាំងនោះពុំមានមូលដ្ឋានទេ។ ហេតុនេះ ចៅក្រមអន្តរជាតិផ្តល់ឧទាហរណ៍មួយអំពីចម្លើយមួយដែលត្រូវបានបញ្ជាក់បន្ថែម ឬបញ្ជាក់បន្ថែមមួយផ្នែក បន្ទាប់មកចៅក្រមអន្តរជាតិគូសបញ្ជាក់នៅក្នុងជើងទំព័របន្តបន្ទាប់នូវឧទាហរណ៍ដែលមិនមានមូលដ្ឋាន ដោយសារសំអាងហេតុផ្សេងទៀត។ *សូមមើលឧទាហរណ៍* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៥៦៤ ជើងទំព័រ ១៩០៧ (ក្រៅពីការដកស្រង់ពីកំណត់ហេតុស្តាប់ចម្លើយរបស់ គួយ មៀច (D219/582) ដែលលើកឡើងថា ទាហានរបស់ អោ អាន បានឈរជើងនៅវត្តតាមាក់ ហើយថា អោ អាន បានបញ្ជាក់ឲ្យកូនចៅគាត់ចាប់ខ្លួន និងសម្លាប់អ្នកជាប់ឃុំ សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏បានយោងទៅភស្តុតាងផ្សេងនៅក្នុងកថាខណ្ឌដដែលនោះដែរ ដើម្បីបញ្ជាក់បន្ថែមចំពោះការសន្និដ្ឋានដែលថា អោ អាន បានគ្រប់គ្រងទៅលើមន្ទីរសន្តិសុខវត្តតាមាក់ *ឧទាហរណ៍* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D219/504 នៅត្រង់ ERN 01146379 (ឆ.៦៦) ("ខ្ញុំគិតថា តាអាន ប្រាកដជាមានជាប់ពាក់ព័ន្ធ ដោយសារតែយោធាថ្នាក់តំបន់ ត្រូវបានគេចាត់តាំងឲ្យទៅយាមមន្ទីរសន្តិសុខ [វត្តតាមាក់] នោះ"។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី សូ សារ៉េន ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ D219/837 នៅត្រង់ ERN 01335583 (ឆ.៦៦) (ពន្យល់ថា "មានតែ តាអាន ហ្នឹង" ដែលបញ្ជាឲ្យចាប់ខ្លួនសាក្សីនៅវត្តតាមាក់)។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ពេញ វ៉ា ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ឯកសារ D219/226 នៅត្រង់ ERN 01075657 (ឆ.១២) ("គឺច្បាស់ជាមិត្ត អាន ហើយព្រោះគាត់ជាប្រធានតំបន់៤១ [...] នេះជាបែបបទការងារនៅសម័យនោះ")។

[696] *សូមមើលឧទាហរណ៍* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ២៧១ ជើងទំព័រ ៧០២ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិដកស្រង់ភស្តុតាងរបស់ គួ សេម ដែលលើកឡើងថា អោ អាន បានបញ្ជូនអតីតអនុលេខារបស់គាត់ឈ្មោះ ស៊ឹម ឲ្យទៅដឹកនាំការសាងសង់ទំនប់ ៦ មករា ជាឧទាហរណ៍មួយដែលបង្ហាញពីការបញ្ជូនកម្មករ និងធនធានពីតំបន់ ៤១ ទៅការដ្ឋានទំនប់នៅក្រៅតំបន់ ៤១។ ក្នុងនាមជាប្រពន្ធរបស់ ស៊ឹម មានហេតុផលដែលជឿថា គួ សេម មានការដឹងជាពិសេសអំពី

កម្រិតខ្ពស់នៃព័ត៌មានលម្អិតជាក់លាក់[697] ដែលអនុញ្ញាតឱ្យអ្នកវិនិច្ឆ័យលើអង្គហេតុមិនលម្អៀងអាចធ្វើការសន្និដ្ឋានយ៉ាងត្រឹមត្រូវ នៅក្នុងដំណាក់កាលចេញដីកាដំណោះស្រាយបាន។ ទាក់ទិននឹងសំអាងហេតុខាងលើ និងការខកខានរបស់សហមេធាវីក្នុងការពន្យល់លម្អិតអំពីកំហុសជាក់លាក់ពីការវាយតម្លៃភស្តុតាងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចៅក្រមអន្តរជាតិសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានកំហុសពាក់ព័ន្ធនឹងចំណុចនេះទេ។ ចៅក្រមអន្តរជាតិសូមបដិសេធមូលដ្ឋានទី ៥(៤)។

## មូលដ្ឋានទី៥(v). ការចោទប្រកាន់ចំពោះកំហុសនៃការសំអាងលើភស្តុតាងចចាមអារ៉ាម

### ១. សារណា

៤២៩. យោងតាមមូលដ្ឋានទី៥ សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានប្រុងប្រយ័ត្នចំពោះការសំអាងលើភស្តុតាងចចាមអារ៉ាម រួមទាំង ពីប្រភពអនាមិក[698] នៅពេលធ្វើការសម្រេចលើអង្គហេតុ ពាក់ព័ន្ធនឹងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ចំពោះ អោ អាន[699]។ ទោះបីជាទទួលស្គាល់ថា

---

ការងារ និងការទទួលខុសត្រូវរបស់ ស៊ឹម ហាក់ដូចជាពួកគាត់រស់នៅបែកគ្នា និងបានជួបគ្នាម្តងម្កាល។ *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី តូ សេម ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៤ ឯកសារ D117/39 នៅត្រង់ ERN 00993585 (ឆ.១០) ("យោងទៅតាមការដឹងរបស់ខ្ញុំ [ស៊ឹម] បានដឹកនាំប្រជាជនឱ្យធ្វើទំនប់ ជីកប្រឡាយ បង្កបង្កើនផល ដើម្បីឱ្យប្រជាជនមានម្ហូបអាហារគ្រប់គ្រាន់។ ឧទាហរណ៍ គាត់បានដឹកនាំប្រជាជនឱ្យកសាងទំនប់ ៦ មករា")។

[697] *សូមមើលឧទាហរណ៍* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៦៨០ ជើងទំព័រ ២៣៣៣ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិយោងទៅលើភស្តុតាងរបស់ ទូច ចំរើន ជាឧទាហរណ៍មួយនៃអាពាហ៍ពិពាហ៍ដោយបង្ខំនៅស្រុកព្រៃឈរ។ សាក្សីបានរៀបរាប់ថាគាត់ត្រូវបានគេនាំទៅតំបន់ ៤១ តាមកាណូតដោយមនុស្សពីរនាក់ដែលមានអាវុធ បេ៤០ មួយដើម និងកាំភ្លើងអាកាមួយដើម។ បុរសទាំងពីរនាក់ដែលមានអាវុធបាននាំ ទូច ចំរើន ទៅមន្ទីររបស់ អោ អាន ដែលនៅទីនោះ គាត់បានឃើញ អោ អាន ឱ្យគាត់រៀបការជាមួយប្រធានអង្គភាពភស្តុភារ។ អោ អាន ធ្វើជាអធិបតីក្នុងការរៀបការនៅថ្ងៃបន្ទាប់។ ទូច ចំរើន ពន្យល់ថា គាត់ "មិនសប្បាយចិត្តទេ" តែមិនហ៊ានប្រកែកព្រោះគាត់ខ្លាចគេសម្លាប់គាត់។ ក្នុងពេលពិធីរៀបការ ប្រពន្ធរបស់ ទូច ចំរើន មិននិយាយអ្វីទាំងអស់។ *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ទូច ចំរើន ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ D219/435 នៅត្រង់ ERN 01124165 (ឆ.២៩-ឆ.៣០), 01124166 (ឆ.៣៧-ឆ.៤១), 01124170 (ឆ.៧៧-ឆ.៧៨), 01124184 (ឆ.២២៦-ឆ.២២៧, ឆ.២៣០)។ ចៅក្រមអន្តរជាតិយល់ឃើញថា ជាការសមហេតុផលដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិសំអាងទៅលើរឿងរ៉ាវលម្អិតនេះ)។

[698] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧៨ *យោងលើ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)(ឯកសារ D360) កថាខណ្ឌ ២១៧ លេខយោងជើងទំព័រ ៤៩៩ កថាខណ្ឌ ២៥៦ លេខយោងជើងទំព័រ ៦៣៣ កថាខណ្ឌ ៦៣៣ លេខយោងជើងទំព័រ ២១៥៥ កថាខណ្ឌ ២៥២ លេខយោងជើងទំព័រ ៦២០។

[699] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧៨ *ដែលយោងទៅលើ* ដីកាដំណោះស្រាយ (ដីកាបញ្ជូន

ភស្តុតាងចចាមអារ៉ាមអាចទទួលយកមកពិចារណាក៏ដោយ ក៏សហ មេធាវីអះអាងថា ភស្តុតាងបែបនេះគួរផ្តល់តម្លៃភស្តុតាងទាប ហើយ "ចាំបាច់ត្រូវមានការ ប្រុងប្រយ័ត្នក្នុងការវាយតម្លៃលើភស្តុតាងនេះ"[700]។ ពាក់ព័ន្ធនឹងភស្តុតាងចចាមអារ៉ាមត្រួតគ្នា និងភស្តុតាងចចាមអារ៉ាមពីប្រភពអនាមិកវិញ សហមេធាវីអះអាងថា អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ភស្តុតាងប្រភេទបែបនេះ "មិនអាចបង្កើតបានជាធាតុផ្សំនៃបទល្មើស ឬ ទម្រង់នៃការទទួលខុសត្រូវហួសពីវិមតិសង្ស័យបានឡើយ"[701]។ សហមេធាវីពិចារណាឃើញថា ទោះបីជាបទដ្ឋាននៃភស្តុតាងមានលក្ខណៈទាបជាងនៅដំណាក់កាលដីកាដំណោះស្រាយក៏ដោយ ក៏បទដ្ឋាននេះត្រូវអនុវត្តដូចគ្នានៅដំណាក់កាលជំនុំជម្រះ នៅពេលសម្រេចលើភាពគ្រប់គ្រាន់នៃភស្តុតាងប្រភេទនេះចំពោះយុត្តាធិការបុគ្គល ឬ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ[702]។

៤៣០. សហព្រះរាជអាជ្ញាអន្តរជាតិឆ្លើយតបថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានប្រុងប្រយ័ត្នយ៉ាងត្រឹមត្រូវចំពោះការសំអាងលើភស្តុតាងចចាមអារ៉ាម ហើយបានពិពណ៌នាលម្អិតយ៉ាងច្បាស់ៗចំពោះកត្តាដែលខ្លួនបានពិចារណានៅពេលវាយតម្លៃលើតម្លៃនៃភស្តុតាង[703]។ យោងតាមសហព្រះ រាជអាជ្ញាអន្តរជាតិ ការលើកឡើងរបស់សហមេធាវីថា ភស្តុតាងចចាមអារ៉ាមគួរទទួលបានតម្លៃជាភស្តុតាងតិចជាងជាងនោះ មិនត្រឹមត្រូវនោះទេ ដោយហេតុថាទម្ងន់ដែលត្រូវផ្តល់ទៅឲ្យភ័ស្តុតាងចចាមអារ៉ាម គឺអាស្រ័យលើខ្លឹមសារនៃភស្តុតាង និងកាលៈទេសៈនៅជុំវិញនោះ[704]។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងបន្ថែមទៀតថា ភស្តុ

---

រឿងទៅជំនុំជម្រះ)(ឯកសារ D360) កថាខណ្ឌ ២៥៦ លេខយោងជើងទំព័រ ៦៣៣ កថាខណ្ឌ ២៥៦ លេខយោងជើងទំព័រ ៦៣៦ កថាខណ្ឌ ២៥៧ លេខយោងជើងទំព័រ ៦៤០ កថាខណ្ឌ ២៥៨ លេខយោងជើងទំព័រ ៦៤២ កថាខណ្ឌ ៣១៦ លេខយោងជើងទំព័រ ៨៣៩ កថាខណ្ឌ ៦៣៣ លេខយោងជើងទំព័រ ២១៥២, ២១៥៦, ២១៥៧, ២១៥៩, ២១៦១ កថាខណ្ឌ ៣០០ លេខយោងជើងទំព័រ ៧៩៩ កថាខណ្ឌ ២៥៩ លេខយោងជើងទំព័រ ៦៥៣ កថាខណ្ឌ ២៦៧ លេខយោងជើងទំព័រ ៦៨០ កថាខណ្ឌ ៣៣០ លេខយោងជើងទំព័រ ៩០៦។ *សូមមើលផងដែរ* សំណុំរឿង ០០៤/២ ប្រតិចារឹក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 001626066 ទំព័រ ១២:០១-១២:០៣ ERN 001626070 ទំព័រ ១៦:០៤-១៦:១៣។

[700] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧៨។

[701] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧៨ *ដែលយោងទៅលើ* សាលដីកាសំណុំរឿង ០០២/១ (ឯកសារ F36) កថាខណ្ឌ ៤៤១-៤៤២។

[702] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧៨។

[703] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៤៩ *ដែលយោងទៅលើ* ដីកាដំណោះស្រាយ (ដីកសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ១២៩-១៣០។

[704] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៤៩ *ដែលយោងទៅលើ* សាលដីកា *Popvić និងអ្នកផ្សេងទៀត* (តុលាការ ICTY) កថាខណ្ឌ ១៣០៧។ តុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញាទល់នឹង Aleksovski* IT-95-14/1-A សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញាស្តីពីភាពអាចទទួលយកបាននៃភស្តុតាង អង្គជំនុំជម្រះ

តាងចចាមអារ៉ាមភាគច្រើនដែលសំអាងដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិគឺជាភស្តុតាងដើមមានប្រភពរបស់វា ហើយទោះក្នុងករណីណាក៏ដោយ ទោះបីជាភស្តុតាងគ្មានប្រភព ឬ កម្រិតទី២ ក៏អាចសំអាងលើបានដែរ ប្រសិនបើការសំអាងនោះធ្វើឡើងដោយប្រុងប្រយ័ត្ន[705]។ ម្យ៉ាងវិញទៀត សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា ឧទាហរណ៍ចំនួនពីរដែលសហមេធាវីបានលើកឡើង មិនមានភស្តុតាងចចាមអារ៉ាមដែលពួកគេបានរៀបរាប់នោះទេ[706] ទោះបីការជំទាស់ជាច្រើនដែលនៅសល់មិនមានផលប៉ះពាល់នោះដោយសារតែភស្តុតាងចចាមអារ៉ាមគ្រាន់តែផ្ដល់នូវការបញ្ជាក់បន្ថែមទៀតទៅលើភស្តុតាងផ្ទាល់ និងភស្តុតាងប្រយោលដែលគ្រប់គ្រាន់សម្រាប់ការគាំទ្រដល់ការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិប៉ុណ្ណោះ[707]។

៤៣១. សហមេធាវីឆ្លើយតបថា សហព្រះរាជអាជ្ញាអន្តរជាតិបានបកស្រាយមិនត្រឹមត្រូវលើទឡ្ហីករណ៍របស់ពួកគេពាក់ព័ន្ធនឹងភស្តុតាងចចាមអារ៉ាម ដោយបានគូសបញ្ជាក់ថា ទោះបីជាភស្តុតាងចចាមអារ៉ាមអាចទទួលយកបានក៏ដោយ ភស្តុតាងទាំងនេះត្រូវពិនិត្យដោយប្រុងប្រយ័ត្ន[708]។ យោងតាមសហមេធាវី

---

តុលាការកំពូល ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ១៩៩៩ ("សាលដីកា *Aleksovski* ស្ដីពីភាពអាចទទួលយកបាននៃបណ្ដឹងសាទុក្ខលើភស្តុតាង (តុលាការ ICTY)") កថាខណ្ឌ ១៥។

[705] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៥២ លេខយោងជើងទំព័រ ១២៥ (ពិភាក្សាយុត្តិសាស្ត្ររបស់តុលាការ ICTY តុលាការ ICTR តុលាការ ICC និងអង្គជំនុំជម្រះតុលាការកំពូល)។ ចៅក្រមអន្តរជាតិ កត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាអន្តរជាតិលើកនូវទឡ្ហីករណ៍ទាំងនេះជាផ្នែកនៃចម្លើយតបរបស់ខ្លួនទៅនឹងមូលដ្ឋានទី៦ ប៉ុន្តែយល់ឃើញថា វាសមស្របក្នុងការឆ្លើយតបទៅនឹងអំណះអំណាងទាំងនេះពាក់ព័ន្ធនឹងភស្តុតាងចចាមអារ៉ាម នៅត្រង់ចំណុចនេះ។ ចៅក្រមអន្តរជាតិយល់ឃើញថា ភស្តុតាងចចាមអារ៉ាម "ដែលមានប្រភព" សំដៅលើចម្លើយដែលបានផ្ដល់ជូននៅក្រៅតុលាការពីប្រភពដែលបានអត្តសញ្ញាណ រីឯភស្តុតាងចចាមអារ៉ាម "គ្មានប្រភព" គឺជាចម្លើយដែលផ្ដល់ជូននៅក្រៅតុលាការពីប្រភពដែលមិនបានបញ្ជាក់អត្តសញ្ញាណ។ ភស្តុតាងចចាមអារ៉ាម "កម្រិតទី១" សំដៅលើចម្លើយនៅក្រៅតុលាការដែលផ្ដល់ជូនដោយរូបវន្តបុគ្គលដែលបានដឹងដោយផ្ទាល់អំពីអង្គហេតុដែលខ្លួនបានអះអាង ចំណែកភស្តុតាងចចាមរ៉ាម "កម្រិតទី២" (ឬហៅម្យ៉ាងទៀត ភស្តុតាងចចាមរ៉ាម "ត្រួត") សំដៅលើការអះអាងរបស់អ្នកផ្សេងនៅក្នុងចម្លើយដែលផ្ដល់ជូនក្រៅតុលាការ។

[706] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៤៩ លេខយោងជើងទំព័រ ១១៧។

[707] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៤៩ លេខយោងជើងទំព័រ ១១៨។

[708] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៣៥។ ទោះបីជាសហមេធាវីលើកអំណះអំណាចទាំងនេះជាផ្នែកនៃចម្លើយតបរបស់ពួកគេក្រោមមូលដ្ឋានទី៦ក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា វាជាការសមស្របក្នុងការឆ្លើយតបទៅ

01634983



ជំហររបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលលើកឡើងថា ភស្តុតាងចចាមអារ៉ាមមានតម្លៃភស្តុតាងស្មើគ្នាដូចភស្តុតាងផ្ទាល់ដែលសំអាងលើការដឹងរបស់បុគ្គលផ្ទាល់គឺផ្ទុយទៅនឹងយុត្តិសាស្ត្រ[709]។ តាមការចោទប្រកាន់ សហមេធាវីគូសបញ្ជាក់ឧទាហរណ៍ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានក្នុងការអនុវត្តលក្ខខណ្ឌនៃការប្រុងប្រយ័ត្ន[710]។

## ២. ការពិភាក្សា

៤៣២. ចៅក្រមអន្តរជាតិយល់ឃើញថា សហមេធាវីខកខានក្នុងការបង្ហាញកំហុសនៅក្នុងវិធីសាស្ត្ររួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិចំពោះភស្តុតាងចចាមអារ៉ាម។ នៅពេលឈានដល់ការសន្និដ្ឋាននេះ អង្គជំនុំជម្រះសូមឆ្លើយតបទៅនឹងទឡ្ហីករណ៍ផ្លូវច្បាប់របស់ភាគីស្តីពីការវាយតម្លៃលើភស្តុតាងចចាមអារ៉ាមជាមុនសិន មុនពេលបន្តទៅពិនិត្យកំហុសនៃការសំអាងលើភស្តុតាងចចាមអារ៉ាម ដូចបានអះអាង ដែលបានប្រព្រឹត្តឡើងដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

៤៣៣. យុត្តិសាស្ត្របង្ហាញច្បាស់ ហើយភាគីក៏ពុំបានតវ៉ា[711]ដែលថា ភស្តុតាងចចាមអារ៉ាមអាចទទួលយកបាន និងអាចសំអាងលើបាន[712]។ ជាក់ស្តែង សហចៅក្រមស៊ើបអង្កេតអន្តរជាតិមាន "ឆន្ទានុសិទ្ធិ" ទូលំទូលាយក្នុងការសំអាងលើភស្តុតាងចចាមអារ៉ាម[713]។ តម្លៃនៃភស្តុតាងចចាមអារ៉ាម មិនខុសពីភស្តុតាង

---

នឹងអំណះអំណាងទាំងនេះនៅក្រោមមូលដ្ឋានទី៥(v) នេះ។

[709] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៣៦ *ដែលយោងទៅលើ*ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៥២ លេខយោងជើងទំព័រ ១២៥ និងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧៨ លេខយោងជើងទំព័រ ១៧៥។

[710] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៣៥។

[711] *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧៨។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៤៩។

[712] សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ៤៥។ សំណុំរឿង ០០២/១ សាលដីកា (ឯកសារ F36) កថាខណ្ឌ ៣០២។ សាលដីកា *Aleksovski* ស្តីពីភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខលើភស្តុតាង (តុលាការ ICTY) កថាខណ្ឌ ១៥។ សាលដីកា *Rutaganda* (តុលាការ ICTR) កថាខណ្ឌ ៣៤, ១៤៨។ តុលាការ ICC *ស្ថានការណ៍នៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោនៅក្នុងរឿងក្តី រដ្ឋអាជ្ញា ទល់នឹង Mathieu Ngudjolo, ICC-01/04-02/12-3-tENG* សាលក្រមអនុលោមតាមមាត្រា ៧៤ នៃលក្ខន្តិកៈ អង្គជំនុំជម្រះសាលាដំបូងទី II ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១២ កថាខណ្ឌ ៥៦។

[713] សំណុំរឿង ០០២/១ សាលដីកា (ឯកសារ F36) កថាខណ្ឌ ៣០២។ សាលដីកា *Popvić និងអ្នកផ្សេងទៀត* (តុលាការ ICTY)"

គ្រប់ទម្រង់ទាំងអស់ មានលក្ខណៈខុសគ្នាដោយផ្អែកលើលក្ខណៈ និងខ្លឹមសារ ហើយនៅចុងក្រោយ "អាស្រ័យទៅតាមកាលៈទេសៈផ្សេងៗដែលកើតមានជុំវិញភស្តុតាងចចាមអារ៉ាមនោះ"[714]។ ចៅក្រមអន្តរជាតិសម្រេចថា សហមេធាវីត្រូវមានកាតព្វកិច្ចបង្ហាញឲ្យឃើញថា គ្មានអ្នកវិនិច្ឆ័យលើអង្គហេតុដ៏សមហេតុផលណាមួយ អាចសំអាងលើភស្តុតាងចចាមអារ៉ាមដើម្បីឈានទៅធ្វើការសម្រេចជាក់លាក់នោះទេ[715]។

៤៣៤. ទោះបីជាសហមេធាវីអះអាងថា យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលហាមឃាត់ការប្រើប្រាស់ភស្តុតាងចចាមអារ៉ាមត្រួតគ្នា ឬ អនាមិក ដើម្បីបង្ហាញសំអាងហេតុឲ្យហួសពីវិមតិសង្ស័យក៏ដោយ[716] ក៏ចៅក្រមអន្តរជាតិសូមរំលឹកឡើងវិញដូចសហមេធាវីអះអាងយ៉ាងត្រឹមត្រូវ[717]ថា បទដ្ឋាននៃការបង្ហាញភស្តុតាងនៅដំណាក់កាលនៃដីកាដំណោះស្រាយគឺមានលក្ខណៈទាបជាងនៅដំណាក់កាលជំនុំជ

---

កថាខណ្ឌ ១៣០៧។ សាលដីកា *Rutaganda* (តុលាការ ICTR) កថាខណ្ឌ ៣៤។ តុលាការ ICTR រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karera*, ICTR-01-74-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៩ ("សាលដីកា *Karera* (តុលាការ ICTR)") កថាខណ្ឌ ៣៩។

[714] សំណុំរឿង ០០២/១ សាលដីកា (ឯកសារ F36) កថាខណ្ឌ ៣០២។ សាលដីកា *Aleksovski* ស្តីពីភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខលើភស្តុតាង (តុលាការ ICTY) កថាខណ្ឌ ១៥។ សាលដីកា *Popvić និងអ្នកផ្សេងទៀត* (តុលាការ ICTY) កថាខណ្ឌ ១៣០៧។ សាលដីកា *Karera* (តុលាការ ICTR) កថាខណ្ឌ ៣៩។ តុលាការ ICC *ស្ថានការណ៍នៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោនៅក្នុងរឿងក្តី រដ្ឋអាជ្ញា ទល់នឹង Germain Katanga,* ICC-01/04-01/07-3436-tENG សាលក្រមអនុលោមតាមមាត្រា ៧៤ នៃលក្ខន្តិកៈ អង្គជំនុំជម្រះសាលាដំបូងទី II ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៤ ("សាលក្រម *Katanga* (តុលាការ ICC)") កថាខណ្ឌ ៨៩។

[715] សំណុំរឿង ០០២/១ សាលដីកា (ឯកសារ F36) កថាខណ្ឌ ៣០២ ("*ភាគីម្ចាស់បណ្តឹងសាទុក្ខត្រូវមានកាតព្វកិច្ចបង្ហាញឲ្យឃើញថា ពុំមានអ្នកវិនិច្ឆ័យអង្គហេតុដោយមិនលម្អៀងអាចសំអាងលើ [ភស្តុតាងចចាមអារ៉ាម] ដើម្បីឈានដល់ការធ្វើសេចក្តីសម្រេចជាក់លាក់មួយនោះទេ*")។ សាលដីកា *Karera* (តុលាការ ICTR) កថាខណ្ឌ ១៩៦ ("*ភាគីម្ចាស់បណ្តឹងសាទុក្ខត្រូវមានកាតព្វកិច្ចបង្ហាញឲ្យឃើញថា គ្មានអ្នកវិនិច្ឆ័យអង្គហេតុដោយមិនលម្អៀងណាម្នាក់អាចយកភស្តុតាងចចាមអារ៉ាម មក ពិចារណាដើម្បីឈានដល់ការធ្វើសេចក្តីសម្រេចជាក់លាក់មួយនោះឡើយ*")។ សាលដីកាលើរឿងក្តី *Nahimana* (តុលាការ ICTR) កថាខណ្ឌ ៥០៩ ("*ម្ចាស់បណ្តឹងសាទុក្ខ Nahimana ត្រូវមានកាតព្វកិច្ចបង្ហាញឲ្យឃើញថា គ្មានអ្នកវិនិច្ឆ័យអង្គហេតុដោយមិនលម្អៀងណាម្នាក់អាចយកភស្តុតាងនេះមកពិចារណាបានឡើយ ពីព្រោះវាជាភស្តុតាងចចាមអារ៉ាមកម្រិតទី២ ដែលគាត់ខកខានមិនបានធ្វើដូច្នោះឡើយ*")។

[716] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧៨ *យោងតាម* សាលដីកាសំណុំរឿង ០០២/១ (ឯកសារ F36) កថាខណ្ឌ ៤៤១-៤៤២។

[717] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៧៨។

ម្រះ។ លើសពីនេះទៀត ចៅក្រមអន្តរជាតិសូមរំលឹកឡើងវិញថា “ភស្តុតាងទាំងអស់សុទ្ធតែអាចទទួលយកបាន ហើយជាទូទៅទទួលបាននូវសច្ចធារណ៍នៃភាពអាចជឿជាក់បានតាមផ្លូវច្បាប់ដូចៗគ្នា” ហើយ “លក្ខណៈវិនិច្ឆ័យពាក់ព័ន្ធតែមួយគត់ គួរតែជាឥទ្ធិពលដែលខ្លឹមសារនៃភស្តុតាងនោះអាចមានទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់សហចៅក្រមស៊ើបអង្កេតទាក់ទងទៅនឹងបញ្ហាថាតើមានភស្តុតាងគ្រប់គ្រាន់ឬអត់សម្រាប់ការចោទប្រកាន់នោះ”[718]។ អាស្រ័យហេតុនេះ ចៅក្រមអន្តរជាតិច្រានចោលអំណះអំណាងរបស់សហមេធាវីដែលផ្តល់ទឡ្ហីករណ៍ថា ភស្តុតាងអនាមិក ឬ កម្រិតទី២ យោងតាមច្បាប់ មិនអាចយកមកគាំទ្របទចោទគ្រប់គ្រាន់នោះ[719]។ នៅពេលនេះ ចៅក្រមអន្តរជាតិសូមបែរទៅវាយតម្លៃ ថាតើសហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសដែរឬទេនៅក្នុងវិធីសាស្ត្រទូទៅរបស់ខ្លួនចំពោះភស្តុតាងចចាមអារ៉ាមនោះ។

៤៣៥. ពីដំបូងឡើយ ចៅក្រមអន្តរជាតិសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពន្យល់យ៉ាងច្បាស់ថា គាត់បានយកតាម “ការអនុវត្តដោយប្រុងប្រយ័ត្ន” មួយចំពោះភស្តុតាងចចាមអារ៉ាម ហើយបានរៀបរាប់លម្អិតអំពីកត្តាដែលគាត់បានពិចារណានៅពេលសំអាងលើភស្តុតាងពាក្យចចាមអារ៉ាមដែលមិនមានការបញ្ជាក់[720]។ ទោះបីជាសហមេធាវីបានលើកឡើងឧទាហរណ៍មួយចំនួនបង្ហាញអំពីការអះអាងថាមានការសំអាងហួសហេតុលើភស្តុតាងចចាមអារ៉ាមក៏ដោយ ក៏សហមេធាវីត្រឹមតែអះអាងថា វាគឺជាកំហុស ដោយសហមេធាវីពុំធ្វើការបង្ហាញប្រកបដោយអត្ថន័យថា គ្មានអ្នកវិនិច្ឆ័យលើអង្គហេតុដែលសមហេតុផលណាមួយអាចសំអាងលើភស្តុតាងបែបនេះដើម្បីយកមកគាំទ្រលើសំអាងហេតុដែលចោទជាបញ្ហានោះទេ។ ចៅក្រមអន្តរជាតិ យល់ឃើញថា ការដកស្រង់ទូទៅនូវឧទាហរណ៍នានាដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិសំអាងលើភស្តុតាងចចាមអារ៉ាមនៅក្នុងដីកាដំណោះស្រាយ (ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ) មិនបានបង្ហាញនូវកំហុសជាទូទៅនៅក្នុងវិធីសាស្ត្ររបស់គាត់ដែលអនុវត្តចំពោះភស្តុតាងចចាមអារ៉ាមនោះឡើយ[721]។

---

718 សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ៥១-៥២។

719 *សូមមើលផងដែរ* សាលដីកាលើសំណុំរឿង ០០២/១ (ឯកសារ F36) កថាខណ្ឌ ៣០២។ សាលដីកា *Gacumbitsi* (តុលាការ ICTR) កថាខណ្ឌ ១១៥ ១១៣។ តុលាការ ICTR រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Rukundo,* ICTR-01-70-A សាលដីកាអង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១០ កថាខណ្ឌ ១៩៦។

720 ដីកាដំណោះស្រាយ (ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ១២៩-១៣០។

721 ចៅក្រមអន្តរជាតិកត់សម្គាល់បន្ថែមទៀតថា មានករណីដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានយោងដាក់លាក់លើ

៤៣៦. លើសពីនេះទៀត នៅក្នុងការវាយតម្លៃដោយប្រុងប្រយ័ត្នលើឧទាហរណ៍ដែលបានលើកឡើង ចៅក្រមអន្តរជាតិកត់សម្គាល់ថា ឧទាហរណ៍ខ្លះពុំបានសំអាងលើចម្លើយចចាមអារ៉ាមដូចបានចោទប្រកាន់នោះទេ[722]។ នៅក្នុងឧទាហរណ៍ផ្សេងទៀត ភស្តុតាងចចាមអារ៉ាមត្រូវបានគាំទ្រដោយភស្តុតាងផ្ទាល់ និងភស្តុតាងប្រយោលដែលដែលមានតម្លៃជាភស្តុតាងពីសាក្សីផ្សេងៗទៀតដែលវាស៊ីសង្វាក់គ្នាទៅវិញទៅមកជាមួយនឹងអង្គហេតុដែលចោទជាបញ្ហាទាំងនេះ[723]។ នៅក្នុងឧទាហរណ៍ផ្សេងទៀត កាលៈទេសៈ និងខ្លឹមសារនៃភស្តុតាងចចាមអារ៉ាមដែលចោទជាបញ្ហានេះ មានតម្លៃគ្រប់គ្រាន់អាចឲ្យអ្នកវិនិច្ឆ័យលើអង្គហេតុ

---

លក្ខណៈចចាមអារ៉ាមនៃភស្តុតាង ហើយបដិសេធធ្វើការសម្រេចលើអង្គហេតុតាមការបង្ហាញដោយភស្តុតាងនោះ។ *សូមមើល* ដីកាដំណោះស្រាយ (ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៣៣៩, ៤៤៨។

[722] *ឧទា.* សូមមើលដីកាដំណោះស្រាយ (ដីកាសម្រេចបញ្ជូនរឿងទៅជំនុំចម្រះ) (ឯកសារ D360) កថាខណ្ឌ ២១៧ លេខយោងជើងទំព័រ ៤៩៩ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសំអាងលើភស្តុតាងរបស់ ញ៉ែម ចេន (ឯកសារ D219/855) ចំពោះការរកឃើញថា មានការកើនឡើងខ្លាំងនៅភូមិភាគកណ្តាលក្រោយកម្មាភិបាលភូមិភាគនិរតី និង អោ អាន បានមកដល់។ ភស្តុតាងដែលបានដកស្រង់ពុំមាន ហើយពុំយោងលើពាក្យចចាមអារ៉ាមអនាមិកអំពី "កងការពារមិនស្គាល់ឈ្មោះដែលត្រូវបានចោទប្រកាន់ថាជាក្មួយប្រុសរបស់ កែ ពក" ដូចសហមេធាវីអះអាងអាងនោះឡើយ។ ទោះក្នុងករណីណាក៏ដោយ នៅក្នុងផ្នែកមួយចំនួននៃកំណត់ហេតុស្តាប់ចម្លើយរបស់ ញ៉ែម ចេន ដែលយោងលើអង្គហេតុផ្សេងពីនេះ ញ៉ែម ចេន កំណត់អត្តសញ្ញាណឈ្មោះរបស់កងការពារនោះ ដោយឈ្មោះហៅក្រៅថា សមមិត្ត វឿន។ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/855 ត្រង់ ERN 01344694 ឆ.៨២។

[723] *ឧទា.* សូមមើលដីកាដំណោះស្រាយ (ដីកាសម្រេចបញ្ជូនរឿងទៅជំនុំចម្រះ) (ឯកសារ D360) កថាខណ្ឌ ២៥៨ លេខយោងជើងទំព័រ ៦៤២ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសំអាងលើភស្តុតាងរបស់ យូ វ៉ាន់ (ឯកសារ D219/138) ដើម្បីគាំទ្រការសម្រេចរបស់ខ្លួនថា អោ អាន បានអនុវត្តសិទ្ធិអំណាចលើយោធាតំបន់ ៤១។ សហមេធាវី តវ៉ាលើភស្តុតាងនេះថាជាភស្តុតាងចចាមអារ៉ាម ដោយសារ យូ វ៉ាន់ បានដឹងអំពីព័ត៌មាននេះពីបុគ្គលម្នាក់ឈ្មោះ នី។ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ឯកសារ D219/138 ត្រង់ ERN 01056061-62 ឆ.៩៨។ ភស្តុតាងនេះ ទោះជាភស្តុតាងចចាមអារ៉ាមក្តី ត្រូវបានគាំទ្រដោយភស្តុតាងស៊ីសង្វាក់របស់ ញ៉ែម ចេន ដែលជាកងការពារផ្ទាល់របស់ អោ អាន ហើយក៏ធ្វើការជាកងការពាររបស់ សុខ ប្រធានយោធាតំបន់ ៤១ ផងដែរ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/855 ត្រង់ ERN 01344684 ឆ.៤ ERN 01344696 ឆ.១០០-១០៤ ("[អោ អាន] ធ្លាប់បញ្ជា ពួកអ៊ំសុក ប្រើឲ្យខ្ញុំហៅ ព្រោះគាត់បញ្ជាតទៀត) ERN 01344714 ឆ.២៥០ (ii) ពេជ្រ ជីម ដែលកាន់មុខនាទីក្នុងនោះជាប្រធានសហជីពកម្មករចំការកៅស៊ូនៅក្នុងខេត្តកំពង់ចាម *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជីម ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០១៤ ឯកសារ D118/259 ត្រង់ ERN 00997027 ឆ.៣២ ERN 00997038 ឆ.១១២ [យោធាតំបន់រាយការណ៍ទៅស្រុក] ERN 00997044 ឆ.១៦៥ [តាអាន ជាអនុភូមិភាគកណ្តាល។ តែការងារចំពោះមុខជាប្រធានតំបន់ ៤១ ការងារស្នូលជាលេខាតំបន់] និង (iii) សាត ភាព *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D219/504 ត្រង់ ERN 01146376 ឆ.៤១ ERN 01146377 ឆ.៥២-៥៣ (ដោយបានពន្យល់ថា សុខ បានរាយការណ៍ជូន តា អាន ដែលជាសាក្សីបានដឹងពីមិត្តភ័ក្ររបស់គាត់) ក្នុងចំណោមសាក្សីផ្សេងទៀត។

ដែលសមហេតុផល សំអាងលើភស្តុតាងនោះដើម្បីធ្វើសេចក្តីសម្រេចនៅដំណាក់កាលនៃដីកាដំណោះស្រាយ[724]។

៤៣៧. យោងតាមហេតុផលដូចបានលើកឡើងខាងលើ ចៅក្រមអន្តរជាតិយល់ឃើញថា សហមេធាវីខកខានក្នុងការបង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសនៅក្នុងវិធីសាស្ត្ររបស់ខ្លួនដែលអនុវត្តចំពោះភស្តុតាងចចាមអារ៉ាម។ អាស្រ័យហេតុនេះ មូលដ្ឋានទី ៥(៥) ត្រូវបដិសេធចោល។

## មូលដ្ឋានទី៦÷ មុខដំណែងរបស់អោ អាន នៅក្នុង ប.ក.ក និងតួនាទីរបស់គាត់នៅក្នុងបទល្មើសធ្ងន់ធ្ងរបំផុត- សេចក្តីផ្តើម

៤៣៨. មូលដ្ឋានទី៦ តវ៉ាចំពោះកំហុសឆ្គងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលរកឃើញថា អោ អាន មានមុខតំណែងនៅក្នុង ប.ក.ក និងដើរតួនាទីនៅក្នុងបទល្មើសធ្ងន់ធ្ងរបំផុត សំខាន់ជាងមន្ត្រីខ្មែរក្រហមដទៃទៀតដែលគេស្គាល់[725]។ សហមេធាវីអះអាងថា ការវិភាគស៊ីជម្រៅទៅលើភស្តុតាងបង្ហាញថា (i) អោ អាន មិនបានកំណត់ ឬបកស្រាយគោលនយោបាយរបស់ ប.ក.ក ទេ[726] និង (ii) មិនមែនជា

---

[724] *ឧទា. សូមមើល* ដីកាដំណោះស្រាយ (ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ)(ឯកសារ D360) កថាខណ្ឌ ៣៣០ លេខយោងជើងទំព័រ ៩០៦ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិសំអាងលើភស្តុតាងរបស់ ទូច ចំរើន (ឯកសារ ២១៩/៤៣៥) ដោយបានសម្រេចថា ទូច ចំរើន បានផ្តល់របាយការណ៍ឱ្យទៅប្រពន្ធរបស់សាក្សីស្តីពីបរិមាណអង្ករចែកជូនកម្មករទំនប់អន្លង់ជ្រៃ ដែលប្រពន្ធនោះក្រោយមកបានផ្តល់របាយការណ៍ជូន អោ អាន។ សហមេធាវីជំទាស់ទៅនឹងភស្តុតាងនេះ ថាជាភស្តុតាងចចាមអារ៉ាមពីប្រពន្ធរបស់សាក្សី ហើយអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិគ្មានការប្រុងប្រយ័ត្នឡើយ។ ប្រសិនបើពុំទាន់បានពិចារណាទៅលើបញ្ហានៃការខកខានរបស់សហមេធាវីក្នុងការពន្យល់លម្អិតថាតើការសំអាងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើភស្តុតាងចចាមអារ៉ាមនេះបង្ហាញនូវកំហុសដោយស្វ័យប្រវត្តិតាមវិធីណានោះ ចៅក្រមអន្តរជាតិពិចារណាឃើញថា កាលៈទេសៈ និងខ្លឹមសារនៃភស្តុតាងចចាមអារ៉ាមនេះ អាចឱ្យអ្នកវិនិច្ឆ័យអង្គហេតុដោយមិនលម្អៀងផ្តល់តម្លៃជាភស្តុតាងលើភស្តុតាងនេះបាន។ ជាពិសេស សាក្សី ធ្លាប់ទទួលខុសត្រូវឃ្លាំងនៅមន្ទីរតំបន់នៅព្រៃទទឹង កាលៈទេសៈដែលភស្តុតាងចចាមអារ៉ាមបានទទួលមកពីប្រពន្ធរបស់សាក្សី និងការពិតថា គាត់ទទួលខុសត្រូវផ្នែកសេដ្ឋកិច្ចនៅមន្ទីរតំបន់ ចម្ងាយប្រហែល ២០០ ម៉ែត្រ ពីមន្ទីររបស់ អោ អាន និងសក្ខីកម្មលម្អិតរបស់សាក្សីថាតើអង្ករត្រូវបានគណនាដោយរបៀបណា និងវិធីដែលប្រពន្ធរបស់គាត់បានរៀបចំរបាយការណ៍ជូន អោ អាន។ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច ចំរើន ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ D219/435 នៅត្រង់ ERN 01124167-68 ឆ.៤៥ ឆ.៥៤ ERN 01124179-81 ឆ.១៨៥-១៩០, ឆ.១៩៣, ឆ.១៩៦-១៩៧, ឆ.២០៣ ERN 01124185 ឆ.២៣៦-២៣៩។

[725] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៨០-៨១, ១៥៦។ ប្រតិចារឹក សំណុំរឿង ០០៤/២ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៩ (CS) ឯកសារ D359/9.1 & ឯកសារ D360/18.1 ERN 01626070 ទំព័រ ១៦:១៥ ដល់ ១៧:៦។

[726] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៨២។

ឧបករណ៍នៅក្នុងការអនុវត្តគោលនយោបាយរបស់ ប.ក.ក ទេ បើប្រៀបធៀបទៅនឹងមន្ត្រីខ្មែរក្រហមដទៃទៀតដែលគេស្គាល់[727]។ សហមេធាវីតវ៉ាបន្ថែមទៀតចំពោះការយល់ឃើញផ្នែកអង្គហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពាក់ព័ន្ធនឹង៖ (iii) ៖ តួនាទីរបស់ អោ អាន នៅក្នុងការបោសសំអាតកម្មាភិបាលភូមិភាគកណ្ដាល និងជនស៊ីវិល[728] (iv) តួនាទីថ្នាក់ភូមិភាគ និងសិទ្ធិអំណាចរបស់ អោ អាន[729] (v) តួនាទី និងសិទ្ធិអំណាចរបស់ អោ អាន នៅក្នុងតំបន់ ៤១[730] (vi) តួនាទីរបស់ អោ អាន នៅក្នុងអំពើប្រល័យពូជសាសន៍ជនជាតិចាម[731] (vii) តួនាទីរបស់ អោ អាន នៅក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទនៅក្នុងស្រុកកំពង់សៀម និងព្រៃឈរ[732] និង (viii) តួនាទីរបស់ អោ អាន នៅក្នុងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅតាមទីតាំងឧក្រិដ្ឋកម្មនានា[733]។ សហមេធាវីលើកឡើងថា ប្រសិនបើគ្មានកំហុសឆ្គងតាមការអះអាងទាំងនេះទេ សហចៅក្រមស៊ើបអង្កេតអន្តរជាតិប្រាកដជាមិនអាចសម្រេចថា អោ អាន ទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ឬសម្រេចថា អោ អាន ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក នោះឡើយ[734]។ អង្គបុរេជំនុំជម្រះនឹងធ្វើការវាយតម្លៃលើអង្គសេចក្ដីនីមួយៗនៃមូលដ្ឋានទាំងនេះ។

---

[727] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៨៣-៨៧។

[728] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៨៨-៩២។ ប្រតិចារឹក សំណុំរឿង ០០៤/២ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៩ (CS) ឯកសារ D359/9.1 & ឯកសារ D360/18.1 ERN 01626071-01626072 ទំព័រ ១៧:៧ ដល់ ១៨:២៣។

[729] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៩៣-១០៥។ ប្រតិចារឹក សំណុំរឿង ០០៤/២ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៩ (CS) ឯកសារ D359/9.1 & ឯកសារ D360/18.1 ERN 01626072-01626074 ទំព័រ ១៨:២៥ ដល់ ២០:៥។

[730] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១០៦-១៤៥។ ប្រតិចារឹក សំណុំរឿង ០០៤/២ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៩ (CS) ឯកសារ D359/9.1 & ឯកសារ D360/18.1 ERN 01626074-01626077 ទំព័រ ២០:៧ ដល់ ២៣:១៤។

[731] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤៦-១៥០។ ប្រតិចារឹក សំណុំរឿង ០០៤/២ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៩ (CS) ឯកសារ D359/9.1 & ឯកសារ D360/18.1 ERN 01626077-01626078 ទំព័រ ២៣:១៦ ដល់ ២៣:៨។

[732] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៥១-១៥៤។

[733] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៥៥។ ប្រតិចារឹក សំណុំរឿង ០០៤/២ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៩ (CS) ឯកសារ D359/9.1 & ឯកសារ D360/18.1 ERN 01626073 ទំព័រ ១៩:១៣ ដល់ ២០:៥។

[734] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៨០-៨១, ១៥៦។ ប្រតិចារឹក សំណុំរឿង ០០៤/២ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៩ (CS) ឯកសារ D359/9.1 & ឯកសារ D360/18.1 ERN 01626070 ទំព័រ ១៦:១៥ ដល់ ១៧:៦។

## មូលដ្ឋានទី៦(i). តួនាទីរបស់អោ អាន ក្នុងការកំណត់ ឬបកស្រាយគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា

### ១. សារណា និងការពិភាក្សា

៤៣៩. ក្រោមមូលដ្ឋានទី ៦(i) សហមេធាវីអះអាងថា អោ អាន ពុំមានអំណាចក្នុងការកំណត់គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា និងមធ្យោបាយក្នុងការអនុវត្ត ឬបកស្រាយឡើយ ដោយសារគាត់មិនមែនជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងសេនាធិការនៅភ្នំពេញនោះទេ[735]។ សហមេធាវីសង្កេតឃើញថា ទាំងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាំងសហព្រះរាជអាជ្ញាអន្តរជាតិ មិនបានផ្តល់ភស្តុតាងផ្ទុយណាមួយឡើយ[736]។

៤៤០. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា វាមានភាពពាក់ព័ន្ធតិចតួចដែលថា អោ អាន មិនបានចូលរួមការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឬសេនាធិការ[737]។ តាមការយល់ឃើញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទឡ្ហីករណ៍នេះពាក់ព័ន្ធជាសំខាន់ជាមួយនឹងអតីតភាពច្រើនជាងបញ្ហាថាតើអ្នកណាស្ថិតក្នុងចំណោមជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ទោះបីជាតួនាទីរបស់ជនត្រូវចោទក្នុងការបង្កើត ឬបកស្រាយគោលនយោបាយ អាចមានការពាក់ព័ន្ធក្នុងការកំណត់ពីកម្រិតនៃទទួលខុសត្រូវរបស់គាត់ក៏ដោយ ក៏ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មទាំងនេះ និងតួនាទីរបស់ជនត្រូវចោទក្នុងឧក្រិដ្ឋកម្ម គឺជាលក្ខណៈវិនិច្ឆ័យសំខាន់បំផុត[738]។

៤៤១. ចៅក្រមអន្តរជាតិ សង្កេតឃើញថា ពុំមានការជំទាស់ដែលថា អោ អាន មិនមែនជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ឬសេនាធិការនៅភ្នំពេញ ហើយដូច្នេះ គាត់មិនបានកំណត់ ឬបកស្រាយគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានោះទេ។ ទោះជាយ៉ាងនេះក្តី កាលៈទេសៈនេះតែមួយមិនគ្រប់គ្រាន់ទេ

---

[735] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៨២ និងជើងទំព័រ ១៧៦។ ប្រតិចារឹកសវនាការក្នុងសំណុំរឿង 00៤/២ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩(CS) ឯកសារ D359/9.1 & D360/18.1, ERN 01626070 ទំព័រ ១៦:២៣ ដល់ ១៦:២៥។

[736] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៨២។

[737] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៨៧។

[738] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៨៧ និងជើងទំព័រ ២១១ យោងទៅសាលក្រមសំណុំរឿង 00១ (ឯកសារ E188) កថាខណ្ឌ ២២។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង 00៤/១ (ឯកសារ D308/3/1/20) មតិយោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣២១។ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D359) កថាខណ្ឌ ៤២៤។

ដើម្បីដោះស្រាយបញ្ហាថាតើ អោ អាន ស្ថិតក្នុងចំណោមជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម [...] ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩"[739]។

## មូលដ្ឋានទី ៦(ii). តួនាទីរបស់ អោ អាន ក្នុងការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ធៀបទៅនឹងមន្ត្រីខ្មែរក្រហមផ្សេងទៀត

### ១. សារណា

៤៤២. នៅក្នុងមូលដ្ឋានទី ៦(ii) សហមេធាវីអះអាងថា អោ អាន មិនមែនជាអ្នកដើរតួសំខាន់នៅក្នុងការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាទេ បើធៀបទៅនឹងមន្ត្រីខ្មែរក្រហមផ្សេងទៀតដូចជា ឌុច, កែ ពក, តាម៉ុក និង សៅ សារុន[740]។ អោ អាន មិនបានធ្វើទំនាក់ទំនងដោយផ្ទាល់ជាមួយគណៈកម្មាធិការអចិន្ត្រៃយ៍ ឬសេនាធិការនៅភ្នំពេញ មិនមែនជាមេដឹកនាំតំបន់ស្វយ័ត និងមិនមែនជាអ្នកកំណត់ថាកម្មាភិបាលមួយណាពីភូមិភាគកណ្តាល ឬតំបន់ ៤១ ត្រូវបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១[741]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏ខកខានផងដែរក្នុងការផ្តល់ភស្តុតាងស៊ីសង្វាក់ និងរឹងមាំគ្រប់គ្រាន់ថា អោ អាន បានចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ជាន់ខ្ពស់នៅភ្នំពេញជាមួយមេដឹកនាំជាន់ខ្ពស់។ ផ្ទុយទៅវិញ គាត់មានចេតនាពន្លើសភស្តុតាងពាក់ព័ន្ធនឹងកន្លែងសម្រាកតាមផ្លូវតែមួយនៅភ្នំពេញ ដែលទោះក្នុងករណីណាក៏ដោយ មិនមែនមានន័យថា អោ អាន ជាអ្នកកំណត់គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ឬមធ្យោបាយអនុវត្ត និងផ្សព្វផ្សាយគោលនយោបាយទាំងនេះទេ[742]។ លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានក្នុងការផ្តល់ភស្តុតាងគ្រប់គ្រាន់ថា អោ អាន បានដឹកនាំការបណ្តុះបណ្តាល ឬការប្រជុំនយោបាយ សន្តិសុខ ឬយោធា ដើម្បីផ្សព្វផ្សាយ ឬអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងតំបន់ ៤១ ឬភូមិភាគកណ្តាល។ ជាងនេះទៀត ទោះបីជា អោ អាន មានវត្តមានក្តី មិនមែនមានន័យថា គាត់

[739] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ១។ កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក មាត្រា ១។ សូមមើលជាទូទៅ ខាងលើ មូលដ្ឋានទី ៣។

[740] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៨៣។ ប្រតិចារឹកសវនាការក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626064 ទំព័រ ១០:១៨ ដល់ ១០:២១ 01626070 ទំព័រ ១៦:២៣ ដល់ ១៦:២៥។

[741] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៨៤-៨៥ និងជើងទំព័រ ១៧៨-១៧៩។

[742] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៨៦ និងជើងទំព័រ ១៨០-១៨២។

ជាអ្នកអនុវត្តដ៏សំខាន់នូវគោលនយោបាយបក្សកុម្មុយនីស្ត ឬ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នោះទេ[743]។ ជាចុងបញ្ចប់ សហមេធាវីបន្ថែមថា ទោះបីជា អោ អាន បានឡើងនិយាយនៅក្នុងការប្រជុំក៏ដោយ ការប្រជុំទាំងនេះពាក់ព័ន្ធតែនឹងបញ្ហាសេដ្ឋកិច្ច និងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនប៉ុណ្ណោះ មិនពាក់ព័ន្ធនឹងបញ្ហានយោបាយ សន្តិសុខ ឬយោធានោះទេ[744]។

៤៤៣. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ទឡ្ហីករណ៍ពាក់ព័ន្ធនឹងអតីតភាពរបស់ អោ អាន ឬទឡ្ហីករណ៍ថា គាត់មិនបានជ្រើសជនរងគ្រោះដោយផ្ទាល់ដើម្បីបញ្ជូនទៅ ស-២១ ដែលបញ្ជាក់ពីចំនួនជនរងគ្រោះតិចតួចប៉ុណ្ណោះពីភូមិភាគកណ្តាល មានភាពពាក់ព័ន្ធតិចតួចទៅនឹងបញ្ហាថា តើគាត់ស្ថិតនៅក្នុងចំណោមជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ឬយ៉ាងណា[745]។ អោ អាន ដើរតួសំខាន់ក្នុងការអនុវត្តគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា ដោយបញ្ជាថ្នាក់ក្រោមរបស់គាត់ឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម និងត្រួតពិនិត្យការអនុវត្តរបស់ពួកគេតាមបញ្ជាទាំងនោះ[746]។

## ២. ការពិភាក្សា

៤៤៤. ចៅក្រមអន្តរជាតិយល់ឃើញថា សេចក្តីសង្កេតរបស់សហមេធាវីថា អោ អាន មិនបានធ្វើទំនាក់ទំនងដោយផ្ទាល់ជាមួយគណៈកម្មាធិការអចិន្ត្រៃយ៍ ឬសេនាធិការ ឬថាគាត់មិនមែនជាមេដឹកនាំតំបន់ស្វយ័ត មិនបង្ហាញឱ្យឃើញថា អោ អាន ស្ថិតនៅក្រៅយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក នោះទេ។ លើសពីនេះទៀត សហមេធាវីមិនបានបង្ហាញឱ្យឃើញថា ហេតុអ្វីទំនួលខុសត្រូវរបស់ អោ អាន រួមបញ្ចូលជាចាំបាច់ទាំងសេចក្តីសម្រេចថាតើកម្មាភិបាលមួយណាត្រូវបញ្ជូនទៅ ស-២១ ប្រសិនបើគាត់ដើរតួសំខាន់នៅក្នុងការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា។ ក្នុងករណីដែលសហមេធាវីអះអាងថា អំណាច ឬការចូលរួមក្នុងការធ្វើសេចក្តីសម្រេចលើឧក្រិដ្ឋកម្មនៅ ស-២១ មានភាពចាំបាច់ដើម្បីនាំទៅកាត់ទោសនូវជនជាប់ចោទម្នាក់ដែលស្ថិតនៅក្នុងចំណោមជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" សម្រាប់គោលបំណងនៃយុត្តាធិការរបស់ អ.វ.ត.ក អង្គជំនុំជម្រះច្រានចោលជំហរនេះ។ ចៅក្រមអន្តរជាតិរម្លឹកបន្ថែមទៀតថា ក្នុងការកំណត់យុត្តាធិការបុគ្គល គ្មាន "បទដ្ឋានកំហិតអំពីតួនាទីនៅក្នុងឋានានុក្រម"[747] និងដូច

---

[743] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៨៧ និងជើងទំព័រ ១៨៣។

[744] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៨៧ និងជើងទំព័រ ១៨៤។

[745] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៨៦-៨៧។

[746] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៨៧។

[747] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) មតិ

បានពិភាក្សានៅខាងលើ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសក្នុងការប្រៀបធៀប អោ អាន ជាមួយនឹងសមាជិកខ្មែរក្រហមមួយចំនួន ប៉ុន្តែ មិនមែនជាមួយអ្នកដទៃទេ[748]។

៤៤៥. ពាក់ព័ន្ធនឹងការមានភស្តុតាងគ្រប់គ្រាន់ពាក់ព័ន្ធនឹងការចូលរួមរបស់ អោ អាន ក្នុងការប្រជុំផ្សព្វផ្សាយ ឬអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ចៅក្រមអន្តរជាតិអះអាងថា សហមេធាវីមិនបានបំពេញលក្ខខណ្ឌរបស់ខ្លួនក្នុងការបង្ហាញថា ពុំមានអ្នកវិនិច្ឆ័យអង្គហេតុសមហេតុផលណាមួយអាចធ្វើសេចក្តីសន្និដ្ឋាន ដែលរងការជំទាស់បានទេ។ ផ្ទុយទៅវិញ ការជំទាស់របស់ពួកគេត្រូវបានកម្រិតត្រឹមការជំទាស់ទៅលើសេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ឬការបកស្រាយភស្តុតាងដដែល ដោយពុំបានលើកអំណះអំណាងគាំទ្រផ្សេងទៀត[749]។ ជាពិសេស ចៅក្រមអន្តរជាតិសន្និដ្ឋានថា ភស្តុតាងគាំទ្រយ៉ាងមុតមាំចំពោះតួនាទីរបស់ អោ អាន ក្នុងការដឹកនាំ និងចេញបញ្ជា នៅក្នុងការប្រជុំអំពីបញ្ហានយោបាយ សន្តិសុខ និងយោធា[750] បន្ថែមលើការប្រជុំពាក់ព័ន្ធនឹងបញ្ហាសេដ្ឋកិច្ច រួមទាំងការប្រជុំអំពីការដ្ឋានការងារដោយបង្ខំ[751]។ ភស្តុតាងក៏គាំទ្រផងដែរចំពោះការចូលរួមរបស់ អោ អាន នៅក្នុងការប្រជុំ

---

យោបល់របស់ចៅក្រម BAIK និង BEAUVALLET កថាខណ្ឌ ៣២១, សូមមើលផងដែរ កថាខណ្ឌ ៣៣៤ ("ពីដំបូង ចៅក្រមទទួលបន្ទុកលើរឿងក្តីសង្កេតឃើញថា "ផលវិបាកជាក់ស្តែងដំបូង" ដែលតួនាទីផ្លូវការរបស់បុគ្គលម្នាក់មាននៅក្នុងឋានានុក្រម ដូចដែលបានអនុវត្តដោយសហចៅក្រមស៊ើបអង្កេត មិនគួររាប់បញ្ចូលដោយស្វ័យប្រវត្តិបុគ្គលនៅថ្នាក់ទាបៗ ដែលពាក់ព័ន្ធដោយផ្ទាល់នៅក្នុងអំពើឃោរឃៅដ៏ធ្ងន់ធ្ងរបំផុតនោះឡើយ")។

[748] សូមមើលខាងលើ មូលដ្ឋានទី ៣ (សន្និដ្ឋានក្នុងចំណោមផ្សេងទៀតថា ខណៈដែលការវាយតម្លៃថាតើជនសង្ស័យស្ថិតនៅក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត អាចរួមបញ្ចូលការប្រៀបធៀបទៅនឹងមន្ត្រីខ្មែរក្រហមដទៃទៀត ការប្រៀបធៀបទៅនឹងមន្ត្រីខ្មែរក្រហមគ្រប់រូបដែលគេស្គាល់មិនចាំបាច់ឡើយ)។

[749] សូមមើល សាលដីកាសំណុំរឿង ០០២/១ (ឯកសារ F36) កថាខណ្ឌ ៩០។

[750] ចៅក្រមអន្តរជាតិ កត់សម្គាល់បន្ថែមទៀតថា ភស្តុតាងជាច្រើនដែលសហមេធាវីជំទាស់ថា "មិនអាចជឿជាក់" ត្រូវបានផ្តល់ដោយសាក្សី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលចៅក្រមអន្តរជាតិសន្និដ្ឋានរួចហើយថាជាសាក្សីអាចជឿជាក់បានជាទូទៅ នៅក្នុងមូលដ្ឋាន ៥(ii)។ សូមមើលឧទាហរណ៍ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ឯកសារ D219/731 ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ERN 01218074-01218075 (ឆ.៥១-ឆ.៥៥) (ពិភាក្សាពីការប្រជុំនៅមន្ទីរសន្តិសុខមិត្តសុខ ដែលនៅពេលនោះ អោ អាន បានបញ្ជាឱ្យសម្លាប់មនុស្ស ទៅតាម "ផែនការ ត្រឹមឆ្នាំ៧៧" ដែលតម្រូវឱ្យសម្លាប់ខ្មាំងទាំងអស់មុនឆ្នាំ១៩៧៨) 01218076 (ឆ.៦៨-ឆ.៧០) (ពិភាក្សាពីការប្រជុំនៅវត្តបាធាយ ដែលនៅពេលនោះ អោ អាន និយាយពីការសាងសង់ និងរបបអាហារ)។ កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពេញ វ៉ា ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ឯកសារ D219/226, ERN 01075654 (ឆ.៦) (ពិភាក្សាពីការប្រជុំនៅខែមីនា ឆ្នាំ១៩៧៧ នៅវត្តតាម: ដែលនៅពេល អោ អាន ចោទកម្មាភិបាលភូមិភាគកណ្តាលថាក្បត់)។

[751] សូមមើលឧទាហរណ៍ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជីន ស៊ីណាល់ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១១ ឯកសារ D78,

មួយនៅភ្នំពេញ ជាមួយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាផ្សេងទៀត ដែលនៅពេលនោះ ប៉ុល ពត បាន ប្រកាសថា កម្មាភិបាលភូមិភាគកណ្តាលជា "ជនក្បត់" នៅពេលបញ្ជូន អោ អាន ពីភូមិភាគនិរតីទៅភូមិភាគកណ្តាល[752]។ នៅពេលពិនិត្យមើលភស្តុតាង ចៅក្រមអន្តរជាតិសន្និដ្ឋានថា សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិថា អោ អាន ជា "អ្នកដើរតួនាទីសំខាន់ម្នាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ" និងជា "អ្នកចូលរួមដោយមានឆន្ទៈ និងទឹកចិត្តនៅក្នុងការអនុវត្តគោលនយោបាយអមនុស្សធម៌កម្ពុជាប្រជាធិបតេយ្យក្នុងរបៀបព្រៃផ្សៃ និងឧក្រិដ្ឋ"[753] មានភាពពាក់ព័ន្ធ និងមានមូលដ្ឋានត្រឹមត្រូវ។

៤៤៦. អាស្រ័យហេតុនេះ ចៅក្រមអន្តរជាតិរកពុំឃើញកំហុសណាមួយឡើយ និងសម្រេចបដិសេធមូលដ្ឋាន ៦ (ii)។

## មូលដ្ឋានទី ៦(iii). តួនាទីរបស់ អោ អាន ក្នុងការរៀបចំផែនការ និងដឹកនាំការបោសសម្អាតកម្មាភិបាលភូមិភាគកណ្តាលដែលកំពុងកាន់តំណែង និងប្រជាជនស៊ីវិល

### ១. សារណា

៤៤៧. ក្រោមមូលដ្ឋានទី ៦(iii) សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសន្និដ្ឋានថា អោ អាន បានរៀបចំផែនការ សហការ ឬដឹកនាំការបោសសម្អាតអតីតកម្មាភិបាលភូមិភាគកណ្តាល និងប្រជាជនស៊ីវិល នៅចុងឆ្នាំ១៩៧៦ ដល់ខែកុម្ភៈ ឆ្នាំ១៩៧៧[754]។ ដោយរំលោភលើគោលការណ៍

ERN 00729740-00729742 (ឆ.១-ឆ.៣, ឆ.១១) (ពិភាក្សាពីការប្រជុំនៅការដ្ឋានទំបន់អន្លង់ជ្រៃ ដែលនៅពេលនោះ អោ អាន បានឡើងនិយាយ)។

[752] សូមមើល កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ឯកសារ D118/259, ERN 00997031-00997032 (ឆ.៦០-ឆ.៦១, ឆ.៦៤-ឆ.៦៥, ឆ.៧០) (ពណ៌នាពីការប្រជុំនៅភ្នំពេញ ដែលនៅពេលនោះ ប៉ុល ពត និយាយថាភូមិភាគកណ្តាលជា "ជនក្បត់")។ ប្រតិចារឹកសវនាការសំណុំរឿង ០០២/០២ ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥ (ពេជ្រ ជឹម) ឯកសារ D219/702.1.99, ERN 01450019 ទំព័រ ៥៤ (ផ្តល់សក្ខីកម្មថា នៅក្នុងការប្រជុំនៅភ្នំពេញ ប៉ុល ពត បញ្ជាក់ "ភូមិភាគកណ្តាលវាក្បត់")។ ប្រតិចារឹកសវនាការសំណុំរឿង ០០២/០២ ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ (យូ វ៉ាន់) ឯកសារ D219/702.1.87, ERN 01451939-01451940 ទំព័រ ៣៧-៣៨ ("មាន ប្រាក់ យុត, តាអាន និងតាម៉ុក, តាចាប មានទៅប្រជុំ [នៅភ្នំពេញ] ...")។ ខណៈដែលចៅក្រមអន្តរជាតិយល់ស្របជាមួយសហមេធាវីថា ការចូលរួមប្រជុំនៅភ្នំពេញនេះតែម្នាក់ឯងមិនគ្រប់គ្រាន់ដើម្បីបង្ហាញឱ្យឃើញថា អ្នកចូលរួមស្ថិតនៅក្នុងចំណោមជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" សហចៅក្រមស៊ើបអង្កេតហាក់ដូចជាមិនប្រកាន់យកជំហរនេះនៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ)។

[753] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៧១២។

[754] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៨៨ និងជើងទំព័រ ១៨៥ យោងទៅ ដីកាដំណោះស្រាយ (ដីកា

នៃ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនអើពើនឹងភស្តុតាងពីសាក្សី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបង្ហាញថា ការបោសសម្អាតបានកើតឡើងមុនពេល អោ អាន មកដល់[755] ថា កែ ពក និង អឿន ជាអ្នកដែលនៅសល់ ពេលកម្មាភិបាលភូមិភាគនិរតីមកដល់[756] និងថា កម្មាភិបាលភូមិភាគនិរតីត្រូវបានបញ្ជូនទៅសម្រាប់តែជំនួសតំណែងប៉ុណ្ណោះ[757]។ លើសពីនេះទៀត សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានផ្អែកទៅលើការរៀបរាប់មិនស៊ីសង្វាក់ និងមិនអាចជឿជាក់បាន ឬមិនអាចកំណត់ពេលវេលាបាន ដើម្បីគាំទ្រដល់កាលបរិច្ឆេទពីចុងឆ្នាំ១៩៧៦ ទៅខែកុម្ភៈ ឆ្នាំ១៩៧៧[758]។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានក្នុងការផ្តល់ភស្តុតាងគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការសន្និដ្ឋានរបស់ខ្លួននោះ។ លើសពីនេះទៀត សហមេធាវីលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានផ្តល់ភស្តុតាងគ្រប់គ្រាន់ដើម្បីសន្និដ្ឋានថា ហេតុផលនៃការផ្ទេរកម្មាភិបាលភូមិភាគនិរតីគឺដើម្បីដឹកនាំធ្វើការបោសសម្អាត[759]។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពន្លើសកន្លែងសម្រាកតាមផ្លូវតែមួយនៅភ្នំពេញថាជាភស្តុតាងអំពីការចោទប្រកាន់ពីការប្រជុំរៀបចំការផែនការបោសសម្អាត[760] និងមានកំហុសក្នុងការសន្និដ្ឋានថា អោ អាន បាន

---

បញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២១២-២១៧, ២៤២-២៤៥, ២៧៦។ ប្រតិចារឹកសវនាការក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626071 ទំព័រ ១៧:១៤ ដល់ ១៧:១៧។

[755] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៨៨ និងជើងទំព័រ ១៨៦។ ប្រតិចារឹកសវនាការក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626071 ទំព័រ ១៧:១៨ ដល់ ១៧:២១។

[756] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៨៨ និងជើងទំព័រ ១៨៧។ ប្រតិចារឹកសវនាការក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626071 ទំព័រ ១៧:២១ ដល់ ១៧:២២។

[757] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៨៨ និងជើងទំព័រ ១៨៨ កថាខណ្ឌ ៩០ និងជើងទំព័រ ១៩៤។ ប្រតិចារឹកសវនាការក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626071 ទំព័រ ១៧:២២ ដល់ ១៧:២៣។

[758] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៨៩ និងជើងទំព័រ ១៨៩-១៩១។ ប្រតិចារឹកសវនាការក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626071 ទំព័រ ១៧:២៣ ដល់ ១៧:២៥។

[759] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៩០ និងជើងទំព័រ ១៩២ យោងទៅ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២១៤ ជើងទំព័រ ៤៨៩-៤៩០។ ប្រតិចារឹកសវនាការក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626072 ទំព័រ ១៨:៣ ដល់ ១៨:៥។

[760] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៩១។ ប្រតិចារឹកសវនាការក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626071-01626072 ទំព័រ ១៧:២៥ ដល់ ១៨:៣។

01634995



បញ្ហា ចូលរួម ឬទទួលបញ្ញាពាក់ព័ន្ធនឹងការបោសសម្អាត[761]។

៤៤៨. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សហមេធាវីខកខានក្នុងការបង្ហាញថា ពុំមានអ្នកវិនិច្ឆ័យអង្គហេតុសមហេតុផលណាមួយអាចធ្វើការសន្និដ្ឋានថា អោ អាន បានរៀបចំផែនការសហការ ឬដឹកនាំការបោសសម្អាតអតីតកម្មាភិបាលភូមិភាគកណ្តាល ឬប្រជាជនស៊ីវិល នៅចុងឆ្នាំ១៩៧៦ ដល់ខែកុម្ភៈ ឆ្នាំ១៩៧៧[762]។ នៅក្នុងការជំទាស់នឹងភាពអាចជឿជាក់បាននៃភស្តុតាង សហមេធាវីទទួលស្គាល់ថា មានភស្តុតាងគាំទ្រដល់ការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[763]។ លើសពីនេះទៀត សហព្រះរាជអាជ្ញាអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានផ្អែកទៅលើភស្តុតាងគ្រប់គ្រាន់ រួមមាន ការដឹងឮផ្ទាល់របស់ អោ អាន អំពីហេតុផលនៃការបញ្ជូនរូបគាត់ទៅភូមិភាគកណ្តាល[764]។

## ២. ការពិភាក្សា

៤៤៩. ចៅក្រមអន្តរជាតិយល់ឃើញថាមានភស្តុតាងស៊ីសង្វាក់ និងរឹងមាំគ្រប់គ្រាន់បង្ហាញថា កែ ពក និង អោ អាន ក្នុងចំណោមអ្នកផ្សេងទៀត បានបង្កើតផែនការបោសសម្អាតកម្មាភិបាលនៅក្នុងភូមិភាគកណ្តាល នៅចុងឆ្នាំ១៩៧៦ ដល់ខែកុម្ភៈ ឆ្នាំ១៩៧៧។ ទោះបីជាសហមេធាវីបានយោងទៅសាក្សីមួយចំនួនដែលឆ្លើយថា ការបោសសម្អាតកម្មាភិបាលកំពុងកាន់តំណែងបានកើតឡើងមុនពេលកម្មាភិបាលភូមិភាគនិរតីមកដល់ក្តី ក៏ចៅក្រមអន្តរជាតិសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាទៅលើភស្តុតាងផ្ទុយពាក់ព័ន្ធនឹងបញ្ហានេះ[765]។ លើសពីនេះទៀត ចៅក្រមអន្តរជាតិសង្កេតឃើញថា សាក្សីខ្លះដែលសហមេធាវីបានផ្អែកលើ មិនគាំទ្រទឡ្ហីករណ៍របស់ពួកគេទេ[766]។ នៅក្នុងការសន្និដ្ឋានថា ការផ្ទេរបានកើត

---

[761] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៩២ យោងទៅដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៧៥, ២៨១-២៨៨, ២៩៣-២៩៨ និងជើងទំព័រ ៧១៨-៧១៩, ៧៣៧-៧៥២, ៧៦៥-៧៩១។ ប្រតិចារឹកសវនាការក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626072 ទំព័រ ១៨:៧ ដល់ ១៨:៩។

[762] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៨៥។

[763] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៨៥ និងជើងទំព័រ ២០៨ យោងទៅ បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៨៩ ជើងទំព័រ ១៨៩។

[764] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៨៥ និងជើងទំព័រ ២០៩ យោងទៅ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) ជើងទំព័រ ៥៩២។

[765] សូមមើល ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) ជើងទំព័រ ៧៨៣។

[766] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទេព ប៉ូច ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ឯកសារ D117/19, ERN 00893175-

ឡើងនៅពេលណាមួយ ចន្លោះពី "ចុងឆ្នាំ១៩៧៦ ដល់ខែកុម្ភៈ ឆ្នាំ១៩៧៧" សហចៅក្រមស៊ើបអង្កេតអន្តរជាតិទទួលស្គាល់ថា មានភស្តុតាងមិនច្បាស់លាស់ និងជួនកាលមិនស៊ីសង្វាក់នៅក្នុងសំណុំរឿង[767]។ ចៅក្រមអន្តរជាតិអាចសន្និដ្ឋានបានថា ពុំមានកំហុសដែលតម្រូវឱ្យមានអន្តរាគមន៍នៅដំណាក់កាលបណ្តឹងឧទ្ធរណ៍ឡើយ។ អង្គជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា ការសន្និដ្ឋានថា ការផ្ទេរបានកើតឡើងនៅខ្ទង់ពីចុងឆ្នាំ១៩៧៦ ដល់ខែកុម្ភៈ ឆ្នាំ១៩៧៧ មានភាពស៊ីសង្វាក់គ្នាជាមួយការសន្និដ្ឋានថា អោ អាន បានប្រកាសថា គាត់ជាលេខាតំបន់ ៤១ ថ្មី នៅក្នុងប្រជុំនៅវត្តតាមៈ នៅខែមីនា ឆ្នាំ១៩៧៧ ប្រហែលមួយខែក្រោយ[768]។

៤៥០. ចៅក្រមអន្តរជាតិសន្និដ្ឋានស្រដៀងគ្នាថា ភស្តុតាងបានបង្ហាញឱ្យឃើញយ៉ាងមុតមាំថា ការផ្ទេរកម្មាភិបាលភូមិភាគនិរតីទៅភូមិភាគកណ្តាលមានគោលបំណងអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាដើម្បីបោសសម្អាតកម្មាភិបាលកំពុងកាន់ដំណែង ដែលត្រូវបានចាត់ទុកថាជា"ជនក្បត់"[769]។ តាមពិត អោ

---

00893176 (ឆ.១, ឆ.៨) (សាក្សីបញ្ជាក់ថា គាត់ត្រូវបានចាត់ឱ្យធ្វើជាលេខាស្រុកបារាយណ៍ នៅចុងឆ្នាំ១៩៧៨ បី ឬបួនខែមុនវៀតណាមចូលមកដល់ ហើយដូច្នេះ គាត់បានទៅដល់ ក្រោយពេលចន្លោះពីចុងឆ្នាំ១៩៧៦ ដល់ខែកុម្ភៈ ឆ្នាំ១៩៧៧ យ៉ាងច្រើន ដែលស្ថិតក្រោមការពិភាក្សា)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ D6.1.386, ERN 00348792 ("អ្នកដែលនៅភូមិភាគកណ្តាលត្រូវបានពួកនិរតីធ្វើការបោសសម្អាតទាំងអស់")។ សូមមើលផងដែរ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១២ ឯកសារ D107/15, ERN 00800954 (ពិភាក្សាពីវត្តមានរបស់ អោ អាន នៅក្នុងការប្រជុំថ្នាក់ភូមិភាគពាក់ព័ន្ធនឹងការបោសសម្អាត)។

[767] ចៅក្រមអន្តរជាតិជឿជាក់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាយ៉ាងត្រឹមត្រូវទៅលើចម្លើយរបស់ប្រាក់ យុត ដែលមិនស៊ីសង្វាក់គ្នា ទាក់ទងនឹងពេលវេលាដែលកម្មាភិបាលភូមិភាគនិរតីមកដល់ភូមិភាគកណ្តាល។ សូមមើល ឧបសម្ព័ន្ធ ឃ នៃបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1.5), ERN 01599794។ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) មិនផ្អែកលើចម្លើយរបស់ ប្រាក់ យុត ដែលអះអាងថា គាត់ត្រូវបានបញ្ជូននៅខែមីនា/មេសា ឆ្នាំ១៩៧៧ ឬនៅពាក់កណ្តាលឆ្នាំ១៩៧៧ ដូចដែលត្រូវបញ្ជាក់នៅក្នុងជើងទំព័រ ៥៩៣ នៃដីកាដំណោះស្រាយ និងបញ្ជាក់ពីការពឹងផ្អែកទៅលើចម្លើយរបស់គាត់ដែលឆ្លើយថា ការបញ្ជូនបានកើតឡើងនៅខែមករា ឬខែកុម្ភៈ ឆ្នាំ១៩៧៧ ដោយដកស្រង់សាក្សីផ្សេងទៀតជាច្រើននាក់ដែលបញ្ជាក់ពីពេលវេលាមុន។ សូមមើលឧទាហរណ៍ កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ញឹម កុល ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ D107/7, ERN 00784980-00784981។ ទោះក្នុងករណីណាក៏ដោយ ភាពខុសគ្នានៃរយៈពេលប្រមាណបួនខែ ក្នុងការប៉ាន់ស្មានពីកាលបរិច្ឆេទនៃព្រឹត្តិការណ៍នៅក្នុងឆ្នាំ១៩៧៧ គឺជាភាពមិនសង្វាក់គ្នាតូចតាចមួយ ដែលមិនកាត់បន្ថយខ្លាំងនូវភាពអាចជឿជាក់ និងភាពអាចជឿទុកចិត្តនៃភស្តុតាងរបស់ ប្រាក់ យុត ផ្សេងទៀតដែលនៅសេសសល់ទេ។

[768] សូមមើលខាងក្រោម មូលដ្ឋាន ៦(v)(ក)។

[769] ចៅក្រមអន្តរជាតិយល់ឃើញថា ការបកស្រាយផ្សេងទៀតរបស់សហមេធាវីទៅលើភស្តុតាងថា ការបញ្ជូនកម្មាភិបាលភូមិភាគនិរតីគឺគ្រាន់តែជាការបែងចែករដ្ឋបាលឡើងវិញ ដើម្បី "អនុវត្តការងារចាត់តាំងថ្មី" ប៉ុណ្ណោះ បង្ហាញឱ្យឃើញនូវកំហុសមួយនៅក្នុងការវិភាគរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ សូមមើលខាងលើ មូលដ្ឋានទី ៦(ii) ពាក់ព័ន្ធនឹងការប្រជុំនៅភ្នំពេញ

01634997



អាន ខ្លួនគាត់ផ្ទាល់ បានបញ្ជាក់ថា តាម៉ុក បានបញ្ជូនគាត់ទៅភូមិភាគកណ្តាល ពីព្រោះ "ថ្នាក់ដឹកនាំកំពង់ចាមហ្នឹងក្បត់អស់ហើយ អ៊ីចឹងទេ បានយកខ្ញុំទៅ"[770]។

៤៥១. ជាចុងក្រោយ សហមេធាវីមិនបានបញ្ជាក់ថា ហេតុអ្វីបានជាគ្មានអ្នកវិនិច្ឆ័យអង្គហេតុណាមួយអាចធ្វើការសន្និដ្ឋានដោយសមហេតុផលថា អោ អាន បានបញ្ជា ឬចូលរួមក្នុងការបោសសម្អាតកម្មាភិបាល និងប្រជាជនស៊ីវិល នៅក្នុងតំបន់ ៤១ ទេ[771]។ ពាក់ព័ន្ធនឹងចម្លើយរបស់ ប្រាក់ យុត ថាតើ អោ អាន បានដឹកនាំការបោសសម្អាតអតីតកម្មាភិបាលភូមិភាគកណ្តាលដែរឬទេនោះ[772] ចៅក្រមអន្តរជាតិរកឃើញថា មានភាពមិនស៊ីសង្វាក់គ្នាជាក់ស្តែងរវាងចម្លើយរបស់គាត់ដែលអះអាងថា មានកម្មាភិបាលពីរបីនាក់ ឬគ្មានតែម្តង មានវត្តមាន នៅក្នុងស្រុករបស់គាត់ ពេលគាត់មកដល់ និងចម្លើយរបស់គាត់ដែលទទួលស្គាល់ថា គាត់បានដកអតីតកម្មាភិបាលចេញ តាមបញ្ជាពីថ្នាក់តំបន់ និងភូមិភាគ។ ទោះបីជាមានភាពមិនស៊ីសង្វាក់គ្នាក្តី ចៅក្រមអន្តរជាតិមិនយល់ឃើញថា វាមិនសមហេតុផលសម្រាប់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងការសន្និដ្ឋានថា អោ អាន បានបញ្ជាឲ្យធ្វើការបោសសម្អាតកម្មាភិបាលនៅថ្នាក់ស្រុក និងឃុំ នោះឡើយ បើ

---

ដែលនៅពេលនោះ ប៉ុល ពត បានប្រកាសថា កម្មាភិបាលភូមិភាគកណ្តាល ជា "ជនក្បត់"។

[770] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អោ អាន ចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០១១ ឯកសារ D219/847.1, ERN 01337370។

[771] សហចៅក្រមស៊ើបអង្កេតអន្តរជាតិយោងទៅការរៀបរាប់របស់សាក្សីជាច្រើនដែលមានតម្លៃជាភស្តុតាង ដែលពណ៌នាពីតួនាទីដឹកនាំរបស់ អោ អាន ក្នុងការបោសសម្អាតនៅក្នុងតំបន់ ៤១។ សូមមើល ឧទាហរណ៍ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តួយ មៀច ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D219/582, ERN 01166938-01166939 (ឆ.៧៦, ឆ.៧៧-ឆ.៧៨, ឆ.៨៣, ឆ.៨៦, ឆ.៨៨) 01166940-01166942 (ឆ.៩២-ឆ.១០៨)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/855, ERN 01344687-01344689 (ឆ.៣០-ឆ.៣៦, ឆ.៤២) 01344690-01344691 (ឆ.៤៦-ឆ.៤៧, ឆ.៥៣-ឆ.៥៤) 01344691 (ឆ.៥៦-ឆ.៥៩) 01344692-01344693 (ឆ.៦៣-ឆ.៦៤, ឆ.៧១, ឆ.៧៣) 01374650-01374651, (ឆ.៧៩-ឆ.៨៦) 01344694 (ឆ.១៣៨-ឆ.១៣៩)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ឯកសារ D219/138, ERN 01056048-01056049 (ឆ.៤៣-ឆ.៤៧) ("ប្រាក់ យុត បានជួបប្រជុំជាមួយនឹងមេភូមិ និងមេឃុំចាស់ៗ ហើយប្រាប់ពួកគេថា គាត់ឈប់ឲ្យពួកគេធ្វើជាមេឃុំ និងមេភូមិបន្តទៀតហើយ ... បទបញ្ជាច្បាស់ជាចេញពីតាអាន ហើយ ព្រោះគាត់ជាប្រធានតំបន់។ ខុម ជាអ្នកដឹក ប្រាក់ យុត ទៅប្រជុំជាមួយនឹងតាអាន នៅថ្នាក់តំបន់។ ពេលត្រឡប់មកវិញ ខុមបានប្រាប់ខ្ញុំថា គេនឹងចាត់ចែងឲ្យមានមេឃុំថ្មីហើយ") 01056061-01056062 (ឆ.៩៨, ឆ.១០០-ឆ.១០១)។ សូមមើលផងដែរខាងក្រោម មូលដ្ឋានទី ៦(v)(ខ)(៤) (ពិភាក្សាក្នុងចំណោមផ្សេងទៀតពីភស្តុតាងថា អោ អាន បានបញ្ជាឲ្យលេខាស្រុកសម្លាប់ប្រជាជនស៊ីវិលដែលតវ៉ាពីលក្ខខណ្ឌរស់នៅ និងធ្វើការរបស់ពួកគេ)។

[772] សូមមើល ឧបសម្ព័ន្ធ ឃ នៃបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1.5), ERN 01599798។

01634998



យោងតាមភស្តុតាងស៊ីសង្វាក់គ្នាពីសាក្សីផ្សេងទៀត រួមមាន ញឹម កុល[773] និងការវាយតម្លៃទូទៅទៅលើភាពអាចជឿជាក់បានរបស់ ប្រាក់ យុត[774]។

៤៥២. ចៅក្រមអន្តរជាតិបដិសេធមូលដ្ឋានទី ៦(iii)។

**មូលដ្ឋានទី៦(iv). តួនាទី និងសិទ្ធិអំណាចរបស់ អោ អាន នៅក្នុងភូមិភាគកណ្ដាល**

១. សារណា

៤៥៣. សហមេធាវីលើកឡើងថា អោ អាន មិនមានតួនាទី ឬសិទ្ធិអំណាចសំខាន់ៗថ្នាក់ភូមិភាគ នៅ ភូមិភាគកណ្ដាលឡើយ។ សហមេធាវីលើកឡើងថា អោ អាន មិនមែនជាលេខាស្ដីទីនៅក្នុង ភូមិភាគកណ្ដាលទេនៅពេលដែល កែ ពក អវត្តមាន និង មិនមែនជាអនុលេខាភូមិភាគ តាមព្រឹត្តិន័យ ឬនីតិន័យទេ[775]។ បើទោះបីជា អោ អាន បានកាន់មុខតំណែងទាំងនេះក៏ដោយ ក៏ការកាន់មុខតំណែងរយៈពេលខ្លីទាំងនេះមិនអាចចាត់ទុកថា គាត់ស្ថិតក្នុងចំណោមជនដែលទទួលខុសត្រូវខ្ពស់បំផុតដែរ[776]។

៤៥៤. ទីមួយ សហមេធាវីលើកឡើងថា សំអាងហេតុរបស់សហចៅក្រមអន្តរជាតិដែលថា អោ អាន គឺជាលេខាស្ដីទីនៃភូមិភាគកណ្ដាលនៅពេលដែល កែ ពក អវត្តមាន គឺមិនផ្អែកលើភស្តុតាង ច្បាស់លាស់ និង

---

[773] សូមមើល កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ញឹម កុល ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ D219/171, ERN 01065947-01065948 (ឆ.១៤-ឆ.១៥) ("ខ្ញុំធ្លាប់បានឃើញគេចាប់ប្រធានឃុំម្ដងនៅពីដើមឆ្នាំ១៩៧៧។ ពេលនោះ អ្នកដែលមកចាប់នោះគឺមានគ្នា ៥ នាក់មកពីខាងនិរតី។ ... ចំពោះប្រធានឃុំផ្សេងទៀតដែលខ្ញុំដឹងថាគេចាប់ខ្លួន គឺដោយសារយើងធ្លាប់ទៅធ្វើការជួបគ្នាពីមុនមក ប៉ុន្តែក្រោយពី ប្រាក់ យុត មកដល់ស្រុកកំពង់សៀម យើងពុំបានជួបមុខគ្នានៅកន្លែងធ្វើការទៀតទេ"។ សូមមើលជាទូទៅ ខាងលើ មូលដ្ឋានទី ៥(ii) សម្រាប់ការវាយតម្លៃលើភាពអាចជឿជាក់នៃភស្តុតាងរបស់ ញឹម កុល។

[774] ចៅក្រមអន្តរជាតិសង្កេតឃើញមានការប្រែប្រួលជាទូទៅក្នុងសក្ខីកម្មរបស់ ប្រាក់ យុត ទៅលើបញ្ហានេះ ក្រោយពីគាត់បានទទួលលិខិតធានាពីការិយាល័យសហចៅក្រមស៊ើបអង្កេត។ សូមមើលជាទូទៅ ខាងលើ មូលដ្ឋានទី ៥(ii) សម្រាប់ការវាយតម្លៃលើភាពអាចជឿជាក់នៃភស្តុតាងរបស់ ប្រាក់ យុត។

[775] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៩៣។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626072-01626073 ទំព័រ ១៨ បន្ទាត់ ៩ ដល់ ទំព័រ ១៩ បន្ទាត់ ១៦។

[776] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៩៣-៩៤, ១០៥។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626072-01626073 ទំព័រ ១៨ បន្ទាត់ ៩ ដល់ ទំព័រ ១៩ បន្ទាត់ ១៦។

01634999



មានការបញ្ជាក់ឡើយ ដោយហេតុថា សាក្សីដែលសហចៅក្រមស៊ើបអង្កេតពឹងផ្អែកលើនោះ គឺមិនស៊ីសង្វាក់ មានភាពប្រឡូសប្រឡាក់ ឬមាន "ចេតនា" ក្នុងការភូតកុហក[777]។ ពុំមានភស្តុតាងដែលថា អោ អាន ពិតជាលេខាស្ដីទីនៅពេល កែ ពក អវត្តមាននោះទេ[778] ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនអើពើចំពោះភស្តុតាងផ្ទុយដោយគ្មានការពន្យល់[779]។ ភស្តុតាងបង្ហាញថា កែ ពក មានអំណាចដាច់ណាត់គ្រប់ពេលវេលា និងថា កម្មាភិបាលដទៃទៀតជាអ្នកទទួលបន្ទុក នៅពេល កែ ពក អវត្តមាន[780]។

៤៥៥. ទីពីរ សំអាងហេតុដែលថា អោ អាន គឺជាអនុលេខាភូមិភាគតាមនីតិន័យ ឬព្រឹត្តិន័យ គឺផ្អែកប្រហាក់ប្រហែលគ្នាលើភស្តុតាងគ្មានមូលដ្ឋានគាំទ្រ និងប្រឡូសប្រឡាក់ ហើយសក្ខីកម្មគ្រាន់តែថ្លែងថា អោ អាន បានកាន់មុខតំណែងបែបនេះប៉ុណ្ណោះ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានផ្ដល់ភស្តុតាងពាក់ព័ន្ធនឹងកាលបរិច្ឆេទតែងតាំង មូលហេតុនៃការតម្លើងតួនាទី និង សេចក្ដីលម្អិតនៃតួនាទីភារកិច្ចរបស់ អោ អាន ឡើយ និងខកខានផងដែរមិនបានពន្យល់អំពីវិធីដែលគាត់សម្របសម្រួលភស្តុតាងប្រទាំងប្រទើសគ្នាទាក់ទិនទៅនឹងរយៈពេលកាន់តំណែងរបស់ អោ អាន និងពាក់ព័ន្ធនឹងសកម្មភាពនានាទាក់ទិនទៅនឹងភូមិភាគរបស់គាត់ ដូចជា ការត្រួតពិនិត្យមើលគម្រោងសាងសង់ ការផ្ដល់ធនធានដល់ការដ្ឋាននៅទូទាំងភូមិភាគនេះ និងចូលរួមកិច្ចប្រជុំថ្នាក់ភូមិភាគ[781]។ សហមេធាវីលើកទឡ្ហីករណ៍បន្ថែមថា មុខតំណែងរបស់គាត់ជាអនុលេខាភូមិភាគ ត្រូវបានប្រើប្រាស់ដើម្បីធ្វើសម្អាងហេតុជាច្រើនដោយពុំបានផ្ដល់នូវមូលដ្ឋានភស្តុតាងដែលមាន ហេតុផលឡើយ[782]។

៤៥៦. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា សហមេធាវីបានខកខានមិនបានបង្ហាញថា គ្មានអ្នកវិនិច្ឆ័យអង្គហេតុឥតលម្អៀងណាមួយអាចបានសន្និដ្ឋានថា អោ អាន បានធ្វើជាអនុ

---

[777] ណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៨៤-៨៥។

[778] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៨៦។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626072 ទំព័រ ១៨ បន្ទាត់ ១៨-២៥។

[779] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៨៧។

[780] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៨៧។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626073 ទំព័រ ១៩ បន្ទាត់ ១-៣។

[781] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៩៨-១០៣។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626073-01626074 ទំព័រ ១៩ បន្ទាត់ ៣ ដល់ ទំព័រ ២០ បន្ទាត់ ២។

[782] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១០៤។

លេខាភូមិភាគកណ្តាលតាមនីតិន័យ ឬព្រឹត្តិន័យឡើយ[783]។ ជាការពិតណាស់ យ៉ាងហោចណាស់ មានសាក្សីនិងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន៧នាក់ថ្លែងថា អោ អាន បានកាន់មុខតំណែងនេះ ហើយ អោ អាន ខ្លួនឯងបានទទួលស្គាល់ថាគាត់ស្ថិតក្នុងគណៈភូមិភាគកណ្តាល និងមានភស្តុតាងដែលបង្ហាញថាគាត់ធ្វើកិច្ចការនានា ដែលជាការទទួលខុសត្រូវថ្នាក់ភូមិភាគពាក់ព័ន្ធនឹងការសាងសង់ និងការងារយោធា[784]។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថែមទៀតថា តួនាទីរបស់ អោ អាន ជាលេខាតំបន់៤១ បញ្ជាក់បន្ថែមលើភស្តុតាងថាគាត់បម្រើការជាអនុលេខាភូមិភាគកណ្តាល ដោយហេតុថាមុខតំណែងនោះអាចទំនងជាត្រូវបានបំពេញដោយលេខានៃតំបន់មួយនៃតំបន់បីចំណុះភូមិភាគ[785]។ ចំនួនលើក និងភាពញឹកញាប់នៃឱកាសដែល អោ អាន ត្រូវបានតម្រូវឱ្យអនុវត្តតួនាទីភារកិច្ចរបស់ កែ ពក ក្នុងនាមជាលេខាភូមិភាគស្តីទី គឺមិនមែនជាកត្តាកំណត់ថាតើ អោ អាន ជាអនុលេខាភូមិភាគ ឬយ៉ាងណានោះទេ[786]។

៤៥៧. នៅក្នុងការឆ្លើយតបរបស់ខ្លួន សហមេធាវីអះអាងថា សហព្រះរាជអាជ្ញាមិនអើពើភស្តុតាងដោះបន្ទុកដ៏សំខាន់ៗដែលបង្ហាញថា អោ អាន មិនបានកាន់មុខតំណែងជាអនុលេខាភូមិភាគកណ្តាល តាមនីតិន័យ ឬព្រឹត្តិន័យឡើយ[787]។

## ២. ការពិភាក្សា

### *ក. អនុលេខាភូមិភាគកណ្តាល*

៤៥៨. ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសក្នុងការរកឃើញថា អោ អាន គឺជាអនុលេខានៃភូមិភាគកណ្តាលចាប់ពីចុងឆ្នាំ១៩៧៧ រហូតដល់ចុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។

៤៥៩. ទីមួយ ពាក់ព័ន្ធនឹងការពឹងផ្អែកលើសក្ខីកម្មរបស់សាក្សីពីររូប (បាន សៀក និង អ៊ឹម ប៉ុន) ដែល ពុំ

---

783 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៧៩។

784 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៨០-៨១។ ប្រតិចារឹកថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/8.1 & D360/17.1, ERN 01626043-01626044 ទំព័រ ៥៤ បន្ទាត់ ២៣ ដល់ ទំព័រ ៥៥ បន្ទាត់ ៨។

785 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៨១។

786 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៧៩-៨៣។

787 ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៤២។

មានភស្តុតាងគាំទ្រ និងដែលប្រឡូសប្រឡាក់ ក្នុងការគាំទ្រសំអាងហេតុដែលថា អោ អាន គឺជា អនុលេខាភូមិភាគកណ្តាល[788] ចៅក្រមអន្តរជាតិយល់ឃើញថា ពុំមានការអនុវត្តមិនត្រឹមត្រូវរបស់អ្នកស៊ើបអង្កេតទេ[789] និងចាត់ទុកថាជាការសមហេតុផលដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិពឹងផ្អែកលើការរៀបរាប់ដំណើររឿងរបស់សាក្សីពីរនាក់នៅក្នុងការធ្វើសំអាងហេតុថាអោអាន គឺជាអនុលេខាភូមិភាគ[790]។ ជាងនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិពឹង ផ្អែកលើភស្តុតាងរបស់សាក្សី បន្ថែមមួយចំនួនធំ ដែលអះអាងបញ្ជាក់ថា អោ អាន ជាអនុលេខាភូមិភាគកណ្តាល[791]។ សំអាងហេតុនេះត្រូវបានអះអាង

---

[788] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៩៩ ជើងទំព័រ ២១២ *យោងទៅ* រឿងរ៉ាវរបស់សាក្សី បាន សៀក និង អ៊ឹម ប៊ុន ដែលត្រូវបានចោទប្រកាន់ថាបានធ្វើឡើងតាមរយៈសំណួរបិទ និង "ការផ្តល់" ព័ត៌មាន។ ចៅក្រមអន្តរជាតិសង្កេតឃើញថា សហមេធាវីធ្លាប់បានជំទាស់ទៅនឹងចម្លើយទាំងនេះរួចមកហើយ។ *សូមមើល* ឧបសម្ព័ន្ធ ខ នៃ សំណើសុំធ្វើមោឃភាពកំណត់ហេតុការស្តាប់ចម្លើយសាក្សី ឯកសារ D338/1/2.3 នៅត្រង់ ERN (ភាសាអង់គ្លេស) 01388928-01388933 លេខរៀង ៦, ៧។ នៅពេលពិនិត្យទៅលើខ្លឹមសារនៃការស្តាប់ចម្លើយនេះ ចៅក្រមអន្តរជាតិយល់ឃើញថា ពុំមានប៉ះពាល់ដល់តម្លៃជាភស្តុតាងនៅទីនេះទេ។

[789] *សូមមើលខាងលើ* មូលដ្ឋានទី ៥(iii)។

[790] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៥២ *យោងទៅ* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី បាន សៀក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៤ ឯកសារ D117/35 នៅត្រង់ ERN 00980366 (ឆ.១៥) ("តាមខ្ញុំដឹង តា អាន គឺជាអនុរបស់ កែ ពក នៅក្នុងគណៈអចិន្ត្រៃយ៍ភូមិភាគ")។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី បាន សៀក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D219/355 នៅត្រង់ ERN 01104608 (ឆ.៩) ("ខ្ញុំគ្រាន់តែដឹងថា គាត់ជាអ្នកទទួលខុសត្រូវតំបន់ ហើយស្ថិតនៅក្នុងគណៈអចិន្ត្រៃយ៍របស់ភូមិភាគ ហើយគាត់គឺជាអនុម្នាក់របស់ កែ ពក") ។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី បាន សៀក ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ D6.1.386 នៅត្រង់ ERN 00348800 ("ចំពោះភូមិភាគមានដូចជា [...] និងឈ្មោះ អាន [...] ជាលេខាស្រុក ៤២")។ ប្រតិចារឹកថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៥ ក្នុងសំណុំរឿង ០០២/២ (បាន សៀក) ឯកសារ D219/702.1.75 នៅត្រង់ ERN 01424074 ទំព័រ ៤៥ ("តា អាន ជាលេខាតំបន់ ជាគណៈអចិន្ត្រៃយ៍របស់ភូមិភាគ ហៅអនុភាគក៏បាន ហៅអចិន្ត្រៃយ៍ក៏បាន ហើយគាត់ទទួលតំបន់ ៤១")។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី អ៊ឹម ប៊ុន ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D117/50 នៅត្រង់ ERN 00990812 (ឆ.២៩), 00990817 (ឆ.៦៨), 00990819 (ឆ.៧៥) ("បាទៗ តាអាន ហ្នឹងគាត់ជាអនុ។ បើនិយាយពីខាងភូមិភាគ គាត់អនុ តាពក [...] តាអាន ហ្នឹងគាត់ខាងអនុភូមិភាគដែរ")។ សាក្សី អ៊ឹម ប៊ុន គឺជាអ្នកបើកឡានឲ្យ អោ អាន។ សាក្សី បាន សៀក គឺជាប្រធានពាណិជ្ជកម្មនៅតំបន់ ៤១ និងជាអនុលេខាស្រុកចម្ការលើ។

[791] *សូមមើលឧទាហរណ៍* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជីម ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ D117/18 នៅត្រង់ ERN 00893171 (ឆ.២) ("ក្រោយពេលចាប់ខ្លួន សែ ខ្ញុំដឹងថា តាអាន គឺជាអនុរបស់ កែ ពក តែម្នាក់ដែលនៅសល់")។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី សួន កានិល ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ ឯកសារ D6.1.707 នៅត្រង់ ERN 00373509 ("ក្រោយពេលនិរតីចូលមកគឺមាន កែ ពក ជាប្រធានដដែល តា [...] អាន [...] (មកពីនិរតី) ជាអនុប្រធាន [...]")។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី សួន កានិល ចុះថ្ងៃទី១០ ខែ

បញ្ជាក់បន្ថែមដោយមុខតំណែងរបស់ អោ អាន ជាសមាជិកគណៈកម្មាធិការភូមិភាគកណ្តាល និងដោយតួនាទីរបស់គាត់ជាលេខាតំបន់៤១[792]។

៤៦០. ទីពីរ ពាក់ព័ន្ធនឹងការតែងតាំង អោ អាន ជាអនុលេខាភូមិភាគ[793] ចៅក្រមអន្តរជាតិកត់សម្គាល់ថា ដោយមិនបានបញ្ជាក់ច្បាស់នូវកាលបរិច្ឆេទនៃការតែងតាំង អោ អាន សហចៅក្រមស៊ើបអង្កេត អន្តរជាតិរកឃើញថា អោ អាន បានកាន់មុខតំណែងជាអនុលេខាភូមិភាគកណ្តាលចាប់ពីចុងឆ្នាំ ១៩៧៧[794]។ ចៅក្រមអន្តរជាតិយល់ឃើញថា សហមេធាវីខកខានមិនបានចង្អុលបញ្ជាក់កំហុស ជាក់លាក់នៅក្នុងភស្តុតាងដែលគាំទ្រដល់សំអាងហេតុដែលថា អោ អាន បានកាន់មុខតំណែង របស់គាត់ចាប់ពីចុងឆ្នាំ១៩៧៧ [795] និងអង្កេតឃើញថា កាលបរិច្ឆេទប៉ាន់ប្រមាណនេះមានលក្ខណៈគ្រប់គ្រាន់សម្រាប់គោលបំណងនៃការធ្វើសំអាងហេតុលើយុត្តាធិការបុគ្គល។

៤៦១. ទីបី ពាក់ព័ន្ធនឹងការខកខានក្នុងការពន្យល់អំពីភស្តុតាងផ្ទុយគ្នាទាក់ទិននឹងរយៈពេលនៃការកាន់មុខតំណែងរបស់ អោ អាន ជាអនុលេខាតំបន់ [796] ជាការផ្ទុយទៅនឹងអំណះអំណាងរបស់សហមេធាវី

---

មិថុនា ឆ្នាំ២០១១ ឯកសារ D29 នៅត្រង់ ERN 00705151 ("សំនួរ៖ តើលោកស្គាល់ តាអាន ទេ? [...] "ឆ្លើយ៖ បាទខ្ញុំស្គាល់គាត់។ គាត់គឺជាលេខាតំបន់ ៤១ ហើយគាត់ក៏ជាអនុលេខាភូមិភាគកណ្តាលផងដែរ")។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី គូ សែម ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៥ ឯកសារ D117/39 នៅត្រង់ ERN 00993585 (ឆ.១៤) ("រចនាសម្ព័ន្ធគណៈភូមិភាគ គឺដូចជា៖ កែ ពក ប្រធាន, តាអាន អនុ និង តាស៊ឹម សមាជិក")។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី គុច វ៉ា ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ D219/178 នៅត្រង់ ERN 01066300 (ឆ.៦) ("តាអាន គឺជាអនុ កែ ពក និងជាសមាជិកគណៈភូមិភាគ")។

[792] *សូមមើលខាងក្រោម* មូលដ្ឋានទី ៦(v)។ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ២៥០-២៥១។

[793] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៩៩ ជើងទំព័រ ២១៤។

[794] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៥០, ២៥២។

[795] សហមេធាវីចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិគ្រាន់តែលើកឡើងថា ក្រោយពេលបញ្ជូន កង ចាប ទៅភូមិភាគពាយ័ព្យ នៅឯកាលបរិច្ឆេទដែលគេមិនដឹងនោះ អោ អាន ក្លាយជាអនុលេខានៅភូមិភាគកណ្តាល៖ *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៩៩ ជើងទំព័រ ២១៤។ ទោះជាយ៉ាងណាក្តី សហចៅក្រមស៊ើបអង្កេតអន្តរជាតិបញ្ជាក់ច្បាស់ថា កង ចាប ត្រូវបានដកចេញពីអនុលេខាភូមិភាគកណ្តាលនៅចុងឆ្នាំ១៩៧៧ ហើយបន្ទាប់មក អោ អាន ក្លាយជាអនុលេខាភូមិភាគកណ្តាល *សូមមើល* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៥០, ២៥២។ សហមេធាវីមិនជំទាស់ទៅនឹងភស្តុតាងជាមូលដ្ឋានអំពីការធ្វើសេចក្តីសន្និដ្ឋាននេះទេ ហេតុនេះ ចៅក្រមអន្តរជាតិយល់ឃើញថា ជាការសមហេតុសមផលដែលសហចៅក្រមស៊ើបអង្កេតសំអាងទៅលើពេលវេលាដែលប៉ាន់ស្មានថានៅ "ចុងឆ្នាំ១៩៧៧"។

[796] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៩៩ ជើងទំព័រ ២១៦ *យោងទៅ* ចម្លើយរបស់សាក្សី អ៊ឹម ប៊ុន

ទោះបីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកលើភស្តុតាងរបស់ អ៊ឹម ប៊ុន[797] និង រី ញ៉[798] ក្នុងការសន្និដ្ឋានថា អោ អាន បានកាន់មុខតំណែងជាអនុលេខាភូមិភាគ កណ្តាលរហូតដល់ចុងរបបក៏ដោយ[799] ក៏គាត់បានពិចារណាលើភស្តុតាងផ្ទុយគ្នារបស់ តូ សែម[800] និងបានផ្តល់មូលហេតុគ្រប់គ្រាន់ថាហេតុអ្វីបានជាគាត់ចាត់ទុកការរៀបរាប់ដំណើររឿងរបស់ អ៊ឹម ប៊ុន អាចជឿជាក់បានច្រើនជាង[801]។

៤៦២. ចំណុចចុងក្រោយ ពាក់ព័ន្ធនឹងតួនាទីភារកិច្ចទូទៅរបស់ អោ អាន ក្នុងនាមជាអនុលេខាភូមិភាគ កណ្តាលនិងសកម្មភាពនានាពាក់ព័ន្ធនឹងភូមិភាគ[802] អង្គបុរេជំនុំជម្រះពុំរកឃើញកំហុសរបស់សហចៅក្រម

---

និងសាក្សី តូ សែម។

[797] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៥២ ជើងទំព័រ ៦២១ *យោងទៅ* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី អ៊ឹម ប៊ុន ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D117/50 នៅត្រង់ ERN 00990817 (ឆ.៦៧-៦៨) ("ស៖ តាមដែលលោកដឹង តាអាន ជាអនុភូមិភាគរហូតដល់ចប់សម័យនុំងឬ? ឆ.៦៧៖ បាទៗ។ ស៖ តាមដែលលោកដឹង មានពេលណាមួយគាត់បានខ្វែងគំនិតអ្វីជាមួយ កែ ពក ហើយក្រោយមកគេដកបុណ្យ ដកស័ក្តិពីគាត់ដែរឬទេ? ឆ.៦៨៖ ដូចអត់ដែល អត់មានដឹងអីផង។ គេអត់បានដកគាត់ទេនាសម័យនោះ")។

[798] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៥២ ជើងទំព័រ ៦២២ *យោងទៅ* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី រី ញ៉ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ D219/870 នៅត្រង់ ERN 01348887 (ឆ.៤១) ("ស៖ តើយល់ត្រូវដែលទេដែលថា តើលោកចង់និយាយថា លោកឮគេថា តាអាន ជាអនុប្រធានភូមិភាគជិតដាច់របបមែនទេ? ឆ.៤១៖ ជិតដាច់របប។")។

[799] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៥២, ៧០៥។

[800] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៥២ ជើងទំព័រ ៦២៣ *យោងទៅ* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី តូ សែម ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៤ ឯកសារ D117/39 នៅត្រង់ ERN 00993585 (ឆ.១៥) ("ស៖ ក្នុងរយៈពេលដែលលោកស្រីនៅក្នុងភូមិភាគកណ្តាល តើលោកស្រីមានបានសង្កេតឃើញមានការផ្លាស់ប្តូរថ្នាក់ដឹកនាំភូមិភាគដែរឬទេ? ឆ.១៥៖ ចាំ មានការផ្លាស់ប្តូរ។ ពេលនោះ កែ ពក នៅតែជាប្រធាន តាអាន ត្រូវបានទម្លាក់ទៅជាសមាជិក ហើយ តាស៊ឹម ត្រូវបានចាត់តាំងឱ្យធ្វើជាអនុប្រធាន [...]"), 00993586 (ឆ.១៩) ("ស៖ លោកស្រីចាំទេ តើពេលណា គេទម្លាក់ តាអាន មកជាសមាជិក ហើយឱ្យ តាស៊ឹម ឡើងជាអនុរបស់ កែ ពក? ឆ.១៩៖ រឿងនេះ កើតឡើងប្រហែលជា៦ខែ មុនពេលវៀតណាមមកដល់ [...]")។

[801] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៥២ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិពន្យល់ថា គាត់ពិចារណាឃើញថា ភស្តុតាងរបស់អ្នកបើកបររថយន្តរបស់ អោ អាន ដែលធ្វើការងារជិតស្និទ្ធជាមួយ អោ អាន មានភាពជឿជាក់បានជាងភស្តុតាងរបស់ប្រពន្ធកម្មាភិបាលតំបន់ម្នាក់ទៀត)។

[802] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៩៩-១០៤។ ចៅក្រមអន្តរជាតិកត់សម្គាល់ថា អង្គជំនុំជម្រះមាន "ឆន្ទានុសិទ្ធិពេញលេញ ក្នុងធ្វើការជ្រើសរើសសារណាដែលសក្តិសមនឹងយកមកបញ្ចេញមតិយោបល់ជាលាយលក្ខណ៍អក្សរដែលមានសំអាងហេតុលម្អិត" [...] ហើយ "អាចបដិសេធចោលភ្លាមៗនូវទឡ្ហីករណ៍នានាដែលពុំមានសក្តានុពលដែលនាំឱ្យ

ស៊ើបអង្កេតអន្តរជាតិដែលផ្តល់សំអាងហេតុថា "ក្នុងឋានៈជាអនុលេខានិងជាសមាជិក គណៈភូមិភាគកណ្តាល អោ អាន បានប្រើសិទ្ធិអំណាចថ្នាក់ភូមិភាគគ្រប់ទិដ្ឋភាពនោះឡើយ[803]។ គាត់បញ្ជាក់ថែមទៀតថា អោ អាន ជាប់ពាក់ព័ន្ធក្នុងគម្រោងសាងសង់ទូទាំងភូមិភាគកណ្តាល ហើយថា អោ អាន បានចុះពិនិត្យតំបន់និងការដ្ឋានដទៃទៀតទូទាំងភូមិភាគ និងបានផ្តល់កម្មករនិងធនធានពីតំបន់៤១[804] និងថា អោ អាន បានចូលរួមប្រជុំនៅភ្នំពេញ[805] និងនៅកំពង់ចាម ដើម្បីរៀបចំផែនការបោសសំអាត និងអនុវត្តគោល

---

បដិសេធ ឬកែប្រែសេចក្តីសម្រេចដែលត្រូវបានជំទាស់ [...]" ។ *សូមមើលឧទាហរណ៍* សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេត លេខD250/3/3 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ និងដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ លើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ ឯកសារ D250/3/2/1/5 (សំណុំរឿង ០០២ សាលដីកាលើអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឯកសារD250/3/2/1/5) កថាខណ្ឌ២២។ *សូមមើលផងដែរ* តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Gotovina និង Markač* សំណុំរឿងលេខ IT-06-90-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១២ កថាខណ្ឌ ១៤។ តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Prlić និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-04-74-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ កថាខណ្ឌ ១៣។

[803] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៥៩។

[804] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៥៩។ សហមេធាវីជំទាស់ទៅនឹងសេចក្តីសន្និដ្ឋាននេះ *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១០១ ជើងទំព័រ ២២០-២២៦ ដោយផ្អែកលើមូលដ្ឋានថា ភស្តុតាងនេះពុំមានមូលដ្ឋាន និងពុំមានការបញ្ជាក់បន្ថែម ហើយថា អោ អាន ត្រឹមតែដឹកនាំកងកម្លាំងទៅតំបន់ ៤១ ទៅតាមការដ្ឋានសាងសង់ថ្នាក់ភូមិភាគប៉ុណ្ណោះ អោ អាន ពុំមានការគ្រប់គ្រង ឬបាត់ចែងនៅតាមការដ្ឋានទេ ហើយគាត់មិនបានផ្តល់ធនធានដល់ការដ្ឋានទាំងនេះដែរ។ ចៅក្រមអន្តរជាតិមិនជឿ ហើយយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានកំហុសឆ្គងទេក្នុងការសំអាងទៅលើចម្លើយរបស់សាក្សី ចាន់ សាង ឬចម្លើយរបស់ អោ អាន ផ្ទាល់ និងបានសន្និដ្ឋានថា វាជារឿងសមហេតុផលដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិធ្វើសេចក្តីសន្និដ្ឋានទាំងនេះ ទាក់ទិននឹងភស្តុតាងរួម។

[805] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៥៩។ សហមេធាវីជំទាស់ទៅនឹងសេចក្តីសន្និដ្ឋាននេះ *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៨៦ ជើងទំព័រ ១៨០។ សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិសំអាងទៅលើសាក្សីដែលពុំមានការបញ្ជាក់បន្ថែម ពោលគឺសក្ខីកម្មរបស់សាក្សី យូ វ៉ាន់ ក្នុងពេលជំនុំជម្រះក្នុងសំណុំរឿង ០០២/២ ដែលគាត់ "បានផ្តល់ភស្តុតាងចចាមអារ៉ាមមិនស៊ីចង្វាក់គ្នារបស់ ប្រាក់ យុត" ដោយ ប្រាក់ យុត បានប្រាប់ យូ វ៉ាន់ ថា អោ អាន បានធ្វើដំណើរតាមឡានជារៀងរាល់ខែ ទៅចូលរួមកិច្ចប្រជុំនៅក្រុងភ្នំពេញ" *សូមមើល* ប្រតិចារឹកថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ ក្នុងសំណុំរឿង ០០២/២ (យូ វ៉ាន់) ឯកសារ D219/702.1.87 នៅត្រង់ ERN 01451947 ទំព័រ ៤៥ ("[គាត់]មកភ្នំពេញ ប៉ុន្តែជិះឡានជាមួយ តាអាន។ គាត់ប្រាប់ថា គាត់មកប្រជុំ [...]")។ ចៅក្រមអន្តរជាតិរម្លឹកថា ចៅក្រមអន្តរជាតិ បានសន្និដ្ឋានថាសក្ខីកម្មរបស់សាក្សី យូ វ៉ាន់ អាចជឿជាក់បានជាទូទៅ និងរម្លឹកដល់ការសន្និដ្ឋានរបស់អង្គជំនុំជម្រះនៅក្នុងមូលដ្ឋានទី ៥(v) ទាក់ទិននឹងភស្តុតាងចចាមអារាម។ នៅទីនេះ ចៅក្រមអន្តរជាតិសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានកំហុសឆ្គងទេក្នុងការសំអាងទៅលើរឿងរ៉ាវរបស់សាក្សី យូ វ៉ាន់ ក្នុងការធ្វើសេចក្តីសន្និដ្ឋានជាក់លាក់នេះ។

នយោបាយ ប.ក.ក[806]។

៤៦៣. ជាងនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិរកឃើញថា សិទ្ធិអំណាចរបស់ អោ អាន បាន លាតសន្ធឹងដល់បញ្ហាយោធារបស់ភូមិភាគទៀតផង[807]។ សហមេធាវីតវ៉ាថា សម្អាងហេតុនេះ មិនមានការគាំទ្រដោយភស្តុតាងផ្ទាល់ ពិតប្រាកដ និងមានការបញ្ជាក់ឡើយ[808] ក៏ប៉ុន្តែ *ក្នុង ចំណោមបញ្ហាផ្សេងៗទៀត* សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកលើការរៀបរាប់ដំណើរ រឿងរបស់ គុច វ៉ា ក្នុងការផ្ដល់អំណះអំណាងថា អោ អាន បានតែងតាំងមេបញ្ជាការនិង អនុបញ្ជាការកងពលថ្នាក់ភូមិភាគនៃកងទ័ពបដិវត្តកម្ពុជា[809]។ ចៅក្រមអន្តរជាតិយល់ឃើញថា ការរៀបរាប់ដំណើររឿងរបស់ គុច វ៉ា ត្រូវបានបញ្ជាក់ជាទូទៅដោយភស្តុតាងដទៃទៀត[810] និង មានរៀបរាប់លម្អិតនៅក្នុងព្រឹត្តិការណ៍មុនៗ៖ ពោលគឺ ការផ្ទុះនៅក្រុង

---

[806] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៥៩។ សហមេធាវីការពារជំទាស់ទៅនឹងការធ្វើសេចក្ដីសន្និដ្ឋាននេះ *សូមមើល* បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១០៣។ ចៅក្រមអន្តរជាតិកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិសំអាងទៅលើសាក្សីជាច្រើននាក់ដែលត្រូវបានសន្និដ្ឋានថាអាចជឿជាក់បានជាទូទៅ។ *ឧទាហរណ៍* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ឯកសារ D219/731 នៅត្រង់ ERN 01218073 (ឆ.៣៦) ("ស៖ គាត់ធ្លាប់ទៅចូលរួមប្រជុំនៅកំពង់ចាមទេ? ឆ.៣៦៖ ទៅប្រជុំជាមួយតាពក") (ឆ.៤០) ("ស៖ អាចលើកបានខ្លះទេ ការចងចាំហ្នឹង ដូចជាកិច្ចប្រជុំ? ឆ.៤០៖ ខ្ញុំចាប់បានខ្លះដែរ ដូចជាខ្មាំងហ្នឹង ធ្វើម៉េចយើងធ្វើឱ្យបាន ចាប់ម្ដងមួយៗមកឱ្យអស់ ខ្មាំងចាប់ឱ្យអស់ [...]")។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/855 នៅត្រង់ ERN 01344684 (ឆ.៥) ("ក្នុងវគ្គពេល១ខែ គេបូកសរុបម្ដង។ ខ្ញុំធ្លាប់ទៅប្រជុំជាមួយ [អោ អាន] បានប្រហែលបួនដង"), 01344686 (ឆ.១៧, ឆ.២១) ("ការប្រជុំនិយាយពីផែនការចាប់ខ្មាំង [...] [អោ អាន] គាត់ភូមិភាគ សមាជិកភូមិភាគដាក់ដាក់គាត់ ហើយទទួលបន្ទុកតំបន់មែន ប៉ុន្តែធ្វើការនៅក្នុងភូមិភាគហ្នឹងដែរ ជាមួយ តាពក") 01344687 (ឆ.២៩) ("[តាពក]និយាយដែរ និយាយរួមខ្មាំង រយៈពេលហ្នឹង ឱ្យចុះតាមស្រុក ចាត់ផែនការហ្នឹងទៅស្រុក ទៅដល់អត់ឱ្យឈប់ទេ ចុះតាមស្រុកចាប់ឱ្យរហ័ស ព្រោះផែនការគេជិតដល់ហើយ")។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយសាក្សី បាន សៀក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១២ ឯកសារ D107/15 នៅត្រង់ ERN 00800954 ("គណៈអចិន្ត្រៃយ៍របស់ភូមិភាគមានគណៈតំបន់បីនាក់ គឺ តាអាន [...]។ តាមដែលខ្ញុំដឹង ការសម្រេចសំខាន់ៗដូចជាការបោសសម្អាតជាដើម ត្រូវបានសម្រេចដោយគណៈអចិន្ត្រៃយ៍នេះនៅក្នុងការប្រជុំសម្ងាត់របស់គេ។ មន្ទីរភូមិភាគកណ្ដាលរបស់ កែ ពក ស្ថិតនៅក្នុងក្រុងកំពង់ចាម")។ *សូមមើលខាងក្រោម* មូលដ្ឋានទី ៥(ii) និង មូលដ្ឋានទី ៦(v)។

[807] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៦០។

[808] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១០៣ ជើងទំព័រ ២២៨-២២៩។

[809] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយសាក្សី គុច វ៉ា ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ D219/178 នៅត្រង់ ERN 01066299 (ឆ.៣-៤) ("តាអាន [...] តែងតាំង ហឿន [...] តាអាន ដែលជាអនុភូមិភាគក៏មានសិទ្ធិសម្រេចដាក់ឱ្យគ្នាគាត់ធ្វើការនៅក្នុងអង្គភាពថ្មីនោះដែរ")។

[810] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៦០ ជើងទំព័រ ៦៥៧-៦៥៨។ *ឧទាហរណ៍* អោ

កំពង់ចាម និងការចាប់ខ្លួនមេបញ្ជាការកងពល១៧៤[811] ហេតុដូចនេះ គួរឱ្យជឿជាក់បាន។

៤៦៤. ហេតុដូច្នេះ ចៅក្រមអន្តរជាតិយល់ឃើញថា សហមេធាវីបានខកខានមិនបានបង្ហាញថា គ្មាន អ្នកវិនិច្ឆ័យអង្គហេតុឥតលម្អៀងណាមួយអាចបានសន្និដ្ឋានថា អោ អាន បានកាន់មុខតំណែងជាអនុលេខាភូមិភាគកណ្ដាលចាប់ពីចុងឆ្នាំ១៩៧៧ ដល់ចុងរបប ឬថា អោ អាន បានប្រើសិទ្ធិអំណាចថ្នាក់ភូមិភាគគ្រប់ទិដ្ឋភាពនោះឡើយ។

*ខ. លេខាភូមិភាគកណ្ដាលស្ដីទី*

៤៦៥. សហមេធាវីតវ៉ាចំពោះសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា "អោ អាន ធ្វើជាលេខាភូមិភាគកណ្ដាលស្ដីទីក្នុងរយៈពេលដែល កែ ពក អវត្តមានពីភូមិភាគ ឬឈឺ"[812]។

៤៦៦. នៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រេចថា "មានភស្តុតាងបង្ហាញថា អោ អាន ជាលេខាភូមិភាគកណ្ដាលស្ដីទីក្នុងពេល កែ ពក អវត្តមាន ឬឈឺ [...]។ ការអះអាងដែលថា អោ អាន ជាលេខាភូមិភាគកណ្ដាលតាមព្រឹត្តិន័យគឺត្រូវបានគាំទ្រដោយអតីតកម្មាភិបាលមួយចំនួន [...]។ ប៉ុន្តែទោះជាយ៉ាងណា ពុំមានសាក្សីណាម្នាក់បង្ហាញ *ករណីជាក់លាក់ថា គាត់កាន់តួនាទីនេះនៅពេលណា និងប៉ុណ្ណានោះទេ*"[813]។ ជាងនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសន្និដ្ឋាននៅពេលក្រោយមកនៅក្នុងផ្នែកយុត្តាធិការបុគ្គលថា "ក៏មានភស្តុតាងគ្រប់គ្រាន់អាចសន្និដ្ឋានបានផងដែរថា អោ អាន បានកាន់កាប់មុខងាររបស់ កែ ពក ច្រើនឡើងៗក្នុងនាមជាលេខាភូមិភាគកណ្ដាលស្ដីទីនៅក្នុងស្ថានភាពជាក់ស្ដែងមួយផ្នែក ដោយសារថា កែ ពក នៅជាប់ការងារសឹកសង្គ្រាម។ ប៉ុន្តែមិនច្បាស់ថា តើនៅពេលណាពិតប្រាកដ និងរយៈពេលយូរប៉ុន្មានដែលតួនាទីនេះត្រូវបានអនុវត្ត ហើយករណីដែល

---

អាន បានទៅចូលរួមប្រជុំផ្នែកយោធាថ្នាក់ភូមិភាគជាប្រចាំ។

[811] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៦០ជើងទំព័រ ៦៥៦ *យោងទៅឧទាហរណ៍* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយសាក្សី សួន កានិល ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ ឯកសារ D6.1.707 នៅត្រង់ ERN 00373514 ("ឃុល មិន [...] គេចាប់ខ្លួនគាត់ ពីព្រោះមានហេតុការណ៍មួយនៅកំពង់ចាម។ ពេលនោះ មានផ្ទុះគ្រាប់បែកមួយយ៉ាងធំ ដែលធ្វើឱ្យផ្ទះមួយចំនួននៅក្បែរកងពលត្រូវឆេះខ្ទេចខ្ទី ហើយកញ្ចក់អគារត្រូវបានបែកបាក់")។

[812] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៩៤ ជើងទំព័រ ២០០ *យោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៥៥។

[813] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៥៥ (គូសបញ្ជាក់បន្ថែម)។

គាត់បានប្រើប្រាស់តួនាទីពិសេសនេះក៏ *មិនអាចរកឃើញមានដែរ*”[814]។

៤៦៧. ទីមួយ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសក្នុង ការសន្និដ្ឋានថា អោ អាន ជាលេខាស្តីទីនៃភូមិភាគកណ្តាលពីខែតុលា ឆ្នាំ១៩៧៨ នៅពេល កែ ពក អវត្តមាននោះទេ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិពឹងផ្អែកលើ ហៀន សាវ៉ាយ ដែលរៀបរាប់ដំណើររឿងច្បាស់លាស់អំពីការណ៍ដែល កែ ពក ចាត់តាំង អោ អាន ជាអ្នកជំនួស ដោយបានបញ្ជាក់ថា ការណ៍នេះបានកើតឡើងនៅក្នុងកំឡុងកិច្ចប្រជុំមួយនៅកំពង់ចាមប្រហែលបីខែមុនពេលចប់របប[815]។ ជាងនេះទៀត ក្នុងលក្ខណៈជាភស្តុតាងបញ្ជាក់បន្ថែម អតីតអ្នកបើកបរ របស់ អោ អាន ឈ្មោះ អ៊ុំ ប៊ុន រៀបរាប់ឡើងវិញថា អោ អាន ធ្វើការងារជំនួស កែ ពក នៅពេលកែ ពក អវត្តមាន និងថាគាត់បានចាត់ចែងការងារនៅការដ្ឋាននៅកំពង់ចាម។[816] ចៅក្រមអន្តរជាតិសង្កេតឃើញថា សំអាងហេតុនេះផ្អែកលើភស្តុតាងគ្រប់គ្រាន់ ហេតុដូចនេះ គឺមិនមែនមិនមានហេតុផលនោះទេ។

៤៦៨. ពាក់ព័ន្ធនឹងទឡ្ហីករណ៍របស់សហមេធាវីដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនអើពើ ភស្តុតាងផ្ទុយដោយគ្មានការពន្យល់នោះ ចៅក្រមអន្តរជាតិរម្លឹកឡើងវិញ “នូវគោលការណ៍សច្ចធារណ៍ថា សហចៅក្រមស៊ើបអង្កេត [អន្តរជាតិ] [បាន] វាយតម្លៃគ្រប់ភស្តុតាងទាំងអស់ ហើយពុំចាំបាច់ លើកឡើងគ្រប់ភស្តុតាងនៅក្នុងសំណុំរឿងនោះទេ ដរាបណាពុំមានការបញ្ជាក់ថា [សហចៅក្រមស៊ើបអង្កេត] ប្រានចោលទាំងស្រុងនូវគ្រប់ភស្តុតាងទាំងអស់នោះ។ សច្ចធារណ៍នេះអាចជំទាស់តវ៉ាបាននៅពេលភស្តុ

---

[814] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៧០៥ (គូសបញ្ជាក់បន្ថែម)។

[815] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ហៀន សាវ៉ាយ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ ឯកសារ D219/762 នៅត្រង់ ERN 01242622-01242623 (ឆ.១៨, ឆ.២២-ឆ.២៦) (“ពេលបងពក អវត្តមាន គាត់ឲ្យបងអានជំនួស [...] ។ គេចាត់តាំងគាត់ [...] [កែ ពក និយាយថា នៅពេលគាត់មិននៅគឺមាន បងអាន ស្តីទី។ ទាំងអស់គ្នាទះអបអរសាទរ”)។ នៅក្នុងចម្លើយពីមុន សាក្សី ហៀន សាវ៉ាយ ពន្យល់ថា “ខ្ញុំដឹងថា នៅពេលលេខាភូមិភាគអវត្តមាន សមាជិកគណៈភូមិភាគនៅក្រោយលេខាជាអ្នកទទួលខុសត្រូវ”)។ ទោះជាយ៉ាងណាក្តី នៅពេលសាកសួរថាតើ អោ អាន គឺជាសមាជិកដំបូងនៅក្នុងគណៈកម្មាធិការភូមិភាគ ហើយទទួលខុសត្រូវការងារនៅភូមិភាគពេល កែ ពក វត្តមាន ឬយ៉ាងណា សាក្សី ហៀន សាវ៉ាយ ឆ្លើយថា “ខ្ញុំមិនដែលឃើញ ឬដឹងរឿងនេះដោយផ្ទាល់ភ្នែកទេ”។ *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ហៀន សាវ៉ាយ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D219/353 នៅត្រង់ ERN 01104593-01104594 (ឆ.៤-៥)។

[816] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី អ៊ុំ ប៊ុន ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D117/50 នៅត្រង់ ERN 00990812 (ឆ.៣១) (“ស៖ តើលោកដឹងដោយរបៀបណាថា តាអាន ជាអនុលេខារបស់ កែពក? ឆ.៣១៖ ពីព្រោះគាត់ធ្វើការងារជំនួស តាពក ពេល តាពក មិននៅ”), 00990818 (ឆ.៦៩) (“ប៉ះតាពកអត់នៅ គាត់ចាត់ចែងនៅកំពង់ចាម ដូចជាតាមកន្លែង ក្រសួងអីហ្នឹង គាត់ជួបគេនៅទីនោះ”)។

តាងដែលពាក់ព័ន្ធយ៉ាងច្បាស់នឹងការរកឃើញពុំបានលើកឡើងក្នុងសំអាងហេតុ"[817]។

៤៦៩. ជាការពិតណាស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានរកឃើញភស្តុតាងមិនស៊ីសង្វាក់ ឬ ផ្ទុយគ្នាពាក់ព័ន្ធនឹងបញ្ហានេះ និងបានយោងនៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ)[818]ដែលបង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានធ្វើការវាយតម្លៃអំពីភាពគួរឱ្យជឿជាក់បានលើភស្តុតាងនេះ។ ចៅក្រមអន្តរជាតិកត់សម្គាល់ថាសាក្សីមួយចំនួនយោងដល់បុគ្គលនានាក្រៅពី អោ អាន ដែលទទួលខុសត្រូវជំនួស កែ ពក នៅពេល កែ ពក អវត្តមាន។ សួន កានិល, បាន សៀក និង ពេជ្រ ជឹម ថ្លែងថាប្រធានមន្ទីរភូមិភាគ("ប្រធានមន្ទីរ")គឺជាអ្នកទទួលបន្ទុក នៅពេល កែ ពក អវត្តមាន ដោយ យោងដល់ឱកាសចំនួនពីរលើក ដែលមឿន បំពេញតួនាទីនេះ[819]។ មិនតែប៉ុណ្ណោះ ដូចដែលបាន

---

[817] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) យោបល់របស់ចៅក្រម BAIK និង BEAUVALLET កថាខណ្ឌ ៣០៦ *យោងទៅ* តុលាការ ICTR *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង* Zigiranyirazo សំណុំរឿងលេខ ICTR-01-73-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ៤៥។ តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Perišić* សំណុំរឿងលេខ IT-04-81-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០១៣ កថាខណ្ឌ ៩២។

[818] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៥៥ ជើងទំព័រ ៦៣២ *យោងទៅ* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី អ៊ិន គីមអេង ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ D107/5 នៅត្រង់ ERN 00784994 (ឆ.២៧) ("នៅពេល កែ ពក អវត្តមាន អនុរបស់គាត់ [...] ឈ្មោះ តាអាន ជាអ្នកទទួលខុសត្រូវ")។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី អ៊ិន គីមអេង ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ D117/66 នៅត្រង់ ERN 01023133 (ឆ.១០) ("ខ្ញុំនៅចាំឈ្មោះ មឿន [...] និង ហែន [...] ដែលពួកគាត់ទាំងពីរធ្វើការជំនួសឱ្យ កែ ពក នៅពេលដែល កែ ពក មានភារកិច្ច ឬអវត្តមានពីភូមិភាគ")។

[819] *សូមមើលឧទាហរណ៍* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី សួន កានិល ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ ២០០៩ ឯកសារ D6.1.707 នៅត្រង់ ERN 00373508 ("ក្នុងករណី កែ ពក អវត្តមានគឺគេមកជួបប្រធានមន្ទីរគណៈភូមិភាគឈ្មោះ ស្វ [...] ញាន [...] ឡើងកាន់កាប់ជំនួស [...] សែន [...] ឡើងកាន់កាប់ជំនួស។ [...] បន្ទាប់មកឈ្មោះ មឿន [...] បានឡើងកាន់កាប់តំណែងជំនួសនៅមន្ទីរនោះ")។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី សួន កានិល ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D29 នៅត្រង់ ERN 00716229 (សៈ ប៉ុន្តែនៅពេលដែល កែ ពក មិននៅ តើអ្នកណាទទួលខុសត្រូវ? ឆ្លើយៈ គឺគេមានប្រធានមន្ទីរភូមិភាគជាអ្នកទទួលខុសត្រូវជំនួស កែ ពក។ សៈ តើប្រធានមន្ទីរនោះឈ្មោះអ្វី? ឆ្លើយៈ [...] ខ្ញុំគ្រាន់តែដឹងឈ្មោះថា មឿន")។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី បាន សៀក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១២ ឯកសារ D107/15 នៅត្រង់ ERN 00800955 ("អ្នកដែលអាចជំនួសគាត់នៅពេលដែលគាត់អវត្តមាន គឺមានតែប្រធានមន្ទីររបស់គាត់ឈ្មោះ មឿន [...]")។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D118/259 នៅត្រង់ ERN 00997051 (ឆ.២១៩) ("សៈ ពេលដែល កែ ពក អវត្តមានពីមន្ទីរភូមិភាគ តើអ្នកណាជាអ្នកជំនួស កែ ពក? [...] ឆ.២១៩៖ ឈ្មោះ ឆាំ ដែលធ្វើការនៅមន្ទីរភូមិភាគរបស់ កែ ពក ជាអ្នកជំនួស [...]")។ ចៅក្រមអន្តរ

កត់សម្គាល់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិផងដែរថា អ៊ិន គីមអេង ថ្លែងថា មឿន និង ហែន បានធ្វើការជំនួស កែ ពក នៅពេល កែ ពក បំពេញភារកិច្ចនៅ កន្លែងផ្សេង ឬមិននៅភូមិភាគ[820]។ ចៅក្រមអន្តរជាតិយល់ឃើញថា ដំណើររឿងទាំងនេះ ពាក់ព័ន្ធជាពិសេសទៅនឹងការចាត់ចែង "មន្ទីរភូមិភាគ" មិនមែនជាការគ្រប់គ្រងភូមិភាគកណ្ដាល ដោយ ប.ក.ក ជាទូទៅនោះទេ។[821] អាស្រ័យហេតុនេះ ចៅក្រមអន្តរជាតិមិនអាចសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនយកចិត្ត ទុកដាក់ចំពោះភស្តុតាងដែលពាក់ព័ន្ធនឹងសំអាងហេតុនោះឡើយ។

៤៧០. ទីពីរ ខណៈដែលចៅក្រមអន្តរជាតិយល់ឃើញថាការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើភស្តុតាងគឺមិនមែនមិនមានហេតុផលនោះ អង្គជំនុំជម្រះកត់សម្គាល់ថា តួនាទីរបស់ អោ អាន ជាលេខាស្តីទីនៃភូមិភាគកណ្ដាលនោះ មានអានុភាពតិចតួចបំផុតទៅលើការកំណត់យុត្តាធិការបុគ្គល ដោយហេតុថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានបង្ហាញភស្តុតាងណាមួយអំពីការបំពេញមុខងាររបស់ អោ អាន នៅក្នុងសមត្ថភាពតាមព្រឹត្តិន័យនេះឡើយ។[822]

៤៧១. ចៅក្រមអន្តរជាតិរម្លឹកថា ការកំណត់អត្តសញ្ញាណបុគ្គលទាំងឡាយដែលស្ថិតក្នុងចំណោមជនដែលទទួលខុសត្រូវខ្ពស់បំផុត ពាក់ព័ន្ធនឹងការវាយតម្លៃតាមបែបគុណវិស័យ និងបរិមាណវិស័យទៅលើ (i) ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និង (ii) កម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យ និងរម្លឹកថា ពុំមានបញ្ជីជាក់លាក់ស្ដីពីកត្តានានាដែលត្រូវយកមកពិចារណា ក្នុងការពិនិត្យទៅលើចំណុចនេះ

ជាតិកត់សម្គាល់ថា នៅក្នុងការស្តាប់ចម្លើយមួយបន្ទាប់ សាក្សី បាន សៀន លើកឡើងថា គាត់មិនបានដឹងថានរណាមកជំនួស កែ ពក ទេ៖ *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី បាន សៀក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៤ ឯកសារ D117/35 នៅត្រង់ ERN 00980370 (ឆ.៣៧) ("ខ្ញុំមិនដឹងថា អ្នកណាជាអ្នកធ្វើជំនួស កែ ពក ទេ នៅពេលដែលគាត់មិននៅក្នុងភូមិភាគ")។

[820] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី អ៊ិន គីមអេង ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ D117/66 នៅត្រង់ ERN 01023133 (ឆ.១០) ("ខ្ញុំនៅចាំឈ្មោះ មឿន [...] និង ហែន [...] ដែលពួកគាត់ទាំងពីរធ្វើការជំនួសឲ្យ កែ ពក នៅពេលដែល កែ ពក មានភារកិច្ច ឬអវត្តមានពីភូមិភាគ")។

[821] *សូមមើលឧទាហរណ៍* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជីម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ឯកសារ D118/259 នៅត្រង់ ERN 00997051 (ឆ.២១៩) ("ស៖ ពេលដែល កែ ពក អវត្តមានពី**មន្ទីរភូមិភាគ** តើអ្នកណាជាអ្នកជំនួស កែ ពក? [...] ឆ.២១៩៖ ឈ្មោះ ឆាំ ដែលធ្វើការនៅមន្ទីរភូមិភាគរបស់ កែ ពក ជាអ្នកជំនួស [...]") (គូស បញ្ជាក់បន្ថែម)។

[822] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៧០៥។

ទេ ហើយក៏ពុំមានបទដ្ឋានកំហិតអំពីតួនាទីនៅក្នុងឋានានុក្រមឡើយ[823]។ ចៅក្រមអន្តរជាតិយល់ឃើញថា ខណៈដែលការកំណត់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិថា អោ អានស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក គប្បីតែបង្កើតជាអាទិ៍តាមរយៈការទទួលខុសត្រូវរបស់គាត់ក្នុងនាមជាលេខាតំបន់៤១ និង អនុលេខាភូមិភាគកណ្តាល ការកាន់មុខតំណែងរយៈពេលខ្លីៗទាំងនេះ[824] មិនមែនជាកត្តាកំណត់ នៅក្នុងការវាយតម្លៃទាំងមូលទៅលើយុត្តាធិការបុគ្គលឡើយ[825]។

៤៧២. ហេតុដូច្នេះ សម្រេចបដិសេធមូលដ្ឋានទី៦(៤)។

## មូលដ្ឋានទី៦(v). មុខដំណែងរបស់ អោ អាន ជាលេខាតំបន់ ៤១

៤៧៣. នៅក្នុងមូលដ្ឋានទី៦(v) សហមេធាវីតវ៉ាលើសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាក់ទងនឹងមុខតំណែង តួនាទី និងសិទ្ធិអំណាចរបស់ អោ អាន នៅក្នុងតំបន់ ៤១។ សហមេធាវីជំទាស់ថា អោ អាន ពុំមែនជាលេខាតំបន់ ៤១ តាមផ្លូវច្បាប់ ឬ តាមជាក់ស្តែងនោះឡើយ ហើយគាត់ពុំមានសិទ្ធិ អំណាចក្នុងការសម្រេចអំពីមធ្យោបាយនៃការផ្សព្វផ្សាយ ឬការអនុវត្តគោលនយោ បាយរបស់ ប.ក.ក នៅ ក្នុងតំបន់[826]។ សហមេធាវីចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពន្លើស និងបង្ហាញភស្តុតាង ដោយមិនត្រឹមត្រូវ ក្នុងការកំណត់មុខតំណែង តួនាទី និងសិទ្ធិ អំណាចរបស់ អោ អាន នៅក្នុងតំបន់ ៤១[827] ។ សេចក្តីសន្និដ្ឋានលម្អិតរបស់ភាគីត្រូវបានយកមកពិភាក្សានៅក្រោមមូលដ្ឋាននីមួយៗ។

[823] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) មតិយោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣២១។ *សូមមើលផងដែរ* កថាខណ្ឌ ៣២៧-៣៣៨។

[824] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ៩៣, ១០៥។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626072-01626073 ទំព័រ ១៨ បន្ទាត់ ៩ ដល់ ទំព័រ ១៩ បន្ទាត់ ១៦។

[825] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) មតិយោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣២១។

[826] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១០៦។

[827] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១០៧។ ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៤២។ សំណុំរឿង ០០៤/២ ប្រតិចារឹក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1, ERN (EN( 01625287 ទំព័រ ២៨:២ ដល់ ២៨:១២។

## ៦(v)(ក) មុខតំណែងរបស់ អោ អាន ក្នុងនាមជាលេខាតំបន់ ៤១ តាមផ្លូវច្បាប់

### ១. សារណា

៤៧៤. សហមេធាវីសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសចំពោះសំអាងហេតុថា អោ អាន គឺជាលេខាតំបន់ ៤១ តាមផ្លូវច្បាប់[828]។ ជាពិសេស សហមេធាវីជំទាស់ថា មិនមានភស្តុតាងជាក់លាក់ និងមានការបញ្ជាក់ ដែលបង្ហាញថា កែ ពក បានតែងតាំង អោ អាន ជាលេខា តំបន់ ៤១ ឬក៏ អោ អាន បានប្រកាសថា គាត់បានកាន់មុខតំណែងនេះនៅក្នុងការប្រជុំនៅវត្តតាមៈ ក្នុងខែមីនា ឆ្នាំ១៩៧៧ នោះទេ[829]។ សហមេធាវីចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានផ្តល់កាលបរិច្ឆេទ ឬ ទីតាំងពិតប្រាកដនៃការតែងតាំង អោ អាន ឬ ហេតុផលអ្វីដែលនាំឱ្យមានការតែងតាំងនេះ[830]។ សហមេធាវីក៏តវ៉ាចំពោះការពឹងផ្អែករបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើភស្តុតាងរបស់ ប្រាក់ យុត ពេជ្រ ជឹម និង ពេញ វ៉ា ផង ដែរ[831]។

៤៧៥. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា ការរៀបរាប់របស់ ប្រាក់ យុត និង ពេជ្រ ជឹម អំពីការតែងតាំងរបស់ អោ អាន ថា មានភាពស៊ីសង្វាក់ និងមានការបញ្ជាក់[832]។ លើសពីនេះទៀត សហមេធាវីខកខានក្នុងការបង្ហាញថា ខ្លួនត្រូវបង្ហាញជាក់លាក់ជាងនេះអំពី កាលបរិច្ឆេទនៃការតែងតាំង អោ អាន ដើម្បីអាចឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិឈានទៅសម្រេចអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងកម្រិតនៃការទទួលខុសត្រូវរបស់ អោ អាន[833]។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថែមទៀតថា ទីតាំងពិតប្រាកដនៃការប្រជុំ មានសារៈសំខាន់តិចតួចប៉ុណ្ណោះ ប៉ុន្តែភស្តុតាងបង្ហាញថា ការ

---

[828] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១០៨។ ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៤២។ សំណុំរឿង ០០៤/២ ប្រតិចារឹក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1, ERN (EN( 01625287-01625288 ទំព័រ ២៨:២៣ ដល់ ២៩:១។

[829] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១០៨។ ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៤២។ សំណុំរឿង ០០៤/២ ប្រតិចារឹក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1, ERN (EN( 01625288 ទំព័រ ២៩:២ ដល់ ២៩:១២។

[830] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១០៨។

[831] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១០៨ និងលេខយោងជើងទំព័រ ២៣៧-២៣៨។

[832] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៥៩។

[833] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៥៩។

ប្រជុំនេះបានធ្វើឡើងនៅមន្ទីររបស់ កែ ពក ក្នុងខេត្តកំពង់ចាម[834]។ ចំណុចចុងក្រោយ សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់ថា សហចៅក្រម ស៊ើបអង្កេតអន្តរជាតិបានបញ្ជាក់យ៉ាងច្បាស់ថា អោ អាន និងកម្មាភិបាលភូមិភាគនិរតីផ្សេងទៀតត្រូវបានតែងតាំងមុខតំណែងថ្មី ដើម្បី "ដោះស្រាយជាមួយ" ជនក្បត់ដែលត្រូវបានចោទប្រកាន់ នៅក្នុងភូមិភាគកណ្ដាល[835]។

## ២. ការពិភាក្សា

៤៧៦. ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសចំពោះការផ្ដល់សំអាងហេតុថា អោ អាន គឺជាលេខាតំបន់ ៤១ តាមផ្លូវច្បាប់នោះឡើយ[836]។ ទី១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបង្ហាញថា កែ ពក បានតែងតាំង អោ អាន ជាលេខាតំបន់ ៤១ ក្នុងកិច្ចប្រជុំនៅខេត្តកំពង់ចាម[837]នៅចន្លោះពេលពីចុងឆ្នាំ១៩៧៦ ដល់ខែកុម្ភៈឆ្នាំ ១៩៧៧[838]។ ចៅក្រមអន្តរជាតិយល់ ឃើញថា ចំណុចនេះមានភាពជាក់លាក់គ្រប់គ្រាន់ ហើយផ្ដល់ការសង្កេតថា ការពឹងផ្អែករបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើ ប្រាក់ យុត[839] និង ពេជ្រ ជឹម[840] មានលក្ខណៈសមហេតុផល ដោយចម្លើយរបស់

[834] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៥៨។

[835] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៥៨។

[836] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៤៥។

[837] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៤៥។

[838] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៤៣។

[839] ចៅក្រមអន្តរជាតិបានច្រានចោលភ្លាមៗលើការចោទប្រកាន់ដែលថា ភស្តុតាងរបស់ ប្រាក់ យុត ជាប់ប្រឡាក់ប្រឡូក។ សូមមើល *ខាងក្រោម* មូលដ្ឋានទី ៥ (iii)។ សហមេធាវីអះអាងថា ភស្តុតាងខ្លះជាប់ពាក់ព័ន្ធនឹង ប្រាក់ យុត លេចឡើងដោយសារអ្នកស៊ើបអង្កេតបាន "ផ្ដល់ព័ត៌មាន" ដាក់បន្ទុកឲ្យគាត់និយាយ។ *សូមមើល* បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១០៨ លេខយោងជើងទំព័រ ២៣៧។ ចៅក្រមអន្តរជាតិសង្កេតឃើញថា ចម្លើយនេះត្រូវបានជំទាស់ដោយសហមេធាវី។ *សូមមើល* ឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយពាក្យសុំមោឃភាពកំណត់ហេតុនៃការស្ដាប់ចម្លើយ (ឯកសារ D338/1/2.3), ERN (EN) 01388963 លេខរៀង ៣៥។

[840] ចៅក្រមអន្តរជាតិមិនឃើញមានកំហុសចំពោះការសំអាងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើ ពេជ្រ ជឹម ហើយយល់ឃើញថា ភាពមិនស៊ីសង្វាក់គ្នានៃភស្តុតាងទាក់ទងនឹងកាលបរិច្ឆេទនៃការមកដល់របស់គាត់នៅភូមិភាគកណ្ដាល (ហេតុដូច្នេះហើយ កាលបរិច្ឆេទនៃការប្រជុំនៅខេត្តកំពង់ចាម) មិនប៉ះពាល់ដល់ភាពអាចជឿជាក់ជាមួយរបស់គាត់ទេ។ (សាក្សីបញ្ជាក់ដំបូងថា គាត់បានមកដល់ភូមិភាគកណ្ដាលក្នុងខែកុម្ភៈ ឆ្នាំ១៩៧៧ ហើយក្រោយមកបានទទួចថា គឺជាខែកុម្ភៈ ឆ្នាំ១៩៧៦វិញ)។ *សូមមើល* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ D117/18, ERN 00893170-00893171 (ឆ.១)។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពេជ្រ ជឹម ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៩ ឯកសារ D6.1.651, ERN 00373387-00373388, 00373389-00373390។ *សូមមើលជាមួយ* កំណត់ហេតុនៃការស្ដាប់ចម្លើយ ពេជ្រ

សាក្សីទាំងពីរដែលបញ្ជាក់គ្នាទៅវិញទៅមក បានផ្តល់ភស្តុតាងលម្អិតថា កែ ពក បានតែងតាំង អោ អាន ជាលេខាតំបន់ ៤១ នៅក្នុងកិច្ចប្រជុំនេះ[841]។ ចំណុចទី ២ សំអាង ហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដោយផ្អែកលើចម្លើយរបស់ ពេញ វ៉ា ថា អោ អាន បានប្រកាសថា គាត់ជាលេខាតំបន់ ៤១ នៅក្នុងកិច្ចប្រជុំនៅវត្តតាមៈ ពុំមែនថាមិនសមហេតុផលឡើយ[842]។ ចៅក្រមអន្តរជាតិរម្លឹកថា ពេញ វ៉ា គឺជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលអាចទុកចិត្តបានម្នាក់ ដែលផ្តល់ព័ត៌មានលម្អិតនៃព្រឹត្តិការណ៍នេះ[843]។

៤៧៧. ចំណុចចុងក្រោយ ចៅក្រមអន្តរជាតិយល់ឃើញថា ការតវ៉ារបស់សហមេធាវីពុំមានមូលដ្ឋានទេ នៅពេលពិចារណាទៅលើភស្តុតាងរបស់សាក្សី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្ប វេណីជាច្រើនដែលបានកំណត់អត្តសញ្ញាណ អោ អាន ថាជាលេខាតំបន់ ៤១[844] ក៏ដូចជា ការទទួលស្គាល់របស់ អោ

---

ជឹម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ឯកសារ D118/259, ERN 00997045 (ឆ.១៦៩, ឆ.១៧៣)។ យោងតាម ភស្តុតាងបន្ថែមទាក់ទងនឹងកាលបរិច្ឆេទមកដល់របស់ អោ អាន និងកម្មាភិបាលនិរតីដទៃទៀត (សូមមើលផងដែរ មូលដ្ឋានទី ៦ (iii) ចៅក្រមអន្តរជាតិយល់ថា មិនសមហេតុផលទេដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនពឹងផ្អែកលើកាលបរិច្ឆេទនៃខែកុម្ភៈ ឆ្នាំ១៩៧៦។

[841] *ឧទា. សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយ ប្រាក់ យុត ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ឯកសារ D117/71, ERN 01046803-01046804 ("កែ ពក បានកោះហៅកម្មាភិបាលក្នុងភូមិភាគកណ្តាលទាំងអស់ឱ្យចូលរួម [...] កែ ពក តែងតាំង *តាអាន* ឱ្យកាន់តំបន់ ៤១")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ D117/18, ERN 00893170-00893171 (ឆ.១)("កែ ពក បាននាំយើងទៅខេត្តកំពង់ចាម ហើយបានរៀបចំអង្គប្រជុំធំមួយ។ នៅក្នុងកិច្ចប្រជុំនោះ [...] តាអាន ត្រូវបានចាត់តាំងជាលេខាតំបន់ ៤១")។ *សូមមើល ខាងក្រោម* មូលដ្ឋានទី ៥ (ii)(ក) (ចំពោះការចោទប្រកាន់ដែលមិនត្រូវគ្នានៅក្នុងការរៀបរាប់របស់ ប្រាក់ យុត ទាក់ទងនឹងមុខតំណែងរបស់ អោ អាន ក្នុងតំបន់ ៤១)។

[842] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ២៤៧។

[843] *សូមមើលខាងលើ* មូលដ្ឋានទី ៥(ii)(ច)។ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេញ វ៉ា ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ឯកសារ D219/226, ERN 01075654-01075655 (ស.៧៖ "តើលោកឃើញ តាអាន លើកទី១ នៅក្នុងឆ្នាំណាដែរ? ឆ. ៦៖ ខ្ញុំឃើញ តាអាន ដំបូង នៅពេល តាអាន ទៅដល់នៅក្នុងខែមីនា ឆ្នាំ១៩៧៧។ គាត់បានកោះហៅបុគ្គលោកថ្នាក់តំបន់ប្រហែល ៣០០នាក់ ឱ្យចូលរួមប្រជុំ នៅវត្តតាមៈ នៅឃុំជ្រៃវៀន ហើយគាត់ប្រកាសប្រាប់ថា គាត់គឺជាប្រធានតំបន់ ៤១ ថ្មី។ កម្មាភិបាលថ្នាក់តំបន់ទាំងនោះ គឺជាបុគ្គលិកនៃសិប្បកម្មតម្បាញ សិប្បកម្មស្ពដែក យានដ្ឋាន ភស្តុភារពាណិជ្ជកម្មតំបន់ ៤១")។

[844] *ឧទា. សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣ ឯកសារ D117/13, ERN 00964454 (ឆ.១២) (តាអាន នៅព្រៃឈរ ហើយកាន់តួនាទីជាលេខាតំបន់ ៤១)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ឯកសារ D219/138, ERN 01056044-01056046 (ឆ.២៣ ឆ.៣៥) (តាអាន គឺជាលេខាតំបន់ ៤១ ហើយគាត់ប្រចាំការនៅព្រៃទទឹង ហើយក៏ជាគណៈស្រុកព្រៃឈរដែរ [...] ខ្ញុំដឹងថា តាអាន ជាលេខាតំបន់ [...] ដោយសារគាត់ប្រកាសដោយខ្លួនឯង [...] មុខងារផ្លូវការរបស់គាត់ដែលចារនៅលើខ្នងសំបុត្រគឺជាមេតំបន់ ៤១)។ កំណត់ហេតុ

អាន ថា គាត់បានកាន់មុខតំណែងនេះ[845]។ លើសពីនេះទៀត ដូចបានបង្ហាញនៅ ក្នុងផ្នែក ៦ (v) (ខ) - (v) (ង) ការដែល អោ អាន បានអនុវត្តតួនាទីតាមច្បាប់របស់ខ្លួនជាលេខាតំបន់ ៤១ នោះ បញ្ជាក់ទៀតថា អោ អាន បានកាន់មុខតំណែងជាលេខាតំបន់ ៤១។

### ៦(v)(ខ) សិទ្ធិអំណាចរបស់ អោ អាន នៅតំបន់ ៤១

៤៧៨. សហមេធាវីចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានបង្ហាញ តាមបទដ្ឋានចាំបាច់ ថា អោ អាន មានសិទ្ធិអំណាចជាក់ស្តែងជាលេខាតំបន់ ៤១[846]។ ចៅក្រមអន្តរជាតិដោះស្រាយចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិចំពោះកំហុស ដែលបានចោទប្រកាន់ នីមួយៗ ទៅតាមផ្នែកពាក់ព័ន្ធផ្សេងៗ។

៤៧៩. ជាបញ្ហាបឋម ចៅក្រមអន្តរជាតិយល់ថា មុខតំណែងតាមផ្លូវច្បាប់របស់ អោ អាន ក្នុងនាមជាលេខាតំបន់ ៤១ មានភាពពាក់ព័ន្ធទៅនឹងការវាយតម្លៃទៅលើការជំទាស់ផ្សេងៗទៀតរបស់សហមេធាវីទាក់ទងនឹងការអនុវត្តមុខងារ និងសិទ្ធិអំណាចរបស់ អោ អាន នៅក្នុងតំបន់ ៤១។ ទោះបី ជាការកាន់កាប់អំណាចតាមផ្លូវច្បាប់នេះពុំគ្រប់គ្រាន់សម្រាប់ការសន្និដ្ឋានថា តាមពិតទៅ បុគ្គល ម្នាក់អនុវត្តភារកិច្ចពាក់

---

នៃការស្តាប់ចម្លើយសាក្សី ពៅ សារ៉ុម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៣ ឯកសារ D117/24, ERN 00947234 (ឆ.៧) (ខ្ញុំមិនបានចូលរួមក្នុងកិច្ចប្រជុំនោះទេ ប៉ុន្តែ បន្ទាប់មក ប្រាក់ យុត បានប្រាប់ខ្ញុំថា តាអាន ជាប្រធានតំបន់ ៤១ ហើយពួកយើងត្រូវធ្វើការក្នុងភូមិភាគ ៤១)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពៅ សារ៉ុម ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៥ ឯកសារ D219/284, ERN 01091373-01091374 (ឆ.១៨, ឆ.១៩, ឆ.២១) ("[...] នៅពេលដែលខ្ញុំទៅដល់មន្ទីរស្រុក ខ្ញុំឮថា តាអាន ជាអ្នកកាន់តំបន់។ ស. តើលោកស្រីឮពីមុខងាររបស់ តាអាន ពីនរណាគេដែរ? ឆ. ខ្ញុំឮពីបងស្រីយុត តាអាន និងប្តីរបស់គាត់ ធ្វើការជាមួយគ្នា [...] ខ្ញុំឮថា គាត់កាន់តំបន់ ប៉ុន្តែ បងស្រី យុត ប្រាប់ខ្ញុំថា ពុំមានអ្នកណាខ្ពស់ជាងគាត់ឡើយ ហើយបងប្រុសខ្ញុំធ្វើការជាមួយគាត់")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តួយ មៀច ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D219/582, ERN 01166932 (ឆ.៣០) (មេរបស់គេគឺ អាន ដែលជាគណៈតំបន់ដែរ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហុង ហេង ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ D219/802, ERN 01308075 (ឆ.១៨) (នៅពេលហ្នឹង គណៈតំបន់ឈ្មោះ តាអាន តែមិនដឹងនាមគាត់អីទេ)។

[845] កិច្ចសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អោ អាន ថ្ងៃទី១ ខែសីហា ឆ្នាំ២០១១ ឯកសារ D191.2 (ភាគ២) ERN (EN) 01025312 ("ដារ៉ា៖ "នៅពេលពូប្តូរទៅកំពង់ចាម តើគេចាត់ឲ្យទទួលតំបន់ណា? តាអាន៖ តំបន់ ៤១។ ដារ៉ា៖ ពូកាន់តំបន់ ៤១? តើពូជំនួស តាំង? អាន៖ បាទ ខ្ញុំជំនួស...តាំងពីព្រោះគេដកតាំងបាត់ហើយ")។

[846] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១០៩។ សំណុំរឿង ០០៤/២ ប្រតិចារិក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1, ERN (EN) 01625288 ទំព័រ ២៩:១៤ ដល់ ២៩:១៨។

ព័ន្ធនឹងមុខតំណែងនេះក៏ដោយ[847] ចៅក្រមអន្តរជាតិយល់ឃើញថា ចំណុចនេះ អាចជាមូលដ្ឋានសមហេតុផលសម្រាប់ការសម្រេចមួយចំនួន ហើយអាចជាភស្តុតាងបញ្ជាក់ ទៅលើភស្តុតាងផ្សេងទៀត។ ហេតុដូច្នេះ ចៅក្រមអន្តរជាតិយល់ឃើញថា មានការពាក់ព័ន្ធយ៉ាងខ្លាំង នៅក្នុងទិដ្ឋភាពនៃភស្តុតាងនេះ ចំពោះសំអាងហេតុដែលពុំមានការតវ៉ារបស់សហចៅក្រមស៊ើប អង្កេតអន្តរជាតិស្តីពីអំណាចនៃតំបន់នានានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលមានចែងច្បាស់ នៅក្នុងលក្ខន្តិកៈ ប.ក.ក[848] ដូចជា ការទទួលខុសត្រូវរបស់គណៈកម្មាធិការតំបន់លើការគ្រប់គ្រង វិន័យ ការរក្សាប្រព័ន្ធរាយការណ៍ និងការអនុវត្តផែនការការងាររបស់គណៈកម្មាធិការភូមិភាគ កណ្តាលនៅទូទាំងតំបន់[849]។ អំណាចរបស់តំបន់ដែលមានចែងក្នុងច្បាប់រួមមាន សិទ្ធិអំណាចតាម ផ្លូវច្បាប់របស់លេខាតំបន់លើកម្មាភិបាលថ្នាក់ស្រុក និងឃុំ នៅក្នុងតំបន់របស់ខ្លួន (រាប់បញ្ចូលទាំង ការតែងតាំង និងការដកហូតមុខតំណែងផងដែរ)[850] ការទទួលខុសត្រូវលើរដ្ឋបាលកិច្ចការ ដែលធ្វើ ឡើងដោយកងទ័ពបដិវត្តន៍កម្ពុជា សិទ្ធិអំណាចរបស់លេខាក្នុងការធ្វើការណែនាំថ្នាក់ក្រោមៗឱ្យ ស្វែងរកខ្មាំងយកមកអប់រំ ឬ "កម្ទេចចោល" សិទ្ធិអំណាចក្នុងការបញ្ជាឱ្យចាប់ខ្លួន និងសម្លាប់បុគ្គលណាមួយ និងសិទ្ធិអំណាចក្នុងការត្រួតពិនិត្យផ្ទាល់របស់ពួកគេលើមន្ទីរសន្តិសុខ[851]។ ចៅក្រមអន្តរជាតិដោះស្រាយទៅលើការជំទាស់ផ្នែកអង្គហេតុដែលតម្រូវឱ្យមានការវាយតម្លៃលម្អិតជាងនេះនៅចំណុចខាងក្រោម ។

### ៦(v)(ខ)(១) សិទ្ធិអំណាចក្នុងការទទួល អនុវត្ត ឬរាយការណ៍អំពីបញ្ជាទៅថ្នាក់ភូមិភាគ

#### ១. សារណា

៤៨០. សហមេធាវីចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសចំពោះសំអាងហេតុថា អោ អាន បានទទួល អនុវត្ត និងរាយការណ៍អំពីបញ្ជាពី កែ ពក ឬពីគណៈកម្មាធិការភូមិភាគកណ្តាល ក្នុង

---

[847] *ឧទា. សូមមើល* តុលាការ ICTY *រដ្ឋអាជ្ញា ទល់នឹង KorDić និង Čerkez*, IT-95-14/2-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ៤១៨ ("អំណាចជាក់ស្តែង [...] នឹងមិនត្រូវបានកំណត់ដោយមើលតួនាទីផ្លូវការតែមួយមុខនោះទេ។ មិនថាតាម*ន័យច្បាប់ ឬ ព្រឹត្តិន័យ* យោធា ឬ ស៊ីវិល អត្ថិភាពនៃមុខនាទីសិទ្ធិអំណាចនឹងត្រូវផ្អែកលើការវាយតម្លៃនៃតថភាពនៃសិទ្ធិអំណាចរបស់ជនជាប់ចោទ")។

[848] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ១៨៩-១៩៤។

[849] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ១៨៩-១៩០។

[850] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ១៩១។

[851] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ១៩២-១៩៤។

ការចាប់ខ្លួន និងសម្លាប់អតីតកម្មាភិបាល និងខ្មាំងនៅក្នុងតំបន់ ៤១[852]។ ជាពិសេស សហមេធាវីអះអាងថា មានភស្តុតាងតិចតួចដែលបង្ហាញថា អោ អាន ទាក់ទងដោយផ្ទាល់ជាមួយកម្មាភិបាលថ្នាក់ភូមិភាគ ព្រោះ មិនមានឯកសារណាមួយកត់ត្រាការជួបគ្នារវាង អោ អាន និង កែ ពក ឬ ជាមួយនរណាម្នាក់ផ្សេងទៀត នៅថ្នាក់ភូមិភាគនោះទេ[853] ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសចំពោះសំអាងហេតុអំពី (i) ចម្លើយមិនជាក់លាក់របស់សាក្សី ទាក់ទងនឹងការប្រជុំប្រចាំខែរបស់ អោ អាន ជាមួយ កែ ពក[854] និង (ii) ចម្លើយមិនមានការបញ្ជាក់ ឬមិនអាចជឿជាក់បានរបស់ ញ៉ែម ចេន និង ប្រាក់ យុត[855]។ ចំណុចចុង ក្រោយ សហមេធាវីតវ៉ាថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសចំពោះការពឹងផ្អែកលើឋានៈតាម ផ្លូវច្បាប់របស់ អោ អាន ជាមូលដ្ឋានក្នុងការសន្និដ្ឋានថា អោ អាន បានរាយការណ៍ទៅថ្នាក់ភូមិភាគ[856]។

៤៨១. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា ភស្តុតាងគាំទ្រយ៉ាងច្បាស់ថា អោ អាន បានទទួលបញ្ជា និងការណែនាំពី កែ ពក[857] ដោយលើកហេតុផលថា ការទទួលស្គាល់របស់ អោ អាន ផ្ទាល់នៅក្នុងបទសម្ភាសន៍តាមប្រព័ន្ធផ្សព្វផ្សាយ បង្ហាញថា កែ ពក បាន បញ្ជាឱ្យ អោ អាន សម្លាប់អ្នកគាំ របប លន់ នល់[858]។ សហព្រះរាជអាជ្ញាអន្តរជាតិចោទប្រកាន់ទៀតថា ការព្យាយាមរបស់សហមេធាវី ដើម្បីបន្ថយអានុភាពភស្តុតាងរបស់ ញ៉ែម ចេន និង បាន សៀក មិនគួរឱ្យជឿ ទេ[859] ហើយភស្តុតាងដែល ថា កែ ពក បានតែងតាំង អោ អាន ជា លេខាតំបន់ ៤១ គាំទ្រចំណុចថា កែ ពក បានចេញបញ្ជា និងការ ណែនាំទៅឱ្យ អោ អាន ស្របតាមមុខតំណែងរបស់ពួកគេ[860]។

---

[852] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១១០។

[853] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១១០។ សំណុំរឿង ០០៤/២ ប្រតិចារឹក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1, ERN (EN) 01625288 ទំព័រ ២៩:១៨ ដល់ ២៩:២២។

[854] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១១១ និងលេខយោងជើងទំព័រ ២៤៣ *ដែលយោងលើ* សេចក្តីថ្លែងការណ៍របស់ ញ៉ែម ចេន ពេជ្រ ជីម ប្រាក់ យុត និងបាន សៀក។

[855] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១១១។ សំណុំរឿង ០០៤/២ ប្រតិចារឹក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1, ERN (EN) 01625288-01625289 ទំព័រ ២៩:២៤ ដល់ ៣០:១១។

[856] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១១២។

[857] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៦០។

[858] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៦០។

[859] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៦០។

[860] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៦០។

៤៨២. នៅក្នុងការឆ្លើយតប សហមេធាវីជំទាស់ថា សហព្រះរាជអាជ្ញាអន្តរជាតិមិនលើកផ្នែកសំខាន់នៃបទសម្ភាសន៍ អោ អាន របស់ប្រព័ន្ធផ្សព្វផ្សាយ ដែលគាត់បានលើកឡើងថា អោ អាន មិនបានអនុវត្តតាមបទបញ្ជារបស់ កែ ពក នោះទេ[861]។

## ២. ការពិភាក្សា

៤៨៣. ចៅក្រមអន្តរជាតិយល់ឃើញថា សហមេធាវីខកខានមិនបានបង្ហាញថា គ្មានចៅក្រមស៊ើបសួរដែលមានហេតុផលអាចយល់ឃើញថា អោ អាន បានរាយការណ៍អំពីសកម្មភាពរបស់តំបន់ ៤១ ទៅថ្នាក់ភូមិភាគនោះឡើយ រួមទាំង កែ ពក។ សំអាងហេតុនេះសមហេតុផល ដោយសារមុខតំណែងរបស់ អោ អាន ជាលេខាតំបន់ ៤១ និងកាតព្វកិច្ចតាមច្បាប់របស់គណៈកម្មាធិការតំបន់ ដែលរួមមានការទទួលខុសត្រូវចំពោះ "មានប្រព័ន្ធរាយការណ៍ជូនថ្នាក់លើអំពីស្ថានការណ៍ និងការងារនៅក្នុងតំបន់"[862]។

៤៨៤. ចំណុចទី ១ ចៅក្រមអន្តរជាតិរម្លឹកថា ភស្តុតាងប្រមូលបាននៅ អ.វ.ត.ក ស្ថិតនៅក្រោមការគ្រប់គ្រងនៃគោលការណ៍សេរីភាពនៃភស្តុតាង[863] ហើយយល់ឃើញថា សហមេធាវីពុំមានមូលដ្ឋាន ក្នុងការជំទាស់ថា សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីការជួបប្រជុំគ្នា ឬ ការទាក់ទងគ្នារវាង អោ អាន និង កម្មាភិបាលថ្នាក់ភូមិភាគ ត្រូវតែមានភស្តុតាងឯកសារគាំទ្រ នោះទេ។

៤៨៥. ចំណុចទី ២ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសចំពោះការសំអាងលើ ក្នុងចំណោមអ្នកផ្សេងទៀត ញ៉ែម ចេន ក្នុងការយល់ឃើញថា (i) អោ អាន បានចូលរួមកិច្ចប្រជុំប្រចាំខែជាមួយ កែ ពក[864] (ii) កែ ពក បានចេញបទបញ្ជាចាប់ខ្លួន ទៅឱ្យ អោ អាន នៅក្នុងកិច្ចប្រជុំមួយនៅខេត្តកំពង់ចាម[865] (iii) កែ ពក អោ អាន និងសមាជិកគណៈកម្មាធិការភូមិភាគ បានរៀបចំផែនការដើម្បីបោសសម្អាតកម្មាភិបាល[866] និង (iv) អោ អាន បានទទួល បញ្ជាជាលាយលក្ខណ៍

---

861 ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៤២ និងលេខយោងជើងទំព័រ ៨៥។

862 ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ១៨៩ លេខយោងជើងទំព័រ ៤០៣។

863 *សូមមើលខាងលើ* កថាខណ្ឌ ៧៦ ដល់ ៨៣។

864 បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១១១ និងលេខយោងជើងទំព័រ ២៤៣ *យោងលើ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៧៦ លេខយោងជើងទំព័រ ៧២១។

865 បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១១១ និងលេខយោងជើងទំព័រ ២៤៥ *យោងលើ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៧៧ លេខយោងជើងទំព័រ ៧២៣-៧២៦។

866 បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១១១ និងលេខយោងជើងទំព័រ ២៤៦ *យោងលើ* ដីកា

អក្សរពី កែ ពក[867]។ សហមេធាវីខកខានមិនបានបង្ហាញថា ភស្តុតាងរបស់ ញ៉ែម ចេន អំពីសំអាងហេតុទាំងនេះ មិនអាចជឿជាក់បាន ពុំស៊ីសង្វាក់ បង្ហាញខុស ឬ មិនមាន ការបញ្ជាក់ និងមិនមានភាពជាក់លាក់[868]។ ចៅក្រមអន្តរជាតិសង្កេតឃើញថា ចម្លើយរបស់ ញ៉ែម ចេន មានភាពស៊ីសង្វាក់គ្នា គាត់មានវត្តមានក្នុងកិច្ចប្រជុំមួយចំនួន និងបានផ្តល់ព័ត៌មានលម្អិតនៅក្នុង ចម្លើយរបស់គាត់[869]។ លើសពីនេះទៀត ចៅក្រមអន្តរជាតិកត់សម្គាល់ឃើញថា ការរៀបរាប់របស់ ញ៉ែម ចេន ស៊ីសង្វាក់ជាមួយនឹង ក្នុងចំណោមអ្នកផ្សេង បាន សៀក ដែលលើកឡើងថា ការសម្រេចសំខាន់ៗ រួមទាំងការបោសសម្អាត ត្រូវបានធ្វើឡើងដោយគណៈកម្មាធិការអចិន្ត្រៃយ៍ ភូមិភាគ[870]។ ទោះបីជា ញ៉ែម ចេន ទទួលស្គាល់ថា គាត់មិនអាចស្តាប់ចូលរួមស្តាប់ ឬឮផ្នែកខ្លះ នៃការប្រជុំថ្នាក់ភូមិភាគរហូតមែនក៏ដោយ ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតអន្តរ

---

ដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៧៨ លេខយោងជើងទំព័រ ៧២៧-៧២៩។

[867] បបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១១១ និងលេខយោងជើងទំព័រ ២៤៧ *យោងលើ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៧៧ លេខយោងជើងទំព័រ ៧២៦។

[868] ទាក់ទងនឹងភាពញឹកញាប់នៃការប្រជុំរបស់ អោ អាន ជាមួយ កែ ពក ចៅក្រមអន្តរជាតិចាត់ទុកថា មិនមានភាព មិនស៊ីសង្វាក់គ្នាសំខាន់នៅក្នុងការរៀបរាប់របស់ ញ៉ែម ចេន។ ញ៉ែម ចេន ដំបូងលើកឡើងថា គាត់មិនបានដឹងជាមុនទេថានឹងមានការប្រជុំនៅពេលណា។ នៅក្នុងបទសម្ភាសន៍នៅពេលក្រោយមក គាត់ប្រាប់ពីភាពញឹកញាប់នៃការប្រជុំទាំងនេះ។ *សូម មើល* កំណត់ហេតុនៃការស្តាប់ចម្លើយ ញ៉ែម ចេន ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ឯកសារ D219/731, ERN 01218073 (ឆ.៣១) ( ពេលគាត់ត្រូវការគាត់ហៅ។ ពេលទៅប្រជុំអី ខ្ញុំមិនដឹងទេ)។ កំណត់ហេតុនៃការស្តាប់ចម្លើយ ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/855, ERN 01344684 (ឆ.៥)(ក្នុងវគ្គមួយខែ គេបូកសរុបម្តង)។

[869] *សូមមើលខាងក្រោម* មូលដ្ឋានទី ៥ (ii) (ឃ)។ ចៅក្រមអន្តរជាតិយល់ឃើញថា ញ៉ែម ចេន ជាទូទៅ គឺជាសាក្សីគួរឱ្យជឿជាក់មួយរូប។ ការរៀបរាប់របស់ ញ៉ែម ចេន ពាក់ព័ន្ធនឹងការប្រជុំមានរៀបរាប់លម្អិត និងស៊ីសង្វាក់គ្នា។ កំណត់ហេតុនៃការស្តាប់ ចម្លើយ ញ៉ែម ចេន ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ឯកសារ D219/731, ERN 01218073 (ឆ.៣៦ ឆ.៤០)(សៈ តើគាត់ធ្លាប់ទៅចូលរួមប្រជុំនៅកំពង់ចាមទេ [...]? ឆៈ ទៅប្រជុំជាមួយ តាពក [...] សៈ អាចលើកបានខ្លះទេ ការចងចាំហ្នឹង ដូចជា កិច្ចប្រជុំ? ឆៈ ខ្ញុំចាប់បានខ្លះដែរ ដូចជាខ្មាំងហ្នឹង ធ្វើម៉េចយើងធ្វើឱ្យបាន ចាប់ម្តងមួយៗមកឱ្យអស់ ខ្មាំងចាប់ឱ្យអស់ចាប់ត្រីកុំឱ្យល្អក់ទឹក")។ កំណត់ហេតុនៃការស្តាប់ចម្លើយ ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/855, ERN 01344684 (ឆ.៥)(ក្នុងវគ្គមួយខែ គេបូកសរុបម្តង។ ខ្ញុំធ្លាប់ទៅប្រជុំជាមួយគាត់ បានប្រហែលបួនដង), ERN 01344686 (ឆ.១៧, ឆ.២១) (ការប្រជុំនិយាយពីផែនការចាប់ខ្មាំង [...] អោ អាន ធ្វើការនៅភូមិភាគហ្នឹងដែរជាមួយ តាពក), ERN 01344687 (ឆ.២៩) (គាត់និយាយដែរ និយាយរួមខ្មាំង រយៈពេលហ្នឹង ឱ្យចុះតាមស្រុក ចាត់ផែនការហ្នឹង ទៅស្រុក ទៅដល់អត់ឱ្យឈប់ទេ ចុះតាមស្រុកចាប់ឱ្យរហ័ស ព្រោះផែនការគេជិតដល់ហើយ)។

[870] ឧទា. សូមមើល កំណត់ហេតុនៃការស្តាប់ចម្លើយ ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D107/15, ERN 01344684 (ឆ.៥)(គណៈអិចន្ត្រៃយ៍របស់ភូមិភាគដែលមានគណៈតំបន់បីនាក់ គឺតាអាន [...]តាមដែលខ្ញុំដឹង ការសម្រេចសំខាន់ៗដូចជាការបោសសម្អាតជាដើម ត្រូវបានសម្រេចដោយគណៈអចិន្ត្រៃយ៍នេះនៅក្នុងការប្រជុំសម្ងាត់សំខាន់របស់គេ)។

ជាតិមិនមាន កំហុសចំពោះការសំអាងលើ ញ៉ែម ចេន ចំពោះអ្វីដែលគាត់ *ពិតជាបាន* ឮ រួមទាំងអំពីផែនការបោសសម្អាតចាមផងដែរ[871]។

៤៨៦. ចំណុចទី៣ ចៅក្រមអន្តរជាតិយល់ឃើញថា ពុំមានកំហុសអ្វីចំពោះការសំអាង របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើភស្តុតាងរបស់ ប្រាក់ យុត ទាក់ទងនឹងការពិគ្រោះយោបល់ដែលបានធ្វើឡើងរវាង អោ អាន និង កែ ពក នោះទេ[872]។ ការចោទប្រកាន់របស់សហមេធាវីថា ប្រាក់ យុត មិនអាចជឿជាក់បានត្រង់ចំណុចនេះ ពុំមានមូលដ្ឋាននោះទេ ពីព្រោះថា ប្រាក់ យុត លើកឡើង យ៉ាងស៊ីសង្វាក់នៅក្នុងចម្លើយផ្សេងៗគ្នារបស់ខ្លួន[873]។ ចំណុចចុងក្រោយ ចៅក្រមអន្តរជាតិយល់ឃើញ ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាដោយសមហេតុផលចំពោះមុខតំណែងតាម ផ្លូវច្បាប់របស់ អោ អាន និងរចនាសម្ព័ន្ធរាយការណ៍ខ្សែទទឹងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយបានកំណត់ថា អោ អាន ខ្លួនឯង ស្ថិតនៅក្នុងគណៈកម្មាធិការ ហើយការបោសសម្អាត ត្រូវបានយកមកពិភាក្សានៅក្នុងកិច្ចប្រជុំគណៈកម្មាធិការភូមិភាគ[874]។

## ៦(v)(ខ)(២) សិទ្ធិអំណាចក្នុងការតែងតាំងកម្មាភិបាល

### ១. សារណា

៤៨៧. សហមេធាវីចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសចំពោះសំអាងហេតុថា អោ អាន មានសិទ្ធិអំណាចតែងតាំងលេខាស្រុក និងកម្មាភិបាលផ្សេងទៀតនៅថ្នាក់តំបន់ ស្រុក និងឃុំ[875]។

---

[871] *ផ្ទុយ* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១១១ លេខយោងជើងទំព័រ ២៤៤។

[872] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១១១ និងលេខយោងជើងទំព័រ ២៤៨ *យោងលើ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៩៧ លេខយោងជើងទំព័រ ៧៨៤។

[873] *សូមមើលខាងលើ* មូលដ្ឋានទី៥ (ii)(ក)(ការវាយតម្លៃទូទៅចំពោះភាពជឿជាក់លើ ប្រាក់ យុត)។ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយ ប្រាក់ យុត ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ឯកសារ D117/71, ERN 01046803-01046807 (ឆ.៣៩) (លើកឡើងថា អោ អាន បានពិគ្រោះជាមួយ កែ ពក និងក្រោយមកស្នើសុំឱ្យជំនួសកម្មាភិបាលចាស់ទាំងអស់)។ កំណត់ហេតុនៃការស្តាប់ចម្លើយ ប្រាក់ យុត ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ D219/120, ERN 01046838 (ឆ.៥១-ឆ.៥២) (លើកឡើងថា អោ អាន បានពិគ្រោះជាមួយ កែ ពក និងបានរៀបចំដកប្រធានឃុំទាំងអស់ដែលនៅសេសល់)។

[874] កំណត់ហេតុនៃការស្តាប់ចម្លើយ បាន សៀក ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១២ ឯកសារ D107/15, ERN 00800954-00800955។

[875] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១១៣។ សំណុំរឿង ០០៤/២ ប្រតិចារឹក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1, ERN (EN) 01625289 ទំព័រ ៣០:១៣ ដល់ ៣០:២៣។

ជាពិសេស ភស្តុតាងពាក់ព័ន្ធស្ទើរតែទាំងស្រុងទៅនឹងស្រុកកំពង់សៀម ហើយភាគច្រើនចេញពីសាក្សីម្នាក់ដែលមិនអាចជឿជាក់បាន គឺ ប្រាក់ យុត[876]។ សហមេធាវីចោទប្រកាន់ថា ក្នុងការព្យាយាមបញ្ជាក់ភស្តុតាងរបស់ ប្រាក់ យុត សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបំភាន់ និងពន្លើសភស្តុតាងរបស់សាក្សីដទៃទៀត[877]។ ចំណុចចុងក្រោយ សហមេធាវីអះអាងថា សិទ្ធិអំណាចរបស់ អោ អាន ក្នុងការធ្វើប្រតិភូកម្មការងារសេដ្ឋកិច្ចទៅឱ្យកម្មាភិបាល មិនផ្អែកលើភស្តុតាងគ្រប់គ្រាន់នោះទេ ហើយទោះក្នុងករណីណាក៏ដោយ មិនគាំទ្រការសន្និដ្ឋានថា អោ អាន មានសិទ្ធិអំណាចតែងតាំងបុគ្គលិកសំខាន់ៗនោះទេ[878]។

៤៨៨. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា សហមេធាវីការពារកំណត់ភស្តុតាងដោយមិនត្រឹមត្រូវថាជាការស្មាន[879] ហើយភស្តុតាងរបស់ ពៅ សារ៉ុម ដែលត្រូវបានចោទប្រកាន់ថាជាភស្តុតាងចចាមអារ៉ាម ទទួលបានមកពី ប្រាក់ យុត អាចត្រូវបានប្រើប្រាស់ដើម្បីបញ្ជាក់ ប្រាក់ យុត[880]។ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងទៀតថា លក្ខន្តិកៈ ប.ក.ក បញ្ជាក់ពីការតែងតាំង បុគ្គលិកក្រោមបង្គាប់របស់ អោ អាន ពីព្រោះនេះជាមុខងារកំណត់ដោយលក្ខន្តិកៈ ចំពោះលេខា ភូមិភាគ[881]។

## ២. ការពិភាក្សា

៤៨៩. ចៅក្រមអន្តរជាតិយល់ឃើញថា សហមេធាវីខកខានក្នុងការបង្ហាញថា គ្មានចៅក្រមស៊ើបសួរដែលមានហេតុផលអាចសម្រេចថា អោ អាន បានតែងតាំងលេខាធិការស្រុក និងបុគ្គលិកក្រោមបង្គាប់ដទៃទៀតនោះទេ។ សំអាងហេតុនេះសមហេតុផលដោយសារភស្តុតាងដែលបានបង្ហាញ និងភារកិច្ចតាមលក្ខន្តិកៈរបស់ អោ អាន ក្នុងឋានៈជាលេខាតំបន់ ដូចជា "សិទ្ធិអំណាចតាមផ្លូវច្បាប់លើកម្មាភិបាលថ្នាក់ស្រុក

---

[876] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១១៣ និងលេខយោងជើងទំព័រ ២៥៤ *យោងលើ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៤៦ លេខយោងជើងទំព័រ ៦០០។ ឧបសម្ព័ន្ធ ឃ ភ្ជាប់ជាមួយបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1.5), ERN 01599796-01599798។

[877] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១១៣ លេខយោងជើងទំព័រ ២៥៥ *យោងលើ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៥៦ ៩២៣ លេខយោង ៦៣៣ ១២៧៨ *យោងលើ* សេចក្តីថ្លែងការណ៍របស់ យូ វ៉ាន់ ពៅ សារ៉ុម ពេញ វ៉ា សួន កានិល និង ប្រាក់ នី។

[878] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១១៤។

[879] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៦១។

[880] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៦២។

[881] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៦៣។

និងឃុំ ក្នុងតំបន់របស់ខ្លួន រួមទាំង ការតែងតាំងសមាជិកគណៈតំបន់ និងស្រុក"[882] និងសិទ្ធិអំណាចរបស់គាត់ "តែងតាំង និងដកកម្មាភិបាលផ្សេងទៀតនៅថ្នាក់តំបន់ ស្រុក និងឃុំ"[883]។

៤៩០. សហមេធាវីខកខានក្នុងការបង្ហាញថា ភស្តុតាងរបស់ ប្រាក់ យុត មិនមានភាពស៊ីសង្វាក់គ្នា[884] ឬមានការប្រលាក់ប្រឡូក[885] ឬពាក់ព័ន្ធតែជាមួយនឹងស្រុកកំពង់សៀមប៉ុណ្ណោះ។ ចៅក្រមអន្តរជាតិមិនបានឃើញពីភាពមិនស៊ីសង្វាក់គ្នាសំខាន់នៅក្នុងការរៀបរាប់របស់ ប្រាក់ យុត នោះទេ។ ប្រាក់ យុត នៅតែអះអាងថា គាត់បានចូលរួមប្រជុំថ្នាក់ភូមិភាគ ក្រោមការដឹកនាំដោយ កែ ពក ដែលបានចាត់តាំងគាត់ឱ្យទៅតំបន់ ៤១ រួមជាមួយ អោ អាន ហើយ អោ អាន បាន តែងតាំង គាត់ជាលេខាស្រុកកំពង់សៀម ក្នុងអំឡុងពេលប្រជុំមួយផ្សេងទៀតនៅមន្ទីរតំបន់ ៤១[886]។ ម្យ៉ាង វិញទៀត សហមេធាវីមិនបានបង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុស ដោយ បានសំអាងលើសាក្សីដទៃទៀត រួមមាន យូ វ៉ាន់ ពៅ សារ៉ុម និង ពេញ វ៉ា សម្រាប់ការបញ្ជាក់ ភស្តុតាងនោះទេ[887]។ យូ វ៉ាន់ បានធ្វើសេចក្តីសន្និដ្ឋានសមហេតុផលថា

---

[882] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ១៩១ លេខយោងជើងទំព័រ ៤០៩។

[883] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ១៩១ លេខយោងជើងទំព័រ ៤១០។

[884] ឧបសម្ព័ន្ធ ឃ ភ្ជាប់ជាមួយបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1.5), ERN 01599796-01599785។

[885] សហមេធាវីអះអាងថា ភស្តុតាងបានមកពីអ្នកស៊ើបអង្កេតផ្តល់ព័ត៌មានមិនពិតរបស់នាងដោយ បញ្ចូលទាំងព័ត៌មានដាក់បន្ទុករួមមានការចងចាំរបស់នាងផងដែរ តាមរយៈ "ការរម្លឹកការចងចាំរបស់គាត់"។ *សូមមើល* ឧបសម្ព័ន្ធ ឃ ភ្ជាប់ជាមួយបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1.5), ERN 01599796-01599785។ ចៅក្រមអន្តរជាតិបានច្រានចោល ភ្លាមៗចំពោះការចោទប្រកាន់ដែលថា ភស្តុតាងរបស់ ប្រាក់ យុត ជាប់ប្រឡាក់ប្រឡូក។ សូមមើល*ខាងក្រោម* មូលដ្ឋានទី ៥ (iii)។ ចៅក្រមអន្តរជាតិសង្កេតឃើញថា ចម្លើយនេះត្រូវបានជំទាស់ដោយសហមេធាវី កាលពីលើកមុន។ *សូមមើល* ឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយពាក្យសុំមោឃភាពកំណត់ហេតុនៃការស្តាប់ចម្លើយ (ឯកសារ D338/1/2.3), ERN (EN) 01388963, លេខរៀង ១០-១១។

[886] កំណត់ហេតុនៃការស្តាប់ចម្លើយ ប្រាក់ យុត ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ ឯកសារ D117/70, ERN 01046745 (ឆ.២៦) (លើកឡើងថា បន្ទាប់ពីកិច្ចប្រជុំភូមិភាគ អោ អាន បានរៀបចំការប្រជុំមួយផ្សេងទៀតនៅមន្ទីរតំបន់ ៤១ ដោយចាត់តាំងគាត់ ឱ្យទៅស្រុកកំពង់សៀម។ កំណត់ហេតុនៃការស្តាប់ចម្លើយ ប្រាក់ យុត ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ឯកសារ D117/71, ERN 01046804 (ឆ.២៣)(លើកឡើងថា គាត់ត្រូវបាន អោ អាន ចាត់តាំង ឱ្យទៅស្រុកកំពង់សៀម")។ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៣ ឯកសារ D219/234.1.2, ERN (EN) 01064283 ("ដានី៖ *តាពក* បានរៀបចំកិច្ចប្រជុំ និងបន្ទាប់មក បានប្រកាសថា អ៊ុំត្រូវបានចាត់ឱ្យទៅកំពង់សៀម? យុត៖ *នៅក្រោយយើងប្រជុំនៅតំបន់ [...] យើងមកពីភូមិភាគ និងមានកិច្ចប្រជុំមួយទៀតនៅតាមតំបន់រៀងៗខ្លួន*") (គូសបញ្ជាក់បន្ថែម)។

[887] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១១៣ លេខយោងជើងទំព័រ ២៥៥។

អោ អាន ច្បាស់ជាបានផ្តល់បទបញ្ជាឱ្យរៀបចំមេឃុំថ្មី[888]។ ការចងចាំរបស់ ពៅ សារ៉ុម អំពីការរៀបរាប់របស់ ប្រាក់ យុត ស្របជាមួយនឹងខ្លឹមសារនៃសក្ខីកម្មរបស់ ប្រាក់ យុត[889]។ ភស្តុតាងរបស់ ពេញ វ៉ា បញ្ជាក់ថា អោ អាន ក្នុងនាមជាលេខាតំបន់ ៤១ មានសិទ្ធិតែងតាំងកម្មាភិបាលថ្មី[890]។

៤៩១. ដោយយល់ថា អោ អាន មានសិទ្ធិអំណាចតែងតាំងកម្មាភិបាល ចៅក្រមអន្តរជាតិនឹងមិនដោះស្រាយ លើការតវ៉ារបស់សហមេធាវីទាក់ទងនឹងសិទ្ធិអំណាចរបស់ អោ អាន "ធ្វើប្រតិភូកម្ម" ការងារសេដ្ឋកិច្ចដល់កម្មាភិបាលនោះឡើយ[891]។

### ៦(v)(ខ)(3) សិទ្ធិអំណាចក្នុងការដក ដាក់ជំនួស ឬដាក់ទណ្ឌកម្មកម្មាភិបាល

### ១. សារណា

៤៩២. សហមេធាវីលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការផ្តល់សំអាងហេតុថា អោ អាន មានសិទ្ធិអំណាចក្នុងការដក ដាក់ជំនួស និងដាក់ទណ្ឌកម្មលេខាស្រុក លេខាឃុំ និងបុគ្គលិកផ្សេងៗទៀត[892]។ ជាពិសេស សហមេធាវីតវ៉ាថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានខកខានមិនបានផ្ត

---

[888] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៥ ឯកសារ D219/138, ERN 01056049 (ឆ.៤៥) (បទបញ្ជាច្បាស់ជាចេញពី តាអាន ហើយព្រោះគាត់ជាប្រធានតំបន់។ ខុម ជាអ្នកដឹក ប្រាក់ យុត ទៅប្រជុំជាមួយនឹង តាអាន នៅថ្នាក់តំបន់។ ពេលត្រឡប់មកវិញ ខុម បានប្រាប់ខ្ញុំថា គេនឹងចាត់ចែងឱ្យមានមេឃុំថ្មីហើយ)។

[889] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពៅ សារ៉ុម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៣ ឯកសារ D117/24, ERN 00947235 (ឆ.១១) ([...] តាអាន ចាត់តាំង ប្រាក់ យុត ឱ្យកាន់ស្រុកកំពង់សៀម)។

[890] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេញ វ៉ា ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ឯកសារ D219/226, ERN 01075657 (ឆ.១២-ឆ.១៣)(ស.៖ [...] មានការចាប់ខ្លួនជាច្រើននៅក្នុងតំបន់ ៤១ តើលោកដឹងថា អ្នកណាមានសិទ្ធិសម្រេចថាត្រូវចាប់ខ្លួនអ្នកណា ហើយត្រូវជំនួសដោយអ្នកណា? ឆ.១២៖ គឺច្បាស់ជាមិត្ត អាន ហើយ [...] ពីព្រោះគាត់ជាប្រធានតំបន់ ៤១។ នេះជាបែបបទការងារនៅសម័យនោះ")។

[891] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១១៤។

[892] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១១៥។ សហមេធាវីក៏បានចោទប្រកាន់ផងដែរថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពន្យល់ថាតើ ពាក្យថា "ដក" មានន័យថា ផ្ទេរតួនាទីកម្មាភិបាល បណ្តេញ ឬ បន្ថយឋានៈតួនាទី ឬ ការចាប់ ឬសម្លាប់ ឬដាក់ទណ្ឌកម្មពួកគេឡើយ។ ពួកគាត់អះអាងថា សកម្មភាពទាំងអស់នេះរួមគ្នាបង្កើតឱ្យមានការយល់ច្រឡំថា អោ អាន មានសិទ្ធិអំណាចសំខាន់។ ក្រៅពីនេះ សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានបែងចែកឱ្យដាច់ពីគ្នារវាងកម្មាភិបាលថ្នាក់តំបន់ ថ្នាក់ស្រុក និងថ្នាក់ឃុំឡើយ។ ចៅក្រមអន្តរជាតិយល់ឃើញថា ការចោទប្រកាន់ទាំងនេះគ្មានមូលដ្ឋាន គ្មានការគាំទ្រដោយការយោងជាក់លាក់ទៅភស្តុតាង ឬមិនមានឥទ្ធិពលទៅលើការធ្វើសេចក្តីសន្និដ្ឋានរបស់

01635023



ល់ភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា អោ អាន បញ្ជា ឬពាក់ព័ន្ធនឹងការដក "បុគ្គលសំខាន់ៗ" ដូចជា មិត្ត សុប, អាំ និង ប្រាក់ យុត[893]។ មិនតែប៉ុណ្ណោះ សំអាងហេតុរបស់ គាត់ត្រូវបានចោទថា ផ្អែកលើពាក្យចចាមអារ៉ាម ឬភស្តុតាងផ្ទុយគ្នា ជាការស្មាន ឬត្រូវ បានបង្ហាញខុស[894]។

៤៩៣. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា សហមេធាវីខកខានមិនបានបង្ហាញថា គ្មានអ្នកវិនិច្ឆ័យអង្គហេតុដ៏សមហេតុផល បានពឹងផ្អែកលើភស្តុតាងផ្ទាល់ពាក់ព័ន្ធនឹងការដកហូតតំណែង មិត្ត សុប និង អាំ ឡើយ។ សហមេធាវីកំណត់មិនត្រឹមត្រូវលើសំអាងហេតុ របស់ សហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធនឹង ប្រាក់ យុត ហើយក្នុងករណីណាក៏ដោយ ក៏គ្មានសំអាងហេតុណាមួយជាកត្តាកំណត់លើការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត អន្តរជាតិដែលថា អោ អាន ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ឬស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឡើយ[895]។

## ២. ការពិភាក្សា

៤៩៤. ចៅក្រមអន្តរជាតិមិនយល់ឃើញថា ពុំមានចៅក្រមស៊ើបអង្កេតដែលមានហេតុផលអាចយល់ឃើញថា អោ អាន បានបញ្ជាឲ្យដកមិត្ត សុប និង អាំ។ ទីមួយ សហមេធាវីខកខាន មិនបានកំណត់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបង្ហាញ ភស្តុតាងខុស[896] នៅពេលផ្តល់សំអាងហេតុថា អោ អាន បានបញ្ជាឲ្យចាប់ និងសម្លាប់ មិត្ត សុប។ គួយ មាជ ថ្លែងច្បាស់ថា អោ អាន បានចាប់ សុប ហើយ រី ញ៉ ថ្លែងថា មានតែ អោ អាន ប៉ុណ្ណោះដែលអាចបញ្ជាឲ្យចាប់ខ្លួនគាត់ ដោយហេតុថា អោ អាន គឺជាកម្មាភិបាលជាន់ខ្ពស់ដែលមានសិទ្ធិចេញបញ្ជា[897]។ សហមេធាវីលើកឡើងទៀតថា សាក្សីចំនួន ៧ នាក់គាំទ្រអង្គហេតុ

---

សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា អោ អាន មានសិទ្ធិអំណាចទៅលើតំបន់ ៤១។ ហេតុនេះ ចៅក្រមអន្តរជាតិមិនលើកឡើងពីទឡ្ហីករណ៍ទាំងនេះថែមទៀតឡើយ។

[893] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១១៦។

[894] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១១៧-១១៩។

[895] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៦៤។

[896] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១១៧ ជើងទំព័រ ២៦១ *យោងទៅ* ចម្លើយរបស់សាក្សី គួយ មៀច, ឃុត សារ៉េត, រី ញ៉, សាត ភាត, សឹង លឹម, គង់ ទឹង និង ដួង ស៊ឹម។

[897] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី គួយ មៀច ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D219/582, ERN 01166942 (ឆ.១០៩)។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី រី ញ៉ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ D219/870, ERN 01348896 (ឆ.១០៧-ឆ.១០៨)។

ដែលថា ជុំ វង្ស (ង៉ូវ) ជាអ្នកឡើងជំនួសមិត្ត សុប[898]។

៤៩៥. ទីពីរ ចៅក្រមអន្តរជាតិមិនយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឆ្គងដែលខកខានមិនបានដោះស្រាយលើភស្តុតាងផ្ទុយគ្នាអំពីកាលបរិច្ឆេទនៃការចាប់ខ្លួនរបស់ អាំ[899] ឬថា ភស្តុតាងពាក់ព័ន្ធនឹងការចាប់ខ្លួនគាត់ពឹងផ្អែកតែទៅលើភស្តុតាងពាក្យចចាមអារ៉ាម ការស្មាន និងការបង្ហាញខុស[900]។ អំណះអំណាងរបស់សហមេធាវីដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនអើពើចំពោះភស្តុតាងរបស់ ប្រាក់ យុត ដែលថា បញ្ជាឲ្យចាប់ខ្លួន អាំ ដែលត្រូវបានចេញដោយភូមិភាគនិរតី មិនមែនចេញដោយ អោ អាន នោះ មិនគួរឲ្យជឿឡើយ[901]។ ចៅក្រមអន្តរជាតិយល់ឃើញថា ការណែនាំទូទៅក្នុងការបោសសម្អាត កម្មាភិបាលមួយចំនួនអាចចេញមកពីមជ្ឈិម ឬភូមិភាគនិរតី ហើយ អោ អាន ក្នុងនាមជាលេខាតំបន់ ៤១ អាចបានបញ្ជាឲ្យអ្នក នៅក្រោមបង្គាប់គាត់អនុវត្តការណែនាំទាំងនោះ។ ចំណុចនេះមិនមានន័យថាជាភស្តុតាង ផ្ទុយនោះទេ។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសឡើយ។

---

[898] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១១៧ ជើងទំព័រ ២៦២ *យោងទៅ* ចម្លើយរបស់សាក្សី សាត ភាព, ណៃ ស៊ុ, គង់ ទឹង, ដួង ស៊ុម, សឹង លឹម, ញ៉ែម ចេន និង ប្រាក់ យុត។ ការដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិគ្រាន់តែលើកឡើងថា ង៉ូវ ត្រូវបានតែងតាំងជាប្រធានសន្តិសុខ (*សូមមើល* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ២៩៥) មិនបានបង្កើតជាភាពស្រពិចស្រពិល ឬអនុញ្ញាតឲ្យមានការសន្និដ្ឋានដែលនាំឲ្យយល់ខុសអំពីតួនាទីរបស់ អោ អាន ដូចដែលសហមេធាវីបានចោទប្រកាន់នោះឡើយ។

[899] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១១៨ ជើងទំព័រ ២៦៤ *យោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ២៩៦ ជើងទំព័រ ៧៧៧។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាយ៉ាងច្បាស់ទៅលើភាពផ្ទុយគ្នាពាក់ព័ន្ធនឹងកាលបរិច្ឆេទនៃការចាប់ខ្លួន អាំ ក្នុងការសន្និដ្ឋានពីកាលបរិច្ឆេទប្រហាក់ប្រហែលនៅពាក់កណ្តាលឆ្នាំ១៩៧៧។ ទោះបីគាត់មិនបានពន្យល់ពីរបៀបដែលគាត់សម្រេចបែបនេះក៏ដោយ ក៏កាលបរិច្ឆេទនៃការចាប់ខ្លួនត្រូវបានកំណត់ដោយអង្គហេតុដែលថា អោ អាន បានចេញបញ្ជាឲ្យចាប់ខ្លួន។

[900] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១១៨ ជើងទំព័រ ២៦៥, ២៦៦។ ការពឹងផ្អែករបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅលើភស្តុតាងចចាមអារ៉ាមរបស់សាក្សី សាត ភាព មិនមែនថា មិនសមហេតុផលនោះទេ ដោយពិចារណាទៅលើរឿងរ៉ាវលម្អិតរបស់សាក្សី និងសិទ្ធិអំណាចតាមច្បាប់របស់ អោ អាន។ *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D219/504, ERN 01146393 (ឆ.១៣៥) ("តាអាំ ត្រូវបានគេឃុំ និងផ្ទុកខ្សែភ្លើងនៅព្រៃទទឹង ប៉ុន្តែខ្ញុំមិនដឹងថា គេយកសទៅសម្លាប់នៅទីណានោះទេ។ តាអានបញ្ជាឲ្យមានការចាប់ខ្លួន តាអាំ។ រឿងរ៉ាវទាំងអស់នេះ គឺនីរសាម្នាក់របស់ តាអួន ជាអ្នកប្រាប់ខ្ញុំ ខ្ញុំភ្លេចឈ្មោះគាត់ហើយ")។ ទាក់ទិននឹងតម្លៃជាភស្តុតាងចចាមអារ៉ាម *សូមមើល* មូលដ្ឋានទី ៥(v)។

[901] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១១៨ ជើងទំព័រ ២៦៧។

៤៩៦. ចុងក្រោយ ការជំទាស់របស់សហមេធាវីពាក់ព័ន្ធនឹងការចាប់ខ្លួន ប្រាក់ យុត[902] ពុំមានមូលដ្ឋានទេ ពីព្រោះសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានរកឃើញថា អោ អាន ទទួលខុសត្រូវចំពោះការ ដក ប្រាក់ យុត ឡើយ[903]។

## ៦(v)(ខ)(៤) សិទ្ធិអំណាចក្នុងការចេញបញ្ជា ឬអនុញ្ញាតឱ្យកម្មាភិបាលអនុវត្ត

### ១. សារណា

៤៩៧. សហមេធាវីលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការផ្តល់សំអាងហេតុថា អោ អាន បានបញ្ជាលេខាស្រុក ឬអ្នកនៅក្រោមបង្គាប់ ឱ្យកំណត់អត្តសញ្ញាណ និងកំណត់មុខសញ្ញាក្រុមជាក់លាក់[904]។ ជាពិសេស សហមេធាវីតវ៉ាចំពោះការពឹងផ្អែករបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ "ស្ទើរតែទាំងស្រុង" ទៅលើភស្តុតាងរបស់ ប្រាក់ យុត ក្នុងការធ្វើសេចក្តីសន្និដ្ឋានទាំងនេះ[905] ដោយអះអាងថា ការរៀបរាប់របស់គាត់មិនអាចជឿជាក់បាន មិនស៊ីសង្វាក់គ្នា មានការប្រឡូកប្រឡាក់ និងមិនមានការបញ្ជាក់គាំទ្រ[906]។ មិនតែប៉ុណ្ណោះ សហមេធាវីតវ៉ាថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានផ្តល់ភស្តុតាងគ្រប់គ្រាន់ពិតប្រាកដ និងមានការបញ្ជាក់ថា អោ អាន បានបញ្ជាឱ្យលេខាស្រុកកំណត់អត្តសញ្ញាណ និងសម្លាប់អ្នកដែលត្អូញត្អែរអំពីលក្ខខណ្ឌរស់នៅ និងលក្ខខណ្ឌការងាររបស់ពួកគេ[907] ឬថា អោ អាន បានបញ្ជាឱ្យ ប្រាក់ យុត និងអ្នកដទៃទៀតចាប់ខ្លួន និងសម្លាប់ប្រជាជនចាមទាំងអស់[908]។ ចំណុចចុងក្រោយ សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបង្ហាញភស្តុតាងខុស នៅពេលភ្ជាប់ទំនាក់ទំនងរវាង អោ អាន និងលេខាស្រុកដទៃទៀត ដូចជា កាន និង ភីម[909] និង នៅក្នុងការផ្តល់សំអាងហេតុថា អោ អាន បានចេញបញ្ជាឱ្យអ្នកនៅក្រោមបង្គាប់ ដូចជា អួន, សុខ និង ជុំ វង្ស ពាក់ព័ន្ធនឹង

---

[902] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១១៩។

[903] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៤២៣។

[904] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២០។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626076 ទំព័រ ២២ បន្ទាត់ ៩-១១។

[905] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២០។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626076 ទំព័រ ២២ បន្ទាត់ ១១-១២។

[906] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២០-១២២។

[907] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២២។

[908] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២២។

[909] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២៣។

ការចាប់ខ្លួន ផែនការសម្លាប់ និងការសួរចម្លើយនៅមន្ទីរសន្តិសុខនានា[910]។ សហមេធាវីសន្និដ្ឋានថា ការប្រកាសទូទៅរបស់ អោ អាន ទៅកាន់មនុស្សមិនស្គាល់អំពីប្រធានបទមិនជាក់លាក់ ត្រូវបានគាំទ្រតែដោយសាក្សីមិនគួរឱ្យជឿ និងមិនគ្រប់គ្រាន់ក្នុងការផ្តល់សំអាងហេតុថា អោ អាន បានចេញបញ្ជាដល់អ្នកនៅក្រោមបង្គាប់ឡើយ[911]។

៤៩៨. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិលើកទឡ្ហីករណ៍ថា សហមេធាវីបានខកខាន មិនបាន ដោះបន្ទុកក្នុងការបង្ហាញថា គ្មានអ្នកវិនិច្ឆ័យអង្គហេតុដ៏សមហេតុផលណាបានពឹងផ្អែក លើភស្តុតាងរបស់ ប្រាក់ យុត និងថា សហមេធាវីបំផ្លើស "យ៉ាងច្រើន" អំពីវិសាលភាពដែល ការសន្និដ្ឋានទាំងអស់នេះផ្អែកតែទៅលើភស្តុតាងរបស់ ប្រាក់ យុត[912]។ សហព្រះរាជអាជ្ញា អន្តរជាតិលើកអំណះអំណាងបន្ថែមទៀតថា សហមេធាវីមើលរំលងវិធីដែលភស្តុតាងទាំងមូលអំពីមុខតំណែង ទង្វើ និងការប្រព្រឹត្តិរបស់ អោ អាន ក្នុងនាមជាលេខាតំបន់ ៤១ គាំទ្រការសន្និដ្ឋានអំពីអង្គហេតុជាច្រើនរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពី អោ អាន បាន ចេញបញ្ជាទៅអ្នកក្រោមបង្គាប់ឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម[913]។

២. ការពិភាក្សា

៤៩៩. ចៅក្រមអន្តរជាតិយល់ឃើញថា សហមេធាវីខកខានមិនបានបង្ហាញថា គ្មានចៅក្រមស៊ើបអង្កេតដ៏សមហេតុផលណាបានផ្តល់សំអាងហេតុថា អោ អាន បានបញ្ជាឱ្យអ្នកនៅក្រោមបង្គាប់កំណត់អត្តសញ្ញាណ និងកំណត់មុខសញ្ញាក្រុមជាក់លាក់ឡើយ។ សំអាងហេតុនេះមានហេតុផល បើពិចារណាលើភស្តុតាង ដែលត្រូវបានបង្ហាញ និងភារកិច្ចរបស់ អោ អាន ជាលេខាតំបន់៤១ ដែលរួមមាន ការទទួលខុសត្រូវ "ចំពោះការណែនាំដល់ថ្នាក់ក្រោម និងប្រជាជនឱ្យតាមរកខ្មាំង ដើម្បីកសាង ឬ "កម្ទេច"[914] និងសិទ្ធិបញ្ជាឱ្យចាប់ខ្លួន និងសម្លាប់បុគ្គលជាក់លាក់"[915]។

---

[910] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២៤។

[911] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២៥ និង ជើងទំព័រ ២៨៦-២៨៨ *យោងទៅ*ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ២៨៣, ២៩៤, ២៩៩, ៣០១, ៣១១, ៦៣៦, និង *យោងទៅ* ចម្លើយរបស់សាក្សី ញ៉ែម ចេន និង យូ វ៉ាន់។

[912] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៦៥-៦៦។

[913] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៦៧។

[914] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ១៩៣។

[915] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ១៩៣។

៥០០. ទីមួយ ផ្ទុយទៅនឹងអំណះអំណាងរបស់សហមេធាវីដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែក "ស្ទើរតែទាំងស្រុង" លើ ប្រាក់ យុត នៅពេលផ្តល់សំអាងហេតុថា អោ អាន បានដាក់បញ្ជាដល់លេខាស្រុក[916] ដែលតាមការពិត ភស្តុតាងនេះមានការបញ្ជាក់ពីសាក្សីផ្សេងៗ ទៀតផងដែរ[917]។ ដូចគ្នានេះដែរ ពាក់ព័ន្ធនឹងការផ្តល់សំអាងហេតុថា អោ អាន បានបញ្ជាលេខា ស្រុកឲ្យកំណត់អត្តសញ្ញាណ និងសម្លាប់អ្នកដែលត្លួញត្លែរអំពីលក្ខខណ្ឌរស់នៅ និងលក្ខខណ្ឌ ការងារ[918] សហមេធាវីខកខានមិនបានបង្ហាញថា ការរៀបរាប់ដំណើររឿងរបស់ ប្រាក់ យុត ពុំមាន ការបញ្ជាក់ ឬមិនគួរឲ្យជឿជាក់លើចំណុចនេះនោះទេ[919]។ ចៅក្រមអន្តរជាតិនឹងដោះស្រាយ ការតវ៉ារបស់សហមេធាវីពាក់ព័ន្ធនឹងការលើកសំអាងហេតុថា អោ អាន បានបញ្ជា ប្រាក់ យុត ឲ្យចាប់ខ្លួន និងសម្លាប់ប្រជាជនចាម[920] នៅចំណុចខាងក្រោមនៅក្នុងមូលដ្ឋានទី ៦ នេះ[921]។

៥០១. នៅក្នុងឧបសម្ព័ន្ធ គ នៃបណ្តឹងឧទ្ធរណ៍របស់សហមេធាវី សហមេធាវីតវ៉ាថា ប្រាក់ យុត រៀបរាប់ដំណើររឿងមិនស្របគ្នាពាក់ព័ន្ធនឹង បញ្ជារបស់ អោ អាន ក្នុងការចាប់ខ្លួនកម្មាភិបាល ខ្នាំង និងអ្នកផ្សេងទៀត[922]។ ចៅក្រមអន្តរជាតិសង្កេតឃើញថាមានភាពមិនស្របគ្នានៅក្នុងភស្តុតាងរបស់ ប្រាក់ យុត លើ

---

[916] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២០ និង ជើងទំព័រ ២៧២ *យោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៣០២, ៣៦៤, ៤២៩, ៦៣៤ ជើងទំព័រ ៨០៥, ៨០៧, ១០៣០, ១៣២៦, ២១៦៣។

[917] *សូមមើលឧទាហរណ៍* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៣០២ ជើងទំព័រ ៨០៥ *ដកស្រង់ពី* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ឯកសារ D219/138, ERN 01056049-01056052 (ឆ.៤៩-ឆ.៥៨), 01056061-01056063 (ឆ.៩៨-១០២)។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ញឹម កុល ឯកសារ D219/171, ERN 01065947 (ឆ.១៣)។

[918] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២២ និងជើងទំព័រ ២៧៧ *យោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ២៧៥ ជើងទំព័រ ៧១៨។

[919] សាក្សី ប្រាក់ យុត ត្រូវបានបញ្ជាក់បន្ថែមដោយសាក្សីនានាដែលបានផ្តល់ព័ត៌មានលម្អិតអំពីការអនុវត្តការបញ្ជាទាំងនោះ។ *សូមមើលឧទាហរណ៍* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ហុក ហឿន ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D6.1.413, ERN 00243079 ("បើមានការតវ៉ា [ពីការហូបមិនគ្រប់] គេនឹងយកចេញទៅ")។

[920] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២២ *យោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៦៣៤ ជើងទំព័រ ២១៦៣។

[921] *សូមមើលខាងក្រោម* មូលដ្ឋានទី ៦(vi)។

[922] ឧបសម្ព័ន្ធ ឃ នៃ បណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/5/1.5), ERN 01599802។

បញ្ហានេះ[923]។ ទោះជាយ៉ាងណាក្ដី ដោយរម្លឹកឡើងវិញពីការវិភាគរបស់ខ្លួនខាងដើម ចៅក្រមអន្តរជាតិយល់ឃើញថា ការបដិសេធពីដំបូងរបស់ ប្រាក់ យុត ដែលថា អោ អាន មិនបានចេញបញ្ជាឱ្យគាត់ចាប់ក្រុមមនុស្សផ្សេងៗនោះ ត្រូវពិនិត្យមើលដោយពិចារណាលើការផ្លាស់ប្ដូរទូទៅនៃភស្តុតាងរបស់គាត់ និងភាពភ័យខ្លាចក្នុងការលាតត្រដាងពីការពាក់ព័ន្ធរបស់គាត់នៅក្នុងឧក្រិដ្ឋកម្ម[924]។ ក្រោយពីការផ្លាស់ប្ដូរនេះ[925] ប្រាក់ យុត រក្សាសង្គតិភាពនៃការរៀបរាប់ដំណើររឿងរបស់គាត់ថា អោ អាន បានបញ្ជាឱ្យចាប់ "ខ្លាំង" ហេតុដូច្នេះ ចៅក្រមអន្តរជាតិយល់ឃើញថា មិនមែនជាការមិនសមហេតុផលនោះទេសម្រាប់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងការផ្ដល់សំអាងហេតុនេះដោយផ្អែកលើភស្តុតាងរបស់ ប្រាក់ យុត ក្នុងចំណោមបញ្ហាផ្សេងទៀត។ ជាងនេះទៀត ការលើកឡើងរបស់សហាមេធាវីដែលថា ប្រាក់ យុត "ត្រូវបានផ្ដល់" ព័ត៌មាននោះ ពុំមានមូលដ្ឋានឡើយ[926]។

៥០២. ទីពីរ ចៅក្រមអន្តរជាតិមិនយល់ស្របថា ការដឹងរបស់ ប្រាក់ យុត មានកម្រិតតែត្រឹមស្រុកកំពង់

---

[923] ឧទាហរណ៍ ចៅក្រមអន្តរជាតិសង្កេតឃើញថា ដំបូងសាក្សី ប្រាក់ យុត លើកឡើងថា គាត់មិនដែលបានទទួលបញ្ជាពី អោ អាន ទេ តែថា គាត់អាចចេញបញ្ជាទៅអនុគាត់ឈ្មោះ ស៊ី។ ក្រោយមក នៅក្នុងការស្ដាប់ចម្លើយដដែលនោះ សាក្សី ប្រាក់ យុត លើកឡើងថា មានការសម្លាប់នៅកំពង់សៀម ហើយថា គាត់បានទទួលបញ្ជាពី អោ អាន ដើម្បីចាប់ខ្លួនជនជាតិចាម និងទាហាន លន់ នល់។ *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ ឯកសារ D117/70, ERN 01046796-01046797 (ឆ.៣៧-ឆ.៣៩, ឆ.៤៣-ឆ.៤៥) ("ខ្ញុំមិនដែលបានទទួលបញ្ជាពី តាអាន ឱ្យចាប់ខ្លួនអ្នកណាទេ [...] ខ្ញុំសូមបញ្ជាក់ថា តាអាន មិនបានបញ្ជាឱ្យខញុំចាប់មនុស្សទាំងនោះទេ ប៉ុន្តែប្រហែលជា តាអាន បានបញ្ជាផ្ទាល់ទៅ តាស៊ី ដែលជាអនុរបស់ខ្ញុំ [...]") ហើយក្រោយមក (ឆ.៤៣-ឆ.៤៥) ("ខ្ញុំសូមសារភាពថា មានការសម្លាប់នៅក្នុងស្រុកកំពង់សៀម ដោយខ្ញុំទទួលបញ្ជាពី តាអាន។ [...] ចាស ខ្ញុំទទួលបញ្ជាពី តាអាន ឱ្យប្រមូលជនជាតិចាម និងអតីតទាហាន លន់ នល់។ [...] តាអាន បញ្ជាក្នុងពេលប្រជុំប្រចាំខែ។ នៅក្នុងកិច្ចប្រជុំនោះ តាអាន បានចេញបញ្ជាដូចគ្នាទៅកាន់គណៈស្រុកផ្សេងទៀត")។

[924] *សូមមើលខាងលើ* មូលដ្ឋានទី ៥(ii)(ក)។ *សូមមើលផងដែរ ឧទាហរណ៍* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ ឯកសារ D117/70, ERN 01046798 (ឆ.៤៧) ("ខ្ញុំមិនបាននិយាយឱ្យអស់នៅក្នុងកិច្ចសម្ភាសន៍មុនៗរបស់ខ្ញុំ [...] ខ្ញុំបារម្ភពីសុវត្ថិភាពរបស់ខ្ញុំ")។

[925] *សូមមើលខាងលើ* មូលដ្ឋានទី ៥(ii)(ក)។

[926] *សូមមើលខាងលើ* មូលដ្ឋានទី ៥(iii)។ នៅក្នុងឧបសម្ព័ន្ធ ឃ សហាមេធាវីអះអាងថា ផ្នែកនៃភស្តុតាងពាក់ព័ន្ធនឹងសាក្សី ប្រាក់ យុត បានយកដោយសារអ្នកស៊ើបអង្កេត "ផ្ដល់" ព័ត៌មានដាក់បន្ទុកដល់គាត់ រួមទាំង "ការរម្លឹកការចងចាំរបស់គាត់" ផងដែរ។ *សូមមើល* ឧបសម្ព័ន្ធ ឃ នៃបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (D360/5/1.5), ERN 01599802។ ចៅក្រមអន្តរជាតិសង្កេតឃើញថា សហាមេធាវីធ្លាប់បានជំទាស់ទៅនឹងចម្លើយនេះរួចមកហើយ។ *សូមមើល* ឧបសម្ព័ន្ធ ខ នៃពាក្យសុំធ្វើមោឃភាពកំណត់ហេតុស្ដាប់ចម្លើយសាក្សី (D338/1/2.3), ERN (EN) 01388934-01388936, 01388939-01388942 លេខរៀង ១០, ១២, ១៤។

សៀម និងថា ការរៀបរាប់របស់គាត់អំពីលេខាស្រុកផ្សេងៗទៀតដែលទទួលបញ្ជា មិនមានសង្គតិភាព[927] ឬជាលទ្ធផល បានមកពី "[ការិយាល័យព្រះរាជអាជ្ញា] ដែលធ្វើឱ្យគាត់នឹកឃើញឡើងវិញ"[928]។

៥០៣. ទីបី ចៅក្រមអន្តរជាតិមិនយល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឆ្គង ដោយបង្ហាញភស្តុតាងខុសនៅពេលធ្វើការភ្ជាប់រវាង អោ អាន និងលេខាស្រុកផ្សេងទៀតក្រៅពី ប្រាក់ យុត[929] និងយល់ឃើញថា ការភ្ជាប់នេះត្រូវបានបង្កើតគ្រប់គ្រាន់ ក្នុងចំណោមបញ្ហាផ្សេងៗ តាមរយៈសិទ្ធិអំណាចតាមច្បាប់របស់ អោ អាន លើស្រុកផ្សេងៗ និងតាមរយៈភស្តុតាងដែលថា អោ អាន និងលេខាស្រុក ឈ្មោះ កាន បានធ្វើការប្រជុំមួយនៅស្រុកកងមាស ដែលពួកគេបានប្រាប់អ្នកភូមិថា មាន "ខ្មាំង" ក្នុងចំណោម

---

[927] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២១ ជើងទំព័រ ២៧៥។ចៅក្រមអន្តរជាតិសង្កេតឃើញថា ដំបូង សាក្សី ប្រាក់ យុត លើកឡើងថា គាត់ "មិនដឹងច្បាស់" ឬ "មិនដឹង" ថាតើ លេខាស្រុកផ្សេងទៀតបានទទួលបញ្ជាឱ្យសម្លាប់ជនជាតិចាម ឬយ៉ាងណាទេ។ ទោះជាយ៉ាងណាក្តី នៅពេលសាកសួរតទល់ទៅនឹងចម្លើយមុនៗរបស់គាត់ សាក្សី ប្រាក់ យុត ផ្តល់សក្ខីកម្មថា គាត់បានទទួលបញ្ជាក្នុងពេលប្រជុំថ្នាក់តំបន់ ដែលនៅទីនោះ មេស្រុកទាំងអស់ត្រូវបានកោះហៅឱ្យចូលរួម។ *សូមមើល* ប្រតិចារឹកថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ក្នុងសំណុំរឿង ០០២ (ប្រាក់ យុត) ឯកសារ D219/702.1.95, ERN 01253281-01253282 ទំព័រ ៨ បន្ទាត់ ៥ ដល់ ទំព័រ ៩ បន្ទាត់ ៤។ ដោយរម្លឹកថា ការរម្លឹកដល់ការចងចាំរបស់សាក្សីដោយប្រើចម្លើយមុនៗ គឺជាការអនុវត្តស្របច្បាប់នោះ ចៅក្រមអន្តរជាតិយល់ឃើញថា ការណ៍ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិសំអាងទៅលើចម្លើយក្រោយរបស់សាក្សី ប្រាក់ យុត ("យោងទៅការប្រជុំដែលតំបន់បានកោះហៅ ដែលមេតំបន់ទាំងអស់ត្រូវបានកោះហៅឱ្យទៅចូលរួម។ ហើយការពិត បញ្ហានេះកើតឡើងជាយូរឆ្នាំមកហើយ ហេតុនេះ ជួនកាល ការចងចាំរបស់ខ្ញុំមិនបានត្រឹមត្រូវទេ។ ក៏ប៉ុន្តែ នៅលើលោកលើកពីបញ្ហានេះ វាធ្វើឱ្យខ្ញុំចងចាំមកវិញខ្លះ។ ហេតុនេះ ពួកយើងពិតជាបានចូលរួមការប្រជុំនោះមែន") និងចម្លើយមុនៗរបស់គាត់ (*សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ ឯកសារ D117/70, ERN 01046797 (ឆ.៤៥) ("តាអាន បញ្ជាក្នុងពេលប្រជុំប្រចាំខែ។ នៅក្នុងកិច្ចប្រជុំនោះ តាអាន បានចេញបញ្ជាដូចគ្នាទៅកាន់គណៈស្រុកផ្សេងៗទៀត") ដើម្បីសន្និដ្ឋានថា លេខាស្រុកផ្សេងទៀតក៏បានទទួលបញ្ជាឱ្យ "កម្ទេច" ជនជាតិចាម មិនមែនថាមិនសមហេតុផលទេ។

[928] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២១ ជើងទំព័រ ២៧៥ *យោង*ប្រតិចារឹកថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ ក្នុងសំណុំរឿង ០០២ (ប្រាក់ យុត) ឯកសារ D219/702.1.94។ ប្រតិចារឹកថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ក្នុងសំណុំរឿង ០០២ (ប្រាក់ យុត) ឯកសារ D219/702.1.95។ សហព្រះរាជអាជ្ញាបានចូលរួមក្នុងការអនុវត្តស្របច្បាប់ក្នុងការប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយមុនៗ ដើម្បីរម្លឹកដល់ការចងចាំរបស់សាក្សី ប្រាក់ យុត ក្នុងអំឡុងពេលគាត់មកផ្តល់សក្ខីកម្ម។ *សូមមើល* ប្រតិចារឹកថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ក្នុងសំណុំរឿង ០០២ (ប្រាក់ យុត) ឯកសារ D219/702.1.95, ERN 01253280 ទំព័រ ៧ បន្ទាត់ ៧-៨ ("*ម្សិលមិញ* លោកស្រីបានឆ្លើយថា លោកបានទទួលបញ្ជាពីថ្នាក់តំបន់ ដើម្បីបោសសម្អាតជនជាតិចាម") (គូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរខាងលើ* មូលដ្ឋានទី ៥(iii)។

[929] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២៣ *យោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៤៦៣។

ប្រជាជន ក្រោយមក ការចាប់ចងក៏មានសន្ទុះឡើងថែមទៀត[930]។ ជាងនេះទៀត ចៅក្រមអន្តរជាតិមិនជឿថា ការពិនិត្យមួយដ៏សមស្របលើភស្តុតាងបង្ហាញថា អោ អាន មិនបានបញ្ជាអ្នកនៅក្រោមបង្គាប់ ដូចជា អ្វូន, សុខ និង ជុំ វង្ស[931] លើ បញ្ហាផ្សេងៗ ក្នុងនោះរួមមានការចាប់ខ្លួន ឬផែនការសម្លាប់[932]។ ចៅក្រមអន្តរជាតិយល់ឃើញថា ការប្រកាស និងការណែនាំរបស់ អោ អាន នៅក្នុងកំឡុងពេលប្រជុំ បញ្ជាក់បន្ថែមលើសំអាងហេតុដែលថា អោ អាន បានចេញបញ្ជា និងបានអនុវត្តសិទ្ធិអំណាចនៅក្នុងតំបន់៤១[933] និងថា ការតវ៉ារបស់សហមេធាវីចំពោះភស្តុតាងជាមូលដ្ឋាននេះ ខកខានមិនបានកំណត់ថា សំអាងហេតុទាំងនេះផ្អែកលើភស្តុតាងពុំមានការបញ្ជាក់ ឬដែលផ្អែកលើសក្ខីកម្ម ពុំមានសង្គតិភាព ឬថា សាក្សីដឹងមិនច្បាស់អំពីខ្លឹមសារនៃកិច្ចប្រជុំទាំងនេះ[934]។

### ៦(v)(ខ)(៥) សិទ្ធិអំណាចក្នុងការទទួលរបាយការណ៍ពីកម្មាភិបាល

### ១. សារណា

៥០៤. សហមេធាវីតវ៉ាថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការលើកសំអាងហេតុថា អោ អាន បានដឹងពីសកម្មភាពទាំងអស់របស់ ប.ក.ក នៅក្នុងតំបន់របស់គាត់តាមរយៈប្រព័ន្ធទំនាក់ទំនង និងរាយការណ៍ដ៏ច្បាស់លាស់ ដែលធ្វើឱ្យគាត់អាចត្រួតពិនិត្យការវិវត្តនៃប្រតិបត្តិការ សម្លាប់មនុស្ស[935]។

---

[930] *សូមមើលឧទាហរណ៍* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៤៦៣, ៤៦៥ (ពាក់ព័ន្ធនឹង កាន)។

[931] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២៤ *យោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ២៧៩, ២៨២, ២៨៧, ៤២៧។

[932] សហមេធាវីជំទាស់ទៅនឹងភស្តុតាងរបស់សាក្សី ញ៉ែម ចេន និង សាក្សី យូ វ៉ាន់ ដែលចោទប្រកាន់ថា រឿងរ៉ាវរបស់ពួកគេពុំមានការបញ្ជាក់បន្ថែម មិនអាចជឿជាក់បាន ចចាមអារ៉ាម និងប្រឡាក់ប្រឡូស។ នៅក្នុងមូលដ្ឋានទី ៥ ចៅក្រមអន្តរជាតិបានបដិសេធទឡ្ហីករណ៍ដូចគ្នា និងបានសម្រេចថា សាក្សីទាំងនេះអាចជឿជាក់បានជាទូទៅ។ *សូមមើល* មូលដ្ឋានទី ៥(v)(ii)(ខ) និង (ឃ)។

[933] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២៥ *យោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ២៨៣, ២៩៤, ២៩៩, ៣០១, ៣១១, ៦៣៦។

[934] សហមេធាវីជំទាស់ទៅនឹងភស្តុតាងរបស់សាក្សី ញ៉ែម ចេន ដោយសារការដឹងរបស់គាត់ពីខ្លឹមសារនៃកិច្ចប្រជុំ "គួរឱ្យសង្ស័យ" ដោយសារវ័យរបស់គាត់ និង សាក្សី យូ វ៉ាន់ ដោយសារ "សក្ខីកម្មមិនស៊ីចង្វាក់" របស់គាត់។ *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២៥។ ចៅក្រមអន្តរជាតិយោងទៅការវាយតម្លៃរបស់ខ្លួនទៅលើភាពជឿជាក់បានជារួមរបស់សាក្សី ញ៉ែម ចេន និង យូ វ៉ាន់ នៅក្នុងមូលដ្ឋានទី ៥(ii)(ខ) និង (ឃ) និងពិចារណាឃើញថា ទឡ្ហីករណ៍ទាំងនេះគ្មានមូលដ្ឋាន។

[935] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២៦។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំ

សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានផ្តល់ភស្តុតាងគ្រប់គ្រាន់ និងមានការបញ្ជាក់អំពីចំណុចដែល អោ អាន បានទទួលរបាយការណ៍ពីលេខាស្រុក អ្នកក្រោមបង្គាប់ ឬថ្នាក់ក្រោម។ ជាពិសេស សហមេធាវីតវ៉ានឹងចំណុចដែល សហចៅក្រមស៊ើបអង្កេតអន្តរជាតិផ្អែកលើភស្តុតាងនៃការរាយការណ៍បានមកពី ប្រាក់ យុត[936] និង ជុំ វង្ស[937]។ សហមេធាវីលើកឡើងថា ភស្តុតាងរបស់ ប្រាក់ យុត អំពីអត្ថិភាព និងខ្លឹមសារ នៃរបាយការណ៍ទាំងនេះ (i) មិនគួរឱ្យជឿជាក់ (ii) ពុំមានសង្គតិភាព (iii) គាំទ្រដោយត្រឹមតែ ពាក្យចចាមអារ៉ាមរបស់ យូ វ៉ាន់[938] និងបង្ហាញខុសពីចម្លើយរបស់សាក្សី ឬអ្នកដាក់ពាក្យ សុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[939]។ សហមេធាវីលើកទឡ្ហីករណ៍តវ៉ាទៀតទៅលើចំណុចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិផ្អែក លើ ជុំ វង្ស និង ញ៉ែម ចេន ក្នុងការលើកសំអាង ហេតុថា ជុំ វង្ស រាយការណ៍ទៅ អោ អាន អំពីការសម្លាប់នៅមន្ទីរសន្តិសុខ មិត្តសុប និងចូលរួម ប្រជុំដែលក្នុងកិច្ចប្រជុំទាំងនោះ គាត់អាចបានរាយការណ៍ទៅ អោ អាន ឬ អួន[940]។

៥០៥. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា លក្ខន្តិកៈ ប.ក.ក ដែលរំពឹងទុកពី វចនាសម្ព័ន្ធនៃការរាយការណ៍ គឺជាការផ្តល់មូលដ្ឋានសមហេតុផលក្នុងការសន្និដ្ឋានថា អោ អាន បានទទួលរបាយការណ៍ពីអ្នកនៅក្រោមបង្គាប់ និងថា ភស្តុតាងបានមកពីសាក្សីជាច្រើន បង្ហាញថាខ្សែចង្វាក់នៃការរាយការណ៍នៅក្នុងតំបន់៤១ មានមុខងារដូចដែលបានគិតទុកក្នុងលក្ខន្តិកៈ ប.ក.ក[941]។ មិនតែប៉ុណ្ណោះ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ភស្តុតាងរបស់ ប្រាក់ យុត អំពីការរាយការណ៍ ត្រូវបានបញ្ជាក់ដោយសាក្សីដទៃទៀត[942]។

៥០៦. ជាការឆ្លើយតប សហមេធាវីអះអាងថា សហព្រះរាជអាជ្ញាអន្តរជាតិបង្ហាញភស្តុតាងខុសនៅពេល

---

រឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626076 ទំព័រ ២២ បន្ទាត់ ៩-១១។

[936] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២៦-១២៧។

[937] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២៧-១២៨។

[938] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២៧ ជើងទំព័រ ២៩៧។

[939] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២៧ ជើងទំព័រ ២៩៨ *យោងទៅ* ចម្លើយរបស់សាក្សី ពៅ សារ៉ុម និង ញឹម កុល។ ឧបសម្ព័ន្ធ ឃ នៃ បណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/5/1.5), ERN 01599802-01599804។

[940] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២៨។

[941] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៦៨។

[942] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៦៨ និងជើងទំព័រ ១៧៤ *យោងទៅ* ចម្លើយរបស់សាក្សី យូ វ៉ាន់, អ៊ឹម ប៉ុន, ហុង ហេង, ញ៉ៃ ចេន, ពុត កុល, លាត ភាព និង សូ សារ៉េន។

ថ្លែងថា ការរៀបរាប់ដំណើររឿងរបស់ ប្រាក់ យុត ត្រូវបានបញ្ជាក់បន្ថែម "យ៉ាងរឹងមាំ" ដោយសាក្សីផ្សេងទៀត។ សហមេធាវីលើកឡើងថា សាក្សីដទៃទៀតទាំងនេះគ្រាន់តែនិយាយ អំពីកិច្ចប្រជុំ មិនមែននិយាយអំពីការរាយការណ៍ឡើយ ហើយជារឿយៗ មិនដឹងអំពីខ្លឹមសារនៃកិច្ច ប្រជុំទាំងនេះទេ[943]។

## ២. ការពិភាក្សា

៥០៧. ចៅក្រមអន្តរជាតិយល់ឃើញថា សហមេធាវីខកខានមិនបានបង្ហាញថា គ្មានសហចៅក្រមស៊ើបអង្កេតដ៏សមហេតុផលណាអាចយល់ឃើញថា អោ អាន បានទទួលរបាយការណ៍ឡើយ ក្នុងនោះរួមមានការចាប់ខ្លួន និងការសម្លាប់។ សំអាងហេតុនេះមានហេតុផល ផ្អែកលើភស្តុតាងដែលបានបង្ហាញ និងមានការបញ្ជាក់បន្ថែមដោយភារកិច្ចរបស់ អោ អាន ក្នុងនាមជាលេខាតំបន់៤១ ដែលរួមមានការទទួលខុសត្រូវក្នុងការ "ទទួលរបាយការណ៍អំពីស្ថានការណ៍ និងការងាររបស់ស្រុក"[944]។

៥០៨. ទីមួយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសក្នុងការពឹងផ្អែកលើភស្តុតាងរបស់ ប្រាក់ យុត ឡើយ[945]។ សហមេធាវីខកខានមិនបានបង្ហាញថា ភស្តុតាងរបស់ ប្រាក់ យុត ពុំមាន សង្គតិភាព ឬមិនគួរឲ្យជឿជាក់លើចំណុចនេះទេ[946]។ ភស្តុតាងរបស់ ប្រាក់ យុត ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរាយការណ៍នៅក្នុង

[943] ការឆ្លើយតបរបស់ អោ អាន (D360/11) កថាខណ្ឌ ៤២។

[944] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ១៩០ ជើងទំព័រ ៤០៦។

[945] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២៦-១២៧ *យោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ២៥៧, ២៦៣, ២៦៦, ២៨៥, ៣៩៨, ៤៣១។

[946] នៅក្នុងឧបសម្ព័ន្ធ ឃ សហមេធាវីលើកឡើងអំពីភាពមិនស៊ីសង្វាក់ដែលត្រូវបានចោទប្រកាន់នៅក្នុងភស្តុតាងរបស់សាក្សី ប្រាក់ យុត ទាក់ទិននឹងការរាយការណ៍ទៅ អោ អាន។ *សូមមើល* ឧបសម្ព័ន្ធ ឃ នៃ បណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/5/1.5), ERN 01599802-01599804។ ចៅក្រមអន្តរជាតិសន្និដ្ឋានថា ពុំមានភាពមិនស៊ីសង្វាក់ទេ។ *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ D219/120, ERN 01046833-01046834៖ *ប្រៀបធៀប* (ឆ.២៦-ឆ.២៨) (លើកឡើងថា "ពេលអនុរក្សបញ្ចប់សព្វគ្រប់ហើយ មេឃុំទាំងអស់បានរាយការណ៍មកខ្ញុំផ្ទាល់។ ក្រោយមក [...] ខ្ញុំធ្វើរបាយការណ៍បញ្ជូនទៅ តាអាន នៅថ្នាក់តំបន់" និងបានលើកឡើងបន្ថែមថា គាត់ "រៀបរាប់អំពីចំនួន ឈ្មោះ និងមូលហេតុនៃការចាប់ខ្លួន ដាក់ឃុំឃាំង ដោះលែង និងការស្លាប់) *ជាមួយ* (ឆ.៣០) (គ្រឹមតែលើកឡើងថា អោ អាន មិនដែលចុះមកផ្ទៀងផ្ទាត់ចំនួនមនុស្សដែលត្រូវបានចាប់ខ្លួន ឃុំឃាំង ឬកម្ទេចទេ តែបានទៅជួបសាក្សី ប្រាក់ យុត យូរៗម្តង)។ ការចោទប្រកាន់បន្ថែមរបស់សហមេធាវីដែលថា "ផ្តល់ចម្លើយ" ត្រូវបានលើកឡើងនៅក្នុងមូលដ្ឋានទី ៥(ii)(ក)។ ក្រៅពីនេះ សហមេធាវីចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិទទួលស្គាល់ពីភាពមិនស៊ីសង្វាក់នៅក្នុងភស្តុតាងរបស់សាក្សី ប្រាក់ យុត តែនៅតែបន្តសំអាងទៅលើរូបគាត់។ *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២៧ *យោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៦៣៥។ ការចោទ

តំបន់ ៤១ តាមពិត ត្រូវបានបញ្ជាក់ដោយសាក្សីដទៃទៀត[947]។ ទឡ្ហីករណ៍របស់សហមេធាវីដែលថា សាក្សីទាំងនេះមិនអាចបញ្ជាក់លើ ការថ្លែងរបស់ ប្រាក់ យុត ដោយហេតុថា ពួកគេគ្រាន់តែនិយាយអំពីកិច្ចប្រជុំ មិនមែនជាការរាយការណ៍ទេ ឬដោយហេតុថាពួកគេមិនដឹងអំពីខ្លឹមសារនៃកិច្ចប្រជុំ[948] មិនត្រឹមត្រូវទេ បើផ្អែកលើភស្តុតាងដែលថា ការរាយការណ៍តាមពិតក៏មាននៅអំឡុងពេលប្រជុំដែរ[949]។ ទីពីរ សហមេធាវីខកខានមិនបានបង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការពឹងផ្អែកលើភស្តុតាងរបស់ យូ វ៉ាន់ សម្រាប់ការបញ្ជាក់[950] ឬផ្អែកលើភស្តុតាងខ្លួនឯង[951] ឬដោយខកខានមិនបានពន្យល់ពីមូលហេតុនៃការថយទម្ងន់នៃភស្តុតាងផ្ទុយពី យូ វ៉ាន់[952]។ ចំណុចចុងក្រោយ ចៅក្រមអន្តរជាតិយល់ឃើញថា សហ

---

ប្រកាន់នេះគ្មានមូលដ្ឋានទេ។ ការដែលថា សាក្សី ប្រាក់ យុត លើកឡើងថា គាត់មិនចាំពីខ្លឹមសារជាក់លាក់នៃរបាយការណ៍ទាំងនោះនៅក្នុងសក្ខីកម្មរបស់គាត់នៅក្នុងសំណុំរឿង ០០២ មិនមែនជាការមិនស៊ីសង្វាក់នោះឡើយ។

[947] *សូមមើលឧទាហរណ៍* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ២៦៣ ជើងទំព័រ ៦៦០-៦៦២ *យោងទៅ* ចម្លើយរបស់សាក្សី យូ វ៉ាន់, អ៊ឹម ប៉ុន, ហុង ហេង, សូ សារ៉េន, ញ៉ែម ចេន, ពុត កុល និង សាត ភាព។

[948] ការឆ្លើយតបរបស់ អោ អាន (D360/11) កថាខណ្ឌ ៤២។

[949] *សូមមើលឧទាហរណ៍* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ជុំ វង្ស (ង៉ូវ) ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D219/442, ERN 01125518-01125519 (ឆ.១១៨, ឆ.១២០) ("របាយការណ៍យោធានឹងបញ្ជូនដោយផ្ទាល់ទៅលេខាតំបន់ [...] ខ្ញុំដឹងថា ពួកគេអាចទាក់ទងជាមួយ តាអាន តាមរបាយការណ៍ជាលាយលក្ខណ៍អក្សរ ឬតាម*របាយការណ៍ផ្ទាល់មាត់នៅក្នុងកិច្ចប្រជុំ*") (គូសបញ្ជាក់បន្ថែម)។

[950] *សូមមើលឧទាហរណ៍* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២៦ ជើងទំព័រ ២៩១ (សហមេធាវីជំទាស់ទៅនឹងការដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិសំអាងទៅលើភស្តុតាងរបស់សាក្សី យូ វ៉ាន់ ដើម្បីបញ្ជាក់បន្ថែមទៅលើភស្តុតាងរបស់សាក្សី ប្រាក់ យុត ទាក់ទិននឹងការរាយការណ៍ទៅ អោ អាន ដោយសារសាក្សី យូ វ៉ាន់ "គ្រាន់តែ" យោងទៅលើរបាយការណ៍ស្តីពីការងារសេដ្ឋកិច្ច)។ ទឡ្ហីករណ៍នេះមិនត្រឹមត្រូវទេ។ ទោះបីសាក្សី យូ វ៉ាន់ យោងទៅលិខិតនានាដែលទាក់ទិននឹងការងារសហករណ៍ និងលទ្ធផលការងារក៏ដោយ ក៏អាចថា របាយការណ៍ទាក់ទិននឹងការរៀបចំការរៀបអាពាហ៍ពិពាហ៍ដែរ។ *សូមមើលឧទាហរណ៍* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ២៦៣ ជើងទំព័រ ៦២២ *យោងទៅ* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ឯកសារ D219/138, ERN 01056044-01056045 (ឆ.២៣-ឆ.២៧) (ពន្យល់ថា គាត់បានបញ្ជូនលិខិតពី អោ អាន ទៅ ប្រាក់ យុត និង ពី ប្រាក់ យុត មក អោ អាន វិញ ហើយថារបាយការណ៍ទាំងនេះលើកឡើងពីចម្លើយមនុស្សដែលរៀបការ)។ ក្រៅពីនេះ ភស្តុតាងនេះបញ្ជាក់បន្ថែមយ៉ាងច្បាស់ទៅលើអត្ថិភាពនៃប្រព័ន្ធរាយការណ៍ ដោយមិនគិតដល់ខ្លឹមសារនៃរបាយការណ៍ដែល សាក្សី យូ វ៉ាន់ អាចចូលរួម។

[951] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២៦ ជើងទំព័រ ២៩១, ២៩៧។ ចៅក្រមអន្តរជាតិរម្លឹកអំពីសេចក្តីសន្និដ្ឋានរបស់ខ្លួននៅក្នុងមូលដ្ឋានទី ៥(ii)(ខ) និង ៥(v) នៅពេលដែលចៅក្រមអន្តរជាតិបានសម្រេចថា សាក្សី យូ វ៉ាន់ អាចជឿជាក់បានជាទូទៅ ទោះបីនៅពេលដែលរឿងរ៉ាវរបស់គាត់មានពាក្យចចាមអារ៉ាមក៏ដោយ។

[952] សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកំណត់ពីភស្តុតាងដែលអាចផ្ទុយគ្នា និងបានយោងទៅភស្តុតាងនោះ ដោយបង្ហាញថា

ចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសក្នុងការពឹងផ្អែកលើ ញ៉ែម ចេន និង ជុំ វង្ស[953] នៅពេលផ្តល់សំអាងហេតុថា ជុំ វង្ស បានបញ្ជូនរបាយការណ៍ទៅ អោ អាន និងមានការប្រជុំជាមួយ អោ អាន[954]។

### ៦(v)(ខ)(៦) សិទ្ធិអំណាចក្នុងការដឹកនាំកិច្ចប្រជុំថ្នាក់តំបន់

### ១. សារណា និងការពិភាក្សា

៥០៩. សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការលើក សំអាងហេតុថា អោ អាន បានដឹកនាំកិច្ចប្រជុំថ្នាក់តំបន់ ឬការបង្រៀននយោបាយ សន្តិសុខ ឬ បញ្ញាយោធា[955]។ ចៅក្រមអន្តរជាតិបានសម្រេចរួចហើយខាងលើថា ពុំមានកំហុសនៅក្នុង សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងកិច្ចប្រជុំដែលដឹកនាំដោយ អោ អាន ទេ ហើយចៅក្រមអន្តរជាតិនឹងមិន

គាត់បានវាយតម្លៃ និងផ្តល់ទម្ងន់ដល់ភស្តុតាង តែបានសន្និដ្ឋានថា ភស្តុតាងនោះមិនអាចរារាំងមិនឱ្យគាត់ធ្វើការសន្និដ្ឋានទាំងនេះបានឡើយ។ *សូមមើលខាងលើ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ២៩៧ ជើងទំព័រ ៧៨៣។ ទោះបីសហចៅក្រមស៊ើបអង្កេតអន្តរជាតិយោងទៅកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣ ឯកសារ D117/31, ERN 00964454 (ឆ.១៤) ("[...] អតីតកម្មាភិបាលត្រូវបានដកចេញមុនពេលយើងមកដល់") ក៏ដោយ ក៏គាត់បានដកស្រង់ភស្តុតាងប្រាំមួយចំណុចទៀត ដើម្បីបង្ហាញថា មានការវាយការណ៍ពីការបោសសម្អាតទៅ អោ អាន។

[953] ភាពជឿជាក់បានជារួមរបស់សាក្សី ញ៉ែម ចេន និងសាក្សី ជុំ វង្ស ត្រូវបានលើកឡើងនៅក្នុងមូលដ្ឋានទី ៥(ii)(ឃ) និង (ង)។ ទាក់ទិននឹងការធ្វើសេចក្តីសន្និដ្ឋានដោយឡែកទាំងនេះ សាក្សី ញ៉ែម ចេន បាននិយាយរឿងរ៉ាវយ៉ាងលម្អិតពីរបៀបដែលគាត់ទទួលបញ្ជាពី អោ អាន និងបានទៅប្រមូលរបាយការណ៍ពីសន្តិសុខ មិត្ត សុប ដោយផ្ទាល់ ហើយថា អោ អាន បានទទួលរបាយការណ៍ដែលថា បញ្ជារបស់គាត់ត្រូវគេអនុវត្តតាមពីសាក្សី ជុំ វង្ស (ង៉ូវ)។ *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/855, ERN 01344691 (ឆ.៥៨-ឆ.៥៩), 01344693 (ឆ.៧៤, ឆ.៧៥-ឆ.៧៦)។ ការចោទប្រកាន់របស់សហមេធាវីដែលថា សាក្សី ញ៉ែម ចេន គ្រាន់តែប៉ាន់ស្មានអំពីខ្លឹមសារនៃរបាយការណ៍ទាំងនេះ ជារឿងមិនត្រឹមត្រូវ។ ទោះបីសាក្សី ញ៉ែម ចេន លើកឡើងថា ស្រោមសំបុត្របិទជិតក៏ដោយ ក៏អាចនិយាយថាគាត់ដឹងថា "របាយការណ៍អ្នកស្លាប់ហើយ" ដែរ ដោយសារ គាត់នៅក្បែរ អោ អាន នៅពេល អោ អាន និយាយថា "មនុស្សប៉ុន្មានត្រូវគេយកទៅរៀនសូត្ររួចហើយ មិនបានប៉ុន្មានទៀតទេ សម្រេចផែនការយើងហើយ"។

[954] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២៨ *យោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ២៧៩, ២៨៥ ជើងទំព័រ ៧៣៣, ៧៤២។

[955] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១២៩។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626076 ទំព័រ ២២ បន្ទាត់ ៩-១១។

01635035



ពិភាក្សាចំណុចនេះបន្ថែមនៅទីនេះទេ[956]។

### ៦(v)(គ) សិទ្ធិអំណាចលើបញ្ហាសន្តិសុខ និងមន្ទីរក្នុងតំបន់៤១

#### ១.សារណា

៥១០. សហមេធាវីជំទាស់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការផ្តល់សំអាងហេតុថា អោ អាន បានអនុវត្តសិទ្ធិអំណាចលើបញ្ហាសន្តិសុខ ក្នុងនោះ រួមមានតាមរយៈការគ្រប់គ្រងលើមន្ទីរសន្តិសុខក្នុងតំបន់៤១[957]។ ជាពិសេស សហមេធាវីអះអាងថា ពុំមានភស្តុតាងពិតប្រាកដ និងមានការបញ្ជាក់ដែលបង្ហាញថា អោ អាន (i) បានចុះពិនិត្យមើលមន្ទីរ (ii) ចេញបញ្ជាដល់ ប្រធានមន្ទីរសន្តិសុខ (iii) ទទួលរបាយការណ៍អំពីបញ្ហាសន្តិសុខ ឬ (iv) អនុញ្ញាតឱ្យដឹក ជញ្ជូនអ្នកទោសឡើយ[958]។

៥១១. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា ពុំមានលក្ខខណ្ឌតម្រូវក្នុងការបង្ហាញ ថាជនសង្ស័យមានវត្តមាននៅទីតាំងឧក្រិដ្ឋកម្ម ដើម្បីកំណត់ថា ជនសង្ស័យនោះមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅទីនោះឡើយ[959]។ តាមការពិនិត្យលើភស្តុតាងដ៏ច្រើន ការសន្និដ្ឋាន សមហេតុផលតែមួយគត់គឺថា អោ អាន បានគ្រប់គ្រងមន្ទីរសន្តិសុខតំបន់ ៤១ ជាការសន្និដ្ឋានមួយ ដែលត្រូវបានគាំទ្របន្ថែមដោយអង្គហេតុដែលថា គាត់បានទៅមើលមន្ទីរសន្តិសុខមួយចំនួន និងចេញបញ្ជា និងអនុវត្តសិទ្ធិអំណាច នៅពេលគាត់នៅទីនោះ[960]។

#### ២. ការពិភាក្សា

៥១២. ចៅក្រមអន្តរជាតិយល់ឃើញថា សហមេធាវីខកខានមិនបានបង្ហាញថា គ្មានសហចៅក្រមស៊ើបអង្កេតដ៏សមហេតុផលណាអាចផ្តល់សំអាងហេតុថា អោ អាន មានសិទ្ធិអំណាចលើបញ្ហាសន្តិសុខ ក្នុងនោះ

---

[956] *សូមមើលខាងលើ* មូលដ្ឋានទី ៦(ii)។

[957] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៣១។

[958] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៣១។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626077 ទំព័រ ២៣ បន្ទាត់ ៣-៨។

[959] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៦៩។

[960] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៦៩-៧០។ ប្រតិចារឹកថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/8.1 & D360/17.1, ERN 01626029 ទំព័រ ៤០ បន្ទាត់ ១៦-១៩។

រួមទាំង មន្ទីរសន្តិសុខនៅក្នុងតំបន់ ៤១ ឡើយ។ សំអាងហេតុនេះសមហេតុផល ដោយពិចារណាលើភស្តុតាងដែលបានបង្ហាញ និងដែលបានទទួលការគាំទ្រដោយភារកិច្ចរបស់ អោ អាន ក្នុងនាមជាលេខាតំបន់៤១ រួមទាំងចំណុចថា "មន្ទីរសន្តិសុខតំបន់ស្ថិតនៅក្រោមការត្រួតពិនិត្យផ្ទាល់របស់លេខាតំបន់"[961]។

៥១៣. ទីមួយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញដោយសមហេតុផលថា អោ អាន បានចុះពិនិត្យមើលមន្ទីរសន្តិសុខចំនួនបី គឺ មន្ទីរសន្តិសុខមិត្តសុប[962] មន្ទីរសន្តិសុខវត្តអូរត្រកួន[963] និងមន្ទីរសន្តិសុខវត្តតាមៈ[964]។ ចៅក្រមអន្តរជាតិយល់ឃើញថា វត្តមានរបស់ អោ អាន នៅមន្ទីរសន្តិសុខមិនមែនជា

---

[961] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ១៩៤ ជើងទំព័រ ៤១៦។

[962] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៣២ ជើងទំព័រ ៣០៩។ សហមេធាវីចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុស (i) ក្នុងការសន្និដ្ឋានថា រឿងរ៉ាវរបស់សាក្សី អ៊ឹម ប៉ុន (ដែលមិនធ្លាប់បើកឡានឲ្យ អោ អាន ទៅ មិត្ត សុប) មិនអាចទុកចិត្តបាន (ii) ដោយមិនពិចារណាដល់ភស្តុតាងផ្សេងទៀត (ផ្ទុយពីភស្តុតាងរបស់សាក្សី ញ៉ែម ចេន) និង (iii) ដោយសន្និដ្ឋានបែបប្រយោលថា ចម្លើយរបស់សាក្សី ជុំ វង្ស (ថា គាត់មិនបានឃើញ ឬស្គាល់ អោ អាន ទៅធ្វើទស្សនកិច្ចនៅ មិត្ត សុប) មិនអាចទុកចិត្តបាន។ ចៅក្រមអន្តរជាតិសង្កេតថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពន្យល់យ៉ាងត្រឹមត្រូវថា ភស្តុតាងរបស់សាក្សី អ៊ឹម ប៉ុន ពុំផ្ទុយពីភស្តុតាងរបស់សាក្សី ញ៉ែម ចេន ទេ ដោយសារពួកគាត់ធ្វើការជាមួយ អោ អាន ក្នុងអំឡុងពេលវេលាខុសគ្នា និងពីមូលហេតុដែលគាត់ពិចារណាឃើញថា ភស្តុតាងរបស់សាក្សី ជុំ វង្ស មិនអាចទុកចិត្តបានចំពោះចំណុចនេះ។ *សូមមើលផងដែរ* មូលដ្ឋានទី ៥(ii)(ឃ) និង (ង)។

[963] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៣២ ជើងទំព័រ ៣០៩។ សហមេធាវីចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសំអាងមិនគ្រប់គ្រាន់តែទៅលើសាក្សីពីរនាក់សម្រាប់ទីតាំងនេះទេ គឺ សាក្សី ញ៉ែម ចេន (ដែលមិនបានផ្តល់ព័ត៌មានលម្អិត) និង សាក្សី សេង ស្រ៊ុន (ដែលសាក្សីរបស់គាត់មិនពេញលេញដើម្បីសន្និដ្ឋានថា អោ អាន បានអនុវត្តសិទ្ធិអំណាចទៅលើមន្ទីរ) និងអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនយកចិត្តទុកដាក់ដល់ភស្តុតាងដោះបន្ទុក (ពីសាក្សី អ៊ឹម ប៉ុន, ជុង គឹមឃុន និង សាយ ឌឿន)។ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានកំហុសក្នុងការសំអាងទៅលើសាក្សី ញ៉ែម ចេន ឬសាក្សី សេង ស្រ៊ុន ដែលបានផ្តល់ព័ត៌មានលម្អិត និងអាចជឿជាក់បានពីវត្តមានរបស់ អោ អាន នៅឯកិច្ចប្រជុំមួយនៅវត្តអូរត្រកួន និងមិនបានពិចារណាថា សាក្សី អ៊ឹម ប៉ុន, ជុង គឹមឃុន និង សាយ ឌឿន ដែលគ្រាន់តែលើកឡើងថា ពួកគេមិនធ្លាប់បានឃើញ ឬជួប អោ អាន នៅទីតាំងនេះ ដែលជាភស្តុតាងផ្ទុយ ឬដោះបន្ទុកដែលចាំបាច់។

[964] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៣២ ជើងទំព័រ ៣០៩។ សហមេធាវីជំទាស់ទៅនឹងសេចក្តីសន្និដ្ឋានទាក់ទិននឹងទីតាំងនេះ ដោយសារសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសំអាងទៅលើសាក្សី ពេញ វ៉ា (ដែលភស្តុតាងរបស់គាត់ជាការប៉ាន់ស្មាន) សាក្សី ញ៉ែម ចេន (ដែលលើកឡើងថា អោ អាន មានវត្តមាននៅឯកិច្ចប្រជុំនៅវត្តតាមាក់ តែថា កិច្ចប្រជុំទាំងនេះទាក់ទិននឹងបញ្ហាសេដ្ឋកិច្ច) និង សាក្សី សូ សាវ៉េន (ដែលលើកឡើងថា អោ អាន មានវត្តមាន តែថា គាត់មិនបានស្តាប់ខ្លឹមសារនៃកិច្ចប្រជុំនោះទេ)។ ចៅក្រមអន្តរជាតិយល់ឃើញថា ភស្តុតាងដែលបានយកមកសំអាង គាំទ្រយ៉ាងច្បាស់ចំពោះការសន្និដ្ឋានថា អោ អាន មានវត្តមាននៅវត្តតាមាក់ជាច្រើនលើកច្រើនសា។

លក្ខខណ្ឌតម្រូវក្នុងការកំណត់អំពីសិទ្ធិអំណាច ឬការគ្រប់គ្រងរបស់ អោ អាន លើទីតាំងទាំងនេះទេ ប៉ុន្តែភស្តុតាងដែលថា អោ អាន បានចុះពិនិត្យមើលទីតាំងទាំងនេះអាចគាំទ្របន្ថែមថា អោ អាន ពិតជាមានសិទ្ធិអំណាចលើបញ្ហាសន្តិសុខ និងមន្ទីរសន្តិសុខក្នុងតំបន់៤១។

៥១៤. ទីពីរ ចៅក្រមអន្តរជាតិយល់ឃើញថា ពុំមានកំហុសឡើយចំពោះការពឹងផ្អែករបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើភស្តុតាងរបស់ ញ៉ែម ចេន ពាក់ព័ន្ធនឹងការបញ្ជាឱ្យសម្លាប់ និងដឹកជញ្ជូនអ្នកទោសពីមន្ទីរសន្តិសុខមួយទៅមន្ទីរសន្តិសុខមួយទៀត[965]។ ទឡ្ហីករណ៍របស់សហមេធាវីដែលថា ភស្តុតាងរបស់ ញ៉ែម ចេន ពុំមានការបញ្ជាក់[966] ឬមិនគួរឱ្យជឿជាក់[967] ពុំត្រឹមត្រូវទេ។

៥១៥. ទីបី ចៅក្រមអន្តរជាតិរម្លឹកសំអាងហេតុរបស់ខ្លួនពីពេលកន្លងទៅពាក់ព័ន្ធនឹងតួនាទីរបស់ អោ អាន នៅក្នុងតំបន់៤១ រួមទាំង សិទ្ធិអំណាចរបស់គាត់ក្នុងការចេញបញ្ជា និងរចនាសម្ព័ន្ធរាយការណ៍នៅក្នុងតំបន់៤១[968] និងយល់ឃើញថា ការតវ៉ានឹងសិទ្ធិអំណាចរបស់ អោ អាន លើ របាយការណ៍អំពីបញ្ហាសន្តិសុខ ឬការសម្លាប់[969]ដែលនៅសេសសល់ មិនមានលក្ខណៈសមស្របទេ។

---

[965] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៣៣-១៣៥ ជើងទំព័រ ៣១៤, ៣១៩, ៣២១។

[966] ចៅក្រមអន្តរជាតិរម្លឹកថា ពុំមានលក្ខខណ្ឌតម្រូវសម្រាប់ការបញ្ជាក់បន្ថែមទេ (*សូមមើល* មូលដ្ឋានទី ៥(iv)) ហើយថាចៅក្រមអន្តរជាតិបានសន្និដ្ឋានថា សាក្សី ញ៉ែម ចេន ជាសាក្សីដែលអាចជឿជាក់បានជាទូទៅ (*សូមមើល* មូលដ្ឋានទី ៥(ii)(ឃ)) ។ សាក្សី ញ៉ែម ចេន បានផ្តល់រឿងរ៉ាវលម្អិតអំពីការបញ្ជាឱ្យសម្លាប់ និងការដឹកជញ្ជូនអ្នកទោសទៅតាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សនានា ដោយគាត់បានឃើញដោយផ្ទាល់ខ្លួន។ *សូមមើលឧទាហរណ៍* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/855, ERN 01344690 (ឆ.៤៧-ឆ.៤៨) (លើកឡើងថា គាត់បានឃើញឡានដឹកមនុស្សទៅមន្ទីរសន្តិសុខ/ទីតាំងសម្លាប់មនុស្សរាល់ថ្ងៃ ដោយលើកឡើងបន្ថែមថា តាអួន (ដែលមិនធ្វើអ្វីដោយគ្មានការអនុញ្ញាតពី អោ អាន) សម្រាប់ពីកន្លែងដែលត្រូវបញ្ជូនអ្នកទោសទៅ)។

[967] ចៅក្រមអន្តរជាតិសង្កេតឃើញថា ការពិត ផ្នែកជាច្រើននៃរឿងរ៉ាវរបស់សាក្សី ញ៉ែម ចេន ត្រូវបានបញ្ជាក់បន្ថែម ឬបញ្ជាក់បន្ថែមមួយផ្នែកដោយសាក្សីនានាដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដកស្រង់ រួមមាន ពីសាក្សី ពេញ វ៉ា (ទាក់ទិននឹងអង្គហេតុដែលថា យានជំនិះនៅតំបន់ ៤១ ត្រូវបានយកទៅដឹកអ្នកទោស)។ *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ពេញ វ៉ា ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ឯកសារ D219/226, ERN 01075661 (ឆ.២១)។

[968] *សូមមើលខាងក្រោម* មូលដ្ឋានទី ៦(v)(ខ)(៤) និង ៦(v)(ខ)(៥)។

[969] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៣៤ ជើងទំព័រ ៣១៧-៣២០។

## ៦(v)(ឃ) សិទ្ធិអំណាចលើយោធាតំបន់៤១

### ១. សារណា

៥១៦. សហមេធាវីលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការលើកសំអាងហេតុថា អោ អាន មានសិទ្ធិអំណាចលើយោធាតំបន់៤១។ ជាពិសេស សំអាងហេតុពាក់ព័ន្ធរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនផ្អែកលើភស្តុតាងដែលពិតប្រាកដគ្រប់គ្រាន់ និងមានការបញ្ជាក់ឡើយ ដោយហេតុថា គាត់ពឹងផ្អែកភាគច្រើនលើសាក្សីចំនួន ៤ នាក់ (យូ វ៉ាន់, ជុំ វង្ស, សូ សារ៉េន និង ញ៉ែម ចេន) ដែល (i) មិនផ្តល់សេចក្តីលម្អិតអំពីតួនាទីរបស់ អោ អាន នៅក្នុងយោធាតំបន់៤១ (ii) មិននិយាយអំពី អោ អាន នៅក្នុងចម្លើយរបស់ពួកគេ (iii) ផ្តល់ភស្តុតាងដែលពុំមានការបញ្ជាក់ ឬដែលប្រឡូសប្រឡាក់[970]។ មិនតែប៉ុណ្ណោះ សហមេធាវីលើកឡើងបន្ថែមទៀតថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានផ្តល់ភស្តុតាងគ្រប់គ្រាន់ពីប្រព័ន្ធរាយការណ៍នៅក្នុងយោធាតំបន់[971] ថា អោ អាន បានប្រជុំជាមួយយោធាតំបន់[972] ថា អោ អាន បានបញ្ជាឲ្យមានការចាប់ខ្លួន និងឈ្មោះ ហម (ដែលជំនួសដោយ សុខ)[973] និងថា អោ អាន បានបញ្ជាយោធាតំបន់ ៤១ ក្នុងចំណោមអ្នកផ្សេងទៀត ឲ្យចាប់ក្រុមជាក់លាក់ និងឲ្យដឹកជញ្ជូនមនុស្ស[974] និងថា សុខ ដែលជាប្រធានយោធាតំបន់ គឺជាដៃស្តាំរបស់ អោ អាន[975]។

៥១៧. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិលើកទឡ្ហីករណ៍ថា សហមេធាវីខកខានមិនបានដោះបន្ទុកក្នុងការបង្ហាញថា គ្មានអ្នកវិនិច្ឆ័យអង្គហេតុដ៏សមហេតុផលណាអាចផ្តល់សំអាងហេតុថា អោ អាន មានសិទ្ធិអំណាចលើយោធាតំបន់ ៤១[976]។ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា ការតវ៉ារបស់ អោ អាន ទៅលើផ្នែកផ្សេងៗនៃភស្តុតាងនេះ ខកខានមិនបានលើកឡើងអំពី ការបញ្ជាក់ពីសំណាក់សាក្សីមួយចំនួន ដែលផ្តល់ភស្តុតាងលើសិទ្ធិអំណាចរបស់ អោ អាន ឡើយ[977]។

---

[970] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៣៦។

[971] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៣៧។

[972] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៣៧។

[973] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៣៨។

[974] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៣៩។

[975] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤០។

[976] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៧១។

[977] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៧១។

01635039



## ២. ការពិភាក្សា

៥១៨. ចៅក្រមអន្តរជាតិយល់ឃើញថា សហមេធាវីខកខានមិនបានបង្ហាញថា គ្មានសហចៅក្រមស៊ើបអង្កេតដ៏សមហេតុផលណាអាចផ្តល់សំអាងហេតុថា អោ អាន មានសិទ្ធិអំណាចលើយោធាតំបន់ឡើយ។ សំអាងហេតុនេះសមហេតុផល ដោយផ្អែកលើភស្តុតាងដែលបានបង្ហាញ បានទទួល ការគាំទ្រដោយសិទ្ធិអំណាចតាមផ្លូវច្បាប់របស់ អោ អាន ក្នុងនាមជាលេខាតំបន់៤១ និងថា "គណៈតំបន់ [...] ទទួលខុសត្រូវក្នុង ការគ្រប់គ្រង និងអនុវត្តភារកិច្ចដែលកងទ័ពបដិវត្តកម្ពុជា បានបំពេញ" និងថា "តំបន់នីមួយៗមានអង្គភាពយោធាមួយដែលរាយការណ៍ផ្ទាល់ទៅលេខា តំបន់"[978]។

៥១៩. ទីមួយ ការលើកឡើងរបស់សហមេធាវីដែលថា សាក្សីមិនបានផ្តល់សេចក្តីលម្អិតអំពីតួនាទីរបស់ អោ អាន នៅក្នុងយោធាតំបន់ មិនសុក្រឹត និងមិនពាក់ព័ន្ធឡើយ។ យ៉ាងហោចណាស់មានសាក្សីចំនួនពីរនាក់ គឺ យូ វ៉ាន់ និង ទូច ចំរើន បាននិយាយដោយផ្ទាល់ថា អោ អាន អនុវត្តសិទ្ធិអំណាចលើយោធាតំបន់[979]។ សាក្សីមួយចំនួនបញ្ជាក់ថា លេខាតំបន់ទទួលបន្ទុកយោធា[980]។ ទីពីរ ពាក់ព័ន្ធនឹងការខកខានមិនបានផ្តល់ភស្តុតាងគ្រប់គ្រាន់អំពីប្រព័ន្ធរាយការណ៍តាមរយៈយោធាតំបន់[981] ការប្រជុំរបស់អោ អាន ជាមួយយោធា

---

[978] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ១៩២។

[979] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ឯកសារ D219/138, ERN 01056061-01056062 (ឆ.៩៨) ("[...] បើសិនជា តាអាន បញ្ជាឲ្យយកមនុស្សទៅសម្លាប់ យោធាតំបន់ត្រូវបញ្ជូនបទបញ្ជានោះទៅឲ្យយោធាស្រុក ដើម្បីធ្វើការចាប់ខ្លួន")។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ទូច ចំរើន ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ D219/435, ERN 01124181 (ឆ.១៩៧) ("ខាងយោធាក៏មានមេបញ្ជាការ និងអ្នកក្តោបក្តាប់របស់គេដែរ ប៉ុន្តែអ្នកទាំងនោះនៅក្រោម តាអាន ដែរ")។

[980] *ផ្ទុយពី* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៣៦ជើងទំព័រ ៣២៥។ *សូមមើលឧទាហរណ៍* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ឯកសារ D118/259, ERN 00997038 (ឆ.១១២) ("យោធាតំបន់ហើយតំបន់រាយការណ៍ទៅភូមិភាគ")។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី រី ញ៉ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ D219/870, ERN 01348888 (ឆ.៤៩) ("ប្រធានតំបន់គឺក្តាប់តែតំបន់ បើតំបន់មានយោធាគេក្តាប់ទាំងយោធាទាំងអស់ [...] ដឹងតែ តាអាន ធំជាងគេ")។

[981] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៣៧ *យោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ២៥៨, ៤៣១។ រឿងរ៉ាវរបស់សាក្សី យូ វ៉ាន់ និងសាក្សី ជុំ វង្ស មានភាពស៊ីចង្វាក់ និងមានការបញ្ជាក់បន្ថែម ដោយលើកឡើងថា របាយការណ៍ធ្វើផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ។ *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ជុំ វង្ស (ង៉ូវ) ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៥ ឯកសារ D219/442, ERN 01125518-01125519 (ឆ.១១៨, ឆ.១២០) ("របាយការណ៍យោធានឹងបញ្ជូនដោយផ្ទាល់ទៅលេខាតំបន់ [...] ខ្ញុំដឹងថា ពួកគេអាចទាក់ទង

តំបន់[982] ការបញ្ជារបស់ អោ អាន ឲ្យចាប់ក្រុមជាក់លាក់ និងការពាក់ព័ន្ធរបស់ អោ អាន ក្នុងការដឹកជញ្ជូនមនុស្ស[983] ការតវ៉ារបស់សហមេធាវីទៅលើចំណុចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិពឹងផ្អែកលើសាក្សី ប្រាក់ យុត, យូ វ៉ាន់, ញ៉ែម ចេន និង ជុំ វង្ស ដោយពួកគាត់ត្រូវបានពិនិត្យទៅលើភាពជឿទុកចិត្តបានរបស់គាត់ ហើយមានការសម្រេចគាំទ្រពួកគាត់[984]។ ចៅក្រមអន្តរជាតិយល់ឃើញថា ការតវ៉ាដដែលៗទាំងនេះ មិនមានភាពត្រឹមត្រូវឡើយ។

៥២០. ទីបី ពាក់ព័ន្ធនឹងការចាប់ខ្លួនប្រធានយោធាតំបន់ឈ្មោះ ហម និងការជំនួសដោយ ឈ្មោះ សុខ សាក្សី

---

ជាមួយ តាអាន តាមរបាយការណ៍ជាលាយលក្ខណ៍អក្សរ ឬតាមរបាយការណ៍ផ្ទាល់មាត់នៅក្នុងកិច្ចប្រជុំ")។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ឯកសារ D219/138, ERN 01056063-01056064 (ឆ.១០៦-ឆ.១០៧) ("នី ជាអ្នករាយការណ៍ផ្ទាល់មាត់ ឬក៏តាមលិខិតទៅឲ្យគាត់វិញតាមរយៈយោធាតំបន់ [...] បញ្ជីទាំងអស់ត្រូវបានផ្ញើត្រឡប់មកយោធាស្រុកវិញតាមរយៈយោធាតំបន់")។ សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនចាប់អារម្មណ៍ទៅនឹងភស្តុតាងដែលបង្ហាញថា កម្មាភិបាលយោធាមិនបានរាយការណ៍តាមរយៈប្រព័ន្ធធម្មតានៅភូមិភាគកណ្តាល (*សូមមើល* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៣៧ ជើងទំព័រ ៣៣២)។ ទោះជាយ៉ាងណាក្តី សាក្សីដែលត្រូវបានចោទប្រកាន់គឺ អ៊ុំ សេង និង ឃុន គីម ផ្តល់សក្ខីកម្មអំពីរចនាសម្ព័ន្ធរាយការណ៍ដែលមិនពាក់ព័ន្ធត្រឹមតែតំបន់ ៤១។

[982] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៣៧ *យោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ២៥៨, ៥៨៩។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/855, ERN 01344695-01344696 (ឆ.៩៣, ឆ.១០៣) ("ស៖ [...] ប្រជុំយោធាហ្នឹង គាត់ប្រជុំនៅឯណា? ឆ.៩៣៖ គាត់ប្រជុំកន្លែងយោធាតំបន់ ប្រជុំវត្តតាមៈហ្នឹងដែរ ជាប់នឹងវត្តតាមៈហ្នឹង [...] ឆ.១០៣៖ [អោ អាន] ផែនការគេដាក់ទៅ មកវិញ គាត់ហៅប្រជុំយោធាចេញពីកំពង់ចាមមក បានទៅវត្តតាមៈ")។ សាក្សីមួយចំនួនលើកឡើងថា នៅពេលមានរៀបចំកិច្ចប្រជុំនៅថ្នាក់តំបន់ យោធាបានចូលរួម។ *សូមមើលឧទាហរណ៍* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី សូ សារ៉េន ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ D219/837, ERN 01335580 (ឆ.២៤-ឆ.២៩) ("[តាអាន] ច្រើនប្រជុំនៅកន្លែងមន្ទីរតំបន់ [...] ស៖ ពេលប្រជុំម្តងៗ តើភាគច្រើនតែជាគណៈណាខ្លះ? ឆ.២៧៖ ច្រើនខាងមេយោធា និង អូន ហ្នឹងម្តង")។

[983] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៣៩ *យោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៣០៣ ជើងទំព័រ ៨១១។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ឯកសារ D219/732, ERN 01218086 (ឆ.៣៥) ("ខ្ញុំនៅផ្ទាល់ដែរ ពេលតាអាន បញ្ជាយោធា")។ សាក្សី យូ វ៉ាន់ ផ្តល់ភស្តុតាងថា កងទ័ពថ្នាក់ស្រុកចូលរួមក្នុងការចាប់ខ្លួន កងទ័ពថ្នាក់ស្រុកបានទាក់ទងជាមួយកងទ័ពថ្នាក់តំបន់។ *សូមមើលឧទាហរណ៍* ប្រតិចារឹកថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ ក្នុងសំណុំរឿង ០០២ (យូ វ៉ាន់) ឯកសារ D219/702.1.94, ERN 01253379 ទំព័រ ៣២ បន្ទាត់ ៦-១២។

[984] *សូមមើលខាងលើ* មូលដ្ឋានទី ៥(ii)(ក), (ខ), (ឃ), (ង)។

01635041



យូ វ៉ាន់, ញ៉ែម ចេន និង សូ សារ៉េន បានរៀបរាប់ភស្តុតាងលម្អិតដែលមានការបញ្ជាក់ទៅវិញទៅមក ដោយបញ្ជាក់ថា អោ អាន បានបញ្ជាឱ្យចាប់ ហាម[985]។ ពាក់ព័ន្ធនឹងការតែងតាំង ឈ្មោះ សុខ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកយ៉ាងត្រឹមត្រូវលើភស្តុតាងរបស់ ញ៉ែម ចេន[986]។ ចំណុចចុងក្រោយ ចៅក្រមអន្តរជាតិនឹងមិនលើកមកដោះស្រាយការតវ៉ាទាំងឡាយផ្សេងៗទៀតរបស់សហមេធាវីឡើយ ពាក់ព័ន្ធនឹងបញ្ហារបស់ អោ អាន នៅវត្តភ្នំប្រុស (ទីតាំងសម្លាប់ថ្នាក់ភូមិភាគ[987]) និងថា តើ សុខ ប្រធានយោធាតំបន់ជា "ដៃស្តាំ" របស់ អោ អាន មែន ឬយ៉ាងណានោះ[988] ដោយហេតុថា ការតវ៉ាទាំងនេះមិនអាចមានឥទ្ធិពលលើសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា អោ អាន មានសិទ្ធិអំណាចលើយោធាតំបន់៤១ ឡើយ។

### ៦(v)(ង) សិទ្ធិអំណាចលើភស្តុភារ និងចលនាប្រជាជនក្នុងតំបន់៤១

### ១. សារណា

៥២១. សហមេធាវីលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការផ្តល់សំអាង ហេតុថា អោ អាន មានសិទ្ធិអំណាចលើធនធានភស្តុភារ និងដឹកជញ្ជូន ឬចលនាប្រជាជន ក្នុងតំបន់៤១[989]។ ជា

[985] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/855, ERN 01344717 (ឆ.២៧៦) ("សៈ លោកដឹងថាអ្នកណាបញ្ជាឱ្យចាប់ ហ៊ុម? ឆ.២៧៦៖ អ៊ំអាន ព្រោះគាត់ប៉ះពាល់សីលធម៌")។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ឯកសារ D219/138, ERN 01056065 (ឆ.១១១) (" តាអាន បានយក ហ៊ុម ទៅដាក់គុក និងសម្លាប់ចោល ដោយសារខុសសីលធម៌ជាមួយនឹងពេទ្យនារីម្នាក់")។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី សូ សារ៉េន ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦ ឯកសារ D219/800, ERN 01308052-01308053 (ឆ.១៧៣-ឆ.១៧៥) ("តែក្រោយមក តំបន់ចាប់ [ហ៊ុម] ដាក់គុកហើយ [...] ដោយសារគាត់ខុសសីលធម៌ជាមួយប្អូនថ្លៃស្រីរបស់ តាអាន")។

[986] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ២៥៨។ *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/855, ERN 01344714 (ឆ.២៥០) ("សៈ តើនរណាជាអ្នកតែងតាំង សុក ឱ្យក្លាយជាមេបញ្ជាការកងទ័ពតំបន់? ឆ.២៥០៖ អ៊ំអាន ព្រោះគាត់នៅជាមួយអ៊ំអាន ពីដើម")។ ចៅក្រមអន្តរជាតិពិចារណាឃើញថា ទីតាំង ឬកាលបរិច្ឆេទជាក់លាក់នៃការតែងតាំង មិនមែនជាការកត្តាសម្រេចសម្រាប់ការធ្វើសេចក្តីសន្និដ្ឋាននេះឡើយ។

[987] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៣៩ ជើងទំព័រ ៣៤៧។

[988] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤០។ ចំណុចនេះគ្រាន់តែជាការពិពណ៌នារបស់សាក្សីម្នាក់តែប៉ុណ្ណោះ។ *សូមមើល* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៥៦២។

[989] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤១។

01635042



ពិសេស សហមេធាវីជំទាស់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានផ្តល់ភស្តុតាងច្បាស់លាស់គ្រប់គ្រាន់ និងមានការគាំទ្រ ដែលថា អោ អាន (i) គ្រប់គ្រងចលនាបុគ្គលិក និងគ្រឿងផ្គត់ផ្គង់[990] (ii) សម្របសម្រួលរចនាសម្ព័ន្ធភស្តុភារ និងអនុញ្ញាតដល់យានយន្ត ក្នុងការដឹកជញ្ជូនអ្នកទោសពីមន្ទីរសន្តិសុខមួយទៅមន្ទីរសន្តិសុខ មួយទៀត[991] (iii) ត្រួតពិនិត្យមើលលើការដឹកជញ្ជូនប្រជាជនចាមពីភូមិភាគបូព៌ាទៅ ភូមិភាគកណ្តាល[992] និង (iv) មានសិទ្ធិអំណាចក្នុងការចេញលិខិតអនុញ្ញាតធ្វើដំណើរ[993]។

៥២២. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ភស្តុតាងពាក់ព័ន្ធនឹងសិទ្ធិអំណាចរបស់ អោ អាន លើការដឹកជញ្ជូន និងធនធានភស្តុភារ និងសិទ្ធិអំណាចរបស់គាត់ក្នុងការអនុញ្ញាតលើការធ្វើដំណើរក្នុងតំបន់ បានមកពីសាក្សីមួយចំនួន និងជាប់ទាក់ទងទៅនឹងផ្នែកនៃភស្តុតាងបញ្ជាក់ជាច្រើនលើតួនាទីរបស់ អោ អាន។ សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា ការតវ៉ារបស់សហមេធាវី ពាក់ព័ន្ធនឹងភាពគួរឱ្យជឿជាក់របស់សាក្សី មិនអាចទទួលយកបានទេ[994]។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងទៀតថា សហមេធាវីមិនបានបង្ហាញថា សំអាងហេតុទាំងនេះគឺជាកត្តាកំណត់លើការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិថា អោ អាន ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ឬថា អោ អាន ស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឡើយ[995]។

## ២. ការពិភាក្សា

៥២៣. ទីមួយ ពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិក និងគ្រឿងផ្គត់ផ្គង់ទូទាំងតំបន់៤១[996] ការតវ៉ារបស់សហមេធាវីទៅលើភាពគួរឱ្យជឿជាក់របស់ ប្រាក់ យុត និង យូ វ៉ាន់[997] ក្នុងចំណោមបញ្ហាផ្សេងទៀត មិន

---

[990] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤១។

[991] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤២។

[992] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤៣។

[993] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤៤។

[994] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៧២។

[995] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៧២។

[996] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤១ និងជើងទំព័រ ៣៥២, ៣៥៦ *យោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ២៥៦, ២៧២ ជើងទំព័រ ៦៣៦, ៧០៥។

[997] *ឧទាហរណ៍* សហមេធាវីចោទប្រកាន់ថា មានភាពមិនស៊ីសង្វាក់គ្នានៅក្នុងចម្លើយរបស់សាក្សី ប្រាក់ យុត ទាក់ទិននឹងការសង់ទំនប់នៅព្រៃឈរ។ *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤១ ជើងទំព័រ ៣៥៣។ ប្រតិចារឹកថ្ងៃទី២៥ ខែមករា ឆ្នាំ២០១២ ក្នុងសំណុំរឿង ០០២ (ប្រាក់ យុត) ឯកសារ D179/1.2.4, ERN 00773512-00773513

អាចយកជាការបានឡើយ។ ភស្តុតាងទាំងនេះគួរឱ្យជឿជាក់បានលើចំណុចនេះ[998]។ លើសពីនេះទៀត ការពិនិត្យផិតដល់លើភស្តុតាងផ្ទុយដែលបានអះអាងនោះ[999] បង្ហាញថា ភស្តុតាងនេះតាមពិតមិនផ្ទុយទៅនឹងសំអាងហេតុពាក់ព័ន្ធនឹងសិទ្ធិអំណាចរបស់ អោ អាន លើ ការគ្រប់គ្រងធនធានឡើយ ដោយហេតុថា ភស្តុតាងនេះមិនបង្ហាញអំពីតួនាទីរបស់ អោ អាន ក្នុងនាមជាអ្នកត្រួតពិនិត្យ ឬអំពី អោ អាន តែម្តង។

៥២៤. ទីពីរ សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា អោ អាន បានសម្របសម្រួលរចនាសម្ព័ន្ធភស្តុភារដើម្បីដឹកជញ្ជូនអ្នកទោសពីមន្ទីរសន្តិសុខមួយទៅមន្ទីរសន្តិសុខមួយទៀត ត្រូវបានលើកមកដោះស្រាយពីមុនរួចហើយ[1000]។ ផ្អែកលើចំណុចនេះ ចៅក្រមអន្តរជាតិយល់ឃើញថាជាការមិនសំខាន់ទេថាតើយានយន្តទាំងនោះដែលត្រូវបានប្រើប្រាស់ក្នុងការដឹកជញ្ជូនអ្នកទោស និងយានយន្តដែល អោ អាន ប្រើប្រាស់ ជាយានយន្តតែមួយ[1001] ហេតុដូច្នេះ ចៅក្រមអន្តរជាតិមិនលើកមកដោះស្រាយបញ្ហានេះទេ។ ទីបី ផ្ទុយទៅនឹងការលើកឡើងរបស់សហមេធាវី[1002] សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនមានកំហុសឡើយក្នុងការផ្តល់សំអាងហេតុថា អោ អាន សម្របសម្រួល និងត្រួតពិនិត្យលើប្រតិបត្តិការដឹកជញ្ជូន

---

ទំព័រ ៧៧ បន្ទាត់ ២២ ទំព័រ ៧៨ បន្ទាត់ ១៥ ("តំបន់គាត់ធ្វើទំនប់មួយ តែនៅស្រុកព្រៃឈរហ្នឹង [...] តំបន់គាត់ដឹកទំនប់។ ខ្ញុំជួយគាត់ដោយបញ្ជូនកម្លាំងខ្លះ")។ នៅក្នុងការស្តាប់ចម្លើយមួយនាពេលបន្ទាប់ ប្រាក់ យុត គ្រាន់តែលើកឡើងថា គាត់មិនចាំរឿងនេះទេ។ *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ D219/120, ERN 01046843 (ឆ.៨៩) ("សៈ តើលោកស្រីចាំពីការលើកទំនប់តំបន់ ៤១ នៅក្នុងស្រុកព្រៃឈរ ដែរឬទេ? ឆ.៨៩៖ ខ្ញុំមិនចាំទេ")។ ទាក់ទិននឹងភស្តុតាងដែលមានការបញ្ជាក់បន្ថែមរបស់សាក្សី យូ វ៉ាន់ ដែលផ្តល់ចម្លើយលម្អិត (*សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ឯកសារ D219/138, ERN 01056054 (ឆ.៧០) ("ប្រាក់ យុត ឱ្យខ្ញុំរើសមនុស្សពីតាមភូមិ ហើយបញ្ជូនទៅលើកដី ធ្វើទំនប់នៅស្រុកព្រៃឈរ។ សំណើសុំកម្លាំងទៅលើទំនប់នេះគឺ ចេញពីថ្នាក់តំបន់")) និងអង្គហេតុដែលថា អោ អាន លើកឡើងថា គាត់បានចូលរួមក្នុងការសាងសង់ទំនប់ជាច្រើន (រួមទាំងទំនប់នៅព្រៃឈរ) និង បានបញ្ជូនកងកម្លាំងពីតំបន់ ៤១ ទៅធ្វើការនៅតាមទំនប់ (*សូមមើល* កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អោ អាន ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១ ឯកសារ D219/847.1, ERN 01337383-01337385) ការជំទាស់របស់សហមេធាវីមិនត្រឹមត្រូវទេ។

[998] *សូមមើលខាងលើ* មូលដ្ឋានទី ៥(v) និងមូលដ្ឋានទី ៥(ii)(ក) និង (ខ)។

[999] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤១ ជើងទំព័រ ៣៥៦ *យោងទៅ* ចម្លើយរបស់សាក្សី ទូច ចំរើន, សាត ភាព, គឹម គឿន, ខេង ថៃ, យូ វ៉ាន់ និង ពេញ វ៉ា។

[1000] *សូមមើលខាងលើ* មូលដ្ឋានទី ៦(v)(គ)។

[1001] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤២។

[1002] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤៣ ជើងទំព័រ ៣៦៦-៣៦៨ *យោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៣០៩ ជើងទំព័រ ៨២៨។

មនុស្សពីភូមិភាគបូព៌ា ទៅភូមិភាគកណ្ដាល រួមទាំងតំបន់ ៤១ និងឆ្ពោះទៅមន្ទីរសន្តិសុខ។ ចៅក្រមអន្តរជាតិសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេត អន្តរជាតិពឹងផ្អែកដោយសមហេតុផលលើការរៀបរាប់ដំណើររឿងរបស់ ញ៉ែម ចេន ដែលត្រូវបានចាត់ទុកថា គួរឱ្យជឿជាក់ ក្នុងចំណោមអ្នកផ្សេងទៀត[1003]។

៥២៥. ទីបួន សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា អោ អាន បានត្រួតពិនិត្យលើការចេញលិខិតធ្វើដំណើរនៅក្នុងតំបន់ ៤១ និងរវាងតំបន់ដទៃទៀត នោះ[1004] មានភាពសមហេតុ ផល។ ចៅក្រមអន្តរជាតិយល់ឃើញថា ពុំមានកំហុសទេដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិពឹង ផ្អែកលើភស្តុតាងរបស់ ជុំ វង្ស ពាក់ព័ន្ធនឹង សិទ្ធិអំណាចរបស់ អោ អានលើការធ្វើដំណើរ[1005]។ លើសពីនេះទៀត ផ្ទុយនឹងការលើកឡើងរបស់សហមេធាវី[1006] ពេញ វ៉ា ដែលជាអ្នកដាក់ពាក្យ សុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី[1007] គាំទ្រសំអាងហេតុនេះ ដោយផ្ដល់ចម្លើយថា ឈ្មោះ ស្រេង ដែលជាសមាជិកគណៈតំបន់ បានចេញលិខិតធ្វើដំណើរឱ្យគាត់[1008]។

## ៦(v)(ច) ឥទ្ធិពលលើយុត្តាធិការបុគ្គល

### ១.សារណា និងការពិភាក្សា

៥២៦. សហមេធាវីលើកឡើងថា បើទោះបីជា អោ អាន ជាលេខាតំបន់៤១ ក៏ដោយ ក៏គាត់មិនត្រូវបាន

---

[1003] *សូមមើលខាងលើ* មូលដ្ឋានទី ៥(ii)(ឃ)។ សាក្សី ញ៉ែម ចេន ផ្ដល់ភស្តុតាងយ៉ាងលម្អិតស្ដីពីការផ្ទេរកម្មាភិបាលពីភូមិភាគបូព៌ា និងការចូលរួមរបស់ អោ អាន ក្នុងការផ្ទេរកម្មាភិបាលទាំងនោះ។ *សូមមើល* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៣០៩ ជើងទំព័រ ៨២៨។

[1004] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤៤ ជើងទំព័រ ៣៦៩-៣៧០ *យោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ២៥៦, ២៧២ ជើងទំព័រ ៦៣៧, ៧០៥។

[1005] *សូមមើល* មូលដ្ឋានទី ៥(ii)(ង)។ *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយសាក្សី ជុំ វង្ស (ង៉ូវ) ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៥ ឯកសារ D219/442, ERN 01125520-01125521 (ឆ.១៣៣-ឆ.១៣៦) (លើកឡើងថា លិខិតធ្វើដំណើរត្រូវបានចុះហត្ថលេខាដោយលេខាតំបន់ ហើយថា ការធ្វើដំណើរជាផ្លូវការ លេខាតំបន់ត្រូវតែដឹង កម្មាភិបាលជាន់ខ្ពស់ត្រូវតែជូនដំណឹងទៅ អោ អាន)។

[1006] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤៤ ជើងទំព័រ ៣៧១។

[1007] *សូមមើលខាងលើ* មូលដ្ឋានទី ៥(ii)(ច)។

[1008] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយសាក្សី ពេញ វ៉ា ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ឯកសារ D219/226, ERN 0107558-01075659 (ឆ.១៤) ("មិត្ត ស្រេង ដែលជាគណៈតំបន់បានធ្វើលិខិតឧទ្ទេសនាមឱ្យខ្ញុំមួយសម្រាប់ឱ្យខ្ញុំធ្វើដំណើរទៅមក")។

ចាត់ទុកជាបុគ្គលស្ថិតក្នុងចំណោមជនដែលទទួលខុសត្រូវខ្ពស់បំផុតដែរ ពីព្រោះថា តំបន់ ៤១ មាន វិសាលភាពភូមិសាស្ត្រតូច អ្នកនៅក្រោមឱវាទផ្ទាល់របស់ អោ អាន មានចំនួនតិច ហើយអំណាចធ្វើការសម្រេចរបស់ អោ អាន មានកម្រិត ពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយរបស់ ប.ក.ក[1009]។ នៅក្នុងចម្លើយតបសហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា សហមេធាវីមិនអើពើដល់កត្តាសំខាន់បំផុតក្នុងការកំណត់ថាតើបុគ្គលម្នាក់ស្ថិតនៅក្នុងចំណោម “ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត” ដែរឬយ៉ាងណា ដែលជាស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម និងវិសាលភាពនៃតួនាទីរបស់ អោ អាន ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម[1010] ។

៥២៧. ចៅក្រមអន្តរជាតិកត់សម្គាល់ថា ទឡ្ហីករណ៍របស់សហមេធាវីពាក់ព័ន្ធនឹង “តំបន់ភូមិសាស្ត្រតូច” នៃតំបន់ ៤១ ត្រូវបានលើកមកដោះស្រាយ និងបដិសេធចោលនៅក្នុងមូលដ្ឋានទី៧ (i)[1011]។ តួនាទី របស់ អោ អាន ក្នុងការអនុវត្តគោលនយោបាយរបស់ ប.ក.ក ត្រូវបានលើកមកដោះស្រាយនៅក្នុងមូលដ្ឋានទី ៦ (ii)[1012]។ ចៅក្រមអន្តរជាតិបញ្ជាក់ថា ការកំណត់អត្តសញ្ញាណបុគ្គលដែលស្ថិតក្នុងប្រភេទជនដែលទទួលខុសត្រូវខ្ពស់បំផុត ពាក់ព័ន្ធនឹងការវាយតម្លៃតាមបែបគុណវិស័យ និងបរិមាណវិស័យនៃ (i) ស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និង (ii) កម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ[1013]។ ទោះជាកត្តានានាតាមការលើកឡើងរបស់សហមេធាវីអាចត្រូវបានចាត់ទុកថាជាកត្តាមួយក្នុងចំណោមកត្តាជាច្រើននៅក្នុងការវាយតម្លៃរួម ចៅក្រមអន្តរជាតិមិនយល់ឃើញថា កត្តាទាំងនោះជាកត្តាកំណត់នៅទីនេះទេ។

៥២៨. ហេតុដូច្នេះ មូលដ្ឋានទី ៦ (៥) ត្រូវបានបដិសេធចោល។

---

[1009] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤៥។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1, ERN ERN 01626077 ទំព័រ ២៣ បន្ទាត់ ៩-១៤។

[1010] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៧៨។

[1011] *សូមមើលខាងក្រោម* មូលដ្ឋានទី ៧(i)។

[1012] *សូមមើលខាងលើ* មូលដ្ឋានទី ៦(ii)។

[1013] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) មតិយោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣២១។ *សូមមើលផងដែរ* កថាខណ្ឌ ៣២៧-៣៣៨។

## មូលដ្ឋានទី៦(vi). តួនាទីរបស់អោ អាន ក្នុងអំពើប្រល័យពូជសាសន៍ជនជាតិចាម

### ១. សារណា

៥២៩. សហមេធាវីការពារក្តីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំបានបង្ហាញភស្តុតាងរឹងមាំ និងមានការគាំទ្រឱ្យគ្រប់គ្រាន់ ដែលថា អោ អាន មានតួនាទីនៅក្នុងអំពើប្រល័យពូជសាសន៍ជនជាតិចាម[1014]។ សហមេធាវីអះអាងថា អោ អាន មិនបានចូលរួមចំណែកជាសំខាន់ចំពោះគោលនយោបាយរបស់ ប.ក.ក ដែលត្រូវបានចោទប្រកាន់ថាកំណត់គោលដៅទៅលើជនជាតិចាម ឬមានចេតនាជាក់លាក់ក្នុងការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍ ឬរៀបចំផែនការ បញ្ជា ឬញុះញង់ឱ្យមានអំពើប្រល័យពូជសាសន៍[1015]។ ជាពិសេស សហមេធាវីជំទាស់ថា ដោយពឹងផ្អែកស្ទើរតែទាំងស្រុងទៅលើការលើកឡើងរបស់ ប្រាក់ យុត និង យូ វ៉ាន់ ដែលគ្មានការបញ្ជាក់ និងមិនអាចជឿជាក់បាន ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសន្និដ្ឋានថា អោ អាន បានបញ្ជាដល់អ្នកក្រោមបង្គាប់ ដូចជា លេខាស្រុក ឱ្យធ្វើការកំណត់អត្តសញ្ញាណ រៀបចំបញ្ជី ធ្វើការចាប់ខ្លួន និងសម្លាប់ជនជាតិចាម ហើយថា អោ អាន ត្រួតពិនិត្យ និងគ្រប់គ្រងលើការអនុវត្តបញ្ជា ទាំងអស់នេះតាមរយៈរបាយការណ៍ និងថា គាត់បានចូលរួមក្នុងការជម្លៀសជនជាតិចាមចេញពីភូមិភាគបូព៌ាទៅភូមិភាគកណ្តាល[1016]។

៥៣០. ក្នុងចម្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សហមេធាវីមិនបានបង្ហាញថា គ្មានអ្នកវិនិច្ឆ័យអង្គហេតុដែលមានហេតុផល អាចធ្វើការសន្និដ្ឋានទាំងនេះឡើយ។ សហព្រះរាជអាជ្ញាអន្តរជាតិចោទប្រកាន់ថា ទឡ្ហីករណ៍របស់សហមេធាវីផ្អែកលើការវាយប្រហារដែលមិនសមរម្យរបស់ អោ អាន ទៅលើភាពអាចជឿជាក់បានរបស់ ប្រាក់ យុត និង យូ វ៉ាន់[1017]។ លើសពីនេះ សហមេធាវីបានលើកឡើងដោយមិនត្រឹមត្រូវពីចំណុចសំខាន់នៃភស្តុតាងរបស់ ប្រាក់ យុត នៅ ពេលចោទប្រកាន់ថា ប្រាក់ យុត "បានផ្តល់ព័ត៌មានតែអំពីស្រុកកំពង់សៀម" នៅពេលដែលភស្តុតាងរបស់គាត់មានភាពស្រពិចស្រពិលលើចំណុច

[1014] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤៦។ ប្រតិចារឹកក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ (CS) ឯកសារ D359/9.1 និងឯកសារ D360/18.1 ERN 01626077 ទំព័រ ២៣:១៧-២៣:២០។

[1015] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤៦។ ប្រតិចារឹកក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ (CS) ឯកសារ D359/9.1 និងឯកសារ D360/18.1 ERN 01626077 ទំព័រ ២៣:២០-២៣:២៣។

[1016] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤៦។ ប្រតិចារឹកក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ (CS) ឯកសារ D359/9.1 និងឯកសារ D360/18.1 ERN 01626077 ទំព័រ ២៣:២៣-២៤:៣។

[1017] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៧៣, ៧៦។

នេះ និងត្រូវបានបញ្ជាក់គាំទ្រដោយអង្គហេតុដែលថា ការសម្លាប់រង្គាលជនជាតិចាមបានកើតឡើងនៅក្នុងស្រុកផ្សេងៗទៀត ជាពិសេសស្រុកកងមាស[1018]។ ចុងបញ្ចប់ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ទឡ្ហីករណ៍របស់សហមេធាវី ពាក់ព័ន្ធនឹងការដឹកជញ្ជូនជនជាតិចាមពីភូមិភាគបូព៌ាទៅកាន់ភូមិភាគកណ្តាល ផ្អែកលើការចោទប្រកាន់ពីកំហុសពាក់ព័ន្ធនឹងតំណែងរបស់ អោ អាន ក្នុងនាមជាលេខាតំបន់ ៤១ ដែលសហមេធាវីមិនបានផ្តល់ការបញ្ជាក់[1019]។

## ២. ការពិភាក្សា

៥៣១. ជាដំបូង ចៅក្រមអន្តរជាតិយល់ឃើញថា សហមេធាវីមិនបានបង្ហាញថា គ្មានចៅក្រមស៊ើបអង្កេតដែលមានហេតុផលណាម្នាក់យល់ថា អោ អាន បានបញ្ជាឱ្យលេខាស្រុក កំណត់អត្តសញ្ញាណ ធ្វើការចាប់ខ្លួន និងសម្លាប់ប្រជាជនចាម[1020] ឬយល់ថា អោ អាន ត្រួតពិនិត្យការអនុវត្តការសម្លាប់ទាំងអស់នេះតាមរយៈរបាយការណ៍ និងបញ្ជី[1021]។ ការដេញដោលរបស់សហមេធាវីចំពោះភាពអាចជឿជាក់បានរបស់ ប្រាក់ យុត មិនត្រឹមត្រូវឡើយ[1022]។ ទោះបីជា ពីដំបូង ប្រាក់ យុត បានបដិសេធថា មិនបានទទួលបញ្ជាចាប់ខ្លួនពី អោ អាន[1023] ប៉ុន្តែក្រោយមក គាត់បានរៀបរាប់លម្អិតថា អោ អាន បានបញ្ជាឱ្យគាត់ និងលេខាស្រុកផ្សេងទៀត កំណត់អត្តសញ្ញាណ ធ្វើការចាប់ខ្លួន និងសម្លាប់ជនជាតិចាម[1024]។ ចៅក្រមអន្តរជាតិយល់ឃើញថា ការលើកឡើងមិនស៊ីសង្វាក់គ្នាទាំងនេះអាចបណ្តាលមកពីភាពភ័យខ្លាចរបស់ ប្រាក់ យុត ក្នុងការលាត

---

[1018] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៧៤-៧៥។

[1019] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៧៦។

[1020] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤៧ *ដែលយោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៣០២-៣០៣, ៦៣៣-៦៣៧។

[1021] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤៨ *ដែលយោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៣០៣, ៦៣៣, ៦៣៥។

[1022] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤៦-១៤៨។ ចៅក្រមអន្តរជាតិធ្លាប់បានលើកឡើងពីភាពមិនស៊ីសង្វាក់គ្នាដែលរងការចោទប្រកាន់ក្នុងភស្តុតាងរបស់ ប្រាក់ យុត ពាក់ព័ន្ធនឹងអត្ថិភាពនៃប្រព័ន្ធរាយការណ៍។ *សូមមើល មូលដ្ឋានទី ៦ (v) (ខ) (4) ខាងលើ*។

[1023] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ ឯកសារ D117/70 នៅត្រង់ ERN 01046796 (ឆ. ៣៧) ("ទេ ខ្ញុំមិនដែលបានទទួលបញ្ជាពីតាអានឱ្យចាប់ខ្លួនអ្នកណាទេ")។

[1024] *សូមមើល ឧទាហរណ៍* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ ឯកសារ D117/70 នៅត្រង់ ERN 01046797 (ឆ.៤៤) ("ខ្ញុំទទួលបញ្ជាពីតាអានឱ្យប្រមូលជនជាតិចាម")។

01635048



ត្រដងពីការពាក់ព័ន្ធរបស់គាត់ក្នុងឧក្រិដ្ឋកម្មទាំងនេះ[1025] និងយល់ថា ការលើកឡើងរបស់ ប្រាក់ យុត នៅពេលក្រោយមកទៀតស៊ីសង្វាក់គ្នា និងលម្អិត។ ដូច្នេះ មិនមែនថាជាការសមហេតុផលដែលសហចៅក្រមស៊ើបអង្កេត អន្តរជាតិពឹងផ្អែកលើភស្តុតាងរបស់ ប្រាក់ យុត នោះ[1026]។

៩៣២. ពាក់ព័ន្ធនឹងការមិនស៊ីសង្វាក់គ្នាបន្ថែមទៀតដែលត្រូវបានចោទប្រកាន់[1027] ចៅក្រមអន្តរជាតិយល់ថា ការខកខានពីដំបូងរបស់ ប្រាក់ យុត ក្នុងការលើកឡើងពី អោ អាន មិនមែនជាការមិនស៊ីសង្វាក់ឡើយ។ តាមពិត ប្រាក់ យុត បានលើកឡើងពីគណៈតំបន់ ៤១ ដែលរួមបញ្ចូលទាំង អោ អាន[1028]។ ទីពីរ ចៅក្រមអន្តរជាតិយល់ថា ប្រាក់ យុត លើកឡើងថា គាត់មិនដឹងថាតើ អោ អាន បាន ទទួលបញ្ជាពីថ្នាក់លើនោះទេ និងយល់ថា ចំណុចនេះមិនស៊ីសង្វាក់គ្នានឹងការរៀបរាប់ពីព្រឹត្តិការណ៍ដំណើររឿងរបស់ ប្រាក់ យុត ដែលថា គាត់ និងលេខាស្រុកផ្សេងទៀត បានទទួលបញ្ជាដោយផ្ទាល់ពី អោ អាន[1029]។ ក្រៅពីនេះ ការយល់ព្រមរប

---

[1025] *សូមមើល មូលដ្ឋានទី ៥ (ii) (ក) ខាងលើ*។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ ឯកសារ D117/70 នៅត្រង់ ERN 01046797 (ឆ.៤៣) ("លោកបានលើកឡើងវិញនូវរឿងរ៉ាវដែលបានកើតឡើង ធ្វើឱ្យខ្ញុំទទួលស្គាល់ និងសូមសារភាព ទោះជាខ្ញុំស្ថិតនៅក្នុងស្ថានភាពលំបាក ដោយសារតាអាននៅរស់រានមានជីវិតនៅឡើយក៏ដោយ។ ខ្ញុំសូមសារភាពថា មានការកាប់សម្លាប់នៅក្នុងស្រុកកំពង់សៀម ដោយខ្ញុំទទួលបញ្ជាពីតាអាន")។

[1026] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ ឯកសារ D117/70 នៅត្រង់ ERN 01046797 (ឆ.៤៤) ("ខ្ញុំទទួលបញ្ជាពីតាអានឲ្យប្រមូលជនជាតិចាម")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ D117/71 នៅត្រង់ ERN 01046808 (ឆ.៤៨) ("ក្នុងពេលប្រជុំប្រចាំខែ តាអានបានបញ្ជាឱ្យខ្ញុំកំណត់អត្តសញ្ញាណប្រជាជនចាម")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ D117/72 នៅត្រង់ ERN 01046814 (ឆ.៦) ("តាអានមិនមានប្រាប់ហេតុផលអីទេ។ គាត់គ្រាន់តែប្រាប់ខ្ញុំថា ឲ្យផ្តោតគោលដៅលើជនជាតិចាម")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី៣០ ខែ កញ្ញា ឆ្នាំ២០១៤ ឯកសារ D219/120 ERN 01046831 (ឆ.១៤) ("យើងប្រជុំនៅតំបន់ ថ្នាក់តំបន់ចេញបញ្ជាឲ្យកម្ទេចជនជាតិចាម"), ERN 01046832-01046833 (ឆ.១៩-ឆ.២៣) ("តាអានចេញបញ្ជាឲ្យខ្ញុំកំណត់អត្តសញ្ញាណអ្នកដែលប្រឆាំងនឹងបដិវត្តន៍ [...] ហើយឲ្យចាប់អ្នកទាំងអស់នោះយកទៅកម្ទេចចោល [...] ពេលចេញបញ្ជា គឺនៅពេលតែមួយឲ្យកម្ទេច ក៏ប៉ុន្តែយើងអនុវត្តបញ្ជាសម្លាប់ជនជាតិចាមអស់នោះ នៅពេលក្រោយដែលចាប់បានសមាសភាពផ្សេងៗរួចហើយ")។

[1027] ឧបសម្ព័ន្ធ ឃ នៃបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1.5) ERN 01599799-01599803។

[1028] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ D6.1.730 នៅត្រង់ ERN 00357511 ("ដំបូងយើងប្រជុំជាមួយគណៈតំបន់ ៤១ ហើយយកផែនការដែលបានប្រជុំនោះ [...] គណៈតំបន់ប្រជុំ ១ ខែម្តង ហើយថ្នាក់ស្រុកប្រជុំកន្លះខែម្តង")។

[1029] *សូមមើល ឧទាហរណ៍* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៣ ឯកសារ D117/73 នៅត្រង់ ERN 01046821 (ឆ.១៥) ("តាមពិតទទួលបញ្ជាឲ្យអនុវត្តធ្វើអ្វីមួយពីតាអាន ប៉ុន្តែខ្ញុំមិនច្បាស់ថា តាអានជាអ្នកផ្តួចផ្តើមបញ្ជានោះ ឬក៏គាត់ទទួលបញ្ជានោះមកពីថ្នាក់លើ ឬយ៉ាងណានោះទេ")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី

01635049



ស់ អោ អាន ក្នុងការទុកជីវិតក្មេងស្រីជនជាតិចាមម្នាក់ដែលស្ថិតក្រោមការថែទាំរបស់ ប្រាក់ យុត[1030] មិនស៊ីសង្វាក់គ្នានឹងភស្តុតាងរបស់ ប្រាក់ យុត ដែលថា អោ អាន បានបញ្ជាឲ្យគាត់ចាប់ខ្លួន និងសម្លាប់ជនជាតិចាមទាំងអស់ផ្សេងទៀតឡើយ។ ប្រាក់ យុត បានបញ្ជាក់យ៉ាងច្បាស់ថា អោ អាន បានបញ្ជាឲ្យគាត់ធ្វើបញ្ជីជនជាតិចាមទាំងអស់ ហើយគ្មានការអនុគ្រោះចំពោះប្រជាជនចាមណាម្នាក់ឡើយ[1031]។ ចុងបញ្ចប់ ការអះអាងថា ភស្តុតាងរបស់ ប្រាក់ យុត បានមកពី "ការបំពេញបន្ថែម" ដោយអ្នកស៊ើបអង្កេត ត្រូវបានបដិសេធចោល[1032]។

៥៣៣. ផ្ទុយពីការអះអាងរបស់សហមេធាវីការពារក្ដី ដែលថា ភស្តុតាងរបស់ ប្រាក់ យុត គ្មានការបញ្ជាក់នោះ[1033] សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកលើ ការបញ្ជាក់លម្អិតដោយ យូ វ៉ាន់ ដែលផ្ដល់ភស្តុតាងឲ្យជឿជាក់បានថា អោ អាន បានបញ្ជាទៅ ប្រាក់ យុទ្ធ ដោយផ្ទាល់ ឬតាមរយៈទាហានតំបន់

---

ប្រាក់ យុត ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ D117/71 នៅត្រង់ ERN 01046808 (ឆ.៤៨) ("ក្នុងពេលប្រជុំប្រចាំខែ តាអានបានបញ្ជាឲ្យខ្ញុំកំណត់អត្តសញ្ញាណប្រជាជនចាម")។។

[1030] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៦២០ លេខយោងជើងទំព័រ ២០៩៦ *ដែលសំដៅលើ*ប្រតិចារឹកក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ (ប្រាក់ យុត) ឯកសារ D219/702.1.95 ERN 01253284-01253285។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៣ ឯកសារ D117/73 នៅត្រង់ ERN 01046818 (ឆ.៤-ឆ.៥) ("គាត់ [តាអាន] បញ្ជាឲ្យខ្ញុំស្រង់ឈ្មោះជនជាតិចាមទាំងអស់ដែលនៅក្នុងស្រុកខ្ញុំ។ [...] ពេលឃើញសំបុត្រនោះ ខ្ញុំភាំងស្មារតីដោយឃើញឈ្មោះ ភា នៅក្នុងនោះ។ ខ្ញុំបានទាក់ទងទៅពូអាន។ [...] ពូអានក៏យល់ព្រមមិនស្រង់ឈ្មោះ ភា ដោយសារ ភា ជាជនជាតិចាមតែម្នាក់ដែលធ្វើការ និងរួមរស់នៅជាមួយខ្ញុំ")។

[1031] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៦២០ លេខយោងជើងទំព័រ ២០៩៧ *ដែលយោងទៅ* ប្រតិចារឹកក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ ២០១៦ (ប្រាក់ យុត) ឯកសារ D219/702/1.95 ERN 01253286 ទំព័រ ១៣:៩-១៣:១០ ("ខ្ញុំកាលហ្នឹងគឺមានចិត្តអនុគ្រោះចំពោះលោកស្រី ភា។ តែដល់ក្រោយមក ចំពោះចាមដទៃ យើងអត់បានអនុគ្រោះ។ ខ្ញុំមិនបានសុំ ពូអាន ថាអនុគ្រោះចាមនោះទេ")។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៣ ឯកសារ D117/73 នៅត្រង់ ERN 0104681 (ឆ.៥) ("ពូអានក៏យល់ព្រមមិនស្រង់ឈ្មោះ ភា [...] ប៉ុន្តែគាត់បញ្ជាខ្ញុំបន្តស្រង់ឈ្មោះជនជាតិចាមដទៃទៀត")។

[1032] ឧបសម្ព័ន្ធ ឃ នៃបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1.5) ERN 01599800-01599801។ *សូមមើលមូលដ្ឋានទី ៥ (iii) ខាងលើ។ អំណះអំណាងដែលរងការជំទាស់ ធ្លាប់ត្រូវបានដេញដោលដោយសហមេធាវី។ សូមមើល* ឧបសម្ព័ន្ធ ខ នៃពាក្យសុំធ្វើមោឃភាពកំណត់ហេតុស្ដាប់ចម្លើយសាក្សី (ឯកសារ D338/1/2.3) ERN (EN) 01388934-01388940, entries 10-12។ ចៅក្រមអន្តរជាតិបានរំឭកឡើងវិញបន្ថែមទៀតថា ការរំឭកការចងចាំរបស់សាក្សីដោយប្រើប្រាស់អំណះអំណាង ឬសក្ខីកម្មពីមុនរបស់សាក្សីគឺជាកិច្ចស៊ើបអង្កេតស្របច្បាប់។

[1033] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤៧, ១៤៨ លេខយោងជើងទំព័រ ៣៧៥, ៣៧៨។

ឬស្រុក ឱ្យធ្វើការចាប់ខ្លួនជនជាតិចាម[1034]។ ពាក់ព័ន្ធនឹងការរាយការណ៍ ចៅក្រមអន្តរជាតិយល់ថា ភស្តុតាងរបស់ ប្រាក់ យុត ត្រូវបានបញ្ជាក់ដោយ ញឹម កុល ដែលបានផ្តល់ព័ត៌មានលម្អិត និងអាចជឿបាន ស្តីពីប្រព័ន្ធរាយការណ៍នៅថ្នាក់ភូមិ ស្រុក និងតំបន់[1035]។ ចុងបញ្ចប់ យូ វ៉ាន់ បានផ្តល់ភស្តុតាងដែលអាចជឿបានថា គាត់ជាអ្នកចងក្រងបញ្ជីឈ្មោះជនជាតិចាម ហើយ គាត់ជាអ្នកផ្តល់បញ្ជីឈ្មោះឱ្យ ប្រាក់ យុត ចំណែក ប្រាក់ យុត ជាអ្នកបញ្ជូនបញ្ជីឈ្មោះនោះទៅ អោ អាន[1036]។ ទោះជាការរៀបរាប់ពីដំណើររឿងរបស់ យូ វ៉ាន់ ពាក់ព័ន្ធនឹងបញ្ជីឈ្មោះទីពីរ គ្មានការបញ្ជាក់ក្តី[1037] ចៅក្រមអន្តរជាតិយល់ថា ការពឹងផ្អែករបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើភស្តុតាងរបស់ យូ វ៉ាន់ មិនមែនថាមិនសមហេតុផលនោះទេ

---

[1034] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ 360) កថាខណ្ឌ ៣០២ *ដែលយោងទៅ*កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ឯកសារ D219/138 នៅត្រង់ ERN 01056061-01056062 (ឆ.៩៨-ឆ.១០០)។

[1035] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ 360) កថាខណ្ឌ ៣០៣ *ដែលយោងទៅ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញឹម កុល ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ D219/171 នៅត្រង់ ERN 01065944-01065945 (ឆ.២) ("ការប្រជុំនេះគឺធ្វើនៅក្នុងកន្លែងមន្ទីរឃុំជាមួយនឹងប្រធានភូមិ ដែលជាការប្រជុំប្រចាំម្តងមួយអាទិត្យ ជួនកាលញឹកញាប់ជាងនេះ។ ប្រធានភូមនឹងរាយការណ៍ទៅឱ្យ រ៉ុម ផ្ទាល់នៅក្នុងអង្គប្រជុំនេះ [...] ការរាយការណ៍នេះគឺធ្វើឡើងជាប្រចាំ រឿន ហើយនិងខ្ញុំចូលរួមក្នុងកិច្ចប្រជុំនេះដែរ។ មួយទៀត គឺខ្ញុំទទួលភារកិច្ចរក្សា និងធ្វើស្ថិតិប្រជាជន គោ ក្របី ហើយនឹងចំនួនស្រូវ អង្ករ។ នៅក្នុងស្ថិតិនោះគឺព័ត៌មានអំពីចំនួនមនុស្សកើត ឬស្លាប់ ឬក៏ត្រូវយកទៅសម្លាប់។ ភូមិនីមួយៗត្រូវតែផ្តល់ព័ត៌មានស្ថិតិទាំងនេះមកឱ្យខ្ញុំក្នុងមួយខែ ៤ ដង។ ខ្ញុំទទួលព័ត៌មានទាំងនេះរៀបចំរួចប្រគល់ទៅឱ្យ រ៉ុម។ បន្ទាប់មក រ៉ុម បញ្ជូនព័ត៌មានស្ថិតិទាំងនេះឡើងទៅឱ្យស្រុកដែលមានឈ្មោះ តាណន ជាអ្នកទទួល [...] ការធ្វើស្ថិតិនេះគឺធ្វើដូចគ្នាសម្រាប់ឃុំទាំងអស់នៅក្នុងស្រុក។ ខ្ញុំដឹងរឿងនេះដោយសារ តាណន ជាអ្នកហៅឃុំទាំងអស់ឱ្យទៅប្រជុំទទួលការណែនាំរួមទាំងរូបខ្ញុំផង។ ពេលនោះ តាណន ជាអ្នកប្រគល់ប្រកាសបែបបទឱ្យយើងជាស្រេចសម្រាប់ឱ្យយើងបំពេញព័ត៌មានបញ្ចូល"), ERN 01065947 (ឆ.១២) ("ពេលនោះ ពួកប្រធានឃុំនៅក្នុងស្រុកកំពង់សៀមត្រូវបានចាប់ខ្លួន លើកលែងតែមារបស់ខ្ញុំម្នាក់ប៉ុណ្ណោះ [...] ពេលនោះ គឺស្រុកចុះមកដោយខ្លួនឯង បើសិនជាគេត្រូវការចាប់ខ្លួនកម្មាភិបាល ប៉ុន្តែចំពោះប្រជាជនធម្មតា គឺប្រធានភូមិរាយការណ៍ទៅឱ្យស្រុក និងឃុំសិន ទើបគេចុះមកចាប់ខ្លួន")។

[1036] ប្រតិចារឹកសំណុំរឿង ០០២ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ (យូ វ៉ាន់) ឯកសារ D219/702.1.87 ERN 01451952-01451953 ទំព័រ ៥០:២៤ -៥១:២១ ("គឺធ្វើហ្នឹងធ្វើតាមរបាយការណ៍របស់ប្រធានភូមិឱ្យមក។ មួយភូមិមានប៉ុន្មានៗ កត់ចម្លងតាមហ្នឹងទៅ [...] ព្រោះ ខុម ហ្នឹង ប្រាប់ខ្ញុំថាប្រហែលជា ប្រាក់ យុត ហ្នឹងមិនស្រួលទេយ៉ាង យកឈ្មោះទៅឱ្យ តាអាន")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ឯកសារ D219/138 នៅត្រង់ ERN 01056051 (ឆ.៥៥)។ អង្គបុរេជំនុំជម្រះបានរំឮកពីមូលដ្ឋានទី ៥ (v) ពាក់ព័ន្ធនឹងពាក្យចចាមអារ៉ាម និងបន្ទាប់ពីការពិនិត្យឡើងវិញលើអង្គសេចក្តីនៃការស្តាប់ចម្លើយ រកឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនមានកំហុសក្នុងការពឹងផ្អែកលើភស្តុតាងរបស់ យូ វ៉ាន់ នៅពេលទាញការសន្និដ្ឋានទាំងនេះឡើយ។

[1037] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤៧ លេខយោងជើងទំព័រ ៣៧៥។

[1038]។ ការអះអាងថា ភស្តុតាងរបស់ យូ វ៉ាន់ បានមកពី "ការបំពេញបន្ថែម" របស់អ្នកស៊ើបអង្កេត ត្រូវបានបដិសេធចោល[1039]។

៥៣៤. ក្រៅពីនេះ ចៅក្រមអន្តរជាតិមិនយល់ស្របចំពោះការអះអាងរបស់សហមេធាវីដែលថា ភស្តុតាងរបស់ ប្រាក់ យុត ពាក់ព័ន្ធតែនឹងស្រុកកំពង់សៀមនោះទេ[1040]។ ភស្តុតាងរបស់ ប្រាក់ យុត គឺថា អោ អាន បានបញ្ជាឱ្យរូបគាត់ *និងលេខាស្រុកផ្សេងទៀត* ធ្វើការចាប់ខ្លួន និងកម្ទេចជនជាតិចាម ហើយបញ្ជាទាំងនេះត្រូវបានអនុវត្ត *ក្នុងស្រុកបួនផ្សេងទៀត*[1041]។ ផ្ទុយពីការអះអាងរបស់សហមេធាវីការពារក្តី ភស្តុតាងនេះត្រូវបានបញ្ជាក់ដោយ សយ ឡឿន និង សេង ស្រ៊ុន ដែលផ្តល់ភស្តុតាងស្តីពីបញ្ជីឈ្មោះ និងបញ្ជាសម្លាប់នៅ

---

[1038] *សូមមើល មូលដ្ឋានទី ៥ (ii) (ខ) និង (iv) ខាងលើ*។ អង្គបុរេជំនុំជម្រះយល់ថា ជាទូទៅ យូ វ៉ាន់ គឺជាសាក្សីដែលអាចជឿជាក់បាន។ បន្ទាប់ពីការពិនិត្យឡើងវិញលើចំណុចសំខាន់នៃភស្តុតាងរបស់ យូ វ៉ាន់ លើចំណុចនេះ ចៅក្រមអន្តរជាតិយល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសក្នុងការពឹងផ្អែកលើភស្តុតាងរបស់ យូ វ៉ាន់ ដើម្បីគាំទ្រដល់ការសន្និដ្ឋាននេះឡើយ។ *សូមមើល* ប្រតិចារឹកក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ (យូ វ៉ាន់) ឯកសារ D219/702.1.87 ERN 01451956-01451958។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ឯកសារ D219/138 ERN 01056049 (ឆ.៤៨)។

[1039] *សូមមើល មូលដ្ឋានទី ៥ (iii) ខាងលើ*។ អំណះអំណាងដែលរងការជំទាស់ធ្លាប់ត្រូវបានដេញដោលដោយសហមេធាវី។ *សូមមើល* ឧបសម្ព័ន្ធ ខ នៃពាក្យសុំធ្វើមោឃភាពកំណត់ហេតុស្តាប់ចម្លើយសាក្សី (ឯកសារ D338/1/2.3) ERN (EN) 01388971, លេខរៀងទី 45។ ឧបសម្ព័ន្ធ ឃ នៃពាក្យសុំធ្វើមោឃភាពកំណត់ហេតុស្តាប់ចម្លើយសាក្សី (ឯកសារ D338/1/2.5) ERN (EN) 01364467, លេខរៀងទី 1។ ចៅក្រមអន្តរជាតិបានរំឭកឡើងវិញបន្ថែមទៀតថា ការរំឭកពីការចងចាំរបស់សាក្សីដោយប្រើប្រាស់អំណះអំណាង ឬសក្ខីកម្មពីមុនរបស់សាក្សី គឺជាកិច្ចការស៊ើបអង្កេតស្របច្បាប់។

[1040] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤៧ លេខយោងជើងទំព័រ ៣៧៥។

[1041] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ ឯកសារ D117/70 នៅត្រង់ ERN 01046797 (ឆ.៤៤-ឆ.៤៥) ("ខ្ញុំទទួលបញ្ជាពីតាអានឱ្យប្រមូលជនជាតិចាម។ [...] តាអានបញ្ជាក្នុងពេលប្រជុំប្រចាំខែ។ នៅក្នុងកិច្ចប្រជុំនោះ តាអាន បានចេញបញ្ជាដូចគ្នាទៅកាន់គណៈស្រុកផ្សេងៗទៀត") (សេចក្តីបញ្ជាក់បន្ថែម)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ D219/120 នៅត្រង់ ERN 01046832-01046833 (ឆ.១៩-ឆ.២៣) ("តាអានចេញបញ្ជាឱ្យខ្ញុំកំណត់អត្តសញ្ញាណអ្នកដែលប្រឆាំងនឹងបដិវត្តន៍ [...] ហើយឱ្យចាប់អ្នកទាំងអស់នោះយកទៅកម្ទេចចោល [...] *បទបញ្ជានេះត្រូវបានអនុវត្តចំពោះឃុំផ្សេងៗទាំងអស់នៅក្នុងស្រុកកំពង់សៀម ហើយក៏អនុវត្តនៅក្នុងស្រុក ៤ ផ្សេងទៀតផងដែរ* [...] ពេលចេញបញ្ជា គឺនៅពេលតែមួយឱ្យកម្ទេច ក៏ប៉ុន្តែយើងអនុវត្តបញ្ជាសម្លាប់ជនជាតិចាមអស់នោះ នៅពេលក្រោយដែលចាប់បានសមាសភាពផ្សេងៗរួចហើយ [...] ខ្ញុំបានទទួលបញ្ជានេះនៅពេលប្រជុំប្រចាំខែនៅតំបន់ ដែលមានគណៈស្រុកទាំងអស់ចូលរួមប្រជុំ") (សេចក្តីបញ្ជាក់បន្ថែម)។ ប្រតិចារឹកក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ (ប្រាក់ យុត) ឯកសារ D219/702.1.95 ERN 01253281 ទំព័រ ៨:៥-៨:២១ ("ខ្ញុំសូមជម្រាបរឿងដែលបានប្រជុំក្នុងតំបន់ទាំងមូល បានស្រុកទាំងអស់បានមកប្រជុំនេះ វាបានប្រជុំ")។

ស្រុកកងមាស[1042]។

៥៣៥. ចុងបញ្ចប់ ផ្អែកតាមតួនាទី និងអំណាចរបស់ អោ អាន ក្នុងនាមជាលេខាតំបន់ ៤១ និងជាអនុលេខាភូមិភាគកណ្ដាល[1043] មិនមែនជាការមិនសមហេតុផលទេដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិសន្និដ្ឋានថា អោ អាន មានតួនាទីក្នុងប្រតិបត្តិការជម្លៀសជនជាតិចាមចេញពីភូមិភាគបូព៌ាទៅភូមិភាគកណ្ដាលនោះ។ ផ្ទុយពីការអះអាងរបស់សហមេធាវី[1044] សហចៅក្រមស៊ើបអង្កេតអន្តរជាតិធ្វើការសន្និដ្ឋាននេះផ្អែកលើតំណែងរបស់ អោ អាន ក្នុងនាមជាលេខាតំបន់ ៤១ និងជាអនុលេខាភូមិភាគកណ្ដាល និងភស្តុតាងដែលថា "អោ អាន បានចូលរួមក្នុងការរៀបចំផែនការបោសសម្អាតភូមិភាគបូព៌ា ដោយក្នុងអំឡុងពេលនោះ ជនជាតិចាមត្រូវបានសម្លាប់" ហើយ "ធនធានពីតំបន់ ៤១ (កាណូត និងឡាន) [ត្រូវបានប្រើប្រាស់] ដើម្បីដឹកជនជាតិចាមខ្លះពីភូមិភាគបូព៌ាទៅភូមិភាគ កណ្ដាល"[1045]។

៥៣៦. ចៅក្រមអន្តរជាតិយល់ថា សហមេធាវីការពារក្ដីមិនបានបង្ហាញថា គ្មានអ្នកវិនិច្ឆ័យអង្គហេតុដែលមានហេតុផលអាចធ្វើការសន្និដ្ឋានលើអង្គហេតុដែលរងការជំទាស់នេះឡើយ។ ហេតុដូច្នេះ មូលដ្ឋានទី ៦ (៦) ត្រូវបានបដិសេធចោល។

---

[1042] ប្រតិចារឹកក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ (សយ ឡឿន) ឯកសារ D219/702.1.85 ERN 01453113-01453114 ទំព័រ ៥៥:១៨-៥៦:២៣ ("ខ្ញុំចាប់បានតែម្ដង។ គេឲ្យចាប់ម្ដងហ្នឹង តែប៉ុណ្ណឹង អត់មានអីទៅទៀតទេ [...] ផ្ទាល់មាត់ [...] ប្រធាន ប្រពន្ធថ្នាក់ស្រុក ចៅហ្វាយខេត្តនោះ--ចៅហ្វាយស្រុក (ភាព) [...] ចាប់ដាក់ថ្នាក់លើមក ប្រាប់តាមឃុំហ្នឹង ឃុំមកប្រាប់ខ្ញុំហ្នឹង ប្រាប់បន្តគ្នាអញ្ចឹង [...] ថាឲ្យចាប់ចាមទាល់តែអស់មួយភូមិហ្នឹង [...] [បញ្ជីឈ្មោះ] មកពីឃុំហ្នឹង")។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សេង ស្រ៊ុន ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D6.1.700 នៅត្រង់ ERN 00418575 (ឆ.៨, ឆ.១០-ឆ.១២) ("ប្រធានកងឈ្មោះ ណូយ ជាអ្នកធ្វើបញ្ជីឈ្មោះជនជាតិចាមដែលធ្វើការនៅការដ្ឋានជើងព្រៃ។ ប្រហែលប្រាំពីរ ឬប្រាំបីខែក្រោយមក ក៏មានការចាប់ខ្លួនជនជាតិចាមភាគតិចតែម្ដង។ ណូយគ្រាន់តែនិយាយថាថ្នាក់លើ ប៉ុន្តែគាត់មិនបាននិយាយឈ្មោះនោះទេ [...] សំបុត្រនោះសរសេរថា ឲ្យស្រង់បញ្ជីឈ្មោះជនជាតិភាគតិចចាម [...] សំបុត្រនោះត្រូវបានចុះហត្ថលេខាដោយភាព")។ ប្រតិចារឹកក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ ២០១៥ (សេង ស្រ៊ុន) ឯកសារ D219/702.1.88 ERN 01416960 ទំព័រ ៤៥:៨-៤៥:១៦ ("ពីបញ្ហាសំបុត្រដែលបានអានពីរឿងករណីគេឲ្យស្រង់ស្ថិតិបងប្អូនចាមហ្នឹង អាហ្នឹងខ្ញុំដូចថាខ្ញុំដឹង ក៏ប៉ុន្តែខ្ញុំអត់បានអានសំបុត្រហ្នឹងទេ [...] គេឈ្មោះដែលនៅជាមួយខ្ញុំហ្នឹងដែលធ្វើការមួយគ្នានេះបានប្រាប់ថា គេឲ្យស្រង់ស្ថិតិបងប្អូនចាមហ្នឹង ប្រុសដោយប្រុស ស្រីដោយស្រី")។

[1043] *សូមមើល មូលដ្ឋានទី ៦ (iv) និង (v) (ក), (ខ) ខាងលើ*។

[1044] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៤៩ លេខយោងជើងទំព័រ ៣៨០។

[1045] *សូមមើល មូលដ្ឋានទី ៦ (v) (ង) ខាងលើ*។ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៣០៧-៣១០, ៦៣៧។

## មូលដ្ឋានទី៦(vii). តួនាទីរបស់ អោ អាន ក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេព សន្ថវៈនៅស្រុកព្រៃឈរ និងស្រុកកំពង់សៀម

### ១. សារណា

៥៣៧. សហមេធាវីការពារក្តីចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំបានផ្តល់ភស្តុតាងឲ្យបានគ្រប់គ្រាន់ ដែលថា អោ អាន បានរួមចំណែកយ៉ាងសំខាន់ចំពោះគោលនយោបាយស្តីពីអាពាហ៍ពិពាហ៍របស់ ប.ក.ក និងបានបង្កើនចំនួនប្រជាជន ឬថា គាត់បានរៀបចំផែនការបញ្ជា ញុះញង់ ឬចូលរួមក្នុងអាពាហ៍ពិពាហ៍ ឬការរំលោភសេពសន្ថវៈ ដែលត្រូវបានចោទប្រកាន់នៅស្រុកព្រៃឈរ និងស្រុកកំពង់សៀម[1046]។ ជាពិសេស សហមេធាវីលើកឡើងថា មានភស្តុតាងមិនគ្រប់គ្រាន់ដែលបញ្ជាក់ថា អោ អាន បានគ្រប់គ្រង គាំទ្រ ឬពិនិត្យមើលការអនុវត្តគោលនយោបាយរបស់ ប.ក.ក ទាំងនេះ ពិនិត្យមើលការអនុវត្តរបស់ពួកគេ ធ្វើជាគណៈអធិបតីក្នុងពិធីអាពាហ៍ពិពាហ៍ ឬធ្វើជាប្រធានកិច្ចប្រជុំស្តីពីអាពាហ៍ពិពាហ៍[1047]។ សហមេធាវីការពារក្តីអះអាងថា ការសន្និដ្ឋានទាំងនេះផ្អែកលើភស្តុតាងមិនជាក់លាក់ មិនមានការបញ្ជាក់ និងលើកឡើងខុស ព្រមទាំងការសន្និដ្ឋានដែលមិនមានការគាំទ្រ ទាក់ទងនឹងតំណែងរបស់ អោ អាន ក្នុងតំបន់ ៤១ និងភូមិភាគកណ្តាល[1048]។

៥៣៨. ក្នុងចម្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា សហមេធាវីមិនបានបង្ហាញថាគ្មានអ្នកវិនិច្ឆ័យអង្គហេតុដែលសមហេតុផលណាអាចធ្វើការសន្និដ្ឋានទាំងនេះឡើយ[1049]។ សហព្រះ រាជអាជ្ញាអន្តរជាតិចោទប្រកាន់ទៀតថា ទឡ្ហីករណ៍របស់សហមេធាវីផ្អែកលើការអះអាងមិនសមហេតុផលថា អោ អាន មិនមែនជាលេខាតំបន់ ៤១ និងសេចក្តីថ្លែងសន្និដ្ឋានពាក់ព័ន្ធនឹងភាពសមហេតុផលនៃភស្តុតាងដែលមិនបំពេញតាមបទដ្ឋានចាំបាច់សម្រាប់បង្ហាញកំហុស[1050]។

[1046] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៥១។ ប្រតិចារឹកក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 និងឯកសារ D360/18.1 ERN 01626071 ទំព័រ ១៧:៣-១៧:៦។

[1047] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៥២-១៥៤។

[1048] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៥២-១៥៤។

[1049] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៧៧។

[1050] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៧៧។

## ២. ការពិភាក្សា

៥៣៩. ចៅក្រមអន្តរជាតិមិនជឿលើការអះអាងរបស់សហមេធាវីការពារក្តីដែលថា អោ អាន "មិនមានតួនាទី" ក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬការរំលោភសេពសន្ថវៈដែលត្រូវបានចោទប្រកាន់ថាមាននៅស្រុកព្រៃឈរ និងស្រុកកំពង់សៀមឡើយ[1051]។ ទោះបីជាការអះអាងរបស់សហមេធាវីការពារក្តីថា មាន "ភស្តុតាងមិនគ្រប់គ្រាន់ដែលបង្ហាញ [ថា] អោ អាន មានតំណែង" ជាលេខាតំបន់ ៤១ និងជាអនុលេខាភូមិភាគ[1052] ចៅក្រមអន្តរជាតិរម្លឹកថា អង្គជំនុំជម្រះមិនបានឃើញកំហុសអ្វីនោះទេ[1053]។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានប្រព្រឹត្តកំហុសតាមរយៈការពឹងផ្អែកលើតំណែង [...] ដែល អោ អាន មានឡើយ រួមជាមួយនឹងភស្តុតាងជាក់លាក់ (*ក្នុងចំណោមនោះ* គឺថា អោ អាន បានធ្វើជាប្រធានកិច្ចប្រជុំស្តីពីអាពាហ៍ពិពាហ៍ និងថា គាត់បានធ្វើជាគណៈអធិបតីក្នុងពិធីអាពាហ៍ពិពាហ៍) នៅពេលរកឃើញថា អោ អាន បានគាំទ្រដល់គោលនយោបាយរបស់ ប.ក.ក ស្តីពីបទប្បញ្ញត្តិអាពាហ៍ពិពាហ៍ និងថា គាត់បានគ្រប់គ្រងការអនុវត្តគោលនយោបាយរបស់ ប.ក.ក ក្នុងស្រុកកំពង់សៀម និងស្រុកព្រៃឈរ[1054]។

៥៤០. លើសពីនេះទៀត ទាក់ទងនឹងការសន្និដ្ឋានថា អោ អន បានធ្វើជាប្រធានកិច្ចប្រជុំស្តីពីអាពាហ៍ពិពាហ៍ ចៅក្រមអន្តរជាតិមិនជឿថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសតាមរយៈការពឹងផ្អែកលើភស្តុតាងមិនជាក់លាក់ មិនមានការបញ្ជាក់ និងត្រូវបានលើកឡើងខុស[1055]។ ចៅក្រមអន្តរជាតិសង្កេត

[1051] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៥១-១៥៤។

[1052] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៥២។

[1053] *សូមមើលខាងលើ* មូលដ្ឋានទី៦(iv) និង(v)។

[1054] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២២៤-២៣២, ៣១៤-៣១៩។

[1055] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៥៣ និងលេខយោងជើងទំព័រ ៣៨៧-៣៩១ *ដែលយោងទៅ*ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៣១៤-៣១៦។ ការអះអាងរបស់សហមេធាវីការពារក្តីថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបកស្រាយបំផ្លែងការពិតនៃភស្តុតាងរបស់ សារ៉ាយ ហៀន ត្រូវបានបដិសេធ។ ចៅក្រមអន្តរជាតិសង្កេតឃើញថា ការសន្និដ្ឋានដ៏ពេញលេញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺថា ("ទាំង កែ ពក និង អោ អាន បានដឹកនាំប្រជុំនិយាយអំពីប្រធានបទរៀបអាពាហ៍ពិពាហ៍ និងយល់ស្របតាមទស្សនៈរបស់ ប៉ុល ពត ក្នុងការបង្កើនចំនួនប្រជាជន") *សូមមើល* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៣១៤។ ការសន្និដ្ឋាននេះត្រូវបានការគាំទ្រយ៉ាងច្បាស់តាមរយៈភស្តុតាងរបស់ សារ៉ាយ ហៀន ដែលបញ្ជាក់ថា កែ ពក បានពិភាក្សាពីគោលនយោបាយអាពាហ៍ពិពាហ៍ក្នុងកិច្ចប្រជុំនៅតំបន់ ៤២។ ការរៀបរាប់ពីព្រឹត្តការណ៍ដំណើររឿងរបស់ សារ៉ាយ ហៀន មិនបានចោទប្រកាន់ អោ អាន ដោយផ្ទាល់ទេ ប៉ុន្តែមានការពាក់ព័ន្ធ ពីព្រោះវាបញ្ជាក់ថា គោលនយោបាយអាពាហ៍ពិពាហ៍របស់ ប.ក.ក ត្រូវបានដាក់

ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពឹងផ្អែកលើ សាត ភាព ដែលជាសាក្សីផ្ទាល់ដែលបានឃើញវត្តមានរបស់ អោ អាន នៅកិច្ចប្រជុំនៅចុងឆ្នាំ១៩៧៧ នៅវត្តតាមាក់ និងផ្តល់ព័ត៌មានលម្អិតជាក់លាក់អំពីខ្លឹមសាររបស់កិច្ចប្រជុំ រួមទាំងវិធីសាស្ត្រដែលស្នើឡើងរបស់ អោ អាន (ផែនការរបស់ ប៉ុល ពត) ដើម្បីបង្កើនចំនួនប្រជាជនតាមរយៈការរៀបចំផែនការអាពាហ៍ពិពាហ៍[1056]។ គាត់ថែមទាំងហៅ អោ អាន ថាជាមន្ត្រីជាន់ខ្ពស់បំផុតដែលចូលរួមក្នុងកិច្ចប្រជុំនេះ[1057]។ ចៅក្រមអន្តរជាតិមិនឃើញមានការអនុវត្តមិនត្រឹមត្រូវរបស់អ្នកស៊ើបអង្កេតនោះទេ ហើយសង្កេតឃើញថា ការរៀបរាប់ដំណើររឿងរបស់ សាត ភាព មានភាពលម្អិត និងអាចជឿទុកចិត្តបាន[1058]។

៩៤១. ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសនោះទេ នៅពេលសន្និដ្ឋានថា អោ អាន បានធ្វើជាគណៈអធិបតីក្នុងពិធីអាពាហ៍ពិពាហ៍ "យ៉ាងហោចណាស់ចំនួន ៥"[1059] ហើយច្រានចោលការសន្និដ្ឋានទៅលើភស្តុតាងរបស់សហមេធាវី ដែលថា ការចោទប្រកាន់នីមួយៗអំពីការចូលរួមរបស់ អោ អាន ក្នុងពិធីអាពាហ៍ពិពាហ៍ តម្រូវឱ្យមានការបញ្ជាក់ផ្ទាល់សម្រាប់ព្រឹត្តិការណ៍នោះ។ ចៅក្រមអន្តរជាតិយល់ឃើញថា ភស្តុតាងដែលទទួលបានពីសាក្សីច្រើន ដែលបញ្ជាក់ថា អោ អាន បានធ្វើជាគណៈធិបតីក្នុងពិធីអាពាហ៍ពិពាហ៍មួយចំនួន បានបញ្ជាក់ទៅវិញទៅមក។ ការពឹងផ្អែករបស់

---

ឱ្យអនុវត្តនៅទូទាំងភូមិភាគកណ្តាល។ ក្នុងករណីនេះ ការបញ្ជាក់មានមកពី កែ ពក ដែលជាថ្នាក់ដឹកនាំផ្ទាល់របស់ អោ អាន។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិពឹងផ្អែកលើ សាត ភាព ចំពោះការចូលរួមក្នុងកិច្ចប្រជុំនានារបស់ អោ អាន។

[1056] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៣១៤-៣១៥ *ដែលយោងទៅ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D219/504 នៅត្រង់ ERN 01146374, 01146394 (ឆ.២៧-ឆ.២៨, ឆ.១៣៨-ឆ.១៣៩) ("គាត់ [អោ អាន] បាននិយាយអំពីផែនការរៀបការ។ ពួកគេគ្រោងនឹងបង្កើនកម្លាំងថ្មី ឬក៏ប្រជាជនថ្មីឱ្យដល់១៥ទៅ២០លាននាក់ នៅក្នុងរយៈពេលពី១៥ទៅ២០ឆ្នាំទៀត [...] នេះគឺជាផែនការអាស៊ី ដែលសំដៅលើផែនការរបស់ ប៉ុល ពត [...] តាមរយៈការរៀបការអ្នកដែលធ្វើការតាមមន្ទីរក្រសួង និងសហករណ៍ជាមួយគ្នា។ គាត់លើកឡើងពីចំណុចនេះជាក់លាក់តែម្តង [...] ក្រោយរៀបការហើយ [...] ត្រូវបង្កើតកូន") និងនៅត្រង់ ERN 01146397 ខ្ញុំចង់បន្តនិយាយពីរឿងកម្លាំងនៅអាស៊ី។ ផែនការរបស់គេ គឺបង្កើតប្រជាជនដែលមានអាយុពី១៥ទៅ២០ឆ្នាំ ឱ្យបាន២០លាននាក់ ហើយវាយយកព្រៃនគរ និងខ្មែរសារិនមកវិញនៅឆ្នាំ២០០១")។

[1057] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D219/504 នៅត្រង់ ERN 01146373 (ឆ.១៩)។

[1058] *សូមមើលខាងលើ* មូលដ្ឋានទី៥(iii)។

[1059] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៥៣ និងលេខយោងជើងទំព័រ ៣៩២ *ដែលយោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២២៨, ៦៨៥។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើភស្តុតាងរបស់ យូ វ៉ាន់ និង ប្រាក់ យុត[1060] នៅពេលសន្និដ្ឋានថា អោ អាន បានធ្វើជាគណៈអធិបតីក្នុងពិធីអាពាហ៍ពិពាហ៍ក្នុងស្រុកកំពង់សៀម និងនៅការិយាល័យស្រុកព្រៃទទឹង មិនមែនថាមិនសមហេតុផលទេ[1061]។ ចៅក្រមអន្តរជាតិសង្កេតឃើញថែមទៀតថា តួយ មៀច និង ទូច ចំរើន បានផ្តល់ភស្តុតាងផ្ទាល់លម្អិតអំពីការធ្វើជាគណៈអធិបតីរបស់ អោ អាន ក្នុងពិធីអាពាហ៍ពិពាហ៍ រួមទាំងអាពាហ៍ពិពាហ៍ផ្ទាល់របស់ ទូច ចំរើន ផងដែរ[1062]។

៥៤២. ចុងក្រោយ ការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា អោ អាន បានប្រកាសគោលនយោបាយមួយដែលតម្រូវឱ្យប្តីប្រពន្ធរៀបការរួមដំណេកជាមួយគ្នា[1063] ត្រូវបានគាំទ្រដោយ សាតភាព ដែលភស្តុតាងរបស់គាត់បង្ហាញថា អោ អាន បានបញ្ជាក់ថា “ក្រោយរៀបការហើយ យើងគួរ

---

[1060] *សូមមើលខាងលើ* មូលដ្ឋាន v(ii)(ក) ដែលចៅក្រមអន្តរជាតិបានពិភាក្សាពីភាពមិនស៊ីសង្វាក់គ្នាសំខាន់ៗនៃភស្តុតាងរបស់ ប្រាក់ យុត ពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងការសន្និដ្ឋានរបស់ខ្លួនដែលថា ការពឹងផ្អែករបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើភស្តុតាងរបស់ ប្រាក់ យុត (ដូចបានបញ្ជាក់ដោយ យូ វ៉ាន់) មិនថា មិនសមហេតុផលទេ។

[1061] យូ វ៉ាន់ និងប្រាក់ យុត ផ្តល់សក្ខីកម្មដោយផ្ទាល់ថា អោ អាន បានធ្វើជាគណៈអធិបតីនៅក្នុងពិធីរៀបការ។ *សូមមើល* ប្រតិចារឹកក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ (ប្រាក់ យុត) ឯកសារ D219/702.1.95 ERN 01253311 ទំព័រ ៣៨:២២-៣៨:២៤ (“ខ្ញុំក៏ទទួលស្គាល់ហើយ ពូអាន គាត់ចូលរួម។ អ៊ីចឹង ខ្ញុំទទួលស្គាល់ទាំងពីរហ្នឹង គឺថានាងខ្ញុំជាអាង គឺចូលរួមក្នុងការរៀបចំអាពាហ៍ពិពាហ៍ឱ្យចាមនេះ ចំនួន១០គូហ្នឹង គឺខ្ញុំទទួលថាខ្ញុំធ្វើទៅចុះ”)។ ប្រតិចារឹកក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ (យូ វ៉ាន់) ឯកសារ D219/702.1.87 ERN 01451961 ទំព័រ ៥៩:៩-៥៩:១១ (“កាលណាការច្រើនគូ ប្រាំប្រាំមួយគូ ទៅ១០គូ ក៏ឃើញមាន តាអាន ហ្នឹងគាត់ទៅជួយរៀបដែរ។ កាលណាតិចតួចទៅ [...] ប្រាក់ យុត ហ្នឹងរៀបទៅ”)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ឯកសារ D219/138 នៅត្រង់ ERN 01056045-10156046 (ឆ.៣១,ឆ.៣៣)។ យូ វ៉ាន់ បញ្ជាក់ថា អោ អាន មានសិទ្ធិអំណាចក្នុងការចាត់ចែងអាពាហ៍ពិពាហ៍ដោយផ្ទាល់។ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ឯកសារ D219/138 នៅត្រង់ ERN 01056045 (ឆ.២៦) (“តាអាន ឱ្យសិទ្ធិថ្នាក់ស្រុកជាអ្នករៀបចំការរៀបការដោយខ្លួនឯង”)។

[1062] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តួយ មៀច ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D219/582 នៅត្រង់ ERN 01166943-01166944 (ឆ.១២២-ឆ.១២៩) (“នៅរោងបាយនៃមន្ទីរភ័ស្តុភារ [...] តា អាន ដែលជាគណៈតំបន់។ គាត់គឺជាអ្នករៀបចំពិធីនេះ [...] គាត់ឡើងប្រកាសបើកពិធីរៀបការនោះ”)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច ចំរើន ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ D219/435 នៅត្រង់ ERN 01124166 (ឆ.៣៨-ឆ.៤០) (“តាអាន និយាយថា ស្អែកខ្ញុំត្រូវរៀបការជាមួយប្រពន្ធខ្ញុំ [...] សៈ តើ តាអាន បានមកចូលរួមក្នុងពិធីរៀបការដែរឬទេ? ឆ.៣៩៖ បាទ។ សៈ តើគាត់ជាអធិបតីក្នុងពិធីរៀបការនោះឬទេ? ឆ.៤០៖ បាទ”)។

[1063] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៥៣-១៥៤ លេខយោងជើងទំព័រ ៣៨៧, ៣៩០-៣៩១, ៣៩៣ *ដែលយោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៣១៦។

ស្រឡាញ់គ្នាជាប្តីប្រពន្ធ" ហើយថា ពួកគេត្រូវ "បង្កើតកូន"[1064]។ ផ្ទុយពីការអះអាងរបស់មេធាវីការពារក្តី[1065] ភស្តុតាងរបស់ សាត ភាព ត្រូវបានបញ្ជាក់បន្ថែមដោយ យូ វ៉ាន់ ដែលបានរៀបរាប់លម្អិតថា គាត់បានស្តាប់ឮពី ប្រាក់ យុត ថា "[អោ] អាន [...] ចេញច្បាប់ថា អ្នកដែលរៀបការហើយ ត្រូវតែរួមដំណេកជាមួយគ្នា"[1066]។ ចុងបញ្ចប់ ភស្តុតាងដែលថា ប្តីប្រពន្ធនៅក្នុងស្រុកកំពង់សៀម និងស្រុកព្រៃឈរ (ក្រោមសិទ្ធិអំណាចរបស់ អោ អាន ក្នុងឋានៈជាលេខាតំបន់ ៤១) ត្រូវបានណែនាំឱ្យរួមដំណេកជាមួយគ្នា[1067] រួមទាំង ប្រាក់ យុត[1068] ផងដែរនោះ គ្រាន់តែគាំទ្រដល់ការសន្និដ្ឋានថា អោ អាន ជាអ្នកប្រកាសគោលនយោបាយនេះប៉ុណ្ណោះ។ ផ្ទុយពីការអះអាងរបស់មេធាវីការពារក្តី[1069] ចំណុចថាតើ អោ អាន បាន ឬមិនបានផ្តល់ការណែនាំជាក់លាក់ដល់ប្តីប្រពន្ធទាំងនោះក្តី មិនមែនជាកត្តាកំណត់ពីការទទួលខុសត្រូវរបស់គាត់

---

[1064] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៣១៦ លេខយោងជើងទំព័រ ៨៣៩ *ដែលយោងទៅ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D219/504 នៅត្រង់ ERN 01146394 (ឆ.១៣៩)។ ចៅក្រមអន្តរជាតិរម្លឹកថា ចៅក្រមអន្តរជាតិមិនបានឃើញកំហុសណាមួយចំពោះការសំអាងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅលើការរៀបរាប់ពីព្រឹត្តិការណ៍ដំណើររឿងយ៉ាងលម្អិតពីរវត្តមានរបស់ អោ អាន នៅក្នុងកិច្ចប្រជុំមួយដែលគាត់បាននិយាយអំពីគោលនយោបាយអាពាហ៍ពិពាហ៍របស់ ប.ក.ក ឡើយ។

[1065] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៥៣ លេខយោងជើងទំព័រ ៣៩១ *ដែលយោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៣១៦។

[1066] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ឯកសារ D219/138 ត្រង់ ERN 01056057 (ឆ.៨០) ("ប្រាក់ យុត ប្រាប់ខ្ញុំថាគឺតាអាន មេតំបន់ជាអ្នកចេញច្បាប់ថាអ្នកដែលរៀបការហើយត្រូវតែរួមដំណេកជាមួយគ្នា")។ អង្គបុរេជំនុំជម្រះរម្លឹកពីសេចក្តីសន្និដ្ឋានរបស់ខ្លួនស្តីពីភស្តុតាងចចាមអារ៉ាមនៅក្នុងមូលដ្ឋានទី៥ (v) និងក្នុងការពិនិត្យឡើងវិញលើចំណុចសំខាន់នៃការស្តាប់ចម្លើយ អង្គបុរេជំនុំជម្រះពុំឃើញមានកំហុសណាមួយដោយសារតែសហចៅក្រមស៊ើបអង្កេតអន្តរជាតិនោះឡើយ។

[1067] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៦៨៦ លេខយោងជើងទំព័រ ២៣៦០។

[1068] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញឹម កុល ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ D219/171 នៅត្រង់ ERN 01065955 (ឆ.៤៤) ("បើសិនជាមានគូណាមិនចុះសម្រុងនឹងគ្នា អ្នកនោះនឹងត្រូវគេចោទប្រកាន់ថាប្រឆាំងនឹងអង្គការ និងក្បត់អង្គការ។ គេមិនបាននិយាយថា ឱ្យយើងត្រូវតែរួមភេទច្បាស់ៗនោះទេ ប៉ុន្តែយើងទាំងអស់គ្នាយល់ថា ការពន្យល់ប្រាប់យើងគឺមានន័យដូច្នេះ។ នៅពេលដែល ប្រាក់ យុត ធ្វើជាអធិបតីក្នុងពិធីការចាប់ដៃនេះ ក៏គាត់ធ្វើការពន្យល់ព្រមានដូចគ្នាអ៊ីចឹងដែរ [...] យើងទាំងអស់គ្នាដឹងជាមុនរួចស្រេចហើយថា បន្ទាប់ពីរៀបការហើយ គឺយើងត្រូវតែរួមដំណេកជាមួយដៃគូរបស់យើង"។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មួក សេងលី ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D219/502 នៅត្រង់ ERN 01142495 (ឆ.៣៧) ("យាយ យុទ្ធ និងមិត្តលឿង និងសៀម ជាគណៈអធិបតីក្នុងពិធីរៀបការនោះ។ ពួកគេបានលើកឡើងឱ្យគូស្រករត្រូវស្រឡាញ់គ្នា និងបង្កើតកូនឱ្យអង្គការ ទាំងពីរលើកដែលខ្ញុំចូលរួម")។

[1069] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៥៤ លេខយោងជើងទំព័រ ៣៩៤-៣៩៥។

01635058



បានឡើយ[1070]។

៥៤៣. ចៅក្រមអន្តរជាតិយល់ឃើញថា សហមេធាវីការពារក្តីមិនបានបង្ហាញថា គ្មានអ្នកវិនិច្ឆ័យលើអង្គហេតុដែលសមហេតុផលណាមួយអាចធ្វើការសន្និដ្ឋានដែលរងការជំទាស់នោះឡើយ។ ហេតុដូច្នេះ មូលដ្ឋានទី៦ (៧) ត្រូវបដិសេធចោល។

**មូលដ្ឋានទី៦(viii) ÷ តួនាទីរបស់ អោ អាន នៅក្នុងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅតាមទីតាំងឧក្រិដ្ឋកម្ម**

១. សារណា

៥៤៤. សហមេធាវីការពារក្តីលើកឡើងថា ដោយសារតែមិនមានសិទ្ធិអំណាច តំណែង តួនាទី និងការទទួលខុសត្រូវរបស់ អោ អាន ក្នុងតំបន់ ៤១ និងភូមិភាគកណ្តាល ការមិនបានប្រព្រឹត្ត និងគ្មានវត្តមានរបស់គាត់នៅទីតាំងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងការគ្មានការដឹង ឬចេតនារបស់គាត់ក្នុងការប្រព្រឹត្តិឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសន្និដ្ឋានថា អោ អាន ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់តាមរយៈទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានចោទប្រកាន់[1071]។ នៅក្នុងចម្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា សហមេធាវីការពារក្តីមិនបានបង្ហាញថា មិនមានអ្នកវិនិច្ឆ័យលើអង្គហេតុដែលសមហេតុផលណាអាចធ្វើការសន្និដ្ឋានទាំងនេះបានទេ ពីព្រោះថា ទឡ្ហីករណ៍របស់ពួកគេផ្អែកលើការចោទប្រកាន់ពីកំហុសដែល អោ អាន មិនបានបង្ហាញភស្តុតាងបញ្ជាក់ឡើយ[1072]។

---

[1070] សហមេធាវីការពារក្តីលើកឡើងថា គ្មានសាក្សីណាម្នាក់ដែលដកស្រង់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ជាក់ថា អោ អាន បានផ្តល់ការណែនាំជាក់លាក់អំពីអាពាហ៍ពិពាហ៍ដែលតម្រូវឱ្យរួមដំណេកនោះទេ។ ក៏ប៉ុន្តែ អង្គជំនុំជម្រះមិនបានរកឃើញកំហុសណាមួយឡើយចំពោះការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា អោ អាន បានប្រកាសពីគោលនយោបាយដែលតម្រូវឱ្យប្តីប្រពន្ធរៀបការ ត្រូវរួមដំណេកជាមួយគ្នា ហើយអង្គជំនុំជម្រះយល់ឃើញថា អ្វីដែលពាក់ព័ន្ធត្រង់ចំណុចនេះ គឺថា គោលនយោបាយនេះត្រូវបានអនុវត្តតាមរយៈការណែនាំជាក់លាក់ (រួមបញ្ចូលទាំងអ្នកនៅក្រោមបង្គាប់ផ្ទាល់របស់ អោ អាន ឈ្មោះ ប្រាក់ យុត) នៅក្នុងតំបន់ដែលស្ថិតនៅក្រោមសិទ្ធិអំណាចរបស់ អោ អាន។

[1071] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៥៥។ ប្រតិចារឹកក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 និងឯកសារ D360/18.1 ERN 01626073 ទំព័រ ១៩:១៦-១៩:២២។

[1072] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៨៤។

២. ការពិភាក្សា

៥៤៥. ចៅក្រមអន្តរជាតិសង្កេតឃើញថា ទឡ្ហីករណ៍របស់ អោ អាន ផ្អែកលើកំហុសនៃការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទាក់ទងនឹងតំណែង សិទ្ធិអំណាច និងការប្រព្រឹត្តិរបស់ អោ អាន នៅភូមិភាគកណ្តាល និងតំបន់ ៤១ ដោយមិនបានចោទប្រកាន់ទៅលើកំហុសអង្គហេតុជាក់លាក់ថ្មីៗឡើយ។ ចៅក្រមអន្តរជាតិបានសម្រេចរួចហើយ *ក្នុងចំណោមចំណុចផ្សេងៗ* ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសនោះទេក្នុងការសន្និដ្ឋានថា អោ អាន គឺជាអនុលេខាភូមិភាគកណ្តាល និងជាលេខាតំបន់ ៤១ និងថា គាត់បានអនុវត្តសិទ្ធិអំណាចរបស់គាត់នៅក្នុងភូមិភាគកណ្តាល និងតំបន់ ៤១[1073]។ ហេតុដូច្នេះ មូលដ្ឋានទី៦ (៨) ត្រូវបដិសេធចោល។

## ច. មូលដ្ឋានទី៧៖ សម្អាងហេតុដែលមានកំហុសឆ្គងដែលថាឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់មានស្ថានទម្ងន់ល្មមគ្រប់គ្រាន់

១. សារណា

៥៤៦. សហមេធាវីលើកទឡ្ហីករណ៍ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឆ្គងដែលសម្រេចថាស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់គឺល្មមគ្រប់គ្រាន់សម្រាប់តុលាការសម្រាប់ឱ្យតុលាការមានយុត្តាធិការបុគ្គលលើ អោ អាន[1074]។ ទីមួយ សហមេធាវីលើកឡើងថា ភស្តុតាងភាគច្រើន ពាក់ព័ន្ធនឹងការទទួលខុសត្រូវ និងតួនាទីរបស់ អោ អាន នៅក្នុងឧក្រិដ្ឋកម្មក្នុងតំបន់៤១ ដែលជា "តំបន់ភូមិសាស្ត្រតូចមួយ" បើប្រៀបធៀបទៅនឹងតំបន់ដទៃទៀតដែលគ្រប់គ្រងដោយកម្មាភិបាលដទៃទៀត ដូចជា កែ ពក និង តាម៉ុក[1075]។ ទីពីរ សហមេធាវីតវ៉ាថាវិធីសាស្ត្រក្នុងការគណនាចំនួនជនរងគ្រោះពាក់ព័ន្ធនឹង អោ អាន (នៅតំបន់៤១ តំបន់៤២ និង តំបន់៤២) គឺផ្អែកលើ "ការទាយស្មាន" ដែលបណ្តាលឱ្យចំនួនជនរងគ្រោះមិនបំពេញបានតាមបទដ្ឋាននៃការ បង្ហាញភស្តុតាង[1076]។

---

[1073] *សូមមើលខាងលើ* មូលដ្ឋានទី៦(iv) និង(v)។

[1074] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៥៧ យោងទៅ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៧០៦-៧០៨។

[1075] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៥៨។ ប្រតិចារឹកសវនាការសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1, ERN 01626077 ទំព័រ ២៣:១១ ដល់ ២៣:១៤។

[1076] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៥៩។

៥៤៧. ទីបី ពាក់ព័ន្ធនឹងទម្រង់នៃការទទួលខុសត្រូវដែលបានចោទប្រកាន់ សហមេធាវីលើកទឡ្ហីករណ៍ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានអនុវត្ត "លក្ខខណ្ឌច្បាប់ក្នុងការដាក់ឱ្យ អោ អាន ទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍នៅក្នុងតំបន់៤២ និង ៤៣ តាមរយៈសហឧក្រិដ្ឋកម្មរួម"[1077]។ សហមេធាវីលើកឡើងថា ជាការចាំបាច់ត្រូវបង្ហាញថា "ឧក្រិដ្ឋកម្មអាចត្រូវដាក់បន្ទុកទៅលើយ៉ាងហោចណាស់ក៏សមាជិកមួយរូបនៃសហឧក្រិដ្ឋកម្មរួម ហើយសមាជិករូបនេះនៅពេលប្រើប្រាស់ចារីផ្ទាល់គឺធ្វើសកម្មភាពដើម្បីជំរុញដល់ផែនការរួម"[1078]។ សហមេធាវីអះអាងថា "ពុំមានការព្យាយាម" ភ្ជាប់ឧក្រិដ្ឋកម្មទៅនឹងសមាជិកសហឧក្រិដ្ឋកម្មរួមឡើយ[1079]។ សហមេធាវីក៏បានលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានផ្តល់ភស្តុតាងថា អោ អាន ទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍នៅក្នុងតំបន់៤២ និង តំបន់៤៣តាម រយៈការរៀបចំផែនការ ការបញ្ជា ការញុះញង់ ឬការទទួលខុសត្រូវរបស់ថ្នាក់លើឡើយ[1080]។ ជាលទ្ធផល សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឆ្គង ដោយបានរួមបញ្ចូលមរណភាពរបស់ប្រជាជនចាមនៅក្នុងតំបន់៤២ និង៤៣ ទៅក្នុងចំនួនសរុបនៃជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ដែលត្រូវបានចោទប្រកាន់ និង ដែលបានសម្រេចថាមានស្ថានទម្ងន់ល្មមគ្រប់គ្រាន់ក្នុងការកំណត់យុត្តាធិការបុគ្គលលើ អោ អាន[1081]។

៥៤៨. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា អោ អាន ខកខានមិនបានបង្ហាញថា ឧក្រិដ្ឋកម្មដែលរូបគាត់ត្រូវបានចោទប្រកាន់នោះ មិនមានទម្ងន់គ្រប់គ្រាន់ដើម្បីដាក់រូបគាត់ឱ្យស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឡើយ[1082]។ សហព្រះរាជអាជ្ញាអន្តរជាតិរំលេចថា ទំហំនៃតំបន់ភូមិសាស្ត្រដែលគ្រប់គ្រងដោយបុគ្គលម្នាក់ពុំមែនជាកត្តាកំណត់នូវកម្រិតនៃការទទួលខុសត្រូវរបស់គាត់ឡើយ ពោលគឺ ពិតណាស់ដែល ឌុច ស្ថិតក្នុងចំណោមជនទាំងឡាយ "ដែលទទួលខុសត្រូវខ្ពស់បំផុត" បើទោះបីជា

[1077] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៦២។

[1078] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៦២។

[1079] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៦២។

[1080] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៦១។

[1081] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៦០-១៦៣។ សំណុំរឿង ០០៤/២ ប្រតិចារឹកសវនាការ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1, ERN ERN 01626077 ទំព័រ ២៣:១៧ ដល់ ២៣:២១។

[1082] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៨៩។ ប្រតិចារឹកសវនាការសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626106 ទំព័រ ៥២:១១ ដល់ ៥២:១៧។

មន្ទីរស-២១ មានទំហំតូចជាងតំបន់៤១ ច្រើនក៏ដោយ។ អ្វីដែលពាក់ព័ន្ធគឺថា ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងអ្វីដែល អោ អាន បានចូលរួមគឺជា "បទចោទព្រហ្មទណ្ឌដ៏ធ្ងន់ធ្ងរបំផុតក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ"[1083]។ សហព្រះរាជអាជ្ញាអន្តរជាតិ កត់សម្គាល់បន្ថែមទៀតថា វិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងការគណនា ចំនួនជនរងគ្រោះគឺក្នុងកម្រិតអប្បបរមា ដោយយកចំនួនទាប ក្នុងករណីមានភាពមន្ទិល និងចំពោះជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍លើជនជាតិចាម នៅតំបន់៤២ និង៤៣បានលើកទឡ្ហីករណ៍ថា ការសន្និដ្ឋានដ៏សមហេតុផលគឺថា ចារីផ្ទាល់ដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍អនុវត្តតាមបញ្ជារបស់ កែ ពក និង កម្មាភិបាល ប.ក.ក ផ្សេងៗទៀតដែលសុទ្ធតែជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម[1084]។

៥៤៩. នៅក្នុងការឆ្លើយតប សហមេធាវីលើកឡើងថា សហព្រះរាជអាជ្ញាអន្តរជាតិខកខានមិនបានផ្ដល់ ភស្តុតាងគាំទ្រទឡ្ហីករណ៍ឬទាញអំណះអំណាងរបស់សហមេធាវី និង ផ្ទុយទៅវិញ "ជ្រើសរើស ដោយមិនត្រឹមត្រូវ"ចំពោះទឡ្ហីករណ៍របស់ពួកគេ[1085]។ សហមេធាវីលើកអំណះអំណាងថា សហព្រះរាជអាជ្ញាអន្តរជាតិខកខានមិនបានជំទាស់អង្គហេតុ ដែលថាភស្តុតាងដែលបានផ្ដល់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ សឹងតែទាំងអស់បានពីតំបន់៤១ និងថាពុំមានភស្តុតាងគ្រប់គ្រាន់គាំទ្រដល់ការគណនាចំនួនជនរងគ្រោះនៅភូមិភាគកណ្ដាលឬតំបន់៤១[1086]។ សហមេធាវី តវ៉ាថា សហព្រះរាជអាជ្ញាអន្តរជាតិអះអាងដោយមិនត្រឹមត្រូវ ជាការផ្ទុយទៅនឹងយុត្តិសាស្ត្រ អ.វ.ត.ក ថា "កត្តានានាដូចជា ដែនកំណត់ភូមិសាស្ត្រ និងចំនួនជនរងគ្រោះមិនសូវសំខាន់ជាងស្ថានទម្ងន់នៃបទឧក្រិដ្ឋ ដែលត្រូវបានចោទប្រកាន់ទេ ហើយថា អំពើប្រល័យ

---

[1083] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៩០ យោងទៅ បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ២២៧។ ប្រតិចារឹកសវនាការសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626106 ទំព័រ ៥២:១៩ ដល់ ៥២:២២។

[1084] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៩០ យោងទៅ បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៩០, ១៩៤, ១៩៥, ៦០៧-៦១៥, ៦២៣-៦២៨។ ប្រតិចារឹកសវនាការសំណុំរឿង ០០៤/២ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/8.1, ERN 01626037-01626038 ទំព័រ ៤៧:២៣ ដល់ ៤៨:៨ 01626038-01626039 ទំព័រ ៤៩:១៦ ដល់ ៥០:១ 01626039 ទំព័រ ៥០:១២ ដល់ ៥០:១៨។ ប្រតិចារឹកសវនាការសំណុំរឿង ០០៤/២ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/10.1, ERN (EN) 01626142-01626143 ទំព័រ ១៥:២៣ ដល់ ១៦:១១។

[1085] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៤៥។

[1086] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៤៤-៤៥។

ពូជសាសន៍នៅក្នុងតំបន់៤២ និង តំបន់៤៣ អាចសន្និដ្ឋានបាន និងកើតឡើងដោយសារតែ អោ អាន"[1087]។

## ២. ការពិភាក្សា

៥៥០. ចៅក្រមអន្តរជាតិសម្រេចថា មិនមែនជាការមិនសមហេតុផលសម្រាប់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលសម្រេចថា ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់មានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ក្នុងការ សន្និដ្ឋានថា អោ អាន ស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[1088]។

៥៥១. ទីមួយ ពាក់ព័ន្ធនឹង "តំបន់ភូមិសាស្ត្រតូច"[1089] ដែលក្នុងនោះរួមមាន ក្នុងការប្រៀបធៀបទៅនឹងតំបន់ នានាដែលគ្រប់គ្រងដោយ កែ ពក និង តាម៉ុក ចៅក្រមអន្តរជាតិមិនយល់ឃើញថា តំបន់ ភូមិសាស្ត្រតូចមួយដែលមានអំពើឧក្រិដ្ឋនៅក្នុងនោះផ្ទាល់ ឬដោយប្រៀបធៀបជាមួយជនល្មើសដទៃទៀតត្រូវ "គាំទ្រ"[1090] ការសម្រេចលើការទទួលខុសត្រូវខ្ពស់បំផុតនោះទេ។ ចៅក្រមអន្តរជាតិអះអាងថា ទោះបីជានៅកន្លែងដែលឧក្រិដ្ឋកម្មបាចសាចនៅក្នុងតំបន់ "ដែលមានកម្រិតភូមិសាស្ត្រ"ក៏ដោយ បទល្មើសធ្ងន់ធ្ងរអាចត្រូវបានពិចារណា ក្នុងបរិបទនៃស្ថានទម្ងន់[1091]។ ចៅក្រមអន្តរជាតិរម្លឹកថាការពិចារណាដែលអាចត្រូវបានវាយតម្លៃត្រឹមត្រូវក្នុងការកំណត់ស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលបានចោទ ត្រូវបានរៀបរាប់ច្បាស់លាស់ និង

[1087] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៤៤-៤៥។

[1088] ចៅក្រមអន្តរជាតិរម្លឹកថា ដូចមានចែងនៅក្នុងមាត្រា ១ និងមាត្រា ២ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ការសម្រេចអំពីយុត្តាធិការបុគ្គលតម្រូវឱ្យមានការកំណត់អត្តសញ្ញាណ "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" សូមមើល ឧទាហរណ៍ សេចក្តីពិចារណាទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) មតិយោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣២១ (រៀបរាប់ថា នេះជាការតម្រូវឱ្យមានការវាយតម្លៃទាំងទៅលើភាពធ្ងន់ធ្ងររបស់ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ឬដាក់បន្ទុក និងកម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យ។ ការវាយតម្លៃនេះត្រូវធ្វើឡើងដោយផ្អែកទាំងទៅលើបរិមាណវិស័យ និងគុណវិស័យ ទៅតាមករណីជាក់ស្តែងនីមួយៗ ដោយពិចារណាទៅលើបរិបទទូទៅ និងកាលៈទេសៈផ្ទាល់ខ្លួនរបស់ជនសង្ស័យ)។

[1089] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៥៨។

[1090] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៥៨។

[1091] សូមមើល ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៧០៦-៧០៨ (ដែលក្នុងកថាខណ្ឌទាំងនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិពិចារណាទៅលើលក្ខណៈ និងផលប៉ះពាល់នៃឧក្រិដ្ឋកម្មរបស់ អោ អាន ប្រឆាំងនឹងប្រជាជនចាម)។ សូមមើលផងដែរ ឧទាហរណ៍ ("សាលក្រម Kunarac និងអ្នកផ្សេងទៀត (តុលាការ ICTY)") កថាខណ្ឌ ៨៥៨ (អង្គជំនុំជម្រះពិចារណាទៅលើតំបន់ភូមិសាស្ត្រដ៏តូចនៃ Foča និងរកពុំឃើញមានកំហុសណាមួយក្នុងការពិចារណាទៅលើមូលដ្ឋានឧក្រិដ្ឋនេះទេ ដោយអះអាងថា ដោយពុំមានជនជាប់ណាម្នាក់ជាអ្នកបញ្ជា ហើយ "ឧក្រិដ្ឋកម្មរបស់ពួកគេត្រូវបានកំណត់តាមលក្ខណៈភូមិសាស្ត្រ" បទល្មើសធ្ងន់ធ្ងរអាចត្រូវបានពិចារណា "នៅក្នុងបរិបទនៃការពិចារណាទៅលើភាពធ្ងន់ធ្ងន់នៃបទល្មើស")។

01635063



ជាប់ទាក់ទងនឹងកត្តានានាដូចជា លក្ខណៈ និងទំហំនៃ ឧក្រិដ្ឋកម្មដែលរងការចោទប្រកាន់ឬត្រូវបានចោទប្រកាន់ ផលប៉ះពាល់លើជនរងគ្រោះ ចំនួនជនរងគ្រោះ វិសាលភាពភូមិសាស្ត្រនិងពេលវេលា និងរបៀបដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត ព្រមទាំងចំនួនហេតុការណ៍ដាច់ពីគ្នានានា[1092]។ វិសាលភាពភូមិសាស្ត្រនៃឧក្រិដ្ឋកម្មគឺជាពហុកត្តា ប៉ុន្តែមិនមែនជាកត្តាកំណត់នោះទេ។

៥៥២. នៅក្នុងរឿងក្តីនេះ ចៅក្រមអន្តរជាតិកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានវាយតម្លៃ លើលក្ខណៈនៃបទល្មើសធ្ងន់ធ្ងរ និងបានពិនិត្យពិច័យកត្តាពាក់ព័ន្ធក្នុងការវាយតម្លៃស្ថានទម្ងន់៖ គាត់សម្រេច*ក្នុងចំណោមបញ្ហាផ្សេងៗ*ថា "បន្ថែមពីតួនាទីខ្ពស់ជាផ្លូវការរបស់ អោ អាន ស្ថានទម្ងន់នៃសកម្មភាពរបស់គាត់និងភាពធ្ងន់ធ្ងរនៃផលប៉ះពាល់ដោយសារសកម្មភាពរបស់គាត់ ជាពិសេស មកលើសហគមន៍ជនជាតិចាម [...] ផ្តល់យុត្តិកម្មសម្រាប់សេចក្តីសន្និដ្ឋានថាគាត់គឺជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"។[1093] ការណ៍នេះ រួមទាំងការពិចារណាលើវិសាលភាពភូមិសាស្ត្រនៃការទទួលខុសត្រូវរបស់ អោ អាន និង "តួនាទីច្បាស់លាស់របស់គាត់ក្នុងការរៀបចំនិងអនុវត្តការបំបាត់ជនជាតិចាមនៅភូមិភាគកណ្តាលទូទាំងតំបន់ ៤១ ជាពិសេស"[1094]។ អាស្រ័យហេតុនេះ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសឆ្គងក្នុងការសម្រេចពីស្ថានទម្ងន់គ្រប់គ្រាន់នៅក្នុងយុត្តាធិការបុគ្គលទេ ពោលគឺ ទោះបីជានៅក្នុង "តំបន់ភូមិសាស្ត្រតូច"ក៏ដោយ។

៥៥៣. ទីពីរ ទោះបីជាមានការគណនាចំនួនជនរងគ្រោះ "កម្រិតទាប" ក៏ដោយ[1095] ប៉ុន្តែចៅក្រមអន្តរជាតិមិនយល់ស្របនឹងអំណះអំណាងរបស់សហមេធាវីដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិប្រើប្រាស់វិធីសាស្ត្រមួយ "ដែលផ្អែកលើការទាយស្មាន""[1096] ឬថាគាត់មិនបានផ្តល់ភស្តុតាងគ្រប់

---

[1092] សេចក្តីពិចារណាទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) មតិយោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣២៧។

[1093] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៧០៦។

[1094] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៧០៨ (លើសពីនេះទៀត ចៅក្រមអន្តរជាតិសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសក្នុងការកំណត់ពីភាពធ្ងន់ធ្ងរទេ ដោយពិចារណា និងសន្និដ្ឋានថា "ការបំបាត់ជនជាតិចាមនៅក្រោមឥទ្ធិពលរបស់ អោ អាន ក្រោយពីគាត់កាន់តំណែងនៅភូមិភាគកណ្តាល គឺកើនឡើងមិនឈប់ឈរហួតដល់ចំណុចកំពូល គ្មានត្រាប្រណី និងមានលក្ខណៈជាប្រព័ន្ធយ៉ាងសាហាវ")។

[1095] សូមមើល ខាងលើ កថាខណ្ឌ ៨៦។

[1096] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៥៩។

គ្រាន់អំពីចំនួនជនរងគ្រោះសម្រាប់"ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងតំបន់ ៤១ និងភូមិភាគកណ្តាល។"[1097]

៥៥៤. ចៅក្រមអន្តរជាតិយល់ឃើញថា ជាការច្បាស់ថា ចំនួនជនរងគ្រោះ ជនជាតិចាមចំនួន ១៧.១១៥[1098] គឺមានឫសគល់ចេញពីភស្តុតាង ពោលគឺមិនមែន "ការទាយស្មាន" ឡើយ[1099]។ អង្គជំនុំជម្រះ ពិចារណាជាពិសេសលើដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ឧបសម្ព័ន្ធ IV - ជនរងគ្រោះចាម ដែលតារាងលម្អិតនេះដែលផ្តល់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិរៀបរាប់អំពីប្រភពនៃភស្តុតាងដែលគាត់យកជាមូលដ្ឋានសម្រាប់ចំនួនជនរងគ្រោះ ក្នុងនោះរួមមាន ជាអាទិ៍ តំបន់(៤១ ៤២ ឬ៤៣) ស្រុក ភូមិ និង ឃុំដែលត្រូវបានចោទប្រកាន់ អត្តសញ្ញាណសាក្សី សំណួរជាក់លាក់ដែលបានលើកឡើង និងចម្លើយតបពិតប្រាកដពាក់ព័ន្ធនឹងចំនួនជាក់លាក់នៃជនរងគ្រោះចាមដែលបានរៀបរាប់[1100]។

៥៥៥. ចៅក្រមអន្តរជាតិរម្លឹកបន្ថែមទៀតថា ពុំមានលក្ខខណ្ឌបែបគណិតវិទ្យាសម្រាប់ចំនួនមនុស្សស្លាប់ដែលភស្តុតាងត្រូវតែលើសក្នុងការវាយតម្លៃភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មនោះទេ សម្រាប់កំណត់យុត្តាធិការបុគ្គល[1101]។ ជាលទ្ធផល ការតវ៉ារបស់សហមេធាវីដែលថា "ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បី

---

[1097] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៥៩។

[1098] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៨១៥។

[1099] សូមមើល ក្នុងចំណោមផ្សេងទៀត សំណុំរឿង ០០៤/២ ឧបសម្ព័ន្ធ ៤ នៃដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ និងជាភាសាខ្មែរនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ឯកសារ D360.4 ("ឧបសម្ព័ន្ធ ៤ នៃនៃដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360.4)")។ សូមមើលផងដែរ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ១៣៨ (ឧទាហរណ៍ បញ្ជាក់ថា "ចំពោះទីតាំង ឬសេណារីយ៉ូឧក្រិដ្ឋកម្មទាំងអស់ យើងប្រកាន់យកតួលេខអភិរក្សនិយម គឺចំនួនជនរងគ្រោះជាអប្បបរមាដែលអាចធ្វើការប៉ាន់ស្មានបាន*តាមរយៈភស្តុតាង* [...]") (គូសបញ្ជាក់បន្ថែម)។

[1100] ឧបសម្ព័ន្ធ ៤ នៃនៃដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360.4)។

[1101] សូមមើលឧទាហរណ៍ សេចក្តីពិចារណាទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) មតិយោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣២១។ ICTY, ព្រះរាជអាជ្ញា និង Karadžić , IT-95-5/18-AR98bis.1.សាលក្រម.ឧទ្ធរណ៍.១១ កក្កដា ២០១៣។ សូមមើលផងដែរ ឧទាហរណ៍ សាលដីកា Karadžić ៩៨ស្ទួន (តុលាការ ICTY) កថាខណ្ឌ ២៣ (អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា នៅក្នុងរឿងក្តី Karadžić អង្គជំនុំជម្រះសាលាដំបូងបានពិចារណាយ៉ាងច្បាស់លាស់ (និងត្រឹមត្រូវ) ថា "ការកំណត់ថាតើមានភស្តុតាងអាចគាំទ្រដល់ការផ្តន្ទាទោសពីបទប្រល័យពូជសាសន៍ដែរឬទេ មិនតម្រូវឱ្យមានការវាយតម្លៃជាតួលេខអំពីចំនួនប្រជាជនដែលត្រូវបានសម្លាប់ និង

គាំទ្រដល់ការគណនា [របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ] ទៅលើជនរងគ្រោះ"[1102] ត្រូវតែបដិសេធចោល។

៥៥៦. ទីបី ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានខកខានមិនបានបំពេញ "លក្ខខណ្ឌតម្រូវគតិយុត្ត"ដើម្បី "កំណត់ថា អោ អាន ទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍" ក្នុងការវាយតម្លៃស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម សម្រាប់គោលបំណងនៃយុត្តាធិការបុគ្គល នោះឡើយ។

៥៥៧. ចៅក្រមអន្តរជាតិកត់សម្គាល់ជាបឋមថា ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចោទប្រកាន់ អោ អាន ចំពោះអំពើប្រល័យពូជសាសន៍លើជនជាតិចាមក្នុងខេត្តកំពង់ចាម តាមរយៈសហឧក្រិដ្ឋកម្មរួម និង ជាជម្រើសម្យ៉ាងទៀត តាមរយៈការរៀបចំផែនការ ការបញ្ជា ឬការញុះញង់ និងជាជម្រើសបន្ថែមទៀត តាមរយៈការទទួលខុសត្រូវរបស់ថ្នាក់លើ[1103]។ ចៅក្រមអន្តរជាតិយល់ឃើញទៀតថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសឆ្គងឡើយក្នុងការរកឃើញ ថា មានភស្តុតាងគ្រប់គ្រាន់បង្ហាញថា អោ អាន ទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍លើ ជនជាតិចាមទូទាំងភូមិភាគកណ្តាល តាមរយៈសហឧក្រិដ្ឋកម្មរួម។

៥៥៨. ចៅក្រមអន្តរជាតិសម្រេចថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបង្ហាញគ្រប់គ្រាន់នូវការរំលេចភស្តុតាង ពាក់ព័ន្ធនឹងការភ្ជាប់ អោ អាន ទៅនឹងឧក្រិដ្ឋកម្មនៅក្នុងតំបន់៤១ តំបន់៤២ និង តំបន់៤៣ ក្នុងនោះរួមមានការណ៍ដែលថា អោ អាន បានបង្កើតផ្នែកមួយនៃគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម ក្នុងការសម្លាប់ប្រជាជនចាម[1104] និងសម្រេចថា ភស្តុតាងបង្ហាញថា អំពើប្រល័យពូជសាសន៍នៅតំបន់៤២

---

គ្មានការកំណត់ចំនួនទេ")។

[1102] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៤៥។

[1103] ការអះអាងរបស់សហមេធាវីទាក់ទងនឹងទំនួលខុសត្រូវថ្នាក់លើនឹងមិនត្រូវបានយកមកពិចារណាបន្ថែមទេ ពីព្រោះសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានចោទប្រកាន់ពីទំនួលខុសត្រូវថ្នាក់លើនៅក្នុងតំបន់ ៤២ និង ៤៣ ទេ។ (សូមមើល ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៨៤៩ ("មិនមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា អោ អាន មានអំណាចគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពទៅលើបណ្តាជនដៃដល់នៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ នៅក្នុងតំបន់ ៤២ និង តំបន់ ៤៣") លើសពីនេះទៀត ចៅក្រមអន្តរជាតិកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិចោទប្រកាន់តែ JCE I ប៉ុណ្ណោះ មិនមែន JCE II ឬ JCE III (ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៤០៩)។

[1104] សូមមើលឧទាហរណ៍ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៩៤-៩៨ (អោ អាន មានចេតនាប្រល័យពូជសាសន៍ នៅក្នុងគោលបំណងរួម រួមទាំងចេតនាជាក់លាក់ដើម្បីកម្ទេចក្រុមជនជាតិចាមនៅកំពង់ចាម)។ ដីកា

និង តំបន់៤៣ ស្របទាំងស្រុងទៅនឹងគោលបំណងរួមនេះ[1105] ដែលបង្កើតលំនាំទូទៅមួយនៃការកំណត់គោលដៅលើជាតិពន្ធុនៅក្នុងភូមិភាគកណ្តាលនៅពេលវេលាដែលពាក់ព័ន្ធ។ លេខាតំបន់៤២ និងតំបន់៤៣ ក៏ត្រូវបានកំណត់ថាជាសមាជិកសហឧក្រិដ្ឋកម្មរួម និងបានអនុវត្តគោលនយោបាយប្រល័យពូជសាសន៍ក្នុងការ "កម្ទេច"ជនជាតិចាម ដូចដែល អោ អាន បានប្រព្រឹត្តនៅក្នុង

---

ដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ១៩៥ (ចាប់ពីប្រហែលចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ និងរហូតដល់យ៉ាងហោចណាស់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ កែ ពក, អោ អាន និងកម្មាភិបាលបក្សកុម្មុយនីស្តផ្សេងទៀត មានគោលបំណងរួមក្នុងការកំណត់គោលដៅក្រុមជាក់លាក់ រួមទាំងជនជាតិចាម នៅក្នុងភូមិភាគកណ្តាលនៃកម្ពុជាប្រជាធិបតេយ្យ) ។ សូមមើលផងដែរ ឧទាហរណ៍ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ ឯកសារ D117/70, ERN 01046794 (ឆ.២៣) ("ស៖ តើអ្នកស្រីនៅចាំឈ្មោះកម្មាភិបាលណាខ្លះ ដែលត្រូវបានចាត់តាំងឲ្យកាន់កាប់តំបន់ និងស្រុកនានាក្នុងភូមិភាគកណ្តាលដែរឬទេ? ឆ.២៣៖ [...] ខ្ញុំចាំតែតំបន់ ៤១ ដែលមានតាអាន ជាលេខា")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ D117/71, ERN 01046804 (ឆ.១៩) ("កែ ពក បានតែងតាំងតាអានឲ្យកាន់តំបន់ ៤១")។ សូមមើលផងដែរ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ D117/18, ERN 00893170 (ឆ.១)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៣ ឯកសារ D219/138, ERN 01056053 (ឆ.៦៤)។

[1105] សូមមើលឧទាហរណ៍ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៣០៥ (ពណ៌នាពីអំណាចរបស់ អោ អាន ក្នុងការចាប់ និងសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ និងមានបែបបទ រួមទាំងជនជាតិចាម និងពីរបៀបដែល "ការបោសសម្អាតបានធ្វើឡើងក្នុងលក្ខណៈប្រហាក់ប្រហែលគ្នានៅតំបន់ ៤២ និងតំបន់ ៤៣")។ សូមមើលផងដែរ ក្នុងចំណោមផ្សេងទៀត ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៦២៣-៦២៩ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិអះអាងថា គំរូនៃភស្តុតាងនៅទូទាំងតំបន់ រួមមាន តំបន់ ៤១ (ស្រុកកំពង់សៀម ស្រុកកងមាស ស្រុកព្រៃឈរ) និងតំបន់ ៤២ (ស្រុកស្ទឹងត្រង់ ស្រុកបារាយណ៍ ស្រុកចំការលើ) និងតំបន់ ៤៣ (ស្រុកសន្ទុក) "បញ្ជាក់ថា ការចាប់ខ្លួន ការសម្លាប់ និងការបាត់ខ្លួនជនជាតិចាម បានកើតឡើងតាមគំរូស្រដៀងគ្នាមួយចំនួននៅទូទាំងភូមិភាគកណ្តាល ដែលនេះបង្ហាញថាមានការសម្របសម្រួលផែនការដើម្បីសម្លាប់ជនជាតិចាមទ្រង់ទ្រាយធំ ហើយពួកគេជាមុខសញ្ញា មិនមែនដោយសារមានកំហុសទេ ប៉ុន្តែដោយសារថាពាក់ព័ន្ធនឹងជាតិពិន្ទុ និងសាសនារបស់ពួកគេ។ យ៉ាងហោចណាស់ មានប្រតិបត្តិការទ្រង់ទ្រាយធំចំនួនពីរ រៀបចំឡើងដើម្បីសម្លាប់ជនជាតិចាម [...] ក្រោយពីកម្មាភិបាលភូមិភាគនិរតីមកដល់៖ ទីមួយ នៅឆ្នាំ១៩៧៧ ការសម្លាប់ជនជាតិចាមជាទូទៅដែលយកមកពីភូមិ និងកងនានានៅទូទាំងភូមិភាគកណ្តាល ហើយភាគច្រើនលើសលុបនៅខេត្តកំពង់ចាម និងទីពីរ នៅឆ្នាំ១៩៧៨ ការសម្លាប់ជនជាតិចាមចំនួនជាច្រើននាក់ ដែលត្រូវផ្លាស់ពីភូមិភាគបូព៌ា ទៅភូមិភាគកណ្តាល")។ សូមមើលផងដែរ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៦១ (សន្និដ្ឋានថា អោ អាន បានចូលរួមក្នុងការប្រជុំថ្នាក់ភូមិភាគដើម្បីរៀបចំផែនការបោសសម្អាតជនជាតិនៅទូទាំងភូមិភាគកណ្តាល តំបន់ ៤១, ៤២ និង ៤៣)។ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៦០៧ (ថ្នាក់ដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា នៅដើមឆ្នាំ១៩៧៧ សន្និដ្ឋាន "ប្រជាជនចាមមិនអាចធ្វើការអប់រំរៀនសូត្របាន ហេតុដូច្នេះ ត្រូវលុបបំបាត់ពួកគេចោលទាំងស្រុង")។

តំបន់៤១ ដែរ[1106]។ ឧទាហរណ៍ ពាក់ព័ន្ធនឹងការបោសសម្អាតនៅក្នុងតំបន់៤២ សាក្សីម្នាក់ដែលរស់រានមានជីវិត ឈ្មោះ ស្អាន កាស បានរៀបរាប់អំពីការចាប់ខ្លួន និងសម្លាប់ជាប្រព័ន្ធ និងរបៀបដែលការបញ្ជាឱ្យសម្លាប់ចេញមកពីថ្នាក់ស្រុកនៃតំបន់៤២[1107]។ អាស្រ័យហេតុនេះ គំរូនៃភស្តុតាងបង្ហាញយ៉ាងគ្រប់គ្រាន់ តាមរយៈភស្តុតាងប្រយោលនិង/ឬភស្តុតាងដែលមានការបញ្ជាក់ទាំងអស់ថា អំពើប្រល័យពូជសាសន៍នៅក្នុងតំបន់៤២ និង ៤៣ គឺមានការភ្ជាប់ទំនាក់ទំនងគ្រប់គ្រាន់ទៅនឹងសមាជិកសហឧក្រិដ្ឋកម្មរួមដែលគ្រប់គ្រងតំបន់ទាំងនោះ ជាផ្នែកមួយនៃគោលបំណងរួមដែលពង្រឹងដោយការចូលរួមចំណែកដ៏សំខាន់របស់ អោ អាន[1108]។ ចៅក្រមអន្តរជាតិយល់ឃើញថា អំពើប្រល័យពូជសាសន៍លើជនជាតិចាមនៅភូមិភាគកណ្តាល តាមរយៈសហឧក្រិដ្ឋកម្មរួម គឺត្រូវបានកំណត់ត្រឹមត្រូវនៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) និងបង្ហាញយ៉ាងគ្រប់គ្រាន់តាមរយៈភស្តុតាងរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[1109]។ ចៅក្រមអន្តរជាតិមិនយល់ស្របថា មានកំហុសឆ្គងក្នុងការពិចារណាលើជនរងគ្រោះនៃតំបន់៤២ និង តំបន់៤៣ នោះឡើយ។

៥៥៩. ចៅក្រមអន្តរជាតិសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសក្នុងការកំណត់ថា ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ មានស្ថានទម្ងន់គ្រប់គ្រាន់នៅក្នុងបរិបទនៃយុត្តាធិការបុគ្គលរបស់

---

[1106] សូមមើលឧទាហរណ៍ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២៥២-២៥៥ (រៀបរាប់ពីការចាត់តាំង អោ អាន ជាអនុលេខា និងការវិវត្តនៃថ្នាក់ដឹកនាំនៅក្នុងតំបន់ ៤២ និងតំបន់ ៤៣ រួមមានឧទាហរណ៍ "សមាជិកផ្សេងទៀតនៃគណៈអចិន្ត្រៃយ៍ភូមិភាគកណ្តាល រួមមាន អឿន ទទួលបន្ទុកតំបន់ ៤២ និង ចាន់ ទទួលបន្ទុកតំបន់ ៤៣")។ សូមមើលផងដែរ ឧទាហរណ៍ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៣០៥។ សូមមើលឧទាហរណ៍ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៦១៤ (សន្និដ្ឋានថា សេចក្តីប្រកាសរបស់បក្សកុម្មុយនីស្តបង្ហាញពីគោលនយោបាយកម្ទេចជនជាតិចាម និងថា ក្រោយពេល អោ អាន និងកម្មាភិបាលភូមិភាគនិរតីមកដល់ ការចាប់ខ្លួន និងសម្លាប់ជនជាតិចាមត្រូវបានកំណត់គោលដៅនៅក្នុងស្រុកយ៉ាងហោចណាស់ចំនួន ១០ ក្នុងភូមិភាគកណ្តាល (រួមមាន ស្រុកចំនួន ៥ នៅក្នុងតំបន់ ៤១, បី នៅក្នុងតំបន់ ៤២ និង ពីរ នៅក្នុងតំបន់ ៤៣)។

[1107] សូមមើលឧទាហរណ៍ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៦៧០ ដកស្រង់ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្អាន កាស ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៦ ឯកសារ D219/767, ERN 01247469 (ឆ.៥១-ឆ.៥២)។

[1108] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៦២។

[1109] ដោយហេតុថា បញ្ហាលក្ខខណ្ឌតម្រូវនៃយុត្តាធិការបុគ្គលដែលសហមេធាវីបានលើកឡើងនាពេលនេះ សមស្របជាមួយ JCE ដែលជាទម្រង់ដំបូងនៃការទទួលខុសត្រូវដែលត្រូវបានចោទប្រកាន់នោះ ចៅក្រមអន្តរជាតិនឹងមិនធ្វើការវាយតម្លៃបន្ថែមទៅលើការរៀបចំផែនការ ការបញ្ជា ឬការញុះញង់ ដែលអាចមានពាក់ព័ន្ធនឹងទំនាក់ទំនងរបស់ អោ អាន ជាមួយនឹងអំពើប្រល័យពូជសាសន៍នៅក្នុងតំបន់ ៤២ និងតំបន់ ៤៣ ទេ។

អ.វ.ត.ក និងសម្រេចបដិសេធមូលដ្ឋានទី៧។

## ង. មូលដ្ឋានទី៨÷ ការអនុវត្តច្បាប់ទំនៀមទំលាប់អន្តរជាតិ រំលោភទៅលើគោលការណ៍នីត្យានុកូលភាព

### ១. សារណា

៥៦០. សសហាមេធាវីការពារក្ដីលើកឡើងថា សហចៅក្រមអន្តរជាតិអនុវត្តខុសលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ ពីព្រោះគាត់ពឹងផ្អែកខ្លាំងពេកទៅលើ "ប្រភពដែលមិនត្រឹមត្រូវនៃ [ច្បាប់ទំនៀមទម្លាប់ អន្តរជាតិ]" ពីតុលាការមិនអចិន្ត្រៃយ៍ និងខកខានមិនបាន "បង្ហាញការអនុវត្តរបស់រដ្ឋដែលទូលំ ទូលាយ និងស៊ីសង្វាក់គ្នា" ដែលថា ការប្រព្រឹត្តិដែលបានចោទប្រកាន់ត្រូវបានហាមឃាត់ក្នុងអំឡុង ឆ្នាំ១៩៧៥-១៩៧៩[1110] ។ តាមការអះអាង សហចៅក្រមស៊ើបអង្កេតអន្តរជាតិ "អនុម័តយកដោយមិន មានភាពសកម្មនូវការអះអាងរបស់ [ច្បាប់ទំនៀមទម្លាប់អន្តរជាតិ] ដែលមាននៅក្នុងសេចក្ដីសម្រេចតាមផ្លូវតុលាការរបស់តុលាការមិនអចិន្ត្រៃយ៍" និង "សំអាងលើយុត្តិសាស្ត្រ អ.វ.ត.ក ដែលពឹងផ្អែកខ្លាំងពេកលើតុលាការមិនអចិន្ត្រៃយ៍"[1111]។ សហមេធាវីអះអាងថា តុលាការមិនអចិន្ត្រៃយ៍មិនគួរឲ្យជឿបានទេ ដោយហេតុថា (i) តុលាការទាំងនោះមិនបានកើតចេញពីការចរចាពហុរដ្ឋជាភាគី និងមិនតំណាងឲ្យការព្រមព្រៀងជាអន្តរជាតិលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ (ii) តុលាការមិនអចិន្ត្រៃយ៍ត្រូវបានបង្កើតឡើងដើម្បីដោះស្រាយជម្លោះជាក់លាក់ (ក្រោយឆ្នាំ១៩៧៥-១៩៧៩) (iii) តុលាការមិនអចិន្ត្រៃយ៍បានរក្សាលទ្ធភាពក្នុងការងាកចេញពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ (iv) តុលាការមិនអចិន្ត្រៃយ៍ប្រកាន់យកវិធីសាស្ត្រទស្សនៈច្បាប់ (ដែលកាត់បន្ថយតម្រូវការចាំបាច់នៃការអនុវត្តរបស់រដ្ឋ) និង (v) តុលាការមិនអចិន្ត្រៃយ៍បំពេញចន្លោះប្រហោងច្បាប់ដោយភាពច្នៃប្រឌិតតាមផ្លូវតុលាការ ដោយហេតុថា រចនាសម្ព័ន្ធនីតិបញ្ញត្តិនៅមានភាពខ្វះខាត[1112]។

៥៦១. លើសពីនេះទៀត សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ "ពិចារណាត្រួសៗ" លើច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងថា ច្បាប់លក្ខខន្តិកៈទីក្រុងរ៉ូមត្រូវបានតាក់តែងចងក្រង ដោយ

[1110] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៦៦-១៦៨។ សំណុំរឿង ០០៤/០២ ប្រតិចារិត ២០ មិថុនា ២០១៩ ឯកសារ D359/9.1 D360/18.1 ERN (EN) 01625294-01625296, pp. 35:24 to 37:11។

[1111] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៦៧។សំណុំរឿង ០០៤/០២ ប្រតិចារិត ២០ មិថុនា ២០១៩ ឯកសារ D359/9.1 & D360/18.1, ERN (EN) 01625296, pp. 37:12 to 37:17។

[1112] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៦៨។ សំណុំរឿង ០០៤/០២ ប្រតិចារិត ២០ មិថុនា ២០១៩ ឯកសារ D359/9.1 & D360/18.1, ERN (EN) 01625296-01625297, pp. 37:19 to 38:16។

សហគមន៍អន្តរជាតិ និងអនុម័តដោយ "រដ្ឋជាច្រើន រួមទាំងកម្ពុជាផង"[1113]។ សហមេធាវី អះអាងថា កំហុសឆ្គងលើច្បាប់ទំនៀមទម្លាប់អន្តរជាតិចាំបាច់ត្រូវតែពិនិត្យមើលរួមគ្នា ថាជាការ ខកខានរួមក្នុងការមិនគោរពគោលការណ៍នីត្យានុកូលភាព"[1114]។

៥៦២. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា មូលដ្ឋានទី ៨ គួរតែត្រូវបដិសេធ ចោលភ្លាមៗ ដោយហេតុថា សហមេធាវីធ្វើបណ្តឹងទូទៅអំពីវិធីដែលសហចៅក្រមអន្តរជាតិ វិភាគលើច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយពុំបានកំណត់ឱ្យឃើញពីកំហុសអង្គច្បាប់ពាក់ព័ន្ធណា មួយ ឬព្យសនកម្ម ឬការប៉ះពាល់លើការសម្រេចផ្លូវច្បាប់ជាក់លាក់ណាមួយឡើយ[1115]។ សហព្រះ រាជអាជ្ញាអន្តរជាតិជំទាស់ថា លក្ខន្តិកៈទីក្រុងរ៉ូមមិនប្រាកដថាឆ្លុះបញ្ចាំងពីច្បាប់ទំនៀមទម្លាប់ អន្តរជាតិឡើយ[1116] និងថា យុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍បានពឹងផ្អែកលើច្បាប់ក្រោយ ពីសង្គ្រាមលោកលើកទី២[1117]។

៥៦៣. នៅក្នុងការឆ្លើយតប សហមេធាវីដោះស្រាយលើមូលដ្ឋានទី៨ ទី៩ ទី១១ ទី១២ ទី១៤ ទី១៥ និងទី១៦ (i)[1118] រួមជាមួយគ្នា និងមានសេចក្តីសង្ខេបនៅក្នុងផ្នែកនេះដូចខាងក្រោម[1119]។

៥៦៤. សហមេធាវីលើកឡើងថា សហព្រះរាជអាជ្ញាអន្តរជាតិខកខានមិនបានបដិសេធការតវ៉ារបស់ខ្លួនថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឆ្គងដែលមិនគោរពភារកិច្ចរបស់ខ្លួនក្នុងការបង្ហាញ អត្ថិភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងឆ្នាំ១៩៧៥-១៩៧៩[1120]។ ផ្ទុយទៅវិញ សហមេធាវី រក្សាជំហរថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិប្រកាន់យកវិធីសាស្ត្រមិនត្រឹមត្រូវមួយក្នុងការ បកស្រាយ និងអនុវត្ត

---

[1113] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៦៩។ សំណុំរឿង ០០៤/០២ ប្រតិចារិត ២០ មិថុនា ២០១៩ ឯកសារ D359/9.1 & D360/18.1, ERN (EN) 01625297-01625299, pp. 38:18 to 40:6។

[1114] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៦៧-១៧០។ សំណុំរឿង ០០៤/០២ ប្រតិចារិត ២០ មិថុនា ២០១៩ ឯកសារ D359/9.1 & D360/18.1, ERN (EN) 01625294-01625296, pp. 35:24 to 37:4។

[1115] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៩២។

[1116] ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1 ERN (EN) 01625344-01625345, pp. 85:18 to 86:15។

[1117] ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1 ERN (EN) 01625345-01625346, pp. 86:2 to 87:5។

[1118] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៤៦-៥២។

[1119] ចំណុចនេះពាក់ព័ន្ធនឹងមូលដ្ឋាន ៨, ៩, ១១, ១២(i), ១៥(i) និង ១៦(ii)(iii) ដែលអាចទទួលយកបាន។

[1120] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៤៦។

ច្បាប់ទំនៀមទម្លាប់អន្តរជាតិ[1121]។ សហមេធាវីជំទាស់ទៀតថា ជំហររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ដែលផ្ទេរបន្ទុកនោះទៅឲ្យសហមេធាវីក្នុងការបង្ហាញអត្ថិភាពនៃច្បាប់ ទំនៀមទម្លាប់អន្តរជាតិទៅវិញនោះ នៅពេលដែលបន្ទុកដែលសមស្របគ្រាន់តែត្រូវបង្ហាញកំហុស អង្គច្បាប់មួយតែប៉ុណ្ណោះ[1122]។ សហមេធាវី អះអាងថា បើទោះជាច្បាប់តុលាការព្រហ្មទណ្ឌ អន្តរជាតិមិនបានឈានដល់ឋានៈជាច្បាប់ទំនៀមទម្លាប់ អន្តរជាតិដែលមិនមានការជំទាស់ក្តី "ត្រឹមតែវត្តមានរបស់ច្បាប់នេះ រួមជាមួយការងាកចេញពីយុត្តិសាស្ត្រ របស់តុលាការចំពោះកិច្ច [...] ក៏អាចបណ្តាលឲ្យមានការចោទសួរ" អំពីសុពលភាពនៃការអះអាងអំពី ច្បាប់ទំនៀមទម្លាប់ អន្តរជាតិរបស់សហចៅក្រមអន្តរជាតិដែលពឹងផ្អែកជាចម្បងទៅលើយុត្តិសាស្ត្ររបស់ តុលាការ ចំពោះកិច្ច[1123]។

៥៦៥. មិនតែប៉ុណោះ សហមេធាវីអះអាងថា សហព្រះរាជអាជ្ញាអន្តរជាតិរិះគន់ដោយមិនត្រឹមត្រូវលើ ការពឹងផ្អែករបស់សហមេធាវីលើច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិធ្វើជាភស្តុតាងនៃច្បាប់ទំនៀមទម្លាប់ អន្តរជាតិ និង "មិនអើពើ" ទៅលើគោលការណ៍ច្បាប់ដាក់ទោសស្រាលជាង[1124]។ សហ មេធាវីស្នើថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិគួរតែបានពិចារណាលើការវិវឌ្ឍថ្មីៗលើវិស័យ ច្បាប់ ជាពិសេសច្បាប់ តុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីវាយតម្លៃ ថាតើការវិវឌ្ឍបែបនេះតំណាង ឲ្យច្បាប់ទំនៀមទម្លាប់អន្តរ ជាតិ និងមានប្រយោជន៍ដល់ជនជាប់ចោទដែរឬទេ[1125]។ សហមេធាវី ផ្តល់ឧទាហរណ៍នានាអំពីច្បាប់ តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលពួកគាត់លើកឡើងថា បង្កើត ជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ និង/ឬផ្ត ល់ប្រយោជន៍ដល់ជនជាប់ចោទច្រើនជាងក្នុង មូលដ្ឋានទី៩ មូលដ្ឋានទី១១ មូលដ្ឋានទី១២ មូលដ្ឋានទី១៤ និង

---

[1121] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៤៨។ សំណុំរឿង ០០៤/០២ ប្រតិចារិត ២០ មិថុនា ២០១៩ ឯកសារ D359/9.1 & D360/18.1, ERN (EN) 01625299, pp. 40:8 to 40:11។

[1122] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៤៧, ៤៩ យោងទៅ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរ ជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៩៣, ៩៦, ១០០-១០១, ១០៥។ ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៥០, ៥២ យោងទៅ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៩៣, ៩៦, ១០១, ១០៥។ សំណុំរឿង ០០៤/០២ ប្រតិចារិត ២០ មិថុនា ២០១៩ ឯកសារ D359/9.1 & D360/18.1, ERN (EN) 01625299-01625300, pp. 40:12 to 41:7។

[1123] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៥២។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1 ERN (EN) 01625298 , pp. 39:16 to 39:20។

[1124] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៥០-៥១។

[1125] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៥១។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 ERN 01626081-01626082 ទំព័រ ២៧ បន្ទាត់ ១៨ ដល់ ទំព័រ ២៨ បន្ទាត់ ៤។

មូលដ្ឋានទី១៦[1126]។

## ២. ការពិភាក្សា

៥៦៦. ចៅក្រមអន្តរជាតិបដិសេធទឡ្ហីករណ៍ពាក់ព័ន្ធនឹង "ការអនុវត្តដោយកំហុសឆ្គង" លើច្បាប់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលពឹងផ្អែកជ្រុលពេកលើតុលាការមិនអចិន្ត្រៃយ៍ ឬការពិចារ ណាត្រួសៗលើច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយហេតុ ថា សហមេធាវីខកខានមិនបានផ្តល់សំអាងហេតុលម្អិត និងការគាំទ្រនៅក្នុងមូលដ្ឋានទី៨[1127]។ ក្រៅពីនេះ ចៅក្រមអន្តរជាតិយល់ឃើញថា ពុំមានភាពសមស្របនៅក្នុងទឡ្ហីករណ៍ពាក់ព័ន្ធនឹងគោល ការណ៍ច្បាប់ដាក់ទោសស្រាលជាង ដែលសហចៅក្រមស៊ើបអង្កេត អន្តរជាតិគួរតែបានពិចារណា (ឬអនុវត្ត) ការវិវឌ្ឍថ្មីៗនៃច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលជាការប្រែប្រួលនៃច្បាប់ទំនៀម ទម្លាប់អន្តរជាតិ ជាប្រយោជន៍ដល់ជនជាប់ចោទ[1128]។

៥៦៧. ពាក់ព័ន្ធនឹងបញ្ហាបឋមនៃទឡ្ហីករណ៍មិនគ្រប់គ្រាន់ ចៅក្រមអន្តរជាតិបានសម្រេចពីមុនថា ទឡ្ហីករណ៍ ដែលពុំមានសក្តានុពលក្នុងការបដិសេធ ឬកែប្រែសេចក្តីសម្រេចដែលរងការជំទាស់ អាចត្រូវបដិសេធភ្លាមៗ[1129]។ ភាគីមួយមានភារៈផ្តល់សេចក្តីយោងជាក់លាក់ដល់ទំព័រ ឬកថាខណ្ឌនៃប្រតិចារឹកនៅក្នុងសេចក្តីសម្រេចដែលត្រូវបានតវ៉ាជំទាស់។ ចៅក្រមអន្តរជាតិ "នឹងមិនផ្តល់ការពិចារណាលម្អិតលើសារណាដែល

---

[1126] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៥១ ជើងទំព័រ ១០៨។

[1127] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៦៦-១៦៩។ (ចៅក្រមអន្តរជាតិកត់សម្គាល់ថា សេចក្តីសន្និដ្ឋាននៃទឡ្ហីករណ៍ដែលគ្មានមូលដ្ឋានមួយនៅក្នុងសំអាងហេតុទី ៨ មិនមានឥទ្ធិពលទៅលើការសម្រេចទៅលើមូលដ្ឋានដាច់ដោយឡែកពីគ្នាទេដែលអាចបានពិចារណាយ៉ាងត្រឹមត្រូវទៅលើទឡ្ហីករណ៍ជាក់លាក់ដោយមានការដកស្រង់ការគាំទ្រផលដែរ) ។

[1128] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៦៦-១៦៩។ ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៥១-៥២។

[1129] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍លើដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលេខ D250/3/3 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ និងដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១០ លើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ ឯកសារ D250/3/2/1/5 ("សាលដីកាលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ (D250/3/2/1/5)") កថាខណ្ឌ ២២ *យោងទៅ*រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង* Blaškić សំណុំរឿងលេខ IT-95-14-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ ("សាលដីកាក្នុងរឿងក្តី *Blaškić* (ICTY)") កថាខណ្ឌ ១៣។ តុលាការ ICTR រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Rutaganda* សំណុំរឿងលេខ ICTR-96-3-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៣ ("សាលដីកាក្នុងរឿងក្តី *Rutagandat* (ICTR)") កថាខណ្ឌ ១៨។

ពិបាកយល់ មានលក្ខណៈផ្ទុយ ឬស្រពិចស្រពិល ឬប្រសិនបើសារណាមានលក្ខណៈមិនគ្រប់គ្រាន់ផ្លូវការ ឬជាក់ស្តែង"[1130]។

៥៦៨. ត្រង់ចំណុចនេះ សហមេធាវីយោងដល់កថាខណ្ឌទី៦៣ ដល់១២០ នៃដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ក្នុងការបង្ហាញអំពីកំហុសឆ្គងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ និង "ការពឹងផ្អែកជ្រុលពេកលើយុត្តិសាស្ត្ររបស់តុលាការ [មិនអចិន្ត្រៃយ៍]"[1131]។ ដោយគ្មានការកំណត់លម្អិតអំពីបញ្ហាទាំងឡាយនៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ អង្គជំនុំជម្រះសម្រេចថា ការយោងទៅកថាខណ្ឌចំនួន ៥៧ មិនមានលក្ខណៈច្បាស់គ្រប់គ្រាន់ ហេតុដូច្នេះបដិសេធទឡ្ហីករណ៍ទាំងនេះ[1132]។

៥៦៩. ចំពោះការវិវឌ្ឍរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែលតាមការអះអាងថាតំណាងឱ្យច្បាប់ទំនៀម

---

[1130] សាលដីកាលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ (D250/3/2/1/5) កថាខណ្ឌ ២២ *យោងទៅ* (ICTY) កថាខណ្ឌ ១៣។ សាលដីកាក្នុងរឿងក្តី *Rutagandat* (ICTR) កថាខណ្ឌ ១៩។ តុលាការ ICTY រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Kunarac និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-96-23 & IT-96-23/1-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ ៤៣។ *សូមមើលផងដែរ* សាលដីកាលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ (D250/3/2/1/5) កថាខណ្ឌ ៤៣ (សន្និដ្ឋានថា មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍មានវិការៈ ដោយសារពុំមានសក្តានុពលដែលអាចច្រានចោល ឬកែប្រែសេចក្តីសម្រេចដែលរងការជំទាស់នៅពេលដែល "ជាការអះអាងដែលគ្មានការបញ្ជាក់ច្បាស់លាស់ពីវិការៈជាក់លាក់ណាមួយ ឬដោយគ្មានការលើកអំពីសំអាងហេតុជាក់លាក់នៃដីកាដែលរងការជំទាស់ [...]" ហើយហេតុនេះ បានច្រានចោលដោយមិនពិចារណាលើអង្គសេចក្តីរបស់វា)។

[1131] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) ជើងទំព័រ ៤១៤, ៤១៩, ៤២០។

[1132] ចៅក្រមអន្តរជាតិកត់សម្គាល់ថា សហមេធាវីព្យាយាមគាំទ្រដល់ការអះអាងដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសំអាងច្រើនពេកទៅលើយុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍ ដោយការដកស្រង់នៅក្នុងកថាខណ្ឌ ៦៣ នៃដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (សូមមើល បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៦៧ ជើងទំព័រ ៤១៧, ៤២០)។ ទោះជាយ៉ាងណាក្តី បន្ទាប់ពីការពិនិត្យរួច កថាខណ្ឌជាប្រភពពីដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) នេះបែរជាគាំទ្រ ពុំមែនច្រានចោលវិធីសាស្ត្រត្រឹមត្រូវរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងការពិចារណាទៅលើច្បាប់អន្តរជាតិ។ សូមមើល ឧទាហរណ៍កថាខណ្ឌនេះដែលលើកឡើងថា "អនុសញ្ញាអន្តរជាតិ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងគោលការណ៍ទូទៅនៃច្បាប់ដែលទទួលស្គាល់ដោយសហគមន៍អន្តរជាតិ គឺជាប្រភពច្បាប់អន្តរជាតិជាធរមាន នៅក្នុងអំឡុងពេលពាក់ព័ន្ធ" និង "អង្គជំនុំជម្រះ [នៅ អ.វ.ត.ក] មានកាតព្វកិច្ចត្រូវសម្រេចថា សេចក្តីសម្រេចបែបនោះអាចអនុវត្តបាន នៅក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក ហើយជនត្រូវចោទ អាចដឹងជាមុនថាមានសេចក្តីសម្រេចបែបនោះ និងអាចចូលពិនិត្យមើលសេចក្តីសម្រេចបែបនោះបានចំពោះពេលវេលាពាក់ព័ន្ធនឹងបទចោទ"។ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៦៣។

ទម្លាប់អន្តរជាតិ ដែលបានជាប្រយោជន៍ដល់ជនជាប់ចោទជាង[1133] ហើយសហចៅក្រមស៊ើបអង្កេតគួរតែបានពិចារណាក្រោមគោលការណ៍ច្បាប់ដាក់ទោសស្រាលជាង[1134] បញ្ហាច្បាប់នេះ (ដែលពាក់ព័ន្ធនឹងមូលដ្ឋានផ្សេងៗទៀត) ត្រូវបានដោះស្រាយនៅទីនេះ ទាក់ទិននឹងទឡ្ហីករណ៍ពាក់ព័ន្ធទាំងអស់ដើម្បីឱ្យមានភាពច្បាស់លាស់ និងភាពឆាប់រហ័ស[1135]។

៥៧០. ចៅក្រមអន្តរជាតិពិចារណាឃើញថា លក្ខន្តិកៈទីក្រុងរ៉ូម និងយុត្តិសាស្ត្រតុលាការព្រហ្មទណ្ឌអន្តរជាតិ មិនមានអនុភាពអនុវត្តនៅ អ.វ.ត.ក ឡើយ[1136]។ អង្គជំនុំជម្រះ និងសហចៅក្រមស៊ើបអង្កេតត្រូវអនុ

---

[1133] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៥០-៥១។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1 ERN 01626081-01626082 ទំព័រ ២៧ បន្ទាត់ ១៨ ដល់ ទំព័រ ២៨ បន្ទាត់ ៤។

[1134] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៥០-៥១។ បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៦៦ ("ការអនុវត្តខុសរបស់ [សហចៅក្រមស៊ើបអង្កេតអន្តរជាតិ] ទៅលើ [ច្បាប់ទំនៀមទម្លាប់អន្តរជាតិ] កើតចេញពីវិធីសាស្ត្រមិនត្រឹមត្រូវរបស់គាត់ក្នុងការសម្រេចលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ")។ បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៦៧ ("ការមិនបានពិចារណាទៅលើប្រភពដទៃផ្សេងទៀតរបស់ [ច្បាប់ទំនៀមទម្លាប់អន្តរជាតិ]")។ សូមមើលឧទាហរណ៍ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1 ERN 01626081-01626082 ទំព័រ ២៧ បន្ទាត់ ១៨ ដល់ ទំព័រ ២៨ បន្ទាត់ ៤ (លោក Gfiran SLUITER លើកឡើងថា "ហើយក៏សូមរំឭកផងដែរ ច្បាប់ស្តីអំពីគោលការណ៍នៃការសម្រាលទោសនេះ ជាច្បាប់ដែលមានលក្ខណៈធូរស្រាលជាង ដែលមានលក្ខណៈសម្រាលទៅដល់ជនជាប់ចោទ ដោយសំអាងទៅលើអង្គហេតុទាំងអស់នេះ ច្បាប់របស់ តុលាការព្រហ្មទណ្ឌអន្តរជាតិ គួរតែត្រូវបានពិចារណាឱ្យបានត្រឹមត្រូវដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ ហើយមេធាវីការពារក្តីបានផ្តល់សំអាងហេតុពាក់ព័ន្ធទៅនឹងផ្នែកផ្សេងៗនៃច្បាប់របស់តុលាការ ICTY ដែលបង្កើតបានទៅជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលជាប្រភពមួយដ៏ចម្បង ហើយក៏មានប្រយោជន៍មួយដល់ជនជាប់ចោទ")។

[1135] *ក្នុងចំណោមនោះ* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៦៧ (សំអាងហេតុទី៨ "ការមិនបានពិចារណាទៅលើប្រភពដទៃផ្សេងទៀតរបស់ [ច្បាប់ទំនៀមទម្លាប់អន្តរជាតិ]"), កថាខណ្ឌ ១៦៩ (សំអាងហេតុទី៨៖ "[សហចៅក្រមស៊ើបអង្កេតអន្តរជាតិ] ពិចារណាត្រួសៗទៅលើច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ"), កថាខណ្ឌ ១៧៤ (សំអាងហេតុទី៩៖ យោងទៅការប្រព្រឹត្តិរួម សហមេធាវីជំទាស់ថា "[សហចៅក្រមស៊ើបអង្កេតអន្តរជាតិ] ចាំបាច់ត្រូវតែអនុវត្តច្បាប់ដែលផ្តល់ជាប្រយោជន៍ដល់ជនជាប់ចោទ"), កថាខណ្ឌ ១៧៩ (សំអាងហេតុទី១១៖ លក្ខន្តិកៈទីក្រុងរ៉ូមក៏មិនមានយោងដល់ការរៀបចំផែនការ ឬការត្រៀម ជាទម្រង់នៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មសង្គ្រាម [ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ] ឬអំពើប្រល័យពូជសាសន៍នោះទេ")។

[1136] បទប្បញ្ញត្តិនៃលក្ខន្តិកៈទីក្រុងរ៉ូមសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ, ១៧ កក្កដា ១៩៩៨, ឯកសារអង្គការសហប្រជាជាតិ, A/CONF. 183/9, 2187 U.N.T.S. 90, 37 I.L.M. 1002 (1998), ដែលត្រូវបានអនុវត្តនៅថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០២ (បទប្បញ្ញត្តិនៃលក្ខន្តិកៈទីក្រុងរ៉ូម)។បទប្បញ្ញត្តិនៃលក្ខន្តិកៈទីក្រុងរ៉ូមតែមួយគត់ដែលចងកាតព្វកិច្ចដល់ អ.វ.ត.ក គឺ មាត្រា ៧ ដែល

វត្តតាមវិធាន និងគោលការណ៍ដែលមានចែងនៅក្នុងក្របខ័ណ្ឌច្បាប់ អ.វ.ត.ក[1137]។ លក្ខន្តិកៈទីក្រុងរ៉ូម និងយុត្តិសាស្ត្រតុលាការព្រហ្មទណ្ឌអន្តរជាតិ មិនផ្ទុះបញ្ចាំងពីច្បាប់ទំនៀមទម្លាប់អន្តរជាតិទាំងស្រុងឡើយ ហើយច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិមិនអាចអនុវត្តចំពោះ អ.វ.ត.ក ដោយគ្មានការបកស្រាយតាមផ្លូវតុលាការឡើយ[1138]។ ច្បាប់ទំនៀមទម្លាប់អន្តរជាតិមានសារៈសំខាន់ក៏ពិតមែន ប៉ុន្តែចៅក្រមអន្តរជាតិនៅពេលនេះមិនយល់ឃើញថា ច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ឬការវិវត្តន៍នានា "តំណាង" ច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ ដែលថា សហចៅក្រម ស៊ើបអង្កេតអន្តរជាតិត្រូវបានបង្ខំឱ្យពិចារណា និងជ្រើសរើសនោះ[1139]។ ដោយហេតុថា ច្បាប់ តុលាការព្រហ្មទណ្ឌអន្តរជាតិពុំចងកាតព្វកិច្ច ចៅក្រមអន្តរជាតិត្រូវ

---

ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយសារមានចែងផ្ទាល់នៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៩។ សូមមើលផងដែរ Antonio CASSESE ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (Oxford University Press ការកែសម្រួលលើកទី ៣ ឆ្នាំ២០១៣) ("CASSESE ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (២០១៣)") ទំព័រ ១០ (លើកឡើងដោយសង្ខេបថា លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិប្រកាន់យកវិធាននានាដែលអាចអនុវត្តបានតែចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយថា លក្ខន្តិកៈទីក្រុងរ៉ូមមិនអនុវត្តចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត (ដូចជា អ.វ.ត.ក)។ តុលាការព្រហ្មទណ្ឌអន្តរជាតិមិនបង្កើតជាក្រមព្រហ្មទណ្ឌអន្តរជាតិណាមួយទេ)។

[1137] អ.វ.ត.ក គឺជាតុលាការបែបអន្តរជាតិ ដែលគ្រប់គ្រងដោយលក្ខន្តិកៈ ច្បាប់ និងគោលការណ៍របស់ខ្លួនផ្ទាល់ រួមមាន កិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ អ.វ.ត.ក វិធានផ្ទៃក្នុង និង ច្បាប់កម្ពុជា ជាធរមានពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះដីកាសម្រេចលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមាន ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១០ ឯកសារ D193/5/5 (សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍នៃសហមេធាវីការពារអោយដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ D193/5/5) កថាខណ្ឌ ២៥។ សូមមើលផងដែរ កិច្ចព្រមព្រៀង អ.វ.ត.ក វិធានផ្ទៃក្នុង។ សូមមើលផងដែរ ច្បាប់ អ.វ.ត.ក មាត្រា ៣៣ថ្មី សំណុំរឿង ០០១ សេចក្តីសម្រេចបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ ឯកសារ D99/3/42, កថាខណ្ឌ ៤៦-៤៧។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ខៀវ សំផន ប្រឆាំងនឹងដីកាបដិសេធលើសំណើសុំដោះលែងឱ្យមានសេរីភាព និងដីកាសម្រេចពន្យារចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៨ ឯកសារ C26/5/26 កថាខណ្ឌ ៧៩។

[1138] *សូមមើលឧទាហរណ៍* តុលាការ ICTY រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Ëainović និងអ្នកផ្សេងទៀត សំណុំរឿងលេខ IT-05-87-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ (សាលដីកា Ëainović et al ICTY) កថាខណ្ឌ ១៦៤៨ ("លើសពីនេះទៀត ទោះបីលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិអាចមាននៅក្នុងវិស័យជាច្រើនដែលត្រូវបានចាត់ទុកជាសញ្ញាណនៃវិធានជាទំនៀមទម្លាប់ នៅក្នុងវិស័យខ្លះ វាបង្កើតជាច្បាប់ថ្មី ឬកែប្រែច្បាប់ដែលមានស្រាប់")។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ (D193/5/5) កថាខណ្ឌ ២៥។ សូមមើលផងដែរ CASSESE ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (២០១៣) ទំព័រ ១០-១១។

[1139] *ផ្ទុយពី* ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៥១។ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ ក្នុងសំណុំរឿង ០០៤/២ (CS) ឯកសារ D359/9.1 & D360/18.1 ERN 01626081-01626082 ទំព័រ ២៧ បន្ទាត់ ១៨ ដល់

យល់ឃើញថា សហចៅក្រម ស៊ើបអង្កេតអន្តរជាតិមិនមានកំហុសឆ្គងក្នុងការខកខានមិនបានអនុវត្តការវិវឌ្ឍមិនស្ងួតតឹងតែង ដែលបានមកពីច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ បើទោះជាការវិវឌ្ឍទាំងនោះផ្តល់ប្រយោជន៍ដល់ ជនជាប់ចោទក្តី[1140]។ ហេតុដូច្នេះ ចៅក្រមអន្តរជាតិបដិសេធសំអាងហេតុនេះទាំងស្រុង[1141]។

---

ទំព័រ ២៨ បន្ទាត់ ៤។ សូមមើលផងដែរ CASSESE ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (២០១៣) ទំព័រ ១០-១១ (លើកឡើងដោយសង្ខេបថា បទប្បញ្ញត្តិមួយចំនួននៅក្នុងបទប្បញ្ញត្តិនៃលក្ខន្តិកៈទីក្រុងរ៉ូមបដែលបង្ហាញតាមរយៈច្បាប់ទំនៀមទម្លាប់អន្តរជាតិ បទប្បញ្ញត្តិផ្សេងអាចបង្កើតជាវិធានមួយដែលជ្រើសរើសរវាងការបកស្រាយផ្ទុយគ្នា ហើយបទប្បញ្ញត្តិផ្សេងទៀតចេញហួសឆ្ងាយពីអ្វីដែលមានចែងដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិ)។

[1140] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ (F28) កថាខណ្ឌ ៣៤៦-៣៤៨ (ក្នុងការវាយតម្លៃពីវិវាទរវាងមាត្រា ៣៩ នៃច្បាប់ អ.វ.ត.ក (អនុញ្ញាតឱ្យដាក់ពន្ធនាគារលើសពី ៣០ ឆ្នាំ) និងមាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ ដែលមានភាពល្អប្រសើរ (ដែលហាមឃាត់មិនឱ្យដាក់ពន្ធនាគារលើសពី ៣០ឆ្នាំ) អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ស្ថានភាពនេះមិនជាបញ្ហាមួយដែលក្លាយជា ច្បាប់ដាក់ទោសស្រាលជាង ទេ ដោយសារក្រមព្រហ្មទណ្ឌកម្ពុជា "មិនចងកាតព្វកិច្ចចំពោះ អ.វ.ត.ក ទេ")។ សូមមើលផងដែរ តុលាការ ICTY រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Nikolić សំណុំរឿងលេខ IT-94-2-A សាលដីកាលើបណ្តឹងឧទ្ធរណ៍ជំទាស់ការផ្តន្ទាទោស អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌ ៨០-៨១ (លើកឡើងថា "ហេតុនេះ គោលការណ៍ច្បាប់ដាក់ទោសស្រាលជាង អាចអនុវត្តបានតែក្នុងករណីដែលច្បាប់ចងកាតព្វកិច្ចដល់តុលាការអន្តរជាតិ ត្រូវបានផ្លាស់ប្តូរទៅជាច្បាប់ដែលមានច្បាប់ដាក់ទោសស្រាលជាង ដែលតុលាការអន្តរជាតិក៏មានកាតព្វកិច្ចត្រូវអនុវត្តតាមដែរ")។ តុលាការ ICTY រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Deronjić សំណុំរឿងលេខ IT-02-61-A សាលដីកាលើបណ្តឹងឧទ្ធរណ៍ជំទាស់ការផ្តន្ទាទោស អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៥ កថាខណ្ឌ ៩៧ (យល់ស្របថា "ធាតុផ្សំនៃគោលការណ៍ [ច្បាប់ដាក់ទោសស្រាលជាង គឺ] ថា ច្បាប់ពាក់ព័ន្ធត្រូវចងកាតព្វកិច្ចដល់តុលាការ")។ តុលាការ ICTY រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Stanisić និង Simatović សំណុំរឿងលេខ IT-03-69-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ កថាខណ្ឌ ១២៨ (សម្រេចថា ច្បាប់ដាក់ទោសស្រាលជាង គឺជាគោលការណ៍មួយដែល "អនុវត្តចំពោះស្ថានភាពដែលមានការផ្លាស់ប្តូរនៅក្នុងច្បាប់ជាធរមានដែលពាក់ព័ន្ធ ...")។

[1141] *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៦៩ (ការចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ "បានពិចារណាត្រួសៗទៅលើច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ" (សំអាងហេតុទី៨))។ សូមមើលផងដែរ បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៧៣ (សហមេធាវីចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពិចារណាពី "ទ្រឹស្តីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនៃសហចារីភាព" គឺជាទម្រង់នៃការទទួលខុសត្រូវមួយផ្សេង រួមមានលក្ខខណ្ឌនៃការចូលរួមចំណែកដ៏សំខាន់ដែលខ្ពស់ជាងគេ (សំអាងហេតុទី៩))។ បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៧៩ (នៅពេលដែលសហមេធាវីចោទប្រកាន់ថា ការរៀបចំផែនការពុំមានជាទម្រង់នៃការទទួលខុសត្រូវទេ ដូចមានបញ្ជាក់ (ជាឧទាហរណ៍មួយ) ដោយលក្ខន្តិកៈទីក្រុងរ៉ូម ដែល "មិនមានចែងអំពីការរៀបចំផែនការ ឬការរៀបចំថាជាទម្រង់នៃការទទួលខុសត្រូវឡើយ" (សំអាងហេតុទី១១))។

01635076



## ៥. មូលដ្ឋានទី ៩៖ សហឧក្រិដ្ឋកម្មរួមពុំមែនជាទម្រង់នៃការទទួលខុសត្រូវមួយ ដែលអាចអនុវត្តបាននៅអ.វ.ត.ក នោះឡើយ

### ១. សារណា

៥៧១. សហមេធាវីការពារក្ដីអះអាងថា សហចៅក្រមស៊ើបអង្កេតមានកំហុស ចំពោះការសំអាងលើសហឧក្រិដ្ឋកម្មរួម ដោយសារវាពុំមានអត្ថិភាពជាទម្រង់នៃការទទួលខុសត្រូវមួយក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬ ច្បាប់កម្ពុជា នៅចន្លោះឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩[1142] ទេ។ សហមេធាវីការពារក្ដីអះអាងថា សហឧក្រិដ្ឋកម្មរួម បានផ្អែកលើទ្រឹស្ដីនៃច្បាប់ខំមិនឡ ហើយត្រូវបានបង្កើតឡើងតាមផ្លូវតុលាការដើម្បីដោះស្រាយកាលៈទេសៈពិសេសៗរបស់តុលាការ ICTY[1143]។ សហមេធាវីការពារក្ដីអះអាងថា ឯកសារសំអាងផ្លូវច្បាប់ដែលយកមកប្រើប្រាស់សម្រាប់ផ្ដល់យុត្តិកម្មលើការបង្កើតសហឧក្រិដ្ឋកម្មរួម ខកខានមិនបានបំពេញលក្ខខណ្ឌរបស់តុលាការ ICJ ចំពោះច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះឡើយ[1144]។

៥៧២. ម្យ៉ាងវិញទៀត សហមេធាវីការពារក្ដីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាទៅលើ "ភស្តុតាងដែលចងកាតព្វកិច្ចអំពីការអនុវត្តរបស់រដ្ឋ ដែលមានលក្ខណៈទូលំទូលាយ និងស៊ីសង្វាក់គ្នា" ដែលចង្អុលបង្ហាញថា សហឧក្រិដ្ឋកម្មរួមពុំមែនជាច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ ជាពិសេស ការខកខាននៃសហគមន៍អន្តរជាតិ ក្នុងការទទួលស្គាល់សហឧក្រិដ្ឋកម្មរួមនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម[1145]។ លើសពីនេះទៀត ទ្រឹស្ដីនៃការរួមប្រព្រឹត្ត នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម ស្របគ្នាខ្លាំងនឹងកម្មវត្ថុ និងគោលបំណង នៃ អ.វ.ត.ក ដោយសារលក្ខខណ្ឌអប្បបរមានៃការទទួលខុសត្រូវកំណត់ខ្ពស់ជាង ពោលគឺ

---

[1142] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៧១។ សំណុំរឿង ០០៤/២ ប្រតិចារិក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1 ERN (ភាសាអង់គ្លេស) 01625303 ទំព័រ ៤៤:១២ ដល់ ៤៤:២១ ។

[1143] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៧២។ សំណុំរឿង ០០៤/២ ប្រតិចារិក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1 ERN (ភាសាអង់គ្លេស) 01625303 ទំព័រ ៤៤:២២ ដល់ ៤៤:២៤។

[1144] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៧២ *យោងលើរឿងក្ដី North Sea Continental Shelf (សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ទល់នឹង ដាណឺម៉ាក សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ទល់នឹង ហូឡង់)* សាលក្រម របាយការណ៍ I.C.J. ១៩៦៩ (ថ្ងៃទី២០ ខែកុម្ភៈ) ទំព័រ ៣ កថាខណ្ឌ ៧៧។ សំណុំរឿង ០០៤/២ ប្រតិចារិក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1 ERN (ភាសាអង់គ្លេស) 01625303-01625304 ទំព័រ ៤៤:២៤ ដល់ ៤៥:៤។

[1145] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៧៣។ សំណុំរឿង ០០៤/២ ប្រតិចារិក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1 ERN (ភាសាអង់គ្លេស) 01625304 ទំព័រ ៤៥:៦ ដល់ ៤៥:១៩។

វាពាក់ព័ន្ធនឹងធាតុផ្សំនៃការចូលរួមចំណែកសំខាន់ ("ការគ្រប់គ្រងលើទ្រឹស្ដីនៃបទល្មើស")[1146]។ សហមេធាវីការពារក្ដីសន្និដ្ឋាន មិនថាសហឧក្រិដ្ឋកម្មរួម ឬ ទ្រឹស្ដីនៃការរួមប្រព្រឹត្តរបស់តុលាការ ICC មានលក្ខណៈតំណាងជាងច្បាប់ទំនៀមទម្លាប់អន្តរជាតិ មិនទាន់ទទួលស្គាល់ជាស្ថាពរក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម ហើយខកខានមិនបានអនុវត្តច្បាប់របស់តុលាការ ICC ដែលផ្ដល់ជាប្រយោជន៍ដល់ជនជាប់ចោទ[1147]។

៥៧៣. សហព្រះរាជអាជ្ញាអន្តរជាតិឆ្លើយតបថា សហមេធាវីការពារក្ដីខកខានមិនបានបង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសចំពោះការអនុវត្តតាមអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល នៃ អ.វ.ត.ក ដែលអង្គជំនុំជម្រះទាំងអស់បានសម្រេចថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី១ អនុវត្តបាននៅតុលាការនេះ[1148]។ សហមេធាវីការពារក្ដីខកខានមិនបានបង្ហាញថា ទ្រឹស្ដីនៃការរួមប្រព្រឹត្ត នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម បានបង្កើតជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិចាប់ពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ១៩៧៩[1149]។

៥៧៤. នៅក្នុងការឆ្លើយតបរបស់ខ្លួន សហមេធាវីការពារក្ដីឆ្លើយតបមូលដ្ឋានទី៩ រួមជាមួយនឹងមូលដ្ឋានទី ៨, ១១, ១២, ១៤, ១៥ និង ១៦(i)[1150] សេចក្ដីសង្ខេបទាំងស្រុងនៃការឆ្លើយតបរបស់ខ្លួន បង្ហាញនៅក្នុងមូលដ្ឋានទី៨ ដើម្បីជៀសវាងចំណុចជាន់គ្នា[1151]។

## ២. ការពិភាក្សា

៥៧៥. ចៅក្រមអន្តរជាតិរកឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានកំហុសចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម នោះឡើយ៖ (១) សហឧក្រិដ្ឋកម្មរួមមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅត្រឹមឆ្នាំ១៩៧៥ ដូចបានបង្ហាញយ៉ាងច្បាស់តាមរយៈការអនុវត្តរបស់រដ្ឋ និង *ទស្សនៈច្បាប់* ដែលបាន

---

[1146] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៧៣។ សំណុំរឿង ០០៤/២ ប្រតិចារឹក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1 ERN (ភាសាអង់គ្លេស) 01625304 ទំព័រ ៤៥:២០ ដល់ ៤៥:២៤។

[1147] បណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៧៤។ សំណុំរឿង ០០៤/២ ប្រតិចារឹក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1 ERN (ភាសាអង់គ្លេស) 01625305 ទំព័រ ៤៦:១ ដល់ ៤៦:៨។

[1148] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៩៣។

[1149] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៩៣។

[1150] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៤៦-៥២។

[1151] *សូមមើល* កថាខណ្ឌ ៥០៣ ដល់ ៥០៥ នៃមូលដ្ឋានទី (viii)។

01635078



វិភាគដោយអង្គជំនុំជម្រះជាច្រើនរបស់ អ.វ.ត.ក ស្របតាមលក្ខខណ្ឌតម្រូវនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិរបស់តុលាការ ICJ និង (២) សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំតម្រូវឱ្យអនុវត្តទ្រឹស្តីនៃការរួមប្រព្រឹត្តជាទម្រង់នៃការទទួលខុសត្រូវមួយផ្សេងនោះទេ ដោយសារលក្ខន្តិកៈទីក្រុងរ៉ូម ពុំចងកាតព្វកិច្ចលើ អ.វ.ត.ក ហើយបទប្បញ្ញត្តិមុនៗពាក់ព័ន្ធនឹងទ្រឹស្តីនៃការរួមប្រព្រឹត្ត ពុំផ្ទុះបញ្ចាំងច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ។

៥៧៦. ចំណុចទី១ ចៅក្រមអន្តរជាតិបញ្ជាក់ថា សហឧក្រិដ្ឋកម្មរួមទម្រង់មូលដ្ឋាន (JCE I) ដូចបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) មានអត្ថិភាពក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅត្រឹមឆ្នាំ១៩៧៥[1152]។ ដោយសារទស្សនទានច្បាប់ជាមូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួម ឃើញមាន

[1152] សេចក្តីសម្រេចលើសហឧក្រិដ្ឋកម្មរួមក្នុងសំណុំរឿង ០០២ (ឯកសារ D97/15/9) កថាខណ្ឌ ៥៤-៨៤ (អង្គបុរេជំនុំជម្រះបានតម្កល់អត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមទម្រង់មូលដ្ឋាន (JCE I) និងទម្រង់ជាប្រព័ន្ធ (JCE II) ជាទម្រង់នៃការទទួលខុសត្រូវ ដោយបានវិភាគយុត្តិសាស្ត្រ និងលិខិតុបករណ៍ច្បាប់ពាក់ព័ន្ធនឹងក្រោយសង្គ្រាមលោកលើកទី II ដូចជា មាត្រា ៦ នៃធម្មនុញ្ញនូរ៉ែមប៊ឺក និងច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០។ អង្គបុរេជំនុំជម្រះបានសម្រេចថា ពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួមទម្រង់ពង្រីក (សហឧក្រិដ្ឋកម្មរួមទម្រង់ទូលាយ (JCE III) ) ឯកសារសំអាងផ្លូវច្បាប់នៅក្នុងរឿងក្តី *Tadic* ពុំ "បង្កើតជាមូលដ្ឋានរឹងមាំ គ្រប់គ្រាន់ក្នុងការសន្និដ្ឋានថា JCE III បានបង្កើតជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ")។ សាលដីកាសំណុំរឿង ០០២/១ (F36) កថាខណ្ឌ ៧៧៥-៨១០ (ទោះបីជាពុំទទួលអនុវត្តក្របខ័ណ្ឌជាក់លាក់ដូចគ្នា អង្គជំនុំជម្រះតុលាការកំពូលតម្កល់ស្រដៀងគ្នាចំពោះអត្ថិភាពនៃ JCE I និង JCE II (ច្រានចោល JCE III) នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងពេលពាក់ព័ន្ធនឹងបទចោទ នៅពេលសម្រេចតម្កល់ថា ចំណុចសំខាន់នៃយុត្តិសាស្ត្រក្រោយសង្គ្រាមលោកគឺ "ការទទួលខុសត្រូវព្រហ្មទណ្ឌបុគ្គល អាចកើតឡើងនៅក្នុងកាលៈទេសៈ ដែលបុគ្គលម្នាក់បានចូលរួមចំណែកនៅក្នុងការអនុវត្តគោលបំណងឧក្រិដ្ឋរួម បើទោះជាការចូលរួមចំណែកនោះពុំមែនជា*អំពើពិរុទ្ធ*នៃបទល្មើស ហើយត្រូវបានដកចេញពីការប្រព្រឹត្តបទល្មើស" និងតាមរយៈការពិចារណាថា "ទោះបីជាយុត្តិសាស្ត្រ [...] ទំនងមិនត្រូវបានប្រើប្រាស់ពាក្យពេចន៍ស៊ីសង្វាក់គ្នារហូតក៏ដោយ វាគ្រប់គ្រាន់ក្នុងការបង្ហាញថា ជនជាប់ចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងពេលអនុវត្តគោលបំណងរួម ដែលជនជាប់ចោទបានចូលរួមចំណែកខ្លះក្រៅពីធ្វើជាអ្នកឈរមើល")។សំណុំរឿង ០០២ សាលក្រមសំណុំរឿង ០០២/១ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ (ឯកសារ E313) កថាខណ្ឌ ៦៩១។ សាលក្រម សំណុំរឿង ០០១ (ឯកសារ E188) កថាខណ្ឌ ៥០៥-៥១២។ សំណុំរឿង ០០២ សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E100/6 ("សំណុំរឿង ០០២ សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម (ឯកសារ E100/6)") កថាខណ្ឌ ២២។ *សូមមើលផងដែរ* សាលដីកា *Tadić* (តុលាការ ICTY) កថាខណ្ឌ ១៨៥-២២៨។ ICTY រដ្ឋអាជ្ញា ទល់នឹង *Krajišinik* សាលដីកាលេខ IT-00-39-A របស់សាលាឧទ្ធរណ៍ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ (សាលដីកា *Krajišinik* (តុលាការ ICTY)) កថាខណ្ឌ ៦៥៩។ តុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Brdanin* IT-99-36-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូលចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៧ ("សាលដីកា *Brdanin* (តុលាការ ICTY)) កថាខណ្ឌ ៣៩៣-៤១០។ តុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Rawamakuba* ICTR-98-44-AR72.4 សាលដីកាលើបណ្តឹងសាទុក្ខបន្ទាន់បន្ទំ ពាក់ព័ន្ធនឹងការអនុវត្តសហឧក្រិដ្ឋកម្មរួម ចំពោះបទប្រល័យពូជសាសន៍ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៤ ("សាលដីកា *Rawamakuba ស្តីពីសហឧក្រិដ្ឋកម្មរួម* ("តុលាការ

លើកឡើងនៅក្នុងឯកសារ និងសាលក្រមនាសម័យនូរ៉ែមប៊ឺក[1153] ចៅក្រមអន្តរជាតិច្រានចោលការអះអាងថា សហឧក្រិដ្ឋកម្មរួម "ត្រូវបានបង្កើតឡើងតាមផ្លូវតុលាការ" នៅតុលាការ ICTY ដើម្បីដោះស្រាយ "កាលៈទេសៈពិសេស ដែលតុលាការនេះបានជួបប្រទះ"[1154]។ ផ្ទុយមកវិញ ចៅក្រមអន្តរជាតិបានតម្កល់ការវិភាគលម្អិត និងគ្រប់ជ្រុងជ្រោយលើច្បាប់ទំនៀមទម្លាប់អន្តរជាតិធ្វើឡើងដោយចៅក្រមអន្តរជាតិជាច្រើននៅ អ.វ.ត.ក និងបញ្ជាក់ជាថ្មីម្តងទៀតនូវការយល់ឃើញថា សហឧក្រិដ្ឋកម្មរួមអាចអនុវត្តបាននៅ អ.វ.ត.ក នៅក្នុងករណីមួយនេះ[1155]។

៥៧៧. ចៅក្រមអន្តរជាតិសូមរម្លឹកថា នៅក្នុងការកំណត់ស្ថានភាពច្បាប់ទំនៀមទម្លាប់អន្តរជាតិ ពាក់ព័ន្ធនឹងអត្ថិភាពនៃទម្រង់នៃការទទួលខុសត្រូវ "តុលាការត្រូវវាយតម្លៃអំពីអត្ថិភាពនៃទម្លាប់អនុវត្តន៍ "ទូទៅប្រកបដោយសង្គតិភាព និងរលូន" របស់រដ្ឋ" ឬ *ទស្សនៈច្បាប់*[1156]។ ចៅក្រមអន្តរជាតិយល់ឃើញថា

---

ICTR") កថាខណ្ឌ ៩-៣១។ ចៅក្រមអន្តរជាតិក៏កត់សម្គាល់ផងដែរថា មានតែសហឧក្រិដ្ឋកម្មរួមទី I តែប៉ុណ្ណោះ ដែលត្រូវបានចោទប្រកាន់ថាជាទម្រង់នៃការទទួលខុសត្រូវនៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) និងបញ្ជាក់បំភ្លឺថា ការសម្រេចរបស់ចៅក្រមអន្តរជាតិនៅក្នុងរឿងក្តីនេះសំដៅលើទម្រង់នៃសហឧក្រិដ្ឋកម្មរួមទី១។

[1153] *សូមមើល ឧទា.* សាលក្រមសំណុំរឿង ០០១ (E188) កថាខណ្ឌ ៥០៤។ សេចក្តីសម្រេចលើសហឧក្រិដ្ឋកម្មរួមក្នុងសំណុំរឿង ០០២ (ឯកសារ D97/15/9) កថាខណ្ឌ ៤០។ មាត្រា ៦ ធម្មនុញ្ញនូរ៉ែមប៊ឺក។ មាត្រា II(២) ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០។

[1154] *ផ្ទុយពី* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៧២។ សេចក្តីសម្រេចលើសហឧក្រិដ្ឋកម្មរួមក្នុងសំណុំរឿង ០០២ (ឯកសារ D97/15/9) កថាខណ្ឌ ៥៥ *យោងលើ សាលដីកា* *Tadić* (តុលាការ ICTY) កថាខណ្ឌ ១៩១ (អង្គបុរេជំនុំជម្រះពិចារណាឃើញថា សហឧក្រិដ្ឋកម្មរួមកំណត់ដោយឧក្រិដ្ឋកម្មអន្តរជាតិជាទូទៅ។ បទល្មើសទាំងនេះជាធម្មតាត្រូវបានប្រព្រឹត្តឡើងនៅក្នុងពេលជម្លោះ និង "ដោយក្រុមបុគ្គលដែលធ្វើសកម្មភាពដើម្បី សម្រេចផែនការឧក្រិដ្ឋរួម")។

[1155] សេចក្តីសម្រេចលើសហឧក្រិដ្ឋកម្មរួមក្នុងសំណុំរឿង ០០២ (ឯកសារ D97/15/9) កថាខណ្ឌ ៥៤-៧៣។ សាលដីកា សំណុំរឿង ០០២/២ (ឯកសារ E313) កថាខណ្ឌ ៦៩១។ សាលដីកា សំណុំរឿង ០០១ (ឯកសារ E188) កថាខណ្ឌ ៥០៥-៥១២។ សេចក្តីសម្រេចក្នុងសំណុំរឿង ០០២/២ ស្តីពីភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម (ឯកសារ E100/6) កថាខណ្ឌ ២២។ *សូមមើលផងដែរ* សាលដីកា *Tadić* (តុលាការ ICTY) កថាខណ្ឌ ១៩៥-២២៨។ សាលដីកា *Krajišinik* (តុលាការ ICTY) កថាខណ្ឌ ៦៥៩។ សាលដីកា *Brdanin* (តុលាការ ICTY) កថាខណ្ឌ ៣៩៣-៤១០។ សេចក្តីសម្រេច *Rawamakuba* *ស្តីពីសហឧក្រិដ្ឋកម្មរួម* កថាខណ្ឌ ៩-៣១។

[1156] សេចក្តីសម្រេចលើសហឧក្រិដ្ឋកម្មរួមក្នុងសំណុំរឿង ០០២ (ឯកសារ D97/15/9) កថាខណ្ឌ ៥៣ (លេខយោងជើងទំព័រត្រូវបានលុបចោល) *ដែលយោងទៅលក្ខន្តិកៈ*របស់តុលាការ ICJ មាត្រា ៣៨(១)។ យុត្តាធិការ *Fisheries* (*ចក្រភពអង់គ្លេស ទល់នឹង អ៊ីស្លង់*) មតិរួមដោយឡែករបស់ចៅក្រម FORSTER, BENGZON, JIMENEZ DE ARECHAGA, NAGENDRA SINGH និង RUDA, របាយការណ៍ I.C.J ១៩៧៤ (ថ្ងៃទី២៥ ខែកក្កដា) ទំព័រ៣ កថាខណ្ឌ ១៦។

លក្ខខណ្ឌនេះបានបំពេញ និងផ្ទុយពីការអះអាងរបស់សហមេធាវីការពារក្តី ហើយ ចៅក្រមអន្តរជាតិពុំជឿជាក់ថា ការវិភាគនេះ "មានចំនួនតិចតួចបំផុត ហើយមិនសំខាន់ទាល់តែសោះ" ដើម្បីបំពេញទៅតាមលក្ខខណ្ឌនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះឡើយ[1157]។

៥៧៨. ចៅក្រមអន្តរជាតិពិចារណាឃើញថា នៅក្នុងសាលដីកា និងសេចក្តីសម្រេចមុនៗ ចៅក្រមអន្តរជាតិបានធ្វើការ "ពិនិត្យដោយប្រុងប្រយ័ត្ន និងដោយមានសំអាងហេតុ"[1158] លើការសម្រេចរបស់សាលាក្តី *មិនអចិន្ត្រៃយ៍* ស្តីពីសហឧក្រិដ្ឋកម្មរួម (ហើយសម្រេចមិនអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទូលាយ (JCE III) ពីតុលាការ ICTY ) ពុំមែនអនុវត្តយកតាមការសម្រេចទាំងអស់នោះទាំងស្រុងឡើយ[1159]។ អង្គជំនុំជម្រះ អ.វ.ត.ក បានពិនិត្យមើលដោយឯករាជ្យលើលិខិតុបករណ៍ និងយុត្តិសាស្ត្រនៅក្រោយសង្គ្រាមលោកលើកទី II ហើយបានផ្តល់ទម្ងន់ជាក់លាក់យ៉ាងសមស្របលើធម្មនុញ្ញនូរ៉ឹមប៊ឺក ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ និងយុត្តិសាស្ត្រពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មសង្គ្រាមនៅក្រោយសង្គ្រាមលោកលើកទី II[1160]។ អាស្រ័យហេតុនេះ ចៅក្រមអន្តរជាតិពិចារណាឃើញថា យុត្តិសាស្ត្រដែលសំអាងដោយអង្គជំនុំជម្រះនៃ អ.វ.ត.ក បំពេញ "តាមលក្ខខណ្ឌតម្រូវរបស់តុលាការយុត្តិធម៌អន្តរជាតិសម្រាប់ [ច្បាប់ទំនៀមទម្លាប់អន្តរជាតិ]"[1161] ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានកំហុសចំពោះការសំអាងលើសហឧក្រិដ្ឋកម្មរួមនោះទេ។

៥៧៩. ចំណុចទី២ ចៅក្រមអន្តរជាតិពុំជឿជាក់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសចំពោះ

---

[1157] *ផ្ទុយពី* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៧២។

[1158] សាលដីកាសំណុំរឿង ០០១ (ឯកសារ F28) កថាខណ្ឌ ៩៧ ("អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា ការពិនិត្យឡើងវិញដោយប្រុងប្រយ័ត្ន និងដោយមានសំអាងហេតុអំពីការកំណត់របស់ [សាលាក្តី *មិនអចិន្ត្រៃយ៍*] មានសារៈសំខាន់ចាំបាច់ណាស់ក្នុងការធានាអំពីធម្មានុរូបរបស់ស្ថាប័ន និងសេចក្តីសម្រេចរបស់ អ.វ.ត.ក")។

[1159] សេចក្តីសម្រេចលើសហឧក្រិដ្ឋកម្មរួមក្នុងសំណុំរឿង ០០២ (ឯកសារ D97/15/9) កថាខណ្ឌ ៨៣ (អង្គបុរេជំនុំជម្រះបានសម្រេចថា ពាក់ព័ន្ធនឹងទម្រង់សហឧក្រិដ្ឋកម្មរួម ទម្រង់ទូលាយ (JCE III) ឯកសារសំអាងនៅក្នុងរឿងក្តី *Tadic* ពុំ "បានបង្កើតាមូលដ្ឋានដ៏រឹងមាំគ្រប់គ្រាន់ដើម្បីធ្វើសេចក្តីសន្និដ្ឋានថា JCE III ជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ"។ *សូមមើលផងដែរ* សាលដីកាសំណុំរឿង ០០២/១ (ឯកសារ F36) កថាខណ្ឌ ៧៩១-៨០៧។ សាលដីកាសំណុំរឿង ០០២/១ (ឯកសារ E313) កថាខណ្ឌ ៦៩១។ សេចក្តីសម្រេចក្នុងសំណុំរឿង ០០២ លើភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម (E100/6) កថាខណ្ឌ ២៩។

[1160] *សូមមើល ឧទា.* សេចក្តីសម្រេចលើសហឧក្រិដ្ឋកម្មរួមក្នុងសំណុំរឿង ០០២ (ឯកសារ D97/15/9) កថាខណ្ឌ ៥៤-៧៣ សាលដីកាសំណុំរឿង ០០២/១ (ឯកសារ F36) កថាខណ្ឌ ៧៧៥-៨១០។ សាលដីកាសំណុំរឿង ០០២/១ (ឯកសារ E313) កថាខណ្ឌ ៦៩១។ សេចក្តីសម្រេចក្នុងសំណុំរឿង ០០២ លើភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម (E100/6) កថាខណ្ឌ ២៩។

[1161] *ផ្ទុយពី* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៧២។

ការមិនពិចារណាលើ "ការអនុវត្តរបស់រដ្ឋដែលមានលក្ខណៈទូលំទូលាយ និងស៊ីសង្វាក់គ្នា ដែល [មិនមែនជាច្បាប់អន្តរជាតិ]"[1162] ឬ ការខកខានមិនអនុវត្តតាមទ្រឹស្តីនៃការរួមប្រព្រឹត្តរបស់តុលាការ ICC ដែលជាប់ពាក់ព័ន្ធនឹងធាតុផ្សំនៃការចូលរួមចំណែកសំខាន់ ក្នុងទម្រង់នៃការទទួលខុសត្រូវមួយផ្សេង[1163]។ ចៅក្រមអន្តរជាតិពិចារណាឃើញថា លក្ខន្តិកៈទីក្រុងរ៉ូម ពុំមែនជាលិខិតុបករណ៍ចងកាតព្វកិច្ចមួយនៅទីនេះឡើយ[1164]។ ម្យ៉ាងវិញទៀត ផ្ទុយពីជំហររបស់សហមេធាវីការពារក្តី[1165] ការបកស្រាយតាមផ្លូវច្បាប់លើបទល្មើស ឬទម្រង់នៃការទទួលខុសត្រូវ ដោយអង្គជំនុំជម្រះរបស់តុលាការ ICC ពុំឆ្លុះបញ្ចាំងគ្រប់គ្រាន់លើច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ[1166]។ ចៅក្រមអន្តរជាតិពិចារណាឃើញថា ការបកស្រាយរបស់តុលាការ ICC លើមាត្រា ២៥(៣)(ក) ដែលទាមទារលក្ខខណ្ឌថា ចារីត្រូវមានកម្រិតនៃការគ្រប់គ្រង *ទាបបំផុត*លើបទល្មើស តាមរយៈការចូលរួមចំណែកសំខាន់របស់ខ្លួនចំពោះ [បទល្មើសនោះ] ("ការគ្រប់គ្រងលើទ្រឹស្តីនៃបទល្មើស")[1167] គឺជាករណីមួយដែលតុលាការ ICC បានបកស្រាយលក្ខន្តិកៈរបស់ខ្លួន ពុំមែន

---

[1162] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៧៣។ សំណុំរឿង ០០៤/២ ប្រតិចារឹក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1 ERN (ភាសាអង់គ្លេស) 01625304 ទំព័រ ៤៥:៦ ដល់ ៤៥:១៩។

[1163] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៧៣។ សំណុំរឿង ០០៤/២ ប្រតិចារឹក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1 ERN (ភាសាអង់គ្លេស) 01625304 ទំព័រ ៤៥:៦ ដល់ ៤៥:២៤។

[1164] *សូមមើលខាងលើ* កថាខណ្ឌទី ៥៧០ មូលដ្ឋាន (viii) សូមមើល CASSESE *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* (ឆ្នាំ២០១៣) ទំព័រ ១០-១១ ("លក្ខន្តិកៈរបស់តុលាការ ICC យកសំណុំវិធានជាធរមាននៅតុលាការ ICC៖ លក្ខន្តិកៈពុំអនុវត្តចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀតនោះឡើយ [...] ដែលតុលាការនីមួយៗកំណត់ដោយ និងត្រូវអនុវត្តលក្ខន្តិកៈរៀងៗខ្លួន")។

[1165] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៧៣-១៧៤។

[1166] *សូមមើល ឧទា.* តុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Šainović និងអ្នកផ្សេងទៀត* កថាខណ្ឌ ១៦៤៨ ("លើសពីនេះទៀត ទោះបីជាលក្ខន្តិកៈរបស់តុលាការ ICC អាចនៅក្នុងករណីខ្លះ ត្រូវបានចាត់ទុកជាភស្តុតាងបញ្ជាក់អំពីវិធានទំនៀមទម្លាប់ក៏ដោយ នៅក្នុងករណីខ្លះទៀត វាបង្កើតច្បាប់ថ្មី ឬ កែប្រែច្បាប់ជាធរមាន")។ *សូមមើល ផងដែរ* CASSESE *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* (ឆ្នាំ ២០១៣) ទំព័រ ១០-១១។

[1167] *សូមមើល ឧទា* តុលាការ ICC *ស្ថានភាពនៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោនៅក្នុងរឿងក្តី រដ្ឋអាជ្ញា ទល់នឹង* Bosco *Ntaganda* ICC-01/04-02/06-2359 សាលក្រម អង្គជំនុំជម្រះសាលាដំបូងទី VI ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៩ កថាខណ្ឌ ៧៧៤។ តុលាការ ICC *ស្ថានភាពនៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោក្នុងរឿងក្តី រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo* ICC-01/04-01/06-3121-Red សាលដីកាលើបណ្តឹងសាទុក្ខរបស់លោក Thomas Lubanga Dyilo ប្រឆាំងនឹងការផ្តន្ទាទោសរបស់គាត់ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ៤៦៩។ សាលក្រម Katanga (ICC) កថាខណ្ឌ ១៣៩៤។ តុលាការ ICC *ស្ថានភាពនៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោក្នុងរឿងក្តី រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo* ICC-01/04-01/06-2842 សាលដីកាអនុវលោមតាមមាត្រា ៧៤ នៃលក្ខន្តិកៈ អង្គជំនុំជម្រះសាលាដំបូង I ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២ (សាលដីកា *Lubanga* (ICC))កថាខណ្ឌ ៩៨៩ កថាខណ្ឌ៩៩៤។ សាលដីកាលើការតម្កល់បទចោទលើ *Lubanga*

ច្បាប់ទំនៀមទម្លាប់អន្តរជាតិជាធរមាននោះឡើយ[1168]។ ដោយហេតុថា គោលការណ៍នៃ*ការអនុវត្តច្បាប់ដែលចែងអំពីទោសស្រាល*ជាង ពាក់ព័ន្ធតែជាមួយនឹងច្បាប់ដែលចងកាតព្វកិច្ចលើតុលាការ[1169] សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានកំហុសចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួមនៅទីនេះទេ អាស្រ័យហេតុនេះ មូលដ្ឋានទី៩ ត្រូវបានច្រានចោល។

## ឈ. មូលដ្ឋានទី១០÷ ការរៀបចំផែនការ មិនមែនជាទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តនៅអ.វ.ត.ក បានទេ

### ១. សារណា

៥៨០. សហមេធាវីការពារក្តីលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុស ដោយរាប់បញ្ចូលការរៀបចំផែនការនៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ពីព្រោះទម្រង់នៃការទទួលខុសត្រូវនេះមិនមានអត្ថិភាពនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ឡើយ[1170]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសដោយពឹងផ្អែកទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលផ្អែកជាសំខាន់ទៅលើយុត្តិសាស្ត្ររបស់*តុលាការមិនអចិន្ត្រៃយ៍*។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំបានពិចារណាឲ្យបានគ្រប់គ្រាន់អំពីការអនុវត្តរបស់រដ្ឋជាទ្រង់ទ្រាយទូលំទូលាយ និងស៊ីសង្វាក់គ្នាថា ការរៀបចំផែនការ គឺជាទម្រង់នៃការទទួលខុសត្រូវនៅក្នុងអំឡុងឆ្នាំ១៩៧៥-

---

(ICC) កថាខណ្ឌ ៣៣៥-៣៤៨។

[1168] លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ២១(១)(ក)&(ខ) ("តុលាការត្រូវអនុវត្ត៖ (ក) ដំបូង លក្ខន្តិកៈនេះ ធាតុផ្សំនៃឧក្រិដ្ឋកម្ម និងវិធាននីតិវិធី និងភស្តុតាង (ខ) នៅក្នុងករណីទីពីរ ក្នុងករណីសមស្រប សន្ធិសញ្ញាជាធរមាន និងគោលការណ៍ និងវិធានច្បាប់អន្តរជាតិ រួមទាំង គោលការណ៍នៃច្បាប់អន្តរជាតិជាធរមានស្តីពីជម្លោះប្រដាប់អាវុធ"។ សាលក្រម *Katanga* (តុលាការ ICC) កថាខណ្ឌ ៣៩ ("អង្គជំនុំជម្រះគូសបញ្ជាក់ថា មាត្រា ២១ នៃលក្ខន្តិកៈ បង្កើតឋានានុក្រមនៃប្រភពច្បាប់ជាធរមាន ហើយ នៅក្នុងសេចក្តីសម្រេចទាំងអស់របស់ខ្លួន អង្គជំនុំជម្រះត្រូវ "នៅក្នុងករណីទី១" អនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនៃលក្ខន្តិកៈ [...] អង្គជំនុំជម្រះត្រូវអនុវត្តប្រភពច្បាប់បន្ទាប់បន្សំ អនុលោមតាមមាត្រា ២១(១)(ខ) និង ២១(១)(គ) នៃលក្ខន្តិកៈ ក្នុងករណីដែលអង្គជំនុំជម្រះរកឃើញចន្លោះប្រហោងនៅក្នុងបទប្បញ្ញត្តិនៃលក្ខន្តិកៈ ធាតុផ្សំនៃបទល្មើស និងវិធាន")។ សាលក្រម *Lubanga* (តុលាការ ICC) កថាខណ្ឌ ៩៩៤ ("យោងតាមការយល់ឃើញរបស់ចៅក្រមភាគច្រើន *ពាក្យពេចន៍នៃមាត្រា ២៥(៣)(ក)* [...] ជាលក្ខខណ្ឌតម្រូវ" (គូសបញ្ជាក់បន្ថែម))។

[1169] *សូមមើល* ក្នុងចំណោម កថាខណ្ឌ ៥៦៩ ដល់ ៥៧០ មូលដ្ឋានទី (viii) ។ *សូមមើល ផងដែរ* សាលដីកា រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Stanišić និង *Simatović* (តុលាការ ICTY) លេខ IT-03-69-A របស់សាលាឧទ្ធរណ៍ កថាខណ្ឌ ១២៨។

[1170] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៧៩។

១៩៧៩ ឡើយ[1171]។ សហមេធាវីការពារក្តីអះអាងថា ការរៀបចំផែនការត្រូវបានកំណត់ត្រឹមតែចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព នៅក្នុងធម្មនុញ្ញតុលាការយោធាអន្តរជាតិទីក្រុងនូរ៉ឺមប៊ឺក និងធម្មនុញ្ញតុលាការយោធាអន្តរជាតិទីក្រុងតូក្យូ[1172] និងកត់សម្គាល់ថា ទាំងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ និងលក្ខន្តិកៈទីក្រុងរ៉ូម ពុំបានយោងទៅលើការរៀបចំផែនការថាជាទម្រង់នៃការទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ[1173]។

៥៨១. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់ថា សហមេធាវីការពារក្តីខកខានពុំបានបង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសចំពោះការសំអាងលើយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងអំពីការរៀបចំផែនការ ឬថា ការវិភាគរបស់អង្គជំនុំជម្រះសាលាដំបូងមិនត្រឹមត្រូវនោះទេ[1174]។

៥៨២. នៅក្នុងការឆ្លើយតបរបស់ខ្លួន សហមេធាវីការពារក្តីលើកឡើងអំពីមូលដ្ឋានទី ១១ រួមទាំងមូលដ្ឋានទី ៨, ១២, ១៤, ១៥ និង ១៦(១)[1175] សេចក្តីសង្ខេបពេញលេញនៃទឡ្ហីករណ៍ក្នុងការឆ្លើយតបមាននៅក្នុងមូលដ្ឋានទី ៨[1176]។

## ២. ការពិភាក្សា

៥៨៣. ចៅក្រមអន្តរជាតិកត់សម្គាល់ឃើញថា ពុំមានកំហុសណាត្រូវបានបង្ហាញឡើងចំពោះការអនុវត្តការរៀបចំផែនការនៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) នោះឡើយ។ ចៅក្រមអន្តរជាតិ

---

[1171] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៧៨។

[1172] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៧៩ *ដែលសំអាងលើ* Robert CRYER និងអ្នកផ្សេងទៀត *សេចក្តីណែនាំអំពីនីតិវិធី និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* (រោងពុម្ពសាកលវិទ្យាល័យខែម្ប្រ៊ីជ បោះពុម្ពលើកទី៣ ឆ្នាំ២០១៤) ទំព័រ ៣៧៩-៣៨០។

[1173] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៧៩ *ដែលសំអាង*លើអនុសញ្ញាស្តីពីការបង្ការ និងការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៤៨ លេខ 78 U.N.T.S. 277 *ដែលចូលជាធរមាននៅថ្ងៃទី ១២ ខែមករា ឆ្នាំ១៩៥១* ("អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍")។ មាត្រា ២៥ នៃលក្ខន្តិកៈទីក្រុងរ៉ូម។

[1174] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៩៥។

[1175] ការឆ្លើយតបរបស់ អោ អាន (D360/11) កថាខណ្ឌ ៤៦-៥២។

[1176] *សូមមើល* កថាខណ្ឌទី ៥៦៣ ដល់ ៥៦៥ មូលដ្ឋានទី ៨។ សារណាលម្អិតទាំងនេះលើកឡើងបញ្ហាក់ពីបញ្ហាជាក់លាក់មួយចំនួនក្នុងមូលដ្ឋានទី ១១។

អះអាងថា ការអនុវត្តរបស់រដ្ឋ និង *ទស្សនៈរបស់ច្បាប់* ស្តែងឲ្យឃើញថា ការរៀបចំផែនការអាចយកមកអនុវត្តបានយ៉ាងត្រឹមត្រូវថាជាទម្រង់នៃការទទួលខុសត្រូវចំពោះអំពើព្រហ្មទណ្ឌទាំងអស់ (មិនមែនចំពោះតែឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាពប៉ុណ្ណោះទេ[1177]) ដូចដែលបានបង្ហាញដោយ ឧទាហរណ៍ (១) តុលាការនូរីមប៊ឺក និង (២) ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦។ លើសពីនេះទៀត នាពេលនេះ ចៅក្រមអន្តរជាតិជាក់ថា (៣) លិខិតុបករណ៍អន្តរជាតិ ដែលពុំមានការពាក់ព័ន្ធទៅលើការបង្ហាញឲ្យឃើញជាក់លាក់ថា ការរៀបចំផែនការជាទម្រង់នៃការទទួលខុសត្រូវនោះ (ឧ. អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ឬលក្ខន្តិកៈទីក្រុងរ៉ូម) ពុំអាចប៉ះពាល់ និងលុបបំបាត់អត្ថិភាពនៃការរៀបចំផែនការនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ។

៥៨៤. ទីមួយ ស្របជាមួយនឹងការអនុវត្តរបស់រដ្ឋ និង *ទស្សនៈរបស់ច្បាប់* នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចៅក្រមអន្តរជាតិយល់ឃើញថា ការរៀបចំផែនការបានលេចឡើងជាទម្រង់នៃការទទួលខុសត្រូវនៅក្រោយសង្គ្រាមលោកលើកទីពីរ និងត្រូវបានចែងជាលើកដំបូង នៅក្នុងធម្មនុញ្ញនៃតុលាការនូរីមប៊ឺកក្នុងឆ្នាំ ១៩៤៥ (ធម្មនុញ្ញទីក្រុងនូរីមប៊ឺក) ដែលអាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មទាំងអស់[1178]។ នៅក្នុងបរិបទនៃការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល កថាខណ្ឌទី ១ នៃមាត្រា ៦ នៃធម្មនុញ្ញ តុលាការនូរីមប៊ឺកចែងយ៉ាងច្បាស់អំពីការហាមឃាត់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ដែលក្នុងនោះ បានរៀបរាប់ពីទង្វើដែលត្រូវបានហាមឃាត់ "... ការរៀបចំផែនការ ការត្រៀមរៀបចំ ការផ្តួចផ្តើមគំនិត ..."[1179]។ កថាខណ្ឌចុងក្រោយក្នុងមាត្រា ៦ ដែលផ្ទុយពីការអះអាងរបស់សហមេធាវីការពារក្តីទៅលើភាពអាចអនុវត្តបានទាំងស្រុងនៃការរៀបចំផែនការ ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាពនោះ បានពង្រឹងដល់គោលការណ៍នៃការរៀបចំផែនការសម្រាប់ឧក្រិដ្ឋកម្មទាំងអស់នៅក្នុងយុត្តាធិការរបស់តុលាការនេះ ដោយបញ្ជាក់ថា "មេដឹកនាំ អ្នករៀបចំ អ្នកញុះញង់ និងអ្នកសមគំនិតចូលរួមនៅក្នុងការរៀបចំតាក់តែង ឬការអនុវត្តផែនការរួម ឬការសមគំនិតប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយដូចបានលើកឡើងខាងលើ ត្រូវទទួលខុសត្រូវចំពោះអំពើទាំងអស់ ដែលប្រព្រឹត្តឡើងដោយបុគ្គលណាម្នាក់នៅក្នុងការអនុវត្តផែនការបែបនោះ"[1180]។ ស្រដៀងគ្នានេះដែរ ច្បាប់ស្តីពីក្រុមប្រឹក្សាត្រួតពិនិត្យពីឆ្នាំ១៩៤៥ ចែងពីការទទួលខុសត្រូវព្រហ្មទណ្ឌសម្រាប់បុគ្គល

---

[1177] *ផ្ទុយពី* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/5/1) កថាខណ្ឌ ១៧៩។

[1178] *ធម្មនុញ្ញទីក្រុងនូរីមប៊ឺក មាត្រា ៦*។

[1179] *មាត្រា ៦ នៃធម្មនុញ្ញទីក្រុងនូរីមប៊ឺក*។

[1180] *សូមមើលផងដែរ ធម្មនុញ្ញតុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា* ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៤៦ ("ធម្មនុញ្ញទីក្រុងតូក្យូ") មាត្រា ៥។ *ផ្ទុយពី* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/5/1) កថាខណ្ឌ ១៧៩។

ទាំងឡាយ ដែលជាប់ទាក់ទងនឹងផែនការនានា ឬសហឧក្រិដ្ឋកម្មដែលពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ[1181]។

៥៨៥. ចៅក្រមអន្តរជាតិបញ្ជាក់ថា ការរៀបចំផែនការត្រូវបានរក្សាទុកជាទម្រង់មួយ ក្នុងចំណោមទម្រង់ទាំងឡាយនៃការទទួលខុសត្រូវ ដើម្បីផ្តន្ទាទោសជនជាប់ចោទចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅឯតុលាការនូរ៉ឹមប៊ឺក ដែលបញ្ជាក់ថា ទម្រង់នៃការទទួលខុសត្រូវនេះបានចូលជាធរមានយ៉ាងត្រឹមត្រូវ ដូចមានចែងក្នុងមាត្រា ៦ នៃធម្មនុញ្ញទីក្រុងនូរ៉ឹមប៊ឺក[1182]។ ចៅក្រមអន្តរជាតិយល់ឃើញថា ទោះបីជាពាក្យ "ការរៀបចំផែនការ" មិនតែងតែត្រូវបានប្រើប្រាស់ច្បាស់លាស់នៅក្នុងលិខិតុបករណ៍ច្បាប់នានាដូចបានលើកឡើងខាងលើក្តី ក៏ទង្វើដែលសំដៅទៅនោះ ដូចជា ការចូលរួមនៅក្នុងការបង្កើត ឬការរៀបចំតាក់តែងផែនការរួម ឬអំពើសមគំនិត ស្ថិតនៅក្នុងវិសាលភាពនៃនិយមន័យនៃការរៀបចំផែនការ ដែលត្រូវបានបញ្ជាក់យ៉ាងច្បាស់ដោយតុលាការ *មិនអចិន្ត្រៃយ៍* នានា ព្រមទាំងយុត្តិសាស្ត្ររបស់ អ.វ.ត.ក ផងដែរ[1183]។

---

[1181] ច្បាប់ស្តីពីក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ មាត្រា II(២)(ឃ)។

[1182] សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ១៣៨ *ដែលយោងទៅ* សាលក្រម តុលាការនូរ៉ឹមប៊ឺក ទំព័រ ២៧៩-៣៤១។ *សូមមើល ឧ.* សាលក្រមតុលាការនូរ៉ឹមប៊ឺក ទំព័រ ២៩២, ២៩៧-២៩៨, ៣០០៖ កាល ពីថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៤៦ តុលាការនូរ៉ឹមប៊ឺកបានសម្រេចផ្តន្ទាទោសជនជាប់ចោទម្នាក់ចំពោះ "ការចូលរួមរបស់គាត់នៅក្នុងការរៀបចំចាត់ចែងជម្លៀសអ្នកទោសពីជំរុំកែប្រែ និងការសម្លាប់អ្នកទោសជាច្រើននាក់ [...] មន្ទីរសន្តិសុខសំខាន់ RSHA បានដើរតួនាទីនាំមុខគេនៅក្នុង "ដំណោះស្រាយចុងក្រោយ" នៃការសួរចម្លើយជនជាតិជ្វីស ដោយសម្លាប់រង្គាលជនជាតិជ្វីស។ ផ្នែកសំខាន់មួយនៅក្រោម Amt IV នៃ RSHA ត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងកម្មវិធីនេះ"។ ដូចគ្នានេះដែរ តុលាការបានរកឃើញថា ជនជាប់ចោទឈ្មោះ FRANK មានពិរុទ្ធភាពចំពោះ "ការណែនាំបង្ហាញពីការបញ្ជូនពលករជាទាសករទៅប្រទេសអាល្លឺម៉ង់ នៅក្នុងដំណាក់កាលដំបូងបំផុតនៃការគ្រប់គ្រងរបស់គាត់។ កាលពីខែមករា ឆ្នាំ១៩៤០ គាត់បានបញ្ជាក់ពីបំណងរបស់គាត់ចង់បញ្ជូនពលករមួយលាននាក់ទៅប្រទេសអាល្លឺម៉ង់ [...] ពួកគេត្រូវបានបង្ខំឲ្យចូលទៅក្នុងតំបន់ដែលមានការរើសអើង ត្រូវបានប្រឈមមុខនឹងច្បាប់ដែលមានលក្ខណៈរើសអើង ត្រូវបានដកចំណីអាហារចាំបាច់ ដើម្បីចៀសពីភាពអត់ឃ្លាន ហើយចុងក្រោយ ត្រូវបានសម្លាប់រង្គាលជាប្រព័ន្ធ និងយ៉ាងព្រៃផ្សៃ"។ ជនជាប់ចោទម្នាក់ទៀតឈ្មោះ FRICK ក៏ត្រូវបានផ្តន្ទាទោស ដោយសារតែគាត់ "បានធ្វើសេចក្តីព្រាង បានចុះហត្ថលេខា និងបានចាត់ចែងច្បាប់ជាច្រើនដែលរៀបចំតាក់តែងឡើងដើម្បីកម្ចាត់ជនជាតិជ្វីសចេញពីការរស់នៅ និងសេដ្ឋកិច្ចប្រទេសអាល្លឺម៉ង់។ [...] ច្បាប់ទាំងនេះបានត្រួសត្រាយផ្លូវសម្រាប់ "ដំណោះស្រាយចុងក្រោយ"។

[1183] តុលាការ ICTY រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Kordić និង Čerkez* សំណុំរឿងលេខ IT-95-14/2-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ២៥។ តុលាការ ICTY រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Tadić* សំណុំរឿងលេខ IT-94-1-T គំនិតយោបល់ និងសាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៧ កថាខណ្ឌ ៦៧៤។ តុលាការ ICTR រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Semanza* សំណុំរឿងលេខ ICTR-97-20-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ ៣៨០។ តុលាការ ICTR រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Bagilishema*

៥៨៦. ជាលទ្ធផល ចៅក្រមអន្តរជាតិយល់ស្របជាមួយនឹងការសម្រេចរបស់អង្គបុរេជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលថា បទប្បញ្ញត្តិនៃមាត្រា *២៩ថ្មី* នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមទាំងការរៀបចំផែនការថាជាទម្រង់នៃការទទួលខុសត្រូវ មានភាពត្រឹមត្រូវជាច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់ចាប់តាំងពីរឿងក្តីតុលាការនូរ៉ឺមប៊ឺកឆ្នាំ១៩៤៥ ហើយត្រូវបានបញ្ជាក់គាំទ្រតាំងពីពេលនោះមក[1184]។

៥៨៧. ទីពីរ ចៅក្រមអន្តរជាតិរម្លឹកឡើងវិញថា ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ដែលជាប្រភពច្បាប់មួយចងកាតព្វកិច្ច អ.វ.ត.ក ដោយផ្ទាល់នោះ[1185] ផ្តន្ទាទោសយ៉ាងច្បាស់លាស់ចំពោះការរៀបចំផែនការ និង

---

សំណុំរឿងលេខ ICTR-95-1A-T សាលក្រមអង្គជំនុំជម្រះសាលាដំបូង I ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ៣០ (“ជនណាដែលចូលរួមដោយផ្ទាល់នៅក្នុងការរៀបចំផែនការដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្ម នៅក្រោមលក្ខន្តិកៈនេះ ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនោះ ទោះបីជាឧក្រិដ្ឋកម្មនោះពិតជាត្រូវបានប្រព្រឹត្តឡើងដោយជនផ្សេងទៀតក្តី កម្រិតនៃការចូលរួមត្រូវតែជាដុំកំភួនដូចជា ការរៀបចំតាក់តែងផែនការឧក្រិដ្ឋ ឬការសម្រេចលើផែនការដែលស្នើឡើងដោយជនផ្សេងទៀត”)។ សាលក្រមសំណុំរឿង ០០១ (E188) កថាខណ្ឌ ៥១៨-៥១៩ (“ការរៀបចំផែនការកំណត់ថា មនុស្សម្នាក់ ឬច្រើននាក់ បានរៀបចំប្រព្រឹត្តអំពើឧក្រិដ្ឋ ហើយក្រោយមក ការប្រព្រឹត្តិអំពើទាំងនោះ បង្កើតឲ្យមានឧក្រិដ្ឋកម្មមួយ ឬច្រើន។ ជាការចាំបាច់ដែលត្រូវតែបង្ហាញឲ្យឃើញថា ផែនការគឺជាកត្តារួមចំណែកយ៉ាងសំខាន់នៅក្នុងការឈានទៅប្រព្រឹត្តឧក្រិដ្ឋកម្ម”)។ [...] ជនជាប់ចោទត្រូវតែមានចេតនាក្នុងការប្រព្រឹត្តិអំពើឧក្រិដ្ឋ ឬបានដឹងអំពីភាពសំខាន់ដែលថា ឧក្រិដ្ឋកម្មទំនងនឹងត្រូវបានប្រព្រឹត្ត នៅពេលអនុវត្តផែនការនោះ”)។ សាលក្រមសំណុំរឿង ០០២ (E313) កថាខណ្ឌ ៦៩៨ (“ដើម្បីដាក់ឲ្យទទួលខុសត្រូវលើការរៀបចំផែនការ ជនជាប់ចោទតែម្នាក់ឯង ឬរួមជាមួយនឹងអ្នកផ្សេងទៀត ត្រូវតែបានរៀបចំការប្រព្រឹត្តិអំពើឧក្រិដ្ឋ ហើយក្រោយមក ការប្រព្រឹត្តិអំពើឧក្រិដ្ឋទាំងនោះពាក់ព័ន្ធ ឬបង្កើតឲ្យមានអំពើឧក្រិដ្ឋ”)។

[1184] សាលក្រមសំណុំរឿង ០០១ (E188) កថាខណ្ឌ ៥១៨-៥១៩។ សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ១៣៨ (“ការដាក់ពិរុទ្ធភាពពីបទធ្វើឲ្យទៅជាទាសករ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដោយតុលាការបានពឹងផ្អែកស្ទើរតែទាំងស្រុងលើតួនាទីរបស់ជនជាប់ចោទនៅក្នុងការរៀបចំផែនការ បញ្ជា អនុវត្ត ត្រួតត្រា ឬចូលរួមក្នុងការបញ្ជូនមនុស្ស ការជ្រើសរើសមនុស្សមកធ្វើការ និងការរំលោភបំពានជាប្រព័ន្ធលើពលករដែលមិនស្ម័គ្រចិត្ត នៅក្រោមគោលនយោបាយពលកម្មទាសកររបស់ពួកណាហ្ស៊ី (Nazi)” *យោងលើ* សាលក្រមតុលាការនូរ៉ឺមប៊ឺក ទំព័រ ២៧៩-៣៤១។ សាលក្រមសំណុំរឿង ០០២ (E313) កថាខណ្ឌ ៦៩៧ (“ត្រឹមឆ្នាំ ១៩៧៥ ការរៀបចំផែនការ គឺជាទម្រង់មួយនៃការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល ដែលត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ដោយសារតួនាទីជាន់ខ្ពស់របស់ជនជាប់ចោទ និងដោយសារថា ការរៀបចំផែនការនេះត្រូវបានទទួលស្គាល់ជាជាទម្រង់មួយនៃការទទួលខុសត្រូវមួយ ទាំងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងនៅក្នុងច្បាប់កម្ពុជាត្រឹមឆ្នាំ ១៩៧៥ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ទម្រង់មួយនៃការទទួលខុសត្រូវនេះអាចឲ្យជនជាប់ចោទប្រមើលឃើញ និងដឹងគ្រប់គ្រាន់ថាមានច្បាប់ចែង” (ជើងទំព័រយោងត្រូវបានលុបចោល))។

[1185] មាត្រា ១ និងមាត្រា ៣ *ថ្មី* នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

ការត្រៀមរៀបចំការប្រព្រឹត្តិអំពើព្រហ្មទណ្ឌ[1186]។ ក្រមព្រហ្មណ្ឌកម្ពុជាឆ្នាំ ១៩៥៦ បង្ហាញយ៉ាងច្បាស់ពីអត្ថិភាពនៃការរៀបចំផែនការថាជាទម្រង់មួយត្រមត្រូវនៃការទទួលខុសត្រូវក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ ក៏ដូចជា ការប្រមើលឃើញ និងដឹងគ្រប់គ្រាន់របស់ជនជាប់ចោទ[1187]។

៥៨៨. ទីបី ទាក់ទងនឹងការមិនមានការលើកឡើងពីការរៀបចំផែនការនៅក្នុងលិខិតុបករណ៍អន្តរជាតិមួយចំនួននោះ ចៅក្រមអន្តរជាតិយល់ឃើញថា អនុសញ្ញាស្តីពីអំពើប្រល័យពូជាសាសន៍ មិនប៉ះពាល់ទៅលើអត្ថិភាពនៃការរៀបចំផែនការ ឬក៏ថា មិនពាក់ព័ន្ធនោះទេ ពីព្រោះថា អនុសញ្ញានេះមាន គោលបំណងចែងកំណត់ពីមូលដ្ឋាននានានៃអំពើប្រល័យពូជសាសន៍ ដោយមិនផ្តោតទៅលើទម្រង់ទាំងឡាយនៃការទទួលខុសត្រូវនៅក្នុងបរិបទនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ[1188]។ លើសពីនេះ ទៀត លក្ខន្តិកៈទីក្រុងរ៉ូម (រួមទាំងការមិនលើកឡើងពីការរៀបចំផែនការនៅក្នុងផ្នែកមួយចំនួន) មិនមែនជាលិខិតុបករណ៍ដែលចងកាតព្វកិច្ចនៅ អ.វ.ត.ក នោះទេ[1189]។ បទប្បញ្ញត្តិនៃលក្ខន្តិកៈនេះមិនឆ្លុះបញ្ចាំងពីច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ[1190] និងមិនអាចប៉ះពាល់ទៅលើអត្ថិភាពនៃការរៀបចំផែនការនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ

---

[1186] *ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា* (*Code Pénal et Lois Pénales*) ឆ្នាំ ១៩៥៦ ("ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦") មាត្រា ២៣៩ និងមាត្រា ២៩០។ សាលក្រមសំណុំរឿង ០០១ (E188) កថាខណ្ឌ ៤៧៤ ("ប៉ុន្តែ ការរៀបចំផែនការត្រូវបានផ្តន្ទាទោសតាមបទប្បញ្ញត្តិជាក់លាក់មួយចំនួន តាមទម្រង់នៃការទទួលខុសត្រូវក្តី ឬជាបទឧក្រិដ្ឋក្តី ដែលការផ្តន្ទាទោសចំពោះអំពើទាំងនេះក៏មានចែងយ៉ាងច្បាស់ផងដែរ")។ មាត្រា ១ និងមាត្រា ៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

[1187] *សូមមើលផងដែរ* សាលក្រមសំណុំរឿង ០០១ (E188) កថាខណ្ឌ ៤៧៤។ សាលក្រមសំណុំរឿង ០០២ (E313) កថាខណ្ឌ ៦៩៧ ដែលទទួលស្គាល់ការរៀបចំផែនការនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងច្បាប់កម្ពុជាត្រឹមឆ្នាំ ១៩៧៥ ព្រមទាំងលើកឡើងត្រង់ផ្នែកពាក់ព័ន្ធថា "...ការរៀបចំផែនការ ត្រូវបានទទួលស្គាល់ជាទម្រង់មួយនៃការទទួលខុសត្រូវ ទាំងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ច្បាប់កម្ពុជាត្រឹមឆ្នាំ ១៩៧៥"។

[1188] អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍។

[1189] *សូមមើល* មូលដ្ឋានទី ៨ (កថាខណ្ឌ ៥៧០)។ បទប្បញ្ញត្តិនៃលក្ខន្តិកៈទីក្រុងរ៉ូមដែលចងកាតព្វកិច្ច អ.វ.ត.ក តែមួយគត់គឺមាត្រា ៧ ជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយសារមាត្រានេះត្រូវបានចែងដោយផ្ទាល់នៅក្នុងមាត្រា ៩ នៃកិច្ចព្រមព្រៀង អ.វ.ត.ក។ *សូមមើលផងដែរ* CASSESE, "ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ" (ឆ្នាំ២០១៣) ទំព័រ ១០ (លើកឡើងយ៉ាងសង្ខេបថា លក្ខន្តិកៈតុលាការ ICC គ្របដណ្តប់ទៅលើវិធាននានាដែលអាចអនុវត្តបានទាំងស្រុងចំពោះតុលាការ ICC និងថា លក្ខន្តិកៈទីក្រុងរ៉ូម មិនអនុវត្តចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត (ដូចជា អ.វ.ត.ក) នោះឡើយ។ តុលាការ ICC ពុំមែនជាទម្រង់ណាមួយក្រមអន្តរជាតិនោះទេ)។

[1190] *សូមមើល* មាត្រា ២១ នៃលក្ខន្តិកៈទីក្រុងរ៉ូម ដែលពន្យល់ពីឋានានុក្រមនៃអនុវត្តច្បាប់នានា ដែលបង្ហាញនៅក្នុងមាត្រា ២១(១)(ក) អនុភាពលប់នៃលក្ខន្តិកៈទីក្រុងរ៉ូម និងក្រមខណ្ឌតុលាការ ICC និងក្នុងមាត្រា ២១(១)(ខ) វិធាននៃច្បាប់អន្តរជាតិ ដែលជាប្រភពបន្ទាប់បន្សំតែប៉ុណ្ណោះ។

01635088



ដែលមានប្រភពដើមចេញមកពីតុលាការនូរ៉ឹមប៊ឺកឡើយ។ អាស្រ័យហេតុនេះ មូលដ្ឋានទី ១១ ត្រូវបាន បដិសេធចោល។

## ញ. មូលដ្ឋានទី ១២(i)÷ ការទទួលខុសត្រូវរបស់ថ្នាក់លើពុំមែនជាទម្រង់នៃការទទួលខុសត្រូវជាធរមាន នៅក្នុងសំណុំរឿង របស់ អោ អាន

### ១. សារណា

៩៨៩. សសហាមេធាវីជំទាស់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសដែលប្រើប្រាស់ការទទួលខុសត្រូវរបស់ថ្នាក់លើដើម្បីចោទប្រកាន់ជនជាប់ចោទ "ជាមេបញ្ជាការស៊ីវិល នៅក្រៅបរិបទនៃជម្លោះប្រដាប់អាវុធអន្តរជាតិ" ហើយថា ការធ្វើបែបនេះនៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) រំលោភទៅលើគោលការណ៍នីត្យានុកូលភាព[1191]។ ទោះបីមានការទទួលស្គាល់ថា "អ.វ.ត.ក បានសម្រេចក្នុងពេលកន្លងមកថា ការទទួលខុសត្រូវរបស់ថ្នាក់លើអាចអនុវត្តបានចំពោះមេបញ្ជាការស៊ីវិល"[1192] ក្តី ក៏សហាមេធាវីជំទាស់ថា សេចក្តីសម្រេចទាំងនោះ "មិនបានផ្តល់" ឲ្យបានគ្រប់គ្រាន់នូវភស្តុតាង ដែលបង្ហាញពីអត្ថិភាពនៃទម្រង់នៃការទទួលខុសត្រូវនេះនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ រួមទាំងភាពអាចអនុវត្តបានរបស់វាចំពោះ "មេបញ្ជាការស៊ីវិលនៅក្រៅជម្លោះប្រដាប់អាវុធអន្តរជាតិ"[1193]។

៩៩០. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា កន្លងមក បន្ទាប់ពីបានធ្វើការវិភាគគ្រប់ជ្រុងជ្រោយទៅលើសំណុំរឿងក្រោយសង្គ្រាមលោកលើកទី២ រួចមក អង្គបុរេជំនុំជម្រះធ្លាប់បាន

---

[1191] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៨០។ ដោយសារមូលដ្ឋានទី១២(ii) មិនត្រូវបានទទួលយក ចៅក្រមអន្តរជាតិនឹងមិនសង្ខេប ឬលើកឡើងនូវខ្លឹមសារនៃទឡ្ហីករណ៍របស់សហមេធាវីអំពី ថាតើសហចៅក្រមស៊ើបអង្កេតអន្តរជាតិអនុវត្តនូវធាតុផ្សំគតិយុត្តិនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ដោយមិនត្រឹមត្រូវ ឬយ៉ាងណាទេ។ *សូមមើល* (បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៨១)។

[1192] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៨០ *យោងទៅ* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (ខ្ទួន ជា និង អៀង ធីរិទ្ធ) (D427/2/15 & D427/3/15) កថាខណ្ឌ ១៩០-២៣២។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង សារី) (D427/1/30) កថាខណ្ឌ ៤១៣-៤៦០។ សាលក្រមក្នុងសំណុំរឿង ០០១ (E188) កថាខណ្ឌ ៤៧៦-៤៧៧។

[1193] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៨០។

សម្រេចថា ការទទួលខុសត្រូវរបស់ថ្នាក់លើអនុវត្តចំពោះថ្នាក់លើជាយោធា និងមិនមែនជាយោធា[1194]។ សហព្រះរាជអាជ្ញាអន្តរជាតិបានចោទប្រកាន់ថា ដោយសារសហមេធាវីមិនបានបង្ហាញថា ការប្រើប្រាស់ការទទួលខុសត្រូវរបស់ថ្នាក់លើនៅក្នុងសំណុំរឿងទាំងនោះ បានផ្អែកលើអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ឬថា រឿងក្តីទាំងនោះអាចត្រូវបានសម្រេចផ្សេងពីនេះ បើសិនគ្មានជម្លោះប្រដាប់អាវុធអន្តរជាតិនោះ សហមេធាវីមិនបានបង្ហាញពីការរំលោភទៅលើគោលការណ៍នីត្យានុកូលភាពនោះឡើយ[1195]។

៥៩១. នៅក្នុងការឆ្លើយតប សហមេធាវីលើកឡើងនូវមូលដ្ឋានទី ១២(i) រួមជាមួយមូលដ្ឋានទី ៨, ៩, ១១, ១៥ និង ១៦[1196]។ សេចក្តីសង្ខេបពេញលេញនៃការឆ្លើយតបនេះ មានបញ្ចូលនៅក្នុងមូលដ្ឋានទី៨ ដើម្បីកុំឱ្យមានភាពច្រំដែល[1197]។

## ២. ការពិភាក្សា

៥៩២. ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានកំហុសឆ្គងក្នុងការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ ឬរំលោភទៅលើគោលការណ៍នីត្យានុកូលភាពនោះឡើយ។ ផ្ទុយពីអំណះអំណាងរបស់សហមេធាវី ចៅក្រមអន្តរជាតិសូមបញ្ជាក់ថា (១) អង្គជំនុំជម្រះនៅ អ.វ.ត.ក បានបង្ហាញយ៉ាងពេញលេញថា ការទទួលខុសត្រូវរបស់ថ្នាក់លើពិតជាមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ដែលបង្ហាញពីទម្លាប់អនុវត្តន៍របស់រដ្ឋ និង*ទស្សនៈច្បាប់ (opinio juris)*[1198]។

---

[1194] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៩៦ *យោងទៅ* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង សារី) (D427/1/30) កថាខណ្ឌ ៤៥៩-៤៦០។

[1195] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (D360/9) កថាខណ្ឌ ៩៦។

[1196] ការឆ្លើយតបរបស់ អោ អាន (D360/11) កថាខណ្ឌ ៤៦-៥២។

[1197] *សូមមើល* កថាខណ្ឌ ៥៦៣ ដល់ ៥៦៥ មូលដ្ឋាន (viii)។ ជាទូទៅ សហមេធាវីជំទាស់តវ៉ាចំពោះកំហុសអង្គច្បាប់នៅក្នុងវិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលយកច្បាប់ទំនៀមទម្លាប់អន្តរជាតិមកអនុវត្ត ដូចជា ការមិនបានបង្ហាញអំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ និង ការរំលោភលើគោលការណ៍នីត្យានុកូលភាព។

[1198] *ផ្ទុយពី* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៨០ ("[សហចៅក្រមស៊ើបអង្កេតអន្តរជាតិ] មានកំហុសឆ្គងក្នុងសំណុំរឿងនេះ ដោយពឹងផ្អែកលើការទទួលខុសត្រូវរបស់ថ្នាក់លើថាជា ទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបាន តាម [ច្បាប់ទំនៀមទម្លាប់អន្តរជាតិ] ក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩"។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (D427/2/15 & D427/3/15) កថាខណ្ឌ ១៩០-២៣២។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង សារី) (D427/1/30) កថាខណ្ឌ ៤១៣-

ជាងនេះទៀត ចៅក្រមអន្តរជាតិយល់ឃើញថា (២) ការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើពុំមែនអាស្រ័យលើថាតើ បទចោទប្រកាន់ប្រឆាំងនឹងជនស៊ីវិលក្រោមទម្រង់ជាការទទួលខុសត្រូវរបស់ថ្នាក់លើមាន ឬមិនមានទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធអន្តរជាតិនោះទេ តែផ្ទុយទៅវិញ វាផ្តោតទៅលើការទទួលខុសត្រូវរបស់បុគ្គល[1199]។

៥៩៣. ទីមួយ ចៅក្រមអន្តរជាតិតម្កល់សេចក្តីសន្និដ្ឋានរបស់ខ្លួនពីមុនៗ និងយល់ស្របជាមួយអង្គជំនុំជម្រះនៅ អ.វ.ត.ក ពាក់ព័ន្ធនឹងអត្ថិភាពនៃការទទួលខុសត្រូវរបស់ថ្នាក់លើនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងបដិសេធទឡ្ហីករណ៍ស្តីពីភស្តុតាងមិនគ្រប់គ្រាន់[1200]។ បន្ទាប់ពីពិនិត្យលើសំណុំរឿង និងច្បាប់នៅ អ.វ.ត.ក ចៅក្រមអន្តរជាតិសូមតម្កល់ថា ការទទួលខុសត្រូវរបស់ថ្នាក់លើពិតជាមានអត្ថិភាពជាទម្រង់នៃការទទួលខុសត្រូវនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩[1201]។

---

៤៦០។ សាលក្រមក្នុងសំណុំរឿង ០០១ (E188) កថាខណ្ឌ ៤៧៦-៤៧៧។ សាលក្រមក្នុងសំណុំរឿង ០០២/០១ (E313) កថាខណ្ឌ ៧១៨-៧១៩។

[1199] តុលាការ ICTY *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* Hadžihasanović *និងអ្នកផ្សេងទៀត* សំណុំរឿង IT-01-47-T សេចក្តីសម្រេចលើ បណ្តឹងឧទ្ធរណ៍បន្ទាន់បង្អំជំទាស់នឹងយុត្តាធិការពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់មេបញ្ជាការ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៣ ("សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្អំជំទាស់នឹងយុត្តាធិការពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់មេបញ្ជាការក្នុង*រឿងក្តី* Hadžihasanović *និងអ្នកផ្សេងទៀត* (ICTY)") កថាខណ្ឌ ២០។ *ផ្ទុយពី* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៨០។

[1200] *ផ្ទុយពី* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៨០។

[1201] *ផ្ទុយពី* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៨០។ *សូមមើល* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (D427/2/15 & D427/3/15) កថាខណ្ឌ ១៩០-២៣២ (*សូមមើល* ឧទាហរណ៍ ការពិភាក្សាលម្អិតអំពី៖ (i) ការវិវត្តន៍នៃការទទួលខុសត្រូវរបស់ថ្នាក់លើដោយចាប់ផ្តើមឡើងនៅក្នុងរបាយការណ៍របស់គណៈកម្មការទទួលបន្ទុកការទទួលខុសត្រូវរបស់អ្នករៀបចំសង្គ្រាម និង ការអនុវត្តន៍ទោសប្បញ្ញត្តិ ឆ្នាំ១៩១៩ ដែលបង្ហាញពី "ការសម្តែងមតិចំពោះទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ" (កថាខណ្ឌ ១៩៣) (ii) ការពិភាក្សាលម្អិតអំពីសំណុំរឿងជាច្រើនក្រោយសង្គ្រាមលោកលើកទី២ នៅពេលដែលមេដឹកនាំជាន់ខ្ពស់ជប៉ុន និងអាល្លឺម៉ង់ត្រូវបានយកទៅកាត់ទោសនៅចំពោះមុខតុលាការ IMTFE និងគណៈកម្មការ ឬសាលាជម្រះក្តីផ្នែកយោធារបស់សម្ព័ន្ធមិត្រ ហើយថា ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើត្រូវបានកំណត់ និងអនុវត្តជាទម្រង់នៃការទទួលខុសត្រូវបុគ្គល (កថាខណ្ឌ ១៩៥-២៣០)។ សេចក្តីសម្រេចនេះក៏បានសម្រេចផងដែរថា ការទទួលខុសត្រូវរបស់ថ្នាក់លើអនុវត្តចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អនុលោមតាមសេចក្តីសន្និដ្ឋានរបស់តុលាការយោធា Nuremberg (កថាខណ្ឌ ២៣១-២៣២) (លុបជើងទំព័រ))។ *សូមមើល* សាលក្រមក្នុងសំណុំរឿង ០០២/០១ (E313) កថាខណ្ឌ ៧១៤, ៧១៨ (ក្នុងផ្នែកពាក់ព័ន្ធ៖ "ការទទួលខុសត្រូវរបស់ថ្នាក់លើដែលអាចយកមកអនុវត្តចំពោះទាំងថ្នាក់លើក្នុងជួរយោធា និងទាំងថ្នាក់លើក្នុងជួរស៊ីវិល ត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥។ [...] អង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថា ទម្រង់នៃការទទួលខុសត្រូវមួយនេះ

ចៅក្រមអន្តរជាតិយល់ឃើញថា ពុំមានហេតុផលណាមួយដែលត្រូវងាកចេញពីយុត្តិសាស្ត្រដែលត្រូវបានទទួលស្គាល់រួចហើយនៅក្នុងសំណុំរឿងនេះទេ។

៥៩៤. ទីពីរ ចៅក្រមអន្តរជាតិមិនយល់ស្របថា "ការចោទប្រកាន់ទៅលើជនស៊ីវិលតាមការទទួលខុសត្រូវ

---

អាចឱ្យជនជាប់ចោទប្រមើលឃើញ និងដឹងគ្រប់គ្រាន់ថាមានច្បាប់ចែង" (កថាខណ្ឌ ៧១៤)។ "ក្រោយពីពិនិត្យមើលយុត្តិសាស្ត្រនាសម័យ Nuremberg អង្គបុរេជំនុំជម្រះបានយល់ឃើញថា ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ [...] មានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩ រួចទៅហើយ" (កថាខណ្ឌ ៧១៨) (លុបជើងទំព័រ))។ *សូមមើល* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង សារី) (D427/1/30) កថាខណ្ឌ ៤១៨, ៤៦០ (សម្រេចថា "[...] យុត្តិសាស្ត្ររបស់តុលាការ Nuremberg ក៏បានបង្ហាញថា ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩" (កថាខណ្ឌ ៤១៨)) និង ("[...] អង្គបុរេជំនុំជម្រះយល់ឃើញថា ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ [...] មានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ដោយគិតអំពីយុត្តិសាស្ត្រអន្តរជាតិក្រោយសង្គ្រាមលោកលើកទី២ ដែលបានលើកឡើងខាងលើ និងលក្ខណៈធ្ងន់ធ្ងរនៃបទឧក្រិដ្ឋនានា អៀង សារី អាចដឹងជាមុនថាជាបទឧក្រិដ្ឋ និងអាចដឹងថាមានច្បាប់ចែងថា ខ្លួនអាចនឹងត្រូវបានផ្តន្ទាទោសក្នុងនាមជាថ្នាក់លើម្នាក់មិនថាជាយោធា ឬមិនមែនជាយោធានោះទេ ចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់របស់ខ្លួនពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩" (កថាខណ្ឌ ៤៦០) (លុបជើងទំព័រ))។ *សូមមើលផងដែរ* សាលក្រមក្នុងសំណុំរឿង ០០១ (E188) កថាខណ្ឌ ៤៧៧ (សម្រេចថា "យុត្តិសាស្ត្ររបស់តុលាការ Nuremberg និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិថ្មីៗជាច្រើន ក៏បានបង្ហាញថា ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩")។ *សូមមើលផងដែរ* ច្បាប់ អ.វ.ត.ក មាត្រា ២៩*ថ្មី* (ដែលកំណត់និយមន័យនៃការទទួលខុសត្រូវរបស់ថ្នាក់លើនៅ អ.វ.ត.ក ដោយលើកឡើងថា "ប្រការដែលថាសកម្មភាពណាមួយក្នុងចំណោមសកម្មភាព [...] ត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់នោះមិនអាចជួយឱ្យថ្នាក់លើរួចផុតពីការទទួលខុសត្រូវ ចំពោះឧក្រិដ្ឋកម្មនោះបានទេ ប្រសិនបើថ្នាក់លើមានបញ្ជា និងមានការគ្រប់គ្រងដ៏មានប្រសិទ្ធិភាព ឬមានអំណាច និងការ ត្រួតពិនិត្យទៅលើអ្នកនៅក្រោមបង្គាប់ ហើយថ្នាក់លើបានដឹង និងមានហេតុផលដឹងថាអ្នកនៅក្រោមបង្គាប់ ប្រព្រឹត្ត ឬបានប្រព្រឹត្តនូវសកម្មភាព បែបនេះ ហើយខ្លួនមិនបានចាត់វិធានការចាំបាច់និងសមស្រប ដើម្បីបង្ការអំពើបែបនេះ ឬដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តបទឧក្រិដ្ឋនេះ")។ *សូមមើលផងដែរ រឿងក្តី ស.រ.អា ទល់នឹង* Karl Brandt *និងអ្នកផ្សេងទៀត* (សំណុំរឿងវេជ្ជសាស្ត្រ) សាលក្រមចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៤៧ ការជំនុំជម្រះទោសឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nuremberg ក្រោមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង វ៉ុល II ទំព័រ ២០៦។ *រឿងក្តី ស.រ.អា ទល់នឹង* Friedrich Flick *និងជនប្រាំនាក់ផ្សេងទៀត* (សំណុំរឿងលេខ ៤៨) សាលក្រមចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៤៧ ការជំនុំជម្រះទោសឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nuernberg ក្រោមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង វ៉ុល IX ទំព័រ ២, ៤ ("*រឿងក្តី* Flick *និងជនប្រាំនាក់ផ្សេងទៀត* (សំណុំរឿងលេខ ៤៨) សាលក្រម (NMT)")។ តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា សាលក្រមចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៤៨ វ៉ុល ២២ ទំព័រ ៤៩, ៨១៦។ *រឿងក្តី ស.រ.អា ទល់នឹង* Oswald Pohl *និងអ្នកផ្សេងទៀត* (សំណុំរឿងលេខ ៤) សាលក្រមបន្ថែមចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៤៨ ការជំនុំជម្រះទោសឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nuernberg ក្រោមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង វ៉ុល V ទំព័រ ១១៧៦។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* Delalić *និងអ្នកផ្សេងទៀត* សាលក្រម (តុលាការ ICTY) កថាខណ្ឌ ៣៥៦-៣៥៧។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* Delalić *និងអ្នកផ្សេងទៀត* សាលដីកា (តុលាការ ICTY) កថាខណ្ឌ ១៩៥។

របស់ថ្នាក់លើ ចាំបាច់ត្រូវមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធអន្តរជាតិ”[1202] នោះឡើយ។ ចៅក្រមអន្តរជាតិយល់ឃើញថា ទោះបីអំពើដែលត្រូវបានចោទប្រកាន់ ដែលបានកើតមាននៅក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ គ្រាន់តែប៉ះពាល់ទៅលើលក្ខណៈនៃបទឧក្រិដ្ឋក៏ដោយ តែការទទួលខុសត្រូវរបស់ថ្នាក់លើមិនអាស្រ័យទៅលើទំនាក់ទំនងរវាងជនជាប់ចោទ និងជម្លោះប្រដាប់អាវុធ ឬទៅលើអត្ថិភាពនៃជម្លោះនោះទេ តែផ្ទុយទៅវិញ វាផ្តោតទៅលើការទទួលខុសត្រូវរបស់បុគ្គល ដែលក្នុងនោះរួមមាន តួនាទីរបស់ជនណាម្នាក់នៅក្នុងឋានានុក្រម ការដឹងឮ កាតព្វកិច្ច និង/ឬ ការមិនបានធ្វើសកម្មភាព[1203]។

---

[1202] *ផ្ទុយពី* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៨០។ *សូមមើល* តុលាការ ICTY *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Hadžihasanović និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-01-47-PT សេចក្តីសម្រេចលើការជំទាស់រួមគ្នាទៅនឹងយុត្តាធិការ អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០២ (“សេចក្តីសម្រេចលើការជំទាស់រួមគ្នាទៅនឹងយុត្តាធិការក្នុង*រឿងក្តី Hadžihasanović និងអ្នកផ្សេងទៀត*(ICTY)”) កថាខណ្ឌ ៧៥ (ឆ្លុះបញ្ចាំងអំពីគណៈកម្មការច្បាប់អន្តរជាតិ (“ILC”) និងការងាររបស់គណៈកម្មការនេះស្តីពីការរៀបរៀងក្រមស្តីពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ នៅឆ្នាំ១៩៥០ ថា បន្ទាប់ពីបានពិភាក្សាអំពីអត្ថិភាពនៃការទទួលខុសត្រូវរបស់ថ្នាក់លើ អង្គជំនុំជម្រះបានថា ““អំពើនៅក្នុងសេចក្តីព្រាងក្រម” បានបញ្ចូល អំពើប្រល័យពូជសាសន៍ ដែលអាចត្រូវបានប្រព្រឹត្តក្នុងពេលពុំមានជម្លោះប្រដាប់អាវុធ [...]”)។

[1203] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង សារី) (D427/1/30) កថាខណ្ឌ ៤១៨, ៤៦០។ ជាងនេះទៀត ចៅក្រមអន្តរជាតិរម្លឹកថា អត្ថបទរបស់ ILC ឆ្លុះបញ្ចាំងពីការពិចារណាផ្លូវច្បាប់ដែលសហគមន៍អន្តរជាតិបានចែករំលែកយ៉ាងទូលំទូលាយ និងអាចកំណត់យ៉ាងជំនាញអំពីវិធាននៃច្បាប់អន្តរជាតិ (សាលដីកាលើសហឧក្រិដ្ឋកម្មរួមក្នុងសំណុំរឿង ០០២ (D97/14/15) កថាខណ្ឌ ៦១ *ដកស្រង់ពី* តុលាការ ICTY *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Vasiljević* សំណុំរឿងលេខ IT-98-32-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង II ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០២ កថាខណ្ឌ ២០០)។ ក្នុងចំណុចនេះ ចៅក្រមអន្តរជាតិកត់សម្គាល់ថា មាត្រានានានៅក្នុងសេចក្តីព្រាងរបស់ ILC ដែលចែងពីគោលការណ៍នានានៃច្បាប់អន្តរជាតិ (ចាប់ផ្តើមប្រហែលក្នុងទសវត្សរ៍១៩៥០) និងការបន្តបញ្ជាក់របស់ ILC អំពីការទទួលខុសត្រូវរបស់ថ្នាក់លើក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ ពង្រឹងនូវអត្ថិភាព និងភាពអាចអនុវត្តន៍បាននៃទម្រង់នៃការទទួលខុសត្រូវនេះជារូបរាងនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលត្រូវបានបង្កើតឡើង (រួមទាំង ពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍) -- *សូមមើល* សេចក្តីសម្រេចលើការជំទាស់រួមគ្នាទៅនឹងយុត្តាធិការក្នុង*រឿងក្តី Hadžihasanović និងអ្នកផ្សេងទៀត* (ICTY) កថាខណ្ឌ ៨៩ (សម្រេចថា នៅឆ្នាំ១៩៨៦ ILC បានធ្វើបច្ចុប្បន្នភាពទៅលើមាត្រានានានៅក្នុងសេចក្តីព្រាង រួមទាំងបទប្បញ្ញត្តិជាក់លាក់មួយស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ ហើយថា បានបញ្ចូលអំពើប្រល័យពូជសាសន៍ទៅក្នុងបញ្ជីបទល្មើស ដែលអង្គជំនុំជម្រះសាលាដំបូងបានដកស្រង់ពីមាត្រានានានៅក្នុងសេចក្តីព្រាងរបស់ ILC ក្នុងផ្នែកដែលពាក់ព័ន្ធ ដើម្បីបញ្ជាក់ថា៖ “ការណ៍ដែលថា បទល្មើសមួយដែលត្រូវបានប្រព្រឹត្តដោយអ្នកក្រោមបង្គាប់មិនធ្វើឱ្យថ្នាក់លើរួចផុតពីការទទួលខុសត្រូវរបស់ខ្លួនឡើយ ប្រសិនបើពួកគេបានដឹង ឬមានព័ត៌មានដែលអាចឱ្យពួកគេសន្និដ្ឋាននៅក្នុងកាលៈទេសៈនានាដែលមានពេលនោះថា អ្នកក្រោមបង្គាប់កំពុងប្រព្រឹត្ត ឬបាននិងកំពុងប្រព្រឹត្តបទល្មើសនេះ ហើយប្រសិនបើពួកគេមិនបានចាត់វិធានការដែលអាចអនុវត្តបានទាំងអស់ទៅតាមសិទ្ធិអំណាចរបស់ខ្លួន ដើម្បីទប់ស្កាត់ ឬបង្ក្រាបបទល្មើសនោះ” (លុបជើងទំព័រ)), កថាខណ្ឌ ៩២ (ពិភាក្សាអំពីការទទួលខុសត្រូវរបស់ថ្នាក់លើ និងកត់សម្គាល់ថា បទ

៩៩៥. ហេតុនេះ ចៅក្រមអន្តរជាតិសូមបដិសេធមូលដ្ឋានទី ១២(១)។

## ៨. មូលដ្ឋានទី១៣÷ ថាតើ អ.វ.ត.ក មានយុត្តាធិការក្នុងការជំនុំជម្រះបទល្មើសជាតិដែលបានប្រព្រឹត្តចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ឬទេ

### ១.សារណា

៩៩៦. សហមេធាវីលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការចោទប្រកាន់ អោ អាន ពីអំពើមនុស្សឃាតគិតទុកជាមុន តាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ដោយសារអាជ្ញាយុកាលរយៈពេល ១០ ឆ្នាំ សម្រាប់បទឧក្រិដ្ឋជាតិដែលបានប្រព្រឹត្តិ នៅអំឡុងពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ បានកន្លងផុតទៅហើយ គឺនៅថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៨៩ ដែលជាពេលចុងក្រោយបំផុត[1204]។ មិនមានភស្តុតាងបង្ហាញថា រយៈកាលអាជ្ញាយុកាលត្រូវបានកាត់ផ្តាច់ ឬផ្អាកដោយសារការស៊ើបអង្កេត ឬការចោទប្រកាន់

---

ឧក្រិដ្ឋនានាដែលបានបញ្ចូលនៅក្នុងសេចក្តីព្រាងក្រម ឆ្នាំ១៩៩១ បានពង្រីកវិសាលភាពហួសពីជម្លោះប្រដាប់អាវុធ ដោយរាប់បញ្ចូលទាំងអំពើភេរវកម្មអន្តរជាតិ ការជួញដូរគ្រឿងញៀន និង ការធ្វើឱ្យអន្តរាយដល់បរិស្ថាន ព្រមទាំង អំពើប្រល័យពូជសាសន៍), កថាខណ្ឌ ៩៣(v) (ដែលអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់អំពីអត្ថិភាពនៃការទទួលខុសត្រូវរបស់មេបញ្ជាការមុនឆ្នាំ១៩៩១ ក្នុងការលើកឡើងថា "(v) ទ្រឹស្តីនេះត្រូវបានទទួលស្គាល់នៅពេលអនុវត្តចំពោះបទល្មើសនានាដែលបានប្រព្រឹត្តនៅពេលមាន ឬគ្មានជម្លោះប្រដាប់អាវុធt [...]" - អង្គជំនុំជម្រះសាលាដំបូងនេះក៏បានទទួលស្គាល់ផងដែរថា គិតមកត្រឹមពេលចេញសេចក្តីសម្រេចរបស់ខ្លួននៅ ឆ្នាំ២០០២ សញ្ញាណនេះមិនត្រូវបានបញ្ចូលនៅក្នុងដោយផ្ទាល់ទៅក្នុងកិច្ចព្រមព្រៀងអន្តរជាតិ ហើយក៏មិនត្រូវបានសម្រេចដោយស្ថាប័នតុលាការអន្តរជាតិណាមួយដែរ នៅពេលនោះ។ *សូមមើល* បន្ថែម សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំជំទាស់នឹងយុត្តាធិការពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់មេបញ្ជាការក្នុង *រឿងក្តី Hadžihasanović និងអ្នកផ្សេងទៀត* (ICTY) កថាខណ្ឌ ២០ ("[...] ការណ៍ដែលថា នៅក្នុងដំណើរការនៃជម្លោះប្រដាប់អាវុធអន្តរជាតិដែលថា ឧក្រិដ្ឋកម្មសង្គ្រាមហៀបនឹងប្រព្រឹត្ត ឬបានប្រព្រឹត្តនោះ មិនពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវរបស់មេបញ្ជាការទេ វាគ្រាន់តែជាការកំណត់លក្ខណៈបទឧក្រិដ្ឋដោយឡែកតែប៉ុណ្ណោះ ហើយមិនពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់មេបញ្ជាការឡើយ។ មូលដ្ឋាននៃការទទួលខុសត្រូវរបស់មេបញ្ជាការពឹងផ្អែកទៅលើកាតព្វកិច្ចរបស់គាត់ ក្នុងនាមជាមេបញ្ជាការកងទ័ពដែលបង្កើតជាកងកម្លាំងយោធាមានការរៀបចំដែលស្ថិតក្នុងបញ្ជាការរបស់គាត់ ហើយមិនស្ថិតនៅក្នុងករណីដោយឡែកដែលសមាជិកនៃកងកម្លាំងយោធានោះបានប្រព្រឹត្តអំពើនោះឡើយ")។ *សូមមើលផងដែរ រឿងក្តី Flick និងជនប្រាំនាក់ផ្សេងទៀត* (សំណុំរឿងលេខ ៤៨) សាលក្រម (NMT) ទំព័រ ២, ៤។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (នួន ជា និង អៀង ធីរិទ្ធ) (D427/2/15 & D427/3/15) កថាខណ្ឌ ២៣០។ សាលក្រមក្នុងសំណុំរឿង ០០២/០១ (E313) កថាខណ្ឌ ៧១៨។

1204 បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៨២-១៨៣, ១៨៥ *យោងទៅ ក្នុងចំណោមនោះ* សំណុំរឿង ០០៤ សំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរដោយសារកង្វះយុត្តាធិការលើបទល្មើស ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ D258 កថាខណ្ឌ ១៨-៣៤។ ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មាត្រា ១០៩, ១១១-១១២, ១១៤។

01635094



ឬដោយសារកាលៈទេសៈពិសេសឡើយ[1205]។ ជាងនេះទៀត ប្រទេសកម្ពុជាមិនបានអនុម័តច្បាប់ដែលអាចមានគោលដៅក្នុងការនាំឱ្យមាននូវការចោទប្រកាន់បទល្មើស ដែលអាចត្រូវបានរារាំងដោយផុតចិរវេលាឡើយ ហើយមាត្រា ៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលត្រូវបានអនុម័តក្រោយអាជ្ញាយុកាលបានកន្លងផុត មិនអាចពន្យារអាជ្ញាយុកាលបែបប្រតិសកម្មបានឡើយ[1206]។ ជាងនេះទៀត សហមេធាវីសង្កេតឃើញថា នៅក្នុងសំណុំរឿង ០០១ ក្រោយពីមិនអាចរកបានសម្លេងភាគច្រើនលើសលប់ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ជនជាប់ចោទមិនអាចត្រូវបានចោទប្រកាន់ពីបទល្មើសជាតិឡើយ[1207] និងបានសន្និដ្ឋានថា ក្នុងករណីពុំមានភាពប្រាកដប្រជា ច្បាប់ត្រូវយកមកអនុវត្តជាប្រយោជន៍ដល់ជនជាប់ចោទ[1208]។

៥៩៧. សហព្រះរាជអាជ្ញាអន្តរជាតិមិនបានឆ្លើយតបទៅនឹងមូលដ្ឋានទី ១៣ នៃបណ្តឹងឧទ្ធរណ៍របស់ អោ អាន ទេ ក្រៅពីលើកឡើងថា គាត់ជឿថា អំពើឧក្រិដ្ឋរបស់ អោ អាន ត្រូវបានរៀបរាប់ប្រសើរជាងនេះ នៅពេលដែលត្រូវបានកំណត់បទចោទជាឧក្រិដ្ឋកម្មអន្តរជាតិនៃអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ការកំណត់បទចោទនៃអំពើប្រព្រឹត្តនេះថាជាឧក្រិដ្ឋកម្មអន្តរជាតិ មិនមែនជាឧក្រិដ្ឋកម្មជាតិ អាចពន្លឿនកិច្ចដំណើរការនីតិវិធី ប្រសិនបើរឿងក្តីនេះត្រូវបានបញ្ជូនទៅជំនុំជម្រះ[1209]។

៥៩៨. សហមេធាវីពុំបានលើកឡើងអំពីមូលដ្ឋានទី ១៣ នៅក្នុងការឆ្លើយតបរបស់ខ្លួនទេ[1210]។

---

[1205] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៨៤ *យោងទៅ* សំណុំរឿង ០០១ សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលលើកឡើងដោយមេធាវីការពារក្តី ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E187 ("សេចក្តីសម្រេចក្នុងសំណុំរឿង ០០១ ស្តីពីអាជ្ញាយុកាលចំពោះបទល្មើសជាតិ (ឯកសារ E187)") កថាខណ្ឌ ១២, ២៧, ៣១-៣៥។

[1206] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៨៤ *យោងទៅ* សេចក្តីសម្រេច ក្នុងសំណុំរឿង ០០១ ស្តីពីអាជ្ញាយុកាលចំពោះបទល្មើសជាតិ (ឯកសារ E187) កថាខណ្ឌ ៤៣-៤៩, ៥០-៥៤។

[1207] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៨២ *យោងទៅ* សេចក្តីសម្រេច ក្នុងសំណុំរឿង ០០១ ស្តីពីអាជ្ញាយុកាលចំពោះបទល្មើសជាតិ (ឯកសារ E187) កថាខណ្ឌ ២៧-៣៥, ៣៩-៥៦។

[1208] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៨៥ និង ជើងទំព័រ ៤៧២។

[1209] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ (ឯកសារ D360/9) កថាខណ្ឌ ៩៧ *យោងទៅ* ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D351/5) កថាខន្ឌ ៦៣៦-៦៣៨។

[1210] *ប្រៀបធៀប* ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៥។

## ២. ការពិភាក្សា

៥៩៩. ចៅក្រមអន្តរជាតិសូមរម្លឹកថា មាត្រា ១០៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បានកំណត់អាជ្ញាយុកាល ១០ ឆ្នាំ ចំពោះបទឧក្រិដ្ឋ ៥ ឆ្នាំ ចំពោះបទមជ្ឈិម និង ១ ឆ្នាំ ចំពោះបទលហុ។ អាជ្ញាយុកាលទាំងនេះចាប់ផ្តើមរាប់ពីពេលដែលប្រព្រឹត្តបទល្មើស និងត្រូវបានផ្តាច់ដោយការផ្តើមកិច្ចស៊ើបសួររបស់តុលាការ ឬការចោទប្រកាន់។ នៅក្នុងករណីដែលមិនមានកិច្ចស៊ើបសួរ ថិរវេលានៃអាជ្ញាយុកាលពាក់ព័ន្ធនឹងបទល្មើសជាតិដែលត្រូវបានចោទប្រកាន់នៅក្នុងករណីនេះបានរលត់ យ៉ាងហោចណាស់ ១០ ឆ្នាំ ក្រោយពេលថិរវេលានៃការចោទប្រកាន់បានកន្លងផុតទៅ ពោលគឺនៅថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៨៩[1211]។

៦០០. ទោះជាយ៉ាងណាក្តី សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកត់សម្គាល់ថា[1212] នៅក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានជាឯកច្ឆ័ន្ទថា យុត្តាធិការរបស់ អ.វ.ត.ក ក្នុងការចោទប្រកាន់បទល្មើសជាតិដែលបានប្រព្រឹត្តចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ មិនត្រូវបានរាំងដោយអាជ្ញាយុកាលទេ[1213]។ ដូចដែលអង្គជំនុះជម្រះបានពន្យល់ថា "គោលការណ៍ជាមូលដ្ឋាននៃអាជ្ញាយុកាល គឺដើម្បីកំណត់ថិរវេលាមួយសម្រាប់ដំណើរការនីតិវិធីព្រហ្មទណ្ឌ។ ហេតុនេះ មានការសន្មតថា ស្ថាប័នតុលាការដំណើរការប្រកបដោយប្រសិទ្ធភាព ដើម្បីចាប់ផ្តើមកិច្ចដំណើរការនីតិវិធីបាន"[1214]។ ហេតុនេះ អង្គជំនុំជម្រះយល់ស្របទៅនឹង "ការសម្រេចជាឯកច្ឆ័ន្ទរបស់អង្គជំនុំជម្រះសាលាដំបូង [ក្នុងសំណុំរឿង ០០១] ដែលថា ថិរវេលាអាជ្ញាយុកាលមិនយកមកពិចារណាទេ នៅពេលស្ថាប័នតុលាការមិនដំណើរការ"[1215]។ ដោយហេតុថា អង្គជំនុំ

---

[1211] សាលដីកាសំណុំរឿង ០០២ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (អៀង សារី) (ឯកសារ D427/1/30) កថាខណ្ឌ ២៧៨។ សេចក្តីសម្រេច ក្នុងសំណុំរឿង ០០១ ស្តីពីអាជ្ញាយុកាលចំពោះបទល្មើសជាតិ (ឯកសារ E187) កថាខណ្ឌ ១០, ១២។ ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មាត្រា ១០៩-១១៤។ *សូមមើលផងដែរ* ដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ១៩៥។

[1212] ដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៥៩។

[1213] សាលដីកាសំណុំរឿង ០០២ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (អៀង សារី) (ឯកសារ D427/1/30) កថាខណ្ឌ ២៧៨-២៨៧។

[1214] សាលដីកាសំណុំរឿង ០០២ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (អៀង សារី) (ឯកសារ D427/1/30) កថាខណ្ឌ ២៨៥។

[1215] សាលដីកាសំណុំរឿង ០០២ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (អៀង សារី) (ឯកសារ D427/1/30) កថាខណ្ឌ ២៨៥ *យោងទៅ*សេចក្តីសម្រេច ក្នុងសំណុំរឿង ០០១ ស្តីពីអាជ្ញាយុកាលចំពោះបទល្មើសជាតិ (ឯកសារ E187) កថាខណ្ឌ ១៤, ១៦-១៧, ២៧, ២៩។

ជម្រះបានរកឃើញ "ថា ក្នុងចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ប្រព័ន្ធច្បាប់ ឬប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេសកម្ពុជាមិនមាននោះ ហេតុដូចនេះ ការស៊ើបសួរ ឬការចោទប្រកាន់ពីបទព្រហ្មទណ្ឌ មិនអាចធ្វើឡើងបានទេនៅក្នុងអំឡុងពេលនោះ [...]។ ហេតុនេះ ថិរវេលានៃអាជ្ញាយុកាលមិនបានចាប់ផ្ដើមរាប់ក្នុងអំឡុងពេលនោះឡើយ"[1216]។

៦០១. ទាក់ទិននឹងថិរវេលាបន្ទាប់ពីពេលដួលរលំរបបខ្មែរក្រហម អង្គបុរេជំនុំជម្រះយល់ស្របបន្ថែមទៀតទៅនឹងសេចក្ដីសន្និដ្ឋានរបស់ចៅក្រមជាតិទាំងបីរូបនៃអង្គជំនុំជម្រះសាលាដំបូងដែលថា "ចាប់តាំងពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨២ ប្រព័ន្ធតុលាការនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា មិនមានដំណើរការទាល់តែសោះ" ដោយសាររបបកម្ពុជាប្រជាធិបតេយ្យបានកម្ទេចប្រព័ន្ធតុលាការចោល ហើយថា ចាប់តាំងពីឆ្នាំ១៩៨២ "រហូតមកទល់នឹងពេលដែលព្រះរាជាណាចក្រកម្ពុជាត្រូវបានបង្កើតឡើងដោយរដ្ឋធម្មនុញ្ញថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ បញ្ហាប្រវត្តិសាស្ត្រ និងបរិការណ៍" *ក្នុងចំណោមនោះ* រួមមាន សង្គ្រាមស៊ីវិល ដំណើរការស្វែងរកសន្តិភាព និងការបន្តទទួលស្គាល់ជាអន្តរជាតិចំពោះពួកខ្មែរក្រហមថាជារដ្ឋាភិបាលរបស់កម្ពុជា "បានរារាំងយ៉ាងខ្លាំងដល់លទ្ធភាពក្នុងការចោទប្រកាន់ និងការស៊ើបសួរ"[1217]។ ហេតុនេះ ថិរវេលានៃអាជ្ញាយុកាលរយៈពេល ១០ ឆ្នាំសម្រាប់បទល្មើសជាតិដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ចាប់ផ្ដើមរាប់ពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣[1218]។ ហេតុនេះ អាជ្ញាយុកាលនេះបានកន្លងផុតនៅឆ្នាំ២០០៣ ដោយរាំងនូវការកាត់ផ្ដាច់នានា។

៦០២. ទោះជាយ៉ាងណាក្ដី មាត្រា ៣ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ដែលបានប្រកាសឱ្យប្រើនៅឆ្នាំ២០០១ មានបំណងពន្យារអាជ្ញាយុកាលចំពោះបទល្មើសជាតិនៅក្នុងយុត្តិការរបស់តុលាការរយៈពេល ២០ ឆ្នាំ ចំណែកមាត្រា ៣*ថ្មី* ដែលត្រូវបានអនុម័តជាវិសោធនកម្មច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក នៅឆ្នាំ២០០៤ បានពន្យារអាជ្ញាយុកាលដល់ទៅ ៣០ ឆ្នាំ។ ទាក់ទិននឹងបញ្ហានេះ ចៅក្រមអន្តរជាតិរម្លឹកថា ទោះបីការបង្កើតជាថ្មីនូវសិទ្ធិក្នុងការចោទប្រកាន់ក្រោយពេលអាជ្ញាយុកាលបានកន្លងផុត អាចរំលោភបំពានទៅមាត្រា

---

1216 សេចក្ដីសម្រេច ក្នុងសំណុំរឿង ០០១ ស្ដីពីអាជ្ញាយុកាលចំពោះបទល្មើសជាតិ (ឯកសារ E187) កថាខណ្ឌ ១៤។ សាលក្រមសំណុំរឿង ០០១ (ឯកសារ E188) កថាខណ្ឌ ៩៤។

1217 សាលដីកាសំណុំរឿង ០០២ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (អៀង សារី) (ឯកសារ D427/1/30) កថាខណ្ឌ ២៨៦ *ដកស្រង់ពី* សេចក្ដីសម្រេច ក្នុងសំណុំរឿង ០០១ ស្ដីពីអាជ្ញាយុកាលចំពោះបទល្មើសជាតិ (ឯកសារ E187) មតិយោបល់របស់ចៅក្រម និល ណុន ចៅក្រម យ៉ា សុខន និង ចៅក្រម ធូ មណី កថាខណ្ឌ ១៩-២០។ *សូមមើល*ផងដែរ កថាខណ្ឌ ១៨-២៥។

1218 សាលដីកាសំណុំរឿង ០០២ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (អៀង សារី) (ឯកសារ D427/1/30) កថាខណ្ឌ ២៨៦-២៨៧។

១៥(១) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[1219] និងគោលការណ៍នីត្យានុកូលភាពក៏ដោយ តែការពន្យារអាជ្ញាយុកាលមុនពេលផុតរលត់គឺជាបញ្ហាគោលនយោបាយរបស់រដ្ឋ និងមិនរំលោភបំពានទៅលើគោលការណ៍នីត្យានុកូលភាពទេ[1220]។ ហេតុនេះ ដោយហេតុថា ចិរវេលានៃអាជ្ញាយុកាលរយៈពេល ១០ឆ្នាំ ចំពោះបទល្មើសជាតិ មិនទាន់ផុតរលត់មុនពេលដែលមាត្រា ៣ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានពន្យារអាជ្ញាយុកាលនៅឆ្នាំ២០០១ និងឆ្នាំ២០០៤នោះ "ការពន្យារចិរវេលាដែលសភាជាតិបានអនុម័តនៅឆ្នាំ២០០១ និងឆ្នាំ២០០៤ រហូតដល់រយៈពេល ២០ ឆ្នាំ និងក្រោយមករហូតដល់រយៈពេល ៣០ ឆ្នាំ មិនបានរំលោភដល់គោលការណ៍នីត្យានុកូលភាពទេ"[1221]។

៦០៣. ហេតុចៅក្រមអន្តរជាតិសន្និដ្ឋានថា ឧក្រិដ្ឋកម្មជាតិដែលជាបទចោទលើ អោ អាន មិនបានផុតអាជ្ញាយុកាលទេ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសម្រេចបដិសេធមូលដ្ឋានទី ១៣ នៃបណ្តឹងឧទ្ធរណ៍។

## ថ. មូលដ្ឋានទី១៥(i)÷ អាពាហ៍ពិពាហ៍ដោយបង្ខំពុំស្ថិតនៅក្រោមយុត្តាធិការនៃ អ.វ.ត.ក

### ១. សារណា

៦០៤. សហមេធាវីការពារក្តីចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតមានកំហុស ដោយបានសន្និដ្ឋានថា អាពាហ៍ពិពាហ៍ដោយបង្ខំគឺជាឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ឬ ច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងឆ្នាំ១៩៧៥-ឆ្នាំ១៩៧៩[1222] និងបានសន្និដ្ឋានថា អាពាហ៍ពិពាហ៍ដោយបង្ខំគឺជាបទល្មើសនៅក្រោមអំពើអមនុស្សធម៌ផ្សេងទៀត[1223] ដោយបានសំអាងដោយភាន់ច្រឡំទៅលើ "ច្បាប់សិទ្ធិមនុស្សដើម្បីបង្កើតពិរុទ្ធភាពនៃអាពាហ៍ពិពាហ៍ដោយបង្ខំក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ"[1224]។ សហ

---

[1219] មាត្រា ១៥(១) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយចែងថា គ្មានជនណាម្នាក់ ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌចំពោះអំពើ ឬការខកខានណាមួយ ដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិក្នុងខណៈពេលប្រព្រឹត្តនោះឡើយ។

[1220] សាលដីកាសំណុំរឿង ០០២ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (អៀង សារី) (ឯកសារ D427/1/30) កថាខណ្ឌ ២៨២។

[1221] សាលដីកាសំណុំរឿង ០០២ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (អៀង សារី) (ឯកសារ D427/1/30) កថាខណ្ឌ ២៨៧។

[1222] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៩២។

[1223] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៩២។

[1224] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៩២។ *សូមមើលផងដែរ* ប្រតិចារឹកក្នុងសំណុំរឿង ០០៤/

ព្រះរាជអាជ្ញាអន្តរជាតិអះអាងថា "អំណះអំណាងរបស់ អោ អាន ស្តីពី "ភាពឧក្រិដ្ឋជាមូលដ្ឋាន" គួរត្រូវច្រានចោលភ្លាមៗ ដោយសារគាត់គ្រាន់តែលើកឡើងវិញពីអំណះអំណាងនានាពីចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ ដោយមិនបានបង្ហាញ" ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុស[1225]។ អំណះអំណាង និងការឆ្លើយតបបន្ថែមទៀតពាក់ព័ន្ធនឹងមូលដ្ឋានទី ១៥(ii) ដែលមិនអាចទទួលយកបាន ហើយនឹងមិនលើកយកមកបង្ហាញនៅក្នុងនេះទេ[1226]។

## ២. ការពិភាក្សា

៦០៥. ជាបញ្ហាបឋម ចៅក្រមអន្តរជាតិកត់សម្គាល់ឃើញថា សហមេធាវីប៉ុនប៉ងដាក់បញ្ចូល "ដោយយោង"[1227] លើទឡ្ហីករណ៍ជំទាស់តវ៉ាមុនៗ ដកស្រង់ចេញពី*សំណើសុំមោឃភាពអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ អោ អាន* ដែលត្រូវបានអង្គបុរេជំនុំជម្រះសម្រេច និងច្រានចោលរួចហើយ[1228]។ ទោះបីជាទឡ្ហីករណ៍ទាំងនេះត្រូវបានដាក់ជូននៅក្នុងដំណាក់កាលថ្មីមួយ ដោយដកស្រង់បញ្ហាជាក់លាក់នានាពាក់ព័ន្ធនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ក៏ដោយ ក៏ចៅក្រមអន្តរជាតិយល់ឃើញថា ពុំមានហេតុផលត្រូវសម្រេចខុសពីលើកមុនស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំនោះឡើយ។

៦០៦. ចៅក្រមអន្តរជាតិពុំជឿជាក់លើអំណះអំណាងរបស់សហមេធាវីការពារក្តីឡើយ និងយល់ឃើញថា ទឡ្ហីករណ៍របស់ពួកគេផ្ទុយនឹងច្បាប់ជាធរមាន ដោយហេតុថា៖ (១) អំពើអមនុស្សធម៌ផ្សេងទៀតមានអត្ថិភាពជាឧក្រិដ្ឋកម្មនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅមុន និង នៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ ឆ្នាំ

២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1 ERN 01626089-01626090 ទំព័រ ៣៥:២២-៣៦:៤។

[1225] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៩៩ (លេខយោងជើងទំព័រត្រូវបានលុបចោល)។

[1226] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ៩៨-១០៣។ បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៩៣។

[1227] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៩២ លេខយោងជើងទំព័រ ៤៨៧។

[1228] សំណុំរឿង ០០៤ សំណើរបស់ តា អាន សុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបអង្កេត ពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ A259។ សំណុំរឿង ០០៤ (អង្គបុរេជំនុំជម្រះ ២១) សេចក្តីពិចារណាលើសំណើរបស់ តា អាន សុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបអង្កេតពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ឯកសារ D257/1/8 ("សេចក្តីពិចារណាលើអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងសំណុំរឿង ០០៤ (ឯកសារ D257/1/8)")។

១៩៧៩[1229] (២) ពុំមានភាពចាំបាច់ត្រូវបង្ហាញអាពាហ៍ពិពាហ៍ដោយបង្ខំជាបទល្មើសព្រហ្មទណ្ឌមួយដោយឡែក (ឬ សំអាងលើច្បាប់សិទ្ធិមនុស្សអន្តរជាតិដើម្បីធ្វើដូច្នោះឡើយ)[1230] និង (៣) អាពាហ៍ពិពាហ៍ដោយបង្ខំអាចស្ថិតនៅក្នុងនិយមន័យដែលត្រូវបានទទួលស្គាល់ស្តីពីអំពើអមនុស្សធម៌ផ្សេងទៀត ហើយការវិភាគតាមករណីនីមួយៗ នឹងធ្វើឡើងលម្អិតស៊ីជម្រៅនៅក្នុងពេលជំនុំជម្រះ[1231]។ ចៅក្រមអន្តរជាតិយល់ឃើញថា វាគ្រប់គ្រាន់ក្នុងការបង្ហាញថា ប្រភេទជាក់លាក់នៃអំពើអមនុស្សធម៌ផ្សេងទៀតគឺជាឧក្រិដ្ឋកម្មអនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហេតុដូច្នេះ ធាតុផ្សំរបស់វាអាចឲ្យជនជាប់ចោទប្រមើលដឹងថាជាបទល្មើស និងដឹងថាមានច្បាប់ចែង[1232]។

៦០៧. ចំណុចទី១ ចៅក្រមអន្តរជាតិបញ្ជាក់ឡើងវិញម្តងទៀតនៅត្រង់នេះអំពីច្បាប់យុត្តិសាស្ត្រ ដែលកំណត់ថា ឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងទៀតបានទទួលឋានៈជាច្បាប់ទំនៀមទម្លាប់អន្តរជាតិអនុលោមតាមលក្ខខណ្ឌពេលវេលាពាក់ព័ន្ធនៅចន្លោះឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩[1233]។ ករណីនេះគាំទ្រ

---

[1229] ឧទាហរណ៍ សូមមើល សាលក្រម សំណុំរឿង ០០២/០២ (ឯកសារ E465) កថាខណ្ឌ ៧២៣។

[1230] ឧទាហរណ៍ សូមមើល សាលក្រម សំណុំរឿង ០០២/០២ (ឯកសារ E465) កថាខណ្ឌ ៤៣៦។

[1231] សូមមើល សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០២ (នួន ជា & អៀង ធីរិទ្ធ) (ឯកសារ D427/2/15 & D427/3/15) កថាខណ្ឌ ៣៩៧។ សំណុំរឿង ០០២ (អង្គបុរេជំនុំជម្រះ១៤៥ និង១៤៦) សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០១១ (ឯកសារលេខ D427/2/15 និង D427/3/15) (សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) (D427/2/15 និង D427/3/15) កថាខណ្ឌ១៦៦។

[1232] គោលការណ៍នីត្យានុកូលភាព ដូចមានចែងនៅក្នុងមាត្រា ១៥ នៃ ICCPR ទាមទារលក្ខខណ្ឌ អំពើល្មើស ឬ ទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក ត្រូវមានអត្ថិភាពនៅក្នុងច្បាប់ នៅក្នុងពេលដែលស្ថិតនៅក្នុងយុត្តាធិការពេលវេលា អ.វ.ត.ក។ លើសពីនេះ អំពើល្មើស ឬ ទម្រង់នៃការទទួលខុសត្រូវអាចត្រូវបានជនជាប់ចោទដឹង ច្បាស់ថាមានច្បាប់ចែង។ ICCPR មាត្រា ១៥។ *សូមមើលផងដែរ* សាលដីកាក្នុងសំណុំរឿង ០០២/១ ("ឯកសារ F36") កថាខណ្ឌ ៥៧៨។ សំណុំរឿង ០០៤ សេចក្តីពិចារណាលើអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងសំណុំរឿង ០០៤ (ឯកសារ D257/1/18) មតិយោបល់លើអង្គសេចក្តីរបស់ចៅក្រម BAIK និង BEAUVALLET (សេចក្តីពិចារណាលើអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងសំណុំរឿង ០០៤ (ឯកសារ D257/1/18) មតិយោបល់លើអង្គសេចក្តីរបស់ចៅក្រម BAIK និង BEAUVALLET កថាខណ្ឌ ១។

[1233] សាលក្រម សំណុំរឿង ០០២/២ (ឯកសារ E465) កថាខណ្ឌ ៧២៣។ សាលក្រម សំណុំរឿង ០០២/១ (ឯកសារ E313) កថាខណ្ឌ ៤៣៥។ សាលក្រមក្នុងសំណុំរឿង ០០១ ("ឯកសារ E188") កថាខណ្ឌ ៣៦៧។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០២ (នួន ជា & អៀង ធីរិទ្ធ) (ឯកសារ D427/2/15 & D427/3/15) កថាខណ្ឌ ១៣០, ១៥៧។ សំណុំរឿង ០០៤ សេចក្តីពិចារណាលើអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងសំណុំរឿង ០០៤ (ឯកសារ D257/1/18) មតិយោបល់លើអង្គសេចក្តីរបស់ចៅក្រម BAIK និង BEAUVALLET កថាខណ្ឌ ៩។ *សូមមើលផងដែរ* សំណុំរឿង *Brima និងអ្នក*

ដោយភស្តុតាងនៃ *ទស្សនៈច្បាប់* និងការអនុវត្តរបស់រដ្ឋ ដូចជា ការដាក់បញ្ចូលនិយាមនេះនៅក្នុងច្បាប់សន្ធិសញ្ញាចាប់តាំងពីឆ្នាំ១៩៤៥ ហើយនឹងការអនុវត្តនិយាមនេះនៅក្នុងរឿងក្តីក្រោយសង្គ្រាមលោកលើកទី២[1234]។ តុលាការនានាដែលបានបង្កើតឡើងក្រោយៗបានទទួលយកលក្ខណៈទំនៀមទម្លាប់នៃអំពើអមនុស្សធម៌ផ្សេងទៀត និងនៅពេលធ្វើការវាយតម្លៃ ដោយបានសំអាងលើប្រភពនៅមុនឆ្នាំ១៩៧៥[1235]។

៦០៨. អង្គជំនុំជម្រះជាច្រើននៅ អ.វ.ត.ក បានសម្រេចថា គេអាចប្រមើលដឹងថាជាបទល្មើស និងអាចដឹងថាមានច្បាប់ចែងថា អំពើអមនុស្សធម៌ផ្សេងទៀតអាចត្រូវបានផ្តន្ទាទោសជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅត្រឹមឆ្នាំ១៩៧៥[1236]។ នៅពេលអនុវត្តសញ្ញាណស្តីពី *ប្រភេទដូចគ្នា*[1237] អង្គបុរេជំនុំជម្រះបានរកឃើញថា ធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមានលក្ខណៈច្បាស់លាស់ និងជាក់លាក់គ្រប់គ្រាន់នៅត្រឹមឆ្នាំ១៩៧៥[1238]។ មានការកំណត់ និងយល់ឃើញជាទូទៅ "បុគ្គលម្នាក់អាចនឹងទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការប្រព្រឹត្តបទល្មើសដែលមាន "លក្ខណៈ និងស្ថានទម្ងន់ស្រដៀងគ្នា" ទៅនឹងឧក្រិដ្ឋកម្មប្រឆាំង

---

*ផ្សេងទៀត* សាលដីកា (តុលាការ SCSL) កថាខណ្ឌ ១៨៣។ តុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Stakić* សំណុំរឿង IT-97-24-A សាលដីកា ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ (សាលដីកាសាលាឧទ្ធរណ៍ *Stakić* (ICTY)) កថាខណ្ឌ ៣១៥។

[1234] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០២ (អៀង សារី) (ឯកសារ D427/1/30) កថាខណ្ឌ ៣៨១-៣៨៣។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០២ (នួន ជា & អៀង ធីរិទ្ធ) (ឯកសារ D427/2/15 & D427/3/15) កថាខណ្ឌ ១៣០។ *ឧទាហរណ៍ សូមមើល* ធម្មនុញ្ញតុលាការយោធាអន្តរជាតិ មាត្រា ៦(គ)។ ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ មាត្រា II(i)(គ)។ ធម្មនុញ្ញទីក្រុងតូក្យូ មាត្រា ៥(គ)។ របាយការណ៍នៃគណកម្មការច្បាប់អន្តរជាតិ ជូនចំពោះរដ្ឋសភា ស្តីអំពីគោលការច្បាប់អន្តរជាតិដែលបានទទួលស្គាល់ក្នុងធម្មនុញ្ញតុលាការនូរ៉ឹមប៊ើក និងនៅក្នុងសេចក្តីសម្រេចនៃអង្គជំនុំជម្រះ ក្នុងសៀវភៅប្រចាំឆ្នាំរបស់គណកម្មការច្បាប់អន្តរជាតិ ឆ្នាំ១៩៥០ វ៉ុល II គោលការណ៍ទី VI(គ) សេចក្តីសម្រេច តុលាការនូរ៉ឹមប៊ើក ទំព័រ ១៧៤ ២៥៣ ២៥៤ ដល់ ២៥៥។

[1235] សាលដីកា សំណុំរឿង ០០២/១ (ឯកសារ F36) កថាខណ្ឌ ៥៧៦។

[1236] សាលដីកា សំណុំរឿង ០០២/១ (ឯកសារ F36) កថាខណ្ឌ ៥៧៨។ សាលក្រម សំណុំរឿង ០០២/០២ (ឯកសារ E465) កថាខណ្ឌ ៧២៣។ សាលក្រមសំណុំរឿង ០០២/១ (ឯកសារ E313) កថាខណ្ឌ៤៣៥។

[1237] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០២ (អៀង សារី) (ឯកសារ D427/1/30) កថាខណ្ឌ ៣៨៩-៣៩០។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០២ (នួន ជា & អៀង ធីរិទ្ធ") (ឯកសារ D427/2/15 & D427/3/15) កថាខណ្ឌ ១៦១-១៦៤។

[1238] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០២ (អៀង សារី) (ឯកសារ D427/1/30) កថាខណ្ឌ ១៦៥។ សេចក្តីពិចារណាលើអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងសំណុំរឿង ០០៤ (ឯកសារ D257/1/18) មតិយោបល់លើអង្គសេចក្តីរបស់ចៅក្រម BAIK និង BEAUVALLET កថាខណ្ឌ ១២។ *សូមមើលផងដែរ* សាលដីកាក្នុងសំណុំរឿង ០០២/១ (ឯកសារ F36) កថាខណ្ឌ ៥៧៨។

មនុស្សជាតិដែលមានរៀបរាប់ដទៃទៀត"[1239]។

៦០៩. នៅពេលពិចារណាចំណុចខាងលើ ចៅក្រមអន្តរជាតិយល់ឃើញថា អំពើជាមូលដ្ឋាន ឬ ប្រភេទរង នៅក្នុងអំពើអមនុស្សធម៌ផ្សេងទៀត (ដូចជាអាពាហ៍ពិពាហ៍ដោយបង្ខំ) ពុំចាំបាច់កំណត់ជាបទល្មើសព្រហ្មទណ្ឌទេ ពីព្រោះគោលការណ៍នីត្យានុកូលភាព "ភ្ជាប់ទៅនឹងប្រភេទនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ទាំងមូល មិនមែនភ្ជាប់ទៅនឹងប្រភេទនីមួយៗ នៃបទល្មើសនេះនោះទេ"[1240]។ ការតម្រូវឱ្យអំពើជាមូលដ្ឋាននៃអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវកំណត់ជាបទល្មើសព្រហ្មទណ្ឌ នឹងធ្វើឱ្យទស្សនទាននៃអំពើអមនុស្សធម៌ផ្សេងទៀត ជាប្រភេទពុំជាក់លាក់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គ្មានប្រសិទ្ធភាព និងគ្មានតម្លៃ[1241]។

៦១០. ចំណុចទី២ ដោយសារគ្មានលក្ខខណ្ឌត្រូវបង្ហាញអាពាហ៍ពិពាហ៍ដោយបង្ខំជាឧក្រិដ្ឋកម្មមួយដោយឡែក កំហុសរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលបានអះអាងថាបានសំអាងលើច្បាប់សិទ្ធិមនុស្ស នោះ គឺពុំពាក់ព័ន្ធ និងពុំមានមូលដ្ឋានទេ[1242]។ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិអះអាងត្រឹមត្រូវថា "អំពើជាមូលដ្ឋាននៃអំពើអមនុស្សផ្សេងៗទៀត មិនចាំបាច់ទាល់តែជាអំពើឧក្រិដ្ឋតាមច្បាប់អន្តរជាតិនោះទេ"[1243]។

៦១១. ចំណុចទី៣ ការពិនិត្យទៅលើអំពើដែលបានចោទប្រកាន់ថាជាអាពាហ៍ពិពាហ៍ដោយបង្ខំ រួមបញ្ចូល

---

[1239] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០២ (អៀង សារី) (ឯកសារ D427/1/30) កថាខណ្ឌ ៣៩៦។ *សូមមើលផងដែរ* សាលដីកាក្នុងសំណុំរឿង ០០២/១ (ឯកសារ F36) កថាខណ្ឌ ៥៧៨។

[1240] សាលក្រមក្នុងសំណុំរឿង ០០២/១ (ឯកសារ E313) កថាខណ្ឌ ៤៣៦។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០២ (នួន ជា & អៀង ធីរិទ្ធ) (ឯកសារ D427/2/15 & ឯកសារ D427/3/15) កថាខណ្ឌ ១៥៦។ *សូមមើលបន្ថែម* សេចក្តីពិចារណាលើអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងសំណុំរឿង ០០៤ (ឯកសារ D257/1/18) មតិយោបល់លើអង្គសេចក្តីរបស់ចៅក្រម BAIK និង BEAUVALLET កថាខណ្ឌ ៩, ១៧ ដែលចៅក្រមអន្តរជាតិ បានសម្រេចនាពេលមុនថា ពាក្យ "បទល្មើសព្រហ្មទណ្ឌ" ពុំត្រូវបានបញ្ចូលនៅក្នុងឃ្លាស្តីពីអំពើអមនុស្សធម៌ផ្សេងទៀតនៅក្នុងមាត្រា ៦(គ) នៃធម្មនុញ្ញ Nuremberg ហើយយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ ពុំចាត់ទុកអំពើជាក់លាក់ផ្សេងទៀត ជាបទល្មើស។

[1241] សាលដីកា ក្នុងសំណុំរឿង ០០២/១ (ឯកសារ F36) កថាខណ្ឌ ៥៨៤។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០២ (អៀង សារី) (ឯកសារ D427/1/30) កថាខណ្ឌ ៣៧៨។ *សូមមើលផងដែរ* សាលក្រមក្នុងសំណុំរឿង ០០២/១ (ឯកសារ E313) កថាខណ្ឌ ៤៣៦។ រឿងក្តី *Brima និងអ្នកផ្សេងទៀត* សាលដីកា (តុលាការ SCSL) កថាខណ្ឌ ១៨៣។

[1242] *ផ្ទុយនឹង* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៩២។

[1243] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៨១។

ការវាយតម្លៃថាតើ អង្គហេតុមានស្ថានទម្ងន់ និងលក្ខណៈស្រដៀងគ្នានឹងឧក្រិដ្ឋកម្មដូចមានចែងផ្សេងទៀត នៅក្រោមអំពើអមនុស្សធម៌ផ្សេងទៀត ដែរឬយ៉ាងណា[1244]។ បញ្ហាចោទនេះត្រូវតែពិចារណាទៅតាមករណីនីមួយៗ ដោយត្រូវពិចារណាឱ្យបានត្រឹមត្រូវលើកាលៈទេសៈនៃរឿងក្តីនីមួយៗ[1245]។ កត្តានានាដែលត្រូវពិចារណានៅក្នុងការវិភាគលក្ខណៈ និងស្ថានទម្ងន់ស្រដៀងគ្នានឹងឧក្រិដ្ឋកម្មដូចមានចែងរៀបរាប់ផ្សេងទៀត អាចរួមបញ្ចូលជាអាទិ "ប្រភេទនៃអំពើសកម្ម ឬ អកម្ម បរិបទដែលវាបានកើតឡើង កាលៈទេសៈផ្ទាល់របស់ជនរងគ្រោះ រាប់បញ្ចូលទាំង អាយុ ភេទ និងសុខភាព ព្រមទាំងផលប៉ះពាល់ផ្នែកសីលធម៌ ផ្លូវកាយ និងផ្លូវចិត្តនៃអំពើនោះមកលើជនរងគ្រោះ"[1246]។ ចៅក្រមអន្តរជាតិពិចារណាឃើញថា ការវិភាគនេះតម្រូវឱ្យធ្វើឡើងលម្អិតស៊ីជម្រៅលើភស្តុតាងទាំងមូល ដែលសមបំផុតនោះគួរទុកជូនអង្គជំនុំជម្រះសាលាដំបូង។

៦១២. ហេតុដូច្នេះ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានកំហុសទេ ហើយអំពើអមនុស្សធម៌ផ្សេងទៀតមានអត្ថិភាពជាឧក្រិដ្ឋកម្មមួយប្រភេទនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅឆ្នាំ១៩៧៥-ឆ្នាំ១៩៧៩ ហើយធាតុផ្សំពាក់ព័ន្ធនៃឧក្រិដ្ឋកម្ម អាចឱ្យជនជាប់ចោទប្រមើលដឹងថាជាបទល្មើស និងអាចដឹងថាមានច្បាប់ចែង។ អាស្រ័យហេតុនេះ មូលដ្ឋានទី១៥(១) ត្រូវបានច្រានចោល។

---

1244 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០២ (អៀង សារី) (ឯកសារ D427/1/30) កថាខណ្ឌ ៣៩៦។ *សូមមើលផងដែរ* សាលដីកាក្នុងសំណុំរឿង ០០២/១ (ឯកសារ F36) កថាខណ្ឌ ៥៧៨។

1245 សាលក្រម នៅក្នុងសំណុំរឿង ០០២/២ (ឯកសារ E465) កថាខណ្ឌ ៧២៥។ សាលក្រម នៅក្នុងសំណុំរឿង ០០១ (ឯកសារ E188) កថាខណ្ឌ ៣៦៩។ សាលក្រម នៅក្នុងសំណុំរឿង ០០២/១ (ឯកសារ E313) កថាខណ្ឌ ៤៣៨។ *សូមមើលផងដែរ* តុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kordić* និង *Čerkez* កថាខណ្ឌ ១១៧។ តុលាការ ICTR រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kayishema* និង *Ruzindana* កថាខណ្ឌ ១៥១។

1246 សេចក្តីពិចារណាលើអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងសំណុំរឿង ០០៤ (ឯកសារ D257/1/18) មតិយោបល់លើអង្គសេចក្តីរបស់ចៅក្រម BAIK និង BEAUVALLET កថាខណ្ឌ ១៦។ សាលក្រម ក្នុងសំណុំរឿង ០០២/២ (ឯកសរ E465) កថាខណ្ឌ ៧២៥។ *សូមមើលផងដែរ* តុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Vasiljević* សាលដីកា សំណុំរឿង IT-98-32-A អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤ កថាខណ្ឌ ១៦៥។ រឿងក្តី *Brima និងអ្នកផ្សេងទៀត* សាលដីកា (SCSL) កថាខណ្ឌ ១៨៤។

## ខ. មូលដ្ឋានទី១៦(ii) និង១៦(iii)÷ ការអនុវត្តដោយខុសឆ្គងនូវធាតុផ្សំ អំពើប្រល័យពូជសាសន៍

### ១. សារណា

៦១៣. សហមេធាវីការពារក្តីជំទាស់ចំពោះការសម្រេចដោយខុសឆ្គងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា អោ អាន ទទួលខុសត្រូវលើអំពើប្រល័យពូជសាសន៍ ហើយថាគាត់ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់តុលាការ[1247]។ ទីមួយសហមេធាវីការពារក្តីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានបង្ហាញថា ប្រជាជនចាម ត្រូវបានកំណត់អត្តសញ្ញាណ និងកំណត់គោលដៅជាវិជ្ជមាន ជាអាទិ៍ ដោយយោងទៅលើអត្តសញ្ញាណក្រុមជាក់លាក់មួយ[1248]។ ផ្ទុយទៅវិញ ការព្យាយាមបង្ហាញថា ជនជាតិចាមត្រូវបានកំណត់គោលដៅជាអវិជ្ជមាន ជាផ្នែកមួយនៃក្រុមជនរងគ្រោះទូលាយ ដែលគេហៅថាជា "ខ្មាំង" សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានអនុវត្តនូវធាតុផ្សំ *អត្តនោម័ត*ត្រឹមត្រូវ នៃអំពើប្រល័យពូជសាសន៍ឡើយ[1249]។ សហមេធាវីការពារក្តីអះអាងថា ការនេះបណ្តាលឱ្យមានការសម្រេចដោយខុសឆ្គងថា អោ អាន និងក្រុមសហឧក្រិដ្ឋកម្មរួម មានចេតនាចាំបាច់ក្នុងការប្រព្រឹត្ត អំពើប្រល័យពូជសាសន៍ ប្រឆាំងជនជាតិចាម[1250]។

៦១៤. ទីពីរ សហមេធាវីការពារក្តីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ "ខកខានមិនបានអនុវត្តលក្ខខណ្ឌ *អត្តនោម័ត* នៃអំពើប្រល័យពូជសាសន៍ចំពោះ អោ អាន និងខកខានមិនបានបង្ហាញថា អោ អាន មានចេតនាប្រល័យពូជសាសន៍ជាក់លាក់"[1251]។ សហមេធាវីការពារក្តីចោទប្រកាន់ថា "ដើម្បីបង្ហាញភាពចិត្តរបស់បុគ្គលម្នាក់ តាមការសន្និដ្ឋាន គឺត្រូវធ្វើការសន្និដ្ឋានដោយមានហេតុផល ផ្អែកលើភស្តុតាងដែល

---

[1247] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៩៩។ ប្រតិចារិកក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1 ERN 01626082-01626083 ERN 01626083 ទំព័រ ២៩:១-២៩:៩។

[1248] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1), កថាខណ្ឌ ១៩៨។ ប្រតិចារិកក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1 ERN 01626083-01626084 ទំព័រ ២៩:១៤-២៩:២១។

[1249] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1), កថាខណ្ឌ ១៩៨។ ប្រតិចារិកក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1 ERN 01626083-01626084 ទំព័រ ២៩:១៤-២៩:២១។,

[1250] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1), កថាខណ្ឌ ១៩៧-១៩៨។ ប្រតិចារិកក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1 ERN 01626083-01626084 ទំព័រ ២៩:១៤-២៩:២១។

[1251] បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1), កថាខណ្ឌ ១៩៩។ ប្រតិចារិកក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1 ERN 01626083-01626084 ទំព័រ ២៩:២១-២៩:២៤។

01635104



មាន"[1252]។ ដោយសារតែ អោ អាន មិនមែនជាមេដឹកនាំជាន់ខ្ពស់ នៃបក្សកុម្មុយនីស្តកម្ពុជា ឬជាស្ថាបនិកនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមការចោទប្រកាន់[1253] និងដោយសារតែ "គាត់អាចទទួលតែបទបញ្ជាពីថ្នាក់លើ" គឺអាចមានការសន្និដ្ឋានដោយសមហេតុផលថា "ការងុប ងល់របស់ អោ អាន ទៅលើបក្សកុម្មុយនីស្តកម្ពុជា អាចនាំឱ្យគាត់ "មានភាពស្វិតស្វាញ" អនុវត្តភារកិច្ចរបស់គាត់ ដោយគ្មានចេតនាប្រល័យពូជសាសន៍"[1254]។ បន្ថែមលើនេះ ភស្តុតាងអំពីការដឹងឮរបស់ អោ អាន តាមរយៈរបាយការណ៍ និងការចូលរួមរបស់គាត់នៅក្នុងការប្រជុំ បង្ហាញយ៉ាងច្រើនបំផុតត្រឹមថា គាត់ប្រហែលជាបានដឹងឮ អំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង ប្រឆាំងប្រជាជនចាម ដែលមិនអាចបំពេញបានតាមលក្ខខណ្ឌតម្រូវតឹងរឹងនៃចេតនាប្រល័យពូជសាសន៍ឡើយ[1255]។

៦១៥. ជាចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់ថា សហមេធាវីការពារក្តីមិនបានបង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងអង្គច្បាប់ ឬអង្គហេតុ ក្នុងការអនុវត្តធាតុផ្សំនៃ អំពើប្រល័យពូជសាសន៍[1256]ឡើយ។ ទីមួយ សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់ថា សហមេធាវីការពារក្តីអះអាងដោយខុសថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានសម្រេចថា អោ អាន និងសមាជិកសហឧក្រិដ្ឋកម្មរួមដទៃទៀត បានកំណត់អត្តសញ្ញាណ និងកំណត់គោលដៅជាវិជ្ជមាន ជាអាទិ៍ចំពោះជនជាតិចាម បើទោះបីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានធ្វើការសម្រេចបែបនេះម្តងហើយម្តងទៀត និងយ៉ាងច្បាស់លាស់ក៏ដោយ[1257]។ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកទឡ្ហីករណ៍ថា ការសម្រេចដែល

---

1252 បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៩៩។ ប្រតិចារឹកក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1 ERN 01626083-01626084 ERN 01626121 ទំព័រ ២៩:២៣-២៩:២៤ ទំព័រ ៦៧:២៥-៦៨:៦។, D359/9.1 & D360/18.1, ERN 01626083-01626084, 01626121, ទំព័រ ២៩:១០ ដល់ ៣០:១៤,៦៧:២១ ដល់ ៦៨:៦។

1253 បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1), កថាខណ្ឌ ២០០។ ប្រតិចារឹកក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1 ERN 01626083 ទំព័រ ៣០:១-៣០:១៤។

1254 បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1), កថាខណ្ឌ ២០១។ ប្រតិចារឹកក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1 ERN 01626084 ទំព័រ ៣០:១-៣០:១៤។

1255 បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1), កថាខណ្ឌ ២០២។

1256 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ១០៥។

1257 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ១០៦ *យោងទៅរក*ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៥៩០-៦៧៧ ៨១២-៨១៩ ជាពិសេស កថាខណ្ឌ ៦១៤-៦១៥, ៦២៣, ៦៣៣-៦៣៧, ៧០៨, ៨១៧-៨១៩។ ប្រតិចារឹកក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែ

សហមេធាវីការពារក្ដីបានដកស្រង់ គ្រាន់តែបង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រេចថា សមាជិកសហឧក្រិដ្ឋកម្មរួម កំណត់មុខសញ្ញា ប្រជាជនជាច្រើនថាជាខ្មាំង ដែលក្នុងនោះមានទាំងជនជាតិចាម ហើយកំណត់គោលដៅទៅលើពួកគេ សម្រាប់ឧក្រិដ្ឋកម្មផ្សេងៗជាច្រើនប្រភេទ[1258]។

៦១៦. ទីពីរ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សហមេធាវីការពារក្ដីមិនបានបង្ហាញថា មិនមានអ្នកវិនិច្ឆ័យការពិតដ៏សមហេតុផលណា បានសម្រេចដោយផ្អែកលើភស្តុតាងផ្ទាល់ និងមានការគាំទ្រនៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ថា ការសន្និដ្ឋានដ៏សមហេតុផលតែមួយគត់នោះគឺថា អោ អាន មានចេតនាជាក់លាក់ ក្នុងការកម្ទេចជនជាតិចាម ក្នុងភូមិភាគកណ្ដាល នៃខេត្តកំពង់ចាម[1259]។ សហព្រះរាជអាជ្ញាអន្តរជាតិបានបន្តថា ទោះបីជាការដឹងឮ រួមជាមួយការចូលរួមជាបន្ត អាចជាការសន្និដ្ឋានបានអំពីចេតនារបស់បុគ្គលម្នាក់ក្ដី ក៏ អោ អាន មិនគ្រាន់តែបានដឹងអំពីការបោសសម្អាត ឬគ្រាន់តែបន្តចូលរួមក្នុងគោលបំណងរួមនោះឡើយ។ ប៉ុន្តែ អោ អាន បានចេញបញ្ជាយ៉ាងជាក់លាក់ ឱ្យមានការបោសសម្អាត និងធានាថាមានការអនុវត្តតាមបញ្ជានោះ[1260]។ លើសពីនេះទៅទៀត ចេតនាជាក់លាក់មិនតម្រូវថា អោ អាន ត្រូវតែជាមេដឹកនាំជាន់ខ្ពស់ ឬជាអ្នកផ្ដើមគោលនយោបាយ ប្រល័យពូជសាសន៍នោះឡើយ ប៉ុន្តែផ្ទុយទៅវិញតម្រូវថា គាត់មានចេតនា ឱ្យអ្នកនៅក្រោមបង្គាប់គាត់ ធ្វើការបោសសម្អាតជនជាតិចាម ពីភូមិភាគកណ្ដាល នៅពេលដែលគាត់ចេញបញ្ជា ដល់អ្នកក្រោមបង្គាប់របស់គាត់ ឱ្យអនុវត្តការងារនេះ[1261]។ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ការអនុវត្តតាមបញ្ជារបស់ថ្នាក់លើ មិនអាចយកជាមូលដ្ឋានដើម្បី

---

មិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1 ERN 01626102-01626103 ទំព័រ ៤៨:១២-៤៩:៨។

[1258] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ១០៦។

[1259] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ១០៧-១០៨ *យោងទៅរក* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៦២៣, ៦៣៣-៦៣៧, ៧០៨, ៨១៨-៨១៩, ៨២៥(iii) ៨២៦, ៨២៩-៨៣០។ សហព្រះរាជអាជ្ញាអន្តរជាតិ ក៏បានលើកទឡ្ហីករណ៍ផងដែរថា តាមការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺច្បាស់ណាស់ថា បទចោទទី១ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ គួរត្រូវបានកម្រិតកំណត់តែចំពោះជនជាតិចាមនៅក្នុងខេត្តកំពង់ចាម ក្នុងភូមិភាគកណ្ដាល ដូចនេះគឺជាការសមស្របសម្រាប់អង្គបុរេជំនុំជម្រះ ក្នុងការកំណត់ប្រភេទឡើងវិញនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ សូមមើល ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ១០៧ ជើងទំព័រ ២៦៧។

[1260] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ១០៨។ ប្រតិចារឹកក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1 ERN 01626101-01626102 ទំព័រ ៤៧:១៣-៤៧:១៦, ៤៩:១៦-៥០:១។

[1261] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ១០៨។

ការពារខ្លួននោះទេ ហើយរឿងក្តីដែលសហមេធាវីការពារក្តីបានដកស្រង់ គឺមិនសមហេតុផលនោះទេ ដោយសារតែមិនមានរឿងក្តីណាមួយដែលជាប់ពាក់ព័ន្ធនឹងជនជាប់ចោទជាអ្នកអនុវត្តដ៏សំខាន់ នូវគោលនយោបាយប្រល័យពូជសាសន៍ ក្នុងតំបន់គ្រប់គ្រងរបស់ខ្លួន ឬជាអ្នកដែលបានបញ្ជាថ្នាក់ក្រោមរបស់ខ្លួនដោយផ្ទាល់ ឱ្យសម្លាប់ក្រុមដែលបានកំណត់គោលដៅនោះឡើយ[1262]។

៦១៧. នៅក្នុងការឆ្លើយតប សហមេធាវីការពារក្តីបន្តរក្សាជំហរថា ប្រជាជនចាមមិនត្រូវបានកំណត់អត្តសញ្ញាណ និងកំណត់គោលដៅជាវិជ្ជមាន ជាអាទិ៍ឡើយ ដែលដូច្នេះហើយ អោ អាន មិនមានចេតនាជាក់លាក់ក្នុងការ ប្រព្រឹត្តអំពើប្រល័យពូជសាសន៍ទេ[1263]។ បន្ថែមលើនេះ ផ្ទុយពីការបកស្រាយដោយមិនត្រឹមត្រូវរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សហមេធាវីការពារក្តីបានជំទាស់ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងដោយមិនពិចារណា ទៅលើភស្តុតាងដែលថា អោ អាន មិនមែនជាថ្នាក់ដឹកនាំជាន់ខ្ពស់ និងមិនមែនជាស្ថានិកនៃយុទ្ធនាការ ប្រល័យពូជសាសន៍នោះឡើយ[1264]។ កត្តាទាំងអស់នេះ ក្នុងចំណោមកត្តាដទៃផ្សេងទៀត គឺពាក់ព័ន្ធជាមួយការវាយតម្លៃ ទៅលើចេតនាប្រល័យពូជសាសន៍ ហើយបង្ហាញអំពីការសន្និដ្ឋាន ដោយសមហេតុផលផ្សេងទៀតដែលថា អោ អាន មិនមានចេតនាបែបនេះឡើយ[1265]។

## ២. ការពិភាក្សា

៦១៨. ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនមានកំហុសឆ្គងឡើយក្នុងការអនុវត្ត ធាតុផ្សំប្រល័យពូជសាសន៍ ព្រោះ (១) ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) បានកំណត់អត្តសញ្ញាណ និងកំណត់ក្រុមដែលត្រូវបានការពារ (ជនជាតិចាម) ជាអាទិ៍ និង (២) ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) បង្ហាញនូវភស្តុតាងស៊ីសង្វាក់ និងជាក់លាក់គ្រប់គ្រាន់ថា អោ អាន មានចេតនាជាក់លាក់ដែលបានតម្រូវ សម្រាប់អំពើប្រល័យពូជសាសន៍។ ផ្នែកខាងក្រោមនឹងពិភាក្សាអំពីមូលដ្ឋាន ១៦(ii) និង១៦( iii)។

---

[1262] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) កថាខណ្ឌ ១០៨។ ប្រតិចារឹកក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1 ERN 01626103 ទំព័រ ៤៩:៨-៤៩:១៤។

[1263] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៦១។

[1264] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៥៩។

[1265] ការឆ្លើយតបរបស់ អោ អាន (ឯកសារ D360/11) កថាខណ្ឌ ៥៩។

៦១៩. ទីមួយ ចំពោះបញ្ហាកំណត់ថាជនជាតិចាម ជាក្រុមដែលត្រូវទទួលបានការការពារ ចៅក្រមអន្តរជាតិគាំទ្រនូវលក្ខណៈដ៏សំខាន់នៃលក្ខខណ្ឌតម្រូវនេះ ដែលមានចែងនៅក្នុងមាត្រា២ នៃអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ និងមាត្រា៤ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ដែលចែងអំពីក្រុមដែលត្រូវបានការពារថាជា "ក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ"[1266]។ ចេតនាបំផ្លិចបំផ្លាញរបស់ចារីចាំបាច់ត្រូវតែផ្អែកជាពិសេសទៅលើសមាជិកភាពរបស់ជនរងគ្រោះនៅក្នុងក្រុម គឺមិនមែនលើលក្ខណៈបុគ្គលរបស់ជនរងគ្រោះឡើយ[1267]។ មានការចែងបន្តថា ក្រុមដែលត្រូវបានការពារ ចាំបាច់ត្រូវតែមានអត្តសញ្ញាណជាក់លាក់ ហើយត្រូវបានកំណត់ថាមានអត្តសញ្ញាណបែបនេះ ដោយលក្ខណៈជាទូទៅរបស់ក្រុមនោះ គឺមិនមែនដោយសារការមិនមានលក្ខណៈទាំងនោះទេ។ ក្រុមដែលត្រូវបានការពារមិនអាចត្រូវបានកំណត់ដោយលក្ខណៈវិជ្ជមានឡើយ[1268]។

[1266] អ.វ.ត.ក មានយុត្តាធិការលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដូចមានចែងក្នុងអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ មាត្រា ២ ("នៅក្នុងអនុសញ្ញាបច្ចុប្បន្ននេះ អំពើប្រល័យពូជសាសន៍សំដៅលើ អំពីទាំងឡាយណាដែលប្រព្រឹត្តិឡើង ក្នុងគោលបំណងបំផ្លាញទាំងស្រុងឬដោយផ្នែក នូវក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ")។ សូមមើលផងដែរ ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក, មាត្រា ៤ ("អំពើប្រល័យពូជសាសន៍ដែលគ្មានអាជ្ញាយុកាល គឺជាអំពីមួយក្នុងចំណោមអំពើដូចខាងក្រោម ដែលបានប្រព្រឹត្តក្នុងគោលបំណង បំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ [...]")។ សាលក្រមសំណុំរឿង ០០២/០២ (ឯកសារ E465) កថាខណ្ឌ ៧៩០, ៧៩៧។

[1267] *សូមមើលជាឧទាហរណ៍* សាលក្រមរឿងក្ដី *Karadžić* (តុលាការ ICTY) សាលដីកាអង្គជំនុំជម្រះសាលាដំបូង លេខIT-95-5/18-T ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ៥៥១។ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង* *Tolimir* IT-05-88/2-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ កថាខណ្ឌ ៧៤៧។ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង* *Popović និងអ្នកដទៃទៀត* IT-05-88-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង ॥ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ ("សាលក្រមរឿងក្ដី *Popović និងអ្នកដទៃទៀត* (តុលាការ ICTY)") កថាខណ្ឌ ៨២១។ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង* *Krajišnik* IT-00-39-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៦ កថាខណ្ឌ ៨៥៦។ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង* *Blagojević and Jokić* IT-02-60-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ កថាខណ្ឌ ៦៦៩។ តុលាការ ICTR *រដ្ឋអាជ្ញា តទល់នឹង* *Niyitegeka* ICTR-96-14-A សាលក្រម អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ៥៣ ។ សាលក្រមរឿងក្ដី *Akayesu* (តុលាការ ICTR) កថាខណ្ឌ ៥២១។ សូមមើលផងដែរ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៩៨ ជើងទំព័រ ២៣៤, ២៣៥។

[1268] រឿងក្ដីទាក់ទងការអនុវត្តអនុសញ្ញាស្ដីពីការរារាំង និងដាក់ទណ្ឌកម្មលើ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (បូស្នី និង ហឺសេហ្គោវីន *តទល់នឹង សែប៊ី និង ម៉ុងតេណេក្រូ*) សាលក្រម របាយការណ៍តុលាការយុត្តិធម៌អន្តរជាតិ ឆ្នាំ២០០៧ (ថ្ងៃទី២៦ ខែកុម្ភៈ) ទំព័រ៤៣ ("*ការអនុវត្តអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍* (តុលាការយុត្តិធម៌អន្តរជាតិ)") កថាខណ្ឌ ១៩១-១៩៤ ។ សាលក្រមសំណុំរឿង ០០២/០២(ឯកសារ E465)កថាខណ្ឌ ៧៩៣។ សាលដីការឿងក្ដី *Stakić* (តុលាការ ICTY)កថាខណ្ឌ ២០-២៨។

៦២០. នៅក្នុងសំណុំរឿងបច្ចុប្បន្ននេះ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនមានកំហុសឆ្គងឡើយ ហើយបានកំណត់អត្តសញ្ញាណជនជាតិចាម ដោយរួមបញ្ចូលជាក្រុមជាក់លាក់មួយ ដែលត្រូវកំណត់គោលដៅសម្រាប់លក្ខណៈជាតិពន្ធុ និងសាសនាជាក់លាក់របស់ពួកគេ។ ចៅក្រមអន្តរជាតិសូមច្រានចោលនូវទឡ្ហីករណ៍ពាក់ព័ន្ធនឹងចំណុចនេះ ហើយពិចារណាថា សហមេធាវីការពារក្តីបានកំណត់ដោយសម្រិតសម្រាំងនូវករណីខ្លះៗ ដែលយោងទៅរកក្រុមជនរងគ្រោះទូលាយ តែចំពោះដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) បានកំណត់អត្តសញ្ញាណយ៉ាងច្បាស់លាស់ថា ជនជាតិចាម គឺជាក្រុមដែលត្រូវបានការពារ ហើយកំណត់និយមន័យពួកគេបែបនេះ[1269]។

---

[1269] *សូមមើលជាឧទាហរណ៍*, ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360), កថាខណ្ឌ ១៩៥ (“ការកំណត់គោលដៅលើក្រុមជាក់លាក់ រួមទាំង [...] ជនជាតិចាម”) កថាខណ្ឌ ២១៨ (“បក្សកុម្មុយនីស្តកម្ពុជា បានកំណត់អត្តសញ្ញាណ និងកំណត់គោលដៅលើប្រភេទប្រជាជនជាក់លាក់ ដែលគេយល់ថាបង្កការគំរាមកំហែងខ្លាំង ដល់របបកម្ពុជាប្រជាធិបតេយ្យ ឬមានទស្សនៈផ្ទុយពីលទ្ធិរបស់ ប.ក.ក រួមទាំង [...] ជនជាតិចាម”) កថាខណ្ឌ ២២០ (“នៅដើមឆ្នាំ១៩៧៦ កែ ពក បានរាយការណ៍ជូន ប៉ុល ពត អំពីសភាពការណ៍ខ្លាំង នៅភូមិភាគកណ្តាល (ឧត្តរចាស់) ដោយបានហៅប្រជាជនចាម [...] ថាជាខ្មាំង”) កថាខណ្ឌ ៣០២ (“អោ អាន បានបញ្ជា ប្រាក់ យុត លេខាស្រុកកំពង់សៀម និងលេខាស្រុកដទៃទៀត ឲ្យកំណត់អត្តសញ្ញាណ និងចាប់ជនជាតិចាម [...]។ ក្នុងករណីខ្លះ អោ អាន បានផ្តល់បញ្ជីឈ្មោះទៅ ប្រាក់ យុត ហើយបញ្ជាឲ្យគាត់ចាប់បុគ្គលជាក់លាក់ទាំងនោះ រួមទាំងជនជាតិចាម [...]។”) កថាខណ្ឌ ៣០៣ (“លើសពីនេះទៀត អោ អាន បានបញ្ជាឲ្យយោធាតំបន់ ចាប់ខ្លួនជនជាតិចាម [...]”) កថាខណ្ឌ ៣០៥ (“សាក្សីបានរៀបរាប់យ៉ាងស៊ីសង្វាក់ថា កម្មាភិបាលភូមិភាគនិរតី ក្រោមឱវាទរបស់ អោ អាន បានចាប់និងសម្លាប់ ក្នុងទ្រង់ទ្រាយធំ និងមានបែបបទ នូវ [...] ជនជាតិចាម”) កថាខណ្ឌ ៣១១ (“អោ ងាន បានបញ្ជាមេស្រុក និងមេឃុំឲ្យ [...] ធ្វើបញ្ជី [...] “*ប្រជាជនជាតិពន្ធុផ្សេងៗ*” ដូចជាជនជាតិចាម ដើម្បី “*បោសសម្អាត*”) កថាខណ្ឌ ៣១៣ (“ការកំណត់គោលដៅ និងការសម្លាប់ជនជាតិចាម នៅតែបន្តរហូតដល់របបនេះដួលរលំ”) កថាខណ្ឌ ៨១៨ (“ជនជាតិចាមត្រូវបានកំនត់ជាមុខសញ្ញាពិសេស ដោយសារអត្តសញ្ញាណពន្ធុ និងសាសនារបស់ពួកគេ។ ការសន្និដ្ឋាននេះមិនអាចជៀសផុតបានឡើយ នៅពេលដែលបានពិចារណា ទៅលើការរិតត្បិតទាំងឡាយ ដែលបានដាក់មកលើជនជាតិចាម ក្នុងបំណងព្យាយាមហាមឃាត់ មិនឲ្យពួកគេអនុវត្តនូវលក្ខណៈទាំងឡាយ ដែលត្រូវតែប្រណិបត្តិ ក្នុងការកំណត់អត្តសញ្ញាណរបស់ពួកគេ។ កត្តាពាក់ព័ន្ធផងដែរគឺថា សមាជិកទាំងឡាយនៃក្រុម ត្រូវបានយកចេញពីភូមិទាំងឡាយ និងកងការងាររបស់ពួកគេ ហើយបន្ទាប់មកបុរស ស្ត្រី និងកុមារទាំងនោះ ត្រូវបានសម្លាប់ចោលដោយមិនរើសមុខ ក្នុងរយៈពេលយ៉ាងខ្លី បន្ទាប់ពីបានចាប់ខ្លួន ដោយមិនបានចាត់វិធានការអ្វីទាំងអស់ ក្នុងការកំណត់ថាតើនរណាបាន ឬមិនបានទទួលខុសត្រូវ ចំពោះកំហុសណាមួយ ឬនរណាដែលបានប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ។ ការសន្និដ្ឋានបែបនេះត្រូវបានគាំទ្រផងដែរ ដោយភស្តុតាងទាំងឡាយនៃកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលបានទទួលស្គាល់យ៉ាងច្បាស់លាស់ថា មានគោលនយោបាយរើសអើង ប្រឆាំងនឹងជនជាតិចាម ដែលជាចុងបញ្ចប់កំណត់បាននូវគោលបំណង នៃការលប់បំបាត់ខាងរូបរាងកាយ នៃជនជាតិចាម”) (លប់ចោលជើងទំព័រ)។ ចៅក្រមអន្តរជាតិកត់សម្គាល់ថា ប្រហែលគ្នានឹងការសម្រេច របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០២ បានសម្រេចថា “នៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ ប.ក.ក ដើម្បីបង្កើតសង្គមមួយ

01635109



៦២១. ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) បានបង្ហាញភស្តុតាងថា គោលដៅរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការបង្កើត "បក្ស និងសង្គមស្អាតស្អំ ខាងនយោបាយ និងមនោគមន៍វិជ្ជា"[1270] ឬបង្កើត "សង្គមមួយដែលមានជាតិសាសន៍តែមួយ ដែលគ្មានសាសនា និងគ្មានវណ្ណៈ"[1271] ដែលត្រូវសម្រេចបានតាមរយៈការកំណត់គោលដៅ ចំពោះក្រុមដែលត្រូវបានកំណត់អត្តសញ្ញាណជាវិជ្ជមាន ដូចជាជនជាតិចាម ជាដើម។ ចៅក្រមអន្តរជាតិសម្រេចថា គោលដៅនេះមិនអាចសម្រេចបាន តាមរយៈការកំណត់អត្តសញ្ញាណជាអវិជ្ជមានដូចជាថា "មិនមែនជនជាតិខ្មែរ" នោះទេ។

៦២២. ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) បានកំណត់អត្តសញ្ញាណប្រជាជនចាមថាជា "ក្រុមជាតិពន្ធុ និងសាសនាផ្សេងដោយឡែកមួយ នៅក្នុងប្រទេសកម្ពុជា"[1272] ដោយយោងទៅលើ "លក្ខណៈទូទៅ"[1273] និងលក្ខណៈពិសេសរបស់ក្រុម ដែលអាចញែកដាច់ចេញពី ជនជាតិខ្មែរភាគច្រើន ដែល

---

ដែលមិនមានសាសនា និងរួបរួមគ្នាដោយមិនមានការបែងចែកវណ្ណៈ គឺបានកំណត់គោលដៅលើជនជាតិចាម ដែលជាក្រុមជាតិពន្ធុមួយ និងសាសនាមួយដោយឡែកពីគេ" *សូមមើល* សាលក្រមសំណុំរឿង ០០២/០២ (ឯកសារ E465) កថាខណ្ឌ ៣២២៨ ("អង្គជំនុំជម្រះយល់ឃើញថា នៅក្នុងកិច្ចប្រឹងប្រែងរបស់ ប.ក.ក ដើម្បីបង្កើតសង្គមមួយ ដែលមិនមានសាសនា និងរួបរួមគ្នាដោយមិនមានការបែងចែកវណ្ណៈ គឺបានកំណត់គោលដៅលើជនជាតិចាម ដែលជាក្រុមជាតិពន្ធុមួយ និងសាសនាមួយដោយឡែកពីគេ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ") កថាខណ្ឌ ៣៣៤៥ ("ចំពោះចេតនាជាក់លាក់ នៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺការធ្វើមនុស្សឃាតដោយចេតនា ក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជនជាតិចាម អង្គជំនុំជម្រះសូមរំឭកថា ប.ក.ក បានកំណត់គោលដៅលើជនជាតិចាម ជាក្រុមជាតិពន្ធុនិងក្រុមសាសនាដោយឡែក នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយដំបូងឡើយរឹតបន្តឹងលើការអនុវត្ត វប្បធម៌និងសាសនារបស់ពួកគេ បន្ទាប់មកដោយការបង្ក្រាបយ៉ាងឃោរឃៅលើ "ការបះបោរ" និងការបំបែកសហគមន៍ចាម នៅនៅដំណាក់កាលក្រោយមកទៀត មានបទបញ្ជាឱ្យបោសសម្អាតជនជាតិចាមទាំងអស់ ដែលត្រូវបានចាត់ទុកថា មិនបានសម្របសម្រួលខ្លួន ចូលក្នុងសង្គមខ្មែរ") កថាខណ្ឌ ៣៩៩៣ ("ដោយបានកំណត់រួចហើយថា គោលនយោបាយរបស់ ប.ក.ក ក្នុងការបំផ្លាញជនជាតិចាម មានអត្ថិភាពតាំងពីឆ្នាំ ១៩៧៧ មកនោះ អង្គជំនុំជម្រះយល់ឃើញថា គោលនយោបាយរបស់ ប.ក.ក ក្នុងការកំណត់គោលដៅទៅលើជនជាតិចាម មានគោលដៅចម្បងក្នុងការកម្ទេចពួកគេ ជាក្រុមជាតិពន្ធុនិងសាសនា។ អង្គជំនុំជម្រះជឿជាក់ថា ការប្រព្រឹត្តទៅលើជនជាតិចាម បង្ហាញអំពីគោលដៅរបស់ ប.ក.ក ក្នុងការបង្កើតសង្គមមួយដែលមិនមានសាសនា រួបរួមគ្នាដោយមិនមានការបែងចែកវណ្ណៈ ហើយដើម្បីសម្រេចបានបែបនេះ បក្សមានចេតនាក្នុងការលុបបំបាត់ វណ្ណៈនិងវប្បធម៌ ជាតិនិងសាសនាផ ដែលខុសគ្នាទាំងអស់ចេញ") (ដោយគូសបញ្ជាក់បន្ថែម) (លុបចោលជើងទំព័រ)។

[1270] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ២០៨។

[1271] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៥៩៧។

[1272] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៥៩០។

[1273] *ការអនុវត្តអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍* (តុលាការយុត្តិធម៌អន្តរជាតិ) កថាខណ្ឌ ១៩១-១៩៤។ សាលក្រមសំណុំ

អាចបង្ហាញបានតាមរយៈ ជំនឿសាសនា ភាសា និងវប្បធម៌របស់ពួកគេ[1274]។ ជាលទ្ធផល ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) បានកំណត់អំពីគោលនយោបាយ របស់បក្សកុម្មុយនីស្តកម្ពុជា (និងការអនុវត្តគោលនយោបាយនោះ) ក្នុងការកំណត់គោលដៅទៅលើជនជាតិចាម ដោយផ្អែកលើមូលដ្ឋាននៃលក្ខណៈវិនិច្ឆ័យទាំងអស់នេះ ដូចជាការចាប់ខ្លួន ការផ្លាស់ទីលំនៅ និងការសម្លាប់[1275]។ បន្ថែមលើនេះ ដីកា

---

រឿង ០០២/០២ (ឯកសារ E465) កថាខណ្ឌ ៧៩៣។ សាលដីការឿងក្តី *Stakić* (តុលាការ ICTY) កថាខណ្ឌ ២០-២៨។

[1274] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៥៩២ ("ប្រជាជនចាមបានរក្សា នូវអត្តសញ្ញាណជាតិពន្ធុ និងវប្បធម៌ដាច់ដោយឡែកមួយ ទោះបីជាពួកគេបានរស់នៅក្នុងប្រទេសកម្ពុជា អស់រយៈពេលជាង៥០០ឆ្នាំមកហើយក៏ដោយ។ [...] ប្រជាជនចាមប្រតិបត្តិទម្រង់ពិសេសដោយឡែកមួយ នៃសាសនាអ៊ីស្លាម និងនិយាយភាសាចាម ដែលខុសប្លែពីភាសាខ្មែរ។ សាក្សីពណ៌នាដោយស៊ីចង្វាក់គ្នា អំពីសហគមន៍ជនជាតិចាម ដែលខុសប្លែកពីជនជាតិខ្មែរ តាមរយៈការស្លៀកពាក់ ភាសា និងប្រពៃណី") (លប់ចោលជើងទំព័រ).

[1275] *សូមមើលជាឧទាហរណ៍,* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៥៩៧("ប.ក.ក បានអនុវត្តគោលនយោបាយមួយ ដោយផ្តោតគោលដៅជាប្រព័ន្ធ ទៅលើក្រុមប្រជាជនជាក់លាក់នានា នៅក្នុងចំណោមប្រជាជនកម្ពុជា") កថាខណ្ឌ ៥៩៩ ("ប្រជាជនចាមត្រូវបានហាមឃាត់ មិនឱ្យប្រតិបត្តិសាសនាអ៊ីស្លាម ឬនិយាយភាសាចាមនោះឡើយ។ វិហារសាសនាអ៊ីស្លាមត្រូវបានបិទទ្វារ មេដឹកនាំសាសនាអ៊ីស្លាមត្រូវបានចាប់ខ្លួន ហើយប្រជាជនចាមត្រូវបាន បង្ខំឱ្យបោះចោលសៀវភៅគម្ពីសាសនារបស់ពួកគេ។ ប្រជាជនចាមដែលបំពានការហាមឃាត់ អាចនឹងទទួលការព្រមាន ប៉ុន្តែជាញឹកញាប់ពួកគេត្រូវបានគេវាយ សម្លាប់ ឬចោទថាជា "ខ្មាំង" និងត្រូវគេនាំយកចេញទៅបាត់ ដែលត្រូវបានសន្មតថាយកទៅសម្លាប់") កថាខណ្ឌ ៦០១ ("ពេញទូទាំងភូមិភាគកណ្តាល ប្រជាជនចាមត្រូវបានហាមឃាត់ មិនឱ្យប្រតិបត្តិសាសនារបស់ពួកគេ។ ពួកគេត្រូវបានបង្ខំឱ្យហូបសាច់ជ្រូក ហើយស្ត្រីត្រូវបានតម្រូវឱ្យដោះ កន្សែងរុំក្បាលរបស់ពួកគេ។ ប្រជាជនចាមក៏ត្រូវបានហាមឃាត់ មិនឱ្យនិយាយភាសារបស់ពួកគេ ឬស្លៀកពាក់សម្លៀកបំពាក់ប្រពៃណី របស់ពួកគេនោះឡើយ") កថាខណ្ឌ ៦០៧-៦០៨ ("គោលនយោបាយរបស់ ប.ក.ក ក្នុងការគាបសង្កត់ការប្រតិបត្តិសាសនា របស់ប្រជាជនចាម និងការបំបែកពង្រាយសហគមន៍ចាម បង្ហាញនូវការប៉ុនប៉ងរួមមួយរបស់ ប.ក.ក ក្នុងការបំបែកសហគមន៍ចាម និងលុបបំបាត់អត្តសញ្ញាណជនជាតិចាម នៅក្នុងខេត្តកំពង់ចាម។ [...] ត្រឹមដើមឆ្នាំ ១៩៧៧ "មេដឹកនាំកំពូល [ប.ក.ក] ដោយបានសន្និដ្ឋានថាប្រជាជនចាម មិនអាចធ្វើការអប់រំរៀនសូត្របាន ហេតុដូច្នេះត្រូវលុបបំបាត់ពួកគេចោលទាំងស្រុង"។ ភាពស៊ីចង្វាក់នៃសេចក្តីអះអាង របស់កម្មាភិបាល ប.ក.ក ចាប់ពីថ្នាក់ខ្ពស់រហូតដល់ថ្នាក់ទាប និងភស្តុតាងនៃការចាប់ខ្លួន និងការសម្លាប់ជាទ្រង់ទ្រាយធំ គឺជាភស្តុតាងដ៏គួរឱ្យជឿជាក់ ស្តីពីការរីកសាយភាយនៃគោលនយោបាយនេះ។ សាក្សីពណ៌នាយ៉ាងស៊ីសង្វាក់ថា បានស្តាប់ឮកម្មាភិបាល ប.ក.ក ប្រកាសអំពីគោលនយោបាយ រើសអើងចំពោះប្រជាជនចាម") កថាខណ្ឌ ៦១៥ ("មានការកើនឡើងនៃការអនុវត្ត គោលនយោបាយរបស់ ប.ក.ក ដែលផ្តោតគោលដៅទៅលើប្រជាជនចាម ក្រោយរដ្ឋបាលគ្រប់គ្រងរបស់ភូមិភាគនិរតី មកដល់ភូមិភាគកណ្តាល។ គោលនយោបាយនេះ ដូចដែលត្រូវបានអនុវត្តនៅក្នុងខេត្តកំពង់ចាម បានវិវត្តពីការគាបសង្កត់អត្តសញ្ញាណវប្បធម៌ និងសាសនារបស់ប្រជាជនចាម ទៅជាការបំផ្លាញរាងកាយរបស់ប្រជាជនចាម") កថាខណ្ឌ ៦២៣ ("ភស្តុតាងខាងក្រោមនេះបញ្ជាក់ថា ការចាប់ខ្លួន ការសម្លាប់ និងការបាត់ខ្លួនជនជាតិចាម បានកើតឡើងតាមគំរូស្រដៀងគ្នាមួយចំនួន នៅទូទាំងភូមិភាគកណ្តាល ដែលនេះបង្ហាញថា មានការសម្របសម្រួលផែនការ ដើម្បីសម្លាប់ជនជាតិចាមទ្រង់ទ្រាយធំ ហើយពួកគេជាមុខសញ្ញា មិនមែនដោយសារ

ដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) បានរៀបរាប់លម្អិតអំពីតួនាទីរបស់ អោ អាន នៅក្នុងការកំណត់គោលដៅលើជនជាតិចាម[1276]។ ចៅក្រមអន្តរជាតិយល់ឃើញថា ការរៀបរាប់ខាងលើមិនអាចកំណត់ ឬបង្កើតបានជាវិធីសាស្ត្រអវិជ្ជមាន សម្រាប់ការកំណត់អត្តសញ្ញាណ ក្រុមដែលត្រូវបានការពារ គឺជនជាតិចាម នោះឡើយ។

៦២៣. ទីពីរ ចំពោះមូលដ្ឋានទី ១៦ (៣) និងការចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានបង្ហាញពីចេតនាប្រល័យពូជសាសន៍ជាក់លាក់នោះ ចៅក្រមអន្តរជាតិសូមរំឭកថា ធាតុផ្សំ *អត្តនោម័ត* នៃអំពីប្រល័យពូជសាសន៍ តម្រូវ "ភស្តុតាងនៃចេតនាក្នុងការប្រព្រឹត្តអំពើទាំងនោះ ព្រមទាំងភស្តុតាងនៃចេតនាជាក់លាក់ ក្នុងការបំផ្លាញក្រុមនោះទាំងស្រុង ឬមួយផ្នែក"[1277]។ ចេតនាជាក់លាក់នេះត្រូវបានហៅ

---

មានកំហុសទេ ប៉ុន្តែដោយសារថាពាក់ព័ន្ធនឹងជាតិពន្ធុ និងសាសនារបស់ពួកគេ") កថាខណ្ឌ ៨១៧-៨១៨ ("អំពើទាំងឡាយនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ត្រូវបានប្រព្រឹត្តដោយមានចេតនា បំផ្លិចបំផ្លាញជនជាតិចាម ក្នុងខេត្តកំពង់ចាម។ ការកំណត់បាននូវចេតនាពិសេសនេះ គឺផ្អែកទៅលើភស្តុតាងយ៉ាងច្រើនលើសលុប នៃការវិវត្តនៃគោលនយោបាយរបស់ បក្សកុម្មុយនីស្តកម្ពុជា ពីដំណាក់កាលនៃការគាបសង្កត់សាសនា ទៅដល់ដំណាក់កាលនៃការលុបបំបាត់ ព្រមទាំងលក្ខណៈនិងទ្រង់ទ្រាយ នៃការសម្លាប់ប្រជាជនចាម ដែលបណ្តាលមកពីគោលនយោបាយ និងអំពើទាំងនោះ។ [...] ជនជាតិចាមត្រូវបានកំណត់ជាមុខសញ្ញាពិសេស ដោយសារអត្តសញ្ញាណពន្ធុ និងសាសនារបស់ពួកគេ។ ការសន្និដ្ឋាននេះមិនអាចជៀសផុតបានឡើយ នៅពេលដែលបានពិចារណាទៅលើការរឹតត្បិតទាំងឡាយ ដែលបានដាក់មកលើជនជាតិចាម ក្នុងបំណងព្យាយាមហាមឃាត់ មិនឱ្យពួកគេអនុវត្តនូវលក្ខណៈទាំងឡាយ ដែលត្រូវតែប្រណិបត្តិ ក្នុងការកំណត់នូវអត្តសញ្ញាណ ក្រុមរបស់ពួកគេ។ កត្តាពាក់ព័ន្ធផងដែរគឺជាសមាជិកទាំងឡាយនៃក្រុម ត្រូវបានយកចេញពីភូមិទាំងឡាយ និងកងការងាររបស់ពួកគេ ហើយបន្ទាប់មកបុរស ស្ត្រី និងកុមារទាំងនោះត្រូវបានសម្លាប់ចោល ដោយមិនរើសមុខក្នុងរយៈពេលយ៉ាងខ្លី បន្ទាប់ពីបានចាប់ខ្លួន ដោយមិនបានចាត់វិធានការអ្វីទាំងអស់ ក្នុងការកំណត់ថាតើនរណាបាន ឬមិនបានទទួលខុសត្រូវ ចំពោះកំហុសណាមួយ ឬនរណាដែលបានប្រឆាំងនឹង របបកម្ពុជាប្រជាធិបតេយ្យ។ ការសន្និដ្ឋានបែបនេះត្រូវបានគាំទ្រផងដែរ ដោយភស្តុតាងទាំងឡាយ នៃកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលបានទទួលស្គាល់យ៉ាងច្បាស់លាស់ថា មានគោលនយោបាយរើសអើង ប្រឆាំងនឹងជនជាតិចាម ដែលជាចុងបញ្ចប់កំណត់បាននូវគោលបំណង នៃការលុបបំបាត់ខាងរូបរាងកាយ នៃជនជាតិចាម") (លុបចោលជើងទំព័រ)។

[1276] *សូមមើលជាឧទាហរណ៍*, ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៦៣៣-៦៣៧ ("អោអាន បានបញ្ជាឲ្យប្រាក់ យុត លេខាស្រុកកំពង់សៀម រៀបចំបញ្ជីឈ្មោះជនជាតិចាម នៅស្រុកកំពង់សៀម"។ [...] អោ អាន បានបញ្ជា ប្រាក់ យុត និងគណៈស្រុកដទៃទៀតនៅតំបន់ ៤១ ចាប់ខ្លួននិងសម្លាប់ជនជាតិចាមទាំងអស់។ [...] ក្រោយមកទៀត យូ វ៉ាន់ ត្រូវបានណែនាំឲ្យធ្វើបញ្ជីឈ្មោះ ជនជាតិចាមលើកទីពីរ នៅក្នុងអង្គប្រជុំមួយមាន អោ អាន ជាប្រធាន") កថាខណ្ឌ ៨២៩-៨៣០ ("អោ អាន បានចូលរួមជាដុំកំភួន នៅក្នុងគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដែលកំណត់មុខសញ្ញាក្រុមពិសេសទាំងឡាយ រួមមានទាំង [...] ប្រជាជនចាម [...] អោ អាន បានចូលរួមមានចេតនាពិសេសផងដែរ ក្នុងការកម្ទេចជនជាតិចាម នៃខេត្តកំពង់ចាម [...]") (លុបចោលជើងទំព័រ)។

[1277] អនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ មាត្រា ២។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ៤។ សាលក្រមសំណុំរឿង

ថា ចេតនាប្រល័យពូជសាសន៍ ជាចេតនាពិសេស (*dolus specialis*)[1278]។

៦២៤. ចៅក្រមអន្តរជាតិពិចារណាថា "តាមលក្ខណៈរបស់វា ចេតនាជាទូទៅមិនទទួលរងផលប៉ះពាល់ដោយសារតែការបង្ហាញភស្តុតាងផ្ទាល់ឡើយ"[1279] ប៉ុន្តែត្រូវតែទាញសន្និដ្ឋានចេញពី អង្គហេតុ និងកាលៈទេសៈពាក់ព័ន្ធនានាដូចជា "បរិបទទូទៅ ការប្រព្រឹត្តអំពីដែលមានពិរុទ្ធភាពផ្សេងៗ ដែលមានគោលដៅជាប្រព័ន្ធទៅលើក្រុមតែមួយ ទំហំនៃអំពើសាហាវយង់ឃ្នងដែលបានប្រព្រឹត្ត ការកំណត់គោលដៅជាប្រព័ន្ធទៅលើជនរងគ្រោះ ផ្អែកលើសមាជិកភាពរបស់ពួកគេ នៅក្នុងក្រុមជាក់លាក់មួយ ឬការប្រព្រឹត្តដដែលៗនូវអំពើរើសអើង ឬបំផ្លិចបំផ្លាញ"[1280]។

៦២៥. នៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ ចៅក្រមអន្តរជាតិមិនអាចជឿជាក់ទេថា "ដើម្បីបង្ហាញភាវចិត្តរបស់បុគ្គលម្នាក់ តាមការសន្និដ្ឋាន គឺត្រូវធ្វើការសន្និដ្ឋានដោយមានហេតុផល ផ្អែកលើភស្តុតាង

---

០០២/០២ (E465) កថាខណ្ឌ ៧៩៧ *យោងទៅរក* តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង* *Krstić* IT-98-33-A សាលក្រម អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ ("សាលដីការឿងក្តី *Krstić* (តុលាការ ICTY)") កថាខណ្ឌ ២០។ *ការអនុវត្តអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍* (តុលាការយុត្តិធម៌អន្តរជាតិ) កថាខណ្ឌ ១៨៦-១៨៧។

[1278] សាលក្រមសំណុំរឿង ០០២/០២ (ឯកសារ E465) កថាខណ្ឌ ៧៩៧ *យោងទៅរក* តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង* *Jelisić* IT-95-10-A សាលក្រម អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០០១ ("សាលដីការឿងក្តី *Jelisić* (តុលាការ ICTY)") កថាខណ្ឌ ៤៥។ សាលក្រមរឿងក្តី *Karadžić* (តុលាការ ICTY) កថាខណ្ឌ ៥៤៩។ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង* *Karadžić* IT-95-5/18-AR98bis.1 សាលក្រម អង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ ២២។ សាលក្រមរឿងក្តី *Akayesu* (តុលាការ ICTR) កថាខណ្ឌ ៥៩៨។ *ការអនុវត្តអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍* (តុលាការយុត្តិធម៌អន្តរជាតិ) កថាខណ្ឌ ១៨៧។

[1279] សាលក្រមរឿងក្តី *Popović និងអ្នកដទៃទៀត* (តុលាការ ICTY) កថាខណ្ឌ ៨២៣, ១៣៩៨ ("ភស្តុតាងផ្ទាល់នៃចេតនាប្រល័យពូជសាសន៍ គឺកម្រមានណាស់។ ជាជំនួសគឺការទាញសន្និដ្ឋានពីអំពើ ការប្រព្រឹត្ត និងការដឹងឮរបស់ជនជាប់ចោទ ព្រមទាំងកាលៈទេសៈពាក់ព័ន្ធដទៃទៀត") *យោងទៅរក* សាលដីការឿងក្តី *Gacumbitsi* (តុលាការ ICTR) កថាខណ្ឌ ៤០។ សូមមើលផងដែរ សាលដីការឿងក្តី *Popović និងអ្នកដទៃទៀត* (តុលាការ ICTY) កថាខណ្ឌ ៤៦៨។ តុលាការ ICTR *រដ្ឋអាជ្ញា តទល់នឹង* *Muvunyi*, តុលាការ ICTR-00-55A-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង III ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០ កថាខណ្ឌ ២៩។ សាលដីការឿងក្តី *Rutaganda* (តុលាការ ICTR) កថាខណ្ឌ ៥២៥។

[1280] សាលក្រមសំណុំរឿង ០០២/០២ (E465) កថាខណ្ឌ ៨០៣ (លុបចោលជើងទំព័រ)។ សូមមើលផងដែរ *ជាឧទាហរណ៍* សាលដីការឿងក្តី *Popović និងអ្នកដទៃទៀត* (តុលាការ ICTY) កថាខណ្ឌ ៤៦៨។ សាលដីការឿងក្តី *Jelisić* (តុលាការ ICTY) កថាខណ្ឌ ៤៧។ តុលាការ ICTR *រដ្ឋអាជ្ញា តទល់នឹង* *Gacumbitsi* តុលាការ ICTR-2001-64-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៤ កថាខណ្ឌ ២៥២-២៥៣។ សាលក្រមរឿងក្តី *Akayesu* (តុលាការ ICTR) កថាខណ្ឌ ៥២៣។ តុលាការ ICTR *រដ្ឋអាជ្ញា តទល់នឹង* *Kayishema* និង *Ruzindana* កថាខណ្ឌ ៩៣។

ដែលមាន"[1281]។ ចៅក្រមអន្តរជាតិជឿជាក់ថា "អនុលោមតាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង លក្ខខណ្ឌវិនិច្ឆ័យសម្រាប់ការចេញដីកាដំណោះស្រាយគឺ អត្ថិភាពនៃ "ភស្តុតាងគ្រប់គ្រាន់... បទចោទ""[1282]។ នៅដំណាក់កាលបុរេជំនុំជម្រះនេះ ជាការគ្រប់គ្រាន់ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បង្ហាញ "ភស្តុតាងស៊ីសង្វាក់ និងជាក់លាក់"[1283]។

៦២៦. ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនត្រូវបានតម្រូវឱ្យបង្ហាញភស្តុតាងផ្ទុយ សម្រាប់ការសន្និដ្ឋានដែលសមហេតុផលដទៃផ្សេងទៀតទាំងអស់ឡើយ ព្រោះការតម្រូវបែបនេះ បង្កើតបានជាការដាក់បន្ទុក នូវបទបង្ហានបង្ហាញភស្តុតាង ដែលខ្ពស់ជាងមុន ដើម្បីបង្ហាញពីភាវចិត្តរបស់ជនជាប់ចោទ ឱ្យហួសពីវិមតិសង្ស័យ ដែលហាក់ដូចជានៅក្នុងការជំនុំជម្រះ[1284]។ ហេតុដូច្នេះ

---

[1281] *Contra* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ១៩៩ *យោងទៅរក* សាលដីការឿងក្តី Krstić (តុលាការ ICTY) កថាខណ្ឌ ៤១។ សាលដីការឿងក្តី *Brđanin* (តុលាការ ICTY) កថាខណ្ឌ ៩៧០។

[1282] *សូមមើលជាឧទាហរណ៍* ខាងលើ កថាខណ្ឌ ៨៤ ដល់ ៨៧។ សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) (ឯកសារ D308/3/1/20) កថាខណ្ឌ ៦១-៦២ ("អនុលោមតាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង លក្ខខណ្ឌវិនិច្ឆ័យសម្រាប់ការចេញ ដីកាដំណោះស្រាយ គឺអត្ថិភាពនៃ "ភស្តុតាងគ្រប់គ្រាន់" [...]បទចោទ")។

[1283] *សូមមើល* ខាងលើ កថាខណ្ឌ ៨៤ ។ សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) (ឯកសារ D308/3/1/20), កថាខណ្ឌ ៦០-៦៣, យោបល់របស់ចៅក្រម BAIK និង BEAUVALLET ៣០៥, ៣១៣។

[1284] *តុលាការព្រហ្មទណ្ឌអន្តរជាតិ ស្ថានភាពនៅ ដាហ្វួរ ប្រទេសស៊ូដង់ រដ្ឋអាជ្ញា តទល់នឹង* *Omar Hassan Ahmad Al Bashir* ICC-02/05/-01/09-OA សាលដីកាលើបណ្តឹងសាទុក្ខ របស់រដ្ឋអាជ្ញា ប្រឆាំង "សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញា សុំដីកាឃាត់ខ្លួន Omar Hassan Ahmad Al Bashir" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១០ កថាខណ្ឌ ៣៣ ("តាមមតិរបស់អង្គជំនុំជម្រះតុលាការកំពូល ការតម្រូវថាអត្ថិភាពនៃចេតនាប្រល័យពូជសាសន៍ ត្រូវតែជាការសន្និដ្ឋានដោយសមហេតុផលតែមួយគត់ គឺជាការតម្រូវឱ្យរដ្ឋអាជ្ញា បង្ហាញភស្តុតាងថា ការសន្និដ្ឋានសមហេតុផលដទៃផ្សេងទៀត គឺមិនត្រឹមត្រូវ និងដើម្បីលុបបំបាត់វិមតិសង្ស័យនានា។ ប្រសិនបើការសន្និដ្ឋានដោយសមហេតុផលតែមួយ ដោយផ្អែកលើភស្តុតាង គឺជាអត្ថិភាពនៃចេតនាប្រល័យពូជសាសន៍ ដូច្នេះមិនអាចនិយាយបានទេថា ការសម្រេចបែបនេះបង្កើតបានត្រឹមតែ "មូលដ្ឋានសមហេតុផលក្នុងការជឿជាក់"។ ប៉ុន្តែការសន្និដ្ឋានបែបនេះនឹងកំណត់នូវចេតនាប្រល័យពូជសាសន៍ "ហួសពីវិមតិសង្ស័យ")។ ចៅក្រមអន្តរជាតិពិចារណាថា បទដ្ឋានដូចខាងក្រោម គឺជាបទដ្ឋានជាធរមាន នៅដំណាក់កាលកិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្តី៖ សាលក្រម សំណុំរឿង ០០២/០២ (ឯកសារ E465) កថាខណ្ឌ ៨០៣ ("ដើម្បីធ្វើការសន្និដ្ឋានពាក់ព័ន្ធនឹងចេតនាជាក់លាក់ អង្គជំនុំជម្រះចាំបាច់ត្រូវពិចារណាទៅលើ "ថាតើភស្តុតាងទាំងអស់រួមគ្នា អាចបង្ហាញអំពីស្ថានភាពផ្លូវចិត្ត នៅក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដែរឬទេ"។ ការទាញសេចក្តីសន្និដ្ឋានអំពីចេតនាជាក់លាក់ ត្រូវតែធ្វើឡើងដោយមានហេតុផលសមរម្យ នឹងផ្អែកលើភស្តុតាង") (លុបចោលជើងទំព័រ)។ សូមមើលផងដែរ សាលដីការឿងក្តី *Stakić* (តុលាការ ICTY) កថាខណ្ឌ ២១៩ ("អង្គជំនុំជម្រះ

ប្រសិនបើការសន្និដ្ឋានអំពីចេតនាប្រល័យពូជសាសន៍ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានទាញចេញពីភស្តុតាង សមហេតុផលគ្រប់គ្រាន់ហើយ នោះបទដ្ឋាននៃការបង្ហាញភស្តុតាងនៅក្នុងដំណាក់កាលនេះត្រូវបានបំពេញ។ អង្គហេតុតែមួយគត់ដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានពិចារណាទៅលើការសន្និដ្ឋាន "សមហេតុផល" ដទៃផ្សេងទៀតនោះ មិនអាចចាត់ទុកថាជាការមិនបានបង្ហាញពីចេតនាប្រល័យពូជសាសន៍ នៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឡើយ។

៦២៧. ដោយចងចាំថាបទដ្ឋានបង្ហាញភស្តុតាងនេះ អាចអនុវត្តនៅក្នុងកិច្ចដំណើរការនីតិវិធីមុនជំនុំជម្រះ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បង្ហាញនូវការសន្និដ្ឋានដែលសមហេតុផលគ្រប់គ្រាន់ថា អោ អាន មានចេតនាជាក់លាក់តាមការតម្រូវ (ដោយហួសពីត្រឹមតែការដឹងឮអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តចំពោះជនជាតិចាមផងដែរ)[1285]។ ភស្តុតាងបានបង្ហាញយ៉ាងច្បាស់ថា អោ អាន ដែលជាលេខាតំបន់ ៤១ អនុលេខាភូមិភាគកណ្ដាល និងជាសមាជិកគណៈកម្មាធិការភូមិភាគកណ្ដាល មានគោលដៅរួមគ្នា ក្នុងការអនុវត្តគោលនយោបាយ របស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការកំណត់គោលដៅលើជនជាតិចាម នៅក្នុងភូមិភាគកណ្ដាល នៃកម្ពុជាប្រជាធិបតេយ្យ។ អោ អាន បានដឹងឮអំពីសកម្មភាពទាំងអស់របស់បក្សកុម្មុយនីស្តកម្ពុជា នៅក្នុងតំបន់ និងភូមិភាគរបស់គាត់[1286]។

៦២៨. ជាក់ស្តែង អោ អាន គឺជាបុគ្គលសំខាន់ដែលទទួលខុសត្រូវ ក្នុងការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងតំបន់៤១ ហើយតាមពិតទៅបានអនុវត្តគោលនយោបាយប្រល័យពូជសាសន៍ ក្នុង

---

សាលាដំបូង អាចត្រឹមតែសម្រេចថា ជនជាប់ចោទមានពិរុទ្ធភាពពីបទឧក្រិដ្ឋមួយ ប្រសិនបើរដ្ឋអាជ្ញាបានបង្ហាញភស្តុតាងថា ធាតុផ្សំនីមួយៗនៃឧក្រិដ្ឋកម្មនោះ (ដូចដែលបានកំណត់ស្របតាម ទម្រង់នៃការទទួលខុសត្រូវពាក់ព័ន្ធ) ឲ្យហួសពីវិមតិសង្ស័យ។ បទដ្ឋាននេះត្រូវអនុវត្ត បើទោះបីជាភស្តុតាងដែលយកមកវាយតម្លៃ ជាភស្តុតាងផ្ទាល់ឬតាមកាលៈទេសៈក្តី។ ចំណែកការជំទាស់នៅដំណាក់កាលបណ្តឹងសាទុក្ខ គឺការសន្និដ្ឋានដែលទាញចេញ ដើម្បីកំណត់អង្គហេតុដែល ការផ្តន្ទាទោសនោះត្រូវពឹងផ្អែកទៅលើ ហើយបទដ្ឋានអាចបំពេញបាន ប្រសិនបើការទាញសន្និដ្ឋាន គឺជាការសន្និដ្ឋានសមហេតុផលតែមួយគត់ដែលអាចទាញចេញពីភស្តុតាងដែលបានដាក់បង្ហាញ។ ក្នុងករណីនេះបញ្ហាសម្រាប់ អង្គជំនុំជម្រះតុលាការកំពូលគឺ ថាតើមានសំអាងហេតុដែរឬទេ ដែលអង្គជំនុំជម្រះសាលាដំបូង ដកចេញឬមិនពិចារណា អំពីការសន្និដ្ឋានដទៃទៀត ដែលនាំទៅដល់ការសន្និដ្ឋានថា ធាតុផ្សំនៃឧក្រិដ្ឋកម្មមិនត្រូវបានបង្ហាញជាភស្តុតាង។ ប្រសិនបើមិនមានអង្គជំនុំជម្រះ ដែលប្រកបដោយសំអាងហេតុណា អាចមិនពិចារណាទៅលើការសន្និដ្ឋាន ដែលផ្តល់ជាប្រយោជន៍ដល់ជនជាប់ចោទទេ អង្គជំនុំជម្រះតុលាការកំពូល នឹងច្រានចោលការផ្តន្ទាទោសទាំងឡាយណា ដែលពឹងផ្អែកលើការសន្និដ្ឋាននោះ") (លប់ចោលជើងទំព័រ)។

[1285] *ផ្ទុយទៅនឹង* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ២០២។

[1286] *សូមមើលជាឧទាហរណ៍* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៨២៤-៨២៦។

01635115



ការកំណត់គោលដៅជនជាតិចាម នៅក្នុងតំបន់ដែលស្ថិតក្រោមការត្រួតត្រារបស់គាត់[1287]។ អោ អាន បានបញ្ជាដល់អ្នកក្រោមបង្គាប់គាត់ ឱ្យរៀបចំបញ្ជីជនជាតិចាម ហើយធ្វើការចាប់ខ្លួននិងសម្លាប់ពួកគេទាំងអស់[1288]។ អោ អាន តាមដានការវិវឌ្ឍន៍ នៃប្រតិបត្តិការសម្លាប់មនុស្ស តាម រយៈការប្រជុំ និងប្រព័ន្ធរាយការណ៍[1289]។ គាត់ក៏ដើរតួនាទីយ៉ាងសំខាន់ផងដែរ ក្នុងប្រតិបត្តិការផ្លាស់ទីលំនៅជនជាតិចាម ពីភូមិភាគបូព៌ាទៅភូមិភាគកណ្តាល ដែលនៅទីនោះជនជាតិចាមត្រូវបានគេសម្លាប់ ព្រមទាំងរៀបចំផែនការបោសសម្អាត និងផ្តល់នូវធនធានសម្រាប់ការបោសសម្អាតផងដែរ[1290]។ ជាលទ្ធផលនៃប្រតិបត្តិការនេះ យ៉ាងតិចបំផុតក៏មានជនជាតិចាម ៧.៩១០ នាក់ ត្រូវបានសម្លាប់នៅក្នុងតំបន់៤១[1291]។ ដោយផ្អែកលើអង្គហេតុ និងកាលៈទេសៈទាំងអស់នេះ ចៅក្រមអន្តរជាតិសន្និដ្ឋានថា ការទាញសន្និដ្ឋានអំពីចេតនាជាក់លាក់របស់ អោ អាន ក្នុងការបំផ្លាញជនជាតិចាម គឺសមហេតុផលគ្រប់គ្រាន់ ដែលអាចបំពេញបានតាមបទដ្ឋាននៃការបង្ហាញភស្តុតាងនៅដំណាក់កាល នៃដីកាដំណោះស្រាយហើយ។

៦២៩. បន្ថែមលើនេះ ចៅក្រមអន្តរជាតិមិនជឿជាក់លើ "ការសន្និដ្ឋានមានហេតុផល" ដទៃទៀត របស់សហចៅក្រមស៊ើបអង្កេតសហមេធាវីការពារក្តីឡើយ ដែលថា ការងប់ងុលរបស់ អោ អាន ទៅលើបក្សកុម្មុយនីស្តកម្ពុជា អាចនាំឱ្យគាត់មានភាពស្វិតស្វាញ អនុវត្តភារកិច្ចរបស់គាត់ ដោយគ្មានចេតនាប្រល័យពូជសាសន៍។ ភស្តុតាងដែលថា អោ អាន (ក្នុងនាមជាលេខាតំបន់៤១ អនុលេខាភូមិភាគកណ្តាល និងជាសមាជិកគណៈកម្មាធិការភូមិភាគ

[1287] *សូមមើលជាឧទាហរណ៍*ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៦៣៣-៦៥៥។

[1288] *សូមមើលជាឧទាហរណ៍*ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៦៣៣-៦៥៥ ("អោអាន បានបញ្ជាឱ្យប្រាក់ យុត លេខាស្រុកកំពង់សៀម រៀបចំបញ្ជីឈ្មោះជនជាតិចាម នៅស្រុកកំពង់សៀម"។ [...] អោ អាន បានបញ្ជា ប្រាក់ យុត និងគណៈស្រុកដទៃទៀតនៅតំបន់ ៤១ ចាប់ខ្លួននិងសម្លាប់ជនជាតិចាមទាំងអស់។ [...] ក្រោយមកទៀត យូ វ៉ាន់ ត្រូវបានណែនាំឱ្យធ្វើបញ្ជីឈ្មោះ ជនជាតិចាមលើកទីពីរ នៅក្នុងអង្គប្រជុំមួយមាន អោ អាន ជាប្រធាន")។

[1289] *សូមមើលជាឧទាហរណ៍*ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ៦៣៣-៦៥៥ ("នៅពេលដែលឈ្មោះជនជាតិចាម ត្រូវបានកត់ត្រារួចហើយ បញ្ជីឈ្មោះទាំងនេះត្រូវបានបញ្ជូនត្រឡប់ទៅ "*ថ្នាក់តំបន់*" ជាពិសេសបញ្ជូនទៅ អោ អាន។ [...] ប្រាក់ យុត បានប្រគល់ឈ្មោះទាំងនេះជូន អោ អាន ដោយផ្ទាល់។ [...] ប្រាក់ យុត រាយការណ៍បញ្ហានេះ [ការចាប់ខ្លួននិងសម្លាប់ជនជាតិចាម] ទៅ អោ អាន")។

[1290] *សូមមើលជាឧទាហរណ៍*ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៦៣៣-៦៥៥។

[1291] *សូមមើលជាឧទាហរណ៍*ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៦៣៨-៦៥៥ ("ជនជាតិចាមយ៉ាងតិចបំផុតចំនួន ១០២៧ នាក់ ត្រូវបានសម្លាប់នៅស្រុកកំពង់សៀម [...] ជនជាតិចាមយ៉ាងតិចបំផុតចំនួន ៦.៤៤៣ នាក់ មកពីស្រុកកងមាស ត្រូវបានសម្លាប់ [...] ជនជាតិចាមយ៉ាងតិចបំផុតចំនួន ២០០ នាក់ ត្រូវបានសម្លាប់នៅស្រុកព្រៃឈរ [...] ជនជាតិចាមយ៉ាងតិចបំផុតចំនួន ២៤០ នាក់ ត្រូវបានសម្លាប់នៅស្រុកបាធាយ") (ដោយគូសបញ្ជាក់បន្ថែម)។

កណ្តាល) អនុវត្តគោលនយោបាយប្រល័យពូជសាសន៍ នៅក្នុងតំបន់ដែលស្ថិតក្រោមការត្រួតត្រារបស់គាត់ តាមរយៈការរៀបចំផែនការ ការបញ្ជា ការតាមដាន ការផ្លាស់ទីលំនៅទ្រង់ទ្រាយធំ និងប្រតិបត្តិការសម្លាប់ជនជាតិចាម មានអធិកភាពយ៉ាងជាក់ស្តែងទៅលើការអះអាងរបស់សហមេធាវីការពារក្តី[1292]។

៦៣០. អាស្រ័យហេតុនេះ មូលដ្ឋានទី ១៦ (២) និង ១៦(៣) ត្រូវបានបដិសេធចោល។

## ៧. សន្និដ្ឋានសម្រាប់បណ្តឹងឧទ្ធរណ៍របស់អោ អាន

៦៣១. សម្រាប់សំអាងហេតុដូចបានលើកឡើងខាងលើ ចៅក្រមអន្តរជាតិសម្រេចថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានប្រព្រឹត្តកំហុស ឬបានរំលោភបំពានទៅលើការប្រើប្រាស់ឆន្ទានុសិទ្ធិ ដែលជាកត្តាកំណត់ជាមូលដ្ឋាន ក្នុងការសម្រេចថា អោ អាន ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងអំឡុងរយៈពេលចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ឡើយ។ ហេតុដូច្នេះ ចៅក្រមអន្តរជាតិសម្រេចតម្កល់ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ហើយសម្រេចថា អោ អាន ស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។

---

[1292] *ផ្ទុយទៅនឹង* បណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/5/1) កថាខណ្ឌ ២០១ ជើងទំព័រ ៥១២ *យោងទៅរក* សាលក្រមរឿងក្តី *Popović និងអ្នកដទៃទៀត* (តុលាការ ICTY) កថាខណ្ឌ ១៤១៤។ នៅក្នុងរឿងក្តី *Popović និងអ្នកដទៃទៀត* អង្គជំនុំជម្រះសាលាដំបូងសម្រេចថា ការទាញសន្និដ្ឋានដោយសមហេតុផលផ្សេងទៀតគឺជា ការព្យាយាមយ៉ាងងុបងល់របស់ Nikolić ចំពោះសេវាសន្តិសុខ បាននាំឲ្យគាត់មានភាពស្និតស្នាញ ក្នុងការអនុវត្តដោយប្រសិទ្ធិភាព នូវភារកិច្ចដែលបានដាក់ចេញសម្រាប់គាត់ ក្នុងប្រតិបត្តិការនេះ”។ ប៉ុន្តែចៅក្រមអន្តរជាតិសម្រេចថា ស្ថានភាពរបស់ Nikolić គឺខុសប្លែកដោយជាក់ស្តែងពីស្ថានភាពរបស់ អោ អាន។ ជាឧទាហរណ៍ Nikolić “ជាអនុសេនីយ៍ត្រី ជាកងកម្លាំងមានឋានន្តរសក្តិទាបបំផុតមួយ ហើយគាត់មិនដែលបានចូលបណ្ឌិតសភាយោធាណាឡើយ ហើយត្រូវកាន់តំណែងប្រធានសន្តិសុខ ជាតំណែងមួយសម្រាប់ឋានន្តរសក្តិ វរសេនីយ៍ត្រី ឬខ្ពស់ជាងនេះ” (កថាខណ្ឌ ១៤១២)។ លើសពីនេះ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចផងដែរថា Nikolić បានដឹងព្រួនៗប៉ុណ្ណោះអំពីការសម្លាប់មនុស្សផ្សេងៗ និងអំពីលក្ខណៈរបស់ជនរងគ្រោះ (កថាខណ្ឌ ១៤០២-១៤០៣) ប៉ុន្តែគាត់បានទទួលព័ត៌មានអំពីប្រតិបត្តិការសម្លាប់មនុស្សភ្លាមៗបន្ទាប់ពី ចាប់ផ្តើមការចូលរួមពាក់ព័ន្ធរបស់គាត់ (កថាខណ្ឌ ១៤០៧)។ លើសពីនេះ ដោយខុសពីការទទួលខុសត្រូវផ្ទាល់របស់ អោ អាន ក្នុងការអនុវត្តគោលនយោបាយប្រល័យពូជសាសន៍ Nikolić “ត្រូវបានយកមកអនុវត្តភារកិច្ចជាក់លាក់ ដែលត្រូវបានចាត់តាំងឲ្យគាត់ ក្នុងការអនុវត្តផែនការ [...] ដែលរៀបចំឡើងដោយអ្នកដទៃ។ អំពើឧក្រិដ្ឋរបស់គាត់ [...] គឺកម្រិតត្រឹមវង្វង់នៃការទទួលខុសត្រូវរបស់គាត់ប៉ុណ្ណោះ គឺទីតាំងសម្លាប់មនុស្ស និងឃុំឃាំងជាក់លាក់មួយចំនួន នៅ Zvornik. [...]។ គាត់បានបានចូលរួមក្នុងការចាប់ខ្លួន ហើយគាត់ក៏មិនបានចូលរួមក្នុងការជ្រើសរើសអ្នកទោសឡើយ។ [...] គាត់ក៏មិនត្រូវបានឆ្លើយដាក់ថា បានរៀបចំការផ្លាស់ទីអ្នកទោសពី Bratunac ទៅ Zvornik ដែរ” (កថាខណ្ឌ ១៤១០)។

៦៣២. ចៅក្រមអន្តរជាតិកត់សម្គាល់ថា បទល្មើស ១ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅក្នុងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចោទប្រកាន់ អោ អាន បញ្ជូនទៅជំនុំជម្រះពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ "ប្រឆាំងជនជាតិចាមនៅខេត្តកំពង់ចាម"[1293] ដែលរួមបញ្ចូលទៅក្នុងវិសាលភាពនូវជនរងគ្រោះជាជនជាតិចាម ទាំងនៅក្នុងភូមិភាគកណ្តាល និងភូមិភាគបូព៌ា។ ទោះបីជាយ៉ាងនេះក្តី អោ អាន អាចមិនត្រូវបានជំនុំជម្រះចំពោះបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ប្រឆាំងជនជាតិចាមនៅក្នុងភូមិភាគបូព៌ា។ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបអង្កេតទៅលើ អោ អាន ហើយបានដកចេញអង្គហេតុទាក់ទងនឹងការចាប់ខ្លួន និងការសម្លាប់ជនជាតិចាម នៅក្នុងភូមិភាគបូព៌ា អនុលោមតាមវិធាន ៦៦ស្ទួន នៃវិធានផ្ទៃក្នុង[1294]។ នៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏បានបញ្ជាក់ជាផ្លូវការនូវការស៊ើបសួរទាក់ទងនឹងអង្គហេតុដែលបានដកចេញនោះ ហើយមិនបានធ្វើការសម្រេចលើអង្គហេតុទាក់ទងនឹងអំពើប្រល័យពូជសាសន៍ជនជាតិចាមនៅក្នុងភូមិភាគបូព៌ាដែរ[1295]។ ចៅក្រមអន្តរជាតិរម្លឹកថា អង្គហេតុដែលបានដកចេញតាមវិធាន ៦៦ស្ទួន នៃវិធានផ្ទៃក្នុង "នឹងមិនត្រូវប្រើជាមូលដ្ឋានសម្រាប់ធ្វើការចោទប្រកាន់" ប្រឆាំងបុគ្គលដែលមានឈ្មោះសម្រាប់ការស៊ើបអង្កេតឡើយ[1296]។ អំពើប្រល័យពូជសាសន៍ប្រឆាំងជនជាតិចាម នៅភូមិភាគបូព៌ា មិនគួររួមបញ្ចូលក្នុងចំណោមឧក្រិដ្ឋកម្មនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ។ ជាលទ្ធផល ចៅក្រមអន្តរជាតិធ្វើការកែសម្រួល[1297] បទល្មើស ១ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីសម្រេចថា អោ អាន ត្រូវបានចោទប្រកាន់ និងបញ្ជូនទៅជំនុំជម្រះ ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប្រឆាំងជនជាតិចាមនៅខេត្តកំពង់ចាម ក្នុងភូមិភាគកណ្តាល[1298]។

៦៣៣. ចៅក្រមអន្តរជាតិតម្កល់បទល្មើសដទៃទៀត ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ ហេតុដូច្នេះ អោ អាន ត្រូវបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ

---

[1293] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) ERN 01588971។

[1294] ដីកាសម្រេចកាត់បន្ថយ វិសាលភាពនៃកិច្ចស៊ើបសួរ ឯកសារ D337។

[1295] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) ERN 01588969។

[1296] វិធាន ៦៦ស្ទួន(៥) នៃវិធានផ្ទៃក្នុង។

[1297] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ឯកសារ D427/4/14។

[1298] អង្គបុរេជំនុំជម្រះកត់សម្គាល់ថា សហព្រះរាជអាជ្ញាអន្តរជាតិ គាំទ្រជាមួយការកែសម្រួលនេះ។ សូមមើល ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះបណ្តឹងឧទ្ធរណ៍របស់ អោ អាន (ឯកសារ D360/9) ជើងទំព័រ ២៦៧។

ក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

**បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ)**

១. សារណា

៦៣៤. សហព្រះរាជអាជ្ញាជាតិបានប្ដឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)[1299] ហើយស្នើអង្គបុរេជំនុំជម្រះឱ្យច្រានចោលសំណុំរឿងប្រឆាំងនឹង អោ អាន ដោយសារតែ អ.វ.ត.ក មិនមានយុត្តាធិការទៅលើ អោ អាន[1300]។

៦៣៥. នៅក្នុងសារណាបណ្ដឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាជាតិបានលើកឡើងអំពី "ការយល់ឃើញ" របស់គាត់ស្ដីពី "ការរួចផុតពីការទទួលខុសត្រូវ" និង "ការមិនអាចអនុវត្តយុត្តាធិការបុគ្គល"[1301] ដោយមិនបានបញ្ជាក់អំពីកំហុសឆ្គងនៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)។ នៅក្នុងសវនាការ សហព្រះរាជអាជ្ញាជាតិបានបញ្ជាក់ថា បណ្ដឹងឧទ្ធរណ៍ចោទប្រកាន់អំពីកំហុសអង្គច្បាប់ក្នុងការសម្រេចលើយុត្តាធិការបុគ្គលទៅលើ អោ អាន[1302]។

៦៣៦. នៅក្រោមផ្នែក "ការរួចផុតពីការទទួលខុសត្រូវ" សហព្រះរាជអាជ្ញាជាតិបានលើកឡើងថា អោ អាន មិនមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ទេ ដោយសារតែគាត់មិនមាន

[1299] ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) (ឯកសារ D360)។

[1300] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៩៨។

[1301] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៦៨-៩៧។ សហព្រះរាជអាជ្ញាជាតិបានបញ្ចូលសំអាងហេតុទៅក្នុងសារណាស្ដីពីបណ្ដឹងឧទ្ធរណ៍របស់ខ្លួន (កថាខណ្ឌ ២៦-៦០)។ ចៅក្រមអន្តរជាតិមិនចាត់ទុកថានេះ ជាមូលដ្ឋានបណ្ដឹងឧទ្ធរណ៍ដាច់ដោយឡែកទេ។

[1302] ប្រតិចារឹកសវនាការក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/10.1 & D360/17.1, ERN 01626139 ទំព័រ ១២:៨ ដល់ ១២:១៥ "[...] សហព្រះរាជអាជ្ញាជាតិយល់ឃើញថា មានតែ ឌុច ម្នាក់តែប៉ុណ្ណោះ ដែលជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយ អ.វ.ត.ក គ្មានយុត្តាធិការបុគ្គលទៅលើ អោ អាន [...] សហព្រះរាជអាជ្ញាជាតិពិនិត្យឃើញថា សហចៅក្រមស៊ើបអង្កេតមានកំហុសអង្គច្បាប់ ក្នុងការកំណត់អំពីយុត្តាធិការបុគ្គលលើ អោ អាន ដូចបានបញ្ជាក់ជូនខាងលើ។ *កំហុសអង្គច្បាប់* ទាក់ទងទៅនឹងយុត្តាធិការបុគ្គល *តែមួយនេះ គឺ គ្រប់គ្រាន់* សម្រាប់ឱ្យអង្គបុរេជំនុំជម្រះមានមូលដ្ឋានក្នុងការសម្រេចដោយមានសំអាងហេតុនៅក្នុងបណ្ដឹងឧទ្ធរណ៍ក្នុងករណីនេះ។" (គូសបញ្ជាក់បន្ថែម)

ស្វ័យភាព ឬសិទ្ធិអំណាចជាក់ស្តែង[1303]។ ដោយសង្កត់ធ្ងន់ទៅលើឋានានុក្រមរបស់បក្សកុម្មុយនីស្តកម្ពុជា និងសិទ្ធិអំណាចក្នុងការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍[1304] សហព្រះរាជអាជ្ញាជាតិបានជំទាស់ថា គណៈកម្មាធិការអចិន្ត្រៃយ៍ភូមិភាគ ដែលគ្រប់គ្រងដោយ តែ ពក ក្នុងនាមជាលេខាភូមិភាគ បានចេញសេចក្តីសម្រេច ទាក់ទងនឹងការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលមានគោលដៅបោសសម្អាតខ្លាំង[1305]។ តែ ពក គឺជាមនុស្សដែលមានសិទ្ធិអំណាច និងមានឥទ្ធិពលបំផុត នៅក្នុងភូមិភាគកណ្តាល ហើយមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ បក្សកុម្មុយនីស្តកម្ពុជា ព្រមទាំងមានសិទ្ធិអំណាចក្នុងការដឹកនាំការប្រជុំភូមិភាគ ចេញបញ្ជាឱ្យចាប់ខ្លួន និងសម្លាប់ និងគ្រប់គ្រងយ៉ាងតឹងរ៉ឹងទៅលើការងារទាំងអស់ នៅក្នុងភូមិភាគ ដែល ជារួម គឺថា “សេចក្តីសម្រេចក្នុងភូមិភាគ គឺធ្វើឡើងដោយ តែ ពក ក្រោយពីបានទាក់ទង និងទទួលការណែនាំ [...] ពីមន្ទីរ៨៧០”[1306]។

៦៣៧. ចំពោះតួនាទីរបស់ អោ អាន ទោះបីជាសហព្រះរាជអាជ្ញាជាតិបានទទួលស្គាល់ថា អោ អាន គឺជាលេខាតំបន់ ៤១[1307] អនុលេខាភូមិភាគ[1308] និង “ក្រោយមកកាន់តំណែងជាលេខាភូមិភាគកណ្តាលនេះបានមួយរយៈខ្លី”[1309] ប៉ុន្តែ សហព្រះរាជអាជ្ញាជាតិអះអាងថា អោ អាន “មិនមានការតែងតាំងជាផ្លូវ

[1303] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៨៣។ សូមមើល ជាទូទៅ កថាខណ្ឌ ៦៨-៨៣។ ប្រតិចារឹកសវនាការក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/8.1 & D360/17.1, ERN 01626008 ទំព័រ ១៩:៤ ដល់ ១៩:៥ ទំព័រ ១៩:៩ ដល់ ១៩:១១។

[1304] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៧២, ៧៨-៧៩, ៨២-៨៣។ ប្រតិចារឹកសវនាការក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/8.1 & D360/17.1, ERN 01626007 ទំព័រ ១៨:៣ ដល់ ១៨:២២។

[1305] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៦៨-៧០, ៧២, ៧៥។ សូមមើលផងដែរ កថាខណ្ឌ ៧៩-៨២។

[1306] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៧០-៧២, ៧៥, ៨២-៨៣។

[1307] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៧៣, ៧៥, សូមមើលផងដែរ កថាខណ្ឌ ៥៨។

[1308] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៧២ សូមមើលផងដែរ កថាខណ្ឌ ៤៨, ៥៨។

[1309] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៧៥។

ការ”[1310] ហើយអះអាងថា មិនមានភស្តុតាងបង្ហាញថា អោ អាន គ្រប់គ្រងក្នុងនាមជាលេខាស្តីទីភូមិភាគកណ្តាលឡើយ នៅពេលដែល កែ ពក អវត្តមាននោះ[1311]។ អោ អាន មិនមានសិទ្ធិអំណាចធ្វើការសម្រេចឡើយ គាត់គ្រាន់តែទទួលបញ្ជាពីថ្នាក់លើ ជាពិសេសពី កែ ពក[1312]។ ពេលខ្លះ កម្មាភិបាលនៅគ្រប់កម្រិតត្រូវបានចាប់ខ្លួន និងសម្លាប់ចោល ប្រសិនបើពួកគេមិនបានបំពេញភារកិច្ចរបស់ពួកគេ ហើយ អោ អាន អះអាងថា គាត់ “ដាច់ខាតត្រូវគោរព” តាមបញ្ជាទាំងអស់ ហើយ “ភ័យខ្លាចដល់ជីវិត ប្រសិនបើគាត់មិនគោរពតាម”[1313]។ ការបោសសម្អាតកម្មាភិបាលនៅកំពង់ចាម បានកើតឡើងនៅមុនពេល អោ អាន មកដល់ភូមិភាគកណ្តាល ហើយតាមពិតទៅ ការមកដល់របស់ អោ អាន គឺជួនគ្នាជាមួយបញ្ជារបស់ ខៀវ សំផន ឱ្យបញ្ឈប់ការសម្លាប់មនុស្ស[1314]។ អត្រានៃការសម្លាប់គឺដោយសារតែគ្រោះរាំងស្ងួតទូទាំងប្រទេស ជាពិសេសនៅក្នុងតំបន់៤១ ដែល អោ អាន គឺជាលេខា ដែលបណ្តាលមកពីការអនុវត្តគោលនយោបាយរបស់ថ្នាក់លើ[1315]។

៦៣៨. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិបានជំទាស់ថា សហព្រះរាជអាជ្ញាជាតិមិនបានអនុវត្តកាតព្វកិច្ចរបស់គាត់ក្នុងនាមជាម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលត្រូវបង្ហាញថា ការសម្រេចដែលរងការ

[1310] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៨២ ប៉ុន្តែ សូមមើល កថាខណ្ឌ ៤៨, ៥៨ (បញ្ជាក់ថា អោ អាន ត្រូវបានតែងតាំងជាលេខាតំបន់ ៤១ ហើយតំណែងរបស់គាត់ជាអនុលេខាភូមិភាគ “ត្រូវបានប្រកាសជាផ្លូវការនៅក្នុងសន្និបាតក្នុងភូមិភាគ”)។

[1311] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៧៦-៧៧ ប៉ុន្តែ សូមមើល កថាខណ្ឌ ៥៨ (បញ្ជាក់ថា “អោ អាន ក៏បានក្លាយទៅជាអនុលេខាធិការភូមិភាគកណ្តាលផងដែរ ដែលជាតំណែងមួយតម្រូវឱ្យគាត់បំពេញតួនាទីជំនួស កែ ពក នៅពេល កែ ពក អវត្តមាន”)។

[1312] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៧២, ៧៥, ៨២-៨៣។ ប្រតិចារឹកសវនាការក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/8.1 & D360/17.1, ERN 01626006-01626007 ទំព័រ ១៧:២៣ ដល់ ១៨:៣ 1626008 ទំព័រ ១៩:៤ ដល់ ១៩:៦។

[1313] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៨៣, សូមមើលផងដែរ កថាខណ្ឌ ៨១។ ប្រតិចារឹកសវនាការក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/8.1 & D360/17.1, ERN 01626008 ទំព័រ ១៩:៦ ដល់ ១៩:៨។

[1314] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៧៣។

[1315] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៧៣។

ជំទាស់នៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) មិនសមហេតុផលឡើយ[1316]។ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ផ្ទុយទៅវិញ សហព្រះរាជអាជ្ញាជាតិ គ្រាន់តែបង្ហាញពីការយល់ឃើញផ្សេងទៅលើអង្គហេតុ ដោយមិនបានឆ្លើយតប ឬយោងទៅការសម្រេចណាមួយឡើយ។ ហេតុដូច្នេះផ្នែកស្តីពីអង្គហេតុនៃបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ គួរត្រូវបានបដិសេធចោល[1317]។ លើសពីនេះទៀត ការអះអាងអំពីអង្គហេតុនៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ មិនមានការគាំទ្រពីភស្តុតាងឡើយ នៅពេលដែលការស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៤/២ ត្រូវបានពិចារណាជារួម[1318]។

៦៣៩. នៅក្នុងផ្នែក "ការមិនអាចអនុវត្តយុត្តាធិការបុគ្គល" សហព្រះរាជអាជ្ញាជាតិបានចោទប្រកាន់ថា អោ អាន មិនស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឡើយ[1319]។ សហព្រះរាជអាជ្ញាជាតិជំទាស់ថា អ.វ.ត.ក មិនមែនជាតុលាការអចិន្ត្រៃយ៍ ហើយ ដូចជាតុលាការ ICTY, ICTR និង SCSL ដែលបានបញ្ចប់អាណត្តិការងាររបស់ខ្លួននោះ "ការកម្រិតវិសាលភាពយុត្តាធិការបុគ្គល" គឺជា "វិធីសាស្ត្រដែលអាចទទួលយកបាន" សម្រាប់ការបញ្ចប់អាណត្តិរបស់ អ.វ.ត.ក[1320]។ តាមការយល់ឃើញរបស់គាត់ "ស្ថាបនិក

---

[1316] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/10) កថាខណ្ឌ ៦ យោងទៅ សាលដីកាលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០២ (អៀង សារី) (ឯកសារ D427/1/30) កថាខណ្ឌ ១១៣។ សាលដីកា *Haradinaj* (តុលាការ ICTY) កថាខណ្ឌ ១២។ សាលដីកា *Krajišnik* (តុលាការ ICTY) កថាខណ្ឌ ១៤។

[1317] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/10) កថាខណ្ឌ ៦ យោងទៅបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៦៨-៨៣។

[1318] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/10) កថាខណ្ឌ ៧ យោងទៅបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៣២-៤១, ៧៣-៧៨, ៨៣-៨៦។

[1319] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៩៧, សូមមើល ជាទូទៅ កថាខណ្ឌ ៨៤-៩៧។ ប្រតិចារិកសវនាការក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/8.1 & D360/17.1, ERN 01626003-01626004 ទំព័រ ១៤:២៤ ដល់ ១៥:៩ 01626004-01626005 ទំព័រ ១៥:២៥ ដល់ ១៦:៥ 01626006 ទំព័រ ១៧:១៦ ដល់ ១៧:១៨ 01626010 ទំព័រ ២១:១៩ ដល់ ២១:២៤ 01626011 ទំព័រ ២២:៧ ដល់ ២២:១៦។ ប្រតិចារិកសវនាការក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/10.1 & D360/19.1 ERN 01626139 ទំព័រ ១២:៧ ដល់ ១២:១៥។

[1320] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៨៤, ៨៦។

តុលាការអន្តរជាតិ អាចមានឥទ្ធិពលលើវិសាលភាព យុត្តាធិការបុគ្គល និងកិច្ចការរបស់តុលាការ ដោយមិនធ្វើឲ្យប៉ះពាល់ដល់អនាគតិ និងឯករាជ្យភាពរបស់តុលាការ"[1321] ហើយរាជរដ្ឋាភិបាលកម្ពុជា ដែលជាស្ថាបនិកនៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក អាចមានឥទ្ធិពលទៅលើការបញ្ចប់អាណត្តិរបស់តុលាការនេះដែរ[1322]។

៦៤០. សហព្រះរាជអាជ្ញាជាតិបានលើកឡើងថា រាជរដ្ឋាភិបាលកម្ពុជា "កំពុងតែដើរតួដូច ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដែលក្រុមប្រឹក្សានេះបានអនុវត្តចំពោះតុលាការ ICTY ICTR និង SCSL អញ្ចឹងដែរ" ហើយអាចកម្រិតយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[1323]។ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ជាស្ថាបនិករបស់តុលាការ ICTY បានបង្គាប់ដល់តុលាការនេះឲ្យផ្តោតដីកាបញ្ជូនរឿងទៅជំនុំជម្រះតែទៅលើមេដឹកនាំជាន់ខ្ពស់ ដែលត្រូវបានសង្ស័យថាទទួលខុសត្រូវខ្ពស់បំផុត។ ចៅក្រមរបស់តុលាការ ICTY បានបង្កើតវិធានថ្មី ដែលអនុលោមតាមវិធាននេះ រឿងក្តីត្រូវបានបញ្ជូនទៅយុត្តាធិការជាតិ ស្របទៅតាមការណែនាំរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ[1324]។

៦៤១. សហព្រះរាជអាជ្ញាជាតិជំរុញអង្គជំនុំជម្រះ "ឲ្យធ្វើសកម្មភាពស្របតាមការកំណត់របស់រាជរដ្ឋាភិបាលកម្ពុជា និងតាមស្មារតីច្បាប់ អ.វ.ត.ក" ដែលតម្រូវឲ្យតុលាការធ្វើការស៊ើបអង្កេត និងជំនុំជម្រះតែ "មេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត" នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ[1325]។ បើតាមការយល់ឃើញរបស់គាត់ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" សំដៅទៅ កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាប្រធានមន្ទីរសន្តិសុខ ស-២១ ដែលដើរតួនាទីយ៉ាងសំខាន់នៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដោយមានស្វ័យភាព និងសិទ្ធិអំណាចជាក់ស្តែង។ ចំនួនអ្នកដែលស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក មានកម្រិតកំណត់ និងតិចតួចបំផុត[1326]។

៦៤២. សហព្រះរាជអាជ្ញាជាតិអះអាងទៀតថា នៅក្នុងបុព្វកថានៃកិច្ចព្រមព្រៀង អ.វ.ត.ក អង្គការសហ

---

1321 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៩០។

1322 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៨៦។

1323 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៩០។

1324 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៨៦-៨៨, ៩០។

1325 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៩០។

1326 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៩១-៩៣។ ប្រតិចារឹកសវនាការក្នុងសំណុំរឿង ០០៤/២ថ្ងៃទី១៩ខែមិថុនា ឆ្នាំ២០១៩(CS) ឯកសារ D359/8.1 & D360/17.1, ERN 01626010 ទំព័រ ២១:២៥ដល់ ២១:១២។

ប្រជាជាតិបានទទួលស្គាល់ពីការព្រួយបារម្ភសមស្របរបស់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ដែលត្រូវថ្លឹងថ្លែងរវាងយុត្តិធម៌ និងការផ្សះផ្សាជាតិ[1327]។ ផ្តើមចេញពីការទទួលស្គាល់នេះ កិច្ចព្រមព្រៀង និងច្បាប់ស្តីការបង្កើត អ.វ.ត.ក មានគោលដៅតែលើបុគ្គលពីរប្រភេទប៉ុណ្ណោះដែលត្រូវយកមកធ្វើការវិនិច្ឆ័យ គឺ "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត"[1328]។ សហព្រះរាជអាជ្ញាជាតិអះអាងថា "ការពង្រីកវិសាលភាពពាក់ព័ន្ធនឹងយុត្តាធិការបុគ្គលលើ អោ អាន លើសពីវិសាលភាពនៃសំណុំរឿង ០០១ និង ០០២ ដែលកំពុងមានស្រាប់នាពេលបច្ចុប្បន្ន នឹងអូសបន្លាយពេលវេលា និងចំណាយថវិកាដោយមិនចាំបាច់"[1329]។ សហព្រះរាជអាជ្ញាជាតិអះអាងទៀតថា យុត្តិធម៌ "សម្រាប់ជនរងគ្រោះ អាចទទួលយកបានហើយ និងត្រូវគ្របដណ្តប់ដោយការជំនុំជម្រះសំណុំរឿង ០០១ និង ០០២"[1330]។ អាស្រ័យហេតុនេះ អោ អាន មិនស្ថិតក្នុងយុត្តាធិការនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឡើយ[1331]។

៦៤៣. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (១) មិនយកចិត្តទុកដាក់លើចេតនាច្បាស់លាស់របស់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ នៅក្នុងការសម្រេចបានកិច្ចព្រមព្រៀង អ.វ.ត.ក (២) ខកខានមិនបានបង្ហាញថា រាជរដ្ឋាភិបាលកម្ពុជាមានអំណាចជាឯកតោភាគីក្នុងការកម្រិតយុត្តាធិការបុគ្គល (៣) អះអាងដោយមិនសមហេតុផលថា សំណុំរឿង ០០១ និង ០០២ បានផ្តល់យុត្តិធម៌គ្រប់គ្រាន់ហើយ[1332]។

៦៤៤. ទីមួយ ប្រវត្តិនៃការចរចាបង្កើត អ.វ.ត.ក បង្ហាញថា រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ មានចេតនារួមចង់ឲ្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" គឺជាប្រភេទបើកចំហមួយ ដែលសមាជិកភាពនៃអ្នកក្នុងប្រភេទនេះត្រូវកំណត់ដោយសហព្រះរាជអាជ្ញា និងចៅក្រម ដោយផ្អែកលើភស្តុតាងទាំងមូល និង

---

[1327] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៩៤។ ប្រតិចារឹកសវនាការក្នុងសំណុំរឿង ០០៤/២ថ្ងៃទី១៩ខែមិថុនា ឆ្នាំ២០១៩(CS) ឯកសារ D359/8.1 & D360/17.1, ERN 01626010 ទំព័រ ២១:១២ ដល់ ២១:១៩។

[1328] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៩៥។

[1329] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៩៦។

[1330] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៩៦។

[1331] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៩៧។

[1332] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/10) កថាខណ្ឌ ៥។

01635124



បំពេញកិច្ចដោយឯករាជ្យ មិនស្ថិតក្រោមការណែនាំណាមួយឡើយ[1333]។ សេចក្តីថ្លែងការណ៍របស់មន្ត្រីរដ្ឋាភិបាលកម្ពុជា នៅពេលចរចាលើកិច្ចព្រមព្រៀង អ.វ.ត.ក និងការអនុម័តច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បង្ហាញថា រាជរដ្ឋាភិបាលកម្ពុជាមានចេតនាមិនជ្រៀតជ្រែកក្នុងកិច្ចការ អ.វ.ត.ក នោះទេ រួមទាំង ក្នុងការកំណត់ថា តើមានមនុស្សចំនួនប៉ុន្មាននាក់គួរត្រូវបានយកមកកាត់ទោសនោះ ពីព្រោះនេះជាសមត្ថកិច្ចផ្តាច់មុខរបស់តុលាការ[1334]។ ដូចគ្នាផងដែរ អង្គការសហប្រជាជាតិយល់ឃើញថា មិនមានកំណត់ចំនួនមនុស្សដែលជាគោលដៅសម្រាប់ការស៊ើបអង្កេតនោះទេ[1335]។

៦៤៥. ទីពីរ គ្មានភាគីណាមួយនៃកិច្ចព្រមព្រៀង អ.វ.ត.ក អាចកែប្រែវិសាលភាពនៃយុត្តាធិការបុគ្គល ជាឯកតោភាគីបានឡើយ[1336]។ ការកែប្រែគោលនយោបាយ ដែលបានលើកឡើងនៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក រួមទាំងយុត្តាធិការបុគ្គល ត្រូវពិភាក្សា និងអនុម័តដោយភាគីទាំងពីរ[1337]។ ដោយហេតុថារាជរដ្ឋា

---

[1333] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/10) កថាខណ្ឌ ១៦, សូមមើលផងដែរ កថាខណ្ឌ ៥។ ប្រតិចារឹកសវនាការក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/8.1 & D360/17.1, ERN 01626014-01626015 ទំព័រ ២៥:៣ ដល់ ២៦:២។

[1334] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/10) កថាខណ្ឌ ៩-១២ ដកស្រង់ លិខិតរបស់នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជាផ្ញើជូនអគ្គលេខាធិការ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៩ ឯកសារ អ.ស.ប លេខ A/53/875, S/1999/324 កថាខណ្ឌ ២-៣។ *សេចក្តីប្រកាសរបស់ខុទ្ទកាល័យសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជានៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៩៩* ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៩ ឯកសារ អ.ស.ប លេខ A/53/916 ឧបសម្ព័ន្ធ។ "ហ៊ុន សែន សោកស្តាយដោយបានបញ្ជាក់ពីចំនួនមេដឹកនាំខ្មែរក្រហមដែលត្រូវជំនុំជម្រះ" *Kyodo News International* ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០០០ ឯកសារ D360/10.1.18 ។ កិច្ចប្រជុំរដ្ឋសភាកម្ពុជា ទំព័រ ៣១, ៣៥, ៤៦-៤៨។

[1335] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/10) កថាខណ្ឌ ១៣-១៤ ដកស្រង់ *របាយការណ៍របស់ក្រុមអ្នកជំនាញសម្រាប់កម្ពុជា ដែលត្រូវបានបង្កើតឡើងយោងតាមសេចក្តីសម្រេចមហាសន្និបាតលេខ 52/135* ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៩ ឯកសារ អ.ស.ប លេខ A/53/850 និង S/1999/231 ឧបសម្ព័ន្ធ កថាខណ្ឌ ១១០។ SCHEFFER "The Negotiating History of the ECCC's Personal Jurisdiction (ប្រវត្តិនៃការចរចាលើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក)" (ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១) ទំព័រ ៣-៥។

[1336] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/10) កថាខណ្ឌ ១៧-២៦។

[1337] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/10) កថាខណ្ឌ ២០ យោងទៅកិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ២(៣)។

ភិបាលកម្ពុជាជាប់កាតព្វកិច្ចតាមកិច្ចព្រមព្រៀង អ.វ.ត.ក រាជរដ្ឋាភិបាលកម្ពុជាមិនអាចកែប្រែលក្ខខណ្ឌទាំងនេះតាមរយៈសេចក្តីប្រកាសគោលនយោបាយជាឯកតោភាគី ដែលធ្វើឡើង ក្រោយពីការអនុម័តកិច្ចព្រមព្រៀងនេះបានឡើយ[1338]។ ការប្រដូចទៅនឹងឥទ្ធិពលរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិទៅលើតុលាការ ICTY និង ICTR មិនត្រឹមត្រូវទេ[1339]។ គោលការណ៍នីតិរដ្ឋជាមូលដ្ឋាននៃឯករាជ្យភាពរបស់តុលាការ ដែលហាមឃាត់ចៅក្រមមិនឱ្យទទួលការណែនាំពីរដ្ឋាភិបាល ឬប្រភពខាងក្រៅណាមួយ ក៏ត្រូវបានការពារផងដែរនៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែរ[1340]។

៦៤៦. ទីបី បុព្វកថានៃកិច្ចព្រមព្រៀង អ.វ.ត.ក មិនត្រូវបានរំពឹងថាជាផ្នែកមួយនៃលក្ខខណ្ឌសម្រាប់ "កម្រិតវិសាលភាពនៃយុត្តាធិការបុគ្គលត្រឹមមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត"ឡើយ[1341]។ "មិនមានសញ្ញាណណាមួយ" បង្ហាញថា សេចក្តីសម្រេចតាមផ្លូវតុលាការលើសំណុំរឿង ០០៤/២ នឹងគំរាមកំហែងដល់សន្តិភាព និងសន្តិសុខរបស់ប្រទេសកម្ពុជានោះទេ[1342]។ សំណុំរឿង ០០៤/២ រួមមាន បញ្ហា និងទីតាំងឧក្រិដ្ឋកម្ម ដែលមិនមែនជាកម្មវត្ថុនៃសំណុំរឿង ០០១ ឬ ០០២។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរាប់រយនាក់ ដែលបានដាក់ពាក្យចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០៤/២ ពិតជាមិនជឿថា យុត្តិធម៌ត្រូវបានផ្តល់ពេញលេញដោយសំណុំរឿង ០០១ និង ០០២ នេះទេ[1343]។

៦៤៧. សហព្រះរាជអាជ្ញាជាតិមិនបានដាក់ការឆ្លើយតបទៅនឹងចម្លើយតបនេះទេ។

---

1338 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/10) កថាខណ្ឌ ២១ យោងទៅអនុសញ្ញាទីក្រុងវីយែន មាត្រា ៥៤, ៥៦។

1339 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/10) កថាខណ្ឌ ១៨-១៩។

1340 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/10) កថាខណ្ឌ ២៦។

1341 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/10) កថាខណ្ឌ ២៨។

1342 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/10) កថាខណ្ឌ ២៩។

1343 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/10) កថាខណ្ឌ ៣៤។

២. ការពិភាក្សា

៦៤៨. ថ្វីត្បិតតែចៅក្រមអន្តរជាតិកត់សម្គាល់ថា សហព្រះរាជអាជ្ញាអាចដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងគ្រប់ដីការបស់សហចៅក្រមស៊ើបអង្កេតក៏ដោយ[1344] ក៏ចៅក្រមអន្តរជាតិបដិសេធភ្លាមៗចំពោះបណ្តឹងឧទ្ធរណ៍ទាំងស្រុងរបស់សហព្រះរាជអាជ្ញាជាតិ ដោយសារតែខកខានមិនបានបង្ហាញកំហុសជាដុំកំភួន ឬជាក់ស្តែង នៅក្នុងដីកាដំណោះស្រាយដែលរងការជំទាស់ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)។

៦៤៩. ចៅក្រមអន្តរជាតិរម្លឹកថា ទឡ្ហីករណ៍របស់ភាគីណាមួយ ដែលមិនមានសក្តានុពលនាំឱ្យមោឃភាព ឬកែប្រែសេចក្តីសម្រេចដែលរងការជំទាស់ អាចត្រូវបានបដិសេធចោលភ្លាម ដោយមិនចាំបាច់ធ្វើការពិចារណាលើអង្គសេចក្តីឡើយ[1345]។ សហព្រះរាជអាជ្ញាជាតិបានដាក់សេចក្តីសន្និដ្ឋានលើប្រវត្តិសាវតារ ឬបរិបទរួម[1346] ការវិភាគតាមបែបផ្សេងទៅលើភស្តុតាង[1347] ហើយគ្រាន់តែអះអាងអំពីការយល់ឃើញ ឬការបកស្រាយរបស់ខ្លួនទៅលើនិយមន័យនៃ "មេដឹកនាំជាន់ខ្ពស់" ឬ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែលស្ថិតនៅក្រោមយុត្តាធិការបុគ្គល[1348]។ ចៅក្រមអន្តរជាតិមិនឃើញមានលទ្ធភាពណាមួយក្នុងសេចក្តី

[1344] វិធាន ៧៤(២) នៃវិធានផ្ទៃក្នុង។

[1345] សាលដីកាក្នុងសំណុំរឿង ០០២ លើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (D250/3/2/1/5) កថាខណ្ឌ ២២ យោងទៅ សាលដីកា *Blaškić* (តុលាការ ICTY) កថាខណ្ឌ ១៣។ សាលដីកា *Rutaganda* (តុលាការ ICTR) កថាខណ្ឌ ១៨។

[1346] សូមមើល ក្នុងចំណោមផ្សេងទៀត បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ២៦-៣០ (ពណ៌នាពីប្រវត្តិ និងការវិវឌ្ឍរបស់ ប.ក.ក) កថាខណ្ឌ ៣១-៥២ (ឧទាហរណ៍ ពណ៌នាពីគណៈកម្មាធិការមជ្ឈិមថាជា "អង្គការប្រតិបត្តិការខ្ពស់ជាងគេបំផុតសម្រាប់ទូទាំងប្រទេស") គណៈកម្មាធិការអចិន្ត្រៃយ៍ និងសមាជបក្ស ពាក់ព័ន្ធនឹងការដឹកនាំ ប.ក.ក) ឬ កថាខណ្ឌ ៥៣-៦០ (ផ្តល់ព័ត៌មានលម្អិតមួយចំនួនអំពីប្រវត្តិផ្ទាល់ខ្លួនរបស់ អោ អាន)។

[1347] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៧០-៧៨។

[1348] សូមមើល ក្នុងចំណោមផ្សេងទៀត បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៨៤-៩៧។ ទាក់ទងនឹងយុត្តាធិការបុគ្គល ចៅក្រមអន្តរជាតិកត់សម្គាល់ថា ទោះបីជាពាក្យ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" មិនត្រូវបានកំណត់និយមន័យនៅក្នុងកិច្ចព្រមព្រៀង ឬច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ក៏ដោយ ការបកស្រាយពាក្យនេះអាចត្រូវបានធ្វើ ដោយពិនិត្យមើលយុត្តិសាស្ត្រអន្តរជាតិពាក់ព័ន្ធ ស្របតាមកម្មវត្ថុ និងគោលបំណងនៃលិខិតូបករណ៍បង្កើតតុលាការ ដោយពុំចាំបាច់មើលប្រវត្តិនៃការចរចា ឬគោលបំណងដើម (សូមមើល អនុសញ្ញាទីក្រុងវីយែន មាត្រា ៣១(១)-(២))។

សន្និដ្ឋានទាំងនេះ ដែលនាំឱ្យមោឃភាព ឬកែប្រែសេចក្តីសម្រេចដែលរងការជំទាស់ឡើយ ហេតុដូច្នេះ បដិសេធចោលបណ្តឹងឧទ្ធរណ៍ទាំងស្រុងភ្លាមៗ។

៦៥០. ទោះជាមានការបដិសេធចោលភ្លាមៗនេះក៏ដោយ ដោយហេតុថា សហព្រះរាជអាជ្ញាជាតិបានលើកឡើងនូវបញ្ហាពីរពាក់ព័ន្ធនឹងសុចរិតភាពនៃ អ.វ.ត.ក អង្គបុរេជំនុំជម្រះអនុវត្តយុត្តាធិការជាមូលដ្ឋានរបស់ខ្លួនដើម្បីដោះស្រាយបញ្ហាទាំងនេះ សម្រាប់ជាប្រយោជន៍នៃយុត្តិធម៌ គឺ (ក) គោលជំហរ និងអំណាចរបស់រាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[1349] និង (ខ) ការចោទប្រកាន់អំពី "ការថ្លឹងថ្លែងរវាងយុត្តិធម៌ និងការផ្សះផ្សាជាតិ" សម្រាប់ជនរងគ្រោះនៃសំណុំរឿង ០០៤/២[1350]។

៦៥១. ទីមួយ ចៅក្រមអន្តរជាតិបដិសេធជាប្រចាំ និងដោយច្បាស់លាស់ ចំពោះការអះអាងរបស់សហព្រះរាជអាជ្ញាជាតិដែលថា រាជរដ្ឋាភិបាលកម្ពុជាដើរតួដូចក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងអាចមាន "ឥទ្ធិពលលើវិសាលភាពយុត្តាធិការបុគ្គល និងកិច្ចការរបស់តុលាការ"[1351]។

៦៥២. ចៅក្រមអន្តរជាតិមិនឃើញមានមូលដ្ឋានផ្លូវច្បាប់ណាមួយដែលថា រាជរដ្ឋាភិបាលកម្ពុជា ក្នុងឋានៈជាភាគីម្ខាងដែលបានបង្កើតតុលាការ អាចមានអំណាចជាឯកតោភាគីក្នុងការកំណត់ឡើងវិញចំពោះនិយមន័យនៃយុត្តាធិការបុគ្គល និង/ឬមាន "ឥទ្ធិពល" លើដំណើរការដោយឯករាជ្យរបស់តុលាការនោះឡើយ។ ការលើកឡើងរបស់សហព្រះរាជអាជ្ញាជាតិអំពីប្រវត្តិនៃការចរចាបង្កើត អ.វ.ត.ក[1352] គ្រាន់តែឆ្លុះបញ្ចាំងអំពីទស្សនៈរបស់រាជរដ្ឋាភិបាលកម្ពុជាប៉ុណ្ណោះ និងមិនបានបង្ហាញមូលដ្ឋានសំខាន់សម្រាប់ការបកស្រាយកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដើម្បីជាគោលបំណងនៃយុត្តាធិការបុគ្គលឡើយ។

៦៥៣. ទីពីរ ចៅក្រមអន្តរជាតិរម្លឹកថា បុព្វកថានៃកិច្ចព្រមព្រៀង អ.វ.ត.ក បញ្ជាក់ថា "មហាសន្និបាតទទួលស្គាល់ការព្រួយបារម្ភពេញច្បាប់របស់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថិរភាព សន្តិភាព និងសន្តិសុខ"។ ចៅក្រមអន្តរជាតិមិនជឿលើការអះអាងរបស់សហព្រះរាជអាជ្ញាជាតិដែលថា ការថ្លឹងថ្លែងរវាង "យុត្តិធម៌" និង "ការផ្សះផ្សាជាតិ"[1353] នាំឱ្យមានការសន្និដ្ឋាន

---

[1349] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៩០។

[1350] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៩៤, ៩៦។

[1351] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៩០។

[1352] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៨៩-៩៣។

[1353] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៩៤។

01635128



ថា យុត្តិធម៌ត្រូវបានផ្តល់ជូនដល់ជនរងគ្រោះនៃសំណុំរឿង ០០៤/២ តាមរយៈការជំនុំជម្រះក្តីលើសំណុំរឿង ០០១ និង ០០២ នោះទេ[1354]។ លើសពីនេះទៀត ចៅក្រមអន្តរជាតិមិនយល់ស្របថា ការអនុវត្តយុត្តាធិការបុគ្គលក្នុងសំណុំរឿង ០០៤/២ នឹងអូសបន្លាយពេលវេលា និងចំណាយថវិកាដោយមិនចាំបាច់នោះឡើយ[1355]។

៦៥៤. មាត្រា ១ នៃកិច្ចព្រមព្រៀង អ.វ.ត.ក បញ្ជាក់ច្បាស់ថា គោលបំណងរបស់កិច្ចព្រមព្រៀងនេះ គឺកំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា *ដើម្បីកាត់សេចក្តី* មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម។ ដូច្នេះ បុព្វកថាគួរត្រូវបានយល់ថា "ការបង្រួបបង្រួមជាតិ ស្ថិរភាព សន្តិភាព និងសន្តិសុខ" ត្រូវបានលើកកម្ពស់ ដោយសារតែការកាត់ទោសមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ជាជាងការបំផ្លាញយុត្តិធម៌ តាមរយៈការបង្កើនលំហនិទណ្ឌភាព និងបំបិទសម្លេងរបស់ជនរងគ្រោះ។

៦៥៥. អោ អាន ត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ ដែលជាឧក្រិដ្ឋកម្មដ៏សាហាវឃោរឃៅបំផុតនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដោយសារតែភាពធ្ងន់ធ្ងរ និងទំហំនៃឧក្រិដ្ឋកម្ម។ នៅក្នុងដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងការចោទប្រកាន់) នៃសំណុំរឿង ០០៤/២ សហចៅក្រមស៊ើបអង្កេតជាតិបានកំណត់ថា ជនរងគ្រោះរាប់ពាន់នាក់បានស្លាប់នៅតាមទីតាំងនានា[1356] ដោយបានបញ្ជាក់ថា ជនរងគ្រោះមានចំនួនប្រមាណ ៣០.០០០ នាក់ នៅទីតាំងឧក្រិដ្ឋកម្មមួយ ដែលប្រហែលស្មើនឹងលលាដ៍ក្បាលជាច្រើនដែលត្រូវបានរកឃើញ នៅមន្ទីរ ស-២១ ដែរ[1357]។ នៅក្នុងសំណុំរឿង ០០៤/២ តែឯង អ្នក

---

[1354] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៩៦។

[1355] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D360/8/1) កថាខណ្ឌ ៩៦។

[1356] សូមមើល ក្នុងចំណោមផ្សេងទៀត ដីកាដំណោះស្រាយ (លើកលែងចោទប្រកាន់) (ឯកសារ D359) កថាខណ្ឌ ២៩៧ (សន្និដ្ឋានថា មានមនុស្សចំនួនប្រមាណមួយម៉ឺននាក់បានស្លាប់នៅភ្នំប្រុស ផ្អែកលើមូលដ្ឋានឯកសាររបស់រដ្ឋាភិបាល និងតាមរយៈការគាស់កកាយប្រមូលឆ្អឹងសាកសពនៅជុំវិញបរិវេណកន្លែងសម្លាប់មនុស្ស) កថាខណ្ឌ ៣១១ (សន្និដ្ឋានថា តាមការប៉ាន់ស្មាន មានជនរងគ្រោះប្រមាណបីម៉ឺននាក់ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខវត្តអូរត្រកួន) កថាខណ្ឌ ៣២២ (សន្និដ្ឋានថា មានជនរងគ្រោះប្រមាណមួយម៉ឺននាក់ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខវត្តបាធាយ) កថាខណ្ឌ ៣៣១ (សន្និដ្ឋានថា តាមការប៉ាន់ស្មាន មានមនុស្សប្រមាណពីរពាន់នាក់ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខមិត្តសុប) និងកថាខណ្ឌ ៣៣៦ (សន្និដ្ឋានថា ជនរងគ្រោះមួយពាន់នាក់បានស្លាប់នៅមន្ទីរសន្តិសុខគោកព្រីង)។

[1357] ដីកាដំណោះស្រាយ (លើកលែងចោទប្រកាន់) (ឯកសារ D359) កថាខណ្ឌ ៣១១។ "ក្រោយការដួលរលំរបបកម្ពុ

ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរាប់រយនាក់បានដាក់ពាក្យសុំចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ក្នុងនោះ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤៣៤ នាក់ ត្រូវបានសហចៅក្រមស៊ើបអង្កេតអន្តរជាតិប្រកាសទទួលយក[1358]។ ទោះជាចៅក្រមអន្តរជាតិទទួលស្គាល់ថា តុលាការត្រូវការពេលវេលា និងធនធាន ដើម្បីធានាថាយុត្តិធម៌ត្រូវបានផ្តល់ជូនក៏ដោយ ក៏ការមិនគិតគូរទៅលើស្ថានភាពរបស់ជនរងគ្រោះក្នុងសំណុំរឿង ០០៤/២ មិនអាចចាត់ទុកជាមធ្យោបាយដែលអាចធ្វើបាន ឬសមហេតុផល ក្នុងការសម្រេចបាន "ការផ្សះផ្សាជាតិ" ឡើយ។ ជនរងគ្រោះនីមួយៗមានសិទ្ធិទទួលបានយន្តការតុលាការ និងជំរុញការដោះស្រាយភ្លាមៗចំពោះព្យសនកម្មដែលគាត់បានទទួលរង[1359]។

## បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន

**(ឯកសារ D359)**

### ១. សារណា

៦៥៦. សហព្រះរាជអាជ្ញាអន្តរជាតិ បានប្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចលើកលែងចោទប្រកាន់ ហើយ

---

ជាប្រជាធិបតេយ្យ គេឃើញមានលលាដ៍ក្បាលជាច្រើននៅមន្ទីរសន្តិសុខវត្តអូរត្រកួន ប្រហែលស្មើនឹងនៅមន្ទីរសន្តិសុខ ស-២១ ដែរ។ ម្យ៉ាងវិញទៀត បន្ទាប់រំដោះ បើតាមអ្នករដ្ឋការសម័យរដ្ឋកម្ពុជា ចំនួនជនរងគ្រោះដែលត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខវត្តអូរត្រកួនមានប្រហែលជា ៣០.០០០ (បីម៉ឺន) នាក់។ បើទោះបីជាមានការបញ្ជាក់ពីអត្រាពាក់ព័ន្ធចំនួនអ្នកស្លាប់នេះក៏ពិតមែន ប៉ុន្តែ វាគ្រាន់តែជាការប៉ាន់ស្មានរបស់មន្ត្រីខ្លះប៉ុណ្ណោះ") សូមមើលផងដែរ កថាខណ្ឌ ៥៤៧ (សន្និដ្ឋានស្រដៀងគ្នាថា មានមនុស្សរហូតដល់ ២០.០០០ នាក់បានស្លាប់ ក្រោមកិច្ចប្រតិបត្តិការដឹកនាំដោយផ្ទាល់នៅមន្ទីរសន្តិសុខ ស-២១)។

[1358] សូមមើល ឧទាហរណ៍ ឧបសម្ព័ន្ធ ក៖ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់ (ពីដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D362.1។

[1359] *សេចក្តីថ្លែងការណ៍អំពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ និងការរំលោភអំណាច* កថាខណ្ឌ ៤។ វិធាន ២១(១) នៃវិធានផ្ទៃក្នុង ("ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយ ក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ [...] ជនរងគ្រោះ")។ សូមមើលផងដែរ វិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង (ចែងថា "អង្គជំនុំជម្រះវិសាមញ្ញត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី [...]")។

ស្នើដល់អង្គបុរេជំនុំជម្រះ៖ ច្រានចោលការសម្រេចរបស់ ដីកាសម្រេចលើកលែងចោទប្រកាន់ដែលថា អោ អាន មិនស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ហើយសម្រេចថា អោ អាន ស្ថិតក្នុងចំណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មខ្មែរក្រហម ព្រមទាំងបញ្ជូន អោ អាន ទៅជំនុំជម្រះ ដោយផ្អែកលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ[1360]។

៦៥៧. សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងថា សហចៅក្រមស៊ើបអង្កេតជាតិ មានកំហុសឆ្គងអង្គច្បាប់ និងអង្គហេតុ ដោយសម្រេចថា អោ អាន មិនស្ថិតក្រោមយុត្តាធិកាបុគ្គលររបស់ អ.វ.ត.ក[1361] ដូចដែលបានរៀបរាប់លម្អិត នៅក្នុងផ្នែកមូលដ្ឋាន ក ដល់ មូលដ្ឋាន ច ខាងក្រោម។ បន្ថែមលើនេះសហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងនូវអំណះអំណាងនានាអំពីដីកាដំណោះស្រាយដែលផ្ទុយគ្នា។

### ក. មូលដ្ឋាន ក៖ កំហុសអង្គច្បាប់នៃការខកខានមិនបានធ្វើការសន្និដ្ឋាន

៦៥៨. សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងថា សហចៅក្រមស៊ើបអង្កេតជាតិ បានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយមិនបានធ្វើការសន្និដ្ឋានអំពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងការទទួលខុសត្រូវរបស់ អោ អាន ចំពោះឧក្រិដ្ឋកម្មទាំងអស់នេះ[1362]។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) គឺ "មិនមានសំអាងហេតុ និងមិនមានលក្ខណៈគ្រប់គ្រាន់តាមផ្លូវច្បាប់" ដោយសារតែដីកាសម្រេចលើកលែងចោទប្រកាន់ មិនបានវាយតម្លៃគ្រប់ជ្រុងជ្រោយ អំពីនរណាដែលជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្ម រួមទាំង ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ផង[1363]។ ទោះបីជាដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) មាន "ការពិនិត្យទៅលើភស្តុតាងមួយផ្នែក និងមានការសន្និដ្ឋានលើអង្គហេតុមួយចំនួន"[1364] ក្តី តែដីកាសម្រេចលើកលែងចោទប្រកាន់ មិនបានឈានទៅដល់ការសន្និដ្ឋានតាមផ្លូវច្បាប់ អំពី "ការប្រព្រឹត្តិឧក្រិដ្ឋកម្ម និងការទទួលខុសត្រូវរបស់ អោ អាន ដែលចេញពីការសន្និដ្ឋានផ្នែកអង្គហេតុនានារបស់ខ្លួន"[1365]។

---

[1360] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៤, ១១២។

[1361] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ១៣។

[1362] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ១៤-៣១។

[1363] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ១៤-១៥។ សំណុំរឿង ០០៤/២ ប្រតិចារឹកថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/8.1 និង D360/17.1 ERN 01626033-01626034 ទំព័រ ៤៤:២៣-៤៥:៥។

[1364] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ១៧។

[1365] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ១៧-៣១។ សូមមើល សំណុំរឿង ០០៤/

៦៥៩. នៅក្នុងចម្លើយតប សហមេធាវីបានលើកឡើងថា មូលដ្ឋាន ក គួរត្រូវបានច្រានចោល ដោយសារតែ សហព្រះរាជអាជ្ញាអន្តរជាតិ មិនបានបង្ហាញអំពីកំហុសអង្គហេតុ ឬកំហុសអង្គច្បាប់ ដែលធ្វើឱ្យមោឃ ភាពដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់)[1366]។ បន្ថែមលើនេះ សហចៅក្រមស៊ើប អង្កេតជាតិ "បានអនុវត្តស្របតាមលក្ខខណ្ឌតម្រូវផ្នែកនីតិវិធី ដែលអាចអនុវត្តបានសម្រាប់ដីកាសម្រេច លើកលែងចោទប្រកាន់ ដែលមានសុពលភាព"[1367] ហើយបានផ្ដល់សំអាងហេតុ សម្រាប់សេចក្ដីសម្រេច របស់ខ្លួន ក្នុងការលើកលែងចោទប្រកាន់ប្រឆាំង អោ អាន ដោយចង្អុលបង្ហាញថា មូលដ្ឋានចម្បងគឺ "កង្វះ យុត្តាធិការបុគ្គលរបស់តុលាការនេះមកលើ អោ អាន"[1368]។ សហមេធាវីអះអាងថា សហចៅក្រមស៊ើប អង្កេតជាតិ បានផ្ដល់ "មូលហេតុគ្រប់គ្រាន់សម្រាប់ការសម្រេចរបស់គាត់" ហើយថា "ការវាយតម្លៃភស្តុ តាងក្នុងកម្រិតដូចគ្នានេះ មិនតម្រូវឱ្យមាននោះទេ នៅពេលលើកលែងចោទប្រកាន់"[1369]។

៦៦០. នៅក្នុងការឆ្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងថា ផ្ទុយពីការអះអាងរបស់សហ មេធាវី ច្បាប់តម្រូវថា ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) ត្រូវមានការសន្និដ្ឋានពាក់ ព័ន្ធនឹងការកំណត់ប្រភេទនៃឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវ ដើម្បីផ្ដល់នូវសេចក្ដីសម្រេចដែល មានសំអាងហេតុអំពីយុត្តាធិការបុគ្គល[1370]។ ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) មិនបានធ្វើការសន្និដ្ឋានផ្លូវច្បាប់ត្រឹមត្រូវ អំពីអង្គហេតុដែលសហចៅក្រមស៊ើបអង្កេត បានទទួលនោះ ឡើយ[1371]។

---

២ ប្រតិចារឹកថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/8.1 និង D360/17.1 ERN 01626030-01626031 01626030-0162512 ទំព័រ ៤១:២០-៤២:១៣។

[1366] ចម្លើយតបរបស់ អោ អាន (ឯកសារ D359/3/4) កថាខណ្ឌ ១៣។

[1367] ចម្លើយតបរបស់ អោ អាន (ឯកសារ D359/3/4) កថាខណ្ឌ ១៣។

[1368] ចម្លើយតបរបស់ អោ អាន (ឯកសារ D359/3/4) កថាខណ្ឌ ៧-១៣។ សំណុំរឿង ០០៤/២ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 01626112-01626113 ទំព័រ ៥៨:២៤-៥៩:៣។

[1369] ចម្លើយតបរបស់ អោ អាន (ឯកសារ D359/3/4) កថាខណ្ឌ ៨-១២។ សំណុំរឿង ០០៤/២ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 01626113-01626114 ទំព័រ ៥៩:៥-៦០:៥។

[1370] ការឆ្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/5) កថាខណ្ឌ ៦-១០។

[1371] ការឆ្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/5) កថាខណ្ឌ ១១-១២។

ខ. មូលដ្ឋាន ខ៖ កំហុសអង្គហេតុឬ កំហុសអង្គច្បាប់ ក្នុងការផ្ដល់ទម្ងន់ហួសហេតុទៅលើការបង្ខិតបង្ខំ ការគាបសង្កត់ និងបញ្ជារបស់ថ្នាក់លើ

៦៦១. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតជាតិ មានកំហុសអង្គហេតុនិងអង្គច្បាប់ ដោយផ្ដល់ទម្ងន់ខ្លាំងហួសហេតុ ចំពោះការបង្ខិតបង្ខំ ការគាបសង្កត់ និងបញ្ជារបស់ថ្នាក់លើ នៅពេលមិនបានសម្រេច អំពីយុត្តាធិការបុគ្គលទៅលើ អោ អាន[1372]។ កំហុសទាំងនោះរួមមាន (១) ការសង្កត់ធ្ងន់របស់ ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) ទៅលើបញ្ជារបស់ថ្នាក់លើ ការបង្ខិតបង្ខំ និងការគាបសង្កត់[1373] (២) មិនបានពិចារណាថា អោ អាន "បានរៀបចំឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម ដោយមិនមានការគាបសង្កត់ណាមួយឡើយ" គឺមានន័យថា គាត់បានប្រព្រឹត្តឧក្រិដ្ឋកម្មដោយចេតនា ដោយមិនមានការគម្រាមកំហែងណាមួយទេ[1374] (៣) ការសន្និដ្ឋានដែលមិនសមហេតុផល និងមិនមានមូលដ្ឋានដែលថា ការចូលរួមរបស់ អោ អាន នៅក្នុងឧក្រិដ្ឋកម្ម "មិនហួសពីវិសាលភាពសិទ្ធិអំណាចផ្លូវការរបស់គាត់ទេ"[1375] និង (៤) ការប្រព្រឹត្តិខុសគ្នាតាមអំពើចិត្ត របស់សហចៅក្រមស៊ើបអង្កេតជាតិ ទៅលើការបញ្ជារបស់ថ្នាក់លើ ការបង្ខិតបង្ខំ និងការគាបសង្កត់ នៅក្នុងសំណុំរឿង ០០១ ធៀបនិងសំណុំរឿង ០០៤/០២[1376]។

៦៦២. នៅក្នុងចម្លើយតប សហមេធាវីបានអះអាងថា សហព្រះរាជអាជ្ញាអន្តរជាតិ មិនបានកំណត់អំពី "កំហុសលើអង្គច្បាប់ ឬអង្គហេតុ ឬការរំលោភបំពានឆន្ទានុសិទ្ធិណាមួយ" ដែលនាំឱ្យដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) អាចត្រូវធ្វើមោឃភាពបាននោះទេ[1377]។ ការនេះរួមបញ្ចូលទាំងការមិនបានចង្អុលបង្ហាញ ពីកំហុសឆ្គងក្នុងការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតជាតិ ទៅលើការបង្ខិតបង្ខំ ការគាបសង្កត់ និងការបញ្ជារបស់ថ្នាក់លើ ដោយសារតែ (១) កត្តាទាំងនេះពាក់ព័ន្ធជាមួយការសម្រេចថាតើ អោ អាន ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតដែរឬទេ[1378] (២) ទម្លឹករណ៍ដែលថា អោ

[1372] បណ្ដឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៣២-៤៦។

[1373] បណ្ដឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៣២-៣៧។

[1374] បណ្ដឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៣៨-៤១។

[1375] បណ្ដឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៤២។

[1376] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៤៣-៤៦។

[1377] ចម្លើយតបរបស់ អោ អាន (ឯកសារ D359/3/4) កថាខណ្ឌ ១៤។

[1378] ចម្លើយតបរបស់ អោ អាន (ឯកសារ D359/3/4) កថាខណ្ឌ ១៤-១៦។ សំណុំរឿង ០០៤/២ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 01626114-01626115 ទំព័រ ៦០:៦-៦១:៩។

អាន ចូលរួមដោយចេតនា នៅក្នុងឧក្រិដ្ឋកម្ម គឺផ្អែកទៅលើភស្តុតាងមិនអាចទុកចិត្តបាន ដែលមិនអាចជឿជាក់បាន[1379] និង (៣) ដោយសារតែការវាយតម្លៃលើយុត្តាធិការបុគ្គល រួមបញ្ចូលទាំងការត្រួតពិនិត្យ ទៅលើកត្តាផ្សេងៗគ្នា សំណុំរឿង ០០៤/០២ គួរត្រូវបានត្រួតពិនិត្យលើអង្គសេចក្តីផ្ទាល់ ដែលដាច់ផ្សេងពីការសម្រេច នៅក្នុងសំណុំរឿង០០១[1380]។

៦៦៣. នៅក្នុងការឆ្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិ បានបន្តរក្សាជំហរថា ផ្ទុយពីទឡ្ហីករណ៍របស់សហមេធាវី តាមយុត្តិសាស្ត្ររបស់ អ.វ.ត.ក ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) មិនគួរត្រូវបានផ្តល់ទម្ងន់ធ្ងន់ខ្លាំងពេក ចំពោះការបញ្ជារបស់ថ្នាក់លើឡើយ នៅពេលវាយតម្លៃទៅលើយុត្តាធិការបុគ្គល[1381]។ បន្ថែមលើនេះ អោ អាន មិនមែន "ជនរងគ្រោះម្នាក់នៃការបង្ខិតបង្ខំ និងការគាបសង្កត់" ឡើយ ប៉ុន្តែគាត់បានអនុវត្តយ៉ាងសកម្ម នូវគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ[1382]។ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) អនុវត្តច្បាប់ដោយមិនស៊ីចង្វាក់គ្នា ពីសំណុំរឿង០០១ ហើយបានច្រានចោលការពន្យល់របស់សហមេធាវីអំពីមូលហេតុដែល ឌុច ត្រូវបានសម្រេចថា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំណែក អោ អាន មិនមែននោះទេ[1383]។

គ. មូលដ្ឋាន គ៖ កំហុសអង្គច្បាប់នៃការសម្រេចថា ឌុច គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់

៦៦៤. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតជាតិ មានកំហុសអង្គច្បាប់ ដោយសម្រេចថា ឌុច គឺជា "ជនដែលទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់"[1384] ដោយសារតែ (១) ការសម្រេចនេះ ផ្ទុយទៅនឹងសេចក្តីថ្លែងការណ៍អំពីយុត្តាធិការបុគ្គលរបស់ប្រធានក្រុមចរចារបស់រាជរដ្ឋាភិបា

---

[1379] ចម្លើយតបរបស់ អោ អាន (ឯកសារ D359/3/4) កថាខណ្ឌ ១៧។ សំណុំរឿង ០០៤/២ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 01626115 ទំព័រ ៦១:១០-៦១:២០។

[1380] ចម្លើយតបរបស់ អោ អាន (ឯកសារ D359/3/4) កថាខណ្ឌ ១៨។ សំណុំរឿង ០០៤/២ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 01626115-01626116 ទំព័រ ៦១:១១-៦២:៥។

[1381] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/5) កថាខណ្ឌ ១៤-១៧។

[1382] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/5) កថាខណ្ឌ ១៨-២២។

[1383] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/5) កថាខណ្ឌ ២៣-២៤ (រួមបញ្ចូលផងដែរថា អោ អាន "គ្រប់គ្រងចំនួនប្រជាជនស៊ីវិល ច្រើនជាងចំនួនអ្នកទោស ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ ឌុច" និង "បញ្ជាអ្នកនៅក្រោមបង្គាប់ក្នុងចំនួនច្រើនជាង" និងត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មច្រើនមុខ ជាពិសេសត្រូវបានចោទប្រកាន់ពីបទអំពើប្រល័យពូជសាសន៍ ដែល ឌុច មិនត្រូវបានចោទប្រកាន់ទេ)។

[1384] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៤៧ - ៤៨ និងជើងទំព័រ ១៤០។

លកម្ពុជា ហើយមិនបានគោរពចំពោះចេតនារបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើត អ.វ.ត.ក[1385] (២) ការសម្រេចនេះមិនស៊ីចង្វាក់គ្នា ជាមួយការយល់ឃើញរបស់អង្គការសហប្រជាជាតិចំពោះ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ដែលបានកំណត់នៅក្នុងការចរចារ និងមានចែងនៅក្នុងពាក្យពេចន៍សាមញ្ញរបស់ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង[1386] (៣) ការសម្រេចនេះផ្ទុយពីការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតជាតិខ្លួនឯងផ្ទាល់ នៅក្នុងដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) និងដីកាដំណោះស្រាយសំណុំរឿង ០០៤/០១[1387] និង (៤) ការសម្រេចនេះរំលោភបំពានទៅលើនិយាមសិទ្ធិមនុស្សអន្តរជាតិ និងការការពារដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា[1388]។

៦៦៥. នៅក្នុងចម្លើយតប សហមេធាវីបានអះអាងថា សហព្រះរាជអាជ្ញាអន្តរជាតិ មានកំហុសឆ្គងដោយមិនបាន "បង្ហាញ" ថា សហចៅក្រមស៊ើបអង្កេតជាតិ បកស្រាយក្របខណ្ឌច្បាប់ អ.វ.ត.ក ថាខុស គឺជា "ជនដែលទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់"[1389] ឬថា នេះគឺជាកត្តាកំណត់ សម្រាប់ការវាយតម្លៃរបស់គាត់ ទៅលើយុត្តាធិការបុគ្គល[1390]។

៦៦៦. នៅក្នុងការឆ្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកទឡ្ហីករណ៍ថា ការអះអាងរបស់ អោ អាន ដែលថា សហចៅក្រមស៊ើបអង្កេតជាតិ មិនបានកម្រិតជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" តែត្រឹម ឌុច នោះ "ផ្ទុយគ្នាទាំងស្រុងដោយពាក្យពេចន៍ចំៗ" នៅក្នុងដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់)[1391] ជាពិសេសថា សហចៅក្រមស៊ើបអង្កេតជាតិ បានសម្រេចថា "ការកាត់ទោសមេដឹកនាំកំពូលទាំងនេះ នឹងមិនរាលដាលដល់កម្មាភិបាល នៅថ្នាក់ក្រោមឡើយ ក្រៅពី ឌុច"[1392]។ សហព្រះ

[1385] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៤៩ និងជើងទំព័រ ១៤៣។

[1386] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៥០-៥១ និងជើងទំព័រ ១៤៤ កថាខណ្ឌ ៥៤-៥៥ និងជើងទំព័រ ១៤៨-១៤៩។

[1387] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៥២-៥៣។

[1388] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៥៦-៥៧។

[1389] ចម្លើយតបរបស់ អោ អាន (ឯកសារ D359/3/4) កថាខណ្ឌ ២០-២៤។ សំណុំរឿង ០០៤/២ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 01626116 ទំព័រ ៦២:០៧-៦២:១៩។

[1390] ចម្លើយតបរបស់ អោ អាន (ឯកសារ D359/3/4) កថាខណ្ឌ ២០។

[1391] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/5) កថាខណ្ឌ ២៥ និងជើងទំព័រ ៧៦-៧៧។

[1392] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/5) កថាខណ្ឌ ២៥ ដកស្រង់ ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារD359) កថាខណ្ឌ ៤៧៨។

01635135



រាជអាជ្ញាអន្តរជាតិអះអាងថា សហមេធាវី "មិនបានលើកឡើងពីកំហុសឆ្គងអង្គច្បាប់" ទាក់ទងការបកស្រាយពាក្យ ជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត ដោយសហព្រះរាជអាជ្ញាអន្តរជាតិ" ហើយជំហររបស់ពួកគេគឺផ្អែកលើ ការបកស្រាយដោយមិនត្រឹមត្រូវនូវ កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង[1393]។

ឃ. មូលដ្ឋាន ឃ៖ កំហុសអង្គហេតុទាក់ទងទៅនឹងការវាយតម្លៃលើភាពអាចជឿជាក់បាននៃភស្តុតាង

៦៦៧. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) ពាក់ព័ន្ធភស្តុតាងរបស់ ប្រាក់ យុត គឺមិនច្បាស់លាស់ដោយសារតែ "កិច្ចពិភាក្សាដែលគ្មានសំអាងហេតុ ក្នុងកថាខណ្ឌចំនួនពីរ" នាំដល់ការសន្និដ្ឋានថា ប្រាក់ យុត អាចមិនគួរឱ្យទុកចិត្តបាន[1394]។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតជាតិ "មិនសមស្រប និងជាការប្រឆាំងទាំងស្រុង ទៅនឹងភស្តុតាងគាំទ្រដ៏ច្រើនសន្ធឹកសន្ធាប់ និងការរកឃើញនៅក្នុងដីកាលើកលែងចោទប្រកាន់ខ្លួនឯងផង" ដែលថាភស្តុតាងរបស់ ប្រាក់ យុត គឺអាចជឿជាក់បាន និងមានការគាំទ្រ[1395]។ សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកទឡ្ហីករណ៍ថា ទោះបីជា "ការបំប៉ែកព័ត៌មានដោយខ្មែរក្រហម" និងពេលវេលាកន្លងផុតទៅ អាចប៉ះពាល់ដល់ការចងចាំក៏ពិតមែន ប៉ុន្តែជាការមិនសមហេតុផលទេ ដែលចាត់ទុកភស្តុតាង អំពីទង្វើឧក្រិដ្ឋទាំងអស់របស់ អោ អាន ថាមិនអាចឱ្យជឿទុកចិត្តបាន ដោយសារតែកត្តាទាំងនេះនោះ[1396]។ សហព្រះរាជអាជ្ញាអន្តរជាតិសង្កត់ធ្ងន់ថា ភស្តុតាងមាននូវសក្ខីកម្មរបស់ សាក្សីឯករាជ្យជាច្រើន ដែលឆ្លើយដាក់បន្ទុកទៅលើ អំពើនិងការប្រព្រឹត្តិរបស់ អោ អាន ក្នុងលក្ខណៈស្របគ្នាខ្លាំង[1397]។

៦៦៨. នៅក្នុងចម្លើយតប សហមេធាវីបានលើកឡើងថា សហព្រះរាជអាជ្ញាអន្តរជាតិ មិនបានបង្ហាញអំពីកំហុសអង្គហេតុ នៅក្នុងការវាយតម្លៃរបស់ សហចៅក្រមស៊ើបអង្កេតជាតិ ចំពោះភស្តុតាងរបស់ ប្រាក់ យុត គឺមិនបានបំពេញនូវបន្ទុកក្នុងការបង្ហាញភស្តុតាង[1398]។ សហមេធាវីអះអាងថា ផ្ទុយពីសំអាងហេតុ

---

[1393] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/5) កថាខណ្ឌ ២៦-២៧។

[1394] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៥៨។

[1395] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៥៨-៦១។

[1396] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៦២-៦៣។ សំណុំរឿង ០០៤/២ ប្រតិចារឹកថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/8.1 និង D360/17.1 ERN 01626034-01626035 ទំព័រ ៤៥:១៨-៤៥:២២។

[1397] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៦៤។

[1398] ចម្លើយតបរបស់ អោ អាន (ឯកសារ D359/3/4) កថាខណ្ឌ ២៥, ២៧។ សំណុំរឿង ០០៤/២ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា

របស់សហព្រះរាជអាជ្ញាអន្តរជាតិ កត្តាដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) មិនបានដកចេញនូវការវាយតម្លៃ ទៅលើភាពអាចជឿជាក់បាន និងភាពអាចទុកចិត្តបានចំពោះភស្តុតាងនៅក្នុងសំណុំរឿង ០០៤/២ ឡើយ[1399]។

៦៦៩. នៅក្នុងការឆ្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកទឡ្ហីករណ៍ថា សហចៅក្រមស៊ើបអង្កេតជាតិ បានវាយតម្លៃដោយមិនសមហេតុផល ទៅលើចម្លើយរបស់ ប្រាក់ យុត ដោយមិនបានពិចារណាទៅលើ ភស្តុតាងដែលគាំទ្រផ្សេងៗទៀត ដែលដាក់បន្ទុកទៅលើ អោ អាន[1400]។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ទោះបីជាការលាក់ការណ៍សម្ងាត់នៃរបប និងពេលវេលាគឺជាកត្តា ដែលអាចប៉ះពាល់ដល់ព័ត៌មានរបស់សាក្សីក្តី តែសហចៅក្រមស៊ើបអង្កេតជាតិ បានច្រានចោលភស្តុតាងបែបនេះ ដោយមិនបានត្រួតពិនិត្យទៅលើខ្លឹមសារ ឬការគាំទ្រ[1401]។ ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) មិនបានផ្តល់នូវការវាយតម្លៃទៅលើភស្តុតាង ទៅតាមករណីជាក់ស្តែង និងប្រកបដោយសំអាងហេតុនោះឡើយ[1402]។

ង. មូលដ្ឋាន ង៖ ការសន្និដ្ឋានលើអង្គហេតុដោយខុសឆ្គង ដោយមានផលប៉ះពាល់ ដែលជាកត្តាសម្រេច ទៅលើបញ្ហាយុត្តាធិការបុគ្គល

៦៧០. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតជាតិ បានធ្វើការសម្រេចលើអង្គហេតុដោយខុសឆ្គង ដែលបណ្តាលឱ្យមានផលប៉ះពាល់ ជាកត្តាសម្រេចទៅលើ យុត្តាធិការបុគ្គល[1403]។ ទីមួយ សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកទឡ្ហីករណ៍ថា ការសម្រេចរបស់ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) ដែលថា អោ អាន បានចូលរួមការប្រជុំភាគច្រើន ហើយមាន "តួនាទីជាអ្នកសម្របសម្រួល" គឺមិនសមហេតុផល ហើយមានការប្រឆាំងជំទាស់ដោយ "ភស្តុតាងដ៏

ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 01626116 ទំព័រ ៦២:២១-៦២:២២។

[1399] ចម្លើយតបរបស់ អោ អាន (ឯកសារ D359/3/4) កថាខណ្ឌ ២៦។ សំណុំរឿង ០០៤/២ ប្រតិចារិកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 01626116-01626117 ទំព័រ ៦២:២៣-៦៣:១២។

[1400] ការឆ្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/5) កថាខណ្ឌ ២៨-២៩។ សំណុំរឿង ០០៤/២ ប្រតិចារិកថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/8.1 និង D360/17.1 ERN 01626035 ទំព័រ ៤៦:១-៤៦:៤។

[1401] ការឆ្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/5) កថាខណ្ឌ ៣០។

[1402] ការឆ្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/5) កថាខណ្ឌ ៣០។

[1403] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៦៥-៦៦។

ច្រើនសន្ធឹកសន្ធាប់" ដែលថា អោ អាន ចេញបញ្ជាឱ្យមានការចាប់ខ្លួន និងការសម្លាប់ជាច្រើន ដែលរួមមានទាំង "ចាមនៅទូទាំងតំបន់ ៤១"[1404]។ ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) "មិនបានលើកឡើង" អំពី "ភស្តុតាងដ៏ច្រើនសន្ធឹកសន្ធាប់"[1405]។

៦៧១. ទីពីរសហព្រះរាជអាជ្ញាអន្តរជាតិ បានលើកទឡ្ហីករណ៍ថា ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) បានសម្រេចដោយខុសឆ្គងថា អោ អាន ត្រូវបាន "បញ្ជូនទៅកាន់ភូមិភាគកណ្តាល នៅពាក់កណ្តាលឆ្នាំ១៩៧៧" នៅពេលដែលការបោសសម្អាត ជិតដល់ពេលបញ្ចប់ហើយ[1406]។ សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកទឡ្ហីករណ៍ថា ការកំណត់ពេលវេលា នៃការមកដល់ភូមិភាគកណ្តាលរបស់ អោ អាន ដែលជាការប៉ាន់ស្មាន ហើយពឹងផ្អែកទៅលើប្រវត្តិរូបរបស់ កែ ពក គឺជាការមិនសមហេតុផល[1407]។ បន្ថែមលើនេះ ភស្តុតាងបានបង្ហាញថា អោ អាន មកដល់ភូមិភាគកណ្តាលនៅក្នុង "ឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧" ដូចដែលបានគាំទ្រដោយចម្លើយ របស់អតីតកម្មាភិបាល ឬអ្នកដែលធ្វើការជាមួយគាត់ នៅពេលដែលគាត់មកដល់[1408]។ ទីបីសហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ភស្តុតាងយ៉ាងច្រើនលើសលប់ ដោយរួមមានទាំងភស្តុតាងពីសាក្សីសំខាន់ៗ បានបង្ហាញពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ត្រូវបានប្រព្រឹត្តឡើងដោយមានការចូលរួមពី អោ អាន ក្នុងនាមជាលេខាតំបន់ ៤១[1409]។ ទីបួនដោយផ្ទុយពីការបរិយាយរបស់ ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) កែ ពក និង អោ អាន បានធ្វើការសម្រេចរួមគ្នា និងដោយសហការណ៍គ្នា[1410]។

៦៧២. នៅក្នុងចម្លើយតប សហមេធាវីបានអះអាងថា សហព្រះរាជអាជ្ញាអន្តរជាតិ បានអនុវត្តដោយខុស

[1404] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៦៧-៧២។

[1405] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៦៨-៧២។

[1406] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៧៣។

[1407] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៧៣-៧៦, ៧៨។

[1408] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៧៧។ សំណុំរឿង ០០៤/២ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 01626106-01626107 ទំព័រ ៥២:២៤-៥៣:៤។

[1409] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៧៩-៨៦។ សំណុំរឿង ០០៤/២ ប្រតិចារឹកថ្ងៃទី២០ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 01626106-01626107 ទំព័រ ៥២:១៩-៥៣:៩។

[1410] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៨៧-៩៤។ សំណុំរឿង ០០៤/២ ប្រតិចារឹកថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/8.1 និង D360/17.1 ERN 01626031-01626032 (EN) 01625125 016260 ទំព័រ ៤២:១៤-៤៣:២។

ឆ្គងនូវបទដ្ឋានសម្រាប់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ មកប្រើលើដីកាសម្រេចលើកលែងចោទប្រកាន់ ហើយថាសហព្រះរាជអាជ្ញាអន្តរជាតិ មិនបានបង្ហាញអំពីកំហុសឆ្គងណាមួយ ដែលធ្វើឱ្យមោឃភាពដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់)[1411]។ សហមេធាវីជំទាស់ចំពោះ ទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលផ្អែកលើការបកស្រាយខុសឆ្គង ការមិនមានគ្រប់គ្រាន់ និងកង្វះភស្តុតាងគាំទ្រ និងគួរឱ្យជឿជាក់បាន ទាក់ទង (១) អោ អាន ចេញបញ្ជាចាប់ខ្លួន និងសម្លាប់[1412] (២) ការចូលរួមរបស់ អោ អាន នៅក្នុងឧក្រិដ្ឋកម្ម ក្នុងនាមជាលេខាតំបន់ ៤១[1413] និង (៣) ការធ្វើការសម្រេចរួមគ្នារបស់ កែ ពក និង អោ អាន[1414]។ បន្ថែមលើនេះសហមេធាវី រក្សាជំហរថា សហចៅក្រមស៊ើបអង្កេតជាតិ មិនមានកំហុសឆ្គងឡើយ ដែលពឹងផ្អែកទៅលើប្រវត្តិរូបរបស់ កែ ពក ធ្វើជាភស្តុតាងដោះបន្ទុក ហើយដែលមានការគាំទ្រដោយ សាក្សីដែលអាចជឿជាក់បាន[1415]។

៦៧៣. នៅក្នុងការឆ្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកទឡ្ហីករណ៍ឡើងថា សហមេធាវីបានកាត់បន្ថយភស្តុតាង និងធ្វើការពិចារណាទៅលើភស្តុតាង “តាមរបៀបម្តងមួយៗ” ដោយមិនគិតអំពីព័ត៌មានរបស់សាក្សីគាំទ្រ ដែលកំណត់អំពីតួនាទីរបស់ អោ អាន ក្នុងការចាប់ខ្លួន និងសម្លាប់[1416]។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ផ្ទុយពីទឡ្ហីករណ៍របស់សហមេធាវី បញ្ហាគឺមិនមែនការកំណត់ពេលវេលាទេ ប៉ុន្តែគឺស្ថានទម្ងន់នៃបទឧក្រិដ្ឋ ដែលពាក់ព័ន្ធសម្រាប់ការសម្រេច ទៅលើការទទួលខុសត្រូវរបស់ អោ អាន ដែលការនេះគឺគាំទ្រដោយភស្តុតាងដែលគួរឱ្យជឿជាក់បានរបស់ ប្រាក់ យុត[1417]។ សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងថា សហមេធាវីមិនបានគិតអំពីភស្តុតាងបញ្ជាក់បន្ថែមដែលពាក់ព័ន្ធ អំពី តួនាទីរបស់ អោ អាន នៅក្នុងការសម្រេចថ្នាក់ភូមិភាគ ដែលគាំទ្រដល់ការសន្និដ្ឋានថា គាត់ស្ថិតក្នុងចំណោម

---

[1411] ចម្លើយតបរបស់ អោ អាន (ឯកសារ D359/3/4) កថាខណ្ឌ ២៨-៣០។ សំណុំរឿង ០០៤/២ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 01626116-01626117 ទំព័រ ៦២:២៣-៦៣:១២។

[1412] ចម្លើយតបរបស់ អោ អាន (ឯកសារ D359/3/4) កថាខណ្ឌ ៣១-៣២។ សំណុំរឿង ០០៤/២ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 01626117-01626118 ទំព័រ ៦៣:២២-៦៤:៥។

[1413] ចម្លើយតបរបស់ អោ អាន (ឯកសារ D359/3/4) កថាខណ្ឌ ៣៨-៤៤។

[1414] ចម្លើយតបរបស់ អោ អាន (ឯកសារ D359/3/4) កថាខណ្ឌ ៤៥-៤៧។ សំណុំរឿង ០០៤/២ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 01626119 ទំព័រ ៦៥:៣-៦៥:៦។

[1415] ចម្លើយតបរបស់ អោ អាន (ឯកសារ D359/3/4) កថាខណ្ឌ ៣៣-៣៧។

[1416] ការឆ្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/5) កថាខណ្ឌ ៣១-៣៥។

[1417] ការឆ្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/5) កថាខណ្ឌ ៣៦-៣៩។

ជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត"[1418]។

ច. មូលដ្ឋាន ចៈ កំហុសអង្គច្បាប់ដែលមិនបានពិចារណា អំពីផលប៉ះពាល់នៃតួនាទីជាអ្នកដឹកនាំរបស់ អោ អាន នៅក្នុងអំពើប្រល័យពូជសាសន៍

៦៧៤. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) មិនបាន "យកចិត្តទុកដាក់ចំពោះផលប៉ះពាល់" នៃតួនាទីរបស់ អោ អាន នៅក្នុងអំពើប្រល័យពូជសាសន៍[1419] រួមទាំងការមិនបានពិចារណាទៅលើតួនាទីសំខាន់ជារួមរបស់ អោ អាន នៅក្នុងអំពើប្រល័យពូជសាសន៍ទៅលើជនជាតិចាម ដើម្បីសម្រេចអំពីយុត្តាធិការបុគ្គល[1420]។ ជាពិសេស តួនាទីរបស់ អោ អាន នៅក្នុងអំពើប្រល័យពូជសាសន៍ "ត្រូវបានកំណត់នឹងចំៗ" ហើយអំពើប្រល័យពូជសាសន៍គឺ "គឺជាឧក្រិដ្ឋកម្មមួយធ្ងន់ធ្ងរបំផុត ដោយសារវាជាការវាយប្រហារមួយ ទៅលើគ្រួសារទាំងមូល ក៏ដូចជាពួកជនរងគ្រោះផ្ទាល់ខ្លួនដែរ"[1421]។

៦៧៥. នៅក្នុងចម្លើយតប សហមេធាវីបានលើកទឡ្ហីករណ៍ថា សហព្រះរាជអាជ្ញាអន្តរជាតិ មិនបានបង្ហាញភស្តុតាងគាំទ្រការអះអាងរបស់គាត់ដែលថា សហចៅក្រមស៊ើបអង្កេតជាតិ មានកំហុសឆ្គងឡើយ[1422]។ សហមេធាវីបានចោទប្រកាន់ថា សហព្រះរាជអាជ្ញាអន្តរជាតិមានកំហុសឆ្គង ដែលអះអាងថា តួនាទីរបស់ អោ អាន នៅក្នុងអំពើប្រល័យពូជសាសន៍គឺ "ត្រូវបានកំណត់នឹងចំៗ" រួមទាំងការបំភ្លើសទៅលើភស្តុតាង[1423]។ សហមេធាវីអះអាងថា ផ្ទុយពីការលើកឡើងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សហចៅក្រមស៊ើបអង្កេតជាតិ បានពិចារណាអំពីតួនាទរបស់ អោ អាន នៅក្នុងអំពើប្រល័យពូជសាសន៍ ក្នុងចំណោម "កត្តាជាច្រើន" ដើម្បីសម្រេចអំពីយុត្តាធិការបុគ្គល[1424]។ សហមេធាវីបានច្រានចោល ទឡ្ហីករណ៍របស់

[1418] ការឆ្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/5) កថាខណ្ឌ ៤០-៤២។

[1419] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៩៥-៩៩។

[1420] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៩៩។

[1421] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ៩៥-៩៨។

[1422] ចម្លើយតបរបស់ អោ អាន (ឯកសារ D359/3/4) កថាខណ្ឌ ៤៩។

[1423] ចម្លើយតបរបស់ អោ អាន (ឯកសារ D359/3/4) កថាខណ្ឌ ៤៩-៥៤។ សំណុំរឿង ០០៤/២ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 01626119 ទំព័រ ៦៥:១៣-៦៥:២០។

[1424] ចម្លើយតបរបស់ អោ អាន (ឯកសារ D359/3/4) កថាខណ្ឌ ៥៥-៥៦។ សំណុំរឿង ០០៤/២ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 01626119-01626120 ទំព័រ ៦៥:២២-៦៦:១៤។

សហព្រះរាជអាជ្ញាអន្តរជាតិដែលថា អ.វ.ត.ក មានកាតព្វកិច្ចតាមអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ដើម្បីចោទប្រកាន់ អោ អាន បញ្ជូនទៅជំនុំជម្រះ ដោយសារតែការលើកឡើងថា "កាតព្វកិច្ចនេះមានវិសាលភាព និងអានុភាពលើសពីការកំណត់យុត្តាធិការ" របស់ អ.វ.ត.ក[1425]។

៦៧៦. នៅក្នុងការឆ្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងថា សហចៅក្រមស៊ើបអង្កេតជាតិមានកំហុសឆ្គងដោយមិនបានវាយតម្លៃយុត្តាធិការបុគ្គលទៅលើ អោ អាន និងមិនបានផ្តល់សំអាងហេតុសម្រាប់ការសម្រេចរបស់ខ្លួន[1426]។ សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកទឡ្ហីករណ៍ថា កំហុសឆ្គងបែបនេះបណ្តាលឱ្យមានការខកខានមិនបានវាយតម្លៃអត្ថិភាព និងស្ថានទម្ងន់នៃអំពើប្រល័យពូជសាសន៍ និងការទទួលខុសត្រូវរបស់ អោ អាន ដែលជះឥទ្ធិពលទៅដល់ការសម្រេចលើយុត្តាធិការបុគ្គល[1427]។ សហព្រះរាជអាជ្ញាអន្តរជាតិរក្សាជំហរថា ផ្ទុយពីការអះអាងរបស់សហមេធាវី រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ មានចេតនាចោទប្រកាន់ ជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះអំពើប្រល័យពូជសាសន៍ រួមទាំង អោ អាន ផងដែរ[1428]។

## ឆ. សារណាពាក់ព័ន្ធនឹងដីកាដំណោះស្រាយដែលផ្ទុយគ្នា

៦៧៧. ចំពោះអត្ថិភាពនៃដីកាដំណោះស្រាយដែលផ្ទុយគ្នា សហព្រះរាជអាជ្ញាអន្តរជាតិ "យល់ឃើញច្បាស់ថា" ការសម្រេចនៅក្នុងដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) អំពីយុត្តាធិការបុគ្គល "ត្រូវកែប្រែ" ហើយបញ្ជូនសំណុំរឿងប្រឆាំង អោ អាន "ទៅជំនុំជម្រះ ដោយផ្អែកលើដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ"[1429]។ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ក្នុងករណីដែលអង្គបុរេជំនុំជម្រះមិនអាចស្វែងរកសម្លេងគាំទ្រភាគច្រើនលើសលប់លើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយពីរបានទេនោះ វិធានផ្ទៃក្នុងដែលគាំទ្រដោយយុត្តិសាស្ត្ររបស់ អ.វ.ត.ក និងគោលនយោបាយរបស់ ក្របខណ្ឌគតិយុត្តិរបស់តុលាការ "កំណត់ថាសំណុំរឿងបន្តទៅជំនុំជម្រះ" ដោយផ្អែកលើមូលដ្ឋាននៃ ដីកាដំណោះស្រាយ

[1425] ចម្លើយតបរបស់ អោ អាន (ឯកសារ D359/3/4) កថាខណ្ឌ ៥៧-៦១។ សំណុំរឿង ០០៤/២ ប្រតិចារិកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 01626120-01626121 ទំព័រ ៦៦:១៥-៦៧:៩។

[1426] ការឆ្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/5) កថាខណ្ឌ ៤៣។

[1427] ការឆ្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/5) កថាខណ្ឌ ៤៤, ៤៦។

[1428] ការឆ្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/5) កថាខណ្ឌ ៤៥។

[1429] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ១០០។

(ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)[1430]។ ដោយសារតែពាក្យពេចន៍នៃ ក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក (រួមទាំង "ការស៊ើបសួរឬការចោទប្រកាន់ ត្រូវដំណើរការទៅមុខ") បើទោះបីជាមិនមានសម្លេងភាគច្រើនលើសលប់ នៅក្នុងអង្គបុរេជំនុំជម្រះក្តី តែសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា "អង្គជំនុំជម្រះសាលាដំបូងត្រូវទទួលសំណុំរឿង និងបន្តទៅជំនុំជម្រះ"[1431]។

៦៧៨. នៅក្នុងការឆ្លើយតប សហមេធាវី "ជំទាស់ដាច់ខាត់" ចំពោះការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា ប្រសិនបើដីកាដំណោះស្រាយទាំងពីរ មិនអាចសម្រេច ដោយសារមិនអាចរកសម្លេងភាគច្រើនលើសលប់បាននោះ ច្បាប់និងនីតិវិធី អ.វ.ត.ក កំណត់ថា សំណុំរឿងបន្តទៅជំនុំជម្រះដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ[1432]។ សហមេធាវីអះអាងថា វិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង "មានបំណងកំណត់ស្ថានភាព ដែលដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះតែមួយចេញដោយ" សហចៅក្រមស៊ើបអង្កេតទាំងពីរ ហើយពុំបានចែងបញ្ជាក់បំភ្លឺអំពីស្ថានភាពនេះទេ[1433]។ បន្ថែមលើនេះ គោលជំហររបស់សហព្រះរាជអាជ្ញាអន្តរជាតិ គឺផ្ទុយជាមួយច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងយុត្តិសាស្ត្ររបស់ អ.វ.ត.ក គោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាបចោទ* និងសច្ចធារណ៍និរទោស[1434] ហើយដែលអង្គបុរេជំនុំជម្រះត្រូវច្រានចោលបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ហើយតម្កល់ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់)[1435]។

៦៧៩. នៅក្នុងការឆ្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិ រក្សាជំហាថា ដោយផ្ទុយពីការអះអាងរបស់សហមេធាវី ប្រសិនបើអង្គបុរេជំនុំជម្រះ មិនអាចធ្វើការសម្រេចដោយសម្លេងភាគច្រើនលើសលប់ ទៅលើដីកាដំណោះស្រាយដែលផ្ទុយគ្នាទេនោះ សំណុំរឿងចាំបាច់ត្រូវតែបន្តទៅជំនុំជម្រះ ដែលជាការអនុលោមទៅតាមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក គឺ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ* និងសិទ្ធិជា

---

[1430] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ១០០-១០៨។ សំណុំរឿង ០០៤/២ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 01626116-01626117 ទំព័រ ៦២:២៣-៦៣:១២។

[1431] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/1) កថាខណ្ឌ ១០៨។

[1432] ចម្លើយតបរបស់ អោ អាន (ឯកសារ D359/3/4) កថាខណ្ឌ ៦៣។

[1433] ចម្លើយតបរបស់ អោ អាន (ឯកសារ D359/3/4) កថាខណ្ឌ ៦៤។

[1434] ចម្លើយតបរបស់ អោ អាន (ឯកសារ D359/3/4) កថាខណ្ឌ ៦៣-៦៧។ សំណុំរឿង ០០៤/២ ប្រតិចារឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 និង D360/18.1 ERN 01626121 ទំព័រ ៦៧:១០-៦៧:២០។

[1435] ចម្លើយតបរបស់ អោ អាន (ឯកសារ D359/3/4) កថាខណ្ឌ ៦៨ដល់ ៦៩។

01635142



សាររវន្តរបស់ អោ អាន[1436]។

## ២. ការពិភាក្សា

៦៨០. សហព្រះរាជអាជ្ញាអាចប្ដឹងឧទ្ធរណ៍ចំពោះដីកាទាំងអស់ដែលចេញដោយសហចៅក្រមស៊ើបអង្កេត[1437]។ ចៅក្រមអន្តរជាតិសូមរំឭកថា សហចៅក្រមស៊ើបអង្កេត បានរំលោភបំពានទៅលើក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ដោយចេញដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា[1438]។ នៅក្នុងបទប្បញ្ញត្តិរបស់ អ.វ.ត.ក មានតែជម្រើសពីរប៉ុណ្ណោះ ដែលអាចជ្រើសរើសបានដោយត្រឹមត្រូវតាមច្បាប់ សម្រាប់សហចៅក្រមស៊ើបអង្កេត ពាក់ព័ន្ធការខ្វែងយោបល់របស់ពួកគាត់៖ (១) ឈានទៅដល់ការឯកភាពគ្នា លើដីកាដំណោះស្រាយតែមួយ ឬ (២) បញ្ជូនការខ្វែងយោបល់គ្នាទៅអង្គបុរេជំនុំជម្រះ[1439]។ សហចៅក្រមស៊ើបអង្កេតមិនបានអនុវត្តដោយត្រឹមត្រូវតាមច្បាប់ នូវនីតិវិធីដែលចាំបាច់ សម្រាប់ដោះស្រាយការខ្វែងយោបល់របស់ខ្លួនឡើយ ហើយបែរជាឯកភាពគ្នា ចេញដីកាដំណោះស្រាយដែលផ្ទុយគ្នា ដោយរំលោភបំពានទៅលើច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ទៅវិញ[1440]។

៦៨១. ចៅក្រមអន្តរជាតិសូមបញ្ជាក់ឡើងវិញថា ទោះបីជាមានការឯកភាពគ្នាដោយខុសឆ្គង របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការចេញដីកាដំណោះស្រាយពីរក្ដី តែដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) អនុលោមតាមច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក[1441]។ ផ្ទុយទៅវិញ ការចេញដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) ត្រូវបានរកឃើញថា ជាចេតនាមួយក្នុងការគេចវេ

[1436] ការឆ្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D359/3/5) កថាខណ្ឌ ៤៧-៥១។

[1437] វិធាន ៧៤(២) នៃវិធានផ្ទៃក្នុង។

[1438] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360)។ ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D359)។

[1439] *សូមមើល* ខាងលើ កថាខណ្ឌ ១០៣ ដល់ ១២៤។

[1440] *សូមមើល* ខាងលើ កថាខណ្ឌ ៨៨ ដល់ ១២៤។

[1441] *សូមមើល* កថាខណ្ឌ ៣០២ ដល់ ៣២៧ មតិយោបល់ចៅក្រមអន្តរជាតិ មូលដ្ឋាន១ ។ មាត្រា ៥(៤) នៃកិច្ចព្រមព្រៀងស្ដីពីការបង្កើត អ.វ.ត.ក ("សហចៅក្រមស៊ើបអង្កេតត្រូវសហការគ្នា ដើម្បីឈានទៅដល់ការឯកភាពគ្នាមួយ ក្នុងការស៊ើបអង្កេត។ នៅក្នុងករណីដែលចៅក្រមស៊ើបអង្កេតមិនអាចឯកភាពគ្នាថា ត្រូវបន្តការស៊ើបអង្កេតណាមួយ ការស៊ើបអង្កេតនោះ ត្រូវដំណើរការទៅមុខទៀត លើកលែងតែចៅក្រមទាំងនេះ ឬចៅក្រមណាម្នាក់ក្នុងចំណោមចៅក្រមទាំងនេះ ធ្វើការស្នើសុំនៅក្នុងរយៈពេលសាមសិបថ្ងៃ ឱ្យដោះស្រាយការខ្វែងគំនិតគ្នានេះតាមមាត្រា ៧") (ដោយគូសបញ្ជាក់បន្ថែម)។ សូមមើលផងដែរ ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក មាត្រា ២៣ថ្មី កថាខណ្ឌ ៣។

សពីលក្ខខណ្ឌតម្រូវដែលសំខាន់ និងចាំបាច់ក្នុងការបញ្ជូនករណីខ្វែងយោបល់គ្នានៅក្នុងសំណុំរឿងនេះ ទៅអង្គបុរេជំនុំជម្រះ ដែលធ្វើឱ្យការចេញដីកាមួយនេះ *ហួសដែនសមត្ថកិច្ច* និងមោឃភាព[1442]។

៦៨២. ចៅក្រមអន្តរជាតិប្រកាសថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ លែងជាការចាំបាច់ហើយ ដោយសារតែដីកាសម្រេចដែលត្រូវបានប្តឹងឧទ្ធរណ៍ ពោលគឺដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) គឺ *ហួសដែនសមត្ថកិច្ច* និងមោឃភាព[1443]។ ផលវិបាកនៃការសម្រេចនេះ ពាក់ព័ន្ធជាមួយវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង ដែលថា អង្គជំនុំជម្រះសាលាដំបូង ត្រូវទទួលយកដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) និងត្រូវយកមកពិភាក្សានៅក្នុងផ្នែកសេចក្តីសន្និដ្ឋាននៃសាលដីកានេះ[1444]។

## សេចក្តីសន្និដ្ឋាន

## ការសម្រេចលើបណ្តឹងឧទ្ធរណ៍

៦៨៣. សម្រាប់សំអាងហេតុដូចបានរៀបរាប់ខាងលើ ចៅក្រមអន្តរជាតិច្រានចោលទាំងស្រុងចំពោះបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ។ ចៅក្រមអន្តរជាតិសម្រេចថា ដីកាដំណោះស្រាយ (ដីកា

---

[1442] *សូមមើល* ខាងលើ កថាខណ្ឌ ៣១៥ ដល់ ៣២៨ និង ខាងក្រោម កថាខណ្ឌ ៦៨៣។

[1443] *សូមមើល* ខាងលើ មូលដ្ឋានទី១ ។ សូមមើល ជាឧទាហរណ៍ តុលាការព្រហ្មទណ្ឌអន្តរជាតិ *ស្ថានភាពនៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល ក្នុងរឿងក្តី រដ្ឋអាជ្ញា តទល់នឹង Jean-Pierre Bemba Gombo* អង្គជំនុំជម្រះតុលាការកំពូល ICC-01/05-01/08 A2 A3 សាលដីកាលើបណ្តឹងសាទុក្ខ របស់រដ្ឋអាជ្ញានិងលោក Jean-Pierre Bemba Gombo ប្រឆាំងសេចក្តីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង III ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ ដែលមានចំណងជើងថា "ដីកាសម្រេចលើការផ្តន្ទាទោស អនុលោមតាមមាត្រា ៧៦ នៃលក្ខន្តិកៈ" ថ្ងៃទី ៨ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ៨ (សម្រេចថា ដោយសារតែអង្គជំនុំជម្រះតុលាការកំពូល បានច្រានចោលដីកាសម្រេចផ្តន្ទាទោស និងលើកលែងចោទប្រកាន់ចំពោះជនជាប់ចោទ បណ្តឹងសាទុក្ខដែលបានប្តឹងប្រឆាំង ដីកាសម្រេចផ្តន្ទាទោសលែងមានភាពចាំបាច់ ហើយត្រូវច្រានចោល)។ សំណុំរឿង ០០២ (អង្គបុរេជំនុំជម្រះ ៧០) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ លោក អៀង សារី ប្រឆាំងទៅនឹងការបដិសេធតាមការសន្មតរបស់ ស.ច.ស លើសំណើទាំងពីររបស់គាត់ ឱ្យអង្គបុរេជំនុំជម្រះ ទទួលយកសំណើសុំធ្វើមោឃភាព ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D381/1/2 កថាខណ្ឌ ២ ("អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបាន ដោយសារកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍នេះ មិនមានសុពលភាព ដោយសារតែដីកាសហចៅក្រមស៊ើបអង្កេត") ។ សូមមើលផងដែរ សាលដីកាសំណុំរឿង ០០២/០១ (ឯកសារF36) កថាខណ្ឌ ៩៩៩, ១០៤០, ១០៧០។ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង Halilović*, IT-01-48-Aសាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៧កថាខណ្ឌ 40។

[1444] *សូមមើល* ខាងក្រោម កថាខណ្ឌ ៦៨៥ ដល់ ៦៨៧។

សម្រេចលើកលែងចោទប្រកាន់) របស់សហចៅក្រមស៊ើបអង្កេតជាតិ ហួសដែនសមត្ថកិច្ច និងគ្មានសុពលភាព ដោយមិនមានអានុភាពគតិយុត្តិ ដូច្នេះហើយ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិលែងជាការចាំបាច់ទៀតហើយ។

៦៨៤. លើសពីនេះទៀត ចៅក្រមអន្តរជាតិសម្រេចច្រានចោលមូលដ្ឋាន ១ ដល់មូលដ្ឋាន ៩ មូលដ្ឋាន ១១, ១២(១), ១៣, ១៥(១), ១៦(២) និង ១៦(៣) នៃបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អោ អាន ហើយសម្រេចថា បទល្មើស ១ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវកែសម្រួល ដើម្បីសម្រេចថា អោ អាន ត្រូវបានចោទប្រកាន់ និងបញ្ជូនទៅជំនុំជម្រះពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ប្រឆាំងជនជាតិចាមនៅខេត្តកំពង់ចាមក្នុងភូមិភាគកណ្តាល។

## **វិធាន ៧៧(១៣)(ខ)**

៦៨៥. អនុលោមតាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង ក្នុងករណីដែលមិនអាចមានសម្លេងភាគច្រើនលើសលប់បាន សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្ររបស់អង្គជំនុំជម្រះ ពាក់ព័ន្ធជាមួយនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ គឺថា "អង្គជំនុំជម្រះសាលាដំបូងទទួលបណ្តឹង ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត"[1445]។ ដូចដែលចៅក្រមអន្តរជាតិបានសម្រេចថា ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) របស់សហចៅក្រមស៊ើបអង្កេតជាតិ ហួសដែនសមត្ថកិច្ច គ្មានសុពលភាព និងមិនមានអានុភាពគតិយុត្តិ ហើយដោយសារតែមិនទទួលបានសម្លេងភាគច្រើនលើសលប់តាមការកំណត់ សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្រ គឺថា ត្រូវបញ្ជូនដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅអង្គជំនុំជម្រះសាលាដំបូង ដើម្បីឱ្យអង្គជំនុំជម្រះទទួលយកដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

៦៨៦. ចៅក្រមអន្តរជាតិសូមបញ្ជាក់ឡើងវិញថា គោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ* ជាសំខាន់គឺជាវិធាននៃការបង្ហាញភស្តុតាង មិនមែនជាវិធាននៃការបកស្រាយគតិយុត្តិឡើយ[1446]

---

[1445] សូមមើលផងដែរ វិធាន ៧៩(១) នៃវិធានផ្ទៃក្នុង ("អង្គជំនុំជម្រះសាលាដំបូងទទួលបណ្តឹង ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ឬ តាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ")។

[1446] សូមមើលមូលដ្ឋាន១ ខាងលើ។ សំណុំរឿង ០០៣ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ (ឯកសារ D87/2/1.7/1/1/7) កថាខណ្ឌ ៦៥។

។ ទីពីរ បើទោះបីជា គោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ* អនុវត្តនៅក្នុងការបកស្រាយច្បាប់ក្ដី ក៏មិនមានវិមតិសង្ស័យដើម្បីដោះស្រាយនៅទីនេះឡើយ ព្រោះដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) របស់សហចៅក្រមស៊ើបអង្កេតជាតិ ហួសដែនសមត្ថកិច្ច គ្មានសុពលភាព និងមិនមានអានុភាពគតិយុត្ត[1447]។ លើសពីនេះទៀត វិធាន ៧៧(១៣)(ក) ពាក់ព័ន្ធនឹងករណីដែលបណ្ដឹងឧទ្ធរណ៍ប្រឆាំង "ដីកាផ្សេងក្រៅពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ត្រូវមានអនុភាពនោះ បទប្បញ្ញត្តិនេះមិនអាចអនុវត្តបានឡើយ ដោយសារតែមិនមានដីកាសម្រេចលើកលែងចោទប្រកាន់ដែលមានសុពលភាពឡើយ។ មានតែដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ដែលមានអានុភាព ហើយអង្គជំនុំជម្រះសាលាដំបូង បានទទួលផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាព អនុលោមតាមវិធាន ៧៧(១៣)(ខ) ដែលត្រូវអនុវត្តយ៉ាងច្បាស់លាស់ចំពោះបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ មិនមានចន្លោះប្រហោងណាដែលអនុញ្ញាតឱ្យមានដំណោះស្រាយជាប្រយោជន៍ដល់ អោ អាន ទេ[1448]។ ជាលទ្ធផល គោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ* មិនមានការអនុវត្តឡើយក្នុងករណីនេះ។

៦៨៧. ដោយផ្អែកទៅលើពាក្យពេចន៍ច្បាស់លាស់នៃវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង ការដែលអង្គបុរេជំនុំជម្រះមិនអាចឈានទៅដល់សេចក្ដីសម្រេច ដោយសម្លេងភាគច្រើនលើសលប់ ដោយចៅក្រមយ៉ាងតិចបួនរូបនោះ មិនបានរារាំងដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ រួមជាមួយសំណុំរឿង មិនឱ្យបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង ដើម្បីឱ្យអង្គជំនុំជម្រះសាលាដំបូងអាចចាប់ផ្ដើមកិច្ចដំណើការនីតិវិធីជំនុំជម្រះប្រឆាំងនឹង អោ អាន។ ស្របជាមួយបទប្បញ្ញត្តិនេះ ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះនឹងបញ្ជូនដីកាសម្រេចនេះ រួមជាមួយដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងសំណុំរឿងដែលនៅសេសសល់ ទៅអង្គជំនុំជម្រះសាលាដំបូង។

## វិធានការសន្តិសុខ

៦៨៨. នៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ថា មិនមានភាពចាំបាច់សម្រាប់ការឃុំខ្លួនបណ្ដោះអាសន្នឡើយ តាមអត្ថន័យនៃវិធាន ៦៣(៣)(ខ) នៃវិធាន

---

1447 សូមមើលមូលដ្ឋាន១ ខាងលើ។

1448 ផ្ទុយពី សេចក្ដីពិចារណារបស់ចៅក្រមជាតិ កថាខណ្ឌ ១៩៩-២០១, ២០៤-២០៦។

01635146



ផ្ទៃក្នុង[1449]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ថា សំអាងហេតុមួយទៀតគឺ "ភាពមិនប្រាកដប្រជានៃនីតិវិធី ដែលបណ្តាលមកពីមានដីកាដំណោះស្រាយពីរផ្ទុយគ្នា"[1450]។ សហចៅក្រមស៊ើបអង្កេតមិនបានប្រមើលមើលអំពីវិធានការសន្តិសុខណាមួយដែលអាចមានឡើយ។

៦៨៩. អោ អាន ត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត គឺ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើមនុស្សឃាត។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកត់សម្គាល់ថា អំពើដែលត្រូវបានឆ្លើយដាក់ ទាក់ទងដោយផ្ទាល់ ឬដោយប្រយោល ជាមួយនឹងការសម្លាប់មនុស្សរាប់ម៉ឺននាក់[1451]។ គាត់ត្រូវប្រឈមមុខនឹងការផ្តន្ទាទោសដាក់ពន្ធនាគារយូរចំពោះបទចោទទាំងអស់នេះ។

៦៩០. ដោយផ្អែកលើចំណុចទាំងអស់នេះ ចៅក្រមអន្តរជាតិយល់ថា សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទទួលរងការប៉ះពាល់ដោយសារកំហុសធ្ងន់ធ្ងរចំនួនពីរ។

៦៩១. នៅក្នុងការពិចារណាថាមិនមានភាពចាំបាច់ឲ្យមានវិធានការសន្តិសុខ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានប្រព្រឹត្តកំហុសទីមួយ។ តាមពិតទៅ ជាការប្រសើរដែលគួរជៀសវាងពីការដាក់សម្ពាធណាមួយទៅលើសាក្សី ជាពិសេស អ្នកដែលទទួលផលប្រយោជន៍ពីលិខិតធានារបស់សហចៅក្រមស៊ើបអង្កេត។ ការនាំយក អោ អាន មកជំនុំជម្រះ ក៏ជាការចាំបាច់ផងដែរ។ ជាចុងក្រោយដោយផ្អែកលើទស្សនៈនៃការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ទាំងកម្រិតជាតិ និងអន្តរជាតិ ដែលបណ្តាលមកពីអំពើដែលបង្កគ្រោះថ្នាក់ខ្លាំងដល់មនុស្សជាតិ ហើយអំពីនោះមិនអាចមានអាជ្ញាយុកាលនោះ ទើបវិធានការឃុំខ្លួនបណ្តោះអាសន្ន ឬវិធានការសន្តិសុខផ្សេងទៀត ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិអាចប្រើប្រាស់ គឺជាការសំខាន់។

៦៩២. អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទថា សហចៅក្រមស៊ើបអង្កេតបានរំលោភបំពានទៅលើច្បាប់ជាធរមាន ដោយចេញដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា[1452]។ ការអះអាងថា ដោយផ្អែកលើភាពមិនប្រាកដប្រជានៃនីតិវិធី ដែលបណ្តាលមកពីការរំលោភបំពាន ដោយចេតនារួមគ្នារបស់សហចៅក្រមស៊ើបអង្កេតទៅលើច្បាប់ជាធរមាន មានន័យជាការប្រព្រឹត្តិកំហុសផ្នែកអង្គច្បាប់បន្ថែមទៀត ជាពិសេសនៅពេលដែល

[1449] ដីកាដំណោះស្រាយ (ឯកសារ D360) កថាខណ្ឌ ៨៥៣។

[1450] ដីកាដំណោះស្រាយ (ឯកសារ D360) កថាខណ្ឌ ៨៥៤។

[1451] ដីកាដំណោះស្រាយ (ឯកសារ D360) កថាខណ្ឌ ៧០៩, ៧១១។

[1452] សូមមើលខាងលើ កថាខណ្ឌ ១០១ ដល់ ១២៤។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានពិចារណាអំពីវិធានការសន្តិសុខដទៃទៀត ដែលគាត់អាចប្រើប្រាស់បាន។ កង្វះខាតនេះរឹតតែបង្ហាញកាន់តែច្បាស់អំពីចេតនារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការគេចវេសពីវិធានការនានា ដែលអាចផ្តល់អត្ថន័យ និងប្រសិទ្ធភាពកាន់តែខ្លាំង សម្រាប់ដីកាសម្រេចរបស់គាត់។

៦៩៣. អនុលោមតាមវិធាន ៤៤ នៃវិធានផ្ទៃក្នុង និងអង្គហេតុដែលមានក្នុងកំណត់ត្រា ចៅក្រមអន្តរជាតិយល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឆ្គងដែលមិនបានពិចារណាឱ្យបានត្រឹមត្រូវទៅលើការចេញដីកាបង្គាប់ឱ្យចាប់ខ្លួន។

## ផ្នែកសម្រេចសេចក្តី

៦៩៤. ដោយសារតែមិនមានសម្លេងភាគច្រើនលើសលប់របស់អង្គជំនុំជម្រះ និងដោយសារតែស្ថានភាពពិសេសនៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយដែលផ្ទុយគ្នា ចៅក្រមអន្តរជាតិយល់ថា ជាការចាំបាច់ដែលត្រូវបញ្ជាក់ពីនីតិវិធីជាបន្ទាប់ ក្រោយសេចក្តីពិចារណាទាំងនេះ ដើម្បីធានានូវសច្ចភាពគតិយុត្តិ តម្លាភាពនីតិវិធី និងផលប្រយោជន៍នៃយុត្តិធម៌។

## ចៅក្រមអន្តរជាតិសម្រេចថាៈ

ដោយយល់ថា ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) មិនត្រូវបានច្រានចោល និងមានសុពលភាពនោះ។

- **យល់ព្រម** បញ្ជូន អោ អាន ទៅជំនុំជម្រះ ដូចមានកំណត់ក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) តាមការកែសម្រួលនៅទីនេះ។
- **យល់ថា** អង្គជំនុំជម្រះសាលាដំបូងត្រូវទទួលវិនិច្ឆ័យ ផ្អែកលើដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) តាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង។

**រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ ធ្នូ ឆ្នាំ ២០១៩**

ចៅក្រម Olivier BEAUVALLET

ចៅក្រម Kang Jin BAIK